# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៦២

បាលីប្រែ ៧៧

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# មធុរត្ថវិលាសិនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ ពុទ្ធវង្ស

# ចរិយាបិដក

# ៦២

## បាលីប្រែ ៧៧

បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣

# ក្បាលទី ៦២

# ខុទ្ទកនិកាយ

# ពុទ្ធវង្ស ចរិយាបិដក

*សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## រតនចង្កមនកណ្ឌ

[ ១ ] *គ្រានោះ សហម្បតីព្រហ្ម ជាអធិបតីនៃលោក ធ្វើអញ្ជលី អារាធនាព្រះសម្ពុទ្ធថា ពួកសត្វក្នុងលោកនេះ មានធូលីគឺរាគាទិក្កិលេសក្នុងភ្នែកស្រាលស្តើងហើយ សូមព្រះអង្គសម្តែងធម៌ សូមព្រះអង្គអនុគ្រោះ ពួកសត្វនេះ ។ ពួកព្រហ្មធ្វើអញ្ជលីអារាធនាព្រះមានព្រះភាគ ជាអធិបតីនៃលោក ខ្ពង់ខ្ពស់ជាងនរជនថា ពួកសត្វក្នុងលោកនេះ មានប្រាជ្ញា មានធូលី គឺរាគាទិក្កិលេសក្នុងភ្នែក ស្រាលស្តើងហើយ សូមព្រះអង្គសម្តែងធម៌ សូមព្រះអង្គអនុគ្រោះពួកសត្វនេះ ។ សូមព្រះសុគតសម្តែងធម៌ សូមសម្តែងព្រះនិព្វានឈ្មោះអមតៈ បពិត្រព្រះនាយក សូមព្រះមានព្រះភាគសម្តែងធម៌ ដើម្បីអនុគ្រោះដល់សត្វលោកទាំងឡាយ ។*

*ព្រះតថាគតទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាតាទិបុគ្គល*
*ទ្រទ្រង់នូវពន្លឺ ទ្រទ្រង់នូវរាងកាយជាទីបំផុត ព្រះអង្គឥតមាន*
*បុគ្គលផ្ទឹមបាន ទ្រង់មានសេចក្តីករុណា កើតឡើងក្នុងសត្វ*

ទាំងពួង ។

ព្រះមានព្រះភាគ ជាសាស្ដា ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ក៏ទ្រង់ពោលនូវពាក្យនេះថា

ទ្វារនៃព្រះនិព្វាននោះ របើកហើយ សត្វទាំងឡាយណា មានសោតប្បសាទ សត្វទាំងនោះ ចូរបញ្ចេញនូវសទ្ធាចុះ ម្នាលព្រហ្ម តថាគតសម្គាល់នូវសេចក្ដីនឿយលំបាក បានជាមិនសម្ដែងធម៌ដ៏ឧត្ដម ដែលតថាគតស្ទាត់ហើយ ចំពោះមនុស្សទាំងឡាយ ។

សម័យនោះ ព្រះមានព្រះភាគ ទ្រង់អនុគ្រោះដល់ពួកវេនេយ្យសត្វ ព្រះអង្គទ្រង់ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់ពុទ្ធដំណើរទៅអំពីដើមអជបាលនិគ្រោធ ។ ព្រះអង្គស្ដេចចូលទៅកាន់ក្រុងពារាណសី ដោយព្រះពុទ្ធដំណើរតាមលំដាប់ គ្រានោះ ព្រះមានព្រះភាគទ្រង់ គង់លើបល្ល័ង្កដ៏ប្រសើរនោះឯង ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងធម្មចក្ក គឺទុក្ខសច្ច ១ ទុក្ខសមុប្បាទសច្ច ១ និរោធសច្ច ១ មគ្គសច្ចដ៏ឧត្ដម ១ ឲ្យប្រព្រឹត្តទៅដល់ពួកបញ្ចវគ្គិយភិក្ខុ ។ លុះព្រះមានព្រះភាគ ទ្រង់ញ៉ាំងធម្មចក្កនោះ ឲ្យប្រព្រឹត្តទៅហើយ គ្រានោះ ពួកឥសី គឺបញ្ចវគ្គិយភិក្ខុទាំងនោះ គឺកោណ្ឌញ្ញៈ ភទ្ទិយៈ វប្បៈ មហានាម អស្សជិ ព្រមទាំងពួកព្រហ្ម និងទេវតា ១៨ កោដិក៏បានត្រាស់ដឹងនូវធម៌ ក្នុងបឋមសន្និបាត ។ គ្រានោះឯង ពួក

បញ្ចវគ្គិយភិក្ខុទាំងអស់ ព្រមទាំងពួកព្រហ្ម និងទេវតា ១៨ កោដិ ដែលព្រះមានព្រះភាគ ទ្រង់ណែនាំពន្យល់ដោយធម្មចក្កនោះ និងដោយធម៌ដទៃទៀត ក៏បានលុះសោតាបត្តិផល ក្នុងបឋមសន្និបាតនោះ តាមលំដាប់ ។ ព្រះសាស្តាស្តេចទៅកាន់ក្រុងរាជគ្រឹះដោយពុទ្ធដំណើរតាមលំដាប់ ។ ព្រះពុទ្ធជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់គង់នៅក្នុងវេឡុវនមហាវិហារ ព្រះបាទពិម្ពិសារ ទ្រង់ឮដំណឹងនោះហើយ ក៏ស្តេចចូលទៅគាល់ព្រះមានព្រះភាគ ។ ព្រះរាជាមានពួកបរិវារច្រើន ចំនួន ១១ ម៉ឺនរូប កាន់ប្រទីប គ្រឿងក្រអូប ធូប និងផ្កាកម្រងជាដើម បូជាព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់សម្តែងទោសនៃកាមក្នុងទីប្រជុំនោះឯង លុះចប់ទេសនា ព្រះរាជាកើតសេចក្តីរីករាយ ក្នុងកាលនោះ ។ ពួកសត្វ ៨ ម៉ឺន ៤ ពាន់រូប បានត្រាស់ដឹងធម៌ ព្រះរាជាជាពុទ្ធបិតា លុះឮដំណឹងនោះហើយ ទើបបញ្ជូនទូត ៩ រូបទៅ ។ ទូតទាំងឡាយព្រមទាំងបរិវារ ៩ ពាន់ ក៏សូមផ្នួសនឹងព្រះមុនី ពួកទូតទាំងនោះមានបរិវារ ៩ ពាន់ ក៏បានលុះព្រះអរហត្ត ។ ក្នុងកាលជាខាងក្រោយបំផុត កាឡុទាយិមានបរិវារមួយពាន់ កាន់យកភេទជាភិក្ខុហើយ លោកក៏និមន្តព្រះមានព្រះភាគមក ។ ព្រះពុទ្ធជាសក្យៈដ៏ប្រសើរ ទ្រង់ទទួលនិមន្តហើយ ក៏ស្តេចទៅកាន់ផ្លូវធំ ស្តេចទៅជាមួយនឹងភិក្ខុពីរម៉ឺនរូប ។ ព្រះអង្គស្តេចទៅកាន់ក្រុងកបិលវត្ថុ ដោយព្រះដំណើរតាមលំដាប់

ទ្រង់ធ្វើបាដិហារ្យ ត្រង់ធ្នេរស្ទឹងរោហិណី ។ ព្រះមានព្រះភាគ ជាសក្យៈដ៏ប្រសើរ ទ្រង់គង់ត្រង់កណ្តាលនៃបល្ល័ង្កនោះ សម្តែងមហាវេស្សន្តរជាតក ថ្វាយព្រះវរបិតា ពួកសត្វ ៨ ម៉ឺន ៤ ពាន់រូប ក៏បានត្រាស់ដឹងនូវធម៌ ។

ពួកមនុស្ស ព្រមទាំងទេវតាទ៉ុះ មិនបានដឹងដូច្នេះថា ព្រះពុទ្ធអង្គនេះ ទ្រង់ឧត្តមជាងនរជនដូចម្តេច ឥទ្ធិពល និងបញ្ញាពល តើដូចម្តេច ពុទ្ធពលរបស់ព្រះសាស្តា ជាប្រយោជន៍ដល់សត្វលោក ដូចម្តេច ។ ពួកមនុស្ស ព្រមទាំងទេវតាទ៉ុះ មិនបានដឹងដូច្នេះថា ព្រះពុទ្ធអង្គនេះ ទ្រង់ឧត្តមជាងនរជនបែបនេះ ឥទ្ធិពល និងបញ្ញាពលបែបនេះ ពុទ្ធពលរបស់ព្រះសាស្តា ជាប្រយោជន៍សត្វលោក បែបនេះ ។

( ព្រះសាស្តា ទ្រង់ជ្រាបអធ្យាស្រ័យនៃមនុស្ស និងទេវតាទាំងនោះ ដូច្នោះហើយ ) ទើបទ្រង់ព្រះចិន្តាថា បើដូច្នោះ តថាគតនឹងសម្តែងនូវពុទ្ធពលដ៏ប្រសើរ និម្មិតទីចង្ក្រម ប្រដាប់ដោយកែវឰដ៏អាកាស ។

ទេវតាទាំងឡាយណា គឺភុម្មទេវតាក្តី មហារាជិកទេវតាក្តី តាវត្តឹសទេវតាក្តី យាមទេវតាក្តី តុសិតទេវតាក្តី និម្មានរតីទេវតាក្តី បរនិម្មិតវសវត្តីទេវតាក្តី ព្រហ្មទាំងឡាយណាក្តី ពួកទេវតា និងព្រហ្មទាំងនោះ រីករាយហើយ បាន

ធ្វើនូវសំឡេង ឲ្យឮកងរំពង ខួរខ្វារ ។ ផែនដី ព្រមទាំងទេវលោក ក៏ភ្ញឹព្រោងព្រាត ទាំងពួកសត្វនរក នៅក្នុងលោកន្តរដ៏ច្រើន ក៏ឥតមានអ្វីបិទបាំង ទាំងងងឹតដ៏ខ្លាំងក្លាទៀតសោត ក៏ខ្ចាត់ខ្ចាយចេញ ក្នុងកាលនោះ គេអាចមើលឃើញនូវបាដិហារ្យ ជាអស្ចារ្យបាន ។ ពន្លឺដ៏ធំទូលាយលើសលុប កើតឡើង ដល់ពួកទេវតា គន្ធព្វ មនុស្ស និងអារក្ស ។ ព្រះសាស្តា ព្រះអង្គឧត្តមជាងសត្វ មិនមានអ្នកណាមួយប្រសើរលើស តែងដឹកនាំសត្វ ដែលទេវតា និងមនុស្សតែងបូជា មានអានុភាពច្រើន មានបុញ្ញលក្ខណៈច្រើន ទ្រង់សម្តែងបាដិហារ្យជាអស្ចារ្យ ផ្សាយទៅក្នុងលោកទាំងពីរ គឺលោកនេះ និងលោកដទៃផង ក្នុងទិសខាងក្រោម ទិសខាងលើ និងទិសទទឹងផង ។

ព្រះជិនស្រីជាសាស្តាចារ្យ ទ្រង់ហោះទៅឰដ៏ផ្ទៃអាកាស ទ្រង់និម្មិតភ្នំសិនេរុជាទីរីករាយ ឲ្យជាទីចង្ក្រមក្នុងទីប្រជុំនោះ ។ ទេវតាទាំងមួយម៉ឺនលោកធាតុនោះ ក៏បានក្រាបថ្វាយបង្គំព្រះតថាគតក្នុងសម្នាក់នៃព្រះជិនស្រី ហើយធ្វើពុទ្ធបូជា ។

គ្រានោះ ព្រះពុទ្ធមានចក្ខុអង្គនោះ ទ្រង់ឧត្តមជាងនរៈ ដែលទេវតាដ៏ប្រសើរអារាធនាហើយ ក៏ទ្រង់ពិចារណានូវអត្ថ ព្រះលោកនាយក ទ្រង់និម្មិតទីចង្ក្រម តាក់តែង

ដោយរតនៈទាំងអស់ សម្រេចដោយល្អហើយ ។ ព្រះ
មានព្រះភាគ ទ្រង់ស្អាតក្នុងបាដិហារ្យ ៣ យ៉ាង គឺឥទ្ធិ-
បាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនី-
បាដិហារ្យ ១ ព្រះលោកនាយក ទ្រង់និម្មិតទីចង្ក្រម
តាក់តែងដោយរតនៈទាំងអស់ សម្រេចល្អហើយ ។

ព្រះអង្គទ្រង់សម្តែង ( នូវបាដិហារ្យ ) លើទីចង្ក្រមសម្រេចដោយកែវ លើភ្នំសិនេរុដ៏ឧត្តមដោយលំដាប់ ដូចជាសសរនៃលោកធាតុទាំងមួយម៉ឺន ។ ព្រះជិនស្រី ទ្រង់និម្មិតទីចង្ក្រម ជាវិការនៃមាសសុទ្ធ ត្រង់ខាងនៃទីចង្ក្រមដ៏សម្រេចដោយកែវ កន្ទងលោកធាតុមួយម៉ឺន ។ ទ្រង់និម្មិតនូវថែវទាំងឡាយ ជាវិការនៃមាសសុទ្ធ មានមេដំបូល និងផ្ទោងប្រព្រឹត្តទៅ ក្រាលដោយក្តារមាស ត្រង់ចំហៀងទាំងសងខាង ( នៃរតនចង្ក្រម និងសុវណ្ណចង្ក្រមនោះ ) ។ ព្រះសម្ពុទ្ធទ្រង់និម្មិតរតនចង្ក្រម ដ៏ពោរពាសដោយខ្សាច់ ជាវិការនៃកែវមណី និងកែវមុក្តា ញុំាងទិសទាំងពួង ឲ្យភ្លឺព្រោងព្រាយ ហាក់ដូចជាព្រះអាទិត្យរះឡើង ។ ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ទ្រង់មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ទ្រង់រុងរឿងក្នុងទីចង្ក្រមនោះ ព្រះជិនស្រីទ្រង់ចង្ក្រមលើទីចង្ក្រម ។ ទេវតាទាំងអស់ មកប្រជុំគ្នាហើយ រោយរាយនូវផ្កាមន្ទារវៈ ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វក្នុងទីចង្ក្រម ។ ពួកទេវតាមួយម៉ឺនលោកធាតុ ដែល

មកប្រជុំគ្នា បានឃើញព្រះមានព្រះភាគអង្គនោះ ក៏មានចិត្តត្រេកអររីករាយ ហើយក្រាបថ្វាយបង្គំ ។ ទេវតាទាំងឡាយណា ជាន់តាវត្តិង្សផង ជាន់យាមៈផង ជាន់តុសិតផង ទេវតាជាន់និម្មានរតីផង ទេវតាជាន់វសវត្តីផង ទេវតាទាំងនោះ មានចិត្តអណ្តែតខ្ពស់ឡើង មានចិត្តរីករាយរមិលមើលព្រះលោកនាយក ។

ពួកទេវតា ពួកគន្ធព្វ ពួកមនុស្ស និងពួកអារក្ស ពួកនាគ ពួកគ្រុឌ ទាំងពួកកិន្នរ ក៏ឃើញព្រះសម្ពុទ្ធម្ចាស់ ទ្រង់មានព្រះហឫទ័យអនុគ្រោះ ដោយប្រយោជន៍ ដល់សត្វលោកនោះ ហាក់ដូចជាមណ្ឌលព្រះចន្ទខ្ពស់ត្រដែតលើអាកាស ។

ពួកព្រហ្មជាន់អាភស្សរៈផង ជាន់សុភកិណ្ហៈផង ជាន់វេហប្ផលៈផង ជាន់អកនិដ្ឋៈផង ស្លៀកសំពត់សសុទ្ធ ឈរផ្គងអញ្ជលី ។

( ពួកព្រហ្មទាំងនោះ ) បញ្ចេញនូវផ្កាមន្ទារវៈ មានពណ៌ ៥ ដ៏លាយដោយលម្អិតខ្លឹមចន្ទន៍ផង បង្វិលគ្រវីសំពត់ទាំងឡាយផង លើអាកាស ក្នុងកាលនោះ ( ហើយពោលថា ) អើហ្ន៎ ព្រះជិនស្រី ទ្រង់អនុគ្រោះដោយប្រយោជន៍ ដល់សត្វលោក ។

ព្រះអង្គជាសាស្តាចារ្យផង ជាទង់ផង ជាទង់ជ័យផង ជាប្រាសាទផង ជាទីពឹងប្រព្រឹត្តទៅខាងមុខផង ជាប្រទីបរបស់ពួកសត្វផង

ទ្រង់ឧត្តមជាងសត្វជើង ២ ផង ។ ពួកទេវតាក្នុងមួយម៉ឺនលោក-ជាតុដែលមានឫទ្ធិច្រើន មានចិត្តត្រេកអរស្រស់ស្រាយរីករាយមកចោមរោម ហើយថ្វាយបង្គំ ។ ពួកទេវតា និងពួកទេពកញ្ញាមានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បូជាព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងនរៈ ដោយផ្កាមានពណ៌ ៥ ។ ពួកទេវតាទាំងឡាយ មានចិត្តជ្រះថ្លា មានចិត្តត្រេកអរ ឃើញព្រះអង្គក៏នាំគ្នាបូជាព្រះសម្ពុទ្ធទ្រង់ប្រសើរជាងនរៈ ដោយផ្កាមានពណ៌ ៥ ( ហើយពោលថា ) ឱហ្ន៎ អស្ចារ្យចម្លែកណាស់ គួរឲ្យព្រឺរោមក្នុងលោក ឯសេចក្តីអស្ចារ្យ គួរឲ្យព្រឺរោមបែបនេះ មិនដែលកើតឡើងសោះឡើយ ។ ពួកទេវតាទាំងនោះ អង្គុយក្នុងភពរបស់ខ្លួនៗ រីករាយខ្លាំង ព្រោះឃើញនូវសេចក្តីអស្ចារ្យ ឰដ៏អាកាស ។ ពួកអាកាសដ្ឋកទេវតា ពួកភុម្មដ្ឋកទេវតា និងពួកទេវតាដែលនៅអាស្រ័យឰដ៏ស្មៅ និងឈើជាថ្នាំ ត្រេកអរស្រស់ស្រាយ រីករាយខ្លាំង នាំគ្នាផ្គងអញ្ជលីនមស្ការ ។ ទាំងពួកនាគដែលមានអាយុវែង មានបុណ្យច្រើន មានឫទ្ធិច្រើន ក៏រីករាយថ្វាយបង្គំ បូជាព្រះពុទ្ធដ៏ខ្ពង់ខ្ពស់ជាងនរៈដែរ ។ ចម្រៀងទាំងឡាយ ប្រព្រឹត្តទៅឰដ៏អាកាស ជាផ្លូវនៃខ្យល់ ពួកទេវតាក៏វាយស្គរ ព្រោះឃើញនូវសេចក្តីអស្ចារ្យឰដ៏អាកាស ស័ង្ខ ស្រឡៃ សម្ភោរដ៏ច្រើន ក៏ប្រគំលាន់ឮឡើងក្នុងកណ្តាលអាកាស ព្រោះឃើញនូវសេចក្តីអស្ចារ្យឰដ៏អាកាស ។

ការព្រឺរោមកើតឡើងដល់ពួកយើងក្នុងថ្ងៃនេះ ចម្លែកពេកណាស់ហ្ន៎ ពួកយើង បាននូវការសម្រេចប្រយោជន៍ដ៏ទៀតទាត់ ខណៈឈ្មោះថា ពួកយើងបានទាន់ហើយ ។ បីតិក៏កើតឡើងដល់ទេវតាទាំងនោះ ក្នុងខណៈនោះឯង ព្រោះឮពាក្យថា ព្រះពុទ្ធ ទេវតាទាំងនោះឈរផ្គងអញ្ជលី ពោលសរសើរថា ព្រះពុទ្ធៗ ។ ពួកសត្វផ្សេងៗ ផ្គងអញ្ជលី ញុំាងសំឡេងទ្រហឹងអឺងកង សំឡេងសាធុការ សំឡេងហ៊ោឲ្យប្រព្រឹត្តទៅ ក្នុងកណ្តាលអាកាស ។

ទេវតាទាំងឡាយច្រៀង ហួច ប្រគំ ទះដៃ រាំ ជម្រុះនូវ
ផ្កាមន្ទារវៈមានពណ៌ ៥ ដែលលាយច្រឡំដោយលម្អិត
នៃខ្លឹមចន្ទន៍ ។

( ហើយពោលថា ) បពិត្រព្រះអង្គមានព្យាយាមធំ លក្ខណៈនៃចក្រ ទង់ជ័យ កែវវជីរ ទង់ជ្រុង គាក់តែងដោយកង្វេរ កំពុងចម្រើន ត្រង់ព្រះបាទាទាំងគូរបស់ព្រះអង្គ ។ ព្រះមានព្រះភាគឥតមានបុគ្គលស្មើ ចំពោះព្រះរូបផង សីលផង សមាធិផង ប្រាជ្ញាផង ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ចំពោះវិមុត្តិ និងការញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ។ កម្លាំងក្នុងព្រះកាយនៃព្រះអង្គ ជាកម្លាំងប្រក្រតី ស្មើនឹងកម្លាំងដំរី ១០ ព្រះអង្គឥតមានបុគ្គលប្រៀបផ្ទឹមស្មើដោយកម្លាំងនៃឫទ្ធិ ក្នុងការញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ។ អ្នកទាំងឡាយ ចូរនាំគ្នាក្រាបថ្វាយបង្គំនូវ

ព្រះមហាមុនី ព្រះអង្គបរិបូណ៌ដោយគុណទាំងពួង ប្រកបដោយអវយវៈទាំងពួង ទ្រង់មានករុណាជាទីពឹងនៃលោក ។ ព្រះអង្គជាបុគ្គលគួរទទួលនូវកិច្ចទាំងពួង របស់ពួកជន គឺការក្រាបសំពះ ការស្ញើច ការថ្វាយបង្គំ ការសរសើរ ការនមស្ការ និងការបូជា ។ ជនទាំងឡាយណាមួយ ក្នុងលោក ដែលគួរគេថ្វាយបង្គំ ឬជនទាំងឡាយណា គួរដល់ការថ្វាយបង្គំ បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គជាបុគ្គលប្រសើរបំផុត ជាងជនទាំងអស់នោះ បុគ្គលស្មើនឹងព្រះអង្គ មិនមានឡើយ ។ ព្រះសារីបុត្តមានប្រាជ្ញាច្រើន ជាអ្នកឈ្លាសក្នុងសមាធិ និងឈាន ស្ថិតនៅលើភ្នំគិជ្ឈកូដ ឃើញព្រះលោកនាយក ។ សម្លឹងមើលព្រះសម្ពុទ្ធទ្រង់ប្រសើរជាងនរៈ ហាក់ដូចជាដើមរាំងភ្នំ ដែលមានផ្ការីកស្គុះស្គាយ ដូចព្រះចន្ទកណ្ដាលអាកាស ឬដូចជាព្រះអាទិត្យត្រង់ជាក់ ។ ឃើញព្រះលោកនាយក មានរស្មីផ្សាយចេញមួយព្យាម រុងរឿងដូចឈើប្រចាំទ្វីប ឬដូចព្រះអាទិត្យស្រទន់ ដែលទើបនឹងរះឡើង ។ ខណៈនោះ ព្រះសារីបុត្តបានប្រជុំពួកភិក្ខុចំនួន ៥០០ រូប ជាអ្នកមានសោឡសកិច្ចធ្វើហើយ ជាតាទិបុគ្គល ជាព្រះខីណាស្រព ប្រាសចាកមន្ទិលហើយ សម្ដែងនូវបាដិហារិយ៍ ឈ្មោះលោកប្បសាទនៈ ថា ពួកយើងនឹងទៅក្នុងទីនោះ ហើយថ្វាយបង្គំព្រះជិនស្រី ។ លោកទាំងឡាយ ចូរមក យើងទាំងអស់គ្នានឹងទៅសាកសួរព្រះ

ជិនស្រី បានជួបព្រះលោកនាយកហើយ នឹងបន្ទោបង់នូវសេចក្តីសង្ស័យ ។ ឯពួកភិក្ខុទាំងនោះ ជាអ្នកមានប្រាជ្ញាចាស់ក្លា សង្រួមឥន្ទ្រិយ ក៏ទទួលព្រមថា សាធុ ហើយប្រដាប់បាត្រ និងចីវរ ដើរទៅជាប្រញាប់ ។ ព្រះសារីបុត្តមានប្រាជ្ញាច្រើន ( ឋិតនៅ ) ក្នុងការទូន្មានដ៏ឧត្តម ក៏ចូលទៅរក ( ព្រះមានព្រះភាគ ) ដោយឫទ្ធិជាមួយនឹងព្រះខីណាស្រពទាំងឡាយ ដែលជាអ្នកប្រាសចាកមន្ទិល មានឥន្ទ្រិយទូន្មាន ។ ព្រះសារីបុត្ត ដែលមានពួកភិក្ខុទាំងនោះហែហម ជាអ្នកមានពួកដ៏ធំ ចូលទៅដោយឫទ្ធិដូចទេវតាកាលលេងសប្បាយពួដ៏អាកាស ។ ពួកភិក្ខុទាំងនោះ ជាអ្នកមានវត្តល្អ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង អត់ទ្រាំនូវការក្អក និងកណ្តាស់ ចូលគាល់ព្រះសម្ពុទ្ធ ។ លុះចូលទៅគាល់ហើយ ក៏បានឃើញព្រះសយម្ភូ ជាលោកនាយក មានព្យាយាម ទ្រង់ហោះទៅពួដ៏អាកាស ហាក់ដូចជាព្រះចន្ទ នាកណ្តាលអាកាស ។ ឃើញព្រះលោកនាយក រុងរឿងដូចឈើប្រចាំទ្វីប ដូចផ្លេកបន្ទោរពួដ៏អាកាស ឬដូចព្រះអាទិត្យត្រង់ជាក់ ។ ភិក្ខុទាំង ៥០០ រូប ឃើញព្រះលោកនាយក ទ្រង់ថ្លាស្អាត ដូចអន្លង់ទឹក ឬដូចផ្កាឈូកដែលរីកស្គុះស្គាយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ ហើយផ្គងអញ្ជលី ក្រាបថ្វាយបង្គំព្រះបាទាដ៏ប្រដាប់ដោយលក្ខណៈ នៃចក្ករបស់ព្រះសាស្តា ។ ព្រះសារីបុត្ត

មានប្រាជ្ញាច្រើន ប្រាកដស្មើដោយផ្កាស្មៅកន្ទុយជីរ ជាអ្នកឈ្លាស ក្នុងសមាធិ និងឈាន ក្រាបថ្វាយបង្គំនូវព្រះលោកនាយក ។ ព្រះមោគ្គល្លានមានឫទ្ធិច្រើន ឥតមានបុគ្គលស្មើដោយកម្លាំងនៃឫទ្ធិ ប្រាកដស្មើដោយផ្កាឧប្បលខៀវ ប្រៀបដូចកាលមេឃកម្ទរ ។ ព្រះមហាកស្សបត្ថេររុងរឿង ដូចជាមាសដែលព្រះសាស្តាសរសើរ លើកតម្កើងតម្កល់ ក្នុងឋានៈដ៏ប្រសើរ ខាងធុតង្គគុណ ។ ឯព្រះអនុរុទ្ធ ជាអ្នកប្រសើរជាងពួកបុគ្គលមានចក្ខុទិព្វ មានពួកច្រើន ជាអ្នកប្រសើរក្នុងញាតិ ស្ថិតនៅក្នុងទីជិតព្រះមានព្រះភាគ ។ ព្រះឧបាលិ អ្នកឈ្លាសក្នុងអាបត្តិ និងអនាបត្តិ ទាំងអាបត្តិនៅកែបាន ដែលព្រះសាស្តាសរសើរតាំងទុកថា ជាអ្នកប្រសើរខាងវិន័យ ។ ភិក្ខុជាកូននៃនាងមន្តានី ប្រាកដនាមថា បុណ្ណៈ អ្នកចាក់ធ្លុះនូវអត្ថដ៏ល្អិតល្អន់ ប្រសើរជាងពួកធម្មថិក ជាអ្នកមានពួក ។ ព្រះមុនីទ្រង់ឈ្លាសក្នុងពាក្យឧបមា ទ្រង់ជ្រាបនូវចិត្តនៃភិក្ខុទាំងឡាយនុ៎ះ ទ្រង់មានព្យាយាមធំ កាត់នូវសេចក្តីសង្ស័យ ទ្រង់សម្តែងនូវគុណរបស់ព្រះអង្គ ។ ទីបំផុតនៃអសង្ខេយ្យទាំងឡាយណា ដែលបុគ្គលដឹងមិនបាន អសង្ខេយ្យទាំងនោះមាន ៤ ប្រការ អសង្ខេយ្យទាំងនុ៎ះ គឺពួកសត្វ ១ អាកាស ១ ចក្កវាឡ មិនមានទីបំផុត ១ ពុទ្ធញាណដែលប្រមាណមិនបាន ១ បុគ្គលមិនអាចដឹងបានឡើយ ។ ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ការដែលតថាគតធ្វើឫទ្ធិ

ប្លែកៗ ណា ការធ្វើឫទ្ធិប្លែកៗ នុ៎ះ នឹងទុកជាហេតុអស្ចារ្យក្នុងលោកដូចម្តេចបាន ព្រោះហេតុជាអស្ចារ្យ ចម្លែក គួរព្រឺរោមដទៃទៀតនៅមានច្រើន ។ កាលដែលតថាគតនៅជាទេវបុត្ត ឈ្មោះសន្តុសិតៈ ក្នុងពួកទេវបុត្តជាន់តុសិត កាលនោះ ទេវតាមួយម៉ឺនលោកធាតុ មកប្រជុំគ្នាធ្វើអញ្ជលីអារាធនាតថាគតថា បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះគួរដល់ព្រះអង្គហើយ សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្សលោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះអមតៈ ។ កាលណាតថាគតច្យុតចាកពួកទេវតាជាន់តុសិត មកចាប់បដិសន្ធិក្នុងផ្ទៃ ( នៃមាតា ) កាលនោះ លោកធាតុមួយម៉ឺន និងព្រះធរណីញាប់ញ័រ ។ កាលដែលតថាគតប្រសូតចាកផ្ទៃមាតា ក៏ដឹងខ្លួនច្បាស់លាស់ ពួកទេវតាញុំាងសាធុការឲ្យប្រព្រឹត្តទៅ លោកធាតុមួយម៉ឺនញាប់ញ័រ ។ តថាគតមិនមានបុគ្គលស្មើ ក្នុងការចុះកាន់គភ៌ព្រះមាតានៃតថាគត ជាបុគ្គលប្រសើរបំផុតក្នុងការប្រសូតចាកផ្ទៃមាតា ក្នុងការត្រាស់ដឹង និងការញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ។ ឱ ! ព្រះពុទ្ធទាំងឡាយ មានគុណដ៏ធំ ជាអស្ចារ្យក្នុងលោកពេកណាស់ លោកធាតុមួយម៉ឺនញាប់ញ័រអស់វារៈ ៦ លើក ។ ពន្លឺដ៏ធំក៏កើតមាន ទាំងសេចក្តីអស្ចារ្យគួរព្រឺរោមក៏កើតឡើង ។ សម័យនោះ ព្រះជិនស្រីមានព្រះភាគ ជាចម្បងក្នុងលោក ប្រសើរជាង

នរៈ ទ្រង់ចង្ក្រម បង្ហាញឲ្យមនុស្សលោក ព្រមទាំងទេវលោក មើលឃើញដោយឫទ្ធិ ។ ព្រះលោកនាយក ចង្ក្រមក្នុងទីចង្ក្រម ទ្រង់មានព្រះបន្ទូល ទ្រង់មិនត្រឡប់វិញ ត្រង់ពាក់កណ្តាល ហាក់ដូចជាចង្ក្រមក្នុងទីចង្ក្រមប្រវែង ៤ ហត្ថ ។ ព្រះសារីបុត្ត មានប្រាជ្ញាច្រើន ឆ្លៀវឆ្លាសក្នុងសមាធិ និងឈាន ជាអ្នកដល់នូវបារមីនៃប្រាជ្ញា បានក្រាបបង្គំទូលសួរ ព្រះលោកនាយកដូច្នេះថា បពិត្រព្រះអង្គមានព្យាយាមធំ ទ្រង់ប្រសើរជាងនរៈ អភិនីហាររបស់ព្រះអង្គ តើដូចម្តេច បពិត្រព្រះអង្គមានព្យាយាម ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ ព្រះអង្គប្រាថ្នាតាំងពីក្នុងកាលណា ។ ទាន សីល នេក្ខម្មៈ បញ្ញា និងវីរិយៈ តើដូចម្តេច ខន្តិ សច្ចៈ និងអធិដ្ឋាន មេត្តា និងឧបេក្ខា តើដូចម្តេច ។ បពិត្រព្រះអង្គមានព្យាយាមធំជាលោកនាយក បារមី ១០ តើដូចម្តេច ឧបបារមី ១០ ដែលបរិបូណ៌ តើដូចម្តេច បរមត្ថបារមី ១០ ដែលបរិបូណ៌ តើដូចម្តេច ។ អធិបតីធម៌ទាំងឡាយ អធិដ្ឋាននូវកតិកម្មដូចម្តេច បារមីទាំងឡាយដូចម្តេច អ្នកប្រាជ្ញទាំងឡាយក្នុងលោក តើដូចម្តេច ។ មេត្តា ករុណា មុទិតា និងឧបេក្ខា តើដូចម្តេច ព្រះពុទ្ធទ្រង់បំពេញពុទ្ធធម៌ ដ៏ពេញលេញដូចម្តេច ។ ព្រះពុទ្ធ ទ្រង់មានព្រះសូរសៀងពីរោះ ដូចជាសត្វករវិក ទ្រង់ញុំាងហឫទ័យ ( នៃពួកសត្វ ) ឲ្យរលត់ ញុំាងមនុស្សលោក ព្រមទាំងទេវលោក

ឲ្យស្រស់ស្រាយ ដែលព្រះសារីបុត្ត សាកសួរហើយ ទ្រង់ដោះស្រាយដល់ព្រះសារីបុត្តនោះវិញ ។

ព្រះសម្ពុទ្ធ ទ្រង់ប្រកាសនូវរឿងដែលព្រះជិនស្រី ជា
អតីតពុទ្ធទាំងឡាយ ទ្រង់សម្តែងចងទុកហើយ ដែល
ជាប់តមក តាំងពីព្រះពុទ្ធទីបង្ករ ជាប្រយោជន៍ក្នុង
លោក ព្រមទាំងទេវលោក ដោយប្រាជ្ញាដែលប្រព្រឹត្ត
ទៅ តាមបុព្វេនិវាស ។

អ្នកទាំងឡាយ ចូរតាំងចិត្តប្រុងស្តាប់ ( នូវពុទ្ធវង្សទេសនា ) របស់តថាគត ជាគ្រឿងញ៉ាំងបីតិ និងបាមោជ្ជឲ្យកើត បន្ទោបង់នូវសរ គឺសេចក្តីសោកបាន ជាហេតុបាននូវសម្បត្តិទាំងពួង ។ អ្នកទាំងឡាយ ចូរប្រតិបត្តិនូវមគ្គ ជាគ្រឿងញ៉ាំញីនូវសេចក្តីស្រវឹង បន្ទោបង់នូវសេចក្តីសោក អាចដោះខ្លួនឲ្យរួចចាកសង្សារ ជាគ្រឿងអស់ទៅនៃទុក្ខទាំងពួងបាន ដោយគោរពចុះ ។

**រតនចង្កមនកណ្ឌ ចប់**

# អដ្ឋកថា
# មធុរត្ថវិលាសិនី
# ខុទ្ទកនិកាយ ពុទ្ធវង្ស

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## គន្ថារម្ភកថា

ខ្ញុំព្រះករុណាសូមនមស្ការចំពោះព្រះពុទ្ធ ទ្រង់មានញាណមិនមាននូវទីបំផុត មានព្រះករុណាជាទីអាស្រ័យ ទ្រង់ទម្លាយមន្ទិល មានព្រះហឫទ័យមាំទាំ ទ្រង់អនុគ្រោះនូវប្រយោជន៍ ។

សូមនមស្ការនូវព្រះធម៌ដ៏ប្រសើរ ជាគ្រឿងរាំងនូវភព ។

សូមនមស្ការព្រះសង្ឃ លោកប្រាសចាកមន្ទិល និងជាប្រភពកើតនៃគុណ ។

ព្រះសារីបុត្ត ជាធម្មសេនាបតី ជាបុគ្គលប្រសើរជាងពួកពុទ្ធសាវកខាងបញ្ញា បានទូលសួរព្រះសាស្តា ជាធម្មរាជា ទ្រង់ជាអ្នកដល់នូវត្រើយ មិនមានព្រំដែន ប្រាសចាកមន្ទិល ដល់ពុទ្ធវង្សណា ក្នុងកណ្តាលពួកព្រះញាតិ ពុទ្ធវង្សណា ដែលព្រះតថាគត ជាវង្សអ្នកត្រាស់ដឹងដោយល្អ ជាវិសុទ្ធិវង្ស ជាអ្នកកម្ចាត់ឱកាសនៃកិលេសហើយ ជានាយកដ៏វិសេស ជាអ្នកមានសមាធិជាគ្រឿងនៅប្រកាសហើយ ក្នុង

កណ្តាលពួកព្រះញាតិនេះ ។

ពួកឱរសព្រះសុគត មិនធ្វើលំដាប់បាលី និងអត្ថនៃបាលីឲ្យសាបសូន្យ នាំគ្នារួបរួមតាមដែលសិក្សា ស្តាប់បន្តគ្នាមក ដរាបដល់បច្ចុប្បន្ននេះ ។

ព្រោះកិច្ចពណ៌នាពុទ្ធវង្សនោះឯង ដែលមិនដាច់ខ្សែនៃព្រះសម្ពុទ្ធដ៏បវរ ជារឿងដែលស្តាប់មិនធុញទ្រាន់នាំ ឲ្យកើតសេចក្តីជ្រះថ្លា និងបញ្ញាដល់ជនទាំងឡាយសព្វកាល ប្រព្រឹត្តទៅតាមលំដាប់ ដូច្នោះ ខ្ញុំដែលព្រះពុទ្ធសីហៈ ជាអ្នកត្រេកអរក្នុងព្រះសទ្ធម្មដោយគោរព ជាអ្នកមាំទាំក្នុងគុណ មានសីលជាដើម អារាធនាហើយ ទើបផ្តើមពណ៌នាពុទ្ធវង្សនោះ ដើម្បីកម្ចាត់ទោសរបស់ជនទាំងឡាយ សព្វកាល ដើម្បីការតាំងមាំនៃព្រះពុទ្ធសាសនា ដើម្បីការកើត និងចម្រើននៃបុណ្យរបស់ខ្ញុំឯង និងដើម្បីញ៉ាំងនូវមហាជនឲ្យជ្រះថ្លា ។

កិច្ចពណ៌នាពុទ្ធវង្សដោយសង្ខេបនេះ អាស្រ័យផ្លូវបាលីដែលមកអំពីសម្នាក់មហាវិហារ ដែលកម្ចាត់នូវទោស គឺការលាយឡំគ្នាហើយ នឹងជាសារៈ តែព្រោះក្នុងទីនេះ មិនមានរឿងដែលគួរស្តាប់ ដែលជាគ្រឿងញ៉ាំងអ្នកត្រេកអរក្នុងពុទ្ធគុណឲ្យជ្រះថ្លា ជាគ្រឿងបន្សាត់បាប ដែលជាមហាមន្ទិលក្រៅអំពីរឿងពុទ្ធវង្ស ដូច្នោះឯង សូមអ្នកទាំងឡាយ ជាអ្នក

ប្រកបនៅក្នុងសមាធិដោយគោរព លះនូវការរាយមាយ មិន
មានចិត្តដទៃ ចូរតាំងសោតប្បសាទ ដូចកាជនមាសទទួល
ស្ដាប់នូវមធុរសរបស់ខ្ញុំ ដែលកំពុងពណ៌នា ។

ជនដែលនឹងត្រូវស្ដាប់ ក្នុងលោកនេះ គួរលះកិច្ចដទៃ
ទាំងអស់ ហើយប្រកបដោយបញ្ញា ដើម្បីការស្ដាប់ក្ដី ការ
ពោលក្ដី ដោយគោរពអស់កាលជានិច្ច ដ្បិតថា កថានេះ រក
បានដោយក្រ ។

ព្រោះក្នុងគាថាប្រារព្ធនោះ ខ្ញុំពោលថា កថាពណ៌នា
ពុទ្ធវង្សនឹងជាសារៈ ទើបគួរកំណត់ពុទ្ធវង្សមុន ។ ការកំណត់
ក្នុងពុទ្ធវង្សនោះ មានដូច្នេះ ការពោលប្រពៃណី យ៉ាងពិស្ដារ
ដោយបរិច្ឆេទ មានកប្បបរិច្ឆេទជាដើម ដែលកើតឡើងដល់
ព្រះពុទ្ធ ២៥ អង្គ ដែលទ្រង់កើតក្នុង ៤ អសង្ខេយ្យ និង ១
សែនកប្ប រាប់ថយក្រោយអំពីកប្បនេះទៅ គប្បីជ្រាបថា
ឈ្មោះថា ពុទ្ធវង្ស ។

ពុទ្ធវង្សនោះ លោកកំណត់ជាបរិច្ឆេទ ២២ បរិច្ឆេទ ដែលមកតាមបាលីទាំងនេះ គឺកប្បបរិច្ឆេទ គឺការពោលដោយកប្ប ១ នាមបរិច្ឆេទ គឺការពោលដោយឈ្មោះ ១ គោត្តបរិច្ឆេទ គឺការពោលដោយគោត្ត ១ ជាតិបរិច្ឆេទ គឺការពោលដោយជាតិ ១ នគរបរិច្ឆេទ គឺការពោលដោយនគរ ១ បិតុបរិច្ឆេទ គឺការពោលដោយបិតា ១ មាតុបរិច្ឆេទ គឺការពោលដោយ

មាតា ១ ពោធិរុក្ខបរិច្ឆេទ គឺការពោលដោយឈើត្រាស់ដឹង ១ ធម្មចក្កប្បវត្តនបរិច្ឆេទ គឺការពោលដោយការប្រកាសធម្មចក្ក ១ អភិសមយបរិច្ឆេទ គឺការពោលដោយការសម្រេចធម៌ ១ សាវកសន្និបាតបរិច្ឆេទ គឺការពោលដោយការប្រជុំសាវក ១ អគ្គសាវកបរិច្ឆេទ គឺការពោលដោយអគ្គសាវក ១ ឧបដ្ឋាកបរិច្ឆេទ គឺការពោលដោយពុទ្ធុបដ្ឋាក ១ អគ្គសាវិកាបរិច្ឆេទ គឺការពោលដោយពុទ្ធអគ្គសាវិកា ១ បរិវារភិក្ខុបរិច្ឆេទ គឺការពោលដោយភិក្ខុជាបរិវារ ១ រំសិបរិច្ឆេទ គឺការពោលដោយព្រះពុទ្ធរស្មី ១ សារីរបរិមាណបរិច្ឆេទ គឺការពោលដោយកម្ពស់ព្រះពុទ្ធសរីរៈ ១ ពោធិសត្តាធិការបរិច្ឆេទ គឺការពោលដោយបារមីរបស់ព្រះពោធិសត្ត ១ ព្យាករបរិច្ឆេទ គឺការពោលដោយការព្យាករ ១ ពោធិសត្តបណិធានបរិច្ឆេទ គឺការពោលដោយការតាំងសេចក្តីប្រាថ្នារបស់ព្រះពោធិសត្ត ១ អាយុបរិច្ឆេទ គឺការពោលដោយព្រះជន្មាយុ ១ បរិនិព្វានបរិច្ឆេទ គឺការពោលដោយការបរិនិព្វាន ១ ។

បើពោលដោយវារៈច្រើនវារៈ ដែលលោកមិនបានលើកដោយបាលី ក៏គប្បីនាំមកក្នុងកថានេះផង ។ វារៈនោះ លោកកំណត់ជា ១០ បរិច្ឆេទ គឺ អគារវាសបរិច្ឆេទ គឺការពោលដោយការនៅគ្រប់គ្រងផ្ទះ ១ បាសាទត្តយបរិច្ឆេទ គឺការពោលដោយប្រាសាទបី ១ នាដកិត្ថីបរិច្ឆេទ គឺការពោលដោយស្រីអ្នករបាំ ១ អគ្គមហេសីបរិច្ឆេទ គឺការពោលដោយអគ្គមហេសី ១ បុត្តបរិច្ឆេទ គឺការពោលដោយព្រះរាជឱរស ១ យានបរិច្ឆេទ គឺការពោលដោយយាន ១ អភិនិក្ខមនបរិច្ឆេទ គឺការពោលដោយអភិនេស្រ្កមណ៍ ១

បធានបរិច្ឆេទ គឺការពោលដោយទ្រង់បំពេញព្យាយាម ១ ឧបដ្ឋាកបរិច្ឆេទ គឺការពោលដោយពុទ្ធុបដ្ឋាក ១ វិហារបរិច្ឆេទ គឺការពោលដោយពុទ្ធវិហារ ១ ។

កាលសម្ដែងវារៈច្រើនវារៈនោះតាមឋានៈហើយ ក៏នឹងពោលតែដោយសង្ខេបក្នុងទីនោះៗ ។ ពុទ្ធវង្សនោះ ខ្ញុំកំណត់ដូច្នេះថា

ពុទ្ធវង្សនេះ អ្នកណាសម្ដែង សម្ដែងទីណា សម្ដែងដើម្បី
ជាប្រយោជន៍ដល់អ្នកណា សម្ដែងដើម្បីអ្វី សម្ដែងកាលណា
ពាក្យរបស់អ្នកណា អ្នកណានាំបន្តមក កាលពោលវិធីទាំង
អស់នេះ ដោយសង្ខេបមុនហើយ ខាងក្រោយ ខ្ញុំនឹងធ្វើកិច្ច
ពណ៌នាអត្ថនៃពុទ្ធវង្ស ។

ក្នុងគាថានោះ ពាក្យសួរថា អ្នកណាសម្ដែង បានដល់ ពុទ្ធវង្សនេះ អ្នកណាសម្ដែង ឆ្លើយថា ព្រះតថាគត ដែលទ្រង់ប្រព្រឹត្តទៅដោយព្រះញាណមិនទើសទាក់ក្នុងធម៌ទាំងពួង ទ្រទ្រង់នូវកម្លាំង ១០ ទ្រង់ក្លៀវក្លាដោយវេសារជ្ជញ្ញាណ ៤ ទ្រង់ជាមេទ័ពធម៌ ជាម្ចាស់នៃធម៌ ជាសព្វញ្ញូ ជាព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងហើយ ។

សួរថា សម្ដែងទីណា ឆ្លើយថា ព្រះតថាគតកំពុងចង្ក្រម លើរតនចង្ក្រម ដែលល្អគួរទស្សនាក្រៃលែង ដែលជាទីប្រជុំនៃភ្នែករបស់ទេវតា និងមនុស្ស ទ្រង់សម្ដែងក្នុងនិគ្រោធារាមមហាវិហារ ជិតកបិលពស្តុមហានគរ ។

សួរថា សម្ដែងដើម្បីជាប្រយោជន៍ដល់អ្នកណា ឆ្លើយថា ទ្រង់សម្ដែង

ដើម្បីជាប្រយោជន៍ដល់ព្រះញាតិ ៨២០០០ និងដល់ទេវតា និងពួកមនុស្ស ច្រើនកោដិ ។

សួរថា សម្តែងដើម្បីអ្វី ឆ្លើយថា ទ្រង់សម្តែងដើម្បីជួយសត្វលោកឲ្យឆ្លងឱឃៈទាំង ៤ ។

សួរថា សម្តែងកាលណា ឆ្លើយថា សេចក្តីពិត ២០ ឆ្នាំ ក្នុងបឋមពោធិកាល ព្រះមានព្រះភាគគង់នៅមិនប្រចាំ ក្នុងទីណា ដែលជាទីផាសុក ក៏យាងទៅគង់ក្នុងទីនោះៗ ឯង សេចក្តីនេះដូចម្តេច គឺ

វស្សាទី ១ ទ្រង់ប្រកាសធម្មចក្កត្រង់ព្រៃឥសិបតនៈ ឲ្យពួកព្រហ្ម ១៨ កោដិ ផឹកនូវអមតៈ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ក្រុងពារាណសី ។

វស្សាទី ២ ទ្រង់គង់នៅក្នុងវត្តវេឡុវនមហាវិហារ ក្រុងរាជគ្រឹះ ។

វស្សាទី ៣-៤ ទ្រង់គង់នៅក្នុងវត្តវេឡុវនមហាវិហារនោះដូចគ្នា ។

វស្សាទី ៥ ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ក្រុងវេសាលី ។

វស្សាទី ៦ ទ្រង់គង់នៅក្នុងមកុឡបព៌ត ។

វស្សាទី ៧ ទ្រង់គង់នៅក្នុងស្ថានតាវត្តិង្ស ។

វស្សាទី ៨ ទ្រង់គង់នៅក្នុងភេសកឡាវ័ន សុង្សុមារគីរី ដែនភគ្គៈ ។

វស្សាទី ៩ ទ្រង់គង់នៅក្នុងក្រុងកោសម្ពី ។

វស្សាទី ១០ ទ្រង់គង់នៅក្នុងដងព្រៃបាលិលេយ្យកៈ ។

វស្សាទី ១១ ទ្រង់គង់នៅក្នុងស្រុកព្រាហ្មណ៍ ឈ្មោះនាឡា ។

វស្សាទី ១២ ទ្រង់គង់នៅក្នុងស្រុកវេរញ្ជា ។

វស្សាទី ១៣ ទ្រង់គង់នៅក្នុងចាលិយបព៌ត ។

វស្សាទី ១៤ ទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ។

វស្សាទី ១៥ ទ្រង់គង់នៅក្នុងកបិលពស្តុមហានគរ ។

វស្សាទី ១៦ ទ្រង់ទូន្មានអាឡវកយក្ខ ឲ្យសត្វ ៨៤០០០ ផឹកទូវអមតៈ ទ្រង់គង់នៅក្នុងក្រុងអាឡវី ។

វស្សាទី ១៧ ទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះ ។

វស្សាទី ១៨ ទ្រង់គង់នៅក្នុងចាលិយបព៌ត ។

វស្សាទី ១៩ ក៏ទ្រង់គង់នៅក្នុងចាលិយបព៌តដូចគ្នា ។

វស្សាទី ២០ ទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះនោះឯង ។

ដោយហេតុនោះ ទើបខ្ញុំពោលថា សេចក្តីពិត ២០ ឆ្នាំ ក្នុងបឋម-ពោធិកាល ព្រះមានព្រះភាគទ្រង់គង់នៅមិនប្រចាំ ទីណាដែលជាផាសុកក៏យាងទៅគង់ក្នុងទីនោះឯង ។

តាំងអំពីនោះទៅ ទ្រង់គង់នៅជាប្រចាំ ក្នុងវត្តជេតពនមហាវិហារ និងបុព្វារាម ក្បែរក្រុងសាវត្ថី ។

កាលណា ព្រះសាស្តាជាព្រះពុទ្ធទ្រង់ចាំវស្សាដំបូង ក្នុងព្រៃឥសិបត-នមិគទាយវ័ន ជិតក្រុងពារាណសី ចេញវស្សាបវារណាហើយ ទ្រង់យាងទៅកាន់តំបន់ឧរុវេលា គង់ក្នុងទីនោះអស់ ៣ ខែ ទ្រង់ទូន្មានជដិល ៣ នាក់បងប្អូន ធ្វើភិក្ខុ ១០០០ រូបឲ្យជាបរិវារ ហើយយាងទៅកាន់នគររាជគ្រឹះ ក្នុង

ថ្ងៃ ១៥ ខែបុស្ស ទ្រង់គង់នៅក្នុងទីនោះអស់ ២ ខែ ។ កាលនោះ តាំងអំពីទ្រង់យាងចេញអំពីនគរពារាណសីក៏អស់ពេល ៥ ខែ កន្លងហេមន្តរដូវអស់មួយរដូវ រាប់អំពីថ្ងៃដែលព្រះឧទាយិត្ថេរមកដល់ ក៏កន្លងទៅ ៧-៨ ថ្ងៃ ។ ព្រះឧទាយិត្ថេរនោះ ក្នុងថ្ងៃ ១៥ ខែផល្គុន ក៏ត្រិះរិះថា ហេមន្តរដូវកន្លងទៅ វសន្តរដូវមកដល់ហើយ ជាសម័យគួរព្រះតថាគត យាងទៅកាន់នគរកបិលពស្តុ កាលលោកត្រិះរិះយ៉ាងនេះហើយ ទើបពណ៌នាការយាងទៅដោយ ៦០ គាថា ដើម្បីជាប្រយោជន៍ដល់ការយាងទៅកាន់នគរនៃត្រកូល ។ កាលនោះ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ព្រះថេរៈ មានព្រះពុទ្ធបំណងនឹងធ្វើការសង្គ្រោះព្រះញាតិ ទើបចោមរោមដោយព្រះខីណាស្រព ២ ម៉ឺនរូប ដែលជាកុលបុត្តអ្នកដែនអង្គៈ និងមគធៈ ១ ម៉ឺនរូប កុលបុត្តអ្នកនគរកបិលពស្តុ ១ ម៉ឺន រាប់អំពីនគររាជគ្រឹះដល់នគរកបិលពស្តុ មានចម្ងាយផ្លូវ ៦០ យោជន៍ អស់រយៈ ២ ខែ ទើបយាងដល់ ទ្រង់ធ្វើយមកប្បាដិហារ្យ ដើម្បីឲ្យព្រះញាតិទាំងឡាយថ្វាយបង្គំ ក្នុងនគរកបិលពស្តុនោះ កាលនោះ ព្រះមានព្រះភាគទ្រង់សម្តែងពុទ្ធវង្សនេះ ។

សួរថា ពាក្យរបស់អ្នកណា ឆ្លើយថា ព្រះតម្រាស់របស់ព្រះសម្មាសម្ពុទ្ធមួយអង្គគត់ មិនទូទៅដល់ព្រះសាវក និងព្រះបច្ចេកពុទ្ធឡើយ ។

សួរថា អ្នកណានាំបន្តមក ឆ្លើយថា អាចារ្យនាំបន្តគ្នាមក ពិតហើយ ពុទ្ធវង្សនេះ ដែលព្រះថេរៈទាំងឡាយយ៉ាងនេះ គឺព្រះសារីបុត្តត្ថេរ ព្រះភទ្ទជិ ព្រះតិស្សកោសិយបុត្ត ព្រះសិគ្គវៈ ព្រះមោគ្គលីបុត្ត ព្រះសុទត្តៈ ព្រះធម្មិកៈ

ព្រះទាសកៈ ព្រះសោណកៈ ព្រះរេវតៈ នាំបន្តគ្នាមកដល់សង្គាយនាលើកទី ៣ បន្ទាប់ពីនោះទៅ សិស្សានុសិស្សរបស់ព្រះថេរៈទាំងនោះឯង នាំតគ្នាមក ហេតុនោះ ទើបគួរជ្រាបថា អាចារ្យនាំបន្តៗ គ្នាមក ដរាបដល់បច្ចុប្បន្ននេះ យ៉ាងនេះ ។

គាថានេះថា

ពុទ្ធវង្សនេះ អ្នកណាសម្តែង សម្តែងទីណា សម្តែងដើម្បី
ជាប្រយោជន៍ដល់អ្នកណា សម្តែងដើម្បីអ្វី សម្តែងកាលណា
ពាក្យរបស់អ្នកណា អ្នកណានាំបន្តមក ។

មានសេចក្តីតាមដែលខ្ញុំពោលហើយ ដោយកថាមានប្រមាណប៉ុណ្ណេះ ។

**គន្ថារម្ភកថា ចប់**

# និទានកថា

## ពាហិរនិទានកថា

ឥឡូវនេះ នឹងពណ៌នាសេចក្តីនៃពុទ្ធវង្សនោះ ដែលនាំបន្តគ្នាមកយ៉ាងនេះ ក៏ព្រោះកិច្ចពណ៌នាសេចក្តីនេះ ចាំបាច់សម្តែងនិទាន ៣ គឺទូរេនិទាន អវិទូរេនិទាន និងសន្តិកេនិទានហើយ ឈ្មោះថា ពណ៌នាដោយល្អ និងឈ្មោះថា បុគ្គលដែលស្តាប់និទាននោះដឹងរឿងបាន ព្រោះដឹងមកតាំងអំពីដើមហេតុដែលកើតហេតុនោះ ខ្ញុំនឹងសម្តែងពណ៌នានិទានទាំងនោះផង ។

ក្នុងនិទាននោះ គប្បីជ្រាបបរិច្ឆេទរបស់និទានទាំងនោះ ផ្តើមតាំងអំពីដើមសិន ការសម្តែងសេចក្តីដោយសង្ខេបក្នុងនិទាននោះ ដូច្នេះ កថាដែលប្រព្រឹត្តទៅ តាំងអំពីព្រះមហាសត្វបំពេញបារមី ទៀបបាទារបស់ព្រះទសពលសម្ពុទ្ធព្រះនាមទីបង្ករ រហូតដល់ចុតិចាកអត្តភាពជាព្រះវេស្សន្តរ ហើយកើតក្នុងស្ថានតុសិត ឈ្មោះថា **ទូរេនិទាន**។

កថាដែលប្រព្រឹត្តទៅ តាំងអំពីចុតិចាកភពតុសិត រហូតត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ ត្រង់ពោធិមណ្ឌលដ្ឋាន ឈ្មោះថា **អវិទូរេនិទាន**។

តាំងអំពីទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ត្រង់មហាពោធិមណ្ឌលដ្ឋាន រហូតដល់គ្រែជាទីបរិនិព្វាន ក្នុងចន្លោះនេះ ព្រះមានព្រះភាគទ្រង់គង់នៅទីណាៗ យ៉ាងនេះថា សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ជាអារាមរបស់អនាថបិណ្ឌិកគហបតី ក្រុងសាវត្ថី ឬពាក្យថា ទ្រង់គង់នៅក្នុងវត្តវេឡុវនកលន្ទកនិវាបស្ថាន ទៀបរាជគ្រឹះ ឬពាក្យថា ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ដូច្នេះ ទីនោះៗ

គប្បីជ្រាបថា ឈ្មោះថា **សន្តិកេនិទាន។**

កិច្ចពណ៌នាពាហិរនិទាន ៣ និទាន គឺទូរេនិទាន ១ អវិទូរេនិទាន ១ សន្តិកេនិទាន ១ ដោយសង្ខេបនេះឯង ជាការបញ្ចប់ដោយនិទានកថាត្រឹមប៉ុណ្ណេះ ។

**ពាហិរនិទានកថា ចប់**

# អដ្ឋកថាវណ្ណនា

## រតនចង្កមនកណ្ឌ

[ ១ ] ឥឡូវនេះ នឹងពណ៌នាអត្ថនៃអដ្ឋកថានិទាន ដែលប្រព្រឹត្តទៅ ដោយន័យជាដើមថា

គ្រានោះ សហម្បតីព្រហ្ម ជាអធិបតីនៃលោក ធ្វើអញ្ជលី
អារាធនា ព្រះសម្ពុទ្ធថា ពួកសត្វក្នុងលោកនេះ មានធូលី
គឺរាគាទិក្កិលេសក្នុងភ្នែក ស្រាលស្តើងហើយ សូមព្រះអង្គ
សម្តែងធម៌ សូមព្រះអង្គអនុគ្រោះ ពួកសត្វនេះ ។

ក្នុងសេចក្តីនេះ បើមានបុគ្គលសួរថា ហេតុអ្វី លោកមិនពោលនិទាន ដោយន័យជាដើមថា សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុង និគ្រោធារាម ក្រុងកបិលពស្តុ ដែនសក្កៈ ។

គ្រានោះឯង ព្រះសារីបុត្តចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ហើយបានទូលសួរព្រះមានព្រះភាគ ដល់ពុទ្ធវង្ស ដូច្នេះ ដូចដែលលោក ពោលក្នុងព្រះសូត្រជាដើមថា សម័យព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុ-វនកលន្ទកនិវាបស្ថាន ក្នុងក្រុងរាជគ្រឹះ ដូច្នេះ តែពោលនិទានដោយន័យ ជាដើមថា សហម្បតីព្រហ្ម ជាអធិបតីនៃលោក ធ្វើអញ្ជលី អារាធនាព្រះ សម្ពុទ្ធ ដូច្នេះ បទដែលដើម្បីចង្អុលបង្ហាញ ដូច្នេះ លោកពោលយ៉ាងនោះ ក៏ដើម្បីចង្អុលដល់ការទូលអារាធនាឲ្យទ្រង់សម្តែងធម៌របស់ព្រហ្ម ដែលជា ហេតុនៃការសម្តែងធម៌ទាំងពួងរបស់ព្រះមានព្រះភាគ សូមចង្អុលបង្ហាញ បញ្ហានេះថា

ព្រះជិនស្រីអង្គនេះ ដែលព្រហ្មអារាធនា ដើម្បីទ្រង់សម្តែងធម៌ ក្នុងកាលណា គាថានេះ អ្នកណាលើកឡើងពោល ពោលកាលណា និងទីណា ។

កាលព្រះមានព្រះភាគជាព្រះពុទ្ធ ចូលសប្តាហ៍ទី ៨ ព្រហ្មទូលអារាធនាព្រះសាស្តាដើម្បីសម្តែងធម៌ ។

ក្នុងរឿងនោះ ពោលតាមលំដាប់ដូច្នេះថា

បានឮថា ក្នុងថ្ងៃចេញមហាភិនេស្ក្រមណ៍ ព្រះមហាបុរស ទ្រង់ឃើញអ្នករបាំដេកពពាក់ពពូនគួរខ្ពើម ទ្រង់សង្វេគក្រៃលែង ហៅនាយឆន្នៈ ដែលបិទកាយដោយសំពត់មួយផ្ទាំង ត្រាស់ថា ចូរអ្នកនាំសេះដែលមានសម្ទុះជើងល្អ ឈ្មោះកណ្ឋកៈ ដែលសង្កត់សត្រូវបានមក ។ ឲ្យនាំសេះកណ្ឋកៈមកហើយ ទ្រង់មាននាយឆន្នជាសម្លាញ់ ឡើងគង់លើសេះ កាលទេវតាស្ថិតនៅត្រង់ទ្វារព្រះនគរបើកទ្វារព្រះនគរហើយ ក៏ចេញពីនគរទៅ ឆ្លងរាជអាណាចក្រ ៣ ដោយចំណែកដែលសេសសល់នៃរាត្រីនោះ ទ្រង់ជាសត្វដែលមិនថោកថយ ប្រថាប់ឈរត្រង់ឆ្នេរស្ទឹងអនោមា ត្រាស់នឹងនាយឆន្នៈនោះឯងថា នៃឆន្ន ចូរអ្នកនាំគ្រឿងអាភរណៈ ដែលមិនទូទៅដល់អ្នកដទៃទាំងនេះ និងសេះកណ្ឋកៈ ដែលមានថ្វីជើងល្អរបស់ខ្ញុំ ត្រឡប់ទៅក្រុងកបិលពស្តុ ទ្រង់បណ្តាយនាយឆន្នៈហើយ ទ្រង់កាត់ផ្នួងសក់ មួយអន្លើដោយព្រះមោលីដោយដាវដ៏មុត ដូចកាត់ត្របកឈូក ហើយបោះទៅក្នុងអាកាស ទ្រង់កាន់បាត្រ និងចីវរ ដែលទេវតាថ្វាយ ទ្រង់ព្រះផ្នួសដោយព្រះអង្គឯង យាងចារិក

ទៅដោយលំដាប់ ទ្រង់ឆ្ងងស្ទឹងគង្គា ដែលមានរលកបោកបក់ព្រោះកម្លាំងខ្យល់បាន ដោយមិនទើសទាស់ យាងទៅកាន់នគរឈ្មោះរាជគ្រឹះ ដែលមានរាជនិវេសន៍រុងរឿង ដោយបណ្តាញរស្មីនៃពួកកែវមណី ទ្រង់មិនជាប់ជំពាក់ដោយការយាង មានព្រះឥន្ទ្រិយស្ងប់ មានព្រះមនសៈស្ងប់ ទ្រង់សម្លឹងមើលមួយជួរទឹម ហាក់បីដូចជាលួងលោមពួកជនដែលស្រវឹង ព្រោះការស្រវឹងក្នុងភាពជាធំនៃក្រុងរាជគ្រឹះនោះ ហាក់ដូចទ្រង់ធ្វើឲ្យកើតនូវការខ្មាសដល់ជនដែលមានភេទរវើរវាយហើយ ហាក់ដូចជាចងនូវហទយៈរបស់អ្នកក្រុងក្នុងព្រះអង្គ ដោយការស្រឡាញ់ក្នុងវ័យ ដូចទ្រង់ដណ្តើមនូវភ្នែករបស់ជនគ្រប់គ្នា ដោយព្រះសិរីរូប ដែលថែងចាំងដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ហាក់បីដូចគំនរបុណ្យ និងហាក់បីដូចបព្វតា ដែលដើរបានដោយព្រះបាទ ដែលមានរូបល្អ យាងបិណ្ឌបាតទៅកាន់ក្រុងរាជគ្រឹះ ទ្រង់ទទួលអាហារត្រឹមតែញ៉ាំងអត្តភាពឲ្យល្មមប្រព្រឹត្តទៅបាន យាងចេញចាកក្រុងរាជគ្រឹះ គង់ប្រថាប់ក្នុងឱកាសស្ងាត់ គួរជាទីត្រេកអរក្រៃលែង ជាភូមិភាគស្អាត ដល់ព្រមដោយម្លប់ និងទឹក ក្បែរភ្នំបណ្ឌវៈ សោយអាហារដែលលាយគ្នា ដោយកម្លាំងពិចារណា ដែលព្រះបាទពិម្ពិសារមហារាជ នៃអាណាចក្រមគធៈ យាងមកតាមបណ្ឌវគិរី យាងទៅរកមហាបុរស ត្រាស់សួរព្រះនាម និងព្រះគោត្រហើយ មានព្រះរាជហឫទ័យត្រេកអរជាមួយព្រះអង្គ ទ្រង់យាងដោយរាជសម្បត្តិថា សូមទ្រង់ទទួលរាជសម្បត្តិមួយចំណែករបស់ខ្ញុំចុះ ព្រះពោធិសត្វឆ្លើយតបថា បពិត្រមហារាជ កុំឡើយ

អាត្មាមិនបំណាងក្នុងរាជសម្បត្តិទេ អាត្មាលះរាជសម្បត្តិ មកប្រកបព្យាយាម ដើម្បីជាប្រយោជន៍ដល់លោក ហើយនឹងបានត្រាស់ជាព្រះពុទ្ធ មានដំបូល គឺកិលេសបើកហើយក្នុងលោក ដូច្នេះហើយ យាងចេញទៅ ដែលព្រះបាទ ពិម្ពិសារអង្គនោះត្រាស់អង្វរថា បើទ្រង់បានត្រាស់ជាព្រះពុទ្ធហើយ សូម យាងមកកាន់ដែនរបស់ខ្ញុំមុនដែនដទៃ ព្រះពោធិសត្វថ្វាយប្តេជ្ញាដល់ព្រះ បាទពិម្ពិសារនោះថា សាធុ ហើយយាងចូលទៅរកអាឡារតាបស និងឧទក-តាបស ទ្រង់មិនជួបនូវសារៈនៃធម្មទេសនារបស់តាបសទាំង ២ អង្គនោះ ទ្រង់ក៏ចៀសចេញអំពីទីនោះ ទ្រង់ធ្វើទុក្ករកិរិយាអស់ ៦ ឆ្នាំ ត្រង់តំបន់ ឧរុវេលា ក៏មិនអាចសម្រេចនូវអមតធម៌ ទ្រង់ធ្វើព្រះសរីរៈឲ្យឆ្អែតស្កប់ស្កល់ ដោយអាហារយ៉ាងគ្រោតគ្រាត ។

គ្រានោះ ទារិកាឈ្មោះសុជាតា កូនស្រីរបស់កុដុម្ពិកសេនានិគម ក្នុង តំបន់ឧរុវេលាសេនានិគម ដល់ព្រមដោយវ័យហើយ ធ្វើសេចក្តីប្រាថ្នាត្រង់ ដើមជ្រៃមួយដើមថា បើខ្ញុំទៅផ្ទះត្រកូលដែលមានជាតិស្មើគ្នា ហើយបានកូន ប្រុសក្នុងផ្ទៃមុន នឹងធ្វើពលីកម្មបួងសួង សេចក្តីប្រាថ្នារបស់នាងសម្រេច ហើយ ។ ក្នុងថ្ងៃពេញបូណ៌មីខែពិសាខ នាងត្រិះរិះថា ថ្ងៃនេះ នឹងធ្វើពលីកម្ម ព្រឹកឡើង ទើបឲ្យរៀបចំមធុបាយាស ដែលមិនរឹង មានរសឆ្ងាញ់ក្រៃលែង ។ ក្នុងថ្ងៃនោះឯង ព្រះពោធិសត្វទ្រង់ធ្វើសរីរកិច្ចហើយ រង់ចាំពេលភិក្ខាចារ ព្រលឹមឡើងក៏យាងទៅគង់ត្រង់គល់ជ្រៃនោះ ។ កាលនោះ ទាសីឈ្មោះបុណ្ណា ជាអ្នកបម្រើរបស់នាងសុជាតា ដើរទៅបំណាងនឹងធ្វើការសម្អាតត្រង់គល់ជ្រៃ

ក៏ជួបព្រះពោធិសត្វ គង់ទតលោកធាតុទិសខាងកើត មានព្រះសរីរៈល្អ ដូចកំពូលភ្នំមាស ដែលរុងរឿងដោយពន្លឺសន្ធយា ដែលជាព្រះអាទិត្យនៃមុនីខាងក្រោមដើមឈើដ៏ប្រសើរ ប្រៀបដូចព្រះអាទិត្យ លាក់ខ្លួនក្នុងស្បែងនីត គឺការកម្ចាត់ងងឹតនៃពពក ចូលចន្លោះនៃពពកហើយ ក៏ត្រង់ព្រៃឈូក ឲ្យផ្កាឈូករីក ដូច្នេះ ព្រោះឃើញដើមនោះ មានពណ៌ដូចពណ៌មាស ទូទៅពេញដើម ដោយរស្មីដែលផ្សាយចេញអំពីសរីរៈរបស់ព្រះពោធិសត្វនោះ ទើបនាងបុណ្ណាទាសីគិតថា ថ្ងៃនេះ ទេវតារបស់យើងចុះអំពីដើមឈើ ប្រហែលជាចង់ទទួលពលីកម្មដោយផ្ទាល់ដៃ ទើបមកអង្គុយរង់ចាំ នាងក៏ប្រញាប់ទៅប្រាប់រឿងនោះ ដល់នាងសុជាតា ។

បន្ទាប់អំពីនោះ នាងសុជាតាកើតនូវសទ្ធាមកឯង តែងខ្លួនដោយគ្រឿងអលង្ការសព្វយ៉ាង ដាក់មធុបាយាសដែលមានរសឆ្ងាញ់ក្រៃលែងពេញថាសមាសដែលមានតម្លៃមួយសែន បិទដោយថាសមាសមួយទៀត ទូលលើក្បាល ដើរតម្រង់ទៅកាន់ត្រង់ដើមជ្រៃ ។ នាងកំពុងដើរទៅ ឃើញព្រះពោធិសត្វនោះអំពីចម្ងាយ ទ្រង់គង់ល្អដូចគំនរបុណ្យ ធ្វើដើមឈើទាំងមូលឲ្យមានពណ៌មាស ដោយរស្មីនៃព្រះសរីរៈ ហាក់បីដូចរុក្ខទេវតា ក៏កើតបីតីបាមោជ្ជ ដើរបង្អោនខ្លួន តាំងអំពីទីដែលខ្លួនមើលឃើញ ដោយសម្គាល់ថាជារុក្ខទេវតា ដាក់ថាសមាសនោះចុះអំពីក្បាលក្នុងដៃរបស់ព្រះមហាសត្វ រួចថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ដោយពោលថា មនោរថ គឺសេចក្តីប្រាថ្នារបស់ខ្ញុំបានសម្រេចហើយ យ៉ាងណា សូមមនោរថរបស់ព្រះអង្គសម្រេច

យ៉ាងនោះចុះ ហើយក៏ត្រឡប់ទៅ ។

គ្រានោះ ព្រះពោធិសត្វទ្រង់កាន់យកភាជន៍មាស យាងទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ទ្រង់ដាក់ថាសមាសត្រង់ឆ្នេរស្ទឹងឈ្មោះសុប្បតិដ្ឋិតៈ ទ្រង់ស្រពស្រង់ហើយឡើងមក ទ្រង់ធ្វើបាយាសនោះឲ្យជា ៤៩ ដុំ សោយបាយាសនោះហើយ ទ្រង់បណ្តែតថាសមាសនោះទៅ ដោយទ្រង់អធិដ្ឋានថា បើថ្ងៃនេះ អាត្មាអញបានជាព្រះពុទ្ធសោត សូមថាសមាសនេះអណ្តែតច្រាសទឹក ។ ថាសនោះក៏អណ្តែតច្រាសទឹក ចូលទៅកាន់ភពរបស់ស្តេចនាគឈ្មោះកាលនាគរាជ លើថាសរបស់ព្រះពុទ្ធ ៣ អង្គឡើងហើយ តាំងនៅខាងក្រោមថាសទាំងនោះ ។

ព្រះមហាសត្វ គង់សម្រាកពេលថ្ងៃក្នុងដងព្រៃនោះឯង លុះដល់ពេលល្ងាច ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអ្នកច្រូតស្មៅឈ្មោះសោត្ថិយៈដឹងអាការរបស់ព្រះមហាបុរសហើយថ្វាយ យាងឡើងកាន់ពោធិមណ្ឌលដ្ឋាន ទ្រង់ឈរក្នុងទិសទក្សិណ ។ ទីត្រង់នោះញាប់ញ័រ ដូចតំណក់ទឹកលើស្លឹកឈូក ។ ព្រះមហាបុរសទ្រង់ជ្រាបថា ប្រទេសនេះ មិនអាចទ្រទ្រង់គុណរបស់អញបាន ក៏យាងទៅកាន់ទិសខាងលិច សូម្បីប្រទេសនោះក៏ញាប់ញ័រដូចគ្នា ទើបយាងទៅកាន់ទិសខាងជើង ប្រទេសនោះក៏ញាប់ញ័រដូចគ្នា ទើបយាងទៅកាន់ទិសខាងកើត ក្នុងទិសនោះ ជាទីកើតបល្ល័ង្ក ទើបមិនញាប់ញ័រ ព្រះមហាបុរសទ្រង់សន្និដ្ឋានថា ទីនេះ ជាទីកម្ចាត់កិលេសដោយពិត ទើបទ្រង់ចាប់ចុងស្មៅទាំងនោះរលាស់ ស្មៅទាំងនោះក៏បានតម្រៀបគ្នា ដូចចុងជក់

សម្រាប់លាបពណ៌ ។ ព្រះពោធិសត្វ ទ្រង់អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ថា បើអាត្មាអញមិនសម្រេចពោធិញ្ញាណ នឹងមិនទម្លាយក្អែន ហើយទ្រង់គង់ពត់ក្អែន ឲ្យដើមពោធិ៍នៅអំពីខាងខ្នង បែរព្រះភក្ត្រទៅកាន់ទិសខាងកើត ។

វេលានោះឯង មារដែលអ្នកពារាំងនូវលោកទាំងពួង ក៏និម្មិតដៃ ១០០០ ជិះស្តេចដំរី ដែលកម្ចាត់សត្រូវយន់ឃ្នង ឈ្មោះគិរិមេខលៈ កម្ពស់ ១៥០ យោជន៍ ដូចកំពូលភ្នំហិមពាន្ត ចោមរោមដោយពលមារ ណែនណាន់តាន់តាប់ មានពលធ្នូ ពលដាវ ពលពូថៅ ពលសរ ពលលំពែងជាកម្លាំង ជុំជិតដូចភ្នំ យាត្រាចូលមករកព្រះមហាសត្វ ដូចព្រះអង្គជាសត្រូវធំ ។ កាលព្រះអាទិត្យមិនទាន់អស់រស្មី ព្រះមហាបុរសទ្រង់កម្ចាត់ពលមារ ដ៏ច្រើនសន្ធឹកសន្ធាប់ បានទទួលនូវការបូជាដោយត្រួយពោធិ៍ដ៏ល្អគួរមើល ដូចពន្លកកែវប្រពាលពណ៌ក្រហម ដែលធ្លាក់ចុះលើចីវរ មានពណ៌ដូចផ្កាច្បារិក ហាក់បីដូចទទួលបីតិនោះឯង ។ ក្នុងបឋមយាម ក៏ទ្រង់បាននូវបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងមជ្ឈិមយាមក៏ទ្រង់ជម្រះទិព្វចក្ខុញ្ញាណឲ្យបរិសុទ្ធ ក្នុងបច្ឆិមយាម ក៏ទ្រង់ញុំាងព្រះញាណចុះក្នុងបដិច្ចសមុប្បាទ ទ្រង់ពិចារណាវដ្ត និងវិវដ្ត លុះអរុណោទ័យ ទ្រង់ក៏បានត្រាស់ជាព្រះពុទ្ធ ទ្រង់បានបន្លឺឧទានទេះថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វេលាតែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខរឿយៗ ។

នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ជំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់សម្ងំនៅដោយការសោយវិមុត្តិសុខអស់ ៧ ថ្ងៃ ថ្ងៃទី ៨ ទ្រង់ចេញអំពីសមាបត្តិ ទ្រង់ជ្រាបសេចក្តីសង្ស័យរបស់ទេវតាទាំងឡាយ ទ្រង់ហោះទៅក្នុងអាកាស ដើម្បីកម្ចាត់សេចក្តីសង្ស័យនៃទេវតាទាំងនោះ កាលទ្រង់សម្តែងនូវយមកប្បាដិហារ្យ កម្ចាត់សេចក្តីសង្ស័យរបស់ទេវតាទាំងនោះហើយ ទ្រង់ឈរក្នុងទិសឧត្តរ ចៀងទិសខាងកើតអំពីបល្ល័ង្កបន្តិច ទ្រង់សម្លឹងមើលបល្ល័ង្ក និងពោធិព្រឹក្ស ដែលជាទីសម្រេចផលនៃបារមីទាំងឡាយ ដែលទ្រង់បំពេញមកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ដោយព្រះនេត្រមិនប៉ប្រិចថា អាត្មាអញត្រាស់ដឹងសព្វញ្ញុតញ្ញាណ លើបល្ល័ង្កនេះ សម្ងំនៅអស់ ៧ ថ្ងៃ ទើបទីនោះ ឈ្មោះថា **អនិមិសចេតិយ។**

បន្ទាប់អំពីនោះ ទ្រង់ចង្ក្រមក្នុងរតនចង្ក្រម បន្ទាប់អំពីទិសបូព៌ា និងទិសបស្ចិម រវាងបល្ល័ង្ក និងទីឈរប្រថាប់ ទ្រង់សម្ងំនៅអស់ ៧ ថ្ងៃ ទើបទីនោះ ឈ្មោះថា **រតនចង្កមចេតិយ។**

បន្ទាប់អំពីនោះ ទេវតាទាំងឡាយនាំគ្នានិម្មិតផ្ទះកែវថ្វាយ ក្នុងចំណែកទិសបស្ចិម ទ្រង់គង់ពត់ភ្នែនក្នុងទីនោះ ពិចារណាព្រះអភិធម្ម ដោយចំពោះយ៉ាងក្រៃលែង គឺគម្ពីរសមន្តប្បដ្ឋាន ដែលមានន័យមិនមានទីបំផុត ក្នុងទីនោះ ទ្រង់សម្ងំនៅអស់ ៧ ថ្ងៃ ទើបទីនោះ ឈ្មោះថា **រតនឃរចេតិយ។**

ព្រះពុទ្ធទ្រង់សម្ងំនៅក្បែរៗ ពោធិព្រឹក្ស អស់ ៤ សប្តាហ៍ យ៉ាងនេះហើយ ក្នុងសប្តាហ៍ទី ៥ ទើបចេញចាកគល់ពោធិ៍ យាងទៅកាន់ដើមអជ-បាលនិគ្រោធ ក្នុងទីនោះ ទ្រង់ពិចារណាធម៌ និងសោយវិមុត្តិសុខ សម្ងំនៅនាអជបាលនិគ្រោធ អស់ ៧ ថ្ងៃ ។

សប្តាហ៍មួយទៀត ទ្រង់គង់នៅយ៉ាងនេះ ត្រង់ដើមមុច្ចលិន្ទ គឺដើមរាំងអន្ទក់ ។ ព្រះមានព្រះភាគ លុះគង់ក្នុងទីនោះប៉ុណ្ណោះ មហាមេឃ គឺភ្លៀងពុំជួកាល ក៏ធ្លាក់ចុះមកពេញផ្ទៃចក្កវាឡ កាលមហាមេឃកើតឡើងហើយ ស្តេចនាគឈ្មោះមុច្ចលិន្ទ ក៏គិតថា កាលព្រះសាស្តាយាងចូលកាន់លំនៅរបស់អញ មហាមេឃនេះក៏កើតឡើង គួរបានជម្រកគង់នៅ សម្រាប់ព្រះសាស្តាអង្គនោះ ស្តេចនាគនោះ ទោះបីអាចនិម្មិតវិមានទិព្វបាន ដូចវិមានទេវតា ដែលសម្រេចដោយរតនៈ ៧ ប្រការ តែគិតថា បើអញនិម្មិតវិមានយ៉ាងនេះ នឹងមិនមានផលច្រើនដល់អញ អញនឹងខ្នះខ្នែង ដោយកាយខ្លួនឯង ដើម្បីព្រះទសពល ទើបធ្វើអត្តភាពឲ្យធំក្រៃលែងព័ទ្ធជុំវិញព្រះសាស្តាដោយភ្នែន ៧ ជាន់ បើកពពារអំពីខាងលើ ។ កាលនោះ ព្រះមានព្រះភាគទ្រង់គង់នៅលើបល្ល័ង្កដែលមានតម្លៃក្រៃលែង ដែលសម្រេចដោយរតនៈ ៧

ប្រការ ពិតានមានកម្រងផ្កាក្រអូបច្រើនប្រភេទ សំយុងចុះខាងលើ អប់ដោយក្លិនក្រអូបច្រើនប្រភេទ ក្នុងឱកាសធំទូលាយ ក្នុងវង្វេលស្តេចនាគ ដូចទ្រង់គង់នៅក្នុងព្រះគន្ធកុដិ ។ ព្រះមានព្រះភាគ ទ្រង់សម្ងំនៅត្រង់ដើមមុច្ចលិន្ទនោះ អស់ ៧ ថ្ងៃយ៉ាងនេះ បន្ទាប់អំពីនោះ ក៏ទ្រង់គង់ត្រង់ដើមរាជាយតនៈ គឺដើមកែស អស់ ៧ ថ្ងៃ សោយវិមុត្តិសុខក្នុងទីនោះឯង ដោយអាការដូចពោលមកនេះ ក៏គ្រប់ ៧ សប្តាហ៍បរិបូណ៌ ។ ក្នុងចន្លោះនេះ ព្រះមានព្រះភាគ ទ្រង់សម្ងំនៅដោយសុខក្នុងឈាន និងសុខក្នុងផល ។

លុះកន្លងទៅ ៧ សប្តាហ៍ ព្រះមានព្រះភាគអង្គនោះ ក៏កើតព្រះតម្រិះថា នឹងខ្ពុរព្រះឱស្ឋ សក្កទេវរាជក៏នាំផ្លែសម៉ដែលជាឱសថមកថ្វាយ ។ កាលនោះ សក្កទេវរាជបានថ្វាយឈើស្ទន់ឈ្មោះនាគលតា និងទឹកខ្ពុរព្រះឱស្ឋដល់ព្រះអង្គ បន្ទាប់អំពីនោះ ព្រះមានព្រះភាគទ្រង់ទំពាឈើស្ទន់ ទ្រង់ខ្ពុរព្រះឱស្ឋ ដោយទឹកក្នុងអនោតត្តស្រះ ទ្រង់គង់ត្រង់គល់រាជាយតនៈ សម័យនោះស្តេចចតុលោកបាលបង្អោនបាត្រថ្ម ដែលមានតម្លៃក្រៃលែង ចូលទៅថ្វាយ ។ ទ្រង់ទទួលសដូវផង់ និងសដូវដុំរបស់ពាណិជ្ជឈ្មោះតបុស្សៈ និងភល្លិកៈ ទ្រង់សោយស្រេចហើយ ត្រឡប់មកគង់ត្រង់គល់អជបាលនិគ្រោធ ។ កាលនោះ លុះទ្រង់គង់ក្នុងទីនោះប៉ុណ្ណោះ ទ្រង់ពិចារណាបញ្ចោសដល់ការៈនៃធម៌ដែលទ្រង់សម្រេច ជាធម៌ជ្រាលជ្រៅ ទ្រង់កើតបរិវិតក្ក ដែលព្រះពុទ្ធគ្រប់អង្គទ្រង់ប្រព្រឹត្តមក ដល់អាការ គឺការដែលមានព្រះពុទ្ធបំណងមិនសម្តែងធម៌ប្រោសអ្នកដទៃថា ក៏ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង

ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌ គឺសត្វឃើញបានដោយកម្រ ជាធម៌ គឺសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ដ៏ឧត្តម ជាធម៌ដែលសត្វមិនគប្បីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះបាន ជាធម៌ដ៏ល្អិត ជាធម៌ លុះតែអ្នកប្រាជ្ញ ទើបត្រាស់ដឹងបាន ។

កាលនោះ សហម្បតីព្រហ្មដឹងដល់បរិវិតក្ករបស់ព្រះមានព្រះភាគដោយចិត្តរបស់ខ្លួន ក៏បន្លឺវាចាថា លោកនឹងវិនាសហ្ន៎ លោកនឹងវិនាសហ្ន៎ កាលពួកព្រហ្មក្នុងម៉ឺនចក្កវាឡចោមរោមហើយ កាលសក្កទេវរាជ ស្ដេចសុយាម ស្ដេចសន្តុសិត ស្ដេចនិម្មិត ស្ដេចនិម្មិតវសវត្តី ជាប់តាមមកប្រាកដត្រង់ព្រះភក្ត្ររបស់ព្រះមានព្រះភាគ សហម្បតីព្រហ្មនោះ ទ្រង់និម្មិតផែនដីដើម្បីជាទីប្រថាប់ឈរខ្លួនឯង ទើបទ្រង់បត់ជានុមណ្ឌល គឺលុតជង្គង់ស្ដាំចុះលើផែនដី ទ្រង់ធ្វើអញ្ជលី ផ្គងម្រាមព្រះហស្តដ៏រុងរឿងដោយទសនខសមោធាន ដូចជាឈូកក្រពុំដែលកើតក្នុងទឹកប្រាសចាកមន្ទិល មិនពិការដាក់លើសិរសា ទូលអារាធនាព្រះមានព្រះភាគដើម្បីសម្ដែងធម៌ ដោយន័យមិនមែនតិចជាដើមយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគសម្ដែងធម៌ សូមព្រះសុគតសម្ដែងធម៌ ( ដ្បិត ) សត្វទាំងឡាយដែលមានធូលី គឺរាគាទិក្កិលេសដ៏ស្រាលស្ដើងក្នុងភ្នែក គឺបញ្ញា តែខានស្ដាប់ធម៌ ក៏មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយ អ្នកបម្រុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ ដូច្នេះហើយ បានពោលគាថាព័ន្ធថា ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា

ពីមុនរៀងមក ធម៌ដែលពួកជនអ្នកប្រកបដោយមន្ទិល បាន
គិតហើយ ជាធម៌មិនបរិសុទ្ធ ក៏កើតប្រាកដហើយក្នុងដែន
មគធៈ សូមព្រះអង្គបើកទ្វារនៃព្រះនិព្វានទុំះ ពួកសត្វប្រុង
ចាំស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិល ទ្រង់ត្រាស់
ដឹងតាម ( លំអានព្រះពុទ្ធអំពីបុរាណ ) ដូចជាបុរសឈរ
លើកំពូលភ្នំថ្មសុទ្ធ ក្រឡេកមើលឃើញប្រជុំជន ដោយជុំ
វិញខ្លួន យ៉ាងណាមិញ បពិត្រព្រះអង្គអ្នកមានបញ្ញាល្អ មាន
បញ្ញាចក្ខុជុំវិញ ព្រះអង្គជាអ្នកមានសេចក្តីសោកសៅ ទៅ
ប្រាសហើយ ស្តេចឡើងកាន់ប្រាសាទ គឺធម៌ ដែលមាន
ឧបមាយ៉ាងនោះ ពិចារណាមើលនូវប្រជុំជន អ្នកប្រឡំដោយ
សេចក្តីសោក ដែលជាតិជរាកំពុងគ្របសង្កត់ បពិត្រព្រះអង្គ
អ្នកមានព្យាយាម អ្នកឈ្នះនូវសង្គ្រាមហើយ ជានាយកនៃ
ពួកសត្វ អ្នកមិនជំពាក់បំណុល គឺកាម សូមព្រះអង្គ
ក្រោកឡើង សូមស្តេចទៅក្នុងលោក សូមព្រះមានព្រះភាគ
ទ្រង់សម្តែងធម៌ ដ្បិតពួកសត្វអ្នកបម្រុងនឹងត្រាស់ដឹងធម៌ ក៏
គង់មានដែរ ដូច្នេះ ។

ព្រះអង្គត្រាស់ដឹងធម៌ដែលគួរត្រាស់ដឹងហើយ ទ្រង់ធ្វូងឱយៈដែលគួរ
ធ្វូងហើយ ទ្រង់រួចផុតទុក្ខដែលទ្រង់គួររួចផុតហើយមិនមែនឬ ។ ទ្រង់ធ្វើ
សេចក្តីប្រាថ្នាថា

តែថា ប្រយោជន៍អ្វី អាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ដោយ
ភេទដែលគេមិនស្គាល់ ក្នុងទីនេះ អាត្មាអញគប្បីដល់នូវ
សព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាងលោក
ព្រមទាំងទេវលោក ឲ្យរួចរដោះ ( ចាកសង្សារ ) ដូច្នេះ ។

ទ្រង់បំពេញបារមីទាំងឡាយ បានសម្រេចសព្វញ្ញុតញ្ញាណហើយ នឹងថា កាលទ្រង់មិនសម្តែងធម៌ តើអ្នកដទៃណានឹងសម្តែងធម៌ វត្ថុដទៃណា ជាសរណៈនៃសត្វលោក ជាគ្រឿងជួយ គ្រឿងពួនសម្ងំ និងគ្រឿងនាំទៅខាងមុខ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា កាលព្រះមានព្រះភាគសម្មាសម្ពុទ្ធ ក្នុងសប្តាហ៍ទី ៨ ព្រហ្មទូលអារាធនាដើម្បីសម្តែងធម៌ ។

ឥឡូវនេះ ដល់ឱកាសឆ្លើយបញ្ហាទាំងនេះថា កថានេះ អ្នកណាលើកឡើងពោល ពោលកាលណា និងទីណា ក្នុងបញ្ហានោះ សួរថា ពោលកាលណា ឆ្លើយថា ពោលកាលធ្វើបឋមមហាសង្គាយនា ។ កាលមហាសង្គាយនាលើកទី ១ នេះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសង្គិតិក្ខន្ធកៈ ។ សួរថា ពោលទីណា ឆ្លើយថា បានឮថា កាលព្រះមានព្រះភាគបរិនិព្វានហើយ គាថានេះថា **ព្រហ្មា ច លោកាធិបតី** ជាដើម គប្បីជ្រាបថា ព្រះអានន្ទត្ថេរអង្គុយក្នុងធម្មាសនៈ ក្នុងមណ្ឌប សារមណ្ឌស្ថាន ដែលគួរទស្សនា ដូចព្រះចន្ទពេញវង់ ដែលព្រះបាទអជាសត្តុទ្រង់ឈ្នះសត្រូវគ្រប់គ្នា ជាស្តេចធំនៃដែនមគធៈ ទ្រង់ឲ្យសាងឡើង ក្បែរទ្វារសត្តបណ្ណគុហា ក្បែរភ្នំវេភារៈ នគររាជគ្រឹះ ដើម្បីសង្គាយនាធម៌ពោលហើយ សម្ពន្ធនៃគាថា

*ក្នុងរឿងនេះ មានដូច្នេះថា*

*គាថានេះថា ព្រះជិនសម្ពុទ្ធ ដែលព្រហ្មអារាធនា ដើម្បីសម្ដែងធម៌ ក្នុងកាលណា គាថានេះ អ្នកណាលើកឡើងពោល ពោលកាលណា និងទីណា ។*

*មានអត្ថដែលពោលហើយ តែខ្ញុំនឹងពណ៌នាបទដែលលំបាកនៃគាថានេះ ដែលពោលហើយ ដោយសម្ពន្ធនេះ ដូចតទៅនេះថា*

*បណ្ដាបទទាំងនោះ បទថា* **ព្រហ្មា** *មានវិគ្គហៈថា ឈ្មោះថា* **ព្រហ្ម** *ព្រោះអត្ថថា ជាអ្នកចម្រើនហើយដោយគុណវិសេសនោះៗ ។* **ព្រហ្ម** *សព្ទនេះ ប្រាកដក្នុងអត្ថទាំងឡាយ មានមហាព្រហ្ម ព្រាហ្មណ៍ ព្រះតថាគត មាតាបិតា និងបុគ្គលប្រសើរបំផុតជាដើម ។ ពិតហើយ* **ព្រហ្ម** *សព្ទ លោកសំដៅយកមហាព្រហ្ម ដូចក្នុងប្រយោគជាដើមថា* **ទ្វិសហស្សោ ព្រហ្មា** *មហាព្រហ្ម ២០០០ ។*

*លោកសំដៅយកថាជាព្រាហ្មណ៍ ដូចក្នុងប្រយោគជាដើមថា*

**តមោនុទោ ពុទ្ធោ សមន្តចក្ខុ លោកន្តគូ សព្ពភវាតិវត្តោ**
**អនាសវោ សព្ពទុក្ខប្បហីនោ សច្ចវ្ហយោ ព្រហ្មេ ឧបាសិតោ មេ ។**

*ព្រះពុទ្ធមានចក្ខុជុំវិញ គឺសព្វញ្ញុតញ្ញាណ បន្ទោបង់នូវសេចក្ដី*
*ងងឹត ដល់នូវទីបំផុតនៃលោក កន្លងផុតនូវភពទាំងពួង ព្រះ*
*អង្គមិនមានអាសវៈ លះបង់នូវទុក្ខទាំងពួង មានព្រះនាមជា*

សច្ចបុគ្គល ខ្ញុំក៏បានចូលទៅរកព្រះមានព្រះភាគ ដ៏ប្រសើរ រួចហើយ ។

លោកសំដៅយកព្រះតថាគត ក្នុងប្រយោគជាដើមថា **ព្រហ្មាតិ ខោ ភិក្ខវេ តថាគតស្សេតំ អធិវចនំ** ម្នាលភិក្ខុទាំងឡាយ ពាក្យថា **ព្រហ្ម** នេះ ជាឈ្មោះរបស់តថាគតនោះឯង ។

លោកសំដៅយកមាតាបិតា ដូចក្នុងប្រយោគជាដើមថា **ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ** មាតាបិតា បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង ។

លោកសំដៅយកថា ប្រសើរបំផុត ដូចក្នុងប្រយោគជាដើមថា **ព្រហ្មចក្កំ បវត្តេតិ** ព្រះមានព្រះភាគ ទ្រង់ញុំាងចក្រដ៏ប្រសើរបំផុត ឲ្យប្រព្រឹត្តទៅដូច្នេះ ។

ឯក្នុងទីនេះ បុគ្គលដែលចម្រើនបឋមជ្ឈានដ៏ប្រណីត ហើយកើតក្នុងភូមិនៃបឋមជ្ឈាន លោកសំដៅសេចក្ដីថា មហាព្រហ្មមានអាយុមួយកប្ប ។ ច សព្ទ មានអត្ថរួម អធិប្បាយថា ព្រហ្ម និងព្រហ្មដទៃក្នុងម៉ឺនចក្កវាឡ ។ ឬថា ច សព្ទ ត្រឹមតែធ្វើបទឲ្យពេញ ។ លោក ៣ គឺសង្ខារលោក សត្វលោក ឱកាសលោក ឈ្មោះថា **លោក** ក្នុងពាក្យថា **លោកធិបតី** នេះ ។ ក្នុងលោកទាំង ៣ នោះ ក្នុងទីនេះ លោកបំណងយកសត្វលោក ឈ្មោះថា **លោកាធិបតី** ព្រោះជាធំ ជាម្ចាស់នៃសត្វលោកនោះ ។ ជាម្ចាស់ចំណែកមួយនៃលោក លោកក៏ហៅថា **លោកាធិបតី** ដូច **ទេវាធិបតី**

**ធរាធិបតី** ជាដើម ។

បទថា **សហម្បតី** សេចក្តីថា បានឮមកថា ព្រហ្មអង្គនោះ ជាព្រះថេរៈឈ្មោះសហកៈ ក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ ធ្វើបឋមជ្ឈានឲ្យកើតហើយ មានឈានមិនសាបសូន្យ កាលអស់ជីវិត កើតជាមហាព្រហ្មមានអាយុមួយកប្ប ក្នុងបឋមជ្ឈានភូមិ តែក្នុងសម័យនោះ គេក៏ស្គាល់ព្រហ្មអង្គនោះបានថា សហម្បតីព្រហ្ម លោកពោលសំដៅដល់ព្រហ្មអង្គនោះ ។ កាលគួរនឹងពោលថា **សហកបតី** តែមនុស្សទាំងឡាយក៏ពោលភ្លាត់ថា **សហម្បតី** ដោយចុះនិគ្គហិតអាគម ដោយអំណាចពាក្យដែលផុសឡើង ។ បទថា **កតញ្ជលី** គឺមានអញ្ជលីដែលធ្វើហើយ អធិប្បាយថា ធ្វើនូវក្រពុំអញ្ជលីលើសិរសា ។ បទថា **អនធិវរំ** សេចក្តីថា មិនមានបុគ្គលប្រសើរឧត្តម មិនមានបុគ្គលប្រសើរក្រៃលែង ជាងព្រះមានព្រះភាគអង្គនោះ ហេតុនោះ ទើបព្រះអង្គ ឈ្មោះថា មិនមានអ្នកណាប្រសើរជាងឬថា បុគ្គលប្រសើរក្រៃលែងជាងព្រះមានព្រះភាគអង្គនោះ មិនមាន ។ ហេតុនោះ ទើបព្រះអង្គឈ្មោះថា មិនមានបុគ្គលណាប្រសើរក្រៃលែង ។ បទថា **អយាចថ** បានដល់ បានទូលអង្វរ បានអារាធនា ។

ឥឡូវនេះ សហម្បតីព្រហ្មនោះ ទូលអារាធនាព្រះមានព្រះភាគ ដើម្បីប្រយោជន៍ណា ដើម្បីសម្តែងប្រយោជន៍នោះ ទើបពោលពាក្យជាដើមថា **សន្តីធ សត្តា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សន្តិ** គឺមាន រកបាន អធិប្បាយថា សត្វទាំងឡាយដែលមកកាន់គន្លងពុទ្ធចក្ខុមាន ។ សព្ទថា **ឥធ** នេះ ជានិបាតប្រើក្នុងការអោនដល់ទីកន្លែង ។ សព្ទថា **ឥធ** នេះ ទីខ្លះ លោកសំដៅដល់សាសនា ដូចព្រះតម្រាស់ថា **ឥធេវ ភិក្ខវេ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហិ** ម្នាលភិក្ខុទាំងឡាយ សមណៈ ( ទី ១ ) ( គឺសោតាបន្ន ) មានតែក្នុងសាសនានេះ សមណៈទី ២ ( គឺសកទាគាមី ) ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ( គឺអនាគាមី ) ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ( គឺអរហន្ត ) ក៏មានតែក្នុងសាសនានេះ វាទៈ ( គឺទិដ្ឋិ ៦២ ) របស់សាសនាដទៃសូន្យចាកសមណៈទាំងឡាយ ( ដែលស្ថិតនៅក្នុងផលទាំង ៤ ពួក ) និងសមណៈទាំងឡាយដទៃ ( ដែលស្ថិតនៅក្នុងមគ្គទាំង ៤ ពួកជាដើម ) ។

ទីខ្លះ សំដៅយកឱកាស ដូចសក្កទេវរាជត្រាស់ថា

**ឥធេវ តិដ្ឋមានស្ស ទេវភូតស្ស មេ សតោ**
**ពុនរាយុ ច មេ លទ្ធោ ឯវំ ជានាហិ មារិសា ។**

ហៃសម្លាញ់រួមទុក្ខ កាលខ្ញុំកើតជាទេវតា តាំងនៅក្នុងឱកាសនេះឯង ហើយខ្ញុំបានអាយុបន្ថែមទៀត សូមអ្នកជ្រាប ដូច្នេះ ។

ទីខ្លះ ត្រឹមតែជាបទបូរណៈ គឺធ្វើបទឲ្យពេញប៉ុណ្ណោះ ដូចព្រះតម្រាស់ថា **ឥធាហំ ភិក្ខវេ ភុត្តាវី អស្សំ បវារិតោ** ម្នាលភិក្ខុទាំងឡាយ តថាគត

បរិភោគស្រេចហើយ ហាមកត្តហើយ ដូច្នេះ ។

ទី២ះ សំដៅដល់លោក ដូចព្រះតម្រាស់ថា **ឯក តថាគតោ លោកេ ឧប្បជ្ជតិ បហុជនហិតាយ ពហុជនសុខាយ** ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត រមែងកើតឡើងក្នុងលោក ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ។ ក្នុងទីនេះ **ឯក** សព្វ គប្បីជ្រាបថា លោកពោលសំដៅដល់លោកប៉ុណ្ណោះ ព្រោះហេតុនោះ ទើបមានសេចក្តីថា ក្នុងសត្វលោកនេះ ។

បទថា **សត្តា** សេចក្តីថា ជាអ្នកជាប់ ជាអ្នកទាក់ ជាអ្នកជំពាក់ ជាអ្នកធ្លាក់ ជាអ្នកជ្ជក់ ក្នុងខន្ធទាំងឡាយ មានរូបក្ខន្ធជាដើម ដោយឆន្ទរាគៈ ហេតុនោះ ទើបឈ្មោះថា **សត្ត** សត្វមានជីវិតទាំងឡាយ លោកក៏ហៅថា **សត្ត** តែព្រោះជាសព្ទដែលប្រើឃ្លៀងឃ្លាត ទើបវោហារនេះ ប្រព្រឹត្តទៅក្នុងបុគ្គលដែលប្រាសចាករាគៈហើយបានដូចគ្នា ។

បទថា **អប្បរជក្ខជាតិកា** សេចក្តីថា កិលេសដូចធូលី គឺរាគៈ ទោសៈ និងមោហៈក្នុងភ្នែក ដែលសម្រេចដោយបញ្ញារបស់សត្វទាំងនោះ មានបន្តិចបន្តួច សត្វទាំងនោះ ក៏មានសភាពយ៉ាងនោះ ហេតុនោះ ទើបសត្វទាំងនោះ ឈ្មោះថា មានធូលីក្នុងភ្នែកតិច ឬថា គប្បីឃើញសេចក្តីក្នុងបទនេះយ៉ាងនេះថា កិលេសដូចធូលី មានរាគៈជាដើមរបស់សត្វពួកណាតិច សត្វទាំងនោះ ឈ្មោះថា មានកិលេសដូចធូលីតិច សត្វទាំងនោះ ឈ្មោះថា **អប្បរជក្ខជាតិកា** ព្រោះមានកិលេសដូចធូលីក្នុងភ្នែកតិចជាសភាវៈ គឺដើម្បី

សត្វដែលមានកិលេសដូចធូលីក្នុងភ្នែកតិច ជាសភាវៈទាំងនោះ ។ គប្បីធ្វើនូវការបូរិកត្តិថា **សន្តានំ** ហើយធ្វើការភ្ជាប់ជាមួយបទនេះថា **ទេសេហិ ធម្មំ** សេចក្តីនឹងជាក់ច្បាស់ ។ បទថា **ទេសេហិ** នេះ ជាពាក្យអារាធនា អធិប្បាយថា សូមសម្តែង សូមពោលប្រៀនប្រដៅ ។ ក្នុងពាក្យថា **ធម្មំ** នេះ **ធម្ម** សព្ទនេះ ប្រើក្នុងអត្ថទាំងឡាយ មានបរិយត្តិ សមាធិ បញ្ញា ប្រក្រតីសភាវៈ សុញ្ញតា បុញ្ញៈ អាបត្តិ ញេយ្យ និងចតុសច្ចធម៌ជាដើម ។

ពិតហើយ **ធម្ម** សព្ទ ប្រើក្នុងអត្ថថា **បរិយត្តិ** ដូចក្នុងប្រយោគជាដើមថា **ឥធ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ ។បេ។ វេទល្លំ** ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ ។បេ។ វេទល្លៈ ។

ប្រើក្នុងអត្ថថា **សមាធិ** ដូចក្នុងប្រយោគជាដើមថា

**ឯវំធម្មា តេ ភគវន្តោ** ព្រះមានព្រះភាគទាំងនោះ មានធម៌យ៉ាងនេះ ។

ប្រើក្នុងអត្ថថា **បញ្ញា** ដូចក្នុងប្រយោគជាដើមថា

**យស្សេតេ ចតុរោ ធម្មា វានរិន្ទ យថា តវ**
**សច្ចំ ធម្មោ ធិតិ ចាគោ ទិដ្ឋំ សោ អតិវត្តតិ ។**

( អារក្សទឹកពោលថា ) បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៣ ដូចអ្នក គឺសេចក្តីសង្វាត ១ សេចក្តីក្លៀវក្លា ១ បញ្ញា ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ដូច្នេះ ។

ប្រើក្នុងអត្ថថា **ប្រក្រតី** ដូចក្នុងប្រយោគជាដើមថា **ជាតិធម្មា ជរាធម្មា អថោ មរណធម្មិនោ** ពួកបុថុជ្ជន មានព្យាធិជាធម្មតា មានជរាជាធម្មតា មានមរណៈជាធម្មតា ដូច្នេះ ។

ប្រើក្នុងអត្ថថា **សភាវៈ** ដូចក្នុងប្រយោគជាដើមថា **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា** ប្រែថា ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ពួកធម៌ជាអព្យាក្រឹត ដូច្នេះ ។

ប្រើក្នុងអត្ថថា **សុញ្ញតា** ដូចក្នុងប្រយោគជាដើមថា **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ ខន្ធា ហោន្តិ** ពួកធម៌ កើតមានក្នុងសម័យនោះ ពួកខន្ធ ។

ប្រើក្នុងអត្ថថា **បុញ្ញ** ដូចក្នុងប្រយោគជាដើមថា **ធម្មោ សុចិណ្ណោ សុខមាវហាតិ** ធម៌ ( បុណ្យ ) ដែលដែលបុគ្គលសន្សំល្អហើយ រមែងនាំមកនូវសេចក្តីសុខ ដូច្នេះ ។

ប្រើក្នុងអត្ថថា **អាបត្តិ** ដូចក្នុងប្រយោគជាដើមថា **ទ្វេ អនិយតា ធម្មា** ធម៌ ( អាបត្តិ ) ទាំងឡាយជាអនិយត មាន ២ ប្រការ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ញេយ្យ** ដូចក្នុងប្រយោគជាដើមថា **សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថំ អាគច្ឆន្តិ** ធម៌ទាំងអស់ រមែងមកកាន់គន្លងចំមុខព្រះញាណនៃព្រះពុទ្ធដ៏មានព្រះភាគ ដោយអាការទាំងពួង ដូច្នេះ ។

ប្រើក្នុងអត្ថថា **ចតុសច្ចធម៌** ដូចក្នុងប្រយោគជាដើមថា **ទិដ្ឋធម្មោ**

**បត្តធម្មោ វិទិតធម្មោ** ( ហោក្ខរសាតិព្រាហ្មណ៍ ) ឃើញអរិយសច្ចធម៌ច្បាស់ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ ដូច្នេះ តែក្នុងទីនេះ **ធម្ម** សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថថា **ចតុសច្ចធម៌**។

បទថា **អនុកម្ប** បានដល់ សូមទ្រង់ធ្វើនូវសេចក្តីករុណា ។ លោកពោលចង្អុលបង្ហាញពួកសត្វដោយពាក្យថា **ឥមំ** ( នេះ ) ។ បទថា **បជំ** ឈ្មោះថា **បជ** ព្រោះជាសត្វកើតហើយ បានដល់ នូវពួកសត្វនោះ អធិប្បាយថា សូមដោះពួកសត្វចាកសង្សារទុក្ខផងចុះ ។ ឯអាចារ្យពួកខ្លះ ពោលថា

ព្រះមានព្រះភាគ ជាធំក្នុងលោក ជាបុគ្គលឧត្តមក្នុងនរជន ដែលពួកព្រហ្មផ្គងអញ្ជលីទូលអារាធនាហើយ ។

គាថានេះ មានសេចក្តីតាមដែលពោលមក ដោយប្រការទាំងពួង ដោយកថាមានប្រមាណប៉ុណ្ណេះ ។

គ្រានោះ ព្រះមហាករុណា កើតឡើងដោយត្រឹមតែធ្វើឱកាសក្នុងសត្វទាំងពួង ដល់ព្រះមានព្រះភាគ ដែលមានកម្លាំងនៃព្រះករុណាផុសឡើងក្នុងសម័យដែលមិនបានកំណត់ ព្រោះទ្រង់ស្តាប់ពាក្យអារាធនារបស់សហម្បតី-ព្រហ្មនោះ ទ្រង់មានកម្លាំង ១០ ទ្រង់ប្រមើលមើលដោយមតិដ៏ល្អិត ក្នុងការធ្វើនូវប្រយោជន៍ដល់អ្នកដទៃ តែកាលធ្វើសង្គាយនា ព្រះសង្គីតិកាចារ្យទាំងឡាយ កាលសម្តែងការកើតនូវករុណារបស់ព្រះមានព្រះភាគអង្គនោះ ទើបតាំងគាថានេះថា

ព្រះតថាគត ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាតាទិបុគ្គល ទ្រទ្រង់

*នូវពន្លឺ ទ្រង់ទ្រង់នូវរាងកាយជាទីបំផុត ព្រោះអង្គឥតមានបុគ្គលផ្ទឹមបាន ទ្រង់មានសេចក្តីករុណា កើតឡើងក្នុងសត្វទាំងពួង ។*

*ក្នុងបទទាំងនោះ បទថា* **សម្បន្នវិជ្ជាចរណស្ស** *ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ឈ្មោះថា* **សម្បន្ន** *មាន ៣ គឺ* **បរិបុណ្ណសម្បន្ន សមង្គិ-សម្បន្ន** *និង* **មធុរសម្បន្ន** *ក្នុង* **សម្បន្ន** *ទាំងបីនោះ* **សម្បន្ន** *នេះថា*

**សម្បន្នំ សាលិកេទារំ សុវា ភុញ្ជន្តិ កោសិយ**
**បដិវេទេមិ តេ ព្រហ្មេ ន នំ វារេតុមុស្សហេ។**

*បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែបរិបូណ៌ដែរ តែពួកសេកតែងស៊ី បពិត្រព្រហ្ម ខ្ញុំសូមជម្រាបលោក ខ្ញុំមិនអាចហាមឃាត់សេកទាំងនោះបានឡើយ ដូច្នេះ ។*

*ឈ្មោះថា* **បរិបុណ្ណសម្បន្ន** *( ដល់ព្រមដោយការបរិបូណ៌ ) ។*

**សម្បន្ន** *នេះថា* **ឥមិនា ចាតិមោក្ខសំវរេន ឧបេតោ ហោតិ សមុ-បេតោ ឧបគតោ សមុបគតោ សម្បន្នោ សមន្នាគតោ** *ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយការសង្រួមក្នុងបាតិមោក្ខនេះ ដូច្នេះឈ្មោះថា* **សមង្គិសម្បន្ន** *( កាលដល់ព្រម គឺការប្រកប ) ។*

**សម្បន្ន** *នេះថា* **ឥមិស្សា ភន្តេ មហាបឋវិយា ហេដ្ឋិមតលំ សម្បន្នំ សេយ្យថាបិ ខុទ្ទមធុំ អនីលកំ ឯវមស្សាទំ** *សូមទ្រង់ព្រះមេត្តាប្រោស ផ្ទៃខាងក្រោមនៃផែនដីនេះ មានឱជារសផ្អែមដូចទឹកឃ្មុំ ដែលស្អាតបរិសុទ្ធ ឥត*

លាយប្រឡំដោយមេឃុំ ដូច្នេះ ឈ្មោះថា **មធុរបរិសម្បន្ន** ( ការដល់ព្រមដោយរសឆ្ងាញ់ ) ។ ក្នុងទីនេះ **បរិបុណ្ណសម្បន្ន** និង **សមង្គិសម្បន្ន** រមែងត្រឹមត្រូវ ។

បទថា **វិជ្ជា** ដែលឈ្មោះថា **វិជ្ជា** ព្រោះអត្ថថា ចោះទម្លុះនូវធម៌ដែលជាសត្រូវ ព្រោះអត្ថថា ធ្វើឲ្យដឹង និងព្រោះអត្ថថា គួរបាន វិជ្ជាទាំងនោះមាន ៣ ក៏មាន ៨ ក៏មាន ។ វិជ្ជា ៣ គប្បីជ្រាបតាមន័យដែលមកក្នុងភយភេរវសូត្រនោះឯង វិជ្ជា ៨ គប្បីជ្រាបតាមន័យដែលមកក្នុងអម្ពដ្ឋសូត្រពិតហើយ ក្នុងអម្ពដ្ឋសូត្រនោះ លោកកំណត់យកអភិញ្ញា ៦ និងវិបស្សនាញាណ និងមនោមយិទ្ធិ ហៅថា វិជ្ជា ៨ ។ ធម៌ ១៥ គឺសីលសំវរៈ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ការស្គាល់ប្រមាណក្នុងភោជន ជាគរិយានុយោគ សទ្ធា ហិរិ ឱត្តប្បៈ ពាហុសច្ចៈ ភាពជាអ្នកប្រារព្ធសេចក្តីព្យាយាម ភាពជាអ្នកមានសតិតាំងមាំ ភាពជាអ្នកដល់ព្រមដោយបញ្ញា រូបាវចរជ្ឈាន ៤ គប្បីជ្រាបថា ជាចរណៈ ។ ពិតហើយ ធម៌ ១៥ នេះឯង លោកពោលថា ចរណៈ ព្រោះជាហេតុដែលព្រះអរិយសាវកប្រព្រឹត្ត ជាហេតុទៅកាន់អមតទិស ដូចព្រះតម្រាស់ថា បពិត្រមហានាម អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសីល ដូច្នេះ ។ ចរណៈទាំងអស់ គប្បីជ្រាបតាមន័យដែលលោកពោលក្នុងមជ្ឈិមបណ្ណាសក ។ វិជ្ជាផង ចរណៈផង ឈ្មោះថា **វិជ្ជា** និង **ចរណា** វិជ្ជា និងចរណៈរបស់បុគ្គលណាដល់ព្រមហើយ បរិបូណ៌ហើយ បុគ្គលនោះឈ្មោះថា ជាអ្នកមានវិជ្ជា និងចរណៈដល់ព្រមហើយ ឬបុគ្គលដល់ព្រមហើយ

បុគ្គលព្រមព្រៀងហើយ បុគ្គលប្រកបព្រមហើយ ដោយវិជ្ជា និងចរណៈទាំងឡាយ ឈ្មោះថា ជាអ្នកមានវិជ្ជា និងចរណៈដល់ព្រមហើយ សេចក្តីត្រឹមត្រូវមានទាំង ២ ន័យ ។ តែព្រះតថាគតអង្គនោះ ជាអ្នកមានវិជ្ជា និងចរណៈដល់ព្រមហើយ ។

បទថា **តាទិនោ** សេចក្តីថា ជាអ្នកមិនញាប់ញ័រ តាមលក្ខណៈនៃបុគ្គលមិនញាប់ញ័រ ដែលមកក្នុងមហានិទ្ទេស ដោយន័យថា លោកនឹងធឹងក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ដូច្នេះជាដើម អធិប្បាយថា ជាអ្នកមានអាការមិនខុសប្រក្រតីក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា ជាតាទិ-បុគ្គល ។ បទថា **ជុតិន្ធរស្ស** បានដល់ ជាអ្នករុងរឿង អធិប្បាយថា ជាអ្នកទ្រទ្រង់នូវការផ្សាយចេញនៃរស្មីសរីរៈ ដែលមានសិរីជាងព្រះអាទិត្យដែលរះឡើងក្នុងសរទរដូវ ដូចស្តេចក្នុំយុគន្ធរ ឬនឹងពោលថា ជាអ្នកទ្រទ្រង់នូវការរុងរឿងដោយសញ្ញា ដូច្នេះក៏គួរ សមដូចតម្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

**ចត្តារោ លោកេ បជ្ជោតា បញ្ចមេត្ថ ន វិជ្ជតិ**
**ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា។**
**អថ អគ្គិ ទិវារត្តឹ តត្ថ តត្ថ បភាសតិ**
**សម្ពុទ្ធោ តបតំ សេដ្ឋោ ឯសា អាភា អនុត្តរា។**

ពន្លឺក្នុងលោកនេះ មាន ៤ យ៉ាង មិនមានដល់ ៥ ទេ ព្រះអាទិត្យ រមែងភ្លឺបានក្នុងវេលាថ្ងៃ ព្រះចន្ទ្រភ្លឺបាន ក្នុងវេលា

យប់ ភ្លឺ ភ្លឺបានទាំងថ្ងៃ ទាំងយប់ គ្រប់វេលា ព្រះសម្ពុទ្ធ
ប្រសើរជាងពួកដែលមានពន្លឺរុងរឿង នេះជាពន្លឺប្រសើរ
បំផុត ។

ព្រោះដូច្នោះ ទើបអធិប្បាយថា បុគ្គលទ្រទ្រង់នូវការផ្សាយទៅនៃព្រះរស្មីសរីរៈ និងព្រះបញ្ញាទាំង ២ ប្រការ ។ បទថា **អន្តិមទេហធារិនោ** បានដល់ ទ្រទ្រង់នូវព្រះសរីរៈចុងក្រោយ អធិប្បាយថា មិនកើតទៀត ។

នឹងវិនិច្ឆ័យក្នុងបទថា **តថាគតស្ស** នេះ ដូចតទៅ

ព្រះមានព្រះភាគ លោកហៅថា **តថាគត** ដោយហេតុ ៨ ប្រការ ហេតុ ៨ ប្រការនោះ គឺអ្វីខ្លះ គឺឈ្មោះថា តថាគត ព្រោះយាងមកហើយយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះយាងទៅហើយយ៉ាងនោះ ១ ឈ្មោះថា តថាគត ព្រោះទ្រទ្រង់នូវលក្ខណៈដែលពិត ១ ឈ្មោះថា តថាគត ព្រោះត្រាស់ដឹងធម៌តាមសេចក្តីពិត ១ ឈ្មោះថា តថាគត ព្រោះទ្រង់ឃើញតាមសេចក្តីពិត ១ ឈ្មោះថា តថាគត ព្រោះត្រាស់តែពាក្យពិត ១ ឈ្មោះថា តថាគត ព្រោះទ្រង់ធ្វើពិត ១ ឈ្មោះថា តថាគត ព្រោះអត្ថថា ទ្រង់គ្របសង្កត់ ១ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះយាងមកហើយយ៉ាងនោះ តើដូចម្តេច ឆ្លើយថា ព្រះសម្មាសម្ពុទ្ធទាំងឡាយ មានព្រះវិបស្សីសម្មាសម្ពុទ្ធជាដើម ទ្រង់បំពេញទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញា-បារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តា និងឧបេក្ខា-

បារមី ទ្រង់បំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទ្រង់ធ្វើមហាបរិច្ចាគ ៥ គឺបរិច្ចាគអវយវៈ ១ បរិច្ចាគជីវិត ១ បរិច្ចាគទ្រព្យ ១ បរិច្ចាគរាជសម្បត្តិ ១ បរិច្ចាគបុត្រភរិយា ១ យាងមកហើយ ដោយអភិនីហារ យ៉ាងណា ព្រះមានព្រះភាគនៃយើងក៏យាងមកហើយ ដោយអភិនីហារនោះ យ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា តថាគត ដូចលោកពោលថា

ព្រះមុនីទាំងឡាយ មានព្រះវិបស្សីសម្ពុទ្ធជាដើម យាងមកកាន់ព្រះសព្វញ្ញុតញ្ញាណក្នុងលោកនេះ យ៉ាងណា សូម្បីព្រះសក្យមុនីអង្គនេះ ក៏យាងមកយ៉ាងនោះ ដោយហេតុនោះ ទើបព្រះមានចក្ខុ លោកហៅថា តថាគត ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះយាងទៅហើយយ៉ាងនោះ តើដូចម្ដេច ឆ្លើយថា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីសម្ពុទ្ធជាដើម ប្រសូតភ្លាម ឈរប្រថាប់ត្រង់ផែនដី ដោយព្រះបាទទាំងគូដ៏ស្មើ បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ យាងទៅដោយព្រះបាទ ៧ ជំហាន យ៉ាងណា ព្រះមានព្រះភាគនៃយើង ក៏យាងទៅយ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា តថាគត ដូចលោកពោលថា

គោមេហ្វូង កើតបានភ្លាម ក៏ប៉ះផែនដីដោយជើងដែលស្មើគ្នា យ៉ាងណា ព្រះគោតមអង្គនោះ ក៏ឈាន ៧ ជំហាន ក៏យ៉ាងនោះ ពួកទេវតាទាំងឡាយ ក៏បាំងស្វេតច្ឆត្រថ្វាយព្រះគោតម

អង្គនោះ កាលឈាន ៧ ជំហានហើយ ទ្រង់សម្លឹងមើល
ទិសស្មើគ្នា ដោយជុំវិញ ទ្រង់បន្លឺអាសភិវាចា ប្រកបដោយ
អង្គ ៨ ដូចស្តេចសីហៈ ឈរសម្តែងឫកលើភ្នំ ដូច្នោះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះដល់នូវលក្ខណៈ ដែលពិត តើដូចម្តេច ឆ្លើយថា ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់មកដល់ ត្រាស់ដឹងមិនខុស ត្រាស់ដឹងនូវលក្ខណៈចំពោះ និងលក្ខណៈទូទៅ ដែលពិតប្រាកដ មិនក្លែងក្លាយរបស់រូបធម៌ និងនាមធម៌ទាំងពួង ដោយញាណគតិ ព្រោះហេតុនោះ ទើបឈ្មោះថា តថាគត ( ដូចលោកពោលថា )

ព្រោះហេតុដែលទ្រង់សម្រេចដល់លក្ខណៈចំពោះ និងលក្ខណៈ
ទូទៅ ដែលពិតនៃធម៌ទាំងពួង ហេតុនោះ ទើបព្រះសាស្តា
ឈ្មោះថា តថាគត ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិត តាមសេចក្តីពិត តើដូចម្តេច ឆ្លើយថា អរិយសច្ច ៤ ឈ្មោះថា ធម៌ពិត ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះ ជារបស់ពិតមិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ធម្មជាត ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយជាដើម ។ បណ្ឌិតគប្បីធ្វើឲ្យពិស្តារ ។ ព្រះមានព្រះភាគត្រាស់ដឹងនូវអរិយសច្ចទាំង ៤ នោះ ព្រោះហេតុនោះ ទើបលោកហៅថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិត ។ សេចក្តីពិត **គត**

សព្វ ក្នុងពាក្យថា **តថាគតោ** នេះ មានអត្ថថា ត្រាស់ដឹង ( ដូចលោកពោលថា )

ព្រះនាយកត្រាស់ដឹងសច្ចៈទាំងឡាយ ដែលជារបស់ពិត
ព្រោះហេតុនោះ ទើបឈ្មោះថា តថាគត ព្រោះត្រាស់ដឹងសច្ចៈ
ទាំងឡាយ ដែលជារបស់ពិត ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះទ្រង់ឃើញសេចក្តីពិត តើពិតដូចម្តេច ឆ្លើយថា ពិតហើយ ព្រះមានព្រះភាគ ដ៏ជាតថាគតទ្រង់ដឹងទ្រង់ឃើញអារម្មណ៍ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មៈ ដែលមកប្រាកដក្នុងទ្វារ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត របស់សត្វទាំងឡាយមិនមានប្រមាណ ក្នុងលោកធាតុដែលមិនមានប្រមាណ ដោយអាការទាំងពួង ហេតុនោះ ទើបឈ្មោះថា តថាគត ព្រោះទ្រង់ឃើញការពិតយ៉ាងនោះ ។ ម្យ៉ាងទៀត វត្ថុណា ដែលជាសេចក្តីពិតក្នុងលោក ទ្រង់សម្តែងតែវត្ថុនោះប៉ុណ្ណោះ ដល់ ( សត្វ ) លោក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ឈ្មោះថា តថាគត ។ ក្នុងទីនេះ គប្បីជ្រាបអត្ថនៃបទថា **តថាគត** ក្នុងអត្ថថា ទ្រង់ឃើញសេចក្តីពិត ( ដូចលោកពោលថា )

បុគ្គលណា ឃើញធម៌ទាំងឡាយ ដោយអាការដែលពិត
បុគ្គលនោះ ឈ្មោះថា ឃើញសេចក្តីពិត ព្រោះហេតុនោះ
ទើបអ្នកត្រាស់ដឹង អ្នកឃើញតាមសេចក្តីពិត លោកហៅថា
តថាគត ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះត្រាស់តែពាក្យពិត តើដូចម្ដេច ឆ្លើយថា ពាក្យណាដែលសង្គ្រោះជានវង្គសត្ថុសាសនៈ មានសុត្តៈជាដើម ដែលព្រះតថាគតត្រាស់អស់កាលប្រមាណ ៤៥ វស្សា រវាងត្រាស់ដឹង និងបរិនិព្វាន ពាក្យទាំងអស់ជាពាក្យពិត មិនកុហកឡើយ ដូចថ្លឹងបានដោយជញ្ជីងតែមួយ ដោយហេតុនោះ ទើបទ្រង់ត្រាស់ ( ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស ) ថា

ម្នាលចុន្ទ ព្រះតថាគត ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ដ៏ក្រៃលែងក្នុងរាត្រីណា បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងរាត្រីណា រមែងពោលចរចា សម្ដែងនូវពាក្យណា ក្នុងចន្លោះនៃការត្រាស់ដឹង និងបរិនិព្វាននោះ របស់ទាំងអស់នោះ នៅដូចដែល មិនប្រែប្រួលទេ ហេតុនោះ ទើបហៅថា ព្រះតថាគត ។

ក្នុងពាក្យថា តថាគតនេះ **គត** សព្ទ មានអត្ថថា ពោលជាក់ច្បាស់ ឈ្មោះថា តថាគត ព្រោះត្រាស់តែពាក្យពិតយ៉ាងនេះ ការពោលជាក់ច្បាស់ឈ្មោះថា **អាគទ** អធិប្បាយថា ព្រះតម្រាស់ ។ ព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ជារបស់ពិត មិនវិបរិត ព្រោះហេតុនោះ ទើបឈ្មោះថា តថាគត លោកពោលយក **ទ** អក្ខរៈ ជា **ត** អក្ខរៈ ( ដូចលោកពោលថា )

ព្រោះហេតុដែលព្រះជិនស្រីសម្ពុទ្ធ ត្រាស់តែពាក្យពិត ទ្រង់
ប្រកាសធម៌ដែលពិត ព្រះតម្រាស់របស់ព្រះអង្គ ក៏ជាពាក្យ
ពិត ហេតុនោះ ទើបព្រះពុទ្ធ ឈ្មោះថា តថាគត ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះទ្រង់ធ្វើពិត តើដូចម្តេច ឆ្លើយថា សេចក្តីពិត ព្រះមានព្រះភាគបានត្រាស់វាចាណាមួយ ក៏ទ្រង់ធ្វើតាមវាចានោះៗ ដោយព្រះកាយ គឺព្រះកាយ ក៏អនុលោមតាមព្រះវាចា ទាំងព្រះវាចាក៏អនុលោមតាមព្រះកាយ ដោយហេតុនោះឯង ទើបត្រាស់ ( ក្នុងអង្គុត្តនិកាយ ចតុក្កនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ តថាគតថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ។បេ។ ហេតុនោះ ទើបបានជាគេហៅថា តថាគត ដូច្នេះ ។

ម្យ៉ាងទៀត ព្រះវាចាទៅយ៉ាងណា ព្រះកាយក៏ទៅយ៉ាងនោះ ព្រះកាយទៅយ៉ាងណា ព្រះវាចាក៏ទៅយ៉ាងនោះ ។ ឈ្មោះថា តថាគត ព្រោះទ្រង់ធ្វើពិត ដោយប្រការដូច្នេះ ( ដូចលោកពោលថា )

ព្រោះហេតុដែលព្រះវាចារបស់ព្រះអង្គទៅយ៉ាងណា ព្រះកាយក៏ទៅយ៉ាងនោះ ព្រោះត្រាស់តែពាក្យពិត ហេតុនោះ ទើបព្រះសាស្តាត្រាស់ដឹងពិត ឈ្មោះថា តថាគត ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះអត្ថថា គ្របសង្កត់ តើដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគទ្រង់គ្របសង្កត់សត្វទាំងពួង ខាងលើដល់ភវគ្គព្រហ្ម ខាងក្រោមដល់អវីចីមហានរក ទទឹងក្នុងលោកធាតុដែលប្រមាណមិនបាន ដោយសីលខ្ធៈ សមាធិខ្ធៈ បញ្ញាខ្ធៈ វិមុត្តិខ្ធៈ វិមុត្តិ-ញ្ញាណទស្សនៈខ្ធៈ មិនមានគ្រឿងថ្លឹង ឬគ្រឿងប្រមាណសម្រាប់ព្រះអង្គ ដែល

ពិត ទ្រង់ក៏ថ្លឹងមិនបាន ប្រមាណមិនបាន មិនមានក្រៃលែងជាង ដោយហេតុនោះ ទើបត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោក ព្រមទាំងទេវលោក ។បេ។ ហេតុនោះ បានជាគេហៅថា តថាគត ។

គប្បីជ្រាបការសម្រេចអត្ថនៃបទ ក្នុងបទថា **តថាគតោ** នេះ យ៉ាងនេះ គឺអានុភាពប្រៀបដូចថ្នាំ ។ អានុភាពនុ៎ះ គឺអ្វី គឺការស្អាតនៃទេសនា និងគំនរបុណ្យ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាពេទ្យ មានអានុភាពច្រើន ទ្រង់គ្របសង្កត់បុគ្គលដែលមានលទ្ធិផ្ទុយគ្នាទាំងអស់ និងគ្របសង្កត់លោក ព្រមទាំងទេវលោក ដោយអានុភាពនោះ ដូចគ្រូពេទ្យគ្របសង្កត់នូវពស់ទាំងឡាយដោយថ្នាំទិព្វ ហេតុនោះ អានុភាព គឺលម្អនៃទេសនា និងគំនរបុណ្យដែលមិនវិបរិត ព្រោះគ្របសង្កត់លោកបានទាំងអស់របស់ព្រះអង្គមាន ហេតុនោះ ទើបព្រះអង្គ ឈ្មោះថា តថាគត ព្រោះធ្វើ **ឧ** អក្ខរៈ ជា **ត** អក្ខរៈ ។ ឈ្មោះថា តថាគត ព្រោះអត្ថថា ទ្រង់គ្របសង្កត់ដោយប្រការដូច្នេះ ( ដូចលោកពោលថា )

ព្រះសាស្តាអង្គណា ទ្រង់មានអានុភាពមិនវិបរិត ព្រះសាស្តា
អង្គនោះ ជាអ្នកមានអំណាច ព្រោះហេតុនោះ ទើបព្រះ
សាស្តាអង្គនោះ ឈ្មោះថា តថាគត ។

បទថា **អប្បដិបុគ្គលស្ស** បានដល់ ប្រាសចាកបុគ្គលដែលអាចប្រៀប

ផ្ទឹមបាន បុគ្គលដទៃណាសោត ឈ្មោះថា អាចឲ្យពាក្យប្តេជ្ញា អះអាងថា ខ្ញុំជាពុទ្ធ: ដូចគ្នានឹងតថាគតនោះមិនមាន ហេតុនោះ ទើបព្រះតថាគតនោះ ឈ្មោះថា មិនមានបុគ្គលប្រៀបបាន បានដល់ ព្រះតថាគត មិនមានបុគ្គលប្រៀបបានអង្គនោះ ។ បទថា **ឧប្បជ្ជិ** គឺ កើតហើយ កើតឡើងហើយ ។ ការមាននៃករុណា ឈ្មោះថា មានសេចក្តីករុណា ក្នុងបទថា **ការុញ្ញតា** ( នេះ ) ។ បទថា **សព្វសត្តេ** ជាពាក្យពោលគ្របដណ្តប់ដល់សត្វ មិនសេសសល់ឡើយ អធិប្បាយថា ពួកសត្វទាំងអស់ ។ គាថានេះ មានអត្ថដូចពោលមកដោយកថា មានប្រមាណប៉ុណ្ណេះ ។

គ្រានោះ ព្រះមានព្រះភាគដែលព្រហ្មទូលអារាធនា ដើម្បីសម្តែងធម៌ ហើយទ្រង់ញ៉ាំងព្រះមហាករុណាឲ្យកើតក្នុងសត្វទាំងឡាយ មានព្រះពុទ្ធបំណងនឹងសម្តែងធម៌ ទើបត្រាស់ព្រះគាថាដល់ព្រហ្មទាំងឡាយថា

ទ្វារនៃព្រះនិព្វាននោះ របើកហើយ សត្វទាំងឡាយណា
មានសោតប្បសាទ សត្វទាំងនោះ ចូរបញ្ចេញនូវសទ្ធាចុះ
បពិត្រព្រហ្ម តថាគតសម្គាល់ នូវសេចក្តីនឿយលំបាក បាន
ជាមិនសម្តែងធម៌ដ៏ឧត្តម ដែលតថាគតស្ទាត់ហើយ ចំពោះ
មនុស្សទាំងឡាយ ដូច្នេះ ។

គ្រានោះ សហម្បតីព្រហ្មដឹងថា ខ្ញុំដែលកាលព្រះមានព្រះភាគ ទ្រង់បើកឱកាស ដើម្បីសម្តែងធម៌ហើយ ទើបផ្គងអញ្ជលីដ៏រុងរឿង ដោយទសនខសមោធាន គឺផ្គុំក្រចកទាំង ១០ លើសិរសា ថ្វាយបង្គំព្រះមានព្រះភាគ

ហើយធ្វើប្រទក្សិណ ដែលពួកព្រហ្មចោមរោមយាងត្រឡប់ទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលប្រទានបេ្ដជ្ញាដល់ព្រហ្មនោះហើយ ទ្រង់ព្រះតម្រិះថា តថាគតគួរសម្ដែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់កើតបរិវិតក្កថា អាឡារ-តាបសជាបណ្ឌិត នឹងដឹងទូទៅដល់ធម៌នេះបានដោយរួសរាន់ ទ្រង់ពិចារណាដោយល្អិតល្អន់ ក៏ដឹងថា អាឡារតាបសនោះ បានស្លាប់កន្លង ៧ ថ្ងៃទៅហើយ ទ្រង់ជ្រាបថា ឧទកតាបសធ្វើកាលកិរិយាហើយ កាលពីពេលព្រលប់ ទ្រង់នឹកដល់បញ្ចវគ្គិយថា ឥឡូវនេះ បញ្ចវគ្គិយនៅឯណាហ្ន៎ ទ្រង់ជ្រាបថា នៅត្រង់ព្រៃឥសិបតនមិគទាយវ័ន ក្រុងពារាណសី លុះរាត្រីអស់ហើយ ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ នាពេលព្រលឹម ទ្រង់កាន់បាត្រ និងចីវរ និមន្តដោយព្រះបាទាអស់ចម្ងាយផ្លូវ ១៨ យោជន៍ តាមផ្លូវ ទ្រង់ជួបអាជីវកឈ្មោះឧបកៈ ទ្រង់ប្រាប់ដល់ឧបកៈថា ទ្រង់ជាព្រះពុទ្ធ ពេលល្ងាចថ្ងៃនោះឯងក៏បានយាងដល់ព្រៃឥសិបតនៈ ក្នុងទីនោះ ទ្រង់ប្រកាសដល់បញ្ចវគ្គិយថាទ្រង់ជាព្រះពុទ្ធ យាងប្រថាប់លើពុទ្ធាសនៈដ៏ល្អដែលបានរៀបចំហើយ ត្រាស់ហៅបញ្ចវគ្គិយ ទ្រង់សម្ដែងធម្មចក្កប្បវត្តនសូត្រ ។

បណ្ដាបញ្ចវគ្គិយភិក្ខុទាំងនោះ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរបញ្ជូនញាណទៅតាមក្រសែទេសនា ចប់សូត្រ ក៏តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយព្រហ្ម ១៨ កោដិ ព្រះសាស្ដាទ្រង់ចាំវស្សាក្នុងទីនោះឯង ស្អែកឡើង ទ្រង់ឲ្យព្រះវប្បត្ថេរ តាំងនៅក្នុងសោតាបត្តិផល ដោយឧបាយនេះឯង ទ្រង់ធ្វើភិក្ខុទាំងនោះឲ្យតាំងនៅក្នុងសោតាបត្តិផលគ្រប់រូបទាំងអស់ ក្នុងថ្ងៃទី ៥ នៃបក្ខ

ទ្រង់ប្រជុំព្រះថេរៈទាំងនោះ ហើយទ្រង់សម្តែងអនត្តលក្ខណសូត្រ ចប់ទេសនា ព្រះថេរៈទាំង ៥ រូប ក៏តាំងនៅក្នុងអរហត្ត ។

កាលនោះ ក្នុងទីនោះឯង ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យរបស់យសកុលបុត្ត និងឃើញកុលបុត្តនោះលះផ្ទះចេញទៅហើយ ទើបត្រាស់ហៅថា មកយស ទ្រង់ធ្វើឲ្យតាំងនៅក្នុងសោតាបត្តិផលទាំងក្នុងរាត្រីនោះឯងស្អែកឡើង ក៏ឲ្យតាំងនៅក្នុងអរហត្ត ។ ក្នុងថ្ងៃដទៃទៀត ទ្រង់ឲ្យជន ៥៤ នាក់ ដែលជាសម្លាញ់របស់យសកុលបុត្ត បួសដោយឯហិភិក្ខុឧបសម្បទា ហើយឲ្យតាំងនៅក្នុងអរហត្ត ព្រះអរហន្តក៏កើតឡើងក្នុងលោកចំនួន ៦១ អង្គយ៉ាងនេះ ព្រះសាស្តាកាលចេញវស្សា ទ្រង់បវារណាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ មានព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកាលបំពេញប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ចូរបែកគ្នា ត្រាច់ទៅប្រកាសធម៌ដល់មនុស្សទាំងឡាយ រហូតលើផែនដីនេះ ។

ពួកអ្នកចូរនៅព្រៃដ៏ស្ងាត់ ប្រកាសសច្ចធម៌របស់តថាគតដល់ ( សត្វ ) លោកជានិច្ច ។

ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកាលធ្វើកិច្ច ជាធម្មទូត ចូរបដិបត្តិដោយល្អ នូវពាក្យរបស់តថាគត ប្រៀនប្រដៅមហាជន ដើម្បីប្រយោជន៍ដល់សន្តិរបស់សត្វទាំងឡាយ ។

ពួកអ្នកមិនមានអាសវៈ ចូរនាំគ្នាបិទនូវទ្វារអបាយទាំងអស់ ចូរនាំគ្នាបើកទ្វារស្ថានសួគ៌ មគ្គ និងផល ។

ពួកអ្នក ចូរមានគុណ មានករុណាជាដើម ជាវិហារធម៌ ចម្រើននូវការដឹង និងសទ្ធាដល់សត្វលោកគ្រប់ប្រការ ដោយទេសនា និងបដិបត្តិ ។

កាលពួកគ្រហស្ថ ធ្វើឧបការៈ ដោយអាមិសទានជានិច្ច ពួកអ្នក ក៏ចូរតបស្នងពួកជនទាំងនោះ ដោយធម្មទានចុះ ។

ពួកអ្នក កាលសម្តែងទន់ជ័យរបស់ឥសី អ្នកស្វែងរកគុណ ក៏ចូរលើកព្រះសទ្ធម្ម កាលការងារដែលគប្បីធ្វើ ធ្វើស្រេចហើយ ក៏ចូរបំពេញប្រយោជន៍ដទៃចុះ ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ទ្រង់បញ្ជូនភិក្ខុទាំងនោះទៅក្នុងទិសទាំងឡាយ ឯព្រះអង្គយាងទៅកាន់ឧរុវេលាបទេស ក្នុងរវាងផ្លូវ ទ្រង់ប្រោសភទ្ទវគ្គិយកុមារ ៣០ នាក់ ត្រង់ព្រៃកប្បាស បណ្តាកុមារទាំង ៣០ នាក់នោះ បុគ្គលដែលមានគុណតិចជាងអ្នកទាំងអស់ ក៏ជាសោតាបន្ន បុគ្គលដែលមានគុណយ៉ាងខ្ពស់ ក៏ជាអនាគាមី តែបុរសម្នាក់ ជាព្រះអរហន្ត និងជាបុថុជ្ជនមិនមានឡើយ ទ្រង់ញុំាងកុមារទាំងនោះឲ្យបួសដោយឯហិភិក្ខុទាំងអស់ ហើយទ្រង់បញ្ជូនទៅក្នុងទិសទាំងឡាយ ទ្រង់ឯងកាលយាងដល់ឧរុវេលាបទេសហើយ ទ្រង់សម្តែងបាដិហារ្យ ៣៥០០ ទូន្មានជដិល ៣ នាក់បងប្អូន មានឧរុវេលកស្សបៈជាដើម និងជដិលបរិវារ ១០០០ រូប ទ្រង់ឲ្យ

បួសដោយឯហិភិក្ខុហើយ ឲ្យអន្តុយប្រជុំគ្នា ត្រង់គយាសីសបទេស ឲ្យតាំងនៅក្នុងអរហត្ត ដោយទេសនាឈ្មោះអាទិត្តបរិយាយសូត្រ មានភិក្ខុសង្ឃ ១០០០ រូបចោមរោមហើយ យាងទៅកាន់លដ្ឋិវនឧទ្យាន ដែលជាឧបចារៈនៃក្រុងរាជគ្រឹះ ដោយពុទ្ធបំណង ដោះនូវពាក្យប្តេជ្ញាដល់ព្រះបាទពិម្ពិសារ ។ បន្ទាប់អំពីនោះ អ្នកយាមព្រះរាជឧទ្យានទូលដល់ព្រះរាជាៗ ស្តាប់ថា ព្រះសាស្តាយាងមកហើយ មានព្រាហ្មណ៍ និងគហបតី ១២ ម៉ឺនចោមរោម ចូលគាល់ព្រះទសពល ដែលទ្រង់ដូចព្រះអាទិត្យនៃព្រះមុនីដ៏ប្រសើរ ដែលទ្រង់នៅក្នុងចន្លោះនៃព្រៃ ដូចព្រះអាទិត្យនៅក្នុងចន្លោះពពក ទ្រង់ឱនព្រះសិរសាដ៏រុងរឿងដោយពន្លឺនៃមកុដមណី ទៀបព្រះយុគលបាទរបស់ព្រះទសពល ដែលជេរជាសដោយកោមុទ ដែលជាផ្កាទឹកមិនមានមន្ទិល មិនវិកល ដែលមានផ្ទៃព្រះបាទប្រដាប់ដោយចក្រ ហើយប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាង មួយអន្លើដោយរាជបរិវារ ។

គ្រានោះ ព្រាហ្មណ៍ និងគហបតីទាំងនោះ ក៏កើតបរិវិតក្កថា ព្រះមហាសមណៈ ទ្រង់ប្រព្រឹត្តព្រហ្មចរិយៈក្នុងឧរុវេលកស្សបៈ ឬឧរុវេលកស្សបៈប្រព្រឹត្តព្រហ្មចរិយៈក្នុងមហាសមណៈ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបបរិវិតក្ករបស់ព្រាហ្មណ៍ និងគហបតីទាំងនោះ ទើបបានត្រាស់នឹងព្រះថេរៈដោយព្រះគាថា ( ក្នុងព្រះវិនយបិដក មហាវគ្គ ) ថា

អ្នកឯងនៅក្នុងឧរុវេលាប្រទេស ជាអ្នកប្រដៅពួកតាបស តើ
អ្នកឃើញអ្វី បានជាលះបង់ការបូជាភ្លើងចោលចេញ ។ ម្នាល

កស្សបៈ តថាគតសួរសេចក្ដីនេះនឹងអ្នក ការបូជាភ្លើងដែល អ្នកលះបង់ហើយ តើព្រោះហេតុអ្វី ដូច្នេះ ។

ព្រះថេរៈជ្រាបពុទ្ធបំណងរបស់ព្រះមានព្រះភាគ ទើបពោលគាថា នេះថា

ជនទាំងឡាយ តែងពោលសរសើរ ចំពោះនូវកាមទាំងឡាយ គឺរូប សំឡេង ព្រមទាំងរសផង នូវស្រីទាំងឡាយផង ព្រោះ ការបូជា ខ្ញុំព្រះអង្គដឹងថា កាមគុណ មានរូបជាដើមនេះ ជា គ្រឿងសៅហ្មងក្នុងឧបធិទាំងឡាយ ព្រោះហេតុដូច្នោះ ខ្ញុំ ព្រះអង្គមិនត្រេកអរក្នុងការបូជាធំ និងការបូជាតូច ( គឺការ គោរពភ្លើងរាល់ថ្ងៃ ) ដូច្នេះ ។

ហើយបង្អោនសិរសា ទៀបយុគលបាទរបស់តថាគត ដើម្បីប្រកាស នូវភាពដែលខ្លួនជាសាវ័ក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមាន ព្រះភាគ ទ្រង់ជាសាស្ដារបស់ខ្ញុំព្រះអង្គៗ ជាសាវ័ក ហើយក៏ហោះឡើងទៅ កាន់អាកាស ៧ ដង ម្ដងកម្ពស់ ១ ជួរដើមត្នោត ២ ដង ពីរជួរដើមត្នោត ។បេ។ ៧ ដង ប្រាំពីរជួរដើមត្នោត ធ្វើបាដិហារ្យហើយ ចុះអំពីអាកាស ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

កាលនោះ មហាជនឃើញបាដិហារ្យរបស់ព្រះថេរៈហើយ គិតថា ឱ ! ធម្មតាព្រះពុទ្ធទាំងឡាយ មានអានុភាពច្រើន ឧរុវេលកស្សបៈ មានទិដ្ឋិរឹង ត្អឹង សម្គាល់ខ្លួនថាជាអរហន្ត ក៏ត្រូវព្រះតថាគតទម្លាយនូវសំណាញ់ គឺទិដ្ឋិ

ទូន្មានហើយ ក៏នាំគ្នាសរសើរគុណរបស់ព្រះតថាគត ។ ព្រះសាស្តាទ្រង់ស្តាប់រឿងនោះហើយ ត្រាស់ថា តថាគតមិនមែនទូន្មានឧរុវេលកស្សបៈនេះតែក្នុងជាតិនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីត ឧរុវេលកស្សបៈនេះ តថាគតក៏ទូន្មានហើយដូចគ្នា ។ កាលនោះ មហាជនក្រោកឡើងអំពីទីអង្គុយ ថ្វាយបង្គំព្រះមានព្រះភាគ ផ្គងអញ្ជលីលើសិរសាក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ជាតិនេះ ឧរុវេលកស្សបៈត្រូវទូន្មាន ពួកខ្ញុំព្រះអង្គឃើញហើយ ចុះក្នុងអតីតជាតិ ព្រះមានព្រះភាគទ្រង់ទូន្មានដូចម្តេច ។ បន្ទាប់អំពីនោះ ព្រះសាស្តា កាលមហាជនទូលអារាធនាហើយ ទើបត្រាស់មហានារទកស្សបជាតក ដែលអន្តរកពបិទបាំង ហើយទ្រង់ប្រកាសអរិយសច្ច ៤ ព្រះបាទពិម្ពិសារទ្រង់ស្តាប់ធម្មកថារបស់ព្រះសាស្តា ទ្រង់តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយរាជបរិវារ ១១ ម៉ឺននាក់ ឯ ១ ម៉ឺនរូបទៀត ប្រកាសខ្លួនជាឧបាសក ។ ព្រះរាជាទ្រង់ដល់នូវសរណៈ ហើយនិមន្តព្រះមានព្រះភាគមួយអន្លើដោយភិក្ខុសង្ឃ ដើម្បីសោយក្នុងថ្ងៃស្អែក ទ្រង់ធ្វើប្រទក្សិណព្រះមានព្រះភាគ ៣ ដង ហើយថ្វាយបង្គំ យាងត្រឡប់ ។

ស្អែកឡើង ព្រះមានព្រះភាគ ដែលភិក្ខុ ១០០០ រូបចោមរោមហើយ យាងទៅកាន់ក្រុងរាជគ្រឹះ ដូចសក្កទេវរាជសហស្សនេត្រ ដែលពួកទេវតាចោមរោមហើយ ដូចស្តេចមហាព្រហ្ម ដែលមហាព្រហ្មហែហមហើយ ព្រះរាជាថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងវេលាសោយស្រេចហើយ ក៏ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ

មិនអាចវៀរព្រះត្រៃរត្នបាន ខ្ញុំព្រះអង្គនឹងមកគាល់ព្រះមានព្រះភាគ ក្នុងកាលខ្លះ មិនមែនកាលខ្លះ ឈ្មោះថា ឧទ្យានលដ្ឋិវ័ននៅឆ្ងាយពេក ឯឧទ្យានឈ្មោះវេឡុវ័នរបស់ខ្ញុំព្រះអង្គនេះ សម្រាប់អ្នកត្រូវការវិវេក មិនឆ្ងាយពេក មិនជិតពេក ដល់ព្រមដោយផ្លូវទៅមក មិនមានមនុស្សរំខាន ជាឧទ្យានស្ងាត់ ប្រកបដោយសេចក្ដីសុខ សម្បូរដោយម្លប់ និងទឹក ប្រដាប់ដោយផ្ទាំងថ្ម ជាទីត្រជាក់ ជាភូមិភាគគួរជាទីត្រេកអរយ៉ាងក្រៃលែង មានដើមឈើល្អត្រកាល មានផ្កាក្រអូប ជានិច្ចនិរន្តរ ប្រដាប់ទៅដោយប្រាសាទកំពូល ប្រាសាទត្រងិល វិហារដូចវិមាន មានអឌ្ឍយោគ និងមណ្ឌបជាដើម សូមព្រះមានព្រះភាគ ទ្រង់ទទួលឧទ្យានវេឡុវ័ននេះរបស់ខ្ញុំព្រះអង្គចុះ ហើយទ្រង់កាន់យកទឹក មានពណ៌ដូចកែវមណី ដែលអប់ដោយផ្កា មានក្លិនក្រអូបដោយឈ្មោកមាសក្រហមដូចរងើកភ្លើង ។ កាលទ្រង់បរិច្ចាគវេឡុវ័នារាម ទ្រង់ក៏ប្រូចទឹកលើព្រះហស្ដរបស់ព្រះទសពល ។ ក្នុងការទទួលអារាមនោះ មហាប្រឹថពីនេះ ក៏ធ្លាក់នៅក្នុងអំណាចបីតិថា ឫសគល់របស់ព្រះពុទ្ធសាសនាចាក់គ្រឹះហើយ ក៏រង្គោះញាប់ញ័រ ។ ធម្មតាសេនាសនៈដទៃ ដែលព្រះមានព្រះភាគទ្រង់ទទួលហើយ ផែនដីកម្រើក វៀរវេឡុវ័នមហាវិហារចេញមិនមាន ក្នុងជម្ពូទ្វីប ។ គ្រានោះ ព្រះសាស្ដាទ្រង់ទទួលវេឡុវ័នារាម ហើយទ្រង់បានធ្វើអនុមោទនាវិហារទានថា

បុរសណាម្នាក់ អាចពោលអានិសង្សនៃអាវាសបាន ក្រៅអំពី
ព្រះពុទ្ធជាលោកនាថ មាត់មនុស្ស ១ ម៉ឺន ក៏មិនគ្រប់គ្រាន់ ។

នរជនណាថ្វាយលំនៅដល់សង្ឃ នរជននោះ លោកពោលថា ឲ្យនូវអាយុ ពណ៌សម្បុរ សេចក្ដីសុខ កម្លាំង និងបដិភាណ ដ៏ប្រសើរ ដែលព្រះពុទ្ធសរសើរហើយ ។

ព្រោះបុគ្គលថ្វាយទីនៅ ការពារនូវឧបទ្ទវនៃជីវិត មានត្រជាក់ជាដើម រមែងរក្សាអាយុរបស់បុគ្គលនោះទុកបាន ហេតុនោះ ទើបសប្បុរសទាំងឡាយ ហៅបុគ្គលនោះថា ជាអ្នកឲ្យអាយុ ។ កម្លាំងក្ដី ពណ៌សម្បុរក្ដី បដិភាណក្ដី មិនមានដល់បុគ្គល ដែលនៅក្នុងទីក្ដៅពេក ត្រជាក់ពេក ព្រោះហេតុនោះឯង អ្នកឲ្យវិហារជាលំនៅនោះ ទើបឈ្មោះថា ឲ្យនូវកម្លាំង ពណ៌សម្បុរ និងភាពឈ្លាសវៃនោះឯង ។

អ្នកឲ្យវិហារ ឈ្មោះថា ឲ្យនូវសុខជានិច្ច ព្រោះការពារនូវទុក្ខច្រើនយ៉ាង ដែលកើតអំពីត្រជាក់កម្ដៅ សត្វលូន សត្វវារ ខ្យល់ កម្ដៅថ្ងៃជាដើម ក្នុងលោក ។

ព្រោះអ្នកថ្វាយវិហារ រមែងការពារនូវទុក្ខ មានត្រជាក់ ក្ដៅ ខ្យល់ កម្ដៅថ្ងៃ របោម ភ្លៀង សត្វលូនវារ និងសត្វសាហាវជាដើមបាន ហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា បាននូវសេចក្ដីសុខក្នុងបរលោក ។

បុគ្គលណា មានចិត្តជ្រះថ្លា ត្រេកអរហើយ ក្នុងការឲ្យវិហារ ដែលជាហេតុនៃភព និងភោគៈ ដែលគួរជាទីត្រេកអរនៃចិត្ត ដល់លោកអ្នកមានសីលគុណជាដើម ដែលកើតហើយ បុគ្គល

នោះ លោកហៅថា ជាអ្នកឲ្យសព្វយ៉ាង ។

បុគ្គលណាលះមន្ទិល គឺសេចក្ដីកំណាញ់ មួយអន្ទើដោយលោភៈ ឲ្យនូវវិហារដល់លោកអ្នក មានគុណនៅអាស្រ័យបុគ្គលនោះ ដូចត្រូវអ្នកដទៃលើកទៅដាក់ក្នុងស្ថានសួគ៌នោះ រមែងកើតជាបុគ្គលប្រាសចាកសេចក្ដីសោក ដល់នូវសម្បត្តិដែលរុងរឿង ។

នរជនសាងវិហារមាសដ៏ប្រសើរឱឡារ និមន្តភិក្ខុទាំងឡាយឲ្យនៅក្នុងវិហារនោះ គប្បីឲ្យបាយទឹក និងសំពត់ ដល់ភិក្ខុទាំងនោះ ដោយចិត្តជ្រះថ្លា ដោយគោរពជានិច្ចចុះ ។

ព្រោះហេតុនោះ មហាបពិត្រ សូមទ្រង់សោយភោគៈ ដែលគួរជាទីត្រេកអរក្នុងភពទាំងឡាយជាកិយោ្យភាព ដោយផលនៃវិហារទាន ខាងក្រោយទ្រង់នឹងជួបនូវធម៌ដ៏សុខស្ងប់ មិនមានសេចក្ដីសោក ដូច្នេះ ។

ព្រះសាស្ដាជាស្ដេចនៃអ្នកប្រាជ្ញ កាលទ្រង់ធ្វើអនុមោទនាវិហារទានដល់ព្រះបាទពិម្ពិសារ ដែលជាកំពូលនៃនរជន ដោយប្រការដូច្នេះហើយ ទ្រង់ក៏ក្រោកចាកអាសនៈ មានភិក្ខុសង្ឃចោមរោមហើយ កាលទ្រង់ធ្វើនគរព្រៃនិងវិមានជាដើមឲ្យក្រហម ដូចស្រោចដោយទឹកមាស ដោយព្រះរស្មីនៃព្រះសរីរៈរបស់ព្រះអង្គ ដែលគួរពិតពិលរមិលក្រៃលែង យាងចូលកាន់វេឡុវនមហាវិហារ ដោយព្រះពុទ្ធលីលា គ្មានអ្វីប្រៀបដោយពុទ្ធសិរី មិន

មានទីបំផុត ។

ព្រះតថាគតជាស្ដេចនៃអ្នកប្រាជ្ញ ទ្រង់គង់នៅក្នុងវេឡុវន-
មហាវិហារ ដែលមិនមែនជាទីលេង តែគួរជាទីត្រេកអរនៃចិត្ត
ដោយវិហារធម៌ផ្សេងៗ ទ្រង់ប្រមើលមើលវេនេយ្យសត្វ
ទាំងឡាយ ។

កាលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវេឡុវនវិហារនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានដំណឹងថា កូនរបស់យើងធ្វើទុក្ករកិរិយា ៦ ឆ្នាំ សម្រេចនូវអភិសម្ពោធិញ្ញាណដ៏កំពូល ប្រកាសធម្មចក្រដ៏ប្រសើរ យាងដល់ក្រុងរាជគ្រឹះ ទ្រង់គង់នៅក្នុងវេឡុវនមហាវិហារ ទ្រង់ហៅមហាអាមាត្យម្នាក់ មកត្រាស់ថា នែអ្នក ចូរអ្នក មួយអន្លើដោយបុរស ១០០០ ជាបរិវារ ទៅកាន់នគររាជគ្រឹះ និយាយតាមពាក្យរបស់យើងថា ព្រះបាទសុទ្ធោទន-មហារាជបិតារបស់ព្រះអង្គ មានបំណងចង់ជួប ហើយចូរនាំកូនរបស់យើងមក ។

មហាមាត្យនោះ ទទួលព្រះរាជឱង្ការហើយ មានបុរស ១០០០ ជាបរិវារ ធ្វើដំណើរ ៦០ យោជន៍ ចូលទៅកាន់វិហារក្នុងពេលទ្រង់សម្ដែងធម៌ មហាមាត្យនោះ គិតថា ដំណឹងដែលព្រះរាជាបញ្ជូនមក ស្ទះសិនចុះ ឈរខាងចុងបរិស័ទ ស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ទាំងកំពុងឈរនោះឯងក៏បានសម្រេចអរហត្ត មួយអន្លើដោយបុរស ១០០០ នាក់ ទូលសូមបព្វជ្ជា ព្រះសាស្ដាទ្រង់លាព្រះហស្តត្រាស់ថា **ឯថ ភិក្ខវោ** ពួកអ្នកចូរមកជាភិក្ខុចុះ

ជនទាំងអស់នោះ ក៏ទ្រទ្រង់នូវបាត្រ និងចីវរសម្រេចដោយឫទ្ធិ ដល់ព្រម ដោយកិរិយាដែលសមគួរដល់សមណៈ ដូចព្រះថេរៈមានវស្សា ១០០ ចោម រោមព្រះមានព្រះភាគ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា បុគ្គលដែលទៅក៏មិនឃើញមក ដំណឹងក៏មិន បានឮ ទ្រង់បញ្ជូនអមាត្យទៅអស់ ៩ ដង ដោយទំនងនេះឯង បណ្ដាបុរស ៩០០០ នាក់នោះ សូម្បីតែម្នាក់ ក៏មិនបានក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ទាំងមិនបញ្ជូនដំណឹងម្ដងម្កាល សម្រេចអរហត្តហើយ នាំគ្នាបួសអស់ ។

គ្រានោះ ព្រះរាជាទ្រង់ព្រះតម្រិះថា អ្នកណាហ្ន៎ នឹងធ្វើតាមពាក្យរបស់ អញ ទ្រង់ពិចារណាមើលពលរបស់ស្ដេចទាំងអស់ ក៏បានឃើញឧទាយិ- អមាត្យ ។ បានឮមកថា ឧទាយីនោះ ជាអមាត្យសម្រេចរាជកិច្ចទាំងអស់ របស់ព្រះរាជា ជាមនុស្សខាងក្នុង មានការស្និទ្ធស្នាលក្រៃពេក កើតក្នុងថ្ងៃ តែមួយ ជាមួយព្រះពោធិសត្វ ជាសម្លាញ់លេងដីជាមួយគ្នា ។ កាលនោះ ព្រះរាជាទ្រង់ហៅឧទាយិអមាត្យមកហើយ ត្រាស់ថា នែឧទាយី អញបំណង ជួបព្រះឱរស ទើបបញ្ជូនបុរសទៅអស់ ៩០០០ នាក់ សូម្បីតែម្នាក់ ដែល មកប្រាប់ដំណឹងក៏មិនមាន អន្តរាយនៃជីវិតរបស់អញ ដឹងបានដោយលំបាក អញចង់ជួបព្រះរាជឱរសទាន់នៅមានជីវិត បាអាចនាំឱរសមកបង្ហាញដល់ អញ បានឬទេ ។

ឧទាយិអមាត្យក្រាបទូលថា បពិត្រព្រះអង្គ បាន បើទូលបង្គំបានបួស ព្រះរាជាត្រាស់ថា បាបួស ឬមិនបួស ក៏ស្រេចតែបាចុះ តែត្រូវនាំកូនរបស់

យើងមក ។

ឧទាយិអមាត្យទទួលព្រះរាជតម្រាស់ហើយ ក៏នាំដំណឹងរបស់ព្រះរាជាទៅដល់ក្រុងរាជគ្រឹះ ។ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ក៏សម្រេចអរហត្ត មួយអន្លើនឹងបុរស ១០០០ នាក់ តាំងនៅក្នុងឯហិភិក្ខុភាវៈហើយ លុះដល់ថ្ងៃពេញបូណ៌មី ខែផល្គុណ គិតថា ហេមន្តរដូវកន្លងទៅហើយ វសន្តរដូវក៏ចូលមកដល់ ដងព្រៃមានផ្ការីកស្រស់បំព្រង ផ្លូវក៏សមគួរដល់ការដើរ ជាកាលសមគួរ ដែលព្រះទសពលធ្វើសេចក្តីសង្គ្រោះដល់ពួកព្រះញាតិ គ្រាត្រិះរិះហើយ ក៏ចូលគាល់ព្រះមានព្រះភាគ ពណ៌នាគុណនៃពុទ្ធ-ដំណើរ ដើម្បីចូលទៅកាន់របស់ត្រកូលដោយគាថាប្រមាណ ៦០ គាថាថា

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើមានពណ៌ដូចរងើក
ភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះ
រុងរឿង ដូចជាអណ្តាតភ្លើង បពិត្រព្រះអង្គ មានព្យាយាមធំ
កាលនេះ ជាកាលគួរបានចំណែកធម្មរសហើយ ។

ដើមឈើទាំងឡាយល្អរុងរឿង ដោយពន្លកពណ៌ក្រហម និង
ស្លឹកខ្ចី ហាក់បីដូចមណ្ឌបដែលរុងរឿងដោយរតនៈ បពិត្រ
ព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះ
អង្គីរសហើយ ។

ដើមឈើទាំងឡាយត្រន់ត្រយមានផ្ការីកល្អ ប្រដាប់ដោយផ្កា
ទាំងឡាយ គួរជាទីត្រេកអរនៃចិត្ត ផ្កាស្រស់ល្អ មានក្លិន

ក្រអូប យោនយានសងខាងផ្លូវ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ដើមឈើដ៏ល្អទាំងឡាយ ក្នុងឱកាសសងខាងផ្លូវ ដេរដាស ដោយផ្លែដ៏ច្រើន បន្ទោបង់នូវចំណាង់ និងការស្រេកឃ្លានបាន បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ដើមឈើទាំងឡាយ មានផ្កាល្អ ស្លឹកខ្ចី ស្រស់ស្អាត ដូចគេតាក់តែងហើយ បក់ទៅមក ដូចកន្ទុយក្ងោក យោនយានសងខាងផ្លូវ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ដើមឈើទាំងឡាយរុងរឿង ដែលផ្កា និងស្លឹកខ្ចីតាក់តែងហើយ ចោលក្លិនក្រអូប រមែងលួងលោមចិត្តពួកសត្វ ដែលហត់នឿយ ក្នុងការដើរផ្លូវឆ្ងាយ បពិត្រព្រះមហាវីរៈ ( នេះ ) ជា ម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

វល្លិជាច្រើន អាស្រ័យគុម្ពឈើក្នុងព្រៃ ខាងចុងនៃត្រួយ មានផ្ការីកល្អ រមែងលួងលោមពួកសត្វ ដូចមណ្ឌបកែវមណី បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

វល្លិជាច្រើន អាស្រ័យនៅនឹងដើមឈើ ហាក់បីដូចស្រីក្រមុំ

នៅរួមជាមួយបុរសជាទីស្រឡាញ់ មានក្លិនក្រអូបឈ្ងុយឈ្ងប់ លួងលោមនូវចិត្ត បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ហ្វូងបក្សី មានពណ៌ដ៏ល្អ គួរជាទីរីករាយនៃចិត្ត មានពណ៌ខៀវជាដើម បន្លឺសំឡេងពីរោះដោយជុំវិញ ដោយសេចក្តីត្រេកអរ លួងលោម ( នូវចិត្ត ) បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ហ្វូងម្រឹគច្រើនប្រភេទ ដេរដាស អើតក្បាល បើកភ្នែកគួរត្រេកអរ នាំគ្នារត់ឆ្វេឆ្វាសព្វទិស បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ផ្ទៃប្រឹថពី មានស្បូវភ្លាំងដុះខៀវស្រងាត់ដោយជុំវិញ គួរជាទីត្រេកអរនៃចិត្ត ដើមឈើមានផ្កាដ៏ល្អ ក៏ប្រដាប់ដូចមោលីបពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ខ្សាច់ទាំងឡាយ ដូចកែវមុក្តា ដែលធម្មជាតិតាក់តែងទុករាត់រាយយ៉ាងល្អ ឲ្យនូវសម្ផស្សជាទីសប្បាយ បញ្ចេញពន្លឺសព្វទិស បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ផ្ទៃប្រឹថពីស្អាត រៀបស្មើ មានសម្ផស្សល្អ អប់ដោយក្លិន

ដែលកើតអំពីផ្កាឈើក្រអូប ឈ្ងុយឈ្ងប់ គួរជាទីត្រេកអរ ជាផ្កាមានពន្លឺស្រស់ស្អាត បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ព្រៃធំ ដែលធម្មជាតិតាក់តែងល្អហើយ ប្រដាប់ដោយដើមឈើច្រើនប្រភេទ រៀងគ្នាស្រស់ត្រកាល មានក្លិនក្រអូប គួរជាទីត្រេកអរ ដូចនន្ទនវ័ន បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ស្រះទាំងឡាយ ច្រើនប្រភេទ វិចិត្រគួរជាទីត្រេកអរនៃចិត្ត ដែលធម្មជាតិតាក់តែងទុក មានបុណ្ឌរីក ពេញដោយទឹកថ្លាត្រជាក់ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ស្រះទាំងឡាយ រុងរឿងដោយឈូកច្រើនប្រភេទ ផ្ការីកល្អ មានក្លិនឈ្ងុយឈ្ងប់ ធ្វើឲ្យពួកមនុស្ស និងទេវតាត្រេកអរ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ហ្វូងបក្សី ទំត្រង់គុម្ពឈូកដែលរីក ស្រែកខ្សៀវខ្សារ ដោយជុំវិញ បក្សីទាំងនោះ ត្រេកអរជាមួយបក្សីញី បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ហ្វូងឃ្មុំក្រេបលម្អងអំពីផ្កាដែលរីក បន្លឺសំឡេងហ៊ឹងៗ ហើរក្រឡឹងក្លិន ទឹកផ្អែមក៏ខ្ចរខ្ចាយទៅកាន់ទិសផ្សេងៗ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ហ្វូងដីរីចុះប្រេង បន្លឺសំឡេង ដើរចេញអំពីញកភ្នំ ក្រខៀវទឹកក៏ក្លីផ្ទេក ហូរអំពីស្ទឹង បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ភ្នំទាំងឡាយ ប្រាកដឃើញជុំវិញ មានពណ៌ខៀវស្រងាត់ដូចផ្ទួតកក្ងោក ក្លីដូចមេឃ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ហ្វូងក្ងោកមួយអន្លើដោយក្ងោកញីនាំគ្នាពែនពង់ លើកំពូលភ្នំ បន្លឺសំឡេងដ៏ពីរោះផ្សេងៗ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ហ្វូងបក្សីជាច្រើន មានសំឡេងពីរោះ គួរជាទីត្រេកអរដេរដាសដោយបក្សី ដែលមានស្លាបស្អាត ស្រែកយំល្វេងល្វើយ លើកំពូលភ្នំ បពិត្រព្រះមហាវីរៈ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ភ្នំទាំងឡាយ មានផ្កាឈើរីកល្អដេរដាសដោយដើមសង្ស័រប្រដាប់ដោយត្របកផ្កាឈើច្រើនប្រភេទ មានក្លិនក្រអូប ល្អ

គ្រប់ទិស បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ជលាល័យ មានក្លិនក្រអូបខ្លាំង មានពន្លឺហូរមកអំពីស្ទឹង ដូច ជលាល័យ ក្នុងឧទ្យានរបស់សក្កទេវរាជ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ស្ទឹងទាំងឡាយ ប្រដាប់ដោយកំពង់ដ៏ល្អ ជាទីដែលហ្វូងម្រឹគ និងហ្វូងបក្សីច្រើនប្រភេទចុះផឹក គួរជាទីត្រេកអរនៃចិត្ត ហូរ បាចសាច បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

គុម្ពឈើដ៏ស្អាត មានក្លិនក្រអូប ចេញផ្ការីក ក្នុងជលាល័យ ទាំងសងខាងច្រាំង ត្រួយប្រដាប់ដោយផ្កា ស្រស់ត្រកាល បពិត្រព្រះមហាវីរៈ( នេះ ) ជាសម័យ សម្រាប់ព្រះអង្គីរស នោះហើយ ។

ដងព្រៃ ដេរដាសដោយជួរនៃដើមឈើច្រើនប្រភេទ មានក្លិន ក្រអូប ល្អដូចសួននន្ទនវ័នរបស់ទេវតា ជាទីត្រេកអរនៃចិត្ត ក្រៃលែងរបស់បុគ្គលដែលទៅរឿយៗ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

បាយទឹកដ៏ស្អាតច្រើនប្រភេទ ដល់ព្រមដោយសម្ភ ប្រកប ដោយរសឆ្ងាញ់ រកបានដោយងាយ ក្នុងស្រុកក្បែរផ្លូវ គួរជាទី

ត្រេកអរនៃចិត្ត បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យ
សមគួរ សម្រាប់ព្រះអង្គីរសហើយ ។
ផែនដីមានពណ៌ដ៏វិចិត្រ ដោយអាសនៈផ្កា ក្លិនក្រអូប ដោយ
ជុំវិញ ក្នុងពេលរាត្រី ក៏ប្រដាប់ដោយអំពិលអំពែកទាំងឡាយ
បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់
ព្រះអង្គីរសហើយ ។
ជនទាំងឡាយ ប្រកបដោយគុណ មានសទ្ធាជាដើមដ៏បរិសុទ្ធ
ប្រាថ្នាក្រែលែងនូវព្រះសម្ពុទ្ធរាជា មានជាច្រើន ជុំវិញក្នុង
ផែនដីនោះឯង បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យ
សមគួរ សម្រាប់ព្រះអង្គីរសហើយ ។
ស្រះបោក្ខរណី ដ៏ល្អគួរត្រេកត្រអាល គ្របដណ្ដប់ដោយ
ឈូកច្រើនប្រភេទដ៏ល្អ រមែងបង្អុរនូវរស ដូចទឹកដោះអំពី
ក្រអៅឈូកទាំងឡាយ បពិត្រព្រះមហាវីរៈ ( នេះ ) ជា
សម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។
ដើមឈើគួរជាទីត្រេកអរទាំងឡាយ ប្រដាប់ដោយស្លឹកពណ៌
ខៀវ ស្រស់ត្រកាល ខ្ពស់ត្រដែត ក្នុងឱកាសសងខាងផ្លូវ
ជាទីប្រជុំរបស់សត្វ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យ
សមគួរ សម្រាប់ព្រះអង្គីរសហើយ ។
ព្រៃមានពណ៌ដូចមេឃ គឺដើមឈើខៀវស្រងាត់ មានផ្កាល្អ

ក្រអូបគ្រប់វេជ្ជ ដូចនន្ទនវ័ន ក្នុងភពរបស់ព្រះឥន្ទ្រ បពិត្រ ព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះ អង្គីរសហើយ ។

ផ្លូវល្អគ្រប់យោជន៍ ស្រុកមានអាហារល្អ រកបានងាយ គួរ ជាទីត្រេកអរ មានមនុស្សក្រុះករ មានបាយទឹករកបានងាយ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ ព្រះអង្គីរសហើយ ។

សាលាធំ និងសភាជាទីប្រជុំ មានម្ហូប និងទឹកច្រើន គួរជាទី ត្រេកអរ ប្រគល់មកនូវសេចក្តីសុខគ្រប់យ៉ាង ដល់បុគ្គល ដែលនៅអាស្រ័យ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យ សមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ស្រះបោក្ខរណីដ៏ល្អ ក្នុងឧទ្យាន គួរជាទីត្រេកអរនៃចិត្ត ប្រដាប់ ដោយជួរនៃដើមឈើច្រើនប្រភេទដ៏ល្អ ដែលធម្មជាតិសាងទុក មានក្លិនក្រអូបឈ្ងុយឈ្ងប់ នាំឲ្យសម្រេចប្រយោជន៍ បពិត្រ ព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ ព្រះអង្គីរសហើយ ។

ខ្យល់ស្រទន់ត្រជាក់ជាសុខ ( បក់មក ) ផ្ទៃមេឃ ក៏ប្រាស ចាកពពក ដោយជុំវិញ ទិសទាំងឡាយ ក៏ភ្លឺស្វាងទាំងអស់ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់

ព្រះអង្គីរសហើយ ។

ភ្លៀងធ្លាក់តិចៗ ក្នុងរាត្រី ដើម្បីមិនឲ្យល្អងធូលីហុយឡើង ត្រង់ផ្លូវ ព្រះអាទិត្យក្នុងលម្ហមេឃ ក៏មានពន្លឺស្រទន់ បពិត្រ ព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះ អង្គីរសហើយ ។

ហ្វូងដំរីចុះប្រេង ជាសត្វមានប្រមោយ លេងជាមួយនឹងដំរីញី ទាំងឡាយ បន្លឺសំឡេង ឆ្លេឆ្លាទៅជុំទិស បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ព្រៃខៀវស្រស់ គួរពិតពិលរមើលមើលក្រៃលែង គួរជាទី ត្រេកអរ ជារបស់គួរចម្លែកសម្រាប់អ្នកសម្លឹងមើល ដូច កំពូលពពកពណ៌ខៀវ បពិត្រព្រះមហាវីរៈ ( នេះ ) ជា សម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ផ្ទៃមេឃ ប្រាសចាកពពក គួរជាទីត្រេកអរ ទិសទាំងពួង ហាក់ដូចប្រដាប់ដោយវត្ថុដែលធ្វើដោយកែវមណី ដ៏រុងរឿង បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ ព្រះអង្គីរសហើយ ។

ពួកគន្ធព្វ ពិទ្យាធរ និងពួកកិន្នរ ច្រៀងដោយសំឡេងដ៏ពីរោះ នាំគ្នាត្រាច់ទៅក្នុងព្រៃធំ ដែលគួរជាទីត្រេកអរនោះ បពិត្រ ព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះ

អគ្គីវេសហើយ ។

ព្រៃដែលពួកអ្នកមានតបៈ ដែលខ្ចាចអំពីពួកកិលេស របស់ខ្លួនឯង សេពហើយ ជាជម្រកដែលគួរត្រេកអរ ដែលសម្រេចប្រយោជន៍ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរសម្រាប់ព្រះអគ្គីវេសហើយ ។

ព្រៃឲ្យសម្រេចផលផ្សេងៗ មិនច្រឡូកច្រឡំ ជាទីគួរត្រេកអរក្រៃលែងនៃចិត្តជានិច្ច ចម្រើននូវសមាធិចិត្ត និងបីតិ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអគ្គីវេសហើយ ។

ព្រៃដែលហ្វូងបក្សីជាច្រើន សេពនៅជានិច្ច ពួកមនុស្សអំពីស្រុកមួយ ទៅកាន់ស្រុកមួយ ក៏នៅជាប្រចាំ ស្រុកទាំងឡាយ ក៏ក្លាយជានគរមួយៗ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអគ្គីវេសហើយ ។

ប្រជុំជនជាច្រើន អាស្រ័យសំពត់ បាយទឹក ទីអង្គុយ ទីដេក គ្រឿងក្រអូប កម្រងផ្កា និងគ្រឿងលាប ក៏សម្រេចប្រយោជន៍ក្នុងស្រុកនោះ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអគ្គីវេសហើយ ។

ជនទាំងឡាយ ដល់នូវភាពប្រសើរនៃយសគ្រប់យ៉ាង ដោយបុញ្ញឫទ្ធិ ស្តុកស្តម្ភដោយភោគៈផ្សេងៗ ជាច្រើន រស់នៅជា

សុខក្នុងស្រុកនោះ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ពពកក្នុងលម្ហមេឃ ក៏មានពណ៌បរិសុទ្ធ ព្រះចន្ទជះពន្លឺទៅសព្វទិស ក្នុងពេលរាត្រី ខ្យល់ក៏បក់ត្រសៀកៗ ជាខ្យល់ត្រជាក់ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរសម្រាប់ព្រះអង្គីរសហើយ ។

លុះព្រះចន្ទរះឡើង ជនទាំងឡាយក៏ត្រេកអរ សន្ទនាគ្នាតែរឿងដែលល្អ ក្នុងផ្ទះរបស់ខ្លួន ត្រេកអរក្រៃលែង ជាមួយជនជាទីស្រឡាញ់ទាំងឡាយ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

រស្មីនៃព្រះចន្ទ ភ្លឺពេញអាកាស ផ្ទៃពសុធាក៏មានរស្មីបរិសុទ្ធគួរជាទីត្រេកអរនៃចិត្ត ទិសទាំងឡាយ ក៏បរិសុទ្ធទាំងអស់ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ព្រោះត្រូវរស្មីនៃព្រះចន្ទដ៏ប្រសើរ អំពីចម្ងាយ ផ្កាទាំងឡាយលើផែនដីដោយជុំវិញ ទើបរីកសម្រាប់មនុស្សទាំងឡាយដែលត្រូវការគុណ គឺក្លិនក្រអូប បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ផែនដីត្រូវបូកលាបដោយរស្មីនៃព្រះចន្ទ ប្រដាប់ដោយផ្កា

ដោយជុំវិញដ៏ស្អាត ដូចស្ត្រីប្រដាប់ដោយកម្រងផ្កា ល្អសព្វាង្គកាយ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរសម្រាប់ព្រះអង្គីរសហើយ ។

ដំរីទាំងឡាយចុះប្រេង ក៏បន្លឺកោញ្ចនាទ ពួកបក្សីដែលមានកន្ទុយល្អ ក៏យំជុំវិញព្រៃធំ ដែលគួរជាទីត្រេកអរ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ម្យ៉ាងទៀត ផ្លូវគ្រប់ខ្សែ ក៏គួរដល់ការដើរ ទាំងរដ្ឋអាណាចក្រ ក៏ស្តុកស្តម្ភ មានទ្រព្យ មានភោគៈ វត្ថុគ្រប់យ៉ាង គួរសរសើរ ឲ្យនូវសេចក្តីសុខគ្រប់យ៉ាង បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ព្រៃទាំងអស់សុទ្ធតែល្អ ដែលធម្មជាតិសាងទុក ដូចនន្ទនវ័នឲ្យកើតបីតិដល់អ្នកប្រព្រឹត្តវត្តទាំងឡាយរឿយៗ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរសម្រាប់ ព្រះអង្គីរសហើយ ។

នគររបស់ត្រកូលមានឈ្មោះថា កបិលពស្តុ ប្រដាប់តាក់តែង គួរជាទីត្រេកអរ ដូចទេវនគរ ជានគរមានសិរី ក្នុងលោកនេះ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរសម្រាប់ព្រះអង្គីរសហើយ ។

ព្រះនគរល្អ លម្អដោយប៉ម គួរជាទីត្រេកអរនៃចិត្ត ប្រដាប់ដោយគុម្ពឈូករីកស្គុះស្គាយ គួរជាទីត្រេកអរ លម្អដោយគូទឹកដ៏វិចិត្រ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

កំពែងដ៏វិចិត្រ ខ្លោងទ្វារ និងព្រះលានដ៏ល្អ ជាទីគង់នៅរបស់ព្រះរាជា ផ្លូវជាទីគួរត្រេកអរដូចទេវលោក បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័សសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ពួកសក្យរាជបុត្ត តាក់តែងព្រះកាយ ល្អរុងរឿងដោយគ្រឿងប្រដាប់ដ៏ប្រសើរ ដូចពួកទេវបុត្តក្នុងស្ថានព្រះឥន្ទ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

បពិត្រព្រះមុនីដ៏ប្រសើរ ព្រះបាទសុទ្ធោទនមហារាជ មានព្រះរាជបំណងនឹងឃើញព្រះមុនី ទើបទ្រង់បញ្ជូនកូនអាមាត្យមួយអន្លើដោយពលដ៏ធំ អស់វារៈ ១០ ដង បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

ព្រះបាទសុទ្ធោទនមហារាជ ទ្រង់មិនឃើញព្រះអង្គ យាងមកទ្រង់មិនបានឮព្រះវាចា ខ្ញុំព្រះអង្គបំណងនឹងលួងលោមព្រះអង្គ

ដែលទ្រង់ប្រសើរ ក្នុងនរជនជាម្ចាស់នៃនរជន ដែលត្រូវសេចក្តីសោកគ្របសង្កត់ហើយ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

បពិត្រព្រះមុនីដ៏ប្រសើរ បីតិដ៏លើសលុប គួរអស្ចារ្យ នឹងកើតឡើង ព្រោះការឃើញព្រះអង្គ សូមទ្រង់លួងលោមព្រះរាជា ដែលជាធំជាងពួកមនុស្ស មានព្រះគុណដ៏ប្រសើរ ដែលរង់ចាំមើលព្រះអង្គផងចុះ បពិត្រព្រះមហាវីរៈ ( នេះ ) ជាសម័យសមគួរ សម្រាប់ព្រះអង្គីរសហើយ ។

អ្នកស្រែ ភ្ជួរស្រែដោយសេចក្តីប្រាថ្នា ព្រោះពូជដោយសេចក្តីប្រាថ្នា ពួកឈ្មួញ អ្នករកទ្រព្យឆ្លងសមុទ្រដោយសេចក្តីប្រាថ្នា ។ ខ្ញុំព្រះអង្គ ស្ថិតនៅដោយសេចក្តីប្រាថ្នាណា សេចក្តីប្រាថ្នារបស់ខ្ញុំព្រះអង្គនោះ សូមឲ្យសម្រេច ។

បពិត្រព្រះមហាមុនី កាលនេះ មិនត្រជាក់ពេក មិនក្តៅពេក អាហារក៏រកបានដោយមិនលំបាក និងមិនអត់ឃ្លាន ផែនដីមានស្មៅខៀវខ្ចី ដោយស្បូវក្លាំង នេះជាកាលសមគួរ ដូច្នេះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ថា ម្នាលឧទាយី ហេតុអ្វី ទើបអ្នកសរសើរការធ្វើដំណើរ ។ ព្រះឧទាយីក្រាបទូលថា បពិត្រព្រះអង្គ ព្រះបាទសុទ្ធោទនមហារាជ ព្រះជនករបស់ព្រះអង្គ មានព្រះបំណងចង់ជួប សូមទ្រង់ធ្វើនូវការសង្គ្រោះព្រះញាតិចុះ ។ ព្រះសាស្តាត្រាស់ថា សាធុ ឧទាយី

តថាគតនឹងធ្វើនូវការសង្គ្រោះព្រះញាតិ បើយ៉ាងនោះ ចូរអ្នកប្រាប់ដល់ភិក្ខុសង្ឃ ភិក្ខុទាំងឡាយនឹងបំពេញគមិកវត្ត ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ថា សាធុ ហើយក៏ប្រាប់ដល់ភិក្ខុសង្ឃ ។

ព្រះសាស្ដា ទ្រង់ចោមរោមដោយភិក្ខុខីណាស្រព ២ ម៉ឺនរូប គឺកុលបុត្តអ្នកអង្គៈ និងមគធៈ ១ ម៉ឺនរូប កុលបុត្តអ្នកកបិលពស្តុ ១ ម៉ឺនរូប យាងចេញអំពីនគររាជគ្រឹះ ធ្វើដំណើរមួយថ្ងៃ ១ យោជន៍ មួយថ្ងៃ ១ យោជន៍ ២ ខែ ក៏ដល់ក្រុងកបិលពស្តុ កាលព្រះមានព្រះភាគយាងដល់ហើយ ស្តេចសក្យៈទាំងឡាយ ក៏នាំគ្នាជ្រើសរើសទីប្រថាប់នៅរបស់ព្រះមានព្រះភាគ ដោយបំណងថា យើងនឹងជួបព្រះញាតិដ៏ប្រសើរបំផុតរបស់ខ្លួន ទើបកំណត់ថា អារាមរបស់និគ្រោធសក្យៈ គួរជាទីត្រេកអរ ឲ្យរៀបចំពិធីបដិបត្តិសព្វយ៉ាង ទើបនាំគ្នាកាន់គ្រឿងក្រអូប និងផ្កាចេញទៅទទួល តែងខ្លួនដោយគ្រឿងអលង្ការសព្វយ៉ាង បូជាដោយគ្រឿងក្រអូប ផ្កា និងលម្អិតជាដើម នាំព្រះមានព្រះភាគទៅកាន់និគ្រោធអារាមនោះ ។

ក្នុងទីនោះ ព្រះមានព្រះភាគ ដែលព្រះខីណាស្រព ២ ម៉ឺនរូបចោមរោមហើយ ទ្រង់គង់លើពុទ្ធាសនៈយ៉ាងល្អដែលគេរៀបចំ ។ ឯពួកសក្យៈជាជាតិដែលមានមានះ រឹងត្អឹងដោយមានះ គិតគ្នាថា សិទ្ធត្ថកុមារ ក្មេងជាងពួកយើង ជាប្អូនប្រុស ជាកូន ជាក្មួយ ជាចៅ ទើបពោលនឹងរាជកុមារក្មេងៗ ថា ចូរពួកអ្នកថ្វាយបង្គំ ពួកយើងនឹងអង្គុយខាងក្រោយពួកអ្នក ។ កាលស្តេចសក្យៈទាំងនោះអង្គុយហើយ ព្រះមានព្រះភាគទ្រង់ទតអធ្យាស្រ័យ

របស់ស្តេចសក្យៈទាំងនោះហើយ ទ្រង់ព្រះតម្រិះថា ព្រះញាតិទាំងនោះ មិនថ្វាយបង្គំតថាគត ព្រោះខ្ញុំជាមនុស្សចាស់ទេ ពួកញាតិទាំងនោះមិនដឹងថា ធម្មតារបស់ព្រះពុទ្ធដូចម្តេច កម្លាំងរបស់ព្រះពុទ្ធដូចម្តេច ឬថា ធម្មតារបស់ព្រះពុទ្ធយ៉ាងនេះ កម្លាំងរបស់ព្រះពុទ្ធយ៉ាងនេះ បើដូច្នោះ តថាគតកាលនឹងសម្តែងកម្លាំងរបស់ព្រះពុទ្ធ និងកម្លាំងនៃឫទ្ធិ ក៏គួរធ្វើបាដិហារ្យ តថាគតនឹងនិម្មិតទីចង្រ្កម ដែលសម្រេចដោយរតនៈ ទំហំប៉ុនម៉ឺនចក្កវាឡ ក្នុងអាកាស កាលចង្រ្កមក្នុងទីចង្រ្កមនោះ មើលអជ្ឈាស្រ័យរបស់មហាជនហើយ សឹមសម្តែងធម៌ ។ ដោយហេតុនោះ ដើម្បីសម្តែងបរិវិតក្ករបស់ព្រះមានព្រះភាគ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា

ពួកមនុស្ស ព្រមទាំងទេវតាទាំង មិនបានដឹងដូច្នេះថា ព្រះពុទ្ធអង្គនេះ ទ្រង់ឧត្តមជាងនរជនដូចម្តេច ឥទ្ធិពល និងបញ្ញាពលតើដូចម្តេច ពុទ្ធពលរបស់ព្រះសាស្តាជាប្រយោជន៍ ដល់សត្វលោកដូចម្តេច ។

ពួកមនុស្ស ព្រមទាំងទេវតាទាំង មិនបានដឹងដូច្នេះថា ព្រះពុទ្ធអង្គនេះ ទ្រង់ឧត្តមជាងនរជនបែបនេះ ឥទ្ធិពល និងបញ្ញាពលបែបនេះ ពុទ្ធពលរបស់ព្រះសាស្តាជាប្រយោជន៍ ដល់សត្វលោកបែបនេះ ។

( ព្រះសាស្តា ទ្រង់ជ្រាបអជ្ឈាស្រ័យនៃមនុស្ស និងទេវតាទាំងនោះ ដូច្នោះហើយ ) ទើបទ្រង់ព្រះចិន្តាថា បើដូច្នោះ

តថាគតនឹងសម្តែងនូវពុទ្ធពលដ៏ប្រសើរ និម្មិតទីចង្ក្រមប្រដាប់ដោយកែវពួដ៏អាកាស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ហោតេ ជានន្តិ** សេចក្តីថា ព្រោះថាញាតិទាំងនោះមិនដឹង ។ **ន** អក្ខរៈ មានអត្ថបដិសេធ ។ **ហិ** អក្ខរៈ ជានិបាត ចុះក្នុងអត្ថថា ហេតុ អធិប្បាយថា ព្រោះទេវតា និងមនុស្ស មានព្រះញាតិជាដើមរបស់តថាគតទាំងនេះ កាលតថាគតមិនធ្វើឲ្យជាក់ច្បាស់ដល់កម្លាំងរបស់ព្រះពុទ្ធ និងកម្លាំងរបស់ឫទ្ធិទេ ក៏មិនដឹងថា ព្រះពុទ្ធមានសភាពយ៉ាងនេះ កម្លាំងឫទ្ធិមានសភាពយ៉ាងនេះ ដូច្នោះ តថាគតគប្បីសម្តែងកម្លាំងរបស់ព្រះពុទ្ធ និងកម្លាំងឫទ្ធិរបស់តថាគត លោកបំណាងយកឧបបត្តិទេពថាទេវតាក្នុងពាក្យថា **សទេវមនុស្សា** នេះ ។ បុគ្គលប្រព្រឹត្តទៅជាមួយទេវតាទាំងឡាយ ហេតុនោះ ទើបឈ្មោះថា **សទេវ** មនុស្សទាំងនោះ គឺអ្នកណាគឺមនុស្ស មនុស្សទាំងឡាយ មួយអន្លើដោយទេវតា ឈ្មោះថា **សទេវមានុស្សា** ម្យ៉ាងទៀត ព្រះបាទសុទ្ធោទនសម្មតិទេព លោកបំណាងយកថា ជាទេវតា ។ បុគ្គលប្រព្រឹត្តទៅជាមួយទេវតា គឺព្រះបាទសុទ្ធោទនៈ ហេតុនោះ ទើបឈ្មោះថា **សទេវា** ។ មនុស្សដែលជាញាតិ ឈ្មោះថា **មានុស្សា** ។ មនុស្សទាំងឡាយ និងទេវតា គឺព្រមដោយព្រះបាទសុទ្ធោទនៈ ឈ្មោះថា **សទេវមានុស្សា** ។ ម្យ៉ាងទៀត អធិប្បាយថា មនុស្សដែលជាញាតិរបស់តថាគតទាំងនេះ មួយអន្លើដោយព្រះរាជា រមែងមិនដឹងកម្លាំងរបស់តថាគត ។ ទេវតាដ៏សេស ក៏សង្គ្រោះចូលផងដែរ ។ ទេវតាទាំងអស់ លោកហៅថា **ទេវតា**

ព្រោះអត្ថថា លេង ។ ឈ្មោះថា លេង ជាអត្ថរបស់ធាតុ មានកីឡធាតុជាដើម ។ មួយវិញទៀត ទេវតាផង មនុស្សផង ឈ្មោះថា **សទេវមានុសា** បុគ្គលប្រព្រឹត្តទៅដោយទេវតា និងមនុស្ស ឈ្មោះថា **សទេវមានុសា** ។ ទាំងនោះ គឺអ្នកណា គប្បីឃើញការបន្ថែមពាក្យដ៏សេសថា **លោកា** ប្រែថា ពួកនោះ គឺសត្វលោក ។ បទថា **ពុទ្ធោ** មានវិគ្គហៈថា ឈ្មោះថា **ពុទ្ធ** ព្រោះអត្ថថា ត្រាស់ដឹង តាមដឹងនូវសច្ចធម៌ទាំង ៤ ដូចព្រះតម្រាស់ថា

ធម្មជាតដែលគួរដឹងច្បាស់ តថាគតបានដឹងច្បាស់ហើយ ធម្មជាតដែលគួរចម្រើន តថាគតបានចម្រើនហើយ ធម្មជាតដែលគួរលះបង់ តថាគតក៏បានលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបតថាគត ឈ្មោះថា ព្រះពុទ្ធ ដូច្នេះ ។

ក្នុងគាថា គប្បីឃើញថា **ពុទ្ធ** សព្ទ សម្រេចក្នុងសេចក្តី ក្នុងអត្ថថា ជាប្រធាន ( កត្តុការកៈ ) ឈ្មោះថា **ពុទ្ធ** ព្រោះជាបុគ្គលដែលទេវតា និងមនុស្ស ដែលសម្រេចគុណវិសេស ដឹងយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធហ្ន៎ ។ ក្នុងពាក្យនេះ គប្បីឃើញថា **ពុទ្ធ** សព្ទ សម្រេចក្នុងអត្ថថា ជាកម្ម ( កម្មការកៈ ) ឬថា ការដឹងរបស់ព្រះមានព្រះភាគនោះមាន ហេតុនោះ ទើបព្រះមានព្រះភាគ ឈ្មោះថា **ពុទ្ធ** អធិប្បាយថា ទ្រង់មានការដឹង ។ ពាក្យទាំងអស់នោះ គប្បីជ្រាបតាមគន្លងសព្ទសាស្ត្រ ។ បទថា **កីទិសកោ** សេចក្តីថា សេចក្តីនេះដូចម្តេច គឺមានបែបដូចម្តេច ដូចអ្វី មានពណ៌សម្បុរដូចម្តេច មានទ្រង់ទ្រាយដូចម្តេច វែង ឬខ្លី ។

បទថា **នរុត្តមោ** មានវិគ្គហៈថា បុគ្គលឧត្តម បុគ្គលប្រសើរ បុគ្គលប្រសើរបំផុតនៃនរជន ឬក្នុងនរជនទាំងឡាយ ហេតុនោះ ទើបឈ្មោះថា **នរុត្តម**។ ការសម្រេច ឈ្មោះថា **ឥទ្ធិ** ក្នុងពាក្យថា **ឥទ្ធិពលំ** នេះ ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេចផល និងព្រោះអត្ថថា បាន ។ ន័យម្យ៉ាងទៀត សត្វទាំងឡាយ សម្រេចបានដោយគុណជាតនោះ គឺជាអ្នកសម្រេច ចម្រើនដល់នូវភាពក្រៃលែង ហេតុនោះ ទើបគុណជាតនោះ ឈ្មោះថា **ឥទ្ធិ**។

## ឫទ្ធិ ១០ យ៉ាង

ឥទ្ធិនោះ មាន ១០ យ៉ាង ដូចលោកពោល ( ក្នុងបដិសម្ភិទាមគ្គ ) ថា បទថា **ឥទ្ធិយោ** បានដល់ ឥទ្ធិ ១០ ។ ឥទ្ធិ ១០ តើដូចម្តេច ឫទ្ធិ គឺការអធិដ្ឋាន ១ ឫទ្ធិ គឺការធ្វើឲ្យវិសេស ១ ឫទ្ធិ គឺអ្វីដែលសម្រេចដោយចិត្ត ១ ឫទ្ធិ គឺការផ្សាយចេញដោយសារញាណ ១ ឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ ១ ឫទ្ធិ គឺគុណជាតប្រសើរ[១] ឫទ្ធិកើតអំពីផលកម្ម ១ ឫទ្ធិរបស់បុគ្គលមានបុណ្យ ១ ឫទ្ធិសម្រេចដោយសារវិជ្ជា ១ ឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះៗ ជាបច្ច័យ ១ ។

ឥទ្ធិទាំងនោះ មានសេចក្តីផ្សេងគ្នាដូច្នេះ ដោយប្រក្រតី មនុស្សម្នាក់អធិដ្ឋានឲ្យជាមនុស្សច្រើន ជា ១០០ ឬជា ១០០០ ហើយអធិដ្ឋានដោយញាណថា អញជាមនុស្សច្រើន ឫទ្ធិដែលបំបែកខ្លួនយ៉ាងនេះ ឈ្មោះថា ការអធិដ្ឋាន ព្រោះសម្រេចដោយអំណាចអធិដ្ឋាន ។ ឥទ្ធិ គឺការអធិដ្ឋាននោះ

---

១- ឫទ្ធិរបស់ព្រះអរិយៈ ។

មានសេចក្តីដូច្នេះ ភិក្ខុចូលចតុត្ថជ្ឈាន ដែលជាបាទនៃអភិញ្ញា ចេញអំពីចតុត្ថជ្ឈាននោះហើយ បើប្រាថ្នាជា ១០០ នាក់ ក៏ធ្វើបរិកម្ម ដោយបរិកម្មចិត្តដែលជាកាមាវចរថា ចូរអាត្មាអញជាមនុស្ស ១០០ ចូរអាត្មាអញជាមនុស្ស ១០០ ហើយចូលចតុត្ថជ្ឈានដែលជាបាទនៃអភិញ្ញាទៀត ចេញអំពីឈាននោះហើយ អធិដ្ឋានទៀត ក៏ក្លាយជា ១០០ នាក់ ជំណាលគ្នានឹងចិត្តអធិដ្ឋាននោះឯង ។ ក្នុងករណី ១០០០ នាក់ជាដើម ក៏ន័យនេះដូចគ្នា ។ ក្នុងឥទ្ធិ គឺការអធិដ្ឋាននោះ ចិត្តដែលប្រកបដោយបាទកជ្ឈាន មាននិមិត្តជាអារម្មណ៍ បរិកម្មចិត្តមានមនុស្ស ១០០ ជាអារម្មណ៍ខ្លះ មានមនុស្ស ១០០០ ឯណានីមួយជាអារម្មណ៍ខ្លះ បរិកម្មចិត្តទាំងនោះឯង ប្រព្រឹត្តទៅដោយអំណាចនៃពណ៌ មិនបានប្រព្រឹត្តទៅដោយអំណាចនៃបញ្ញត្តិឡើយ សូម្បីអធិដ្ឋានចិត្តក៏មានមនុស្ស ១០០ ជាអារម្មណ៍តែម្យ៉ាង តែអធិដ្ឋានចិត្តនោះ ក៏ដូចអប្បនាចិត្ត កើតឡើងក្នុងលំដាប់គោត្រភូចិត្តប៉ុណ្ណោះ ប្រកបដោយចតុត្ថជ្ឈានខាងរូបាវចរ ។ ព្រះអភិក្ខុនោះ លះបង់ភេទជាប្រក្រតី ហើយសម្តែងភេទជាកុមារខ្លះ សម្តែងភេទជានាគខ្លះ សម្តែងភេទជាគ្រុឌខ្លះ ។បេ។ សម្តែងភេទជាកងទាហានប្លែកៗ គ្នាខ្លះ ឫទ្ធិដែលមកដោយអាការដូចពោលមកយ៉ាងនេះ ឈ្មោះថា ឫទ្ធិ គឺការធ្វើឲ្យវិសេស ព្រោះប្រព្រឹត្តទៅ ដោយលះភេទប្រក្រតី និងធ្វើឲ្យប្លែកៗ ។

ភិក្ខុក្នុងសាសនានេះ និម្មិតនូវកាយ មានរូបដែលសម្រេចអំពីចិត្ត មានអវយវៈធំតូចសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយជាដើម ឈ្មោះថា ឫទ្ធិ

គឺអ្វីដែលសម្រេចដោយចិត្ត ព្រោះប្រព្រឹត្តទៅ ដោយការសម្រេចនៃសរីរៈដទៃ ដែលសម្រេចមកអំពីចិត្តខាងក្នុងសរីរៈនោះឯង ។

គុណវិសេសដែលកើតឡើង ដោយអានុភាពនៃអរហត្តញាណ គប្បីបានដោយអត្តភាពនោះ មុន ឬក្រោយញាណកើត ឬក្នុងខណៈនោះឯង ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញដោយសារញាណ ។ ព្រះពាកុលៈ ព្រះសង្កិច្ចៈមានឫទ្ធិដែលផ្សាយទៅដោយញាណ ។ រឿងព្រះថេរៈទាំង ២ នោះ គប្បីពោលក្នុងសេចក្ដីនេះ ។

គុណវិសេសដែលកើតឡើងដោយអានុភាពនៃសមថៈ មុន ឬក្រោយសមាធិ ឬក្នុងខណៈនោះឯង ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ ។ ព្រះសារីបុត្តមានឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ ព្រះសញ្ជីវៈក៏មានឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ ព្រះថាណុកោណ្ឌញ្ញៈក៏មានឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ នាងឧត្តរាឧបាសិកាក៏មានឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ នាងសាមាវតីឧបាសិកាក៏មានឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ រឿងទាំងឡាយរបស់លោកទាំងនោះដូចពោលមកនេះ ក៏គប្បីពោលក្នុងសេចក្ដីនេះ តែខ្ញុំមិនបានពោលឲ្យពិស្ដារដើម្បីចៀសវាងនូវទោស គឺការពិស្ដារនៃគម្ពីរ ។

ឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ បើប្រាថ្នាថា អាត្មាអញគប្បីមានសេចក្ដីសម្គាល់ថាមិនគួរខ្ពើម ក្នុងរបស់គួរខ្ពើម លោកក៏ជាអ្នកសម្គាល់ថា មិនគួរខ្ពើមក្នុងរបស់នោះ បើប្រាថ្នាថា អាត្មាអញគប្បី

មានសេចក្ដីសម្គាល់ថា គួរខ្ពើមក្នុងរបស់មិនគួរខ្ពើម លោកក៏ជាអ្នកសម្គាល់ថា គួរខ្ពើមក្នុងរបស់នោះ ។បេ។ ជឹងខ្លួនប្រកបដោយឧបេក្ខា លោកក៏ជាអ្នកមានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខាក្នុងរបស់នោះ ។ ឥទ្ធិនេះឈ្មោះថា ឫទ្ធិ គឺគុណជាតប្រសើរ ព្រោះជាដែនកើតនៃព្រះអរិយៈទាំងឡាយ ដែលដល់នូវការជំនាញផ្លូវចិត្ត ។

ឫទ្ធិកើតអំពីផលកម្ម តើដូចម្ដេច ។ ឫទ្ធិរបស់សត្វស្លាបទាំងអស់ របស់ទេវតាទាំងអស់ របស់ពួកមនុស្សខ្លះ របស់សត្វជាវិនិបាតិកកំណើតពួកខ្លះ ឈ្មោះថា ឫទ្ធិកើតអំពីផលកម្ម ។

ឫទ្ធិរបស់បុគ្គលមានបុណ្យ តើដូចម្ដេច ។ ព្រះរាជាចក្រពត្តិ ទ្រង់ទៅកាន់អាកាសបាន មួយអន្លើដោយសេនាប្រកបដោយអង្គ ៤ ។ ភ្នំមាសកម្ពស់ ៨០ ហត្ថ កើតឡើងដល់ជដិលគហបតី ឫទ្ធិនេះ ឈ្មោះថា ឫទ្ធិរបស់បុគ្គលមានបុណ្យ ឃោសកគហបតី កាលត្រូវគេព្យាយាមសម្លាប់ ក្នុងទី ៧ កន្លែងក៏មិនមានអន្តរាយ នេះឈ្មោះថា ឫទ្ធិរបស់បុគ្គលមានបុណ្យ ។ កាលប្រាកដនៃពពែទាំងឡាយ ដែលធ្វើដោយរតនៈ ៧ ក្នុងប្រទេសប្រមាណ ៨ ករីស របស់មេណ្ឌកសេដ្ឋី នេះឈ្មោះថា ឫទ្ធិរបស់បុគ្គលមានបុណ្យ ។

ឫទ្ធិសម្រេចដោយវិជ្ជា តើដូចម្ដេច ឫទ្ធិដែលប្រព្រឹត្តទៅ ដោយន័យជាដើមថា ពួកវិជ្ជាធររាយ ( ឬជប់ ) នូវវិជ្ជា ហោះទៅកាន់អាកាសទទេតាំងខ្លួនជាដំរីខ្លះ ។បេ។ តាំងខ្លួនជាកងទាហានផ្សេងៗ ខ្លះ នេះឈ្មោះថា ឫទ្ធិសម្រេចដោយសារវិជ្ជា ។

គុណវិសេសដែលធ្វើកិច្ចកម្មនោះហើយកើតឡើង ឈ្មោះថា ឥទ្ធិ ព្រោះអត្ថថា សម្រេចដោយការប្រកបដោយប្រពៃជាបច្ច័យ ហេតុនោះ ទើប ឥទ្ធិនេះ ឈ្មោះថា ឫទ្ធិ ដោយអត្ថថា សម្រេចព្រោះការប្រកបត្រូវក្នុងអំពើ នោះៗ ជាបច្ច័យ អធិប្បាយថា កម្លាំងនៃឫទ្ធិ ១០ យ៉ាងនេះ ឈ្មោះថា ឥទ្ធិពល ព្រះញាតិទាំងនេះ មិនស្គាល់កម្លាំងឫទ្ធិរបស់តថាគត ។

កម្លាំងនៃបញ្ញា គឺអរហត្តមគ្គដែលឲ្យគុណវិសេសជាលោកិយ និង លោកុត្តរទាំងអស់ លោកបំណងយកថា កម្លាំងនៃបញ្ញា ព្រះញាតិទាំងនេះ ក៏មិនស្គាល់កម្លាំងនៃបញ្ញានោះ ។ អាចារ្យពួកខ្លះពោលថា ពាក្យថា កម្លាំង នៃបញ្ញានេះ ជាឈ្មោះនៃញាណដែលមិនសាធារណៈ ៦ ប្រការ ។ ពុទ្ធា-នុភាព ឬទសពលញាណ ឈ្មោះថា កម្លាំងនៃព្រះពុទ្ធ ក្នុងពាក្យថា កម្លាំង នៃព្រះពុទ្ធនេះ ។

## ទសពលញ្ញាណ ១០

ក្នុងញាណទាំងនោះ ញាណ ១០ ឈ្មោះថា ទសពលញាណ គឺឋានា-ឋានញ្ញាណ គឺញាណដែលកំណត់ដឹងឋានៈ និងអឋានៈ ១ អតីតានា-គតបច្ចុប្បន្នកម្មវិបាកជាននញ្ញាណ គឺបញ្ញាកំណត់ដឹងផលនៃកម្មដែលជាអតីត អនាគត និងបច្ចុប្បន្ន ១ សព្វត្ថគាមិនីបដិបទាញាណ បញ្ញាកំណត់ដឹងផ្លូវ ទៅកាន់ភូមិទាំងពួង ១ អនេកធាតុនានាធាតុលោកជាននញ្ញាណ បញ្ញាកំណត់ ដឹងលោក គឺដឹងធាតុជាអនេក និងធាតុផ្សេងៗ ១ នានាធិមុត្តិកញ្ញាណ បញ្ញាកំណាំដឹងអធិមុត្តិ គឺអធ្យាស្រ័យនៃសត្វទាំងឡាយដែលផ្សេងៗ គ្នា ១

អាសយានុសយញ្ញាណ ឬឥន្ទ្រិយបរោបរិយត្តិញ្ញាណ គឺបញ្ញាកំណត់ដឹងការទន់ខ្សោយ និងការចាស់ក្លានៃឥន្ទ្រិយរបស់សត្វទាំងឡាយ ១ ឈានវិមោក្ខ-សមាធិសមាបត្តិសង្កិលេសវោទានវុដ្ឋានយថាភូតញ្ញាណ គឺបញ្ញាកំណត់ដឹងតាមសេចក្តីពិត ក្នុងការសៅហ្មង ការបរិសុទ្ធ និងការចេញនៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ ១ បុព្វេនិវាសានុស្សតិញ្ញាណ ១ គឺបញ្ញាកំណត់រឭកជាតិបាន ១ ចុតូបបាតញ្ញាណ គឺបញ្ញាកំណត់ដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ១ អាសវក្ខយញ្ញាណ ១ គឺបញ្ញាកំណត់ដឹងដែលធ្វើអាសវៈឲ្យអស់ទៅ ១ ។

ពាក្យថា កម្លាំងនៃព្រះពុទ្ធ ជាឈ្មោះរបស់ញាណ ១០ នេះ ។ បទថា **ឯទិសំ** បានដល់ បែបនេះ ឬបាឋៈ ក៏យ៉ាងនេះដូចគ្នា ។

សព្ទថា **ហន្ទ** ជានិបាត ចុះក្នុងអត្ថថា អញ្ជើញ ព្រះមានព្រះភាគទ្រង់ចង្អុលបង្ហាញព្រះអង្គ ដោយបទថា **អហំ** ។ ទ្រង់អធិប្បាយដូចម្តេច ទ្រង់អធិប្បាយថា ព្រោះញាតិទាំងឡាយរបស់តថាគតមិនដឹងកម្លាំងនៃព្រះពុទ្ធ ឬពុទ្ធគុណ អាស្រ័យការដែលខ្លួនជាមនុស្សចាស់ទទេ មិនថ្វាយបង្គំតថាគតដែលជាបុគ្គលចម្រើនបំផុត ប្រសើរបំផុតក្នុងលោកទាំងពួង ដោយអំណាចមានះតែម្យ៉ាង ហេតុនោះ ទង់ គឺមានះរបស់ពួកញាតិទាំងនោះមាន តថាគតនឹងកាច់បំបាក់មានះនោះហើយ គប្បីសម្តែងកម្លាំងរបស់ព្រះពុទ្ធ ដើម្បីព្រះញាតិបានថ្វាយបង្គំតថាគត ។ បទថា **ឧស្សយិសាមិ** បានដល់ គប្បីសម្តែង ។ បាឋៈថា **ឧស្សេស្សាមិ** ដូច្នេះក៏មាន សេចក្តីក៏យ៉ាងនោះដូចគ្នា ។ បទថា

**ពុទ្ធពលំ** បានដល់ ពុទ្ធានុភាព ឬញាណវិសេសរបស់ព្រះពុទ្ធ ។ បទថា **អនុត្តរំ** បានដល់ មិនមានអ្វីដទៃក្រៃលែងជាង ទីចង្ក្រម លោកហៅថា **ចង្កមំ** ។ បទថា **មាបយិស្សាមិ** បានដល់ គប្បីនិម្មិត ។ បាឋៈថា **ចង្កមនំ មាបេស្សាមិ** ដូច្នេះក៏មាន សេចក្តីក៏យ៉ាងនោះដូចគ្នា ។ បទថា **ឆភេ** បាន ដល់ ក្នុងអាកាស ។ បទថា **សព្វរតនមណ្ឌិតំ** សេចក្តីថា ដែលតាក់តែង ប្រដាប់ដោយរតនៈ ព្រោះអត្ថថា ឲ្យកើតនូវការត្រេកអរទាំងអស់ មួយមុខៗ ១០ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាល ប្រាក់ មាស កែវមកត និងកែវទទឹម ឈ្មោះថា ប្រដាប់ដោយរតនៈទាំងពួង បាន ដល់នូវទីចង្ក្រមនោះ ដែលប្រដាប់ដោយរតនៈទាំងពួង ។ បាឋៈខ្លះជា **បភេ រតនមណ្ឌិតំ** ប្រែថា ប្រដាប់ដោយរតនៈក្នុងអាកាសក៏មាន ។

គ្រានោះ លុះព្រះមានព្រះភាគទ្រង់ព្រះតម្រិះយ៉ាងនេះ ទេវតាទាំងឡាយ មានភុម្មទេវតាជាដើម ដែលនៅក្នុងម៉ឺនចក្កវាឡ ក៏មានចិត្តត្រេកអរ នាំគ្នា ថ្វាយសាធុការ គប្បីជ្រាបថា ព្រះសង្គីតិកាចារ្យទាំងឡាយ កាលប្រកាស សេចក្តីនោះ ក៏បានតាំងគាថាជាដើមថា

> ទេវតាទាំងឡាយណា គឺភុម្មទេវតាក្តី មហារាជិកទេវតាក្តី
> តាវត្តឹសទេវតាក្តី យាមទេវតាក្តី តុសិតទេវតាក្តី និម្មានរតី-
> ទេវតាក្តី បរនិម្មិតវសវត្តីទេវតាក្តី ព្រហ្មទាំងឡាយណាក្តី
> ពួកទេវតា និងព្រហ្មទាំងនោះ រីករាយហើយ បានធ្វើនូវ
> សំឡេង ឲ្យឮកងរំពងខ្ទរខ្ទារ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភុម្មា** បានដល់ ដែលស្ថិតនៅលើផែនដី ដូចជាស្ថិតនៅត្រង់ថ្ម ភ្នំ ព្រៃ និងដើមឈើជាដើម ។ បទថា **មហារាជិកា** បានដល់ ជាអ្នកខាងចំណែកមហារាជ អធិប្បាយថា ទេវតាដែលនៅក្នុងអាកាស បានឮសំឡេងរបស់ពួកទេវតាដែលនៅលើផែនដី ក៏បន្លឺសំឡេងខ្លាំង បន្ទាប់អំពីនោះ អព្ភវលាហកាទេវតា គឺទេវតាពពក ឧណ្ហវលាហកាទេវតា គឺទេវតាកម្ដៅ សីតវលាហកាទេវតា គឺទេវតាត្រជាក់ វស្សវលាហកាទេវតា គឺទេវតាភ្លៀង វាតវលាហកាទេវតា គឺទេវតាខ្យល់ បន្ទាប់អំពីនោះ ទេវតាជាន់ចាតុម្មហារាជិក ជាន់តាវត្តិង្ស ជាន់យាមា ជាន់តុសិត ជាន់និម្មានរតី ជាន់បរនិម្មិតវសវត្តី បន្ទាប់អំពីនោះ ពួកព្រហ្ម ព្រហ្មជាន់បុរោហិត ជាន់មហាព្រហ្ម ជាន់បរិត្តាភា ជាន់អប្បមាណាភា ជាន់អាភស្សរា ជាន់បរិត្តសុភា ជាន់អប្បមាណសុភា ជាន់សុភកិណ្ហា ជាន់វេហប្ផលា ជាន់អវិហា ជាន់អតប្បា ជាន់សុទស្សា ជាន់សុទស្សី បន្ទាប់អំពីនោះ ទេវតាជាន់អកនិដ្ឋា បានឮសំឡេងខ្លាំងរបស់ទេវតា មនុស្ស និងនាគជាដើមទាំងអស់ក្នុងទីដែលសោតាយតនៈទទួលស្ដាប់បាន វៀរអសញ្ញីសត្វ និងអរូបាវចរសត្វ មានចិត្តជ្រាក់នៅក្នុងអំណាចបីតិ ក៏នាំគ្នាបន្លឺសំឡេងខ្លាំងកងរំពង ។ បទថា **អានន្ទិតា** បានដល់ មានចិត្តត្រេកអរហើយ អធិប្បាយថា កើតនូវបីតិសោមនស្សឯង ។ បទថា **វិបុលំ** បានដល់ ខ្ញរខ្ញារ ។

គ្រានោះ ព្រះសាស្ដាទ្រង់ចូលសមាបត្តិ មានឱទាតកសិណជាអារម្មណ៍ ក្នុងលំដាប់ដែលទ្រង់ព្រះពុទ្ធតម្រិះហើយនោះឯង ទ្រង់អធិដ្ឋានថា ចូរពន្លឺមាន

ដល់មុឺនចក្កវាឡ ជំណាលគ្នានឹងអធិដ្ឋានចិត្តនោះ ពន្លឺក៏ប្រាកដតាំងពីផែនដី ទៅទល់គ្នានឹងអកនិដ្ឋកព ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយ ពោលថា

ផែនដី ព្រមទាំងទេវលោក ក៏ភ្លឺព្រោងព្រាត ទាំងពួកសត្វ នរក នៅក្នុងលោកន្តរដ៏ច្រើន ក៏ឥតមានអ្វីបិទបាំង ទាំងងងឹត ដ៏ខ្លាំងក្លាទៀតសោត ក៏ខ្ចាត់ខ្ចាយចេញក្នុងកាលនោះ គេអាច មើលឃើញនូវបាដិហារ្យជាអស្ចារ្យបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱភាសិតា** បានដល់ ភ្លឺច្បាស់ ។ ក្នុង បទថា **បឋវី** នេះ បឋវីមាន ៤ យ៉ាង គឺកក្ខឡបឋវី សសម្ភារបឋវី និមិត្តបឋវី និងសម្មតិបឋវី ។

ក្នុងបឋវី ៤ យ៉ាងនោះ បឋវីដែលលោកពោលក្នុងបាលីថា អាវុសោ បឋវីធាតុខាងក្នុង តើដូចម្ដេច ។ ធម្មជាតណា ជាខាងក្នុង អាស្រ័យនូវខ្លួន រឹង ១៖ ដូច្នេះជាដើម នេះ ឈ្មោះថា **កក្ខឡបឋវី** ។

បឋវីដែលពោលក្នុងបាលីថា ភិក្ខុណាមួយ ជីកដោយខ្លួនឯងក្ដី ប្រើ អ្នកដទៃឲ្យជីកក្ដី នូវផែនដី ដូច្នេះជាដើម នេះ ឈ្មោះថា **សសម្ភារបឋវី** ។ បឋវីធាតុ ២០ អាការ មានកេសា ( សក់ ) ជាដើម និងចំណែកខាងក្រៅ មានដែក លោហៈជាដើម យ៉ាងណា បឋវីនោះ ក៏ឈ្មោះថា សសម្ភារបឋវី ព្រោះជាបឋវី ប្រកបដោយចំណែកប្រកប មានវណ្ណៈ គឺពណ៌ជាដើម ។

បឋវីដែលលោកដែលពោលក្នុងបាលីថា គឺបុគ្គលម្នាក់ចាំបាននូវបឋវី-

កសិណដូច្នេះជាដើម នេះ ឈ្មោះថា **និមិត្តបឋវី** លោកហៅថា អារម្មណ-បឋវីក៏មាន ។

បុគ្គលណា បានទូវឈាន មានបឋវីកសិណជាអារម្មណ៍ កើតនៅក្នុងទេវលោកហើយ បានឈ្មោះថា បឋវីទេវៈ ដោយការសម្រេចបឋវីកសិណ-ជ្ឈាន សមដូចលោកពោលក្នុងបាលីថា អាបោទេវតាក្តី បឋវីទេវតាក្តី ដូច្នេះជាដើម នេះ ឈ្មោះថា **សម្មតិបឋវី** ។ គប្បីជ្រាបថា ឈ្មោះថា **បញ្ញត្ត-បឋវី** ។ តែក្នុងទីនេះ បំណងយកសសម្ភារបឋវី ។

បទថា **សទេវកា** បានដល់ ព្រមទាំងទេវលោក ។ បាឋៈថា **សទេវតា** ដូច្នេះក៏មាន បើមានក៏ល្អជាង សេចក្តីថា មនុស្សលោក ព្រមទាំងទេវលោក ក្ដីស្វាងហើយ ។ បទថា **បុថុ** បានដល់ ច្រើន ។ បទថា **លោកន្តរិកា** នេះ ជាឈ្មោះនៃសត្វនរកប្រភេទអសុរកាយ លោកន្តរិកនរកទាំងនោះ ជាលោកន្តរិកនរកមួយនៅត្រង់ចន្លោះចក្កវាឡ ៣ លោកន្តរិកនរកនីមួយៗ ដូចគ្នានឹងដាក់កង់រទេះ ៣ ឲ្យទល់គ្នា ពោលដល់ទំហំ ៨ ពាន់យោជន៍ ។ បទថា **អសំវុតា** បានដល់ មិនតាំងនៅខាងក្រោម ។ បទថា **តមោ ច** បានដល់ ងងឹត ។ បទថា **តិព្វោ** បានដល់ ក្រាស់ ។ មានភាពងងឹតជានិច្ច ព្រោះមិនមានពន្លឺរបស់ព្រះចន្ទ និងព្រះអាទិត្យ ។ បទថា **វិហតោ** បានដល់ ត្រូវកម្ចាត់ហើយ ។ បទថា **តទា** សេចក្តីថា កាលណាព្រះមានព្រះភាគទ្រង់អាស្រ័យសេចក្តីករុណាក្នុងសត្វទាំងឡាយ ទ្រង់ផ្សាយពន្លឺ ដើម្បីធ្វើបាដិហារ្យ កាលនោះ ងងឹតដែលតាំងនៅក្នុងលោកន្តរិនរកទាំង

ឡាយ ក៏ត្រូវកម្ចាត់ឲ្យអន្តរធានទៅ ។

បទថា **អច្ឆេរកំ** បានដល់ គួរដល់ការទះដៃ អធិប្បាយថា គួរដល់ការទះដោយម្រាមដៃ ដោយការអស្ចារ្យក្នុងចិត្ត ។ បទថា **បាដិហីរំ** បានដល់ ឈ្មោះថា បាដិហីរៈ ព្រោះនាំបដិបក្ខចេញទៅ ឬឈ្មោះថា បាដិហីរៈ ព្រោះនាំទៅចំពោះនូវដួងចិត្ត ដែលចូលដល់ទិដ្ឋិ និងមានះនៃសត្វទាំងឡាយ ឬឈ្មោះថា បាដិហីរៈ ព្រោះនាំមកចំពោះនូវការជ្រះថ្លារបស់សត្វទាំងឡាយដែលមិនជ្រះថ្លា ។ បាឋៈថា **បាដិហេរ** ដូច្នេះក៏មាន ។ សេចក្តីក៏យ៉ាងនោះដូចគ្នា ពាក្យនេះ ជាឈ្មោះរបស់គុណវិសេសនៃវិធីកម្ចាត់ពន្លឺ ក្នុងសេចក្តីនេះ ។ គប្បីនាំពាក្យនេះថា ទេវតា មនុស្ស និងសត្វដែលកើតក្នុងលោកន្តរិកនរកទាំងឡាយ ឃើញបាដិហារ្យរបស់ព្រះមានព្រះភាគនោះហើយ ក៏ចូលដល់បីតិ និងសោមនស្សយ៉ាងក្រៃលែង ដូច្នេះហើយ គប្បីឃើញអត្ថក្នុងពាក្យនេះថា គេអាចមើលឃើញនូវបាដិហារ្យជាអស្ចារ្យបាន ។ ក្រៅអំពីនេះនឹងយកពាក្យខាងចុងមកខាងដើមក៏មិនត្រូវ ឬយកពាក្យខាងដើមមកខាងចុងក៏មិនត្រូវ ។

ឥឡូវនេះ ដើម្បីសម្តែងថា មិនមែនមានពន្លឺក្នុងមនុស្សលោកតែម្យ៉ាងប៉ុណ្ណោះទេ ក្នុងលោក ពោល គឺសង្ខារលោក សត្វលោក និងឱកាសលោកទាំង ៣ ក៏មានពន្លឺទាំងអស់ដូចគ្នា ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថានេះថា

ពន្លឺដ៏ធំ ទូលាយលើសលុប កើតឡើងដល់ពួកទេវតា គន្ធព្វ មនុស្ស

និងអារក្ស ។ ( ពន្លឺដ៏ធំទូលាយលើសលុប កើតឡើងក្នុងលោកទាំងពីរ គឺ ) ក្នុងលោកនេះ និងលោកដទៃផង ក្នុងទិសខាងក្រោម ទិសខាងលើ និងទិសទទឹងផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទេវា** បានដល់ សម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព ទេវៈទាំងអស់ លោកសង្គ្រោះហើយក្នុងបទនេះ ។ ទេវតាផង គន្ធព្វផង មនុស្សផង អារក្សផង ឈ្មោះថា ទេវគន្ធព្វមនុស្សរក្ខសា ។ ប្រព្រឹត្តទៅជាមួយដោយទេវតាផង គន្ធព្វផង មនុស្សផង អារក្សផង ឈ្មោះថា សទេវគន្ធព្វមនុស្សរក្ខសោ ។ នុំ គឺអ្វី គឺលោក ។ ក្នុងលោក ព្រមទាំងទេវតា គន្ធព្វ មនុស្ស និងអារក្សនោះ ។ បទថា **អាភា** បានដល់ ពន្លឺ ។ បទថា **ឱឡារា** នេះ ប្រាកដក្នុងអត្ថថា ឆ្ងាញ់ ប្រសើរ និងបរិបូណ៌ ជាដើម ។ ពិតហើយ **ឱឡារ** សព្ទនេះ ប្រាកដក្នុងអត្ថថា ឆ្ងាញ់ ដូចក្នុងប្រយោគជាដើមថា **ឱឡារានិ ខាទនីយភោជនីយានិ ខាទន្តិ ភុញ្ជន្តិ** អបេលក៍ទាំងនោះ ជូនកាល ទំពាស៊ីនូវខាទនីយៈទាំងឡាយដ៏ឧត្ដមក្រៃលែង បរិភោគនូវភោជនទាំងឡាយដ៏ឧត្ដមក្រៃលែង ។

ប្រាកដក្នុងអត្ថថា ប្រសើរ ដូចក្នុងប្រយោគជាដើមថា **ឱឡារាយ ខោ បន ភវំ វច្ឆាយនោ បសំសាយ សមណំ គោតមំ បសំសតិ** ម្ដេចក៏វច្ឆាយនៈដ៏ចម្រើន ពោលសរសើរព្រះសមណគោតម ដោយពាក្យសរសើរដ៏ខ្ពង់ខ្ពស់ ( ប្រសើរ ) ដល់ម៉្លេះ ។

ប្រាកដក្នុងអត្ថថា បរិបូណ៌ ដូចក្នុងប្រយោគជាដើមថា **អតិក្កម្ម ទេវានំ**

**ទេវានុភាវំ អប្បមាណោ ឱឡារោ ឱភាសោ** *កាលនោះ ពន្លឺដ៏លើសលុបហួសប្រមាណ ជាពន្លឺកន្លងនូវទេវានុភាពរបស់ទេវតាទាំងឡាយ ។ ក្នុងទីនេះ* **ឱឡារ** *សព្ទនេះ គប្បីឃើញថា ប្រើក្នុងអត្ថថា ប្រសើរ ។*

*បទថា* **វិបុលា** *បានដល់ មិនមានប្រមាណ ។ បទថា* **អជាយថ** *បានដល់ កើតហើយ កើតឡើងហើយ ប្រព្រឹត្តទៅហើយ ។ បទថា* **ឥមស្មឹ លោកេ បរស្មិញ្ច** *សេចក្តីថា ក្នុងមនុស្សលោកនេះ និងក្នុងលោកដទៃ ។ បទថា* **ឧភយស្មឹ** *បានដល់ ក្នុងលោកទាំង ២ នោះ គប្បីឃើញដូចក្នុងលោកខាងក្នុងនិងលោកខាងក្រៅជាដើម ។ បទថា* **អធោ ច** *បានដល់ ក្នុងនរកទាំងឡាយ មានអវីចីជាដើម ។ បទថា* **ឧទ្ធំ** *បានដល់ ក្នុងកណ្តាលអាកាស រាប់អំពីភវគ្គព្រហ្មចុះមក ។ បទថា* **តិរិយញ្ច** *បានដល់ ក្នុងមុំនចក្កវាឡខាងទទឹង ។ បទថា* **វិត្ថតំ** *បានដល់ ផ្សាយទូលាយទៅ អធិប្បាយថា ពន្លឺកម្ចាត់នូវងងឹត គ្របដណ្តប់លោក និងបទេសដូចពោលហើយប្រព្រឹត្តទៅ ។ម្យ៉ាងទៀត បទថា* **តិរិយញ្ច វិត្ថតំ** *បានដល់ ផ្សាយទៅខាងទទឹង គឺធំ អធិប្បាយថា ពន្លឺគ្របដណ្តប់សព្វបទេស មិនមានប្រមាណ ។*

*គ្រានោះ ព្រះមានព្រះភាគទ្រង់ផ្សាយពន្លឺទៅក្នុងមុំនចក្កវាឡ ទ្រង់ចូលចតុត្ថជ្ឈាន ដែលជាបាទនៃអភិញ្ញា ទ្រង់ចេញចាកឈាននោះហើយ ទ្រង់ហោះឡើងកាន់អាកាស ដោយអធិដ្ឋានចិត្ត ទ្រង់សម្តែងយមកប្បាដិហារ្យកណ្តាលទេវបរិស័ទ និងមនុស្សបរិស័ទដ៏ធំ ដូចទ្រង់រោយធូលីព្រះបាទលើសិរសារបស់ព្រះញាតិទាំងនោះ ។*

យមកប្បាដិហារ្យនោះ គប្បីជ្រាបអំពីបាលីយ៉ាងនេះថា

យមកប្បាដិហិរយញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគត ទ្រង់ធ្វើយមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវ័ក ក្នុងលោកនេះ គឺគំនរភ្លើងចេញ អំពីព្រះកាយខាងលើ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ផ្ការទឹកចេញអំពីព្រះកាយខាងលើ គំនរភ្លើងចេញអំពីព្រះកាយខាងមុខ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោយ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោយ ផ្ការទឹកចេញអំពីព្រះកាយខាងមុខ គំនរភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ផ្ការទឹកចេញអំពីព្រះនេត្រខាងឆ្វេង គំនរភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ផ្ការទឹកចេញអំពីព្រះនេត្រខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងស្តាំ គំនរភ្លើងចេញអំពីចង្កូយព្រះអង្សាខាងស្តាំ ផ្ការទឹកចេញអំពីចង្កូយព្រះអង្សាខាងឆ្វេង គំនរភ្លើងចេញអំពីចង្កូយព្រះអង្សាខាងឆ្វេង ផ្ការទឹកចេញអំពីចង្កូយព្រះអង្សា

ខាងស្តាំ គំនរភ្លើងចេញអំពីព្រះហស្តខាងស្តាំ ផ្ការទឹកចេញអំពីព្រះហស្តខាងឆ្វេង គំនរភ្លើងចេញអំពីព្រះហស្តខាងឆ្វេង ផ្ការទឹកចេញអំពីព្រះហស្តខាងស្តាំ គំនរភ្លើងចេញអំពីខាងខាងស្តាំ ផ្ការទឹកចេញអំពីខាងខាងឆ្វេង គំនរភ្លើងចេញអំពីខាងខាងឆ្វេង ផ្ការទឹកចេញអំពីខាងខាងស្តាំ គំនរភ្លើងចេញអំពីព្រះបាទខាងស្តាំ ផ្ការទឹកចេញអំពីព្រះបាទខាងឆ្វេង គំនរភ្លើងចេញអំពីព្រះបាទខាងឆ្វេង ផ្ការទឹកចេញអំពីព្រះបាទខាងស្តាំ គំនរភ្លើងចេញអំពីព្រះអង្គុលីមួយៗ ផ្ការទឹកចេញអំពីចន្លោះនៃព្រះអង្គុលី គំនរភ្លើងចេញអំពីចន្លោះនៃព្រះអង្គុលី ផ្ការទឹកចេញអំពីព្រះអង្គុលីមួយៗ គំនរភ្លើងចេញអំពីព្រះលោមាមួយៗ ផ្ការទឹកចេញអំពីព្រះលោមាមួយៗ គំនរភ្លើងចេញអំពីរណ្តៅព្រះលោមាមួយៗ ផ្ការទឹកចេញអំពីរណ្តៅព្រះលោមា ( ព្រះមានព្រះភាគទ្រង់បញ្ចេញ ) នូវព្រះឆព្វណ្ណរង្សីខៀវ លឿង ក្រហម ស ហង្សបាទ ភ្លេកៗ ព្រះមានព្រះភាគទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ឈរ ព្រះពុទ្ធនិម្មិត ទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់គង់ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់គង់ ព្រះមាន

ព្រះភាគទ្រង់ចង្ក្រម ឬទ្រង់គង់ ឬផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ឈរ ព្រះមានព្រះភាគទ្រង់ចង្ក្រម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះពុទ្ធ-និម្មិតទ្រង់គង់ ព្រះមានព្រះភាគទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ចង្ក្រម ព្រះពុទ្ធនិម្មិតទ្រង់ផ្ទំ នេះ ឈ្មោះថា យមកប្បា-ដិហិរយញ្ញាណរបស់ព្រះតថាគត ដូច្នេះ ។

តែគប្បីជ្រាបថា ដែលលោកពោលថា ភ្លើងចេញអំពីព្រះកាយខាងក្រោម ផ្ទារទឹកហូរចេញអំពីព្រះកាយខាងលើ ក៏ដើម្បីសម្តែងថា ផ្ទារភ្លើងចេញអំពីព្រះកាយខាងលើរបស់ព្រះមានព្រះភាគអង្គនោះ ដោយតេជោ-កសិណសមាបត្តិ ផ្ទារទឹកហូរចេញអំពីព្រះកាយខាងក្រោម ដោយអំណាចអាបោកសិណសមាបត្តិ ដើម្បីសម្តែងទៀតថា ផ្ទារភ្លើងរមែងចេញអំពីទីដែលផ្ទារទឹកហូរចេញ ផ្ទារទឹកក៏ហូរចេញអំពីទីដែលផ្ទារភ្លើងផ្សាយចេញ ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ក្នុងសេចក្តីនេះ ផ្ទារភ្លើងក៏មិនលាយឡំជាមួយផ្ទារទឹក ផ្ទារទឹកក៏មិនលាយឡំជាមួយផ្ទារភ្លើងដូចគ្នា ។ បណ្តារស្មីទាំងឡាយ រស្មីមានពណ៌ពីរៗ រមែងផ្សាយទៅក្នុងខណៈតែមួយ ដូចជាគូជាមួយរស្មីខាងដើមៗ ។ ចម្មតាចិត្ត ២ ដួង ប្រព្រឹត្តទៅក្នុងខណៈតែមួយមិនមាន ។ តែសម្រាប់ព្រះពុទ្ធទាំងឡាយ រស្មីទាំងនេះ រមែងផ្សាយចេញទៅដូចក្នុងខណៈតែមួយ ព្រោះទ្រង់ជាអ្នកជំនាញ ដោយអាការ ៥ ព្រោះការបញ្ឈប់នៃភវង្គចិត្ត ប្រព្រឹត្តទៅរហ័សក្រៃលែង ។ តែការនឹកបរិកម្ម និងការអធិដ្ឋានរស្មីនោះ ជាម្នាក់មួយចំណែក ។ ពិតហើយ កាលត្រូវការរស្មី

ពណ៌ទៀត ព្រះមានព្រះភាគទ្រង់ចូលនីលកសិណសមាបត្តិ កាលត្រូវការរស្មីពណ៌លឿងជាដើម ក៏ទ្រង់ចូល បីតកសិណសមាបត្តិជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់ធ្វើយមកបា្បដិហារ្យយ៉ាងនេះ ហាក់ដូចជាវេលានៃការប្រជាប់នូវម៉ឺនចក្កវាឡទាំងមូល ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា

ព្រះសាស្តា ព្រះអង្គឧត្តមជាងសត្វ មិនមានអ្នកណាមួយប្រសើរលើស តែងដឹកនាំសត្វ ដែលទេវតា និងមនុស្សតែងបូជា មានអានុភាពច្រើន មានបុញ្ញលក្ខណៈច្រើន ទ្រង់សម្តែងបាដិហារិយ៍ជាអស្ចារ្យ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សត្តុត្តមោ** បានដល់ ឈ្មោះថា **សត្តុត្តម** ព្រោះជាបុគ្គលដ៏ឧត្តម ជាអគ្គបុគ្គលប្រសើរបំផុតក្នុងសត្វទាំងអស់ ដោយព្រះគុណទាំងឡាយ មានសីលជាដើមរបស់ព្រះអង្គ ឬជាបុគ្គលឧត្តមនៃសត្វទាំងឡាយ ឈ្មោះថា **សត្តុត្តម** សេចក្តីពិត ពាក្យថា **សត្ត** ជាឈ្មោះរបស់ញាណ ។ ឈ្មោះថា **សត្តុត្តម** ព្រោះទ្រង់ប្រសើរបំផុត ឧត្តមដោយព្រះញាណ ពោល គឺទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណ ដែលជាអសាធារណញ្ញាណនោះ ឬទ្រង់ជាសត្វដ៏ឧត្តម ដោយទ្រង់ធ្វើក្រៃលែងដោយព្រះញាណដែលទ្រង់មាន ឈ្មោះថា **សត្តុត្តម** ។ បើដូច្នោះ ក៏គួរពោលថា **ឧត្តមសត្ត** ដោយចុះ **ឧត្តម** សព្ទ ខាងដើម ។ តែសព្ទនោះមិនខុសទេ គប្បីជ្រាបដោយការមិននិយម និងដោយព្រះបាលីចំណែកច្រើន ដូច

សព្ទថា **នរុត្តម បរិសុត្តម** និង **នរវរ** ជាដើម ។ ន័យម្យ៉ាងទៀត ញាណដ៏ឧត្តម មានដល់បុគ្គលណា បុគ្គលនោះឈ្មោះថា **សត្តុត្តម** ។ ក្នុងទីនេះក៏មានការចុះ **ឧត្តម** សព្ទខាងដើម ដោយបាឋៈថា ចុះវិសេសនៈខាងដើមថា **ឧត្តមសត្តោ** ដូចក្នុងពាក្យនេះថា **ចិត្តគូ បទ្ធគូ** ហេតុនោះ ទើបសព្ទនេះមិនខុស ឬគប្បីឃើញដោយវិសេសនៈទាំង ២ សព្ទ ដូចបាឋៈថា **អាហិតគ្គិ** ជាដើម ។ បទថា **វិនាយកោ** មានវិគ្គហៈថា ឈ្មោះថា **វិនាយក** ព្រោះទ្រង់ដឹកនាំ គឺទ្រង់បង្ហឹកសត្វទាំងឡាយ ដោយឧបាយជាគ្រឿងទូន្មានដ៏ច្រើន ។ បទថា **សត្ថា** មានវិគ្គហៈថា ឈ្មោះថា **សត្ថា** ព្រោះទ្រង់ប្រៀនប្រដៅសត្វទាំងឡាយ តាមការសមគួរ ដោយប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ខាងមុខ ។ បទថា **អហុ** គឺមានហើយ ។ បទថា **ទេវមនុស្សបូជិតោ** សេចក្តីថា ឈ្មោះថា **ទេវ** ព្រោះត្រេកអរក្នុងការលេង ដោយអំណាចកាមគុណ ៥ ដែលជាទិព្វ ។ ឈ្មោះថា **មនុស្ស** ព្រោះមានចិត្តខ្ពស់ ។ ទេវតាផង មនុស្សផង ឈ្មោះថា **ទេវមនុស្ស** ។ អ្នកបានទទួលការបូជាអំពីទេវតា និងមនុស្សឈ្មោះថា **ទេវមនុស្សបូជិតោ** ដែលទេវតា និងមនុស្សទាំងឡាយបូជាដោយផ្កាជាដើម និងបូជាដោយបច្ច័យ អធិប្បាយថា គោរពក្រែងហើយ ។ សួរថា ព្រោះហេតុអ្វី ទើបលោកកាន់យកតែទេវតា និងមនុស្សប៉ុណ្ណោះ សត្វទាំងឡាយ សូម្បីជាសត្វតិរច្ឆាន ដូចជាដំរីឈ្មោះអាវាឡៈ កាលាបលាលៈ ធនបាល បាលិលេយ្យកៈជាដើម សូម្បីពួកវិនិបាតិកៈ ដូចជាយក្ខឈ្មោះសាតាគិរៈ អាឡវកៈ ហេមវតៈ សូចិលោមៈ ខរលោមៈជាដើម ក៏បូជាព្រះ

មានព្រះភាគដែរ មិនមែនឬ ឆ្លើយថា សេចក្តីនោះ ពិត តែពាក្យនេះគប្បី ឃើញថា លោកពោលដោយកំណត់យ៉ាងឧក្រិដ្ឋ និងដោយកំណត់ចំពោះ កព្វបុគ្គល ។ បទថា **មហានុភាវោ** បានដល់ ដែលប្រកបហើយដោយ ពុទ្ធានុភាពធំ ។ បទថា **សតបុញ្ញលក្ខណោ** សេចក្តីថា សត្វទាំងអស់ ក្នុង អានន្តចក្កវាឡ គប្បីធ្វើបុញ្ញកម្មណាមួយ រាប់រយដង ព្រះពោធិសត្វតែមួយ អង្គឯង ក៏ធ្វើកម្មដែលជនទាំងឡាយ មានប្រមាណប៉ុណ្ណោះ ធ្វើហើយជា ១០០ ដង ទើបកើតឡើង ព្រោះហេតុនោះ ទើបលោកហៅថា **សតបុញ្ញ-លក្ខណោ** មានបុញ្ញលក្ខណៈច្រើន ។ តែអាចារ្យពួកខ្លះពោលថា ទ្រង់មាន លក្ខណៈនីមួយៗ ដែលកើតឡើងព្រោះបុញ្ញកម្មជាមួយរយៗ ពាក្យនោះ លោកជំទាស់ក្នុងអដ្ឋកថាថា កាលបើយ៉ាងនោះ បុគ្គលណានីមួយ ក៏គប្បីជា ព្រះពុទ្ធបាន ។ បទថា **ឧស្សេសិ** បានដល់ ទ្រង់សម្តែងយមកប្បាដិហារ្យ ដែលធ្វើនូវការចម្លែកចិត្តក្រៃលែងដល់ទេវតា និងមនុស្សទាំងពួង ។

គ្រានោះ ព្រះសាស្តាកាលទ្រង់ធ្វើបាដិហារ្យក្នុងអាកាសហើយ ទ្រង់ក៏ ប្រមើលមើលអាចារផ្លូវចិត្តនៃមហាជន មានពុទ្ធបំណងចង្រ្កម ត្រាស់ធម្ម-កថា ដែលឧបការៈដល់អជ្ឈាស្រ័យរបស់មហាជននោះ ទើបទ្រង់និម្មិតរតន-ចង្រ្កម ដែលសម្រេចដោយរតនៈទាំងអស់ ទទឹងប៉ុនម៉ឺនចក្កវាល ក្នុង អាកាស ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា

គ្រានោះ ព្រះពុទ្ធមានចក្ខុអង្គនោះ ទ្រង់ឧត្តមជាងនរៈ ដែល
ទេវតាដ៏ប្រសើរអារាធនាហើយ ក៏ទ្រង់ពិចារណានូវអត្ថ ព្រះ

លោកនាយក ទ្រង់និម្មិតទីចង្ក្រម តាក់តែងដោយរតនៈ
ទាំងអស់ សម្រេចដោយល្អហើយ ។

បណ្ដាបទទាំងនោះ បទថា **សោ** បានដល់ ព្រះសាស្ដាអង្គនោះ ។ បទថា **យាចិតោ** សេចក្ដីថា ត្រូវទូលអារាធនាឲ្យទ្រង់សម្ដែងធម៌ក្នុងសប្ដាហ៍ ទី ៨ ជាលើកដំបូងនោះឯង ។ បទថា **ទេវេហេ** បានដល់ សហម្បតីព្រហ្ម ។ ក្នុងបទ **ចក្ខុមា** នេះ មានវិគ្គហៈថា ឈ្មោះថា **ចក្ខុម** ព្រោះទ្រង់ឃើញ អធិប្បាយថា ទ្រង់ឃើញច្បាស់នូវទីរាបស្មើ និងទីមិនរាបស្មើ ។

ចក្ខុនោះមាន ២ យ៉ាង គឺញាណចក្ខុ និងមំសចក្ខុ ។ បណ្ដាចក្ខុទាំង ២ នោះ ញាណចក្ខុមាន ៥ យ៉ាង គឺពុទ្ធចក្ខុ ១ ធម្មចក្ខុ ១ សមន្តចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញា ១ ។

បណ្ដាចក្ខុទាំង ៥ នោះ បញ្ញាដែលដឹងអាសយៈ និងអនុសយៈ និង បញ្ញាដែលឈមចុះ ដឹងនូវការទន់ខ្សោយ និងការចាស់ក្លានៃឥន្ទ្រិយ ដែល មកក្នុងបាលី ( ទីឃនិកាយ មហាវគ្គ ) ថា ទ្រង់ប្រមើលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ ឈ្មោះថា **ពុទ្ធចក្ខុ**។

មគ្គ ៣ ផល ៣ ខាងក្រោម ដែលមកក្នុងបាលី ( ទីឃនិកាយ សីលក្ខន្ធ ) ថា ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដែលប្រាសចាកធូលី ប្រាសចាក មន្ទិល នឹងកើតឡើង ឈ្មោះថា **ធម្មចក្ខុ**។

ព្រះសព្វញ្ញុតញ្ញាណដែលមកក្នុងបាលី ( វិនយបិដក មហាវគ្គ ) ថា បពិត្រព្រះអង្គមានបញ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គជាអ្នកមានសេចក្ដី

សោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទដ៏ហើយ ដោយធម៌មាន ឧបមាដូច្នោះដែរ ឈ្មោះថា **សមន្តចក្ខុ**។

ញាណដែលប្រកបព្រមដោយអភិញ្ញាចិត្ត ដែលកើតឡើងដោយការចម្រើនអាលោកកសិណសមាបត្តិ ដែលមកក្នុងបាលី ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ចក្ខុដូចជាទិព្វដ៏បរិសុទ្ធ ឈ្មោះថា **ទិព្វចក្ខុ**។

ញាណដែលមកហើយថា បញ្ញាចក្ខុ មានបុព្វេនិវាសញ្ញាណជាដើម ដែលមកក្នុងបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) ថា ចក្ខុកើតឡើង ញាណកើតឡើង ឈ្មោះថា **បញ្ញាចក្ខុ**។

មំសចក្ខុ ជាទីអាស្រ័យនៃបសាទ ដែលមកក្នុងបាលី ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ព្រោះអាស្រ័យចក្ខុបសាទ និងរូបារម្មណ៍ ឈ្មោះថា **មំសចក្ខុ**។

មំសចក្ខុនោះមាន ២ គឺសសម្ភារចក្ខុ ១ បសាទចក្ខុ ១ ។ បណ្ដាចក្ខុទាំង ២ នោះ ដុំសាច់ណាដែលគ្របកន្ទែកទាំងឡាយព័ទ្ធក្នុងប្រឡង់ភ្នែក ក្នុងដុំសាច់ណាមានចំណែកប្រកប ១៣ ចំណែកដោយសង្ខេប គឺធាតុ ៤ ពណ៌ ក្លិន រស ឱជា សម្ភវ ជីវិត ភាវៈ ចក្ខុបសាទ កាយបសាទ តែដោយពិស្ដារ មាន ( ៤០ ) គឺរូប ៣៦[១] ដែលកើតអំពីសមុដ្ឋាន ៤ និងរូបដែលមានកម្មជាសមុដ្ឋាន ៤ គឺជាជីវិត ភាវៈ ចក្ខុបសាទ កាយបសាទ នេះ ឈ្មោះថា **សសម្ភារចក្ខុ**។

---

១- រូប ៣៦ គឺធាតុ ៤ ពណ៌ ក្លិន រស ឱជា សម្ភវ រួមជា ៩ គុណនឹងសមុដ្ឋាន ៤ រួមជា ៣៦ ។

ចក្ខុណា តាំងនៅក្នុងវង្វង់មូល ជាគ្រឿងឃើញ ដែលត្រូវវង្វង់មូលពណ៌ខ្មៅ ព័ទ្ធដោយវង្វង់មូលពណ៌ស ត្រឹមតែជាបសាទ អាចឃើញរូបបាន ចក្ខុនេះ ឈ្មោះថា **បសាទចក្ខុ**។

ចក្ខុទាំងអស់មានតែ ១ ដោយភាពមិនទៀង និងមានបច្ច័យប្រជុំតាក់តែង ។ មាន ២ យ៉ាង ដោយប្រព្រឹត្តទៅជាមួយអាសវៈ និងមិនប្រព្រឹត្តទៅជាមួយអាសវៈ ដោយជាលោកិយ និងលោកុត្តរ ។ មាន ៣ យ៉ាង ដោយភូមិ និងដោយឧបាទិន្នតិក ។ មាន ៤ យ៉ាង ដោយជាឯកន្តារម្មណ៍ បរិត្តារម្មណ៍ អប្បមាណារម្មណ៍ និងអនិយតារម្មណ៍ ។ មាន ៥ យ៉ាង ដោយជារូបារម្មណ៍ និព្វានារម្មណ៍ អរូបារម្មណ៍ សព្វារម្មណ៍ និងអនារម្មណ៍ ។ មាន ៦ យ៉ាង ដោយអំណាចពុទ្ធចក្ខុជាដើម ចក្ខុដូចពោលមកនេះ មានដល់ព្រះមានព្រះភាគអង្គនោះ ហេតុនោះ ទើបព្រះមានព្រះភាគ លោកហៅថា **ចក្ខុមា**។

បទថា **អត្ថំ សមេក្ខិត្វា** បានដល់ ទ្រង់និម្មិតទីចង្ក្រម អធិប្បាយថា ទ្រង់ពិចារណាប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ ដែលជានិមិត្តនៃការសម្តែងធម៌ ។ បទថា **មាបយិ** បានដល់ ទ្រង់និម្មិត ។ បទថា **លោកនាយកោ** មានវិគ្គហៈ ឈ្មោះថា ជាលោកនាយក ព្រោះទ្រង់នាំសត្វលោកបែរមុខតម្រង់ទៅកាន់ស្ថានសួគ៌ និងនិព្វាន ។ បទថា **សុនិដ្ឋិតំ** បានដល់ សម្រេចដោយល្អ អធិប្បាយថា ចប់ហើយ ។ បទថា **សព្វរតននិម្មិតំ** បានដល់ សម្រេចដោយរតនៈ ១០ យ៉ាង ។ ឥឡូវនេះ ដើម្បី

សម្តែងការដល់ព្រមដោយបាដិហារ្យ ៣ យ៉ាងរបស់ព្រះមានព្រះភាគ ទើបព្រះសង្គីតិកចារ្យពោលថា

ព្រះមានព្រះភាគទ្រង់ស្ទាត់ក្នុងបាដិហារ្យ ៣ យ៉ាង គឺឥទ្ធិ-
បាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនី-
បាដិហារ្យ ១ ព្រះលោកនាយក ទ្រង់និម្មិតទីចង្ក្រម តាក់តែង
ដោយរតនៈទាំងអស់ សម្រេចល្អហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទ្ធិ** បានដល់ ការសម្តែងឫទ្ធិ ឈ្មោះថា **ឥទ្ធិប្បាដិហារិយ** ។ ឥទ្ធិប្បាដិហារ្យនោះ មកដោយន័យជាដើមថា មនុស្សម្នាក់អធិដ្ឋានឲ្យជាមនុស្សច្រើន មនុស្សច្រើននាក់ អធិដ្ឋានឲ្យជាមនុស្សម្នាក់ ។ បទថា **អាទេសនា** បានដល់ ការដឹងអាចារផ្លូវចិត្តរបស់អ្នកដទៃ ហើយពោល ឈ្មោះថា **អាទេសនាបាដិហារិយ** ។ អាទេសនាបាដិហារ្យនោះ គឺការសម្តែងធម៌ជាប្រចាំរបស់សាវកទាំងឡាយ និងរបស់ព្រះពុទ្ធទាំងឡាយ ។ បទថា **អនុសាសនី** គឺអនុសាសនីបាដិហារ្យ អធិប្បាយថា ឱវាទដែលអនុគ្រោះដល់អធ្យាស្រ័យរបស់មហាជននោះៗ ។ បាដិហារ្យ ៣ នេះ មានដូចពោលមក ដូច្នេះ ។ បណ្តាបាដិហារ្យ ៣ នោះ អនុសាសនីបាដិហារ្យផង ឥទ្ធិប្បាដិហារ្យផង ជាអាចិណ្ណបដិបត្តិរបស់ព្រះមហាមោគ្គល្លាន ។ អនុសានីបាដិហារ្យផង អាទេសនាបាដិហារ្យផង ជាអាចិណ្ណបដិបត្តិរបស់ព្រះធម្មសេនាបតី ឯអនុសានីបាដិហារ្យ ជាការសម្តែងធម៌ប្រចាំរបស់ព្រះពុទ្ធទាំងឡាយ ។ បទថា **តិបាដិហីរេ** បានដល់ ក្នុងបាដិហារ្យ ៣ នេះ ។ បទ

ថា **ភគវា** នេះ ជាឈ្មោះរបស់បុគ្គលដែលគួរគោរពក្នុងឋានៈជាគ្រូ ឧត្តមក្នុងសត្វ ប្រសើរបំផុតដោយគុណ សមដូចបុរាណាចារ្យពោលថា

ពាក្យថា **ភគវា** ជាពាក្យប្រសើរបំផុត ពាក្យថា **ភគវា**
ជាពាក្យឧត្តម ទ្រង់ជាបុគ្គលគួរដល់ការគោរព ក្នុងឋានៈ
ជាគ្រូ ដោយហេតុនោះ ទើបគេហៅថា **ភគវា**។

បទថា **វសី** បានដល់ ដល់នូវភាពជាអ្នកជំនាញក្នុងបាដិហារ្យ ៣ យ៉ាងនេះ អធិប្បាយថា ប្រព្រឹត្តវសីជានិច្ច ។ វសី ៥ គឺអាវជ្ជនវសី ១ សមាបជ្ជនវសី ១ អធិដ្ឋានវសី ១ វុដ្ឋានវសី ១ បច្ចវេក្ខណវសី ១ ឈ្មោះថា **វសី**។

បណ្តាវសីទាំងនោះ ព្រះមានព្រះភាគ ទ្រង់នឹកដល់ឈានណាមួយតាមប្រាថ្នា តាមពេលប្រាថ្នា រយៈពេលដែលប្រាថ្នា ការយឺតយូរក្នុងការនឹកមិនមានឡើយ ហេតុនោះ ភាពដែលទ្រង់នឹងបានរហ័ស ទើបឈ្មោះថា **អាវជ្ជនវសី** ។ ទ្រង់ចូលឈានណាមួយតាមប្រាថ្នា ។បេ។ ក៏ដូចគ្នា ការយឺតយូរក្នុងការចូលឈានមិនមានឡើយ ហេតុនោះ ភាពដែលទ្រង់អាចចូលឈានបានរហ័ស ទើបឈ្មោះថា **សមាបជ្ជនវសី** ។ ភាពដែលទ្រង់តាំងនៅបានអស់កាលរហ័ស ទើបឈ្មោះថា **អធិដ្ឋានវសី** ។ ភាពដែលទ្រង់អាចចេញចាកឈានបានរហ័សក៏ដូចគ្នា ទើបឈ្មោះថា **វុដ្ឋានវសី** ។ ឯបច្ចវេក្ខណវសី ជាបច្ចវេក្ខណជវនចិត្តទាំងអស់ បច្ចវេក្ខណជវនចិត្តទាំងនោះកើតឡើងក្នុងលំដាប់បន្ទាប់អំពីអាវជ្ជនចិត្តនោះឯង ហេតុនោះ ទើបលោក

ពោលដោយអាវជ្ជវសីនោះឯង ភាពដែលទ្រង់ជាអ្នកជំនាញក្នុងវសី ៥ នេះ ឈ្មោះថា ទ្រង់ជាអ្នកជំនាញ ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា ព្រះមានព្រះភាគទ្រង់ស្ទាត់ក្នុងបាដិហារ្យ ៣ ដូច្នេះ ។

ឥឡូវនេះ ដើម្បីសម្ដែងវិធីនិម្មិតរតនចង្ក្រមនោះ ទើបសង្គីតិកាចារ្យទាំងឡាយពោលគាថាជាដើមថា

ព្រះអង្គទ្រង់សម្ដែង ( នូវបាដិហារ្យ ) លើទីចង្ក្រម សម្រេច
ដោយកែវ លើភ្នំសិនេរុដ៏ឧត្ដម ដោយលំដាប់ ដូចជាសសរ
នៃលោកធាតុទាំងមួយម៉ឺន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទសសហស្សី លោកធាតុយា** បានដល់ក្នុងម៉ឺនចក្កវាឡ ។ បទថា **សិនេរុបព្វតុត្តមេ** បានដល់ ភ្នំដ៏ប្រសើរ ដែលហៅថា **មហាមេរុ**។ បទថា **ថម្ភេវ** សេចក្ដីថា ទ្រង់ធ្វើសិនេរុបព៌តក្នុង ម៉ឺនចក្កវាឡឲ្យដូចជាសសរតាំងនៅរៀងគ្នា ទ្រង់ធ្វើឲ្យដូចជាសសរមាស ហើយទ្រង់និម្មិតទីចង្ក្រមខាងលើសសរទាំងនោះសម្ដែងហើយ ។ បទថា **រតនា-មយេ** គឺ **រតនមយេ** ប្រែថា សម្រេចដោយរតនៈ ។

បទថា **ទសសហស្សី អតិក្កម្ម** សេចក្ដីថា ព្រះមានព្រះភាគកាលទ្រង់និម្មិតរតនចង្ក្រម ទ្រង់ក៏និម្មិតធ្វើចុងម្ខាងនៃរតនចង្ក្រមនោះឲ្យកល់លើកណ្ដាប់ចក្កវាឡ ទាំងទិសខាងកើត ធ្វើចុងម្ខាងទៀតឲ្យកល់លើកណ្ដាប់ចក្កវាឡទិសខាងលិច ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលថា

ព្រះជិនស្រី ទ្រង់និម្មិតទីចង្ក្រមជាវិការនៃមាសសុទ្ធ ត្រង់ខាងនៃទីចង្ក្រមដ៏សម្រេចដោយកែវ កន្លងលោកធាតុមួយម៉ឺន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជិនោ** បានដល់ ឈ្មោះថា **ជិន** ព្រោះទ្រង់ឈ្នះសត្រូវ គឺកិលេស ។ បទថា **សព្វសោណ្ណមយា បស្សេ** សេចក្តីថា ខាងចុងសងខាងនៃទីចង្ក្រមដែលទ្រង់និម្មិតនោះ ជាវិការនៃមាស គួរជាទីត្រេកអរក្រៃលែង អធិប្បាយថា ត្រង់កណ្តាលជាកែវមណី ។

បទថា **តុលាសង្ឃាដា** បានដល់ គូនៃផ្ទោង ។ គូនៃផ្ទោងនោះ គប្បីជ្រាបថា ជារតនៈផ្សេងៗ ។ បទថា **អនុវគ្គា** បានដល់ ស្របតាមគ្នា ។ បទថា **សោវណ្ណផលកត្ថតា** បានដល់ ក្រាលដោយបន្ទះក្តារដែលសម្រេចអំពីមាស អធិប្បាយថា ដំបូលជាមាសខាងលើផ្ទោង ។ បទថា **វេទិកា សព្វសោវណ្ណា** សេចក្តីថា វេទិកា ( ក្ដាក់ដៃ ) ជាមាសទាំងអស់ ឯវេទិកាដែលព័ទ្ធទីចង្ក្រម ក៏មានវេទិកាមាសតែម្យ៉ាង មិនលាយឡំជាមួយរតនៈដទៃៗ ។ បទថា **ឧភតោ បស្សេសុ និម្មិតា** បានដល់ ទ្រង់និម្មិតទីទាំងសងខាង ។ **ឧ** អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទ ។

បទថា **មណិមុត្តាវាលុកាកិណ្ណា** បានដល់ រោយដោយខ្សាច់ដែលជាកែវមណី និងកែវមុក្តា ។ ម្យ៉ាងទៀត កែវមណីផង កែវមុក្តាផង ខ្សាច់ផង ឈ្មោះថា **មណិមុត្តាវាលុកា** ។ ដេរដាស គឺក្រាលដោយកែវមណី កែវមុក្តា និងខ្សាច់ទាំងនោះ ហេតុនោះ ទើបឈ្មោះថា **មណិមុត្តាវាលុកា-**

**កតិណ្ណា** ។ បទថា **និម្មិតោ** បានដល់ ទ្រង់និម្មិត គឺទ្រង់ធ្វើដោយអាការនេះ ។ បទថា **រតនាមយោ** បានដល់ ទីចង្ក្រមសម្រេចដោយរតនៈទាំងអស់ ។ បទថា **ឱភាសេតិ ទិសា សព្វា** បានដល់ បែងចាំងសព្វទិសទាំង ១០ ។ បទថា **សតរំសីវ** បានដល់ ដូចព្រះអាទិត្យ ១០០០ បញ្ចេញរស្មី ដូច្នោះ ។ បទថា **ឧគ្គតោ** បានដល់ រះឡើង អធិប្បាយថា ព្រះអាទិត្យរះឡើង រមែងបែងចាំងទាំង ១០ ទិស យ៉ាងណា ទីចង្ក្រមដែលជារតនៈទាំងអស់នេះ ក៏បញ្ចេញរស្មីដូច្នោះដូចគ្នា ។

ឥឡូវនេះ កាលទីចង្ក្រមសម្រេចហើយ ដើម្បីសម្តែងការប្រព្រឹត្តទៅនៃព្រះមានព្រះភាគក្នុងទីចង្ក្រមនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយ ពោលគាថាថា

ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ទ្រង់មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ទ្រង់រុងរឿងក្នុងទីចង្ក្រមនោះ ព្រះជិនស្រី ទ្រង់ចង្ក្រមលើទីចង្ក្រម ។ ទេវតាទាំងអស់ មកប្រជុំគ្នាហើយ រោយរាយនូវផ្កាមន្ទារវៈ ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្ស ជាទិព្វក្នុងទីចង្ក្រម ។ ពួកទេវតាមួយម៉ឺនលោកធាតុ ដែលមកប្រជុំគ្នាបានឃើញព្រះមានព្រះភាគអង្គនោះ ក៏មានចិត្តត្រេកអររីករាយ ហើយក្រាបថ្វាយបង្គំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធីរោ** បានដល់ ដែលប្រកបដោយធិតិ-ប្បញ្ញា ។ បទថា **ទ្វត្តឹសវរលក្ខណោ** សេចក្តីថា ទ្រង់ប្រកបដោយព្រះ

មហាបុរិសលក្ខណៈ ៣២ ប្រការ មានផ្ទៃព្រះបាទតម្កល់ដោយល្អជាដើម ។ បទថា **ទិព្វំ** បានដល់ ផ្កាដែលកើតក្នុងទេវលោក ឈ្មោះថា ជារបស់ទិព្វ ។ បទថា **ឆារិជត្តកំ** សេចក្តីថា ដើមបារិច្ឆត្តកៈដែលគួរសរសើរក្រៃលែង ទំហំ ១០០ យោជន៍ដោយជុំវិញ កើតព្រោះផលបុណ្យនៃការថ្វាយដើមរលួសផ្អុំ របស់ទេវតាជាន់តាវត្តិង្ស ។ កាលបារិច្ឆត្តកៈដើមណាមានផ្ការីកហើយ ទេវតាក្នុងទេវនគរ នឹងអប់ដោយក្លិនតែម្យ៉ាង ក្រអូបដូចគ្នា ។ វិមានមាសថ្មីទាំងឡាយ ដែលដេរដាសដោយលម្អងផ្ការបស់បារិច្ឆត្តកៈនោះ នឹងប្រាកដជាពណ៌ក្រហមព្រៀងៗ ផ្ការបស់បារិច្ឆត្តកៈនេះ លោកហៅថា **ឆារិច្ឆត្តក** ។ បទថា **ចង្កមេ ឱកិរន្តិ** បានដល់ រមែងរោយចុះត្រង់រតនចង្ក្រមនោះ សេចក្តីថា បូជាព្រះមានព្រះភាគ ដែលកំពុងចង្ក្រមក្នុងទីចង្ក្រមនោះ ដោយផ្កាដូចពោលនោះ ។ បទថា **សព្វេ ទេវា** បានដល់ ទេវតាទាំងឡាយ មានទេវតាដែលជាកាមាវចរជាដើម ។ ដោយហេតុនោះ ទើបលោកពោលថា **បស្សន្តិ តំ ទេវសង្ឃា** អធិប្បាយថា ពួកទេវតាឃើញព្រះមានព្រះភាគអង្គនោះ ដែលទ្រង់ចង្ក្រមក្នុងរតនចង្ក្រម ក្នុងសុរាល័យទាំងឡាយរបស់ខ្លួនឯង ។ បទថា **ទសសហស្សី** ជាបឋមាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ អធិប្បាយថា ពួកទេវតាក្នុងម៉ឺនលោកធាតុ ឃើញព្រះមានព្រះភាគអង្គនោះ ។ បទថា **បមោ-ទិតា** ប្រែថា ត្រេកអរ ។ បទថា **និបតន្តិ** បានដល់ ប្រជុំគ្នា ។ បទថា **តុដ្ឋហដ្ឋា** បានដល់ ត្រេកអរដោយអំណាចបីតិ គប្បីឃើញការភ្ជាប់សេចក្តីថា បទថា **បមោទិតា** បានដល់ ត្រេកអរជាមួយទេវតាទាំងឡាយ មានទេវតា

ជាន់តាវត្តិង្សជាដើម ដែលគប្បីពោលក្នុងឥឡូវនេះ ការក្ដាប់សេចក្ដីក្រៅអំពីនេះ ក៏មិនផុតទោស គឺការពោលដដែល ។ ម្យ៉ាងទៀត សេចក្ដីថា ទេវតាទាំងឡាយត្រេកអរហើយ ឃើញព្រះមានព្រះភាគអង្គនោះ សប្បាយរីករាយ ហើយនាំគ្នាប្រជុំក្នុងទីនោះៗ ។

ឥឡូវនេះ ដើម្បីសម្ដែងដល់ពួកទេវតាដែលឃើញ ហើយប្រជុំគ្នាដោយសរុប ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថាទាំងនេះថា

ទេវតាទាំងឡាយណា ជាន់តាវត្តិង្សផង ជាន់យាមៈផង ជាន់តុសិតផង ទេវតាជាន់និម្មានរតីផង ទេវតាជាន់វសវត្តីផង ទេវតាទាំងនោះ មានចិត្តអណ្ដែតខ្ពស់ឡើង មានចិត្តរីករាយ រមិលមើលព្រះលោកនាយក ។

ពួកទេវតា ពួកគន្ធព្វ ពួកមនុស្ស និងពួកអារក្ស ពួកនាគ ពួកគ្រុឌ ទាំងពួកកិន្នរ ក៏ឃើញព្រះសម្ពុទ្ធម្ចាស់ ទ្រង់មានព្រះហឫទ័យអនុគ្រោះដោយប្រយោជន៍ ដល់សត្វលោកនោះ ហាក់ដូចជាមណ្ឌលព្រះចន្ទ ខ្ពស់ត្រដែតព្ធដ៏អាកាស ។

ពួកព្រហ្មជាន់អាភស្សរៈផង ជាន់សុភកិណ្ហៈផង ជាន់វេហប្ផលៈផង ជាន់អកនិដ្ឋៈផង ស្លៀកសំពត់សសុទ្ធ ឈរផ្គងអញ្ជលី ។

( ពួកព្រហ្មទាំងនោះ ) បញ្ចេញនូវផ្កាមន្ទារវបុស្ស មានពណ៌ ៥ ដ៏លាយដោយលម្អិតខ្លឹមចន្ទន៍ផង បង្វិល គ្រវីសំពត់ទាំង

ឡាយផង ឮដ៏អាកាស ក្នុងកាលនោះ ( ហើយពោលថា )
អើហ្ន៎ ព្រះជិនស្រី ទ្រង់អនុគ្រោះដោយប្រយោជន៍ ដល់សត្វ
លោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទគ្គចិត្តា** បានដល់ ជាអ្នកមានចិត្តត្រេកអរដោយអំណាចបីតិសោមនស្ស ។ បទថា **សុមនា** បានដល់ អ្នកមានចិត្តល្អ ព្រោះជាអ្នកមានចិត្តរីក ។ បទថា **លោកហិតានុកម្បកំ** បានដល់ ទ្រង់ឲ្យប្រយោជន៍ដល់លោក ទ្រង់អនុគ្រោះលោក ឬអនុគ្រោះដោយប្រយោជន៍ដល់លោក ឈ្មោះថា **លោកហិតានុកម្បក** ។ បទថា **នភេវ អច្ចុគ្គតចន្ទមណ្ឌលំ** សេចក្ដីថា នាំគ្នាសរសើរព្រះមានព្រះភាគដែលរុងរឿងដោយពុទ្ធសិរី ដែលធ្វើសេចក្ដីត្រេកអរដល់ភ្នែក ដូចសរសើរព្រះចន្ទពេញវង់ក្នុងសរទរដូវ ដែលផុតចាកឧទ្ទវទាំងពួង ដែលទើបតែរះក្នុងអាកាស ។

បទថា **អាភស្សរា** លោកពោលដោយកំណត់ភូមិដ៏ឧត្ដម ព្រហ្មជាន់បរិត្តាភា អប្បមាណាភា និងអាភស្សរាដែលកើតដោយទុតិយជ្ឈាន មានកម្លាំងតិច កណ្ដាល និងប្រណីត គប្បីជ្រាបថា លោកកាន់យកទាំងអស់ ។ បទថា **សុភកិណ្ហា** នេះ លោកក៏ពោលដោយកំណត់ភូមិដែលឧត្ដមដូចគ្នា ព្រោះហេតុនោះ ព្រហ្មជាន់បរិត្តសុភា ជាន់អប្បមាណសុភា និងជាន់សុភកិណ្ហៈ ដែលកើតដោយតតិយជ្ឈាន ដែលមានកម្លាំងតិចជាដើម ក៏គប្បីជ្រាបថា លោកកាន់យកទាំងអស់ដូចគ្នា ។ បទថា **វេហប្ផលា** ឈ្មោះថា វេហប្ផលា ព្រោះមានផលបរិបូណ៌ ។ ព្រហ្មជាន់វេហប្ផលាទាំងនោះ កើតដោយចតុត្ថជ្ឈាន

នៅជាន់ជាមួយអសញ្ញសត្តព្រហ្មទាំងឡាយ ។ តែទេវតាដែលទាក់ទងក្នុងពួកព្រហ្មជាដើម ដែលកើតដោយបឋមជ្ឈាន លោកសម្តែងក្នុងភូមិជាន់ទាប ព្រោះហេតុនោះ ទើបលោកមិនសម្តែងក្នុងទីនេះ ។ អសញ្ញសត្ត និងអរូបិសត្វ លោកមិនបានលើកឡើងសម្តែងក្នុងទីនេះ ព្រោះមិនមានចក្ខុ និងសោតៈ ។ បទថា **អកនិដ្ឋា ច ទេវតា** លោកពោលក្នុងទីនេះ ដោយកំណត់ភូមិចុងក្រោយដូចគ្នា ។ ព្រោះហេតុនោះ ព្រហ្មជាន់សុទ្ធាវាសទាំង ៥ គឺអវិហា អតប្បា សុទស្សា សុទស្សី និងអកនិដ្ឋា គប្បីជ្រាបថា លោកកាន់យកផងដែរ ។ បទថា **សុសុទ្ធសុក្កវត្ថវសនា** បានដល់ សំពត់ទាំងឡាយដែលស្អាតដោយល្អ គឺបរិសុទ្ធល្អ ជាសំពត់សផូរផង់ ។ សំពត់សស្អាតល្អ ដែលព្រហ្មពួកណាស្លៀកដណ្តប់ហើយ ព្រហ្មទាំងនោះ ឈ្មោះថា ស្លៀកដណ្តប់សំពត់សដែលស្អាតល្អ អធិប្បាយថា ដែលស្លៀកដណ្តប់នូវសំពត់សបរិសុទ្ធ ។ បាឋៈថា **សុសុទ្ធសុក្កវសនា** ដូច្នេះក៏មាន ។ បទថា **បញ្ជលី-កតា** សេចក្តីថា ឈរផ្គងអញ្ជលី គឺធ្វើអញ្ជលីដូចផ្កាឈូកក្រពុំលើសិរសា ។

បទថា **មុញ្ចន្តិ** បានដល់ រោយចុះ ។ បទថា **បុប្ផំ បន** បានដល់ ផ្កា ។ បាឋៈថា **បុប្ផានិវា** ដូច្នេះក៏មាន គប្បីឃើញថា ជាវចនវិបល្លាស តែអត្ថនៃពាក្យនោះក៏យ៉ាងនោះដូចគ្នា ។ បទថា **បញ្ចវណ្ណិកំ** បានដល់ មានពណ៌ ៥ គឺពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស និងពណ៌ក្រហមចាស់ ។ បទថា **ចន្ទនចុណ្ណមិស្សិតំ** បានដល់ ផ្សំដោយលម្អិតខ្លឹមចន្ទន៍ ។ បទថា **ភមេន្តិ ចេលានិ** បានដល់ គ្រវីនូវសំពត់ទាំងឡាយ ។ បទថា **អហោ**

**ឯតោ លោកហិតានុកម្បកោ** បានដល់ និយាយពាក្យពីរោះជាដើម យ៉ាងនេះថា ឱ ! ព្រះជិនស្រី ទ្រង់នាំប្រយោជន៍ដល់លោក ឱ ! ទ្រង់អនុគ្រោះដល់លោក ឱ ! ទ្រង់មានព្រះករុណា គប្បីភ្ជាប់សេចក្តីថា រោយនូវផ្កា គ្រវីនូវសំពត់ទាំងឡាយ ។

ឥឡូវនេះ ដើម្បីសម្តែងពាក្យសរសើរដែលព្រហ្មទាំងនោះប្រកបហើយ ទើបព្រះសង្គីតិកាចារ្យទាំងឡាយ ពោលគាថាទាំងនេះថា

ព្រះអង្គជាសាស្តាចារ្យផង ជាទង់ផង ជាទង់ជ័យផង ជាប្រាសាទផង ជាទីពឹងប្រព្រឹត្តទៅខាងមុខផង ជាប្រទីបរបស់ពួកសត្វផង ទ្រង់ឧត្តមជាងសត្វជើង ២ ផង ។ ពួកទេវតាក្នុងមួយម៉ឺនលោកធាតុ ដែលមានឫទ្ធិច្រើន មានចិត្តត្រេកអរស្រស់ស្រាយរីករាយ មកចោមរោម ហើយថ្វាយបង្គំ ។ ពួកទេវតា និងពួកទេពកញ្ញាមានចិត្តជ្រះថ្លា មានចិត្តត្រេកអរបូជាព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងនរៈ ដោយផ្កាមានពណ៌ ៥ ។ ពួកទេវតាទាំងឡាយ មានចិត្តជ្រះថ្លា មានចិត្តត្រេកអរ ឃើញព្រះអង្គ ក៏នាំគ្នាបូជាព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងនរៈ ដោយផ្កាមានពណ៌ ៥ ( ហើយពោលថា ) ឱហ្ន៎ អស្ចារ្យចម្លែកណាស់ គួរឲ្យព្រឺរោមក្នុងលោក ឯសេចក្តីអស្ចារ្យ គួរឲ្យព្រឺរោមបែបនេះ មិនដែលកើតឡើងសោះឡើយ ។ ពួកទេវតាទាំងនោះ អង្គុយក្នុងភពរបស់ខ្លួនៗ រីករាយខ្លាំង ព្រោះ

ឃើញនូវសេចក្ដីអស្ចារ្យ ឰដ៏អាកាស ។ ពួកអាកាសដ្ឋក-
ទេវតា ពួកភុម្មដ្ឋកទេវតា និងពួកទេវតាដែលនៅអាស្រ័យ
ឰដ៏ស្មៅ និងឈើជាថ្នាំ ត្រេកអរស្រស់ស្រាយ រីករាយខ្លាំង
នាំគ្នាផ្គងអញ្ជលីនមស្ការ ។ ទាំងពួកនាគ ដែលមានអាយុវែង
មានបុណ្យច្រើន មានឫទ្ធិច្រើន ក៏រីករាយ ថ្វាយបង្គំ បូជា
ព្រះពុទ្ធដ៏ខ្ពង់ខ្ពស់ជាងនរៈដែរ ។ ចម្រៀងទាំងឡាយ ប្រព្រឹត្ត
ទៅឰដ៏អាកាស ជាផ្លូវនៃខ្យល់ ពួកទេវតាក៏វាយស្គរ ព្រោះ
ឃើញនូវសេចក្ដីអស្ចារ្យឰដ៏អាកាស ស័ង្ខ ស្រឡៃ សម្ភោរ
ដ៏ច្រើន ក៏ប្រគំលាន់ឮឡើងក្នុងកណ្ដាលអាកាស ព្រោះឃើញ
នូវសេចក្ដីអស្ចារ្យ ឰដ៏អាកាស ។ ការព្រឺរោមកើតឡើងដល់
ពួកយើង ក្នុងថ្ងៃនេះ ចម្លែកពេកណាស់ហ្ន៎ ពួកយើងបាននូវ
ការសម្រេចប្រយោជន៍ដ៏ទៀងទាត់ ខណៈ ឈ្មោះថា ពួក
យើងបានទាន់ហើយ ។ បីតិក៏កើតឡើងដល់ទេវតាទាំងនោះ
ក្នុងខណៈនោះឯង ព្រោះឮពាក្យថា ព្រះពុទ្ធ ទេវតាទាំងនោះ
ឈរផ្គងអញ្ជលី ពោលសរសើរថា ព្រះពុទ្ធៗ ។ ពួកសត្វ
ផ្សេងៗ ផ្គងអញ្ជលី ញុំាងសំឡេងទ្រហឹងអឺងកង សំឡេង
សាធុការ សំឡេងហ៊ោឲ្យប្រព្រឹត្តទៅ ក្នុងកណ្ដាលអាកាស ។
ទេវតាទាំងឡាយច្រៀង ហួច ប្រគំ ទះដៃ រាំ ជម្រុះនូវផ្កា

មន្ទារវៈមានពណ៌ ៥ ដែលលាយប្រឡំដោយលម្អិតនៃខ្លឹមចន្ទន៍ ។

( ហើយពោលថា ) បពិត្រព្រះអង្គ មានព្យាយាមធំ លក្ខណៈនៃចក្រ ទង់ជ័យ កែវវជិរ ទង់ជ្រុង តាក់តែងដោយកង្វេរ កំពុងចម្រើន ត្រង់ព្រះបាទាទាំងគូរបស់ព្រះអង្គ ដូច្នេះ ។

ក្នុងបទទាំងនោះ ឈ្មោះថា **សត្ថា** ព្រោះទ្រង់ទូន្មាននូវប្រយោជន៍ ក្នុងលោកនេះ និងលោកខាងមុខ ។ បទថា **កេតុ** ឈ្មោះថា **កេតុ** ព្រោះទ្រង់ដូចជាទង់ ព្រោះអត្ថថា ទង់គប្បីជារបស់ដែលគប្បីកោតក្រែង ។ បទថា **ធជោ** បានដល់ ជាទង់ព្រះឥន្ទ្រ ព្រះសាស្តាដូចជាទង់ជ័យ ព្រោះអត្ថថា លើកឡើង និងព្រោះអត្ថថា គួរសរសើរ ហេតុនោះ ទើបឈ្មោះថា **ធជ** ។ ន័យម្យ៉ាងទៀត ដូចបុគ្គលឃើញទង់របស់បុគ្គលណាមួយ ក៏ដឹងថា នេះជាទង់របស់បុគ្គលឈ្មោះនេះ បុគ្គលនេះជាអ្នកមានទង់ ជាម្ចាស់របស់ទង់ យ៉ាងណា ព្រះមានព្រះភាគក៏យ៉ាងនោះដូចគ្នា គឺគ្រាន់តែឃើញព្រះមានព្រះភាគកាលសម្រេចនិព្វាន ក៏ប្រកបដោយការសម្រេចនិព្វានដោយបញ្ញា ដោយហេតុនោះ ទើបទេវតាពោលថា **ធជោ យូបោ** ច អធិប្បាយថា ទ្រង់ជាសសរគោលដែលគេលើកឡើងដើម្បីបូជាយញ្ញទាំងឡាយទាំងពួង មានទានជាដើម មានអាសវក្ខយញ្ញាណជាទីបំផុត ដូចត្រាស់ក្នុងកូដទន្តសូត្រ ។ បទថា **បរាយនោ** បានដល់ ជាទីពំនាក់ ដូចផែនដី ជាទីអាស្រ័យ ព្រោះជាទីទទួលសត្វទាំងឡាយទាំងពួង ដូច្នោះ ។ បទថា **ទីបោ** ច បានដល់ ជាប្រទីប

អធិប្បាយថា ប្រទីបដែលលើកឡើងសម្រាប់សត្វទាំងឡាយ ដែលនៅក្នុងភាពងងឹត ដែលប្រកបដោយអង្គ ៤ រមែងបំភ្លឺឲ្យឃើញរូប យ៉ាងណា ទ្រង់ក៏ជាប្រទីបបំភ្លឺឲ្យឃើញបរមត្ថធម៌ សម្រាប់ពួកសត្វដែលនៅក្នុងភាពងងឹត គឺអវិជ្ជា ដូច្នោះ ។ ម្យ៉ាងទៀត ទ្រង់ក៏ឈ្មោះថា ដូចកោះ ព្រោះដូចជាកោះរបស់សត្វទាំងឡាយ ដែលលិចចុះក្នុងសាគរ គឺសង្សារវដ្ត ដែលមិនមានទីពឹង ដូចកោះកណ្ដាលសមុទ្រ ជាទីពឹងនៃសត្វទាំងឡាយ ដែលទូកលិចក្នុងមហាសមុទ្រ ដូច្នោះ ។

បទថា **ទ្វិបទុត្តមោ** សេចក្ដីថា ទ្រង់ឧត្ដមជាងសត្វជើង ២ ឈ្មោះថា **ទ្វិបទុត្តម** ។ ក្នុងពាក្យនេះ មិនបដិសេធឆដ្ឋីសមាស ព្រោះមិនមានលក្ខណៈនៃនិទ្ធារណៈ ទើបសម្រេចរូបជាសមាសនៃឆដ្ឋីវិភត្តិ ដែលមាននិទ្ធារណៈជាលក្ខណៈ ។ បើមានពាក្យសួរថា ព្រះសម្មាសម្ពុទ្ធ ទ្រង់ឧត្ដមជាងសត្វទាំងឡាយដែលមិនមានជើង មានជើង ២ មានជើង ៤ មានជើងច្រើន មានរូប មិនមានរូប មានសញ្ញា មិនមានសញ្ញា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន តែព្រោះហេតុអ្វី ក្នុងទីនេះ ទើបលោកពោលថា ឧត្ដមជាងសត្វជើង ២ ។ គប្បីឆ្លើយថា ព្រោះសត្វជើង ២ ជាបុគ្គលប្រសើរជាង ។ ពិតហើយ ធម្មតាបុគ្គលប្រសើរបំផុតក្នុងលោកនេះ កាលកើត រមែងមិនកើតក្នុងពួកសត្វមិនមានជើង សត្វជើង ៤ និងសត្វជើងច្រើន បុគ្គលនេះរមែងកើតក្នុងពួកសត្វជើង ២ ប៉ុណ្ណោះ ។ សួរថា ក្នុងពួកសត្វជើង ២ ប្រភេទណា ឆ្លើយថា ក្នុងពួកមនុស្ស និងពួកទេវតាទាំងឡាយ ។ កាល

កើតក្នុងពួកមនុស្ស រមែងកើតជាព្រះពុទ្ធ ជាអ្នកអាចធ្វើ ៣ ពាន់លោកធាតុ ច្រើនពាន់លោកធាតុ ឲ្យនៅក្នុងអំណាចបាន កាលកើតក្នុងពួកទេវតា រមែងកើតជាមហាព្រហ្ម ដែលមានអំណាចក្នុងម៉ឺនលោកធាតុ ។ មហាព្រហ្មនោះរមែងស្មើនឹងកប្បិយការកៈ ឬអារាមិករបស់ព្រះពុទ្ធអង្គនោះ ហេតុនោះទើបព្រះសម្ពុទ្ធ លោកហៅថា ឧត្តមជាងសត្វជើង ២ ដោយហេតុដែលទ្រង់ជាបុគ្គលប្រសើរជាងមហាព្រហ្មនោះ ។

បទថា **ទសសហស្សីលោកធាតុយា** បានដល់ ក្នុងលោកធាតុដែលរាប់បានមួយម៉ឺន ។ បទថា **មហិទ្ធិកា** បានដល់ ប្រកបដោយឫទ្ធិយ៉ាងច្រើន អធិប្បាយថា មានអានុភាពច្រើន ។ បទថា **បរិវារេត្វា** បានដល់ ចោមរោមព្រះមានព្រះភាគដោយជុំវិញ ។ បទថា **បសន្នា** បានដល់ កើតនូវសទ្ធា ។ បទថា **ឆាសភំ** បានដល់ ទ្រង់ជាបុគ្គលប្រសើរបំផុតក្នុងនរជន ។ ក្នុងបទថា **អហោ អច្ឆរិយំ** នេះ ឈ្មោះថា អច្ឆរិយៈ ព្រោះមិនមានជានិច្ច ដូចមនុស្សខ្វាក់ឡើងភ្នំ ឬឈ្មោះថា អច្ឆរិយៈ ព្រោះគួរដល់ការទះដៃ អធិប្បាយថា គួរទះដៃថា ឱ ! នេះ គួរចម្លែកពិត ។ បទថា **អព្ភុតំ** មានវិគ្គហៈថា ឈ្មោះថា អព្ភុតៈ ព្រោះមិនធ្លាប់មាន មិនធ្លាប់កើត ។ ពាក្យ ២ នេះ ជាឈ្មោះនៃការអស្ចារ្យក្នុងចិត្ត ។ បទថា **លោមហំសនំ** បានដល់ ធ្វើឲ្យលោមជាតិមានចុងបះឡើង ។ បទថា **ន មេទិសំ ភូតបុព្វំ** សេចក្តីថា រឿងបែបនេះ អាត្មាអញមិនធ្លាប់កើត អាត្មាអញមិនធ្លាប់មាន អាត្មាអញមិនធ្លាប់ឃើញ ។ គប្បីនាំពាក្យថា ឃើញ មកប្រកបផង ។ បទថា **អច្ឆេរកំ**

គឺសេចក្តីអស្ចារ្យក្នុងចិត្ត ។

បទថា **សកសកម្ហិ ភវនេ** បានដល់ ក្នុងលំនៅរៀងៗ ខ្លួន ។ បទថា **និសីទិត្វាន** បានដល់ ចូលទៅអង្គុយជិត ។ ពាក្យថា **ទេវតា** នេះ គប្បីជ្រាបថា ជាពាក្យពោលទូទៅ ទាំងទេវបុត្ត ទាំងទេពធីតា ។ បទថា **ហសន្តិ តា** សេចក្តីថា ទេវតាទាំងនោះសើចក្អាកក្អាយ មិនធ្វើនូវការញញឹម សើចកង់រំពង ព្រោះហទយៈធ្លាក់ក្នុងអំណាចបីតិ ។ បទថា **នភេ** បានដល់ ក្នុងអាកាស ។

បទថា **អាកាសដ្ឋា** បានដល់ ទេវតាដែលនៅក្នុងវិមាន ក្នុងអាកាសជាដើម ។ សូម្បីក្នុងពួកភុម្មដ្ឋកទេវតាក៏ន័យនេះដូចគ្នា ។ បទថា **តិណា-បន្ថនិវាសិនោ** បានដល់ លំនៅប្រចាំ មានចុងស្មៅ និងផ្លូវជាច់ស្រយាល ។ បទថា **បុញ្ញវន្តោ** បានដល់ មានបុណ្យច្រើន ។ បទថា **មហិទ្ធិកា** បានដល់ មានអានុភាពច្រើន ។ បទថា **សង្គីតិយោ បវត្តេន្តិ** បានដល់ គ្រឿងលេងនូវតន្ត្រីរបស់ទេវតា អធិប្បាយថា ប្រកបដើម្បីបូជាព្រះតថាគត ។ បទថា **អម្ពរេ** បានដល់ ក្នុងអាកាស ។ បទថា **អនិលញ្ជសេ** បានដល់ ផ្លូវអាកាស ។ លោកពោលថា **អនិលញ្ជសេ** ក៏ព្រោះអាកាស មានអត្ថច្រើនយ៉ាង ។ ពាក្យជាវេវចនៈនៃពាក្យដើម ។ បទថា **ចម្មនទ្ធានិ** បានដល់ ស្គរដែលពាសដោយស្បែក ។ បាឋៈក៏យ៉ាងនោះដូចគ្នា ។ អធិប្បាយថា ស្គរទិព្វ ។ បទថា **វាទេន្តិ** សេចក្តីថា ទេវតាទាំងឡាយ នាំគ្នាប្រគំ ។

បទថា **សង្ខា** បានដល់ ស័ង្ខសម្រាប់ផ្លុំ ។ បទថា **បណវា** បានដល់

គ្រឿងតន្ត្រីវិសេសត្រង់កណ្តាលស្តួច ( ស្គរតូច ) ។ ស្គរតូចៗ លោកហៅថា **ឌិណ្ឌិមា**។ បទថា **វជ្ជន្តិ** បានដល់ ប្រគំ ។ បទថា **អច្ចុតោ វត នោ** បានដល់ គួរអស្ចារ្យពិតហ្ន៎ ។ បទថា **ឧប្បជ្ជិ** បានដល់ កើតហើយ ។ បទថា **លោមហំសនោ** បានដល់ ធ្វើរោមឲ្យព្រឺ ។ បទថា **ធុវំ** អធិប្បាយថា ព្រោះព្រះសាស្តាអង្គនោះ អស្ចារ្យកើតឡើងក្នុងលោក ដូច្នោះ ពួកយើងនឹងបានសម្រេចប្រយោជន៍ដោយពិតប្រាកដ ។ បទថា **លភាម** បានដល់ នឹងបាន ។ បទថា **១ណោ** សេចក្តីថា ខណៈទី ៩ វៀរខណៈ ៨ ។ បទថា **នោ** បានដល់ ដែលយើងទាំងឡាយ ។ បទថា **បដិបាទិតោ** បានដល់ បានចំពោះហើយ ។

បទថា **ពុទ្ធោតិ តេសំ សុត្វាន** សេចក្តីថា បីតិ ៥ យ៉ាងកើតដល់ទេវតាទាំងនោះ ព្រោះបានឮពាក្យនេះថា **ពុទ្ធោ**។ បទថា **តាវទេ** បានដល់ ក្នុងវេលានោះ ។ បទថា **ហិង្ការា** បានដល់ សំឡេងដែលធ្វើថា **ហឹ ហឹ**។ យក្ខជាដើម រមែងធ្វើសំឡេងថា **ហឹ ហឹ** ក្នុងវេលារីករាយ ។ បទថា **សាធុការា** បានដល់ សំឡេងធ្វើថា សាធុ ក៏ប្រព្រឹត្តទៅ ។ បទថា **ឧក្កុដ្ឋិ** បានដល់ សំឡេងហៅ និងសំឡេងកងរំពង ។ ទេវតាជាដើម លោកហៅថា **បជា**។ អាចារ្យពួកខ្លះពោលថា ទង់ជ្វាលាផ្សេងៗ ក៏ប្រព្រឹត្តទៅក្នុងអាកាស ។ បទថា **គាយន្តិ** បានដល់ ចម្រៀងដែលប្រកបដោយពុទ្ធគុណ ។

បទថា **សេឡេន្តិ** បានដល់ ធ្វើសំឡេងប្រគំដោយមាត់ ។ បទថា **វាទយន្តិ** សេចក្តីថា ពិណ មានពិណឈ្មោះថា **វិបច្ចិកា** និង **មក្ករមុខ**

ជាដើមដែលមានទំហំធំ និងតន្ត្រីទាំងឡាយ ក៏ទេវតាបន្ទីប្រកបឡើងដើម្បីបូជាព្រះតថាគត ។ បទថា **ភុជានិ ផោដេន្តិ** បានដល់ ទះដៃ ។ គប្បីឃើញថា ជាលិង្គវិបល្លាស ។ បទថា **ឆឌ្ឌេន្តិ ច** បានដល់ ប្រើឲ្យអ្នកដទៃរាំផងរាំឯងផង ។

ក្នុងបទថា **យថា តុយ្ហំ មហាវីរ ចាទេសុ ចក្កលក្ខណំ** នេះ **យថា** ប្រែថា ដោយប្រការណា ។ ឈ្មោះថា **មហាវីរ** ព្រោះទ្រង់ប្រកបដោយសេចក្តីព្យាយាមធំ ។ បទថា **ចាទេសុ ចក្កលក្ខណំ** សេចក្តីថា ត្រង់ផ្ទៃព្រះបាទទាំងសងខាងរបស់ព្រះអង្គមានរូបចក្ក មានកាំ មានខ្នងកង់ និងដុំបរិបូណ៌ ដោយអាការគ្រប់យ៉ាង ល្អត្រកាល ។ **ចក្ក** សព្ទនេះ ប្រាកដប្រើក្នុងអត្ថថា សម្បត្តិ ចំណែករបស់រថ ឥរិយាបថ ទាន រតនចក្ក ធម្មចក្កខុរចក្ក និងលក្ខណៈជាដើម ។ ដែលប្រើក្នុងអត្ថថា សម្បត្តិ ដូចក្នុងប្រយោគជាដើមថា **ចត្តារីមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវមនុស្សានំ** ម្នាលភិក្ខុទាំងឡាយ ចក្រនេះ មាន ៤ យ៉ាង ចក្រនេះ តែងប្រព្រឹត្តទៅដល់ពួកទេវតា និងមនុស្សដែលប្រកបដោយចក្រ ដូច្នេះ ។

ប្រើក្នុងអត្ថថា ចំណែកនៃរថ ដូចក្នុងប្រយោគជាដើមថា **ចក្កំវ វហតោ បទំ** ដូចកង់រទេះវិលតាមជានជើងគោ ដែលកំពុងអូសទៅ ដូច្នោះ ។

ដែលប្រើក្នុងអត្ថថា ឥតិយាបថ បានក្នុងប្រយោគជាដើមថា **ចតុចក្កំ នវទ្វារំ** សរីរៈ មានចក្រ ៤ មានទ្វារ ៩ ដូច្នេះ ។

ដែលប្រើក្នុងអត្ថថា ទាន ដូចក្នុងប្រយោគជាដើមថា **ទទំ ភុញ្ជ ច**

**មា ច បមាទោ ចក្កំ បវត្តយ សព្វទាណភីធំ** សូមព្រះអង្គទ្រង់ឲ្យទាន ហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ ( ក្នុងបុណ្យទាំងឡាយ ) សូមព្រះអង្គ ញ៉ាំងចក្កធម៌ឲ្យប្រព្រឹត្តទៅ ដូច្នោះ ។

ប្រើក្នុងអត្ថថា រតនចក្រ ដូចក្នុងប្រយោគជាដើមថា **ទិព្វំ ចក្ករតនំ បាតុរហោសិ** ចក្ករ័តន៍ជាទិព្វ មានកាំ ១០០០ ព្រមទាំងខ្នង និងដុំ បរិបូណ៌ ដោយអាការទាំងពួង ក៏កើតប្រាកដហើយ ដូច្នោះ ។

ដែលប្រើក្នុងអត្ថថា ធម្មចក្រ ដូចក្នុងប្រយោគជាដើមថា **មយា បវត្តិតំ ចក្កំ** ញ៉ាំងធម្មចក្រជាចក្រដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ដូច្នោះ ។

ប្រើក្នុងអត្ថថា ខុរចក្រ អធិប្បាយថា ចក្រសម្រាប់ប្រហារ ដូចក្នុងប្រយោគជាដើមថា **ឥច្ឆាហតស្ស បោសស្ស ចក្កំ ភមតិ មត្ថកេ** ចក្រវិលកិនអំបែងក្បាល បុគ្គលដែលឥស្សាគ្របសង្កត់ហើយ ដូច្នោះ ។

ប្រើក្នុងអត្ថថា លក្ខណៈ ដូចក្នុងប្រយោគជាដើមថា **បាទតលេសុ ចក្កានិ ជាតានិ** ចក្រទាំងឡាយ កើតមានត្រង់ផ្ទៃព្រះបាទា ដូច្នោះ ។

ក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងអត្ថថា ចក្រ គឺលក្ខណៈ ។ បទថា **ធជវជិរបដាកា វឌ្ឍមានង្កុសាចិតំ** សេចក្ដីថា លក្ខណចក្រត្រង់ព្រះបាទទាំងគូ រួបរួម ប្រដាប់ ហោមរោមដោយទង់ជ័យ វជិរាវុធ ទង់ផ្កាលា គឺតាក់តែងដោយកង្វេរ ។ កាលលោកកាន់យកលក្ខណចក្កហើយ ឈ្មោះថា កាន់យកលក្ខណៈដ៏សេសផងដែរ ។ អនុព្យញ្ជនៈ ៨០ និងព្រះរស្មីមួយព្យាម

ក៏ដូចគ្នា ព្រោះហេតុនោះ ព្រះរូបកាយរបស់ព្រះមានព្រះភាគ ដែលប្រដាប់ព្រមដោយព្រះមហាបុរិសលក្ខណៈ ៣២ អនុព្យញ្ជនៈ ៨០ និងព្រះរស្មីមួយព្យាម ក៏បញ្ចេញព្រះពុទ្ធរស្មី មានពណ៌ ៦ ដែលធៀបធ្វាត់ល្អក្រៃពេក ដូចដើមបារិច្ឆត្តកៈ មានផ្ការីកស្គុះស្គាយ ដូចគុម្ពឈូកដែលមានផ្ការីកហើយ ដូចសសរខឿនមាស លម្អដោយរតនៈច្រើនប្រភេទ ដូចអាកាស លម្អដោយហ្វូងផ្កាយ ។

ឥឡូវនេះ ដើម្បីសម្តែងសម្បត្តិ គឺរូបកាយ និងធម្មកាយរបស់ព្រះមានព្រះភាគ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថានេះថា

> ព្រះមានព្រះភាគ ឥតមានបុគ្គលស្មើ ចំពោះព្រះរូបផង សីលផង សមាធិផង ប្រាជ្ញាផង ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ចំពោះវិមុត្តិ និងការញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ។

**រូប** សព្ទ ក្នុងបទថា **រូបេ** ក្នុងគាថានោះ ប្រាកដក្នុងអត្ថថា ខន្ធ ភព និមិត្ត បច្ច័យ សរីរៈ វណ្ណៈ និងទ្រង់ទ្រាយជាដើម ដូចលោកពោលថា **រូប** សព្ទ ប្រើក្នុងអត្ថថា **រូបក្ខន្ធ** ដូចក្នុងប្រយោគជាដើមថា **យង្កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ** រូបក្ខន្ធឯណាមួយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ដូច្នេះ ។

មកក្នុងអត្ថថា **រូបភព** ដូចក្នុងប្រយោគជាដើមថា **រូបូបត្តិយា មគ្គំ ភាវេតិ** ចម្រើនមគ្គដើម្បីកើតឡើងក្នុងរូបភព ដូច្នេះ ។

មកក្នុងអត្ថថា **កសិណនិមិត្ត** ដូចក្នុងប្រយោគជាដើមថា **អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ** កំណត់រូបខាងក្នុង ឃើញរូបកសិណខាងក្រៅ ដូច្នេះ ។

មកក្នុងអត្ថថា **បច្ចយ** ដូចក្នុងប្រយោគជាដើមថា **សរូបា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អរូបា** ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយរូប ទើបកើតឡើងបាន មិនមែនឥតរូបទេ ដូច្នេះ ។

មកក្នុងអត្ថថា **សរីរ** ដូចក្នុងប្រយោគជាដើម **អាកាសោ បរិវារិតោ រូបន្តេវ សង្ខំ គច្ឆតិ** អាកាសដែលអាស្រ័យ ( ឆ្អឹងខ្ចះ ... ) រួបរួមជាមួយគ្នាហើយ ទើបហៅថា រូបបាន ដូច្នេះ ។

មកក្នុងអត្ថថា **វណ្ណ** ដូចក្នុងប្រយោគជាដើមថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ** វិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែក និងរូប ដល់នូវកិរិយារាប់ថា ចក្ខុវិញ្ញាណ ដូច្នេះ ។

មកក្នុងអត្ថថា **ទ្រង់ទ្រាយ** ដូចក្នុងប្រយោគជាដើមថា **រូបប្បមាណោ រូបប្បសន្នោ** បុគ្គលជ្រះថ្លាក្នុងរូប ឈ្មោះថា រូបប្បមាណៈ ដូច្នេះ ។ តែក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងអត្ថថា ទ្រង់ទ្រាយ ។

បទថា **សីលេ** បានដល់ ក្នុងសីល ៤ យ៉ាង ។ បទថា **សមាធិម្ហិ** បានដល់ ក្នុងសមាធិ ៣ យ៉ាង ។ បទថា **បញ្ញាយ** បានដល់ ក្នុងបញ្ញាដែលជាលោកិយ និងលោកុត្តរ ។ បទថា **អសាទិសោ** បានដល់ មិនមាន

អ្នកណាដូច មិនមានអ្នកណាប្រៀប ។ បទថា **វិមុត្តិយា** បានដល់ ក្នុងផលវិមុត្តិ ។ បទថា **អសមសមោ** សេចក្តីថា អតីតព្រះពុទ្ធទាំងឡាយមិនមានអ្នកណាស្មើ ទ្រង់ស្មើនឹងព្រះពុទ្ធទាំងឡាយដែលមិនមានណាស្មើទាំងនោះ ដោយព្រះគុណទាំងឡាយ មានសីលជាដើម ហេតុនោះ ទើបទ្រង់ព្រះនាមថា ស្មើនឹងព្រះពុទ្ធដែលមិនមានបុគ្គលស្មើ លោកសម្តែងសម្បត្តិ គឺរូបកាយរបស់ព្រះមានព្រះភាគ ដោយកថាត្រឹមប៉ុណ្ណោះ ។

ឥឡូវនេះ ដើម្បីសម្តែងកម្លាំងព្រះកាយជាដើម របស់ព្រះមានព្រះភាគ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា

> កម្លាំងក្នុងព្រះកាយនៃព្រះអង្គ ជាកម្លាំងប្រក្រតី ស្មើនឹង
> កម្លាំងដំរី ១០ ព្រះអង្គឥតមានបុគ្គលប្រៀបផ្ទឹម ស្មើដោយ
> កម្លាំងនៃឫទ្ធិ ក្នុងការញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ។

បណ្តាបទទាំងនោះ បទថា **ឆសនាគពលំ** បានដល់ កម្លាំងស្តេចដំរីឆទ្ទន្ត ១០ ។ ពិតហើយ កម្លាំងរបស់ព្រះតថាគត មាន ២ គឺកម្លាំងព្រះវរកាយ ១ កម្លាំងព្រះញាណ ១ ។ បណ្តាកម្លាំងទាំង ២ នោះ កម្លាំងព្រះកាយ គប្បីជ្រាបតាមគន្លងត្រកូលដំរី សួរថា ជ្រាបដូចម្តេច ឆ្លើយថា គប្បីជ្រាបដំរី ១០ ត្រកូលទាំងនេះ គឺ

> **កាឡាវកញ្ច គង្គេយ្យំ បណ្ឌរំ តម្ពបិង្គលំ**
> **គន្ធមង្គលហេមញ្ច ឧបោសថឆទ្ទន្តិមេ ទស ។**

ដំរី ១០ ត្រកូល គឺកាឡាវកៈ គង្គេយ្យៈ បណ្ឌរៈ តម្ពៈ
បិង្គលៈ គន្ធៈ មង្គលៈ ហេមៈ ឧបោសថៈ ឆទ្ទន្តៈ ។

កាឡាវកៈ បានដល់ ត្រកូលដំរីប្រក្រតី ។ កម្លាំងកាយនៃបុរស ១០ នាក់ ស្មើនឹងកម្លាំងរបស់ដំរីត្រកូលកាឡាវកៈ ១ ។ កម្លាំងនៃដំរីត្រកូលកាឡាវកៈ ១០ ស្មើនឹងកម្លាំងរបស់ដំរីត្រកូលគង្គេយ្យៈ ១ គប្បីនាំកម្លាំងនៃដំរីត្រកូលផ្សេងៗ ដោយឧបាយដូចពោលមកនេះ រហូតដល់កម្លាំងរបស់ដំរីត្រកូលឆទ្ទន្ត ។ កម្លាំងរបស់ដំរីត្រកូលឆទ្ទន្ត ១០ ស្មើនឹងកម្លាំងរបស់ព្រះតថាគតមួយអង្គ ។ កម្លាំងរបស់ព្រះតថាគតនេះឯង ហៅថា កម្លាំងនារាយណ៍ កម្លាំងវជិរៈ ។ កម្លាំងរបស់ព្រះតថាគតនេះ ស្មើនឹងកម្លាំងដំរីប្រក្រតី ១ ពាន់កោដិ ស្មើនឹងកម្លាំងបុរស ១០ ពាន់កោដិ ។ កម្លាំងព្រះវរកាយប្រក្រតីរបស់ព្រះតថាគត មានដូច្នេះ ។ ឯកម្លាំងព្រះញាណ មិនមានប្រមាណ កម្លាំងព្រះញាណមានជាដើមយ៉ាងនេះ គឺព្រះទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ អកម្បនញ្ញាណ ក្នុងបរិស័ទ ៨ ចតុយោនិបរិច្ឆេទកញ្ញាណ បញ្ចគតិបរិច្ឆេទកញ្ញាណ ពុទ្ធញ្ញាណ ១៤ តែក្នុងទីនេះ បំណងយកកម្លាំងព្រះវរកាយ ។ បទថា **កាយេ តុយ្ហំ ធាកត្តិកំ ពលំ** សេចក្តីថា កម្លាំងតាមប្រក្រតីក្នុងព្រះវរកាយរបស់ព្រះអង្គនោះ ព្រោះហេតុនោះ បទថា **ឆសនាគពលំ** មានសេចក្តីថា ស្មើគ្នានឹងកម្លាំងរបស់ដំរីត្រកូលឆទ្ទន្ត ១០ ។

ឥឡូវនេះ ដើម្បីសម្តែងកម្លាំងព្រះញាណ ទើបលោកពោលថា ដែលមិនមានបុគ្គលស្មើ ដោយកម្លាំងនៃឫទ្ធិ ក្នុងការញ៉ាំងចម្មចក្រឲ្យប្រព្រឹត្តទៅ

ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទ្ធិពលេន អសមោ** បានដល់ មិនមានបុគ្គលស្មើ មិនមានបុគ្គលដូច មិនមានបុគ្គលប្រៀប ដោយកម្លាំងឫទ្ធិ មានឫទ្ធិ គឺការធ្វើឲ្យវិសេស និងឫទ្ធិ គឺការអធិដ្ឋានជាដើម ។ បទថា **ធម្ម-ចក្កប្បវត្តនេ** សេចក្តីថា មិនមានបុគ្គលស្មើក្នុងទេសនាញាណ ។

ឥឡូវនេះ ដើម្បីសម្តែងការប្រកបក្នុងការនមស្ការព្រះតថាគតថា ព្រះសាស្តាអង្គណា ប្រកបព្រមដោយព្រះគុណ ដូចពោលមកនេះជាដើម ព្រះសាស្តាអង្គនោះ ទ្រង់ជានាយកឯកនៃលោកទាំងពួងរបស់អ្នកទាំងឡាយ ចូរនមស្ការព្រះសាស្តាអង្គនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា

អ្នកទាំងឡាយ ចូរនាំគ្នាក្រាបថ្វាយបង្គំនូវព្រះមហាមុនី ព្រះអង្គបរិបូណ៌ដោយគុណទាំងពួង ប្រកបដោយអវយវៈទាំងពួង ទ្រង់មានករុណាជាទីពឹងនៃលោក ។

ក្នុងគាថានោះ សព្ទថា **ឯវំ** ជានិបាត ចុះក្នុងអត្ថចង្អុលបង្ហាញ ដូចដែលពោលមកហើយ ។ សព្ទនេះថា **សព្វោ** ក្នុងពាក្យថា **សព្វគុណាបេតំ** នេះ ជាសព្ទពោលដល់ មិនសេសសល់ឡើយ ។ **គុណ** សព្ទនេះថា **គុណោ** ប្រាកដក្នុងអត្ថជាច្រើន ។

ពិតហើយ **គុណ** សព្ទនេះ ប្រើក្នុងអត្ថថា ជាន់ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ អហាតានំ វត្ថានំ ទិគុណំ សង្ឃាដឹ** ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នៅថ្មោង តថាគតអនុញ្ញាត ( ឲ្យអ្នក

ទាំងឡាយធ្វើ ) សង្ស្សាជីពីរជាន់ ដូច្នេះ ។

មកក្នុងអត្ថថា ក្រុម ឬជំនាន់ ដូចក្នុងប្រយោគជាដើមថា **អច្ចេន្តិកាលា តរយន្តិ រត្តិយោ វយោគុណា អនុបតុំ ជហន្តិ** កាលទាំងឡាយ តែង កន្លងផុតទៅ រាត្រីទាំងឡាយ តែងធ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយ តែងលះបង់នូវលំដាប់ ដូច្នេះ ។

មកក្នុងអត្ថថា អានិសង្ស ដូចក្នុងប្រយោគជាដើមថា **សតគុណា ទក្ខិណា បាដិកង្ខិតព្វា** ទក្ខិណាមានគុណ ១០០ ដែលបុគ្គលត្រូវបាន ( ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន ) ដូច្នេះ ។

មកក្នុងអត្ថថា ចំណង ឬកម្រង ដូចក្នុងប្រយោគជាដើមថា **អន្តំ អន្តគុណំ** ពោះវៀនធំ ពោះវៀនតូច ដូច្នេះ ។ និងដូចក្នុងប្រយោគមួយ ទៀតថា **កយិរា មាលាគុណេ ពហូ** មាលាការបេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កាឲ្យច្រើនបាន ដូច្នេះ ។

មកក្នុងអត្ថសម្បត្តិ ដូចក្នុងប្រយោគជាដើមថា **អដ្ឋគុណា សមុបេតំ អភិញ្ញាពលមាហរឹ** នាំមកនូវអភិញ្ញាពល ដែលប្រកបដោយគុណ ៨ ប្រការដូច្នេះ ។ តែក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងអត្ថថា សម្បត្តិ ព្រោះ ហេតុនោះ ទើបមានអត្ថថា ចូលដល់ ប្រកបព្រមហើយដោយគុណដែល ជាលោកិយ និងលោកុត្តរទាំងពួង គឺដោយសម្បត្តិសព្វយ៉ាង ។ បទថា **សព្វគ្គសមុបាគតំ** បានដល់ ចូលមកដល់ហើយ ប្រកបព្រមហើយ ដោយ ពុទ្ធគុណ ឬដោយអគ្គគុណទាំងពួង ។ បទថា **មហាមុនី** ឈ្មោះថា មហាមុនី

ព្រោះក្រៃលែងជាងមុនីទាំងឡាយ មានព្រះបច្ចេកពុទ្ធជាដើមដទៃ ព្រោះហេតុនោះ ទើបហៅថា មហាមុនី ។ បទថា **ការុណិកំ** ឈ្មោះថា ការុណិកៈ ព្រោះប្រកបដោយករុណាគុណ ។ បទថា **លោកនាថំ** បានដល់ ជានាថឯកនៃលោកទាំងពួង អធិប្បាយថា ដែលលោកទាំងពួងប្រាថ្នាយ៉ាងនេះថា បុរសនេះជាអ្នកកម្ចាត់ ជាអ្នករម្ងាប់នូវការក្តៅក្រហាយ គឺទុក្ខរបស់ពួកយើង ដូច្នេះ ។

ឥឡូវនេះ ដើម្បីសម្តែងភាពដែលព្រះទសពល ទ្រង់ជាអ្នកគួរដល់ការគោរពឱនលំទោនសព្វយ៉ាង ទើបព្រះសង្គីតិកាចារ្យពោលថា

ព្រះអង្គជាបុគ្គលគួរទទួលនូវកិច្ចទាំងពួងរបស់ពួកជន គឺការក្រាបសំពះ ការស្ញើច ការថ្វាយបង្គំ ការសរសើរ ការនមស្ការ និងការបូជា ។ ជនទាំងឡាយណាមួយ ក្នុងលោកដែលគួរគេថ្វាយបង្គំ ឬជនទាំងឡាយណា គួរដល់ការថ្វាយបង្គំ បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គជាបុគ្គលប្រសើរបំផុត ជាងជនទាំងអស់នោះ បុគ្គលស្មើនឹងព្រះអង្គមិនមានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភិវាទនំ** បានដល់ ឲ្យអ្នកដទៃធ្វើការក្រាបសំពះខ្លួន ។ បទថា **ថោមនំ** បានដល់ សរសើរដោយកំប៉ាំង ។ បទថា **វន្ទនំ** បានដល់ ការថ្វាយបង្គំ ។ បទថា **បសំសនំ** បានដល់ ការសរសើរចំពោះមុខ ។ បទថា **នមស្សនំ** បានដល់ ការធ្វើនូវអញ្ជលី ឬថ្វាយបង្គំ

ដោយចិត្ត ។ បទថា **បូជនំ** បានដល់ ការបូជាដោយមាល័យ គ្រឿងក្រអូប និងគ្រឿងលាបជាដើម ។ បទថា **សក្កំ** សេចក្តីថា ទ្រង់សមគួរដល់សក្ការៈវិសេស ដូចពោលហើយនោះគ្រប់យ៉ាង ។ បទថា **យេ កេចិ លោកេ វន្ទនេយ្យា** សេចក្តីថា ជនពួកណាមួយដែលបុគ្គលត្រូវក្រាបសំពះ ដែលបុគ្គលត្រូវថ្វាយបង្គំ គួរដល់ការថ្វាយបង្គំក្នុងលោក ។ បទថា **យេ** បានដល់ម្យ៉ាងទៀត ជនពួកណា គួរដល់ការថ្វាយបង្គំក្នុងលោក ។ បទនេះ ជាវេវចនៈនៃបទដើមនោះឯង ។ បទថា **សព្វសេដ្ឋោ** សេចក្តីថា បពិត្រមហាវីរៈ ទ្រង់ប្រសើរបំផុត ឧត្តមជាងជនទាំងអស់នោះ ជនណាដែលស្មើដូចព្រះអង្គមិនមានក្នុងលោក ។

គ្រានោះ កាលព្រះមានព្រះភាគទ្រង់សម្តែងយមកប្បដិហារ្យ ទ្រង់និម្មិតរតនចង្ក្រម ទ្រង់យាងចង្ក្រមក្នុងរតនចង្ក្រមនោះ ព្រះសារីបុត្ត មួយអន្លើដោយភិក្ខុបរិវារ ៥០០ នៅត្រង់ភ្នំគិជ្ឈកូដ ក្រុងរាជគ្រឹះ កាលនោះ ព្រះថេរៈត្រួតប្រមើលមើលព្រះមានព្រះភាគ ក៏ឃើញព្រះអង្គយាងចង្ក្រម ក្នុងរតនចង្ក្រម នៅក្នុងអាកាស ត្រង់ក្រុងកបិលពស្តុ ។ ដោយហេតុនោះ ទើបព្រះសង្គីតិការចារ្យទាំងឡាយពោលពាក្យជាដើមថា

ព្រះសារីបុត្តមានប្រាជ្ញាច្រើន ជាអ្នកឈ្លាសក្នុងសមាធិ និង
ឈាន ស្ថិតនៅភ្នំគិជ្ឈកូដ ឃើញព្រះលោកនាយក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សារិបុត្តោ** ឈ្មោះថា សារីបុត្ត ព្រោះជាកូនរបស់ព្រាហ្មណីឈ្មោះរូបសារី ។ បទថា **មហាបញ្ញោ** ឈ្មោះថា

មានបញ្ញាច្រើន ព្រោះជាអ្នកប្រកបដោយបញ្ញាធំ ១៦ យ៉ាង ។ ក្នុងបទថា **សមាធិជ្ឈានកោវិទោ** នេះ បទថា **សមាធិ** ឈ្មោះថា សមាធិ ព្រោះផ្ចង់ គឺដាក់ចិត្តស្មើក្នុងអារម្មណ៍ ។ សមាធិនោះ មាន ៣ គឺសមាធិដែលមានវិតក្កវិចារៈ សមាធិដែលមិនមានវិតក្ក មានតែវិចារៈ និងសមាធិមិនមានវិតក្ក មិនមានវិចារៈ ។ បទថា **ឈានំ** បានដល់ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន សូម្បីឈានដទៃ មានមេត្តាឈានជាដើម ក៏ជាការដែលលោកសង្គ្រោះដោយឈានដែលពោលមកហើយនេះ មានបឋមជ្ឈានជាដើម ។

ឈានមាន ២ យ៉ាង គឺលក្ខណូបនិជ្ឈាន និងអារម្មណូបនិជ្ឈាន បណ្តាឈានទាំង ២ នោះ វិបស្សនាញាណ ហៅថា លក្ខណូបនិជ្ឈាន ព្រោះចូលទៅសម្ងឹងលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ឯឈានមានបឋមជ្ឈានជាដើម ហៅថា ឈាន ព្រោះចូលទៅសម្ងឹងអារម្មណ៍ ឬដុតនូវធម៌ដែលជាសត្រូវ ។ បុគ្គលឈ្លាសក្នុងសមាធិផង ក្នុងឈានផង ហេតុនោះ ទើបឈ្មោះថា ជាអ្នកឈ្លាសក្នុងសមាធិ និងឈាន អធិប្បាយថា ជាអ្នកមុតស្រួចក្នុងសមាធិ និងឈាន ។ បទថា **គិជ្ឈកូដេ** សេចក្តីថា ឈរត្រង់ភ្នំមានឈ្មោះយ៉ាងនេះឯង ។ បទថា **បស្សតិ** បានដល់ ឃើញហើយ ។

បទថា **សុផុល្លំ សាលរាជំវ** ភ្ជាប់សេចក្តីជាមួយបទថា **ឱលោកេសិ** យ៉ាងនេះថា ព្រះសារីបុត្តពិនិត្យមើលព្រះទសពល ដូចជាដើមសាលព្រឹក្សដែលមានសីលជាឫស មានសមាធិជាតួដើម មានបញ្ញាជាមែក មានអភិញ្ញា

ជាផ្កា មានវិមុត្តិជាផ្លែ ដូចដើមស្តេចសាលព្រឹក្ស មានដើមមូល មានមែកប្រដាប់ដោយផ្កាក្រពុំ ផ្លែ ស្លឹកខ្ចី និងពន្លក ដែលដុះឡើង មានផ្ការីកស្គុះស្គាយពេញដើម ។ បទថា **ចន្ទំវ គគនេ យថា** សេចក្តីថា សម្លឹងមើលព្រះមុនីដ៏ប្រសើរ ដូចព្រះចន្ទជាអ្នកធ្វើនូវការកម្ចាត់ងងឹត គឺកិលេសទាំងពួងជាអ្នកធ្វើនូវការញញឹមដល់ព្រៃកោមុទ គឺវេនេយ្យជន ដូចព្រះចន្ទពេញវង់ក្នុងសរទរដូវ ដែលចោមរោមដោយពួកផ្កា រួចផុតចាកឧបសគ្គ គឺពពកសន្សើម ផ្សែង លម្អងធូលី និងរាហូ ។ បទថា **យថា** ត្រឹមតែជានិបាត ។ បទថា **មជ្ឈន្តិកេវ សូរិយំ** សេចក្តីថា រុងរឿងដូចព្រះអាទិត្យ ដែលចែងចាំងជាសំណុំ ដោយសិរីក្នុងពេលថ្ងៃត្រង់ ។ បទថា **ឱភាសកំ** បានដល់ឧត្តមក្នុងនរជន ។

បទថា **ជលន្តំ** សេចក្តីថា រុងរឿង អធិប្បាយថា ព្រះវរសរីរៈប្រដាប់ព្រមដោយមហាបុរិសលក្ខណៈ និងអសីតិអនុព្យញ្ជនៈ មានព្រះភក្ត្រដូចមាស មានសិរីដូចព្រះចន្ទពេញវង់ក្នុងសរទរដូវ រុងរឿងដោយព្រះពុទ្ធសិរីក្រៃលែង ។ បទថា **ទីបរុក្ខំវ** បានដល់ ដូចប្រទីបដែលគេលើកឡើង ។ បទថា **តរុណសូរិយំវ ឧគ្គតំ** បានដល់ ដូចព្រះអាទិត្យដែលទើបរះ អធិប្បាយថា រុងរឿងដោយការៈរៀបរយ ។ លោកហៅព្រះអាទិត្យដែលទើបតែរះ ព្រោះហេតុឧទ័យឡើង ។ មិនមានថយពន្លឺ ឬបន្ថែមពន្លឺ ដូចពន្លឺព្រះចន្ទ ( ព្រោះព្រះអាទិត្យមិនមានខ្នើតរនោច ) ។ បទថា **ព្យាមប្បភានុរញ្ជិតំ** បានដល់ ដែលព្រះរស្មីមួយព្យាមចែងចាំងហើយ ។ បទថា **ធីរំ**

**បស្សតិ លោកនាយកំ** សេចក្តីថា ឃើញព្រះនាយកដែលជាអ្នកប្រាជ្ញឯក នៃលោកទាំងពួង ។

លំដាប់នោះ ព្រះធម្មសេនាបតីឈរត្រង់ភ្នំគិជ្ឈកូដ មានកំពូលទល់គ្នា នឹងផ្ការទឹកត្រជាក់ មានកំពូលអប់ដោយក្លិនផ្កា ដែលមានក្លិនក្រអូបច្រើន ប្រភេទ មានកំពូលដ៏វិចិត្រក្រៃលែង ឃើញព្រះមានព្រះភាគដែលពួកទេវតា និងព្រហ្ម ដែលមកអំពីម៉ឺនចក្កវាឡចោមរោមហើយ ដែលទ្រង់យាងចង្ក្រម ក្នុងទីចង្ក្រមដែលជារតនៈសុទ្ធ ដោយព្រះពុទ្ធសិរីដ៏កំពូល ដោយព្រះពុទ្ធ-លីលាប្រៀបមិនបាន ទើបគិតថា ណ្ហើយចុះ អញនឹងចូលគាល់ព្រះមាន ព្រះភាគ ទូលសូមពុទ្ធវង្សទេសនាដែលសម្តែងព្រះពុទ្ធគុណ ទើបប្រជុំភិក្ខុ ៥០០ រូប ដែលនៅជាមួយខ្លួន ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យ ពោលថា

ខណៈនោះ ព្រះសារីបុត្របានប្រជុំពួកភិក្ខុចំនួន ៥០០ រូប
ជាអ្នកមានសោឡសកិច្ចធ្វើហើយ ជាតាទិបុគ្គល ជាព្រះ
ខីណាស្រពប្រាសចាកមន្ទិល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បញ្ចន្នំ ភិក្ខុសតានំ** បានដល់ ភិក្ខុ ៥០០ រូប ។ ឆដ្ឋីវិភត្តិ គប្បីឃើញថា លោកប្រើក្នុងអត្ថទុតិយាវិភត្តិ ។ បទថា **កតកិច្ចានំ** សេចក្តីថា ជាអ្នកចប់សោឡសកិច្ចហើយ គឺបរិញ្ញាកិច្ច បហាន-កិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ចដោយមគ្គ ៤ ក្នុងសច្ចៈ ៤ ។ បទថា **ខីណាសវានំ** បានដល់ ជាអ្នកអស់អាសវៈ ៤ ។ បទថា **វិមលានំ** បាន

ដល់ ប្រាសចាកមន្ទិល ឬឈ្មោះថា មានមន្ទិលទៅប្រាសហើយ អធិប្បាយថា មានចិត្តសន្តានបរិសុទ្ធក្រៃលែង ព្រោះជាអ្នកមានអាសវៈអស់ហើយ ។ បទថា **ខណោ** បានដល់ ក្នុងវេលានោះឯង ។ បទថា **សន្និបាតយិ** បានដល់ ឲ្យប្រជុំគ្នាហើយ ។

ឥឡូវនេះ ដើម្បីសម្ដែងហេតុក្នុងការប្រជុំ និងក្នុងការទៅរបស់ភិក្ខុទាំងនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថាទាំងនេះថា

> ហើយសម្ដែងនូវបាដិហារិយៈ ឈ្មោះលោកប្បសាទនៈថា
> ពួកយើងនឹងទៅក្នុងទីនោះ ហើយថ្វាយបង្គំព្រះជិនស្រី ។ លោក
> ទាំងឡាយចូរមក យើងទាំងអស់គ្នា នឹងទៅសាកសួរព្រះ
> ជិនស្រី បានជួបព្រះលោកនាយកហើយ នឹងបន្ទោបង់នូវ
> សេចក្ដីសង្ស័យ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លោកប្បសាទនំ នាម** លោកហៅបាដិហារ្យថា **លោកប្បសាទន** ព្រោះធ្វើការជ្រះថ្លាឲ្យដល់សត្វលោក ។ បាឋៈថា **ឧល្លោកប្បសាទនំ** ដូច្នេះក៏មាន ។ សេចក្ដីថា ឈ្មោះបាដិហារ្យថា ព្រះពុទ្ធបើកលោក បាដិហារ្យនោះលោកពោលថា អធិដ្ឋានធ្វើសត្វទាំងអស់ខាងលើ តាំងអំពីអកនិដ្ឋភព ខាងក្រោមដល់អវីចី ធ្វើឲ្យជាពន្លឺតែមួយក្នុងចន្លោះនេះ ឲ្យឃើញគ្នានិងគ្នាក្នុងរវាងនេះ ។ បទថា **និទស្សយិ** បានដល់សម្ដែងហើយ ។ បទថា **អម្ហេបិ** បានដល់ សូម្បីយើងទាំងឡាយ ។ បទថា **តត្ថ** សេចក្ដីថា ទៅក្នុងទីដែលព្រះមានព្រះភាគប្រថាប់គង់ ។ បទថា

**វន្ទិស្សាម** សេចក្តីថា ពួកយើងនឹងថ្វាយបង្គំព្រះបាទរបស់ព្រះមានព្រះភាគ ដោយសិរសា គឺត្បូង ។ តែក្នុងពាក្យទាំងនេះ គប្បីឃើញការភ្ជាប់សេចក្តីនៃសព្ទទាំងពីរនេះថា **អម្ហេបិ មយំ** សព្ទដើម ភ្ជាប់សេចក្តីជាមួយកិរិយាដើរទៅ សព្ទក្រោយ **មយំ** ភ្ជាប់សេចក្តីជាមួយកិរិយាថ្វាយបង្គំ ។ សេចក្តីពិត សេចក្តីក្រៅអំពីនេះ ក៏មិនផុតទោស គឺការពោលជដែល ។

បទថា **ឯថ** ប្រែថា មកចុះ ។ ក្នុងបទថា **កង្ខំ វិនោទយិស្សាម** នេះ អ្នកចោទពោលថា ឈ្មោះថា សេចក្តីសង្ស័យណាមួយរបស់ព្រះខីណាស្រព ទាំងឡាយមិនមាន ហេតុអ្វី ទើបព្រះថេរៈពោលយ៉ាងនេះ ឆ្លើយថា សេចក្តីនោះ ជាសេចក្តីពិតនោះឯង សេចក្តីសង្ស័យដាច់ទៅដោយបឋមមគ្គនោះឯង ដូចលោកពោលថា

ទស្សនេនបហាតព្វធម៌ តើដូចម្តេច គឺចិត្តុប្បាទដែលសម្បយុត្តដោយទិដ្ឋិ ៤ ដួង ចិត្តុប្បាទដែលសហគតៈដោយវិចិកិច្ឆា ១ លោភៈ ទោសៈ មោហៈ មានះ ដែលនាំទៅកាន់អបាយ និងកិលេសទាំងឡាយ ដែលតាំងនៅក្នុងឋានៈជាមួយនឹងចិត្តទាំងនោះ ។

តែសេចក្តីសង្ស័យនោះ មិនមែនហៅថាវិចិកិច្ឆា ។ ឈ្មោះថា ការមិនដឹងបញ្ញត្តនឹងមានឬ ។ តែព្រះថេរៈបំណងនឹងទូលសួរព្រះមានព្រះភាគ ដល់ពុទ្ធវង្ស ព្រោះថា ពុទ្ធវង្សនោះ ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ មិនមែនវិស័យនៃព្រះបច្ចេកពុទ្ធ និងព្រះសាវកទាំងឡាយទេ ព្រោះហេតុនោះ ទើបគួរដឹងថា ព្រះថេរៈពោលយ៉ាងនេះ ក៏ព្រោះពុទ្ធវង្ស មិនមែន

វិស័យ ។ បទថា **វិគតបរិស្សយា** គឺជា **វិគតបរិស្សយា** ( ទីងបន្ទោបង់ ) ។

គ្រានោះ ភិក្ខុទាំងនោះស្តាប់ពាក្យរបស់ព្រះថេរៈហើយ នាំគ្នាកាន់បាត្រ និងចីវររៀងៗ ខ្លួន ដូចដំរីធំពាក់ក្រោះល្អហើយ មានកិលេសដែលទម្លាយហើយ មានចំណងកាត់ផ្តាច់ហើយ ជាអ្នកប្រាជ្ញាតិច សន្តោស ស្ងាត់ មិនប្រឡូកប្រឡំ ដល់ព្រមដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈ ក៏នាំគ្នាប្រញាប់ប្រញាល់មកប្រជុំ ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា

ឯពួកភិក្ខុទាំងនោះ ជាអ្នកមានប្រាជ្ញាចាស់ក្លា សង្រួមឥន្ទ្រិយ
ក៏ទទួលព្រមថា សាធុ ហើយប្រដាប់បាត្រ និងចីវរ ដើរទៅ
ជាប្រញាប់ ដូច្នេះ ។

ក្នុងគាថានោះ **សាធុ** សព្ទ ក្នុងបទថា **សាធុ** នេះ ប្រើក្នុងអត្ថទាំងឡាយ មានសំណូមពរ ទទួល ល្អចិត្ត និងប្រពៃជាដើម ពិតហើយ **សាធុ** សព្ទនេះ ប្រើក្នុងអត្ថថា សំណូមពរ ដូចក្នុងប្រយោគជាដើមថា **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះមានព្រះភាគ សម្តែងធម៌ដោយសង្ខេបដល់ខ្ញុំ ដូច្នេះ ។

មកក្នុងអត្ថទទួល ដូចក្នុងប្រយោគជាដើមថា **សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា** ភិក្ខុនោះ ទទួលពាក្យថា សាធុព្រះអង្គ ហើយរីករាយអនុមោទនាភាសិតរបស់ព្រះមានព្រះភាគដូច្នេះ ។

មកក្នុងអត្ថថា ឲ្យរីករាយចិត្ត ដូចក្នុងប្រយោគជាដើមថា **សាធុ សាធុ សារីបុត្ត** ប្រពៃហើយ ប្រពៃហើយ សារីបុត្ត ដូច្នេះ ។

មកក្នុងអត្ថថា ប្រពៃ ដូចក្នុងប្រយោគជាដើមថា

**សាធុ ធម្មរុចិ រាជា សាធុ បញ្ញាណវា នរោ**

**សាធុ មិត្តានមទ្ទុព្ភោ បាបស្សាករណំ សុខំ ។**

ព្រះរាជាជាអ្នកគាប់ចិត្តដោយធម៌ទើបល្អ ជនមានប្រាជ្ញាទើបល្អ ការមិនប្រទូស្តមិត្តទើបល្អ កិរិយាមិនធ្វើបាបទើបសុខ ដូច្នេះ ។

តែក្នុងទីនេះ បំណងយកអត្ថថា ទទួល ព្រោះហេតុនោះ ទើបមានសេចក្តីថា ភិក្ខុទាំងនោះទទួលពាក្យរបស់ព្រះថេរៈថា សាធុ ប្រែថា ប្រពៃ ។ បទថា **និបកា** បានដល់ បណ្ឌិតអ្នកមានបញ្ញា ។ បទថា **សំវុត្តិន្ទ្រិយា** បានដល់ គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ អធិប្បាយថា ជាអ្នកប្រកបដោយឥន្ទ្រិយសំវរៈ ។ បទថា **តរមានា** ប្រែថា ប្រញាប់ ។ បទថា **ឧបាគមុំ** បានដល់ ចូលទៅរកព្រះថេរៈ ។

ឥឡូវនេះ ព្រះសង្គីតិកាចារ្យទាំងឡាយ កាលសម្តែងការប្រព្រឹត្តទៅរបស់ព្រះធម្មសេនាបតី ទើបពោលគាថាថា **វីណាសវេហិ វិមលេហិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ទន្តេហិ** បានដល់ ជាអ្នកទូន្មានផ្លូវកាយផ្លូវចិត្តហើយ ។ បទថា **ឧត្តមេ ទមេ** បានដល់ ក្នុងអរហត្ត ។ គប្បីឃើញថាជាសត្តមីវិភត្តិ ចុះក្នុងអត្ថនិមិត្តសត្តមី ។ បទថា **តេហិ ភិក្ខូហិ** បានដល់

ដែលភិក្ខុ ៥០០ ។ បទថា **មហាគណី** សេចក្តីថា ឈ្មោះថា **មហាគណី** ព្រោះលោកមានគណៈធំ ដោយសីលជាដើម និងដោយរាប់ចំនួន ។ ឬ ឈ្មោះថាមហាគណៈ ព្រោះជាគណៈធំដោយគុណទាំងឡាយ មានសីលជាដើម ដោយអំណាចនៃបទផ្សេងៗ ឈ្មោះថា មហាគណៈ ព្រោះគណៈធំរបស់លោកមាន ។ បទថា **លឡន្តោ ទេវោវ គគនេ** សេចក្តីថា ល្អហើយ ដោយឥទ្ធិវិលាស ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងផ្ទៃអាកាស ដូចទេវតា ។

ឥឡូវនេះ ដើម្បីសម្តែងវិធីចូលគាល់ថា ភិក្ខុមានឈ្មោះយ៉ាងនេះទាំងនោះ ចូលគាល់ហើយ ទើបព្រះសង្គីតិកាចារ្យទាំងឡាយ ពោលពាក្យថា **ឧក្កាសិតញ្ច ខិបិតំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឧក្កាសិតញ្ច** បានដល់ សំឡេងក្អក ។ បទថា **ខិបិតញ្ច** បានដល់ សំឡេងកណ្តាស ។ បទថា **អជ្ឈុបេក្ខិយ** បានដល់ ព្រងើយ អធិប្បាយថា មិនធ្វើទាំង ២ យ៉ាង គឺស្ងប់ស្ងាត់ ។ បទថា **សុព្វតា** បានដល់ មានធុតង្គគុណផូរផង់ល្អ ។ បទថា **សប្បតិស្សា** បានដល់ មានការកោតក្រែង អធិប្បាយថា ឱនលំទោនខ្លួន ។

បទថា **សយម្ភុំ** សេចក្តីថា មានពុទ្ធការៈដែលទ្រង់បំពេញព្រះបារមីទាំងឡាយ សម្រេចហើយដោយព្រះអង្គឯង វៀរការអាងដល់អ្នកដទៃ ។ បទថា **អច្ចុគ្គតំ** បានដល់ រះថ្មីៗ ។ បទថា **ចន្ទំវ** បានដល់ បីដូចព្រះចន្ទ ។ គប្បីភ្ជាប់បទយ៉ាងនេះថា ឃើញព្រះមានព្រះភាគរុងរឿងក្នុងផ្ទៃអាកាស ដូច

ព្រះចន្ទក្នុងលម្ហ ដូច្នោះ ។ **យថា** សព្វ ក្នុងទីនេះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។ បទថា **វិទ្ធំវ** បានដល់ ដូចផ្ទៃកបន្ទោរ អធិប្បាយថា ដូចផ្ទៃកបន្ទោរ មានពន្លឺមួយខណៈ តែតាំងនៅយូរ ដូច្នោះ ។ បទថា **គគនេ យថា** បានដល់ ដូចក្នុងអាកាស ។ តែក្នុងទីនេះ **យថា** សព្វ ត្រឹមតែជានិបាតប៉ុណ្ណោះ ។ ក្រៅអំពីទីនេះ **យថា** សព្វ ក្នុងលក្ខណៈបែបនេះ គប្បីឃើញថា ត្រឹមតែជានិបាត ។

បទថា **រហទមិវ វិប្បសន្នំ** សេចក្ដីថា ទឹកមិនល្អក់ ថ្លា ដូចអន្លង់ទឹកធំ ជ្រៅផង ធំផង ដូច្នោះ ។ បទថា **សុផុល្លំ បទុមំ យថា** គប្បីឃើញសេចក្ដីថា ដូចអន្លង់ទឹក មានគុម្ពឈូកដែលមានផ្ការីក ។ បាឋៈថា **សុផុល្លំ កមលំ យថា** ដូច្នេះក៏មាន សេចក្ដីថា ដូចព្រៃឈូកមានផ្ការីកស្គុះស្គាយ ព្រោះផ្កាឈូកនោះ គួរប្រាថ្នា ។

គ្រានោះ ភិក្ខុទាំងនោះ មានព្រះធម្មសេនាបតីជាប្រធាន ធ្វើអញ្ជលីលើសិរសា ក្រាបចុះទៀបយុគលបាទដែលប្រដាប់ដោយចក្រ ។ ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា **អញ្ជលឹ បគ្គហេត្វាន តុដ្ឋហដ្ឋា បមោទិតា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **និបតន្តិ** បានដល់ ក្រាបចុះ អធិប្បាយថា ថ្វាយបង្គំ ។ បទថា **ចក្កលក្ខណេ** សេចក្ដីថា ព្រះបាទដែលមានលក្ខណាចក្រឈ្មោះថា ចក្កលក្ខណៈ បានដល់ ត្រង់ព្រះបាទដែលមានចក្កលក្ខណៈនោះ លោកពោលពាក្យថា **ឋានេ** ដោយអំណាចនៃជាតិ អធិប្បាយថា ក្រាប

ចុះទៀបព្រះយុគលបាទនៃព្រះសាស្តា ដែលប្រដាប់ដោយចក្ក ។

ឥឡូវនេះ ព្រះសង្គីតិកាចារ្យទាំងឡាយ កាលសម្តែងនាមខ្លះរបស់ព្រះថេរៈទាំងនោះ ទើបពោលគាថាថា **សារិបុត្តោ មហាបញ្ញោ កោរណ្ឌសមសាធិសោ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **កោរណ្ឌសមសាធិសោ** បានដល់ អ្នកមានពណ៌សម្បុរដូចផ្កាសិរមាន់ ។ បើមានពាក្យសួរថា បើដូច្នោះ ក៏គួរពោលថា **កោរណ្ឌសមោ** ឬ **កោរណ្ឌសធិសោ** ហេតុអ្វី ទើបលោកពោលថា **សមសាធិសោ** ដល់ទៅ ២ ដង ។ ឆ្លើយថា នេះមិនខុសទេ ព្រះថេរៈនោះ ឈ្មោះថា ដូចគ្នានឹងផ្កាសិរមាន់ ដោយដូចគ្នានឹងផ្កាសិរមាន់ ព្រោះស្មើគ្នានឹងផ្កាសិរមាន់ អធិប្បាយថា មិនមែនពោលដោយលើស ។ **កុសល** សព្ទនេះ ក្នុងបទថា **សមាធិជ្ឈានកុសលោ** នេះ ប្រើក្នុងអត្ថទាំងឡាយ មានអត្ថថា មិនមានរោគ មិនមានទោស ឈ្លាស និងមានសុខជាវិបាកជាដើម ។ ពិតហើយ **កុសល** សព្ទនេះ ប្រើក្នុងអត្ថថា មិនមានរោគ ដូចក្នុងប្រយោគជាដើមថា **កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ** លោកដ៏ចម្រើន មានសេចក្តីសុខស្រួលទេឬ លោកដ៏ចម្រើន មានអនាម័យទេឬ ដូច្នេះ ។

មកក្នុងអត្ថថា មិនមានទោស ដូចក្នុងប្រយោគជាដើមថា **កតមោ បន ភន្តេ កាយសមាចារោ កុសលោ យោ ខោ មហារាជ កាយសមាចារោ អនវជ្ជោ** បពិត្រលោកម្ចាស់ កាយសមាចារជាកុសល គឺអ្វី ។

ថ្វាយព្រះពរមហាបពិត្រ កាយសមាចារជាកុសល គឺមិនមានទោស ដូច្នេះ ។

មកក្នុងអត្ថថា ឈ្លាស ដូចក្នុងប្រយោគជាដើមថា **កុសលោ ត្វំ រថស្ស អង្គបច្ចង្គានំ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកឈ្លាសក្នុងអវយវៈ តូចធំនៃរថដែរ ដូច្នេះ ។

មកក្នុងអត្ថថា មានសុខជាវិបាក ដូចក្នុងប្រយោគជាដើមថា **កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា** ព្រោះហេតុបានធ្វើ បានសន្សំនូវកម្ម ( ជាកាមាវចរ ) កុសល ដូច្នេះ ។ តែក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងអត្ថថា ឈ្លាស ។ បទថា **វន្ទតេ** បានដល់ ថ្វាយបង្គំហើយ ។

បទថា **គជ្ជិតា** មានវិគ្គហៈថា ឈ្មោះថា គជ្ជិតៈ ព្រោះអត្ថថា គំរាម ។ បទថា **កាលមេឃោវ** បានដល់ គំរាមដូចអាកាស ដែលទ្រទ្រង់នូវទឹកពណ៌ខៀវគំរាម អធិប្បាយថា ក្នុងវិស័យនៃឫទ្ធិ ។ បទថា **នីលុប្បលសមសាទិសោ** បានដល់ មានពណ៌ដូចឧប្បលខៀវ គប្បីជ្រាបសេចក្ដីក្នុងទីនេះ ដោយន័យដែលពោលហើយខាងដើម ។ ព្រះកោលិតៈដែលបានឈ្មោះតាមគោត្រយ៉ាងនេះថា មោគ្គល្លាន ។

បទថា **មហាកស្សបោបិ ច** បានដល់ ប្រៀបធៀបនឹងឧរុវេលកស្សបៈ នទីកស្សបៈ គយាកស្សបៈ កុមារកស្សបៈ ដែលជាព្រះថេរៈតូចនិងតូច ព្រះកស្សបៈរូបនេះជាធំ ព្រោះហេតុនោះ ទើបលោកហៅថា មហាកស្សបៈ ។ សព្ទថា **បិ ច** មានអត្ថថា សរសើរ និងរួបរួម ។ បទថា **ឧត្តត្តកនកសន្និភោ** បានដល់ មានពណ៌សម្បុរដូចគ្នានឹងមាសដែលគេរំលាយ ។ ក្នុង

បទថា **ធុតគុណោ** នេះ ធម៌ ឈ្មោះថា **ធុត** ព្រោះកម្ចាត់កិលេស ធម៌កម្ចាត់កិលេស ឈ្មោះថា **ធុតគុណ** ។ **ធុតធម៌** គឺអ្វី គឺធម៌ ៥ ប្រការ បរិវារ របស់ធុតង្គ ចេតនាទាំងនេះ គឺអប្បិច្ឆតា ការប្រាថ្នាតិច ១ សន្តុដ្ឋិតា ការសន្តោស ១ សល្លេខតា ការជុសខាត់ ១ បវិវេកតា ការស្ងាត់ ១ ឥទមត្ថិកតា ការកាន់យកតែប្រយោជន៍ ១ ។ ឈ្មោះថា **ធុតធម៌** ព្រោះបាលីជាដើមថា អាស្រ័យការប្រាថ្នាតិចនោះឯង ។ ម្យ៉ាងទៀត **ញាណ** ឈ្មោះថា **ធុត** ព្រោះកម្ចាត់កិលេសទាំងឡាយក្នុងធុតគុណនោះ ។ បទថា **អគ្គនិក្ខិត្តោ** បានដល់ ដែលទ្រង់ស្ថាបនាថា ជាកំពូល ជាបុគ្គលប្រសើរបំផុត ជាអគ្គបុគ្គល អធិប្បាយថា ដែលព្រះមានព្រះភាគទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកពោលពាក្យកម្ចាត់បង់កិលេស ស្រេចនឹងមហាកស្សបៈប្រសើរជាងគេ ដូច្នេះ ។ **អគ្គ** សព្ទនេះ ប្រើក្នុងអត្ថទាំងឡាយ មានអត្ថថា ជាខាងដើមចុង ចំណែកប្រសើរ បំផុតជាដើម ។

ពិតហើយ **អគ្គ** សព្ទ ប្រើក្នុងអត្ថថា ជាខាងដើម ដូចក្នុងប្រយោគជាដើមថា **អជ្ជតគ្គេ សម្ម ទោវារិក អាវរាមិ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ** ម្នាលអ្នករក្សាទ្វារជាសម្លាញ់ ពីថ្ងៃនេះជាដើមរៀងទៅ ខ្ញុំបិទទ្វារចំពោះពួកនិគ្គណ្ឋប្រុស និងពួកនិគ្គណ្ឋស្រី ដូច្នេះ ។

មកក្នុងអត្ថថា ចុង ដូចក្នុងប្រយោគជាដើមថា **តេនេវ អង្គុលគ្គេន តំ អង្គុលគ្គំ បរាមសតិ** ស្ទាបអង្គែលនូវចុងម្រាមនោះ ដោយចុងម្រាមនោះ

និង **ឧច្ចុគ្គំ វេឡុគ្គំ** ចុងអំពៅ ចុងឫស្សី ដូច្នេះ ។

មកក្នុងអត្ថថា ចំណែក ដូចក្នុងប្រយោគជាដើមថា **អម្ពិលគ្គំ វា ... មធុរគ្គំ វា** មានឱជារសជូរក្តី ... មានឱជារសផ្អែមក្តី និង **អនុជានាមិ ភិក្ខវេ វិហារគ្គេន គាហេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រគល់តាមកំណត់នៃវិហារ និង **អនុជានាមិ ភិក្ខវេ បរិវេណគ្គេន គាហេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រគល់ តាមកំណត់នៃបរិវេណ ដូច្នេះ ។

មកក្នុងអត្ថថា ប្រសើរបំផុត ដូចក្នុងប្រយោគជាដើមថា **យាវតា ភិក្ខវេ សត្តា អបទា វា ។បេ។ តថាគតោ តេសំ អគ្គមក្ខាយតិ** ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី ។បេ។ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ ដូច្នេះ ។ **អគ្គ** សព្ទនោះ ក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងអត្ថថា ប្រសើរបំផុត និងប្រើក្នុងអត្ថថា កំពូលក៏មាន ព្រះថេរៈតាំងនៅក្នុងភាពជាបុគ្គលប្រសើរ និងជាកំពូលក្នុងតំណែងរបស់ខ្លួន ដោយហេតុនោះ ទើបខ្ញុំពោលថាបទថា **អគ្គនិក្ខិត្តោ** បានដល់ ជាបុគ្គលប្រសើរ ជាបុគ្គលប្រសើរបំផុត ជាកំពូល ។ បទថា **ថោមិតោ** បានដល់ ដែលទេវតា និងមនុស្សជាដើមសរសើរហើយ ។ បទថា **សត្ថុ វណ្ណិតោ** បានដល់ ដែលព្រះសាស្តា ទ្រង់សរសើរហើយ អធិប្បាយថា ដែលព្រះសាស្តាទ្រង់សរសើរដោយន័យដែលមកក្នុងព្រះសូត្រជាច្រើន ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ជាដើម យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កស្សបៈមានឧបមាដូចព្រះចន្ទ្រ តែងដកកាយ ដកចិត្តចេញ ផ្ទើ

ដូចជាអាគន្តុកភិក្ខុ មិនឃើញសយ្យានៈក្នុងត្រកូលទាំងឡាយ ហើយចូលទៅកាន់ត្រកូល ដូច្នេះ ។ ព្រះមហាកស្សបៈនោះ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ។

បទថា **ទិព្វចក្ខុ** សេចក្តីថា ទិព្វចក្ខុ មានដល់ភិក្ខុពួកណា ភិក្ខុទាំងនោះ ឈ្មោះថា មានទិព្វចក្ខុ ព្រះអនុរុទ្ធ ជាកំពូលជាងភិក្ខុទាំងឡាយ ខាងទិព្វចក្ខុ ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុ អ្នកមានទិព្វចក្ខុ ស្រេចនឹងអនុរុទ្ធប្រសើរជាងគេ ។ ព្រះអនុរុទ្ធត្ថេរ ជាឱរសរបស់ព្រះបាទអមិតោទនសក្យៈ ដែលជាឱពុកមារបស់ព្រះមានព្រះភាគ ជាប្អូនប្រុសរបស់ព្រះបាទមហានាមសក្យៈ ជាអ្នកមានបុណ្យច្រើន ជាស្តេចសុខុមាលជាតិ ជាបុគ្គលគម្រប់ ៧ ចេញអំពីផ្ទះ បួសមិនមានផ្ទះ ។ លំដាប់បព្វជ្ជារបស់ព្រះថេរៈមកហើយ ក្នុងសង្ឃភេទក្ខន្ធកៈ ។ បទថា **អភិទូរេ** បានដល់ ក្នុងសម្នាក់របស់ព្រះមានព្រះភាគនោះឯង ។ បទថា **អាបត្តិ-អនាបត្តិយា** បានដល់ ឈ្លាសក្នុងអាបត្តិ និងអនាបត្តិ ។ បទថា **សតេ-កិច្ឆាយ** សេចក្តីថា ក្នុងអាបត្តិដែលសម្តែងបានក៏មាន សម្តែងមិនបានក៏មាន ។ បណ្តាអាបត្តិទាំងនោះ អាបត្តិដែលសម្តែងបាន មាន ៦ យ៉ាង អាបត្តិដែលសម្តែងមិនបាននោះ គឺអាបត្តិបារាជិក ។ បាឋៈថា **អាបត្តិអនា-បត្តិយា សតេកិច្ឆាយ កោវិទោ** ដូច្នេះក៏មាន ។ សេចក្តីក៏យ៉ាងនោះដូចគ្នា ។ បទថា **វិនយេ** បានដល់ ក្នុងវិនយបិដក ។ បទថា **អគ្គនិក្ខិត្តោ** សេចក្តីថា ព្រះឧបាលីដែលព្រះមានព្រះភាគ ទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ស្រេចនឹងឧបាលី ប្រសើរ

ជាងគេ ដូច្នេះ ។ បទថា **ឧបាលិ** បានដល់ ព្រះឧបាលិត្ថេរ ។ បទថា **សត្ថុ-វណ្ណិតោ** បានដល់ ដែលព្រះសាស្ដាទ្រង់លើកតម្កើង ទ្រង់សរសើរ ។ បាន ឮថា ព្រះថេរៈរៀនវិនយបិដកក្នុងសម្នាក់ព្រះតថាគតប៉ុណ្ណោះ ដោះស្រាយ ៣ រឿង គឺភារុកច្ឆកវត្ថុ អជ្ជុកវត្ថុ កុមារកស្សបវត្ថុ ប្រហាក់ប្រហែលនឹង សព្វញ្ញុតញ្ញាណ ។ ព្រោះហេតុនោះ ទើបលោកពោលថា ដែលព្រះសាស្ដា ទ្រង់សរសើរ ដោយន័យជាដើមយ៉ាងនេះថា ជាកំពូលជាងភិក្ខុសាវកអ្នក ទ្រទ្រង់វិន័យ ។

បទថា **សុខុមនិបុណត្ថបដិវិទ្ធោ** បានដល់ ចាក់ធ្លុះនូវអត្ថដ៏ល្អិតសុខុម អធិប្បាយថា ជាអ្នកចាក់ធ្លុះនូវអត្ថដែលល្អិត ឃើញបានលំបាកហើយ ។ បទថា **កថិកានំ បវរោ** បានដល់ ជាបុគ្គលប្រសើរបំផុតជាងភិក្ខុដែលជា ធម្មកថិក ។ ព្រះសាស្ដាទ្រង់ស្ថាបនាក្នុងឯតទគ្គបាលីថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកជាធម្មកថិក ស្រេចនឹងបុណ្ណមន្តានីបុត្តប្រសើរជាងគេ ដូច្នេះ ។ ដោយហេតុនោះ ទើបលោកពោលថា ជាបុគ្គលប្រសើរបំផុត ជាងភិក្ខុ សាវកដែលជាធម្មកថិក ។ បទថា **គណី** បានដល់ ជាអ្នកមានគណៈ ។ បានឮថា កុលបុត្តដែលបួសក្នុងសម្នាក់ព្រះថេរៈមាន ៥០០ អង្គ ភិក្ខុទាំងនោះ ជាកុលបុត្តដែលកើតក្នុងជាតិភូមិរបស់ព្រះទសពល គ្រប់អង្គសុទ្ធតែជាព្រះ ខីណាស្រព សុទ្ធតែបាននូវកថាវត្ថុ ១០ ដោយហេតុនោះ ទើបលោកពោល ថា **គណី** គឺជាអ្នកមានគណៈ ។ បទថា **ឥសិ** ឈ្មោះថា ឥសី ព្រោះស្វែង រកកុសលធម៌ទាំងឡាយ ។ បទថា **មន្តាណិយា បុត្តោ** បានដល់ ជាបុត្តរបស់

ព្រាហ្មណី ឈ្មោះមន្តានី ។ បទថា **បុណ្ណោ** ជាឈ្មោះរបស់ព្រះថេរៈ ។ បទថា **វិស្សុតោ** បានដល់ មានឈ្មោះបោះសំឡេងដោយគុណរបស់ខ្លួន មានការប្រាថ្នាតិចជាដើម ។

ឯព្រះអញ្ញាកោណ្ឌញ្ញត្ថេរ កាលព្រះសាស្តាទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ប្រកាសនូវធម្មចក្កដ៏ប្រសើរហើយ យាងមកតាមលំដាប់ ទ្រង់អាស្រ័យក្រុងរាជគ្រឹះគង់នៅ លោកត្រឡប់មកកាន់នគរកបិលពស្តុ បំបួសមាណពឈ្មោះបុណ្ណៈជាក្មួយប្រុសរបស់ខ្លួន ថ្វាយបង្គំលាព្រះមានព្រះភាគទៅកាន់ស្រះឆទ្ទន្ត ដើម្បីនៅជាប្រចាំ ។ ឯបុណ្ណៈមកជាមួយព្រះថេរៈ ដើម្បីគាល់ព្រះមានព្រះភាគ គិតថា អញនឹងធ្វើកិច្ចរបស់អ្នកបួសឲ្យស្រេចមុនហើយសឹមទៅគាល់ព្រះទសពល ទើបសម្ងំនៅក្នុងនគរកបិលពស្តុនោះឯងលោកធ្វើយោនិសោមនសិការ មិនយូរប៉ុន្មានក៏សម្រេចអរហត្ត ចូលគាល់ព្រះមានព្រះភាគ បណ្តាព្រះថេរៈទាំងនោះ ព្រះថេរៈ ២ រូប គឺអនុរុទ្ធត្ថេរនិងព្រះឧបាលិត្ថេរ អាចារ្យពួកខ្លះ សម្តែងដូចពួកលោកបួសក្នុងថ្ងៃដែលព្រះមានព្រះភាគ យាងចូលទៅកាន់នគរកបិលពស្តុ ហើយប្រជុំពួកព្រះញាតិពាក្យនោះ មិនសាកសមនឹងបាលីក្នុងខន្ធកៈ និងអដ្ឋកថា គប្បីពិចារណាហើយកាន់យកចុះ ។

គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបអាចារនៃចិត្តរបស់ភិក្ខុ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាដើម ហើយទ្រង់ផ្តើមត្រាស់នូវគុណទាំងឡាយរបស់ព្រះអង្គ ដោយហេតុនោះ ទើបព្រះសង្គីតិការចារ្យទាំងឡាយបានពោលថា

ព្រះមុនីទ្រង់ឈ្វាសក្នុងពាក្យឧបមា ទ្រង់ជ្រាបនូវចិត្តនៃភិក្ខុ
ទាំងឡាយនុ៎ះ ទ្រង់មានព្យាយាមធំ កាត់នូវសេចក្ដីសង្ស័យ
ទ្រង់សម្ដែងនូវគុណរបស់ព្រះអង្គ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱបម្មកុសលោ** បានដល់ ឈ្វាសក្នុងឧបមា ។ បទថា **កង្ខច្ឆេទោ** បានដល់ ទ្រង់កាត់សេចក្ដីសង្ស័យរបស់សត្វទាំងពួង ។

ឥឡូវនេះ ដើម្បីទ្រង់សម្ដែងព្រះគុណទាំងឡាយរបស់ព្រះអង្គ ដែលទ្រង់ត្រាស់ហើយ ទើបទ្រង់ត្រាស់ថា

ទីបំផុតនៃអសង្ខេយ្យទាំងឡាយណា ដែលបុគ្គលដឹងមិនបាន
អសង្ខេយ្យទាំងនោះមាន ៤ ប្រការ អសង្ខេយ្យទាំងនុ៎ះ គឺ
ពួកសត្វ ១ អាកាស ១ ចក្កវាឡ មិនមានទីបំផុត ១
ពុទ្ធញ្ញាណដែលប្រមាណមិនបាន ១ បុគ្គលមិនអាចដឹងបាន
ឡើយ ដូច្នេះ ។

ក្នុងគាថានោះ សព្ទថា **ចត្តារោ** បានដល់ កំណត់ចំនួន ។ ព្រះមានព្រះភាគ ទ្រង់ចង្អុលដើម្បីត្រាស់ក្នុងឥឡូវនេះ ដោយបទថា **ឯតេ** ។ បទថា **អសង្ខេយ្យា** បានដល់ ឈ្មោះថា អសង្ខេយ្យ ព្រោះបុគ្គលណាមួយ មិនអាចរាប់បាន អធិប្បាយថា ហួសនឹងរាប់ ។ បទថា **កោដិ** បានដល់ ព្រំដែនខាងដើម ឬខាងចុង ។ បទថា **យេសំ** បានដល់ អសង្ខេយ្យ ៤ ពួកណា ។ បទថា **ន ញាយតិ** បានដល់ មិនមានបុគ្គលណាមួយដឹង ។ ឥឡូវនេះ ដើម្បីសម្ដែងអសង្ខេយ្យ ៤ ដូចពោលហើយនោះ ទើបត្រាស់ពាក្យថា

**សត្តកាយោ** ជាដើម ។ បទថា **សត្តកាយោ** បានដល់ពួកសត្វ ។ ពួកសត្វ មិនមានទីបំផុត មិនមានប្រមាណ រាប់មិនបាន ។ អាកាសក៏យ៉ាងនោះ ទីបំផុតនៃអាកាសមិនមាន ចក្កវាឡក៏ដូចគ្នា មិនមានទីបំផុតដូចគ្នា ពុទ្ធញាណ គឺសព្វញ្ញុតញ្ញាណក៏រាប់មិនបាន ។ បទថា **ន សក្កា ឯតេ វិជានិតុំ** សេចក្តីថា ព្រោះអសង្ខេយ្យទាំងនោះ មិនមានទីបំផុត ហេតុនោះ ទើបបុគ្គលណាមួយ មិនអាចដឹងបាន ។

ឥឡូវនេះ ព្រះសាស្តាកាលទ្រង់ពង្រីកព្រះធម្មទេសនាថា ក្នុងការធ្វើឫទ្ធិផ្សេងៗ របស់ព្រះអង្គនោះ អស្ចារ្យដូចម្តេច សម្រាប់ទេវតា និងមនុស្សជាដើម ដែលកើតនូវការអស្ចារ្យ ការអស្ចារ្យវិសេសក្រៃលែងជាងនោះនៅមាន សូមអ្នកទាំងឡាយស្តាប់ការអស្ចារ្យនោះរបស់តថាគត ទើបត្រាស់ពាក្យជាដើមថា

> ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ការដែលតថាគតធ្វើឫទ្ធិប្លែកៗ
> ណា ការធ្វើឫទ្ធិប្លែកៗ នុ៎ះ នឹងទុកជាហេតុអស្ចារ្យ ក្នុងលោក
> ដូចម្តេចបាន ព្រោះហេតុជាអស្ចារ្យចម្លែក គួរព្រឺរោមដទៃ
> ទៀត នៅមានច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កឹ** ជាពាក្យជំទាស់ ។ ព្រះសាស្តាត្រាស់ពាក្យថា **ឯតំ** ទ្រង់សំដៅដល់ការធ្វើឫទ្ធិផ្សេងៗ នេះ ។ បទថា **យំ** នេះ ក្នុងបទថា **យំ** ប្រើក្នុងអត្ថទុតិយាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **យំ តំ អបុច្ឆិម្ហ អកិត្តយីនោ អញ្ញំ តំ បុច្ឆាម តទិង្ឃ ព្រូហិ** ខ្ញុំបានសួរនូវធម៌ណា

ព្រះអង្គក៏បានសម្តែងធម៌នោះដល់ខ្ញុំរួចហើយ ខ្ញុំសូមសួរធម៌ផ្សេងទៀត សូមព្រះអង្គសម្តែងធម៌នោះដល់ខ្ញុំឲ្យទាន ដូច្នេះ ៗ ប្រើក្នុងអត្ថថា តតិយា ដូចក្នុងប្រយោគជាដើមថា **អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ឯកិស្សា លោកធាតុយា ទ្វេ អរហន្តោ សម្មាសម្ពុទ្ធា** ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គ គប្បីកើតឡើង មិនមុនមិនក្រោយ ក្នុងលោកធាតុតែមួយ គឺចក្កវាឡ ១ ដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនបច្ច័យ គឺថា ហេតុនុ៎ះ មិនមានឡើយ ដូច្នេះ ប្រើក្នុងអត្ថសត្តមីវិភត្តិ ដូចក្នុងប្រយោគនេះថា **យំ វិបស្សី ភគវា កប្បេ ឧទបាទិ** ព្រះវិបស្សីមានព្រះភាគទ្រង់កើតឡើងក្នុងកប្បណា ដូច្នេះ ៗ ប្រើក្នុងអត្ថថា បឋមាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **យំ មេ ភន្តេ ទេវានំ តាវតឹសានំ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អាចេក្ខាមិ តំ ភគវតោ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលព្រះមានព្រះភាគ នូវសេចក្តីដែលខ្ញុំព្រះអង្គ បានស្តាប់ក្នុងទីចំពោះមុខ បានទទួលក្នុងទីចំពោះមុខ នៃពួកទេវតាជាន់តាវត្តិង្ស ដូច្នេះ ៗ តែក្នុងទីនេះ គប្បីជ្រាបថា ប្រើក្នុងអត្ថបឋមាវិភត្តិ ៗ ទ្រង់សម្តែងថា ភាពអស្ចារ្យទាំងឡាយ ភាពវិសេសដែលគួរអស្ចារ្យដទៃរបស់តថាគត នៅមានច្រើន ៗ ឥឡូវនេះ កាលនឹងសម្តែងភាពអស្ចារ្យនោះ ទើបត្រាស់ពាក្យជាដើមថា

កាលដែលតថាគតនៅជាទេវបុត្ត ឈ្មោះសន្តុសិតក្នុងពួកទេវបុត្តជាន់តុសិត កាលនោះ ទេវតាមួយម៉ឺនលោកធាតុ មក

ប្រជុំគ្នា ធ្វើអញ្ជលី អារាធនាតថាគត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យទា** បានដល់ ក្នុងកាលណា ។ ព្រះមានព្រះភាគទ្រង់ចង្អុលព្រះអង្គឯង ដោយបទថា **អហំ** ។ បទថា **តុសិតេ កាយេ** បានដល់ ពួកទេវតាដែលឈ្មោះថា តុសិត ។ ក្នុងកាលណា តថាគតបំពេញបារមី ៣០ មហាបរិច្ចាគ ៥ ដែលដល់ទីបំផុត នៃញាតត្ថចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយា ឲ្យនូវសត្តសតកមហាទាន ធ្វើផែនដីឲ្យញ័រអស់ ៧ ដង ចុតិចាកអត្តភាពជាព្រះវេស្សន្តរហើយ កើតក្នុងតុសិតភពក្នុងវារចិត្តទី ២ ក្នុងកាលនោះ តថាគតក៏បានជាទេវរាជ ឈ្មោះសន្តុសិត ។ បទថា **ទសសហស្សី អាគម្ម** សេចក្ដីថា ទេវតាក្នុងម៉ឺនចក្កវាឡមកប្រជុំគ្នាហើយ ។ បទថា **យាចន្តិ បញ្ជលី មមំ** សេចក្ដីថា ទេវតាម៉ឺនលោកធាតុចូលទៅអារាធនាតថាគតថា បពិត្រលោកនិទ្ទុក្ខ ទ្រង់បំពេញបារមី ១០ មិនមែនប្រាថ្នាសក្កសម្បត្តិ មិនមែនប្រាថ្នាមារសម្បត្តិ មិនមែនប្រាថ្នាព្រហ្មសម្បត្តិ មិនមែនប្រាថ្នាចក្កពត្តិសម្បត្តិ តែទ្រង់ប្រាថ្នាជាព្រះពុទ្ធ បំពេញដើម្បីចម្លងសត្វឆ្លងចាកឱឃសង្សារ បពិត្រលោកនិទ្ទុក្ខ នេះជាកាលដើម្បីភាពជាព្រះពុទ្ធរបស់លោក បពិត្រលោកនិទ្ទុក្ខ នេះជាសម័យដើម្បីភាពជាព្រះពុទ្ធរបស់លោក ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យពោលថា

បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ គួរដល់ព្រះអង្គ
ហើយ សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្ស-
លោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន

ឈ្មោះអមតៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាលោ តេ** បានដល់ ជាការសមគួរសម្រាប់ព្រះអង្គ បាឋៈក៏យ៉ាងនោះដូចគ្នា ។ បទថា **ឧប្បជ្ជ** បានដល់ បដិសន្ធិ ។ បាឋៈថា **ឱក្កម្ម** ក៏មាន ។ បទថា **សទេវកំ** សេចក្ដីថា មនុស្សលោក ព្រមទាំងទេវលោក ។ ក្នុងបទថា **តារយន្តោ** នេះ ទ្រង់បំពេញបារមីក៏ឈ្មោះថា ជួយឲ្យឆ្លង ដោយទ្រង់បំពេញបារមីស្រេច ក៏ឈ្មោះថា ជួយឲ្យឆ្លង ។ ទ្រង់ចុតិចាកអត្តភាពជាព្រះវេស្សន្តរ បដិសន្ធិក្នុងតុសិត តាំងនៅក្នុងតុសិតនោះអស់ ៥៧ កោដិ ៦ លានឆ្នាំ ក៏ឈ្មោះថា ជួយឲ្យឆ្លង ។ ទ្រង់ត្រូវទេវតាទាំងឡាយទូលអារាធនា ទ្រង់ប្រមើលមើលមហាវិលោកនៈ ៥ ហើយ ទ្រង់បដិសន្ធិក្នុងគភ៌របស់ព្រះនាងមហាមាយាទេវីក្ដី ទ្រង់នៅក្នុងព្រះគភ៌គ្រប់ទសមាសក្ដី ក៏ឈ្មោះថា ជួយឲ្យឆ្លង ទ្រង់នៅគ្រប់គ្រងឃរាវាសវិស័យ ២៩ វស្សា ក៏ឈ្មោះថា ជួយឲ្យឆ្លង ក្នុងថ្ងៃប្រសូតព្រះរាហុលកុមារ ទ្រង់មាននាយឆន្នជាសម្លាញ់ ឡើងផែលសេះកណ្ឋកៈយាងចេញមហាភិនេស្ក្រមណ៍ក្ដី ទ្រង់រំលងរាជអាណាចក្រ ៣ ទ្រង់ព្រះផ្នួសត្រង់ឆ្នេរស្ទឹងអនោមាក្ដី ក៏ឈ្មោះថា ទ្រង់ជួយឲ្យឆ្លង ។ ទ្រង់បំពេញព្យាយាម ៦ ឆ្នាំក្ដី ក្នុងថ្ងៃវិសាខបុណ្ណមីទ្រង់ឡើងកាន់មហាពោធិមណ្ឌលដ្ឋាន ទ្រង់ផ្ចាញ់ពលរបស់មារក្នុងបឋមយាម ទ្រង់រម្លឹកដល់ខន្ធក្នុងបុព្វជាតិ មជ្ឈិមយាមទ្រង់ជម្រះទិព្វចក្ខុ បច្ឆិមយាម ទ្រង់ពិចារណាបដិច្ចសមុប្បាទមានអង្គ ១២ ទាំងអនុលោម និងបដិលោម ទ្រង់សម្រេចសោតាបត្តិមគ្គក្ដី ក៏ឈ្មោះថា ជួយឲ្យឆ្លង ។ ក្នុង

ខណៈសោតាបត្តិផលក្តី ក្នុងខណៈសកទាគាមិមគ្គក្តី ក្នុងខណៈសកទាគាមិផលក្តី ក្នុងខណៈអនាគាមិមគ្គក្តី ក្នុងខណៈអនាគាមិផលក្តី ក្នុងខណៈអរហត្តមគ្គក្តី ក្នុងខណៈអរហត្តផលក្តី ក៏ឈ្មោះថា ជួយឲ្យឆ្លង ក្នុងកាលណា បានប្រទានទឹកអម្រឹតដល់បញ្ចវគ្គិយភិក្ខុ មួយអន្លើដល់ទេវតា ១៨ ពាន់កោដិ[1] តាំងអំពីកាលនោះ លោកហៅថា ទ្រង់ជួយឲ្យឆ្លងហើយ ដោយហេតុនោះ ទើបលោកពោលថា

សូមទ្រង់ចម្លងមនុស្សលោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះអមតៈ ដូច្នេះ ។

គ្រានោះ ព្រះមហាសត្វសូម្បីត្រូវទេវតាទាំងឡាយអារាធនា ក៏មិនបានប្រទានពាក្យប្តេជ្ញាដល់ទេវតាទាំងឡាយ តែទ្រង់ប្រមើលមើលមហាវិលោកនៈ ៥ គឺកំណត់កាល ទ្វីប បទេស ត្រកូល ព្រះជន្មរបស់ព្រះជននី បណ្តាមហាវិលោកនៈ ៥ នោះ ទ្រង់ប្រមើលមើលកាលជាមុនថា ជាកាលសមគួរ ឬមិនសមគួរ ។ ក្នុងកាលនោះ អាយុកាលរបស់សត្វខ្ពស់ជាងមួយសែនឆ្នាំ មិនឈ្មោះថា កាល ព្រោះហេតុអ្វី ព្រោះទុក្ខ មានជាតិ ជរា មរណៈជាដើម មិនប្រាកដ ជម្មតាព្រះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយ ដែលឈ្មោះថា ផុតចាកត្រៃលក្ខណ៍ មិនមានឡើយ កាលព្រះពុទ្ធទាំងនោះត្រាស់ថា **អនិច្ចំ ទុក្ខំ អនត្តា** ដូច្នេះ សត្វទាំងឡាយមិនដឹងថា ព្រះពុទ្ធទាំងនោះត្រាស់រឿងអ្វី បន្ទាប់អំពីនោះ ការត្រាស់ដឹងក៏មិនមាន កាលការត្រាស់ដឹងនោះមិនមាន

---

១- ក្នុងទីខ្លះជា ១៨ កោដិ ។

ពាក្យប្រៀនប្រដៅ ក៏មិនជានិយ្យានិក ព្រោះហេតុនោះ ទើបកាលនោះ មិនជាកាលសមគួរ ។ សូម្បីអាយុកាលរបស់សត្វទាបជាង ១០០ ឆ្នាំ ក៏មិនជាកាលសមគួរ ព្រោះហេតុអ្វី ព្រោះកាលនោះ សត្វទាំងឡាយមានកិលេសក្រាស់ ហើយឱវាទដែលប្រទានដល់សត្វទាំងឡាយដែលមានកិលេសក្រាស់ មិននៅក្នុងឋានៈជាឱវាទ ព្រោះហេតុនោះ កាលនោះក៏មិនជាកាលសមគួរ ។ អាយុកាលយ៉ាងទាប ចាប់ពីមួយសែនឆ្នាំចុះមក អាយុកាលយ៉ាងខ្ពស់ ចាប់ពី ១០០ ឆ្នាំឡើងទៅ ឈ្មោះថា ជាកាលសមគួរ ។ ឥឡូវនេះ មនុស្សទាំងឡាយមានអាយុ ១០០ ឆ្នាំ ព្រោះហេតុនោះ កាលនោះ ព្រះពោធិសត្វទ្រង់ឃើញថា ជាកាលដែលគួរកើត ។

បន្ទាប់អំពីនោះ ទ្រង់ប្រមើលមើលទ្វីប ទ្រង់ឃើញទ្វីបថា ព្រះពុទ្ធទាំងឡាយ រមែងកើតក្នុងជម្ពូទ្វីបប៉ុណ្ណោះ ។ ធម្មតាជម្ពូទ្វីបជាទ្វីបធំ មានផ្ទៃប្រមាណមួយម៉ឺនយោជន៍ ។

កាលទ្រង់ប្រមើលមើលប្រទេសថា ព្រះពុទ្ធទាំងឡាយកើតក្នុងប្រទេសណាហ្ន៎ ក៏ទ្រង់ឃើញមជ្ឈិមបទេស ។

បន្ទាប់អំពីនោះ ទ្រង់ក៏ប្រមើលមើលត្រកូលថា ធម្មតាព្រះពុទ្ធទាំងឡាយ កើតក្នុងត្រកូលដែលសត្វលោកលើកតម្កើង ឥឡូវនេះ ត្រកូលក្សត្រជាត្រកូលដែលសត្វលោកលើកតម្កើង អាត្មាអញនឹងកើតក្នុងត្រកូលក្សត្រនោះ ព្រះរាជាព្រះនាមសុទ្ធោទនៈ នឹងជាព្រះជនករបស់អាត្មាអញ ។

បន្ទាប់អំពីនោះ ទ្រង់ប្រមើលមើលព្រះជននីថា ស្ត្រីអ្នកលេងសុរា ជា

ស្រីឡេះឡោះ ជាពុទ្ធមាតាមិនបាន នឹងត្រូវជាស្ត្រីមានសីល ៥ មិនដាច់ ដូច្នោះ ព្រះរាជទេវីព្រះនាមមាយានេះក៏ដូច្នេះ ព្រះនាងមហាមាយានេះ នឹងជាព្រះជននីរបស់អាត្មាអញ កាលទ្រង់គិតថា ព្រះនាងមានព្រះជន្មាយុប៉ុនណា ទ្រង់ឃើញថា រស់នៅបាន ៧ ថ្ងៃ បន្ទាប់អំពីគ្រប់ទសមាសហើយ ។

កាលទ្រង់ប្រមើលមើលមហាវិលោកនៈ ៥ ដូច្នេះហើយ ក៏ប្រទាននូវពាក្យប្តេជ្ញាដល់ទេវតាទាំងឡាយថា ជាកាលសមគួរដែលយើងនឹងជាព្រះពុទ្ធ ទ្រង់តាំងនៅក្នុងសន្តុសិតនោះអស់ព្រះជន្មាយុ ហើយចុតិចាកស្ថានតុសិតនោះ ទ្រង់បដិសន្ធិក្នុងផ្ទៃព្រះនាងមាយាទេវី ក្នុងរាជត្រកូលសក្យៈ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា

> កាលណា តថាគតច្យុតចាកពួកទេវតាជាន់តុសិត មកចាប់បដិសន្ធិក្នុងផ្ទៃ ( នៃមាតា ) កាលនោះ លោកធាតុមួយម៉ឺន និងព្រះធរណីញាប់ញ័រ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱក្កមិ** បានដល់ ឈានចុះចូលទៅ ។ បទថា **កុច្ឆិយំ** បានដល់ ក្នុងព្រះគភ៌របស់ព្រះពុទ្ធមាតា ។ បទថា **ទស សហស្សី លោកធាតុ កម្បិត្ថ** សេចក្តីថា ព្រះពោធិសត្វទ្រង់មានសតិសម្បជញ្ញៈ ឈានចុះកាន់ព្រះគភ៌របស់ព្រះពុទ្ធមាតា ទ្រង់បដិសន្ធិដោយនក្ខត្តឫក្ស ខែអាសាឍ្ហ ក្នុងតិថីពេញបូណ៌មី ដោយមហាវិបាកចិត្ត ដូចគ្នានឹងកុសលចិត្ត ជាអសង្ខារិក ដែលសហគតៈដោយសោមនស្ស សម្បយុត្តដោយញាណ មានមេត្តាជាបុព្វភាគ ក្នុងបណ្តាបដិសន្ធិចិត្ត ១៩ ដួង ។

កាលនោះ មុឺនលោកធាតុ ក៏កក្រើករំពើក ។ ធម្មជាតណា ទ្រទ្រង់ទុកនូវសភាវៈដែលមិនញាប់ញ័រ និងសភាវៈដែលឃ្លាតចាកទីទាំងអស់ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា ធរណី គឺផែនដី ។

ក្នុងបទថា **សម្បជានោវ និក្ខមិ** នេះ មានអធិប្បាយថា ក្នុងកាលណា តថាគតមានសតិសម្បជញ្ញៈ ឈរសណ្ដូកដៃ និងជើងទាំង ២ ចេញអំពីផ្ទៃរបស់ព្រះជននី ដូចព្រះធម្មកថិកចុះអំពីធម្មាសនៈ និងដូចបុរសចុះអំពីជណ្ដើរ ដែលរបស់មិនស្អាតណាមួយ ដែលជាសម្ភារក្នុងព្រះគភ៌ មិនប្រឡាក់ប្រឡូសឡើយ ។ បទថា **សាធុការំ បវត្តេន្តិ** បានដល់ ទេវតាទាំងឡាយញុំាំងសាធុការឲ្យប្រព្រឹត្តទៅ អធិប្បាយថា ថ្វាយសាធុការ ។ បទថា **បកម្បិត្ថ** បានដល់ ញាប់ញ័រ អធិប្បាយថា មុឺនលោកធាតុញាប់ញ័រទាំងខណៈយាងចុះកាន់ព្រះគភ៌ ទាំងខណៈប្រសូតចាកព្រះគភ៌ របស់ព្រះជននី ។

គ្រានោះ ព្រះមានព្រះភាគទ្រង់មិនឃើញបុគ្គលណាមួយ ដែលស្មើដូចព្រះអង្គក្នុងការយាងចុះកាន់ផ្ទៃជាដើមឡើយ ទើបត្រាស់គាថានេះថា **ឱក្កន្តិ មេ សមោ នត្ថិ** ជាដើម ក៏ដើម្បីសម្ដែងភាពអស្ចារ្យរបស់ព្រះអង្គ ក្នុងការយាងចុះកាន់ផ្ទៃជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឱក្កន្តិ** បានដល់ ក្នុងការយាងចុះកាន់ផ្ទៃ ។ ពាក្យនេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ អធិប្បាយថា ក្នុងបដិសន្ធិ ។ បទថា **មេ** កែជា **មយា**។ បទថា **សមោ** បានដល់ មិនមានបុគ្គលណា

ស្មើ ។ ក្នុងបទថា **ជាតិតោ** នេះ សេចក្តីថា ជនរមែងកើតអំពីមាតានេះ ហេតុនោះ ទើបមាតា លោកហៅថា **ជាតី** អធិប្បាយថា ចាកមាតាអ្នកឲ្យកំណើតនោះ ។ បទថា **អភិនិក្ខមេ** បានដល់ ក្នុងការយាងចេញ គឺហួរចេញចាកផ្ទៃរបស់ព្រះជននី ។

ក្នុងបទថា **សម្ពោធិយំ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ការត្រាស់ដឹងដ៏ល្អដែលលោកសរសើរហើយ ឈ្មោះសម្ពោធិ ។ **ពោធិ** សព្ទនេះប្រើក្នុងអត្ថទាំងឡាយ គឺដើមឈើ មគ្គ និព្វាន សព្វញ្ញុតញ្ញាណជាដើម ។

ពិតហើយ ដើមឈើ លោកហៅថា **ពោធិ** ដូចក្នុងប្រយោគជាដើមថា **ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ** បានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្ស និងបទថា **អន្តរា ច ពោធឹ អន្តរា ច គយំ** ក្នុងចន្លោះនៃគយាសីសប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង ។

**មគ្គ** ហៅថា **ពោធិ** បានក្នុងប្រយោគជាដើមថា **ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ** សម្មាទិដ្ឋិ ( ញាណ ) ក្នុងមគ្គ ៤ លោកហៅថា **ពោធិ** ។

**និព្វាន** ហៅថា **ពោធិ** ដូចក្នុងប្រយោគជាដើមថា **បត្វាន ពោធឹ អមតំ អសង្ខតំ** ព្រះមានព្រះភាគ ទ្រង់សម្រេចពោធិ ដែលជាអមតៈ មិនមានបច្ច័យតាក់តែង ។

**ព្រះសព្វញ្ញុតញ្ញាណ** ហៅថា **ពោធិ** ដូចក្នុងប្រយោគជាដើមថា **បប្បោតិ ពោធឹ វរភូរិ មេធសោ** តថាគតនោះ មានប្រាជ្ញាដ៏ប្រសើរ ប្រៀបដោយផែនដី និងបានដល់ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ មានចំណែកដ៏ប្រសើរក្នុង

ផ្លូវប្រាជ្ញា ។ តែក្នុងទីនេះ លោកបំណងយកអរហត្តមគ្គញ្ញាណ របស់ព្រះមានព្រះភាគ អាចារ្យពួកខ្លះពោលថា **សព្វញ្ញុតញ្ញាណ** ដូច្នេះក៏មាន អធិប្បាយថា តថាគតជាបុគ្គលប្រសើរបំផុត ក្នុងសព្វញ្ញុតញ្ញាណនោះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគអាស្រ័យសម្ពោធិញ្ញាណសរសើរព្រះអង្គឯង ឆ្លើយថា ព្រោះសម្ពោធិញ្ញាណឲ្យនូវគុណសព្វយ៉ាងពិតហើយ ការត្រាស់ដឹងព្រមរបស់ព្រះមានព្រះភាគ ឲ្យនូវគុណសព្វយ៉ាងរមែងឲ្យពុទ្ធគុណទាំងអស់មិនសេសសល់ឡើយ តែមិនឲ្យគុណដល់អ្នកដទៃបណ្ដាជនទាំងឡាយដទៃ អរហត្តមគ្គ រមែងឲ្យនូវអរហត្តផលប៉ុណ្ណោះដល់បុគ្គលខ្លះ ឲ្យវិជ្ជា ៣ ដល់បុគ្គលខ្លះ ឲ្យអភិញ្ញា ៦ ដល់បុគ្គលខ្លះ ឲ្យបដិសម្ភិទា ៤ ដល់បុគ្គលខ្លះ ឲ្យសាវកបារមីញាណដល់បុគ្គលខ្លះ ឲ្យបច្ចេកពោធិញ្ញាណប៉ុណ្ណោះ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយ តែឲ្យនូវគុណសម្បត្តិគ្រប់យ៉ាងដល់ព្រះពុទ្ធទាំងឡាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សរសើរព្រះអង្គឯងថា តថាគតជាបុគ្គលប្រសើរបំផុត ក្នុងការត្រាស់ដឹង ព្រោះសម្ពោធិញ្ញាណឲ្យនូវគុណសព្វយ៉ាង ។ ម្យ៉ាងទៀត ទ្រង់ធ្វើផែនដីឲ្យញាប់ញ័រហើយ ក៏ទ្រង់សម្រេចសម្ពោធិញ្ញាណ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា តថាគតជាបុគ្គលប្រសើរបំផុត ក្នុងការត្រាស់ដឹង ។ បទថា **ធម្មចក្កប្បវត្តនេ** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ធម្មចក្ក មាន ២ គឺបដិវេធញ្ញាណ ១ ទេសនាញ្ញាណ ១ ។ ក្នុងធម្មចក្ក ២ នោះ ធម្មចក្កដែលបញ្ញាអប់រំហើយ នាំមកនូវអរិយផលដល់ព្រះអង្គ ឈ្មោះ

ថា បដិវេធញ្ញាណ ។ ធម្មចក្កដែលករុណាអប់រំហើយ នាំមកនូវអរិយផល ដល់សាវកទាំងឡាយ ឈ្មោះថា ទេសនាញាណ ។ បដិវេធញ្ញាណ ជាលោកុត្តរកុសល សហគតៈដោយឧបេក្ខា មិនមានវិតក្ក មិនមានវិចារៈ ទេសនាញាណជាលោកិយ ជាអព្យាកតៈ ។ សូម្បីញាណទាំង ២ នោះ ក៏មិនទូទៅដល់អ្នកដទៃៗ តែក្នុងទីនេះ បំណងយកទេសនាញាណ ។

ឥឡូវនេះ ទេវតាទាំងឡាយ ស្ដាប់ការប្រព្រឹត្តទៅ មានផែនដីកម្រើកជាដើម ព្រោះការយាងចុះកាន់គភ៌របស់ព្រះមានព្រះភាគហើយ ក៏នាំគ្នាពោលគាថានេះថា **អហោ អច្ឆរិយំ លោកេ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ពុទ្ធានំ គុណមហន្តតា** សេចក្ដីថា ឱ ! ព្រះពុទ្ធទាំងឡាយ មានព្រះគុណច្រើន ឱ! ព្រះពុទ្ធទាំងឡាយ មានអានុភាពច្រើន ។

បទថា **ទសសហស្សី លោកធាតុ ឆប្បការំ បកម្បថ** សេចក្ដីថា មហាប្រឹថពីក្នុងម៉ឺនចក្កវាឡញាប់ញ័រដោយ ៦ អាការ គឺបះខាងមុខ ស្រុតខាងក្រោយ ស្រុតខាងក្រោយ បះខាងមុខ បះខាងឆ្វេង ស្រុតខាងស្ដាំ បះខាងស្ដាំ ស្រុតខាងឆ្វេង បះត្រង់កណ្ដាល ស្រុតដោយជុំវិញ បះដោយជុំវិញ ស្រុតត្រង់កណ្ដាល ។ មហាប្រឹថពីនេះ កម្រាស់ដល់ ២ សែន ៤ ម៉ឺនយោជន៍ មានទឹកទ្រផែនដីដោយជុំវិញ ដូចទូកដែលឃ្លោងព្រោះរលកនៃទឹកដែលញាប់ញ័រ ព្រោះកម្លាំងខ្យល់ សូម្បីមិនមានចិត្តក៏ដូចមានចិត្ត បានញាប់ញ័រដូចរាំដោយបីតិ ។ បទថា **ឱភាសោ ច មហា អាសិ** សេចក្ដីថា

មានពន្លឺកន្លងទេវានុភាពរបស់ទេវតាទាំងឡាយ ។ បទថា **អច្ឆេរំ លោមហំសនំ** សេចក្តីថា មានការអស្ចារ្យព្រឺរោមព្រឺស្បែក ។

ឥឡូវនេះ កាលសេចក្តីអស្ចារ្យទាំងឡាយ មានផែនដីកម្រើក និងប្រាកដពន្លឺជាដើម កំពុងប្រព្រឹត្តទៅ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលថា **ភគវា តម្ហិ សមយេ** ជាដើម ដើម្បីសម្តែងការប្រព្រឹត្តទៅ របស់ព្រះមានព្រះភាគ ។

បណ្តាបទទាំងនោះ បទថា **លោកជេដ្ឋោ** បានដល់ ជាបុគ្គលប្រសើរបំផុតក្នុងលោក ។ បទថា **សទេវកំ** បានដល់ នៃលោក ព្រមទាំងទេវលោក គប្បីឃើញថា ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថឆដ្ឋីវិភត្តិ ។ បទថា **ឧស្សយន្តោ** បានដល់ កាលទ្រង់សម្តែងបាដិហារ្យ ។

បទថា **ចង្កមន្តោ វ** សេចក្តីថា យាងចង្ក្រមក្នុងរតនចង្ក្រមនោះ ដែលតាំងជុំវិញម៉ឺនលោកធាតុត្រាស់ធម្មកថា ។ បទថា **លោកនាយកោ** សេចក្តីថា គ្រានោះ ព្រះសាស្តាត្រាស់ធម្មកថាដ៏ពីរោះ ដែលទ្រង់យាងមកដោយត្រៃលក្ខណ៍ ប្រកបដោយសច្ចៈ ៤ មានន័យវិចិត្រផ្សេងៗ ដោយព្រះសូរសៀងដូចព្រហ្ម គួរស្តាប់ គួរប្រាថ្នា ប្រកបដោយអង្គ ៨ ដូចរាជសីហ៍បន្លឺសីហនាទលើផ្ទាំងមនោសិលា ដូចផ្គរក្នុងរដូវភ្លៀងគំរាម និងហាក់ដូចអាកាសគង្គាធ្លាក់ចុះ ។

ក្នុងពាក្យថា **អន្តរា ន និវត្តេតិ ចតុហត្ថេ ចង្កមេ យថា** សេចក្តីថា ទីចង្ក្រមដែលព្រះសាស្តាទ្រង់និម្មិតនោះ ចុងម្ខាង នៅត្រង់កណ្តាប់ចក្កវាឡ

ទិសខាងកើត ចុងម្ខាង នៅត្រង់កណ្ដាប់ចក្កវាឡទិសខាងលិច ព្រះសាស្ដា ទ្រង់ចង្រ្កមក្នុងរតនចង្រ្កមនោះ ដែលតាំងនៅដូចពោលនេះ ទ្រង់យាងដល់ចុងទាំងសងខាង ទើបយាងត្រឡប់ បើមិនទាន់ដល់ចុងសងខាងទេ ទ្រង់មិនត្រឡប់ឡើយ អធិប្បាយថា ព្រះសាស្ដា កាលទ្រង់ចង្រ្កមក្នុងទីចង្រ្កមប្រមាណ ៤ ហត្ថ ដល់ចុងសងខាងរហ័ស ទើបទ្រង់យាងត្រឡប់ យ៉ាងណា ទ្រង់មិនយាងត្រឡប់ក្នុងរវាងយ៉ាងនោះទេ ។ សួរថា ហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់មិនបំព្រួមទីចង្រ្កម ដែលវែងប្រមាណមួយម៉ឺនយោជន៍ឲ្យខ្លី ឬ ទ្រង់និម្មិតអត្តភាពឲ្យធំ ឆ្លើយថា ទ្រង់មិនបានធ្វើយ៉ាងនោះ ពុទ្ធានុភាពនៃព្រះពុទ្ធទាំងឡាយជាអចិន្តេយ្យ មិនគួរគិត លោកធាតុមួយម៉ឺន ហាក់ដូចជាទីធ្លាតែមួយ រាប់តាំងអំពីអកនិដ្ឋកព រហូតដល់អវិចីនរក និងដោយទទឹង ម៉ឺនចក្កវាឡ ដូចជាទីធ្លាតែមួយ ។ ទេវតាទាំងឡាយ ឃើញមនុស្ស មនុស្សទាំងឡាយ ក៏ឃើញទេវតា ទេវតា និងមនុស្សទាំងអស់ ឃើញព្រះមានព្រះភាគទ្រង់ចង្រ្កមដោយប្រក្រតី ដោយប្រការណា ក៏ឃើញព្រះមានព្រះភាគកំពុងយាងចង្រ្កម ដោយប្រការនោះ ។ ព្រះមានព្រះភាគ កំពុងយាងចង្រ្កម ទ្រង់សម្ដែងធម៌ ទ្រង់ចូលសមាបត្តិក្នុងចន្លោះៗ ។ កាលនោះ ព្រះសារីបុត្តបានឃើញព្រះមានព្រះភាគ ដែលពួកទេវតាក្នុងម៉ឺនលោកធាតុចោមរោមហើយ យាងចង្រ្កមដោយពុទ្ធសិរីវិលាស គ្មានអ្វីប្រៀប ដោយពុទ្ធលីលាគ្មានអ្វីប្រដូច ដូចភ្នំមាសដ៏ប្រសើរកម្រើកចាកទីបាន មានពុទ្ធសរីរៈដ៏ប្រសើរ ល្អដោយព្រះវរលក្ខណៈ ៣២ ដែលកម្លាំងកុសល ដែលទ្រង់សាង

សន្សំមក អស់សម័យដែលប្រមាណមិនបាន រុងរឿងដោយអនុព្យញ្ជនៈ ៨០ មានព្រះសិរី ចោមរោមដោយព្រះរស្មីមួយព្យាម កម្ពស់ ១៨ ហត្ថ ដូចព្រះចន្ទពេញវង់ក្នុងសរទសម័យ និងដូចផ្កាបារិច្ឆត្តកៈ កម្ពស់ ១០០ យោជន៍ ចេញផ្ការីកស្គុះស្គាយពេញដើម ។ លុះឃើញហើយ ក៏ត្រិះរិះថា លោកធាតុមួយម៉ឺននេះ ប្រជុំគ្នាហើយត្រង់ទីប្រជុំនេះ គួរមានមហាទេសនា ឯពុទ្ធវង្សទេសនានឹងមានឧបការៈច្រើន នាំមកនូវការជ្រះថ្លា បើដូច្នោះ អញគប្បីទូលសួរពុទ្ធវង្ស ចាប់តាំងអំពីអភិនីហារ គឺការផ្ដើមបំពេញបារមីរបស់ព្រះទសពល ហើយធ្វើចីវរឆៀងស្មាម្ខាង ចូលគាល់ព្រះមានព្រះភាគ ផ្គងអញ្ជលីដ៏រុងរឿងដោយទសនខសមោធាន ( ប្រជុំម្រាម ១០ ) ដូចផ្កាឈូកក្រពុំកើតឡើងក្នុងទឹក មិនមានមន្ទិល មិនវិកល ដាក់លើសិរសាហើយ ទូលសួរព្រះមានព្រះភាគថា **កីទិសោ តេ មហាវីរ** ជាដើម ។ ដោយហេតុនោះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលពាក្យជាដើមថា

> ព្រះសារីបុត្រ មានប្រាជ្ញាច្រើន ឆ្លៀវឆ្លាសក្នុងសមាធិ និង
> ឈាន ជាអ្នកដល់នូវបារមីនៃប្រាជ្ញា បានក្រាបបង្គំទូលសួរ
> ព្រះលោកនាយក ដូច្នេះថា បពិត្រព្រះអង្គ មានព្យាយាមធំ
> ទ្រង់ប្រសើរជាងនរៈ អភិនីហាររបស់ព្រះអង្គ តើដូចម្ដេច
> បពិត្រព្រះអង្គ មានព្យាយាម ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ ព្រះអង្គ
> ប្រាថ្នាតាំងពីក្នុងកាលណា ដូច្នេះ ។

សួរថា អនុសន្ធិនេះឈ្មោះអ្វី ឆ្លើយថា ឈ្មោះថា បុច្ឆានុសន្ធិ ពិតហើយ

អនុសន្ធិមាន ៣ គឺបុច្ឆានុសន្ធិ អជ្ឈាសយានុសន្ធិ និងយថានុសន្ធិ ។ ក្នុងអនុសន្ធិទាំង ៣ នោះ គប្បីជ្រាបបុច្ឆានុសន្ធិដោយព្រះសូត្រដែលព្រះមានព្រះភាគទ្រង់ឆ្លើយបញ្ហារបស់អ្នកសួរ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) យ៉ាងនេះថា កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក៏ទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាត្រើយអាយ អ្វីជាត្រើយនាយ ដូច្នេះ ។

គប្បីជ្រាបអជ្ឈាសយានុសន្ធិ តាមដែលព្រះមានព្រះភាគ ទ្រង់ជ្រាបនូវអធ្យាស្រ័យរបស់អ្នកដទៃ ហើយត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) យ៉ាងនេះថា គ្រានោះ ភិក្ខុមួយរូប កើតបរិវិតក្កក្នុងចិត្តយ៉ាងនេះថា អើហ្ន៎ បានឮថា រូប ជាអនត្តា វេទនា ជាអនត្តា សញ្ញា ជាអនត្តា សង្ខារ ជាអនត្តា វិញ្ញាណ ជាអនត្តា កម្មដែលអនត្តាធ្វើហើយ នឹងពាល់ត្រូវនូវខ្លួនដូចម្តេចបាន ដូច្នេះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបបរិវិតក្កនៃចិត្តរបស់ភិក្ខុរូបនោះដោយព្រះហឫទ័យ ក៏ទ្រង់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការណ៍នុ៎ះ រមែងមានពិត គឺត្រង់ដែលមោឃបុរសខ្លះ ក្នុងលោកនេះ ជាអ្នកមិនដឹង ប្រកបដោយអវិជ្ជា សម្គាល់នូវសាសនារបស់ព្រះសាស្តាថា ជាពាក្យគួរប្រព្រឹត្តកន្លងដោយចិត្ត ដែលមានតណ្ហាជាធំថា អើហ្ន៎ បានឮថា រូប ជាអនត្តា វេទនា ជាអនត្តា សញ្ញា ជាអនត្តា សង្ខារ ជាអនត្តា វិញ្ញាណ ជាអនត្តា កម្មដែលអនត្តាធ្វើហើយ នឹងពាល់ត្រូវនូវខ្លួនដូចម្តេចបាន ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នក

ទាំងឡាយ សម្គាល់នូវហេតុនោះដូចម្តេច រូប ទៀង ឬមិនទៀងទេ ដូច្នេះ ។

ម្យ៉ាងទៀត ទេសនាខាងដើម តាំងឡើងដោយធម៌ណា ទេសនាជាន់ខ្ពស់មកក្នុងព្រះសូត្រទាំងឡាយណា ដោយជាធម៌សមគួរដល់ធម៌នោះ ឬដោយជំទាស់ គប្បីជ្រាបយថានុសន្ធិដោយអំណាចព្រះសូត្រទាំងនោះ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា ជាបុច្ឆានុសន្ធិ ។

បណ្តាបទទាំងនោះ បទថា **បញ្ញាយ ចារមិប្បត្តោ** សេចក្តីថា ដល់នូវទីបំផុតនៃសាវកបារមីញាណ ។ បទថា **បុច្ឆតិ** បានដល់ បានសួរហើយ ។ ក្នុងពាក្យថា **បុច្ឆតិ** នោះ ឈ្មោះថា **បុច្ឆា** មាន ៥ យ៉ាង គឺអទិដ្ឋជោតនាបុច្ឆា ទិដ្ឋសំសន្ទនាបុច្ឆា វិមតិច្ឆេទនាបុច្ឆា អនុមតិបុច្ឆា និងកថេតុកម្យតាបុច្ឆា ។ បើសួរថា ក្នុងបុច្ឆាទាំងនោះ បុច្ឆារបស់ព្រះថេរៈនេះ ជាបុច្ឆាអ្វី ឆ្លើយថា ព្រោះពុទ្ធវង្សនេះ មិនមែនវិស័យនៃព្រះបច្ចេកពុទ្ធទាំងឡាយ ដែលសន្សំបុញ្ញសម្ភារមកពីរអសង្ខេយ្យ និងមួយសែនកប្ប និងរបស់អគ្គសាវកទាំង ២ ដែលសន្សំបុញ្ញាធិការមកអស់មួយអសង្ខេយ្យ និងមួយសែនកប្ប ឬរបស់មហាសាវកដ៏សេស ដែលសន្សំបុញ្ញាធិការមកមួយសែនកប្ប ជាវិស័យនៃព្រះសព្វញ្ញុពុទ្ធទាំងឡាយប៉ុណ្ណោះ ព្រោះហេតុនោះ ទើបបុច្ឆារបស់ព្រះថេរៈ គប្បីជ្រាបថា ជាអទិដ្ឋជោតនាបុច្ឆា ។

សព្ទថា **កីទិសោ** ជាអាការសួរ អធិប្បាយថា មានប្រការដូចម្តេច ។ បទថា **តេ** កែជា **តវ** ( របស់ព្រះអង្គ ) ។ បទថា **អភិនីហារោ** សេចក្តីថា ការបងចិត្តដើម្បីជាព្រះពុទ្ធ ហើយផ្តោតចិត្តអធិដ្ឋានសេចក្តីព្យាយាមថា

អញមិនបានពាក្យព្យាករបស់ព្រះពុទ្ធ នឹងមិនក្រោកឡើង ដូច្នេះ ឈ្មោះថា **អភិនីហារ** ។ ដោយហេតុនោះ ទើបព្រះសារីបុត្តពោលថា បពិត្រព្រះអង្គមានព្យាយាម ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ ព្រះអង្គប្រាថ្នាតាំងពីកាលណា ។

បទថា **កម្ហិ កាលេ** បានដល់ ក្នុងកាលណា ។ បទថា **បត្ថិតា** បានដល់ ប្រាថ្នាហើយ បំណងហើយ ។ ព្រះថេរៈទូលសួរថា ទ្រង់ធ្វើការតាំងសេចក្តីប្រាថ្នាជាព្រះពុទ្ធក្នុងកាលណា ដោយន័យជាដើមថា អាត្មាអញ បានជាព្រះពុទ្ធហើយ គប្បីញុំាំងពួកសត្វឲ្យត្រាស់ដឹង អាត្មាអញ រួចផុតហើយ គប្បីញុំាំងពួកសត្វឲ្យរួចផុត ។ បទថា **ពោធិ** បានដល់ សម្មាសម្ពោធិញ្ញាណ ពាក្យនេះ ជាឈ្មោះរបស់អរហត្តមគ្គញ្ញាណ និងសព្វញ្ញុតញ្ញាណ ។ បទថា **ឧត្តមា** លោកពោលថា **ឧត្តម** ព្រោះប្រសើរជាងសាវកពោធិ និងបច្ចេកពោធិ ។ **ម** អក្ខរៈ ធ្វើបទសន្ធិ រវាងសព្ទទាំង ២ ។

ឥឡូវនេះ ព្រះថេរៈកាលទូលសួរដល់ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ ក៏ពោលថា

ទាន សីល នេក្ខម្មៈ បញ្ញា និងវីរិយៈ តើដូចម្តេច ខន្តិ
សច្ចៈ និងអធិដ្ឋាន មេត្តា និងឧបេក្ខា តើដូចម្តេច ។ បពិត្រ
ព្រះអង្គមានព្យាយាមធំ ជាលោកនាយក បារមី ១០ តើដូច
ម្តេច ឧបបារមី ១០ ដែលបរិបូណ៌ តើដូចម្តេច បរមត្ថបារមី
១០ ដែលបរិបូណ៌ តើដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ នឹងពោលទានបារមីមុន កិរិយាបរិច្ចាគវត្ថុខាងក្រៅ

ឈ្មោះថា **ទានមី** កិរិយាបរិច្ចាគអវយវៈ ឈ្មោះថា **ឧបទានមី** កិរិយាបរិច្ចាគជីវិត ឈ្មោះថា **បរមត្ថទានមី ។** ក្នុងបារមីដ៏សេសក៏ន័យនេះដូចគ្នា ។ បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ រួមជាបារមី ៣០ គត់ ដោយប្រការដូច្នេះ ។ ក្នុងបារមី ៣០ នោះ អត្ថភាពដែលព្រះពោធិសត្វ បំពេញទានបារមីក៏រាប់មិនអស់ ក្នុងសសបណ្ឌិតជាតក ទានបារមីរបស់ព្រះពោធិសត្វនោះ ដែលធ្វើការលះបង់ជីវិតជាបរហិតប្រយោជន៍យ៉ាងនេះថា

តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួន
ជារបស់ខ្លួន បុគ្គលអ្នកឲ្យទានស្មើដោយទានរបស់តថាគត
មិនមានឡើយ នេះជាទានបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

អត្តភាពដែលព្រះពោធិសត្វ បំពេញសីលបារមី ក៏រាប់មិនអស់ដូចគ្នា ក្នុងសង្ខបាលជាតក សីលបារមីរបស់ព្រះពោធិសត្វនោះ ដែលធ្វើនូវការលះបង់ខ្លួនយ៉ាងនេះថា

( ប៉ុន្តែ ) តថាគតមិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែល
ចោះដោយដែកស្រួច នឹងចាក់ដោយលំពែងទាំងឡាយឡើយ
នេះជាសីលបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរត្ថបារមីដោយចំណែកមួយដូចគ្នា ។

អត្តភាពដែលព្រះពោធិសត្វ លះរាជសម្បត្តិធំ បំពេញនេក្ខម្មបារមីក៏រាប់មិនអស់ដូចគ្នា ក្នុងចូឡសុត្តសោមជាតក នេក្ខម្មបារមីរបស់ព្រះ

ពោធិសត្វនោះ ដែលលះរាជសម្បត្តិ ព្រោះមិនមានការជាប់ជំពាក់ ទ្រង់ចេញបួស យ៉ាងនេះថា

តថាគតលះរាជសម្បត្តិធំ ដែលនៅក្នុងកណ្តាប់ដៃ ដូចដុំទឹកមាត់ តថាគតលះបង់ដោយមិនជាប់ជំពាក់ឡើយ នេះជានេក្ខម្មបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

អត្ថភាពដែលព្រះពោធិសត្វ បំពេញបញ្ញាបារមី ក្នុងកាលជាមហោសថបណ្ឌិតជាដើម ក៏រាប់មិនអស់ដូចគ្នា ។ កាលនៅជាសត្តុភត្តកបណ្ឌិត បញ្ញាបារមីរបស់ព្រះពោធិសត្វនោះ ដែលបង្ហាញពស់ក្នុងថៃស្បៀកថា

តថាគតកាលពិនិត្យពិច័យដោយបញ្ញា ក៏ដោះនូវទុក្ខរបស់ព្រាហ្មណ៍បាន បុគ្គលស្មើដោយតថាគតដោយបញ្ញា មិនមាន នេះជាបញ្ញាបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

អត្ថភាពព្រះពោធិសត្វ ដែលបំពេញវីរិយបារមី ក៏រាប់អស់ដូចគ្នា ក្នុងមហាជនកជាតក វីរិយបារមីរបស់ព្រះពោធិសត្វនោះ ដែលឆ្លងមហាសមុទ្រយ៉ាងនេះថា

តថាគតមើលមិនឃើញត្រើយ កណ្តាលសមុទ្រជ្រៅ មនុស្សទាំងឡាយ ត្រូវភ័យកម្ចាត់ហើយ ចិត្តរបស់តថាគត ក៏មិនប្រែប្រួល នេះជាវីរិយបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមីដោយចំណែកមួយ ។

ក្នុងខន្តិវាទីជាតកក៏ដូចគ្នា ខន្តិបារមីរបស់ព្រះពោធិសត្វ ដែលអត់ធន់ក្នុងមហាទុក្ខ ហាក់បីដូចមិនមានចិត្តយ៉ាងនេះថា

ព្រះបាទកាសី ទ្រង់យកពូថៅដ៏មុត កាប់តថាគត ដែលហាក់ដូចជាបុគ្គលមិនមានចិត្ត តថាគតក៏មិនខឹងក្រោធ នេះជាខន្តិបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមី ។

ក្នុងមហាសុត្តសោមជាតកក៏ដូចគ្នា សច្ចបារមីរបស់ព្រះពោធិសត្វ ដែលលះបង់ជីវិត រក្សាសច្ចៈយ៉ាងនេះថា

តថាគត កាលតាមរក្សាសច្ចវាចា ក៏ព្រមលះបង់ជីវិតរបស់ខ្លួន ដោះនូវទុក្ខស្តេច ១០១ អង្គ នេះជាសច្ចបារមីរបស់តថាគត ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមី ។

ក្នុងមូគបក្ខជាតក ( តេមិយជាតក ) ក៏ដូចគ្នា អធិដ្ឋានបារមីរបស់ព្រះពោធិសត្វ ដែលព្រមលះបង់ជីវិត អធិដ្ឋានវត្តយ៉ាងនេះថា

មាតាបិតា មិនជាទីស្អប់ខ្ពើមរបស់តថាគត ខ្លួនក៏មិនជាទីស្អប់ខ្ពើមរបស់តថាគត សព្វញ្ញុតញ្ញាណជាទីស្រឡាញ់ក្រៃលែងរបស់តថាគត ព្រោះហេតុនោះ ទើបតថាគត អធិដ្ឋានវត្តដូច្នេះ ។

ឈ្មោះថា បរមត្ថបារមី ។

ក្នុងសុវណ្ណសាមជាតកក៏ដូចគ្នា មេត្តាបារមីរបស់ព្រះពោធិសត្វ ដែលមិនអាល័យសូម្បីតែជីវិត ប្រព្រឹត្តមេត្តាយ៉ាងនេះថា

បុគ្គលណាមួយ ធ្វើតថាគតឲ្យតក់ស្លុតមិនបាន តថាគតក៏មិន
ខ្លាចចំពោះបុគ្គលណា តថាគតកាលកម្លាំងមេត្តាឧបការៈ
ហើយ ទើបត្រេកអរនៅក្នុងព្រៃធំ ក្នុងគ្រានោះ ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមី ។

ក្នុងលោមហំសជាតកក៏ដូចគ្នា ឧបេក្ខាបារមីរបស់ព្រះពោធិសត្វ កាលក្មេងអ្នកស្រុកទាំងឡាយធ្វើឲ្យកើតសេចក្តីសុខ និងសេចក្តីទុក្ខ ដោយការស្តោះទឹកមាត់ដាក់ និងដោយការបូជាដោយកម្រងផ្កា និងគ្រឿងក្រអូបជាដើម ក៏មិនប្រព្រឹត្តកន្លងឧបេក្ខាយ៉ាងនេះថា

តថាគតដាក់គ្រោងឆ្អឹងទុកហើយ ដេកកើយក្នុងព្រៃស្មសាន
ពួកក្មេងអ្នកស្រុកចូលទៅរកហើយ សម្តែងអាការប្លែកៗ
មិនមែនតិច ដូច្នេះ ។

ឈ្មោះថា បរមត្ថបារមី ។

សេចក្តីសង្ខេបក្នុងសេចក្តីនេះមានប្រមាណប៉ុណ្ណេះ ឯសេចក្តីពិស្តារគប្បីកាន់យកចាកគម្ពីរចរិយាបិដក ។

ឥឡូវនេះ ព្រះសង្គីតិកាចារ្យទាំងឡាយ កាលសម្តែងពាក្យព្យាករនៃព្រះមានព្រះភាគ ដែលព្រះថេរៈទូលសួរហើយ ទើបពោលថា

ព្រះពុទ្ធទ្រង់មានព្រះសូរសៀងពីរោះ ដូចជាសត្វករវិក ទ្រង់ញុំាងហឫទ័យ ( នៃពួកសត្វ ) ឲ្យរលត់ ញុំាងមនុស្សលោកព្រមទាំងទេវលោក ឲ្យស្រស់ស្រាយ ដែលព្រះសារីបុត្តសាកសួរហើយ ទ្រង់ដោះស្រាយដល់ព្រះសារីបុត្តនោះវិញ ។ ព្រះសម្ពុទ្ធទ្រង់ប្រកាសនូវរឿង ដែលព្រះជិនស្រីជាអតីតពុទ្ធទាំងឡាយ ទ្រង់សម្តែងចងទុកហើយ ដែលជាប់តមកតាំងពីព្រះពុទ្ធទីបង្ករ ជាប្រយោជន៍ក្នុងលោក ព្រមទាំងទេវលោក ដោយប្រាជ្ញាដែលប្រព្រឹត្តទៅតាមបុព្វេនិវាស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តស្ស បុដ្ឋោ វិយាកាសិ** សេចក្ដីថា ព្រះសាស្ដាកាលព្រះធម្មសេនាបតីទូលសួរហើយ ទ្រង់ក៏ព្យាករដល់លោក គឺត្រាស់ពុទ្ធវង្សទាំងអស់ តាំងអំពីអភិនីហាររបស់ព្រះអង្គ មានការត្រាស់ដឹងជាទីបំផុត ។ បទថា **ករវីកមធុរគិរោ** សេចក្ដីថា សំឡេងរបស់បុគ្គលណាពីរោះ ដូចសំឡេងរបស់សត្វករវិក បុគ្គលនោះ ឈ្មោះថា **ករវីក-មធុរគិរ** អធិប្បាយថា មានសំឡេងពីរោះរណ្ដំដូចសត្វករវិក ក្នុងសេចក្ដីនេះ សូមពោលដូច្នេះថា សត្វករវិកទាំងឡាយ មានសំឡេងពីរោះ បានឮថា សត្វករវិកទាំងឡាយ យកចំពុះចឹកផ្លែស្វាយទុំ ដែលមានរសផ្អែម បឺតទឹកផ្លែស្វាយដែលហូរចេញមក យកស្លាបទទះ ធ្វើជាចង្វាក់ ស្រែកយំល្ហើយៗដូចអោយសត្វជើងបួនស្រវឹងក្នុងសំឡេងច្រៀង ។ ហ្វូងសត្វចតុប្បាទសូម្បីត្រេកអរដោយការបរិភោគចំណី ក៏ទម្លាក់ស្មៅចោល ហារមាត់ហើយ

ស្តាប់សំឡេងដ៏ពីរោះនោះ ។ សត្វសាហាវទាំងឡាយ កំពុងដេញតាមម្រឹគតូចៗ ក៏មិនដាក់ជើងដែលលើកឡើង ឈរដូចរូបយន្ត សូម្បីម្រឹគដែលត្រូវដេញ ក៏លែងខ្លាចស្លាប់ ឈរនៅមួយកន្លែង សូម្បីសត្វបក្សីដែលកំពុងហើរក្នុងអាកាស ក៏សំកាំងស្លាប ហ្វូងត្រីក្នុងទឹក ក៏មិនកម្រើកស្រកី ឈប់មួយកន្លែង ស្តាប់សំឡេងនោះ សត្វករវិកមានសំឡេងពីរោះយ៉ាងនេះ ។ បទថា **និព្វាបយន្តោ ហទយំ** សេចក្តីថា ញុំាងចិត្តរបស់ជនគ្រប់គ្នា ដែលក្តៅក្រហាយដោយភ្លើងកិលេស ឲ្យកើតនូវការត្រជាក់ដោយធម្មកថា ដូចអមតធារា ។ បទថា **ហាសយន្តោ** បានដល់ ឲ្យត្រេកអរ ។ បទថា **សទេវកំ** បានដល់ សត្វលោក ព្រមទាំងទេវលោក ។

បទថា **អតីតពុទ្ធានំ** បានដល់ ដែលព្រះពុទ្ធទាំងឡាយក្នុងអតីតកាល ។ មុនអភិនីហាររបស់ព្រះមានព្រះភាគនៃយើង ក្នុងកប្ប ១ មានព្រះពុទ្ធ ៤ អង្គ គឺព្រះពុទ្ធតណ្ហង្ករ ព្រះពុទ្ធមេធង្ករ ព្រះពុទ្ធសរណង្ករ ព្រះពុទ្ធទីបង្ករ ។ តមកខាងក្រោយព្រះពុទ្ធ ៤ ព្រះអង្គនោះ មានព្រះពុទ្ធ ២៣ ព្រះអង្គ មានព្រះកោណ្ឌញ្ញៈជាដើម ដូច្នោះ ត្រូវជាព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះពុទ្ធព្រះនាមទីបង្ករជាដើមគ្រប់អង្គ លោកបំណងថាជាអតីតពុទ្ធក្នុងទីនេះ ។ របស់អតីតពុទ្ធទាំងនោះ ។ បទថា **ជិនានំ** ជាវេវចនៈនៃបទថា **អតីត ពុទ្ធានំ** នោះឯង ។ បទថា **ទេសិតំ** បានដល់ ត្រាស់ហើយ គឺធម្មកថាដែលប្រកបដោយសច្ចៈ ៤ របស់ព្រះពុទ្ធ ២៤ ព្រះអង្គ ។ បទថា **និកីលិតំ** បានដល់ ចរិយារបស់ព្រះពុទ្ធទាំងនោះ ។ គោលដែលកំណត់

ដោយកប្ប ជាតិ គោត្រ អាយុ ដើមពោធិ៍ សាវកសន្និបាត ឧបដ្ឋាក មាតា បិតា បុត្ត កិរិយាជាដើម ឈ្មោះថា **និក្ខិត្ត** ( ប្រវត្តិ ) ។ បទថា **ពុទ្ធបរម្បរាគតំ** សេចក្ដីថា ទេសនា ឬចរិយា ដែលចាប់តាំងអំពីព្រះទសពលព្រះនាមទីបង្ករ បន្តគ្នាមករហូតដល់ព្រះកស្សបសម្ពុទ្ធ ។ បទថា **បុព្វេ និវាសានុគតាយ ពុទ្ធិយា** សេចក្ដីថា ការដឹងដល់ខន្ធដែលអាស្រ័យនៅក្នុងកាលមុន ពោល គឺខន្ធសន្តានដែលនៅអាស្រ័យក្នុងកាលមុន ដែលចែកយ៉ាងនេះថា ១ ជាតិខ្លះ ២ ជាតិខ្លះជាដើម ។ ដោយការដឹងខន្ធ ដែលអាស្រ័យនៅក្នុងកាលមុន គឺដោយបុព្វេនិវាសានុស្សតិញ្ញាណ ។ បទថា **បកាសយី** បានដល់ ទ្រង់ព្យាករ ។ បទថា **លោកហិតំ** បានដល់ ពុទ្ធវង្សដែលជាប្រយោជន៍ដល់លោកទាំងមូល ។ បទថា **សទេវកេ** បានដល់ ក្នុងសត្វលោក ព្រមទាំងទេវលោក ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ទូន្មានសត្វលោក ព្រមទាំងទេវលោក ក្នុងការស្ដាប់ ដោយព្រះហឫទ័យដ៏ត្រជាក់ ដោយករុណា ទើបត្រាស់ថា **បីតិចាមោជ្ជជននំ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **បីតិចាមោជ្ជជននំ** បានដល់ ដែលធ្វើបីតិ និងបាមោជ្ជ គឺបាមោជ្ជដែលជាផ្នែកខាងដើមនៃបីតិ អធិប្បាយថា ញុំាងបីតិ ៥ ឲ្យកើត ។ បទថា **សោកសល្លវិនោទនំ** បានដល់ បន្ទោបង់នូវកូនសរទាំងឡាយ ដែលហៅថា សោក ។ បទថា **សព្វសម្បត្តិបដិលាភំ** សេចក្ដីថា ជនទាំងឡាយ រមែងបាននូវសម្បត្តិគ្រប់យ៉ាង មានទេវសម្បត្តិ និងមនុស្សសម្បត្តិជាដើម ដោយពុទ្ធវង្ស

នេះ ហេតុនោះ ទើបពុទ្ធវង្សនេះ ឈ្មោះថា ជាហេតុឲ្យបាននូវសម្បត្តិគ្រប់យ៉ាង អធិប្បាយថា ពុទ្ធវង្សទេសនា ជាហេតុឲ្យបាននូវសម្បត្តិគ្រប់យ៉ាងនោះ ។ បទថា **ចិត្តីកត្វា** បានដល់ ធ្វើទុកក្នុងចិត្ត អធិប្បាយថា ធ្វើពុទ្ធានុស្សតិទុកខាងមុខ ។ បទថា **សុណាថ** បានដល់ ចូរតាំងចិត្តស្តាប់ ចូរក្រាក់ ។ បទថា **មេ** កែជា **មម** ( របស់ខ្ញុំ ) ។

បទថា **មទនិម្មទនំ** បានដល់ ធ្វើនូវការបន្ទោបង់នូវសេចក្តីស្រវឹងគ្រប់យ៉ាង មានស្រវឹងក្នុងជាតិជាដើម ។ បទថា **សោកនុទំ** សេចក្តីថា ការក្តៅក្រហាយនៃចិត្តរបស់បុគ្គល ដែលត្រូវសេចក្តីវិនាសនៃញាតិជាដើមប៉ះខ្ទប់ហើយ ឈ្មោះថា សោក ដោយអត្ថ ក៏ជាទោមនស្សនោះឯង តែសេចក្តីសោក មានការដុតខាងក្នុងជាលក្ខណៈ មានការស្ងិតស្រពោននៃចិត្តជាកិច្ច មានការស្ងុបស្ងៅជាអាការប្រាកដ ។ ពុទ្ធវង្សរមែងបន្ទោបង់នូវសេចក្តីសោកនោះ ហេតុនោះ ទើបពុទ្ធវង្ស ឈ្មោះថា បន្ទោបង់នូវសេចក្តីសោក ។ នូវពុទ្ធវង្សដែលបន្ទោបង់នូវសោកនោះ ។ បទថា **សំសារបរិមោចនំ** បានដល់ ធ្វើនូវការដោះចាកចំណង គឺសង្សារ ។ បាឋៈថា **សំសារ សមតិក្កមំ** ( កន្លងបង់នូវសង្សារ ) ដូច្នេះក៏មាន សេចក្តីនៃបាឋៈនោះថា ធ្វើនូវការឈានកន្លងសង្សារ ។

**ទុក្ខ** សព្ទ ក្នុងបទថា **សព្វទុក្ខក្ខយំ** នេះ ប្រើក្នុងអត្ថទាំងឡាយ មានទុក្ខវេទនា ទុក្ខវត្ថុ ទុក្ខារម្មណ៍ ទុក្ខប្បច្ច័យ ទុក្ខដ្ឋានជាដើម ។ ពិតហើយ **ទុក្ខ** សព្ទ ដែលប្រើក្នុងអត្ថថា ទុក្ខវេទនា ដូចក្នុងប្រយោគជាដើមថា **ទុក្ខស្ស**

**ច បហានា** លះបង់ទុក្ខផង ដូច្នេះ ។ ប្រើក្នុងអត្ថថា **ទុក្ខវត្ថុ** គឺជាទីតាំងនៃទុក្ខ ដូចក្នុងប្រយោគជាដើមថា **ជាតិបិ ទុក្ខា ជរាបិ ទុក្ខា** គឺកំណើតជាកងទុក្ខ ១ សេចក្ដីចាស់គ្រាំគ្រាជាកងទុក្ខ ១ ដូច្នេះ ។ ប្រើក្នុងអត្ថថា **ទុក្ខារម្មណ៍** ដូចក្នុងប្រយោគជាដើមថា **យស្មា ច ខោ មហាលិ រូបំ ទុក្ខំ ទុក្ខានុបតិតំ ទុក្ខាវក្កន្តំ** ម្នាលមហាលិ រូបនេះ មានទុក្ខតែម្យ៉ាង មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ ដូច្នេះ ។ ប្រើក្នុងអត្ថថា **ទុក្ខប្បច្ច័យ** ដូចក្នុងប្រយោគជាដើមថា **ទុក្ខោ បាបស្ស ឧច្ចយោ** ការសន្សំបាប តែងនាំសេចក្ដីទុក្ខមកឲ្យ ដូច្នេះ ។ ប្រើក្នុងអត្ថថា **ទុក្ខដ្ឋាន** ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងរៀបរាប់អំពីនរក ដោយអនេកបរិយាយទៅក៏បាន ។ ម្នាលភិក្ខុទាំងឡាយ តែដំណើរដែលតថាគតពោលទៅ មិនងាយនឹងដល់កម្រិតនរកដែលមានទុក្ខបានឡើយ ដូច្នេះ ។

តែក្នុងទីនេះ **ទុក្ខ** សព្ទនេះ គប្បីឃើញថា ប្រើក្នុងអត្ថទុក្ខវត្ថុក៏មាន ក្នុងអត្ថថា ទុក្ខប្បច្ច័យក៏មាន ។ ព្រោះហេតុនោះ ទើបមានសេចក្ដីថា ដែលធ្វើនូវការអស់ទុក្ខទាំងពួង មានជាតិជាដើម ។ គប្បីជ្រាបអធិប្បាយក្នុងបទថា **មគ្គំ** នេះដូចតទៅ ពុទ្ធវង្សទេសនា ហៅថា **មគ្គ** ព្រោះបុគ្គលត្រូវការកុសល ស្វែងរក ឬសម្លាប់កិលេសទាំងឡាយ ។ នូវពុទ្ធវង្សទេសនា ដែលជាផ្លូវនៃនិព្វាននោះ ។ បទថា **សក្កច្ចំ** បានដល់ គោរព ធ្វើនូវការកោតក្រែង អធិប្បាយថា ជាអ្នកតាំងចិត្តស្ដាប់ពុទ្ធវង្សទេសនានោះ ។ បទថា **បដិបជ្ជថ** បានដល់ ចូរតាំងចិត្តក្រៃលែង អធិប្បាយថា ចូរស្ដាប់ ម្យ៉ាងទៀត ព្រះមាន

ព្រះភាគ ញ៉ាំងនូវឧស្សាហ៍ តាំងនូវសេចក្តីប្រាថ្នាភាពជាព្រះពុទ្ធឲ្យកើតដល់ទេវតា និងមនុស្សទាំងពួងថា អ្នកទាំងឡាយ ចូរតាំងចិត្តប្រុងស្តាប់ ( ពុទ្ធវង្សទេសនា ) របស់តថាគត ជាគ្រឿងញ៉ាំងបីតិ និងបាមោជ្ជឲ្យកើត បន្ទោបង់នូវសរ គឺសេចក្តីសោកបាន ជាហេតុបាននូវសម្បត្តិទាំងពួង ។ អ្នកទាំងឡាយ ចូរប្រតិបត្តិនូវមគ្គ ជាគ្រឿងញ៉ាំញីនូវសេចក្តីស្រវឹងជាដើម ។ ពាក្យដ៏សេស ក្នុងសេចក្តីនេះ ងាយយល់ហើយ ។

**អដ្ឋកថារតនចង្កមនកណ្ឌ ចប់**

**អព្ភន្តរនិទាន ចប់**

**និទានកថា ចប់**

# សុត្តន្តបិដក

## ទីបង្ករពុទ្ធវង្សទី ១

[ ២ ] ក្នុង ៤ អសង្ខេយ្យ និងមួយសែនកប្ប មាននគរឈ្មោះ អមរវតី ជានគរគួរពិតពិលរមិលមើល ជាទីរីករាយនៃចិត្ត ជានគរបរិបូណ៌ដោយបាយ និងទឹក ទាំងមិនស្ងាត់ដោយមានសំឡេង ១០ យ៉ាង គឺសំឡេងដំរី សំឡេងសេះ សំឡេងស្គរ សំឡេងស័ង្ខ និងសំឡេងរថជាដើម ។ ទាំងជានគរគឹកកងដោយសំឡេងដែលប្រកបដោយបាយ និងទឹកថា ចូរស៊ី ចូរផឹក ជានគរសម្បូរដោយសត្វ និងគ្រឿងឧបករណ៍ទាំងពួង បរិបូណ៌ដោយការងារគ្រប់យ៉ាង ។ បរិបូណ៌ដោយកែវ ៧ ប្រការ កុះករដោយជនជាតិផ្សេងៗ សម្រេច ( ដោយគ្រឿងបរិភោគ និងឧបភោគទាំងពួង ) ដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នកមានបុណ្យទាំងឡាយ ។ វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ។ ជាអ្នករៀនមន្ត្រ ចងចាំនូវមន្ត្រ ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមីក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ។ កាលនោះ តថាគតនៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយសរីរៈ ក៏នាំមកនូវសេចក្តីទុក្ខដូចគ្នា ( សេចក្តីស្លាប់ប្រកបដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមក

នូវទុក្ខ ) អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញ នឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ។ បើដូច្នោះ អាត្មាអញគួរតែលះកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ហើយនឹងចេញទៅ ។ ផ្លូវនោះនឹងមានពិត ផ្លូវនោះ មិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញនឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ។ កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមាន ការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នាក៏មាន យ៉ាងនោះដែរ ។ កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើជាតិមាន ព្រះនិព្វានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នា ក៏មានយ៉ាងនោះដែរ ។ បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹកហើយ មិនស្វែងរកស្រះ ទោសនោះ មិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វានមានហើយ បុគ្គលមិនស្វែងរកស្រះសម្រាប់លាងនូវកិលេស ជាមន្ទិលចេញទេ ទោសនោះមិនមែនជាទោសនៃស្រះ គឺនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ ។ បុរសដែលត្រូវសត្រូវទាំងឡាយចោមព័ទ្ធហើយ

កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះមិនរត់ទៅ ទោស នោះ មិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវកិលេស រួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោសនៃផ្លូវនិព្វានទេ គឺជាទោសរបស់ បុគ្គលនោះឯង យ៉ាងនោះដែរ ។ បុរសដែល មានជំងឺ កាលបើពេទ្យមាន តែមិនឲ្យពេទ្យនោះព្យាបាលជំងឺនោះ ទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ យ៉ាងណា បុគ្គល ត្រូវជំងឺ គឺកិលេសទាំងឡាយបៀតបៀនហើយ ដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះ មិនមែនជាទោសនៃអាចារ្យ ទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ ។ ( បើ ដូច្នោះ ) គួរតែអាត្មាអញលះបង់កាយស្អុយនេះ ដែលពេញ ដោយសាកសពផ្សេងៗ ចេញ គប្បីជាអ្នកមិនមានសេចក្តី អាឡោះអាល័យ មិនមានសេចក្តីត្រូវការរូប ហើយចេញទៅ ។ បុរសបានស្រាយសាកសពដ៏គួរខ្ពើមរអើម ដែលជាប់ពួដ៏ក គប្បី ជាអ្នកមានសេចក្តីសុខ នៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែល ជាទីប្រមូលមកនូវសាកសពផ្សេងៗ ចេញ ហើយគប្បីជាអ្នកមិន អាឡោះអាល័យ មិនមានសេចក្តីត្រូវការចេញទៅ យ៉ាងនោះដែរ ។ បុរសស្ត្រីទាំងឡាយ ទៅបន្ទោបង់នូវករីសក្នុងបង្គន់ហើយ ឥត

មានអាឡោះអាល័យ ឥតមានសេចក្ដីត្រូវការ ដើរចេញទៅ យ៉ាង ណាមិញ ឯអាត្មាអញ នឹងលះបង់នូវកាយស្អុយនេះ ដែលពេញ ដោយសាកសពផ្សេងៗ ចេញទៅ ដូចបុរសស្ត្រីទាំងឡាយ ដែល បន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។ ម្ចាស់ទូកទាំងឡាយ តែង លះបង់នូវទូកចាស់ ដែលពុកផុយលេចចូលទឹក ឥតមាន អាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹង លះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូកលះបោលនូវទូកចាស់ ដូច្នោះឯង ។ បុរសកាល ដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពី ការខូចខាតទ្រព្យ ក៏លះបង់ ហើយដើរទៅ យ៉ាងណា កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញ នឹងលះបង់កាយ នេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាងនោះដែរ ។ លុះ តថាគតគិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយ ចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយឈ្មោះធម្មិក នៅជិតព្រៃ ហិមពាន្ត តថាគតធ្វើអាស្រម សាងបណ្ណសាលា ក្បែរភ្នំនោះ ។ តថាគតនិម្មិតនូវទីចង្ក្រម ដែលប្រាសចាកទោស ៥ ប្រការ នៅ ក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញាពល ដែលប្រកបដោយ គុណ ៨ ប្រការ ។ លះបង់សំពត់សាដកដែលប្រកបដោយ

ទោស ៩ ប្រការ ក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បក ឈើ ដែលប្រកបដោយគុណ ១២ ប្រការវិញ ។ លះបង់ បណ្ណសាលាដែលប្រកបដោយទោស ៨ ប្រការ ចូលទៅកាន់ គល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង ។ លះបង់ស្រូវ ដែលគេព្រោះ គេដាំ ដោយមិនសេសសល់ កាន់យកផ្លែឈើ ដែលជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ ។ តថាគតផ្គង ព្យាយាម ក្នុងអាស្រមបទនោះ ( ញុំាំងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្ក្រម បានលុះអភិញ្ញាពល ក្នុងវាង ៧ ថ្ងៃ ។ កាលតថាគតសម្រេចអភិញ្ញាហើយ ជាអ្នកមានវសី ក្នុងសាសនានៃតាបស កាលនោះ ព្រះជិនស្រីព្រះនាមទីបង្ករ ជា នាយកនៃលោក ទ្រង់កើតឡើង ។ កាលព្រះពុទ្ធចាប់បដិសន្ធិផង ប្រសូតផង កាលត្រាស់ដឹងផង សម្តែងធម្មចក្កផង តថាគតជា អ្នកផ្អែតស្កប់ស្កល់ ដោយសេចក្តីត្រេកអរក្នុងឈាន ប៉ុន្តែ មិន បានឃើញនូវនិមិត្តទាំង ៤ ឡើយ ។ ពួកមហាជនក្នុងបច្ចន្ត ប្រទេស មានចិត្តត្រេកអរ និមន្តព្រះតថាគត បាននាំគ្នាជម្រះផ្លូវ ជាទីមកនៃព្រះតថាគតនោះ ។ សម័យនោះឯង តថាគតចេញអំពី អាស្រមរបស់ខ្លួន កាលរលាស់ចីវរសម្បកឈើ ហោះទៅឯ អាកាស តថាគតឃើញជន កំពុងតែពេញចិត្តត្រេកអរ ស្រស់ ស្រាយ រីករាយ ក៏ចុះអំពីអាកាស ហើយសួរមនុស្សទាំងឡាយ

ក្នុងខណៈនោះថា មហាជនត្រេកអរ ស្រស់ស្រាយ រីករាយ ពេញចិត្ត ជម្រះផ្លូវ គន្ធងប្រឡាយ ដើម្បីអ្នកណា ។ ពួកជន ទាំងនោះដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថា ព្រះពុទ្ធដ៏ ប្រសើរក្នុងលោក ជាព្រះជិនស្រីព្រះនាមទីបង្ករ ជាលោកនាយក ទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវ គន្ធងប្រឡាយ ដើម្បី ព្រះពុទ្ធទីបង្ករនោះ ។ បីតិកើតឡើងដល់តថាគតក្នុងខណៈនោះ ព្រោះតែឮពាក្យថា ព្រះពុទ្ធ តថាគតទន្ទេញថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះហើយ ក៏បាននូវសោមនស្ស ។ តថាគតឋិតនៅក្នុងប្រទេស នោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្តុះពូជ កុសលក្នុងបុញ្ញក្ខេត្តនេះកុំឲ្យខណៈកន្លងទៅទទេឡើយ ។ ( លុះ គិតដូច្នេះហើយ ក៏និយាយទៅរកមហាជនថា ) បើអ្នកទាំងឡាយ ជម្រះផ្លូវថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយដល់អាត្មាផង អាត្មានឹង ជម្រះផ្លូវប្រឡាយដែរ ។ កាលនោះ ពួកជននោះក៏ឲ្យឱកាសមួយ ដល់តថាគត ដើម្បីជម្រះផ្លូវ តថាគតគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ជម្រះផ្លូវបណ្តើរ ក្នុងឱកាសនោះ ។ កាលដែលឱកាស ( ផ្លូវ ) របស់តថាគតធ្វើមិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះ ជិនស្រី ជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្តេចយាងមកតាមផ្លូវជា មួយនឹងព្រះខីណាស្រព ៤ សែនរូប សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ជាតាទិបុគ្គល ប្រាសចាកមន្ទិល ។ ការក្រោកទទួល ( ព្រះ

សាស្តា ) ក៏ប្រព្រឹត្តទៅ ស្គរទាំងឡាយជាច្រើន ក៏លាន់ឮឡើង គគ្រឹកគគ្រេង ពួកមនុស្ស និងទេវតាក៏ត្រេកអរ ញុំាងសាធុការឲ្យប្រព្រឹត្តទៅ ។ ពួកទេវតាឃើញពួកមនុស្ស ឯពួកមនុស្ស ក៏ឃើញពួកទេវតា ទេវតា និងមនុស្សទាំងពីរពួកនេះ បានផ្គងអញ្ជលីដើរដង្ហែព្រះតថាគត ។ ពួកទេវតាប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្សក៏ប្រគំតូរ្យតន្ត្រីជារបស់មនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគត ។ ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវបុស្សផ្កាឈូក ផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ឰដ៏អាកាសអំពីទិសតូចទិសធំ ។ ពួកទេវតា ដែលឋិតនៅឰដ៏អាកាស ក៏រោយរាយលម្អិតខ្លឹមចន្ទន៍ទិព្យផង គ្រឿងក្រអូបដ៏ប្រសើរទាំងអស់ផង អំពីទិសតូច ទិសធំឰដ៏អាកាស ។ ពួកមនុស្សដែលឋិតនៅលើផែនដី ក៏រោយរាយផ្កាចម្ប៉ា ផ្កាស្រល់ ផ្កាកូម្ព ផ្កាខ្ទឹង ផ្កាបុសនាគ និងផ្កាកាកេសអំពីទិសតូចទិសធំ ។ តថាគតរំសាយសក់ត្រង់ប្រទេសនោះ ហើយក្រាលចីវរសម្បកឈើ និងកំណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ ( អធិដ្ឋានថា ) សូមព្រះពុទ្ធ ព្រមទាំងពួកសិស្សជាន់អាត្មាអញ យាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ ។ កាលតថាគតដេកលើផែនដី ក៏មានសេចក្តីត្រិះរិះដោយចិត្តយ៉ាងនេះថា បើ

អាត្មាអញ ប្រាថ្នាដុតកិលេសទាំងឡាយ របស់អញក្នុងថ្ងៃនេះ ក៏បាន ។ តែថា ប្រយោជន៍ អាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ ដោយភេទដែលគេមិនស្គាល់ ក្នុងទីនេះ អាត្មាអញគប្បីដល់នូវ សព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាងលោក ព្រមទាំងទេវលោកឲ្យរួចរដោះ ( ចាកសង្សារ ) ។ ប្រយោជន៍អ្វី អាត្មាអញជាបុរស សម្តែងកម្លាំងធ្លងទៅម្នាក់ឯង អាត្មាអញគួរ ដល់នូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មាអញនឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ ខ្ពស់ ។ តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់ភពទាំង ៣ ឡើង ជិះលើនាវា គឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួល គ្រឿងបូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈរបស់តថាគត ត្រាស់ ពាក្យនេះថា ( ម្នាលភិក្ខុទាំងឡាយ ) អ្នកទាំងឡាយ ចូរមើល តាបសនេះ ជាជដិល មានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះ នឹងបាន ត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបានអំពីកប្ប នេះទៅ ។ សត្វនេះ នឹងចេញចាកក្រុង ឈ្មោះកបិលវត្ថុ ជាទី រីករាយ តម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ អង្គុយ ទៀបគល់អជបាលព្រឹក្ស ទទួលបាយាសដែលនាងសុជាតាថ្វាយ

ក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ បាន ទទួលបាយាសទៀបច្រាំងស្ទឹងនេរញ្ជរាហើយ នឹងត្រឡប់មកតាម ផ្លូវ ដែលគេតាក់តែងយ៉ាងប្រសើរ ( អង្គុយ ) ទៀបគល់ពោធិ- ព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណ ពោធិមណ្ឌល នឹងបានត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ទៀប គល់អស្សត្ថព្រឹក្ស ។ ព្រះជនិកាមាតារបស់តាបសនោះ នឹងមាន នាមថាព្រះនាងមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯតាបស នេះ នឹងមានឈ្មោះថាព្រះគោតម អគ្គសាវកទាំងពីររូប គឺ កោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាក រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាកឈ្មោះ អានន្ទ នឹងបម្រើព្រះជិនស្រីនេះ ។ អគ្គសាវិកាពីររូប គឺនាង ខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាក រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឯឧបាសក ជាឧបដ្ឋាកដ៏ប្រសើរពីររូប គឺចិត្តៈ ១ ហត្ថាឡវកៈ ១ ។ នាង នន្ទមាតា និងនាងឧត្តរា ជាឧបដ្ឋាយិកាដ៏ប្រសើរ ព្រះគោតមមាន យសនោះ មានព្រះជន្ម ១០០ វស្សា ។ ពួកមនុស្ស និងទេវតា លុះឮពាក្យព្យាកររបស់ព្រះពុទ្ធទីបង្ករ ទ្រង់ស្វែងរកគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយ ដោយគិតថា សុមេធ-

តាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោទាំងឡាយ ក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោក ទាំងមួយម៉ឺនលោកធាតុ ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការផង ពោលថា បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោម ក៏ឈ្មោះថា ឆ្លងស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរអំពើរបស់តថាគតហើយ ទ្រង់លើកព្រះបាទខាងស្តាំ ។ សាវកទាំងឡាយណា ជាបុត្រនៃព្រះជិនស្រីក្នុងទីនោះ ពួកសាវកទាំងនោះ ក៏ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួកមនុស្ស ពួកអសុរ ពួកយក្ខ ក៏ក្រាបថ្វាយបង្គំតថាគត ហើយចៀសចេញទៅ ។ កាលព្រះលោកនាយក ព្រមទាំងព្រះសង្ឃ កន្លងនូវការឃើញរបស់តថាគតទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ ។ តថាគតជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខរីករាយដោយបាមោជ្ជ ផ្សព្វផ្សាយដោយបីតិ អង្គុយពែនភ្នែន

ក្នុងកាលនោះ ។ តថាគតអង្គុយពែនភ្នែន គិតយ៉ាងនេះ ក្នុងកាលនោះថា អាត្មាអញជាអ្នកស្ទាត់ក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញា ។ ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសី ស្មើដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើ ក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវសេចក្តីសុខបែបនេះ ។ ក្នុងកាលដែលតថាគតអង្គុយពែនភ្នែនគិតយ៉ាងនេះ ពួកមហាព្រហ្មដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញុំាងសំឡេងខ្លាំងឲ្យលាន់ឮថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែននៃពោធិសត្វទាំងឡាយ ប្រាកដក្នុងកាលមុន និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ។ ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះលោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លោកធាតុទាំងមួយម៉ឺនក៏ឥតមានសំឡេង ឥតវឹកវរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះលោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ខ្យល់ធំទាំងឡាយ ក៏ឈប់បក់ ស្ទឹងទាំងឡាយ ក៏ឈប់ហូរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាទាំងពួងដែលកើតលើគោក កើតក្នុងទឹក ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ វល្លិ៍ទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែក្នុង

ខណៈនោះ វល្លិ៍ និងឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ កែវទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្យ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាសក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ មហាសមុទ្រក៏ស្រែកចុះ លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រ ក្នុងខណៈនោះ មហាសមុទ្រ និងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ភ្លើងក្នុងនរកទាំងមួយម៉ឺន ក៏រលត់ក្នុងខណៈនោះ ភ្លើងទាំងនោះ ក៏រលត់ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ព្រះអាទិត្យប្រាសចាកមន្ទិល ផ្កាយទាំងពួងក៏ប្រាកដ ព្រះអាទិត្យ និងផ្កាយទាំងនោះ ក៏បានប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុលឡើងលើផែនដី ក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដីក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធ

ប្រាកដ ។ ពួកផ្កាយទាំងឡាយក៏រុងរឿង ផ្កាយនក្ខត្តឫក្សទាំងឡាយប្រកបដោយព្រះចន្ទខែវិសាខ ( ក៏រុងរឿង ) ក្នុងមណ្ឌលនៃអាកាស លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោលក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ សេចក្តីអផ្សុកមិនមានដល់សត្វទាំងឡាយ សត្វទាំងឡាយជាអ្នកត្រេកអរក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគទាំងឡាយដ៏ស្រាលៗ ក៏ស្ងប់រម្ងាប់ទៅ ទាំងសេចក្តីស្រេកឃ្លានក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្តីស្រេកឃ្លានទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រាគក៏ស្រាកស្រាន្តទៅ ទោសៈមោហៈ ក៏បាត់បង់ទៅក្នុងកាលនោះ រាគ និងកិលេសទាំងអស់នោះ ក៏ប្រាសចេញទៅក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ឯភ័យមិនមានក្នុងកាលនោះ ការមិនមានភ័យនុ៎ះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ធូលីដ៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលី ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្លិនស្អុយ

ក៏ផាត់ចេញ ក្លិនទិព្វក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញ ដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរកទាំងអស់នោះឯង ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងពាំងមិនមានឡើយ កំពែងសន្ទះទ្វារ និងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអកាស ( ប្រាកដ ) ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចុតិ និងឧបបត្តិមិនមានក្នុងខណៈនោះ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ( និមិត្តទាំងនេះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មោធិញ្ញាណ ) ( ពួកសត្វពោលថា បពិត្រសុមេធតាបស ) សូមលោកផ្គងព្យាយាមឲ្យមាំមួនឡើង កុំត្រឡប់កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុ៎ះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ តថាគតលុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និងទេវតាទាំងមួយម៉ឺនចក្កវាឡហើយ ក៏ត្រេកអរស្រស់ស្រាយ រីករាយ គិតក្នុងកាលនោះយ៉ាងនេះថា ធម្មតា

ព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ព្រះជិនស្រីទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធ-ដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ដុំដីដែលគេចោលទៅក្នុងអាកាសទៀងតែធ្លាក់មកលើផែនដីវិញ យ៉ាងណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះឃ្លៀងឃ្លាត អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ សេចក្តីស្លាប់របស់សព្វសត្វទៀងទាត់ប្រាកដយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយទៀងទាត់ប្រាកដដូច្នោះដែរ ។ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែរះឡើង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ សីហៈដែលចេញអំពីដំណេក តែងបន្លឺសំឡេង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ ការសម្រាលគភ៌នៃស្រី ដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ។ បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។ កាលនោះ

តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូងជាគន្លងធំ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវទានបារមីជាដំបូងនេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះ ចាក់មិនឲ្យសល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះយ៉ាងណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឲ្យទានកុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញសីលបារមីទី ២ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកឯងចូរសមាទាន ធ្វើសីលបារមីទី ២ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។ សត្វចាមរី ( កាលឃើញ ) រោមកន្ទុយជំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយយ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឲ្យដូចជាសត្វចាមរី រក្សាកន្ទុយយ៉ាង

នោះចុះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញនេក្ខម្មបារមីទី ៣ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់នៅក្នុងគុកអស់កាលយូរ ត្រូវសេចក្តីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្តីត្រេកអរឲ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច ( ចាកគុកនោះ ) យ៉ាងណា អ្នកចូរឃើញនូវភពទាំងអស់ ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មៈ ដើម្បីរួចចាកភពយ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើបញ្ញាបារមីទី ៤ នេះ ឲ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។ ភិក្ខុកាលប្រព្រឹត្ត

បិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរជនជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញវីរិយបារមីទី ៥ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើវីរិយបារមីទី ៥ នេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ ។ សត្វសីហៈ ជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គងព្យាយាមឲ្យមាំមួនក្នុងភពទាំងពួង យ៉ាងនោះចុះ លុះដល់វីរិយបារមីហើយ នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព

ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវខន្តិបារមីទី ៦ នេះ ឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយរបស់ពួកជនទាំងពួងយ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀតដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញសច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើសច្ចបារមីទី ៧ នេះ ឲ្យមាំមួន កុំមានពាក្យបែកជាពីរក្នុងសច្ចបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថីក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាតចាកវិថីក្នុងសច្ចៈទាំងឡាយយ៉ាងនោះដែរ លុះដល់នូវ

សច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើអធិដ្ឋានបារមីទី ៨ នេះ ឲ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកម្រើកក្នុងអធិដ្ឋានបារមីសព្វកាល យ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវមេត្តាបារមីទី ៩ នេះ ឲ្យមាំមួន អ្នកចូរកុំឲ្យមានបុគ្គលដទៃស្មើដោយមេត្តា បើ

អ្នកចង់លុះនូវពោធិញ្ញាណ ។ ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិល យ៉ាងណា ។ អ្នកចូរចម្រើនមេត្តាឲ្យស្មើចំពោះមិត្ត និងសត្រូវ យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះតថាគតកំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខាបារមីទី ១០ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើឧបេក្ខាបារមីទី ១០ នេះ ឲ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី តែងព្រងើយកន្តើយចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួនឲ្យដូចជាជញ្ជីងចំពោះសុខ និងទុក្ខសព្វកាល យ៉ាងនោះដែរ ។ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណពុំខាន ។ ធម៌ទាំងឡាយណា ជាគ្រឿងញុំាងពោធិញ្ញាណឲ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោកត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃក្រៅ

អំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌ទាំង ១០ នោះឲ្យមាំមួនចុះ ។ កាលតថាគតពិចារណានូវបារមីធម៌ទាំងនេះដោយសភាវសរសេលក្ខណៈ ផែនដីទាំងមួយម៉ឺនលោកធាតុក៏ញាប់ញ័រដោយតេជះនៃធម៌ ។ ផែនដីកម្រើកបន្លឺឡើង ដូចជាឃ្នាបអំពៅ ដែលត្រូវគេគាប ឬចក្កយន្តប្រេង ត្រូវគេគាបហើយ ( រមែងវិលញ័រ ) យ៉ាងណា ផែនដីក៏ញាប់ញ័រ យ៉ាងនោះដែរ ។ បរិស័ទរបស់ព្រះពុទ្ធមានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាសបរិស័ទនោះក៏ញាប់ញ័រ ដេកជ្រប់លើផែនដីក្នុងទីអង្គាសនោះ ថ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏ទង្គិចគ្នាបែកខ្ទេចខ្ទីអស់ ក្នុងទីនោះ ។ ពួកមហាជនមានចិត្តរន្ធត់តក់ស្លុត ភិតភ័យភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នាហើយ ចូលទៅគាល់ព្រះពុទ្ធទីបង្ករ ( ហើយទូលសួរថា ) បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់ដូចម្ដេច នឹងមានដល់មនុស្សលោក លោកទាំងមូល ត្រូវសេចក្ដីអន្តរាយបៀតបៀនហើយ សូមព្រះអង្គទ្រង់មេត្តាប្រោស បន្ទោបង់សេចក្ដីអន្តរាយនោះចេញ ។ គ្រានោះ ព្រះមហាមុនីទីបង្ករ ទ្រង់ញ៉ាំងមហាជនទាំងនោះឲ្យយល់ច្បាស់ថា អ្នកទាំងឡាយ ចូរកុំមានសេចក្ដីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនេះឡើយ ។ ដ្បិតតថាគត បានព្យាករក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក

( ក្នុងកាលជាអនាគត ) សុមេធបណ្ឌិតនុ៎ះ កំពុងពិចារណាធម៌ ដែលព្រះជិនស្រីអំពីបុរាណ ធ្លាប់សេពមក ។ កាលសុមេធបណ្ឌិតពិចារណាធម៌ គឺពុទ្ធភូមិដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុ ក្នុងលោក ព្រមទាំងទេវលោកញាប់ញ័រ ។ ចិត្ត ( នៃមហាជន ) ក៏រលត់ស្ងប់ក្នុងខណៈនោះភ្លាម ព្រោះបានស្តាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នា ក៏ចូលមករកតថាគត ហើយក្រាបថ្វាយបង្គំម្តងទៀត ។ គ្រានោះ តថាគតសមាទាននូវពុទ្ធគុណ ធ្វើចិត្តឲ្យមាំមួន ក្រាបថ្វាយបង្គំព្រះពុទ្ធទីបង្ករ ហើយក្រោកចាកអាសនៈ ។ ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្សចំពោះសុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ ។ ពួកទេវតា និងពួកមនុស្សទាំងពីរពួកនោះ បាននូវសួស្តី ( ពោលថា ) តំណែងដ៏ធំដែលលោកប្រាថ្នាហើយ សូមលោកបាននូវតំណែងនោះ សមគួរតាមប្រាថ្នាចុះ ។ ចង្រៃទាំងពួង ចូរបរវៀសចៀសចេញទៅ សេចក្តីសោក និងរោគ ក៏ចូរចៀសវាងចេញទៅ សេចក្តីអន្តរាយ កុំបីមានដល់លោកឡើយ សូមលោកបានលុះនូវសព្វញ្ញុតញ្ញាណដ៏ខ្ពង់ខ្ពស់ឆាប់ៗ ចុះ ។ កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែងបញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបញ្ចេញផ្កាដោយពុទ្ធញ្ញាណយ៉ាងនោះដែរ ។

ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់បំពេញហើយនូវបារមីទាំង ១០ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបំពេញបារមីទាំង ១០ យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹងទៀបគល់ពោធិមណ្ឌៈ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរត្រាស់ដឹងទៀបគល់ពោធិមណ្ឌៈនៃព្រះជិនស្រី យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ យ៉ាងនោះចុះ ។ ព្រះចន្ទពេញវង់រមែងរុងរឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញ ចូររុងរឿងក្នុងលោកធាតុទាំងមួយម៉ឺន យ៉ាងនោះ ។ ព្រះអាទិត្យដែលរួចផុតអំពីរាហុ រមែងរុងរឿងដោយកម្តៅ យ៉ាងណា លោកចូររួចចាកលោកធម៌ ចូររុងរឿងដោយពុទ្ធសិរីយ៉ាងនោះដែរ ។ ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រ យ៉ាងណា ពួកលោក ព្រមទេវលោក ក៏រមែងប្រជុំក្នុងសម្នាក់របស់លោក យ៉ាងនោះដែរ ។ គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតា និងមនុស្សទាំងនោះ សើ្ញចសរសើរហើយ ក៏សមាទាននូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូលទៅកាន់ព្រៃធំ ។

សុមេធកថា ចប់

គ្រានោះ ពួកឧបាសកឧបាសិកាទាំងនោះ ញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់រួចហើយ ក៏ដល់នូវព្រះសាស្តាទីបង្ករ នោះជាទីពឹង ។ ព្រះតថាគត ទ្រង់ញុំាងបុគ្គលខ្លះ ឲ្យតម្កល់នៅក្នុងសរណគមន៍ ញុំាងបុគ្គលខ្លះ ឲ្យតាំងនៅក្នុងសីល ៥ ញុំាងបុគ្គលដទៃទៀត ឲ្យតម្កល់នៅក្នុងសីល ១០ ។ ព្រះអង្គទ្រង់ប្រទានមគ្គដល់បុគ្គលខ្លះ ប្រទានផលដ៏ឧត្តមទាំង ៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើដល់បុគ្គលខ្លះ ។ ព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់ប្រទានសមាបត្តិ ៨ ដ៏ប្រសើរ ដល់បុគ្គលខ្លះ ប្រទានវិជ្ជា ៣ ដល់បុគ្គលខ្លះ អភិញ្ញា ៦ ដល់បុគ្គលខ្លះ ។ ព្រះមហាមុនី ទ្រង់ទូន្មានពួកជនដោយន័យជាគ្រឿងប្រកបនោះ ព្រោះហេតុនោះ បានជាសាសនានៃព្រះលោកនាថជាគុណជាតដ៏ធំទូលាយ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្រះហនុកា ( ដូចព្រះចន្ទក្នុងថ្ងៃ ១២ កើត ) មានដងខ្លួនមូលក្លំ ដូចគោឧសភ ទ្រង់ចម្លងពួកជនច្រើន ឲ្យរួចចាកទុគ្គតិ ។ ព្រះមហាមុនីទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹង ស្ថិតនៅក្នុងទីមួយសែនយោជន៍ ទ្រង់ចូលទៅជិត ហើយញុំាងពួកជននោះឲ្យត្រាស់ដឹងក្នុងខណៈនោះ ។ ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធទ្រង់ញុំាងពួកទេវតា ១០០ កោដិ ឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ព្រះលោកនាថ ទ្រង់ញុំាងពួកទេវតា និងមនុស្ស ៩០ កោដិ ឲ្យត្រាស់

ដឹង ។ កាលណាព្រះពុទ្ធ ទ្រង់សម្តែងធម៌ក្នុងភពនៃទេវតា កាលនោះ ពួកទេវតា ៩០ ពាន់កោដិ ( បានត្រាស់ដឹង ) នេះជាការត្រាស់ដឹងទី ៣ ។ ព្រះសាស្តាទីបង្ករ មានសាវកសន្និបាត ( ការជួបជុំសាវក ) ៣ លើក គឺសន្និបាតលើកទី ១ មានភិក្ខុសង្ឃមួយសែនកោដិ ។ កាលដែលព្រះជិនស្រីទ្រង់យាងទៅក្នុងទីស្ងាត់លើកំពូលភ្នំនារទៈ ពួកព្រះខីណាស្រពប្រាសចាកមន្ទិល ចំនួន ១០០ កោដិ មកប្រជុំគ្នា ( នេះជាសន្និបាតលើកទី ២ ) ។ កាលព្រះ មហាមុនី មានព្យាយាមធំ ទ្រង់បវារណាជាមួយនឹងពួកភិក្ខុ ៩០ កោដិ ឮដ៏ភ្នំសុទស្សនៈ ( នេះជាសន្និបាតលើកទី ៣ ) ។ សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅឮដ៏អាកាស ជាអ្នកបានដល់នូវត្រើយនៃអភិញ្ញាទាំង ៥ ។ ពួកសត្វចំនួន ៣ ម៉ឺន បានត្រាស់ដឹងនូវសច្ចៈ ការត្រាស់ដឹងរបស់សត្វ នឹងរាប់ថា ១ ឬ ២ រាប់មិនអស់ឡើយ ។ សាសនារបស់ព្រះទីបង្ករមានព្រះភាគ ជាគុណជាតធំទូលាយ មានជនច្រើន ស្តុកស្តម្ភ សាយភាយ គឺព្រះអង្គទ្រង់ជម្រះល្អហើយក្នុងកាលនោះ ។ ពួកព្រះខីណាស្រពចំនួន ៤ សែនរូប បានលុះអភិញ្ញា ៦ មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធទីបង្ករដែលទ្រង់ជ្រាបច្បាស់នូវលោកសព្វកាល ។ ក្នុងសម័យនោះ ពួកជនណាមួយ ដែលមិនបានលុះព្រះអរហត្ត នៅជាសេក្ខបុគ្គល លះបង់

នូវការកើតជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល ។ សាសនា ( របស់ព្រះពុទ្ធទីបង្ករនោះ ) រីកសាយល្អ រុងរឿង ដោយពួកព្រះអរហន្តខីណាស្រព ជាតាទិបុគ្គល ប្រាសចាកមន្ទិល សព្វកាល ។ នគររបស់ព្រះសាស្តាព្រះនាមទីបង្ករ ឈ្មោះរម្មាវតី ក្សត្រិយ៍ព្រះនាមសុទេវៈ ( ជាព្រះបិតា ) ព្រះជនិកា ព្រះនាម សុមេធា ។ ព្រះជិនស្រីនៅគ្រប់គ្រងផ្ទះ អស់មួយម៉ឺនឆ្នាំ ប្រាសាទ ដ៏ខ្ពង់ខ្ពស់មាន ៣ ខ្នង គឺហង្សប្រាសាទ ១ កោញ្ចប្រាសាទ ១ មាយុរប្រាសាទ ១ ។ ពួកនារី ៣ សែននាក់សុទ្ធសឹងតែតាក់តែង យ៉ាងល្អ នារីឈ្មោះបទុមានោះ ( ជាមហេសី ) ព្រះឱរសព្រះ នាមឧសភក្ខន្ធ ។ ព្រះជិនស្រីឃើញនិមិត្តទាំង ៤ ទ្រង់ចេញទៅ ( បួស ) ដោយយានដំរី ទ្រង់ផ្គងព្យាយាមអស់ ១០ ខែឥតខ្វះ ។ លុះព្រះមុនីមានព្រះហឫទ័យប្រព្រឹត្តព្យាយាមហើយ ក៏បានត្រាស់ ជាព្រះពុទ្ធ ព្រះមហាមុនីទីបង្ករ ត្រូវព្រហ្មអារាធនាហើយ ។ ព្រះ ជិនស្រី មានព្យាយាមធំ ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុង វត្តនន្ទៈ ទ្រង់គង់ទៀបគល់ព្រេស ធ្វើនូវការញាំញីតិត្ថិយ ។ ព្រះ សុមង្គលៈ និងព្រះតិស្សៈ ជាអគ្គសាវក ព្រះសាគតៈ ជាឧបដ្ឋាក របស់ព្រះសាស្តាទីបង្ករ ។ នាងនន្ទា និងសុនន្ទា ជាអគ្គសាវិកា ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថា ដើមលៀប ។ ឧបាសកឈ្មោះតបុស្សៈ និងភល្លិកៈ ជាឧបដ្ឋាកដ៏ប្រសើរ នាង

សិរិមា និងនាងសោណា ជាឧបដ្ឋាយិការបស់ព្រះសាស្តាទីបង្ករ ។ ព្រះមហាមុនីទីបង្ករមានកម្ពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬដូចដើមសាលរាជព្រឹក្ស មានផ្ការីកស្គុះស្គាយ ។ រស្មីរបស់ព្រះអង្គផ្សាយទៅចម្ងាយ ១០ យោជន៍ជុំវិញ ព្រះមហេសីនោះមានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញ៉ាំងព្រះសទ្ធម្មឲ្យរុងរឿង ចម្លងមហាជន ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លងចាកសង្សារវដ្ត ។ ព្រះទីបង្ករនោះ ព្រមទាំងសាវកនិព្វានទៅ ដូចគំនរភ្លើងដែលរុងរឿងរលត់ទៅ ដូច្នោះ ឫទ្ធិនោះក្តី យសនោះក្តី ទាំងចក្ករតនៈឮដ៏ព្រះបាទានោះក្តី ក៏រលត់ទៅ ។ សម្បត្តិទាំងអស់ក៏អន្តរធានទៅ ឱហ្ន៎ ! សង្ខារទាំងពួង ជារបស់សូន្យទទេ ព្រះជិនស្រីជាសាស្តាចារ្យ ព្រះនាមទីបង្ករ ទ្រង់បរិនិព្វានក្នុងវត្តនន្ទៈ ។ ព្រះស្តូបរបស់ព្រះជិនស្រីនោះ កម្ពស់ ៣៦ យោជន៍ ( គេសាងទុក ) ក្នុងវត្តនន្ទៈនោះឯង ។ គ្រានោះ ( ពួកជនកសាង ) ព្រះស្តូបកម្ពស់ ៣ យោជន៍ ទៀបគល់ពោធិព្រឹក្ស (សម្រាប់បញ្ចុះ) បាត្រ និងចីវរ គ្រឿងបរិក្ខារ និងគ្រឿងប្រើប្រាស់របស់ព្រះសាស្តា ។

**ទីបង្ករពុទ្ធវង្សទី ១ ចប់**

# អដ្ឋកថា
# ធីបង្ករពុទ្ធវង្សទី ១

## សុមេធកថា

[ ២ ] ឥឡូវនេះ ដល់ឱកាសពណ៌នាពុទ្ធវង្ស ដែលប្រព្រឹត្ត ទៅដោយន័យជាដើមថា

ក្នុង ៤ អសង្ខេយ្យ និង ១ សែនកប្ប មាននគរ
ឈ្មោះអមរវតី ជានគរគួរពិតពិលរមិលមើល ជាទី
រីករាយនៃចិត្ត ដូច្នេះ ។

ឯកិច្ចពណ៌នាពុទ្ធវង្សនេះ ព្រោះចាំបាច់ពិចារណាដល់ហេតុ ដែលផ្ដើមសូត្រហើយ ទើបប្រាកដច្បាស់ ហេតុនោះ ទើបគួរជ្រាបការពិចារណាហេតុផ្ដើមព្រះសូត្រជាមុន ហេតុផ្ដើមសូត្រមាន ៤ យ៉ាង គឺទាក់ទងដោយអធ្យាស្រ័យនៃព្រះអង្គ ១ ទាក់ទងដោយអធ្យាស្រ័យនៃអ្នកដទៃ ១ ទាក់ទងដោយការទូលសួរ ១ ទាក់ទងដោយរឿងដែលកើតឡើង ១ ។

ក្នុងហេតុនៃការផ្ដើមសូត្រ ៤ នោះ ព្រះមានព្រះភាគ កាលអ្នកដទៃមិនបានទូលសួរ ត្រាស់នូវសូត្រទាំងឡាយណា ដោយអធ្យាស្រ័យរបស់ព្រះអង្គតែម្យ៉ាង ដូចជាអាកង្ខេយ្យសូត្រ វត្ថសូត្រ ( វត្ថូបមសូត្រ ) ជាដើម ហេតុផ្ដើមសូត្រទាំងនោះ ឈ្មោះថា ទាក់ទងដោយអធ្យាស្រ័យរបស់ព្រះអង្គ ។ ព្រះសូត្រណា ដែលព្រះមានព្រះភាគ ទ្រង់ប្រមើលមើលអធ្យាស្រ័យ ការ

គាប់ចិត្ត និងភាពជាអ្នកត្រាស់ដឹងរបស់ជនដទៃយ៉ាងនេះថា ធម៌ទាំងឡាយសម្រាប់ធ្វើវិមុត្តិឲ្យចាស់ក្លារបស់រាហុល ចាស់ក្លាហើយ បើដូច្នោះ គួរតែតថាគតទូន្មានរាហុល ក្នុងការអស់ទៅនៃអាសវៈទាំងឡាយតទៅទៀត ដូច្នេះជាដើម ហើយត្រាស់ដោយអធ្យាស្រ័យនៃអ្នកដទៃ ដូចជារាហុលោវាទសូត្រ ធម្មចក្កប្បវត្តនសូត្រ ដូច្នេះជាដើម ការផ្ដើមសូត្រទាំងនោះ ឈ្មោះថា ទាក់ទងដោយអធ្យាស្រ័យរបស់ដទៃ ។

ទេវតា និងមនុស្សចូលគាល់ព្រះមានព្រះភាគ ហើយទូលសួរបញ្ហា ព្រះសូត្រទាំងឡាយណា ដែលព្រះមានព្រះភាគត្រូវទេវតា និងមនុស្សទូលសួរហើយ ត្រាស់យ៉ាងនេះ មានទេវតាសំយុត្ត និងពោជ្ឈង្គសំយុត្តជាដើម ហេតុកើតឡើងនៃសូត្រទាំងនោះ ឈ្មោះថា ទាក់ទងដោយការទូលសួរ ។

ព្រះសូត្រណា ដែលព្រះមានព្រះភាគទ្រង់សម្ដែងអាស្រ័យហេតុដែលកើតឡើង មានធម្មទាយាទសូត្រ និងបុត្តមំសូបមសូត្រជាដើម ហេតុកើតនៃសូត្រទាំងនោះ ឈ្មោះថា ទាក់ទងដោយរឿងដែលកើតឡើង ។ បណ្ដាហេតុកើតនៃសូត្រ ៤ យ៉ាងនេះ ហេតុកើតនៃពុទ្ធវង្សនេះ ជាហេតុដែលទាក់ទងដោយការទូលសួរ ។ ពិតហើយ ពុទ្ធវង្សនេះ ព្រះមានព្រះភាគលើកឡើងតាំងទុក ដោយការសួររបស់អ្នកណា ឆ្លើយថា របស់ព្រះសារីបុត្តត្ថេរ ។ សមដូចព្រះសង្គីតិកាចារ្យទាំងឡាយ ពោលក្នុងនិទាននោះថា

ព្រះសារីបុត្ត មានប្រាជ្ញាច្រើន ឈ្លាសវៃក្នុងសមាធិ និងឈាន ជាអ្នកដល់នូវបារមីនៃប្រាជ្ញា បានក្រាបបង្គំទូលសួរព្រះលោកនាយក ដូច្នេះថា

បពិត្រព្រះអង្គមានព្យាយាមធំ ទ្រង់ប្រសើរជាងនរៈ អភិនីហាររបស់ព្រះអង្គ តើដូចម្ដេច ដូច្នេះជាដើម ។ ដោយហេតុនោះ ពុទ្ធវង្សទេសនានេះ គប្បីជ្រាបថា ទាក់ទងដោយការទូលសួរ ។

ក្នុងពាក្យថា **កប្បេ ច សតសហស្សេ** នេះ ក្នុងគាថានោះ **កប្ប** សព្ទប្រើក្នុងអត្ថទាំងឡាយ គឺការជឿមាំ វោហារ កាល បញ្ញត្ត តាក់តែង កំណត់ លេស ដោយជុំវិញ អាយុកប្ប និងមហាកប្បជាដើម ។

ពិតហើយ **កប្ប** សព្ទ ប្រើក្នុងអត្ថថា ជឿមាំ ដូចក្នុងប្រយោគជាដើមថា **ឱកប្បនិយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ សម្មាសម្ពុទ្ធស្ស** ពាក្យសរសើរព្រះគោតមដ៏ចម្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនោះ ជាពាក្យគួរជឿពិតហើយ ដូច្នេះ ។

ប្រើក្នុងអត្ថថា វោហារ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលផ្លែឈើ ដោយសមណកប្ប ៥ យ៉ាង ដូច្នេះ ។

ប្រើក្នុងអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា **យេន សុទំ និច្ចកប្បំ វិហរាមិ** តថាគតនោះឯង តែងនៅអស់កាលជានិច្ច ដូច្នេះ ។

ប្រើក្នុងអត្ថថា បញ្ញត្ត ដូចក្នុងប្រយោគជាដើមថា **ឥច្ចាយស្មា កប្បោ** កប្បមាណពដ៏មានអាយុទូលសួរថា និងដូចក្នុងប្រយោគជាដើមថា **និគ្រោធកប្បោ ឥតិ តស្ស នាមំ តយា កតំ ភគវា ព្រាហ្មណស្ស** បពិត្រព្រះមានព្រះភាគ ឈ្មោះរបស់ភិក្ខុជាព្រាហ្មណ៍នោះ ព្រះអង្គទ្រង់ប្រោសប្រទានហើយ

ថា និគ្រោធកប្បភិក្ខុនោះ ។

ប្រើក្នុងអត្ថថា តាក់តែង ដូចក្នុងប្រយោគជាដើមថា **អលង្កតោ កប្បិតកេសមស្សុ** អ□មានខ្ទ□ប្រដាប□មានសក□និងពុកចង្កា កាត□□ល ហើយ ដូចេ□ះ ។

ប្រើក្នុងអត្ថថា កំណត់ ដូចក្នុងប្រយោគជាដើមថា **កប្បតិ ទ្វង្គុល-កប្បោ** កំណត□យស្រមោលព្រះអាទិត□ជទៅ ប្រមាណពីរធា□□គួរ ដូចេ□ះ ។

ប្រើក្នុងអត្ថថា លេស ដូចក្នុងប្រយោគជាដើមថា **អត្ថិ កប្បោ និបជ្ជិតុំ** បើដូចោ□អាត្មាអញដេកសិន ដូចេ□ះ ។

ប្រើក្នុងអត្ថថា ដោយជុំវិញ ដូចក្នុងប្រយោគជាដើមថា **កេវលកប្បំ ជេតវនំ ឱភាសេត្វា** ញ□តដ□តពនឲ្យភ្លឺ□ងដោយជុំវិញ ដូច្នេះ ។

ប្រើក្នុងអត្ថថា អាយុកប្ប ដូចក្នុងប្រយោគជាដើមថា **តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ** បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគស្ថិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតស្ថិតនៅអស់ ១ អាយុកប្ប ដូច្នេះ ។

ប្រើក្នុងអត្ថថា មហាកប្ប ដូចក្នុងប្រយោគជាដើមថា **កីវ ទីឃោ នុ ខោ ភន្តេ កប្បោ** បពិត្រព្រះអង្គដ៏ចម្រើន កប្បមានកាលវែងប៉ុន្មាន ដូច្នេះ ។

ដោយ **អាទិ** សព្ទ **កប្ប** សព្ទ ប្រើក្នុងអត្ថថា ប្រៀបធៀប ដូចក្នុង ប្រយោគជាដើម **សត្ថុកប្បេន វត ភោ កិរ សាវកេន សទ្ធឹ មន្តយមានា**

ពុទ្ធោអើយ យើងបានប្រឹក្សាជាមួយនឹងសាវ័ក ដែលទុកស្មើនឹងព្រះសាស្តាផងតើ ដូច្នេះ ។

ប្រើក្នុងអត្ថថា គួរដល់វិន័យ ដូចក្នុងប្រយោគជាដើមថា **កប្បោ ឆដ្ឋោ ហោតិ កប្ប កតោកាសោ ចិណ្ណោ ហោតិ** កប្បពិន្ទុខូចខាតទៅ ១ កន្ទែងដែលធ្វើកប្បពិន្ទុគ្រាំគ្រាទៅ ១ ដូច្នេះ ។ តែក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងអត្ថថា មហាកប្ប ព្រោះហេតុនោះ បទថា **កប្បេ ច សតសហស្សេ** ទើបមានសេចក្តីថា នៃសែនមហាកប្ប ។

ក្នុងពាក្យថា **ចតុរោ ច អសង្ខិយេ** សេចក្តីថា ក្នុងទីបំផុតនៃ ៤ អសង្ខេយ្យ ។ បទថា **អមរំ ឆាម ឆគរំ** បានដល់ បានជានគរដែលបាននាមថា **អមរ** និង **អមរវតី** តែក្នុងពាក្យនេះ អាចារ្យពួកខ្លះ ពណ៌នាជាប្រការដទៃទៅវិញ នឹងត្រូវការអ្វីជាមួយអាចារ្យទាំងនោះ ។ ពាក្យនេះ ត្រឹមតែជានាមរបស់នគរនោះ ។ បទថា **ឧស្សនេយ្យំ** មានវិគ្គហៈថា ឈ្មោះថា ទស្សនេយ្យៈ ព្រោះប្រដាប់ដោយប្រាសាទ ដែលនៅអាស្រ័យជុំវិញដោយរបង មានផ្លូវបែកជា ៤ ផ្លូវបែកជា ៣ មានទ្វារ មានទីលានដ៏ស្អាត វាស់បែកដោយចំណែកយ៉ាងល្អ ។ បទថា **មនោរមំ** មានវិគ្គហៈថា ឈ្មោះថា **មនោរម** ព្រោះធ្វើចិត្តរបស់ទេវតា និងមនុស្សជាដើមឲ្យត្រេកអរ ព្រោះជានគរមានផ្ទៃរាបស្មើ គួរត្រេកអរក្រៃលែង ព្រោះជានគរដែលសម្បូរដោយម្ហូប និងទឹក ព្រោះជានគរដែលមានអាហាររកបានងាយ ព្រោះជានគរដែលប្រកបដោយគ្រឿងឧបករណ៍សព្វយ៉ាង និងព្រោះជានគរដែលស្តុកស្តម្ភ ។

បទថា **ទសហិ សទ្ទេហិ អវិវិត្តំ** សេចក្តីថា ជានគរមិនប្រាសចាក សំឡេង ១០ យ៉ាង គឺសំឡេងសេះ សំឡេងរថ សំឡេងស្គរ សំឡេងស័ង្ខ សំឡេងសម្ភោរ សំឡេងពិណ សំឡេងច្រៀង សំឡេងឈិង សំឡេងហៅឲ្យបរិភោគអាហារជាគម្រប់ ១០ ថា អញ្ជើញអ្នកទាំងឡាយ បរិភោគ ផឹក ទំពា អធិប្បាយថា អ្នករបាំសម្តែងមហោស្រពដែលប្រៀប មិនបានក៏លេងសព្វកាល ។ បទថា **អន្នបានសមាយុតំ** បានដល់ ប្រកប ដោយបាយ គឺអាហារ ៤ យ៉ាង និងទឹកស្អាត ឈ្មោះថា **អន្នបាន សមាយុត** ។ ដោយបទនេះ លោកសម្តែងថា នគរនោះរកអាហារបានដោយងាយ អធិប្បាយថា ដល់ព្រមហើយ ដោយបាយ និងទឹកច្រើន ។

ឥឡូវនេះ ដើម្បីសម្តែងសំឡេងទាំងនោះដោយវត្ថុ ទើបត្រាស់ថា
មានសំឡេង ១០ យ៉ាង គឺសំឡេងដំរី សំឡេងសេះ សំឡេង
ស្គរ សំឡេងស័ង្ខ និងសំឡេងរថជាដើម ទាំងជានគរគឹកកង
ដោយសំឡេងដែលប្រកបដោយបាយ និងទឹកថា ចូរស៊ី
ចូរផឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហត្ថិសទ្ទំ** បានដល់ ដោយសំឡេង កោញ្ចនាទរបស់ដំរីទាំងឡាយ ។ ពាក្យនេះ គប្បីឃើញថា ជាទុតិយាវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។ ក្នុងបទដ៏សេសក៏ន័យនេះឯង ។ បទថា **ភេរិ-សង្ខរថានិ ច** សេចក្តីថា ដោយសំឡេងស្គរ សំឡេងស័ង្ខ និងសំឡេងរថ ។ លោកពោលជាលិង្គវិបល្លាស អធិប្បាយថា គឹកកងដោយសំឡេងដែល

ប្រព្រឹត្តទៅយ៉ាងនេះថា ចូរស៊ី ចូរផឹកជាដើម ។ អ្នកចោទសួរ ពោលក្នុងសេចក្ដីនេះថា សំឡេងទាំងនេះ លោកសម្ដែងទុកតែឯកទេសប៉ុណ្ណោះ មិនបានសម្ដែងទុកទាំងអស់ឬ ឆ្លើយថា មិនមែនសម្ដែងត្រឹមតែឯកទេសឡើយ សម្ដែងទាំង ១០ សំឡេង ។ សម្ដែងដូចម្ដេច លោកសម្ដែង ១០ សំឡេង គឺសំឡេងសម្ភោរ លោកសង្គ្រោះដោយសំឡេងស្គរ សំឡេងពិណ សំឡេងច្រៀង និងឈិង សង្គ្រោះដោយសំឡេងស័ង្ខ ។

កាលទ្រង់ពណ៌នាសម្បត្តិរបស់នគរ ដោយបរិយាយមួយយ៉ាងនេះហើយ ដើម្បីសម្ដែងសម្បត្តិនោះទៀត ទើបត្រាស់ថា

ជានគរសម្បូរដោយសត្វ និងគ្រឿងឧបករណ៍ទាំងពួង បរិបូណ៌
ដោយការងារគ្រប់យ៉ាង បរិបូណ៌ដោយកែវ ៧ ប្រការ កុះករ
ដោយជនជាតិផ្សេងៗ សម្រេច ( ដោយគ្រឿងបរិភោគ និង
ឧបភោគទាំងពួង ) ដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នក
មានបុណ្យទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វង្គសម្បន្នំ** សេចក្ដីថា ដល់ព្រមដោយចំណែកប្រកបសព្វយ៉ាង មានកំពែង ខ្លោងទ្វារ ខឿនជាដើម ឬមានឧបករណ៍ជាគ្រឿងត្រេកអរ ទ្រព្យ ស្រូវសាលី ស្មៅ និងទឹកទាំងពួងបរិបូណ៌ ។ បទថា **សព្វកម្មមុបាគតំ** បានដល់ ប្រកបដោយការងារគ្រប់យ៉ាង អធិប្បាយថា មានការងារគ្រប់យ៉ាងដល់ព្រម ។ បទថា **សត្តរតនសម្បន្នំ** បានដល់ មានរតនៈ ៧ មានកែវមុក្តាជាដើមបរិបូណ៌ ឬសម្បូរដោយរតនៈ ៧ មាន

ហត្ថិរតនជាដើម ដោយភូមិភាគដែលជាទីប្រថាប់នៅរបស់ស្តេចចក្រពត្តិ ។ បទថា **នានាជនសមាកុលំ** បានដល់ ដេរដាសដោយជនទាំងឡាយ មានទឹកដី និងភាសាផ្សេងៗ គ្នា ។ បទថា **សមិទ្ធំ** បានដល់ ចម្រើន ដល់ព្រមដោយគ្រឿងឧបភោគ និងគ្រឿងឧបករណ៍សព្វយ៉ាងរបស់មនុស្ស ។ បទថា **ទេវនគរំ វ** លោកអធិប្បាយថា អមរវតីនគរ ស្តុកស្តម្ភដូចទេវនគរ និងដូចអាលកមន្ទាទេវធានី ។ បទថា **អាវាសំ បុញ្ញកម្មិនំ** សេចក្តីថា ជនទាំងឡាយដែលមានបុញ្ញកម្ម រមែងនៅក្នុងប្រទេសនោះ ហេតុនោះ ទើបប្រទេសនោះ ឈ្មោះថា ជាលំនៅ ។ គប្បីជ្រាបថា កាលគួរនឹងពោលថា **អាវាសោ** តែក៏ធ្វើឲ្យផ្សេងដោយលិង្គថា **អាវាសំ** ។ ឈ្មោះថា **បុញ្ញ** ព្រោះជាគ្រឿងប្រាកដ អធិប្បាយថា ប្រាកដដោយត្រកូល រូប មហាភោគៈ និងភាពជាធំ ។ ឬឈ្មោះថា បុណ្យ ព្រោះជម្រះ អធិប្បាយថា កម្មដែលជាបុណ្យ ជាគ្រឿងជម្រះនូវធូលីដែលជាមន្ទិលរបស់កុសលទាំងពួង របស់ជនពួកណាមាន ជនទាំងនោះ ឈ្មោះថា មានបុញ្ញកម្ម ។ នគរនោះ ជាទីនៅអាស្រ័យរបស់អ្នកមានបុញ្ញកម្មទាំងនោះ ។

ព្រាហ្មណ៍ឈ្មោះសុមេធ អាស្រ័យនៅក្នុងនគរអមរវតីនោះ ជាឧភតោសុជាតិ គឺកើតល្អទាំង ២ ចំណែក គឺចំណែកមាតា និងចំណែកបិតា ជាអ្នកកាន់យកគភ៌បរិសុទ្ធមកអស់ ៧ ជួរត្រកូល មិនមានអ្នកជំទាស់ ឬរង្កៀសដោយជាតិ ជាអ្នកមានរូបស្អាត គួរសរសើរ គួរជ្រះថ្លា ប្រកបដោយពណ៌សម្បុរស្អាតក្រៃលែង សិក្សាចប់ត្រៃវេទ មួយអន្លើដោយនិឃណ្ឌុសាស្ត្រ

កេដុភសាស្ត្រ ទាំងអក្ខរប្បភេទ មានឥតិហាសសាស្ត្រជាគម្រប់ ៥ ជំនាញក្នុងបទកវី ជំនាញក្នុងវេយ្យាករណ៍ ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណសាស្ត្រ តែមាតាបិតាបានស្លាប់តាំងពីសុមេធនៅក្មេង ។ សម្លាញ់អ្នករៀបចំគំនរទ្រព្យ នាំបញ្ជីទ្រព្យមកហើយ បើកឃ្លាំងជាច្រើនដែលពេញដោយរតនៈផ្សេង មានមាស ប្រាក់ កែវមណី កែវមុក្តាជាដើមប្រាប់ដល់ទ្រព្យរហូតដល់ ៧ ជួរត្រកូលថា បពិត្រកុមារ នេះទ្រព្យជាចំណែករបស់មាតា នេះទ្រព្យជាចំណែករបស់បិតា នេះទ្រព្យជាចំណែករបស់ជីដូនជីតា នេះទ្រព្យជាចំណែករបស់តាទួតយាយទួត ហើយប្រគល់ឲ្យថា សូមលោកម្ចាស់គ្រប់គ្រងទ្រព្យនេះចុះ ។ សុមេធទទួលថា សាធុហើយធ្វើបុណ្យទាំងឡាយនៅគ្រប់គ្រងផ្ទះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ។ ជាអ្នករៀនមន្ត្រ ចងចាំនូវមន្ត្រ ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមីក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នគរេ អមរវតិយា** បានដល់ ក្នុងនគរដែលហៅថា អមរវតី ។ ក្នុងបទថា **សុមេធោ នាម** នេះ បញ្ញា លោកហៅថា **មេធា** ។ មេធារបស់ព្រាហ្មណ៍នោះល្អ ដែលអ្នកប្រាជ្ញសរសើរហើយ

ហេតុនោះ ទើបព្រាហ្មណ៍នោះ គេស្គាល់ថា សុមេធ: ព្រោះជាអ្នកមានបញ្ញាល្អ ។ បទថា **ព្រាហ្មណោ** មានវិគ្គហៈថា ឈ្មោះថា **ព្រាហ្មណ** ព្រោះសិក្សានូវមន្តរបស់ព្រហ្ម អធិប្បាយថា ទន្ទេញនូវមន្ត ។ អ្នកប្រាជ្ញខាងអក្ខរ-សាស្ត្រ ពោលថា ពូជពង្សរបស់ព្រហ្ម ឈ្មោះថា ព្រាហ្មណ៍ ។ តែអ្នកប្រាជ្ញទាំងឡាយពោលថា ព្រះអរិយៈទាំងឡាយ ឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាបបាន ។ បទថា **អនេកកោដិសន្និចយោ** សេចក្ដីថា ការសន្សំនូវទ្រព្យច្រើនកោដិ ឈ្មោះថា **កោដិសន្និចយ** ។ ការសន្សំទ្រព្យច្រើនកោដិនៃបុគ្គលណាមាន បុគ្គលនោះ ឈ្មោះថា **អនេកកោដិសន្និចយ** អធិប្បាយថា សន្សំទ្រព្យច្រើនកោដិ ។ បទថា **បហូតធនធញ្ញវា** បានដល់ជាអ្នកមានទ្រព្យ និងស្រូវច្រើន ។ ពាក្យដើមគប្បីជ្រាបថា ត្រាស់ដោយទ្រព្យ និងស្រូវ ដែលនៅលើផែនដី និងនៅក្នុងឃ្លាំង ពាក្យនេះ គប្បីជ្រាបថា ត្រាស់ដោយទ្រព្យ និងស្រូវដែលបរិភោគ ប្រើប្រាស់ជាប្រចាំ ។

បទថា **អជ្ឈាយកោ** មានវិគ្គហៈថា បុគ្គលណាមិនសម្លឹងឈាន ហេតុនោះ បុគ្គលនោះឈ្មោះថា **អជ្ឈាយក** អធិប្បាយថា ជាអ្នកវៀរចាកការអប់រំឈាន សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងទីឃនិកាយ បាដិក-វគ្គ ) ថា ម្នាលវាសេដ្ឋៈ សត្វទាំងនេះ រមែងមិនសម្លឹងអារម្មណ៍ ក្នុងកាលឥឡូវនេះ សត្វទាំងនេះ រមែងមិនសម្លឹងអារម្មណ៍ក្នុងកាលឥឡូវនេះ ដូច្នេះ ។ ហេតុនោះឯង អក្សរទី ៣ ថា អ្នកមិនសម្លឹង អ្នកមិនសម្លឹង ទើបកើតឡើង ព្រោះហេតុនោះ ពាក្យនិន្ទាព្រាហ្មណ៍ទាំងឡាយ ដែលវៀរចាកការ

សម្ដីងឈាន ទើបកើតឡើងដល់មនុស្សដើមកប្ប ដោយប្រការដូច្នេះ ។ ឥឡូវនេះ ជនណាសម្ដីងមន្ត ហេតុនោះ ទើបជននោះ ឈ្មោះថា **អជ្ឈាយក** ពួកព្រាហ្មណ៍ទាំងឡាយ ធ្វើនូវការសរសើរ ពោលដោយសេចក្ដីនេះថា រាយមន្ត ។ បុគ្គលណាចាំនូវមន្ត ហេតុនោះ បុគ្គលនោះ ឈ្មោះថា **មន្តធរ** ។ បទថា **តិណ្ណំ វេទានំ** បានដល់ គម្ពីរវេទ ៣ គឺឥរុវេទ យជុវេទ និង សាមវេទ ។ **វេទ** សព្ទនេះ ប្រើក្នុងអត្ថថា ញាណ សោមនស្ស និងគន្ថៈ ។

ពិតហើយ **វេទ** សព្ទនេះ ប្រើក្នុងអត្ថថា ញាណ ដូចក្នុងប្រយោគជាដើមថា **យំ ព្រាហ្មណំ វេទគុំ អភិជញ្ញា អកិញ្ចនំ កាមភវេ អសត្តំ** អ្នកស្គាល់ច្បាស់នូវព្រាហ្មណ៍ណា ដល់នូវវេទ មិនមានកិលេសគ្រឿងកង្វល់ មិនជាប់ជំពាក់ក្នុងកាមភព ដូច្នេះ ។

ប្រើក្នុអត្ថថា សោមនស្ស ដូចក្នុងប្រយោគជាដើមថា **យេ វេទជាតា ចរន្តិ លោកេ** ជនទាំងឡាយណា រឭកឃើញនូវយញ្ញត្រាច់ទៅក្នុងលោក ដូច្នេះ ។

ប្រើក្នុអត្ថថា គន្ថៈ ដូចក្នុងប្រយោគជាដើមថា **តិណ្ណំ វេទនំ បារគូ សនិឃណ្ដុកេដុភានំ** ជាអ្នកដល់នូវត្រើយនៃត្រៃវេទ ព្រមទាំងគប្បីនិឃណ្ឌុ គម្ពីរកេតុភៈ ដូច្នេះ ។ ក្នុងទីនេះ ប្រើក្នុងអត្ថ គន្ថៈ ។ បទថា **បារគូ** មាន វិគ្គហៈថា ឈ្មោះថា **បារគូ** ព្រោះដល់ត្រើយនៃវេទដោយ ត្រឹមតែធ្វើឲ្យ រត់មាត់ ។ បទថា **លក្ខណេ** បានដល់ ក្នុងលក្ខណសាស្ត្រ មានលក្ខណ-ស្ត្រី លក្ខណបុរស និងមហាបុរិសលក្ខណៈជាដើម ។ បទថា **ឥតិហាសេ**

បានដល់ ក្នុងគម្ពីរពិសេស ពោល គឺបុរាណគតិដែលប្រកបដោយពាក្យដូច្នេះថា **ឥតិហ អាស ឥតិហ អាស** បានឮមកដូច្នេះ បានឮមកដូច្នេះ ។ បទថា **សធម្មេ** បានដល់ ក្នុងធម៌របស់ខ្លួន ឬក្នុងអាចារ្យរបស់ខ្លួន របស់ព្រាហ្មណ៍ ។ បទថា **ចារមឹ គតោ** បានដល់ ដល់នូវត្រើយ អធិប្បាយថា បានជាអាចារ្យទិសាបាមោក្ខ ។

ថ្ងៃមួយ សុមេធបណ្ឌិត ត្រេកអរដោយគំនរគុណ ១០ ប្រការ នៅក្នុងទីកំបាំងលើប្រាសាទជាន់លើ អង្គុយពត់ភ្នែន ត្រិះរិះថា ឈ្មោះថា បដិសន្ធិក្នុងភពថ្មីជាទុក្ខ ការបែកធ្លាយនៃសរីរៈក្នុងទីដែលកើតហើយ ក៏ជាទុក្ខដូចគ្នា អាត្មាអញមានជាតិ ជរា ព្យាធិ មរណៈជាធម្មតា អាត្មាអញកើតយ៉ាងនេះ គួរស្វែងរកព្រះនិព្វាន ដែលមិនមានជាតិ ជរា ព្យាធិ និងមរណៈ ជាទីចម្រើនសុខ ដែលផុតចាកការអន្ទោលទៅក្នុងភព គប្បីមានដោយមគ្គណាមួយ ដែលឲ្យដល់ព្រះនិព្វានពិត ដោយហេតុនោះ ទើបត្រាស់ថា

> កាលនោះ តថាគតនៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយសរីរៈក៏នាំមកនូវសេចក្តីទុក្ខដូចគ្នា ( សេចក្តីស្លាប់ ប្រកបដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមកនូវទុក្ខ ) អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ។ បើដូច្នោះ អាត្មាអញគួរ

តែលះកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ហើយនឹងចេញទៅ ។ ផ្លូវនោះ នឹងមានពិត ផ្លូវនោះ មិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញនឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ដូច្នេះ ។

ក្នុងគាថានោះ ខ្ញុំនឹងពោលភ្ជាប់សេចក្តីនៃគាថា និងសេចក្តីរបស់បទដែលលំបាកតទៅ

បណ្តាបទទាំងនោះ បទថា **រហោគតោ** បានដល់ ទៅហើយក្នុងទីស្ងាត់ គឺអង្គុយក្នុងទីស្ងាត់ ។ បទថា **ឯវំ ចិន្តេសហំ** កាត់បទថា **ឯវំ ចិន្តេសឹ អហំ** ប្រែថា តថាគតគិតហើយយ៉ាងនេះ ទ្រង់សម្តែងអាការ គឺការគិតដោយបទថា **ឯវំ** នេះ ។ បទថា **តទា** បានដល់ ក្នុងកាលជាសុមេធបណ្ឌិត ។ ព្រះមានព្រះភាគទ្រង់ធ្វើសុមេធបណ្ឌិត និងព្រះអង្គថាជាមនុស្សតែមួយដូចគ្នានឹងព្រះអង្គ ដោយពាក្យថា **ឯវំ ចិន្តេសហំ** នេះ ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់ប្រកាសថា គ្រានោះ សុមេធបណ្ឌិតនោះ គឺតថាគតនេះឯង ទើបត្រាស់ដោយឧត្តមបុរសថា **ឯវំ ចិន្តេសហំ តទា** ។ បទថា **ជាតិធម្មោ** បានដល់ មានជាតិជាសភាវៈ ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ បទថា **និព្វុតឹ** បានដល់ ព្រះនិព្វាន ។

សព្ទថា **យន្នូន** ជានិបាត ចុះក្នុងអត្ថថា បរិវិតក្ក សេចក្តីថា បើតថាគត ។ បទថា **បូតិកាយំ** បានដល់ កាយដែលមានសភាពស្អុយ ។

បទថា **នានាកុណបបូរិតំ** បានដល់ ពេញទៅដោយសាកសពជាច្រើន មានបសុស្សាវៈ ឧច្ចារៈ ខ្ទុះ ឈាម សេម្ហៈ ទឹកមាត់ ទឹកសម្បោរជាដើម ។ បទថា **អនបេក្ខោ** បានដល់ មិនអាល័យ ។ បទថា **អត្ថិ** បានដល់ រមែងរកបានពិត ។ បទថា **ហេហិតិ** បានដល់ នឹងមាន ពាក្យនេះ ជាពាក្យសម្តែងនូវបរិវិតក្ក ។ បទថា **ន សោ សក្កា ន ហេតុយេ** សេចក្តីថា មិនអាចមិនមានដោយមគ្គនោះ មគ្គនោះ រមែងមានដើម្បីជាហេតុ គឺរមែងមិនមានដើម្បីជាហេតុក៏មិនមែន អធិប្បាយថា ជាហេតុនោះឯង ។ បទថា **ភវតោ បរិមុត្តិយា** បានដល់ ដើម្បីរួចផុតចាកចំណង គឺភព ។

ឥឡូវនេះ ដើម្បីទ្រង់ធ្វើភាពដែលទ្រង់បរិវិតក្កឲ្យសម្រេចផល ទើបត្រាស់ថា **យថាបិ** ជាដើម ដូចធម្មតាសុខជាសត្រូវរបស់ទុក្ខមាន យ៉ាងណា កាលការកើតមាន ការមិនកើតដែលជាបដិបក្ខនៃការកើតនោះ ក៏គប្បីមានដូច្នោះ ម្យ៉ាងទៀត កាលកម្តៅមាន ត្រជាក់ដែលរម្ងាប់នូវកម្តៅនោះក៏មាន យ៉ាងណា និព្វានដែលជាគ្រឿងរម្ងាប់ភ្លើង គឺកិលេស មានរាគៈជាដើម ក៏គប្បីមានយ៉ាងនោះ ។ ម្យ៉ាងទៀត ធម៌ដែលមិនមានទោស ជាបដិបក្ខចំពោះធម៌លាមកក៏មាន យ៉ាងណា កាលជាតិជារបស់អាក្រក់មាន និព្វានដែលឈ្មោះថា មិនកើត ព្រោះហាមការកើតទាំងពួងបាន ក៏គប្បីមាន យ៉ាងនោះដូចគ្នា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមាន
ការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។

កាលបើក្តៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នាក៏មាន យ៉ាងនោះដែរ ។ កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើជាតិមាន ព្រះនិព្វានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នាក៏មានយ៉ាងនោះដែរ ដូច្នេះ ។

ក្នុងគាថានោះ សព្ទថា **យថាបិ** ជានិបាត ចុះក្នុងអត្ថឧបមា ។ បទថា **សុខំ** បានដល់ សុខកាយ និងសុខចិត្ត ។ ដែលឈ្មោះថា សុខ ព្រោះជីកនូវទុក្ខដោយល្អ ។ បទថា **ភវេ** គឺកាលការកើត ។ បទថា **វិភវោ** បានដល់ ការមិនកើត ។ កាលការកើតមាន ធម៌ គឺការមិនកើត បុគ្គលគប្បីប្រាថ្នា ។ បទថា **តិវិធគ្គិ វិជ្ជន្តេ** សេចក្តីថា កាលភ្លើង ៣ កង មានរាគៈជាដើមមាន ។ បទថា **និព្វានំ** សេចក្តីថា ព្រះនិព្វានដែលជាគ្រឿងរម្ងត់រម្ងាប់នូវភ្លើងរាគៈជាដើមទាំង ៣ កងនោះ បុគ្គលគួរប្រាថ្នា ។ បទថា **បាបេ** បានដល់ កាលអកុសលដ៏លាមក ។ បទថា **កល្យាណមបិ** បានដល់ សូម្បីកុសល ។ បទថា **ឯវមេវ** បានដល់ ខ្ញុំនោះឯង ។ បទថា **ជាតិ វិជ្ជន្តេ** សេចក្តីថា កាលការកើតមាន លោកពោលឲ្យផ្សេងដោយលិង្គ និងលុបវិភត្តិ ។ បទថា **អជាតិបិ** សេចក្តីថា សូម្បីនិព្វាន គឺការមិនកើតជាគ្រឿងរារាំងនូវការកើត បុគ្គលក៏គប្បីប្រាថ្នា ។

គ្រានោះ តថាគតក៏គិតដល់ប្រការដទៃថា បុរសដែលលិចចុះក្នុងគំនរឧច្ចារៈ ឃើញនូវស្រះទឹកដែលមានទឹកថ្លា ប្រដាប់ដោយឈូកក្រហម គោមុទ

និងឈូក-ស ក៏គួរស្វែងរកស្រះទឹក ដោយបំណងថា គួរទៅស្រះទឹកនោះដោយផ្លូវណាហ្ន៎ ។ ការមិនស្វែងរកស្រះនោះ មិនមែនជាទោសរបស់ស្រះនោះឡើយ ជាទោសរបស់បុរសនោះឯង យ៉ាងណា កាលស្រះធំ គឺអមតធម៌ ដែលជាគ្រឿងជម្រះមន្ទិល គឺកិលេសមាន ការមិនស្វែងរកស្រះធំ គឺអមតធម៌នោះ មិនមែនជាទោសរបស់ស្រះធំ គឺអមតធម៌ ជាទោសរបស់បុរសនោះឯងក៏យ៉ាងនោះ ។ មួយវិញទៀត បុរសត្រូវចោរចោមព័ទ្ធ កាលផ្លូវគេចមាន បើបុរសនោះមិនគេចទៅ ក៏មិនមែនជាទោសរបស់ផ្លូវនោះឡើយ ជាទោសរបស់បុរសនោះឯង យ៉ាងណា បុរសដែលត្រូវពួកចោរ គឺកិលេសព័ទ្ធចាប់ កាលផ្លូវធំដ៏រុងរឿងដែលទៅកាន់មហានគរ គឺព្រះនិព្វានមាន ក៏មិនស្វែងរកផ្លូវនោះ ក៏មិនមែនជាទោសរបស់ផ្លូវនោះឡើយ ជាទោសរបស់បុរសនោះក៏យ៉ាងនោះដូចគ្នា ។ បុរសត្រូវជំងឺបៀតបៀន កាលគ្រូពេទ្យអ្នកព្យាបាលជំងឺមាន បើមិនស្វែងរកគ្រូពេទ្យនោះ មិនព្រមឲ្យគ្រូពេទ្យនោះព្យាបាលជំងឺនុ៎ះក៏មិនមែនជាទោសរបស់គ្រូពេទ្យនោះឡើយ ជាទោសរបស់បុរសនោះឯង យ៉ាងណា បុគ្គលណា ត្រូវជំងឺ គឺកិលេសបៀតបៀន មិនស្វែងរកអាចារ្យអ្នកឈ្លាសក្នុងផ្លូវរម្ងាប់កិលេសដែលមាន ក៏ជាទោសរបស់បុរសនោះឯង មិនមែនជាទោសរបស់អាចារ្យដែលកម្ចាត់ជំងឺ គឺកិលេសនោះឡើយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹកហើយ
មិនស្វែងរកស្រះ ទោសនោះ មិនមែនជាទោសនៃស្រះទេ

យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វានមានហើយ បុគ្គល មិនស្វែងរកស្រះសម្រាប់លាងនូវកិលេស ជាមន្ទិលចេញទេ ទោសនោះ មិនមែនជាទោសនៃស្រះ គឺនិព្វានទេ គឺជាទោស របស់បុរស ក៏យ៉ាងនោះដែរ ។ បុរសដែលត្រូវសត្រូវទាំង ឡាយចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរស នោះមិនរត់ទៅ ទោសនោះ មិនមែនជាទោសនៃផ្លូវទេ យ៉ាង ណា បុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វាន មាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោសនៃ ផ្លូវនិព្វានទេ គឺជាទោសរបស់បុគ្គលនោះឯងយ៉ាងនោះដែរ ។ បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឲ្យពេទ្យនោះ ព្យាបាលជំងឺនោះទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ យ៉ាងណា បុគ្គលត្រូវជំងឺ គឺកិលេសទាំងឡាយបៀតបៀន ហើយ ដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោស នោះ មិនមែនជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គល នោះឯង យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គូថគតោ** បានដល់ ធ្លាក់ក្នុងរណ្តៅឧច្ចារៈ ឬត្រូវឧច្ចារៈប្រឡាក់ ។ បទថា **កិលេសមលធោវំ** បានដល់ ជាទីជម្រះ មន្ទិល គឺកិលេស ។ ពាក្យនេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ។ បទ ថា **អមតន្តឡេ** បានដល់ នៃស្រះទឹក ពោល គឺអមតៈ ។ ពាក្យនេះ ជា

សត្តមីវិភត្តិ គប្បីឃើញថា ចុះក្នុងអត្ថឆដ្ឋីវិភត្តិ លោកពោលដាក់និគ្គហិត ។ បទថា **អរីហិ** បានដល់ ដែលបច្ចាមិត្តទាំងឡាយ ។ បទថា **បរិរុទ្ធោ** បានដល់ ចោមរោមដោយជុំវិញ ។ បទថា **គមនម្បថេ** គឺផ្លូវគេចទៅ ។ ពាក្យនេះ លោកចុះនិគ្គហិតអាគម ដើម្បីមិនឲ្យខូចនូវឆន្ទលក្ខណៈ ។ បទថា **ន បលាយតិ** បានដល់ បើមិនគប្បីគេចទៅ ។ បទថា **សោ បុរិសោ** បានដល់ បុរសដែលត្រូវពួកចោរចោមព័ទ្ធនោះ ។ បទថា **អញ្ជសស្ស** បានដល់ នៃផ្លូវ ។ ពិតហើយ ផ្លូវមានឈ្មោះច្រើន គឺ

**មគ្គោ បន្ថោ បថោ បជ្ជោ អញ្ជសំ វដុមាយនំ**
**នាវា ឧត្តរសេតុ ច កុល្លោ ច ភិសិ សង្កមោ ។**

មគ្គ បានដល់ តម្រាយ គន្លង ប្រទេសសម្រាប់ទៅដោយជើង ទីសម្រាប់ដើរ ទីសម្រាប់ដើរទៅដើរមក ទូក ស្ពានសម្រាប់ឆ្លង ផែ ពោងពាយ ដូច្នេះ ។

តែក្នុងទីនេះ ផ្លូវនោះ លោកពោលដោយប្រើឈ្មោះថា **អញ្ជស** ។ បទថា **សិវេ** បានដល់ ឈ្មោះថា **សិវ** ព្រោះមិនមានឧបទ្រវទាំងពួង ។ បទថា **សិវមញ្ជសេ** សេចក្តីថា នៃផ្លូវដែលផុតភ័យ ។ បទថា **តិកិច្ឆកេ** បានដល់ គ្រូពេទ្យ ។ បទថា **ន តិកិច្ឆាបេតិ** បានដល់ មិនព្រមឲ្យព្យាបាល ។ បទថា **ន ទោសោ សោ តិច្ឆកេ** បានដល់ មិនមែនជាទោសរបស់គ្រូពេទ្យ អធិប្បាយថា ជាទោសរបស់អ្នកជំងឺតែម្យ៉ាង ។ បទថា **ទុក្ខិតោ** បានដល់ កើតនូវសេចក្តីទុក្ខផ្លូវកាយ ផ្លូវចិត្ត ។ បទថា **អាចរិយំ** បានដល់ អាចារ្យ

ដែលប្រាប់ផ្លូវរួចផុត ។ បទថា **វិនាយកោ** បានដល់ អាចារ្យ ។

តថាគតកាលគិតដូច្នេះហើយ ទើបគិតក្រៃលែងឡើងយ៉ាងនេះថា បុរសដែលចូលចិត្តតែងខ្លួន ទម្លាក់ចុះសាកសពដែលព្យួរត្រង់ក គប្បីនៅជាសុខយ៉ាងណា សូម្បីអាត្មាអញក៏លះបង់កាយស្អុយនេះ មិនអាល័យ គប្បីចូលទៅកាន់មហានគរ គឺនិព្វានក៏យ៉ាងនោះ ។ ម្យ៉ាងទៀត បុរសស្ត្រី បន្ទោបង់ឧច្ចារបស្សាវៈត្រង់ផែនដី ប្រឡាក់ឧច្ចារបស្សាវៈហើយ ក៏មិនយកថ្នក់ ឬជាយសំពត់ខ្ចប់ឧច្ចារបស្សាវៈនោះនាំយកទៅ ដែលពិត ក៏នាំគ្នាខ្ពើម មិនចង់សូម្បីតែមើល មិនអាល័យ បោះបង់ចោលទៅ យ៉ាងណា សូម្បីអាត្មាអញ ក៏មិនអាឡោះអាល័យកាយស្អុយនេះ គួរបោះបង់ចោល ចូលទៅកាន់អមតនគរ គឺនិព្វានក៏យ៉ាងនោះ ។ ម្យ៉ាងទៀត ធម្មតានាយទូកទាំងឡាយ ក៏លះបង់នូវទូកដែលធ្លុះធ្លាយគ្រាំគ្រា មិនអាឡោះអាល័យ យ៉ាងណា សូម្បីអាត្មាអញក៏លះបង់កាយដែលជារបស់ស្មោកគ្រោក ហូរចេញចាកមុខដំបៅទាំង ៩ នេះ មិនជាប់ជំពាក់ ចូលទៅកាន់មហានគរ គឺនិព្វានក៏យ៉ាងនោះ ។ ម្យ៉ាងទៀត បុរសពួកខ្លះ វេចនូវរតនៈច្រើនយ៉ាង មានកែវមុក្តា កែវមណី និងកែវពិទូរ្យជាដើម ធ្វើដំណើរទៅជាមួយពួកចោរ ចាំបាច់លះបង់ពួកចោរទាំងនោះ ព្រោះខ្លាចសាបសូន្យរតនៈ ជ្រើសរើសយកតែផ្លូវក្សេម ផុតភ័យ យ៉ាងណា កាយស្អុយនេះ ក៏ដូចចោរប្លន់រតនៈ បើអញធ្វើចំណង់ក្នុងកាយនេះ រតនៈ គឺអរិយមគ្គ និងកុសលធម៌របស់អញ ក៏នឹងសាបសូន្យទៅ ព្រោះហេតុនោះ អាត្មាអញគួរលះបង់នូវករជកាយ ដែលដូចមហាចោរនេះ ហើយចូលទៅ

កាន់មហានគរ គឺនិព្វាន ក៏យ៉ាងនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

បុរសបានស្រាយសាកសព ដ៏គួរខ្ពើមរអើម ដែលជាប់ព្វដ៏កគប្បីជាអ្នកមានសេចក្ដីសុខ នៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញ គួរតែលះបង់កាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេងៗ ចេញហើយគប្បីជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្ដីត្រូវការចេញទៅ យ៉ាងនោះដែរ ។ បុរសស្ត្រីទាំងឡាយ ទៅបន្ទោបង់នូវករីសក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្ដីត្រូវការ ដើរចេញទៅ យ៉ាងណាមិញ ឯអាត្មាអញនឹងលះបង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ចេញទៅ ដូចបុរសស្ត្រីទាំងឡាយ ដែលបន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។ ម្ចាស់ទូកទាំងឡាយ តែងលះបង់នូវទូកចាស់ ដែលពុកផុយ លិចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅដូចជាម្ចាស់ទូកលះបោលនូវទូកចាស់ ដូច្នោះឯង ។ បុរសកាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ ហើយដើរទៅ យ៉ាងណា

កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹង លះបង់កាយនេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាង នោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថាបិ កុណបំ បុរិសោ** សេចក្តីថា បុរសដែលមានវ័យក្មេង ជាអ្នកស្រឡាញ់នូវការស្អាត មិនចូលចិត្ត ខ្ពើម ឆ្អើមនូវសាកសពសត្វ សាកសពឆ្កែ ឬសាកសពមនុស្សដែលចងត្រង់ក ក៏ ដោះសាកសពនោះចេញ យ៉ាងណា ។ បទថា **សុខី** បានដល់ ជួបនូវសេចក្តី សុខ ។ បទថា **សេរី** បានដល់ នៅតាមទំនើងចិត្ត ។ បទថា **ឆាធាកុណា-បសញ្ចយំ** បានដល់ ជាគំនរសាកសពផ្សេងៗ ច្រើនយ៉ាង ។ បាឋៈថា **ឆាធាកុណបបូរិតំ** ដូច្នេះក៏មាន ។

បទថា **ឧច្ចារដ្ឋានម្ហិ** សេចក្តីថា ជនទាំងឡាយបន្ទោបង់ឧច្ចារៈ គឺ ធ្វើនូវការបន្ទោបង់ឧច្ចារៈ ក្នុងប្រទេសនោះ ហេតុនោះ ទើបប្រទេសនោះ ឈ្មោះថា ជាទីបន្ទោបង់ឧច្ចារៈ ។ ទីជាទីបន្ទោបង់ឧច្ចារៈផង ជាឋានៈផង ហេតុនោះ ទើបឈ្មោះថា ទីជាទីបន្ទោបង់ឧច្ចារៈ ។ ម្យ៉ាងទៀត ប្រទេសដែល គេបន្ទោបង់ឧច្ចារៈ ហេតុនោះ ទើបឈ្មោះថា ទីបន្ទោបង់ឧច្ចារៈ ពាក្យនេះ ជាឈ្មោះរបស់ឧច្ចារៈ ។ ទីរបស់ឧច្ចារៈនោះ ឈ្មោះថា ទីរបស់ឧច្ចារៈ ក្នុងទី នៃឧច្ចារៈនោះ អធិប្បាយថា ក្នុងទីដែលប្រឡាក់ដោយរបស់ស្មោកគ្រោក ។ បទថា **វច្ចំ កត្វា យថា កុដី** សេចក្តីថា ដូចបុរសស្ត្រីលះបង់នូវខ្ទមដែល បន្ទោបង់ឧច្ចារៈ គឺបង្គន់ ដូច្នោះ ។

បទថា **ជជ្ជរំ** បានដល់ ចាស់គ្រាំគ្រា ។ បទថា **បលុគ្គំ** បានដល់ បាក់បែក អធិប្បាយថា ខ្ទាត់ខ្ទាយ ។ បទថា **ឧទគាហិនី** បានដល់ ទឹកចូលបាន ។ បទថា **សាមិ** បានដល់ ម្ចាស់របស់ទូក ។ បទថា **នវច្ឆិទ្ទំ** បានដល់ ឈ្មោះថា **នវច្ឆិទ្ទ** ព្រោះប្រកបដោយមុខដំបៅ ៩ មានភ្នែក ត្រចៀកជាដើម និងប្រហោងតូចធំ ។ បទថា **ធុវស្សវំ** បានដល់ ហូរចេញជាប្រចាំ អធិប្បាយថា មានវត្ថុមិនស្អាតហូរចេញជានិច្ច ។

បទថា **ភណ្ឌមាទិយ** បានដល់ កាន់យកទ្រព្យ មានរតនៈជាដើមណាមួយ ។ បទថា **ភណ្ឌច្ឆេទភយំ ទិស្វា** សេចក្តីថា ឃើញភ័យអំពីការដណ្តើមទ្រព្យ ។ បទថា **ឯវមេវ** សេចក្តីថា ដូចបុរសស្តាយទ្រព្យធ្វើដំណើរទៅដូច្នោះ ។ បទថា **អយំ កាយោ** សេចក្តីថា សភាវៈនេះ ជាទីកើតនៃវត្ថុដែលគេខ្ពើម ដែលគួរខ្ពើមក្រៃលែង ហេតុនោះ ទើបឈ្មោះថា កាយ ។ ពាក្យថា **អាយ** បានដល់ ទីកើត ។ អាការទាំងឡាយ រមែងមកអំពីសភាវៈនោះ ហេតុនោះ ទើបសភាវៈនោះ ឈ្មោះថា **អាយ** គឺជាដែនមក គឺអាការទាំងឡាយ មានសក់ជាដើម ដែលគេខ្ពើម ។ សភាវៈជាដែនមកនៃ អាការទាំងឡាយ មានសក់ជាដើមដែលគេខ្ពើម ដោយប្រការដូច្នោះ ហេតុនោះ ទើបសភាវៈនោះ ឈ្មោះថា **កាយ** ។ បទថា **មហាចោរសមោ វិយ** សេចក្តីថា កាយ ឈ្មោះថា មហាចោរសមៈ ព្រោះជាចោរ គឺបាណាតិបាត និងអទិន្នាទានជាដើម រង់ចាំប្លន់កុសលគ្រប់យ៉ាង ដោយអំណាចការត្រេកអរជាដើម ក្នុងបិយរូបទាំងឡាយ មានរូបារម្មណ៍ជាដើម ដោយចក្ខុជាដើម ព្រោះ

ហេតុនោះ ទើបគួរជ្រាបការភ្ជាប់សេចក្តីថា បុរសដែលកាន់យកទ្រព្យ ជារតនៈទៅជាមួយពួកចោរនោះ ចាំបាច់លះបង់ពួកចោរទាំងនោះ ហើយទៅយ៉ាងណា សូម្បីអាត្មាអញ ក៏ចាំបាច់លះបង់កាយដែលស្មើដោយមហាចោរនេះទៅ ដើម្បីស្វែងរកផ្លូវដែលធ្វើនូវសួស្តីឲ្យដល់ខ្លួន ក៏យ៉ាងនោះដូចគ្នា ។ បទថា **កុសលច្ឆេទនាភយា** សេចក្តីថា ព្រោះខ្លាចចំពោះការបូទ់កុសលធម៌ ។

គ្រានោះ សុមេធបណ្ឌិត កាលគិតដល់ហេតុនៃនេក្ខម្មៈ ដោយឧបមាច្រើនប្រការយ៉ាងនេះហើយ ទើបគិតទៀតថា បិតា និងជីតាជាដើមរបស់អញប្រមូលគំនរទ្រព្យធំនេះដើម្បីទៅបរលោក ក៏នាំយកសូម្បីតែ ១ កហាបណៈទៅមិនបាន ឯអញ គួរកាន់យកដើម្បីធ្វើហេតុទៅបរលោក ដូច្នេះហើយ ក៏ទៅក្រាបទូលដល់ព្រះរាជាថា បពិត្រមហារាជ ទូលបង្គំមានហទយៈ ត្រូវជាតិជរាជាដើមបៀតបៀន នឹងចេញអំពីផ្ទះ បួសមិនមានផ្ទះ ទូលបង្គំមានទ្រព្យច្រើនសែនកោដិ សូមទ្រង់ចាត់ចែងទ្រព្យនោះចុះ ព្រះរាជាត្រាស់ថា យើងមិនត្រូវការទ្រព្យរបស់អ្នកទេ អ្នកនោះឯង ចូរធ្វើតាមប្រាថ្នាចុះ ។

សុមេធបណ្ឌិតនោះ ទទួលថា សាធុ ហើយឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ឲ្យទានដល់មហាជន លះវត្ថុកាម និងកិលេសកាមហើយ ក៏ចេញចាកអមរនគរ ដែលដូចគ្នានឹងទេវនគរដ៏ប្រសើរ ទៅតាមទំនើងចិត្ត អាស្រ័យធម្មិកបព៌ត ក្នុងហិមវន្តប្បទេស មានហ្វូងម្រឹគច្រើនប្រភេទ ធ្វើអាស្រម សាងបណ្ណសាលា សាងទីចង្រ្កមដែលវៀរទោស ៥ ប្រការក្នុងទីនោះ លះសំពត់ដែលប្រកបដោយទោស ៩ ប្រការហើយ ស្លៀកដណ្តប់សំពត់សម្បកឈើ

ដែលប្រកបដោយគុណ ១២ ប្រការ ដើម្បីប្រមូលកម្លាំងនៃអភិញ្ញា ដែលប្រកបដោយគុណ ៨ ប្រការ បួសហើយ ។

សុមេធបណ្ឌិតបួសយ៉ាងនេះហើយ ក៏លះបង់បណ្ណសាលាដែលប្រកបដោយទោស ៨ ប្រការ អាស្រ័យគល់ឈើ ដែលប្រកបដោយគុណ ១០ ប្រការ លះធញ្ញជាតិច្រើនប្រភេទ បរិភោគតែផ្លែឈើដែលមានតាមធម្មជាតិ តាំងសេចក្តីព្យាយាម ដោយការអង្គុយ ឈរ និងដើរ ក៏បានសមាបត្តិ ៨ និងអភិញ្ញា ៥ ខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយ ឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រម សាងបណ្ណសាលា ក្បែរភ្នំនោះ ។ តថាគតនិម្មិតនូវទីចង្រ្កម ដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញាពល ដែលប្រកបដោយគុណ ៨ ប្រការ ។ លះបង់សំពត់សាដកដែលប្រកបដោយទោស ៩ ប្រការ ក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បកឈើដែលប្រកបដោយគុណ ១២ ប្រការវិញ ។ លះបង់បណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការ ចូលទៅកាន់គល់ឈើដែលប្រកបដោយគុណ ១០

យ៉ាង ។ លះបង់ស្រូវដែលគេព្រោះ គេដាំ ដោយមិនសេស សល់ កាន់យកផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណ ច្រើនប្រការ ។ តថាគតផ្គងព្យាយាម ក្នុងអាស្រមបទនោះ ( ញុំាងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និង ទីចង្រ្កម បានលុះអភិញ្ញាពលក្នុងរវាង ៧ ថ្ងៃ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯវាហំ** កាត់បទជា **ឯវំ អហំ** សេចក្ដីថា តថាគតគិតដោយប្រការដូចពោលមកហើយខាងដើម ។ បទថា **ធាថាធាថានំ** សេចក្ដីថា តថាគតឲ្យដល់អ្នកមានទីពឹង និងអ្នកមិនមានទីពឹង គឺទាំងបុគ្គលស្ដុកស្ដម្ភ និងបុគ្គលក្រីក្រ ត្រង់ខ្លោងទ្វារ និងទ្វារផ្ទះ ដោយពោលថា អ្នកត្រូវការក៏ចូរទទួលយក ។ បទថា **ហិមវន្តស្សាវិទូរេ** បានដល់ ក្នុងទីមិនឆ្ងាយ គឺជិតភ្នំហិមពាន្ត ។ បទថា **ធម្មិកោ នាម បព្វតោ** បានដល់ ភ្នំដែលមានឈ្មោះយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ទើបភ្នំនេះមានឈ្មោះថាធម្មិកៈ ឆ្លើយថា ព្រះពោធិសត្វទាំងឡាយដោយច្រើន បួសជាឥសី ចូលអាស្រ័យភ្នំនោះ ធ្វើអភិញ្ញាឲ្យកើត ហើយធ្វើនូវសមណធម៌ ព្រោះហេតុនោះ ទើបភ្នំនោះ ប្រាកដឈ្មោះថា **ធម្មិក** ព្រោះជាទីអាស្រ័យនៃបុគ្គលដែលមានសមណធម៌ ។ ដោយបទថា **អស្សមោ សុកតោ មយ្ហំ** ជាដើម ត្រាស់ដូចសុមេធបណ្ឌិតសាងអាស្រម បណ្ណសាលា ទីចង្រ្កម ដោយដៃខ្លួនឯងតែសេចក្ដីពិត មិនសាងដោយដៃខ្លួនឯងឡើយ សក្កទេវរាជ ទ្រង់បញ្ជូនវិស្សកម្មទេវបុត្តទៅសាង មិនមែនឬ តែព្រះមានព្រះភាគ សំដៅដល់ផល

សម្រេចនោះ ដែលកើតដោយបុញ្ញានុភាពរបស់ព្រះអង្គ ក្នុងគ្រានោះ ទើបត្រាស់ពាក្យជាដើមថា ម្នាលសារីបុត្ត ត្រង់ភ្នំនោះ

តថាគតធ្វើអាស្រម សាងបណ្ណសាលាក្បែរភ្នំនោះ តថាគតនិម្មិតនូវទីចង្ក្រម ដែលប្រាសចាកទោស ៥ ប្រការ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បណ្ណសាលា** បានដល់ សាលាដែលប្រក់ដោយស្លឹកឈើ ។ បទថា **តត្ថ** បានដល់ ក្នុងអាស្រមបទនោះ ។ បទថា **បញ្ចទោសវិវជ្ជិតំ** បានដល់ វៀរឆ្ងាយចាកទោសនៃទីចង្ក្រម ៥ ប្រការ ។ ឈ្មោះថា ទោសនៃទីចង្ក្រមមាន ៥ ប្រការ អ្វីខ្លះ វៀរចាកទោស ៥ ប្រការ គឺមានដីរឹងខ្ពស់ទាប ១ មានដើមឈើនៅខាងក្នុងទីចង្ក្រម ១ មានមែកឈើស្មុគស្មាញ ១ តូចពេក ១ ធំពេក ១ ដោយការកំណត់យ៉ាងធំ លោកពោលថា ទីចង្ក្រម បណ្ដោយ ៦០ ហត្ថ ទទឹង ១ ហត្ថកន្លះ ។

មួយ៉ាងទៀត បទថា **បញ្ចទោសវិវជ្ជិតំ** បានដល់ វៀរចាកទោស គឺនីវរណៈ ៥ ប្រការ គប្បីឃើញថា ភ្ជាប់ជាមួយបទក្រោយនេះថា **អភិញ្ញាពលមាហរឹ** ដូច្នេះ ។ បទថា **អដ្ឋគុណសមុបេតំ** សេចក្ដីថា នាំមកនូវកម្លាំងនៃអភិញ្ញា ដែលប្រកបដោយគុណ ៨ ប្រការ តាមដែលលោកពោលយ៉ាងនេះថា ភិក្ខុនោះ កាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនៃកម្មដល់នូវសេចក្ដីមិនញាប់ញ័រ ដូច្នេះ ។

តែអាចារ្យពួកខ្លះពោលភ្ជាប់ជាមួយអាស្រមថា តថាគតសាងអាស្រម

ដែលប្រកបដោយសមណសុខ ៨ ប្រការ គឺប្រកបព្រមដោយសមណសុខ ៨ ទាំងនេះ គឺឈ្មោះថា សមណសុខ ៨ ប្រការ បានដល់ មិនហួងហែងទ្រព្យ និងស្រូវ ១ ស្វែងរកតែបិណ្ឌបាតដែលមិនមានទោស ១ បរិភោគតែបិណ្ឌបាតដែលត្រជាក់ ១ មិនមានការបៀតបៀនអំពីព្រះរាជាទាំងឡាយមានបៀតបៀនដោយកាស៊ី ឬដោយការរឹបអូសយកទ្រព្យមានតម្លៃ និងកហាបណៈជាដើម ១ ប្រាសចាកតម្រេក ដោយការពេញចិត្តក្នុងគ្រឿងឧបករណ៍ទាំងឡាយ ១ មិនមានភ័យព្រោះចោរប្លន់ ១ មិនប្រឡូកប្រឡំដោយព្រះរាជា និងមហាអមាត្យរបស់ព្រះរាជា ១ មិនទើសទាក់ក្នុងទិសទាំងបួន ១ ពាក្យនោះ មិនសមនឹងបាលី ។ បទថា **សាដកំ** បានដល់ សំពត់ស្លៀកដណ្តប់ ។ បទថា **តត្ថ** បានដល់ ក្នុងអាស្រមបទនោះ ។ ដោយបទថា **នវទោសមុបាគតំ** ទ្រង់សម្តែងថា ម្នាលសារីបុត្ត តថាគតកាលនៅក្នុងទីនោះ ក៏លះបង់នូវសំពត់ដែលមានតម្លៃច្រើន ដែលខ្លួនស្លៀកដណ្តប់ហើយ កាលលះបង់សំពត់ បានឃើញទោស ៩ ប្រការ ក្នុងសំពត់នោះទើបលះបង់ ។ សេចក្តីពិត ប្រកាសទោស ៩ ប្រការក្នុងសំពត់ដល់អ្នកបួសជាតាបសទាំងឡាយ ។ ទោស ៩ ប្រការ គឺអ្វី គឺទ្រង់សម្តែងថា តថាគតលះសំពត់ដែលប្រកបដោយទោស ៩ ប្រការ គឺសំពត់ជារបស់មានតម្លៃច្រើន ១ កើតឡើងព្រោះទាក់ទងនឹងអ្នកដទៃ ១ សៅហ្មងរហ័សព្រោះការប្រើប្រាស់បន្តិចបន្តួច ១ សំពត់ចាស់ទៅដោយការប្រើប្រាស់ សៅហ្មងហើយចាំបាច់បោកគក់ និងជ្រលក់ ១ សំពត់កើតបានលំបាកដោយការស្វែង

រកជាថ្មី ចាស់ហើយចាំបាច់ដេរប៉ះ ១ មិនសមគួរដល់ការបួសជាតាបស ១ ជារបស់សាធារណៈដល់ពួកចោរ ១ លំបាកក្នុងការរក្សាកុំឲ្យចោរលួច ជាឋានៈនៃការតែងខ្លួនរបស់អ្នកប្រើប្រាស់ដណ្តប់ ១ បុគ្គលដែលកាន់យកត្រាច់ទៅ ក្លាយជាបុគ្គលប្រាថ្នាច្រើន ១ ហើយទើបស្លៀកសំពត់សម្បកឈើ ។ បទថា **វាកចីរំ** សេចក្តីថា កាន់យកសំពត់ដែលសម្រេចដោយសម្បកឈើដែលក្រងដោយស្មៅជំណោកទន្សាយជាសរសៃៗ ធ្វើហើយដើម្បីស្លៀកដណ្តប់ ។ បទថា **ទ្វាទសគុណមុបាគតំ** បានដល់ ប្រកបដោយអានិសង្ស ១២ ប្រការ ។ ក្នុងបទនេះ **គុណ** សព្ទ មានអត្ថថា អានិសង្ស ដូចក្នុងប្រយោគជាដើមថា **សតគុណំ ទក្ខិណា បាដិកង្ខិតព្វា** ទក្ខិណាមានគុណមួយរយ ។ **ម** អក្ខរៈ ត្រឹមតែបទសន្ធិ ។ សំពត់សម្បកឈើដល់ព្រមដោយគុណ ១២ ប្រការ គឺសំពត់សម្បកឈើមានអានិសង្ស ១២ ប្រការ គឺមានតម្លៃតិច ១ មិនទាក់ទងដោយអ្នកដទៃ ១ អាចធ្វើដោយដៃរបស់ខ្លួនឯង ១ បើចាស់ដោយការប្រើប្រាស់ ក៏មិនចាំបាច់ដេរប៉ះ ១ មិនមានចោរភ័យ ១ កាលស្វែងរកក៏ធ្វើបានដោយងាយ ១ សមគួរដល់ការបួសជាតាបស ១ មិនជារបស់តែងខ្លួន ១ អ្នកប្រើឈ្មោះថាប្រាថ្នាតិចក្នុងបច្ច័យ គឺចីវរ ១ ប្រើស្រួល ១ សម្បកឈើដែលកើតក៏រកបានងាយ ១ កាលបាត់ក៏មិនសោកស្តាយ ១ ។

គ្រានោះ សុមេធបណ្ឌិតនៅក្នុងបណ្ណសាលាអាស្រមនោះ ទៀបភ្លឺ ក៏ក្រោកឡើងពិចារណាដល់ហេតុ នៃការចេញបួសរបស់ខ្លួន គិតយ៉ាងនេះថា

អញលះផ្ទះដែលមានអាការដ៏ប្រសើរដូចរបស់ទេវតា លម្អដោយសម្បត្តិដ៏ឱឡារ គួរជាទីត្រេកអររបស់គ្រហស្ថ ជាអ្នកសើច និងចរចាដោយសំឡេងដ៏ពីរោះ ដែលលាយឡំដោយសំឡេងកងដៃ កងជើងមាសជាដើមថ្មី ដែលប៉ះទង្គិចគ្នា អាត្មាអញលះបង់ដូចដុំទឹកមាត់ ចូលទៅកាន់ព្រៃតបោវន បំពេញតបៈ ជាគ្រឿងបន្សាត់បាបនៃជនទាំងពួង ព្រោះជាអ្នកត្រេកអរដោយវិវេក តែការនៅត្រង់បណ្ណសាលាក្នុងអាស្រមនេះរបស់អាត្មាអញ ក៏ដូចជាការនៅគ្រប់គ្រងផ្ទះជាលើកទី ២ ណ្ហើយចុះ អញនឹងនៅត្រង់គល់ឈើ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

តថាគតលះបង់បណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការ ។

បណ្តាបទទាំងនោះ បទថា **អដ្ឋទោសសមាកិណ្ណំ** សេចក្តីថា ដេរដាស គឺប្រកបដោយទោស ៨ ប្រការ ។ ទោស ៨ ប្រការអ្វីខ្លះ ព្រះមហាសត្វឃើញទោសទាំង ៨ នេះ គឺការធ្វើ ត្រូវប្រើគ្រឿងទព្វសម្ភារច្រើន ១ ចាំបាច់ទំនុកបម្រុងជានិច្ចដោយស្មៅ ស្លឹកឈើ និងដីឥដ្ឋជាដើម ១ មិនមានឯកគ្គតាចិត្ត ព្រោះត្រូវក្រោកឡើងក្នុងពេលមិនសមគួរ ព្រោះ ឈ្មោះថាសេនាសនៈ រមែងដល់លំដាប់បព្វជិតដែលចាស់ជាង ១ ជាអ្នកមានរាងកាយទន់ខ្សោយ ព្រោះបណ្ណសាលាការពារនូវត្រជាក់ និងក្តៅ ១ បិទបាំងនូវពាក្យតិះដៀល ព្រោះបុគ្គលចូលទៅក្នុងផ្ទះ អាចធ្វើអំពើអាក្រក់ឯណាមួយបាន ១ ត្រូវហួងហែងថា នេះរបស់អញ ១ ការមានផ្ទះ បញ្ជាក់ថា ជាអ្នក

មានសម្ភារៈ ( ករិយា ) ១ ជារបស់សាធារណៈដល់សត្វច្រើន ព្រោះជារបស់ទូទៅដល់សត្វទាំងឡាយ មានសុច សរន្តិច ជីងចក់ជាដើម ១ ដូច្នេះហើយ ទើបលះបង់បណ្ណសាលា ។

បទថា **គុណេហិ ទសហុបាគតំ** សេចក្តីថា តថាគតបដិសេធទីបិទបាំង ចូលទៅកាន់គល់ឈើដែលប្រកបដោយគុណ ១០ ប្រការ គុណ ១០ ប្រការ គឺអ្វីខ្លះ ត្រាស់ថា តថាគតឃើញគុណ ១០ គឺមានការផ្តើមធ្វើតិចតួច ១ មិនមានទោស ព្រោះរកបានងាយ គឺគ្រាន់តែចូលទៅត្រង់នោះប៉ុណ្ណោះ ដោយគ្រាន់តែគល់ឈើប៉ុណ្ណោះ ១ ធ្វើអនិច្ចសញ្ញាឲ្យតាំងឡើង ព្រោះកាលឃើញការប្រែប្រួលរបស់ដើមឈើ និងស្លឹកឈើ ១ មិនធ្វើនូវការកំណាញ់សេនាសនៈ ១ មិនធ្វើនូវបាប ព្រោះកាលធ្វើបាបត្រង់គល់ឈើនោះរមែងខ្មាស ១ មិនធ្វើនូវការហួងហែង ១ នៅជាមួយទេវតាទាំងឡាយ ១ បដិសេធទីបិទបាំង ១ ប្រើប្រាស់ងាយស្រួល ១ មិនសម្លឹងព្រោះសេនាសនៈ គល់ឈើរកបានងាយក្នុងទីដែលទៅ ១ ហើយទើបចូលទៅកាន់គល់ឈើ ព្រោះហេតុនោះ ទើបលោកពោលថា

> គល់ឈើ ព្រះពុទ្ធដ៏ប្រសើរសរសើរហើយ គល់ឈើ ជានិស្ស័យ ជាទីអាស្រ័យ លំនៅរបស់អ្នកស្ងាត់ ស្មើដោយគល់ឈើមិនមាន ពិតណាស់ បុគ្គលនៅត្រង់គល់ឈើដែលស្ងាត់ ដែលកម្ចាត់នូវសេចក្តីកំណាញ់ លំនៅដែលទេវតារក្សាហើយ ឈ្មោះថា មានវត្តល្អ ។ បុគ្គលឃើញដើមឈើ

និងស្លឹកឈើដែលមានពណ៌ក្រហមខៀវលឿង ដែលជ្រុះហើយ
រមែងបន្ទោបង់និច្ចសញ្ញាបាន ។
ព្រោះហេតុនោះឯង បុគ្គលមានប្រាជ្ញាឃើញប្រយោជន៍ មិនគួរ
មើលងាយគល់ឈើដ៏ស្ងាត់ ដែលជាទីមតិករបស់ព្រះពុទ្ធ
ជាលំនៅរបស់អ្នកត្រេកអរក្រៃលែង ក្នុងភាវនា ។

គ្រានោះ សុមេធបណ្ឌិត ជាអ្នកឃើញទោសរបស់បណ្ណសាលា បាន
នូវអានិសង្សក្នុងសេនាសនៈ គឺគល់ឈើ ទើបគិតក្រៃលែងថា ការដែល
អាត្មាអញចូលទៅកាន់ស្រុកដើម្បីស្វែងរកអាហារជាទុក្ខ ក្នុងការស្វែងរកអាហារ
អាត្មាអញមិនមែនអស់អ្វីមួយ ទើបចេញបួសដើម្បីត្រូវការអាហារ តែទុក្ខ
មានការស្វែងរកអាហារជាមូលមិនមានប្រមាណ បើដូច្នោះ អញនឹងញុំាង
អត្តភាពឲ្យប្រព្រឹត្តទៅដោយផ្លែឈើដែលជ្រុះឯង តែកាលទ្រង់សម្តែងភាព
វិសេសនៃប្រយោជន៍នេះ ទើបត្រាស់គាថាជាដើមថា

តថាគតលះបង់ស្រូវដែលគេព្រោះ គេដាំ ដោយមិនសេស
សល់ កាន់យកផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណ
ច្រើនប្រការ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វាបិតំ** បានដល់ សាបព្រោះស្រេចហើយ ។
បទថា **រោបិតំ** បានដល់ ដែលស្ទូងស្រេចហើយ សម្ទូងនឹងសម្រេចផល
មាន ២ វិធី គឺដោយការសាបព្រោះ និងការស្ទូង ។ តថាគតលះបង់វិធីទាំង
២ យ៉ាង ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយផ្លែឈើដែលជ្រុះឯង ព្រោះ

អាត្មាអញជាអ្នកប្រាថ្នាតិច ។ បទថា **បវត្តផលំ** បានដល់ ផ្លៃឈើដែលជ្រុះឯង ។ បទថា **អាទិយឹ** បានដល់ បរិភោគ ។ ដូចលោកពោលថា

បុគ្គលសន្តោសដោយផ្លៃឈើ ដែលជ្រុះឯង ចិញ្ចឹមជីវិត
មិនទាក់ទងដោយអ្នកដទៃ លះនូវការលោភលន់ក្នុងអាហារ
រមែងជាមុនីក្នុងទិសទាំង ៤ ។

មុនីរមែងលះនូវចំណង់ក្នុងរស ទើបការចិញ្ចឹមជីវិតរបស់
លោកបរិសុទ្ធ ព្រោះហេតុនោះឯង ទើបមិនគួរមើលងាយ
ការបរិភោគផ្លៃឈើដែលជ្រុះឯង ដូច្នេះ ។

សុមេធបណ្ឌិត កាលប្រព្រឹត្តយ៉ាងនេះ មិនយូរប៉ុន្មានក៏បានសមាបត្តិ ៨ និងអភិញ្ញា ៥ ខាងក្នុង ៧ ថ្ងៃ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសេចក្តីនេះ ទើបត្រាស់ថា **តត្ថប្បធានំ បទហឹ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងអាស្រមនោះ ។ បទថា **បធានំ** បានដល់ សេចក្តីព្យាយាម ។ ពិតហើយ សេចក្តីព្យាយាម លោកហៅថា **បធាន** ព្រោះជាគុណគួរតាំងទុក ឬព្រោះធ្វើនូវភាវៈ គឺការតាំងទុក ។ បទថា **បទហឹ** បានដល់ ផ្តើមសេចក្តីព្យាយាម ។ បទថា **និសជ្ជដ្ឋាន-បង្កមេ** បានដល់ ដោយការអង្គុយ ការឈរ និងការដើរ ។

សុមេធបណ្ឌិតបដិសេធការដេក ញុំាំងយប់ និងថ្ងៃឲ្យកន្លងទៅ ដោយការអង្គុយ ការឈរ និងការដើរប៉ុណ្ណោះ ទើបសម្រេចកម្លាំង គឺអភិញ្ញាបានខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ។ កាលសុមេធតាបសសម្រេចកម្លាំង គឺអភិញ្ញា

យ៉ាងនេះហើយ ក៏សម្ងំនៅដោយសុខក្នុងសមាបត្តិ ។ កាលនោះ ព្រះសាស្ដា ព្រះនាមទីបង្ករ ជាអ្នកធ្វើនូវការសង្គ្រោះជនទាំងពួង ទ្រង់ធ្វើភ័យដល់ពល នៃមារ ទ្រង់ធ្វើប្រទីប គឺព្រះញាណកើតឡើងក្នុងលោក ។

កាលពោលដោយសង្ខេបប៉ុណ្ណោះ ការពោលលំដាប់រឿងព្រះពុទ្ធអង្គ នោះ មានដូច្នេះ បានឮថា ព្រះមហាសត្វព្រះនាមទីបង្ករអង្គនេះ ទ្រង់បំពេញ នូវបារមី ៣០ ទ្រង់តាំងនៅក្នុងអត្តភាព ដូចអត្តភាពរបស់ព្រះវេស្សន្តរ ទ្រង់ ឲ្យមហាទាន ជាហេតុឲ្យផែនដីញាប់ញ័រជាដើម កាលអស់ព្រះជន្មាយុ ក៏ កើតក្នុងស្ថានសួគ៌ជាន់តុសិត ទ្រង់តាំងនៅក្នុងទីនោះ ដរាបដល់អស់ព្រះ ជន្មាយុ កាលទេវតាក្នុងម៉ឺនចក្កវាឡ ប្រជុំគ្នាទូលថា

> បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ គួរដល់ព្រះអង្គ
> ហើយ សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្ស-
> លោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន
> ឈ្មោះអតមៈ ដូច្នេះ ។

ដូច្នេះហើយ កាលទ្រង់ស្ដាប់ពាក្យរបស់ទេវតាទាំងឡាយហើយ ទ្រង់ ពិចារណាមហាវិលោកនៈ ៥ ទ្រង់ចុតិចាកតុសិតសួគ៌នោះហើយ ទ្រង់ បដិសន្ធិដោយផ្កាយនក្ខត្តឫក្ស ក្នុងខែអាសាឍ គឺ ១៥ កើត ខែអាសាឍ ក្នុងព្រះឧទររបស់ព្រះនាងសុមេធាទេវី ក្នុងត្រកូលរបស់ព្រះរាជា ព្រះនាម សុទេវៈ ដែលជាទេវៈនៃនរជន ដូចស្ដេចវិជិតវាសុទេព នៃព្រះយសរបស់ ព្រះអង្គ ក្នុងនគរអមរវតី មានរាជបរិវារធំចាំថែរក្សា ទ្រង់មិនប្រឡាក់ដោយ

របស់ស្មោកគ្រោកណាមួយ ក្នុងព្រះឧទររបស់ព្រះមហាទេវី ដូចដុំកែវមណី គ្រប់ទសមាស ក៏ប្រសូតចាកព្រះឧទររបស់ព្រះនាង ដូចព្រះចន្ទក្នុងសរទ-រដូវ គោចរក្នុងស្រទាប់ពពក ។

## បុព្វនិម្មិត ៣២ ប្រការ

បាដិហារ្យ ៣២ ប្រការ ដែលជារបស់ព្រះទីបង្ករាជកុមារអង្គនោះ បានប្រាកដហើយ ទាំងក្នុងខណៈបដិសន្ធិ ទាំងក្នុងខណៈប្រសូត បាដិហារ្យ ៣២ ប្រការ ប្រព្រឹត្តទៅក្នុងឋានៈទាំង ៤ នេះ គឺកាលព្រះសព្វញ្ញុពោធិសត្វ គ្រប់អង្គ ចុះកាន់គភ៌របស់ព្រះមាតា ១ ប្រសូត ១ ត្រាស់ដឹង ១ ប្រកាសនូវធម្មចក្រ ១ ព្រោះហេតុនោះ ទើបខ្ញុំសម្ដែងបាដិហារ ៣២ ក្នុងការប្រសូតិរបស់ព្រះទីបង្ករាជកុមារ ព្រោះជារបស់ប្រាកដហើយដូច្នេះថា

កាលព្រះទីបង្ករាជកុមារ ជាអ្នកធ្វើនូវអំពើស្អាត ជាអ្នកធ្វើសេចក្ដីចម្រើន ជាអ្នកធ្វើនូវការស្ងប់ ប្រសូតហើយ ក្នុងកាលនោះ ម៉ឺនលោកធាតុក៏ញាប់ញ័រដោយជុំវិញ ។

កាលនោះ ទេវតាក្នុងម៉ឺនចក្កវាឡ ក៏នាំគ្នាប្រជុំក្នុងចក្កវាឡមួយ ។

លុះព្រះមហាសត្វដែលជាពោធិសត្វប្រសូត ទេវតាទាំងឡាយ ក៏ទទួលមុន ក្រោយមក ទើបពួកមនុស្សទទួលក្រោយ ។

ខណៈនោះ ស្គរតូច និងស្គរធំទាំងឡាយ ពិណទាំងឡាយដែលបុគ្គលណាមួយមិនបានប្រគំ គ្រឿងអាភរណៈទាំងឡាយ ដែលបុគ្គលណាមួយមិនបានពាល់ត្រូវ បញ្ចេញសំឡេងយ៉ាងពីរោះដោយជុំវិញ ។

ចំណងទាំងឡាយគ្រប់យ៉ាង ក៏ដាច់របូតទៅ រោគភ័យទាំងពួង ក៏ស្ងប់ទៅ មនុស្សខ្វាក់អំពីកំណើត ក៏មើលឃើញរូបទាំងឡាយ មនុស្សថ្លង់ ក៏បានឮសំឡេងជុំវិញខ្លួន ។

បុគ្គលល្ងីល្ងើអំពីកំណើត ក៏បាននូវសតិរឭកបាន បុគ្គលជើងពិការ ក៏ប្រើជើងដើរបាន ទូកដែលទៅតាមប្រទេសដទៃ ក៏ត្រឡប់មកកាន់កំពង់សុបដ្ដនៈឯង បានយ៉ាងរហ័ស ។

រតនៈគ្រប់យ៉ាង ទាំងនៅក្នុងអាកាស ទាំងនៅលើផែនដី ក៏មានពន្លឺដោយជុំវិញ ភ្លើងក្នុងនរកដ៏ពន្លឹកក៏រលត់ ទឹកក្នុងស្ទឹងទាំងឡាយក៏មិនហូរ ។

ពន្លឺដ៏ឱឡារបរិបូណ៌ ក៏មានក្នុងលោកន្តរិកនរក ដែលមានទុក្ខមិនមានចន្លោះ គ្រានោះ មហាសមុទ្រក៏មានរលកស្ងប់ ទឹកក៏មានរសសាបឆ្ងាញ់ ។

ខ្យល់ដែលបក់ខ្លាំងក្លា ក៏មិនបក់ ដើមឈើទាំងឡាយ ក៏ចេញផ្ការីកស្គុះស្គាយ ព្រះចន្ទ មួយអន្លើដោយផ្កាយ ក៏ភ្លឺច្បាស់ក្រៃលែង ព្រះអាទិត្យក៏មិនបញ្ចេញកម្ដៅ ។

ហ្វូងបក្សីត្រេកអរ ចុះអំពីអាកាស និងដើមឈើ មកកាន់ផែនដីខាងក្រោម ភ្លៀងធ្លាក់ក្នុងទ្វីបទាំង ៤ ទឹកភ្លៀងក៏មានរសឆ្ងាញ់ដោយជុំវិញ ។

ទេវតាទាំងឡាយនៅក្នុងទិព្វដ្ឋានរបស់ខ្លួន មានចិត្តជ្រះថ្លា ក៏នាំគ្នារាំច្រៀង ប្រគំ ស្រែកហ៊ោខ្ទរខ្ទារ ។

បានឮថា ក្នុងខណៈនោះ ទ្វារតូច និងទ្វារធំ ក៏បើកឯង បានឮថា ការស្រេកឃ្លាន មិនបានកើតឡើងដល់មហាជន ឬសត្វលោកណាឡើយ ។

ឯពួកសត្វ ដែលមានពៀរនឹងគ្នាជានិច្ច ក៏បាននូវមេត្តាចិត្តយ៉ាងក្រៃលែង ហ្វូងក្អែកក៏ត្រាច់ទៅជាមួយហ្វូងមៀម ហ្វូងខ្លែងព្រៃក៏រាក់ទាក់ជាមួយហ្វូងជ្រូក ។

ពស់មានពិសក្តី មិនមានពិសក្តី ក៏យកក្បាលជល់គ្នាជាមួយស្ការទាំងឡាយ ពួកកណ្តុរមានចិត្តស្និទ្ធស្នាល ក៏ប្រលែងជាមួយឆ្មា ។

ការស្រេកទឹកក្នុងលោករបស់បិសាច ដែលមិនបានទឹកមកអស់មួយពុទ្ធន្តរក៏ស្ងប់ទៅ មនុស្សគម ក៏មានរាងកាយសមសួន មនុស្ស-គនិយាយបានយ៉ាងពីរោះ ។

ឯពួកសត្វដែលមានចិត្តជ្រះថ្លា ក៏ពោលបិយវាចាជល់គ្នានិងគ្នា ពួកសេះមានចិត្តត្រេកអរ ក៏កញ្ច្រៀវ ពួកដំរីចុះប្រេង ក៏បន្លឺសំឡេងដូចសត្វក្រៀល ។

លោកធាតុមួយម៉ឺនដោយជុំវិញ ដេរដាសដោយលម្អិតខ្លឹមចន្ទន៍ក្រអូបឈ្ងុយឈ្ងប់ដោយក្លិនផ្កា ក្លិនស្បូវក្លាំង និងធូប មានកម្រងផ្កា និងទង់ជ័យលម្អផ្សេងៗ ។

ក្នុងបាដិហារ្យទាំង ៣២ ប្រការនោះ ការញាប់ញ័រនៃលោកធាតុទាំងមួយម៉ឺន ជាបុព្វនិមិត្តនៃការបានសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ នេះជាបុព្វ-និមិត្តទី ១ ។

ការដែលទេវតាទាំងឡាយមកប្រជុំគ្នាក្នុងចក្កវាឡតែមួយ ជាបុព្វនិមិត្តនៃការប្រជុំព្រមគ្នាទទួលនូវធម៌ ក្នុងកាលដែលទ្រង់សម្តែងធម្មចក្ក នេះជាបុព្វនិមិត្តទី ២ ។

ការដែលទេវតាទាំងឡាយទទួលមុន ជាបុព្វនិម្មិតនៃការបានរូបាវចរជ្ឈាន ៤ នេះជាបុព្វនិម្មិតទី ៣ ។

ការដែលមនុស្សទាំងឡាយ ទទួលក្នុងកាលឯក្រោយ ជាបុព្វនិម្មិតនៃការបានអរូបាវចរជ្ឈាន ៤ នេះជាបុព្វនិម្មិតទី ៤ ។

ការប្រគំឯង របស់ស្គរតូច និងស្គរធំទាំងឡាយ ជាបុព្វនិម្មិតនៃការញុំាងមហាជនឲ្យបានឮសំឡេងមហាធម្មភេរី នេះជាបុព្វនិម្មិតទី ៥ ។

ការប្រគំនៃពិណឯង និងសំឡេងអាភរណៈ ជាបុព្វនិម្មិតនៃការបានអនុបុព្វវិហារសមាបត្តិ នេះជាបុព្វនិម្មិតទី ៦ ។

ការដែលចំណងជាច់របូតឯង ជាបុព្វនិម្មិតនៃការកាត់អស្មិមានះ នេះជាបុព្វនិម្មិតទី ៧ ។

ការប្រាសចាករោគសព្វយ៉ាងរបស់មហាជន ជាបុព្វនិម្មិតនៃការបានផលនៃសច្ចៈ ៤ នេះជាបុព្វនិម្មិតទី ៨ ។

ការឃើញរូប របស់អ្នកខ្វាក់អំពីកំណើត ជាបុព្វនិម្មិតនៃការបានទិព្វចក្ខុ នេះជាបុព្វនិម្មិតទី ៩ ។

ការបានឮសំឡេងរបស់អ្នកថ្លង់ ជាបុព្វនិម្មិតនៃកាបានទិព្វសោតធាតុ នេះជាបុព្វនិម្មិតទី ១០ ។

ការកើតអនុស្សតិរបស់មនុស្សល្ងីល្ងើអំពីកំណើត ជាបុព្វនិម្មិតនៃការបានសតិប្បដ្ឋាន ៤ នេះជាបុព្វនិម្មិតទី ១១ ។

ការដើរបានដោយជើងរបស់មនុស្សខ្វិន ជាបុព្វនិម្មិតនៃការបានឥទ្ធិបាទ

៤ នេះជាបុព្វនិមិត្តទី ១២ ។

ការត្រឡប់មកឯង កាន់កំពង់សុបដ្ឋនៈរបស់ទូក ជាបុព្វនិមិត្តនៃការបានបដិសម្ភិទា ៤ នេះជាបុព្វនិមិត្តទី ១៣ ។

ការរុងរឿងឯង នៃរតនៈទាំងឡាយ ជាបុព្វនិមិត្តនៃការបានពន្លឺក្នុងធម៌ នេះជាបុព្វនិមិត្តទី ១៤ ។

ការរលត់នៃភ្លើងនរក ជាបុព្វនិមិត្តនៃការរម្ងត់នូវភ្លើង ១១ កង នេះជាបុព្វនិមិត្តទី ១៥ ។

ការមិនហូរទៅនៃទឹកស្ទឹងទាំងឡាយ ជាបុព្វនិមិត្តនៃការបានចតុវេសារជ្ជញ្ញាណ នេះជាបុព្វនិមិត្តទី ១៦ ។

លោកន្តរនរកភ្លឺស្វាង ជាបុព្វនិមិត្តនៃការកម្ចាត់ងងឹត គឺអវិជ្ជា ហើយឃើញពន្លឺដោយញាណ នេះជាបុព្វនិមិត្តទី ១៧ ។

មហាសមុទ្រមានទឹកឆ្ងាញ់ ជាបុព្វនិមិត្តនៃធម្មវិន័យមានរសតែមួយ គឺព្រះនិព្វាន នេះជាបុព្វនិមិត្តទី ១៨ ។

ការមិនបក់បោកនៃខ្យល់ ជាបុព្វនិមិត្តនៃការទម្លាយទិដ្ឋិ ៦២ នេះ ជាបុព្វនិមិត្តទី ១៩ ។

ការៈដែលឈើទាំងឡាយចេញផ្ការីកស្គុះស្គាយ ជាបុព្វនិមិត្តនៃធម្មវិន័យ ចេញផ្ការីកស្គុះស្គាយ ដោយផ្កា គឺវិមុត្តិ នេះជាបុព្វនិមិត្តទី ២០ ។

ការបញ្ចេញពន្លឺដ៏ក្រៃលែងរបស់ព្រះចន្ទ ជាបុព្វនិមិត្តនៃភាពដែលព្រះសាស្តា ជាទីស្រឡាញ់របស់ជនច្រើន នេះជាបុព្វនិមិត្តទី ២១ ។

ការៈដែលព្រះអាទិត្យផ្សាយផង់មិនក្ដៅ ជាបុព្វនិមិត្តនៃការកើតឡើងនៃសេចក្ដីសុខកាយ សុខចិត្ត នេះជាបុព្វនិមិត្តទី ២២ ។

ការហើរចុះពីអាកាសមកកាន់ផែនដីរបស់ហ្វូងបក្សី ជាបុព្វនិមិត្តនៃការស្ដាប់ឱវាទ ហើយដល់សរណៈស្មើដោយជីវិតរបស់មហាជន នេះជាបុព្វ-និមិត្តទី ២៣ ។

ការធ្លាក់ចុះមកនៃភ្លៀងធំ ដែលប្រព្រឹត្តទៅក្នុងទ្វីបទាំង ៤ ជាបុព្វនិមិត្តនៃភ្លៀង គឺព្រះធម៌ដ៏ធំ នេះជាបុព្វនិមិត្តទី ២៤ ។

ការនៅក្នុងភពរៀងៗ ខ្លួន ត្រេកអរដោយការរាំជាដើមរបស់ទេវតាទាំងឡាយ ជាបុព្វនិមិត្តនៃការត្រាស់ដឹងជាព្រះពុទ្ធ ហើយទ្រង់បន្លឺឧទាន នេះជាបុព្វនិមិត្តទី ២៥ ។

ការបើកឯងនៃទ្វារតូច និងទ្វារធំ ជាបុព្វនិមិត្តនៃការបើកទ្វារ គឺមគ្គមានអង្គ ៨ នេះជាបុព្វនិមិត្តទី ២៦ ។

ការមិនមាននូវការឃ្លាន ជាបុព្វនិមិត្តនៃការបានអមតៈ ដោយកាយគតាសតិ នេះជាបុព្វនិមិត្តទី ២៧ ។

ការមិនមានសេចក្ដីស្រេក ជាបុព្វនិមិត្តនៃការមានសេចក្ដីសុខ ដោយសុខក្នុងវិមុត្តិ នេះជាបុព្វនិមិត្តទី ២៨ ។

ការបាននូវមេត្តាចិត្តនៃបុគ្គល ដែលមានពៀរទាំងឡាយ ជាបុព្វនិមិត្តនៃការបានព្រហ្មវិហារ ៤ នេះជាបុព្វនិមិត្តទី ២៩ ។

ការដែលលោកធាតុមានទង់ជាមាល័យ ជាបុព្វនិមិត្តនៃភាពដែលព្រះ

សាសនា មានទង់អរិយៈជាមាល័យ នេះជាបុព្វនិមិត្តទី ៣០ ។

ឯបុព្វនិមិត្តវិសេសដ៏សេស គប្បីជ្រាបថា ជាបុព្វនិមិត្តនៃការបាននូវពុទ្ធគុណដ៏សេស នេះជាបុព្វនិមិត្តទី ៣១ និងទី ៣២ ។

គ្រានោះ ព្រះទីបង្ករាជកុមារទ្រង់បានបម្រើដោយសម្បត្តិធំ ទ្រង់ចម្រើនវ័យដោយលំដាប់ សោយសិរីរាជលើប្រាសាទ ៣ ខ្នង ដែលសមគួរដល់រដូវទាំង ៣ ដូចសោយសិរីក្នុងទេវលោក សម័យយាងទៅលេងកីឡាក្នុងរាជឧទ្យាន ទ្រង់ឃើញទេវទូត ៣ គឺមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់តាមលំដាប់ ទ្រង់កើតនូវការតក់ស្លុត ត្រឡប់ចូលកាន់នគរអមរវតី ដែលរុងរឿងដោយសម្បត្តិ ដូចគ្នានឹងសុទស្សនទនគរ គ្រាយាងចូលនគរហើយ ក្នុងលើកទី ៤ ទ្រង់ត្រាស់ហៅហត្ថាចារ្យសួរថា នែបាយើងនឹងចេញទៅប្រពាតឧទ្យាន ចូរបាត្រៀមយាន គឺដំរីឲ្យដល់ព្រម ហត្ថាចារ្យទទួលថា សាធុ រៀបចំដំរី ៨៤០០០ ។ គ្រានោះ ទេវបុត្ត ឈ្មោះវិស្សកម្ម ក៏ជួយប្រដាប់តាក់តែងព្រះពោធិសត្វ ដែលទ្រទ្រង់នូវសំពត់មានពណ៌ផ្សេងៗ ពាក់កងមុក្តាហារត្រង់ដើមដៃ ទ្រទ្រង់នូវកងដៃមាស ម្កុដ និងកុណ្ឌល ប្រដាប់ទៅដោយរតនៈ ៩ យ៉ាងដ៏ល្អ ព្រះមោលីប្រដាប់ដោយកម្រងផ្កាក្រអូបក្រៃលែង ។

ខណៈនោះ ព្រះទីបង្ករាជកុមារ ដែលដំរី ៨៤០០០ ចោមរោមហើយ ដូចទេវកុមារយាងឡើងកដំរី ដែលពួកពលធំ ចោមរោមហើយ យាងចូលកាន់ព្រះរាជឧទ្យាន ដែលឲ្យកើតនូវការត្រេកអរ ទ្រង់ចុះអំពីកដំរីហើយ

យានទតព្រះរាជឧទ្យាននោះ គង់ប្រថាប់លើផ្ទាំងសិលា ដែលជាទីត្រជាក់ព្រះហឫទ័យរបស់ព្រះអង្គ ល្អគួរសរសើរក្រៃលែង ទ្រង់គិតនឹងបួសក្នុងវេលានោះឯង មហាព្រហ្មជាព្រះខីណាស្រព ក្នុងជាន់សុទ្ធាវាសកាន់សមណបរិក្ខារ ៨ មកប្រាកដក្នុងគន្លងចក្ខុរបស់ព្រះមហាបុរស ។

ព្រះមហាបុរស ទ្រង់ឃើញមហាព្រហ្មខីណាស្រពនោះ ត្រាស់សួរថា នេះអ្វី ទ្រង់បានស្តាប់ថា សមណបរិក្ខារ ទ្រង់ក៏ដោះគ្រឿងប្រដាប់ប្រទានក្នុងដៃភ្នាក់ងាររក្សាឃ្លាំងគ្រឿងប្រដាប់ ទ្រង់កាន់ព្រះខ័នមង្គល កាត់ព្រះកេសាមួយអន្លើដោយព្រះមោលី ទ្រង់បោះទៅក្នុងអាកាស ។ ខណៈនោះ សក្កទេវរាជទ្រង់យកប្រអប់មាសទទួលព្រះកេសា និងព្រះមោលីនោះ ទ្រង់ធ្វើជាម្កុដចេតិយ សម្រេចដោយកែវមណីឥន្ទនិល ទំហំ ៣ យោជន៍ លើកំពូលភ្នំសិនេរុ ។ កាលនោះ ព្រះមហាបុរសទ្រង់គ្រងនូវសំពត់កាសាវៈ ដែលជាទង់ជ័យនៃអរហត្ត ដែលទេវតាថ្វាយ ទ្រង់បោះគូសំពត់ទៅក្នុងអាកាស ព្រហ្មក៏ទទួលសំពត់នោះ យកទៅធ្វើចេតិយ ដែលសម្រេចដោយរតនៈ ទំហំ ១២ យោជន៍ ក្នុងព្រហ្មលោក ។ បុរសមួយកោដិ បួសតាមព្រះទីបង្កររាជកុមារដែលកំពុងព្រះផ្នួស ព្រះពោធិសត្វ ដែលបរិស័ទនោះ ចោមរោមហើយ បានបំពេញបធានចរិយា ប្រព្រឹត្តសេចក្តីព្យាយាមអស់ ១០ ខែតមក ក្នុងថ្ងៃ ១៥ កើត ខែពិសាខ ទ្រង់ចូលទៅបិណ្ឌបាត កាន់នគរមួយកន្លែង ។

បានឮថា មនុស្សទាំងឡាយក្នុងនគរនោះ ដាំមធុបាយាសមិនមានទឹក

ដើម្បីធ្វើពលិកម្មទេវតាក្នុងថ្ងៃនោះ តែមនុស្សទាំងឡាយ បានថ្វាយដល់ព្រះមហាសត្វអង្គនោះ មួយអន្លើដោយបរិស័ទដែលយាងចូលទៅបិណ្ឌបាត មធុ-បាយាសមិនមានទឹក ក៏គ្រប់គ្រាន់ដល់ភិក្ខុរាប់កោដិ តែក្នុងបាត្ររបស់ព្រះមហាបុរស ទេវតាទាំងឡាយដាក់ទិព្វឱជៈចូលទៅ ព្រះមហាបុរស កាលសោយនូវមធុបាយាសនោះហើយ ទ្រង់ក៏សម្រាកពេលថ្ងៃ ក្នុងព្រៃសាលៈក្នុងព្រះរាជឧទ្យាននោះឯង វេលាល្ងាច ទ្រង់ចេញអំពីទីសម្ងំហើយ ទ្រង់លះគណៈ ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអាជីវកឈ្មោះសុទន្ទថ្វាយ ហើយយាងទៅកាន់គល់ឈើសម្រាប់ត្រាស់ដឹង ឈ្មោះបិប្ផលិ គឺដើមល្វៀប ។ ទ្រង់ក្រាលស្មៅប្រថាប់គង់ពត់ភ្នែន យកខ្នងទៅរកឈើសម្រាប់ត្រាស់ដឹង ដែលមានកម្ពស់ ៩០ ហត្ថ ទ្រង់អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ គង់ប្រថាប់ត្រង់គល់ពោធិព្រឹក្ស បន្ទាប់អំពីនោះ ទ្រង់កម្ចាត់ពលមារ ក្នុងរាត្រីបឋមយាម ទ្រង់រឮកបុព្វេនិវាសញ្ញាណ ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងបច្ឆិមយាម ទ្រង់ពិចារណាបច្ចយាការដោយអនុលោម និងបដិលោម ទ្រង់ចូលចតុត្ថជ្ឈាន មានអានាបានស្សតិជាអារម្មណ៍ ចេញអំពីចតុត្ថជ្ឈាននោះហើយ ទ្រង់ញ៉ាំងញាណឲ្យឈមចុះក្នុងខន្ធ ៥ ទ្រង់ឃើញលក្ខណៈដោយបញ្ញា ដោយបញ្ញាដ៏ប្រព្រៃ ដោយឧទយព្វយញ្ញាណ ទ្រង់ចម្រើនវិបស្សនារហូតដល់គោត្រភូញាណ លុះអរុណឧទ័យ ទ្រង់ក៏សម្រេចពុទ្ធគុណទាំងអស់ដោយអរិយមគ្គ ទ្រង់បន្លឺពុទ្ធសីហនាទ ទ្រង់សម្ងំក្បែរដើមពោធិ-ព្រឹក្សអស់ ៧ សប្តាហ៍ ទ្រង់ប្រកាសធម្មចក្រ ក្នុងសុនន្ទារាម ដោយទ្រង់

បេ្ជាទទួលអារាធនាសម្តែងធម៌របស់ព្រហ្ម ទ្រង់ញុំាងទេវតា និងមនុស្ស ១ ឃោដិឲ្យផឹកនូវអមតធម៌ ទ្រង់ញុំាងភ្លៀង គឺធម៌ ដូចមហាមេឃទាំង ៤ ទ្វីប ឲ្យបង្អុរចុះ ទ្រង់ចរិកទៅកាន់ជនបទ ដោះនូវមហាជនឲ្យផុតចំណង ។

បានឮថា គ្រានោះ សុមេធបណ្ឌិតសម្ងំដោយសុខក្នុងសមាបត្តិ មិនឃើញនិម្មិតទាំងនោះ មិនឃើញការកម្រើកផែនដី និងមិនឃើញនិម្មិតទាំងនោះ ដោយហេតុនោះ ទើបត្រាស់ថា

កាលតថាគតសម្រេចអភិញ្ញាហើយ ជាអ្នកមានវសី ក្នុងសាសនានៃតាបស កាលនោះ ព្រះជិនស្រីព្រះនាមទីបង្ករ ជានាយកនៃលោក ទ្រង់កើតឡើង ។ កាលព្រះពុទ្ធ ចាប់បដិសន្ធិផង ប្រសូតផង កាលត្រាស់ដឹងផង សម្តែងធម្មចក្រផង តថាគតជាអ្នកផ្អែតស្កប់ស្កល់ដោយសេចក្តីត្រេកអរ ក្នុងឈាន ប៉ុន្តែ មិនបានឃើញនូវនិមិត្តទាំង ៤ ឡើយ ដូច្នេះ ។

ទ្រង់សម្តែងពាក្យដែលគប្បីត្រាស់ក្នុងឥឡូវនេះ ដោយបទថា **ឃរំ** ក្នុងគាថានោះ ។ បទថា **មេ** កែជា **មម** ។ បទថា **សិទ្ធិបត្តស្ស** បានដល់ ដល់នូវសេចក្តីសម្រេចនៃអភិញ្ញា ៥ ។ បទថា **វសីភូតស្ស** បានដល់ ជាអ្នកជំនាញហើយ អធិប្បាយថា ដល់នូវភាពជាអ្នកជំនាញ ។ បទថា **សាសនេ** បានដល់ ក្នុងសាសនានៃតាបស ដែលអាស្រ័យការស្ងាត់ ។ គប្បីឃើញថា ឆដ្ឋីវិភត្តិ ប្រើក្នុងលក្ខណៈអនាទរ ។ បទថា **ជិនោ** មានវិគ្គហៈថា ឈ្មោះថា **ជិន** ព្រោះឈ្នះសត្រូវ គឺកិលេស ។

បទថា **ឧប្បជ្ជន្តេ** បានដល់ ក្នុងការចាប់បដិសន្ធិ ។ បទថា **ជាយន្តេ** បានដល់ ក្នុងការប្រសូតិចាកផ្ទៃព្រះមាតា ។ បទថា **ពុជ្ឈន្តេ** បានដល់ ក្នុងការត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ។ បទថា **ធម្មទេសនេ** បានដល់ ក្នុងការប្រកាសធម្មចក្រ ។ បទថា **ចតុរោ និមិត្តេ** កែជា **ចត្តារិ និមិត្តា** ។ អធិប្បាយថា និមិត្ត មានម៉ឺនលោកធាតុញាប់ញ័រជាដើម ក្នុងឋានៈ ៤ គឺ បដិសន្ធិ ប្រសូត ត្រាស់ដឹង និងប្រកាសធម្មចក្រ ។ អ្នកចោទសួរក្នុងសេចក្តីនេះពោលថា និមិត្តទាំងនោះ មានច្រើន ហេតុអ្វី ទើបត្រាស់ថា និមិត្ត ៤ មិនត្រឹមត្រូវ មិនមែនឬ ឆ្លើយថា មិនមែនមិនត្រឹមត្រូវ ព្រោះនិមិត្តទាំងនោះសូម្បីមានច្រើន តែត្រាស់ថា និមិត្ត ៤ ព្រោះប្រព្រឹត្តទៅក្នុងឋានៈ ៤ ។ បទថា **នាទ្ទសំ** កែជា **នាទ្ទសឹ** ។ ឥឡូវនេះ កាលទ្រង់សម្តែងហេតុក្នុងការមិនឃើញនិមិត្ត ៤ នោះ ទើបត្រាស់ថា **ឈានរតិសមប្បិតោ** ។ បទថា **ឈានរតិ** នេះ ជាឈ្មោះនៃសេចក្តីសុខក្នុងសមាបត្តិ អធិប្បាយថា មិនបានឃើញនិមិត្តទាំងនោះ ព្រោះដល់ព្រមដោយការត្រេកអរក្នុងឈាន ។

សម័យនោះ ព្រះទីបង្ករទសពល ដែលព្រះខីណាស្រព ៤ សែនចោមរោមហើយ ទ្រង់យាងចារិកទៅតាមលំដាប់ ដល់នគរឈ្មោះរម្មៈ ជាទីគួរត្រេកអរក្រៃលែង ប្រថាប់នៅក្នុងសុទស្សនមហាវិហារ ។ អ្នករម្មនគរបានដំណឹងថា បានឮថា ព្រះទីបង្ករទសពល ទ្រង់សម្រេចអនុត្តរសម្មាសម្ពោ-ធិញ្ញាណ ប្រកាសនូវធម្មចក្រដ៏ប្រសើរ ហើយយាងចារិកមកដោយលំដាប់ ដល់រម្មនគរ ហើយគង់នៅក្នុងសុទស្សនមហាវិហារ ក៏កាន់យកភេសជ្ជៈ មាន

សប្បិជាដើម បរិភោគអាហារព្រឹកហើយ ដណ្តប់សំពត់ស្អាត កាន់ផ្កា ធូប និងគ្រឿងក្រអូប ចូលទៅគាល់ព្រះពុទ្ធ កាលគាល់ក្នុងទីដែលព្រះពុទ្ធគង់នៅ កាលចូលគាល់ហើយ ក៏ថ្វាយបង្គំ បូជាដោយផ្កាជាដើម អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ស្តាប់ធម្មកថាដ៏ពីរោះក្រៃលែង និមន្តព្រះមានព្រះភាគ ដើម្បីសោយក្នុងថ្ងៃស្អែក ក្រោកចាកទីអង្គុយហើយ ធ្វើប្រទក្សិណព្រះទសពល ហើយត្រឡប់ទៅ ។

ស្អែកឡើង អ្នកនគរទាំងនោះ ក៏រៀបចំអសទិសមហាទាន សាងមណ្ឌប ដែលប្រក់ដោយផ្កាឈូកដែលឥតមន្ទិល និងគួរស្រឡាញ់ ប្រោះព្រំដោយគ្រឿងក្រអូប ៤ ប្រភេទ រោយដោយផ្កាក្រអូប មានលាជជាគម្រប់ ៥ តម្កល់ក្អមដែលពេញដោយទឹកត្រជាក់ មានរសឆ្ងាញ់ក្នុងជ្រុងទាំង ៤ នៃមណ្ឌប គ្របដោយស្លឹកចេក ចងពិតានសំពត់ ល្អគួរមើលក្រៃលែង ដូចផ្កាច្បាលើមណ្ឌប ប្រដាប់ដោយផ្កាយមាស ផ្កាយកែវមណី និងផ្កាយប្រាក់ សំយុងគ្រឿងប្រអូប កម្រងផ្កា កម្រងស្លឹកឈើ និងកម្រងរតនៈ ធ្វើថ្ងៃអាប់អួឲ្យក្លិស្រឡូះដោយធូបទាំងឡាយ និងធ្វើរម្មនគរដែលគួរជាទីត្រេកអរនោះ ឲ្យស្អាតទូទៅពេញព្រះនគរ តាំងដើមចេក ព្រមទាំងផ្លែ និងថ្នាំងពេញដោយទឹក ប្រដាប់ដោយផ្កា និងលើកទង់ជ្វាលាច្រើនពណ៌ ព័ទ្ធដោយកំពែងវាំងននសងខាងផ្លូវធំ តាក់តែងផ្លូវយាងមករបស់ព្រះទីបង្ករទសពល បំពេញដីត្រង់ទីទឹកប្រោះ លុបត្រង់ភក់ ធ្វើទីមិនរាបស្មើឲ្យរាបស្មើ រោយដោយខ្សាច់ដូចកែវមុក្តា រោយដោយផ្កា មានលាជជាគម្រប់ ៥ រៀបចំផ្លូវ ដែលមានដើម

ចេក ដើមស្វា មួយអន្ទើដោយផ្លែ ។

សម័យនោះ សុមេធតាបសចេញអំពីអាស្រមរបស់ខ្លួន ហោះទៅតាមអាកាស ខាងលើអ្នកស្រុករម្មនគរទាំងនោះ ឃើញពួកអ្នកស្រុកកំពុងត្រេកអរ កំពុងធ្វើផ្លូវ និងតាក់តែងផ្លូវ ក៏គិតថា ហេតុអ្វីហ្ន៎ ទើបចុះពីអាកាស ទាំងដែលមនុស្សកំពុងឃើញ ឈរក្នុងទីសមគួរ នាចំណែកម្ខាង សួរមនុស្សទាំងនោះថា អ្នកដ៏ចម្រើន ពួកអ្នកធ្វើផ្លូវនេះ ដើម្បីប្រយោជន៍ដល់អ្នកណា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ពួកមហាជន ក្នុងបច្ចន្តប្រទេស មានចិត្តត្រេកអរ និមន្តព្រះ
តថាគត បាននាំគ្នាជម្រះផ្លូវជាទីមកនៃព្រះតថាគតនោះ ។
សម័យនោះឯង តថាគតចេញអំពីអាស្រមរបស់ខ្លួន កាល
រលាស់ចីវរសម្បកឈើ ហោះទៅឯអាកាស តថាគតឃើញ
ជនកំពុងតែពេញចិត្ត ត្រេកអរ ស្រស់ស្រាយ រីករាយ ក៏ចុះ
អំពីអាកាស ហើយសួរមនុស្សទាំងឡាយ ក្នុងខណៈនោះថា
មហាជនត្រេកអរ ស្រស់ស្រាយ រីករាយពេញចិត្ត ជម្រះផ្លូវ
គន្លងប្រឡាយ ដើម្បីអ្នកណា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បច្ចន្តទេសវិសយេ** បានដល់ ជនបទដែលគេយល់ថា បច្ចន្តប្បទេស នៅក្បែរមជ្ឈិមបទេសនោះឯង ។ បទថា **តស្ស អាគមនំ មគ្គំ** សេចក្ដីថា ផ្លូវដែលទ្រង់គប្បីយាងមក ។ បទថា **អហំ តេន សមយេន** បានដល់ ក្នុងសម័យនោះ តថាគត ។ បទថា **សមយេន** នេះ

ជាតតិយាវិភត្តិ គប្បីឃើញថា ចុះក្នុងអត្ថសត្តមីវិភត្តិ ។ បទថា **សកស្សមា** បានដល់ ចេញអំពីអាស្រមបទរបស់ខ្លួន ។ បទថា **ធុនន្តោ** គឺរលាស់ ។ គប្បីជ្រាបថា ពីរបទនេះថា **តេន សមយេន** និង **តទា** ភ្ជាប់សេចក្តីជាមួយកិរិយាថា ចេញទៅ របស់បទដើម និងកិរិយាទៅរបស់បទក្រោយ ព្រោះមានសេចក្តីដូចគ្នា ។ ក្រៅអំពីនេះ ក៏មិនផុតទោស គឺការពោលដដែល ។ បទថា **តទា** បានដល់ ក្នុងសម័យនោះ ។ បទថា **វេទជាតំ** បានដល់ កើតសោមនស្សឯង ។ ៣ បទនេះថា **តុដ្ឋហដ្ឋំ បមោទិតំ** ជាវេវចនៈនៃគ្នានិងគ្នា សម្តែងសេចក្តីរបស់គ្នានិងគ្នា ម្យ៉ាងទៀត ត្រេកអរដោយសុខ ត្រេកអរដោយបីតិ ត្រេកអរដោយបាមោជ្ជ ។ បទថា **ឱរោហិត្វាន** កែជា **ឱតរិត្វា** ( ចុះ ) ។ បទថា **មនុស្សេ បុច្ឆិ** កែជា **មានុសេ បុច្ឆិ** ( សួរមនុស្សទាំងឡាយ ) ឬបាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **តាវទេ** គឺកាលនោះ អធិប្បាយថា ខណៈនោះឯង ។ ឥឡូវនេះ ដើម្បីសម្តែងនូវពាក្យសួរ ទើបត្រាស់ថា ស្រស់ស្រាយ ត្រេកអរ រីករាយជាដើម ក្នុងពាក្យនោះ គប្បីនាំសព្ទថា **សោធេតិ** មកប្រកបសេចក្តីយ៉ាងនេះថា មហាជននេះ ត្រេកអរហើយ មានចិត្តត្រេកអរហើយ រមែងក្លារផ្លូវ ព្រោះហេតុអ្វី ទើបក្លារផ្លូវ ឬថា ក្លារផ្លូវដើម្បីជាប្រយោជន៍ដល់អ្នកណា ។ សេចក្តីក្រៅអំពីនេះ មិនត្រឹមត្រូវ ។ បទថា **សោធីយតិ** បានដល់ ធ្វើនូវការសម្អាត ។ បទទាំងនេះថា **មគ្គោ អញ្ជសំ វដុមាយនំ** ជាវេវចនៈនៃពាក្យថា ផ្លូវនោះឯង ។

មនុស្សទាំងនោះ ត្រូវសុមេធតាបសនោះ សួរយ៉ាងនេះហើយ ទើប

ឆ្លើយថា បពិត្រសុមេធ លោកមិនដឹងអ្វីឬ ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់បាន សម្រេចអនុត្តរសម្មាសម្ពោធិញ្ញាណ ប្រកាសធម្មចក្រដ៏ប្រសើរ យាងចារិក ទៅក្នុងជនបទ មកដល់នគររបស់ពួកយើង ប្រថាប់នៅក្នុងសុទស្សនមហា-វិហារ ពួកយើងនិមន្តព្រះមានព្រះភាគអង្គនោះ ទើបនាំគ្នាធ្វើផ្លូវយាងមក របស់ព្រះមានព្រះភាគសម្ពុទ្ធអង្គនោះ ។ លំដាប់នោះ សុមេធបណ្ឌិតស្តាប់ ពាក្យនោះហើយ គិតថា សូម្បីពាក្យថា **ពុទ្ធោ** ក៏ឮបានដោយក្រ នឹងពោល ថ្វីដល់ការកើតឡើងរបស់ព្រះពុទ្ធ បើដូច្នោះ អញនឹងរួមជាមួយមនុស្សទាំង នេះ ធ្វើផ្លូវ ក៏គួរពិត ។ ទើបលោកពោលនឹងមនុស្សទាំងនោះថា អ្នកដ៏ ចម្រើន បើពួកអ្នកធ្វើផ្លូវនេះ ដើម្បីជាប្រយោជន៍ដល់ព្រះពុទ្ធសោត ក៏ចូរឲ្យ ឱកាសមួយកន្លែងដល់ខ្ញុំ ខ្ញុំនឹងរួមជាមួយពួកអ្នក ជួយធ្វើផ្លូវដើម្បីជាប្រយោជន៍ ដល់ព្រះពុទ្ធ ពួកមនុស្សទាំងនោះក៏ទទួលថា សាធុ កាលដឹងថា សុមេធ-បណ្ឌិតមានឫទ្ធិច្រើន មានអានុភាពច្រើន ទើបកំណត់ឱកាសមួយកន្លែងឲ្យ ដែលធ្វើមិនទាន់ល្អ ត្រូវទឹកច្រោះ ទាបខ្ពស់ខ្វាំង ប្រគល់ឲ្យដោយពោលថា សូមលោកម្ចាស់ធ្វើត្រង់នេះ ហើយតាក់តែងលម្អផង ។ សុមេធបណ្ឌិតកើត នូវបីតិ មានពុទ្ធគុណជាអារម្មណ៍ គិតថា អញអាចធ្វើឱកាសត្រង់នេះ ឲ្យគួរ ជាទីត្រេកអរក្រៃលែងបានដោយឫទ្ធិ តែបើធ្វើយ៉ាងនោះ ក៏មិនជាទីពេញចិត្ត របស់អញ ថ្ងៃនេះ អញនឹងខ្វល់ខ្វាយដោយកាយ ទើបគួរ ហើយទើប នាំអាចម៍ដីមកលុបប្រទេសនោះឲ្យពេញ ។

កាលសុមេធបណ្ឌិតនោះធ្វើផ្លូវឱកាសនោះមិនទាន់សម្រេច មនុស្សអ្នក

រម្មនគរ ក៏ក្រាបទូលដល់ព្រះមានព្រះភាគដល់ពេលភត្តាហារថា អាហារសម្រេចហើយព្រះអង្គ កាលមនុស្សទាំងនោះ ក្រាបទូលភត្តកាលយ៉ាងនេះហើយ ព្រះទសពល ស្លៀកអន្តរវាសក ២ ជាន់ ដែលមានពណ៌ដូចផ្កាច្បាបិទមណ្ឌលទាំង ៣ ទ្រង់ចងវត្ថពន្ធចង្កេះដ៏មានសិរី ដូចផ្ទេកបន្ទោរ អំពីខាងលើអន្តរវាសកនោះ ដូចព័ទ្ធគំនរផ្កាច្បាដោយកម្រងមាស ទ្រង់ដណ្តប់បង្សុកូលចីវរដ៏ប្រសើរ ពណ៌ក្រហមដូចផ្កាចារ ដែលជ្រលក់ដោយទឹកល័ខ ដូចស្រោចទឹកល័ខលើកំពូលភ្នំមាស ដូចព័ទ្ធចេតិយមាស ដោយបណ្តាញកែវប្រពាល ដូចពាក់មាសដ៏មានតម្លៃ ដោយសំពត់កម្ពលក្រហម និងដូចបិទព្រះចន្ទក្នុងសរទរដូវ ដោយវលាហកក្រហម ទ្រង់ចេញអំពីទ្វារព្រះគន្ធកុដិ ដូចរាជសីហ៍ចេញអំពីគុហាមាស ប្រថាប់ឈរត្រង់មុខព្រះគន្ធកុដិ ។ ខណៈនោះ ភិក្ខុទាំងអស់កាន់បាត្រ និងចីវររៀងៗ ខ្លួន ចោមរោមព្រះមានព្រះភាគ ភិក្ខុដែលឈរចោមរោមទាំងនោះ ក៏មានសភាពយ៉ាងនោះ

ភិក្ខុទាំងឡាយ ជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នក
អត់ធន់ ចំពោះពាក្យជេរ ជាអ្នកស្ងាត់ មិនច្រឡូកច្រឡំ បាន
ទទួលការទូន្មានហើយ ជាអ្នកតិះដៀលនូវបាប ។
ភិក្ខុគ្រប់រូប ដល់ព្រមដោយសីល ឈ្លាសក្នុងសមាធិ និង
ឈាន ដល់ព្រមដោយបញ្ញា និងវិមុត្តិ ជាអ្នកប្រកបដោយ
ចរណៈ ១៥ ជាអ្នកអស់អាសវៈហើយ ដល់នូវការជំនាញ
មានឫទ្ធិ មានយស មានឥន្ទ្រិយស្ងប់ ដល់នូវការទូន្មានហើយ

ជាអ្នកបរិសុទ្ធហើយ អស់នូវភពថ្មីហើយ ។

ដោយប្រការដូចពោលមកនេះ ព្រះមានព្រះភាគ ទ្រង់ប្រាសចាករាគៈ ដែលពួកភិក្ខុប្រាសចាករាគៈចោមរោមហើយ ទ្រង់ប្រាសចាកទោសៈ ដែលពួកភិក្ខុប្រាសចាកទោសៈចោមរោមហើយ ទ្រង់ប្រាសចាកមោហៈ ដែលពួកភិក្ខុប្រាសចាកមោហៈចោមរោមហើយ ទ្រង់រុងរឿងពន់ពេក ។ គ្រានោះ ព្រះសាស្តា កាលពួកភិក្ខុជាអ្នកមានអានុភាពច្រើន ជាអ្នកអស់អាសវៈហើយ ជាអ្នកបាននូវអភិញ្ញា ៦ ចំនួន ៤ សែនរូបចោមរោមហើយ ទ្រង់យាងទៅតាមផ្លូវនោះ ដែលគេប្រដាប់តាក់តែងហើយ ដោយពុទ្ធលីលា គ្មានអ្វីប្រៀបដែលកម្លាំងកុសល ដែលទ្រង់សន្សំអស់សម័យរាប់មិនអស់ បណ្តាលឲ្យកើតហើយ ដូចស្តេចសហស្សនេត្រ ដែលពួកទេវតាចោមរោមហើយ ដូចស្តេចហារិតមហាព្រហ្ម ដែលពួកព្រហ្មចោមរោមហើយ ដូចព្រះចន្ទក្នុងសរទរដូវ ដែលពួកផ្កាយចោមរោមហើយ ។

បានឮថា ព្រះមានព្រះភាគជាអ្នកប្រាជ្ញ ទ្រង់មានព្រះរស្មីពណ៌
ដូចមាស ទ្រង់ធ្វើដើមឈើក្នុងផ្លូវ ឲ្យមានពណ៌ដូចមាស
ទ្រង់ធ្វើផ្កាឈើ ឲ្យមានពណ៌ដូចមាស ទ្រង់មានរស្មីពណ៌ដូច
មាស ទ្រង់យាងចុះកាន់ផ្លូវ ។

សុមេធតាបស ពិនិត្យមើលអត្តភាពរបស់ព្រះមានព្រះភាគទីបង្ករ ដែលយាងមកតាមផ្លូវ ដែលគេប្រដាប់តាក់តែងហើយនោះ ដែលប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ បូកលាបដោយអនុព្យញ្ជនៈ ៨០ ចោមរោម

ដោយព្រះរស្មី ១ ព្យាម មានសិរីដូចកែវមណី ពណ៌កែវមណីឥន្ទនីល កំពុងផ្សាយពុទ្ធរស្មី ដែលមានពណ៌ ៦ ដូចផ្លេកបន្ទោរ មានប្រការផ្សេងៗ ក្នុងអាកាស មានរូបល្អ ហើយគិតថា ថ្ងៃនេះ អញនឹងលះបង់ជីវិត ដើម្បីព្រះទសពលក៏គួរ សម្រេចចិត្តថា សូមព្រះមានព្រះភាគទ្រង់កុំជាន់កក់ឡើយ សូមទ្រង់ជាន់ខ្នងអាត្មាអញយាង មួយអន្លើដោយព្រះខីណាស្រព ៤ សែនរូប ដូចទ្រង់ជាន់ស្ពានក្តារកែវផលិកចុះ សេចក្តីនេះ នឹងជាប្រយោជន៍ និងសេចក្តីសុខដល់អញអស់កាលយូរ ដូច្នេះហើយ ក៏ដោះផ្នួងសក់ ក្រាលកំណាត់ស្បែកជជា និងសំពត់សម្បកឈើលើកក់ដែលមានពណ៌ខ្មៅ ហើយផ្តេកខ្លួនដេកលើកក់ក្នុងទីនោះឯង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពួកជនទាំងនោះ ដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថា ព្រះពុទ្ធដ៏ប្រសើរក្នុងលោក ជាព្រះជិនស្រីព្រះនាមទីបង្ករ ជាលោកនាយក ទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវ គន្លងប្រឡាយ ដើម្បីព្រះពុទ្ធទីបង្ករនោះ ។ បីតិកើតឡើង ដល់តថាគតក្នុងខណៈនោះ ព្រោះតែឮពាក្យថា ព្រះពុទ្ធ តថាគតទន្ទេញថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះហើយ ក៏បាននូវសោមនស្ស ។ តថាគតស្ថិតនៅក្នុងប្រទេសនោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្តុះពូជកុសល ក្នុងបុញ្ញក្ខេត្តនេះ កុំឲ្យខណៈកន្លងទៅទទេឡើយ ។ ( លុះគិតដូច្នេះហើយ ក៏និយាយទៅរកមហាជនថា ) បើអ្នកទាំងឡាយ

ជម្រះផ្លូវថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជម្រះផ្លូវប្រឡាយដែរ ។ កាលនោះ ពួកជននោះ ក៏ឲ្យឱកាសមួយដល់តថាគត ដើម្បីជម្រះផ្លូវ តថាគតគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ជម្រះផ្លូវបណ្តើរក្នុងឱកាសនោះ ។ កាលដែលឱកាស ( ផ្លូវ ) របស់តថាគតធ្វើមិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះជិនស្រី ជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្តេចយាងមកតាមផ្លូវជាមួយនឹងព្រះខីណាស្រព ៤ សែនរូប សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ជាតាទិបុគ្គល ប្រាសចាកមន្ទិល ។ ការក្រោកទទួល ( ព្រះសាស្តា ) ក៏ប្រព្រឹត្តទៅ ស្គរទាំងឡាយជាច្រើន ក៏លាន់ឮឡើង គគ្រឹកគគ្រេងពួកមនុស្ស និងទេវតាក៏ត្រេកអរ ញុំាងសាធុការឲ្យប្រព្រឹត្តទៅ ។ ពួកទេវតាឃើញពួកមនុស្ស ឯពួកមនុស្សក៏ឃើញពួកទេវតា ទេវតា និងមនុស្សទាំងពីរពួកនេះ បានផ្គងអញ្ជលីដើរដង្ហែព្រះតថាគត ។ ពួកទេវតាប្រគុំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្សក៏ប្រគុំតូរ្យតន្ត្រីជារបស់មនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងពីរក្រុមនេះ ប្រគុំភ្លេងដង្ហែព្រះតថាគត ។ ពួកទេវតាដែលស្ថិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវបុស្សផ្កាឈូក ផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ឰដ៏អាកាស អំពីទិសតូចទិសធំ ។ ពួកទេវតាដែលស្ថិតនៅឰដ៏អាកាស ក៏រោយរាយ

លម្ពិតខ្ញីមចន្ទន៍ទិព្វផង គ្រឿងក្រអូបដ៏ប្រសើរទាំងអស់ផង អំពីទិសតូចទិសធំព្ធដ៏អាកាស ។ ពួកមនុស្សដែលស្ថិតនៅលើផែនដី ក៏រោយរាយផ្កាចម្ប៉ា ផ្កាស្រល់ ផ្កាកុម្ព ផ្កាខ្ទឹង ផ្កាបុសនាគ និងផ្កាកាកេស អំពីទិសតូចទិសធំ ។ តថាគតរំសាយសក់ត្រង់ប្រទេសនោះ ហើយក្រាលចីវរសម្បកឈើ និងកំណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ ( អធិដ្ឋានថា ) សូមព្រះពុទ្ធ ព្រមទាំងពួកសិស្សជាន់អាត្មាអញ យាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ ដល់អាត្មាអញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិយាកំសុ** បានដល់ ព្យាករហើយ ។ បាឋៈថា **ទីបង្ករោ នាម ជិនោ តស្ស សោធីយតិ បថោ** ដូច្នេះក៏មាន ។ បទថា **សោមនស្សំ បវេទយឹ** សេចក្តីថា សោយសោមនស្ស ។ បទថា **តត្ថ បត្វា** បានដល់ ឈរក្នុងប្រទេសដែលចុះចាកអាកាសនោះឯង ។ បទថា **សំវិគ្គមានសោ** បានដល់ មានចិត្តភាន់ភាំងព្រោះបីតិ ។ បទថា **ឥធ** បានដល់ ក្នុងបុញ្ញក្ខេត្ត គឺព្រះពុទ្ធទីបង្ករអង្គនេះ ។ បទថា **ពីជានិ** បានដល់ ពូជ គឺកុសល ។ បទថា **រោបិស្សំ** កែជា **រោបិស្សាមិ** ។ បទថា **ខណោ** បានដល់ ប្រជុំខណៈទី ៩ មិនមែនខណៈ ៨ ខណៈនោះ រកបានដោយក្រតថាគតក៏បានហើយ ។ បទថា **វេ** ត្រឹមតែជានិបាត ។ បទថា **មា ឧបច្ចគា** សេចក្តីថា ខណៈនោះកុំបីកន្លង គឺកុំកន្លងទៅឡើយ ។ បទថា **ឥនាជ** កែជា

ចេង ចូរឲ្យ ។ បទថា តេ បានដល់ ពួកមនុស្សដែលតថាគតសួរ ។ បទថា **សោចេមហំ តទា** កាត់បទជា **សោចេម អហំ តទា។** បទថា **អនិដ្ឋិតេ** បានដល់ មិនទាន់សម្រេច ផ្អាកហើយ ។ ក្នុងបទថា **ខីណាសវេហិ** នេះ អាសវៈមាន ៤ គឺកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។ អាសវៈ ៤ នេះនៃភិក្ខុណាអស់ទៅហើយ លះហើយ ដកហើយ រម្ងាប់ហើយ មិនគួរកើតដុតហើយដោយភ្លើង គឺញាណ ភិក្ខុទាំងនោះ ឈ្មោះថា មានអាសវៈអស់ហើយ ជាអ្នកមានអាសវៈអស់ហើយទាំងនោះ ។ ឈ្មោះថា **វិមលេហិ** ព្រោះជាអ្នកអស់អាសវៈហើយនោះឯង ។

ក្នុងបទថា **ទេវា មនុស្សេ បស្សន្តិ** នេះ មិនចំបាច់ត្រូវពោល ក្នុងការដែលទេវតាទាំងឡាយឃើញមនុស្ស ដ្បិតថា ដោយប្រក្រតី ទេវតាទាំងឡាយរមែងឃើញមនុស្សទាំងឡាយ ដូចមនុស្សទាំងឡាយឈរក្នុងទីនេះ ឃើញគ្នានិងគ្នា ។ បទថា **ទេវតា** បានដល់ ទេវតាទំងឡាយ ។ បទថា **ឧភោបិ** បានដល់ ទេវតា និងមនុស្សទាំង ២ ពួក ។ បទថា **បញ្ជលិកា** បានដល់ ផ្គងអញ្ជលី អធិប្បាយថា យកដៃទាំង ២ ដាក់លើសិរសា ។ បទថា **អនុយន្តិ តថាគតំ** បានដល់ ទៅខាងក្រោយព្រះតថាគត ។ គប្បីជ្រាបលក្ខណៈថា កាលមានការប្រកប **អនុ** សព្ទ ទុតិយាវិភត្តិ រមែងចុះក្នុងអត្ថឆដ្ឋីវិភត្តិ ដោយហេតុនោះ ទើបត្រាស់ថា **អនុយន្តិ តថាគតំ។** បទថា **វន្ទយន្តា** បានដល់ ប្រគំ ។

បទថា **មន្ទារវំ** បានដល់ ផ្កាមន្ទារវៈ ។ បទថា **ធិសោធិសំ** បានដល់

គ្រប់ទិស ។ បទថា **ឱកិរន្តិ** បានដល់ រោយចុះ ។ បទថា **អាកាសនភគតា** បានដល់ ទៅក្នុងលម្ហ គឺអាកាស ន័យម្យ៉ាងទៀត ទៅកាន់អាកាស គឺទៅកាន់ស្ថានសួគ៌នោះឯង ។ ពិតហើយ ស្ថានសួគ៌ លោកហៅថា មេឃ ។ បទថា **មរូ** បានដល់ ទេវតាទាំងឡាយ ។ បទថា **សរលំ** បានដល់ ផ្កាស្រល់ ។ បទថា **នីបំ** បានដល់ ផ្កាកូម្ព ។ បទថា **នាគបុន្នាគកេតកំ** បានដល់ ផ្កាបុន្នាគ និងផ្កាកាកែស ។ បទថា **ភូមិតលគតា** បានដល់ ទៅកាន់ផែនដី ។

បទថា **កេសេ មុញ្ចិត្វាហំ** សេចក្តីថា ដោះ គឺរំសាយសក់ចាកផ្នួង និងជដាដែលរុំ ។ បទថា **តត្ថ** បានដល់ ក្នុងឱកាសដែលឲ្យដល់តថាគត ។ បទថា **ចម្មកំ** បានដល់ បន្ទះស្បែក ។ បទថា **កលលេ** បានដល់ ត្រង់ភក់ ។ បទថា **អវកុជ្ជោ** បានដល់ ផ្កាប់មុខ ។ បទថា **និបជ្ជហំ** កាត់បទជា **និបជ្ជឹ អហំ** ។ សព្ទថា **មា** ក្នុងបទថា **មានំ** ជានិបាត ចុះក្នុងអត្ថបដិសេធ ។ សព្ទថា **នំ** ជានិបាត ចុះក្នុងអត្ថបទបូរណៈ គឺគ្រាន់តែធ្វើបទឲ្យពេញ សេចក្តីថា សូមព្រះពុទ្ធទ្រង់កុំជាន់ត្រង់ភក់ឡើយ ។ បទថា **ហិតាយ មេ ភវិស្សតិ** សេចក្តីថា ការមិនជាន់លើភក់នោះ នឹងមានប្រយោជន៍ ដល់អាត្មាអញអស់កាលយូរ ។ បាឋៈថា **សុខាយ មេ ភវិស្សតិ** ដូច្នេះក៏មាន ។

បន្ទាប់អំពីនោះ សុមេធបណ្ឌិតដេកលើភក់គិតយ៉ាងនេះថា បើអាត្មាអញប្រាថ្នាសោត ក៏គប្បីដុតកិលេសទាំងអស់ហើយ ហើយជាសង្ឃនវកៈ ចូលទៅកាន់រម្មនគរ តែអាត្មាអញមិនមានកិច្ចដែលត្រូវដុតកិលេស ហើយសម្រេច

ព្រះនិព្វាន ដោយភេទដែលមិនមានអ្នកណាស្គាល់ឡើយ បើដូច្នោះ អញគប្បី ដូចព្រះទីបង្ករទសពល សម្រេចបរមាភិសម្ពោធិញ្ញាណ ឡើងកាន់ធម្មនាវា ញុំាងមហាជនឲ្យឆ្លងសង្សារសាគរ ហើយសឹមបរិនិព្វាន ក្នុងកាលឯក្រោយ នេះជាការសមគួរដល់អាត្មាអញ ។ បន្ទាប់អំពីនោះ ទើបប្រជុំធម៌ ៨ ក្រាបចុះធ្វើអភិនីហារ ដើម្បីបានជាព្រះពុទ្ធ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលតថាគតដេកលើផែនដី ក៏មានសេចក្តីត្រិះរិះដោយចិត្ត យ៉ាងនេះថា បើអាត្មាអញ ប្រាថ្នាដុតកិលេសទាំងឡាយ របស់អញក្នុងថ្ងៃនេះក៏បាន ។ តែថា ប្រយោជន៍អ្វី អាត្មាអញ ធ្វើឲ្យជាក់ច្បាស់នូវធម៌ ដោយភេទដែលគេមិនស្គាល់ក្នុងទីនេះ អាត្មាអញគប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះ ចាកកិលេស ញុំាងលោក ព្រមទាំងទេវលោក ឲ្យរួចរដោះ ( ចាកសង្សារ ) ។ ប្រយោជន៍អ្វី អាត្មាអញជាបុរស សម្តែងកម្លាំងឆ្លងទៅម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុ-តញ្ញាណ ចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មា អញនឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ។ តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់ភពទាំង ៣ ឡើងជិះលើនាវា គឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំង

ទេវលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បឋវិយំ និបន្នស្ស** បានដល់ ដេកលើផែនដី បាឋៈក៏យ៉ាងនោះដូចគ្នា ។ បទថា **ចេតសោ** សេចក្ដីថា ចិត្តក៏មានបរិវិតក្ក ។ បាឋៈថា **ឯវំ មេ អាសិ ចេតសា** ដូច្នេះក៏មាន ។ បទថា **ឥច្ឆមានោ** បានដល់ ប្រាថ្នា ។ បទថា **កិលេសេ** មានវិគ្គហៈថា ធម្មជាតពួកណា រមែងសៅហ្មង រមែងធ្វើឲ្យក្ដៅក្រហាយ ហេតុនោះ ធម្មជាតទាំងនោះ ឈ្មោះថា កិលេស គឺកិលេស ១០ មានរាគៈជាដើម ។ បទថា **ឈាបយេ** បានដល់ គប្បីឲ្យឆេះ អធិប្បាយថា អាត្មាអញគប្បីដុតកិលេសទាំងឡាយរបស់អញ ។

បទថា **កឹ** ជាពាក្យបដិសេធ ។ បទថា **អញ្ញាតវេសេន** បានដល់ ដោយភេទដែលមិនប្រាកដ ដែលមិនមានអ្នកណាស្គាល់ ដែលបិទបាំង អធិប្បាយថា អញគប្បីធ្វើអាសវៈឲ្យអស់ ដូចកិក្ខុទាំងឡាយក្នុងសាសនានេះ ឬបំពេញពុទ្ធការកធម៌ ហើយធ្វើមហាប្រឹថពីឲ្យញាប់ញ័រ ក្នុងសម័យបដិសន្ធិ ប្រសូត ត្រាស់ដឹង និងប្រកាសធម្មចក្រ ជាអ្នកត្រាស់ដឹងឯង ហើយញុំាង សត្វឲ្យត្រាស់ដឹង ជាអ្នកឆ្លងឯង ហើយញុំាងសត្វឲ្យឆ្លងសង្សារសាគរ ជាអ្នក រួចផុតឯង ហើយញុំាងសត្វឲ្យរួចផុត ។ បទថា **សទេវកេ** បានដល់ ក្នុង លោក ព្រមទាំងទេវលោក ។

បទថា **ថាមទស្សិនា** បានដល់ ឃើញកម្លាំងរបស់ខ្លួន ។ បទថា **សន្តារេស្សំ** បានដល់ នឹងឲ្យឆ្លង ។ បទថា **សទេវកំ** បានដល់ ញុំាងពួក សត្វ ព្រមទាំងទេវតា ឬញុំាងលោក ព្រមទាំងទេវលោក ។ បទថា **អធិការេន**

បានដល់ ដោយការធ្វើដ៏វិសេសក្រៃលែង អធិប្បាយថា ដោយការលះបង់ជីវិតខ្លួនដើម្បីព្រះពុទ្ធ ហើយដេកលើភក់ ឈ្មោះថា អធិការ ។

បទថា **សំសារសោតំ** សេចក្តីថា ការអន្ទោលទៅខាងនោះខាងនេះ ក្នុងកំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាស ៩ ដោយអំណាចកម្ម និងកិលេស ឈ្មោះថា សង្សារ ដូចព្រះតម្រាស់ថា

លំដាប់នៃខន្ធ ធាតុ និងអាយតនៈ ប្រព្រឹត្តទៅមិនដាច់
លោកហៅថា សង្សារ ដូច្នេះ ។

សង្សារផង ក្រសែផង ហេតុនោះ ទើបឈ្មោះថា **សំសារសោត** នូវសង្សារ និងក្រសែនោះ ។ ន័យម្យ៉ាងទៀត ក្រសែនៃសង្សារ ឈ្មោះថា **សំសារសោត** សេចក្តីថា កាត់ក្រសែតណ្ហាដែលជាហេតុនៃសង្សារ ។ បទថា **តយោ ភវេ** បានដល់ កាមភព រូបភព និងអរូបភព ។ កម្ម និងកិលេសដែលឲ្យកើតភព ៣ លោកបំណងយកថា ភព ៣ ។ បទថា **ធម្មនាវំ** បានដល់ អរិយមគ្គមានអង្គ ៨ ។ ពិតហើយ អរិយមគ្គមានអង្គ ៨ នោះ លោកហៅថា **ធម្មនាវា** ព្រោះអត្ថថា ជាគ្រឿងឆ្លងឱឃៈ ៤ ។ បទថា **សមារុយ្ហ** បានដល់ ឡើងហើយ ។ បទថា **សន្តារេស្សំ** គឺ **សន្តារេស្សាមិ**។

អភិនីហារ រមែងសម្រេចដល់បុគ្គល ដែលប្រាថ្នាជាព្រះពុទ្ធ
ព្រោះការប្រជុំព្រមនៃធម៌ ៨ ប្រការ គឺភាពជាមនុស្ស ១
ភាពជាអ្នកសម្បូរដោយភេទ ១ ហេតុ ១ ការជួបព្រះសាស្តា

១ បព្វជ្ជា ១ សម្បូរដោយគុណ ១ មានអធិការ ១ មានឆន្ទៈ ១ ។

បណ្ដាបទអង្គទាំង ៨ នោះ ពាក្យថា ភាពជាមនុស្ស សេចក្ដីថា សេចក្ដីប្រាថ្នា រមែងសម្រេចដល់បុគ្គលដែលតាំងនៅក្នុងអត្តភាពជាមនុស្ស ប៉ុណ្ណោះ ហើយប្រាថ្នាជាព្រះពុទ្ធ រមែងមិនសម្រេចដល់សត្វទាំងឡាយ ដែលតាំងនៅក្នុងកំណើតនាគជាដើមឡើយ បើសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយបានថា ព្រោះជាតិនាគជាដើម ជាអហេតុកសត្វ ។

ពាក្យថា ភាពជាអ្នកសម្បូរដោយភេទ សេចក្ដីថា សេចក្ដីប្រាថ្នា រមែងសម្រេចដល់បុគ្គល ដែលនៅក្នុងអត្តភាពជាមនុស្ស ហើយតាំងនៅក្នុងភេទបុរសប៉ុណ្ណោះ រមែងមិនសម្រេចដល់ស្ត្រី បណ្ឌកៈ នបុំសកៈ និងឧភតោព្យញ្ជនកៈឡើយ បើសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយបានថា ព្រោះលក្ខណៈមិនសម្បូរ ដូចព្រះមានព្រះភាគត្រាស់ ( ត្រាស់ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ស្ត្រីបានជាព្រះអរហន្តសម្មាសម្ពុទ្ធ ដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យ គឺថា ហេតុនុ៎ះ មិនដែលមានឡើយ ដូច្នេះ គប្បីជ្រាបសេចក្ដីពិស្ដារឯងចុះ ។ ព្រោះហេតុនោះ សេចក្ដីប្រាថ្នា រមែងមិនសម្រេចដល់បុគ្គលមានជាតិជាមនុស្ស ដែលតាំងនៅក្នុងភេទជាស្រីឡើយ ។

ពាក្យថា ហេតុ សេចក្ដីថា សូម្បីជាបុរស ក៏ត្រូវជាបុរសដែលដល់ព្រមដោយហេតុ ក្នុងការដែលសម្រេចអរហត្តក្នុងអត្តភាពនោះប៉ុណ្ណោះ សេចក្ដី

ប្រាថ្នាមិនសម្រេចដល់បុរសក្រៅអំពីនេះឡើយ ។

ពាក្យថា ការជួបព្រះសាស្តា សេចក្តីថា បើបុរសប្រាថ្នាក្នុងសម្នាក់របស់ព្រះសម្ពុទ្ធដែលគង់ព្រះជន្មនៅប៉ុណ្ណោះ ទើបសេចក្តីប្រាថ្នាសម្រេច កាលព្រះមានព្រះភាគបរិនិព្វានហើយ សេចក្តីប្រាថ្នាត្រង់សម្នាក់ព្រះចេតិយ ឬត្រង់គល់ពោធិព្រឹក្ស ឬត្រង់ព្រះពុទ្ធបដិមា ឬក្នុងសម្នាក់នៃព្រះបច្ចេកពុទ្ធ និងពុទ្ធសាវក រមែងមិនសម្រេច ។ ព្រោះហេតុអ្វី ព្រោះព្រះបច្ចេកពុទ្ធ និងពុទ្ធសាវក មិនអាចដឹងដល់កព្វសត្វ និងអកព្វសត្វ ហើយកំណត់ដោយញាណជាគ្រឿងកំណត់ និងវិបាក ហើយព្យាករបានឡើយ ។ ព្រោះហេតុនោះ ទើបសេចក្តីប្រាថ្នាសម្រេចតែក្នុងសម្នាក់របស់ព្រះពុទ្ធប៉ុណ្ណោះ ។

បទថា បព្វជ្ជា សេចក្តីថា សូម្បីបុគ្គលប្រាថ្នាក្នុងសម្នាក់របស់ព្រះមានព្រះភាគសម្ពុទ្ធ ក៏ត្រូវបួសជាតាបសទាំងឡាយ ដែលជាកម្មកិរិយវាទី ឬជាភិក្ខុទាំងឡាយប៉ុណ្ណោះ ទើបសេចក្តីប្រាថ្នាសម្រេចបាន មិនសម្រេចដល់បុគ្គលដែលតាំងនៅក្នុងភេទគ្រហស្ថ ព្រោះហេតុអ្វី ព្រោះថា ព្រះពោធិសត្វទាំងឡាយ ជាបព្វជិតប៉ុណ្ណោះ ទើបសម្រេចសម្ពោធិញ្ញាណបាន បើជាគ្រហស្ថសម្រេចមិនបានឡើយ ។ ព្រោះហេតុនោះ ត្រូវតែជាបព្វជិតប៉ុណ្ណោះ ក្នុងការផ្តើមបណិធាន គឺប្រាថ្នា

ពាក្យថា សម្បូរដោយគុណ សេចក្តីថា សូម្បីបួសហើយ ត្រូវជាអ្នកបានសមាបត្តិ ៨ មានអភិញ្ញា ៥ ប៉ុណ្ណោះ ទើបសេចក្តីប្រាថ្នាសម្រេចបាន តែបុគ្គលវៀរចាកគុណសម្បត្តិទាំងនេះ សម្រេចមិនបានឡើយ ព្រោះហេតុអ្វី

ព្រោះពោធិញ្ញាណនោះ មិនមានដល់បុគ្គលដែលឥតគុណសម្បត្តិឡើយ ។

ពាក្យថា មានអធិការ សេចក្ដីថា បុគ្គលណា សូម្បីដល់ព្រមដោយគុណ ដែលអាចលះបង់ជីវិតខ្លួន ដើម្បីព្រះពុទ្ធទាំងឡាយបាន សេចក្ដីប្រាថ្នារមែងសម្រេចដល់បុគ្គលនោះ ដែលដល់ព្រមហើយដោយអធិការបែបនេះប៉ុណ្ណោះ មិនសម្រេចដល់បុគ្គលក្រៅអំពីនេះឡើយ ។

ពាក្យថា មានឆន្ទៈ សេចក្ដីថា បុគ្គលណា ដល់ព្រមហើយដោយអភិនីហារ ក៏មានឆន្ទៈព្យាយាម ឧស្សាហ៍ ស្វែងរកយ៉ាងធំ ដើម្បីប្រយោជន៍ដល់ពុទ្ធការកធម៌ទាំងឡាយ សេចក្ដីប្រាថ្នា រមែងសម្រេចដល់បុគ្គលនោះប៉ុណ្ណោះ មិនសម្រេចដល់បុគ្គលក្រៅអំពីនេះ ឧបមានៃភាពជាអ្នកមានឆន្ទៈធំក្នុងសេចក្ដីនោះ មានដូច្នេះថា បើមានបុគ្គលពោលយ៉ាងនេះថា បុគ្គលណាអាចឆ្លងផ្ទៃចក្កវាឡទាំងមូល ដែលពេញដោយទឹក ដោយកម្លាំងដើមដៃរបស់ខ្លួន ទៅដល់ត្រើយបាន បុគ្គលនោះ នឹងសម្រេចជាព្រះពុទ្ធបាន បុគ្គលណាមិនគិតថា កិច្ចនេះ លំបាកសម្រាប់ខ្លួន ប្រកបដោយឆន្ទៈ និងឧស្សាហៈមានឆន្ទៈធំយ៉ាងនេះថា អញនឹងឆ្លងផ្ទៃចក្កវាឡនេះឲ្យដល់ត្រើយ សេចក្ដីប្រាថ្នារមែងសម្រេចដល់បុគ្គលនោះ មិនសម្រេចដល់បុគ្គលក្រៅអំពីនេះឡើយ ។

សុមេធបណ្ឌិតសមោធានធម៌ ៨ នេះហើយ ធ្វើអភិនីហារដើម្បីបានជាព្រះពុទ្ធ ទើបក្រាបចុះ ។ ឯព្រះមានព្រះភាគទីបង្ករប្រថាប់ឈរក្បែរសីសៈនៃសុមេធបណ្ឌិត ទតឃើញសុមេធតាបសកំពុងនៅលើភក់ ទ្រង់បញ្ជូនអនាគតំសញ្ញាណថា តាបសនេះ ធ្វើអភិនីហារដើម្បីបានជាព្រះពុទ្ធ ក្រាបចុះហើយ

ការប្រាថ្នារបស់គេសម្រេចឬហ្ន៎ ទ្រង់ពិចារណាមើលក៏ជ្រាបថា កន្លងទៅ ៤ អសង្ខេយ្យ និង ១ សែនកប្ប រាប់អំពីកប្បនេះទៅ កុលបុត្តនេះនឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ទ្រង់ប្រថាប់ឈរព្យាករកណ្តាលបរិស័ទថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឃើញតាបសដែលមានតបៈដ៏ឧត្តមដេកលើកក់នេះដែរឬហ្ន៎ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឃើញ ទើបត្រាស់ថា តាបសនេះ ធ្វើអភិនីហារដើម្បីបានជាព្រះពុទ្ធ ទើបដេកហើយ សេចក្តីប្រាថ្នារបស់តាបសនេះ នឹងសម្រេចក្នុងទីបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប រាប់អំពីកប្បនេះទៅ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតមក្នុងលោក ក្នុងអត្តភាពនោះរបស់តាបសនោះ នគរឈ្មោះកបិលពស្តុជាទីប្រថាប់នៅ ព្រះមាតាព្រះនាមមហាមាយាទេវី ព្រះបិតាព្រះនាមព្រះបាទសុទ្ធោទនៈ ព្រះអគ្គសាវកទាំង ២ ឈ្មោះឧបតិស្សៈ និងកោលិតៈ ឧបដ្ឋាកឈ្មោះអានន្ទ អគ្គសាវិកាទាំង ២ ឈ្មោះខេមា និងឧប្បលវណ្ណា តាបសដែលមានញាណខ្ចាំងក្លា នឹងយាងចេញមហាភិនេស្រ្កមណ៍ តាំងសេចក្តីព្យាយាមធំ ទទួលមធុបាយាសដែលនាងសុជាតាថ្វាយត្រង់គល់និគ្រោធ សោយត្រង់ឆ្នេរស្ទឹងនេរញ្ជរា ឡើងកាន់ពោធិមណ្ឌលដ្ឋាន ត្រាស់ដឹងត្រង់គល់អស្សត្ថព្រឹក្ស ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរ
ទទួលគ្រឿងបូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈរបស់
តថាគត ត្រាស់ពាក្យនេះថា ( ម្នាលភិក្ខុទាំងឡាយ ) អ្នក

ទាំងឡាយ ចូរមើលតាបសនេះ ជាជដិល មានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្ប ប្រមាណមិនបាន អំពីកប្បនេះទៅ ។ សត្វនេះ នឹងចេញ ចាកក្រុងឈ្មោះកបិលវត្ថុ ជាទីរីករាយ តម្កល់ព្យាយាម ធ្វើ ទុក្ករកិរិយា ។ សត្វនេះ អង្គុយទៀបគល់អជបាលព្រឹក្ស ទទួល បាយាសដែលនាងសុជាតាថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ បានទទួលបាយាសទៀប ឆ្នេរស្ទឹងនេរញ្ជរា ហើយនឹងត្រឡប់មកតាមផ្លូវដែលគាត់តែង យ៉ាងប្រសើរ ( អង្គុយ ) ទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិមណ្ឌល នឹងបាន ត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជនិកាមាតា របស់តាបសនោះ នឹងមាននាមថាព្រះនាង មាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯតាបសនេះ នឹង មានឈ្មោះថាព្រះគោតម អគ្គសាវកទាំងពីររូប គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាកឈ្មោះ អានន្ទ នឹងបម្រើព្រះជិនស្រីនេះ ។ អគ្គសាវិកាពីររូប គឺនាង ខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាស ចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ឈើជាទី

ត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឯ
ឧបាសកជាឧបដ្ឋាកដ៏ប្រសើរពីររូប គឺចិត្តៈ ១ ហត្ថាឡវកៈ
១ ។ នាងនន្ទមាតា និងនាងឧត្តរា ជាឧបដ្ឋាយិកាដ៏ប្រសើរ
ព្រះគោតមមានយសនោះ មានព្រះជន្ម ១០០ វស្សា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លោកវិទូ** បានដល់ ឈ្មោះថា លោកវិទូ ព្រោះទ្រង់ដឹងច្បាស់នូវលោកដោយអាការទាំងពួង ។ សេចក្តីពិត ព្រះមានព្រះភាគទ្រង់ដឹង ទ្រង់ដឹងទូទៅ ទ្រង់ចាក់ធ្លុះនូវលោក ដោយប្រការទាំងពួង គឺដោយសភាវៈ ការកើត ការរលត់ ដោយឧបាយឲ្យដល់ការរលត់ ព្រោះហេតុនោះ ទើបលោកហៅថា **លោកវិទូ** ដូចទ្រង់ត្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

ព្រោះហេតុនោះ បុគ្គលអ្នកមានបញ្ញាល្អ ដឹងច្បាស់នូវលោក
ដល់នូវទីបំផុតនៃលោក មានព្រហ្មចរិយធម៌ នៅស្រេចហើយ
មានបាបរម្ងាប់បង់ហើយ ដឹងនូវទីបំផុតនៃលោក រមែងមិន
ប្រាថ្នានូវលោកនេះផង នូវលោកខាងមុខផង ដូច្នេះ ។

ម្យ៉ាងទៀត លោកមាន ៣ គឺសង្ខារលោក សត្វលោក និងឱកាសលោក បណ្តាលោកទាំង ៣ នោះ ធម៌ទាំងឡាយ មានបឋវីជាដើម ដែលអាស្រ័យគ្នាកើតឡើង ឈ្មោះថា **សង្ខារលោក** សត្វទាំងឡាយមានសញ្ញា មិនមានសញ្ញា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ឈ្មោះថា **សត្វលោក** លំនៅរបស់សត្វទាំងឡាយ ឈ្មោះថា **ឱកាសលោក**។ ក្នុង

លោកទាំង ៣ នេះ ព្រះមានព្រះភាគទ្រង់ជ្រាបហើយតាមសេចក្តីពិត ព្រោះហេតុនោះ ទើបព្រះមានព្រះភាគគេហៅថា **លោកវិទូ ។** បទថា **អាហុតីនំ បដិគ្គហោ** បានដល់ ឈ្មោះថា ទ្រង់គួរទទួលគ្រឿងបូជាទាំងឡាយ ព្រោះជាអ្នកគួរទទួលនូវទានទាំងឡាយ គឺព្រោះជាទក្ខិណេយ្យបុគ្គល ។ បទថា **ឧស្សីសកេ មំ ឋត្វាន** បានដល់ ប្រថាប់ឈរក្បែរសីសៈរបស់តថាគត ។ បានត្រាស់ពាក្យនេះ គឺពាក្យដែលគួរពោលក្នុងឥឡូវនេះ ។ បទថា **ជដិលំ** សេចក្តីថា ជដារបស់អ្នកបួសនោះមាន ហេតុនោះ ទើបអ្នកបួសនោះ ឈ្មោះថា ជដិល បុគ្គលមានជដា បានដល់ ជដិលនោះ ។ បទថា **ឧគ្គាតាបនំ** បានដល់ មានតបៈខ្ពង់ខ្ពស់ ។ បទថា **អហុ** បានដល់ ក្នុងថ្ងៃ អធិប្បាយថា សម័យនោះ ។ បាឋៈក៏យ៉ាងនោះដូចគ្នា ។ បទថា **កបិលវ្ហយា** បានដល់ មានឈ្មោះថា ហៅថា កបិលពស្តុ ។ បទថា **រម្មា** បានដល់ គួរជាទីត្រេកអរ ។ បទថា **បធានំ** បានដល់ សេចក្តីព្យាយាម ។ បទថា **ឃហិតិ** បានដល់ នឹងដល់ នឹងទៅ ។ ពាក្យដ៏សេសក្នុងគាថាទាំងឡាយ មានអត្ថងាយយល់ហើយ ។

លំដាប់នោះ សុមេធបណ្ឌិតកើតនូវសោមនស្សថា បានឮថា សេចក្តីប្រាថ្នារបស់អញនឹងសម្រេចផល ។ មហាជនស្តាប់ព្រះតម្រាស់របស់ព្រះទីបង្ករទសពលហើយ ក៏នាំគ្នាត្រេកអរថា សុមេធតាបសជាសព្វេញ្ញូតា-ញាណ ។ សុមេធបណ្ឌិតនោះគិតយ៉ាងនេះ ជនទាំងឡាយក៏បានធ្វើសេចក្តីប្រាថ្នាថា បុរសកំពុងឆ្លងស្ទឹង កាលមិនអាចឆ្លងដោយកំពង់ចំពោះមុខ ក៏នឹង

ធ្នូកំពង់ឯក្រោយ យ៉ាងណា ពួកយើងបើមិនបានមគ្គផលក្នុងសាសនារបស់ព្រះទីបង្ករទសពល ក្នុងអនាគតកាល គប្បីធ្វើឲ្យជាក់ច្បាស់នូវមគ្គផលចំពោះមុខតាបសនេះ ក្នុងពេលដែលលោកបានជាព្រះពុទ្ធ ក៏យ៉ាងនោះដូចគ្នា ។ ព្រះទីបង្ករទសពល ទ្រង់ទតព្រះមហាពោធិសត្វ ដែលព្រះពោធិសត្វបូជាដោយផ្កា ៨ ក្ដាប់ ទ្រង់ធ្វើប្រទក្សិណយាងចៀសចេញទៅ សូម្បីព្រះខីណាស្រព ៤ សែនអង្គនោះ ក៏នាំគ្នាបូជាព្រះពោធិសត្វដោយផ្កា និងគ្រឿងក្រអូបធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ចំណែកទេវតា និងមនុស្សក៏បូជាថ្វាយបង្គំហើយយ៉ាងនោះ ក៏ចៀសចេញទៅ ។

គ្រានោះ ព្រះមានព្រះភាគទីបង្ករ ទ្រង់ធ្វើប្រទីប គឺការដឹងនូវលោកទាំងពួង ដែលព្រះខីណាស្រព ៤ សែនរួបចោមរោមហើយ កាលអ្នករម្មនគរបូជា ដែលទេវតាទាំងឡាយថ្វាយបង្គំ ក៏យាងទៅ ដូចកំពូលភ្នំមាសដ៏ប្រសើរ ស្រោចដោយពន្លឺប្រាក់ កាលបាដិហារ្យទាំងឡាយជាច្រើនកំពុងប្រព្រឹត្តទៅ ក៏យាងទៅតាមផ្លូវដែលអ្នករម្មនគរប្រដាប់តាក់តែងនោះ យាងចូលទៅកាន់រម្មនគរដែលគួរជាទីត្រេកអរ អប់ដោយក្លិនផ្កាក្រអូបច្រើនប្រភេទនិងក្លិនលម្អិត ដែលគួរជាទីត្រេកអរ ទង់ជ្វាលាដែលលើកឡើង មានហ្វូងភមរ ដែលជាប់ចិត្តក្នុងក្លិន ហើរក្រឡឹងជាក្រុមៗ ឈ្ងុយឈ្ងប់ ដោយក្លិនធូប ស្អាតដូចទេវនគរ ព្រះទសពលក៏គង់ប្រថាប់លើពុទ្ធាសនៈដ៏សមគួរយ៉ាងធំ ដែលគេបានរៀបចំ ដូចព្រះចន្ទដ៏ល្អក្នុងសរទរដូវ លើកំពូលភ្នំយុគន្ធរដូចព្រះអាទិត្យកម្ចាត់នូវងងឹត ធ្វើនូវការរីកដល់គុម្ពឈូក ។ សូម្បីភិក្ខុសង្ឃ

ក៏អង្គុយលើអាសនៈសមគួររៀងៗ ខ្លួនតាមលំដាប់ ។ ឯឧបាសកអ្នករម្មនគរ ដែលដល់ព្រមហើយដោយគុណ មានសទ្ធាជាដើម ក៏នាំគ្នាថ្វាយទាន ដែលប្រដាប់ព្រមដោយរបស់ទំពាជាដើមប្រភេទផ្សេងៗ សម្បូរដោយពណ៌ ក្លិននិងរស មិនមានទានដទៃស្មើ ជាហេតុនៃសេចក្តីសុខដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។

គ្រានោះ ព្រះពោធិសត្វស្តាប់ពាក្យព្យាកររបស់ព្រះទសពល សម្គាល់នូវភាពជាព្រះពុទ្ធ ហាក់បីដូចនៅក្នុងកណ្តាប់ដៃ ក៏ត្រេកអរ កាលអ្នករម្មនគរត្រឡប់ទៅអស់ហើយ ក៏ក្រោកឡើងអំពីទីដេក គិតថា អញនឹងជ្រើសរើសបារមីទាំងឡាយ ទើបអង្គុយពត់ភ្នែនលើគំនរផ្កា កាលព្រះមហាសត្វកំពុងអង្គុយយ៉ាងនោះ ទេវតាទាំងម៉ឺនចក្កវាឡក៏ឲ្យសាធុការ ពោលថា សុមេធ-តាបស ក្នុងពេលដែលព្រះពោធិសត្វអង្គមុនៗ អង្គុយពត់ភ្នែន បំណងថា អញនឹងស្រាវជ្រាវរកបារមី ធម្មតាបុព្វនិមិត្តទាំងឡាយណាប្រាកដ បុព្វនិមិត្តទាំងនោះក៏ប្រាកដហើយក្នុងថ្ងៃនេះទាំងអស់ លោកនឹងបានជាព្រះពុទ្ធ ដោយឥតសង្ស័យ ពួកយើងដឹងសេចក្តីនេះថា បុព្វនិមិត្តទាំងនេះ ប្រាកដដល់អ្នកណា បុគ្គលនោះ នឹងបានជាព្រះពុទ្ធដោយចំណែកមួយប៉ុណ្ណោះ ព្រោះហេតុនោះ សូមលោកផ្គងសេចក្តីព្យាយាមរបស់ខ្លួនឲ្យមាំ ហើយបានសរសើរព្រះពោធិសត្វដោយពាក្យដ៏ពីរោះច្រើនប្រការ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ពួកមនុស្ស និងទេវតា លុះឮពាក្យព្យាកររបស់ពុទ្ធទីបង្ករ ទ្រង់ស្វែងរកគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយ ដោយគិតថា សុមេធតាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោទាំងឡាយក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោក ទាំងមួយម៉ឺនលោកធាតុ ទះដៃផងសើចផង ផ្គងអញ្ជលីនមស្ការផង ពោលថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោម ក៏ឈ្មោះថា ឆ្លងស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរអំពើរបស់តថាគតហើយ ទ្រង់លើកព្រះបាទខាងស្តាំ ។ សាវកទាំងឡាយណា ជាបុត្រនៃព្រះជិនស្រីក្នុងទីនោះ ពួកសាវកទាំងនោះ ក៏ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួកមនុស្ស ពួកអសុរ ពួកយក្ខក៏ក្រាបថ្វាយបង្គំតថាគត ហើយចៀសចេញទៅ ។ កាលព្រះលោកនាយក ព្រមទាំងព្រះសង្ឃ កន្លង

នូវការឃើញរបស់តថាគតទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ ។ តថាគតជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខ រីករាយដោយបាមោជ្ជ ផ្សព្វផ្សាយដោយបីតិ អង្គុយពែនភ្នែនក្នុងកាលនោះ ។ តថាគតអង្គុយពែនភ្នែនគិតយ៉ាងនេះ ក្នុងកាលនោះថា អាត្មាអញជាអ្នកស្ទាត់ក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញា ។ ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសីស្មើដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវសេចក្តីសុខបែបនេះ ។ ក្នុងកាលដែលតថាគតអង្គុយពែនភ្នែន គិតយ៉ាងនេះ ពួកមហាព្រហ្មដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញុំាងសំឡេងខ្ទាំងឲ្យលាន់ឮថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែននៃពោធិសត្វទាំងឡាយ ប្រាកដក្នុងកាលមុន និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ។ ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសំឡេង ឥតវឹកវរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ខ្យល់ធំទាំងឡាយ ក៏ឈប់បក់ ស្ទឹងទាំងឡាយ ក៏ឈប់ហូរ

និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាទាំងពួងដែលកើតលើគោក កើតក្នុងទឹក ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ វល្លិ៍ទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែក្នុង ខណៈនោះ វល្លិ៍ និង ឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ កែវទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្វ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាសក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ មហាសមុទ្រក៏ស្រកចុះ លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រក្នុងខណៈនោះ មហាសមុទ្រ និងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ភ្លើងក្នុងនរកទាំងមួយម៉ឺន ក៏រលត់ក្នុងខណៈនោះ ភ្លើងទាំងនោះ ក៏រលត់ក្នុងថ្ងៃនេះ លោកនឹង

បានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ព្រះអាទិត្យប្រាសចាកមន្ទិល ផ្កាយទាំងពួង ក៏ប្រាកដ ព្រះអាទិត្យ និងផ្កាយទាំងនោះ ក៏បានប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុលឡើងលើផែនដីក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដី ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកផ្កាយទាំងឡាយ ក៏រុងរឿងផ្កាយនក្ខត្តឫក្សទាំងឡាយប្រកប ដោយព្រះចន្ទខែវិសាខ ( ក៏រុងរឿង ) ក្នុងមណ្ឌលនៃអាកាស លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោលក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ សេចក្តីអផ្សុក មិនមានដល់សត្វទាំងឡាយ សត្វទាំងឡាយជាអ្នកត្រេកអរក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគទាំងឡាយដ៏ស្រាលៗ ក៏ស្ងប់រម្ងាប់ទៅ ទាំងសេចក្តីស្រេកឃ្លាន ក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្តីស្រេកឃ្លានទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈ ក៏បាត់បង់ទៅក្នុងកាលនោះ រោគ និង

កិលេសទាំងអស់នោះ ក៏ប្រាសចេញទៅក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ឯភ័យមិនមានក្នុងកាលនោះ ការមិនមានភ័យនុ៎ះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ធូលីដ៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលី ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្លិនស្អុយក៏ផាត់ចេញ ក្លិនទិព្វ ក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញ ដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរកទាំងអស់នោះឯង ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងរាំងមិនមានឡើយ កំពែងសន្ទះទ្វារ និងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអកាស ( ប្រាកដ ) ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចុតិ និងឧបបត្តិមិនមានក្នុងខណៈនោះ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់

ជាព្រះពុទ្ធប្រាកដ ។ ( និមិត្តទាំងនេះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មោធិញ្ញាណ ) ( ពួកសត្វពោលថា បពិត្រសុមេធតាបស ) សូមលោកផ្គងព្យាយាមឲ្យមាំមួនឡើង កុំត្រឡប់ កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុ៎ះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទំ សុត្វាន វចនំ** សេចក្តីថា ស្តាប់ពាក្យដែលព្រះមានព្រះភាគទីបង្ករ ព្យាករដល់ព្រះពោធិសត្វនេះ ។ បទថា **អសមស្ស** បានដល់ ឈ្មោះថា ឥតមានបុគ្គលស្មើ ព្រោះមិនមានអ្នកស្មើ សមដូចទ្រង់ត្រាស់ថា ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា

តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលស្មើនឹងតថាគតទេ ក្នុងលោកនេះ ព្រមទាំងទេវលោក ក៏មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ។

តថាគតមិនមានអាចារ្យ បុគ្គលស្មើតថាគតមិនមាន បុគ្គលដែលអាចប្រៀបនឹងតថាគត មិនមានក្នុងលោក ព្រមទាំងទេវលោក ដូច្នេះ ។

បទថា **មហេសិនោ** សេចក្តីថា ឈ្មោះថា ទ្រង់ស្វែងរកគុណដ៏ធំ ព្រោះស្វែងរកគំនរ គឺសីល សមាធិ និងបញ្ញាដែលជាធំ បានដល់ អ្នកស្វែងរកគុណធំអង្គនោះ ។ បទថា **នរមរូ** បានដល់ មនុស្ស និងទេវតា

ទាំងឡាយ សព្វនេះ ចន្លុលបង្ហាញសេចក្ដីយ៉ាងខ្ពស់ សត្វទាំងអស់ សូម្បីតែនាគ គ្រុឌ និងយក្ខជាដើមក្នុងម៉ឺនលោកធាតុ ក៏នាំគ្នាត្រេកអរ ។ បទថា **ពុទ្ធោ អយំ ភវិស្សតិ** សេចក្ដីថា នាំគ្នាត្រេកអរថា បានឮថា ពន្លកពុទ្ធង្កូរនេះកើតឡើងហើយ ។

បទថា **ឧក្កុដ្ឋិសទ្ទា** សេចក្ដីថា សំឡេងហ៊ោប្រព្រឹត្តទៅ ។ បទថា **អប្ផោដេន្តិ** បានដល់ លើកដៃឡើងប្រណម្យ ។ បទថា **ទសសហស្សី** បានដល់ លោកធាតុ ១ ម៉ឺន ។ បទថា **សទេវកា** សេចក្ដីថា ម៉ឺនលោកធាតុ និងទេវតាទាំងឡាយ ដែលឈ្មោះថា សទេវកៈ រមែងនមស្ការ ។ បទថា **យទិមស្ស** កាត់បទជា **យទិ** **ឥមស្ស** ឯបាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **វិរជ្ឈិស្សាម** បានដល់ បើមិនទាន់ ។ បទថា **អនាគតម្ហិ អទ្ធានេ** បានដល់ ក្នុងអនាគតកាល ។ បទថា **ហេស្សាម** បានដល់ នឹងជា ។ បទថា **សម្មុខា** បានដល់ ចំពោះមុខ ។ បទថា **ឥមំ** គឺ **ឥមស្ស** ទុតិយាវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ ប្រែថា របស់បុរសនេះ ។

បទថា **នទី តរន្តា** បានដល់ ដែលឆ្លងស្ទឹង បាឋៈថា **នទិតរន្តា** ដូច្នេះក៏មាន ។ បទថា **បដិតិត្ថំ** បានដល់ កំពង់ចំពោះមុខ ។ បទថា **វិរជ្ឈិយ** បានដល់ ឃ្លាងហើយ ។ បទថា **យទិ មុញ្ចាម** សេចក្ដីថា បើពួកយើងឃ្លាងព្រះមានព្រះភាគអង្គនេះ ដោយមិនបានធ្វើកិច្ច ។ បទថា **មម កម្មំ បកិត្តេត្វា** បានដល់ ទ្រង់ព្យាករប្រយោជន៍ដែលអាត្មាអញចម្រើនហើយ ។ បទថា **ឧក្ខិបិ ទក្ខិណំ បាទំ** បានដល់ ទ្រង់លើកព្រះបាទខាងស្ដាំ បាឋៈថា

**កតបញ្ជលិនោ** ដូច្នេះក៏មាន ។

បទថា **ជិនបុត្តា** បានដល់ សាវករបស់ព្រះសាស្តាទីបង្ករ ។ បទថា **ទេវា មនុស្សា អសុរា ច អភិវាទេត្វាន បក្កមុំ** សេចក្តីថា ជនទាំងអម្បាលម៉ាន មានទេវតាជាដើម ធ្វើប្រទក្សិណតថាគត ៣ ជុំ បូជាដោយផ្កាជាដើម តម្កល់អញ្ជលីយ៉ាងល្អ ថ្វាយបង្គំហើយក៏ត្រឡប់ សម្លឹងមើលរឿយៗ សរសើរដោយសាធុការច្រើនយ៉ាង ដែលមានអត្ថ ព្យញ្ជនៈដ៏ពីរោះហើយចៀសចេញទៅ បាឋៈថា **នរា នាគា ច គន្ធព្វា អភិវាទេត្វាន បក្កមុំ** ដូច្នេះក៏មាន ។

បទថា **ទស្សនំ មេ អតិក្កន្តេ** សេចក្តីថា កាលព្រះមានព្រះភាគកន្លងនូវទស្សនវិស័យនៃតថាគតទៅហើយ ។ បាឋៈថា **ជហិតេ ទស្សនូបចារេ** ដូច្នេះក៏មាន ។ បទថា **សសង្ឃេ** បានដល់ ព្រមជាមួយព្រះសង្ឃ ឈ្មោះថា **សសង្ឃ** ព្រមជាមួយសង្ឃនោះ ។ បទថា **សយនា វុដ្ឋហិត្វា** បានដល់ ក្រោកឡើងចាកកក់ដែលខ្ទនដេកហើយ ។ បទថា **បល្លង្កំ អាភុជឹ** សេចក្តីថា ធ្វើភ្នែន គឺអង្គុយពត់ភ្នែកលើគំនរផ្កា ។ បាឋៈថា **ហដ្ឋោ ហដ្ឋេន ចិត្តេន អាសនា វុដ្ឋហឹ តទា** ( ត្រេកអរមានចិត្តរីករាយ ក្រោកឡើងចាកទីអង្គុយក្នុងខណៈនោះ ) ដូច្នេះក៏មាន ។ បាឋៈនោះមានអត្ថងាយយល់ហើយ ។

បទថា **បីតិយា ច អភិស្សន្នោ** បានដល់ មានបីតិជ្រួតជ្រាបពាល់ត្រូវហើយ ។ បទថា **វសីភូតោ** បានដល់ ដល់នូវភាពជាអ្នកជំនាញ ។ បទថា **ឈានេ** បានដល់ រូបាវចរជ្ឈាន និងអរូបាវចរជ្ឈាន ។ បទថា **សហស្សិយម្ហិ**

បានដល់ មួយម៉ឺន ។ បទថា **លោកម្ហិ** បានដល់ លោកធាតុ ។ បទថា **មេ សមា** បានដល់ ស្មើនឹងតថាគត ។ ទ្រង់ត្រាស់ដោយមិនប្លែកថា បុគ្គលដែលស្មើមិនមាន ឥឡូវនេះ កាលទ្រង់កំណត់សេចក្តីនោះ ទើបត្រាស់ថា អាត្មាអញឥតមានបុគ្គលស្មើក្នុងឥទ្ធិធម៌ទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទ្ធិធម្មេសុ** សេចក្តីថា ក្នុងឥទ្ធិធម៌ ៥ ។ បទថា **អលភឹ** បានដល់ បានទទួលហើយ ។ បទថា **ឦទិសំ សុខំ** បានដល់ សោមនស្សបែបនេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា គ្រានោះ សុមេធតាបសស្តាប់ព្យាកររបស់ព្រះទសពលហើយ សម្គាល់ភាពជាព្រះពុទ្ធ ហាក់បីដូចនៅក្នុងកណ្តាប់ដៃ ហើយក៏មានចិត្តត្រេកអរ មហាព្រហ្មក្នុងជាន់សុទ្ធាវាសទាំងឡាយក្នុងម៉ឺនលោកធាតុធ្លាប់ឃើញអតីតពុទ្ធ មកប្រកាសការទៀងទាត់ មិនប្រែប្រួលនៃព្រះតម្រាស់របស់ព្រះតថាគត ព្រោះឃើញបាដិហារ្យដែលកើតឡើង ក្នុងការព្យាករណ៍ពោធិសត្វដែលទៀងពិត សម្តែងការត្រេកអរជាមួយតថាគតបានពោលគាថាទាំងនេះ ទើបត្រាស់ថា **បល្លង្កាភុជនេ មយ្ហំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **បល្លង្កាភុជនេ មយ្ហំ** បានដល់ ក្នុងការអង្គុយពត់ភ្នែនរបស់តថាគត ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **ទស-សហស្សាធិវាសិនោ** បានដល់ មហាព្រហ្មទាំងឡាយ ដែលនៅក្នុងម៉ឺនលោកធាតុ ។ បទថា **យា បុព្វេ** បានដល់ **យានិ បុព្វេ** ពាក្យនេះ គប្បីជ្រាបថា លោកពោលលុបវិភត្តិ ។ បទថា **បល្លង្កវរមាភុជេ** បានដល់ ក្នុង

ការអង្គុយពត់ភ្នែនយ៉ាងល្អ ។ បទថា **និមិត្តានិ បទិស្សន្តិ** សេចក្តីថា និមិត្តទាំងឡាយប្រាកដហើយ កាលគួរពោលពាក្យជាអតីតកាល ក៏ពោលពាក្យជាបច្ចុប្បន្នកាល សូម្បីពាក្យពោលដែលជាបច្ចុប្បន្នកាល តែក៏គួកាន់យកជាអតីតកាល ។ បទថា **តានិ អជ្ជ បទិស្សរេ** សេចក្តីថា និមិត្តទាំងឡាយណាកើតឡើងហើយ ក្នុងការដែលនិយតពោធិសត្វទាំងឡាយអង្គុយពត់ភ្នែនក្នុងកាលមុន និមិត្តទាំងនោះក៏ឃើញក្នុងថ្ងៃនេះ ព្រោះហេតុនោះ អ្នកនឹងបានជាព្រះពុទ្ធប្រាកដ ។ តែមិនមែននិមិត្តទាំងនោះប៉ុណ្ណោះដែលកើតឡើងហើយ ។ បទថា **និមិត្តានិ បទិស្សន្តិ** គប្បីជ្រាបថា លោកពោល ក៏ព្រោះដូចនិមិត្តដែលកើតឡើងហើយនោះ ។

បទថា **សីតំ** បានដល់ មានអាកាសត្រជាក់ ។ បទថា **ព្យបគតំ** បានដល់ ទៅហើយ ទៅប្រាសហើយ ។ បទថា **តានិ** សេចក្តីថា ត្រជាក់ក៏ស្ងប់ទៅ ក្តៅក៏ស្ងប់ទៅ ។ បទថា **និស្សទ្ទា** បានដល់ មិនមានសំឡេង មិនខ្វះខ្វារ ។ បទថា **និរាកុលា** បានដល់ មិនរីករវ ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **ន សន្ទន្តិ** បានដល់ មិននាំទៅ មិនហូរទៅ ។ បទថា **សវន្តិយោ** បានដល់ ស្ទឹងទាំងឡាយ ។ បទថា **តានិ** បានដល់ មិនបោកបក់ មិនហូរ ។ បទថា **ថលជា** បានដល់ ផ្កាដែលកើតត្រង់ដើមឈើលើផែនដី និងលើភ្នំ ។ បទថា **ទកជា** បានដល់ ផ្កាដែលកើតក្នុងទឹក ។ បទថា **បុប្ផន្តិ** បានដល់ រីកហើយ ដល់ព្រះពោធិសត្វទាំងឡាយក្នុងកាលមុន ។ ពាក្យជាបច្ចុប្បន្ន ចុះក្នុងអត្ថអតីតកាល គប្បីជ្រាបដោយន័យដែល

ពោលហើយខាងដើមនោះឯង ។ បទថា **តេបជ្ជ បុប្ផិតានិ** សេចក្តីថា ផ្កាទាំងនោះរីកហើយក្នុងថ្ងៃនេះ ។

បទថា **ផលភារា** បានដល់ ទ្រទ្រង់នូវផ្លែ ។ បទថា **តេបជ្ជ** កាត់បទជា **តេបិ អជ្ជ** លោកពោលថា **តេបិ** ដោយជាបុំលិង្គ ព្រោះលោកពោលថា **លតា វា រុក្ខា វា**។ បទថា **ផលិតា** បានដល់ ចេញផ្លែហើយ ។ បទថា **អាកាសដ្ឋា ច ភុម្មដ្ឋា** បានដល់ តាំងនៅក្នុងអាកាស និងតាំងនៅលើផែនដី ។ បទថា **រតនានិ** បានដល់ រតនៈទាំងឡាយ មានកែវមុក្តាជាដើម ។ បទថា **ជោតន្តិ** បានដល់ ពន្លឺរុងរឿង ។ បទថា **មានុស្សកា** បានដល់ ជារបស់មនុស្សទាំងឡាយ ឈ្មោះថា ដែលជារបស់មនុស្ស ។ បទថា **ទិព្វា** បានដល់ ជារបស់ទេវតាទាំងឡាយ ឈ្មោះថា ជារបស់ទេវតា ។ បទថា **តុរិយា** បានដល់ តន្ត្រី ៥ គឺអាតតៈ វិតតៈ អាតតវិតតៈ សុសិរៈ និងឃនៈ ។ បណ្តាតន្ត្រីទាំងនោះ តន្ត្រីមានស្គរជាដើមដែលពាសដោយស្បែក តន្ត្រីដែលពាសដោយស្បែកម្ខាង ឈ្មោះថា **អាតត** តន្ត្រីដែលពាសដោយស្បែកទាំងសងខាង ឈ្មោះថា **វិតត** តន្ត្រី មានពិណធំជាដើម ដែលពាសដោយស្បែក ឈ្មោះថា **អាតតវិតត** តន្ត្រី មានប៉ីជាដើម ឈ្មោះថា **សុសិរ** តន្ត្រី មានឈិងជាដើម ឈ្មោះថា **ឃន**។ បទថា **វជ្ជន្តិ** បានដល់ ប្រគំហើយ ដោយន័យដូចពោលមកហើយខាងដើម ពាក្យនេះ ជាបច្ចុប្បន្នកាល គប្បីជ្រាបថា ប្រើក្នុងអត្ថអតីតកាល សូម្បីក្នុងពាក្យតទៅក៏ន័យនេះ ។ បទថា **អភិរវន្តិ** សេចក្តីថា ស្រែកខ្លាំង បន្លឺដូចតន្ត្រីអ្នកឈ្លាសបន្លឺហើយ ប្រគំ

ហើយ ច្រៀងហើយ ។

បទថា **វិចិត្តបុប្ផា** បានដល់ ផ្កាដែលល្អ មានក្លិន និងពណ៌ផ្សេងៗ ។ បទថា **អភិវស្សន្តិ** បានដល់ ធ្លាក់ចុះហើយ អធិប្បាយថា ជ្រុះហើយ ។ បទថា **តេបិ** សេចក្តីថា ផ្កាដ៏ល្អទាំងនោះ ធ្លាក់ចុះក៏ឃើញក្នុងថ្ងៃនេះ អធិប្បាយថា ពួកទេវតា និងព្រហ្មបាចចុះមក ។ បទថា **អាកុជតិ** បានដល់ មូរត្រឡប់ ។ បទថា **តេបជ្ជភោ** បានដល់ មហាសមុទ្រ និងម៉ឺនលោកធាតុទាំងពីរនោះថ្ងៃនេះ ។ បទថា **អភិរវន្តិ** បានដល់ បន្លឺសំឡេងដ៏ក្រៃលែង ។ បទថា **និរយេ** បានដល់ ក្នុងនរកទាំងឡាយ ។ បទថា **ទសសហស្សា** បានដល់ មិនមែន ១ ម៉ឺន ។ បទថា **និព្វន្តិ** បានដល់ ស្ងប់ អធិប្បាយថា ដល់នូវការស្ងប់ ។ បទថា **តារកា** បានដល់ ផ្កាយព្រឹកទាំងឡាយ ។ បទថា **តេបិ អជ្ជ បទិស្សន្តិ** សេចក្តីថា ផ្កាយទាំងនោះក៏ឃើញពេលថ្ងៃក្នុងថ្ងៃនេះ ព្រោះព្រះអាទិត្យផូរផង់ ឥតមន្ទិល ។

បទថា **អនោវដ្ឋេន** សេចក្តីថា មិនធ្លាប់ចុះ ពាក្យថា នេះ ជាតតិយាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ។ ម្យ៉ាងទៀត បទថា **អនោវដ្ឋេ** បានដល់ មិនមានអ្វីបិទបាំងក៏មាន ។ បទថា **ច** ត្រឹមតែជានិបាត ដូចក្នុងប្រយោគជាដើមថា **សុត្វា ច ទូតវចនំ** ( ស្តាប់របស់ពាក្យទូត ) ។ បទថា **តម្បជ្ជភិជ្ជតេ** សេចក្តីថា ស្ទឹងនោះ ក៏ផុលឡើងក្នុងថ្ងៃនេះ អធិប្បាយថា ជ្រែកផុសឡើង ។ បទថា **មហិយា** បានដល់ ផែនដី ពាក្យនេះ ជាបញ្ចមីវិភត្តិ ។ បទថា **តារាគណា** បានដល់ ពួកផ្កាយទាំងឡាយ មានផ្កាយគ្រោះ និងផ្កាយនក្ខត្ត-

ឫក្សជាដើម ។ បទថា **នក្ខត្តា** បានដល់ ផ្កាយឫក្សទាំងឡាយ ។ បទថា **គគនមណ្ឌលេ** សេចក្ដីថា បញ្ចេញពន្លឺពេញមណ្ឌលអាកាស ។ បទថា **ពិលាសយា** បានដល់ សត្វដែលនៅក្នុងរន្ធ មានពស់ ស្ការ ក្រពើ និងទន្សងជាដើម ។ បទថា **ទរីសយា** បានដល់ សត្វដែលនៅក្នុងជ្រោះ ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **និក្ខមន្តិ** បានដល់ ចេញទៅហើយ ។ បទថា **សកាសយា** បានដល់ ចាកលំនៅរៀងៗ ខ្លួន ។ បាឋៈថា **តទាសយា** ដូច្នេះក៏មាន ។ បាឋៈនោះ មានសេចក្ដីថា ក្នុងកាលនោះ គឺក្នុងកាលនោះចេញចាកលំនៅ គឺរន្ធ ។ បទថា **ចុតា** បានដល់ ដែលគេបន្សាត់ទៅហើយ ឡើងទៅហើយ គឺចេញទៅ ។ បទថា **អរតិ** បានដល់ ការអផ្សុក ។ បទថា **សន្តុដ្ឋា** បានដល់ ពេញចិត្ត ដោយការពេញចិត្តយ៉ាងក្រៃលែង ។ បទថា **វិនស្សតិ** បានដល់ ទៅប្រាស ។ បទថា **រាគោ** បានដល់ កាមរាគៈ ។ បទថា **តទា តនុ ហោតិ** បានដល់ មានប្រមាណតិច ទ្រង់សម្ដែងបរិយុដ្ឋានកិលេសដោយបទនេះ ។ បទថា **វិគតា** បានដល់ សាបសូន្យ ។ បទថា **តទា** បានដល់ គ្រាមុន អធិប្បាយថា កាលព្រះពោធិសត្វទាំងឡាយអង្គុយពត់ភ្នែន ។ បទថា **ន ភវតិ** បានដល់ មិនមានប្រាកដ ។ បទថា **អជ្ឈុបេតំ** សេចក្ដីថា កាលលោកអង្គុយពត់ភ្នែកក្នុងថ្ងៃនេះ ភ័យនោះក៏មិនមាន ។ បទថា **តេន លិង្គេន ជានាម** សេចក្ដីថា ពួកយើងគ្រប់គ្នារមែងដឹងដោយហេតុដែលលោកនឹងបានជាព្រះពុទ្ធ ។

បទថា **អនុន្នមតិ** បានដល់ មិនផ្សាយឡើង ។ បទថា **អនិជ្ជគតោ**

បានដល់ ក្លិនស្អុយ ។ បទថា **បក្កមតិ** បានដល់ បាត់ទៅហើយ ប្រាសទៅហើយ ។ បទថា **បវាយតិ** បានដល់ បក់មក ។ បទថា **សោបជ្ជ** បានដល់ ក្លិនទិព្វនោះ ក្នុងថ្ងៃនេះ ។ បទថា **បទិស្សន្តិ** បានដល់ ឃើញគ្នាហើយ ។ បទថា **តេបជ្ជ** បានដល់ ទេវតាទាំងអស់ក្នុងថ្ងៃនេះ ។ សព្ទថា **យាវតា** ជានិបាត ចុះក្នុងអត្ថថា កំណត់ សេចក្តីថា មានប្រមាណប៉ុនណា ។ បទថា **កុដ្ដា** បានដល់ កំពែង ។ បទថា **ន ហោន្ដាវរណា** បានដល់ ធ្វើការរាំងមិនបាន ។ បទថា **តទា** បានដល់ គ្រាមុន ។ បទថា **អាកាសភូតា** បានដល់ កំពែងសន្ទះទ្វារ និងភ្នំទាំងនោះ មិនអាចធ្វើការរាំង ធ្វើខាងក្រៅបាន អធិប្បាយថា អាកាសទទេ ។ បទថា **ចុតិ** បានដល់ មរណៈ ។ បទថា **ឧបបត្តិ** បានដល់ បដិសន្ធិ ។ បទថា **ខណេ** បានដល់ ក្នុងខណៈព្រះពោធិសត្វទាំងឡាយ អង្គុយពត់ភ្នែនក្នុងកាលមុន ។ បទថា **ន វិជ្ជតិ** បានដល់ មិនមានហើយ ។ បទថា **តាជ្ជិបជ្ជ** សេចក្តីថា ចុតិបដិសន្ធិក្នុងថ្ងៃទាំងនោះ ។ បទថា **មា និវត្តិ** បានដល់ សូមកុំថយក្រោយ ។ បទថា **អភិក្កម** បានដល់ ចូរឈានទៅខាងមុខ ពាក្យដ៏សេសក្នុងរឿងនេះ មានអត្ថងាយយល់ហើយ ។

ក្រោយអំពីសុមេធបណ្ឌិត ស្ដាប់ពាក្យរបស់ព្រះទីបង្ករទសពល និងរបស់ទេវតាទាំងឡាយ ក្នុងម៉ឺនចក្កវាឡហើយ ក៏កើតឧស្សាហៈដ៏ក្រៃលែងគិតថា ធម្មតាព្រះពុទ្ធទាំងឡាយ មានព្រះវាចាមិនទទេ ព្រះវាចារបស់ព្រះពុទ្ធទាំងឡាយមិនប្រែប្រួល ដូចដុំដីដែលបោះទៅក្នុងអាកាស ក៏នឹងធ្លាក់ពិតប្រាកដ

សត្វដែលកើតមកហើយក៏ស្លាប់ កាលអរុណរះ ព្រះអាទិត្យ ក៏ឡើងកាន់វេហាស៍ រាជសីហ៍ចេញអំពីលំនៅ ក៏បន្លឺសីហនាទ ស្ត្រីមានគភ៌ចាស់ ក៏នឹងដាក់ភារៈដោយពិត យ៉ាងនេះដោយពិត យ៉ាងណា ធម្មតាព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយក៏ពិតប្រាកដ មិនទទេ យ៉ាងនោះដូចគ្នា អញនឹងបានជាព្រះពុទ្ធពិតប្រាកដ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

តថាគត លុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និងទេវតាទាំងមួយម៉ឺនចក្រវាលហើយ ក៏ត្រេកអរ ស្រស់ស្រាយរីករាយ គិតក្នុងកាលនោះយ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ព្រះជិនស្រីទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ដុំដីដែលគេចោលទៅឰដ៏អាកាស ទៀងតែធ្លាក់មកលើផែនដីវិញ យ៉ាងណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ ប្រាកដយ៉ាងនោះដែរ ។ ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះឃ្លៀងឃ្លាត អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ សេចក្តីស្លាប់របស់សព្វសត្វ ទៀងទាត់ ប្រាកដ យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ទៀងទាត់ ប្រាកដដូច្នោះដែរ ។ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែរះឡើង

យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ទៀងទាត់ ប្រាកដយ៉ាងនោះដែរ ។ សីហៈដែលចេញអំពីដំណេក តែងបន្លឺសំឡេង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ទៀងទាត់ ប្រាកដយ៉ាងនោះដែរ ។ ការសម្រាលគភ៌នៃស្រីដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់ យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធ ដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដយ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពុទ្ធស្ស វចនំ សុត្វា ឧសសហាស្សៀនចូភយំ** សេចក្ដីថា ស្ដាប់ព្រះតម្រាស់របស់ព្រះទីបង្ករសម្មាសម្ពុទ្ធ និងរបស់ទេវតាក្នុងម៉ឺនចក្កវាឡ ។ បទថា **ឧភយំ** បានដល់ **ឧភយេសំ** ពាក្យនេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ ឬពាក្យទាំង ២ ។ បទថា **ឯវំ ចិន្តេសហំ** កាត់បទជា **ឯវំ ចិន្តេសឹ អហំ** ។

បទថា **អទ្វេជ្ឈវចនា** បានដល់ មានព្រះតម្រាស់មិនបែកជា ២ អធិប្បាយថា មានព្រះតម្រាស់តែមួយ៉ាង ។ បាឋៈថា **អច្ឆិន្នវចនា** ដូច្នេះក៏មាន បាឋៈមានសេចក្ដីថា មានព្រះតម្រាស់មិនខុសក្លាំងក្លាត់ ។ បទថា **អមោឃវចនា** បានដល់ មានព្រះតម្រាស់មិនកុហក ។ បទថា **វិតថំ** សេចក្ដីថា ពាក្យកុហកមិនមាន ។ បទថា **ធុវំ ពុទ្ធោ ភវាមហំ** គប្បីជ្រាបថា លោកធ្វើជាពាក្យបច្ចុប្បន្នកាល ដោយជារឿងពិតប្រាកដ និងជារឿងមានដោយពិតថា អញនឹងបានជាព្រះពុទ្ធដោយចំណែកមួយ ។

បទថា **សុរិយុគ្គមនំ** បានដល់ ការរះរបស់ព្រះអាទិត្យ ប្រាប់ៈក៏យ៉ាង នោះដូចគ្នា ។ បទថា **ធុវសស្សតំ** បានដល់ មានភាពជាចំណែកមួយ និង ទៀងពិត ។ បទថា **និក្ខន្តសយនស្ស** បានដល់ ដែលចេញទៅអំពីដំណេក ។ បទថា **អាបន្នសត្តានំ** បានដល់ សត្វដែលមានគភ៌ចាស់ អធិប្បាយថា អ្នកមានគភ៌ ។ បទថា **ភារមោរោបនំ** បានដល់ ដាក់ភារៈចុះ អធិប្បាយ ថា ដាក់ចុះនូវគភ៌ ។ **ម** អក្ខរៈ ធ្វើនូវការភ្ជាប់បទ ពាក្យដ៏សេស ក្នុង សេចក្តីនេះ មានអត្ថងាយយល់ហើយ ។

សុមេធបណ្ឌិត ធ្វើនូវការសម្រេចចិត្តយ៉ាងនេះថា អញនឹងបានត្រាស់ ជាព្រះពុទ្ធដោយពិត ដើម្បីពិចារណាដល់ពុទ្ធការកធម៌ទាំងឡាយ ទើបត្រិះរិះ ថា ពុទ្ធការកធម៌ទាំងឡាយនៅទីណាហ្ន៎ កាលជ្រើសរើសធម្មធាតុទាំងមូល ដោយលំដាប់ថា នៅខាងលើ ខាងក្រោម ក្នុងទិសធំ ទិសតូចទាំងឡាយ ក៏ ឃើញទានបារមីជាលំដាប់ដំបូង ដែលបុរាណពោធិសត្វទាំងឡាយក្នុងកាល មុនសេពជាប្រចាំមក ទើបទូន្មានខ្លួនយ៉ាងនេះថា នែសុមេធបណ្ឌិត តាំងពី នេះទៅ អ្នកគប្បីបំពេញទានបារមីមុន ដូចក្អមទឹកដែលគេផ្កាប់ រមែងហូរទឹក ចេញមិនមានសេសសល់ មិននាំទឹកត្រឡប់ចូលទៅ យ៉ាងណា អ្នកក៏មិន គប្បីស្តាយទ្រព្យ ឬយស បុត្ត ភរិយា និងអវយវៈតូចធំ កាលឲ្យគ្រប់ យ៉ាង ដែលយាចកត្រូវការ មិនបន្សល់ទុកក្នុងទីទាំងពួង ក៏នឹងអង្គុយជា ព្រះពុទ្ធត្រង់គល់ពោធិព្រឹក្ស ដូច្នេះហើយ អធិដ្ឋានទានបារមីឲ្យមាំជាលំដាប់ ដំបូង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។ កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវទានបារមីជាដំបូងនេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះចាក់មិនឲ្យសល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឲ្យទានកុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **හන្ទ** ជានិបាត ចុះក្នុងអត្ថថាអញ្ជើញ ។ បទថា **ពុទ្ធករេ ធម្មេ** បានដល់ ធម៌ដែលធ្វើភាពជាព្រះពុទ្ធធម៌ ១០ ប្រការ មានទានបារមីជាដើម ឈ្មោះថា ពុទ្ធការកធម៌ ។ បទថា **វិចិនាមិ** បានដល់ នឹងជ្រើសរើស អធិប្បាយថា នឹងស្រាវជ្រាវ នឹងស្ទាបស្ទង់ ។ បទថា **ឥតោ ចិតោ** បានដល់ ខាងនោះ ខាងនេះ ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ សេចក្តីថា ជ្រើសរើសក្នុងទីនោះៗ ។ បទថា **ឧទ្ធំ** បានដល់ ក្នុងទេវលោក ។ បទថា **អធោ** បានដល់ ក្នុងមនុស្សលោក ។ បទថា **ទសទិសា** បានដល់ ក្នុងទិស

ទាំង ១០ អធិប្បាយថា ពុទ្ធការធម៌ទាំងនោះ នៅក្នុងទីណាហ្ន៎ ខាងលើ ខាងក្រោម ទទឹង ក្នុងទិសធំ ទិសតូច ។ ពាក្យថា **យាវតា** ក្នុងពាក្យថា **យាវតា ធម្មធាតុយា** នេះ ជាពាក្យពោលកំណត់ ។ បទថា **ធម្មធាតុយា** បានដល់ នៃសភាវធម៌ គប្បីឃើញថា បន្ថែមពាក្យដ៏សេសថា បវត្តន័យ ប្រែថា ការប្រព្រឹត្តទៅនៃសភាវធម៌ លោកអធិប្បាយដូចម្ដេច លោកអធិប្បាយថា នឹងជ្រើសរើសត្រឹមសភាវធម៌ គឺធម៌ចំណែកកាមាវចរ រូបាវចរ អរូបាវចរ ប្រព្រឹត្តទៅ ។

បទថា **វិចិនន្តោ** បានដល់ ស្រាវជ្រាវ ស្ទាបស្ទង់ ។ បទថា **បុព្វកេហិ** បានដល់ ដែលព្រះពោធិសត្វទាំងឡាយអង្គមុនៗ ។ បទថា **អនុចិណ្ណំ** បានដល់ សន្សំ សេពមកហើយ ។ បទថា **សមាទិយ** បានដល់ ចូរធ្វើការសមាទាន អធិប្បាយថា ចូរសមាទានយ៉ាងនេះថា តាំងអំពីថ្ងៃនេះ អាត្មាអញគួរបំពេញទានបារមីនេះមុន ។ បទថា **ទានបារមិតំ គច្ឆ** បានដល់ ចូរដល់នូវទានបារមី អធិប្បាយថា ចូរធ្វើឲ្យពេញ ។ បទថា **យទិ ពោធឹ បត្តុមិច្ឆសិ** សេចក្ដីថា បើអ្នកប្រាថ្នានឹងចូលកាន់គល់ពោធិព្រឹក្ស ហើយត្រាស់ដឹងអនុត្តរសម្មាសម្ពោធិ ។ បទថា **យស្ស កស្សចិ** សេចក្ដីថា ពេញដោយទឹក ឬទឹកដោះណាមួយ កាលប្រកប **សម្បុណ្ណោ** សព្ទ អ្នកប្រាជ្ញខាងសព្ទសាស្ត្រ បំណងឲ្យជាឆដ្ឋីវិភត្តិ ឬឆដ្ឋីវិភត្តិ ចុះក្នុងអត្ថ តតិយាវិភត្តិ ។ សេចក្ដីថា ដោយទឹកណាមួយ ។ បទថា **អធោកតោ** បានដល់ ផ្កាប់មាត់ចុះក្រោម ។ បទថា **ន តត្ថ បរិរក្ខតិ** បានដល់ មិនរក្សា ក្នុងសេចក្ដីនោះ

អធិប្បាយថា បង្ហូរទឹកចេញមិនឲ្យសេសសល់ ។ បទថា **ហីនមុក្កដ្ឋមជ្ឈិមេ** បានដល់ ជាន់ទាប ជាន់កណ្ដាល និងជាន់ខ្ពស់ ។ **ម** អក្ខរៈ គ្រាន់តែជាបទសន្ធិ ។ បទថា **កុម្ភោ វិយ អធោកតោ** បានដល់ ដូចក្អមដែលផ្កាប់ ។ សុមេធបណ្ឌិតទូន្មានខ្លួនឯងយ៉ាងនេះថា នែសុមេធ អ្នកជួបយាចកដែលចូលទៅរក ចូរបំពេញទានបារមី ដោយបរិច្ចាគទ្រព្យទាំងអស់របស់ខ្លួន មិនឲ្យសេសសល់ ចូរបំពេញឧបបារមី ដោយបរិច្ចាគអវយវៈ និងចូរបំពេញបរមត្ថបារមី ដោយការបរិច្ចាគជីវិត ។

លំដាប់នោះ សុមេធបណ្ឌិតនោះ ពិចារណាក្រៃលែងឡើងថា ពុទ្ធការកធម៌ មិនមែនមានត្រឹមប៉ុណ្ណោះទេ ក៏ឃើញសីលបារមីជាលំដាប់ទី ២ ក៏ទូន្មានខ្លួនឯងយ៉ាងនេះថា នែសុមេធបណ្ឌិត តាំងពីពេលនេះទៅ អ្នកគួរបំពេញសីលបារមី ឈ្មោះថា សត្វចាមរី មិនអាឡោះអាល័យសូម្បីតែជីវិតរមែងរក្សារោមកន្ទុយរបស់ខ្លួនតែម្យ៉ាង យ៉ាងណា តាំងអំពីនេះទៅ អ្នកកុំអាឡោះអាល័យក្នុងជីវិត រក្សាសីលតែម្យ៉ាង ដូច្នេះហើយ នឹងបានត្រាស់ជាព្រះពុទ្ធ ទើបអធិដ្ឋានសីលបារមីទី ២ យ៉ាងមាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញសីលបារមីទី ២ ដែលពោធិសត្វ

ទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយ ទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកឯងចូរសមាទាន ធ្វើសីលបារមីទី ២ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។ សត្វចាមរី ( កាលឃើញ ) រោមកន្ទុយជំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្ដាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឲ្យដូចជាសត្វចាមរី រក្សាកន្ទុយយ៉ាងនោះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន ហោតេ** បានដល់ **ន ហិ ឃាតេយេវ** ។ បទថា **ពោធិបាចនា** បានដល់ អប់រំបន្ទុំមគ្គ ឬអប់រំបន្ទុំព្រះសព្វញ្ញុតញ្ញាណ ។ បទថា **ទុតិយំ សីលបារមី** សេចក្ដីថា ធម្មតាសីល ជាទីតាំងនៃកុសល-ធម៌គ្រប់យ៉ាង អ្នកតាំងនៅក្នុងសីល រមែងមិនសាបសូន្យចាកកុសលធម៌ទាំងឡាយ ទាំងបានសម្រេចគុណ ជាចំណែកលោកិយ និងលោកុត្តរគ្រប់យ៉ាង ព្រោះហេតុនោះ ទើបឃើញសីលបារមីជាលំដាប់ទី ២ ថា គួរបំពេញសីលបារមី ។

បទថា **អសេវិតនិសេវិតំ** បានដល់ ចម្រើនហើយ និងធ្វើឲ្យច្រើនហើយ ។ បទថា **ចមរី** បានដល់ ម្រឹគចាមរី ។ បទថា **កិស្មិញ្ចិ** បានដល់ ក្នុងទីណាមួយ គឺក្នុងដើមឈើ វល្លិ ឬបន្ទាជាដើមណាមួយ ។ បទថា **បដិ-លគ្គិតំ** បានដល់ ជាប់ ។ បទថា **តត្ថ** សេចក្ដីថា រោមកន្ទុយជាប់ក្នុង

ទីណា សត្វចាមរីក៏ឈរព្រមស្លាប់ក្នុងទីនោះ ។ បទថា **ឆ វិកោបេតិ** បានដល់ មិនធ្វើឲ្យដាច់ ។ បទថា **វាលធិ** បានដល់ មិនផ្តាច់រោមកន្ទុយ អធិប្បាយថា ព្រមស្លាប់ក្នុងទីនោះឯង ។ បទថា **ចតូសុ ភូមីសុ សីលានិ** សេចក្តីថា សីលទាំងឡាយ ចែកជា ៤ ឋានៈ គឺបាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ។ តែបើពោលដោយភូមិ សីល ៤ នោះ ទាក់ទងក្នុងភូមិ ២ នោះឯង ។ បទថា **បរិបូរយ** បានដល់ ចូរឲ្យបរិបូណ៌ដោយមិនដាច់កំណាត់ មិនធ្លុះ មានមន្ទិលជាដើម ។ បទថា **សព្វទា** បានដល់ សព្វកាល ។ បទថា **ចមរី វិយ** បានដល់ ដូចម្រឹគចាមរី ។ ពាក្យដ៏សេស ក្នុងសេចក្តីនេះ មានអត្ថងាយយល់ហើយ ។

លំដាប់នោះ សុមេធបណ្ឌិតនោះ ពិចារណាក្រៃលែងឡើងថា ពុទ្ធ-ការកធម៌ មិនមែនមានត្រឹមប៉ុណ្ណោះទេ ក៏ឃើញនេក្ខម្មបារមីជាលំដាប់ទី ៣ ទើបទូន្មានខ្លួនឯងយ៉ាងនេះថា នែសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកគប្បីបំពេញនេក្ខម្មបារមី បុរសដែលនៅក្នុងគុកយូរហើយ រមែងមិនស្រឡាញ់គុកនោះ ដែលពិត ក៏ខ្ពើមរអើម មិនចង់នៅ យ៉ាងណា ខ្លួនអ្នកក៏ចូរឃើញភពទាំងពួងដូចគុក ចូរនឿយណាយចង់រួចផុតអំពីភពទាំងពួង បែរមុខទៅកាន់នេក្ខម្មៈតែម្យ៉ាង ក៏យ៉ាងនោះដូចគ្នា កាលបើដូច្នោះ អ្នកក៏នឹងបានត្រាស់ជាព្រះពុទ្ធ ហើយអធិដ្ឋាននេក្ខម្មបារមីលំដាប់ទី ៣ ឲ្យមាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញនេក្ខម្មបារមីទី ៣ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់ នៅក្នុងគុកអស់កាលយូរ ត្រូវសេចក្តីទុក្ខបៀតបៀន ហើយ រមែងមិនញុំាងសេចក្តីត្រេកអរឲ្យកើតឡើងក្នុង គុក នោះទេ រមែង ស្វែងរកការរួច ( ចាកគុកនោះ ) យ៉ាងណា អ្នកចូរឃើញនូវ ភពទាំងអស់ដូចជាគុកចុះ ចូរបែរមុខ ទៅរកនេក្ខម្មៈ ដើម្បីរួចចាកភពយ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អន្ទុឃរេ** បានដល់ ក្នុងគុកសម្រាប់ឃុំខាំង ។ បទថា **ចិរវុដ្ឋោ** បានដល់ នៅអស់កាលយូរ ។ បទថា **ទុខទ្ទិតោ** បានដល់ ត្រូវសេចក្តីទុក្ខបៀតបៀន ។ បទថា **ឯ តត្ថ រាគំ ជនេតិ** សេចក្តីថា មិនញុំាងនូវការគិតត្រេកអរឲ្យកើតក្នុងគុកនោះ អធិប្បាយថា មិនញុំាងសេចក្តីត្រេកអរឲ្យកើតក្នុងគុកនោះយ៉ាងនេះថា បើអញរួចផុតអំពីគុកនេះហើយ នឹងមិនទៅទីដទៃ រមែងស្វែងរកតែវិធីរួចផុតប៉ុណ្ណោះ ។ បទ

ថា **នេក្ខម្មាភិមុខោ** បានដល់ ចូរបែរមុខចំពោះការបួស ។ បទថា **ភវ សោ** បានដល់ ចាកកពទាំងពួង ។ បទថា **បរិមុត្តិយា** បានដល់ ដើម្បីរួចផុត បាឋៈថា **នេក្ខម្មាភិមុខោ ហុត្វា សម្ពោធឹ បាបុណិស្សសិ** ( អ្នកបែរមុខចំពោះនេក្ខម្មៈហើយ នឹងសម្រេចសម្ពោធិញ្ញាណបាន ) ដូច្នេះក៏មានពាក្យដ៏សេស ក្នុងសេចក្តីនោះ មានអត្ថងាយយល់ហើយ ។

លំដាប់នោះ សុមេធបណ្ឌិតកាលពិចារណាជាក្រៃលែងឡើងថា ពុទ្ធ-ការកធម៌ មិនមែនមានត្រឹមប៉ុណ្ណោះទេ ក៏ឃើញបញ្ញាបារមីជាលំដាប់ទី ៤ ហើយទូន្មានខ្លួនឯងយ៉ាងនេះថា នែសុមេធ តាំងអំពីនេះទៅ អ្នកគប្បីបំពេញបញ្ញាបារមី មិនគប្បីវៀរមនុស្សថោកថយ មនុស្សថ្នាក់កណ្តាល មនុស្សថ្នាក់ខ្ពស់ណាមួយឡើយ ចូលទៅរកបណ្ឌិតគ្រប់ទិសទី ហើយសួរបញ្ហា ។ ភិក្ខុសមាទានបិណ្ឌបាតជាវត្ត មិនវៀរត្រកូលទាំងឡាយ មានត្រកូលថោកទាបជាដើមណាមួយ ត្រាច់បិណ្ឌបាតទៅតាមលំដាប់ រមែងបាននូវអាហារល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន យ៉ាងណា សូម្បីអ្នក ក៏ចូលទៅរកបណ្ឌិតទាំងអស់ សាកសួរបញ្ហាយ៉ាងនោះដូចគ្នា ក៏នឹងបានត្រាស់ជាព្រះពុទ្ធ ហើយអធិដ្ឋានបញ្ញាបារមីលំដាប់ទី ៤ ឲ្យមាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញ
> នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាង
> ពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើស

> វើសវក ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើបញ្ញាបារមីទី ៤ នេះឲ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។ ភិក្ខុកាល ប្រព្រឹត្តបិណ្ឌបាត មិនវៀលវនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរជន ជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភិក្ខុ ភិក្ខន្តោ** បានដល់ ដែលត្រាច់ទៅ ដើម្បីដុំបាយ ។ បទថា **ហីនមុក្កដ្ឋមជ្ឈិមេ** សេចក្តីថា ទាំងត្រកូលទាប ទាំងខ្ពស់ និងជាន់កណ្តាល ។ លោកធ្វើឲ្យជាលិង្គវិបល្លាស ។ បទថា **ន វិវជ្ជេន្តោ** បានដល់ មិនវៀរ អធិប្បាយថា ភិក្ខុលះលំដាប់ផ្ទះត្រាច់បិណ្ឌបាត ឈ្មោះថាវៀរ យ៉ាងណា មិនធ្វើយ៉ាងនោះ ។ បទថា **យាបនំ** សេចក្តីថា រមែងបានអាហារល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ គឺតម្កល់ជីវិត ។ បទថា **បរិបុច្ឆំ** សេចក្តីថា ចូលទៅរកបណ្ឌិតដែលមានកេរ្តិ៍ឈ្មោះក្នុងទីនោះៗ សាកសួរដោយន័យជាដើមថា បពិត្រលោកម្ចាស់ អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីមិនមានទោស ដូច្នេះ ។ បទថា **ពុធំ ជនំ** បានដល់ ជនដែលជាបណ្ឌិត ។

បាឋៈថា **ពុធេ ជនេ** ដូច្នេះក៏មាន ។ បទថា **បញ្ញាយ ចារមឹ** បានដល់ត្រើយនៃបញ្ញាបារមី ។ បាឋៈថា **បញ្ញាចារមិតំ គន្ត្វា** ដូច្នេះក៏មាន ។ ពាក្យដ៏សេស ក្នុងសេចក្តីនេះ មានអត្ថងាយយល់ហើយ ។

លំដាប់នោះ សុមេធបណ្ឌិតនោះ ពិចារណាក្រៃលែងឡើងថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ ក៏ឃើញវិរិយបារមីជាលំដាប់ទី ៥ ទើបទូន្មានខ្លួនឯងយ៉ាងនេះថា នៃសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកត្រូវបំពេញវិរិយបារមី ។ រាជសីហ៍ស្តេចម្រឹគ មានសេចក្តីព្យាយាមមាំ ក្នុងឥរិយាបថទាំងអស់ យ៉ាងណា សូម្បីខ្លួនអ្នក ក៏ត្រូវមានសេចក្តីព្យាយាមមាំ មានសេចក្តីព្យាយាមមិនធូរថយ ក្នុងឥរិយាបថទាំងពួង ក្នុងភពទាំងពួង ក៏យ៉ាងនោះ ទើបអ្នកបានត្រាស់ជាព្រះពុទ្ធ ហើយអធិដ្ឋានវិរិយបារមីទី ៥ យ៉ាងមាំទាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញវិរិយបារមីទី ៥ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើវិរិយបារមីទី ៥ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវិរិយបារមីចុះ ។ សត្វសីហៈ ជាស្តេចនៃម្រឹគ

មានព្យាយាមមិនរួញរា មានចិត្តផ្គួងសព្វកាល ក្នុងការ
អង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គួង ព្យាយាមឲ្យ
មាំមួនក្នុងភពទាំងពួង យ៉ាងនោះចុះ លុះដល់វិរិយបារមី
ហើយ នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អលីនវីរិយោ** បានដល់ មានសេចក្តីព្យាយាម មិនធូរថយ ។ បទថា **សព្វភវេ** បានដល់ ក្នុងភពដែលកើតហើយកើតទៀត អធិប្បាយថា ក្នុងភពទាំងពួង ។ បាឋៈថា **អារទ្ធវីរិយោ ហុត្វា សម្ពោធឹ ធាបុណិស្សសិ** ( អ្នកប្រារព្ធព្យាយាមហើយ នឹងសម្រេចពោធិញ្ញាណបាន ) ដូច្នេះក៏មាន ពាក្យដ៏សេស ក្នុងសេចក្តីនេះ មានអត្ថងាយយល់ហើយ ។

លំដាប់នោះ សុមេធបណ្ឌិតពិចារណាក្រៃលែងឡើងថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ ក៏ឃើញខន្តិបារមីជាលំដាប់ទី ៦ ទើបទូន្មានខ្លួនឯងយ៉ាងនេះថា នែសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកត្រូវបំពេញខន្តិបារមី ត្រូវអត់ធន់ ទាំងក្នុងការសរសើរ ទាំងក្នុងការមើលងាយ ដូចជនទាំងឡាយ លះបង់របស់ស្អាតខ្លះ របស់មិនស្អាតខ្លះ លើផែនដីៗ ក៏មិនធ្វើសេចក្តីស្រឡាញ់ ឬការអាក់អន់ ដោយហេតុនោះ រមែងអត់ធន់បានទាំងអស់ យ៉ាងណា សូម្បីខ្លួនអ្នក ក៏ត្រូវអត់ធន់ក្នុងការសរសើរ និងការមើលងាយរបស់មនុស្សទាំងពួងបាន ក៏យ៉ាងនោះដូចគ្នា ទើបនឹងបានត្រាស់ជាព្រះពុទ្ធ ហើយអធិដ្ឋានខន្តិបារមីជាលំដាប់ទី ៦ ឲ្យមាំទាំ ដោយហេតុនោះ

ទើបព្រះមានព្រះភាគត្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើខន្តិបារមីទី ៦ នេះឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរ ក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយរបស់ពួកជនទាំងពួង យ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងខន្តិបារមីនោះ ។ បទថា **អទ្វេជ្ឈមានសោ** បានដល់ មានចិត្តដោយចំណែកមួយ ។ បទថា **សុចិម្បិ** បានដល់ របស់ស្អាត មានខ្លឹមចន្ទន៍ ស្បូវភ្លាំង គ្រឿងក្រអូប និងផ្កាជាដើម ។ បទថា **អសុចិម្បិ** បានដល់ របស់មិនស្អាត មានគម្រង់ពស់

គម្រង់ឆ្កែ គម្រង់មនុស្ស ទឹកមូត្រ ទឹកមាត់ ទឹកសម្បោរជាដើម ។ បទថា **សហាតិ** បានដល់ អត់សង្កត់ ។ បទថា **និក្ខេបំ** បានដល់ ដែលគេចោលហើយ ។ បទថា **បដិឃំ** បានដល់ សេចក្តីក្រោធ ។ បទថា **តយា** បានដល់ ព្រោះព្រឹត្តិការណ៍នោះ ឬព្រោះហេតុដែលបោះចោលរបស់នោះ ។ បាឋៈថា **បដិឃំ ឧយំ** ដូច្នេះក៏មាន បាឋៈនោះ មានសេចក្តីថា មិនធ្វើនូវការត្រេកអរ ឬការអាក់អន់ ព្រោះការបោលរបស់នោះ ។ បទថា **សម្មានាវ-មានក្ខមោ** សេចក្តីថា សូម្បីខ្លួនអ្នកក៏ចូរអត់ធន់ចំពោះការសរសើរ និងការមើលងាយរបស់មនុស្សទាំងពួង ។ អាចារ្យទាំងឡាយសូធ្យថា **តថេវ ត្វម្បិ សព្វេ សម្មានាវមានក្ខមោ** ដូច្នេះក៏មាន បាឋៈថា **ខន្តិយា ធារមី គន្ធា** ដូច្នេះក៏មាន ។ ពាក្យដ៏សេស ក្នុងសេចក្តីនេះ មានអត្ថងាយយល់ហើយ ។ បន្ទាប់អំពីនេះទៅ នឹងមិនពោលសេចក្តីដែលមានលក្ខណៈយ៉ាងនេះ ពោលតែសេចក្តីដែលប្លែកគ្នា សម្តែងបាឋៈដទៃប៉ុណ្ណោះ ។

លំដាប់នោះ សុមេធបណ្ឌិតពិចារណាក្រៃលែងថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ ក៏ឃើញសច្ចបារមីលំដាប់ទី ៧ ទើបទូន្មានខ្លួនឯងយ៉ាងនេះថា នៃសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកគប្បីបំពេញសច្ចបារមី ទោះបីវទ្ធុះធ្លាក់ចុះត្រង់អំបែងក្បាល អ្នកកុំពោលសម្បជានមុសាវាទដោយអគតិ មានឆន្ទាគតិជាដើម ដើម្បីប្រយោជន៍ដល់ទ្រព្យជាដើមឡើយ ធម្មតាផ្កាយព្រឹកក្នុងរដូវទាំងឡាយ មិនលះគោចររបស់ខ្លួន ទៅកាន់ផ្លូវដទៃ គោចរក្នុងផ្លូវរបស់ខ្លួនប៉ុណ្ណោះ យ៉ាងណា សូម្បីអ្នក ក៏កុំលះបង់

សច្ចៈ និយាយកុហកយ៉ាងនោះដូចគ្នា ក៏នឹងបានត្រាស់ជាព្រះពុទ្ធ ហើយអធិដ្ឋានសច្ចបារមីទី ៧ យ៉ាងមាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញសច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើសច្ចបារមីទី ៧ នេះឲ្យមាំមួន កុំមានពាក្យបែកជាពីរ ក្នុងសច្ចបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផ្កាយព្រឹកជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថីក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាតចាកវិថី ក្នុងសច្ចៈទាំងឡាយយ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងការបំពេញសច្ចបារមី ។ បទថា **អទ្វេជ្ឈវចនោ** បានដល់ មានវាចាមិនកុហក ។ បទថា **ឱសធី ឆាម** បានដល់ ផ្កាយឱសធ ។ ព្រោះថា ក្នុងការកាន់យកថ្នាំ ( ផឹកថ្នាំ ) ជន

ទាំងឡាយឃើញផ្កាយព្រឹករះឡើង ទើបកាន់យកថ្នាំ ព្រោះហេតុនោះ ទើបគេហៅថា ផ្កាយឱសធ ។ បទថា **តុលាភូតា** បានដល់ ជាគ្រឿងថ្លឹង ។ បទថា **សទេវកេ** បានដល់ របស់លោក ព្រមទាំងទេវលោក ។ បទថា **សមយេ** បានដល់ ក្នុងរដូវភ្លៀង ។ បទថា **ឧតុវស្សេ** បានដល់ ក្នុងរដូវរងា និងក្ដៅ ។ បាឋៈថា **សមយេ ឧតុវដ្ដេ** ដូច្នេះក៏មាន ។ បាឋៈនោះ មានសេចក្ដីថា បទថា **សមយេ** បានដល់ រដូវប្រាំង ។ បទថា **ឧតុវដ្ដេ** បានដល់ រដូវរងា និងរដូវភ្លៀង ។ បទថា **ន ឱក្កមតិ វីថិតោ** សេចក្ដីថា ផ្កាយព្រឹក រមែងមិនគោចរចេញអំពីវិថី គឺមិនគោចរក្រៅវិថីរបស់ខ្លួន ក្នុងរដូវនោះៗ គឺគោចរទៅក្នុងទិសបស្ចិម ៦ ខែ គោចរទៅទិសបូព៌ ៦ ខែ ។ ន័យម្យ៉ាងទៀត ថ្នាំ មានទ្វី ដីបី ម្រេចជាដើម ឈ្មោះថា **ឱសធី** ។ បទថា **ន ឱក្កមតិ** សេចក្ដីថា ថ្នាំណាមួយអាចឲ្យផល ថ្នាំនោះៗ ដល់ពេលឲ្យផល កាលមិនទាន់ឲ្យផលរបស់ខ្លួន រមែងមិនអស់ឫទ្ធិ ។ បទថា **វីថិតោ** បានដល់ ចាកផ្លូវទៅ ។ អធិប្បាយថា ថ្នាំប្រមាត់ក៏រក្សាប្រមាត់ ថ្នាំខ្យល់ក៏រក្សាខ្យល់ ថ្នាំសេម្ហៈក៏រក្សាសេម្ហៈ ។ ពាក្យដ៏សេស ក្នុងសេចក្ដីនេះ មានអត្ថងាយយល់ហើយ ។

លំដាប់នោះ សុមេធបណ្ឌិតនោះ ពិចារណាក្រៃលែងឡើងថា ពុទ្ធ-ការកធម៌ទាំងឡាយ មិនមែនមានប៉ុណ្ណោះទេ ក៏ឃើញអធិដ្ឋានបារមីជាលំដាប់ទី ៨ ទើបទូន្មានខ្លួនឯងយ៉ាងនេះ នៃសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកត្រូវតែបំពេញអធិដ្ឋានបារមី តាំងអធិដ្ឋានណា ក៏មិនជាអ្នកឃ្លៀងឃ្លាតក្នុង

អធិដ្ឋាននោះ ឈ្មោះថា ភ្នំ កាលខ្យល់បក់មកគ្រប់ទិស ក៏មិនញាប់ញ័រ នៅស្ងៀមក្នុងទីនៃខ្លួនប៉ុណ្ណោះ យ៉ាងណា ទោះបីខ្លួនអ្នក កាលមិនឃ្លៀងឃ្លាតក្នុងអធិដ្ឋាននៃខ្លួន ក៏យ៉ាងនោះដូចគ្នា ក៏នឹងបានត្រាស់ជាព្រះពុទ្ធ ក៏តាំងអធិដ្ឋានបារមីជាលំដាប់ទី ៨ យ៉ាងមាំទាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើអធិដ្ឋានបារមីទី ៨ នេះឲ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។ ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកម្រើកក្នុងអធិដ្ឋានបារមីសព្វកាល យ៉ាងនោះដែរ លុះដល់នូវអធិដ្ឋាន-បារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោលោ** បានដល់ ដែលសម្រេចដោយថ្ម ។

បទថា **អចលោ** បានដល់ មិនឃ្លៀងឃ្លាត ។ បទថា **សុបតិដ្ឋិតោ** បានដល់ ឈ្មោះថា **សុបតិដ្ឋិតោ** ព្រោះមិនឃ្លៀងឃ្លាតនោះឯង ។ បាឋៈថា **យថាបិ បព្វតោ អចលោ ឋិតោ សុបតិដ្ឋិតោ** ដូច្នេះក៏មាន ។ បទថា **កុសវាតេហិ** បានដល់ ដោយខ្យល់មានកម្លាំង ។ បទថា **សកដ្ឋានេវ** បានដល់ ក្នុងឋានៈរបស់ខ្លួននោះឯង អធិប្បាយថា ក្នុងឋានៈតាមដែលតាំងនៅនោះឯង ពាក្យដ៏សេស ក្នុងសេចក្ដីនេះ ក៏ងាយយល់ដូចគ្នា ។

លំដាប់នោះ សុមេធបណ្ឌិតក៏ពិចារណាក្រៃលែងឡើងថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ ក៏ឃើញមេត្តាបារមីជាលំដាប់ទី ៩ ហើយក៏ទូន្មានខ្លួនឯងយ៉ាងនេះថា នៃសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកត្រូវបំពេញមេត្តាបារមី អ្នកគប្បីមានចិត្តតែមួយ ទាំងបុគ្គលមានប្រយោជន៍ផង បុគ្គលមិនមានប្រយោជន៍ផង ទឹករមែងធ្វើនូវភាពត្រជាក់តែម្យ៉ាង ទាំងបាបជន ទាំងកល្យាណជន យ៉ាងណា អ្នកក៏គួរមានចិត្តតែមួយ ដោយមេត្តាក្នុងសព្វសត្វទាំងឡាយ ក៏យ៉ាងនោះដូចគ្នា ទើបបានត្រាស់ជាព្រះពុទ្ធ ហើយអធិដ្ឋានមេត្តាបារមីលំដាប់ទី ៩ ឲ្យមាំទាំនោះឯង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វទាំងឡាយ

អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវមេត្តា-បារមីទី ៩ នេះឲ្យមាំមួន អ្នកចូរកុំឲ្យមានបុគ្គលដទៃស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញ្ញាណ ។ ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី និងមន្ទិល យ៉ាងណា ។ អ្នកចូរចម្រើនមេត្តាឲ្យស្មើចំពោះមិត្រ និងសត្រូវយ៉ាងនោះដែរ លុះដល់នូវមេត្តា-បារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសមោ ហោហិ** បានដល់ ចូរជាបុគ្គលមិនមានអ្នកស្មើដោយមេត្តាភាវនា ។ ក្នុងពាក្យនោះ បាឋៈថា **ត្វំ សមសមោ ហោហិ** ដូច្នេះក៏មាន ។ បាឋៈនោះ មានអត្ថងាយយល់ហើយ ។ បទថា **សមំ** បានដល់ ប្រឹងបាន ។ បទថា **ផរតិ** បានដល់ រមែងពាល់ត្រូវ ។ បទថា **បវាហេតិ** បានដល់ ជម្រះឲ្យស្អាត ។ បទថា **រជោ** បានដល់ ធូលីដែលចរមក ។ បទថា **មលំ** បានដល់ មន្ទិល មានមន្ទិល គឺញើសជាដើមដែលកើតឡើងត្រង់សរីរៈ បាឋៈថា **រជមលំ** ដូច្នេះក៏មាន សេចក្តីក៏យ៉ាងនោះដូចគ្នា ។ បទថា **ហិតាហិតេ** បានដល់ អ្នកមានប្រយោជន៍ និងមិនមានប្រយោជន៍ អធិប្បាយថា មិត្រ និងសត្រូវ ។ បទថា **មេត្តាយ ភាវយ**

បានដល់ ចូរចម្រើនមេត្តា ។ ពាក្យដ៏សេស ក្នុងបទនេះ មានអត្ថងាយយល់ដូចគ្នា ។

លំដាប់នោះ សុមេធបណ្ឌិតពិចារណាក្រៃលែងឡើងថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ ឃើញឧបេក្ខាបារមីជាលំដាប់ទី ១០ ទើបទូន្មានខ្លួនឯងយ៉ាងនេះថា នែសុមេធបណ្ឌិត តាំងអំពីនេះទៅ អ្នកត្រូវតែបំពេញឧបេក្ខាបារមី គប្បីដាក់ខ្លួនជាកណ្តាល ទាំងក្នុងសុខ ទាំងក្នុងទុក្ខ ឈ្មោះថា ផែនដី រមែងជាកណ្តាលក្នុងបុគ្គលដែលដាក់របស់ស្អាតខ្លះ មិនស្អាតខ្លះ យ៉ាងណា សូម្បីខ្លួនអ្នក កាលដាក់ខ្លួនជាកណ្តាលក្នុងសុខ និងទុក្ខយ៉ាងនោះហើយ ក៏នឹងបានត្រាស់ជាព្រះពុទ្ធ ហើយអធិដ្ឋានឧបេក្ខាបារមីទី ១០ ឲ្យមាំទាំ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខាបារមីទី ១០ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើឧបេក្ខាបារមីទី ១០ នេះឲ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផែនដី តែងព្រងើយកន្តើយចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះ

ហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរ ចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួនឲ្យដូចជាជញ្ជីងចំពោះសុខ និងទុក្ខសព្វកាល យ៉ាងនោះដែរ ។ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណពុំខានដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តុលាភូតោ** បានដល់ តាំងនៅក្នុងភាពជាកណ្តាល ជញ្ជីងដែលគេថ្លឹងប៉ុណ្ណោះ ដែលមិនស្រុតចុះ មិនបះឡើង យ៉ាងណា សូម្បីខ្លួនអ្នក ក៏ត្រូវតែដូចជាជញ្ជីង ក្នុងសុខ និងទុក្ខទាំងឡាយ យ៉ាងនោះដូចគ្នា ទើបបានសម្រេចសម្ពោធិញ្ញាណ ។ បទថា **កោធានុនយវជ្ជិតា** បានដល់ វៀរនូវការអាក់អន់ និងការត្រេកអរ ។ បាឋៈថា **ទយាកោ បរិវជ្ជិតា** ដូច្នេះក៏មាន ឯសេចក្តីក៏យ៉ាងនោះដូចគ្នា ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងខន្តិបារមីនោះឯង ។

បន្ទាប់អំពីនោះ សុមេធបណ្ឌិត កាលជ្រើសរើសបារមីធម៌ ១០ នេះហើយ បន្ទាប់ពីនោះ ក៏គិតថា ធម៌ដែលធ្វើឲ្យបានត្រាស់ជាព្រះពុទ្ធ ដែលជួយអប់រំ បន្ទុំពោធិញ្ញាណ ដែលព្រះពោធិសត្វទាំងឡាយ គប្បីបំពេញក្នុងលោកនេះ មានត្រឹមប៉ុណ្ណោះឯង មិនមានក្រៅលែងជាងនេះ ឯបារមីទាំងនេះ មិនមានក្នុងអាកាសខាងលើ មិនមានក្នុងទិសទាំងឡាយ មានទិសបូព៌ាជាដើម តែតាំងនៅក្នុងហទយៈរបស់អាត្មាអញប៉ុណ្ណោះ ឃើញថា បារមីទាំងនោះតាំងនៅក្នុងហទយៈរបស់ខ្លួនយ៉ាងនេះហើយ ក៏អធិដ្ឋានបារមីទាំងនោះឲ្យមាំទាំ

កាលពិចារណារឿយៗ ទាំងអនុលោម និងបដិលោម ពីខាងចុង មកខាងដើម ពីខាងដើម ទៅខាងចុង ពីកណ្តាល មកទាំងសងខាង ពីសងខាងទៅត្រង់កណ្តាល ។ ការបរិច្ចាគវត្ថុខាងក្រៅ ឈ្មោះថា **បារមី** បរិច្ចាគអវយវៈ ឈ្មោះថា **ឧបបារមី** បរិច្ចាគជីវិត ឈ្មោះថា **បរមត្ថបារមី** រួមជាបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ រួមជាបារមី ៣០ ពិចារណាដូចបង្វិលប្រេងក្នុងយន្ត ។ កាលសុមេធបណ្ឌិតពិចារណាបារមី ១០ ដោយតេជះនៃធម៌ មហាប្រឹថពីដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ក៏បញ្ចេញសំឡេងខ្ទរខ្ទារញាប់ញ័រ ហាក់បីដូចបាច់បបុសដែលត្រូវដំរីជាន់ និងហាក់បីដូចគ្រឿងយន្តគាបអំពៅ វិលដូចក្តារយន្ត ដូចចក្កយន្ត ដែលធ្វើភាជនៈដី និងកង់យន្តគាបប្រេង ដូច្នោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ធម៌ទាំងឡាយណា ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោកត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃក្រៅអំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌ទាំង ១០ នោះ ឲ្យមាំមួនចុះ ។ កាលតថាគតពិចារណានូវបារមីធម៌ទាំងនេះ ដោយសភាវសរសលក្ខណៈ ផែនដីទាំងមួយម៉ឺនលោកធាតុក៏ញាប់ញ័រ ដោយតេជះនៃធម៌ ។ ផែនដីកម្រើកបន្ទឺឡើង ដូចជាឃ្នាបអំពៅដែលត្រូវគេគាប ឬចក្កយន្តប្រេង ត្រូវគេគាបហើយ ( រមែងវិលញ័រ ) យ៉ាង

ណា ផែនដីក៏ញាប់ញ័រយ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯត្តកាយេវ** លោកពោលដើម្បីសម្ដែងថា បារមី ១០ ដែលលើកឡើងសម្ដែងមិនខ្វះមិនលើស ។ បទថា **តតុទ្ធំ** សេចក្ដីថា ដែលច្រើនជាងបារមី ១០ នោះមិនមាន ។ បទថា **អញ្ញត្រ** បានដល់ ដទៃ ។ **លក្ខណា** សព្វ គប្បីកាន់យកតាមគម្ពីរសព្ទសាស្ត្រ សេចក្ដីថា ពុទ្ធការកធម៌ដទៃចាកបារមីធម៌ ១០ នោះមិនមាន ។ បទថា **តត្ថ** បានដល់ ក្នុងបារមី ១០ នោះ ។ បទថា **បតិដ្ឋហ** បានដល់ ចូរតាំងមាំ សេចក្ដីថា ចូរធ្វើឲ្យបរិបូណ៌តាំងនៅ ។

បទថា **ឥមេ ធម្មេ** បានដល់ បារមីធម៌ ។ បទថា **សម្មសតោ** បានដល់ ទ្រង់ស្រាវជ្រាវ គប្បីឃើញថាជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថអនាទរ ។ បទថា **សភាវសរសលក្ខណេ** សេចក្ដីថា ទ្រង់ពិចារណាដោយលក្ខណៈដែលមានកិច្ច ពោលគឺសភាវៈតាមពិត ។ បទថា **ធម្មតេជេន** បានដល់ ដោយតេជះគឺអំណាចនៃការជ្រើសរើសបារមី ។ រតនៈ ហៅថា **វសុ** ក្នុងបទថា **វសុធា**។ ធម្មជាតិណាទ្រទ្រង់នូវរតនៈនោះ ឬរតនៈទ្រទ្រង់នៅក្នុងធម្មជាតិនោះ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **វសុធា** ( ទ្រទ្រង់នូវរតនៈ ឬជាទីទ្រទ្រង់នូវរតនៈ ) ។ ធម្មជាតិនោះ គឺអ្វី គឺ **មេទនី** ( ផែនដី ) ។ បទថា **បកម្បថ** បានដល់ ញាប់ញ័រហើយ អធិប្បាយថា កាលសុមេធបណ្ឌិតកំពុងជ្រើសរើសនូវបារមីទាំងឡាយ ដោយតេជះនៃញាណរបស់សុមេធបណ្ឌិតនោះ លោកធាតុមួយម៉ឺនក៏ញាប់ញ័រ ។

បទថា **ចលតិ** បានដល់ ញាប់ញ័រមាន ៦ ប្រការ ។ បទថា **រវតិ** បានដល់ បន្លឺសំឡេង ។ បទថា **ឧច្ឆុយន្តំវ បីឡិតំ** បានដល់ ដូចយន្តគាបទឹកអំពៅ ។ បាឋៈថា **គុឡយន្តំវ បីឡិតំ** ដូច្នេះក៏មាន ឯសេចក្ដីក៏ដូចគ្នា ។ បទថា **តេលយន្តេ** បានដល់ ក្នុងយន្តដែលគាបប្រេង ។ បទថា **យថា ចក្កំ** បានដល់ ដូចយន្តដែលមានកង់ធំរបស់អ្នកប្រើយានមានកង់ ។ បទថា **ឯវំ** សេចក្ដីថា យន្តដែលប្រើរបស់មូលគាបប្រេង រមែងវិល រមែងលាន់ឮ យ៉ាងណា **មេទនី** គឺផែនដីនេះ ក៏ញាប់ញ័រយ៉ាងនោះ ។ ពាក្យដ៏សេស ក្នុងសេចក្ដីនេះ មានអត្ថងាយយល់ហើយ ។

កាលមហាប្រឹថពីញាប់ញ័រយ៉ាងនេះ មនុស្សអ្នករម្មនគរ ដែលចូលគាល់ព្រះមានព្រះភាគ មិនអាចឈរបាន ក៏ដួលចុះ ដូចដើមសាលព្រឹក្សធំត្រូវយុគន្ធរវាតបក់បោក ភាជនៈដី មានក្អមជាដើមក៏ទង្គិចគ្នានិងគ្នា បែកជាលម្អិតតូចធំ មហាជនតក់ស្លុត ចូលទៅរកព្រះសាស្ដាទូលសួរថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គមិនដឹងហេតុនេះថា នេះជាការបង្វិលខ្ទរបស់នាគ ឬរបស់ភូត យក្ខ ទេវតា ពួកណាមួយ ឬមហាជនទាំងអស់នេះ ត្រូវភ័យបៀតបៀនឬហ្ន៎ ឬថា លោកនេះ នឹងមានគ្រោះអាក្រក់ ឬគ្រោះល្អ សូមទ្រង់ត្រាស់ហេតុនោះផងចុះ ។

គ្រានោះ ព្រះសាស្ដាទ្រង់ស្ដាប់ពាក្យរបស់ជនទាំងនោះហើយ ត្រាស់ថា ពួកអ្នកកុំខ្លាចឡើយ កុំគិតថ្វីឡើយ មិនមានភ័យដែលកើតអំពីហេតុនេះដល់ពួកអ្នកទេ ។ តថាគតព្យាករបុគ្គលណាថា ថ្ងៃនេះ សុមេធបណ្ឌិតនឹង

បានត្រាស់ជាព្រះពុទ្ធ ឈ្មោះថា គោតម ក្នុងអនាគតកាល បុរសនោះកំពុងពិចារណាបារមីទាំងឡាយក្នុងឥឡូវនេះ ដោយតេជះនៃធម៌របស់បុគ្គលដែលកំពុងតែពិចារណានោះ ម៉ឺនលោកធាតុ ដល់នូវការញាប់ញ័រ និងមានសំឡេងព្រមគ្នា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

បរិស័ទរបស់ព្រះពុទ្ធ មានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាស
បរិស័ទនោះ ក៏ញាប់ញ័រ ដេកជ្រប់លើផែនដី ក្នុងទីអង្គាស
នោះ ឆ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏ទង្គិចគ្នា បែក
ខ្ទេចខ្ទីអស់ក្នុងទីនោះ ។ ពួកមហាជនមានចិត្តរន្ធត់ តក់ស្លុត
ភិតភ័យ ភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នាហើយ
ចូលទៅគាល់ព្រះពុទ្ធទីបង្ករ ( ហើយទូលសួរថា ) បពិត្រ
ព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់ដូចម្តេច នឹងមាន
ដល់មនុស្សលោក លោកទាំងមូលត្រូវសេចក្តីអន្តរាយ បៀត
បៀនហើយ សូមព្រះអង្គទ្រង់មេត្តាប្រោស បន្ទោបង់សេចក្តី
អន្តរាយនោះចេញ ។ គ្រានោះ ព្រះមហាមុនីទីបង្ករ ទ្រង់ញ៉ាំង
មហាជនទាំងនោះឲ្យយល់ច្បាស់ថា អ្នកទាំងឡាយ ចូរកុំមាន
សេចក្តីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនេះឡើយ ។
ជ្សិតតថាគតបានព្យាករក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះ នឹង
បានត្រាស់ជាព្រះពុទ្ធ ក្នុងលោក ( ក្នុងកាលជាអនាគត )
សុមេធបណ្ឌិតនុ៎ះ កំពុងពិចារណាធម៌ ដែលព្រះជិនស្រីអំពី

បុរាណធ្លាប់សេពមក ។ កាលសុមេធបណ្ឌិតពិចារណាធម៌ គឺពុទ្ធភូមិដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុ ក្នុងលោក ព្រមទាំងទេវលោកញាប់ញ័រ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាវតា** បានដល់ មានប្រមាណប៉ុនណា ។ បទថា **អាសិ** បានដល់ មានហើយ ។ បាឋៈថា **យា តទា បរិសា អាសិ** ដូច្នេះក៏មាន បាឋៈនោះមានសេចក្តីថា បរិស័ទណាតាំងនៅក្នុងទីនោះ ។ បទថា **បវេធមានា** បានដល់ ញាប់ញ័រ ។ បទថា **សា** បានដល់ បរិស័ទនោះ ។ បទថា **តត្ថ** បានដល់ ក្នុងទីចូលគាល់នោះ ។ បទថា **សេតិ** បានដល់ ដេកហើយ ។

បទថា **ឃដា** បានដល់ នៃក្អមទឹកទាំងឡាយ ពាក្យនេះជាបឋមាវិភត្តិចុះក្នុងអត្ថឆដ្ឋីវិភត្តិ សេចក្តីថា ច្រើនពាន់នៃឆ្នាំងទាំងឡាយ ។ បទថា **សញ្ចុណ្ណមថិតា** បានដល់ ជាលម្អិតផង បែកផង សេចក្តីថា បែកជាលម្អិតតូចធំ ។ បទថា **អញ្ញមញ្ញំ បឃដ្ដិតា** បានដល់ ប៉ះទង្គិចនូវគ្នានិងគ្នា ។ បទថា **ឧព្វិគ្គា** បានដល់ មានចិត្តតក់ស្លុត ។ បទថា **តសិតា** បានដល់ កើតនូវការតក់ស្លុត ។ បទថា **ភីតា** បានដល់ ភ័យខ្លាច ។ បទថា **ភន្តា** បានដល់ មានចិត្តប្រែប្រួល អធិប្បាយថា មានចិត្តវិលត្រឡប់ប្រែប្រួល ពាក្យទាំងអស់ជាវេវចនៈនៃគ្នានិងគ្នា ។ បទថា **សមាគម្ម** បានដល់ មកប្រជុំគ្នា បាឋៈក៏យ៉ាងនោះដូចគ្នា ។

បទថា **ឧបទ្ទុតោ** បានដល់ ត្រូវញាំញី ។ បទថា **តំ វិនោទេហិ** បានដល់ ចូរបន្ទោបង់ អធិប្បាយថា ចូរកម្ចាត់ភ័យដែលគំរាមនោះ ។ បទថា **ចក្ខុម** សេចក្តីថា បពិត្រព្រះអង្គទ្រង់មានចក្ខុ ៥ ។ បទថា **តេសំ តទា** បានដល់ គ្រានោះ ទ្រង់ញុំាងជនទាំងនោះ ពាក្យនេះជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ បទថា **សញ្ញាបេសិ** បានដល់ ឲ្យដឹង ឲ្យក្រាក់ ។ បទថា **វិសត្ថា** បានដល់ មានចិត្តស្និទ្ធស្នាល ។ បទថា **មា ភាថ** បានដល់ កុំខ្លាចឡើយ ។ បទថា **យមហំ** កាត់បទជា **យំ អហំ** សំដៅដល់សុមេធបណ្ឌិត ។ បទថា **ធម្មំ** បានដល់ បារមីធម៌ ។ បទថា **បុព្វកំ** បានដល់ របស់បុរាណ ។ បទថា **ជិនសេវិតំ** សេចក្តីថា ដែលព្រះជិនស្រីទាំងឡាយសេពហើយ កាលជាព្រះពោធិសត្វ ។ បទថា **ពុទ្ធភូមឹ** បានដល់ បារមីធម៌ ។ បទថា **តេន** បានដល់ ដោយហេតុដែលពិចារណានោះ ។ បទថា **កម្បិតា** បានដល់ ញាប់ញ័រហើយ ។ បទថា **សទេវកេ** បានដល់ ក្នុងលោក ព្រមទាំងទេវលោក ។

បន្ទាប់អំពីនោះ មហាជនស្តាប់ព្រះតម្រាស់របស់ព្រះតថាគតហើយ ក៏ត្រេកអរ នាំគ្នាកាន់យកផ្កាគ្រឿងប្រអូប និងគ្រឿងលាបជាដើម ចេញអំពីរម្មនគរ ចូលទៅរកព្រះពោធិសត្វ បូជាដោយផ្កា គ្រឿងក្រអូបជាដើម ថ្វាយបង្គំហើយ ធ្វើប្រទក្សិណ ហើយត្រឡប់ទៅកាន់រម្មនគរ ។ គ្រានោះ ព្រះពោធិសត្វពិចារណាបារមី ១០ ធ្វើអធិដ្ឋានវីរិយៈឲ្យមាំទាំ ហើយក្រោកឡើងចាកអាសនៈ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ចិត្ត ( នៃមហាជន ) ក៏រលត់ស្ងប់ក្នុងខណៈនោះភ្លាម ព្រោះបានស្តាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នាក៏ចូលមករកតថាគត ហើយក្រាបថ្វាយបង្គំម្តងទៀត ។ គ្រានោះ តថាគតសមាទាននូវពុទ្ធគុណ ធ្វើចិត្តឲ្យមាំមួន ក្រាបថ្វាយបង្គំព្រះពុទ្ធទីបង្ករ ហើយក្រោកចាកអាសនៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មនោ និព្វាយិ** សេចក្តីថា ចិត្តរបស់មហាជនដែលមានសេចក្តីតក់ស្លុត ព្រោះផែនដីកម្រើក ក៏ស្ងប់ត្រជាក់ ព្រោះស្តាប់ ដែលផែនដីកម្រើកនោះ អធិប្បាយថា ដល់ការស្ងប់ ។ បាឋៈថា **ជនោ និព្វាយិ** ដូច្នេះក៏មាន បាឋៈនោះងាយយល់ដូចគ្នា ។ បទថា **សមាទិយិត្វា** បានដល់ កាន់យកដោយប្រពៃ អធិប្បាយថា សមាទាន ។ បទថា **ពុទ្ធគុណំ** បានដល់ បារមីទាំងឡាយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

លំដាប់នោះ ព្រះពោធិសត្វជាអ្នកករុណាសព្វសត្វ ក្រោកឡើងចាកអាសនៈ ទេវតាទាំងម៉ឺនចក្កវាឡ ក៏ប្រជុំគ្នា បូជាដោយផ្កា និងគ្រឿងក្រអូបជាដើមដែលជាទិព្វ ក៏បន្លឺសាធុការជាមង្គលថា បពិត្រសុមេធតាបស ថ្ងៃនេះលោកប្រាថ្នាដ៏ក្រៃលែង ទៀបបាទមូលព្រះទីបង្ករទសពល សូមសេចក្តីប្រាថ្នានោះសម្រេចដល់លោក កុំបីមានអន្តរាយចុះ ភ័យ ឬក៏ការតក់ស្លុតក្នុងសេចក្តីប្រាថ្នានោះ កុំបីមានដល់លោកឡើយ រោគបន្តិចបន្តួច កុំបីកើតក្នុងសរីរៈរបស់លោកឡើយ សូមលោកបំពេញបារមីទាំងឡាយ ហើយចាក់ធ្លុះសម្មាសម្ពោធិញ្ញាណ ដោយឆាប់រហ័ស ដើមឈើផ្កា ដើមឈើផ្លែ រមែងចេញផ្កា

ចេញផ្លែ តាមរដូវកាល យ៉ាងណា ខ្ទួនលោក កុំបីកន្ទងនូវឧតុសម័យនោះឡើយ សូមពាល់ត្រូវនូវពោធិញ្ញាណដោយរួសរាន់ហោង ។ កាលបន្ទឺសាធុការយ៉ាងនេះហើយ ក៏នាំគ្នាថ្វាយបង្គំ ហើយត្រឡប់ទៅកាន់ទេវស្ថានរៀងៗ ខ្លួន ។ ឯព្រះពោធិសត្វ កាលទេវតាទាំងឡាយឲ្យសាធុការហើយ ត្រិះរិះថា អញនឹងបំពេញបារមី ១០ ហើយនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងទីបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប ហើយអធិដ្ឋាននូវសេចក្តីព្យាយាមមាំ ហោះឡើងកាន់អាកាស ទៅកាន់ហិមវន្តប្បទេសដែលមានគណៈឥសី ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្សចំពោះសុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ ។ ពួកទេវតា និងពួកមនុស្ស ទាំងពីរពួកនោះ បាននូវសួស្តី ( ពោលថា ) តំណែងដ៏ធំ ដែលលោកប្រាថ្នាហើយ សូមលោកបាននូវតំណែងនោះ សមគួរតាមប្រាថ្នាចុះ ។ ចង្រៃទាំងពួង ចូរបវៀសចៀសចេញទៅ សេចក្តីសោក និងរោគក៏ចូរចៀសវាងចេញទៅ សេចក្តីអន្តរាយ កុំបីមានដល់លោកឡើយ សូមលោកបានលុះនូវសព្វញ្ញុតញ្ញាណដ៏ខ្ពង់ខ្ពស់ឆាប់ៗចុះ ។ កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែងបញ្ចេញផ្កាយ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបញ្ចេញផ្កាដោយពុទ្ធញ្ញាណ យ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធទាំងឡាយ

ណាមួយ ទ្រង់បំពេញហើយនូវបារមីទាំង ១០ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបំពេញបារមីទាំង ១០ យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹងទៀបគល់ពោធិមណ្ឌ: យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរត្រាស់ដឹងទៀបគល់ពោធិមណ្ឌ: នៃព្រះជិនស្រី យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ យ៉ាងនោះចុះ ។ ព្រះចន្ទពេញវង់ រមែងរុងរឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញ ចូររុងរឿងក្នុងលោកធាតុទាំងមួយម៉ឺន យ៉ាងនោះ ។ ព្រះអាទិត្យ ដែលរួចផុតអំពីរាហុ រមែងរុងរឿងដោយកម្តៅ យ៉ាងណា លោកចូររួចចាកលោកធម៌ ចូររុងរឿងដោយពុទ្ធសិរី យ៉ាងនោះដែរ ។ ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រ យ៉ាងណា ពួកលោក ព្រមទាំងទេវលោក ក៏រមែងប្រជុំក្នុងសម្នាក់របស់លោកយ៉ាងនោះដែរ ។ គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតា និងមនុស្សទាំងនោះ សើ្វចសរសើរហើយ ក៏សមាទាននូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូលទៅកាន់ព្រៃធំដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិព្វំ** សេចក្តីថា ទេវតាទាំងឡាយកាន់យក ផ្កាទិព្វ មានផ្កាមន្ទារវៈ ផ្កាបារិច្ឆត្តកៈ ផ្កាកប្បព្រឹក្ស និងផ្កាឈូកជាដើម មនុស្សទាំងឡាយក៏កាន់យកជារបស់មនុស្ស ។ បទថា **សមោកិរន្តិ** សេចក្តីថា រោយលើខ្លួននៃតថាគត ។ បទថា **វុដ្ឋហន្តស្ស** បានដល់ កំពុងក្រោកឡើង ។ បទថា **វេទយន្តិ** បានដល់ ឲ្យដឹងហើយ ឲ្យយល់ហើយ ។ បទថា **សោត្ថី** បានដល់ ភាពជាបុគ្គលសួស្តី ។ ឥឡូវនេះ ដើម្បីសម្តែងអាការដែលឲ្យដឹង ទើបពោលថា តំណែងដ៏ធំ ដែលលោកប្រាថ្នាហើយជាដើម អធិប្បាយថា បពិត្រសុមេធបណ្ឌិត លោកប្រាថ្នាតំណែងធំក្រៃលែង សូមលោកបានតំណែងនោះ សមតាមប្រាថ្នាចុះ ។

បទថា **សព្វីតិយោ** មានវិគ្គហៈថា ឈ្មោះថា ចង្រៃ ព្រោះជាទីមករបស់អន្តរាយ ដែលអន្តរាយទាំងពួង ឈ្មោះថា ចង្រៃ បានដល់ ឧបទ្វឧបទ្រពទាំងឡាយ ។ បទថា **វិវជ្ជន្តុ** បានដល់ កុំបីមានឡើយ ។ បទថា **សោកោ រោគោ វិនស្សតុ** សេចក្តីថា សោក ពោល គឺការសង្រេងសង្រែ និងរោគ ពោល គឺការចាក់ដោត សូមវិនាសទៅ ។ បទថា **តេ** កែជា **តវ** ។ បទថា **មា ភវត្វន្តរាយា** បានដល់ អន្តរាយទាំងឡាយកុំបីមាន ។ បទថា **ផុស** បានដល់ សូមដល់ សូមសម្រេច ។ បទថា **ពោធិ** បានដល់ អរហត្តមគ្គញាណ បានដល់ ព្រះសព្វញ្ញុតញ្ញាណក៏ត្រឹមត្រូវ ។ បទថា **ឧត្តមំ** បានដល់ ប្រសើរបំផុត អរហត្តមគ្គញាណ លោកពោលថា ប្រសើរបំផុត ព្រោះឲ្យនូវពុទ្ធគុណទាំងពួង ។

បទថា **សមយេ** សេចក្តីថា កាលដល់សម័យចេញផ្កានៃដើមឈើទាំងនោះ ។ បទថា **បុប្ផិតោ** បានដល់ ដើមផ្កា ។ បទថា **ពុទ្ធញ្ញាណេហិ** បានដល់ ដោយពុទ្ធញាណ ១៨ ។ បទថា **បុប្ផសុ** បានដល់ ចូរចេញផ្កា ។ បទថា **បូរយុំ** បានដល់ បំពេញហើយ ។ បទថា **ពុជ្ឈរេ** បានដល់ ត្រាស់ដឹងហើយ ។ បទថា **ជិនពោធិយំ** បានដល់ ក្នុងការត្រាស់ដឹងនៃព្រះជិនស្រីគឺរបស់ព្រះពុទ្ធទាំងឡាយ អធិប្បាយថា ត្រង់គល់ឈើដែលជាទីត្រាស់ដឹងសព្វញ្ញុតញ្ញាណ ។ បទថា **បុណ្ណមាយេ** បានដល់ ក្នុងរាត្រីព្រះចន្ទពេញវង់ ។ បទថា **បុណ្ណមនោ** បានដល់ មានមនោរថពេញបរិបូណ៌ហើយ ។

បទថា **រាហុមុត្តោ** បានដល់ ផុតចាករាហុ ដោយពន្លឺដ៏ល្អ ។ បទថា **តាបេន** បានដល់ ដោយពន្លឺក្តៅរុងរឿង ។ បទថា **លោកោ មុច្ចិត្វា** សេចក្តីថា ជាបុគ្គលដែលលោកធម៌បូកលាបមិនបានហើយ ។ បទថា **វិរោច** បានដល់ ចូររុងរឿង ។ បទថា **សិរិយា** បានដល់ ដោយពុទ្ធសិរី ។ បទថា **ឱសរន្តិ** បានដល់ រមែងហូរចូលទៅកាន់មហាសមុទ្រ ។ បទថា **ឱសរន្តុ** បានដល់ ចូរហូរចូលទៅ ។ បទថា **តវន្តិកេ** សេចក្តីថា កាន់សម្នាក់របស់លោក ។ បទថា **តេហិ** បានដល់ ដែលទេវតាទាំងឡាយ ។ បទថា **ថុតប្បសត្ថោ** បានដល់ សរសើរហើយ លើកតម្កើងហើយ ឬដែលព្រះទីបង្ករសម្ពុទ្ធជាដើម ដែលទេវតា និងមនុស្សសរសើរហើយ លើកតម្កើងហើយ ហេតុនោះ ទើបឈ្មោះថា បុគ្គលដែលព្រះពុទ្ធ ដែលទេវតា និងមនុស្សសរសើរហើយ លើក

តម្កើងហើយ ។ បទថា **ឧស ធម្មេ** បានដល់ បារមីធម៌ ១០ ។ បទថា **បវនំ** បានដល់ ព្រៃធំ អធិប្បាយថា ចូលទៅកាន់ព្រៃធំក្បែរធម្មិកបព៌ត ។ គាថាដ៏សេស មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាសុមេធកថា ចប់

ឧបាសកអ្នករម្មនគរទាំងនោះ ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រធានហើយ ក៏បូជាព្រះមានព្រះភាគដែលសោយស្រេច ដកព្រះហស្តចេញអំពីបាត្រហើយ ដោយផ្កា និងគ្រឿងក្រអូបជាដើមទៀត ថ្វាយបង្គំហើយ ចង់ស្តាប់អនុមោទនាទាន ទើបចូលទៅអង្គុយជិត លំដាប់នោះព្រះសាស្តា ទ្រង់បានធ្វើអនុមោទានដ៏ពីរោះក្រៃលែងដល់ឧបាសកទាំងនោះថា

ធម្មតាទាន បណ្ឌិតសន្មតថា ជាហេតុនៃសេចក្តីសុខជាដើម
ម្យ៉ាងទៀត ជាទីតាំង ជាជណ្តើរ ទៅកាន់ព្រះនិព្វាន ។
ទាន ជាជាទីជ្រកកោនរបស់មនុស្ស ទាន ជាផៅពង្ស គឺជា
ជាទីពឹងទៅមុខ ជាគតិសំខាន់របស់សត្វដែលដល់នូវសេចក្តី
ទុក្ខ ។
ទាន បណ្ឌិតសម្តែងថា ជានាវា ព្រោះអត្ថថា ជាគ្រឿងនាំ
ឆ្លងចាកទុក្ខ និងសរសើរថា ជានគរ ព្រោះអត្ថថា ការពារ
នូវភ័យ ។
ទាន បណ្ឌិតពោលថា ជាអាសិរពិស ព្រោះអត្ថថា ចូលជិត

បានដោយក្រ ទាន ដូចផ្កាឈូក ព្រោះមន្ទិល គឺលោភៈ ជាដើម ប្រឡាក់មិនបាន ។

ទីពឹងរបស់បុរស ស្មើដោយទាន មិនមានក្នុងលោក ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរបំពេញទាន ដោយការធ្វើតាមអធ្យាស្រ័យ ។

នរជនណា ដែលមានបញ្ញាក្នុងលោកនេះ ជាអ្នកត្រេកអរក្នុងប្រយោជន៍ មិនឲ្យទានទាំងឡាយ ដែលជាហេតុនៃស្ថានសួគ៌ ដូចម្តេចកើត ។

នរជនណា បានឮថា ទាន ជាដែនកើតសម្បត្តិក្នុងទេវតាទាំងឡាយ មិនឲ្យទាន ដែលឲ្យដល់នូវសេចក្តីសុខ ដូចម្តេចកើត ទាន ជាគ្រឿងញុំាងចិត្តឲ្យត្រេកអរ ។

នរជនបំពេញទានហើយ ក៏ជាបុគ្គលដែលពួកទេពអប្សរចោមរោម ត្រេកអរ ក្នុងនន្ទវ័ន ដែលជាទីសុខសាន្តរបស់ពួកទេវតា អស់កាលយូរ ។

បុគ្គលអ្នកឲ្យ រមែងបាននូវបីតិដ៏ឱឡារ រមែងបានទទួលនូវសេចក្តីគោរព ក្នុងលោកនេះ អ្នកឲ្យ រមែងបានទទួលនូវកិត្តិយសជាច្រើន អ្នកឲ្យ រមែងជាបុគ្គលគួរគប់រក ។

នរជននោះ ឲ្យទានហើយ រមែងដល់នូវការមាំទាំនៃភោគៈ និងមានអាយុវែង រមែងបាននូវកេរ្តិ៍ឈ្មោះពីរោះ និងរូបស្អាត

ក្នុងវិមានទាំងឡាយ ដែលបក្សីក្ងោក ដែលគួរត្រេកអរច្រើនប្រភេទ យំល្ហើយល្ហេង ត្រេកអរជាមួយទេវតាទាំងឡាយក្នុងស្ថានសួគ៌ ។

ទាន ជាទ្រព្យមិនទូទៅដល់ភ័យទាំងឡាយ គឺចោរភ័យ អរិភ័យ រាជភ័យ ឧទកភ័យ និងអគ្គិភ័យ ទាននោះ តែងឲ្យនូវសាវកញ្ញាណភូមិ បច្ចេកភូមិ រហូតដល់ពុទ្ធភូមិ ។

កាលទ្រង់អនុមោទនាទាន ប្រកាសអានិសង្សនៃទាន ដោយន័យដូចពោលមកនេះជាដើមហើយ ក៏ត្រាស់សីលកថា ក្នុងលំដាប់បន្ទាប់អំពីទាននោះ ធម្មតាសីលនោះ ជាមូលនៃសម្បត្តិក្នុងលោកនេះ និងលោកខាងមុខ

សីលជាហេតុនៃសេចក្តីសុខទាំងឡាយ បុគ្គលមានសីលជាប្រក្រតី រមែងទៅកាន់ស្ថានត្រៃត្រិង្ស សីលជាគ្រឿងជ្រកកោន ជាទីពួនសម្ងំ ជាទីពឹងពំនាក់ របស់បុគ្គលដែលចូលដល់សង្សារវដ្ត ។

ទីពឹងដទៃរបស់ជនទាំងឡាយ ក្នុងលោកនេះ ឬក្នុងលោកខាងមុខ ដែលស្មើដោយសីលនឹងមានអំពីណា សីលជាទីតាំងនៃគុណទាំងឡាយក្រៃលែង ដូចផែនដីជាទីតាំងនៃវត្ថុសម្ភារទាំងឡាយ និងវត្ថុដែលកម្រើកមិនបាន ដូច្នោះ ។

បានឮថា សីល ជាគុណជាតល្អ សីលជាគុណជាតដ៏លើសលុប ក្នុងលោក បុគ្គលមានសីល បណ្ឌិត ហៅថា អ្នក

ប្រព្រឹត្តក្នុងបែបរបស់ព្រះអរិយៈ ។

គ្រឿងអលង្ការ ស្មើដោយសីលមិនមាន ក្លិនស្មើដោយក្លិនសីលមិនមាន គ្រឿងជម្រះមន្ទិល គឺកិលេស ស្មើដោយសីលមិនមាន គ្រឿងរម្ងាប់ការក្តៅក្រហាយ ស្មើដោយសីលមិនមាន គ្រឿងឲ្យកើតកិត្តិយស ស្មើដោយសីលមិនមាន ជណ្តើរឡើងទៅកាន់ស្ថានសួគ៌ ស្មើដោយសីលមិនមាន ទ្វារក្នុងការចូលទៅកាន់នគរ គឺព្រះនិព្វាន ស្មើដោយសីលមិនមាន ដូចជាព្រះតម្រាស់ថា

ព្រះរាជាទាំងឡាយ ទ្រង់ប្រដាប់ដោយកែវមុក្តា និងកែវមណី គង់មិនល្អដូចអ្នកប្រព្រឹត្តវត្តទាំងឡាយ ដែលប្រដាប់ដោយគ្រឿងអលង្ការ គឺសីល ។

ក្លិនប្រអូប ប្រព្រឹត្តទៅជានិច្ច ទាំងបណ្តោយខ្យល់ និងច្រាសខ្យល់ ដោយស្មើដោយក្លិនសីល នឹងមានអំពីណា ។

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់ មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។

ក្លិននៃសីលជាគុណជាតប្រសើរបំផុត ជាងគន្ធជាតិទាំងនេះ គឺខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។

ស្ទឹងធំ គឺគង្គា យមុនា សរភូ សរសវតី និន្នគា អចិរវតី
មហី មិនអាចជម្រះមន្ទិលរបស់សត្វទាំងឡាយ ក្នុងលោក
នេះបាន តែទឹក គឺសីល ជម្រះនូវមន្ទិលរបស់សត្វទាំងឡាយ
បាន ។

ខ្យល់លាយភ្លៀង រម្ងាប់ការក្តៅក្រហាយរបស់សត្វទាំងឡាយ
មិនបាន ខ្លឹមចន្ទន៍លឿងក៏រម្ងាប់មិនបាន កែវមុក្តា ក៏រម្ងាប់មិន
បាន កែវមណីក៏រម្ងាប់មិនបាន រស្មីព្រះចន្ទ ក៏រម្ងាប់មិនបាន
តែអរិយសីល ដែលបុគ្គលរក្សាល្អហើយនេះ មានសភាព
ត្រជាក់ក្រៃលែង រមែងរម្ងាប់បាន ។

សីលជារបស់កម្ចាត់ភ័យ មានការតិះដៀលខ្លួនឯងជាដើម
បានសព្វកាល និងឲ្យកើតកិត្តិយស និងការត្រេកអរដល់
អ្នកមានសីល សព្វកាល ។

សីលជាជណ្តើរឡើងទៅកាន់ស្ថានសួគ៌ វត្ថុដទៃស្មើដោយ
សីល នឹងមានមកអំពីណា សីលជាទ្វារចូលទៅកាន់នគរ គឺ
ព្រះនិព្វាន ។

អ្នកទាំងឡាយ ចូរដឹងអានិសង្សដ៏កំពូលនៃសីល ដែលជា
មូលនៃគុណទាំងឡាយ កម្ចាត់កម្លាំងនៃទោសទាំងឡាយ
ដូចពោលមក ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងអានិសង្សនៃសីលយ៉ាងនេះហើយ ដើម្បីសម្តែងថា អាស្រ័យសីលនេះ រមែងបាននូវស្ថានសួគ៌ ទើបត្រាស់គាថា

ក្នុងលំដាប់បន្ទាប់អំពីសីលនោះ ធម្មតាស្ថានសួគ៌នេះ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត មានតែសុខដោយចំណែកមួយ ។ ទេវតាទាំងឡាយ រមែងបាននូវការលេងក្នុងស្ថានសួគ៌នោះជានិច្ច បាននូវសម្បត្តិទាំងឡាយជានិច្ច ពួកទេវតាជាន់ចាតុម្មហារាជ រមែងបានសុខទិព្វ សម្បត្តិទិព្វ អស់ ៩ លានឆ្នាំ ទេវតាជាន់តាវត្តិង្សបាន ៣ កោដិ ៦ លានឆ្នាំ ។ ព្រះសាស្តាត្រាស់កថាប្រកបដោយគុណនៃស្ថានសួគ៌ដូចពោលមកនេះជាដើម កាលទ្រង់លួងលោមដោយសគ្គកថាយ៉ាងនេះហើយ ទ្រង់ក៏ប្រកាសទោសថោកទាប សៅហ្មងនៃកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈថា សូម្បីស្ថានសួគ៌នេះក៏មិនទៀង មិនស្ថិតស្ថេរ មិនគួរធ្វើនូវការត្រេកអរ ពេញចិត្តក្នុងស្ថានសួគ៌នោះ ហើយត្រាស់ធម្មកថាដែលបញ្ចប់ដោយអមតធម៌ កាលទ្រង់សម្តែងធម៌ដល់មហាជនយ៉ាងនេះហើយ ឲ្យបុគ្គលពួកខ្លះ តាំងនៅក្នុងសរណៈ ពួកខ្លះ តាំងនៅក្នុងសីល ៥ ពួកខ្លះ តាំងនៅក្នុងសោតាបត្តិផល ពួកខ្លះ តាំងនៅក្នុងសកទាគាមិផល ពួកខ្លះ តាំងនៅក្នុងអនាគាមិផល ពួកខ្លះ តាំងនៅក្នុងផលទាំង ៤ ពួកខ្លះ តាំងនៅក្នុងវិជ្ជា ៣ ពួកខ្លះ តាំងនៅក្នុងអភិញ្ញា ៦ ពួកខ្លះ តាំងនៅក្នុងសមាបត្តិ ៨ ទ្រង់ក្រោកចាកអាសនៈហើយ យាងចេញអំពីរម្មនគរ ចូលទៅកាន់សុទស្សនមហាវិហារនោះឯង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

គ្រានោះ ពួកឧបាសកឧបាសិកាទាំងនោះ ញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃ ឲ្យឆ្អែតរួចហើយ ក៏ដល់នូវព្រះ

សាស្តាទីបង្ករនោះជាទីពឹង ។ ព្រះតថាគតទ្រង់ញ៉ាំងបុគ្គលខ្លះឲ្យតម្កល់នៅក្នុងសរណគមន៍ ញ៉ាំងបុគ្គលខ្លះឲ្យតាំងនៅក្នុងសីល ៥ ញ៉ាំងបុគ្គលដទៃទៀត ឲ្យតម្កល់នៅក្នុងសីល ១០ ។ ព្រះអង្គទ្រង់ប្រទានមគ្គដល់បុគ្គលខ្លះ ប្រទានផលដ៏ឧត្តមទាំង ៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើដល់បុគ្គលខ្លះ ។ ព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់ប្រទានសមាបត្តិ ៨ ដ៏ប្រសើរដល់បុគ្គលខ្លះ ប្រទានវិជ្ជា ៣ ដល់បុគ្គលខ្លះ អភិញ្ញា ៦ ដល់បុគ្គលខ្លះ ។ ព្រះមហាមុនីទ្រង់ទូន្មានពួកជន ដោយន័យជាគ្រឿងប្រកបនោះ ព្រោះហេតុនោះ បានជាសាសនានៃព្រះលោកនាថ ជាគុណជាតដ៏ធំទូលាយ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្រះហនុកា ( ដូចព្រះចន្ទក្នុងថ្ងៃ ១២ កើត ) មានជង្ឃខ្ទនមូលក្លំ ដូចគោឧសភទ្រង់ចម្លងពួកជនច្រើន ឲ្យរួចចាកទុគ្គតិ ។ ព្រះមហាមុនី ទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹង ស្ថិតនៅក្នុងទីមួយសែនយោជន៍ ទ្រង់ចូលទៅជិត ហើយញ៉ាំងពួកជននោះ ឲ្យត្រាស់ដឹងក្នុងខណៈនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេ** បានដល់ ឧបាសកអ្នករម្មនគរទាំងនោះ ។ គប្បីជ្រាបសរណៈ សរណគមន៍ និងអ្នកដល់សរណៈ ក្នុងពាក្យថា **សរណំ** នេះ ។ គុណជាតណាគាបសង្កត់ បៀតបៀត កម្ចាត់ ហេតុនោះ

គុណជាតនោះ ឈ្មោះថា **សរណា**។ សរណៈនោះ គឺអ្វី គឺព្រះរតនត្រ័យ ។ ព្រះរតនត្រ័យនោះ លោកពោលថា សរណៈ ព្រោះកាត់ ព្រោះបៀតបៀន ព្រោះកម្ចាត់នូវភ័យ ការតក់ស្លុត សេចក្តីទុក្ខ ទុគ្គតិ សេចក្តីសៅហ្មង របស់បុគ្គលដែលដល់រតនៈ ដោយសរណគមន៍នោះឯង សមដូចព្រះមានព្រះភាគដែលត្រាស់ ( ក្នុងទីឃនិកាយ មហាវគ្គ ) ថា

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធជាទីពឹង ទីរឭកហើយ
ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះ
លះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញ
ពពួកនៃទេវតាមិនខាន ។

ពួកជនណាមួយ បានដល់នូវព្រះធម៌ជាទីពឹង ទីរឭកហើយ
ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះ
លះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញ
ពពួកនៃទេវតាមិនខាន ។

ពួកជនណាមួយ បានដល់នូវព្រះសង្ឃជាទីពឹង ទីរឭកហើយ
ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះ
លះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញ
ពពួកនៃទេវតាមិនខាន ដូច្នេះ ។

ចិត្តុប្បាទដែលប្រព្រឹត្តទៅដោយអាការ មានព្រះរតនត្រ័យជាខាងមុខ ឈ្មោះថា សរណគមន៍ ។ បុគ្គលដល់ព្រមដោយសរណគមន៍នោះ ឈ្មោះ

ថា ជាអ្នកដល់នូវសរណៈ ។ តិកៈនេះ គឺសរណៈ សរណគមន៍ អ្នកដល់សរណៈ គប្បីជ្រាបដូចពោលមកនេះសិន ។ បទថា **តស្ស** បានដល់ ព្រះពុទ្ធទីបង្ករនោះ ។ ពាក្យនេះគប្បីជ្រាបថា ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ បាឋៈថា **ឧបគច្ឆំ សរណំ តត្ថ** ដូច្នេះក៏មាន ។ បទថា **សត្ថុនោ** កែជា **សត្ថារំ** ( នូវព្រះសាស្តា ) ។ បទថា **សរណាគមនេ កញ្ចិ** សេចក្តីថា ទ្រង់ធ្វើបុគ្គលពួកខ្លះឲ្យតាំងនៅក្នុងសរណៈ ត្រាស់ជាបច្ចុប្បន្នកាលក៏ពិត តែគប្បីកាន់យកជាអតីតកាល ។ ក្នុងបទដ៏សេស ក៏មានន័យនេះ ។ បាឋៈថា **កស្សចិ សរណាគមនេ** ដូច្នេះក៏មាន ។ បាឋៈនោះ សេចក្តីក៏យ៉ាងនោះដូចគ្នា ។ បទថា **កញ្ចិ បញ្ចសុ សីលេសុ** សេចក្តីថា ទ្រង់ធ្វើបុគ្គលពួកខ្លះ ឲ្យតាំងនៅក្នុងវិរតិសីល ៥ ។ បាឋៈថា **កស្សចិ បញ្ចសុ សីលេសុ** ដូច្នេះក៏មាន ឯសេចក្តីក៏យ៉ាងនោះឯង ។ បទថា **សីលេ ទសវិធេ បរំ** សេចក្តីថា ទ្រង់ធ្វើបុគ្គលដទៃទៀតឲ្យតាំងនៅក្នុងសីល ១០ ។ បាឋៈថា **កស្សចិ កុសលេ ទស** ដូច្នេះក៏មាន បាឋៈនោះសេចក្តីថា ទ្រង់ធ្វើបុគ្គលពួកខ្លះឲ្យសមាទាននូវកុសលធម៌ ១០ ។ ដោយបរមត្ថ មគ្គ លោកហៅថា **សាមញ្ញ** ក្នុងពាក្យនេះថា **កស្សចិ ទេតិ សាមញ្ញំ** ដូចដែលព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ចុះសាមញ្ញគុណ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។ គឺអ្វីខ្លះ ។ គឺសេចក្តីឃើញត្រូវ ១ ។បេ។ សេចក្តីតាំងចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា សាមញ្ញគុណ ដូច្នេះ ។

បទថា **ចតុរោ ផលមុត្តមេ** សេចក្តីថា ផលដ៏ឧត្តម ៤ ។ **ម** អក្ខរៈ គ្រាន់តែធ្វើបទសន្ធិ លោកពោលជាលិង្គវិបល្លាស សេចក្តីថា បានប្រទានមគ្គ ៤ និងសាមញ្ញផល ៤ ដល់បុគ្គលខ្លះតាមឧបនិស្ស័យ ។ បទថា **កស្សចិ អសមេ ធម្មេ** សេចក្តីថា បានប្រទានធម៌ គឺបដិសម្ភិទា ៤ មិនមានធម៌ដទៃដូច ដល់បុគ្គលខ្លះ ។

បទថា **កស្សចិ វរសមាបត្តិយោ** សេចក្តីថា ម្យ៉ាងទៀត បានប្រទានសមាបត្តិ ៨ ដែលជាប្រធាន ព្រោះប្រាសចាកនីវរណៈដល់បុគ្គលខ្លះ ។ បទថា **តិស្សោ កស្សចិ វិជ្ជាយោ** សេចក្តីថា វិជ្ជា ៣ គឺទិព្វចក្ខុញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអាសវក្ខយញ្ញាណ តាមឧបនិស្ស័យដល់បុគ្គលខ្លះ ។ បទថា **ឆឡភិញ្ញា បវេច្ឆតិ** សេចក្តីថា បានប្រទានអភិញ្ញា ៦ ដល់បុគ្គលខ្លះ ។

បទថា **តេន យោគេន** បានដល់ ដោយន័យនោះឯង ដោយលំដាប់នោះ ។ បទថា **ជនកាយំ** បានដល់ ប្រជុំជន ។ បទថា **ឱវទតិ** បានដល់ ទូន្មានហើយ គប្បីឃើញថា លោកពោលជាកាលវិបល្លាស ក្នុងពាក្យបែបនេះ តអំពីនេះទៅ គប្បីកាន់យកជាអតីតកាលទាំងអស់ ។ បទថា **តេន វិត្ថារិកំ អាសិ** សេចក្តីថា ព្រោះឱវាទពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគទីបង្ករអង្គនោះ ព្រះសាសនាក៏ផ្សាយទៅទូលំទូលាយ ។

បទថា **មហាហនុ** សេចក្តីថា បានឮថា ព្រះមហាបុរសទាំងឡាយ មានព្រះហនុ គឺចង្កាទាំងសងខាងបរិបូណ៌ មានអាការដូចព្រះចន្ទក្នុងថ្ងៃ ១២

កើត ហេតុនោះ ទើបមហាបុរសអង្គណាមានព្រះហនុធំ ព្រះមហាបុរសអង្គនោះ ឈ្មោះថា **មហាហនុ** លោកអធិប្បាយថា មានព្រះហនុដូចរាជសីហ៍ ។ បទថា **ឧសភក្ខន្ធោ** សេចក្តីថា មហាបុរសអង្គណាមានដង-កដូចគោឧសភ ព្រះមហាបុរសអង្គនោះ ឈ្មោះថា មានព្រះស្កន្ធដូចគោឧសភ អធិប្បាយថា មានដង-កល្អ ដូចដម្បារមាស មានដង-កស្អាត មូលស្មើគ្នា ។ បទថា **ទីបង្ករសនាមកោ** បានដល់ មានព្រះនាមថា ទីបង្ករ ។ បទថា **ពហូ ជនេ តារយតិ** សេចក្តីថា ទ្រង់ធ្វើជនដែលជាពុទ្ធវេនេយ្យជាច្រើន ឲ្យឆ្លងឱឃ-សង្សារ ។ បទថា **បរិមោចេតិ** បានដល់ ដោះហើយ ។ បទថា **ទុគ្គតឹ** បានដល់ ចាកទុគ្គតិភូមិ ។ ពាក្យនេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថបញ្ចមីវិភត្តិ ។

ឥឡូវនេះ ដើម្បីសម្តែងអាការ គឺទ្រង់ធ្វើសត្វឲ្យឆ្លងឱឃសង្សារ និងដោះចាកទុគ្គតិ ទើបត្រាស់គាថាថា **ពោធនេយ្យំ ជនំ** ។ ក្នុងគាថានោះ បទថា **ពោធនេយ្យំ ជនំ** បានដល់ ពួកសត្វដែលគួរត្រាស់ដឹង បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **ទិស្វា** បានដល់ ទ្រង់ឃើញដោយពុទ្ធចក្ខុ ឬសមន្តចក្ខុ ។ បទថា **សតសហស្សេបិ យោជនេ** បានដល់ ដែលនៅក្នុងទីឆ្ងាយមួយសែនយោជន៍ ។ ពាក្យនេះ គប្បីជ្រាបថា លោកពោលសំដៅដល់លោកធាតុមួយម៉ឺននោះឯង ។

បានឮថា ព្រះសាស្តាទីបង្ករទ្រង់សម្រេចភាពជាព្រះពុទ្ធហើយ ទ្រង់សម្ងំអស់ ៧ សប្តាហ៍ត្រង់គល់ពោធិព្រឹក្ស ក្នុងសប្តាហ៍ទី ៨ ទ្រង់ប្រកាសធម្មចក្រក្នុងសុនន្ទារាម តាមប្បដិញ្ញាដែលទ្រង់ទទួលអារាធនាសម្តែងធម៌របស់

មហាព្រហ្ម ទ្រង់ញ៉ាំងទេវតា និងមនុស្ស ១០០ កោដិឲ្យផឹកនូវអមតធម៌ នេះជាការសម្រេចធម៌លើក ១ ។

បន្ទាប់មក ព្រះសាស្តាទ្រង់ជ្រាបថា ព្រះឱរសដែលមានជង្គ-កមូលស្មើគ្នា ព្រះនាមឧសភក្ខន្ធ មានញាណចាស់ក្លា ទើបទ្រង់ធ្វើព្រះរាជឱរសនោះឲ្យជាប្រធាន ទ្រង់សម្តែងធម៌ ដូចគ្នានឹងរាហុលោវាទសូត្រ ទ្រង់ញ៉ាំងទេវតា និងមនុស្ស ៩០ កោដិ ឲ្យផឹកនូវអមតធម៌ នេះជាការសម្រេចធម៌លើកទី ២ ។

តមក ព្រះសាស្តាទ្រង់ធ្វើយមកប្បាដិហារ្យត្រង់គល់ប្រេសធំ ក្បែរទ្វារនគរអមរវតី ទ្រង់ដោះមហាជនអំពីចំណងដែលពួកទេវតាចោមរោមហើយគង់ប្រថាប់លើផ្ទៃបណ្ឌុកម្ពលសិលា ដែលត្រជាក់ក្រៃលែង ត្រង់គល់បារិច្ឆត្តកៈ ក្នុងស្ថានតាវត្តិង្ស ជាកពពផ្សាយទៅនៃកាពរុងរឿងពន់ពេក ដូចព្រះអាទិត្យ ទ្រង់ធ្វើព្រះនាងសុមេធាទេវី ដែលជាព្រះមាតារបស់ព្រះអង្គឲ្យកើតបីតិ ដល់ពួកទេវតាទាំងពួងជាប្រធាន ទ្រង់ជាវិសុទ្ធិទេព ទ្រង់ដឹងនូវលោកទាំងពួង ជាទេវតាក្រៃលែងជាងទេវតា ទ្រង់ធ្វើប្រទីប ទ្រង់ចែកនូវធម៌ ទ្រង់សម្តែងអភិធម្មបិដក ៧ បករណ៍ ដែលធ្វើសេចក្តីបរិសុទ្ធនៃការត្រាស់ដឹងដ៏សុខុមជ្រាលជ្រៅក្រៃលែង ធ្វើប្រយោជន៍ដល់សត្វទាំងពួងញ៉ាំងទេវតា ៩ ម៉ឺនកោដិឲ្យផឹកនូវអមតធម៌ នេះជាការត្រាស់ដឹង ធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធទ្រង់ញ៉ាំងពួកទេវតា ១០០
កោដិ ឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ព្រះលោកនាថ

ទ្រង់ញ៉ាំងពួកទេវតា និងមនុស្ស ៩០ កោដិ ឲ្យត្រាស់ដឹង ។
កាលណាព្រះពុទ្ធទ្រង់សម្ដែងធម៌ក្នុងភពនៃទេវតា កាលនោះ
ពួកទេវតា ៩០ ពាន់កោដិ ( បានត្រាស់ដឹង ) នេះជាការ
ត្រាស់ដឹងទី ៣ ដូច្នេះ ។

កាប្រជុំសាវករបស់ព្រះមានព្រះភាគទីបង្ករ មាន ៣ ដង ក្នុង ៣ ដង នោះ ដំបូង ទ្រង់ប្រជុំទេវតា និងមនុស្សមួយសែនកោដិ ក្នុងសុនន្ទារាម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្ដាទីបង្ករ មានសាវកសន្និបាត ( ការជួបជុំសាវក )
៣ លើក គឺសន្និបាតលើកទី ១ មានភិក្ខុសង្ឃមួយសែនកោដិ
ដូច្នេះ ។

សម័យតមក ព្រះទសពលដែលភិក្ខុ ៤ សែនរូបចោមរោម ទ្រង់ធ្វើសេចក្ដីអនុគ្រោះមហាជនតាមលំដាប់ តាមនិគម និងនគរ ទ្រង់ចារិកមកដោយលំដាប់ ក៏ដល់ភ្នំមួយគួរជាទីត្រេកអរក្រៃលែង ឈ្មោះនារទកូដ មានកំពូលខ្ពស់ទល់គ្នានឹងពពក មានកំពូលអប់ដោយក្លិនផ្កាឈើច្រើនប្រភេទ លើកំពូលមានហ្វូងម្រឹគជាច្រើនត្រកូលត្រាច់ទៅ ជាទីដែលអមនុស្សហួងហែង គួរខ្លាចក្រៃលែង ល្បីទៅក្នុងលោកទាំងពួង មហាជននាំគ្នាបួងសួងក្នុងទីមួយកន្លែង បានឮថា ភ្នំនោះមានយក្ខឈ្មោះនារទៈថេរក្យា ។ ក្នុងទីនោះ មហាជននាំមនុស្សមកធ្វើពលី បួងសួងដល់យក្ខនោះរាល់ៗ ឆ្នាំ ។

បានឮថា គ្រានោះ ព្រះមានព្រះភាគទីបង្ករទ្រង់ឃើញឧបនិស្ស័យ

សម្បត្តិរបស់មហាជន បន្ទាប់អំពីនោះ ទ្រង់ក៏បញ្ជូនភិក្ខុទៅកាន់ទិសទាំង ៤ មួយអង្គឯង មិនមានមិត្រ មិនមានសម្លាញ់ មានព្រះហឫទ័យដែលមហាករុណាជាស់តឿនហើយ ទ្រង់ឡើងកាន់ភ្នំនោះ ដើម្បីទូន្មានយក្ខនោះ ។ គ្រានោះ យក្ខដែលមានមនុស្សជាភក្សា មិនសម្លឹងប្រយោជន៍ដល់ខ្លួន គាប់ចិត្តក្នុងការសម្លាប់អ្នកដទៃ អន់ធន់នឹងការលុបគុណមិនបាន មានចិត្តឆួលឆេះដោយសេចក្តីក្រោធ បំណងឲ្យព្រះទសពលខ្លាច ហើយគេចទៅ ទើបអង្រួនភ្នំនោះ បានឮថា ភ្នំនោះ ត្រូវយក្ខនោះអង្រួន មានអាការហាក់ដូចបាក់សង្កត់លើអំបែងក្បាលខ្លួនឯងនោះឯង ព្រោះអានុភាពរបស់ព្រះមានព្រះភាគ ។

បន្ទាប់អំពីនោះ យក្ខនោះក៏ខ្លាច គិតថា ណ្ហើយចុះ អញនឹងប្រើភ្លើងដុតសមណៈនេះ ហើយក៏បណ្តាលគំនរភ្លើងធំ ដែលគួរខ្លាចក្រៃលែង គំនរភ្លើងនោះ ក៏ធាបឆួលបង្កនូវសេចក្តីទុក្ខដល់ខ្លួនឯង មិនអាចឆេះត្រឹមតែជាយចីវររបស់ព្រះមានព្រះភាគបាន ។ ឯយក្ខពិនិត្យមើលថា ភ្លើងឆេះសមណៈនេះឬហ្ន៎ ក៏ឃើញព្រះមានព្រះភាគ ដូចប្រថាប់គង់លើត្របកឈូក នៅលើផ្ទៃទឹកត្រជាក់ដូចព្រះចន្ទបញ្ចេញពន្លឺស្រទន់ ក្នុងសរទរដូវ ធ្វើនូវការត្រេកអរដល់ជនទាំងពួង ទើបគិតថា ឱ ! សមណៈនេះ មានអានុភាពច្រើន អញធ្វើនូវសេចក្តីវិនាសណាដល់សមណៈនេះ សេចក្តីវិនាសនោះៗ ត្រឡប់ធ្លាក់លើអញនោះឯង វៀរសមណៈនេះ អញមិនមានទីពឹង មនុស្សទាំងឡាយដែលដួលលើផែនដី អាស្រ័យផែនដីប៉ុណ្ណោះ ទើបក្រោកឡើងបាន ណ្ហើយចុះ អញនឹងដល់នូវសមណៈនេះជាសរណៈ ។

ដូច្នោះ យក្ខនោះ កាលគិតយ៉ាងនេះហើយ ទើបបង្អោនសីសៈទៀប ព្រះយុគលបាទដែលប្រដាប់ដោយចក្ររបស់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតខុសពន់ពេក ហើយបានដល់ព្រះមានព្រះភាគជាសរណៈ ។ លំដាប់នោះ ព្រះមានព្រះភាគក៏ត្រាស់អនុបុព្វីកថា ប្រោសយក្ខនោះ ចប់ទេសនា យក្ខនោះ មួយអន្លើដោយយក្ខមួយម៉ឺន ក៏តាំងនៅក្នុងសោតាបត្តិផល ។ បានឮថា ក្នុងថ្ងៃនោះ មនុស្សក្នុងជម្ពូទ្វីប ធ្វើបុរសម្នាក់មួយភូមិៗ មកដើម្បីធ្វើពលីកម្មដល់យក្ខនោះ និងនាំវត្ថុដទៃៗ ជាច្រើនមានល្ង អង្ករ សណ្ដែកខ្មៅ សណ្ដែកបាយ សណ្ដែករាជមាសជាដើម និងមានសប្បិ នវនីត ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម ។ ខណៈនោះ យក្ខនោះក៏ឲ្យរបស់ទាំងអស់ មានអង្ករជាដើម ដែលនាំមកថ្ងៃនោះ ដល់ជនទាំងនោះវិញ ហើយបានប្រគល់មនុស្សដែលគេនាំមកដើម្បីពលីកម្ម ថ្វាយដល់ព្រះទសពល ។

គ្រានោះ ព្រះសាស្តាឲ្យមនុស្សទាំងនោះ បួសដោយឯហិភិក្ខុឧបសម្បទាខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ទ្រង់ឲ្យបុគ្គលនោះ តាំងនៅក្នុងអរហត្តទាំងអស់ ប្រថាប់គង់ក្នុងចំណោមភិក្ខុ ១០០ កោដិ ទ្រង់លើកឱវាទបាតិមោក្ខឡើងសម្ដែងក្នុងទីប្រជុំ ដែលប្រកបដោយអង្គ ៤ ក្នុងថ្ងៃពេញបូណ៌មី ខែមាឃ ។ អង្គ ៤ នោះ គឺភិក្ខុទាំងអស់សុទ្ធតែជាឯហិភិក្ខុ ភិក្ខុទាំងអស់សុទ្ធតែបានអភិញ្ញា ៦ ភិក្ខុទាំងអស់ មិនបានណាត់គ្នា គឺមកឯង ថ្ងៃនោះ គឺជាថ្ងៃឧបោសថ ១៥ កើត នេះឈ្មោះថា អង្គ ៤ ។ នេះជាសន្និបាតលើកទី ២

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលដែលព្រះជិនស្រី ទ្រង់យាងទៅក្នុងទីស្ងាត់លើកំពូលភ្នំ
នារទៈ ពួកព្រះខីណាស្រពប្រាសចាកមន្ទិល ចំនួន ១០០
កោដិ មកប្រជុំគ្នា ( នេះជាសន្និបាតលើកទី ២ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បរិវេកគតេ** បានដល់ លះពួកគណៈទៅ ។ បទថា **សមឹសុ** បានដល់ ប្រជុំគ្នាហើយ ។

កាលណាព្រះទីបង្ករលោកនាយក ទ្រង់ចាំវស្សាត្រង់ភ្នំឈ្មោះសុទស្សនៈ បានឮថា កាលនោះ មនុស្សអ្នកជម្ពូទ្វីបរៀបចំធ្វើមហោស្រព លើកំពូលភ្នំរាល់ៗ ឆ្នាំ បានឮថា មនុស្សដែលប្រជុំក្នុងមហោស្រពនោះ ជួបព្រះទសពលហើយ ក៏ស្ដាប់ធម្មកថា ជ្រះថ្លាក្នុងធម្មកថានោះ នាំគ្នាបួសក្នុងថ្ងៃមហាបវារណា ព្រះសាស្ដាបានត្រាស់វិបស្សនាកថា ដែលអនុកូលដល់អធ្យាស្រ័យរបស់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ ស្ដាប់វិបស្សនាកថានោះហើយ ពិចារណាសង្ខារហើយ សម្រេចអរហត្តដោយលំដាប់វិបស្សនា និងដោយលំដាប់មគ្គគ្រប់រូប ។ គ្រានោះ ព្រះសាស្ដាទ្រង់បវារណា មួយអន្លើដោយភិក្ខុ ៩ ម៉ឺនកោដិ នេះជាការប្រជុំលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលព្រះមហាមុនី មានព្យាយាមធំ ទ្រង់បវារណាជាមួយ
នឹងពួកភិក្ខុ ៩០ កោដិ[១] ឰដ៏ភ្នំសុទស្សនៈ ( នេះជាសន្និបាត

---

១- គួរតែ ៩០ ពាន់កោដិ ព្រោះបាលីបិដកថា នវុតិកោដិសហស្សេហិ ។

លើកទី ៣ ) ។ សម័យនោះ តថាគតជាតាបស មានផ្នួងសក់
មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅឰដ៏អាកាស ជាអ្នកបានដល់
នូវត្រើយនៃអភិញ្ញាទាំង ៥ ដូច្នេះ ។

គាថានេះ លោកបានរចនាក្នុងទីបង្ករពុទ្ធវង្ស កថាពណ៌នានិទានរបស់អដ្ឋកថាធម្មសង្គហៈ ឈ្មោះអដ្ឋសាលិនី តែក្នុងពុទ្ធវង្សនេះមិនមាន ការដែលគាថានោះមិនមាននោះឯងសមជាង ។ បើសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយបានថា ព្រោះពោលមកហើយ ក្នុងសុមេធកថា ។

បានឮថា កាលព្រះមានព្រះភាគទីបង្ករទ្រង់សម្ដែងធម៌ ធម្មាភិសម័យមានដល់សត្វ ១ ម៉ឺន និង ២ ម៉ឺន តែការត្រាស់ដឹង ដោយចំនួន ១ នាក់ ២ នាក់ ៣ នាក់ ៤ នាក់ជាដើម មិនមានទីបំផុត ព្រោះហេតុនោះ ទើបសាសនារបស់ព្រះមានព្រះភាគទីបង្ករ ផ្សាយទៅទូលំទូលាយ មានមនុស្សត្រាស់ដឹងច្រើន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ពួកសត្វចំនួន ៣ ម៉ឺន បានត្រាស់ដឹងនូវសច្ចៈ ការត្រាស់ដឹង
របស់សត្វ នឹងរាប់ថា ១ ឬ ២ រាប់មិនអស់ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទសវីសសហស្សានំ** បានដល់ ១ ម៉ឺន និង ២ ម៉ឺន ។ បទថា **ធម្មាភិសមយោ** បានដល់ ចាក់ធ្លុះនូវធម៌ គឺសច្ចៈ ៤ ។ បទថា **ឯកទ្វិន្នំ** សេចក្ដីថា មិនរាប់ដោយន័យជាដើមថា ម្នាក់ ឬពីរនាក់ បីនាក់ បួននាក់ ។បេ។ ដប់នាក់ ។ សាសនា ឈ្មោះថា ផ្សាយទៅទូលាយ ដល់នូវភាពជាចំនួនច្រើន ព្រោះការត្រាស់ដឹងរាប់មិនអស់យ៉ាងនេះ ដែលទេវតា និង

មនុស្សជាបណ្ឌិតជាច្រើនត្រាស់ដឹង ព្រោះជានិយ្យានិកធម៌ ឈ្មោះថា សម្រេចហើយ ដោយអធិសីលសិក្ខាជាដើម និងឈ្មោះថា ចម្រើនហើយ ដោយសមាធិជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សាសនារបស់ព្រះទីបង្ករមានព្រះភាគ ជាគុណជាតធំទូលាយ
មានជនច្រើន ស្តុកស្តម្ភ សាយភាយ គឺព្រះអង្គទ្រង់ជម្រះល្អ
ហើយ ក្នុងកាលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុវិសោធិតំ** បានដល់ ដែលព្រះមានព្រះភាគទ្រង់ជម្រះហើយ ធ្វើឲ្យបរិសុទ្ធដោយល្អ បានឮថា ភិក្ខុអ្នកមានអភិញ្ញា ៦ មានឫទ្ធិច្រើន ៤ សែនរូប ចោមរោមព្រះទីបង្ករសាស្តាសព្វកាល អធិប្បាយថា សម័យនោះ ភិក្ខុពួកណាជាសេក្ខៈធ្វើកាលកិរិយា ភិក្ខុទាំងនោះរមែងត្រូវគេតិះដៀល ទើបភិក្ខុទាំងអស់ជាព្រះខីណាស្រពបរិនិព្វាន ព្រោះហេតុនោះឯង ទើបសាសនារបស់ព្រះមានព្រះភាគអង្គនោះរីកចម្រើន ពេញទំហឹង សម្រេចដោយល្អ បរិសុទ្ធពន់ពេក ដោយភិក្ខុខីណាស្រពទាំងឡាយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ពួកព្រះខីណាស្រពចំនួន ៤ សែនរូប បានលុះអភិញ្ញា ៦
មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធទីបង្ករ ដែលទ្រង់ជ្រាប
ច្បាស់នូវលោកសព្វកាល ។ ក្នុងសម័យនោះ ពួកជនណា
មួយ ដែលមិនបានលុះព្រះអរហត្ត នូវជាសេក្ខបុគ្គល លះបង់
នូវការកើតជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល ។

សាសនា ( របស់ព្រះពុទ្ធទីបង្ករនោះ ) រីកសាយល្អ រុងរឿង ដោយពួកព្រះអរហន្តទីណាស្រេព ជាតាទិបុគ្គល ប្រាសចាក មន្ទិលសព្វកាល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចត្តារិ សតសហស្សានិ** គប្បីកាន់យក សេចក្ដីយ៉ាងនេះថា លោកពោលថា **ឆឡភិញ្ញា មហិទ្ធិកា** ក៏ដើម្បីសម្ដែង ថា ភិក្ខុទាំងនេះ លោកសម្ដែងដោយការរាប់ហើយ មានចំនួនដែលសម្ដែង បានយ៉ាងនេះ ។ ម្យ៉ាងទៀត ពាក្យថា **ឆឡភិញ្ញា មហិទ្ធិកា** គប្បីជ្រាបថា ជាបឋមាវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិថា **ឆឡភិញ្ញានំ មហិទ្ធិកានំ** ។ បទថា **បរិវារេន្តិ សព្វទា** បានដល់ ចោមរោមព្រះទសពល អស់កាលជានិច្ច អធិប្បាយថា មិនលះព្រះមានព្រះភាគទៅក្នុងទីណាមួយឡើយ ។ បទថា **តេន សមយេន** បានដល់ ក្នុងសម័យនោះ **សមយ** សព្ទនេះ ប្រើក្នុងអត្ថ ៩ យ៉ាង មានអត្ថថា **សមវាយ** ជាដើម ដូចលោកពោលថា

**សមយ** សព្ទ ប្រើក្នុងអត្ថថា **សមវាយ ខណ កាល**
**សមូហ ហេតុ ទិដ្ឋិ បដិលាភ បហាន** និង **បដិវេធ**។[១]

តែក្នុងទីនេះ **សមយ** សព្ទនោះ គប្បីឃើញថា ប្រើក្នុងអត្ថថា **កាល** សេចក្ដីថា ក្នុងកាលនោះ ។ បទថា **មានុសំ ភវំ** បានដល់ ភាវៈជាមនុស្ស ។ បទថា **អប្បត្តមានសា** សេចក្ដីថា អរហត្តដែលព្រះសេក្ខៈពួកណា មិន ទាន់ដល់ មិនទាន់សម្រេច ព្រះសេក្ខៈទាំងនោះ ឈ្មោះថា មិនទាន់សម្រេច

---

១- មើលក្នុងអត្ថរបស់សមយសព្ទ ដែលមានសម្ដែងហើយក្នុងសូត្រផ្សេងៗ ខាងដើម។

អរហត្ត ។ បទថា **មានសំ** ជាឈ្មោះនៃរាគៈរបស់ចិត្ត និងរបស់អរហត្ត ។

រាគៈ លោកហៅថា **មានស** ដូចក្នុងប្រយោគជាដើមថា **អន្តលិក្ខចរោ ចាសោ យ្វាយំ ចរតិ មានសោ** អន្ទាក់ គឺរាគៈណា ដែលត្រាច់ទៅលើអាកាស ។

ចិត្ត លោកហៅថា **មានស** ដូចក្នុងប្រយោគជាដើមថា **ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ** ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ។

អរហត្ត លោកហៅថា **មានស** ដូចក្នុងបាលីថា **អប្បត្តមានសោ សេក្ខោ កាលំ កយិរា ជនេសុតា** បពិត្រព្រះមានព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវករបស់ព្រះអង្គ ជាសេក្ខបុគ្គល មានបំណងមិនទាន់សម្រេចនៅត្រេកអរក្នុងសាសនា គប្បីធ្វើមរណកាលដូចម្ដេចបាន ។

តែក្នុងទីនេះ បំណងយកអរហត្ត ព្រោះហេតុនោះ ទើបមានសេចក្ដីថា ដែលមានអរហត្តផលមិនទាន់សម្រេចហើយ ។ បទថា **សេក្ខា** មានវិនិច្ឆ័យថា ឈ្មោះថា **សេក្ខ** ព្រោះអត្ថថា ដូចម្ដេច ឈ្មោះថា **សេក្ខ** ព្រោះអត្ថថា បានទូវសេក្ខធម៌ សមដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថាសេក្ខៈនោះ ដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសេក្ខសម្មាទិដ្ឋិ ។បេ។ ប្រកបដោយសេក្ខសម្មាសមាធិ ។ ម្នាលភិក្ខុ ដែលឈ្មោះថាសេក្ខៈដោយហេតុប៉ុណ្ណោះឯង ដូច្នេះ ។ម្យ៉ាងទៀត ឈ្មោះថា **សេក្ខ** ព្រោះនៅ

សិក្សានៅឡើយ សមដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ថា ម្នាលភិក្ខុ ព្រោះតែភិក្ខុនៅសិក្សា ហេតុនោះ បានជាតថាគត ហៅថា សេក្ខៈ ។ នៅសិក្សាអ្វី ។ ម្នាលភិក្ខុ នៅសិក្សាអធិសីលផង នៅសិក្សាអធិចិត្តផង នៅសិក្សាអធិប្បញ្ញាផង ហេតុនោះ បានជាតថាគតហៅថា សេក្ខ ដូច្នេះ ។ បទថា **សុបុប្ផិតំ** បានដល់ រីកដោយល្អហើយ ។ បទថា **ចាវចនំ** បានដល់ ពាក្យដែលបណ្ឌិតសរសើរហើយ ឬពាក្យដែលដល់នូវសេចក្តីចម្រើនហើយ ឈ្មោះថា **ចាវចន**។ ពាក្យជាប្រធាននោះឯង ឈ្មោះថា **ចាវចន** អធិប្បាយថា ព្រះសាសនា ។ បទថា **ឧបសោភតិ** បានដល់ ត្រចះត្រចង់ក្រៃលែង រុងរឿងក្រៃលែង ។ បទថា **សព្វទា** បានដល់ សព្វកាល ។ បាឋៈថា **ឧប-សោភតិ សទេវកេ** ដូច្នេះក៏មាន ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់មាននគរឈ្មោះរម្មវតី បិតាជាក្សត្រព្រះនាមសុទេវៈ ព្រះមាតាជាព្រះទេវី ព្រះនាមសុមេធា គូនៃអគ្គសាវកឈ្មោះសុមង្គលៈ ១ តិស្សៈ ១ ឧបដ្ឋាកឈ្មោះសាគតៈ គូនៃអគ្គសាវិកាឈ្មោះនន្ទា ១ សុនន្ទា ១ ឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគអង្គនោះ គឺដើមលៀប ព្រះកាយកម្ពស់ ៨០ ហត្ថ ព្រះជន្មាយុមួយសែនឆ្នាំ ។

បើសួរថា ក្នុងការសម្តែងនគរ កំណើតជាដើមនេះ មានប្រយោជន៍អ្វី ។ សូមចង្អុលបង្ហាញដូច្នេះថា បើព្រះពុទ្ធអង្គណា នគរមិនប្រាកដ ព្រះជនកមិនប្រាកដ ព្រះជននីមិនប្រាកដសោត ព្រះពុទ្ធអង្គនេះ ក៏មិនប្រាកដព្រះនគរ ព្រះជនក ព្រះជននី ។ ជនទាំងឡាយ កាលសម្គាល់ថា បុគ្គលនេះ ជា

ទេវតា សក្កៈ យក្ខ មារ ឬព្រហ្ម បាដិហារ្យបែបនេះ របស់ទេវតាទាំងឡាយ មិនអស្ចារ្យ ក៏មិនគប្បីសម្គាល់ព្រះតម្រាស់ថា គួរស្តាប់ គួរកាន់យក បន្ទាប់អំពីនោះ ការត្រាស់ដឹងក៏មិនមាន ការកើតឡើងនៃព្រះពុទ្ធ ក៏អសារឥតការ ព្រះសាសនាក៏មិននាំសត្វចេញចាកទុក្ខ ព្រោះហេតុនោះ ទើបគួរសម្តែងបរិច្ឆេទខាងដើម មាននគរកំណើតរបស់ព្រះពុទ្ធគ្រប់អង្គជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

នគររបស់ព្រះសាស្តាព្រះនាមទីបង្ករ ឈ្មោះរម្មាវតី ក្សត្រិយ៍ព្រះនាមសុទេវៈ ( ជាព្រះបិតា ) ព្រះជនិកា ព្រះនាមសុមេធា ។ ព្រះជិនស្រីនៅគ្រប់គ្រងផ្ទះ អស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ខ្ពង់ខ្ពស់មាន ៣ ខ្នង គឺហង្សប្រាសាទ ១ កោញ្ចប្រាសាទ ១ មាយុរប្រាសាទ ១ ។ ពួកនារី ៣ សែននាក់ សុទ្ធសឹងតែតាក់តែងយ៉ាងល្អ នារីឈ្មោះបទុមានោះ ( ជាមហេសី ) ព្រះឱរស ព្រះនាមឧសភក្ខន្ធ ។ ព្រះជិនស្រីឃើញនិមិត្តទាំង ៤ ទ្រង់ចេញទៅ ( បួស ) ដោយយានដំរី ទ្រង់ផ្គងព្យាយាមអស់ ១០ ខែឥតខ្វះ ។ លុះព្រះមុនីមានព្រះហឫទ័យប្រព្រឹត្តព្យាយាមហើយ ក៏បានត្រាស់ជាព្រះពុទ្ធ ព្រះមហាមុនីទីបង្ករ ត្រូវព្រហ្មអារាធនាហើយ ។ ព្រះជិនស្រីមានព្យាយាមធំ ទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅក្នុងវត្តនន្ទៈ ទ្រង់គង់ទៀបគល់ប្រេស ធ្វើនូវការញាំញីតិរ្ថិយ ។ ព្រះសុមង្គលៈ

និងព្រះតិស្សៈជាអគ្គសាវក ព្រះសាគតៈជាឧបដ្ឋាករបស់ព្រះសាស្តាទីបង្ករ ។ នាងនន្ទា និងសុនន្ទាជាអគ្គសាវិកា ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថាដើមល្វៀប ។ ឧបាសកឈ្មោះតបុស្សៈ និងភល្លិកៈជាឧបដ្ឋាកដ៏ប្រសើរ នាងសិរិមា និងនាងសោណាជាឧបដ្ឋាយិកា របស់ព្រះសាស្តាទីបង្ករ ។ ព្រះមហាមុនីទីបង្ករមានកម្ពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬដូចដើមសាលរាជព្រឹក្ស មានផ្ការីកស្គុះស្គាយ ។ រស្មីរបស់ព្រះអង្គផ្សាយទៅចម្ងាយ ១០ យោជន៍ជុំវិញ ព្រះមហេសីនោះ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញុំាងព្រះសទ្ធម្មឲ្យរុងរឿង ចម្លងមហាជន ញុំាងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារវដ្ត ។ ព្រះទីបង្ករនោះ ព្រមទាំងសាវកនិព្វានទៅ ដូចគំនរភ្លើងដែលរុងរឿង រលត់ទៅ ដូច្នោះ ឫទ្ធិនោះក្តី យសនោះក្តី ទាំងចក្ករតនៈឰដ៏ព្រះបាទានោះក្តី ក៏រលត់ទៅ ។ សម្បត្តិទាំងអស់ ក៏អន្តរធានទៅ ឱហ្ន៎ ! សង្ខារទាំងពួង ជារបស់សូន្យទទេ ព្រះជិនស្រីជាសាស្តាចារ្យ ព្រះនាមទីបង្ករ ទ្រង់បរិនិព្វានក្នុងវត្តនន្ទៈ ។ ព្រះស្តូបរបស់ព្រះជិនស្រីនោះ កម្ពស់ ៣៦ យោជន៍ ( គេសាងទុក ) ក្នុងវត្តនន្ទៈនោះឯង ។ គ្រានោះ ( ពួកជនកសាង ) ព្រះស្តូបកម្ពស់ ៣ យោជន៍ ទៀបគល់ពោធិព្រឹក្ស

( សម្រាប់បញ្ចុះ ) បាត្រ និងចីវរ គ្រឿងបរិក្ខារ និងគ្រឿងប្រើប្រាស់របស់ព្រះសាស្តា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុទេវោ នាម ខត្តិយោ** សេចក្តីថា ទ្រង់មានព្រះជនកព្រះនាមសុទេវៈ ។ បទថា **ជនិកា** បានដល់ ព្រះមាតាអ្នកឲ្យកំណើត ។ បទថា **បិប្ផលិ** បានដល់ ដើមលៀប ឬដើមម្ពក់ ជាដើមឈើត្រាស់ដឹង ។ បទថា **អសីតិហត្ថមុព្វេធោ** បានដល់ ទ្រង់មានកម្ពស់ ៨០ ហត្ថ ។ បទថា **ទីបរុក្ខោវ** សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់គង់ព្រះជន្មនៅ ទ្រង់មានព្រះសរីរៈប្រដាប់ដោយព្រះវរលក្ខណ៍ ៣២ ប្រការ និងអនុព្យញ្ជនៈ បរិបូណ៌ដោយសណ្ឋាន កម្ពស់ និងទំហំ ដូចដើមឈើប្រចាំទ្វីប ដែលប្រដាប់ដោយប្រទីបមាលាដ៏រុងរឿង ទ្រង់ល្អដូចផ្ទៃអាកាសដែលរុងរឿងដោយពួកផ្កាយ បញ្ចេញនូវរស្មីត្រចះត្រចង់ ។ បទថា **សោភតិ** បានដល់ ស្អាត ។ បទថា **សាលរាជាវ ផុល្លិតោ** សេចក្តីថា ព្រះមានព្រះភាគកម្ពស់ ៨០ ហត្ថ ទ្រង់ល្អក្រៃលែង ដូចស្តេចសាលព្រឹក្ស ដែលចេញផ្កាស្គុះស្គាយ តាំងពីគល់ដល់ចុង និងដូចដើមបារិច្ឆត្តកៈ កម្ពស់ ១០០ យោជន៍ មានផ្ការីកត្រសាយត្រសុំ ។

បទថា **សតសហស្សវស្សានិ** សេចក្តីថា ទ្រង់មានព្រះជន្មាយុមួយសែនឆ្នាំ ។ បទថា **តាវតា តិដ្ឋមានោ** បានដល់ ទ្រង់មានព្រះជន្មវែងជរាបនោះ ។ បទថា **ជនតំ** បានដល់ ប្រជុំជន ។ បទថា **សន្តារេត្វា មហាជនំ** បានដល់ ញ៉ាំងមហាជនឲ្យឆ្លងឱឃសង្សារ ។ បាឋៈថា **សន្តាជាវេត្វា សទេវកំ**

ដូច្នេះក៏មាន បាឋៈនោះ មានសេចក្តីថា ញ៉ាំងលោក ព្រមទាំងទេវលោកឲ្យឆ្អែតឱយសង្ស័យ ។ បទថា **សា ច ឥទ្ធិ** បានដល់ សម្បត្តិ គឺអានុភាពនោះផង ។ បទថា **សោ ច យសោ** បានដល់ បរិវារយសនោះផង ។ បទថា **សព្វំ តមន្តរហិតំ** សេចក្តីថា សម្បត្តិ មានប្រការដូចពោលមកទាំងអស់នោះ ក៏អន្តរធានប្រាសទៅ ។ បទថា **ននុ រិត្តា សព្វសង្ខារា** សេចក្តីថា សង្ខតធម៌ទាំងឡាយទទេហ្ន៎ គឺវៀរចាកនិច្ចសារៈជាដើម ។

ក្នុងពុទ្ធវង្សនេះ បរិច្ឆេទដែលពោលដោយនគរជាដើម មកក្នុងបាលីហើយ ។ ឯវារៈច្រើនវារៈ ដែលមិនបានមកក្នុងបាលីវារៈនោះ គួរនាំមកសម្តែងផងដែរ វារៈនោះ គឺអ្វី គឺបុត្តបរិច្ឆេទ បរិច្ឆេទពោលដោយព្រះរាជឱរស ១ ភរិយាបរិច្ឆេទ បរិច្ឆេទពោលដោយអគ្គមហេសី ១ បាសាទបរិច្ឆេទ បរិច្ឆេទពោលដោយប្រាសាទ ១ អគារវាសបរិច្ឆេទ បរិច្ឆេទពោលដោយការនៅគ្រប់គ្រងផ្ទះ ១ នាដកិត្ថីបរិច្ឆេទ បរិច្ឆេទពោលដោយស្ត្រីអ្នករបាំ ១ អភិនិក្ខមនបរិច្ឆេទ បរិច្ឆេទពោលដោយអភិនេស្ក្រមណ៍ ១ បធានបរិច្ឆេទ បរិច្ឆេទពោលដោយការបំពេញព្យាយាម ១ វិហារបរិច្ឆេទ បរិច្ឆេទពោលដោយព្រះវិហារ ១ ឧបដ្ឋាកបរិច្ឆេទ បរិច្ឆេទពោលដោយពុទ្ធុបដ្ឋាក ១ ។

ហេតុក្នុងការសម្តែងបរិច្ឆេទទាំងនោះ ពោលហើយអំពីខាងដើម ព្រះទីបង្ករអង្គនោះ មានស្នំ ៣ សែន មានអគ្គមហេសីព្រះនាមបទុមា ព្រះឱរសព្រះនាមឧសភក្ខន្ធ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តាទីបង្ករ មានមហេសីនាមថា បទុមា ល្អដូចផ្កាឈូករីក ព្រះឱរសព្រះនាមថា ឧសភក្ខន្ធៈ ។

មានប្រាសាទ ៣ គឺហង្សប្រាសាទ កោញ្ចប្រាសាទ មយូរប្រាសាទ ទ្រង់គ្រប់គ្រងឃរាវាសនិស្ស័យ ១ ម៉ឺនឆ្នាំ ។

ព្រះជិនស្រីយាងចេញអភិនិស្រ្កមណ៍ ដោយយានដំរី គង់នៅក្នុងវិហារឈ្មោះនន្ទារាម ឧបដ្ឋាកឈ្មោះថា នន្ទៈ[១] ធ្វើនូវការត្រេកអរដល់សត្វលោក ។

ព្រះពុទ្ធគ្រប់អង្គ មានវេមត្តៈ គឺការប្លែកផ្សេងគ្នា ៥ យ៉ាង គឺអាយុវេមត្តៈ ការផ្សេងគ្នានៃអាយុ ១ បមាណវេមត្តៈ ការផ្សេងគ្នានៃព្រះសរីរៈ ១ កុលវេមត្តៈ ការផ្សេងគ្នានៃត្រកូល ១ បធានវេមត្តៈ ការផ្សេងគ្នានៃសេចក្តីព្យាយាម ១ រស្មិវេមត្តៈ ការផ្សេងគ្នានៃរស្មី ១ ។

បណ្តាវេមត្តៈ ៥ នោះ **អាយុវេមត្ត** បានដល់ ព្រះពុទ្ធអង្គខ្លះ មានព្រះជន្មាយុវែង អង្គខ្លះ មានព្រះជន្មាយុខ្លី ។ ពិតហើយ ព្រះមានព្រះភាគទីបង្ករ មានព្រះជន្មាយុប្រមាណមួយសែនឆ្នាំ ព្រះមានព្រះភាគនៃយើង មានព្រះជន្មាយុប្រមាណ ១០០ ឆ្នាំ ។

ឈ្មោះថា **បមាណវេមត្ត** បានដល់ ព្រះពុទ្ធអង្គខ្លះខ្ពស់ ព្រះពុទ្ធអង្គខ្លះទាប ពិតហើយ ព្រះពុទ្ធទីបង្ករកម្ពស់ ៨០ ហត្ថ ឯព្រះមានព្រះភាគនៃយើងកម្ពស់ ១៨ ហត្ថ ។

---

១- បិដកខ្មែរជាសាគតៈ ។

ឈ្មោះថា **កុលវេមត្ត** បានដល់ ព្រះពុទ្ធអង្គខ្លះកើតក្នុងត្រកូលក្សត្រ អង្គខ្លះកើតក្នុងត្រកូលព្រាហ្មណ៍ ពិតហើយ ព្រះពុទ្ធទីបង្ករកើតក្នុងត្រកូលក្សត្រ ព្រះពុទ្ធកកុសន្ធៈ និងព្រះពុទ្ធកោនាគមនៈជាដើម កើតក្នុងត្រកូលព្រាហ្មណ៍ ។

ឈ្មោះថា **បធានវេមត្ត** បានដល់ ព្រះពុទ្ធអង្គខ្លះបំពេញព្យាយាមអស់កាលបន្តិចបន្តួចប៉ុណ្ណោះ ដូចព្រះមានព្រះភាគកស្សបៈ អង្គខ្លះបំពេញព្យាយាមអស់កាលយូរ ដូចព្រះមានព្រះភាគនៃយើង ។

ឈ្មោះថា **រស្មិវេមត្ត** បានដល់ ព្រះរស្មីសរីរៈរបស់ព្រះមានព្រះភាគមង្គលៈ ផ្សាយទៅអស់ម៉ឺនលោកធាតុ របស់ព្រះមានព្រះភាគនៃយើងប្រមាណមួយព្យាម ។

បណ្តាវេមត្តៈ ៥ នោះ រស្មីវេមត្តៈ ទាក់ទងដោយព្រះអធ្យាស្រ័យ ព្រះពុទ្ធអង្គណាប្រាថ្នាប៉ុនណា រស្មីព្រះសរីរៈរបស់ព្រះពុទ្ធអង្គនោះ ក៏ផ្សាយទៅប៉ុណ្ណោះ ។ ឯអធ្យាស្រ័យរបស់ព្រះមង្គលសម្ពុទ្ធ មានហើយថា សូមរស្មីផ្សាយទៅអស់ម៉ឺនលោកធាតុ ។ តែមិនមានការផ្សេងគ្នា ក្នុងការចាក់ធ្លុះនូវគុណទាំងឡាយរបស់ព្រះពុទ្ធគ្រប់អង្គ ។

ម្យ៉ាងទៀត មានទី ៤ កន្លែង ដែលព្រះពុទ្ធគ្រប់អង្គមិនលះបង់ គឺពោធិបល្ល័ង្ក ជាទីដែលទ្រង់មិនលះបង់ គឺមានត្រង់ទីតែមួយពិតប្រាកដ ។ ទីប្រកាសធម្មចក្រ ក៏ទ្រង់មិនលះបង់ គឺត្រង់ឥសិបតនមិគទាយវ័នប៉ុណ្ណោះ ។ ទីដែលទ្រង់ចុះចាកទេវលោក ក្បែរទ្វារនគរសង្កស្ស ឈានព្រះបាទដំបូង ក៏

ទ្រង់មិនលះបង់ ។ ទីដែលជើងគ្រែទាំង ៤ តាំងនៅត្រង់ព្រះគន្ធកុដិ ក្នុងជេតពនមហាវិហារ ក៏ទ្រង់មិនលះបង់ដូចគ្នា ។ សូម្បីព្រះវិហារ ក៏ទ្រង់មិនលះបង់ តែវិហារនោះ តូចខ្លះ ធំខ្លះ ។

ម្យ៉ាងទៀត ប្រការដទៃទៀតរបស់ព្រះមានព្រះភាគនៃយើង មានសហជាតបរិច្ឆេទ ( បរិច្ឆេទពោលដោយរបស់ដែលកើតឡើងព្រមគ្នា ) និងនក្ខត្តបរិច្ឆេទ ( បរិច្ឆេទពោលដោយនក្ខត្តឫក្សមានជាពិសេស ) ។ បានឮថា សហជាត គឺវត្ថុដែលកើតរួមជាមួយព្រះសព្វញ្ញូពោធិសត្វនៃយើង មាន ៧ គឺ រាហុលមាតា ១ អានន្ទត្ថេរ ១ ឆន្ន ១ ស្តេចសេះកណ្ឋក: ១ កំណប់ទ្រព្យ ១ មហាពោធិព្រឹក្ស ១ កាឡុទាយី ១ ។ បានឮថា ដោយនក្ខត្តឫក្សក្នុងខែអាសាឍនោះឯង ព្រះមហាបុរសក៏ចុះកាន់គភ៌ព្រះមាតា ទ្រង់ចេញមហាភិនេស្ក្រមណ៍ ប្រកាសធម្មចក្រ ទ្រង់ធ្វើយមកប្បាដិហារ្យ ។ ដោយនក្ខត្តឫក្សក្នុងខែវិសាខក៏ប្រសូត ត្រាស់ដឹង និងបរិនិព្វាន ។ ដោយនក្ខត្តឫក្សខែមាឃ ទ្រង់ក៏ប្រជុំសាវក ទ្រង់ដាក់អាយុសង្ខារ ។ ដោយនក្ខត្តឫក្សក្នុងខែអស្សុជ ទ្រង់ចុះអំពីទេវលោក ។ សេចក្តីវិសេសដូចពោលមកនេះ គួរនាំមកសម្តែង នេះជាបរិច្ឆេទពោលដោយភារៈច្រើនភារ: គាថាដ៏សេសមានអត្ថងាយហើយ ។

ព្រះមានព្រះភាគទីបង្ករ តាំងនៅជរាបដល់អស់ព្រះជន្មាយុ ទ្រង់ធ្វើ

ពុទ្ធកិច្ចសព្វយ៉ាង ទ្រង់រម្ងាត់ខន្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុតាមលំដាប់ ។

បានឮថា ក្នុងកប្បណាដែលព្រះទីបង្ករទសពលទ្រង់កើតឡើង ក្នុងកប្បនោះ មានព្រះពុទ្ធអង្គដទៃៗ ៣ អង្គទៀត គឺព្រះតណ្ហង្ករ ព្រះមេធង្ករ និងព្រះសរណង្ករ ការព្យាករណ៍ព្រះពោធិសត្វក្នុងសម្នាក់របស់ព្រះពុទ្ធទាំងនោះ មិនមាន ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងនោះមិនបានសម្តែងក្នុងទីនេះ តែដើម្បីសម្តែងព្រះពុទ្ធគ្រប់អង្គដែលកើតហើយ តាំងពីដើមកប្បនោះ ទើបលោកពោលពាក្យនេះថា

ព្រះសម្ពុទ្ធ ជាកំពូលនៃសត្វជើង ២ គឺព្រះតណ្ហង្ករ ព្រះមេធង្ករ ព្រះសរណង្ករ ព្រះទីបង្ករ និងព្រះកោណ្ឌញ្ញៈ ។
ព្រះមុនី គឺព្រះមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតៈ ព្រះអនោមទស្សី ព្រះបទុមៈ ព្រះនារទៈ ព្រះបទុមុត្តរៈ ។
ព្រះសាស្តាមានយសធំ ជាលោកនាយក គឺព្រះសុមេធ ព្រះសុជាត ព្រះបិយទស្សី ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថ ។
ព្រះសម្មាសម្ពុទ្ធជានាយក គឺព្រះតិស្សៈ ព្រះផុស្សៈ ព្រះ

វិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈ ។

ព្រះសម្ពុទ្ធទាំងនោះ មានមកហើយ ទ្រង់ប្រាសចាករាគៈ មានព្រះហឫទ័យមាំទាំ ទ្រង់កើតហើយ ទ្រង់បន្ទោបង់មោហន្ធការ ដូចព្រះអាទិត្យ ព្រះអង្គ មួយអន្លើដោយសាវក រមែងទ្រង់បរិនិព្វានទៅហើយ ដូចគំនរភ្លើងឆេះហើយ រលត់ទៅ ដូច្នោះ ។ល។

## អដ្ឋកថាឌីបង្ករពុទ្ធវង្សទី ១ ចប់

# សុត្តន្តបិដក

## កោណ្ឌញ្ញពុទ្ធវង្សទី ២

[ ៣ ] សម័យខាងក្រោយ អំពីព្រះសម្ពុទ្ធទីបង្ករមក ព្រះលោកនាយកព្រះនាមកោណ្ឌញ្ញៈ ទ្រង់មានតេជៈរកទីបំផុតគ្មាន មានយសរាប់មិនបាន មានគុណប្រមាណមិនបាន មិនងាយបុគ្គលគ្របសង្កត់បាន ។ ព្រះអង្គមានការអត់ធន់ ប្រៀបដោយធរណី មានសីលប្រៀបដោយសាគរ មានសមាធិប្រៀបដោយភ្នំសុមេរុ មានញាណប្រៀបដោយអាកាស ។ ព្រះសម្ពុទ្ធទ្រង់ប្រកាសហើយនូវការប្រកាសឥន្ទ្រិយពល ពោជ្ឈង្គ និងមគ្គសច្ច ដើម្បីប្រយោជន៍ដល់សព្វសត្វទាំងឡាយ សព្វកាល ។ កាលព្រះកោណ្ឌញ្ញៈ ជាលោកនាយក ទ្រង់សម្តែងធម្មចក្រ ពួកសត្វមួយសែនកោដិបានសម្រេចមគ្គផលលើកទី ១ ។ លំដាប់តអំពីនោះ កាលព្រះអង្គទ្រង់សម្តែងធម៌ក្នុងសមាគមនៃមនុស្ស និងទេវតា ពួកសត្វ ៩០ ពាន់កោដិ បានសម្រេចមគ្គផលលើកទី ២ ។ កាលព្រះលោកនាយកទ្រង់សម្តែងធម៌ញាំញីពួកតិរ្ថិយ ពួកសត្វ ៨០ ពាន់កោដិបានសម្រេចមគ្គផលលើកទី ៣ ។ ព្រះមហេសីកោណ្ឌញ្ញៈ មានសាវកសន្និបាត ៣ លើក គឺសន្និបាតទី ១ មានព្រះខីណាស្រពដែលប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹងចំនួនមួយសែនកោដិ សន្និបាតទី ២ មានព្រះខីណាស្រពមួយពាន់កោដិ សន្និបាតទី ៣ មានព្រះខីណាស្រព ៩០ កោដិ ។

ក្នុងសម័យនោះ តថាគតបានកើតជាក្សត្រ មានឈ្មោះថាវិជិតាវី បានញ៉ាំងឥស្សរិយយសឲ្យប្រព្រឹត្តទៅ រហូតដល់សមុទ្រជាទីបំផុត ។ តថាគតបាននិមន្តព្រះខីណាស្រពមួយសែនកោដិ ដែលប្រាសចាកមន្ទិល ស្វែងរកគុណដ៏ធំ ព្រមទាំងព្រះសម្ពុទ្ធ ជាទីពឹងដ៏ប្រសើររបស់សត្វលោក ឲ្យឆាន់ស្កប់ស្កល់ដោយម្ហូបចំណីដ៏ថ្លៃថ្លា ។ ព្រះសម្ពុទ្ធជាលោកនាយក ព្រះនាមកោណ្ឌញ្ញៈអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបានអំពីកប្បនេះ បុរសនេះ នឹងបានជាព្រះពុទ្ធក្នុងលោក ។ សត្វ ( នេះ ) នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វ ( នេះ ) នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ តអំពីនោះមក សត្វ ( នេះ ) មានយសច្រើន ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ( ដើមពោធិ៍ ) ។ ព្រះមាតាបង្កើតនៃព្រះពុទ្ធនេះ នឹងមានព្រះនាមថាមាយា ព្រះបិតាមានព្រះនាមថាសុទ្ធោទនៈ ឯព្រះពុទ្ធអង្គនេះ មានព្រះនាមថាគោតម ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ មិនមានអាសវៈ ប្រាស

ចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គ-សាវក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាកបម្រើព្រះជិនស្រី អង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិន មានអាសវៈ ប្រាសចាកតម្រេក មានចិត្តតម្កល់មាំ នឹងជាអគ្គ-សាវិកា ។ ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកជាឧបដ្ឋាកដ៏ប្រសើរឈ្មោះចិត្តៈ ១ ហត្ថា-ឡវកៈ ១ ។ ឧបាសិកាជាឧបដ្ឋាយិកាដ៏ប្រសើរ ឈ្មោះនន្ទមាតា ១ ឧត្តរា ១ ព្រះគោតមដ៏ទ្រង់យសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ភាសិតរបស់ព្រះ សម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំនេះ ហើយ ក៏រីករាយថា បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួក មនុស្ស ព្រមទាំងទេវតាមួយម៉ឺន មានសំឡេងហ៊ោឡើងផង ទះ ដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនា របស់ព្រះលោកនាថកោណ្ឌញ្ញៈអង្គ នេះ គង់នឹងបានជួបចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ក្នុង កាលជាអនាគតមិនខាន ។ ពួកមនុស្សកាលនឹងឆ្លងស្ទឹង បើឃ្លាង កំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹង ធំ យ៉ាងណា យើងទាំងអស់គ្នា បើលះបង់ព្រះជិនស្រីនេះហើយ គង់នឹងបានជួបចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាល

ជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់នូវព្រះតម្រាស់របស់ព្រះសម្ពុទ្ធអង្គនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក កាលញ៉ាំងប្រយោជន៍នោះឲ្យសម្រេច បានថ្វាយរាជសម្បត្តិដ៏ធំចំពោះព្រះជិនស្រី លុះថ្វាយរាជសម្បត្តិដ៏ធំហើយ ទើបបួសក្នុងសម្នាក់របស់ព្រះអង្គ ។ តថាគតបានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនាមានអង្គ ៩ ទាំងអស់ ហើយញ៉ាំងសាសនានៃព្រះជិនស្រីឲ្យរុងរឿង ។ តថាគតមិនប្រមាទ កាលនៅក្នុងទីនោះ បានសម្រេចអភិញ្ញាបារមីក្នុងទីអង្គុយ និងទីចង្រ្កម ក៏បានទៅកើតក្នុងព្រហ្មលោក ។ ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះរម្មវតី មានព្រះបិតាព្រះនាមសុនន្ទៈ ព្រះមាតាព្រះនាមនាងសុជាតាទេវី ។ ព្រះអង្គគង់នៅក្នុងកណ្តាលផ្ទះអស់មួយម៉ឺនឆ្នាំ ឯប្រាសាទដ៏ប្រសើរសម្រាប់ព្រះអង្គ មាន ៣ គឺរុចិប្រាសាទ ១ សុរុចិប្រាសាទ ១ សុភប្រាសាទ ១ ។ នារី ៣ សែន មានគ្រឿងប្រដាប់សមរម្យ នារីជាកិរិយានោះព្រះនាមរុចិទេវី មានព្រះរាជបុត្រ ១ ព្រះអង្គ ព្រះនាមជីវិតសេន ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាង ទ្រង់ចេញដោយរថយាន ទៅតាំងសេចក្តីព្យាយាមអស់ ១០ ខែឥតខ្វះ ។ ព្រះសម្ពុទ្ធព្រះនាមកោណ្ឌញ្ញៈ មានព្រះហឫទ័យស្ងប់រម្ងាប់ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ មានចក្កប្រព្រឹត្តទៅ មានព្យាយាមច្រើន ត្រូវមហាព្រហ្ម

អារាធនាក្នុងមហាវ៉នរបស់ពួកទេវតា ។ ព្រះថេរៈឈ្មោះភទ្ទៈ ១ សុភទ្ទៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះអនុរុទ្ធ ជាឧបដ្ឋាករបស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកគុណដ៏ធំ ។ ភិក្ខុនីឈ្មោះតិស្សា ១ ឧបតិស្សា ១ ជាអគ្គសាវិកា សាលកល្យាណិព្រឹក្សជាពោធិ៍របស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ឧបាសកឈ្មោះសោណៈ ១ ឧបសោណៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនន្ទា ១ សិរិមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីអង្គនោះ មានកម្ពស់ ៨៨ ហត្ថ ទ្រង់ល្អល្អះដូចព្រះចន្ទ ពុំនោះសោតដូចព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ ។ ព្រះអង្គមានជន្មាយុមួយសែនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់កាលដរាបនោះ ទ្រង់ញ៉ាំងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកវាលវដ្តសង្សារ ) ។ ផែនដីដ៏វិចិត្រដោយព្រះខីណាស្រពទាំងឡាយ ដែលអស់មន្ទិល ព្រះសម្ពុទ្ធអង្គនោះទ្រង់រុងរឿងដូចមេឃ ដែលល្អដោយពួកផ្កាយ ។ ព្រះនាគត្ថេរទាំងអម្បាលនោះ មានគុណប្រមាណមិនបាន មានសន្តានមិនកម្រើកបុគ្គលចូលទៅរកបានដោយកម្រ សម្តែងនូវឫទ្ធិ ដូចការធ្លាក់ចុះនៃផ្លេកបន្ទោរ ព្រះអរហន្តដ៏មានយសធំទាំងនោះ និព្វានហើយ ។ចំណែកឫទ្ធិរបស់ព្រះជិនស្រីនោះ ជាគុណឥតប្រឹងថ្លែងបាន សមាធិ

មានញាណអប់រំហើយ របស់ទាំងអស់វិនាស សូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ។ ព្រះកោណ្ឌញ្ញសម្ពុទ្ធ ព្រះអង្គទ្រទ្រង់សិរី ទ្រង់បរិនិព្វានក្នុងនន្ទារាម ពួកមហាជនបានបញ្ចុះ ( ព្រះអដ្ឋិ ) របស់ព្រះអង្គនោះ ក្នុងចេតិយមានកម្ពស់ ៧ យោជន៍ ក្នុងនន្ទារាមនោះឯង ។

## កោណ្ឌញ្ញពុទ្ធវង្សទី ២ ចប់

# អដ្ឋកថា

## កោណ្ឌញ្ញពុទ្ធវង្សទី ២

បានឮមកថា កាលព្រះមានព្រះភាគទីបង្ករ រម្ងត់ខន្ធបរិនិព្វានហើយ សាសនារបស់ព្រះអង្គតាំងនៅមួយសែនឆ្នាំ ។ កាលនោះ ព្រោះអន្តរធាននៃសាវកទាំងឡាយដែលត្រាស់ដឹងតាមព្រះពុទ្ធ សូម្បីសាសនារបស់ទ្រង់ ក៏អន្តរធានទៅ ។ តមក ក្នុងកាលខាងក្រោយអំពីសាសនាព្រះអង្គ កន្លងទៅមួយអសង្ខេយ្យ ព្រះសាស្តាព្រះនាមកោណ្ឌញ្ញៈ ក៏ឧប្បត្តិកក្នុងកប្បមួយ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមីមកអស់ ១៦ អសង្ខេយ្យ និង ១ សែនកប្ប អប់រំបន្ទុំញាណចាស់ក្លាហើយ ទ្រង់តាំងនៅក្នុងអត្តភាពដូចគ្នានឹងអត្តភាពព្រះវេស្សន្តរ ចុតិចាកអត្តភាពនោះហើយ កើតក្នុងស្ថានសួគ៌ជាន់តុសិត តាំងនៅក្នុងតុសិតនោះដរាបដល់អស់អាយុ ប្រទានបដិញ្ញាដល់ទេវតាទាំងឡាយ ចុតិចាកតុសិត បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងសុជាតាទេវី ក្នុងរាជត្រកូលរបស់ព្រះបាទសុនន្ទៈ នគររម្មវតី ។ ក្នុងខណៈដែលព្រះអង្គបដិសន្ធិ កើតបាដិហារ្យ ៣២ ប្រការ ដូចពោលក្នុងវង្សរបស់ព្រះទីបង្ករសម្ពុទ្ធ ។ ទ្រង់មានពួកទេវតារក្សា គ្រប់ទសមាស ក៏ប្រសូតចាកគភ៌ព្រះមាតា ទ្រង់ជាកំពូលរបស់សព្វសត្វ បែរព្រះភក្ត្រទៅទិសឧត្តរ ទ្រង់ឈាន ៧ ជំហាន ក្រឡេកមើលទិស ទ្រង់បន្លឺអាសភិវាចាថា **អគ្គោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស អយ-មន្តិមា ជាតិ នត្ថិ ទានិ បុនព្ភវោ។**

អញជាបុគ្គលខ្ពង់ខ្ពស់របស់លោក អញជាបុគ្គលធំបំផុតរបស់លោក អញ

ជាបុគ្គលប្រសើរបំផុតរបស់លោក នេះជាកំណើតបំផុតរបស់អញ ឥឡូវនេះ ភពថ្មីតពីនេះទៅទៀតមិនមានឡើយ ដូច្នេះ ។

បន្ទាប់អំពីនោះ ក្នុងថ្ងៃថ្វាយព្រះនាមរបស់ព្រះពោធិសត្វនោះ ព្រះញាតិទាំងឡាយថ្វាយព្រះនាមថា កោណ្ឌញ្ញៈ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់មានព្រះគោត្រ ជាកោណ្ឌញ្ញគោត្រ ។ បានឮថា ទ្រង់មានប្រាសាទ ៣ គួរជាទីត្រេកអរក្រៃលែង ឈ្មោះរាមប្រាសាទ ១ សុរាមប្រាសាទ ១ សុភប្រាសាទ ១[1] ប្រាសាទ ៣ ខ្នងនោះ មានស្ត្រីរបាំដែលជំនាញក្នុងការរាំការប្រគំ នៅប្រចាំរហូត ៣ សែននាក់ ទ្រង់មានអគ្គមហេសីព្រះនាមថា រុចិទេវី មានព្រះឱរសព្រះនាមថាវិជិតសេន ទ្រង់គ្រប់គ្រងឃរាវាសវិស័យមួយម៉ឺនឆ្នាំ ។

ព្រះពោធិសត្វនោះ ទ្រង់ឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួស ទ្រង់យាងចេញអភិនេស្រ្កមណ៍ ដោយរថដែលទឹមដោយសេះ ទ្រង់ព្រះផ្នួសហើយ ទ្រង់បំពេញព្យាយាម ១០ ខែ ។ មនុស្ស ១០ កោដិ ក៏បួសតាមព្រះអង្គ ។ កោណ្ឌញ្ញកុមារទ្រង់ផ្នួស ដែលមនុស្សទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាម ១០ ខែ ក្នុងតិថី ១៥ កើត ខែវិសាខ សោយមធុបាយាសមានរសក្រៃលែង ដែលសេដ្ឋីធីតាឈ្មោះ យសោធរា ដែលមានស្តនប៉ុនគ្នា ក្នុងស្រុកសុនន្ទគាមថ្វាយហើយ ទ្រង់សម្រាកពេលថ្ងៃត្រង់ព្រៃសាលព្រឹក្ស ដែលប្រដាប់ដោយផ្លែ ស្លឹកខ្ចី និងពន្លក ពេលល្ងាច

---
១- បិដកខ្មែរជា រុចិប្រាសាទ សុរុចិប្រាសាទ និងសុភប្រាសាទ ។

ទ្រង់លះពួកគណៈ ហើយទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលសុនទ្ទកអាជីវក ថ្វាយ ទ្រង់ធ្វើប្រទក្សិណដើមសាលកល្យាណី គឺដើមភ្លៅនាង ៣ ជុំ ទ្រង់ពិនិត្យមើលត្រង់ទិសបូព៌ា ទ្រង់ឲ្យដើមឈើដែលត្រាស់ដឹងនៅអំពីខាងក្រោយ ទ្រង់ក្រាលស្មៅទំហំ ៥៨ ហត្ថ ទ្រង់គង់ពត់ភ្នែន អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ទ្រង់កម្ចាត់កម្លាំងរបស់មារក្នុងបឋមយាម ទ្រង់ជម្រះបុព្វេនិវាសានុស្សតិញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុក្នុងបច្ឆិមយាម ទ្រង់ពិចារណាបច្ចយាការ ទ្រង់ចេញអំពីចតុត្ថជ្ឈាន មានអានាបានស្សតិជាអារម្មណ៍ ទ្រង់ពិចារណាបញ្ចក្ខន្ធ ទ្រង់ឃើញលក្ខណៈទាំងឡាយដោយបញ្ញាដ៏ស្មើ ដោយឧទយព្វយញ្ញាណ ទ្រង់ចម្រើនវិបស្សនា រហូតដល់គោត្រភូញាណ ទ្រង់ចាក់ធ្លុះនូវមគ្គញ្ញាណ ៤ ផលញ្ញាណ ៤ បដិសម្ភិទា ៤ ញាណកំណត់កំណើត ៤ ញាណកំណត់គតិ ៥ អសាធារញ្ញាណ ៦ និងពុទ្ធគុណទាំងអស់ ទ្រង់មានព្រះតម្រិះបរិបូណ៌ គង់ត្រង់គល់ឈើជាទីត្រាស់ដឹងនោះឯង ទ្រង់បន្លឺឧទានយ៉ាងនេះថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខ
រឿយៗ ។

នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ
អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹង

ជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ជំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។ បុគ្គល រមែងមិនដឹងគតិ របស់ភ្លើងកំពុងឆេះ ទឹងជុំដែកដែលគេដំហើយ ដែលរលត់ទៅ ដោយលំដាប់ យ៉ាងណាមិញ គតិរបស់ពួកលោក អ្នករួចស្រឡះចាកកិលេស ដោយប្រពៃ អ្នកឆ្លងចាកចំណង និងឱឃៈ គឺកាម ដល់នូវសេចក្តីសុខ មិនញាប់ញ័រ រមែងមិនអាចដឹងបាន ក៏យ៉ាងនោះដែរ ដូច្នេះ ។

ទ្រង់សម្ងំដោយសុខក្នុងផលសមាបត្តិ ត្រង់គល់ពោធិព្រឹក្ស ៧ សប្តាហ៍ ក្នុងសប្តាហ៍ទី ៨ ទ្រង់អាស្រ័យការអារាធនារបស់ព្រហ្ម ទ្រង់ពិចារណាថា តថាគតនឹងសម្តែងធម៌ដំបូងដល់អ្នកណាហ្ន៎ ក៏ទ្រង់ឃើញភិក្ខុ ១០ កោដិ ដែលបួសជាមួយព្រះអគ្គថា កុលបុត្តទាំងនេះ សន្សំកុសលមូលមក ទើបបួសតាមតថាគតដែលកំពុងបួស បំពេញព្យាយាមជាមួយតថាគត បម្រើតថាគត ណ្ហើយចុះ តថាគតគប្បីសម្តែងធម៌ដល់កុលបុត្តទាំងនេះមុនគេ ទ្រង់ពិចារណាយ៉ាងនេះហើយ ទ្រង់ប្រមើលមើលថា ភិក្ខុទាំងនោះ ឥឡូវនេះ នៅឯណា ទ្រង់ឃើញថា នៅត្រង់ទេវវ័ន ក្នុងនគររម្មវតី[១] ចម្ងាយផ្លូវ ១៨

---

១- ច្បាប់ឆដ្ឋសង្គាយនា ជានគរអរុន្ធវតី ។

យោជន៍អំពីទីនេះ ទើបទ្រង់បាត់អំពីគល់ពោធិព្រឹក្ស ទៅប្រាកដត្រង់ទេវវ័ន ដូចបុរសមានកម្លាំងលាដៃ ហើយបត់ ឬបត់ដៃដែលលា ដូច្នោះ ។

សម័យនោះ ភិក្ខុទាំង ១០ កោដិនោះ អាស្រ័យនៅត្រង់ទេវវ័ន នគររម្មវតី ។ ភិក្ខុទាំងនោះ ឃើញព្រះទសពលទ្រង់យាងមកអំពីចម្ងាយ នាំគ្នាមានចិត្តជ្រះថ្លា ទទួលបាត្រ ចីវររបស់ព្រះមានព្រះភាគ ក្រាលពុទ្ធាសនៈធ្វើសេចក្ដីគោរព ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយចោមរោម ក្នុងទីសមគួរនាចំណែកម្ខាង ។ ក្នុងទីនោះ ព្រះកោណ្ឌញ្ញទសពល ដែលពួកមុនីចោមរោមហើយ គង់លើពុទ្ធាសនៈដ៏រុងរឿង ដូចស្ដេចសហស្សនេត្រ ដែលពួកទេវតាស្ថានត្រៃត្រិង្សចោមរោម ដូចមណ្ឌលព្រះអាទិត្យក្នុងសរទរដូវ ដែលគោចរក្នុងផ្ទៃនភាកាស ដែលឥតមន្ទិល និងដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើតដែលចោមរោមពួកផ្កាយ ។ គ្រានោះ ព្រះសាស្ដាត្រាស់ធម្មចក្កប្បវត្តនសូត្រ មានបរិវដ្ដ ៣ អាការ ១២ ដ៏កំពូលដែលព្រះពុទ្ធគ្រប់អង្គ ទ្រង់សេពហើយ ដល់ភិក្ខុទាំងនោះ ទ្រង់ញ៉ាំងទេវតា និងមនុស្សមួយសែនកោដិ មានភិក្ខុ ១០ កោដិជាប្រធាន ឲ្យផឹកនូវអមតធម៌ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យខាងក្រោយ អំពីព្រះសម្ពុទ្ធទីបង្ករមក ព្រះលោក-
នាយកព្រះនាមកោណ្ឌញ្ញៈ ទ្រង់មានតេជៈ រកទីបំផុតគ្មាន
មានយសរាប់មិនបាន មានគុណប្រមាណមិនបាន មិនងាយ
បុគ្គលគ្របសង្កត់បាន ។ ព្រះអង្គមានការអត់ធន់ ប្រៀប

ដោយធរណី មានសីល ប្រៀបដោយសាគរ មានសមាធិ ប្រៀបដោយភ្នំសុមេរុ មានញាណប្រៀបដោយអាកាស ។ ព្រះសម្ពុទ្ធទ្រង់ប្រកាសហើយ នូវការប្រកាសឥន្ទ្រិយពល ពោជ្ឈង្គ និងមគ្គសច្ច ដើម្បីប្រយោជន៍ដល់សព្វសត្វទាំងឡាយ សព្វកាល ។ កាលព្រះកោណ្ឌញ្ញៈ ជាលោកនាយក ទ្រង់សម្តែងធម្មចក្រ ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផលលើកទី ១ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទីបង្ករស្ស អបរេន** សេចក្តីថា ក្នុងសម័យបន្ទាប់អំពីសម័យរបស់ព្រះទីបង្ករសាស្តា ។ បទថា **កោណ្ឌញ្ញោ នាម** បានដល់ ជានាមាភិធេយ្យ ដែលទ្រង់បានទទួលដោយព្រះគោត្ររបស់ព្រះអង្គ ។ បទថា **នាយកោ** បានដល់ ជាអ្នកនាំវិសេស ។ បទថា **អនន្តតេជោ** បានដល់ មានព្រះតេជៈមិនមានទីបំផុត ដោយតេជៈនៃសីលគុណ ញាណ និងបុណ្យ ។ ខាងក្រោមចាប់ពីអវិចី ខាងលើដល់ភវគ្គព្រហ្ម ខាងទទឹង ដល់លោកធាតុមិនមានទីបំផុត ក្នុងរវាងនេះ បុគ្គលណាមួយ ឈ្មោះថា ជាអ្នកអាចឈរសម្លឹងព្រះភក្ត្ររបស់ព្រះអង្គមិនមានឡើយ ដោយហេតុនោះ ទើបត្រាស់ថា **អនន្តតេជោ** ។ បទថា **អមិតយសោ** បានដល់ មានបរិវារយសមិនមានទីបំផុត ។ ពិតហើយ មួយសែនឆ្នាំរបស់ព្រះមានព្រះភាគអង្គនោះ ដរាបដល់សម័យដែលទ្រង់រម្មត់ខន្ធបរិនិព្វាន ក្នុងចន្លោះនេះ ចំនួនភិក្ខុបរិស័ទកំណត់មិនបានឡើយ ។ ព្រោះហេតុនោះ ទើបត្រាស់ថា **អមិត យសោ**

មានយសរាប់មិនបាន សូម្បីព្រះកិត្តិគុណដែលកំណត់មិនបាន ក៏ត្រាស់ថា **អមិត យសោ**។ បទថា **អប្បមេយ្យោ** បានដល់ ប្រមាណមិនបាន ដោយប្រមាណពួកនៃគុណ ហេតុនោះ ទើបឈ្មោះថា **អប្បមេយ្យោ** ដូចលោកពោលថា

បើព្រះពុទ្ធគប្បីត្រាស់សរសើរគុណ របស់ព្រះពុទ្ធផងគ្នា មិនចាំបាច់ត្រាស់ដល់រឿងដទៃឡើយ សូម្បីអស់កប្ប កប្បដែលមានចន្លោះកាលដ៏យូរ ក៏គប្បីអស់ទៅ តែការសរសើរព្រះគុណរបស់ព្រះសាស្តា មិនទាន់អស់ទៅឡើយ ដូច្នេះ ។

ព្រោះហេតុនោះ ទើបលោកហៅថា **អប្បមេយ្យោ** ព្រោះទ្រង់មានព្រះគុណទាំងឡាយប្រមាណមិនបាន ។ បទថា **ទុរាសទោ** បានដល់ ដែលបុគ្គលណាមួយចូលគាល់បានលំបាក ឈ្មោះថា **ទុរាសទោ** ភាពជាបុគ្គលដែលបុគ្គលណាមួយ មិនអាចចូលទៅបៀតបៀនខ្ទាំងខ្ទប់ គឺជាបុគ្គលដែលបុគ្គលណាមួយ មិនអាចគ្របសង្កត់បាន ។

បទថា **ធរណូបមោ** បានដល់ ជាបុគ្គលស្មើដោយធរណី ។ បទថា **ខមនេន** បានដល់ ដោយខន្តី ព្រះពុទ្ធ លោកហៅថា ឧបមាដូចធរណី ព្រោះទ្រង់មិនញាប់ញ័រដោយឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ មានលាភ និងមិនមានលាភជាដើម ដូចមហាប្រឹថពីមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ មិនញាប់ញ័រដោយខ្យល់ប្រក្រតី ដូច្នោះ ។ បទថា **សីលេន សាគរូបមោ** បានដល់ ទ្រង់ស្មើដោយសាគរ ព្រោះទ្រង់មិនល្មើសព្រំដែនដោយសីល-

សំវរៈ ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទនិកាយ ឧទាន ) ថា ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបានឡើយ ដូច្នេះ ។

បទថា **សមាធិនា មេរូបមោ** បានដល់ ទ្រង់ជាបុគ្គលស្មើដោយភ្នំសិនេរុ ព្រោះមិនមានការញាប់ញ័រ ដែលនឹងកើតអំពីធម៌ជាសត្រូវចំពោះសមាធិ ឬមានព្រះសរីរៈមាំទាំ ដូចស្តេចភ្នំមេរុ ។ ក្នុងបទថា **ញាណេន គគនូបមោ** នេះ លោកឧបមាដោយអាកាស ដែលមិនមានទីបំផុត ។ ព្រោះព្រះញាណរបស់ព្រះមានព្រះភាគមិនមានទីបំផុត ព្រះមានព្រះភាគត្រាស់នូវអនន្តៈ ៤ យ៉ាង ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ ពុទ្ធវង្ស ) ថា

ពួកសត្វ ១ អាកាស ១ ចក្កវាឡមិនមានទីបំផុត ១ ពុទ្ធញាណ
ដែលប្រមាណមិនបាន ១ បុគ្គលមិនអាចដឹងបានឡើយ ។

បទថា **ឥន្ទ្រិយពលពោជ្ឈង្គមគ្គសច្ចប្បកាសនំ** សេចក្តីថា សូម្បីសតិប្បដ្ឋាន សម្មប្បធាន និងឥទ្ធិបាទ ឈ្មោះថា ទ្រង់កាន់ហើយដូចគ្នា ដោយការចង្អុលបង្ហាញដល់សត្វថា យកឥន្ទ្រិយ ពល ពោជ្ឈង្គ និងមគ្គសច្ចទាំងនេះ ព្រោះហេតុនោះ ទើបទ្រង់ប្រកាសសម្តែងធម៌ជាគ្រឿងប្រកាសពោធិ-បក្ខិយធម៌ ៣៧ ប្រការ ដោយសង្ខេប ៤ មានឥន្ទ្រិយជាដើម ។ បទថា **ហិតាយ** បានដល់ ដើម្បីជាប្រយោជន៍ ។ បទថា **ធម្មចក្កំ បវត្តេន្តោ** បានដល់ ទ្រង់ឲ្យទេសនាញាណប្រព្រឹត្តទៅ ។

បន្ទាប់អំពីនោះ ក្នុងមហាមណ្ឌលសមាគម ទេវតាក្នុងម៉ឺនចក្កវាឡ និម្មិត

អត្តភាពតូចៗ ប្រជុំគ្នាក្នុងចក្កវាឡនេះឯង ។ បានឮថា ក្នុងមហាមង្គលសមាគមនោះ ទេវបុត្តមួយអង្គ ទូលសួរមង្គលប្បញ្ហានឹងព្រះកោណ្ឌញ្ញទសពល ទើបព្រះមានព្រះភាគត្រាស់មង្គលទាំងឡាយ ប្រោសទេវបុត្រអង្គនោះ ។ ក្នុងមហាមង្គលសមាគមនោះ ទេវតា ៩ ម៉ឺនកោដិសម្រេចអរហត្ត ។ ចំនួនព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើមកំណត់មិនបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

លំដាប់តអំពីនោះ កាលព្រះអង្គទ្រង់សម្តែងធម៌ ក្នុងសមាគម
នៃមនុស្ស និងទេវតា ពួកសត្វ ៩០ ពាន់កោដិ បានសម្រេច
មគ្គផលលើកទី ២ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តតោ បរម្បិ** បានដល់ ក្នុងចំណែកដទៃអំពីនោះទៀត ។ បទថា **ទេសេន្តេ** បានដល់ កាលព្រះមានព្រះភាគទ្រង់សម្តែងធម៌ ។ បទថា **នរមរូនំ** បានដល់ មនុស្សនិង ទេវតាទាំងឡាយ ។ កាលណាព្រះមានព្រះភាគទ្រង់ធ្វើយមកប្បាដិហារ្យ ញ៉ាំញីមានះរបស់តិរ្ថិយ ទ្រង់សម្តែងធម៌ក្នុងនភាកាស កាលនោះ មនុស្ស និងទេវតា ៨ ម៉ឺនកោដិសម្រេចអរហត្ត តាំងនៅក្នុងផល ៣ រាប់មិនបាន ដោយហេតុនោះ ទើបត្រាស់ព្រះមានព្រះភាគថា

កាលព្រះលោកនាយក ទ្រង់សម្តែងធម៌ញ៉ាំញីពួកតិរ្ថិយ ពួក
សត្វ ៨០ ពាន់កោដិបានសម្រេចមគ្គផលលើកទី ៣ ដូច្នេះ ។

គប្បីនាំ **តទា** សព្ទមក ទើបឃើញសេចក្តីក្នុងគាថានោះថា កាលណា

ព្រះមានព្រះភាគទ្រង់សម្តែងធម៌ កាលនោះ ធម្មាភិសម័យ កើតមានដល់សត្វ ៨ ម៉ឺនកោដិ ។

បានឮថា ព្រះកោណ្ឌញ្ញសាស្តាត្រាស់ដឹងនូវអភិសម្ពោធិញ្ញាណហើយ វស្សាដំបូង ទ្រង់អាស្រ័យនគរចន្ទវតី គង់នៅក្នុងវិហារចន្ទារាម ក្នុងទីនោះ ភទ្ទមាណព បុត្តរបស់ព្រាហ្មណមហាសាល ឈ្មោះសុចិន្ទរ និងសុភទ្ទ-មាណព កូនរបស់យសោធរព្រាហ្មណ៍ ស្តាប់ព្រះធម្មទេសនាចំពោះព្រះភក្ត្ររបស់ព្រះកោណ្ឌញ្ញសម្ពុទ្ធហើយ មានចិត្តជ្រះថ្លា ចេញបួសក្នុងសម្នាក់របស់ព្រះអង្គ មួយអន្លើដោយមាណពមួយម៉ឺន សម្រេចអរហត្តហើយ ។

គ្រានោះ ព្រះកោណ្ឌញ្ញសាស្តា កាលភិក្ខុមួយសែនកោដិ មានព្រះសុភទ្ទត្ថេរជាប្រធានចោមរោមហើយ ទ្រង់លើកបាតិមោក្ខឡើងសម្តែង ក្នុងថ្ងៃ ១៥ កើត ខែជេស្ឋ នេះជាការប្រជុំលើកទី ១ ។ បន្ទាប់អំពីនោះ កាលព្រះឱរសរបស់ព្រះកោណ្ឌញ្ញសាស្តា ព្រះនាមវិជិតសេន ទ្រង់សម្រេចអរហត្តព្រះមានព្រះភាគទ្រង់លើកបាតិមោក្ខឡើង សម្តែងក្នុងកណ្តាលភិក្ខុ ១ ពាន់កោដិ មានព្រះវិជិតសេននោះជាប្រធាន នេះជាការប្រជុំលើកទី ២ ។ សម័យតមក ព្រះទសពលយាងចារិកក្នុងជនបទ ទ្រង់ញុំាងព្រះបាទឧទេន ដែលមានជន ៩០ កោដិជាបរិវារ ឲ្យទ្រង់ព្រះផ្នួស មួយអន្លើដោយបរិស័ទ កាលព្រះបាទឧទេននោះទ្រង់សម្រេចអរហត្តហើយ ព្រះមានព្រះភាគ មានព្រះអរហន្ត ៩០ កោដិ មានព្រះបាទឧទេនជាប្រធានចោមរោមហើយ ទ្រង់ក៏សម្តែងបាតិមោក្ខ នេះជាការប្រជុំលើកទី ៣ ដោយហេតុនោះ ទើបព្រះមាន

ព្រះភាគត្រាស់ថា

ព្រះមហេសីកោណ្ឌញ្ញៈ មានសាវកសន្និបាត ៣ លើក គឺ សន្និបាតទី ១ មានព្រះខីណាស្រព ដែលប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ចំនួនមួយសែនកោដិ សន្និបាតទី ២ មានព្រះខីណាស្រពមួយពាន់កោដិ សន្និបាតទី ៣ មានព្រះខីណាស្រព ៩០ កោដិ ដូច្នេះ ។

បានឮថា កាលនោះ ព្រះពោធិសត្វនៃយើង កើតជាស្តេចចក្រពត្តិ ព្រះនាមវិជិតាវី គង់នៅក្នុងនគរចន្ទវតី ។ បានឮថា ព្រះរាជាអង្គនោះ កាលនរជនដ៏ប្រសើរជាច្រើនចោមរោមហើយ ទ្រង់គ្រប់គ្រងផែនដី ដែលជាលំនៅនៃទឹក និងកំណាប់ទ្រព្យ មួយអន្លើដោយស្តេចភ្នំសិនេរុ និងភ្នំយុគន្ធរ ទ្រទ្រង់នូវរតនៈប្រមាណមិនបានដោយធម៌ ទ្រង់មិនប្រើអាជ្ញា មិនប្រើសស្ត្រា ។ សម័យនោះ ព្រះកោណ្ឌញ្ញសម្ពុទ្ធ កាលព្រះខីណាស្រពមួយសែនកោដិចោមរោមហើយ ទ្រង់ចារិកទៅកាន់ជនបទ ដល់ចន្ទវតីនគរដោយលំដាប់ ។

បានឮថា ព្រះបាទវិជិតាវីទ្រង់បានដំណឹងថា ព្រះសម្មាសម្ពុទ្ធយាងដល់នគររបស់យើងហើយ ទើបចេញទៅទទួល រៀបចំទីគង់របស់ព្រះមានព្រះភាគ និមន្តដើម្បីសោយភត្តក្នុងថ្ងៃស្អែក មួយអន្លើដោយភិក្ខុសង្ឃ ។ ស្អែកឡើងទ្រង់ឲ្យគេរៀបចំភត្តយ៉ាងល្អ ហើយបានថ្វាយមហាទានដល់ភិក្ខុសង្ឃមួយសែនកោដិ មានព្រះពុទ្ធជាប្រធាន ព្រះពោធិសត្វទ្រង់ឲ្យព្រះមានព្រះភាគសោយហើយ លុះចប់អនុមោទនា ទ្រង់ទូលអារាធនាថា បពិត្រព្រះអង្គដ៏

ចម្រើន កាលទ្រង់ធ្វើសេចក្តីអនុគ្រោះមហាជន សូមទ្រង់គង់នៅក្នុងនគរនេះឯង អស់កាល ៣ ខែ ។ ព្រះរាជាទ្រង់បានថ្វាយអសទិសទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានជានិច្ច អស់ត្រៃមាស ។

គ្រានោះ ព្រះសាស្តាទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម ក្នុងអនាគតកាល ហើយទ្រង់សម្តែងធម៌ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ ទ្រង់ប្រគល់រាជសម្បត្តិ ទ្រង់ចេញបួស ទ្រង់រៀនព្រះត្រៃបិដក ធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយ មានឈានមិនសាបសូន្យ ទៅកើតក្នុងព្រហ្មលោក ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងសម័យនោះ តថាគតបានកើតជាក្សត្រ មានឈ្មោះថា
វិជិតាវី បានញុំាងឥស្សរិយយសឲ្យប្រព្រឹត្តទៅ រហូតដល់
សមុទ្រជាទីបំផុត ។ តថាគត បាននិមន្តព្រះខីណាស្រពមួយ
សែនកោដិ ដែលប្រាសចាកមន្ទិល ស្វែងរកគុណដ៏ធំ ព្រម
ទាំងព្រះសម្ពុទ្ធ ជាទីពឹងដ៏ប្រសើររបស់សត្វលោក ឲ្យឆាន់
ស្កប់ស្កល់ ដោយម្ហូបចំណីដ៏ថ្លៃថ្លា ។ ព្រះសម្ពុទ្ធ ជាលោក-
នាយក ព្រះនាមកោណ្ឌញ្ញៈអង្គនោះ ទ្រង់ព្យាករតថាគតថា
ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះ បុរសនេះនឹងបាន
ជាព្រះពុទ្ធក្នុងលោក ។ សត្វ ( នេះ ) នឹងចេញអំពីក្រុង
កបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ធ្វើ

ទុក្ករកិរិយា ។ សត្វ ( នេះ ) នឹងអង្គុយទៀបគល់អជបាល-ព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ តអំពីនោះមក សត្វ ( នេះ ) មានយសច្រើន ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ( ដើមពោធិ ) ។ ព្រះមាតាបង្កើតនៃព្រះពុទ្ធនេះ នឹងមានព្រះនាមថាមាយា ព្រះបិតាមានព្រះនាមថាសុទ្ធោទនៈ ឯព្រះពុទ្ធអង្គនេះ មានព្រះនាមថាគោតម ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ មិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកជាឧបដ្ឋាកដ៏ប្រសើរ ឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ។ ឧបាសិកាជាឧបដ្ឋាយិកាដ៏ប្រសើរ ឈ្មោះនន្ទមាតា ១ ឧត្តរា ១ ព្រះគោតមដ៏ទ្រង់យសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។

ពួកមនុស្ស និងទេវតា បានស្តាប់ភាសិតរបស់ព្រះសម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំនេះហើយ ក៏រីករាយថា បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺន មានសំឡេងហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលី នមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនា របស់ព្រះលោកនាថកោណ្ឌញ្ញៈ អង្គនេះ គង់នឹងបានជួបចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្ស កាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា យើងទាំងអស់គ្នា បើលះបង់ព្រះជិនស្រីនេះហើយ គង់នឹងបានជួបចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់នូវព្រះតម្រាស់ របស់ព្រះសម្ពុទ្ធអង្គនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក កាលញុំាំងប្រយោជន៍នោះឲ្យសម្រេច បានថ្វាយរាជសម្បត្តិដ៏ធំ ចំពោះព្រះជិនស្រី លុះថ្វាយរាជសម្បត្តិដ៏ធំហើយ ទើបបួសក្នុងសម្នាក់របស់ព្រះអង្គ ។ តថាគតបានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនាមានអង្គ ៩ ទាំងអស់ ហើយញុំាំងសាសនានៃព្រះជិនស្រីឲ្យរុងរឿង ។ តថាគតមិនប្រមាទ កាលនៅក្នុងទីនោះ បានសម្រេច

អភិញ្ញាបារមីក្នុងទីអង្គុយ និងទីចង្ក្រម ក៏បានទៅកើតក្នុងព្រហ្មលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អហំ តេន សមយេន** បានដល់ តថាគតក្នុងសម័យនោះ ។ បទថា **វិជិតាវី នាម** បានដល់ ជាស្ដេចចក្រពត្តិមានឈ្មោះយ៉ាងនេះ ។ ក្នុងបទថា **សមុទ្ទំ អន្តមន្តេន** នេះ សេចក្ដីថា តថាគតជាធំរហូតដល់ភ្នំកណ្ដាប់ចក្កវាឡ ធ្វើភ្នំកណ្ដាប់ចក្កវាឡជាព្រំដែន ធ្វើនូវសាគរជាទីបំផុត ភាពជាធំមិនមែនប្រាកដដោយហេតុ មានប្រមាណត្រឹមតែប៉ុណ្ណោះឡើយ ។

បានឮថា ដោយអានុភាពនៃចក្ករ័តន៍ ស្ដេចចក្រពត្តិយាងទៅកាន់បុព្វវិទេហទ្វីប ដែលមានទំហំ ៨០០០ យោជន៍ តាមផ្លូវខាងលើសមុទ្រ មានភ្នំសិនេរុនៅខាងឆ្វេង ក្នុងទីនោះ ស្ដេចចក្រពត្តិប្រទានឱវាទថា មិនត្រូវសម្លាប់សត្វ មិនត្រូវលួចទ្រព្យដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវនិយាយកុហក មិនត្រូវផឹកទឹកស្រវឹង ចូរបរិភោគរបស់តាមដែលបរិភោគបាន ។ កាលប្រទានឱវាទយ៉ាងនេះហើយ ចក្ករ័តន៍នោះ ក៏ហោះទៅកាន់អាកាស ចុះកាន់សមុទ្រទិសខាងកើត ទឹកសមុទ្រក៏ញែកដោយប្រការនោះៗ កាលចុះកាន់មហាសមុទ្រ ទឹកក៏ថយទៅមួយយោជន៍តាំងនៅគួរមើលក្រៃលែង ដូចជញ្ជាំងកែវពិទូរ្យ កែវមណី ដោយជុំវិញក្នុងសមុទ្រ ចក្ករ័តន៍នោះទៅ មានសាគរទិសខាងកើតជាទីបំផុតយ៉ាងនោះ ក៏វិលត្រឡប់ ។ កាលចក្ករ័តន៍នោះវិលត្រឡប់ បរិស័ទនោះក៏នៅខាងមុខ ស្ដេច

ចក្រពត្តិនៅត្រង់កណ្តាល ចក្ករ័តន៍នៅខាងក្រោយ ចក្ករ័តន៍នោះប៉ះទឹកត្រឹមតែដុំប៉ុណ្ណោះ វិលទៅលើផ្ទៃទឹក ហើយចូលទៅកាន់ប្រាំង ។

ស្តេចចក្រពត្តិទ្រង់ឈ្នះបុព្វវិទេហទ្វីប ដែលមានសមុទ្រទិសខាងកើតជាទីបំផុតយ៉ាងនេះហើយ មានព្រះរាជបំណងនឹងឈ្នះជម្ពូទ្វីប ដែលមានសមុទ្រទិសខាងត្បូងជាទីបំផុត ទើបបែរមុខទៅទិសខាងត្បូង យាងទៅតាមផ្លូវដែលចក្ករ័តន៍បង្ហាញ ចក្ករ័តន៍នោះកាលឈ្នះជម្ពូទ្វីប ដែលមានទំហំមួយម៉ឺនយោជន៍ហើយ ក៏ឡើងអំពីសមុទ្រទិសទក្សិណដោយន័យដូចពោលខាងដើមនោះឯង ។ ដើម្បីឈ្នះអបរគោយាបទ្វីប ដែលមានទំហំ ៧០០០ យោជន៍ កាលឈ្នះអបរគោយានទ្វីបនោះ ដែលមានសាគរជាទីបំផុតហើយ ក៏ឡើងអំពីសមុទ្រទិសបស្ចិមទៅយ៉ាងនោះដូចគ្នា ដើម្បីឈ្នះឧត្តរកុរុទ្វីប ដែលមានទំហំ ៨០០០ យោជន៍ ក៏ឈ្នះយ៉ាងនោះដូចគ្នា ធ្វើឧត្តរកុរុទ្វីបនោះ មានសមុទ្រជាទីបំផុត ក៏ឡើងពីសមុទ្រទិសខាងជើង ។ កាពជាធំ ឈ្មោះថាស្តេចចក្រពត្តិបានហើយលើផែនដី ដែលមានសាគរជាទីបំផុត ដោយហេតុមានប្រមាណប៉ុណ្ណោះ ដោយហេតុនោះ ទើបត្រាស់ថា តថាគតជាធំលើប្រឹថពី មានមហាសមុទ្រជាទីបំផុត ។

បទថា **កោដិសតសហស្សានំ** បានដល់ ប្រមាណមួយសែនកោដិ ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **វិមលានំ** បានដល់ ព្រះខីណាស្រពទាំងឡាយ ។ បទថា **សហ លោកគ្គនាយេន** សេចក្តីថា សែនកោដិ មួយអន្លើទាំងព្រះទសពល ។ បទថា **បរមន្នេន** បានដល់ ដោយបាយដ៏ប្រណីត ។

បទថា **តប្បយឹ** បានដល់ ឲ្យឆ្អែតហើយ ។ បទថា **អបរិមេយ្យិតោ កប្បេ** សេចក្ដីថា កន្លងទៅ ៣ អសង្ខេយ្យ និង ១ សែនកប្បអំពីកប្បនេះ គឺក្នុងកទ្ទកប្បនេះ ។

បទថា **បធានំ** បានដល់ សេចក្ដីព្យាយាម ។ បទថា **តមេវ អត្ថំ សាធេន្តោ** សេចក្ដីថា បំពេញប្រយោជន៍ គឺទានបារមីដែលធ្វើកាពជាព្រះពុទ្ធនោះឯងឲ្យសម្រេច ឲ្យជាផល ។ បទថា **មហារជ្ជំ** បានដល់ ភាពជាស្ដេចចក្រពត្តិ ។ បទថា **ជិនេ** បានដល់ ក្នុងព្រះមានព្រះភាគ ឬគប្បីឃើញសត្តមីវិភត្តិ ចុះក្នុងអត្ថចតុត្ថីវិភត្តិ ។ បទថា **អទំ** បានដល់ បានឲ្យហើយ ។ គប្បីឃើញការភ្ជាប់សេចក្ដីដោយបទនេះថា **ឯវមត្ថំ សាធេន្តោ** ។ អាចារ្យពួកខ្លះសូធ្យថា **មហារជ្ជំ ជិនេ ទទឹ** ដូច្នេះក៏មាន ។ បទថា **ទទិត្វាន** បានដល់ កាលលះបង់ហើយ ។ បទថា **សុត្តន្តំ** បានដល់ សុត្តន្តបិដក ។ បទថា **វិនយំ** បានដល់ វិនយបិដក ។ បទថា **នវង្គំ** បានដល់ នវង្គសត្ថុសាសនៈ មានសុត្តៈ និងគេយ្យៈជាដើម ។ បទថា **សោភយឹ ជិនសាសនំ** បានដល់ ប្រដាប់ព្រមដោយអាគម ( បរិយត្តិ ) និងអធិគម ( បដិវេធ ) ដែលជាលោកិយ ។ បទថា **តត្ថ** បានដល់ ក្នុងសាសនារបស់ព្រះមានព្រះភាគអង្គនោះ ។ បទថា **អប្បមត្តោ** បានដល់ ដល់ព្រមដោយសតិ ។ បទថា **ព្រហ្មលោកមគញ្ឆហំ** កាត់បទជា **ព្រហ្មលោកំ អគញ្ឆឹ អហំ**។

ព្រះកោណ្ឌញ្ញពុទ្ធអង្គនោះ មាននគរឈ្មោះរម្មវតី ព្រះបិតាព្រះនាមព្រះបាទសុនន្ទៈ ព្រះមាតាព្រះនាមសុជាតាទេវី គូនៃអគ្គសាវកឈ្មោះភទ្ទៈ ១

សុភទ្ទៈ ១ ឧបដ្ឋាកឈ្មោះអនុរុទ្ធ គូនៃអគ្គសាវិកាឈ្មោះតិស្សា ១ ឧបតិស្សា ១ ដើមឈើត្រាស់ដឹងឈ្មោះសាលកល្យាណី គឺដើមក្តៅនាង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះជន្មាយុប្រមាណមួយសែនឆ្នាំ មហេសីព្រះនាមរុចិទេវី មានព្រះឱរសព្រះនាមវិជិតសេន[១] ព្រះរាជាព្រះនាមចន្ទះជាពុទ្ធុបដ្ឋាក ប្រថាប់នៅក្នុងវិហារចន្ទារាម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះរម្មវតី មានព្រះបិតាព្រះនាមសុនន្ទៈ ព្រះមាតាព្រះនាមសុជាតាទេវី ។ ព្រះថេរៈឈ្មោះភទ្ទៈ ១ សុភទ្ទៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះអនុរុទ្ធជាឧបដ្ឋាករបស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកគុណដ៏ធំ ។ ភិក្ខុនីឈ្មោះតិស្សា ១ ឧបតិស្សា ១ ជាអគ្គសាវិកា សាលកល្យាណិព្រឹក្សជាពោធិ៍ របស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះមហាមុនីអង្គនោះ មានកម្ពស់ ៨៨ ហត្ថ ទ្រង់ល្អល្អះដូចព្រះចន្ទ ពុំនោះសោត ដូចព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ ។ ព្រះអង្គមានជន្មាយុមួយសែនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកវាលវដ្តសង្សារ ) ។

ផែនដី ដ៏វិចិត្រដោយព្រះខីណាស្រពទាំងឡាយ ដែលអស់
មន្ទិល ព្រះសម្ពុទ្ធអង្គនោះ ទ្រង់រុងរឿងដូចមេឃ ដែលល្អ
ដោយពួកផ្កាយ ។ ព្រះនាគត្ថេរទាំងអម្បាលនោះ មានគុណ
ប្រមាណមិនបាន មានសន្ដានមិនកម្រើក បុគ្គលចូលទៅរក

---

១- បិដកខ្មែរជា ជីវិតសេន ។

បានដោយកម្រ សម្តែងនូវឫទ្ធិ ដូចការធ្លាក់ចុះនៃផ្លេកបន្ទោរ
ព្រះអរហន្តដ៏មានយសធំទាំងនោះ និព្វានហើយ ។ ចំណែក
ឫទ្ធិរបស់ព្រះជិនស្រីនោះ ជាគុណឥតប្រឹងថ្លែងបាន សមាធិ
មានញាណអប់រំហើយ របស់ទាំងអស់ វិនាសសូន្យទៅ
សង្ខារទាំងពួងជារបស់ទទេពិត ដូច្នេះ ។[១]

បណ្តាបទទាំងនោះ បទថា **សាលកល្យាណិកោ** បានដល់ ដើមសាល-កល្យាណី ដើមសាលកល្យាណីនោះ កើតក្នុងសម័យដែលមានព្រះពុទ្ធ និង ក្នុងសម័យដែលមានស្តេចចក្រពត្តិប៉ុណ្ណោះ មិនកើតក្នុងសម័យដទៃឡើយ ។ បានឮថា ដើមសាលកល្យាណីនោះ ដុះឡើងក្នុងរយៈមួយថ្ងៃប៉ុណ្ណោះ ។ បទថា **វីណាសវេហិ វិមលេហិ វិចិត្តា អាសិ មេទនី** សេចក្តីថា ផែនដីនេះ រុងរឿងដោយសំពត់កាសាវៈ ស្រស់ត្រកាលដោយព្រះខីណាស្រពទាំងឡាយ គួរពិតពិលរមិលមើលក្រៃលែង ។ សព្ទថា **យថា ហិ** ជានិបាត ចុះក្នុងអត្ថ ឧបមា ។ បទថា **ឧឡុភិ** បានដល់ ដោយផ្កាយទាំងឡាយ អធិប្បាយថា ផែនដីនេះលម្អដោយព្រះខីណាស្រពទាំងឡាយ ឈ្មោះថា ស្រស់ត្រកាល ដូចផ្ទៃមេឃ លម្អទៅដោយហ្វូងផ្កាយ ដូច្នោះ ។

បទថា **អសមង្គោញ្ញា** បានដល់ មិនកម្រើក មិនវិការដោយលោកធម៌

---

១- គាថាទាំងនេះ អដ្ឋកថាច្បាប់ឆដ្ឋសង្គាយនា លោកកាត់ឈ្មោះប្រាសាទ ចំនួននារី អគ្គមហេសី និងព្រះរាជបុត្តជាដើមចោលខ្លះ បណ្ឌិតត្រូវការសេចក្តីពិស្តារ សូមមើលក្នុង បិដកខ្មែរចុះ ឯព្រះពុទ្ធអង្គខាងមុខ មានព្រះមង្គលៈជាដើម ក៏ដូចគ្នានេះ ។

៨ ប្រការ ។ បទថា **វិជ្ជុចាតំវ ឥស្សេត្វា** បានដល់ សម្ដែងឫទ្ធិដូចផ្លេកបន្ទោរ បាឋៈថា **វិជ្ជុប្បាតំវ** ដូច្នេះក៏មាន សេចក្ដីពិត ក្នុងសាសនាព្រះកោណ្ឌញ្ញសម្ពុទ្ធ កាលភិក្ខុទាំងឡាយបរិនិព្វាន តែងហោះទៅកាន់អាកាស ៧ ជួរត្នោត រុងរឿង ដោយជុំវិញ ដូចផ្លេកបន្ទោរវាសក្នុងស្រទាប់មេឃពណ៌ខៀវ ចូលតេជោធាតុហើយ ក៏បរិនិព្វាន ដូចភ្លើងអស់នូវកំញម ដោយហេតុនោះ ទើបត្រាស់ថា សម្ដែងនូវឫទ្ធិដូចការធ្លាក់ចុះនៃផ្លេកបន្ទោរ ។ បទថា **អតុលិយា** បានដល់ ថ្លឹងមិនបាន មិនមានអ្វីស្មើ ។ បទថា **ញាណបរិភាវិតោ** បានដល់ ដែលញាណឲ្យចម្រើនហើយ គាថាដ៏សេសមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចបានពោលខាងដើមនោះឯង ។

ព្រះកោណ្ឌញ្ញសម្ពុទ្ធ ព្រះអង្គទ្រទ្រង់សិរី ទ្រង់បរិនិព្វានក្នុងនន្ទារាម
ពួកមហាជនបានបញ្ចុះ ( ព្រះអដ្ឋិ ) របស់ព្រះអង្គនោះ ក្នុង
ចេតិយមានកម្ពស់ ៧ យោជន៍ ក្នុងនន្ទារាមនោះឯង ដូច្នេះ ។

ព្រះធាតុទាំងឡាយរបស់ព្រះសាស្ដាអង្គនោះ មិនបែកខ្ចាត់ខ្ចាយ តាំងនៅជាដុំនោះឯង ដូចបដិមាមាស ។ មនុស្សអ្នកជម្ពូទ្វីបទាំងមូល នាំគ្នាយកថ្មុទន់ពណ៌លឿងជំនួសដី ប្រើប្រេង និងសប្បិជំនួសទឹក សាងចេតិយដែលសម្រេចដោយរតនៈ ៧ ប្រការ កម្ពស់ ៧ យោជន៍ រហូតសម្រេចហើយ ៕

## អដ្ឋកថាអញ្ញាកោណ្ឌញ្ញពុទ្ធវង្សទី ២ ចប់

# សុត្តន្តបិដក

## មង្គលពុទ្ធវង្សទី ៣

[ ៤ ] កាលខាងក្រោយ អំពីព្រះសម្ពុទ្ធកោណ្ឌញ្ញៈមក ព្រះលោកនាយក ព្រះនាមមង្គលៈ ទ្រង់កម្ចាត់បង់ងងឹតក្នុងលោក ព្រះអង្គទ្រទ្រង់នូវគប់ភ្លើង គឺព្រះធម៌ ។ ពន្លឺរបស់ព្រះអង្គឥតប្រៀបបាន ជាពន្លឺលើសលុបជាងព្រះជិនស្រីដទៃ គ្របសង្កត់ពន្លឺព្រះចន្ទនិងព្រះអាទិត្យ រុងរឿងអស់មួយម៉ឺនលោកធាតុ ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ប្រកាសសច្ចៈ ៤ ដ៏ប្រសើរ ពួកសត្វនោះៗ បានផឹករសសច្ចៈហើយ កម្ចាត់ងងឹតធំ គឺមោហៈ ។ ព្រះសម្ពុទ្ធអង្គនោះ បានដល់នូវពោធិញ្ញាណ ជាគុណឥតប្រៀបបាន កាលសម្តែងធម៌ជាដំបូង ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផលលើកទី ១ ។ ព្រះសម្ពុទ្ធទ្រង់សម្តែងធម៌ ក្នុងសុរិន្ទទេវភព កាលនោះ ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផលលើកទី ២ ។ កាលព្រះបាទសុនន្ទចក្រពត្តិ ទ្រង់ចូលទៅគាល់ព្រះសម្ពុទ្ធ កាលនោះ ព្រះសម្ពុទ្ធ ទ្រង់វាយស្គរ គឺព្រះធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ ។ កាលនោះ ពួកជនដែលតាមហែព្រះបាទសុនន្ទៈ មានចំនួន ៩០ កោដិ ជនទាំងអស់នោះ បានជាឯហិភិក្ខុឥតសេសសល់ ( លើកទី ៣ ) ព្រះមង្គលសម្ពុទ្ធ ព្រះអង្គស្វែងរកគុណដ៏ធំ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានព្រះខីណាស្រព មួយសែនកោដិ សន្និបាតលើកទី ២ មានព្រះខីណាស្រព មួយសែនកោដិ

សន្និបាតលើកទី ៣ មានព្រះខីណាស្រព ៩០ កោដិ ។ សមាគម ក្នុងកាលនោះ សុទ្ធតែព្រះខីណាស្រព ប្រាសចាកមន្ទិល សម័យ នោះ តថាគតជាព្រាហ្មណ៍ ឈ្មោះសុរុចិ ។ តថាគតអ្នករៀនមន្ត ចងចាំមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ចូលទៅគាល់ព្រះសម្ពុទ្ធ អង្គនោះ ហើយបានដល់ព្រះសាស្ដាជាទីពឹង ។ តថាគតបានបូជា ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយគ្រឿងក្រអូប និងផ្កា កម្រង លុះបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងហើយ ក៏ញុំាង ព្រះភិក្ខុសង្ឃឲ្យឆាន់ស្កប់ស្កល់ ដោយទឹកដោះគោ ។ ព្រះសម្ពុទ្ធ ព្រះនាមមង្គលៈនោះ ព្រះអង្គឧត្តមជាសត្វទ្វេបាទ ទ្រង់ទំនាយ តថាគតថា ក្នុងរវាងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ បុរសនោះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុង កបិលពស្ដុ ជាទីរីករាយ តាំងសេចក្ដីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វ ( នេះ ) នឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួល បាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះ ជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេ ចាត់ចែង ។ លំដាប់អំពីនោះទៅ ព្រះជិនស្រី មានយសច្រើន នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើត របស់ព្រះពុទ្ធអង្គនេះ

នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមថាសុទ្ធោទនៈ ឯបុរសនេះជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទនឹងបានជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គ-សាវិកា ។ ឈើសម្រាប់ត្រាស់ដឹងរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ( ដើមពោធិ ) ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទ-មាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានឮព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធមិនមានបុគ្គលស្មើស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុមានសំឡេងហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលី នមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនារបស់ព្រះលោកនាថនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង

បើឃ្វាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លង ស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្វាងព្រះជិនស្រីអង្គ នេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុង កាលជាអនាគតមិនខានយ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះ តម្រាស់របស់ព្រះពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក បាន អធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។ ក្នុងកាល នោះ តថាគតចម្រើនបីតិ ថ្វាយផ្ទះរបស់តថាគតចំពោះព្រះពុទ្ធ ហើយបួសក្នុងសម្នាក់ព្រះអង្គ ដើម្បីសម្រេចពោធិញ្ញាណដ៏ ប្រសើរ ។ តថាគតបានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុ-សាសនាមានអង្គ ៩ ទាំងអស់ ហើយញុំាងសាសនានៃព្រះជិនស្រី ឲ្យល្អរុងរឿង ។ តថាគតមិនប្រមាទ កាលនៅក្នុងទីនោះ ចម្រើន ព្រហ្មវិហារ បានសម្រេចអភិញ្ញាបារមី ហើយក៏បានទៅកើតក្នុង ព្រហ្មលោក ។ ព្រះមង្គលសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណធំ មាន នគរឈ្មោះឧត្តរៈ មហាក្សត្រព្រះនាមឧត្តរៈជាព្រះបិតា ព្រះមាតា ព្រះនាមឧត្តរា ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងរាជដំណាក់ អស់ ៩ ពាន់ឆ្នាំ មានប្រាសាទ ៣ ដ៏ល្អឧត្តម គឺយសវប្រាសាទ ១ សុចិមប្រាសាទ ១ សិរិមប្រាសាទ ១ មានពួកនារី ៣ ម៉ឺន នាក់ មានខ្លួនប្រដាប់សមរម្យ នារីជាភរិយាឈ្មោះយសវតី មាន ព្រះរាជបុត្រឈ្មោះសីវលៈ ។ ព្រះជិនស្រី ទ្រង់ឃើញនិមិត្ត ៤

ហើយទ្រង់ចេញទៅដោយយានសេះ តាំងសេចក្តីព្យាយាមអស់ ៨ ខែឥតខ្វះ ។ ព្រះលោកនាយក ព្រះនាមមង្គលៈមានព្រះទ័យស្ងប់រម្ងាប់ ទ្រង់មានចក្កប្រព្រឹត្តទៅ មានព្យាយាម ទ្រង់ប្រសើរជាងសត្វទ្វេបាទ ត្រូវមហាព្រហ្មអារាធនាហើយ ទើបស្តេចត្រាច់ទៅ គឺសម្តែងធម៌ ។ ព្រះថេរៈឈ្មោះសុទេវៈ ១ ធម្មសេនៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះបាលិតៈជាឧបដ្ឋាក របស់ព្រះមង្គលសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះសីវលា ១ អសោកា ១ ជាអគ្គសាវិកា ដើមឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគអង្គនោះ ហៅថា នាគព្រឹក្ស ( ដើមខ្ទឹង ) ។ ឧបាសកឈ្មោះនន្ទៈ ១ វិសាខៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះអនុឡា ១ សុមនា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនី ទ្រង់មានកម្ពស់ ៨៨ ហត្ថ រស្មីច្រើនសែន ផ្សាយចេញអំពីកាយព្រះអង្គ ។ ព្រះជន្មាយុរបស់ព្រះអង្គ ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ស្ថិតនៅជរាបនោះ ញ៉ាំងពួកជនច្រើន ឲ្យឆ្លង ( វដ្ដសង្សារ ) ។ រលកក្នុងសាគរ គេមិនអាចរាប់បានយ៉ាងណាមិញ សាវកទាំងឡាយរបស់ព្រះអង្គ ក៏គេមិនអាចរាប់បានយ៉ាងនោះដែរ ។ ព្រះមង្គលសម្ពុទ្ធ ជាលោកនាយក ទ្រង់បានស្ថិតនៅជរាបណា មរណៈប្រកបដោយកិលេស មិនមានក្នុងសាសនានៃព្រះអង្គ ជរាបនោះ ។ ព្រះសម្ពុទ្ធទ្រង់មានយសច្រើនអង្គនោះ ទ្រទ្រង់

នូវគប់ភ្លើង គឺព្រះធម៌ ហើយញ៉ាំងមហាជនឲ្យឆ្លង ដ៏រុងរឿងដូចជាផ្កាយដុះកន្ទុយ ទ្រង់បរិនិព្វាន ។ ព្រះសម្ពុទ្ធទ្រង់សម្ដែងនូវសភាពប្រែប្រួលនៃសង្ខារ ដល់ពួកមនុស្ស ព្រមទាំងទេវតា រុងរឿងដូចគំនរភ្លើង ពុំនោះសោត ដូចព្រះអាទិត្យដែលទើបនឹងអស្ដង្គត ។ ព្រះមង្គលសម្ពុទ្ធ ទ្រង់បរិនិព្វានក្នុងឧទ្យាន ឈ្មោះវេស្សរៈ ព្រះស្ដូបរបស់ព្រះជិនស្រីអង្គនោះ មានកម្ពស់ ៣០ យោជន៍ មាននៅក្នុងទីនោះឯង ។

## មង្គលពុទ្ធវង្សទី ៣ ចប់

# អដ្ឋកថា

## មង្គលពុទ្ធវង្សទី ៣

បានឮថា កាលព្រះកោណ្ឌញ្ញសាស្ដារម្ងត់ខន្ធបរិនិព្វានទៅហើយ ព្រះសាសនារបស់ព្រះអង្គតាំងនៅមួយសែនឆ្នាំ ព្រោះព្រះសាវករបស់ព្រះពុទ្ធនិងអនុពុទ្ធអន្តរធាន សាសនាព្រះអង្គក៏អន្តរធាន ។ បន្ទាប់អំពីសម័យរបស់ព្រះកោណ្ឌញ្ញសម្ពុទ្ធកន្លងទៅមួយអសង្ខេយ្យ ក្នុងកប្បតែមួយនោះឯង មានព្រះពុទ្ធ ៤ អង្គ គឺព្រះមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតៈ ។ ក្នុង ៤ អង្គនោះ ព្រះមង្គលសម្ពុទ្ធ ជាលោកនាយក ទ្រង់បំពេញបារមី ១៦ អសង្ខេយ្យ និង ១ សែនកប្ប កើតក្នុងស្ថានសួគ៌ជាន់តុសិត ទ្រង់តម្កល់អាយុក្នុងស្ថានសួគ៌នោះ កាលបុព្វនិមិត្ត ៥ ប្រការ កើតឡើងហើយ ពុទ្ធ-កោលាហលក៏កើតឡើង កាលនោះ ទេវតាក្នុងម៉ឺនចក្កវាឡ ក៏ប្រជុំគ្នាក្នុងចក្កវាឡនោះ នាំគ្នាអារាធនាថា

បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ គួរដល់ព្រះអង្គហើយ
សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្សលោក
ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះ
អមតៈ ដូច្នេះ ។

ទ្រង់ត្រូវទេវតាទាំងឡាយ អារាធនាយ៉ាងនេះហើយ ទ្រង់ពិចារណានូវវិលោកនៈ ៥ ប្រការ ក៏ចុតិចាកស្ថានសួគ៌ជាន់តុសិត បដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងឧត្តរាទេវី ក្នុងរាជត្រកូលរបស់ព្រះបាទឧត្តរៈ ក្នុងឧត្តរនគរ ដែលជានគរឧត្តមជាងនគរទាំងឡាយ ។ កាលនោះ បាដិហារ្យបានប្រាកដជាច្រើន

បាដិហារ្យទាំងនោះ គប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងវង្ស
ព្រះទីបង្ករនោះឯង ។

តាំងអំពីព្រះមង្គលមហាសត្វ ជាមង្គលរបស់សត្វលោកទាំងពួង ទ្រង់
បដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងឧត្តរាមហាទេវីអង្គនោះ រស្មីនៃសរីរៈក៏ផ្សាយទៅ
អស់ទីប្រមាណ ៨០ ហត្ថ ទាំងពេលយប់ និងពេលថ្ងៃ គ្របះគ្របង់ជាង
ពន្លឺព្រះចន្ទ និងព្រះអាទិត្យ រស្មីនោះកម្ចាត់នូវងងឹតបានដោយការកើតឡើង
នៃព្រះរស្មីសរីរៈរបស់ព្រះនាងប៉ុណ្ណោះ មិនចាំបាច់ប្រើពន្លឺដទៃ ភីលៀង
ប្រមាណ ៦៨ នាក់ ចាំប្រតិបត្តិហើយ ។

បានឮថា ព្រះនាងឧត្តរាទេវីនោះ មានទេវតាថែរក្សា គ្រប់ទសមាស
ក៏ប្រសូតព្រះមង្គលមហាបុរស ក្នុងមង្គលរាជឧទ្យាន ឈ្មោះឧត្តរមធុរឧទ្យាន
ដែលមានផ្កាក្រអូបឈ្ងុយឈ្ងប់ ដើមឈើមានផ្លែ មែក និងប្រគាប ប្រដាប់
ដោយផ្កាឈូកដើម និងឈូកវល្លិ មានក្ងាន់ រាជសីហ៍ ខ្លា ដំរី គោព្រៃ
ក្របី ប្រើស និងហ្វូងម្រឹគច្រើនប្រភេទត្រាច់ទៅ គួរជាទីត្រេកអរក្រៃលែង
ព្រះមហាសត្វអង្គនោះ គ្រាន់តែប្រសូតប៉ុណ្ណោះ ទ្រង់ក៏សម្លឹងមើលទិស បែរ
ព្រះភក្ត្រទៅទិសឧត្តរ ទ្រង់ឈានព្រះបាទ ៧ ជំហាន បន្លឺអាសភិវាចា ។
ខណៈនោះ ទេវតាក្នុងម៉ឺនលោកធាតុក៏ប្រាកដកាយ ប្រដាប់ខ្លួនដោយទិព្វ-
មាល័យជាដើម ឈរក្នុងទីនោះ ថ្វាយសាធុការជ័យមង្គល ។ បាដិហារ្យ
ទាំងឡាយ មានន័យដូចពោលហើយនោះឯង ។ ក្នុងថ្ងៃថ្វាយព្រះនាមមហា
បុរសនោះ ហោរាទាយលក្ខណៈ ថ្វាយព្រះនាមថា មង្គលកុមារ ព្រោះ

ប្រសូត ដោយមង្គលសម្បត្តិសព្វយ៉ាង ។

បានឮថា ព្រះមហាបុរសនោះមានប្រាសាទ ៣ គឺយសវា ១ រុចិមា ១[១] សិរិមា ១ ស្រ្តីអ្នកបម្រើប្រមាណ ៣ ម៉ឺន មាននាងយសវតីជាប្រធាន ។ ក្នុងប្រាសាទនោះ ព្រះមហាសត្វសោយសុខដូចទិព្វសុខ ៩ ពាន់ឆ្នាំ ទ្រង់បានព្រះឱរសព្រះនាមសីលវៈ[២] ក្នុងផ្ទៃរបស់ព្រះនាងយសវតីអគ្គមហេសី ទ្រង់ឃើញនិមិត្ត ៤ ប្រការ ទ្រង់ឡើងផែលសេះដ៏ល្អ ឈ្មោះបណ្ឌរៈ ដែលប្រដាប់តាក់តែងហើយ ។ ទ្រង់ចេញមហាភិនេស្រ្កមណ៍ បួសហើយ ។ មនុស្ស ៣ កោដិ ក៏នាំគ្នាបួសតាមព្រះមហាសត្វ ដែលទ្រង់ផ្នួសអង្គនោះ ។ ព្រះមហាបុរស កាលកិច្ចទាំងនោះចោមរោមហើយ ទ្រង់បំពេញសេចក្តីព្យាយាមអស់ ៨ ខែ ។

បន្ទាប់អំពីនោះ ក៏សោយមធុបាយាស មានឱជទិព្វ ដែលទេវតាដាក់ចូលទៅ ដែលនាងឧត្តរាធីតារបស់ឧត្តរសេដ្ឋី ក្នុងស្រុកឧត្តរគាមថ្វាយហើយ ទ្រង់សម្រាកពេលថ្ងៃក្នុងព្រៃសាលវ័ន ដែលប្រដាប់ដោយផ្កាក្រអូប មានពន្លឺពណ៌ខៀវ គួរជាទីត្រេកអរ ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលឧត្តរអាជីវកថ្វាយ ចូលទៅកាន់ដើមឈើជាទីត្រាស់ដឹង ឈ្មោះនាគៈ គឺដើមខ្លឹង ដែលមានម្លប់ត្រឈឹងត្រឈៃ ដូចគ្នានឹងអញ្ជនគិរី ពណ៌ខៀវចាស់ ដូចមានកំពូល មានបណ្តាញមាសគ្របដណ្តប់ វៀរចាកការប្រជុំរបស់ពួកម្រឹគច្រើនអម្បូរ ប្រដាប់ដោយមែក និងស្លឹកដ៏ក្រាស់ ដែលត្រូវខ្យល់ត្រសៀកៗ បក់បោករេរាំ

---

១- បិដកខ្មែរ ជាសុចិមា ។ ២- បិដកខ្មែរ ជាសីវលៈ ។

រុងរឿងដោយបីតិ ដូចអ្នករបាំ ដើមនាគពោធិព្រឹក្សនោះ គួរសរសើរ ទ្រង់ធ្វើប្រទក្សិណដើមនាគពោធិព្រឹក្ស ប្រថាប់ឈរក្នុងទិសឦសាន ទ្រង់លាតសន្ថតស្មៅទំហំ ៥៨ ហត្ថ ប្រថាប់គង់ពត់ភ្នែនលើសន្ថតស្មៅនោះ ទ្រង់អធិដ្ឋានសេចក្តីព្យាយាមដែលប្រកបដោយអង្គ ៤ ទ្រង់កម្ចាត់កម្លាំងនៃមារព្រមទាំងសេហ៍ពល ទ្រង់បានបុព្វេនិវាសញ្ញាណនិងទិព្វចក្ខុញ្ញាណ ទ្រង់ធ្វើការពិចារណាបច្ចយាការ ឈមចុះដោយអំណាចអនិច្ចលក្ខណៈជាដើម ក្នុងខន្ធទាំងឡាយ ទ្រង់សម្រេចអនុត្តរសម្មាសម្ពោធិញ្ញាណដោយលំដាប់ បន្លឺឧទាន ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា។**

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ រវល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្តមានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។ នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់

ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

រស្មីព្រះសរីរៈរបស់ព្រះមង្គលសម្ពុទ្ធ ក្រៃលែងជាងព្រះពុទ្ធអង្គដទៃៗទាំងអស់ រស្មីនៃព្រះសរីរៈរបស់ព្រះអង្គ មិនដូចរស្មីព្រះសម្មាសម្ពុទ្ធអង្គដទៃៗ ដែលមានរស្មីព្រះសរីរៈប្រមាណ ៨០ ហត្ថខ្វះ មួយព្យាមខ្វះដោយជុំវិញ ឯរស្មីនៃព្រះសរីរៈរបស់ព្រះមង្គលសម្ពុទ្ធអង្គនោះ ផ្សាយទៅអស់ម៉ឺនលោកធាតុជានិច្ចកាល ដើមឈើ ភ្នំ ផ្ទះ កំពែង ក្អមទឹក សន្ទះទ្វារជាដើម ដូចស្រោបដោយបន្ទះមាស ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។ រស្មីរបស់ព្រះចន្ទ ព្រះអាទិត្យ និងផ្កាយជាដើម មិនប្រាកដអស់កាលមានប្រមាណប៉ុណ្ណោះ ការកំណត់ពេលយប់ ពេលថ្ងៃ មិនប្រាកដ សត្វទាំងឡាយធ្វើការងារគ្រប់យ៉ាងដោយពន្លឺរបស់ព្រះសម្ពុទ្ធប៉ុណ្ណោះ ដូចធ្វើការងារដោយពន្លឺព្រះអាទិត្យ ក្នុងពេលថ្ងៃ លោកកំណត់ពេលយប់ និងពេលថ្ងៃ ដោយផ្ការីកក្នុងពេលល្ងាច និងបក្សីយំក្នុងពេលព្រឹក ។

សួរថា អានុភាពនេះរបស់ព្រះពុទ្ធអង្គដទៃៗ មិនមានឬ ឆ្លើយថា មិនមានក៏មិនមែន សេចក្តីពិត ព្រះពុទ្ធទាំងនោះ បើទ្រង់បំណង ទ្រង់ក៏ផ្សាយរស្មីទៅរហូតម៉ឺនលោកធាតុ ឬក្រៃលែងជាងនោះ តែរស្មីនៃព្រះសរីរៈរបស់ព្រះមានព្រះភាគមង្គលៈ ផ្សាយទៅមួយម៉ឺនលោកធាតុជានិច្ចកាល ដូចរស្មីមួយ

ព្យាមរបស់ព្រះពុទ្ធអង្គដទៃៗ ដោយអំណាចសេចក្តីប្រាថ្នាអំពីខាងដើម ។ បានឮថា កាលព្រះពោធិសត្វមង្គលសម្ពុទ្ធអង្គនោះ ទ្រង់មានព្រះឱរស និងព្រះជាយា ក្នុងអត្តភាពដូចគ្នានឹងព្រះវេស្សន្តរ ទ្រង់នៅត្រង់ភ្នំ ដូចគ្នានឹងភ្នំវង្កត ។ កាលនោះ យក្ខឈ្មោះថា ខរទាឋិកៈ មានសក្តិធំមួយ បរិភោគមនុស្សជាអាហារ ចូលចិត្តបៀតបៀនមនុស្សគ្រប់គ្នា បានដំណឹងថា ព្រះមហាបុរសចូលចិត្តឲ្យទាន ទើបកាឡាខ្លួនជាព្រាហ្មណ៍ចូលទៅរក ទូលសូមទារកទាំង ២ នឹងព្រះមហាសត្វ ។ ព្រះមហាសត្វ ទ្រង់ត្រេកអរថា អញនឹងឲ្យកូនតូចទាំង ២ ដល់ព្រាហ្មណ៍ ទ្រង់បានប្រទានរាជបុត្តទាំងទ្វេហើយ ធ្វើផែនដីឲ្យកម្រើក រហូតដល់ទឹកទ្រផែនដី ។ ខណៈនោះ ទាំងព្រះមហាសត្វកំពុងឃើញ យក្ខលះភេទជាព្រាហ្មណ៍ មានភ្នែកក្រឡោតក្រឡាប់ ក្រហមដូចអណ្តាតភ្លើង មានចង្កូមប្រឯងមិនស្មើគ្នា គួរខ្ពើម និងគួរខ្លាច មានច្រមុះបើប មានសក់ក្រហមកន្ទ្រើង មានសរីរៈដូចដើមត្នោត ដែលត្រូវភ្លើងឆេះចាប់ទារកទាំង ២ ទំពាស៊ីដូចក្រអៅឈូក ព្រះមហាបុរសសម្លឹងមើលយក្ខគ្រាន់តែយក្ខហាមាត់ ក៏ឃើញមាត់យក្ខនោះ មានតំណក់ឈាមហូរចេញក្រហមដូចអណ្តាតភ្លើង ក៏មិនកើតទោមនស្ស សូម្បីប៉ុនចុងសក់ គិតថា **សុទិន្នំ វត មេ ទានំ** ទានអញឲ្យល្អហើយ បីតិ និងសោមនស្សជាច្រើនកើតក្នុងសរីរៈ ។ ព្រះមហាសត្វទ្រង់ធ្វើសេចក្តីប្រាថ្នាថា ដោយផលនៃទានរបស់អញនេះ ក្នុងអនាគតកាល រស្មីទាំងឡាយ ចូរផ្សាយចេញដោយទំនងនេះ កាលទ្រង់អាស្រ័យសេចក្តីប្រាថ្នាជាព្រះពុទ្ធហើយ រស្មីទាំងឡាយ ក៏

ផ្សាយចេញអំពីសរីរៈអស់ទីប្រមាណប៉ុណ្ណោះ ។

បុព្វចរិយាជនៃទេរបស់ព្រះមានព្រះភាគអង្គនេះ នៅមានទៀត បានឮថា កាលនៅជាព្រះពោធិសត្វ ព្រះមង្គលសម្ពុទ្ធអង្គនេះ ឃើញចេតិយរបស់ព្រះសម្មាសម្ពុទ្ធមួយអង្គ គិតថា អញគួរលះបង់ជីវិតដើម្បីព្រះពុទ្ធអង្គនេះ ឲ្យគេរុំសរីរៈដូចប្រទីប ឲ្យដាក់ថាសមាសដែលមានតម្លៃមួយសែន មានបាច់ផ្កាក្រពុំប្រមាណមួយហត្ថ ពេញដោយគ្រឿងក្រអូប និងសប្បិ ដាក់ប្រទេះក្នុងថាសនោះ ប្រើសីសៈទូលថាសនោះ ហើយដុតភ្លើងត្រង់ខ្លួន ធ្វើប្រទក្សិណចេតិយរបស់ព្រះជិនស្រី ឲ្យពេលវេលាកន្លងទៅអស់មួយយប់ កាលព្រះពោធិសត្វព្យាយាមរហូតទល់ភ្លឺយ៉ាងនេះ កម្តៅមិនពាល់ត្រូវសូម្បីរន្ធរោម ដូចចូលទៅកាន់ស្រទាប់នៃផ្កាឈូក ពិតហើយ ធម៌រមែងរក្សាបុគ្គលអ្នករក្សាធម៌ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ ធម្មោ សុចិណ្ណោ សុខមាវហាតិ**
**ឯសានិសំសោ ធម្មេ សុចិណ្ណេ ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។**

ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ដូច្នេះ ។

ដោយផលនៃកម្មនេះ ទើបរស្មីនៃសរីរៈរបស់ព្រះអង្គ ផ្សាយទៅរហូត

ម៉ឺនលោកធាតុ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលខាងក្រោយ អំពីព្រះសម្ពុទ្ធកោណ្ឌញ្ញៈមក ព្រះលោក-
នាយក ព្រះនាមមង្គលៈ ទ្រង់កម្ចាត់បង់ងងឹត ក្នុងលោក
ព្រះអង្គទ្រទ្រង់នូវគប់ភ្លើង គឺព្រះធម៌ ។ ពន្លឺរបស់
ព្រះអង្គឥតប្រៀបបាន ជាពន្លឺលើសលុបជាង ព្រះជិនស្រីដទៃ
គ្របសង្កត់ពន្លឺព្រះចន្ទនិង ព្រះអាទិត្យរុងរឿងអស់មួយម៉ឺន
លោកធាតុ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តមំ** បានដល់ ងងឹតក្នុងលោក និងងងឹតក្នុងហទយៈ ។ បទថា **និហន្ត្វាន** បានដល់ គ្របសង្កត់ ។ ក្នុងបទថា **ឧម្មោក្កំ** នេះ **ឧក្កា** សព្ទនេះ ប្រើក្នុងអត្ថជាច្រើន មានស្នប់របស់ជាងមាសជាដើម ។

ពិតហើយ ស្នប់របស់ជាងមាសទាំងឡាយ គប្បីជ្រាបថា ឈ្មោះថា **ឧក្កា** ក្នុងអាគតដ្ឋានថា **សណ្ឌាសេន ជាតរូបំ គហេត្វា ឧក្កាមុខេ បក្ខិ-បេយ្យ** គប្បីយកដង្កាប់ចាប់មាសដាក់ទៅក្នុងមាត់នៃចង្ក្រានស្នប់ ដូច្នេះ ។

ភាជន៍ដាក់រងើកភ្លើង របស់ជាងមាសទាំងឡាយ គប្បីជ្រាបថា **ឧក្កា** ដូចក្នុងអាគតដ្ឋានថា **ឧក្កំ ពន្ធេយ្យ ឧក្កំ ពន្ធិត្វា ឧក្កាមុខំ អាលិម្បេយ្យ** គប្បីរៀបចំនូវចង្ក្រានស្នប់ លុះរៀបចំនូវចង្ក្រានស្នប់រួចហើយ គប្បីដុតនូវមាត់នៃចង្ក្រានស្នប់ ដូច្នេះ ។

ចង្ក្រានរបស់ជាងមាស គប្បីជ្រាបថា **ឧក្កា** ដូចក្នុងអាគតដ្ឋានថា

**កម្មារានំ យថា ឧក្កា អន្តោ ឈាយតិ នោ ពហិ** ចង្ក្រានរបស់ជាងមាស ឆេះតែខាងក្នុង មិនឆេះខាងក្រៅ ដូច្នេះ ។

ភាពរបហ័សនៃព្យុះ គប្បីជ្រាបថា **ឧក្កា** ដូចក្នុងអាគតដ្ឋានថា **ឯវំ-ចាតោ ឧក្កាចាតោ ភវិស្សតិ** ឧក្កាបាតនឹងបណ្តាលឲ្យមានទុក្ខ សុខ យ៉ាងនេះ ដូច្នេះ ។ គប់ភ្លើង ហៅថា **ឧក្កា** ក្នុងអាគតដ្ឋានថា **ឧក្កាសុ ធារិយមានាសុ** កាន់គប់ភ្លើង ដូច្នេះ ។ ក្នុងទីនេះ គប់ភ្លើង លោកបំណង យកថាជា **ឧក្កា** ព្រោះហេតុនោះ ទើបក្នុងទីនេះ សេចក្តីថា ទ្រង់ធ្វូលនូវគប់ភ្លើងដែលសម្រេចដោយធម៌ ទ្រង់ធ្វូលគប់ភ្លើង ដែលសម្រេចដោយធម៌ ដល់សត្វលោក ដែលត្រូវងងឹត គឺអវិជ្ជាបិទបាំង ដែលងងឹត គឺអវិជ្ជាគ្រប សង្កត់ ។

បទថា **អតុលាសិ** បានដល់ មិនមានរស្មីដទៃប្រៀបបាន ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ សេចក្តីថា មានព្រះរស្មីដែលព្រះពុទ្ធអង្គដទៃៗ ប្រៀបផ្ទឹមមិនបាន ។ បទថា **ជិនេហាញ្ញេហិ** កាត់បទជា **ជិនេហិ អញ្ញេហិ** ។ បទថា **ចន្ទសុរិយប្បភំ ហន្ត្វា** បានដល់ កម្ចាត់នូវរស្មីរបស់ព្រះចន្ទ និងព្រះអាទិត្យ ។ បទថា **ឧសសហស្សី វិរោចតិ** សេចក្តីថា រឿងនូវពន្លឺរបស់ព្រះចន្ទ និងព្រះអាទិត្យម៉ឺនលោកធាតុ រមែងភ្លឺដោយពន្លឺរបស់ព្រះពុទ្ធប៉ុណ្ណោះ ។

ព្រះមង្គលសម្មាសម្ពុទ្ធ ទ្រង់សម្រេចពោធិញ្ញាណហើយ ទ្រង់នៅសម្ងំត្រង់មណ្ឌលពោធិព្រឹក្ស ៧ សប្តាហ៍ ទ្រង់ទទួលពាក្យអារាធនាសូមឲ្យសម្តែងធម៌របស់ព្រហ្ម ទ្រង់ពិចារណាថា តថាគតនឹងសម្តែងធម៌នេះដល់អ្នកណាហ្ន៎

ក៏ទ្រង់ឃើញថា ភិក្ខុ ៣ កោដិដែលបួសជាមួយទ្រង់ ដល់ព្រមដោយឧប-និស្ស័យ គ្រានោះ ទ្រង់ព្រះតម្រិះថា កុលបុត្តទាំងនេះ បួសតាមតថាគត ដែលកំពុងបួស ដល់ព្រមដោយឧបនិស្ស័យ ជនទាំងនេះ ត្រូវតថាគតដែល ត្រូវការវិវេកលះបង់ ក្នុងថ្ងៃ ១៥ កើត ខែវិសាខ ជនទាំងនោះ ទៅ អាស្រ័យសិរិវឌ្ឍនគរ ស្នាក់នៅត្រង់ជដសិរិវ័ន ណ្ហើយចុះ តថាគតនឹង ទៅសម្តែងធម៌ដល់ជនទាំងនោះ ក្នុងទីនោះ ហើយទ្រង់កាន់បាត្រ ចីវររបស់ ព្រះអង្គ ហោះទៅកាន់អាកាស ដូចស្តេចហង្ស ប្រាកដព្រះកាយត្រង់ជដ-សិរិវ័ន ភិក្ខុទាំងនោះថ្វាយបង្គំព្រះមានព្រះភាគ ធ្វើនូវអន្តេវាសិកវត្ត ហើយ អង្គុយចោមរោមព្រះមានព្រះភាគៗ ត្រាស់ធម្មចក្កប្បវត្តនសូត្រ ដែលព្រះពុទ្ធ គ្រប់អង្គទ្រង់បដិបត្តិមកហើយ ដល់ភិក្ខុទាំងនោះ ។ បន្ទាប់ពីនោះ ភិក្ខុ ៣ កោដិ ក៏សម្រេចនូវអរហត្ត ធម្មាភិសម័យ គឺការត្រាស់ដឹងធម៌ មានដល់ ទេវតា និងមនុស្សមួយសែនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា

ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ប្រកាសសច្ចៈ ៤ ដ៏ប្រសើរ ពួកសត្វ
នោះៗ បានផឹករសសច្ចៈ ហើយកម្ចាត់ងងឹតធំ គឺមោហៈ ។
ព្រះសម្ពុទ្ធអង្គនោះ បានដល់នូវពោធិញ្ញាណ ជាគុណឥតប្រៀប
បាន កាលសម្តែងធម៌ជាដំបូង ពួកសត្វមួយសែនកោដិ បាន
សម្រេចមគ្គផលលើកទី ១ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុរោ** កែជា **ចត្តារិ** ។ បទថា **សច្ចវរុត្តមេ**

សេចក្តីថា ពិតផង ប្រសើរផង ឈ្មោះថា សច្ចៈដ៏ប្រសើរ អធិប្បាយថា សច្ចៈដ៏ឧត្តម ។ បាឋៈថា **ចត្តារោ សច្ចវរុត្តមេ** ដូច្នេះក៏មាន សេចក្តីថា សច្ចៈដ៏ប្រសើរឧត្តមទាំង ៤ ។ បទថា **តេ តេ** បានដល់ ទេវតា និងមនុស្ស នោះ ដែលព្រះសម្ពុទ្ធទ្រង់ទូន្មានហើយ ។ បទថា **សច្ចរសំ** បានដល់ ផឹកនូវ អមតៈ គឺការចាក់ធ្លុះសច្ចៈ ៤ ។ បទថា **វិនោទេន្តិ មហាតមំ** សេចក្តីថា បន្ទោបង់ គឺកម្ចាត់នូវងងឹត គឺមោហៈ ដែលគប្បីលះដោយមគ្គនោះៗ ។ បទ ថា **បត្វាន** បានដល់ ទ្រង់ចាក់ធ្លុះ ។ **ពោធិ** សព្ទ ក្នុងបទថា **ពោធឹ** នេះ មកក្នុងអត្ថដូចតទៅនេះថា

មគ្គ ផល និព្វាន ដើមឈើ បញ្ញត្តិ និងសព្វញ្ញុតញ្ញាណ ។

ពិតហើយ **ពោធិ** សព្ទ មកក្នុងអត្ថថា **មគ្គ** ដូចក្នុងប្រយោគជាដើម ថា **ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ** សម្មាទិដ្ឋិ ( ញាណ ) ក្នុងមគ្គ ៤ លោកហៅថា **ពោធិ** ដូច្នេះ ។

មកក្នុងអត្ថថា **ផល** ដូចក្នុងប្រយោគជាដើមថា **ឧបសមាយ អភិញ្ញាយ សម្ពោធាយ សំវត្តតិ** ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បី សេចក្តីដឹងច្បាស់ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ដូច្នេះ ។

មកក្នុងអត្ថថា **និព្វាន** ដូចក្នុងប្រយោគជាដើមថា **និព្វាន បត្វាន ពោធឹ អមតំ អសង្ខតំ** ព្រះមានព្រះភាគ ទ្រង់សម្រេចពោធិ ដែលជា អមតៈ មិនមានបច្ច័យតាក់តែង ។

មកក្នុងអត្ថថា **ដើមឈើ** ដូចក្នុងប្រយោគជាដើមថា **អន្តរា ច គយំ**

**អន្តរា ច ពោធី**(១) ក្នុងចន្លោះនៃគយាសីសប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង ដូច្នេះ ។

មកក្នុងអត្ថថា **បញ្ញត្តិ** ដូចក្នុងប្រយោគថា **ពោធិ ភោ រាជកុមារោ ភោតោ គោតមស្ស បាទេ សិរសា វន្ទតិ** បពិត្រព្រះអង្គដ៏ចម្រើន ពោធិរាជកុមារ សូមថ្វាយបង្គំព្រះបាទាព្រះអង្គដោយត្បូង ។

មកក្នុងអត្ថថា **សព្វញ្ញុតញ្ញាណ** ដូចក្នុងប្រយោគជាដើមថា **បប្បោតិ ពោធឹ វរភូរិ មេធសោ** តថាគតនោះ មានប្រាជ្ញាដ៏ប្រសើរ ប្រៀបដោយផែនដី និងបានដល់ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ មានចំណែកដ៏ប្រសើរក្នុងផ្លូវប្រាជ្ញា ដូច្នេះ ។ ក្នុងទីនេះ គប្បីឃើញថា លោកសំដៅយកសព្វញ្ញុតញ្ញាណ ឬអរហត្តមគ្គញ្ញាណក៏គួរ ។

បទថា **អតុលំ** បានដល់ វៀរការថ្លឹង គឺហួសប្រមាណ អធិប្បាយថា មិនមានប្រមាណ គប្បីកាន់យកសេចក្តីថា ក្នុងបឋមធម្មទេសនានៃព្រះមានព្រះភាគអង្គនោះ ដែលទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ហើយទ្រង់សម្តែងធម៌ ។

សម័យណា ព្រះមង្គលសម្ពុទ្ធទ្រង់អាស្រ័យនគរឈ្មោះចិត្តៈ ទ្រង់ធ្វើយមកប្បាដិហារ្យ សង្កត់នូវមានះរបស់ពួកតិរ្ថិយត្រង់គល់ចម្បា ដូចព្រះមានព្រះភាគនៃយើង ទ្រង់ធ្វើយមកប្បាដិហារ្យត្រង់គល់គណ្ឌាម្ពព្រឹក្សហើយ ប្រថាប់គង់ត្រាស់ព្រះអភិធម្ម លើព្រះទែនបណ្ឌុកម្ពលសិលាអាសនៈ ក្រោមដើមបារិច្ឆត្តកក្នុងស្ថានតាវត្តិង្ស ដែលជាភពប្រសើរ សម្រេចដោយមាស

---

១- បិដកខ្មែរជា អន្តរា ច ពោធី អន្តរា ច គយំ ។

និងប្រាក់ដ៏ល្អ ជាដែនសម្រាកសម្រាន្តរបស់ទេវតា និងអសុរកំលោះក្រមុំ ។ សម័យនោះ ការត្រាស់ដឹងធម៌ មានដល់ទេវតាមួយសែនកោដិ នេះជាការត្រាស់ដឹងធម៌លើកទី ២ ។

សម័យណា ស្តេចចក្រពត្តិ ព្រះនាមសុនន្ទៈ ទ្រង់បំពេញចក្កវត្តិវត្ត ត្រង់សុរភីនគរ ទ្រង់បាននូវចក្ករ័តន៍ បានឮថា កាលព្រះមង្គលទសពលទ្រង់កើតឡើងក្នុងលោក ចក្ករ័តន៍នោះក៏ឃ្លាតចាកបល្ល័ង្ក ព្រះបាទសុនន្ទៈ ទ្រង់ឃើញហើយ ទ្រង់ក៏អស់នូវការត្រេកអរក្នុងព្រះហឫទ័យ ទើបទ្រង់សាកសួរពួកព្រាហ្មណ៍ថា ចក្ករ័តន៍នេះ កើតព្រោះកុសលរបស់យើង ហេតុអ្វី ទើបឃ្លាតចាកស្ថាន សម័យនោះ ព្រាហ្មណ៍ទាំងនោះ ក៏ព្យាករដល់ហេតុដែលចក្ករ័តន៍នោះរំកិលចាកទីដល់ព្រះរាជាថា កាលណាចក្ករ័តន៍ឃ្លាតចាកស្ថាន ស្តេចចក្រពត្តិនឹងអស់ព្រះជន្មាយុ ព្រោះស្តេចចក្រពត្តិចេញបួស ឬព្រោះព្រះពុទ្ធកើតឡើង ហើយក្រាបទូលថា បពិត្រមហារាជ ព្រះជន្មាយុរបស់ព្រះអង្គមិនទាន់អស់ទេ ព្រះអង្គទ្រង់មានព្រះជន្មាយុយឺនយូរ តែព្រះមង្គលសម្មាសម្ពុទ្ធ ទ្រង់កើតឡើងហើយក្នុងលោក ដោយហេតុនោះ ទើបចក្ករ័តន៍របស់ព្រះអង្គឃ្លាតចាកទី ព្រះបាទសុនន្ទចក្រពត្តិរាជ មួយអន្លើដោយបរិស័ទស្តាប់ពាក្យព្យាករនោះហើយ ទើបទ្រង់ថ្វាយបង្គំចក្ករ័តន៍នោះ ដោយសិរសា ទ្រង់អង្វរថា សូមអ្នកកុំទាន់អន្តរធាន ទម្រាំយើងធ្វើសក្ការៈព្រះមង្គលទសពល ដោយអានុភាពរបស់អ្នក ។ លំដាប់នោះ ចក្ករ័តន៍នោះ ក៏បានតម្កល់នៅត្រង់ទីដើម ។

បន្ទាប់អំពីនោះ ស្តេចសុនន្ទចក្រពត្តិ មានសេចក្តីត្រេកអរដល់ព្រម កាលបរិស័ទប្រមាណ ៣៦ យោជន៍ ចោមរោមហើយ ក៏យាងទៅគាល់ព្រះមង្គលទសពល ដែលជាមង្គលរបស់សត្វលោកទាំងពួង ទ្រង់អង្គាសព្រះសាស្តា មួយអន្លើដោយសាវកឲ្យឆ្អែតស្កប់ស្កល់ដោយមហាទាន ថ្វាយសំពត់ដែនកាសីដល់ព្រះអរហន្តមួយសែនកោដិ ថ្វាយបរិក្ខារសព្វយ៉ាងដល់ព្រះ-តថាគត ទ្រង់ធ្វើនូវការបូជាដល់ព្រះមានព្រះភាគ ដែលជាទីភ្ញុកភ្ញឹករបស់សត្វលោក ហើយចូលគាល់ព្រះមង្គលសម្ពុទ្ធ ដែលជាទីពឹងនៃសត្វលោកទាំងពួង ទ្រង់ធ្វើក្រពុំអញ្ជលី ដូចផ្កាឈូកប្រាសចាកមន្ទិល ដែលរុងរឿងដោយទសនខសមោធាន ដាក់លើសិរសា គឺត្បូង ទ្រង់ថ្វាយបង្គំហើយ ប្រថាប់គន់ក្នុងទីសមគួរ នាចំណែកម្ខាង សូម្បីព្រះរាជឱរសរបស់ព្រះអង្គព្រះនាមថាអនុរាជកុមារ ក៏ប្រថាប់គន់យ៉ាងនោះដូចគ្នា ។

គ្រានោះ ព្រះមានព្រះភាគត្រាស់អនុបុព្វីកថាប្រោសជនទាំងនោះ ដែលមានព្រះបាទសុនន្ទចក្រពត្តិជាប្រធាន ។ ព្រះបាទសុនន្ទចក្រពត្តិ មួយអន្លើដោយបរិស័ទសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ។ លំដាប់នោះព្រះសាស្តាទ្រង់រំពឹងមើលបុព្វចរិយារបស់ជនទាំងនោះ ទ្រង់ឃើញឧបនិស្ស័យនៃបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ទ្រង់លាព្រះហស្តខាងស្តាំ ដែលប្រដាប់ដោយបណ្តាញនៃចក្រ ត្រាស់ថា ចូរពួកអ្នកមកជាភិក្ខុចុះ ។ ក្នុងរំពេចនោះឯង ជនទាំងអស់មានសក់ប្រមាណ ២ ធ្នាប់ ទ្រទ្រង់នូវបាត្រ ចីវរដែលសម្រេចដោយឫទ្ធិ ដល់ព្រមដោយអាការ សមគួរដល់សមណៈ ដូច

ព្រះថេរៈមានវស្សា ៦០ ចោមរោមព្រះមានព្រះភាគ នេះជាការត្រាស់ដឹងធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសម្ពុទ្ធទ្រង់សម្ដែងធម៌ ក្នុងសុរិន្ទទេវភព កាលនោះ ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផលលើកទី ២ ។ កាលព្រះបាទសុនន្ទចក្រពត្តិ ទ្រង់ចូលទៅគាល់ព្រះសម្ពុទ្ធ កាលនោះ ព្រះសម្ពុទ្ធទ្រង់វាយស្គរ គឺព្រះធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ ។ កាលនោះ ពួកជនដែលតាមហែព្រះបាទសុនន្ទៈ មានចំនួន ៩០ កោដិ ជនទាំងអស់នោះ បានជាឯហិភិក្ខុឥតសេសសល់ ( លើកទី ៣ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុរិន្ទ ទេវភវនេ** សេចក្ដីថា ក្នុងភពរបស់សក្កៈ ដែលជាកំពូលនៃទេវតា ។ បទថា **ធម្មំ** បានដល់ ព្រះអភិធម្ម ។ បទថា **អាហនិ** បានដល់ ទ្រង់វាយ ។ បទថា **វរុត្តមំ** សេចក្ដីថា ព្រះមានព្រះភាគដ៏ប្រសើរ ទ្រង់បានទូងធម្មភេរីដ៏ឧត្ដម ។ បទថា **អនុចរា** បានដល់ សេវកៈដែលតាមព្រះរាជាជាប់រហូត ។ បទថា **អាសុំ** បានដល់ មានហើយ បាឋៈថា **តទាសិ នវុតិកោដិយោ** ដូច្នេះក៏មាន សេចក្ដីថា ពួកជនរបស់ព្រះបាទសុនន្ទចក្រពត្តិអង្គនោះ មានហើយ បើសួរថា ពួកជនទាំងនោះមានចំនួនប៉ុន្មាន ក៏ឆ្លើយថា មានចំនួន ៩០ កោដិ ។

បានឮថា សម័យនោះ ព្រះមង្គលលោកនាថប្រថាប់នៅត្រង់មេខលបុរី ក្នុងនគរនោះឯង សុទេវមាណព និងធម្មសេនមាណព មានមាណព ១០០០

ជាបរិវារ នាំគ្នាបួសដោយឯហិភិក្ខុបព្វជ្ជាក្នុងសម្នាក់របស់ព្រះមានព្រះភាគអង្គនោះ ។ កាលគូអគ្គសាវក មួយអន្លើដោយបរិវារសម្រេចអរហត្ត ក្នុងថ្ងៃ ១៥ កើត ខែមាឃ ព្រះសាស្តាទ្រង់លើកបាតិមោក្ខឡើងសម្តែងក្នុងកណ្តាលភិក្ខុមួយសែនកោដិ នេះជាការប្រជុំលើកទី ១ ទ្រង់លើកបាតិមោក្ខឡើងសម្តែងក្នុងការប្រជុំរបស់បព្វជិត ក្នុងសមាគមញាតិដ៏កំពូល ក្នុងឧត្តរារាមទៀត នេះជាការប្រជុំលើកទី ២ ។ ទ្រង់លើកបាតិមោក្ខឡើងសម្តែង ក្នុងកណ្តាលភិក្ខុ ៩ ម៉ឺនកោដិ[១] ក្នុងសមាគមគណៈ ភិក្ខុព្រះបាទសុនន្ទចក្រពត្តិ នេះជាការប្រជុំលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមង្គលសម្ពុទ្ធ ព្រះអង្គស្វែងរកគុណដ៏ធំ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានព្រះខីណាស្រព
មួយសែនកោដិ សន្និបាតលើកទី ២ មានព្រះខីណាស្រព
មួយសែនកោដិ សន្និបាតលើកទី ៣ មានព្រះខីណាស្រព
៩០ កោដិ ។ សមាគមក្នុងកាលនោះ សុទ្ធតែព្រះខីណាស្រព
ប្រាសចាកមន្ទិល ដូច្នេះ ។

គ្រានោះ ព្រះពោធិសត្វនៃយើងជាព្រាហ្មណ៍ ឈ្មោះសុរុចិ នៅក្នុងស្រុកព្រាហ្មណ៍ឈ្មោះសុរុចិ ជាអ្នកចប់ត្រៃវេទ មួយអន្លើដោយនិឃណ្ឌុសាស្ត្រ កេដុភសាស្ត្រ និងប្រភេទអក្ខរសាស្ត្រ ជំនាញក្នុងកាព្យឃ្លោង ជំនាញក្នុងកម្រងកែវ និងជំនាញក្នុងលោកាយតនសាស្ត្រ និងមហាបុរិ-

១- បិដកខ្មែរថា ៩០ កោដិ ។

សលក្ខណសាស្ត្រ ។ សុរុចិព្រាហ្មណ៍នោះចូលទៅគាល់ព្រះសាស្តា ស្តាប់ធម្មកថាដ៏ពីរោះរបស់ព្រះទសពលហើយ ជ្រះថ្លាដល់នូវសរណៈ និមន្តព្រះមានព្រះភាគ មួយអន្លើដោយសង្ឃសាវកថា សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែកនេះ ព្រាហ្មណ៍នោះ កាលព្រះមានព្រះភាគត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកត្រូវការភិក្ខុចំនួនប៉ុន្មាន ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុបរិវាររបស់ព្រះអង្គមានប៉ុន្មាន ។ កាលនោះ ជាការប្រជុំលើកទី ១ ព្រោះហេតុនោះ កាលត្រាស់ថា មានមួយសែនកោដិ សុរុចិ-ព្រាហ្មណ៍និមន្តថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ មួយអន្លើដោយភិក្ខុគ្រប់រូប ។ ព្រះសាស្តា ទ្រង់ក៏ទទួលនិមន្ត ។

ព្រាហ្មណ៍កាលនិមន្តព្រះមានព្រះភាគ ដើម្បីសោយក្នុងថ្ងៃស្អែកហើយ ក៏ត្រឡប់ទៅផ្ទះ គិតថា ភិក្ខុចំនួនប៉ុណ្ណោះអញអាចថ្វាយបបរ បាយ និងសំពត់ជាដើមបាន តែទីអង្គុយនឹងធ្វើដូចម្តេច ការគិតរបស់ព្រាហ្មណ៍នោះ ក៏ក្តៅដល់ព្រះទែនបណ្ឌុកម្ពលសិលាអាសនៈ របស់សហស្សនេត្រសក្កទេវរាជ ដែលស្ថិតនៅលើកំពូលភ្នំមេរុ ដែលមានចម្ងាយផ្លូវ ៨៤០០០ យោជន៍ ។ កាលនោះ សក្កទេវរាជទ្រង់ឃើញអាសនៈក្តៅ ក៏កើតបរិវិតក្កថា អ្នកណាហ្ន៎ បំណងនឹងឲ្យអញឃ្លាតចាកទីនេះ ទ្រង់ប្រមើលមើលមនុស្សលោកដោយព្រះនេត្រទិព្វ ឃើញមហាបុរស គិតថា មហាសត្វនេះ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន គិតរឿងអាសនៈសម្រាប់ភិក្ខុសង្ឃអង្គុយ អញគួរទៅកាន់

ទីនោះ ទទួលចំណែកបុណ្យ ទើបកាឡាខ្លួនជាជាងឈើ កាន់កាំបិត និង ពូថៅ ហើយប្រាកដចំពោះមុខមហាបុរស ពោលថា អ្នកណាហ្ន៎ មានកិច្ច ដែលជួលខ្ញុំឲ្យធ្វើការងារខ្លះ ។

ព្រះមហាសត្វឃើញហើយ ក៏សួរថា អ្នកអាចធ្វើការងាររបស់ខ្ញុំបាន ដែរឬ ឥន្ទនិម្មិតពោលថា ឈ្មោះថា សិប្បៈដែលខ្ញុំមិនចេះ មិនមាន បុគ្គល ណាបំណងនឹងឲ្យធ្វើវត្ថុណា ទោះជាមណ្ឌប ប្រាសាទ ឬនិវេសន៍ជាដើម ខ្ញុំ អាចធ្វើឲ្យដល់បុគ្គលនោះៗ បានទាំងអស់ ។ មហាសត្វប្រាប់ថា បើដូច្នោះ ខ្ញុំមានការងារ ។ ឥន្ទនិម្មិតសួរថា ការងារអ្វី ។ មហាសត្វប្រាប់ថា ខ្ញុំនិមន្ត ភិក្ខុមួយសែនកោដិ ដើម្បីឆាន់អាហារក្នុងថ្ងៃស្អែក អ្នកត្រូវសាងមណ្ឌប សម្រាប់ភិក្ខុទាំងនោះគង់ ឥន្ទនិម្មិតពោលថា ខ្ញុំធ្វើបាន បើលោកអាចឲ្យថ្លៃ ឈ្នួលដល់ខ្ញុំ ។ ព្រះមហាសត្វទទួលថា ខ្ញុំអាច ឥន្ទនិម្មិតពោលថា សាធុ បើយ៉ាងនោះខ្ញុំនឹងធ្វើ ហើយក៏ពិនិត្យមើលទីកដីមួយកន្លែង ដែលមានប្រមាណ ១២ យោជន៍ មានផ្ទៃរាបស្មើ ដូចមណ្ឌលកសិណ គួរជាទីត្រេកអរយ៉ាង ក្រៃលែង ។ ឥន្ទនិម្មិតគិតថា មណ្ឌបដែលមានចំណែកសំខាន់សម្រេចទៅ ដោយរតនៈ ៧ ប្រការ ចូរផុសឡើងក្នុងទីប្រមាណប៉ុណ្ណោះ ហើយសម្លឹង មើល ។ រំពេចនោះ មណ្ឌបជ្រែកផែនដីផុសឡើង ដូចមណ្ឌបពិត មណ្ឌប នោះ មានផ្ទាំងប្រាក់នៅត្រង់សសរមាស មានផ្ទាំងមាសនៅត្រង់សសរប្រាក់ មានផ្ទាំងកែវប្រពាលនៅត្រង់សសរកែវមណី មានផ្ទាំងកែវមណីនៅត្រង់ សសរកែវប្រពាល មានផ្ទាំងរតនៈ ៧ នៅត្រង់សសររតនៈ ៧ ។

បន្ទាប់អំពីនោះ ឥន្ទនិម្មិតពិនិត្យមើលដោយគិតថា បណ្តាញកណ្តឹង ចូរសំយុងចុះត្រង់ជាយពិតាននៃមណ្ឌប ដំណាលគ្នានឹងការសម្លឹងមើល បណ្តាញកណ្តឹងក៏សំយុង កាលត្រូវខ្យល់ត្រសៀកៗ បក់មក ក៏បន្លឺសំឡេងពីរោះ គួរជាទីត្រេកអរក្រៃលែង ដូចតន្ត្រីប្រកបដោយអង្គ ៥ ។ ក្នុងវេលាព្រឹកនោះ ដូចវេលាពន្លឺទិព្វសង្គិត: ។ ឥន្ទនិម្មិតគិតថា កម្រង គ្រឿងក្រអូប កម្រងផ្កា កម្រងស្លឹកឈើ និងកម្រងរតនៈ ៧ ដ៏ជាទិព្វ ចូរសំយុងជាចន្លោះៗ ដំណាលគ្នានឹងការគិត កម្រងផ្កាទាំងឡាយក៏សំយុងចុះ ។ ឥន្ទនិម្មិតគិតទៀតថា អាសនៈកម្រាលដែលមានតម្លៃជារបស់កប្បិយ និងគ្រឿងទម្រទាំងឡាយសម្រាប់ភិក្ខុចំនួនមួយសែនកោដិ ចូរជ្រែកផែនដីផុសឡើង ។ ក្នុងរំពេចនោះ របស់ដូចពោលក៏ផុសឡើង ឥន្ទនិម្មិតគិតថា ចូរក្អមទឹកតាំងនៅគ្រប់ជ្រុង មួយជ្រុង ១ ក្អម រំពេចនោះឯង ក្អមទឹកទាំងឡាយ ក៏ពេញដោយទឹកស្អាត ជាទឹកក្រអូប និងជាកប្បិយ មានរសឆ្ងាញ់ត្រជាក់ក្រៃលែង មានមាត់បិទដោយស្លឹកចេក ក៏ប្រាកដឡើង ។ ស្តេចសហស្សនេត្រ ទ្រង់និម្មិតវត្ថុមានប្រមាណប៉ុណ្ណេះហើយ ចូលទៅរកព្រាហ្មណ៍ ពោលថា បពិត្រលោកម្ចាស់ មក លោកម្ចាស់ឃើញមណ្ឌបរបស់លោកម្ចាស់ហើយ សូមឲ្យថ្លៃឈ្នួលដល់ខ្ញុំ ព្រះមហាសត្វសម្លឹងមើលមណ្ឌបនោះ កាលឃើញមណ្ឌបនោះឯង សរីរៈក៏ត្រូវបីតិ ៥ ពាល់ត្រូវហើយ ជ្រួតជ្រាបមិនមានចន្លោះ ។

គ្រានោះ មហាសត្វគ្រាន់តែឃើញ ក៏គិតយ៉ាងនេះថា មណ្ឌបនេះមិនមែនជាថ្វីដៃរបស់មនុស្ស អាស្រ័យអធ្យាស្រ័យរបស់អញ គុណរបស់អញ

ទើបក្តៅដល់ស្ថានសក្កទេវរាជ បន្ទាប់អំពីនោះ ទើបសក្កទេវរាជទ្រង់និម្មិតមណ្ឌបនេះពិត ។ ព្រះមហាសត្វគិតថា ការថ្វាយទានមួយថ្ងៃ ក្នុងមណ្ឌបបែបនេះ មិនសមគួរដល់អញ អញនឹងថ្វាយអស់ ៧ ថ្ងៃ ។ ធម្មតាទានខាងក្រៅមានប្រមាណប៉ុណ្ណោះ គង់មិនអាចធ្វើហទយៈរបស់ព្រះពោធិសត្វឲ្យពេញចិត្តបាន ព្រះពោធិសត្វទាំងឡាយ អាស្រ័យចាគៈ រមែងពេញចិត្តតែក្នុងពេលកាត់សីសៈដែលប្រដាប់ហើយ ឬខ្វេះភ្នែកដែលបន្តក់ហើយ ឬខ្វេះយកបេះដូងឲ្យជាទាន ។ ពិតហើយ ក្នុងសិវិជាតក កាលព្រះពោធិសត្វនៃយើងលះបង់នូវទ្រព្យ ៥ សែនកហាបណៈរាល់ៗ ថ្ងៃ ឲ្យទាន ៥ កន្លែង គឺត្រង់ទ្វារនគរ ៤ ត្រង់កណ្តាលនគរ ១ ទាននោះ មិនអាចឲ្យកើតនូវការពេញចិត្តក្នុងចាគៈបានឡើយ ។ តែសម័យណា សក្កទេវរាជកាឡាខ្លួនជាព្រាហ្មណ៍ មកសូមចក្ខុទាំងទ្វេ សម័យនោះ ព្រះពោធិសត្វនោះ ក៏ខ្វេះចក្ខុទាំងនោះឲ្យ កំពុងឲ្យទាននោះឯង ទើបកើតនូវសេចក្តីត្រេកអរ ចិត្តមិនបានប្រែប្រួលសូម្បីប៉ុនចុងសក់ ។ ដោយប្រការដូចពោលមកនេះ ព្រះសព្វញ្ញូពោធិសត្វទាំងឡាយ អាស្រ័យទានខាងក្រៅមិនឆ្អែតឡើយ ព្រោះហេតុនោះ ព្រះមហាបុរសអង្គនោះ គិតថា អញគួរថ្វាយទានដល់ភិក្ខុមួយសែនកោដិ ទើបឲ្យភិក្ខុទាំងនោះអង្គុយក្នុងមណ្ឌបនោះ ហើយថ្វាយទាន ដែលមានឈ្មោះថា គវបាន អស់ ៧ ថ្ងៃ ។

ភោជនដែលគេដាក់ពេញឆ្នាំងធំៗ ពេញដោយទឹកដោះគោ ហើយលើកឡើងដាក់លើចង្ក្រាន ដាក់អង្ករបន្តិចបន្តួចក្នុងទឹកដោះ រម្ងាស់របួតខះ

ហើយផ្សំដោយទឹកឃ្មុំ លាយដោយស្ករក្រាម មួយអន្ទើដោយសប្បិ ហៅថា **គវបាន** ក្នុងបាលីនោះ **គវបាន** នេះឯង គេហៅថា ភោជនដែលមានរស ៤ ដូច្នេះក៏មាន ។ តែមនុស្សទាំងឡាយ មិនអាចអង្គាសបាន ចំណែកទេវតាទាំងឡាយ ចូលត្រង់ចន្លោះៗ ជួយអង្គាស ទីនោះ សូម្បីមានទំហំ ១២ យោជន៍ គង់មិនល្មមសម្រាប់ទទួលភិក្ខុទាំងនោះបានឡើយ តែភិក្ខុទាំងនោះ អង្គុយដោយអានុភាពរៀងៗ ខ្លួន ។ ក្នុងថ្ងៃចុងក្រោយ មហាបុរសឲ្យលាងបាត្រភិក្ខុគ្រប់រូប ដាក់ពេញដោយសប្បិ នវនីត ទឹកឃ្មុំ ទឹកអំពៅជាដើម បានប្រគេនមួយអន្ទើដោយត្រៃចីវរ សំពត់ចីវរដែលភិក្ខុសង្ឃនវកក្នុងទីនោះបានហើយ ក៏ជារបស់មានតម្លៃរាប់សែន ។

គ្រានោះ ព្រះសាស្តាកាលទ្រង់ធ្វើអនុមោទនា ទ្រង់ពិចារណាថា មហាបុរសនេះ បានថ្វាយទានបែបនេះ នឹងបានជាអ្វីហ្ន៎ ទ្រង់ក៏ឃើញថា ក្នុងអនាគតកាល បុរសនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ក្នុងទីបំផុត ២ អសង្ខេយ្យ និង ១ សែនកប្ប បន្ទាប់អំពីនោះ ទើបទ្រង់ហៅព្រះមហាសត្វមក ហើយទ្រង់ព្យាករថា កន្លងកាលប្រមាណប៉ុណ្ណេះ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម ។ លំដាប់នោះ មហាបុរសស្តាប់ពាក្យព្យាកររបស់ព្រះមានព្រះភាគហើយ ក៏មានហទយៈត្រេកអរ គិតថា ព្រះសាស្តាត្រាស់ថា អញនឹងបានជាព្រះពុទ្ធ អញមិនត្រូវនៅគ្រប់គ្រងផ្ទះ ទើបលះសម្បត្តិបែបនោះដូចដុំទឹកមាត់ បួសក្នុងសម្នាក់របស់ព្រះសាស្តា រៀនទូវពុទ្ធវចនៈ ញុំាងនូវអភិញ្ញា និងសមាបត្តិ ៨ ឲ្យកើត មានឈានមិនសាបសូន្យ តាំងនៅដរាប

ដល់អស់អាយុ ក្នុងទីបំផុតនៃអាយុ កើតក្នុងព្រហ្មលោក ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សមាគមក្នុងកាលនោះ សុទ្ធតែព្រះខីណាស្រព ប្រាសចាក មន្ទិល សម័យនោះ តថាគតជាព្រាហ្មណ៍ ឈ្មោះសុរុចិ ។ តថាគតអ្នករៀនមន្ត ចងចាំមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ចូលទៅគាល់ព្រះសម្ពុទ្ធអង្គនោះ ហើយបានដល់ព្រះសាស្តា ជាទីពឹង ។ តថាគតបានបូជាព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយគ្រឿងក្រអូប និងផ្កាកម្រង លុះបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងហើយ ក៏ញុំាងព្រះភិក្ខុសង្ឃឲ្យឆាន់ស្កប់ស្កល់ ដោយទឹកដោះគោ ។ ព្រះសម្ពុទ្ធព្រះនាមមង្គលៈនោះ ព្រះអង្គ ឧត្តមជាសត្វទ្វេបាទ ទ្រង់ទំនាយតថាគតថា ក្នុងរវាងកប្ប ប្រមាណមិនបាន អំពីកប្បនេះទៅ បុរសនោះ នឹងបានត្រាស់ ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីក រាយ តាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វ ( នេះ ) នឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួលបាយាសក្នុង ទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គ នោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយ ចូលទៅជិតគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ ចែង ។ លំដាប់អំពីនោះទៅ ព្រះជិនស្រី មានយសច្រើន

នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនេះ នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមថាសុទ្ធោទនៈ ឯបុរសនេះ ជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទ នឹងបានជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ គេហៅថាអស្សត្ថព្រឹក្ស ( ដើមពោធិ៍ ) ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានឮព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធមិនមានបុគ្គលស្មើស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោផង ទះដៃផង សើចផង ធ្វើ

អញ្ជលីនមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះលោកនាថនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបាន សម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជា អនាគតមិនខាន យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះ តម្រាស់របស់ព្រះពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។ ក្នុងកាលនោះ តថាគតចម្រើនបីតិ ថ្វាយផ្ទះរបស់តថាគត ចំពោះព្រះពុទ្ធ ហើយបួសក្នុងសម្នាក់ព្រះអង្គ ដើម្បីសម្រេច ពោធិញ្ញាណដ៏ប្រសើរ ។ តថាគតបានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនាមានអង្គ ៩ ទាំងអស់ ហើយញ៉ាំងសាសនា នៃព្រះជិនស្រី ឲ្យល្អរុងរឿង ។ តថាគតមិនប្រមាទ កាលនៅ ក្នុងទីនោះ ចម្រើនព្រហ្មវិហារ បានសម្រេចអភិញ្ញាបារមី ហើយក៏បានទៅកើតក្នុងព្រហ្មលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គន្ធមាលេន** បានដល់ ដោយគ្រឿងក្រអូប និងកម្រងផ្កាទាំងឡាយ ។ បទថា **គវេចាន** នេះ បានពោលមកហើយ ។

អាចារ្យពួកខ្លះពោលថា **យតចានេន** ដូច្នេះក៏មាន ។ បទថា **តប្បយឹ** បានដល់ ឲ្យឆ្អែតស្កប់ស្កល់ហើយ ។ បទថា **ឧត្តរឹ វតមធិដ្ឋាសឹ** បានដល់ អធិដ្ឋានវត្តឲ្យក្រៃលែងឡើង ។ បទថា **ទសបារមិប្បូរិយា** បានដល់ ដើម្បីធ្វើបារមី ១០ ឲ្យពេញ ។ បទថា **បីតឹ** បានដល់ សេចក្តីត្រេកអរនៃចិត្ត ។ បទថា **អនុព្រូហាន្តោ** បានដល់ ឲ្យចម្រើន ។ បទថា **សម្ពោធិវរបត្តិយា** បានដល់ ដើម្បីសម្រេចភាពជាព្រះពុទ្ធ ។ បទថា **ពុទ្ធេ ទត្វាន** បានដល់ បរិច្ចាគដល់ព្រះពុទ្ធ ។ បទថា **មំ គេហំ** សេចក្តីថា បរិច្ចាគគេហៈ គឺសម្បត្តិគ្រប់យ៉ាងរបស់យើង ដល់ព្រះមានព្រះភាគ ដើម្បីជាបច្ច័យ ៤ ។ បទថា **តត្ថ** បានដល់ ក្នុងព្រះពុទ្ធសាសនានោះ ។ បទថា **ព្រូហំ** បានដល់ ចម្រើនព្រហ្មវិហារភាវនា ។

ព្រះមង្គលសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណធំ មាននគរឈ្មោះឧត្តរៈ មហាក្សត្រព្រះនាមឧត្តរៈជាព្រះបិតា ព្រះមាតាព្រះនាមឧត្តរា ។ ព្រះថេរៈឈ្មោះសុទេវៈ ១ ធម្មសេនៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះបាលិតៈជាឧបដ្ឋាក របស់ព្រះមង្គលសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះសីវលា ១ អសោកា ១ ជាអគ្គសាវិកា ដើមឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគអង្គនោះហៅថា នាគព្រឹក្ស ( ដើមខ្ទឹង ) ។ ព្រះមហាមុនី ទ្រង់មានកម្ពស់ ៨៨ ហត្ថ រស្មីច្រើនសែន ផ្សាយចេញអំពីកាយព្រះអង្គ ។ ព្រះជន្មាយុរបស់ព្រះអង្គ ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ស្ថិតនៅ

ជរាបនោះ ញុំាងពួកជនច្រើនឲ្យឆ្លង ( វដ្តសង្សារ ) ។ រលក ក្នុងសាគរ គេមិនអាចរាប់បាន យ៉ាងណាមិញ សាវកទាំងឡាយ របស់ព្រះអង្គ ក៏គេមិនអាចរាប់បាន យ៉ាងនោះដែរ ។ ព្រះមង្គលសម្ពុទ្ធ ជាលោកនាយក ទ្រង់បានស្ថិតនៅជរាបណា មរណៈ ប្រកបដោយកិលេស មិនមានក្នុងសាសនានៃព្រះអង្គជរាបនោះ ។ ព្រះសម្ពុទ្ធ ទ្រង់មានយសច្រើនអង្គនោះ ទ្រទ្រង់នូវគប់ភ្លើង គឺ ព្រះធម៌ ហើយញុំាងមហាជនឲ្យឆ្លង ដ៏រុងរឿងដូចជាផ្កាយដុះកន្ទុយ ទ្រង់បរិនិព្វាន ។ ព្រះសម្ពុទ្ធ ទ្រង់សម្តែងនូវសភាពប្រែប្រួលនៃសង្ខារ ដល់ពួកមនុស្ស ព្រមទាំងទេវតា រុងរឿងដូចគំនរភ្លើង ពុំនោះសោត ដូចព្រះអាទិត្យដែលទើបនឹងអស្តង្គត ។ ព្រះមង្គលសម្ពុទ្ធ ទ្រង់បរិនិព្វានក្នុងឧទ្យានឈ្មោះវេស្សរៈ ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះ មានកម្ពស់ ៣០ យោជន៍ មាននៅក្នុងទីនោះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តតោ** បានដល់ ចាកសរីរៈរបស់ព្រះមង្គលសម្ពុទ្ធអង្គនោះ ។ បទថា **និច្ឆាវតី** គឺ **និច្ឆារំ** គប្បីឃើញថា ជាវចនវិបល្លាស ។ បទថា **រំសី** បានដល់ រស្មីទាំងឡាយ ។ បទថា **អនេកសតសហស្សិយោ** បានដល់ មិនមែនមួយសែន ។ បទថា **"មី** បានដល់ រលក ។ បទថា **គណេតុយេ** បានដល់ ដើម្បីគណនា គឺរាប់ អធិប្បាយថា បុគ្គលមួយណា មិនអាចរាប់ថា រលកក្នុងមហាសមុទ្រ មានប៉ុណ្ណេះ យ៉ាង

ណា សាវកទាំងឡាយរបស់ព្រះមានព្រះភាគអង្គនោះ បុគ្គលណាមួយ មិនអាចរាប់បាន ក៏យ៉ាងនោះ ដែលពិត ហួសនឹងរាប់បាន ។ បទថា **យាវ** បានដល់ អស់កាលត្រឹមណា ។ បទថា **សកិលេសមរណំ តទា** សេចក្តីថា បុគ្គលប្រព្រឹត្តទៅដោយកិលេសទាំងឡាយ ឈ្មោះថា ប្រកបដោយកិលេស ។ សេចក្តីស្លាប់របស់បុគ្គលដែលប្រព្រឹត្តទៅដោយកិលេស ឈ្មោះថា មរណៈប្រកបដោយកិលេស ។ ការស្លាប់របស់បុគ្គល អ្នកមានកិលេសនោះមិនមាន ។ បានឮថា សម័យនោះ សាវកទាំងឡាយ ក្នុងសាសនារបស់ព្រះមានព្រះភាគអង្គនោះ សម្រេចអរហត្តហើយ ទើបបរិនិព្វាន បុគ្គលដែលនៅជាបុថុជ្ជន ឬជាព្រះសោតាបន្នជាដើម ក៏មិនទាន់ធ្វើកាលកិរិយា អាចារ្យពួកខ្លះពោលថា **សម្មោហមារណំ តទា** ដូច្នេះក៏មាន ។

បទថា **ធម្មោក្កំ** បានដល់ សម្តែងធម៌ ។ ភ្លើង លោកហៅថា **ធូមកេតុ** តែក្នុងទីនេះ គប្បីឃើញថា ប្រទីប ព្រោះហេតុនោះ ទើបមានសេចក្តីថា ដូចប្រទីបចែងចាំងពន្លឺ ហើយរលត់ទៅ ។ បទថា **មហាយសោ** បានដល់ ទ្រង់មានបរិវារច្រើន ។ អាចារ្យពួកខ្លះពោលថា ព្រះមង្គលសម្ពុទ្ធអង្គនោះ មួយអន្លើដោយសាវកនោះ រលត់ខន្ធបរិនិព្វានហើយ ដូច្នេះ ។ បទថា **សង្ខារានំ** បានដល់ សង្ខតធម៌ គឺធម៌ដែលមានបច្ច័យ ។ បទថា **សភាវត្តំ** បានដល់

សាមញ្ញលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ បទថា **សុរិយោ អត្ថង្គតោ យថា** សេចក្តីថា ព្រះអាទិត្យដែលមានរស្មីរាប់ពាន់ កម្ចាត់នូវងងឹតទាំងអស់ និងពន្លឺទាំងអស់ក្នុងលោកគង់អស្តង្គត យ៉ាងណា សូម្បីព្រះមង្គលសម្ពុទ្ធ ទ្រង់ដូចព្រះអាទិត្យ ទ្រង់ធ្វើវេនេយ្យសត្វឲ្យរីកដូចគុម្ពឈូក ទ្រង់កម្ចាត់ងងឹតក្នុងលោក ទាំងខាងក្នុង ទាំងខាងក្រៅ សព្វយ៉ាង ទ្រង់រុងរឿងដោយព្រះរស្មីនៃព្រះសរីរៈរបស់ព្រះអង្គក៏ដល់នូវការតាំងនៅមិនបាន ក៏យ៉ាងនោះ ។ គាថាដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាមង្គលពុទ្ធវង្សទី ៣ ចប់

# សុត្តន្តបិដក

## សុមនពុទ្ធវង្សទី ៤

[ ៥ ] កាលខាងក្រោយអំពីព្រះមង្គលសម្ពុទ្ធមក ព្រះលោកនាយក ព្រះនាមសុមនៈ រកបុគ្គលស្មើគ្មានដោយធម៌ទាំងពួង ព្រះអង្គឧត្តមជាងសព្វសត្វ ។ កាលនោះ ព្រះអង្គទ្រង់ទូងស្គរ គឺអមតៈ ប្រកបដោយសង្ខ គឺធម៌ ជាសាសនារបស់ព្រះជិនស្រី មានអង្គ ៩ ក្នុងមេខលបុរី ។ ព្រះសាស្តាអង្គនោះ ទ្រង់ឈ្នះកិលេស ហើយសម្រេចនូវសម្ពោធិញ្ញាណដ៏ប្រសើរ ទ្រង់សាងនគរជាបុរី គឺព្រះសទ្ធម្មដ៏ប្រសើរខ្ពង់ខ្ពស់ ។ ព្រះអង្គទ្រង់សាងផ្លូវធំ មិនមានចន្លោះ ជាផ្លូវមិនវៀច ជាផ្លូវត្រង់ មានទទឹងដ៏ធំទូលាយ គឺសតិប្បដ្ឋានដ៏ប្រសើរខ្ពង់ខ្ពស់ ។ ព្រះអង្គទ្រង់លាតសាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ សមាបត្តិ ៨ ក្នុងផ្លូវនោះ ។ ពួកសត្វណា មិនមានសេចក្តីប្រមាទ មិនរឹងរូស ប្រកបដោយសេចក្តីខ្មាសបាប និងសេចក្តីព្យាយាម ពួកសត្វនោះៗ តែងកាន់យកគុណដ៏ប្រសើរទាំងនេះ តាមសប្បាយ ។ ព្រះសាស្តា ទ្រង់ស្រោចស្រង់មហាជន ដោយសេចក្តីព្យាយាមនោះ យ៉ាងនេះឯង បានញ៉ាំងសត្វមួយសែនកោដិ ឲ្យត្រាស់ដឹងលើកទី ១ ។ ព្រះសាស្តាមានព្យាយាមច្រើន ទ្រង់ឲ្យឱវាទពួកតិរ្ថិយ ក្នុងកាលណា កាលនោះ សត្វមួយសែនកោដិ ( បានសម្រេចគុណវិសេស ) ក្នុងធម្មទេសនាលើកទី ២ ។ ពួកទេវតា និងមនុស្ស មានសេចក្តី

ព្រមព្រៀងគ្នា មានចិត្តស្រួលបួល សួរប្រស្នាក្នុងនិរោធផង សេចក្តីសង្ស័យផង សេចក្តីប្រាថ្នាក្នុងចិត្តផង ក្នុងកាលណា កាលនោះ ពួកសត្វ ៩០ ពាន់កោដិ បានសម្រេចមគ្គផលលើក ទី ៣ ក្នុងធម្មទេសនា ជាគ្រឿងបំភ្លឺនូវនិរោធ ។ ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣ លើក ដែល សុទ្ធតែជាពួកព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់ រម្ងាប់ ទាំងមានចិត្តនឹងធឹង ។ កាលព្រះមានព្រះភាគ ទ្រង់ចេញ វស្សាហើយ កាលភិក្ខុសង្ឃប្រកាសបវារណាហើយ ព្រះតថាគត ទ្រង់បវារណា ដោយភិក្ខុចំនួនមួយសែនកោដិ ( នេះជាសន្និបាត លើកទី ១ ) ។ ក្នុងការប្រជុំដទៃអំពីនោះមក មានសន្និបាតលើក ទី ២ នៃព្រះខីណាស្រព ៩០ ពាន់កោដិ លើកញ្ចូនបព៌ត មិន មានមន្ទិល ។ កាលសក្កទេវរាជចូលមកគាល់ព្រះសម្ពុទ្ធ ជា សន្និបាតលើកទី ៣ របស់ព្រះខីណាស្រព ៨០ ពាន់កោដិ ។ ក្នុងសម័យនោះ តថាគតកើតជាស្តេចនាគ មានឫទ្ធិច្រើន មាន ឈ្មោះថាអតុលៈ ជាអ្នកសន្សំកុសល ។ កាលនោះ តថាគត ចេញអំពីភពនាគ ជាមួយនឹងពួកញាតិ បានទៅបម្រើព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ដោយតន្ត្រីជាទិព្វរបស់នាគ ។ តថាគតបាន ញុំាងព្រះភិក្ខុសង្ឃមួយសែនកោដិ ឲ្យឆាន់ស្កប់ស្កល់ ដោយបាយ ទិព្វ ហើយថ្វាយសំពត់មួយគូៗ មួយអង្គ ហើយយកព្រះភិក្ខុសង្ឃ

នោះជាទីពីរ ។ ព្រះសម្ពុទ្ធព្រះនាមសុមនៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្ប មានប្រមាណមិនបាន អំពីកប្បនេះ នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ទៅតម្កល់សេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរាហើយ ស្តេចចូលមកទៀបគល់ពោធិព្រឹក្ស តាមផ្លូវដែលគេចាត់ចែងដ៏ប្រសើរ ។ លំដាប់តពីនោះមក ព្រះសម្ពុទ្ធមានយសច្រើនអង្គនោះ ទ្រង់ធ្វើប្រទក្សិណ នូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសម្ពុទ្ធអង្គនេះ ព្រះនាមថាមាយា ព្រះបិតាព្រះនាមថាសុទ្ធោទនៈ ឯនាគរាជនេះ នឹងបានត្រាស់ជាព្រះសម្ពុទ្ធព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ មិនមានរាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទនឹងជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ មិនមានរាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹងនៃ

ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់មានយស អង្គនោះ នឹងមានព្រះជន្ម ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ពុទ្ធដីកានេះ របស់ព្រះមហេសី មិនមានបុគ្គលស្មើ ហើយ ក៏រីករាយថា នាគរាជនេះ នឹងជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុ ស្រែកហ៊ោឡើង ផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំង ឡាយ បើនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គ នេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើ ឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លង ស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គ នេះ គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គ នេះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ តថាគតបាន ស្តាប់ព្រះតម្រាស់របស់ព្រះសម្ពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លា ក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។ ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានទីក្រុង ឈ្មោះមេខលៈ មានមហាក្សត្រព្រះនាមសុទត្តៈជាព្រះបិតា មាន

ព្រះមាតាព្រះនាមសិរិមា ។ ព្រះអង្គគ្រប់គ្រងព្រះរាជដំណាក់អស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺចន្ទប្រាសាទ ១ សុចន្ទប្រាសាទ ១ វដំសប្រាសាទ ១ ។ ពួកនារី ៦៣ សែននាក់ មានរូបប្រដាប់សមរម្យ នារី ( ជាអគ្គមហេសី ) ព្រះនាមវដំសកី ព្រះរាជបុត្រព្រះនាមអនូបមៈ ។ ព្រះជិនស្រីឃើញនិមិត្ត ៤ ហើយ ទ្រង់ចេញបព្វជ្ជាដោយយានដំរី ទ្រង់តាំងសេចក្តីព្យាយាមអស់ ១០ ខែឥតខ្វះ ។ ព្រះលោកនាយក ព្រះនាមសុមនៈ មានព្រះហឫទ័យស្ងប់រម្ងាប់ ទ្រង់មានចក្កប្រព្រឹត្តទៅ មានព្យាយាមធំ ត្រូវព្រហ្មអារាធនាក្នុងមេខលបុរី ដ៏ប្រសើរខ្ពង់ខ្ពស់ ។ ព្រះថេរៈឈ្មោះសរណៈ ១ ភាវិតត្តៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះឧទេនជាឧបដ្ឋាករបស់ព្រះសម្ពុទ្ធ ព្រះនាមសុមនៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះសោណា ១ ឧបសោណា ១ ជាអគ្គសាវិកា ព្រះសម្ពុទ្ធនោះ ស្មើដោយព្រះពុទ្ធដែលឥតមានបុគ្គលស្មើ ទ្រង់បានត្រាស់ដឹងទៀបគល់នាគព្រឹក្ស ។ ឧបាសកឈ្មោះវរុណៈ ១ សរណៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះចាលា ១ ឧបចាលា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៩០ ហត្ថ មានលម្អនៃព្រះរូបប្រហែលដូចគ្រឿងបូជាមាស ទ្រង់រុងរឿងក្នុងមួយម៉ឺនលោកធាតុ ។ ព្រះជន្មាយុ ( របស់ព្រះអង្គ ) ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ស្ថិតនៅ

ជកាបនោះ ទ្រង់ញ៉ាំងប្រជុំច្រើនឲ្យឆ្លង ( វដ្តសង្សារ ) ។ ព្រះសម្ពុទ្ធ ទ្រង់ចម្លងពួកសត្វដែលគួរចម្លង ទ្រង់បានដាស់តឿនពួកសត្វដែលគួរដាស់តឿន ហើយទ្រង់បរិនិព្វានដូចព្រះចន្ទអស្តង្គត ។ ភិក្ខុទាំងឡាយនោះ ជាព្រះខីណាស្រពក្តី ព្រះសម្ពុទ្ធអង្គនោះក្តី ទ្រង់មិនមានបុគ្គលណាស្មើ ទ្រង់បញ្ចេញរស្មីឥតប្រៀបផ្ទឹមបាន ព្រះខីណាស្រពមានយសច្រើនទាំងនោះ និព្វានហើយ ។ ព្រះញាណនោះ ជាគុណឥតមានអ្វីប្រៀបផ្ទឹមបានផង រតនៈទាំងនោះ ឥតអ្វីប្រៀបបានផង របស់ទាំងអស់នេះ វិនាសសូន្យទៅ សង្ខារទាំងពួងជារបស់ទទេពិត ។ ព្រះសុមនសម្ពុទ្ធ ទ្រទ្រង់យស ទ្រង់បរិនិព្វានក្នុងអង្គារាម ព្រះស្តូបរបស់ជិនស្រីអង្គនោះ មានកម្ពស់ ៤ យោជន៍ ប្រតិស្ឋាននៅក្នុងអារាមនោះ ។

## សុមនពុទ្ធវង្សទី ៤ ចប់

# អដ្ឋកថា

## សុមនពុទ្ធវង្សទី ៤

កាលព្រះមានព្រះភាគអង្គនោះ ទ្រង់រម្ងាប់ខន្ធបរិនិព្វាន ធ្វើនូវម៉ឺនលោកធាតុឲ្យងងឹតព្រមគ្នាយ៉ាងនេះហើយ បន្ទាប់អំពីសម័យរបស់ព្រះអង្គ កាលមនុស្សទាំងឡាយ មានអាយុ ៩ ម៉ឺនឆ្នាំ ហើយក៏ថយចុះដោយលំដាប់ រហូតដល់អាយុ ១០ ឆ្នាំ ហើយចម្រើនឡើងវិញ រហូតដល់មានអាយុដល់មួយអសង្ខេយ្យឆ្នាំ ហើយថយចុះមកវិញ នៅសល់ ៩ ម៉ឺនឆ្នាំ ព្រះពោធិសត្វព្រះនាមសុមនៈ ទ្រង់បំពេញបារមីហើយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះ បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងសិរិមាទេវី ក្នុងរាជត្រកូលរបស់ព្រះបាទសុទត្តៈ ក្នុងមេខលនគរ ។ បាដិហារ្យទាំងឡាយ មានន័យដូចពោលខាងដើមនោះឯង ។

ព្រះពោធិសត្វចម្រើនវ័យមកដោយលំដាប់ ដែលពួកស្រ្តីអ្នករបាំ ៦ លាន ៣ សែននាក់ ចាំបម្រើក្នុងប្រាសាទ ៣ គឺសិរិវឌ្ឍប្រាសាទ ១ សោមវឌ្ឍប្រាសាទ ១ ឥន្ទវឌ្ឍប្រាសាទ ១[១] ដូចទេវកុមារ ដែលពួកយុវទេពធីតាបម្រើ សោយលោកិយសុខដូចទិព្វសុខអស់ ៩ ពាន់ឆ្នាំ ទ្រង់ឲ្យកំណើតព្រះរាជឱរស ដែលមិនមានបុគ្គលប្រៀប ព្រះនាមអនូបមៈជាមួយព្រះនាងវដំសិកាទេវី[២] ទ្រង់ឃើញនិមិត្ត ៤ ហើយ ចេញអភិនេស្រ្កមណ៍ដោយយាន គឺដំរី ទ្រង់បួសហើយ ជន ៣០ កោដិក៏បួសតាមព្រះពោធិសត្វ

---

១- បិដកខ្មែរជា ចន្ទប្រាសាទ សុចន្ទប្រាសាទ និងវដំសប្រាសាទ ។

២- បិដកខ្មែរជា វដំសកី ។

ដែលទ្រង់បួស ។

ព្រះពោធិសត្វ កាលជន ៣០ កោដិនោះចោមរោមហើយ ទ្រង់បំពេញព្យាយាម ១០ ខែ ក្នុងថ្ងៃ ១៥ កើត ខែពិសាខ សោយមធុបាយាសដែលទេវតាដាក់ឱជទិព្វ ដែលនាងអនុបមាធីតារបស់អនោមសេដ្ឋី ក្នុងអនោមនិគមថ្វាយហើយ ទ្រង់សម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃសាលវ័ន ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអនុបមាជីវកថ្វាយ ទ្រង់ចូលទៅកាន់ពោធិព្រឹក្សឈ្មោះនាគ គឺដើមខ្លឹង ទ្រង់ធ្វើប្រទក្សិណនាគពោធិ៍នោះ ទ្រង់យកស្មៅ ៨ ក្តាប់ក្រាលជាសន្ថ័តស្មៅ ទំហំ ៣០ ហត្ថ ប្រថាប់គង់ពត់ភ្នែនលើសន្ថ័តស្មៅនោះ ។ បន្ទាប់ពីនោះ ទ្រង់កម្ចាត់ពលមារ ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្ដ មានជាតិដ៏ច្រើន ។បេ។ តថាគតបានដល់
ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។
ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា
កាលខាងក្រោយអំពីព្រះមង្គលសម្ពុទ្ធមក ព្រះលោកនាយក
ព្រះនាមសុមនៈ រកបុគ្គលស្មើគ្មានដោយធម៌ទាំងពួង ព្រះអគ្គ
ឧត្តមជាងសព្វសត្វ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មង្គលស្ស អបរេន** សេចក្ដីថា តមកខាង

ក្រោយសម័យនៃព្រះមានព្រះភាគមង្គលសម្ពុទ្ធ ។ បទថា **សព្វធម្មេហិ អសមោ** បានដល់ មិនមានបុគ្គលស្មើ មិនមានបុគ្គលដូច ដោយធម៌ គឺ សីល សមាធិ បញ្ញា សព្វយ៉ាង ។ បានឮថា ព្រះមានព្រះភាគសុមនសម្ពុទ្ធ ទ្រង់សម្រាំនៅ ៧ សប្តាហ៍ ក្បែរពោធិព្រឹក្ស ទ្រង់ទទួលពាក្យអារាធនារបស់ព្រហ្មដើម្បីសម្តែងធម៌ ទ្រង់ពិចារណាថា នឹងសម្តែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់ឃើញថា ជនដែលបួសជាមួយទ្រង់ ៣០ កោដិ ព្រះកនិដ្ឋភាតាមាតាដទៃនៃព្រះអង្គ ព្រះនាមសរណកុមារ និងបុត្តបុរោហិតឈ្មោះភាវិតត្តមាណព ជាអ្នកដល់ព្រមដោយឧបនិស្ស័យ ទ្រង់ព្រះតម្រិះថា នឹងសម្តែងធម៌ដល់ជនទាំងនោះមុន ទើបយាងទៅតាមអាកាស ចុះត្រង់មេខលឧទ្យាន ទ្រង់បញ្ជូនឧទ្យានបាលឲ្យទៅហៅសរណកុមារ ដែលជាប្អូនប្រុសមាតាដទៃរបស់ព្រះអង្គ និងភាវិតត្តមាណព បុត្តបុរោហិត ហើយទ្រង់ញ៉ាំងសត្វមួយសែនកោដិ គឺ បរិវាររបស់ជនទាំងនោះ ៣៧ កោដិ ជនដែលបួសជាមួយព្រះអង្គ ៣០ កោដិ ទេវតា និងមនុស្សដទៃៗ ច្រើនកោដិ ឲ្យផឹកនូវអមតធម៌ ដោយទ្រង់ប្រកាសធម្មចក្រ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលនោះ ព្រះអង្គទ្រង់ទូងស្គរ គឺអមតៈ ប្រកបដោយស័ង្ខ
គឺធម៌ជាសាសនារបស់ព្រះជិនស្រី មានអង្គ ៩ ក្នុងមេខល-
បុរី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អមតភេរឹ** បានដល់ ស្គរដើម្បីត្រាស់ដឹងនូវអមតៈ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ។ បទថា **អាហាតិ** បានដល់ ប្រគំ

អធិប្បាយថា សម្តែងធម៌ឈ្មោះអមតភេរីនោះ គឺពុទ្ធវចនៈមានអង្គ ៩ មានអមតៈជាទីបំផុត ដោយហេតុនោះឯង ទើបត្រាស់ថា ប្រកបដោយស័ទ្ធ គឺធម៌ជាសាសនារបស់ព្រះជិនស្រី មានអង្គ ៩ ។ ក្នុងបទទាំងនោះ បទថា **ធម្ម-សង្ខសមាយុត្តំ** បានដល់ ដែលប្រកបដោយស័ទ្ធដ៏ប្រសើរ គឺកថាពោលដោយសច្ចៈ ៤ ។

ព្រះសុមនសម្ពុទ្ធលោកនាយក ទ្រង់សម្រេចអភិសម្ពោធិញ្ញាណហើយ កាលទ្រង់បដិបត្តិបដិបទា ដែលសមគួរដល់បញ្ញា ក៏បានសាងអមតនគរដ៏ប្រសើរ មានសីលជារបងដ៏បរិបូណ៌ មានសមាធិជាគូទឹកព័ទ្ធជុំវិញ មានវិបស្សនាញាណជាទ្វារ មានសតិសម្បជញ្ញៈជាសន្ទះទ្វារដ៏រឹងមាំ ប្រដាប់ដោយមណ្ឌប គឺសមាបត្តិជាដើម ដេរដាសដោយជនជាចំណែកនៃពោធិញ្ញាណ ដើម្បីការពារនូវរតនៈ គឺកុសល ដែលពួកចោរ គឺកិលេសទាំងឡាយចាំប្លន់ ដើម្បីជាប្រយោជន៍ដល់ការដោះមហាជនឲ្យផុតចំណាំង គឺភព ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តាអង្គនោះ ទ្រង់ឈ្នះកិលេស ហើយសម្រេចនូវ
សម្ពោធិញ្ញាណដ៏ប្រសើរ ទ្រង់សាងនគរជាបុរី គឺព្រះសទ្ធម្ម
ដ៏ប្រសើរខ្ពង់ខ្ពស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និជ្ជិនិត្វា** បានដល់ ទ្រង់ឈ្នះបានជាសមុច្ឆេទ គឺទ្រង់គ្របសង្កត់ អធិប្បាយថា ទ្រង់កម្ចាត់កិលេសមារ និងទេវបុត្តមារ ។ បទថា **សោ** បានដល់ ព្រះមានព្រះភាគសុមនៈអង្គនោះ ។ បាឋៈថា **វិជិនិត្វា**

**កិលេសេហិ** ដូច្នេះក៏មាន ។ **ហិ** អក្ខរៈ ក្នុងបទថា **កិលេសេហិ** ត្រឹមតែជានិបាត ប្រើក្នុងអត្ថបទបូរណៈ ។ បទថា **បត្វា** បានដល់ ទ្រង់សម្រេចហើយ ។ បាឋៈថា **បត្តោ** ដូច្នេះក៏មាន ។ បទថា **ឆគរំ** បានដល់ នគរ គឺព្រះនិព្វាន ។ បទថា **សទ្ធម្មបុរវរុត្តមំ** បានដល់ នគរ ពោលសទ្ធម្មនគរឧត្តម ប្រសើរ ជាប្រធាន បណ្តានគរដ៏ប្រសើរទាំងឡាយ ។ ន័យម្យ៉ាងទៀត និព្វានជានគរដ៏ឧត្តម ក្នុងបណ្តានគរដែលប្រសើរ ដែលសម្រេចដោយព្រះសទ្ធម្ម ទើបឈ្មោះថា **សទ្ធម្មបុរ** ដ៏ប្រសើរខ្ពង់ខ្ពស់ ។ ក្នុងអត្ថវិកប្បដើមគប្បីឃើញថា ពាក្យថា **ឆគរំ** ជាវេវចនៈនៃព្រះនិព្វាននោះឯង ។

ព្រះនិព្វានជាទីតាំងនៃព្រះអរិយបុគ្គលទាំងឡាយ ដែលជាព្រះសេក្ខៈនិងអសេក្ខៈ ជាអ្នកចាក់ធ្លុះនូវសភាវធម៌ហើយ ។ លោកហៅថា **ឆគរំ** ព្រោះអត្ថថា ជាគោចរ និងជាលំនៅ ក្នុងសទ្ធម្មនគរដ៏ប្រសើរនោះ ព្រះសាស្តាអង្គនោះទ្រង់សាងមហាវិថីដែលសម្រេចដោយសតិប្បដ្ឋាន ដែលមិនដាច់ មិនវៀច ជាផ្លូវត្រង់ប្រកបកម្រាស់ ទាំងទទឹង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ព្រះអង្គទ្រង់សាងផ្លូវធំ មិនមានចន្លោះ ជាផ្លូវមិនវៀច ជាផ្លូវត្រង់ មានទទឹងដ៏ធំទូលាយ គឺសតិប្បដ្ឋានដ៏ប្រសើរខ្ពង់ខ្ពស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធិរន្តរំ** បានដល់ ឈ្មោះថា **ធិរន្តរំ** ព្រោះកុសលជវនចិត្តសញ្ចារទៅ មិនមានចន្លោះ ។ បទថា **អកុដិលំ** បានដល់

ឈ្មោះថា **អក្កុដិល** ព្រោះវៀរចាកទោសដែលធ្វើឲ្យវៀច ។ បទថា **ឧជុំ** បានដល់ ឈ្មោះថា **ឧជុំ** ព្រោះមិនវៀច ពាក្យនេះ ជាពាក្យសម្តែងសេចក្តីនៃបទដើម ។ បទថា **វិបុលវិត្ថតំ** បានដល់ ឈ្មោះថា **វិបុលវិត្ថតំ** ព្រោះវែងផង ធំទូលាយផង ការៈដែលសតិប្បដ្ឋានក្រាស់ផង ធំទូលាយផង គប្បីឃើញបានដោយសតិប្បដ្ឋានដែលជាលោកិយ និងលោកុត្តរ ។ បទថា **មហាវីថី** បានដល់ ផ្លូវធំ ។ បទថា **សតិប្បដ្ឋានវរុត្តមំ** សេចក្តីថា សតិប្បដ្ឋាននោះផង ឧត្តមក្នុងធម៌ដ៏ប្រសើរផង ហេតុនោះ ទើបឈ្មោះថា សតិប្បដ្ឋានដ៏ឧត្តមក្នុងធម៌ដ៏ប្រសើរ ។ ន័យម្យ៉ាងទៀត វិថីដ៏ឧត្តម ដែលសម្រេចដោយសតិប្បដ្ឋានដ៏ប្រសើរ ។

ឥឡូវនេះ ទ្រង់ក្រាលនូវរតនៈដែលមានតម្លៃច្រើនទាំងនេះ គឺសាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ សមាបត្តិ ៨ លើធម្មាបណៈ គឺផ្សារធម៌ទាំងសងខាង ត្រង់សតិប្បដ្ឋានវិថីនោះ នៃព្រះនិព្វានមហានគរនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះអង្គទ្រង់លាតសាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦
សមាបត្តិ ៨ ក្នុងផ្លូវនោះ ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងឧបាយជាគ្រឿងកាន់យកនូវរតនៈទាំងនោះ កុលបុត្តពួកណាមិនប្រមាទ មានសតិ ជាបណ្ឌិត ប្រកបព្រមដោយហិរិឱត្តប្បៈ និងវិរិយៈជាដើម កុលបុត្តអម្បាលម៉ាននោះ រមែងកាន់យកបាននូវទំនិញ គឺរតនៈទាំងនេះ ទើបព្រះមានព្រះភាគត្រាស់ថា

ពួកសត្វណា មិនមានសេចក្តីប្រមាទ មិនរឹងរូស ប្រកប
ដោយសេចក្តីខ្មាសបាប និងសេចក្តីព្យាយាម ពួកសត្វនោះៗ
តែងកាន់យកគុណដ៏ប្រសើរទាំងនេះតាមសប្បាយ ដូច្នេះ ។

ក្នុងគាថានោះ សព្ទថា **យេ** ជាឧទ្ទេស ដែលសម្តែងសេចក្តីមិនចំពោះ ។ បទថា **អប្បមត្តា** បានដល់ ប្រកបព្រមហើយ ដោយសេចក្តីមិនប្រមាទ ដែលជាបដិបក្ខចំពោះសេចក្តីប្រមាទ ដែលមានលក្ខណៈ គឺការមិនប្រាសចាកសតិ ។ បទថា **អខិលា** បានដល់ ប្រាសចាកចេតោខិល ៥ ប្រការ ។ បទថា **ហិរិវិរិយេហុបាគតា** មានវិគ្គហៈថា ឈ្មោះថា ហិរិ ព្រោះខ្មាសចំពោះកាយទុច្ចរិតជាដើម ពាក្យនេះ ជាឈ្មោះនៃការខ្មាស ។ ភាពនៃបុគ្គលក្លាហាន ឈ្មោះថា **វិរិយ** ។ វិរិយៈនោះមានការខ្នះខ្នែងជាលក្ខណៈ ភព្វបុគ្គលទាំងឡាយចូលដល់ហើយ ប្រកបព្រមហើយដោយហិរិ និងវិរិយៈទាំងនោះ ។ បទថា **តេ** នេះ ជាការសម្តែងចំពោះនៃការសម្តែងភាពដែលមិនចំពោះ ក្នុងពាក្យមុន ។

ម្យ៉ាងទៀត បទថា **តេ** សេចក្តីថា កុលបុត្តទាំងនោះ រមែងកាន់យកបាន រមែងបាន រមែងជួបនូវរតនៈ វិសេស គឺគុណដូចពោលហើយ ព្រះមានព្រះភាគសុមនៈ ទ្រង់ធ្វើនូវការដឹងច្បាស់ដោយផ្លូវចិត្តហើយ ទ្រង់ទូន្មានធម្មភេរី ទ្រង់សាងធម្មនគរ ទ្រង់ញុំាងសត្វមួយសែនកោដិឲ្យត្រាស់ដឹងមុនដោយន័យនេះ ។ នេះជាការត្រាស់ដឹងធម៌លើកទី ១ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តាទ្រង់ស្រោចស្រង់មហាជន ដោយសេចក្តីព្យាយាម
នោះ យ៉ាងនេះឯង បានញ៉ាំងសត្វមួយសែនកោដិ ឲ្យត្រាស់
ដឹងលើកទី ១ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្តរន្តោ** បានដល់ ទ្រង់លើកឡើងចាក សាគរ គឺសង្សារវដ្ត ដោយនាវា គឺអរិយមគ្គ ។ បទថា **កោដិសត-សហស្សិយោ** បានដល់ សត្វមួយសែនកោដិ ទ្រង់សម្តែងពាក្យដោយ បរិយាយ ដែលប្លែកចេញទៅ ។

ក្នុងសម័យណា ព្រះសុមនសម្ពុទ្ធលោកនាយក ទ្រង់សម្តែងយមក-បាដិហារ្យ ញាំញីនូវសេចក្តីស្រវឹង និងមានះរបស់តិរ្ថិយ នាគល់ស្វាយ ក្រុងសុនន្ទវតី ទ្រង់ញ៉ាំងសត្វមួយសែនកោដិឲ្យផឹកនូវអមតធម៌ នេះជាការ ត្រាស់ធម៌ដឹងលើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តាមានព្យាយាមច្រើន ទ្រង់ឲ្យឱវាទពួកតិរ្ថិយ ក្នុង
កាលណា កាលនោះ សត្វមួយសែនកោដិ ( បានសម្រេច
គុណវិសេស ) ក្នុងធម្មទេសនាលើកទី ២ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តិត្ថិយេ គណោ** បានដល់ គណៈដែលជា តិរ្ថិយ ឬគណៈរបស់តិរ្ថិយទាំងឡាយ ។ អាចារ្យពួកខ្លះពោលថា **តិត្ថិយេ អភិមទ្ទន្តោ ពុទ្ធោ ធម្មទេសយិ** ព្រះពុទ្ធកាលទ្រង់ផ្ចាញ់ពួកតិរ្ថិយ ទ្រង់ក៏ សម្តែងធម៌ ។

សម័យណា ទេវតា និងមនុស្សក្នុងម៉ឺនចក្កវាឡប្រជុំគ្នា ក្នុងចក្កវាឡ

នេះ តាំងរឿងនិរោធឡើងថា លោកចូលនិរោធដូចម្ដេច ដល់ព្រមដោយនិរោធដូចម្ដេច ចេញអំពីនិរោធដូចម្ដេច ទេវតាក្នុងកាមាវចរទេវលោក ៨ ជាន់ ព្រហ្មក្នុងព្រហ្មលោក មួយអន្លើដោយមនុស្សទាំងឡាយ មិនអាចវិនិច្ឆ័យក្នុងការចូល ការតាំងនៅ និងការចេញចាកសមាបត្តិជាដើមបានយ៉ាងនេះ ទើបបែកគ្នាជា ២ ពួក បន្ទាប់អំពីនោះ ព្រះរាជាព្រះនាមអរិន្ទមៈដ៏ប្រសើរជាងនរៈនាំគ្នាទៅគាល់ព្រះសុមនទសពលដែលជាលោកនាថ ក្នុងវេលាល្ងាច ។ ព្រះបាទអរិន្ទមៈ កាលចូលគាល់ហើយ ទើបទូលនិរោធបញ្ហានឹងព្រះដ៏មានព្រះភាគ បន្ទាប់អំពីនោះ កាលព្រះមានព្រះភាគទ្រង់ឆ្លើយនូវនិរោធបញ្ហាហើយ ការត្រាស់ដឹង ក៏មានដល់សត្វ ៩ ម៉ឺនកោដិ ។ នេះជាការត្រាស់ដឹងធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ពួកទេវតា និងមនុស្ស មានសេចក្ដីព្រមព្រៀងគ្នា មានចិត្តស្រួលបួល សួរប្រស្នាក្នុងនិរោធផង សេចក្ដីសង្ស័យផង សេចក្ដីប្រាថ្នាក្នុងចិត្តផង ក្នុងកាលណា កាលនោះ ពួកសត្វ ៩០ ពាន់កោដិ បានសម្រេចមគ្គផលលើកទី ៣ ក្នុងធម្មទេសនាជាគ្រឿងបំភ្លឺនូវនិរោធ ដូច្នេះ ។

ព្រះមានព្រះភាគសុមនៈ ទ្រង់មានសាវកសន្និបាត ៣ លើក សាវកសន្និបាតលើកទី ១ ព្រះមានព្រះភាគ និងព្រះអរហន្តមួយពាន់កោដិ[១] ដែលបួសដោយឯហិភិក្ខុបព្វជ្ជា ទ្រង់អាស្រ័យមេខលនគរ ទ្រង់ចាំវស្សាហើយ

---

១- បិដកខ្មែរជា ១ សែនកោដិ ។

ទ្រង់ក៏បវារណាដោយបឋមបវារណា នេះជាសាវកសន្និបាតលើកទី ១ គ្រាក្រោយមក ព្រះមុនីប្រសើរដូចព្រះអាទិត្យ ប្រថាប់គង់លើភ្នំមាសប្រមាណ ១ យោជន៍ ដែលកើតឡើងដោយកម្លាំងកុសលរបស់ព្រះបាទអរិន្ទម: មិនឆ្ងាយអំពីសង្កស្សនគរ ដូចព្រះទិន្នករជះរស្មីដ៏ស្រទន់ក្នុងសារទរដូវ លើភ្នំយុគន្ធរ ទ្រង់ទូន្មានបុរស ៩ ម៉ឺនកោដិដែលចោមរោមអរិន្ទម: ទ្រង់ឲ្យជនទាំងនោះ បួសដោយឯហិភិក្ខុគ្រប់រូប ពួកភិក្ខុដែលសម្រេចអរហត្តក្នុងថ្ងៃនោះឯងចោមរោមហើយ ទ្រង់លើកបាតិមោក្ខសម្តែងក្នុងសន្និបាតដែលប្រកបដោយអង្គ ៤ នេះជាសន្និបាតលើកទី ២ ។ សម័យណា សក្កទេវរាជចូលទៅគាល់ព្រះសុគត សម័យនោះ ព្រះមានព្រះភាគសុមន: ដែលព្រះអរហន្ត ៨ ម៉ឺនកោដិចោមរោមហើយ ទ្រង់ក៏លើកបាតិមោក្ខឡើងសម្តែង នេះជាសាវកសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវក-
សន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព ប្រាស
ចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ ទាំងមានចិត្តនឹងធឹង ។ កាល
ព្រះមានព្រះភាគទ្រង់ចេញវស្សាហើយ កាលភិក្ខុសង្ឃប្រកាស
បវារណាហើយ ព្រះតថាគតទ្រង់បវារណា ដោយភិក្ខុចំនួន
មួយសែនកោដិ ( នេះជាសន្និបាតលើកទី ១ ) ។ ក្នុងការប្រជុំ
ដទៃអំពីនោះមក មានសន្និបាតលើកទី ២ នៃព្រះខីណាស្រព
៩០ ពាន់កោដិ លើកញ្ចនបព៌ត មិនមានមន្ទិល ។ កាល

សក្កទេវរាជចូលមកគាល់ព្រះសម្ពុទ្ធ ជាសន្និបាតលើកទី ៣ របស់ព្រះខីណាស្រព ៨០ ពាន់កោដិ ដូច្នេះ ។

គប្បីឃើញលិង្គវិបល្លាសក្នុងពាក្យថា **អភិឃុត្ថេ បវារណេ** ក្នុងគាថានោះ សេចក្តីថា **អភិឃុត្ថាយ បវារណាយ** កាលទ្រង់ប្រកាសបវារណាហើយ ។ បទថា **តតោ បរំ** បានដល់ ក្នុងសម័យបន្ទាប់អំពីសន្និបាតលើកទី ១ នោះ ។ បទថា **កញ្ចនបព្វតេ** បានដល់ ត្រង់ភ្នំដែលសម្រេចដោយមាស ។ បទថា **ពុទ្ធទស្សនុបាគមិ** បានដល់ ចូលទៅដើម្បីគាល់ព្រះពុទ្ធ ។

បានឮថា គ្រានោះ ព្រះពោធិសត្វនៃយើង ជាស្តេចនាគឈ្មោះអតុលៈ មានឫទ្ធានុភាពច្រើន នាគបានដំណឹងថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ដែលពួកញាតិចោមរោមហើយ ចេញអំពីភពរបស់ខ្លួន បូជាព្រះមានព្រះភាគសុមនៈ ដែលមានភិក្ខុមួយសែនកោដិជាបរិវារ ដោយតន្ត្រីទិព្វ ថ្វាយមហាទាន ថ្វាយនូវគូសំពត់ មួយអង្គមួយគូ ហើយតាំងនៅក្នុងសរណៈ ព្រះសាស្តាអង្គនោះ ទ្រង់ព្យាករនាគនោះថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងសម័យនោះ តថាគតកើតជាស្តេចនាគ មានឫទ្ធិច្រើន មាន
ឈ្មោះថាអតុលៈ ជាអ្នកសន្សំកុសល ។ កាលនោះ តថាគត
ចេញអំពីភពនាគ ជាមួយនឹងពួកញាតិ បានទៅបម្រើព្រះ
ជិនស្រី ព្រមទាំងព្រះសង្ឃ ដោយតន្ត្រីជាទិព្វ របស់នាគ ។
តថាគត បានញុំាងព្រះភិក្ខុសង្ឃមួយសែនកោដិ ឲ្យឆ្អែតស្កប់

ស្អាប់ដោយបាយទិព្វ ហើយថ្វាយសំពត់មួយគូៗ មួយអង្គ ហើយយកព្រះភិក្ខុសង្ឃនោះជាទីពឹង ។ ព្រះសម្ពុទ្ធ ព្រះនាម សុមនៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុង កប្បមានប្រមាណមិនបាន អំពីកប្បនេះ នាគរាជនេះ នឹងបាន ត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ទៅតម្កល់សេចក្តីព្យាយាម ។បេ។ ក្នុងកាលជា អនាគតមិនខាន ។ ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គ នេះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ដូច្នេះ ។

គប្បីពោល ១៨ គាថាឲ្យពិស្តារ ដូចក្នុងវង្សរបស់ព្រះកោណ្ឌញ្ញសម្ពុទ្ធ ផងចុះ ។

តថាគត បានស្តាប់ព្រះតម្រាស់របស់ព្រះសម្ពុទ្ធនោះហើយ ក៏ ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៀត ដោយ ការបំពេញបារមី ១០ ដូច្នេះ ។

ព្រះមានព្រះភាគសុមនៈអង្គនោះ ទ្រង់មាននគរឈ្មោះមេខលៈ មាន ព្រះជនកព្រះនាមព្រះបាទសុទត្តៈ មានព្រះជននីព្រះនាមសិរិមាទេវី គូនៃអគ្គ-សាវកឈ្មោះសរណៈ ១ ភាវិតត្តៈ ១ ពុទ្ធុបដ្ឋាកឈ្មោះឧទេន គូអគ្គសាវិកា

ឈ្មោះសោណា ១ ឧបសោណា ១ មានដើមនាគ គឺដើមខ្ទឹងជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៩០ ហត្ថ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ព្រះមហេសីព្រះនាមវដំសិកាទេវី ព្រះឱរសព្រះនាមអនូបមៈ ទ្រង់ចេញអភិនេស្ក្រមណ៍ដោយយានដំរី មានពុទ្ធុបដ្ឋាកឈ្មោះអង្គរជា គង់ប្រថាប់នៅត្រង់វិហារឈ្មោះអង្គារាម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានទីក្រុងឈ្មោះមេខលៈ មានមហាក្សត្រព្រះនាមសុទត្តៈជាព្រះបិតា មានព្រះមាតាព្រះនាមសិរិមា ។ ព្រះអង្គគ្រប់គ្រងព្រះរាជដំណាក់អស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺចន្ទប្រាសាទ ១ សុចន្ទប្រាសាទ ១ វដំសប្រាសាទ ១ ។ ពួកនារី ៦៣ សែននាក់ មានរូបប្រដាប់សមរម្យ នារី ( ជាអគ្គមហេសី ) ព្រះនាមវដំសកី ព្រះរាជបុត្រព្រះនាមអនូបមៈ ។ ព្រះជិនស្រីឃើញនិមិត្ត ៤ ហើយ ទ្រង់ចេញបព្វជ្ជាដោយយានដំរី ទ្រង់តាំងសេចក្តីព្យាយាមអស់ ១០ ខែឥតខ្វះ ។ ព្រះលោកនាយកព្រះនាមសុមនៈ មានព្រះហឫទ័យស្ងប់រម្ងាប់ ទ្រង់មានចក្កប្រព្រឹត្តទៅ មានព្យាយាម ជំត្រូវព្រហ្មអារាធនាក្នុងមេខលបុរីដ៏ប្រសើរខ្ពង់ខ្ពស់ ។ ព្រះថេរៈឈ្មោះសរណៈ ១ ភាវិតត្តៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះឧទេនជាឧបដ្ឋាក របស់ព្រះសម្ពុទ្ធព្រះនាមសុមនៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរី

ឈ្មោះសោណា ១ ឧបសោណា ១ ជាអគ្គសាវិកា ព្រះសម្ពុទ្ធនោះ ស្មើដោយព្រះពុទ្ធដែលឥតមានបុគ្គលស្មើ ទ្រង់បានត្រាស់ដឹងទៀបគល់នាគព្រឹក្ស ។ ឧបាសកឈ្មោះវរុណៈ ១ សរណៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះចាលា ១ ឧបចាលា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៩០ ហត្ថ មានលម្អនៃព្រះរូបប្រហែលដូចគ្រឿងបូជាមាស ទ្រង់រុងរឿងក្នុងមួយម៉ឺនលោកធាតុ ។ ព្រះជន្មាយុ ( របស់ព្រះអង្គ ) ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ស្ថិតនៅជរាបនោះ ទ្រង់ញ៉ាំងប្រជុំច្រើនឲ្យឆ្លង ( វដ្ដសង្សារ ) ។ ព្រះសម្ពុទ្ធ ទ្រង់ចម្លងពួកសត្វដែលគួរចម្លង ទ្រង់បានដាស់តឿនពួកសត្វ ដែលគួរដាស់តឿន ហើយទ្រង់បរិនិព្វាន ដូចព្រះចន្ទអស្តង្គត ។ ភិក្ខុទាំងឡាយនោះ ជាព្រះខីណាស្រពក្តី ព្រះសម្ពុទ្ធអង្គនោះក្តី ទ្រង់មិនមានបុគ្គលណាស្មើ ទ្រង់បញ្ចេញរស្មីឥតប្រៀបផ្ទឹមបាន ព្រះខីណាស្រព មានយសច្រើនទាំងនោះ និព្វានហើយ ។ ព្រះញាណនោះ ជាគុណឥតមានអ្វីប្រៀបបានផង រតនៈទាំងនោះ ឥតអ្វីប្រៀបបានផង របស់ទាំងអស់នេះ វិនាសសូន្យទៅ សង្ខារទាំងពួងជារបស់ទទេពិត ។ ព្រះសុមនសម្ពុទ្ធទ្រទ្រង់យស ទ្រង់បរិនិព្វានក្នុងអង្គារាម ព្រះស្តូបរបស់ជិនស្រីអង្គនោះ មានកម្ពស់ ៤ យោជន៍

ប្រតិស្ឋាននៅក្នុងអារាមនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កញ្ចនគ្ឃិយសង្កាសោ** បានដល់ មានព្រះរូបឆោម ល្អដូចរូបដែលគេបូជាធ្វើដោយមាស វិចិត្រដោយរតនៈច្រើនប្រភេទ ។ បទថា **ទសសហស្សី វិរោចតិ** សេចក្ដីថា ទាំងម៉ឺនលោកធាតុរុងរឿងដោយរស្មីរបស់ព្រះអង្គ ។ បទថា **តារណីយេ** បានដល់ ញ៉ាំងពួកជនដែលគួរឲ្យឆ្លង គឺអ្នកគួរឆ្លង អធិប្បាយថា ពុទ្ធវេនេយ្យទាំងពួង ។ បទថា **ឧឡុរាជាវ** បានដល់ ដូចព្រះចន្ទ ។ បទថា **អត្ថមិ** បានដល់ រលត់ទៅ ។ អាចារ្យពួកខ្លះពោលថា **អត្ថំ គតោ** ដល់នូវការតាំងនៅមិនបាន ដូច្នេះក៏មាន ។ បទថា **អសាទិសោ** ក៏គឺ **អសទិសោ** ជាអ្នកមិនមានបុគ្គលដូច ។ បទថា **មហាយសា** បានដល់ ជាអ្នកមានកិត្តិសព្ទច្រើន និងមានបរិវារច្រើន ។ បទថា **តញ្ច ញាណំ** បានដល់ សព្វញ្ញុតញ្ញាណនោះ ។ បទថា **អតុលិយំ** បានដល់ វាស់វែងមិនបាន មិនមានអ្វីដូច ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថយល់ទាំងអស់ហើយ ។៚

## អដ្ឋកថាសុមនពុទ្ធវង្សទី ៤ ចប់

# សុត្តន្តបិដក

## រេវតពុទ្ធវង្សទី ៥

[ ៦ ] កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមសុមនៈមក មានព្រះលោកនាយកព្រះនាមរេវតៈ មិនមានបុគ្គលប្រៀប មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រឹងបាន ព្រះអង្គឧត្តម ទ្រង់ឈ្នះពួកមារ ។ ព្រះសម្ពុទ្ធអង្គនោះ លុះមហាព្រហ្មអារាធនាហើយ ទ្រង់ប្រកាសធម៌ ដ៏កំណត់ដោយខន្ធ និងធាតុ ជាធម៌មិនប្រព្រឹត្តទៅក្នុងភពតូចភពធំ ។ ក្នុងការសម្ដែងធម៌នៃព្រះរេវតសម្ពុទ្ធនោះ មានការត្រាស់ដឹងមគ្គផល ៣ លើក គឺការត្រាស់ដឹងលើកទី ១ មិនគប្បីពោលដោយការរាប់ចំនួនបាន ។ ព្រះមហាមុនី ព្រះនាមរេវតៈ ទ្រង់ទូន្មានព្រះបាទអរិន្ទមៈក្នុងកាលណា កាលនោះ ពួកសត្វមួយពាន់កោដិ បានត្រាស់ដឹងមគ្គផលលើកទី ២ ។ ព្រះនរាសភៈ ទ្រង់ក្រោកចាកទីពួនសម្ងំអស់ ៧ ថ្ងៃ ហើយទូន្មានពួកមនុស្ស និងទេវតាមួយរយកោដិ ( ឲ្យតាំងនៅ ) ក្នុងផលដ៏ឧត្តមលើកទី ៣ ។ ព្រះសម្ពុទ្ធព្រះនាមរេវតៈ ទ្រង់ស្វែងរកគុណធំ មានសាវកសន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះហឫទ័យរួចស្រឡះដោយប្រពៃ មានចិត្តនឹងធឹង គឺសន្និបាតលើកទី ១ កន្លងផុតផ្លូវនៃការរាប់ ( រាប់ពុំបាន ) សន្និបាតលើកទី ២ មានព្រះអរហន្តមួយសែនកោដិ ។ ព្រះអគ្គសាវកអង្គណា រកបុគ្គលស្មើគ្មានដោយប្រាជ្ញា ជាអ្នក

ប្រព្រឹត្តតាមធម្មចក្កនៃព្រះសម្ពុទ្ធអង្គនោះ កាលនោះ ព្រះអគ្គ-សាវកនោះ មានព្យាធិ ដល់នូវការសង្ស័យក្នុងជីវិត ។ កាលនោះ ពួកព្រះអរហន្តចូលទៅគាល់ព្រះមុនី ដើម្បីសាកសួរអាពាធរបស់ព្រះអគ្គសាវកនោះ មានចំនួនមួយសែនកោដិ នេះជាសន្និបាតលើកទី ៣ ។ សម័យនោះ តថាគតកើតជាព្រាហ្មណ៍ឈ្មោះអតិទេវៈ បានចូលទៅគាល់ព្រះរេវតសម្ពុទ្ធ ហើយបានយកព្រះអង្គជាទីពឹង ។ តថាគតបានសរសើរ សីល សមាធិ និងបញ្ញាគុណដ៏ប្រសើររបស់ព្រះអង្គ ហើយបានថ្វាយសំពត់ឧត្តរាសង្គៈតាមកម្លាំង ។ ព្រះសម្ពុទ្ធព្រះនាមរេវតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ ព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្សទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេបានចាត់ចែង ។ លំដាប់អំពីនោះមក ព្រះទ្រង់យសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតនៃព្រះសម្ពុទ្ធអង្គនេះ ព្រះនាម

មាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រាហ្មណ៍នេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទនឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំនឹងជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់យសអង្គនោះ មានព្រះជន្ម ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយត្រេកអរថា ព្រាហ្មណ៍នេះ នឹងបានជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុ ស្រែកហ៊ោឡើងផងទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា ពួកយើង បើឃ្លាងមគ្គផលក្នុងសាសនារបស់ព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ

គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានជួបក្នុងទីចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះតម្រាស់របស់ព្រះសម្ពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យត្រេកអរក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។ កាលនោះ តថាគតនឹកឃើញ ហើយបានអប់រំពុទ្ធការកធម៌នោះ ទាំងបានបំពេញនូវពុទ្ធការកធម៌នោះ តាមគួរដល់សេចក្តីប្រាថ្នានៃតថាគត ។ ព្រះរេវតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានទីក្រុងឈ្មោះសុធញ្ញកៈ មានព្រះមហាក្សត្រ ព្រះនាមវិបុលៈជាព្រះបិតា មានព្រះមាតាព្រះនាមវិបុលា ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងព្រះរាជដំណាក់អស់ ៦ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ ដែលកើតដោយបុញ្ញកម្មមាន ៣ គឺសុទស្សនប្រាសាទ ១ រតនគ្ឃិប្រាសាទ ១ អាវេឡប្រាសាទ ១ ដែលគេស្អិតស្អាងហើយ ។ ពួកនារី ៣៣ សែននាក់ មានរូបតាក់តែងសមរម្យ ឯនារីជាអគ្គមហេសី ព្រះនាមសុទស្សនា មានព្រះរាជបុត្រព្រះនាមវរុណៈ ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាងហើយ ទ្រង់ចេញបព្វជ្ជាដោយរថយានហើយតាំងសេចក្តីព្យាយាមអស់ ៧ ខែឥតខ្វះ ។ ព្រះសម្ពុទ្ធទ្រង់ព្រះនាមរេវតៈ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់

ទ្រង់ញុំាងចក្រឲ្យប្រព្រឹត្តទៅ ទ្រង់មានព្យាយាមច្រើន ទ្រង់ឈ្នះមារ ត្រូវមហាព្រហ្មអារាធនាហើយ ទ្រង់គង់នៅក្នុងវរុណារាម ។ ព្រះថេរៈឈ្មោះវរុណៈ ១ ព្រហ្មទេវៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះសម្ភវៈជាឧបដ្ឋាក របស់ព្រះរេវតៈសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះភទ្ទា ១ សុភទ្ទា ១ ជាអគ្គសាវិកា ឯព្រះសម្ពុទ្ធឥតមានបុគ្គលស្មើអង្គនោះ ទ្រង់បានត្រាស់ដឹងទៀបដើមខ្នឹង ។ ឧបាសកឈ្មោះវរុណៈ ១ សរភៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះបាលា ១ ឧបបាលា ១ ជាអគ្គឧបដ្ឋាកយិកា ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ព្រះអង្គ ៨០ ហត្ថ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺរុងរឿង ដូចទង់ជ័យរបស់ព្រះឥន្ទដ៏ខ្ពង់ខ្ពស់ ។ កម្រងរស្មីដ៏ប្រសើរ កើតក្នុងសរីរៈនៃព្រះអង្គ ផ្សាយចេញមួយយោជន៍ជុំវិញ ទាំងថ្ងៃទាំងយប់ ។ ព្រះសម្ពុទ្ធអង្គនោះមានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើនឲ្យឆ្លង ( ចាកវដ្តសង្សារ ) ។ ព្រះសម្ពុទ្ធទ្រង់សម្តែងកម្លាំងនៃព្រះពុទ្ធហើយ ទ្រង់ប្រកាសអមតធម៌ ក្នុងលោក ព្រះអង្គមិនមានសេចក្តីប្រកាន់ ទ្រង់បរិនិព្វាន

ព្រោះអស់ឧបាទាន ដូចភ្លើងដែលអស់កំញម ។ ព្រះកាយរបស់ព្រះអង្គនោះ មានពណ៌ដូចកែវ ព្រះធម៌របស់ព្រះអង្គ មិនមានអ្វីស្មើដូចទេ របស់ទាំងអស់ វិនាសសូន្យទៅ សង្ខារទាំងពួងទទេពិត ។ ព្រះរេវតសម្ពុទ្ធទ្រទ្រង់យសអង្គនោះ ទ្រង់មានបុណ្យច្រើន ទ្រង់បរិនិព្វានហើយ ព្រះធាតុរបស់ព្រះអង្គ បានសាយកាយទៅក្នុងប្រទេសនោះ ដោយចំណែកៗ ។

រេវតពុទ្ធវង្សទី ៥ ចប់

# អដ្ឋកថា

## រេវតពុទ្ធវង្សទី ៥

សម័យខាងក្រោយ នៃព្រះមានព្រះភាគសុមនៈ កាលសាសនារបស់ព្រះអង្គអន្តរធានទៅហើយ ពួកមនុស្សដែលមានអាយុ ៩ ម៉ឺនឆ្នាំ ក៏ថយចុះទៅដោយលំដាប់ រហូតដល់អាយុ ១០ ឆ្នាំ ហើយឡើងដោយលំដាប់ រហូតដល់មានអាយុមួយអសង្ខេយ្យហើយ ក៏ថយចុះវិញ រហូតមានអាយុ ៦ ម៉ឺនឆ្នាំ ។ សម័យនោះ ព្រះសាស្ដាព្រះនាមថារេវតៈទ្រង់កើតឡើង ។ ទ្រង់បំពេញបារមីទាំងឡាយហើយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ដែលជាភពរុងរឿងដោយរតនៈច្រើន ។ ចុតិចាកស្ថានសួគ៌ជាន់តុសិតនោះហើយ ទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងវិបុលា បរិបូណ៌ដោយគុណរាសីដ៏ល្អគួរចាប់ចិត្ត ដែលជាទីផ្ដោតចក្ខុនៃជនទាំងពួង រុងរឿងដោយលម្អ ដែលកើតអំពីមុខនិងហទយៈដ៏មានសិរី ដូចផ្កាឈូករីកត្រកាល អគ្គមហេសីក្នុងរាជត្រកូលរបស់ព្រះបាទវិបុលរាជ បរិបូណ៌ដោយភាពស្អុកស្កម្ភគ្រប់យ៉ាង ដែលដេរដាសដោយហេតុកើតនៃសិរីសម្បត្តិ ព្រះនាងចោមរោមដោយរាជបរិវារដ៏ល្អប្រមាណមិនបាន ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ក្នុងក្រុងសុធញ្ញវតីដែលមានទ្រព្យ និងស្រូវច្រើន ។ គ្រប់កំណត់ទសមាស ក៏ប្រសូតចាកផ្ទៃរបស់ព្រះជននី ដូចស្ដេចហង្សមាស ហើរចេញអំពីចិត្រកូដបព៌ត ។

បាដិហារ្យទាំងឡាយ ក្នុងបដិសន្ធិ និងប្រសូតរបស់ព្រះអង្គ ក៏មានន័យដូចពោលមកហើយខាងដើម ។ ទ្រង់មានប្រាសាទ ៣ ខ្នង ឈ្មោះសុទស្សនៈ ១ រតនគ្ឃិ ១ អាវេឡៈ ១ មានស្ត្រីចំនួន ៣ ម៉ឺន ៣ ពាន់ ដែល

មានព្រះនាងសុទស្សនាទេវីជាប្រធានក៏ប្រាកដ ។ ព្រះរេវតរាជកុមារនោះ ដែលពួកស្ត្រីចោមរោមហើយ ដូចទេវកុមារដែលពួកយុវទេពធីតាចោមរោមហើយ ទ្រង់នៅជាយរាវាសវិស័យ សោយលោកិយសុខ ៦ ពាន់ឆ្នាំ កាលព្រះរាជឱរសព្រះនាមវរុណៈរបស់ព្រះនាងសុទស្សនាទេវីប្រសូត ទ្រង់ឃើញនិមិត្ត ៤ ហើយទ្រង់ស្លៀកដណ្តប់នូវសំពត់យ៉ាងល្អ មានពណ៌ផ្សេងៗ ទ្រង់ពាក់កុណ្ឌលមណីមុក្តាហារ ទ្រទ្រង់នូវគ្រឿងប្រដាប់ដៃ មកុដ និងកងដៃយ៉ាងល្អ ទ្រង់ប្រដាប់ដោយគ្រឿងប្រអប់ និងផ្កាកម្រង ដែលមានក្លិនក្រអូបក្រៃលែង ធ្វើនូវលម្អយ៉ាងក្រៃលែង ដូចព្រះចន្ទក្នុងសរទរដូវ ដែលចតុរង្គសេនាធំចោមរោមហើយ ដូចព្រះចន្ទដែលហ្វូងផ្កាយចោមរោម ដូចស្តេចសហស្សនេត្រដែលពួកទេវតាស្ថានត្រៃត្រិង្សហែហមហើយ និងដូចស្តេចហារិតមហាព្រហ្មដែលពួកព្រហ្មចោមរោមហើយ ទ្រង់ចេញអភិនេស្រ្កមណ៍ ដោយរថដែលទឹមដោយសេះ ទ្រង់ដោះនូវគ្រឿងអាភរណៈសព្វយ៉ាង ប្រទានក្នុងដៃកណ្ឋគារិក ទ្រង់កាត់ព្រះកេសា និងព្រះមោលីរបស់ព្រះអង្គ ដោយកាំបិតដែលសំលៀងល្អហើយ ដូចគ្នានឹងកាត់ស្រទាប់ផ្កាឈូក ដែលកើតក្នុងទឹក ដែលឥតមន្ទិល មិនវិកល ហើយទ្រង់បោះទៅក្នុងអាកាស សក្កទេវរាជទ្រង់យកប្រអប់មាសមកទទួលព្រះកេសា និងព្រះមោលីនោះ ទ្រង់នាំទៅកាន់ស្ថានតាវត្តិង្ស សាងចេតិយសម្រេចដោយរតនៈ ៧ ប្រការ លើកំពូលភ្នំសិនេរុ ។

ឯព្រះមហាបុរស ទ្រង់ស្លៀកសំពត់កាសាវៈដែលទេវតាថ្វាយ ហើយទ្រង់ព្រះផ្នួស ។ បុរសមួយកោដិក៏បួសតាមព្រះអង្គ ។ មហាបុរសនោះដែល

បុរសទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាម ៧ ខែ ក្នុងថ្ងៃវិសាខ-បុណ្ណមី សោយមធុបាយាសដែលសេដ្ឋីធីតាម្នាក់ ឈ្មោះសាធុទេវីប្រគេន ហើយទ្រង់សម្រាកពេលថ្ងៃក្នុងព្រៃសាលវ័ន វេលាល្ងាចទ្រង់ទទួលស្មៅ ៨ ក្ដាប់ ដែលអាជីវកម្នាក់ប្រគេន ទ្រង់ចូលទៅកាន់គល់នាគព្រឹក្សដ៏ប្រសើរ ដែលគួរជាទីត្រេកអរ ទ្រង់ធ្វើប្រទក្សិណពោធិព្រឹក្ស ទ្រង់លាតសន្ថ័តស្មៅទំហំ ៥៣ ហត្ថ ហើយគង់ប្រថាប់ អធិដ្ឋានសេចក្ដីព្យាយាមដែលប្រកបដោយអង្គ ៤ ទ្រង់កម្ចាត់មារ ព្រមទាំងសេនា ទ្រង់ត្រាស់ដឹងនូវសព្វញ្ញុ-តញ្ញាណ ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វរល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ដ មានជាតិដ៏ច្រើន ។បេ។ ហើយតថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលខាងក្រោយអំពីព្រះសម្ពុទ្ធព្រះនាមសុមនៈមក មានព្រះលោកនាយកព្រះនាមរេវតៈ មិនមានបុគ្គលប្រៀប មិនមានបុគ្គលស្មើ មិនមានបុគ្គលប្ដឹងបាន ព្រះអង្គឧត្តម ទ្រង់ឈ្នះពួកមារ ដូច្នេះ ។

បានឮថា ព្រះរេវតសាស្ដា ទ្រង់សម្ងំនៅក្នុងទីជិតពោធិព្រឹក្សនោះឯង

៧ សប្តាហ៍ ទ្រង់ទទួលពាក្យអារាធនារបស់មហាព្រហ្ម ដើម្បីទ្រង់សម្តែងធម៌ ទ្រង់ពិចារណាថា តថាគតនឹងសម្តែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់ឃើញភិក្ខុមួយកោដិដែលបួសជាមួយព្រះអង្គ ទេវតា និងមនុស្សដទៃជាច្រើនដែលដល់ព្រមដោយឧបនិស្ស័យ ទើបទ្រង់យាងទៅតាមអាកាស ទ្រង់ចុះត្រង់ព្រះវិហារវរុណារាម ដែលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ដែលជាធម៌ល្អិតជ្រាលជ្រៅ មានបរិវដ្ត ៣ ដែលអ្នកដទៃជំទាស់មិនបាន ទ្រង់ញ៉ាំងភិក្ខុមួយកោដិឲ្យតាំងនៅក្នុងអរហត្ត ដែលតាំងនៅក្នុងមគ្គ ៣ ផល ៣ កំណត់ចំនួនរាប់មិនអស់ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

> ព្រះសម្ពុទ្ធអង្គនោះ លុះមហាព្រហ្មអារាធនាហើយ ទ្រង់ប្រកាសធម៌ដ៏កំណត់ដោយខន្ធ និងធាតុ ជាធម៌មិនប្រព្រឹត្តទៅក្នុងភពតូចភពធំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខន្ធធាតុវវត្ថានំ** បានដល់ ធ្វើនូវការបែកខន្ធ ៥ ធាតុ ១៨ ដោយកំណត់នាមរូបជាដើម ។ ការកំណត់រូបធម៌ និងអរូបធម៌ ដោយសភាវលក្ខណៈ និងសាមញ្ញលក្ខណៈជាដើម ឈ្មោះថាកំណត់ខន្ធ និងធាតុ ។ ម្យ៉ាងទៀត គប្បីជ្រាបការកំណត់ខន្ធ និងធាតុ ដោយអនិច្ចានុបស្សនាជាដើម ដោយន័យជាដើមយ៉ាងនេះថា រូប ប្រៀបដូចដុំពពុះទឹក ព្រោះមិនអត់ធន់ចំពោះការញាំញី និងព្រោះបែកធ្លាយជាលម្អិតតូចធំជាដើម វេទនា ប្រៀបដូចក្រពេញទឹក ព្រោះត្រេកអរមួយឆ្អូវខណៈ សញ្ញា

ប្រៀបដូចថ្ងៃបណ្តើរកូន ព្រោះបោកបញ្ឆោតក្មេក សង្ខារទាំងឡាយ ប្រៀបដូចដើមចេក ព្រោះមិនមានខ្លឹម វិញ្ញាណ ប្រៀបដូចអ្នកលេងកលមាយា ព្រោះបោកបញ្ឆោត ។ ក្នុងពាក្យនេះថា **អប្បវត្តំ ភវាភវេ** មានវិនិច្ឆ័យថា សេចក្តីចម្រើន ឈ្មោះថា **ភវ** សេចក្តីវិនាស ឈ្មោះថា **អភវ** ។ គប្បីជ្រាបសេចក្តីនៃ **ភវ** និង **អភវ** ដោយន័យជាដើមយ៉ាងនេះថា សស្សតទិដ្ឋិ ឈ្មោះថា **ភវ** ឧច្ឆេទទិដ្ឋិ ឈ្មោះថា **អភវ** ។ ភពតូច ឈ្មោះថា **ភវ** ភពធំ ឈ្មោះថា **អភវ** ។ កាមភព ឈ្មោះថា **ភវ** រូបភព និងអរូបភព ឈ្មោះថា **អភវ** អធិប្បាយថា ទ្រង់ប្រកាសធម៌ដែលជាហេតុមិនប្រព្រឹត្តទៅនៃភវៈ និងអភវៈទាំងនោះ ។ ន័យម្យ៉ាងទៀត ឧបបត្តិនិមិត្តក្នុងភពទាំង ៣ មានកម្មជាដើម ឈ្មោះថា **ភវ** ព្រោះជាគ្រឿងមាន ។ ឧបបត្តិភព ឈ្មោះថា **អភវ** អធិប្បាយថា ទ្រង់សម្តែងធម៌ដែលធ្វើនូវការលះ គឺមិនប្រព្រឹត្តទៅនៃសេចក្តីត្រេកអរក្នុងធម៌ទាំង ២ គឺភវៈ និងអភវៈ ។ ព្រះរេវតសម្ពុទ្ធអង្គនោះ មានការត្រាស់ដឹងធម៌ ៣ លើកដូចគ្នា តែការត្រាស់ដឹងធម៌លើកទី ១ របស់ព្រះអង្គហួសនឹងរាប់ចំនួន របស់អ្នកត្រាស់ដឹង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ក្នុងការសម្តែងធម៌នៃព្រះរេវតសម្ពុទ្ធនោះ មានការត្រាស់ដឹងមគ្គផល ៣ លើក គឺ ការត្រាស់ដឹងលើកទី ១ មិនគប្បីពោលដោយការរាប់ចំនួនបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តីណិ** គឺ **តយោ** លោកធ្វើជាលិង្គ-

វិបល្លាស ។ ការសម្រេចធម៌លើកទី ១ នេះ មានហើយ ។

សម័យតមក ព្រះរាជាព្រះនាមអរិន្ទមៈ ទ្រង់ឈ្នះសត្រូវក្នុងឧត្តរនគរ ដែលជានគរខាងជើង ។ បានឮថា ព្រះបាទអរិន្ទមៈអង្គនោះ ទ្រង់បានដំណឹងថា ព្រះមានព្រះភាគយាងដល់នគររបស់ព្រះអង្គ ទ្រង់មានជន ៣ កោដិចោមរោម យាងចេញទៅទទួលព្រះមានព្រះភាគ និមន្តដើម្បីសោយក្នុងថ្ងៃស្អែក ទ្រង់ថ្វាយទាន ៧ ថ្ងៃដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់ធ្វើការបូជាដោយប្រទីប ទទឹង ៣ គាវុត ចូលគាល់ព្រះមានព្រះភាគ គង់ប្រថាប់ហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់សម្តែងធម៌មានន័យដ៏វិចិត្រ សមគួរដល់ព្រះហឫទ័យរបស់ព្រះបាទអរិន្ទមៈនោះ ។ ក្នុងទីប្រជុំនោះ ការត្រាស់ធម៌លើកទី ២ មានដល់ទេវតា និងមនុស្ស ១០០០ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ព្រះមហាមុនីព្រះនាមរេវតៈ ទ្រង់ទូន្មានព្រះបាទអរិន្ទមៈ ក្នុង
> កាលណា កាលនោះ ពួកសត្វមួយពាន់កោដិ បានត្រាស់ដឹង
> មគ្គផលលើកទី ២ ដូច្នេះ ។

សម័យតមក ព្រះរេវតសាស្តាទ្រង់អាស្រ័យឧត្តរនិគមប្រថាប់គង់ចូលនិរោធសមាបត្តិ ៧ ថ្ងៃ ។ បានឮថា កាលនោះ មនុស្សអ្នកឧត្តរនិគម នាំយកបបរ និងបាយ របស់ទំពា ភេសជ្ជៈ និងទឹកបានជាដើម ថ្វាយមហាទានដល់ភិក្ខុសង្ឃ ហើយនាំគ្នាសួរថា បពិត្រលោកម្ចាស់ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងទីណា ភិក្ខុទាំងឡាយក៏ប្រាប់ដល់មនុស្សទាំងនោះថា អាវុសោ ព្រះ

មានព្រះភាគទ្រង់ចូលនិរោធសមាបត្តិ ។ កាលកន្លងទៅ ៧ ថ្ងៃ ពួកជនទាំងនោះ ឃើញព្រះមានព្រះភាគ ទ្រង់ចេញចាកនិរោធសមាបត្តិ ទ្រង់រុងរឿងដោយពុទ្ធសិរីរបស់ព្រះអង្គគ្មានអ្វីប្រៀប ដូចព្រះអាទិត្យក្នុងសរទរដូវ ទើបទូលសួរគុណានិសង្សនៃនិរោធសមាបត្តិ ។ ទើបព្រះមានព្រះភាគ ត្រាស់គុណានិសង្សនៃនិរោធសមាបត្តិដល់មនុស្សទាំងនោះ កាលនោះ ទេវតា និងមនុស្ស ១០០ កោដិក៏តាំងនៅក្នុងព្រះអរហត្ត ។ នេះជាការត្រាស់ដឹងធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះនរាសភៈ ទ្រង់ក្រោកចាកទីពួនសម្ងំអស់ ៧ ថ្ងៃ ហើយ
ទូន្មានពួកមនុស្ស និងទេវតាមួយរយកោដិ ( ឲ្យតាំងនៅ )
ក្នុងផលដ៏ឧត្តមលើកទី ៣ ដូច្នេះ ។

ក្នុងសុធញ្ញវតីនគរ ព្រះអរហន្តដែលបួសដោយឯហិភិក្ខុបព្វជ្ជារាប់មិនអស់ មានក្នុងសន្និបាតលើកទី ១ ក្នុងមហាបាតិមោក្ខុទ្ទេសលើកទី ១ ។ ក្នុងមេខលនគរ ព្រះអរហន្តដែលបួសដោយឯហិភិក្ខុបព្វជ្ជារាប់សែនកោដិ ក៏មានសន្និបាតលើកទី ២ ។ អគ្គសាវករបស់ព្រះមានព្រះភាគរេវតៈ ឈ្មោះវរុណ ជាអ្នកអនុវត្តតាមធម្មចក្រដ៏ប្រសើរ នៃភិក្ខុអ្នកមានបញ្ញាទាំងឡាយ កើតនូវអាពាធ ក្នុងកាលនោះ ព្រះរេវតសម្ពុទ្ធទ្រង់សម្តែងធម៌ ដែលសម្តែងដល់ត្រៃលក្ខណ៍ ដល់មហាជនដែលប្រជុំគ្នា ដើម្បីសួរសុខទុក្ខភិក្ខុឈឺ ទ្រង់ញ៉ាំងបុរសមួយសែនកោដិ ឲ្យបួសដោយឯហិភិក្ខុបព្វជ្ជា ហើយឲ្យតាំងនៅក្នុងអរហត្ត ទ្រង់លើកបាតិមោក្ខឡើងសម្តែងក្នុងសន្និបាត ដែលប្រកបដោយអង្គ

៤ នេះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសម្ពុទ្ធព្រះនាមរេវតៈ ទ្រង់ស្វែងរកគុណធំ មានសាវក
សន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រព ប្រាសចាក
មន្ទិល មានព្រះហឫទ័យរួចស្រឡះដោយប្រពៃ មានចិត្តនឹងធឹង
គឺសន្និបាតលើកទី ១ កន្លងផុតផ្លូវនៃការរាប់ ( រាប់ពុំបាន )
សន្និបាតលើកទី ២ មានព្រះអរហន្តមួយសែនកោដិ ។ ព្រះ
អគ្គសាវកអង្គណា រកបុគ្គលស្មើគ្មាន ដោយប្រាជ្ញា ជាអ្នក
ប្រព្រឹត្តតាមធម្មចក្ក នៃព្រះសម្ពុទ្ធអង្គនោះ កាលនោះ ព្រះ
អគ្គសាវកនោះ មានព្យាធិ ដល់នូវការសង្ស័យក្នុងជីវិត ។
កាលនោះ ពួកព្រះអរហន្តចូលទៅគាល់ព្រះមុនី ដើម្បីសាក
សួរអាពាធរបស់ព្រះអគ្គសាវកនោះ មានចំនួនមួយសែន
កោដិ នេះជាសន្និបាតលើកទី ៣ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចក្កានុវត្តកោ** បានដល់ ដែលអនុវត្តតាមព្រះធម្មចក្រ ។ ក្នុងបទថា **បត្តោ ជីវិតសំសយំ** នេះ សេចក្ដីសង្ស័យក្នុងជីវិត ឈ្មោះថា **ជីវិតសំសយ** ។ ដល់នូវការសង្ស័យក្នុងជីវិតយ៉ាងនេះថា ព្រះថេរៈដល់នូវការអស់ជីវិត ឬមិនទាន់ដល់នូវការអស់ជីវិត គឺដល់នូវការសង្ស័យក្នុងជីវិតថា ព្រោះភាវៈដែលអាពាធខ្លាំងក្លា ព្រះថេរៈនឹងធ្វើមរណ-ភាព ឬមិនធ្វើមរណកាលទេ ។ បទថា **យេ តទា ឧបគតា មុនី** សេចក្ដីថា កាលពាក្យថា ( មុនី ) ជាទីយៈ ដូចពោលនេះ ក៏សំដៅដល់ភិក្ខុទាំងឡាយ

កាលជាវស្សៈ ព្រមទាំងនិគ្គហិត ( មុនី ) ក៏សំដៅដល់ព្រះវរុណអគ្គសាវក ។

គ្រានោះ ព្រះពោធិសត្វនៃយើងកើតជាព្រាហ្មណ៍ ឈ្មោះអតិទេវៈ ក្នុងរម្មវតីនគរ ដល់នូវត្រៃយក្នុងព្រាហ្មណធម៌ ឃើញព្រះរេវតសម្មាសម្ពុទ្ធ ស្តាប់នូវធម្មកថារបស់ព្រះអង្គហើយ តាំងនៅក្នុងសរណៈ ពោលសរសើរព្រះទសពលដោយគាថា ១០០០ បូជាដោយសំពត់ដណ្តប់ដែលមានតម្លៃ ១ ពាន់ ។ ព្រះពុទ្ធអង្គនោះ ក៏ទ្រង់ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ក្នុងទីបំផុត ២ អសង្ខេយ្យ និង ១ សែនកប្ប រាប់អំពីកប្បនេះទៅ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតកើតជាព្រាហ្មណ៍ឈ្មោះអតិទេវៈ បានចូលទៅគាល់ព្រះរេវតៈសម្ពុទ្ធ ហើយបានយកព្រះអង្គជាទីពឹង ។ តថាគតបានសរសើរសីល សមាធិ និងបញ្ញា គុណដ៏ប្រសើររបស់ព្រះអង្គ ហើយបានថ្វាយសំពត់ឧត្តរាសង្គៈតាមកម្លាំង ។ ព្រះសម្ពុទ្ធព្រះនាមរេវតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបានអំពីកប្បនេះទៅ ព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ។បេ។ គង់នឹងបានជួបក្នុងទីចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខានយ៉ាងនោះ

ដែរ គប្បីពោលគាថា ១៧ ត្រង់បេយ្យាលខាងលើឲ្យពិស្តារ ផងចុះ ដូច្នេះ ។

គប្បីពោលគាថា ១៧ ឲ្យពិស្តារ

តថាគត បានស្តាប់ព្រះតម្រាស់របស់ព្រះសម្ពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យត្រេកអរក្រៃពេក បានអធិដ្ឋានទូវវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។ កាលនោះ តថាគតនឹកឃើញហើយ បានអប់រំពុទ្ធការកធម៌នោះ ទាំងបានបំពេញនូវពុទ្ធការកធម៌នោះ តាមគួរដល់សេចក្តីប្រាថ្នានៃតថាគត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សរណំ តស្ស គច្ឆហំ** បានដល់ តថាគតដល់ព្រះមានព្រះភាគអង្គនោះ ថាជាសរណៈ ពាក្យនេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ បទថា **បញ្ញាគុណំ** បានដល់ សម្បត្តិ គឺបញ្ញា ។ បទថា **អនុត្តមំ** បានដល់ ប្រសើរបំផុត ។ បាឋៈថា **បញ្ញាវិមុត្តិគុណមុត្តមំ** ដូច្នេះក៏មាន ។ បាឋៈនោះក៏ងាយយល់ដូចគ្នា ។ បទថា **ថោមយិត្វា** បានដល់ លើកតម្កើងហើយ សរសើរហើយ ។ បទថា **យថាថាមំ** ក៏គឺ **យថាពលំ** ( តាមកម្លាំង ) ។ បទថា **ឧត្តរិយំ** បានដល់ សំពត់ដណ្តប់ ។ បទថា **អទាសហំ** កាត់បទជា **អទាសឹ អហំ** ( តថាគតបានថ្វាយ ) ។ បទថា **ពុទ្ធធម្មំ** បានដល់ ធម៌ដែលធ្វើនូវភាពជាព្រះពុទ្ធ អធិប្បាយថា បារមីធម៌ ។ បទថា **សរិត្វា** បានដល់ គឺរឭករឿយៗ ។ បទថា **អនុព្រូហយឹ** បានដល់ ធ្វើឲ្យចម្រើនក្រៃលែងហើយ ។ បទថា **អាហរិស្សាមិ** បានដល់ នឹងនាំមក ។

បទថា **តំ ធម្មំ** បានដល់ ភាពជាព្រះពុទ្ធនោះ ។ បទថា **យំ មយ្ហំ អភិបត្ថិតំ** សេចក្តីថា តថាគតនឹងនាំភាពជាព្រះពុទ្ធ ដែលតថាគតប្រាថ្នាក្រៃលែងមកឲ្យបាន ។

ព្រះមានព្រះភាគវេវតៈអង្គនោះ ទ្រង់មាននគរឈ្មោះសុធញ្ញវតី[១] ព្រះជនកព្រះនាមវិបុលរាជ ព្រះជននីព្រះនាមវិបុលា គូអគ្គសាវកឈ្មោះវរុណៈ ១ ព្រហ្មទេវៈ ឧបដ្ឋាកឈ្មោះសម្ភវៈ គូអគ្គសាវិកាឈ្មោះភទ្ទា ១ សុភទ្ទា ១ ដើមនាគព្រឹក្សជាពោធិ៍ត្រាស់ដឹង សរីរៈកម្ពស់ ៨០ ហត្ថ ព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ អគ្គមហេសីព្រះនាមសុទស្សនា ព្រះរាជឱរសព្រះនាមវរុណ ទ្រង់ចេញអភិនេស្ក្រមណ៍ដោយរថទឹមសេះ ។

កាលនោះ កម្រងរស្មីដ៏ប្រសើរ ផ្សាយចេញអំពីព្រះវរកាយ
របស់ព្រះអង្គដែលជាអគ្គបុគ្គល ១ យោជន៍ជានិច្ច ទាំង
ពេលថ្ងៃ និងពេលយប់ ។
ព្រះមហាវីរជិនស្រីអង្គនោះ ទ្រង់អនុគ្រោះសព្វសត្វ ទ្រង់
អធិដ្ឋានថា ធាតុទាំងឡាយរបស់តថាគត ចូរបែងចែកជា
ចំណែកស្មើៗ សាយភាយទូទៅ ។

ព្រះរេវតសម្ពុទ្ធអង្គនោះ ដែលមនុស្ស និងទេវតាទាំងឡាយបូជាហើយ ទ្រង់រម្ងត់ខន្ធបរិនិព្វាន ក្នុងព្រះរាជឧទ្យានមហានាគវ័ន នៃមហានគរនោះឯងដូច្នេះ ។

---

១- បិដកខ្មែរជា សុធញ្ញកៈ ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះរេវតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានទីក្រុងឈ្មោះ សុធញ្ញកៈ មានព្រះមហាក្សត្រ ព្រះនាមវិបុលៈជាព្រះបិតា មានព្រះមាតាព្រះនាមវិបុលា ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងព្រះរាជដំណាក់អស់ ៦ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ ដែលកើតដោយបុញ្ញកម្ម មាន ៣ គឺសុទស្សនប្រាសាទ ១ រតនគ្ឃិ-ប្រាសាទ ១ អាវេឡប្រាសាទ ១ ដែលគេស្អិតស្អាងហើយ ។ ពួកនារី ៣៣ សែននាក់ មានរូបតាក់តែងសមរម្យ ឯនារីជាអគ្គ-មហេសី ព្រះនាមសុទស្សនា មានព្រះរាជបុត្រព្រះនាមវរុណៈ ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាងហើយ ទ្រង់ចេញបព្វជ្ជាដោយរថយាន ហើយតាំងសេចក្តីព្យាយាមអស់ ៧ ខែឥតខ្វះ ។ ព្រះសម្ពុទ្ធទ្រង់ព្រះនាមរេវតៈ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ ទ្រង់ញ៉ាំងចក្រឲ្យប្រព្រឹត្តទៅ ទ្រង់មានព្យាយាមច្រើន ទ្រង់ឈ្នះមារ ត្រូវមហាព្រហ្មអារាធនាហើយ ទ្រង់គង់នៅក្នុងវរុណារាម ។ ព្រះថេរៈឈ្មោះវរុណៈ ១ ព្រហ្មទេវៈ ១ ជាអគ្គ-សាវក ព្រះថេរៈឈ្មោះសម្ភវៈជាឧបដ្ឋាក របស់ព្រះរេវតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះភទ្ទា ១ សុភទ្ទា ១ ជាអគ្គសាវិកា ឯព្រះសម្ពុទ្ធឥតមានបុគ្គលស្មើអង្គនោះ ទ្រង់បានត្រាស់ដឹងទៀបដើមខ្លឹង ។ ឧបាសកឈ្មោះវរុណៈ ១ សរភៈ ១

ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះបាលា ១ ឧបបាលា ១ ជាអគ្គឧបដ្ឋាកយិកា ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៨០ ហត្ថ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺរុងរឿង ដូចទង់ជ័យរបស់ព្រះឥន្ទដ៏ខ្ពង់ខ្ពស់ ។ កម្រងរស្មីដ៏ប្រសើរ កើតក្នុងសរីរៈនៃព្រះអង្គ ផ្សាយចេញមួយយោជន៍ជុំវិញ ទាំងថ្ងៃ ទាំងយប់ ។ ព្រះសម្ពុទ្ធអង្គនោះ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើនឲ្យឆ្លង ( ចាកវដ្តសង្សារ ) ។ ព្រះសម្ពុទ្ធទ្រង់សម្តែងកម្លាំងនៃព្រះពុទ្ធ ហើយទ្រង់ប្រកាសអមតធម៌ក្នុងលោក ព្រះអង្គមិនមានសេចក្តីប្រកាន់ ទ្រង់បរិនិព្វានព្រោះអស់ឧបាទាន ដូចភ្លើងដែលអស់កំញម ។ ព្រះកាយរបស់ព្រះអង្គនោះ មានពណ៌ដូចកែវ ព្រះធម៌របស់ព្រះអង្គ មិនមានអ្វីស្មើដូចទេ របស់ទាំងអស់ វិនាសសូន្យទៅ សង្ខារទាំងពួងទទេពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱភាសេតិ** បានដល់ ពន្លឺភ្លឺស្វាង ។ បទថា **ឧគ្គតោ** បានដល់ ខ្ពស់ឡើងទៅ ។ បទថា **បភាមាលា** បានដល់ ព្រំដែនព្រះរស្មី ។ បទថា **យថគ្គិ** បានដល់ ដូចគ្នានឹងភ្លើង ។ បទថា **ឧចា-**

**ធានសន្ធិយា** បានដល់ អស់នូវកំញម ។ បទថា **សោ ច កាយោ រតន-និភោ** បានដល់ ព្រះវរកាយរបស់ព្រះមានព្រះភាគអង្គនោះ មានវណ្ណៈដូចមាស ។ បាឋៈថា **តញ្ច កាយំ រតននិភំ** ដូច្នេះក៏មាន ។ លោកពោលជាលិង្គវិបល្លាស ។ បាឋៈនោះសេចក្តីក៏យ៉ាងនោះដូចគ្នា ។ គាថាដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាវេតពុទ្ធវង្សទី ៥ ចប់**

# សុត្តន្តបិដក

## សោភិតពុទ្ធវង្សទី ៦

[ ៧ ] *កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមរេវតៈមក មានព្រះលោកនាយក ព្រះនាមសោភិតៈ មានព្រះហឫទ័យតម្កល់ខ្ជាប់ មានព្រះហឫទ័យស្ងប់ មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹម ។ ព្រះជិនស្រីអង្គនោះ ទ្រង់ញ៉ាំងបំណងក្នុងព្រះហឫទ័យឲ្យប្រព្រឹត្តទៅ ក្នុងព្រះដំណាក់របស់ព្រះអង្គ ទ្រង់បានសម្រេចសម្ពោធិញ្ញាណដោយសព្វគ្រប់ ហើយទ្រង់សម្តែងព្រះធម្មចក្ក ។ ខាងលើរាប់អំពីអវិចីនរកឡើងទៅ ខាងក្រោមរាប់អំពីភវគ្គព្រហ្មចុះមក ក្នុងចន្លោះនេះ ពេញដោយបរិស័ទតែម្យ៉ាង ក្នុងការសម្តែងធម្មទេសនា ។ កាលព្រះសម្ពុទ្ធទ្រង់សម្តែងព្រះធម្មចក្ក ដល់បរិស័ទនោះ ការត្រាស់ដឹងធម៌លើកទី ១ គេមិនគប្បីពោលដោយការរាប់ចំនួនបានឡើយ ។ លំដាប់អំពីនោះមកទៀត កាលព្រះសម្ពុទ្ធទ្រង់សម្តែងធម៌ក្នុងទីសមាគម នៃមនុស្ស និងទេវតា មានពួកបរិស័ទ ៩ ម៉ឺនកោដិ ត្រាស់ដឹងធម៌លើកទី ២ ។ មួយវិញទៀត កាលនោះ ព្រះរាជបុត្តជាក្សត្រ ព្រះនាមជយសេន ដាំសួនវេរថ្វាយព្រះសម្ពុទ្ធ ។ ព្រះចក្ខុមសម្ពុទ្ធ ទ្រង់ប្រកាសការបូជានៃព្រះបាទជយសេននោះ ហើយសម្តែងធម្មទេសនា ក្នុងកាលនោះ មានបរិស័ទមួយពាន់កោដិ ត្រាស់ដឹងធម៌លើកទី ៣ ។ ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានសាវកសន្និបាត*

៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង គឺកាលព្រះរាជាព្រះនាមឧគ្គតៈអង្គនោះ ទ្រង់ថ្វាយទានចំពោះព្រះសម្ពុទ្ធ ថ្ងៃថ្វាជាធនរជន ក្នុងវេលាថ្វាយទាននោះ មានអហន្តមួយរយកោដិ និមន្តមកប្រជុំគ្នា ( នេះជាសន្និបាតលើកទី ១ ) ។ មួយវិញទៀត មានពួកបរិស័ទថ្វាយទានចំពោះព្រះសម្ពុទ្ធ ថ្ងៃថ្វាជាធពួកនរជន ក្នុងកាលនោះ មានពួកបរិស័ទ ៩០ កោដិ ( មកប្រជុំគ្នា ) នេះជាសន្និបាតលើកទី ២ ។ ព្រះជិនស្រីទ្រង់គង់ក្នុងទេវលោក ហើយស្ដេចចុះចាកទេវលោកក្នុងកាលណា កាលនោះ មានពួកបរិស័ទ ៨០ កោដិ ( មកប្រជុំគ្នា ) នេះជាសន្និបាតលើកទី ៣ ។ សម័យនោះ តថាគតកើតជាព្រាហ្មណ៍ ឈ្មោះសុជាតៈ កាលនោះ តថាគតនិមន្តព្រះពុទ្ធ ព្រមទាំងសាវក ឲ្យឆាន់ឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ។ ព្រះសម្ពុទ្ធព្រះនាមសោភិតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ ព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយនៅទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា

ហើយចូលទៅគន់ទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែងហើយ ។ លំដាប់អំពីនោះមក ព្រះជិនស្រីទ្រង់យសធំអង្គនោះ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងបានត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនោះ នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រាហ្មណ៍នេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ មិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទនឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំនឹងជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់យសអង្គនោះ មានព្រះជន្ម ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសោភិតសម្ពុទ្ធ ឥតមានបុគ្គលស្មើទ្រង់ស្វែងរកនូវគុណដ៏ធំហើយ ក៏រីករាយថា ព្រាហ្មណ៍នេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាក្នុងមួយម៉ឺន

លោកធាតុ នាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលី
នមស្ការផងថា ពួកយើង បើនឹងឃ្លាងមគ្គផលក្នុងសាសនារបស់
ព្រះលោកនាថនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះ
សាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្ស កាល
ឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម
ហើយឆ្លងស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះ
ជិនស្រីអង្គនេះទៅ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសម្ពុទ្ធ
អង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ ចំណែកតថាគត
លុះបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះសម្ពុទ្ធអង្គនោះ ក៏មានចិត្ត
ត្រេកអរ មានចិត្តតក់ស្លុត ហើយបានធ្វើនូវប្រាជ្ញាឲ្យខ្ពង់ខ្ពស់
ដើម្បីសម្រេចប្រយោជន៍នោះ ។ ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែង
រកនូវគុណដ៏ធំ មាននគរឈ្មោះសុធម្ម: ព្រះមហាក្សត្រព្រះនាម
សុធម្ម:ជាព្រះបិតា ព្រះមាតាព្រះនាមសុធម្មា ព្រះសោភិតសម្ពុទ្ធ
អង្គនោះ ទ្រង់គ្រប់គ្រងជំណាក់អស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ
មាន ៣ គឺកុមុទប្រាសាទ ១ នឡិនីប្រាសាទ ១ បទុមប្រាសាទ
១ ។ ពួកនារី ៤ ពាន់នាក់ មានរូបតាក់តែងសមរម្យ ឯនារីជា
អគ្គមហេសីឈ្មោះកិមិលា មានព្រះរាជបុត្តឈ្មោះសីហ: ។ ព្រះ
សម្ពុទ្ធខ្ពង់ខ្ពស់ជាងបុរស ទ្រង់ឃើញនិមិត្ត ៤ យ៉ាងហើយ ស្ដេច
ចេញទៅទ្រង់ព្រះផ្នួសដោយប្រាសាទ ទៅប្រព្រឹត្តបធានចារៈអស់

៧ ថ្ងៃ ។ ព្រះសោភិតសម្ពុទ្ធ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ ទ្រង់មានចក្កប្រព្រឹត្តទៅ មានព្យាយាមច្រើន ត្រូវមហាព្រហ្មអារាធនាហើយ ក្នុងសុធម្មឧទ្យានដ៏ប្រសើរ ។ ព្រះថេរៈឈ្មោះអសមៈ ១ សុនេត្តៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអនោមៈជាឧបដ្ឋាករបស់ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ ។ ព្រះថេរីឈ្មោះនកុលា ១ សុជាតា ១ ជាអគ្គសាវិកា ព្រះសម្ពុទ្ធអង្គនោះ កាលត្រាស់ដឹង ទ្រង់ត្រាស់ទៀបដើមខ្ទឹង ។ ឧបាសកឈ្មោះរម្មៈ ១ សុនេត្តៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនកុលា ១ ចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីទ្រង់មានកម្ពស់ ៥៨ ហត្ថ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺរុងរឿងដូចព្រះអាទិត្យរះឡើង ។ ព្រៃធំដែលមានផ្កាឈើរីកល្អ ដែលអប់ដោយក្លិនក្រអូបផ្សេងៗ យ៉ាងណា ពាក្យប្រដៅរបស់ព្រះសម្ពុទ្ធអង្គនោះ តែងអប់ដោយក្លិនក្រអូប គឺសីល ក៏យ៉ាងនោះដែរ ។ ធម្មតាសាគរ គេតែងមិនឆ្អែតដោយការរមិលមើល យ៉ាងណា ពាក្យប្រដៅរបស់ព្រះសម្ពុទ្ធអង្គនោះ គេមិនឆ្អែតដោយការស្តាប់ក៏យ៉ាងនោះដែរ ។ ព្រះអង្គមានព្រះជន្ម ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គគង់នៅជរាបអស់កាលប៉ុណ្ណោះ ទ្រង់ញុំាងប្រជុំជនឲ្យឆ្លង

( វង្គសង្ហារ ) ។ ព្រះអង្គ ព្រមទាំងសាវ័ក ទ្រង់ឲ្យឱវាទ និង ការប្រៀនប្រដៅចំពោះជនដ៏សេស ហើយញុំាងជនទាំងនោះ ឲ្យ មានព្យាយាម ដុតកម្តៅកិលេសដូចភ្លើង រួចបរិនិព្វាន ។ ព្រះ សម្ពុទ្ធស្មើដោយព្រះពុទ្ធ ឥតមានបុគ្គលស្មើអង្គនោះក្តី ពួកសាវ័ក ទាំងនោះ ដែលដល់នូវកម្លាំងក្តី របស់ទាំងអស់នេះ ក៏វិនាស សូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ។ ព្រះសោភិតសម្ពុទ្ធ ដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងសីហារាម ព្រះធាតុ ( របស់ ព្រះអង្គ ) សាយកាយទៅក្នុងប្រទេសនោះ តាមចំណែកៗ ។

សោភិតពុទ្ធវង្សទី ៦ ចប់

# អដ្ឋកថា

## សោភិតពុទ្ធវង្សទី ៦

ខាងក្រោយសម័យនៃព្រះរេវតសម្ពុទ្ធអង្គនោះ កាលព្រះសាសនារបស់ព្រះអង្គអន្តរធានហើយ ព្រះពោធិសត្វព្រះនាមសោភិតៈ បានបំពេញបារមី ៤ អសង្ខេយ្យ និង ១ សែនកប្ប កើតក្នុងស្ថានសួគជាន់តុសិត ទ្រង់តាំងនៅដរាបដល់អាយុក្នុងទីនោះហើយ កាលពួកទេវតាអារាធនាហើយ ក៏ចុតិចាកស្ថានសួគ៌ជាន់តុសិត បដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងសុធម្មាទេវី ក្នុងរាជត្រកូលរបស់ព្រះបាទសុធម្មៈ ក្នុងសុធម្មនគរ ។ ព្រះពោធិសត្វនោះ គ្រប់កំណត់ទសមាស ក៏ប្រសូតចាកផ្ទៃរបស់ព្រះជននី ក្នុងសុធម្មរាជឧទ្យាន ដូចព្រះចន្ទផុតចាកស្រទាប់ពពក ។ បាដិហារ្យក្នុងបដិសន្ធិ និងប្រសូតរបស់ព្រះពោធិសត្វ មានប្រការដូចពោលហើយខាងដើម ។

ព្រះពោធិសត្វនោះ គ្រងឃរាវាសវិស័យមួយម៉ឺនឆ្នាំ កាលព្រះរាជឱរសព្រះនាមសីហកុមារ បដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងមខិលាទេវី[១] អគ្គមហេសីជាធំលើស្រីស្នំ ៧ ម៉ឺន ហើយទ្រង់ឃើញនិមិត្ត ៤ មានព្រះហឫទ័យសង្វេគ ទ្រង់ព្រះផ្នួសក្នុងប្រាសាទនោះឯង ទ្រង់ចម្រើនអនាបានស្សតិសមាធិក្នុងប្រាសាទនោះឯង ទ្រង់បានឈាន ៤ ទ្រង់បំពេញព្យាយាមក្នុងប្រាសាទនោះអស់ ៧ ថ្ងៃ បន្ទាប់អំពីនោះ សោយមធុបាយាសមានរសឆ្ងាញ់ ដែលព្រះនាងមខិលាមហាទេវីថ្វាយហើយ ទ្រង់កើតចិត្តគិតចេញអភិនេស្រ្កមណ៍ថា ចូរប្រាសាទដែលប្រដាប់តាក់តែងហើយនេះ ទៅតាមអាកាស ចំពោះមុខ

---

១- បិដកខ្មែរជា កិមិលា ។

មហាជនដែលកំពុងមើល ហើយចុះលើផែនដី ដោយមានពោធិព្រឹក្សនៅត្រង់កណ្តាលប្រាសាទ កាលអាត្មាអញអង្គុយត្រង់គល់ពោធិព្រឹក្ស ស្រ្តីទាំងនេះមិនចាំបាច់មានអ្នកប្រាប់ ចូរចុះអំពីប្រាសាទឯងចុះ ដំណាលនឹងចិត្តគិតដូច្នោះ ប្រាសាទក៏ហោះចេញអំពីព្រះរាជនិវេសន៍របស់ព្រះបាទសុធម្មរាជ ឡើងកាន់អាកាស ដូចកម្រងលោហៈមានពណ៌ខៀវចាស់ ប្រាសាទនោះ មានផ្ទៃប្រដាប់ដោយកម្រងផ្កា មានក្លិនក្រអូប ដូចប្រដាប់ពេញផ្ទៃអាកាស រុងរឿងដូចព្រះអាទិត្យ ធ្វើនូវលម្អ ដូចផ្ការទឹកមាស ដូចព្រះចន្ទក្នុងសរទរដូវ មានបណ្តាញកណ្តឹងដ៏វិចិត្រច្រើនប្រភេទសំយុងចុះ កាលត្រូវខ្យល់បក់ ក៏បន្លឺនូវសំឡេងពីរោះ គួរស្រឡាញ់ ដូចតន្ត្រីប្រកបដោយអង្គ ៥ ដែលអ្នកជំនាញប្រគំហើយ ។

ដោយសំឡេងពីរោះ បានឮមកអំពីចម្ងាយ សំឡេងពីរោះនោះ ក៏ឈមចុះកាន់សោតៈរបស់សត្វទាំងឡាយ ដូចលួងលោមតាមអាកាសដែលមិនឆ្ងាយអំពីជាយព្រៃ ដែលស្រស់ត្រកាលដោយដើមឈើ មិនទាបពេក មិនខ្ពស់ពេក ក្នុងពួកមនុស្សដែលឈរចរចាប្រាស្រ័យគ្នាក្នុងផ្ទះ ត្រង់ផ្លូវបែកជា ៣ ផ្លូវបែកជា ៤ និងត្រង់វិថីជាដើម ហាក់បីដូចទាញយកភ្នែកមហាជន ដោយពណ៌ដែលរុងរឿងដោយរតនៈផ្សេងៗ គឺមែកដ៏ល្អរបស់ដើមឈើ និងដូចឃោសនាបុញ្ញានុភាព ប្រព្រឹត្តទៅពេញផ្ទៃអាកាស ។ ពួកអ្នករបាំក្នុងទីនោះក៏ប្រៀងមានសំឡេងស៊ីគ្នានឹងសំឡេងនៃតន្ត្រី ដ៏ពីរោះដែលប្រកបដោយអង្គ ៥ ។ បានឮថា កង‌ទ័ព ៤ ពួករបស់ព្រះអង្គ ដល់នូវភាពស្អាតដោយអាករណៈ

គឺផ្កាក្រអូប និងសំពត់មានពណ៌ផ្សេងៗ រុងរឿង ចាំងចែងចេញពីគ្រឿងអលង្ការ និងអាភរណៈ ឆ្មៀលឆ្វាត់ជុំវិញប្រាសាទ នាផ្ទៃអាកាស ដូចកងទ័ពទេវតា ដូចផែនដីដែលល្អគួរមើលក្រៃលែង ។

បន្ទាប់អំពីនោះ ប្រាសាទក៏ទៅធ្វើដើមពោធិព្រឹក្សឈ្មោះនាគ កម្ពស់ ៨៨ ហត្ថ មានដើមស្រឡៅន ប្រដាប់ដោយផ្កាដែលក្រពុំ មានត្រួយខ្ទីត្រង់កណ្ដាល ហើយចុះត្រង់ផែនដី ។ ឯពួកស្រីរបាំ បុគ្គលណាមួយមិនបានប្រាប់ ក៏ចុះអំពីប្រាសាទនោះ ចៀសចេញទៅ ។ បានឮថា ព្រះសោភិតមហាបុរស ល្អដោយគុណជាច្រើន ធ្វើមហាជនឲ្យជាបរិវារនោះឯង ទ្រង់ញុំាងវិជ្ជា ៣ ឲ្យកើតក្នុងយាមទាំង ៣ នៃរាត្រី ។ ឯកម្លាំងនៃមារ ក៏ទៅតាមផ្លូវដែលទៅ ដោយកម្លាំងធម្មតារបស់ព្រះមហាបុរសនោះឯង ។ ចំណែកប្រាសាទ បានតាំងនៅក្នុងទីនោះឯង ។ ព្រះមានព្រះភាគសោភិតៈ ទ្រង់សម្រេចសម្ពោធិញ្ញាណហើយ ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ តថាគតបានដល់
ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់សម្ងំនៅក្បែរគល់ពោធិព្រឹក្ស អស់ ៧ សប្តាហ៍ ទ្រង់ទទួលអារាធនារបស់មហាព្រហ្ម ទ្រង់ប្រមើលមើលដោយពុទ្ធចក្ខុថា តថាគតនឹងសម្តែងធម៌ ដល់អ្នកណាហ្ន៎ ទ្រង់ឃើញអសមកុមារ និងសុនេត្តកុមារ ព្រះ

កនិដ្ឋភាតាមាតាដទៃរបស់ព្រះអង្គ ទ្រង់ព្រះតម្រិះថា កុមារទាំង ២ អង្គនេះ ដល់ព្រមដោយឧបនិស្ស័យ អាចចាក់ធ្លុះនូវធម៌ជ្រាលជ្រៅបាន ហើយចុះ តថាគតនឹងសម្ដែងធម៌ដល់កុមារទាំង ២ នេះ ហើយយាងទៅតាមអាកាស ចុះត្រង់សុធម្មរាជឧទ្យាន ឲ្យឧទ្យានបាលហៅព្រះរាជកុមារទាំង ២ អង្គមក កាលព្រះរាជកុមារ មួយអន្លើដោយបរិវារចោមរោមហើយ ទ្រង់ប្រកាស ធម្មចក្រកណ្ដាលមហាជន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមរេវតៈមក មានព្រះ
> លោកនាយក ព្រះនាមសោភិតៈ មានព្រះហឫទ័យតម្កល់ខ្ជាប់
> មានព្រះហឫទ័យស្ងប់ មិនមានបុគ្គលស្មើ មិនមានបុគ្គល
> ប្រៀបផ្ទឹម ។ ព្រះជិនស្រីអង្គនោះ ទ្រង់ញុំាងបំណង ក្នុងព្រះ
> ហឫទ័យឲ្យប្រព្រឹត្តទៅ ក្នុងព្រះដំណាក់របស់ព្រះអង្គ ទ្រង់
> បានសម្រេចសម្ពោធិញ្ញាណ ដោយសព្វគ្រប់ ហើយទ្រង់
> សម្ដែងព្រះធម្មចក្ក ។ ខាងលើ រាប់អំពីអវិចីនរកឡើងទៅ
> ខាងក្រោម រាប់អំពីភវគ្គព្រហ្មចុះមក ក្នុងចន្លោះនេះ ពេញ
> ដោយបរិស័ទតែម្យ៉ាង ក្នុងការសម្ដែងធម្មទេសនា ។ កាល
> ព្រះសម្ពុទ្ធទ្រង់សម្ដែងព្រះធម្មចក្កដល់បរិស័ទនោះ ការត្រាស់
> ដឹងធម៌លើកទី ១ គេមិនគប្បីពោលដោយការរាប់ចំនួនបាន
> ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សកគេហម្ហិ** បានដល់ ក្នុងនិវេសន៍របស់

ព្រះអង្គឯងនោះ អធិប្បាយថា ក្នុងផ្ទៃប្រាសាទនោះឯង ។ បទថា **មានសំ វិធិវត្តយិ** បានដល់ ត្រឡប់ចិត្ត អធិប្បាយថា នៅក្នុងនិវេសន៍របស់ព្រះអង្គ ប្តូរចិត្តចាកភាពជាបុថុជ្ជនខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ហើយទ្រង់សម្រេចភាព ជាព្រះពុទ្ធ ។ បទថា **ហេដ្ឋា** បានដល់ ខាងក្រោម ។ បទថា **ភវគ្គា** បាន ដល់ អំពីអកនិដ្ឋភព ។ បទថា **តាយ បរិសាយ** បានដល់ កណ្តាល បរិស័ទនោះ ។ បទថា **គណនាយ ន វត្តព្វោ** សេចក្តីថា ហួសនឹងរាប់ ចំនួនបាន ។ បទថា **បឋមាភិសមយោ** បានដល់ ការត្រាស់ដឹងធម៌លើកទី ១ ។ បទថា **អហុ** សេចក្តីថា បរិស័ទរាប់ចំនួនមិនបាន ។ បាឋៈថា **បឋមេ អភិសម្បេយេ** ដូច្នេះក៏មាន សេចក្តីថា ជនទាំងឡាយណាត្រាស់ដឹងធម៌ ក្នុង ការសម្តែងធម៌របស់ព្រះសោភិតសម្ពុទ្ធនោះ ជនទាំងនោះ ដែលបុគ្គលណា មួយពោលមិនបាន ដោយការរាប់ចំនួន ។ សម័យតមក ព្រះសោភិតសម្ពុទ្ធ ទ្រង់ធ្វើយមកប្បាដិហារ្យ ត្រង់គល់ចិត្តបាដលី ( ដើមប្រទៀង ) ក្បែរទ្វារ នគរសុទស្សនៈ ទ្រង់គង់សម្តែងអភិធម្ម លើផ្ទៃបណ្ឌុកម្ពលសិលាអាសនៈ នាគល់បារិច្ឆត្តកព្រឹក្សក្នុងស្ថានតាវត្តិង្ស ដែលជាកពសម្រេចដោយនវរតនៈ និងមាស ។ ចប់ទេសនា ទេវតា ៩ ម៉ឺន កោដិត្រាស់ដឹងធម៌ នេះជាការ ត្រាស់ដឹងធម៌លើកទី ២ ដោយហេតុនោះ ទើប ព្រះមានព្រះភាគត្រាស់ថា

លំដាប់អំពីនោះមកទៀត កាលព្រះសម្ពុទ្ធទ្រង់សម្តែងធម៌
ក្នុងទីសមាគមនៃមនុស្ស និងទេវតា មានពួកបរិស័ទ ៩ ម៉ឺន
កោដិ ត្រាស់ដឹងធម៌លើកទី ២ ដូច្នេះ ។

សម័យតមក ព្រះរាជកុមារព្រះនាមជ័យសេន ក្នុងនគរសុទស្សនៈ ទ្រង់សាងវិហារប្រមាណមួយយោជន៍ ទ្រង់ស្ថាបនាអារាម ដែលពេញទៅដោយដើមឈើដ៏ល្អ ដូចជាដើមអសោក ដើមស្រល់ ដើមចម្បា ដើមអំបែងថ្ងៃ ដើមបុន្នាគ ដើមពុលក្រអូប ស្វាយ ខ្នុរ ធ្នង់ រាំងភ្នំ ម្ទិះ ស្វាយក្រអូប ដើមសុរភីជាដើម ទ្រង់វេរថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនាទាន ទ្រង់សរសើរការបរិច្ចាគទាន ហើយទ្រង់សម្តែងធម៌ ។ គ្រានោះ ការសម្រេចធម៌ មានដល់ពួកសត្វមួយសែនកោដិ[១] នេះជាការត្រាស់ដឹងធម៌ទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> មួយវិញទៀត កាលនោះ ព្រះរាជបុត្តជាក្សត្រ ព្រះនាម
> ជយសេន ដាំសួនវេរថ្វាយព្រះសម្ពុទ្ធ ។ ព្រះចក្ខុមសម្ពុទ្ធ
> ទ្រង់ប្រកាសការបូជានៃព្រះបាទជយសេននោះ ហើយសម្តែង
> ធម្មទេសនា ក្នុងកាលនោះ មានបរិស័ទមួយពាន់កោដិ
> ត្រាស់ដឹងធម៌លើកទី ៣ ដូច្នេះ ។

ព្រះរាជាព្រះនាមឧគ្គតៈ ទ្រង់សាងវិហារឈ្មោះសុនន្ទៈ ក្នុងសុនន្ទនគរ ថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ក្នុងកាលនោះ ព្រះអរហន្តមួយរយកោដិ ដែលបួសដោយឯហិភិក្ខុបព្វជ្ជាប្រជុំគ្នា ។ ព្រះមានព្រះភាគសោភិតៈ ទ្រង់លើកបាតិមោក្ខឡើង សម្តែងក្នុងកណ្តាលព្រះអរហន្តទាំងនោះ ។ នេះជា

---

១- បិដកខ្មែរជា ១ ពាន់កោដិ ។

សន្និបាតលើកទី ១ ។ គណៈធម៌ក្នុងមេខលនគរ សាងវិហារដែលគួរត្រេកអរយ៉ាងល្អ ឈ្មោះធម្មគណារាម ថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទៀត ហើយបានថ្វាយទាន មួយអន្លើដោយបរិក្ខារសព្វយ៉ាង ។ ក្នុងសមាគមនោះ ព្រះមានព្រះភាគទ្រង់លើកបាតិមោក្ខឡើង សម្ដែងក្នុងការប្រជុំព្រះអរហន្ត ៩០ កោដិ ដែលបួសដោយឯហិភិក្ខុភាវៈ នេះជាសន្និបាតលើកទី ២ ។ ឯសម័យដែលព្រះមានព្រះភាគទ្រង់ចាំវស្សា ក្នុងស្ថានរបស់ស្ដេចសហស្សនេត្រ ដែលពួកទេវតាចោមរោមហើយ ទ្រង់ចុះអំពីទេវលោកក្នុងតិថីបវារណាចេញវស្សា ទ្រង់បវារណា មួយអន្លើដោយព្រះអរហន្ត ៨០ កោដិ ក្នុងការប្រជុំដែលប្រកបដោយអង្គ ៤ នេះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានសាវកសន្និបាត
៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល
មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង គឺកាលព្រះរាជាព្រះនាម
ឧគ្គតៈអង្គនោះ ទ្រង់ថ្វាយទានចំពោះព្រះសម្ពុទ្ធ ថ្ងៃថ្លាជាងនរជន
ក្នុងវេលាថ្វាយទាននោះ មានអហន្តមួយរយកោដិ និមន្តមកប្រជុំ
គ្នា ( នេះជាសន្និបាតលើកទី ១ ) ។ មួយវិញទៀត មានពួក
បរិស័ទថ្វាយទានចំពោះព្រះសម្ពុទ្ធ ថ្ងៃថ្លាជាងពួកនរជន ក្នុង
កាលនោះ មានពួកបរិស័ទ ៩០ កោដិ ( មកប្រជុំគ្នា ) នេះ
ជាសន្និបាតលើកទី ២ ។ ព្រះជិនស្រី ទ្រង់គង់ក្នុងទេវលោក

ហើយស្តេចចុះចាកទេវលោកក្នុងកាលណា កាលនោះ មានពួកបរិស័ទ ៨០ កោដិ ( មកប្រជុំគ្នា ) នេះជាសន្និបាតលើកទី ៣ ដូច្នេះ ។

បានឮថា កាលនោះ ព្រះពោធិសត្វនៃយើងកើតជាព្រាហ្មណ៍ ឈ្មោះសុជាត ជាអ្នកមានកំណើតល្អទាំង ២ ចំណែក ក្នុងរម្មវតីនគរ ស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគសោភិតៈហើយ តាំងនៅក្នុងសរណៈ ថ្វាយមហាទានអស់ត្រៃមាសដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះសោភិត-សម្ពុទ្ធអង្គនោះ ក៏ទ្រង់ព្យាករសុជាតព្រាហ្មណ៍នោះថា ក្នុងអនាគតកាល ព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតកើតជាព្រាហ្មណ៍ ឈ្មោះសុជាតៈ
កាលនោះ តថាគតនិមន្តព្រះពុទ្ធ ព្រមទាំងសាវក ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ ព្រះសម្ពុទ្ធព្រះនាម
សោភិតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា
ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ ព្រាហ្មណ៍នេះ
នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុង
កបិលវត្ថុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ធ្វើទុក្ករ-
កិរិយា ។បេ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ
ទៅ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសម្ពុទ្ធអង្គនេះ

ក្នុងកាលជាអនាគតក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះសម្ពុទ្ធអង្គនោះ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ហើយបានធ្វើនូវប្រាជ្ញាឲ្យខ្ពង់ខ្ពស់ដើម្បីសម្រេចប្រយោជន៍នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្សេវត្តមនុបត្តិយា** បានដល់ ដើម្បីឲ្យកើតភាពជាព្រះពុទ្ធអង្គនោះ ។ អធិប្បាយថា ការស្តាប់ព្រះតម្រាស់របស់ព្រះសោភិតសម្ពុទ្ធអង្គនោះថា ក្នុងអនាគតកាល បុរសនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមគោតម ដូច្នេះហើយ ទើបបដិបត្តិដើម្បីសម្រេចភាពជាព្រះពុទ្ធ ព្រោះថា ព្រះពុទ្ធទាំងឡាយ មានព្រះតម្រាស់មិនខុស ។ បទថា **ឧគ្គំ** បានដល់ ខ្លាំងក្លា ។ បទថា **ធិតឹ** បានដល់ សេចក្តីព្យាយាម ។ បទថា **អកាសហំ** កាត់បទជា **អកាសឹ អហំ** បានដល់ ខ្ញុំបានធ្វើហើយ ។ ព្រះមានព្រះភាគសោភិតៈអង្គនោះ មាននគរឈ្មោះសុធម្មៈ ព្រះជនកព្រះនាមព្រះបាទសុធម្មៈ ព្រះជននីព្រះនាមសុធម្មា គូនៃអគ្គសាវកឈ្មោះអសមៈ ១ សុនេត្តៈ ១ ពុទ្ធុបដ្ឋាកឈ្មោះអនោមៈ គូអគ្គសាវិកាឈ្មោះនកុលា ១ សុជាតា ១ ពោធិព្រឹក្សឈ្មោះដើមនាគព្រឹក្ស ( ខ្លឹង ) ។ ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ អគ្គមហេសីព្រះនាមមខិលា[១] ព្រះរាជឱរសព្រះនាមសីហកុមារ មានស្រីស្នំនារី ៣ ម៉ឺន ៧ ពាន់នាក់[២] ទ្រង់នៅជាឃរាវាស ៩ ពាន់ឆ្នាំ[៣] ទ្រង់ចេញអភិនេស្រ្កមណ៍ទាំងប្រាសាទ ឧបដ្ឋាកព្រះនាមព្រះបាទ

---

១- បិដកខ្មែរជា កិមិលា ។ ២- បិដកខ្មែរជា ៤ ពាន់ ។ ៣- បិដកខ្មែរជា ៩ ម៉ឺនឆ្នាំ ។

ជយសេន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះ សុធម្មៈ ព្រះមហាក្សត្រព្រះនាមសុធម្មៈជាព្រះបិតា ព្រះមាតាព្រះនាមសុធម្មា ព្រះសោភិតសម្ពុទ្ធអង្គនោះ ទ្រង់គ្រប់គ្រងដំណាក់អស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ គឺកុមុទប្រាសាទ ១ នឡិនីប្រាសាទ ១ បទុមប្រាសាទ ១ ។ ពួកនារី ៤ ពាន់នាក់ មានរូបតាក់តែងសមរម្យ ឯនារីជាអគ្គមហេសីឈ្មោះកិមិលា មានព្រះរាជបុត្តឈ្មោះសីហៈ ។ ព្រះសម្ពុទ្ធ ខ្ពង់ខ្ពស់ជាងបុរស ទ្រង់ឃើញនិមិត្ត ៤ យ៉ាងហើយ ស្ដេចចេញទៅទ្រង់ព្រះផ្នួសដោយប្រាសាទ ទៅប្រព្រឹត្តបធានចារៈ អស់ ៧ ថ្ងៃ ។ ព្រះសោភិតសម្ពុទ្ធ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ ទ្រង់មានចក្កប្រព្រឹត្តទៅ មានព្យាយាមច្រើន ត្រូវមហាព្រហ្មអារាធនាហើយ ក្នុងសុធម្មឧទ្យានដ៏ប្រសើរ ។ ព្រះថេរៈឈ្មោះអសមៈ ១ សុនេត្តៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអនោមៈ ជាឧបដ្ឋាករបស់ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ ។ ព្រះថេរីឈ្មោះនកុលា ១ សុជាតា ១ ជាអគ្គសាវិកា ព្រះសម្ពុទ្ធអង្គនោះ កាលត្រាស់ដឹង ទ្រង់ត្រាស់ទៀបដើមរាំង ។ ឧបាសកឈ្មោះរម្មៈ ១ សុនេត្តៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនកុលា ១ ចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនី ទ្រង់

មានកម្ពស់ ៥៨ ហត្ថ ទ្រង់ញ៉ាំងទិសទាំងពួងឲ្យភ្លឺរុងរឿង ដូចព្រះអាទិត្យរះឡើង ។ ព្រៃធំដែលមានផ្កាឈើរីកល្អ ដែលអប់ដោយក្លិនក្រអូបផ្សេងៗ យ៉ាងណា ពាក្យប្រដៅរបស់ព្រះសម្ពុទ្ធអង្គនោះ តែងអប់ដោយក្លិនក្រអូប គឺសីល ក៏យ៉ាងនោះដែរ ។ ធម្មតាសាគរ គេតែងមិនឆ្អែតដោយការរមិលមើល យ៉ាងណា ពាក្យប្រដៅរបស់ព្រះសម្ពុទ្ធអង្គនោះ គេមិនឆ្អែតដោយការស្តាប់ ក៏យ៉ាងនោះដែរ ។ ព្រះអង្គមានព្រះជន្ម ៩ ម៉ឺនឆ្នាំជាកំណត់ ព្រះអង្គគង់នៅដរាបអស់កាលប៉ុណ្ណោះ ទ្រង់ញ៉ាំងប្រជុំជន ឲ្យឆ្លង ( វដ្តសង្សារ ) ។ ព្រះអង្គ ព្រមទាំងសាវ័ក ទ្រង់ឲ្យឱវាទនិងការប្រៀនប្រដៅចំពោះជនដ៏សេស ហើយញ៉ាំងជនទាំងនោះឲ្យមានព្យាយាម ដុតកម្តៅកិលេសដូចភ្លើង រួចបរិនិព្វាន ។ ព្រះសម្ពុទ្ធស្មើដោយព្រះពុទ្ធ ឥតមានបុគ្គលស្មើអង្គនោះក្តី ពួកសាវ័កទាំងនោះ ដែលដល់នូវកម្លាំងក្តី របស់ទាំងអស់នេះ ក៏វិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតរំសីវ** សេចក្តីថា ដូចព្រះអាទិត្យចាំងរស្មីទៅគ្រប់ទិស ។ បទថា **បវនំ** បានដល់ ព្រៃធំ ។ បទថា **ធូបិតំ** បានដល់ អប់ធ្វើឲ្យមានក្លិន ។ បទថា **អតប្បិយោ** បានដល់ មិនធ្វើនូវការឆ្អែត ឬមិនកើតការឆ្អែត ។ បទថា **តាវទេ** បានដល់ ក្នុងកាលនោះ សេចក្តីថា ក្នុងកាលមានប្រមាណប៉ុណ្ណោះ ។ បទថា **តារេសិ** បានដល់ ឲ្យឆ្លង ។ បទថា

**ឱវាទំ** សេចក្តីថា ការទូន្មានមុន ឈ្មោះថា ឱវាទៈ ។ បទថា **អនុសិដ្ឋី** បានដល់ ពោលរឿយៗ ឈ្មោះថា **អនុសិដ្ឋិ** ។ បទថា **សេសកេ ជនេ** បានដល់ ដល់ជនដ៏សេស ដែលមិនទាន់ចាក់ធ្លុះសច្ចៈ ។ បទនេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ ។ បទថា **ហុតាសនោវ តាបេត្វា** បានដល់ ដូចភ្លើងឆេះហើយ ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា សេចក្តីថា ព្រះមានព្រះភាគបរិនិព្វាន ព្រោះអស់ឧបាទាន ។ ក្នុងគាថាដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។

## អដ្ឋកថាសោភិតពុទ្ធវង្សទី ៦ ចប់

# សុត្តន្តបិដក

## អនោមទស្សិពុទ្ធវង្សទី ៧

[ ៨ ] កាលជាខាងក្រោយអំពីព្រះសោភិតសម្ពុទ្ធមក មានព្រះសម្ពុទ្ធព្រះនាមអនោមទស្សី ព្រះអង្គប្រសើរជាងសត្វទ្វេបាទ ទ្រង់មានយសរាប់មិនបាន ទ្រង់មានតេជះ ទ្រង់កម្របុគ្គលកន្លងបាន ។ ព្រះសម្ពុទ្ធទ្រង់កាត់ចំណងទាំងអស់ កម្ចាត់បង់ភពទាំង ៣ ហើយសម្តែងផ្លូវសម្រាប់ដើរឆ្ពោះទៅរកនិព្វាន មិនត្រឡប់វិញ ចំពោះទេវតា និងមនុស្ស ។ ព្រះអនោមទស្សីអង្គនោះ ទ្រង់មិនរំកើបដូចជាសាគរ គេគ្របសង្កត់បានដោយក្រ ដូចជាភ្នំ ទ្រង់មានគុណរកទីបំផុតគ្មាន ដូចជាអាកាស មានព្រះកាយរីកពេញ ដូចជាស្តេចឈើ ។ ពួកសត្វគ្រាន់តែឃើញព្រះសម្ពុទ្ធអង្គនោះ ក៏មានសេចក្តីត្រេកអរ សត្វទាំងនោះ លុះបានស្តាប់មធុរវាចាដែលលាន់ឮ ក៏បានដល់អមតនិព្វាន ។ កាលនោះ ការត្រាស់ដឹងធម៌របស់ព្រះអង្គ ក៏ធំទូលាយផ្សាយទៅ ចំនួនពួកសត្វ ១០០ កោដិ បានត្រាស់ដឹង ក្នុងការសម្តែងធម៌លើកទី ១ ។ លំដាប់អំពីនោះមក កាលព្រះសម្ពុទ្ធបង្អុរចុះនូវភ្លៀង គឺធម៌ក្នុងអភិសម័យ ពួកសត្វ ៨០ កោដិ បានត្រាស់ដឹងក្នុងការសម្តែងធម៌លើកទី ២ ។ តអំពីនោះមកទៀត កាលព្រះសម្ពុទ្ធទ្រង់បង្អុរចុះគ្រាប់ភ្លៀង គឺធម៌ ទ្រង់ញុំាងពួកសត្វឲ្យឆ្អែតស្កប់ស្កល់ ( ដោយធម៌ ) ពួកសត្វ ៧៨ កោដិ បានសម្រេចមគ្គផលលើកទី ៣ ។

ព្រះអនោមទស្សីអង្គនោះ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះអរហន្ត បានសម្រេចអភិញ្ញាពល រីកពេញដោយវិមុត្តិ គឺសន្និបាតលើកទី ១ កាលនោះ មានព្រះអរហន្ត ៨ សែន ដែលមានសេចក្តីស្រវឹង និងសេចក្តីវង្វេងលះបង់ហើយ មានសន្តានស្ងប់រម្ងាប់ ទាំងមានចិត្តនឹងធឹង ។ សន្និបាតលើកទី ២ មានព្រះអរហន្ត ៧ សែន ដែលមិនមានទីទួល គឺកិលេស ប្រាសចាកធូលី គឺកិលេស ទាំងមានសន្តានស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ សន្និបាតលើកទី ៣ មានព្រះអរហន្ត ៦ សែន ដែលបានសម្រេចអភិញ្ញាពល មានទុក្ខរម្ងត់ហើយ មានព្យាយាមដុតកម្តៅកិលេស ។ សម័យនោះ តថាគតកើតជាយក្ខ មានឫទ្ធិច្រើន ជាធំជាងពួកយក្ខ ច្រើនកោដិក្នុងវសវត្តីទេវលោក ។ កាលនោះ តថាគតបានចូលទៅគាល់ព្រះសម្ពុទ្ធប្រសើរអង្គនោះ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ហើយអង្គាសព្រះលោកនាយក ព្រមទាំងព្រះសង្ឃ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ ឯព្រះមុនីអង្គនោះ ទ្រង់មានព្រះនេត្រដ៏បរិសុទ្ធ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ យក្ខនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញចាកអំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយនៅទៀបគល់នៃអជបាល-

ព្រឹក្ស ទទួលបាយាសក្នុងទីនោះ រួចហើយ ចូលទៅកាន់ស៊ឹង នេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរ ស៊ឹងនេរញ្ជរា ហើយក៏ចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ តអំពីនោះមក ព្រះជិនស្រីមាន យស ច្រើន ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយបានត្រាស់ ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតនៃព្រះសម្ពុទ្ធនេះ នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ យក្ខនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្ត ស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ព្រះថេរៈឈ្មោះ អានន្ទនឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះ ខេមា ១ ឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ឈើ សម្រាប់ត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ គេហៅថា អស្សត្ថ-ព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមដ៏ទ្រង់យសអង្គនោះ មានព្រះជន្ម ១០០ ឆ្នាំ ។ ពួក មនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះ អនោមទស្សីមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំហើយ ក៏

មានចិត្តរីករាយថា យក្ខនេះ ជាពូជពន្ធកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតា មួយម៉ឺនលោកធាតុ នាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា ពួកយើង បើនឹងឃ្លាងមគ្គផលក្នុងសាសនា របស់ព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តានេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រព្រះពុទ្ធអង្គនេះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអនោមទស្សីអង្គនោះ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត បានអធិដ្ឋានទូវវត្តតទៅទៀត ដោយការបំពេញបារមីទាំង ១០ ។ ព្រះសាស្តាព្រះនាមអនោមទស្សី មាននគរឈ្មោះចន្ទវតី មហាក្សត្រព្រះនាមយសវាជាព្រះបិតា ព្រះមាតាព្រះនាមយសោ-ធរា ។ ព្រះអនោមទស្សីអង្គនោះ ទ្រង់នៅគ្រប់គ្រងព្រះរាជដំណាក់អស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ប្រសើរ មាន ៣ គឺសិរិប្រាសាទ ១ ឧបសិរិប្រាសាទ ១ វឌ្ឍប្រាសាទ ១ ( សម្រាប់ព្រះអង្គ ) ។ ពួកនារី ២ ម៉ឺន ៣ ពាន់នាក់ មានរូបប្រដាប់សមរម្យ នារីជាអគ្គមហេសីនោះ ព្រះនាមសិរិមា មានព្រះរាជបុត្ត ព្រះនាម

ឧបសាលៈ ។ ព្រះជិនស្រី ទ្រង់បានឃើញនូវនិមិត្ត ៤ យ៉ាង ហើយស្តេចចេញទៅដោយរ ( គ្រែស្នែង ) ទ្រង់តាំងសេចក្តីព្យាយាមអស់ ១០ ខែឥតខ្វះ ។ ព្រះអនោមទស្សីមហាមុនី មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ដែលព្រហ្មអារាធនាហើយ ទ្រង់សម្តែងធម្មចក្កក្នុងសុទស្សនឧទ្យានដ៏ឧត្តម ។ ព្រះថេរៈឈ្មោះនិសភៈ ១ អនោមៈ ១ ជាអគ្គសាវក ឯព្រះថេរៈឈ្មោះវរុណៈ ជាឧបដ្ឋាករបស់ព្រះសាស្តាព្រះនាមអនោមទស្សីនោះ ។ ព្រះថេរីឈ្មោះ សុន្ទរា ១ សុមនា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថា អជ្ជុនព្រឹក្ស ( ដើមអង្គ្រង ) ។ ឧបាសកឈ្មោះ នន្ទិវឌ្ឍៈ ១ សិរិវឌ្ឍៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះឧបលា ១ បទុមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីមានកម្ពស់ ៥៨ ហត្ថ ពន្លឺនៃព្រះអង្គផ្សាយចេញទៅ ដូចព្រះអាទិត្យរះឡើង ។ ព្រះអង្គមានព្រះជន្មាយុមួយសែនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់កាលដរាបនោះ ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( វដ្តសង្សារ ) ។ ពាក្យជាប្រធាន គឺសាសនារីកល្អហើយ ដោយពួកអរហន្ត ជាតាទិបុគ្គល ប្រាសចាករាគៈ ប្រាសចាកមន្ទិល សាសនារបស់ព្រះ

ជិនស្រី ល្អរុងរឿង ។ ឯព្រះសាស្តាអង្គនោះ មានយសរាប់មិនបានក្តី គូនៃសាវ័កទាំងនោះ មានគុណថ្លឹងមិនបានក្តី របស់ទាំង ( នោះ ) វិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ។ ព្រះជិនស្រីជាសាស្តា ព្រះនាមអនោមទស្សី ទ្រង់បរិនិព្វានក្នុងធម្មារាម ឯព្រះស្តូបបញ្ចុះព្រះធាតុរបស់ព្រះជិនស្រីអង្គនោះ មានកម្ពស់ ២០ យោជន៍ ប្រតិស្ឋាននៅក្នុងអារាមនោះ ។

## អនោមទស្សិពុទ្ធវង្សទី ៧ ចប់

# អដ្ឋកថា

## អនោមទស្សីពុទ្ធវង្សទី ៧

កាលព្រះសោភិតសម្ពុទ្ធបរិនិព្វានហើយ ក្រោយសាសនារបស់ព្រះអង្គ មួយអសង្ខេយ្យ មិនមានព្រះពុទ្ធកើតឡើង កាលអសង្ខេយ្យនោះកន្លងទៅហើយ ព្រះពុទ្ធ ៣ ព្រះអង្គ គឺអនោមទស្សីសម្ពុទ្ធ ១ បទុមសម្ពុទ្ធ ១ នារទសម្ពុទ្ធ ១ ទ្រង់កើតឡើងក្នុងកប្បជាមួយគ្នា ។ បណ្ដាព្រះពុទ្ធ ៣ អង្គនោះ ព្រះមានព្រះភាគអនោមទស្សី ទ្រង់បំពេញបារមី ១៦ អសង្ខេយ្យ និង ១ សែនកប្ប កើតក្នុងស្ថានសួគ៌ជាន់តុសិត កាលពួកទេវតាអារាធនាហើយ ក៏ចុតិចាកតុសិតសួគ៌នោះ ទ្រង់កាន់យកបដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងយសោធរា មានព្រះសុជន់ល្អ ដែលជាអគ្គមហេសី ក្នុងរាជត្រកូលរបស់ព្រះបាទយសវា នគរចន្ទវតីរាជធានី ។ បានឮថា កាលព្រះអនោមទស្សីកុមារ នៅក្នុងផ្ទៃរបស់ព្រះនាងយសោធរាទេវី ដោយអានុភាពបុណ្យបារមី ព្រះរស្មីផ្សាយទៅអស់ទីប្រមាណ ៨០ ហត្ថ រស្មីព្រះចន្ទ និងព្រះអាទិត្យ គ្របសង្កត់មិនបាន ។ លុះគ្រប់កំណត់ទសមាស ព្រះនាងក៏ប្រសូតព្រះពោធិសត្វ បាដិហារ្យទាំងឡាយ មានន័យដូចបានពោលអំពីខាងដើម ។

ក្នុងថ្ងៃទទួលព្រះនាម ព្រះញាតិកាលថ្វាយព្រះនាមរបស់ព្រះអង្គ ព្រោះរតនៈ ៧ ប្រការធ្លាក់ចុះអំពីអាកាសក្នុងខណៈប្រសូត ហេតុនោះ ទើបថ្វាយព្រះនាមថា អនោមទស្សី ព្រោះជាហេតុកើតរតនៈមិនថោកថយ ។ ព្រះអង្គទ្រង់ចម្រើនវ័យដោយលំដាប់ ទ្រង់បានទទួលការបម្រើដោយកាមគុណដូចជាទិព្វ ទ្រង់នៅជាយរាវាសវិស័យអស់មួយម៉ឺនឆ្នាំ ។ បានឮថា ទ្រង់មានប្រាសាទ

៣ គឺសិរីប្រាសាទ ១ ឧបសិរីប្រាសាទ ១ សិរិវឌ្ឍប្រាសាទ ១[១] ទ្រង់មានស្នំ ២ ម៉ឺន ៣ ពាន់ មានព្រះនាងសិរិមាទេវីជាប្រធាន កាលព្រះឧបវាណឱរសរបស់ព្រះនាងសិរិមាទេវីប្រសូត ព្រះពោធិសត្វនោះ ទ្រង់ឃើញនិមិត្ត ៤ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយយាន គឺរ ទ្រង់បួសហើយ ជន ៣ កោដិក៏បួសតាមព្រះអង្គ ។

ព្រះមហាបុរស ដែលជន ៣ កោដិចោមរោមហើយ ទ្រង់បំពេញព្យាយាម ១០ ខែ បន្ទាប់អំពីនោះ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់បិណ្ឌបាតក្នុងស្រុកព្រាហ្មណ៍អនូបមៈ ទ្រង់សោយមធុបាយាសដែលធីតាអនូបមសេដ្ឋីថ្វាយហើយទ្រង់សម្រាកពេលថ្ងៃក្នុងព្រៃសាលវ័ន ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអាជីវកឈ្មោះអនូបមៈថ្វាយហើយ ទ្រង់ធ្វើប្រទក្សិណអជ្ជុនពោធិព្រឹក្ស គឺដើមថ្វាន់ ទ្រង់លាតសន្ថតស្មៅទំហំ ៣៨ ហត្ថ គង់ពត់ភ្នែន អធិដ្ឋានសេចក្តីព្យាយាមប្រកបដោយអង្គ ៤ ទ្រង់កម្ចាត់មារ មួយអន្លើដោយសេនា ទ្រង់ញុំាងវិជ្ជា ៣ ឲ្យកើតក្នុងយាមទាំង ៣ ទ្រង់បន្លឺឧទានថា

> កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វរល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយដូច្នេះ ។

---

១- បិដកខ្មែរជា វឌ្ឍប្រាសាទ ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលជាខាងក្រោយអំពីព្រះសោភិតសម្ពុទ្ធមក មានព្រះសម្ពុទ្ធ ព្រះនាមអនោមទស្សី ព្រះអង្គប្រសើរជាងសត្វទ្វេបាទ ទ្រង់មានយសរាប់មិនបាន ទ្រង់មានតេជះ ទ្រង់កម្របុគ្គលកន្លងបាន ។ ព្រះសម្ពុទ្ធទ្រង់កាត់ចំណងទាំងអស់ កម្ចាត់បង់ភពទាំង ៣ ហើយ សម្តែងផ្លូវសម្រាប់ដើរឆ្ពោះទៅរកនិព្វាន មិនត្រឡប់វិញ ចំពោះទេវតា និងមនុស្ស ។ ព្រះអនោមទស្សី អង្គនោះ ទ្រង់មិនរំភើប ដូចជាសាគរ គេគ្របសង្កត់បានដោយក្រ ដូចជាភ្នំ ទ្រង់មានគុណរកទីបំផុតគ្មាន ដូចជាអាកាស មានព្រះកាយរីកពេញដូចជាស្តេចឈើ ។ ពួកសត្វគ្រាន់តែឃើញព្រះសម្ពុទ្ធអង្គនោះ ក៏មានសេចក្តីត្រេកអរ សត្វទាំងនោះ លុះបានស្តាប់មធុរវាចា ដែលលាន់ឮ ក៏បានដល់អមតនិព្វាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនោមទស្សី** បានដល់ គួរមើល មិនមានអ្វីប្រៀប ឬគួរមើលប្រមាណមិនបាន ។ បទថា **អមិតយសោ** បានដល់ ទ្រង់មានបរិវារប្រមាណមិនបាន ឬមានកិត្តិយសប្រមាណមិនបាន ។ បទថា **តេជស្សី** បានដល់ ទ្រង់ប្រកបដោយតេជះ គឺសីល សមាធិ និងបញ្ញា ។ បទថា **ទុរតិក្កមោ** បានដល់ ដែលបុគ្គលណាមួយកម្ចាត់បានលំបាក អធិប្បាយថា ទ្រង់ជាបុគ្គលដែលទេវតា មារ ឬបុគ្គលណាមួយ មិនអាច

បំពានបាន ។ បទថា **សោ ចេត្វា ពន្ធនំ សព្វំ** បានដល់ ទ្រង់កាត់នូវសំយោជនៈ ១០ បានទាំងអស់ ។ បទថា **វិធំសេត្វា តយោ ភវេ** បានដល់ ទ្រង់កម្ចាត់កម្មដែលទៅកាន់ភពទាំង ៣ ដោយញាណជាគ្រឿងធ្វើឲ្យអស់កម្ម អធិប្បាយថា ធ្វើមិនឲ្យមាន ។ បទថា **អនិវត្តិគមនំ មគ្គំ** សេចក្ដីថា ព្រះនិព្វានជាបដិបក្ខចំពោះការត្រឡប់ ការមិនត្រឡប់ លោកហៅថា **អនិវត្តិ** បុគ្គលរមែងដល់ព្រះនិព្វាន ដែលមិនត្រឡប់នោះដោយមគ្គនោះ ហេតុនោះ មគ្គនោះ ឈ្មោះថា **អនិវត្តិគមន** អធិប្បាយថា ទ្រង់សម្ដែងមគ្គមានអង្គ ៨ ដែលមានការទៅមិនត្រឡប់នោះ ។ បាឋៈថា **ទស្សេតិ** ដូច្នេះក៏មាន ។ សេចក្ដីក៏យ៉ាងនោះដូចគ្នា ។ បទថា **ទេវមានុសេ** បានដល់ សម្រាប់ទេវតា និងមនុស្សទាំងឡាយ គប្បីឃើញថា ពាក្យនេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ ។

បទថា **អសង្ខោភោ** សេចក្ដីថា ទ្រង់ជាបុគ្គលដែលបុគ្គលណាមួយមិនអាចឲ្យរំភើប ឲ្យញាប់ញ័របាន ព្រោះហេតុនោះ ទើបឈ្មោះថា **អសង្ខោភ** អធិប្បាយថា ដូចសមុទ្រជម្រៅ ៨៤០០០ យោជន៍ ជាលំនៅនៃកូតច្រើនពាន់យោជន៍ ដែលបុគ្គលណាមួយឲ្យរញ្ជួយមិនបាន យ៉ាងណា ទ្រង់ក៏ជាបុគ្គលដែលបុគ្គលណាមួយឲ្យរំភើបមិនបាន ក៏យ៉ាងនោះ ។ បទថា **អាកាសោវ អនន្តោ** សេចក្ដីថា ដូចទីបំផុតនៃអាកាសមិនមាន ពិតហើយ អាកាសមានទីបំផុតប្រមាណមិនបាន មិនមានព្រំដែន យ៉ាងណា ព្រះមានព្រះភាគ ក៏មិនមានទីបំផុត ប្រមាណមិនបាន មិនមានព្រំដែន ដោយពុទ្ធគុណទាំងឡាយ ក៏

យ៉ាងនោះ ។ បទថា **សោ** បានដល់ ព្រះមានព្រះភាគអង្គនោះ ។ បទថា **សាលរាជាវ ផុល្លិតោ** សេចក្ដីថា ល្អ ដូចស្ដេចសាលព្រឹក្ស ដែលមានផ្ការីកស្គុះស្គាយ ព្រោះទ្រង់មានព្រះសរីរៈប្រដាប់ដោយព្រះលក្ខណៈ និងអនុព្យញ្ជនៈសព្វយ៉ាង ។ បទថា **ឧស្សនេនបិ តំ ពុទ្ធំ** សេចក្ដីថា ដោយការឃើញព្រះពុទ្ធអង្គនោះ ។ ក្នុងឋានៈបែបនេះ អ្នកប្រាជ្ញខាងសព្ទសាស្ត្រ រមែងប្រកបចដ្ឋីវិភត្តិ ។ បទថា **តោសិតា** បានដល់ ត្រេកអរ ឆ្អែត ។ បទថា **ព្យាហរន្តំ** បានដល់ កំពុងត្រាស់ដឹង ពាក្យនេះ ជាទុតិយាវិភត្តិ តែចុះក្នុងអត្ថចដ្ឋីវិភត្តិ ។ បទថា **អមតំ** បានដល់ ព្រះនិព្វាន ។ បទថា **ចាបុណន្តិ** បានដល់ សម្រេច ។ បទថា **តេ** សេចក្ដីថា សត្វទាំងឡាយណា ស្ដាប់ព្រះតម្រាស់ គឺព្រះធម្មទេសនារបស់ព្រះអង្គ សត្វទាំងនោះ រមែងសម្រេចអមតធម៌ ។

ព្រះមានព្រះភាគ ទ្រង់សម្រាំនៅក្បែរមណ្ឌលពោធិព្រឹក្ស ៧ សប្ដាហ៍ កាលមហាព្រហ្មអារាធនាហើយ ទ្រង់ប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ ដើម្បីទ្រង់សម្ដែងធម៌ ទ្រង់ឃើញជន ៣ កោដិ ដែលដល់ព្រមដោយឧបនិស្ស័យ បួសជាមួយព្រះអង្គ ទ្រង់ពិចារណាថា ឥឡូវនេះ ជនទាំងនោះនៅឯណាហ្ន៎ ទ្រង់ក៏ឃើញជនទាំងនោះ នៅត្រង់សុធម្មរាជឧទ្យាន ក្នុងសុរវតីនគរ ទ្រង់យាងទៅតាមអាកាស ចុះត្រង់សុធម្មរាជឧទ្យាន ។ ព្រះសាស្ដា កាលជនទាំងនោះចោមរោមហើយ ទ្រង់ប្រកាសធម្មចក្រកណ្ដាលបរិស័ទ មួយអន្លើដោយទេវតា និងមនុស្សក្នុងទីនោះ ការសម្រេចធម៌លើកទី

១ មានដល់សត្វមួយរយកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលនោះ ការត្រាស់ដឹងធម៌របស់ព្រះអង្គ ក៏ជំទូលាយផ្សាយ
ទៅ ចំនួនពួកសត្វ ១០០ កោដិ បានត្រាស់ដឹង ក្នុងការ
សម្តែងធម៌លើកទី ១ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជីតោ** បានដល់ ដល់នូវសេចក្តីចម្រើន ដោយជនជាច្រើនដែលដឹងធម៌ ។ បទថា **កោដិសតានិ** បានដល់ ១០០ កោដិ ឈ្មោះថា **កោដិសត្ត** បាឋៈថា **កោដិសតយោ** ដូច្នេះក៏មាន ។ បាឋៈនោះ សេចក្តីថា ១០០ កោដិ ។

សម័យក្រោយមក ព្រះមានព្រះភាគទ្រង់ធ្វើយមកប្បាដិហារ្យ ត្រង់គល់ផ្ទង់ ក្បែរទ្វារឱសធីនគរ ប្រថាប់គង់លើទែនបណ្ឌុកម្ពលសិលាអាសនៈ ក្នុងភពតាវត្តិង្ស ដែលអសុរគ្របសង្កត់បានដោយលំបាក ទ្រង់ញុំាងភ្លៀង គឺព្រះអភិធម្មឲ្យធ្លាក់អស់ ៣ ខែ ។ កាលនោះ ទេវតា ៨០ កោដិ បានត្រាស់ដឹងធម៌ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

លំដាប់អំពីនោះមក កាលព្រះសម្ពុទ្ធបង្អុរចុះនូវភ្លៀង គឺធម៌
ក្នុងអភិសម័យ ពួកសត្វ ៨០ កោដិ បានត្រាស់ដឹង ក្នុងការ
សម្តែងធម៌លើកទី ២ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វស្សន្តេ** បានដល់ កាលមហាមេឃ គឺព្រះពុទ្ធបង្អុរនូវភ្លៀងឲ្យធ្លាក់ ។ បទថា **ធម្មវុដ្ឋិយា** បានដល់ គ្រាប់ភ្លៀង គឺធម្មកថា ។

សម័យបន្ទាប់អំពីនោះ ក្នុងកាលដែលទ្រង់សម្តែងមង្គលបញ្ហា សត្វ ៧៨ កោដិ បានត្រាស់ដឹងធម៌ ។ នេះជាការសម្រេចធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

តអំពីនោះមកទៀត កាលព្រះសម្ពុទ្ធទ្រង់បង្អុរបុះ គ្រាប់ភ្លៀង
គឺធម៌ ទ្រង់ញុំាងពួកសត្វ ឲ្យឆ្អែតស្កប់ស្កល់ ( ដោយធម៌ )
ពួកសត្វ ៧៨ កោដិ បានសម្រេចមគ្គផលលើកទី ៣ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វស្សន្តេ** បានដល់ ទ្រង់បង្អុរនូវធារទឹក គឺធម្មកថា ។ បទថា **តប្បយន្តេ** បានដល់ ឲ្យឆ្អែតដោយទឹកភ្លៀង គឺអមតធម៌ អធិប្បាយថា កាលព្រះមានព្រះភាគទ្រង់ធ្វើបុគ្គលនោះឲ្យឆ្អែត ។

ព្រះមានព្រះភាគអនោមទស្សី ទ្រង់មានសាវកសន្និបាត ៣ លើក ក្នុង ៣ លើកនោះ ទ្រង់លើកបាតិមោក្ខឡើងសម្តែងត្រង់កណ្តាលព្រះអរហន្ត ៨ សែន ដែលជ្រះថ្លាក្នុងធម៌ ដែលទ្រង់សម្តែងប្រោសព្រះបាទឥសិទត្តៈ ក្នុងនគរសោរេយ្យ ហើយបួសដោយឯហិភិក្ខុ នេះជាការប្រជុំលើកទី ១ ។ ក្នុងកាលទ្រង់សម្តែងធម៌ប្រោសព្រះបាទសុន្ទរិន្ធរៈ ត្រង់នគររាជវតី ទ្រង់លើកបាតិមោក្ខឡើងសម្តែងត្រង់កណ្តាលព្រះអរហន្ត ៧ សែន ដែលបួសដោយឯហិភិក្ខុ ។ នេះជាការប្រជុំលើកទី ២ ។ ទ្រង់លើកបាតិមោក្ខឡើងកណ្តាលព្រះអរហន្ត ៦ សែន ដែលបួសដោយឯហិភិក្ខុ ជាមួយព្រះបាទសោរេយ្យ ក្នុងនគរសោរេយ្យទៀត ។ នេះជាការប្រជុំលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះអនោមទស្សីអង្គនោះ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាន សាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះអរហន្ត បាន សម្រេចអភិញ្ញាពល រីកពេញដោយវិមុត្តិ គឺសន្និបាតលើកទី ១ កាលនោះ មានព្រះអរហន្ត ៨ សែន ដែលមានសេចក្តី ស្រវឹង និងសេចក្តីវង្វេង លះបង់ហើយ មានសន្តានស្ងប់រម្ងាប់ ទាំងមានចិត្តនឹងធឹង ។ សន្និបាតលើកទី ២ មានព្រះអរហន្ត ៧ សែន ដែលមិនមានទីទួល គឺកិលេស ប្រាសចាកធូលី គឺ កិលេស ទាំងមានសន្តានស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ សន្និបាតលើកទី ៣ មានព្រះអរហន្ត ៦ សែន ដែលបាន សម្រេចអភិញ្ញាពល មានទុក្ខរម្ងត់ហើយ មានព្យាយាមដុត កម្តៅកិលេស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្សាបិ ច មហេសិនោ** បានដល់ ព្រះ អនោមទស្សីសម្ពុទ្ធ ទ្រង់ស្វែងរកគុណធំអង្គនោះ ។ បាឋៈថា **តស្សាបិ ទ្វិបទុត្តមោ** ដូច្នេះក៏មាន សេចក្តីថា អគ្គបុគ្គលក្រៃលែងជាងសត្វជើង ២ អង្គនោះ ។ គប្បីកាន់យកលក្ខណៈដោយអត្ថនៃសព្ទ ។ បទថា **អភិញ្ញា-ពលប្បត្តានំ** បានដល់ ជាអ្នកដល់នូវកម្លាំងនៃអភិញ្ញាទាំងឡាយ អធិប្បាយ ថា ដល់នូវការមាំទាំក្នុងអភិញ្ញាទាំងឡាយ ដោយការពិចារណាយ៉ាងរួសរាន់ ព្រោះជាអ្នកជំនាញ ។ បទថា **បុប្ផិតានំ** បានដល់ ដល់នូវការស្អាតពន់ពេក ព្រោះរីកពេញហើយ ។ បទថា **វិមុត្តិយា** បានដល់ ដោយអរហត្តផលវិមុត្តិ ។

ក្នុងបទថា **អនង្គណានំ** នេះ **អនង្គណា** សព្ទ ទីខ្លះ ប្រើក្នុងកិលេសទាំងឡាយ ដូចទ្រង់ត្រាស់ ( ក្នុងអភិធម្មវិភង្គ ) ថា បណ្តាធម៌ទាំងនោះ ទីទួល ៣ តើដូចម្តេច ។ រាគៈ ជាទីទួល ១ ទោសៈ ជាទីទួល ១ មោហៈ ជាទីទួល ១ នេះទីទួល ៣ ដូច្នេះ ។ និងព្រះសារីបុត្តពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) អង្គណៈនេះ ជាឈ្មោះនៃវត្ថុអ្វី ។ ព្រះសារីបុត្រឆ្លើយថា ម្នាលអាវុសោ ពាក្យថា អង្គណៈនេះ ជាឈ្មោះនៃអកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចនៃសេចក្តីប្រាថ្នា ។ ក្នុងទីខ្លះ ប្រើក្នុងអត្ថថា មន្ទិលឯណានីមួយ ដូចព្រះមហាមោគ្គល្លានពោលថា តែងព្យាយាមជម្រះធូលី ឬមន្ទិលនោះចេញដូច្នេះ ។ ក្នុងទីខ្លះ ប្រើជាទីកន្លែង ដូចពាក្យថា **ចេតិយង្គណំ** លានព្រះចេតិយ **ពោធិយង្គណំ** លានពោធិព្រឹក្ស **រាជង្គណោ** លានព្រះរាជវាំង ឯក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងកិលេសទាំងឡាយ ព្រោះហេតុនោះ ទើបមានសេចក្តីថា បុគ្គលមិនមានកិលេស ។ បទថា **វិរជានំ** ជាវេវចនៈនៃបទថា **អនង្គណានំ** នោះឯង ។ បទថា **តបស្សិនំ** សេចក្តីថា **តប** ពោល គឺអរិយមគ្គ ដែលធ្វើនូវការអស់កិលេសរបស់ភិក្ខុណាមាន ភិក្ខុទាំងនោះ ឈ្មោះថា **តបស្សី** គឺអ្នកមានតបៈ ។ ភិក្ខុដែលមានតបៈទាំងនោះ គឺព្រះខីណាស្រព ។

គ្រានោះ ព្រះពោធិសត្វនៃយើងទាំងឡាយ កើតជាយក្ខសេនាបតី មានសក្តិធំ មានឫទ្ធានុភាពច្រើន ជាអធិបតីនៃយក្ខច្រើនសែនកោដិ ព្រះពោធិសត្វនោះ បានដំណឹងថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ក៏មកនិម្មិត

មណ្ឌប សម្រេចដោយរតនៈ ៧ ល្អគួរមើលក្រៃលែង ដូចព្រះចន្ទល្អត្រកាល ថ្វាយមហាទានដល់សង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងមណ្ឌបនោះ អស់ ៧ ថ្ងៃ ។ ពេលអនុមោទនាភត្តទាន ព្រះមានព្រះភាគទ្រង់ព្យាករថា ក្នុងកាលអនាគត កន្លងទៅមួយអសង្ខេយ្យ និងមួយសែនកប្ប យក្ខនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតកើតជាយក្ខ មានឫទ្ធិច្រើន ជាធំជាងពួកយក្ខច្រើនកោដិ ក្នុងវសវត្តីទេវលោក ។ កាលនោះ តថាគតបានចូលទៅគាល់ព្រះសម្ពុទ្ធប្រសើរអង្គនោះ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ហើយអង្គាសព្រះលោកនាយក ព្រមទាំងព្រះសង្ឃ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ ឯព្រះមុនីអង្គនោះ ទ្រង់មានព្រះនេត្រដ៏បរិសុទ្ធ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ យក្ខនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញចាកអំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ។បេ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រព្រះពុទ្ធអង្គនេះ ក្នុងកាលជាអនាគតមិនខានក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអនោមទស្សីអង្គនោះ ក៏មានចិត្តត្រេកអរ

មានចិត្តតក់ស្លុត បានអធិដ្ឋានទូវវត្តតទៅទៀត ដោយការ
បំពេញបារមីទាំង ១០ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧត្តរិំ វតមធិដ្ឋាសឹ** សេចក្តីថា តថាគត បានធ្វើសេចក្តីព្យាយាមក្រៃលែងឡើង ដើម្បីឲ្យបារមីបរិបូណ៌ ។

ព្រះមានព្រះភាគអនោមទស្សីអង្គនោះ ទ្រង់មានព្រះនគរឈ្មោះចន្ទវតី ព្រះជនកព្រះនាមព្រះបាទយសវា ព្រះជននីព្រះនាមយសោធរា គូអគ្គសាវក ឈ្មោះនិសភៈ ១ អនោមៈ ១ ពុទ្ធុប្បដ្ឋាកឈ្មោះវរុណៈ គូនៃអគ្គសាវិកា ឈ្មោះសុន្ទរី ១ សុមនា ១ ដើមអជ្ជុន គឺដើមថ្ងាន់ជាពោធិព្រឹក្ស ព្រះសរីរៈ កម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុមួយសែនឆ្នាំ អគ្គមហេសីព្រះនាមសិរិមា ព្រះ ឱរសព្រះនាមឧបវាណ[១] ទ្រង់នៅជាយរាវាសវិស័យមួយម៉ឺនឆ្នាំ ទ្រង់យាង អភិនេស្រ្កមណ៍ដោយយាន គឺវ ។ ឯការយាងទៅ គប្បីជ្រាបតាមន័យដែល ពោលមកហើយ ក្នុងការយាងដោយប្រាសាទ នៃកិច្ចពណ៌នាវង្សរបស់ព្រះ សោភិតសម្ពុទ្ធ ។ ព្រះបាទធម្មកៈជាឧបដ្ឋាក បានឮថា ព្រះមានព្រះភាគ គង់នៅត្រង់វិហារធម្មារាម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តាព្រះនាមអនោមទស្សី មាននគរឈ្មោះចន្ទវតី មហា
ក្សត្រព្រះនាមយសវាជាព្រះបិតា ព្រះមាតាព្រះនាមយសោធរា ។
ព្រះថេរៈឈ្មោះនិសភៈ ១ អនោមៈ ១ ជាអគ្គសាវក ឯព្រះថេរៈ
ឈ្មោះវរុណៈ ជាឧបដ្ឋាករបស់ព្រះសាស្តា ព្រះនាមអនោមទស្សី

---

១- បិដកខ្មែរជា ឧបសាលៈ ។

នោះ ។ ព្រះថេរីឈ្មោះសុន្ទរា ១ សុមនា ១ ជាអគ្គសាវិកា ឈើ សម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថាអជ្ជុនព្រឹក្ស ( ដើមអង្រ្គង ) ។ ព្រះមហាមុនីមានកម្ពស់ ៥៨ ហត្ថ ពន្លឺនៃ ព្រះអង្គផ្សាយចេញទៅ ដូចព្រះអាទិត្យរះឡើង ។ ព្រះអង្គមាន ព្រះជន្មាយុមួយសែនឆ្នាំជាកំណត់ ទ្រង់ស្ថិតនៅអស់កាលដរាប នោះ ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( វដ្តសង្សារ ) ។ ពាក្យជា ប្រធាន គឺសាសនា រីកល្អហើយ ដោយពួកអរហន្ត ជាតាទិបុគ្គល ប្រាសចាករាគៈ ប្រាសចាកមន្ទិល សាសនារបស់ព្រះជិនស្រី ល្អរុងរឿង ។ ឯព្រះសាស្តាអង្គនោះ មានយសរាប់មិនបានក្តី គូនៃ សាវកទាំងនោះ មានគុណប្រឹងមិនបានក្តី របស់ទាំង ( នោះ ) វិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បភា និទ្ធាវតី** សេចក្តីថា ព្រះរស្មីផ្សាយ ចេញអំពីសរីរៈរបស់ព្រះអង្គ ។ ព្រះរស្មីនៃព្រះសរីរៈ ផ្សាយទៅអស់ទីមាន ប្រមាណ ១២ យោជន៍ អស់កាលជានិច្ច ។ បទថា **យុគានិ តានិ** បាន ដល់ គូអគ្គសាវកជាដើម ។ បទថា **សព្វំ តមន្តរហិតំ** សេចក្តីថា ព្រះ សាស្តា និងសាវកទាំងពួង មានប្រការដូចពោលហើយ ចូលកាន់មាត់

អនិច្ចលក្ខណៈ ហើយក៏អន្តរធានទៅ ។ បាឋៈថា **ឆន្នុ វិត្តកាមេវ សង្ខារា** ដូច្នេះក៏មាន ។ បាឋៈនោះ សេចក្តីថា សង្ខារទាំងពួង ក៏សោះសូន្យទទេពិត ។ **ម** អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទ ក្នុងគាថាដ៏សេសគ្រប់អន្លើ មានអត្ថងាយយល់ហើយ ។

គូអគ្គសាវកនេះ គឺព្រះសារីបុត្ត និងព្រះមោគ្គល្លាន ក៏បានធ្វើបណិធាន ដើម្បីបានជាអគ្គសាវក ក្នុងសម្នាក់របស់ព្រះមានព្រះភាគអនោមទស្សីអង្គនេះ រឿងរបស់ព្រះថេរៈទាំងនេះ គួរពោលក្នុងទីនេះ តែខ្ញុំមិនលើកឡើងសម្តែង ព្រោះនាំឲ្យគម្ពីរពិស្តារពេក ។ល។

**អដ្ឋកថាអនោមទស្សីពុទ្ធវង្សទី ៧ ចប់**

# សុត្តន្តបិដក

## បទុមពុទ្ធវង្សទី ៨

[ ៩ ] ក្នុងកាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមអនោមទស្សី មក មានព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ឥត មានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។ សីលនៃព្រះអង្គ ឥតមានសីលនៃបុគ្គលដទៃស្មើ ទាំងសមាធិក៏រកទីបំផុតគ្មាន ព្រះ ញាណដ៏ប្រសើរនឹងរាប់ពុំបាន ទាំងវិមុត្តិក៏មិនមានឧបមា ។ កាល ដែលព្រះពុទ្ធព្រះនាមបទុមៈ ព្រះអង្គនោះ មានតេជះប្ញទ្ធិ៍មិនបាន ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ មានការត្រាស់នូវធម៌បីលើក ដែលជាគ្រឿងបន្សាត់បង់នូវងងឹតដ៏ធំ ។ គឺព្រះពុទ្ធទ្រង់ញ៉ាំងសត្វ មួយរយកោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធជាអ្នក ប្រាជ្ញ ទ្រង់ញ៉ាំងសត្វ ៩០ កោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ ដឹងទី ២ ។ មួយទៀត ព្រះពុទ្ធព្រះនាមបទុមៈ ទ្រង់ទូន្មានព្រះ ឱរសរបស់ព្រះអង្គ ក្នុងកាលណា កាលនោះ ពួកសត្វ ៨០ កោដិត្រាស់ដឹងលើកទី ៣ ។ ព្រះពុទ្ធព្រះនាមបទុមៈ ជាមហេសី មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើក ១ មានភិក្ខុមួយ សែនកោដិ ។ កាលកឋិនចីវរកើតឡើងហើយ ក្នុងសម័យជាទី ក្រាលនូវកឋិន ភិក្ខុទាំងឡាយបានដេរនូវចីវរ ដើម្បីប្រគេនព្រះ ធម្មសេនាបតី ។ ក្នុងកាលនោះ ភិក្ខុទាំង ៣ សែនរូបនោះ សុទ្ធ តែប្រាសចាកមន្ទិល មានអភិញ្ញា ៦ មានប្ញទ្ធិច្រើន ជាអ្នកមិនចាល

ចាញ់ បានមកប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ។ មួយវិញទៀត ព្រះពុទ្ធព្រះនាមបទុមៈអង្គនោះ ទ្រង់ប្រសើរជាងពួកនរៈ ស្តេចចូលទៅកាន់លំនៅក្នុងព្រៃធំ ក្នុងកាលនោះ មានភិក្ខុ ២ សែនរូបជួបជុំគ្នា នេះជាសន្និបាតលើកទី ៣ ។ សម័យនោះ តថាគតកើតជាសត្វសីហៈ គ្របសង្កត់លើពួកម្រឹគ បានឃើញព្រះជិនស្រីព្រះអង្គកំពុងចម្រើននូវវិវេក ក្នុងព្រៃធំ ។ តថាគតបានថ្វាយបង្គំនូវព្រះបាទទាំងគូ ដោយសិរ្សៈ ហើយធ្វើប្រទក្សិណព្រះអង្គ រួចបន្លឺឡើងនូវសីហនាទ អស់ ៣ ដង បានបម្រើព្រះជិនស្រីអស់ ៧ ថ្ងៃ ។ ព្រះតថាគត ទ្រង់ចេញចាកសមាបត្តិដ៏ប្រសើរអស់ ៧ ថ្ងៃ ហើយទ្រង់ព្រះចិន្តាដោយព្រះហឫទ័យ រួចទ្រង់ប្រមូលមកនូវភិក្ខុចំនួនមួយកោដិ ។ កាលនោះ ព្រះមហាវីរៈនោះ ទ្រង់ព្យាករក្នុងកណ្តាលភិក្ខុសង្ឃ ទាំងមួយកោដិនោះថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ សត្វសីហៈនេះ នឹងបានជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញចាកក្រុង ជាទីត្រេកអរ ឈ្មោះកបិលពស្តុ ហើយតម្កល់សេចក្តីព្យាយាម នឹងធ្វើនូវទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេជម្រះហើយ ។ លំដាប់នោះ

ព្រះពុទ្ធ មានយសធំ ទ្រង់ធ្វើនូវការប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើត នៃព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះសម្ពុទ្ធអង្គនេះ នឹងមានព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងបានជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជា ឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនេះ ។ ព្រះនាង ខេមា ១ ព្រះនាងឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាក រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ នឹងជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវក-គហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុនៃព្រះគោតម មានយសអង្គ នោះកំណត់ ១០០ ឆ្នាំ ។ ទេវតា និងមនុស្សទាំងឡាយ លុះបាន ស្តាប់នូវព្រះបន្ទូលនេះ របស់ព្រះពុទ្ធព្រះនាមបទុមៈ ទ្រង់ស្វែង រកនូវគុណធំរកបុគ្គលស្មើគ្មាន ក៏មានចិត្តត្រេកអរថា សត្វសីហៈ នេះជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោឡើង ក៏ប្រព្រឹត្តទៅ ឯមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើច ផ្គងអញ្ជលីនមស្ការថា បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃ

ព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះពុំខាន ។ មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងកំពង់ក្នុងទីចំពោះមុខ គង់កាន់យកនូវ កំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណា យើង ទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត ពួក យើងគង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏ យ៉ាងនោះដែរ ។ ឯតថាគត លុះបានឮព្រះបន្ទូលនៃព្រះសម្ពុទ្ធ ទ្រង់ព្រះនាមបទុមៈនោះហើយ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋាននូវវត្តដ៏លើសលុប ដោយការបំពេញនូវបារមីទាំង ១០ ។ ព្រះសម្ពុទ្ធ ព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះចម្បកៈ មានមហាក្សត្រ ព្រះនាមអសមៈជាបិតា មានព្រះមាតាព្រះនាមអសមា ។ ព្រះសម្ពុទ្ធ ព្រះនាមបទុមៈនោះ នៅគ្រប់គ្រងផ្ទះអស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ ខ្នង គឺនន្ទប្រាសាទ ១ វសុប្រាសាទ ១ យសុត្តរប្រាសាទ ១ ។ មាន នារី ៣ ម៉ឺន ៣ ពាន់រូប សឹងតាក់តែងល្អ ឯនារីជាអគ្គមហេសី នោះ ឈ្មោះនាងឧត្តរា មានព្រះរាជឱរសឈ្មោះនាមរម្មៈ ។ ព្រះ ជិនស្រីទ្រង់បានឃើញនូវនិមិត្ត ៤ យ៉ាង ហើយស្តេចចេញមហា-ភិនិស្រ្កម ដោយយាន គឺរថ ទ្រង់តម្កល់នូវព្យាយាម អស់ ៨ ខែគត់ ។ ព្រះសម្ពុទ្ធព្រះនាមបទុមៈ ជាលោកនាយក ជាមហាវីរៈ

ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្ក ឲ្យប្រព្រឹត្តទៅក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះធនញ្ជៈ ។ ភិក្ខុឈ្មោះសាលៈ ១ ឈ្មោះឧបសាលៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះវរុណៈជាឧបដ្ឋាករបស់ព្រះពុទ្ធព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណធំ ។ ព្រះនាងរាធា ១ ព្រះនាងសុរាធា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថា មហាសោណៈ ( ដើមម្រុម ) ឧបាសកឈ្មោះសភិយៈ ១ ឈ្មោះអសមៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះរុចិ ១ ឈ្មោះនន្ទិមារា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះសម្ពុទ្ធព្រះនាមបទុមៈ ជាមហាមុនី ទ្រង់មានកម្ពស់ ៥៨ ហត្ថ កម្រងរស្មីនៃព្រះមហាមុនីអង្គនោះ តែងផ្សាយចេញសព្វទិស ទាំងឥតមានអ្វីស្មើ ។ រស្មីព្រះចន្ទ រស្មីព្រះអាទិត្យ រស្មីកែវមណី រស្មីទាំងអស់នោះ ក៏សាបសូន្យទៅ ព្រោះប៉ះនឹងពន្លឺរបស់ព្រះជិនស្រីដ៏ឧត្តម ។ ព្រះជន្មាយុ ( របស់ព្រះមហាមុនីនោះ ) មួយសែនឆ្នាំជាកំណត់ ព្រះមហាមុនីអង្គនោះ កាលទ្រង់ព្រះជន្មនៅជរាបនោះ ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះមហាមុនីអង្គនោះ ទ្រង់ញ៉ាំងសត្វដែលមានឥន្ទ្រិយចាស់ក្លា ឲ្យត្រាស់ដឹងមិនមានសេសសល់ ទ្រង់ប្រៀន

ប្រជាសត្វទាំងឡាយ ដែលសេសសល់ ទ្រង់បរិនិព្វានទៅជាមួយនឹងសាវក ។ ព្រះមហាមុនីអង្គនោះ ទ្រង់លះបង់នូវសង្ខារទាំងពួង ដូចជាពស់ដែលលះបង់នូវសំណកចាស់ ឬដូចជាដើមឈើជម្រុះនូវស្លឹកចាស់ ហើយទ្រង់បរិនិព្វានទៅ ដូចជាអណ្តាតប្រទីប ដូច្នោះ ។ ព្រះសាស្តាព្រះនាមបទុមៈ ជាព្រះជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងធម្មារាម មានព្រះធាតុផ្សាយទៅក្នុងប្រទេសនោះៗ ។

បទុមពុទ្ធវង្សទី ៨ ចប់

# អដ្ឋកថា

## បទុមពុទ្ធវង្សទី ៨

បន្ទាប់អំពីសម័យ ព្រះមានព្រះភាគអនោមទស្សី មនុស្សទាំងឡាយមានអាយុមួយសែនឆ្នាំ ហើយថយចុះដោយលំដាប់ រហូតដល់មានអាយុ ១០ ឆ្នាំ រួចកើនឡើងវិញដោយលំដាប់ រហូតដល់មួយសែនឆ្នាំ ។ កាលនោះព្រះសាស្តាព្រះនាមបទុមៈ ទ្រង់កើតឡើងក្នុងលោក ។ ព្រះសាស្តាអង្គនោះទ្រង់ក៏បំពេញបារមី ហើយកើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីតុសិតនោះហើយ បដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងអសមា ជាអ្នកមិនមានបុគ្គលស្មើដោយរូបជាដើម ដែលជាអគ្គមហេសីក្នុងរាជត្រកូល របស់ព្រះបាទអសមរាជ ក្នុងនគរចម្បកៈ ។ គ្រប់កំណត់ទសមាសហើយ ទ្រង់ក៏ប្រសូតចាកផ្ទៃរបស់ព្រះជននី ក្នុងចម្បករាជឧទ្យាន ។ កាលព្រះរាជកុមារប្រសូត ភ្លៀងផ្កាឈូកបានធ្លាក់ចុះអំពីអាកាស ពេញជម្ពូទ្វីបរហូតដល់មហាសមុទ្រ ។ ដោយហេតុនោះ ក្នុងថ្ងៃថ្វាយព្រះនាមព្រះរាជកុមារនោះ ពួកហោរា និងពួកព្រះញាតិក៏ថ្វាយព្រះនាមថា មហាបទុមកុមារ ។ ទ្រង់នៅជាយរាវាសវិស័យមួយម៉ឺនឆ្នាំ មានប្រាសាទ ៣ គឺនន្ទុត្តរប្រាសាទ ១ វសុត្តរប្រាសាទ ១ និងយសុត្តរប្រាសាទ ១[1] មាននារី ៣ ម៉ឺន ៣ ពាន់នាក់ ដែលមាននាងឧត្តរាទេវីជាប្រធាន ។

គ្រានោះ កាលរម្មរាជកុមាររបស់ព្រះនាងឧត្តរាមហាទេវីប្រសូត ព្រះមហាសត្វ ទ្រង់ឃើញនិមិត្ត ៤ ទើបចេញអភិនេស្រ្កមណ៍ដោយរថ ដែល

---

១- បិដកខ្មែរជាយសត្តរប្រាសាទ ។

ទឹមដោយសេះ បុរសមួយកោដិបួសតាមព្រះមហាសត្វ ដែលទ្រង់បួសនោះ ។ ព្រះមហាសត្វដែលបុរសទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាម ៨ ខែ ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ ទ្រង់សោយមធុបាយាស ដែលនាងធញ្ញវតី ធីតារបស់សុធញ្ញសេដ្ឋី ក្រុងធញ្ញវតីថ្វាយហើយ ទ្រង់សម្រាកពេលថ្ងៃក្នុងមហាសាលវ័ន ពេលល្ងាច ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលតិត្តកអាជីវកថ្វាយ ហើយយាងចូលទៅកាន់ពោធិព្រឹក្ស ឈ្មោះដើមមហាសោណៈ គឺដើមម្រុម ទ្រង់លាតសន្ថតស្មៅ ទទឹង ៣៨ ហត្ថ ប្រថាប់គង់ពត់ភ្នែន អធិដ្ឋានសេចក្តីព្យាយាមដែលមានអង្គ ៤ ទ្រង់កម្ចាត់មារ ព្រមទាំងសេនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ក្នុងយាមទាំង ៣ ទ្រង់បន្លឺព្រះឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយ តថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់សម្ងំនៅក្បែរពោធិព្រឹក្ស ៧ សប្តាហ៍ ទ្រង់ទទួលអារាធនារបស់មហាព្រហ្ម ទ្រង់ប្រមើលមើលបុគ្គលដែលដូចជាភាជនៈ ទទួលនូវព្រះធម្មទេសនា ទ្រង់ឃើញភិក្ខុមួយកោដិ ដែលបួសជាមួយព្រះអង្គ ក្នុងខណៈនោះឯង ទ្រង់ក៏ទៅតាមអាកាស ចុះត្រង់ធនញ្ជយរាជឧទ្យាន ក្បែរក្រុងធញ្ញវតី កាលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់ប្រកាសព្រះធម្មចក្រកណ្តាល

ភិក្ខុទាំងនោះ ។ កាលនោះ ការត្រាស់ដឹងធម៌មានដល់សត្វ ១០០ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងកាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមអនោមទស្សីមក មានព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ឥត មានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។ សីលនៃព្រះអង្គ ឥតមានសីលនៃបុគ្គលដទៃស្មើ ទាំងសមាធិក៏រកទីបំផុតគ្មាន ព្រះញាណដ៏ប្រសើរនឹងរាប់ពុំបាន ទាំងវិមុត្តិក៏មិនមានឧបមា ។ កាលដែលព្រះពុទ្ធព្រះនាមបទុមៈ ព្រះអង្គនោះ មានតេជៈថ្លឹង មិនបាន ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ មានការត្រាស់នូវ ធម៌បីលើក ដែលជាគ្រឿងបន្សាត់បង់នូវងងឹតដ៏ធំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសមំ សីលំ** បានដល់ មិនមានបុគ្គលដទៃស្មើដោយសីល អធិប្បាយថា ឧត្តមប្រសើរបំផុត ។ បទថា **សមាធិបិ អនន្តកោ** បានដល់ ទាំងសមាធិក៏ប្រមាណមិនបាន ។ ភាពដែលសមាធិនោះមិនមានទីបំផុត គប្បីឃើញក្នុងយមកប្បាដិហារ្យ និងការបើកលោកជាដើម ។ បទថា **ញាណវរំ** បានដល់ ព្រះសព្វញ្ញុតញ្ញាណ ឬអសាធារណញ្ញាណទាំងឡាយ ។ បទថា **វិមុត្តិបិ** បានដល់ អរហត្តផលវិមុត្តិរបស់ព្រះមានព្រះភាគ ។ បទថា **អនូបមា** បានដល់ វៀរបុគ្គលដែលប្រៀបធៀបបាន ។ បទថា **អតុលតេជស្ស** បានដល់ ទ្រង់មានតេជៈ គឺញាណថ្លឹងថ្លែងមិនបាន ។ បាឋៈថា **អតុលញ្ញាណតេជា** ដូច្នេះក៏មាន ។ បាឋៈនោះ គប្បី

ឃើញថា ភ្ជាប់ជាមួយបទក្រោយថា **តយោ អភិសមយា។** បទថា **មហា-តមបវាហណោ** បានដល់ ញុំាងមោហៈធំឲ្យវិនាស អធិប្បាយថា កម្ចាត់ងងឹត គឺមោហៈ ។

សម័យក្រោយមក ព្រះមានព្រះភាគបទុមៈ ទ្រង់ឲ្យសាលកុមារ និងឧបសាលកុមារ ដែលជាប្អូនប្រុសរបស់ព្រះអង្គ បួសក្នុងសមាគមព្រះញាតិមួយអន្លើដោយបរិវារ ទ្រង់សម្តែងធម៌ប្រោសជនទាំងនោះ ទ្រង់ញុំាងសត្វ ៩០ កោដិ ឲ្យផឹកនូវអមតធម៌ កាលដែលទ្រង់សម្តែងធម៌ប្រោសព្រះធម្មត្ថេរ ការសម្រេចធម៌ក៏មានដល់សត្វ ៨០ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

គឺព្រះពុទ្ធទ្រង់ញុំាងសត្វ មួយរយកោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ញុំាងសត្វ ៩០ កោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ។ មួយទៀត ព្រះពុទ្ធព្រះនាមបទុមៈ ទ្រង់ទូន្មានព្រះឱរសរបស់ព្រះអង្គ ក្នុងកាលណា កាលនោះ ពួកសត្វ ៨០ កោដិ ត្រាស់ដឹងលើកទី ៣ ដូច្នេះ ។

គ្រានោះ ព្រះបាទសុភាវិតត្ថៈ មានព្រះរាជបរិវារមួយសែនកោដិ ទ្រង់បួសដោយឯហិភិក្ខុ ក្នុងសម្នាក់នៃព្រះបទុមសម្ពុទ្ធ ទ្រង់មានព្រះភក្ត្រដូចផ្កាឈូករីក ។ ក្នុងសន្និបាតនោះ ព្រះមានព្រះភាគ ទ្រង់លើកបាតិមោក្ខឡើងសម្តែង នេះជាសន្និតបាតលើកទី ១ ។

សម័យតមក ព្រះមហាបទុមសម្ពុទ្ធជាអគ្គមុនី ទ្រង់មានគតិស្មើដោយគោឧសភ ទ្រង់អាស្រ័យក្រុងឧសភវតី ដើម្បីចាំវស្សា ពួកអ្នកនគរបំណងនឹងឃើញព្រះមានព្រះភាគ ទើបនាំគ្នាចូលគាល់ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ប្រោសជនទាំងនោះ ។ មនុស្សដ៏ច្រើនក្នុងទីនោះ មានចិត្តជ្រះថ្លា ក៏នាំគ្នាបួស បន្ទាប់អំពីនោះ ព្រះទសពលទ្រង់បវារណាជាវិសុទ្ធិប្បវារណាជាមួយភិក្ខុទាំងនោះ និងភិក្ខុ ៣ សែនដទៃៗ នេះជាសន្និបាតលើកទី ២ ។ ឯជនទាំងឡាយណា មិនទាន់បួសក្នុងកាលនោះ ជនទាំងនោះ ស្តាប់អានិសង្សកឋិនហើយ ក៏នាំគ្នាប្រគេនកឋិនចីវរ ដែលឲ្យនូវអានិសង្ស ៥ ក្នុងកាល ៥ ខែ ក្នុងថ្ងៃបាដិបទ ។ បន្ទាប់អំពីនោះ ភិក្ខុទាំងឡាយអារាធនាព្រះសាលត្ថេរ ដែលជាព្រះធម្មសេនាបតីអគ្គសាវក ដែលមានបញ្ញាធំទូលាយនោះដើម្បីក្រាលកឋិន បានថ្វាយកឋិនចីវរដល់ព្រះសាលត្ថេរនោះ ។ កាលកឋិនចីវររបស់ព្រះថេរៈ ដែលភិក្ខុទាំងឡាយធ្វើ ភិក្ខុទាំងឡាយដែលជាសម្លាញ់ ក៏នាំគ្នាជួយដេរ ។ ឯព្រះបទុមសម្មាសម្ពុទ្ធទ្រង់ដោតអំបោះក្នុងច្បោះប្រទាន កាលចីវរសម្រេចហើយ ព្រះមានព្រះភាគចៀសចេញទៅ មួយអន្លើដោយភិក្ខុ ៣ សែន ។

សម័យតមក ព្រះពុទ្ធសីហៈទ្រង់យាងទៅដោយលីលា ដូចរាជសីហ៍ទ្រង់ចាំវស្សាត្រង់ព្រៃធំ ដែលមានផ្កាក្រអូបឈ្ងុយឈ្ងុប មានផ្លែជាចង្កោមមានមែកយោនយាន មានប្រគាបដូចព្រៃគោសិង្គសាលវ័ន បរិបូណ៌ដោយអន្លង់ទឹកត្រជាក់ល្អ ប្រដាប់ដោយផ្កាឈូក-សឈូកក្រហម ប្រាសចាកមន្ទិល

ជាទីត្រាច់ទៅមករបស់ម្រឹគ ដូចជាប្រើស ចាមរី រាជសីហ៍ ខ្លា ដំរី សេះ គោ ក្របីជាដើម ដែលហ្វូងកន្ទង់ និងឃ្មុំញី មានចិត្តជាប់ក្នុងក្លិនបោមរោម ហើរជាហ្វូងៗ ដោយជុំវិញ ដែលពួកតាវៅញី មានចិត្តត្រេកអរដោយរសនៃផ្លែឈើ បន្លឺសំឡេងដ៏ពីរោះ ដូចគ្នានឹងច្រៀងបំពេ គួរត្រេកអរក្រៃលែង ជាទីស្ងាត់ ប្រាសចាកពួកមនុស្ស សមគួរដល់ការប្រកបព្យាយាម ។ ព្រះតថាគតទសពល ព្រះធម្មរាជា មួយអន្លើដោយបរិវារ គង់ប្រថាប់នៅក្នុងព្រៃធំនោះ រុងរឿងដោយពុទ្ធសិរី មនុស្សទាំងឡាយឃើញហើយ ស្តាប់ធម៌របស់ព្រះអង្គ ក៏ជ្រះថ្លា នាំគ្នាបួសដោយឯហិភិក្ខុ ។ កាលនោះ ព្រះសាស្តាមានភិក្ខុ ២ សែនរូប បោមរោម ហើយទ្រង់បវារណាចេញវស្សា ទុ៎ះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះពុទ្ធព្រះនាមបទុមៈ ជាមហេសី មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើក ១ មានភិក្ខុមួយសែនកោដិ ។ កាលកឋិនចីវរកើតឡើងហើយ ក្នុងសម័យជាទីក្រាលនូវកឋិន ភិក្ខុទាំងឡាយបានដេរនូវចីវរ ដើម្បីប្រគេនព្រះធម្មសេនាបតី ។ ក្នុងកាលនោះ ភិក្ខុទាំង ៣ សែនរូបនោះ សុទ្ធតែប្រាសចាកមន្ទិល មានអភិញ្ញា ៦ មានឫទ្ធិច្រើន ជាអ្នកមិនចាលចាញ់ បានមកប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ។ មួយវិញទៀត ព្រះពុទ្ធព្រះនាមបទុមៈអង្គនោះ ទ្រង់ប្រសើរជាងពួកនរៈ ស្តេចចូលទៅកាន់លំនៅក្នុងព្រៃធំ ក្នុងកាលនោះ មានភិក្ខុ ២ សែន

រូបជួបជុំគ្នា នេះជាសន្និបាតលើកទី ៣ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កឋិនត្ថារសមយេ** បានដល់ ក្នុងសម័យក្រាលកឋិនចីវរ ។ បទថា **ធម្មសេនាបតិត្ថាយ** បានដល់ ដើម្បីព្រះសារីបុត្រជាធម្មសេនាបតី ។ បទថា **អបរាជិតា** បានដល់ ដែលបុគ្គលណាមួយឲ្យចាលចាញ់មិនបាន ។ គប្បីឃើញថា លុបវិភត្តិ ។ បទថា **សោ** បានដល់ ព្រះបទុមសម្ពុទ្ធអង្គនោះ ។ បទថា **បវនេ** បានដល់ ព្រៃធំ ។ បទថា **វាសំ** បានដល់ នៅចាំវស្សា ។ បទថា **ឧបាគមិ** បានដល់ យាងចូលទៅ ។ បទថា **ទ្វិន្នំ សតសហស្សិនំ** កែជា **ទ្វិន្នំ សតសហស្សានំ** បានដល់ ២ សែនរូប ។ បាឋៈថា **តទា អាសិ សមាគមោ** បើមានក៏ល្អ ។

កាលនោះ កាលព្រះតថាគតប្រថាប់គង់នៅត្រង់ដងព្រៃនោះ ព្រះពោធិសត្វនៃយើង កើតជារាជសីហ៍ ឃើញព្រះសាស្ដាគង់ចូលនិរោធសមាបត្តិ ៧ ថ្ងៃ ក៏មានចិត្តជ្រះថ្លា ធ្វើប្រទក្សិណ កើតបីតិសោមនស្ស បន្លឺសីហនាទ ៣ ដង មិនលះបីតិ មានពុទ្ធគុណជាអារម្មណ៍ អស់ ៧ ថ្ងៃ ដោយបីតិ និងសុខនោះឯង ក៏មិនចេញទៅរកចំណី លះបង់ជីវិត ឈរនៅក្បែរនោះ ។ លុះកន្លងទៅ ៧ ថ្ងៃ ព្រះសាស្ដាចេញអំពីនិរោធសមាបត្តិ ទ្រង់ជាសីហៈក្នុងនរជន ទ្រង់ទតរាជសីហ៍ ទ្រង់ព្រះតម្រិះថា រាជសីហ៍ ចូរមានចិត្តជ្រះថ្លាក្នុងភិក្ខុសង្ឃៗ ទាំងឡាយចូរមក ភិក្ខុច្រើនកោដិ ក៏នាំគ្នាមកមួយរំពេច ។ រាជសីហ៍ក៏មានចិត្តជ្រះថ្លាក្នុងសង្ឃ ។ គ្រានោះ ព្រះសាស្ដាទ្រង់ប្រមើលមើលចិត្តរបស់រាជសីហ៍នោះ ទ្រង់ព្យាករថា ក្នុងអនាគតកាល រាជសីហ៍នេះ

នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតកើតជាសត្វសីហៈ គ្របសង្កត់លើពួកម្រឹគ បានឃើញព្រះជិនស្រី ព្រះអង្គកំពុងចម្រើននូវវិវេកក្នុងព្រៃធំ ។ តថាគតបានថ្វាយបង្គំ នូវព្រះបាទទាំងគូ ដោយសិរ្សៈ ហើយធ្វើប្រទក្សិណព្រះអង្គ រួចបន្លឺឡើងនូវសីហនាទអស់ ៣ ដង បានបម្រើព្រះជិនស្រី អស់ ៧ ថ្ងៃ ។ ព្រះតថាគតទ្រង់ចេញចាកសមាបត្តិដ៏ប្រសើរ អស់ ៧ ថ្ងៃ ហើយទ្រង់ព្រះចិន្តាដោយព្រះហឫទ័យ រួចទ្រង់ប្រមូលមកនូវភិក្ខុចំនួនមួយកោដិ ។ កាលនោះ ព្រះមហាវីរៈនោះ ទ្រង់ព្យាករក្នុងកណ្តាលភិក្ខុសង្ឃទាំងមួយកោដិនោះថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ សត្វសីហៈនេះ នឹងបានជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញចាក ក្រុងជាទីត្រេកអរ ឈ្មោះកបិលពស្តុ ហើយតម្កល់សេចក្តីព្យាយាម ។បេ។ ពួកយើង គង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះក៏យ៉ាងនោះដែរ ។ ឯតថាគត លុះបានឮព្រះបន្ទូលនៃព្រះសម្ពុទ្ធ ទ្រង់ព្រះនាមបទុមៈនោះហើយ ក៏ញុំាំងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋាននូវវត្តដ៏លើសលុប ដោយការបំពេញនូវបារមីទាំង ១០ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បរិវេកមនុព្រូហន្តំ** បានដល់ ទ្រង់ចូលនិរោធសមាបត្តិ ។ បទថា **បទក្ខិណំ** បានដល់ ធ្វើប្រទក្សិណ ៣ ជុំ ។ បទថា **អភិនាទិត្វា** បានដល់ បន្លឺសីហនាទ ៣ ដង ។ បទថា **ឧបដ្ឋហំ** តែជា **ឧបដ្ឋហី** ( បម្រើ ) ។ម្យ៉ាងទៀត បាឋៈក៏យ៉ាងនោះដូចគ្នា ។ បទថា **វរសមាបត្តិយា** បានដល់ ចេញអំពីនិរោធសមាបត្តិ ។ បទថា **មនសា ចិន្តយិត្វាន** សេចក្ដីថា ទ្រង់ព្រះតម្រិះដោយព្រះហឫទ័យថា ភិក្ខុទាំងអស់ចូរមកទីនេះ ។ បទថា **សមានយិ** បានដល់ នាំមកហើយ ។

ព្រះមានព្រះភាគបទុមៈអង្គនោះ ទ្រង់មាននគរឈ្មោះចម្បកៈ ព្រះជនកព្រះនាមព្រះបាទអសមៈ ព្រះជននីព្រះនាមអសមា គូអគ្គសាវកឈ្មោះសាលៈ ១ ឧបសាលៈ ១ ពុទ្ធុបដ្ឋាកឈ្មោះថាវរុណៈ គូអគ្គសាវិកាឈ្មោះរាធា ១ សុរាធា ១ ដើមមហាសោណៈជាពោធិព្រឹក្ស ។ ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំ ព្រះអគ្គមហេសីព្រះនាមឧត្តរា ឧត្តមដោយគុណមានរូបជាដើម ព្រះឱរសរបស់ព្រះអង្គគួរត្រេកអរក្រៃលែង ព្រះនាមរម្មកុមារ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសម្ពុទ្ធ ព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរ
ឈ្មោះចម្បកៈ មានមហាក្សត្រព្រះនាមអសមៈជាបិតា មានព្រះ
មាតាព្រះនាមអសមា ។ ភិក្ខុឈ្មោះសាលៈ ១ ឈ្មោះឧបសាលៈ
១ ជាអគ្គសាវក ភិក្ខុឈ្មោះវរុណៈជាឧបដ្ឋាក របស់ព្រះពុទ្ធ
ព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណធំ ។ ព្រះនាងរាធា ១ ព្រះ

នាងសុភជា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថា មហាសោណៈ ( ដើមម្រុម ) ។ ព្រះសម្ពុទ្ធព្រះនាមបទុមៈ ជាមហាមុនី ទ្រង់មានកម្ពស់ ៥៨ ហត្ថ កម្រងរស្មីនៃព្រះមហាមុនីអង្គនោះ តែងផ្សាយចេញសព្វទិស ទាំងឥតមានអ្វីស្មើ ។ រស្មីព្រះចន្ទ រស្មីព្រះអាទិត្យ រស្មីកែវមណី រស្មីទាំងអស់នោះ ក៏សាបសូន្យទៅ ព្រោះប៉ះនឹងពន្លឺរបស់ព្រះជិនស្រីដ៏ឧត្តម ។ ព្រះជន្មាយុ ( របស់ព្រះមហាមុនី នោះ ) មួយសែនឆ្នាំជាកំណត់ ព្រះមហាមុនីអង្គនោះ កាលទ្រង់ព្រះជន្មនៅដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះមហាមុនីអង្គនោះ ទ្រង់ញុំាងសត្វដែលមានឥន្ទ្រិយចាស់ក្លាឲ្យត្រាស់ដឹងមិនមានសេសសល់ ទ្រង់ប្រៀនប្រដៅសត្វទាំងឡាយ ដែលសេសសល់ ទ្រង់បរិនិព្វានទៅជាមួយនឹងសាវ័ក ។ ព្រះមហាមុនីអង្គនោះ ទ្រង់លះបង់នូវសង្ខារទាំងពួង ដូចជាពស់ដែលលះបង់នូវសំណាកចាស់ ឬដូចជាដើមឈើជម្រុះនូវស្លឹកចាស់ ហើយទ្រង់បរិនិព្វានទៅ ដូចជាអណ្តាត ប្រទីបដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **រតនគ្គិមណិប្បភា** បានដល់ ពន្លឺរតនៈ ពន្លឺភ្លើង និងពន្លឺកែវមណី ។ បទថា **ហាតា** បានដល់ ត្រូវគ្របសង្កត់ ។

បទថា **ជិនបភុត្តមំ** សេចក្តីថា ពន្លឺទាំងនោះមកដល់រស្មីនៃព្រះសរីរៈដ៏រុងរឿងរបស់ព្រះជិនស្រីក៏សាបសូន្យទៅ ។ បទថា **បរិបក្កមានសេ** បានដល់ វេនេយ្យសត្វដែលមានឥន្ទ្រិយចាស់ក្លា ។ បទថា **វទ្ធុបត្តំ** បានដល់ ស្លឹកឈើចាស់ ។ បទថា **ចាគចោរ** គឺ **ចាគចោ វិយ** បានដល់ ដូចដើមឈើ ។ បទថា **សព្វសន្ថារេ** បានដល់ សន្ថារខាងក្នុងខាងក្រៅសព្វយ៉ាង ។ បាឋៈថា **ហិត្វា សព្វសន្ថារំ** ដូច្នេះក៏មាន ឯសេចក្តីក៏យ៉ាងនោះដូចគ្នា ។ បទថា **យថា សិខី** សេចក្តីថា ទ្រង់ប្រាសចាកឧបាទាន ដូចភ្លើងប្រាសចាកកំញម គឺទ្រង់ដល់ ទ្រង់សម្រេច នូវការរលត់ឥតសេសសល់ ។ ពាក្យដ៏សេសក្នុងទីនេះមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយខាងដើម ក្នុងគាថាទាំងឡាយនោះឯង ៕

**អដ្ឋកថាបទុមពុទ្ធវង្សទី ៨ ចប់**

# សុត្តន្តបិដក

## នារទពុទ្ធវង្សទី ៩

[ ១០ ] ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធព្រះនាមបទុមៈមក មានព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមាន បុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។ ព្រះអង្គនោះ ជាព្រះ រាជបុត្រច្បង ជាព្រះរាជឱរសជាទីស្រឡាញ់ របស់ស្តេចចក្រពត្តិ ទ្រង់បានពាក់នូវកែវមណី និងគ្រឿងអាភរណៈ ហើយស្តេចចូល ទៅកាន់ឧទ្យាន ។ ក្នុងឧទ្យាននោះ មានឈើមួយដើម ឈ្មោះ មហាសោណព្រឹក្ស ជាឈើសមរម្យ ធំល្អស្អាត ព្រះសម្ពុទ្ធ ស្តេចទៅដល់ នូវដើមឈើនោះហើយ ទ្រង់គង់ខាងក្រោមនៃឈើ នោះ ។ ព្រះញាណប្រសើររកទីបំផុតគ្មាន មានឧបមាដូចជាកែវ វជីរ បានកើតឡើង ( ដល់ព្រះអង្គ ) ក្នុងទីនោះ ព្រះអង្គពិចា-រណានូវសង្ខារទាំងឡាយ ដោយព្រះញាណនោះ ដូចជាបុគ្គល ដែលផ្កាប់ ឬផ្ងារឡើងនូវកាជនៈ ។ ក្នុងទីនោះ ព្រះអង្គទ្រង់ បន្សាត់បង់នូវកិលេសទាំងពួង មិនឲ្យសេសសល់ ហើយបាន សម្រេចនូវពោធិញ្ញាណទាំងអស់ផង នូវពុទ្ធញ្ញាណទាំង ១៤ ផង ។ លុះព្រះអង្គសម្រេចនូវពោធិញ្ញាណហើយ ទើបទ្រង់ សម្តែងនូវធម្មចក្ក សត្វមួយសែនកោដិ បានត្រាស់ដឹងជាដំបូង ។ ព្រះមហាមុនីទូន្មានស្តេចនាគ ឈ្មោះមហាទោណៈ ក្នុងកាល នោះ ទ្រង់ពន្យល់នូវពួកមនុស្ស ព្រមទាំងទេវតា ហើយទ្រង់ធ្វើ

នូវបាដិហារ្យ ។ ក្នុងកាលនោះ ទេវតា និងមនុស្សទាំងឡាយ ៩០ ពាន់កោដិ បានឆ្លងផុតនូវសេចក្ដីសង្ស័យទាំងអស់ ក្នុងការប្រកាសនូវព្រះធម៌នោះ នេះជាការត្រាស់ដឹងទី ២ ។ ព្រះមហាវីរៈ ទ្រង់ទូន្មាននូវបុត្របង្កើតរបស់ព្រះអង្គ ក្នុងកាលណា ( កាលនោះ ) ពួកសត្វចំនួន ៨០ កោដិ បានត្រាស់ដឹងក្នុងលើកទី ៣ ។ ព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកដំបូង មានពួកព្រះអរហន្តប្រមាណមួយសែនកោដិ ។ ព្រះសម្ពុទ្ធទ្រង់ប្រកាសពុទ្ធគុណ ព្រមទាំងនិទានក្នុងកាលណា កាលនោះ ព្រះអរហន្តប្រមាណ ៩០ ពាន់កោដិ ប្រាសចាកមន្ទិល មកប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ។ នាគរាជឈ្មោះវេរោចនៈ បានថ្វាយទានដល់ព្រះសាស្ដា ក្នុងកាលណា កាលនោះ ពួកសាវកជាបុត្តនៃព្រះជិនស្រីប្រមាណ ៨០ សែន បានមកប្រជុំគ្នា ( នេះជាសន្និបាតលើកទី ៣ ) ។ សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមក្លៀវក្លា បានដល់ត្រើយនៃអភិញ្ញាទាំង ៥ ត្រាច់ទៅតាមអាកាសបាន ។ គ្រានោះ តថាគតបានញុំាងព្រះសម្ពុទ្ធ ដែលស្មើដោយព្រះពុទ្ធមិនមានបុគ្គលស្មើ ព្រមទាំងព្រះសង្ឃ និងជនជាបរិស័ទឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ហើយបូជាដោយខ្លឹមចន្ទន៍ ។ គ្រានោះ ព្រះនារទៈ ជាលោកនាយកអង្គនោះ ទ្រង់បាន

ព្យាករតថាគតថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅតាបសនេះ នឹងបានជាព្រះពុទ្ធក្នុងលោក ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីត្រេកអរ តម្កល់នូវសេចក្តីព្យាយាម ហើយធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងគង់ទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ រួចចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលមកទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែងហើយ ។ លំដាប់នោះ ព្រះពុទ្ធទ្រង់មានយសធំ នឹងធ្វើប្រទក្សិណាពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះសម្ពុទ្ធអង្គនេះ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់មានចិត្តតាំងមាំ នឹងជាអគ្គសាវ័ក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីនេះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ ទាំងមានចិត្តតាំងមាំ នឹងជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។

នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុ របស់ព្រះគោតមមានយសអង្គនោះ កំណត់ ១០០ ឆ្នាំ ។ ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់ព្រះបន្ទូលនេះ របស់ព្រះសម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណធំ ក៏ត្រេកអរថា ជដិលនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើច ក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងឃ្លាងមគ្គផល ក្នុង សាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើង គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ។ មនុស្ស ទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាងនូវកំពង់ចំពោះមុខ គង់កាន់ យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណាមិញ ។ បើយើងទាំងអស់គ្នា ឃ្លាងព្រះជិនស្រីអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតម អង្គនេះ ក៏យ៉ាងនោះដែរ ។ តថាគតបានឮព្រះពុទ្ធដីកា នៃព្រះពុទ្ធ អង្គនោះហើយ ក៏ញុំាងចិត្តឲ្យរីករាយ ដោយក្រៃលែង បាន អធិដ្ឋាននូវវត្តដ៏លើសលុប ដោយការបំពេញនូវបារមីទាំង ១០ ។ ព្រះពុទ្ធព្រះនាមនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះ ធញ្ញវតី មហាក្សត្រព្រះនាមសុទេវៈជាព្រះបិតា ព្រះមាតាព្រះនាម អនោមា ។ ព្រះនារទៈនោះ នៅគ្រប់គ្រងផ្ទះអស់ ៩ ពាន់ឆ្នាំ

ប្រាសាទដ៏ប្រសើ មាន ៣ ខ្នង គឺជិតប្រាសាទ ១ វិជិតប្រាសាទ ១ អភិរាមប្រាសាទ ១ ។ មាននារី ៣-៤ ពាន់រូប សុទ្ធសឹងស្អិតស្អាងល្អ ព្រះនារី ( ដែលជាអគ្គមហេសី ) នោះ ព្រះនាមវិជិតសេនា ឯព្រះរាជបុត្តព្រះនាមឧទ្ទុត្តរៈ ។ ព្រះពុទ្ធជាបុរសរត្នដ៏ប្រសើរ ទ្រង់ទតឃើញនូវនិមិត្តទាំង ៤ ហើយ ស្តេចចេញមហាភិនិស្រ្កមណ៍ ដោយការយានទៅ ដោយព្រះបាទផ្ទាល់ ហើយទ្រង់ប្រព្រឹត្តព្យាយាម អស់ ៧ ថ្ងៃ ។ ព្រះនារទៈ ជាលោកនាយក ជាមហាវីរបុរស ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះធនញ្ជៈ ។ ភិក្ខុឈ្មោះភទ្ទសាលៈ ១ ឈ្មោះជិតមិត្តៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះវាសេដ្ឋៈ ជាឧបដ្ឋាករបស់ព្រះសម្ពុទ្ធនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ នាងឧត្តរា ១ នាងផគ្គុនី ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថាមហា សោណព្រឹក្ស ។ ឧបាសកឈ្មោះឧគ្គរិន្ទៈ ១ ឈ្មោះវសភៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះឥន្ទវរី ១ ឈ្មោះគណ្ឌី ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនី ទ្រង់មានកម្ពស់ ៨៨ ហត្ថក្រពុំ មានព្រះរូបស្មើដោយគ្រឿងបូជា ជាវិការនៃមាស បានញុំាងលោកធាតុទាំងមួយម៉ឺន ឲ្យភ្លឺរុងរឿង ។ ព្រះកាយរបស់ព្រះអង្គ មានរស្មីប្រមាណមួយព្យាម តែងផ្សាយទៅកាន់

ទិសតូចទិសធំ តែងផ្សាយទៅកាន់ទីប្រមាណមួយយោជន៍ ទាំងថ្ងៃទាំងយប់ ជានិរន្តរ៍ សព្វៗ កាល ។ សម័យនោះ ជនទាំងឡាយពួកខ្លះ នៅក្នុងទីប្រមាណមួយយោជន៍ដោយជុំវិញ ត្រូវរស្មីទាំងឡាយនៃព្រះពុទ្ធ គ្របសង្កត់ហើយ មិនចាំបាច់អុជភ្លើងគប់ ឬអុជភ្លើងប្រទីបទាំងឡាយឡើយ ។ ព្រះជន្មាយុកំណត់ប្រាំបួនម៉ឺនឆ្នាំគត់ កាលទ្រង់ព្រះជន្មាយុនៅជរាបនោះ តែងញ៉ាំងប្រជុំជនដ៏ច្រើន ឲ្យឆ្លងចាកសង្សារ ។ អាកាសដ៏វិចិត្ររុងរឿងដោយផ្កាយទាំងឡាយ យ៉ាងណា សាសនារបស់ព្រះនារទៈអង្គនោះ ក៏រុងរឿងដោយព្រះអរហន្តទាំងឡាយ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធព្រះនាមនារទៈ ប្រសើរជាងពួកនរៈអង្គនោះ ទ្រង់ធ្វើស្ពានគឺព្រះធម៌ឲ្យមាំ ដើម្បីចម្លងនូវជនទាំងឡាយដ៏សេស ដែលកំពុងដើរទៅ ដើម្បីឆ្លងនូវខ្សែទឹក គឺសង្សារ ហើយបរិនិព្វាន ។ ព្រះពុទ្ធស្មើដោយព្រះពុទ្ធ ដែលគ្មានបុគ្គលស្មើអង្គនោះក្តី ព្រះខីណាស្រពទាំងឡាយ មានតេជះប្រឹងពុំបាន ទាំងអម្បាលនោះក្តី ក៏និព្វានបាត់បង់អស់ របស់ទាំងពួង ក៏អន្តរធានអស់ ឧហ្ន៎ ! សង្ខារទាំងពួង ជារបស់សោះសូន្យពិត ។ ព្រះនារទៈ ជាព្រះជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងព្រះសុទស្សនបុរី ព្រះស្តូបដ៏ប្រសើរមានកម្ពស់ប្រមាណ ៤ យោជន៍ ។

នារទពុទ្ធវង្សទី ៩ ចប់

# អដ្ឋកថា

## នារទពុទ្ធវង្សទី ៩

កាលព្រះបទុមសម្ពុទ្ធបរិនិព្វានហើយ សាសនាព្រះអង្គក៏អន្តរធានទៅ មនុស្សទាំងឡាយមានអាយុមួយសែនឆ្នាំ ខែចុះដោយលំដាប់ រហូតដល់អាយុ ១០ ឆ្នាំ ហើយឡើងមកវិញ រហូតអាយុដល់មួយអសង្ខេយ្យឆ្នាំ ហើយក៏ខែចុះ រហូតសល់អាយុ ៩ ម៉ឺនឆ្នាំ ។ កាលនោះ ព្រះសាស្ដា ជាកំពូលនៃនរៈ ព្រះនាមនារទៈ ទ្រទ្រង់នូវកម្លាំង ១០ មានវិជ្ជា ៣ ជាបុគ្គលក្លៀវក្លាដោយវេសារជ្ជញ្ញាណ ៤ ជាអ្នកប្រទានវិមុត្តិសារៈ កើតឡើងក្នុងលោក ។ ទ្រង់បំពេញបារមីមក ៤ អសង្ខេយ្យ និង ១ សែនកប្ប ទ្រង់កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងអនោមាទេវី ជាស្ត្រីមានរូបល្អ មិនមានបុគ្គលប្រៀប ជាអគ្គមហេសីក្នុងរាជត្រកូលព្រះបាទសុទេវៈ ដែលព្រះបាទវាសុទេពដណ្ដើមមកបានដោយកម្លាំងរបស់ព្រះអង្គ ក្នុងនគរធញ្ញវតី ។ លុះគ្រប់ទសមាស ទ្រង់ក៏ប្រសូតចាកផ្ទៃព្រះជននី ត្រង់ធនញ្ជយរាជឧទ្យាន ។ ក្នុងថ្ងៃថ្វាយព្រះនាម កាលកំពុងធ្វើពិធីចងគ្រឿងអាភរណៈទាំងឡាយ ដែលសមគួរដល់ការប្រើប្រាស់សម្រាប់មនុស្សទាំងឡាយក្នុងជម្ពូទ្វីប ក៏ធ្លាក់ចុះអំពីដើមកប្បព្រឹក្សជាដើមតាមអាកាស ដោយហេតុនោះ ទើបមនុស្សទាំងឡាយ ថ្វាយគ្រឿងអាភរណៈទាំងឡាយ ដែលសមគួរសម្រាប់នរជនទាំងឡាយដល់ព្រះអង្គ ព្រោះហេតុនោះ ទើបពួកហោរា និងព្រះញាតិវង្សានុវង្ស ថ្វាយព្រះនាមថា នារទៈ ។

ព្រះពោធិសត្វនៅជាឃរាវាស ៩ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ខ្នង សមគួរដល់រដូវទាំង ៣ គឺវិជិតប្រាសាទ ១ វជិតាវីប្រាសាទ ១ វិជិតាភិរាមប្រាសាទ ១ ព្រះមាតាបិតា ទ្រង់ធ្វើខត្តិយកញ្ញាដែលជាអ្នកមានបុណ្យក្រៃលែង ឈ្មោះវិជិតសេនា ជាអ្នកដល់ព្រមដោយត្រកូល សីលាចារវត្តនិងរូបសម្បត្តិឲ្យជាអគ្គមហេសីដល់នារទកុមារនោះ ។ នារីជាស្នំ ១ សែន ២ ម៉ឺន មានព្រះនាងវិជិតសេនាជាប្រធាន ។ កាលនន្ទុត្តរកុមារដែលជាអ្នកនាំសេចក្ដីត្រេកអរដល់សត្វលោកទាំងពួង របស់ព្រះនាងវិជិតសេនាទេវីនោះប្រសូតហើយ នារទកុមារនោះ ទ្រង់ឃើញនិមិត្ត ៤ ដែលចតុរង្គសេនាធំចោមរោមហើយ ទ្រទ្រង់នូវគ្រឿងស្លៀកដណ្ដប់ដែលស្រាលល្អ មានពណ៌ផ្សេងៗ ពាក់កុណ្ឌលមណីមុក្តាហារ ទ្រទ្រង់នូវគ្រឿងប្រដាប់ដៃ ម្កុដ និងកងដៃយ៉ាងល្អ ទ្រង់ប្រដាប់ដោយផ្កា មានក្លិនក្រអូបក្រៃលែង យាងដោយព្រះបាទ ចូលកាន់ព្រះរាជឧទ្យាន ទ្រង់ដោះគ្រឿងអលង្ការទាំងអស់ ទុកក្នុងដៃកណ្ឌាគារិក ទ្រង់កាត់ព្រះកេសា និងព្រះមោលី ដែលដូចត្របកឈូកមិនមានមន្ទិល ប្រដាប់ដោយរតនៈដ៏ល្អក្រៃលែង ដោយព្រះខ័នដ៏មុត ដោយព្រះអង្គឯង ហើយទ្រង់បោះទៅក្នុងអាកាស សក្កទេវរាជទ្រង់ទទួលដោយប្រអប់មាស នាំទៅកាន់ស្ថានតាវត្តិង្ស ទ្រង់សាងព្រះចេតិយ សម្រេចដោយរតនៈ ៧ លើកំពូលភ្នំសិនេរុ កម្ពស់ ៣ យោជន៍ ។

ឯព្រះមហាបុរសទ្រង់ស្លៀកដណ្ដប់សំពត់កាសាវៈ ដែលទេវតាប្រគេនទ្រង់បួសក្នុងព្រះឧទ្យាននោះឯង មួយអន្លើដោយបុរស ១ សែននាក់ ព្រះ

មហាបុរស ទ្រង់បំពេញព្យាយាមក្នុងទីនោះអស់ ៧ ថ្ងៃ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់សោយមធុបាយាស ដែលព្រះនាងវិជិតសេនាអគ្គមហេសីប្រគេន ទ្រង់សម្រាកពេលថ្ងៃក្នុងរាជឧទ្យាន ទទួលស្មៅ ៨ ក្ដាប់ ដែលឧទ្យានបាលអ្នករក្សាសុទស្សនរាជឧទ្យានថ្វាយ ទ្រង់ធ្វើប្រទក្សិណដើមមហាសោណពោធិព្រឹក្ស ទ្រង់លាតសន្ថតស្មៅទំហំ ៥៨ ហត្ថ ប្រថាប់គង់ ទ្រង់កម្ចាត់ពលមារ ទ្រង់ញ៉ាំងវិជ្ជា ៣ ឲ្យកើតក្នុងយាមទាំង ៣ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ទ្រង់បន្លឺព្រះឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារ វដ្ដមានជាតិដ៏ច្រើន ។បេ។ ហើយតថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយដូច្នេះ ។

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធព្រះនាមបទុមៈមក មានព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ឧត្ដមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។ ព្រះអង្គនោះ ជាព្រះរាជបុត្រច្បង ជាព្រះរាជឱរសជាទីស្រឡាញ់ របស់ស្ដេចចក្កពត្តិ ទ្រង់បានពាក់នូវកែវមណី និងគ្រឿងអាភរណៈ ហើយស្ដេចចូលទៅកាន់ឧទ្យាន ។ ក្នុងឧទ្យាននោះ មានឈើមួយដើម ឈ្មោះមហាសោណព្រឹក្ស ជាឈើសមរម្យ ធំល្អ

ស្អាត ព្រះសម្ពុទ្ធ ស្ដេចទៅដល់នូវដើមឈើនោះហើយ ទ្រង់គង់ខាងក្រោមនៃឈើនោះ ។ ព្រះញាណប្រសើររកទីបំផុតគ្មាន មានឧបមាដូចជាកែវវជីរ បានកើតឡើង ( ដល់ព្រះអង្គ ) ក្នុងទីនោះ ព្រះអង្គពិចារណានូវសង្ខារទាំងឡាយ ដោយព្រះញាណនោះ ដូចជាបុគ្គលដែលផ្កាប់ ឬផ្ងារឡើងនូវកាជនៈ ។ ក្នុងទីនោះ ព្រះអង្គទ្រង់បន្សាត់បង់នូវកិលេសទាំងពួង មិនឲ្យសេសសល់ ហើយបានសម្រេចនូវពោធិញ្ញាណទាំងអស់ផង នូវពុទ្ធញ្ញាណទាំង ១៤ ផង ។ លុះព្រះអង្គសម្រេចនូវពោធិញ្ញាណហើយ ទើបទ្រង់សម្ដែងនូវធម្មចក្ក សត្វមួយសែនកោដិ បានត្រាស់ដឹងជាដំបូង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចក្កវត្តិស្ស** បានដល់ ស្ដេចចក្រពត្តិ ។ បទថា **ជេដ្ឋោ** បានដល់ កើតមុន ។ បទថា **ឧយ្យិតឱរសោ** បានដល់ ព្រះរាជឱរស ព្រះរាជបុត្តដែលគួរមើល គួរស្រឡាញ់ ។ បុត្រដែលគេអាណិតហើយ ដែលគេឱបត្រង់ទ្រូង ឈ្មោះថា **ឧយ្យិតឱរស** ។ បទថា **អាមុក្កមាលាភរណោ** បានដល់ ពាក់នូវគ្រឿងប្រដាប់ដៃ មកុដ និងកុណ្ឌលមុក្ដាហារជាមាល័យ ។ បទថា **ឧយ្យានំ** សេចក្ដីថា បានទៅកាន់អារាម ឈ្មោះធនញ្ជយរាជឧទ្យាន ក្រៅព្រះនគរ ។

បទថា **តត្ថាសិ រុក្ខោ** សេចក្ដីថា បានឮថា ក្នុងព្រះរាជឧទ្យាននោះ មានដើមឈើមួយ ឈ្មោះរត្តសោណៈ ។ បានឮថា ដើមរត្តសោណៈនោះ

កម្ពស់ ៩០ ហត្ថ មានដើមមូល មានប្រគាប និងមែកសាខា មានស្លឹកពណ៌ខៀវក្រាស់ និងធំ មានម្លប់ត្រឈឹងត្រឈៃ ព្រោះមានទេវតានៅអាស្រ័យ ទើបប្រាសចាកពួកបក្សីច្រើនប្រភេទដែលសញ្ចរទៅមក ជាឈើដុះចំផ្ចិតផែនដី ហាក់ដូចជាស្តេចនៃដើមឈើ គួរត្រេកអរក្រៃលែង មែកទាំងអស់ ប្រដាប់ដោយផ្កាពណ៌ក្រហម ជាទីប្រជុំចុះនៃភ្នែករបស់ទេវតា និងមនុស្ស ។ បទថា **យសវិបុលោ** បានដល់ មានយសបរិបូណ៌ អធិប្បាយថា ដែលលោកទាំងពួងពោលដល់ ប្រាកដល្បីល្បាញក្នុងទីទាំងពួង ព្រោះសម្បត្តិនៃដើមឈើឯង ។ អាចារ្យពួកខ្លះពោលថា **តត្ថាសិ រុក្ខោ វិបុលោ** ដូច្នេះក៏មាន ។ បទថា **ព្រហា** បានដល់ ធំ អធិប្បាយថា ដូចគ្នានឹងដើមបារិច្ឆត្តកៈរបស់ពួកទេវតា ។ បទថា **តមជ្ឈបត្វា** សេចក្តីថា ដល់ គឺចូលទៅកាន់ដើមសោណៈនោះហើយ ។ បទថា **ហេដ្ឋតោ** បានដល់ ក្រោមដើមឈើនោះ ។

បទថា **ញាណវរុប្បជ្ជិ** បានដល់ ញាណដ៏ប្រសើរកើតឡើង ។ បទថា **អនន្តំ** បានដល់ រាប់មិនបាន ប្រមាណមិនកើត ។ បទថា **វជិរូបមំ** បានដល់ មុតដូចពេជ្រ ពាក្យនេះ ជាឈ្មោះរបស់វិបស្សនាញាណ មានអនិច្ចានុបស្សនាជាដើម ។ បទថា **តេន វិចិនិ សង្ខារេ** បានដល់ ពិចារណាសង្ខារទាំងឡាយមានរូបជាដើម ដោយវិបស្សនាញាណនោះ ។ បទថា **ឧក្កុជ្ជមវកុជ្ជកំ** សេចក្តីថា ពិចារណានូវការកើត និងការសូន្យរបស់សង្ខារទាំងឡាយ អធិប្បាយថា ព្រោះហេតុនោះ ទ្រង់ពិចារណាបច្ចយាការ ចេញចាកចតុត្ថជ្ឈាន មានអានាបានស្សតិជាអារម្មណ៍ ឈមចុះក្នុងខន្ធ ៥ ឃើញលក្ខណៈ ៥០ ដោយ

ឧទយព្វយញ្ញាណ ចម្រើនវិបស្សនា រហូតដល់គោត្រភូញាណ ក៏បានសម្រេចនូវពុទ្ធគុណទាំងអស់ ដោយលំដាប់នៃអរិយមគ្គ ។

បទថា **តត្ថ** បានដល់ ត្រង់ដើមសោណៈនោះ ។ បទថា **សព្ព-កិលេសានិ** បានដល់ កិលេសទាំងទាំងពួង លោកពោលជាលិង្គវិបល្លាស ។ អាចារ្យពួកខ្លះពោលថា **តត្ថ សព្ពកិលេសេហិ**។ បទថា **អសេសំ** បានដល់ មិនសេសសល់ ។ បទថា **អភិវាហយិ** បានដល់ កម្ចាត់កិលេសទាំងអស់ ដោយដែននៃមគ្គ និងដែននៃកិលេស អធិប្បាយថា នាំចូលទៅកាន់ភាពសាបសូន្យ ។ បទថា **ពោធិ** បានដល់ អរហត្តមគ្គញ្ញាណ ។ បទថា **ពុទ្ធញ្ញាណោ ច ចុទ្ទស** បានដល់ ពុទ្ធញ្ញាណ ១៤ យ៉ាង ។ ពុទ្ធញ្ញាណ ១៤ គឺអ្វី គឺមគ្គញ្ញាណ និងផលញ្ញាណ ៨ អសាធារណញ្ញាណ ៦ ឈ្មោះថា ពុទ្ធញ្ញាណរបស់ព្រះពុទ្ធ ។ **ច** សព្ទ ជាសម្បិណ្ឌនត្ថៈ សេចក្ដីថា ដោយ **ច** សព្ទនោះ ទើបសង្គ្រោះដល់ញាណដទៃៗ គឺបដិសម្ភិទាញាណ ៤ វេសា-រជ្ជញ្ញាណ ៤ ញាណកំណត់កំណើត ៤ ញាណកំណត់គតិ ៥ ទស-ពលញ្ញាណ ចូលក្នុងពុទ្ធគុណទាំងអស់ ។

ព្រះមហាបុរសនារទៈ ទ្រង់សម្រេចភាពជាព្រះពុទ្ធយ៉ាងនេះ ទ្រង់ទទួលអារាធនារបស់មហាព្រហ្ម ទ្រង់ធ្វើភិក្ខុមួយសែនកោដិដែលបួសជាមួយព្រះអង្គក្នុងធនញ្ជយរាជឧទ្យាន ក្នុងទីចំពោះព្រះភក្ត្រហើយ ទ្រង់ប្រកាសធម្មចក្រ ។ កាលនោះ ការត្រាស់ដឹងធម៌លើកទី ១ មានដល់ភិក្ខុមួយសែនកោដិ ។ បានឮថា កាលនោះ ស្ដេចនាគឈ្មោះទោណៈ ជាសត្វមានឫទ្ធានុភាពច្រើន

មហាជន នាំគ្នាគោរពកោតក្រែងបូជា អាស្រ័យត្រង់ឆ្នេរស្ទឹងគង្គា ក្បែរមហាទោណនគរ ពួកមនុស្សអ្នកជនបទ ក្នុងទីណា មិនធ្វើការបួងសួងស្តេចនាគនោះក៏ធ្វើទឹកដីរបស់មនុស្សទាំងនោះឲ្យវិនាស ដោយធ្វើមិនឲ្យមានភ្លៀងខ្លះ ឲ្យមានភ្លៀងធ្លាក់ខ្លាំងខ្លះ ធ្វើភ្លៀងដុំក្រួសឲ្យធ្លាក់ខ្លះ ។

លំដាប់នោះ នារទសាស្តាទ្រង់ជាអ្នកឃើញត្រើយ ទ្រង់សម្លឹងឧបនិស្ស័យរបស់សត្វជាច្រើន ទ្រង់ទូន្មានស្តេចនាគឈ្មោះទោណៈ ដែលមានមហាកិត្តិសព្ទរោចរាមហើយ ទើបចូលទៅកាន់លំនៅរបស់ស្តេចនាគនោះមនុស្សទាំងឡាយឃើញព្រះសាស្តាហើយ ទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ស្តេចនាគមានពិសដ៏ពន្លឹក មានតេជៈខ្ពស់ មានឫទ្ធានុភាពច្រើន នៅអាស្រ័យក្នុងទីនោះ នាគនោះ នឹងបៀតបៀនព្រះអង្គ ទ្រង់មិនគួរយាងទៅទេ ។ ព្រះមានព្រះភាគនៅតែយាងទៅ ធ្វើហាក់ដូចមិនបានឮពាក្យរបស់មនុស្សទាំងនោះ ។ កាលយាងទៅហើយ ក៏ប្រថាប់គង់លើកម្រាលផ្កាដែលមានក្លិនក្រអូបក្រៃលែង ដែលពួកមនុស្សបូជាដល់ស្តេចនាគនោះ ក្នុងទីនោះ ។ បានឮថា មហាជនប្រជុំគ្នា ដោយគិតថា យើងនឹងឃើញសង្គ្រាមទាំង ២ ចំណែក គឺព្រះនារទមហាមុនី និងស្តេចនាគឈ្មោះទោណៈ ។

គ្រានោះ ស្តេចនាគឃើញព្រះនាគមុនីគង់យ៉ាងនោះ អត់ធន់មិនបាន ក៏ប្រាកដខ្លួន ព្រួសទូវផ្សែង ។ ឯព្រះទសពល ទ្រង់ក៏បន្ហុយផ្សែង ស្តេចនាគក៏បណ្តាលជាភ្លើង ព្រះមុនីក៏ទ្រង់បណ្តាលភ្លើង ។ ស្តេចនាគនោះ មានខ្លួនលំបាកពន់ពេក ព្រោះផ្សែង និងភ្លើងដែលចេញអំពីសរីរៈរបស់ព្រះទសពល

អត់ធន់នឹងសេចក្តីទុក្ខមិនបាន ក៏ព្រួសពិសចេញទៅ ដោយគិតថា នឹងសម្លាប់ព្រះសាស្តាដោយកម្លាំងពិស កម្លាំងពិសនោះ សូម្បីជម្ពូទ្វីបទាំងមូលក៏អាចវិនាសបាន ។ តែពិសនោះ មិនអាចធ្វើព្រះលោមាត្រឹមមួយសរសៃ ក្នុងព្រះសរីរៈរបស់ព្រះទសពល ឲ្យកម្រើកញាប់ញ័របាន ពេលនោះ ស្តេចនាគនោះក៏ពិចារណាថា សមណៈនេះ ដូចម្តេចទៅហើយហ្ន៎ ឃើញព្រះមានព្រះភាគមានព្រះកក្រ្តផូរផង់ រុងរឿងដោយព្រះពុទ្ធរស្មី ដែលមានពណ៌ ៦ បរិបូណ៌ដូចព្រះអាទិត្យ និងព្រះចន្ទក្នុងសរទរដូវ គិតថា ឱ ! សមណៈនេះ មានឫទ្ធិច្រើន អញមិនដឹងកម្លាំងរបស់ខ្លួន អញខុសហើយហ្ន៎ ស្វែងរកទីពឹង ក៏ដល់នូវព្រះមានព្រះភាគនោះឯងជាសរណៈ ។ លំដាប់នោះ ព្រះនារទមុនីទូន្មានស្តេចនាគនោះហើយ ទ្រង់ក៏ធ្វើយមកបាដិហារ្យ ដើម្បីញុំាងចិត្តរបស់មហាជនដែលប្រជុំគ្នាក្នុងទីនោះ ឲ្យមានសេចក្តីជ្រះថ្លា ។ កាលនោះ សត្វ ៩ ម៉ឺនកោដិ តាំងនៅក្នុងអរហត្ត ។ នេះជាការត្រាស់ដឹងធម៌លើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហាមុនីទូន្មានស្តេចនាគ ឈ្មោះមហាទោណៈ ក្នុងកាលនោះ ទ្រង់ពន្យល់នូវពួកមនុស្ស ព្រមទាំងទេវតា ហើយទ្រង់ធ្វើនូវបាដិហារ្យ ។ ក្នុងកាលនោះ ទេវតា និងមនុស្សទាំងឡាយ ៩០ ពាន់កោដិ បានឆ្លងផុតនូវសេចក្តីសង្ស័យទាំងអស់ ក្នុងការប្រកាសនូវព្រះធម៌នោះ នេះជាការត្រាស់ដឹងទី ២ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធាជិហេរំ តធាកាសិ** សេចក្ដីថា បានធ្វើនូវយមកប្បាដិហារ្យ ។ បាឋៈក៏យ៉ាងនោះដូចគ្នា ។ បាឋៈថា **តធា ទេវ-មនុស្សា វា** ដូច្នេះក៏មាន ។ ក្នុងបាឋៈនោះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិថា **ទេវមនុស្សានំ** ព្រោះហេតុនោះ ទើបមានសេចក្ដីថា ដល់ទេវតានិងមនុស្ស ៩ ម៉ឺនកោដិ ។ បទថា **តរឹសុ** បានដល់ ឈានកន្លងផុត ។

កាលព្រះសាស្ដា ទ្រង់ឲ្យឱវាទដល់នន្ទុត្តរកុមារដែលជាឱរសរបស់ព្រះអង្គ ការសម្រេចធម៌លើកទី៣ មានដល់សត្វ ៨ ម៉ឺនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហាវីរៈ ទ្រង់ទូន្មាននូវបុត្របង្កើត របស់ព្រះអង្គ ក្នុង
កាលណា ( កាលនោះ ) ពួកសត្វចំនួន ៨០ ពាន់កោដិ
បានត្រាស់ដឹងក្នុងលើកទី ៣ ដូច្នេះ ។

កាលព្រាហ្មណ៍ជាសម្លាញ់ ២ នាក់ ឈ្មោះកទ្ទសាលៈ ១ វិជិតមិត្តៈ ១ កំពុងស្វែងរកអន្លង់ទឹក គឺអមតធម៌ ក៏បានឃើញព្រះនារទសម្មាសម្ពុទ្ធ ជាបុគ្គលក្បៀវក្លាក្រៃលែង ប្រថាប់គង់ក្នុងកណ្ដាលបរិស័ទ ។ ជនទាំងពីរឃើញមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងព្រះកាយរបស់ព្រះមានព្រះភាគ ក៏ដាក់ចិត្តថា នេះជាព្រះសម្មាសម្ពុទ្ធ ទ្រង់មានកិលេសដូចដំបូល បើកហើយក្នុងលោក កើតនូវសទ្ធាក្នុងព្រះមានព្រះភាគ មួយអន្លើដោយបរិវារ ក៏បួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ កាលសម្លាញ់ទាំង ២ បួសហើយ ក៏សម្រេចអរហត្ត ។ ព្រះមានព្រះភាគទ្រង់លើកឡើងនូវបាតិមោក្ខ សម្ដែងកណ្ដាលភិក្ខុ

មួយសែនកោដិ នេះជាសន្និបាតលើកទី ១ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាន
សាវកសន្និបាត ៣ លើក គឺសន្និបាតលើកដំបូង មានពួកព្រះ
អរហន្តប្រមាណមួយសែនកោដិ ដូច្នេះ ។

សម័យដែលព្រះនារទសម្មាសម្ពុទ្ធត្រាស់ពុទ្ធវង្ស ចាប់តាំងពីទ្រង់តាំងបណិធានរបស់ព្រះអង្គ ក្នុងសមាគមព្រះញាតិ ភិក្ខុ ៩ ម៉ឺនកោដិប្រជុំគ្នា ជាសន្និបាតលើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសម្ពុទ្ធទ្រង់ប្រកាសពុទ្ធគុណ ព្រមទាំងនិទាន ក្នុងកាលណា
កាលនោះ ព្រះអរហន្តប្រមាណ ៩០ ពាន់កោដិ ប្រាសចាក
មន្ទិល មកប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិមលា** បានដល់ ប្រាសចាកមន្ទិល អធិប្បាយថា ព្រះខីណាស្រព ។

កាលស្ដេចនាគឈ្មោះវេរោចនៈ ជាអ្នកជ្រះថ្លា ក្នុងកាលព្រះមានព្រះភាគ ទូន្មានស្ដេចនាគឈ្មោះមហាទោណៈ និម្មិតមណ្ឌបសម្រេចដោយរតនៈ ៧ ប្រការ ទំហំ ៣ គាវុត ក្នុងស្ទឹងគង្គា អារាធនាព្រះមានព្រះភាគមួយអន្លើដោយភិក្ខុសង្ឃឲ្យប្រថាប់គង់ក្នុងមណ្ឌបនោះ មួយអន្លើដោយបរិវារនិមន្តព្រះមានព្រះភាគ ដើម្បីសរសើរទានរបស់ខ្លួន ក្នុងជនបទរបស់ខ្លួន ឲ្យពួកអ្នករបាំ អ្នកតន្ត្រី ប្រគំនូវតន្ត្រីឈ្មោះតាលៈ ដែលទេវទ្រង់នូវគ្រឿង

អលង្ការច្រើនប្រភេទ បានថ្វាយមហាទានដល់ព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ដោយសក្ការៈធំ សោយស្រេច ព្រះមានព្រះភាគ ទ្រង់ធ្វើអនុមោទនា ដូចយាងចុះកាន់មហាគង្គា ។ ក្នុងកាលនោះ ទ្រង់លើកបាតិមោក្ខឡើងសម្តែងកណ្តាលភិក្ខុ ៨ លានរូប ដែលស្តាប់ធម៌ក្នុងកាលទ្រង់ធ្វើភត្តានុមោទនា ជ្រះថ្លាហើយ បួសជាឯហិភិក្ខុ នុ៎ះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> នាគរាជឈ្មោះវេរោចនៈ បានថ្វាយទានដល់ព្រះសាស្តា ក្នុងកាលណា កាលនោះ ពួកសាវកជាបុត្តនៃព្រះជិនស្រីប្រមាណ ៨០ សែន បានមកប្រជុំគ្នា ( នេះជាសន្និបាតលើកទី ៣ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសីតិសតសហស្សិយោ** បានដល់ ៨០ សែន ។

គ្រានោះ ព្រះពោធិសត្វនៃយើងបួសជាឥសី ជាអ្នកជំនាញក្នុងអភិញ្ញា ៥ និងសមាបត្តិ ៨ សាងអាស្រមនៅអាស្រ័យត្រង់ភ្នំហិមពាន លំដាប់នោះ ព្រះមានព្រះភាគនារទៈ ដែលព្រះអរហន្ត ៨០ កោដិ និងឧបាសកដែលតាំងនៅក្នុងអនាគាមិផលមួយម៉ឺនរូបចោមរោម ទ្រង់យាងទៅកាន់អាស្រមនោះ ដើម្បីអនុគ្រោះឥសីនោះ ។ តាបសឃើញព្រះមានព្រះភាគប៉ុណ្ណោះ ក៏ត្រេកអរសាងអាស្រមដើម្បីជាទីគន់ប្រថាប់របស់ព្រះមានព្រះភាគ មួយអន្លើដោយបរិវារ ប្រកាសនូវគុណរបស់ព្រះសាស្តាអស់មួយរាត្រី ស្តាប់ធម្មកថារបស់

ព្រះមានព្រះភាគ ស្អែកឡើងក៏ទៅកាន់ឧត្តរកុរុទ្វីប នាំអាហារមកអំពីទីនោះ បានថ្វាយនូវមហាទានដល់ព្រះពុទ្ធ មួយអន្លើដោយភិក្ខុសង្ឃ ។ ឥសីថ្វាយមហាទានយ៉ាងនេះអស់ ៧ ថ្ងៃ ហើយនាំខ្លឹមចន្ទន៍ក្រហមដែលមានតម្លៃកាត់ថ្លៃមិនបាន មកអំពីព្រៃហិមពាន្ត បូជាព្រះមានព្រះភាគដោយចន្ទន៍ក្រហមនោះ ។ កាលនោះ ព្រះទសពលដែលទេវតា និងមនុស្សចោមរោមហើយ ត្រាស់ធម្មកថាហើយ ទ្រង់ព្យាករថា បុរសនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ព្រះនាមគោតមក្នុងអនាគតកាល ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> សម័យនោះ តថាគតជាតាបស មានផ្ទះសក់ មានព្យាយាមក្លៀវក្លា បានដល់ត្រើយនៃអភិញ្ញាទាំង ៥ ត្រាច់ទៅតាមអាកាសបាន ។ គ្រានោះ តថាគតបានញុំាងព្រះសម្ពុទ្ធ ដែលស្មើដោយព្រះពុទ្ធ មិនមានបុគ្គលស្មើ ព្រមទាំងព្រះសង្ឃ និងជនជាបរិស័ទ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ហើយបូជាដោយខ្លឹមចន្ទន៍ ។ គ្រានោះ ព្រះនារទៈ ជាលោកនាយកអង្គនោះ ទ្រង់បានព្យាករតថាគតថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ តាបសនេះ នឹងបានជាព្រះពុទ្ធក្នុងលោក ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីត្រេកអរ តម្កល់នូវសេចក្តីព្យាយាម ។បេ។ បើយើងទាំងអស់គ្នា យាងព្រះជិនស្រីអង្គនេះ ក្នុងកាលជាអនាគត ពួក

យើងគង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតម
អង្គនេះ ក៏យ៉ាងនោះដែរ ។
តថាគតបានឮព្រះពុទ្ធដីកា នៃព្រះពុទ្ធអង្គនោះហើយ ក៏ញុំាង
ចិត្តឲ្យរីករាយដោយក្រៃលែង បានអធិដ្ឋានទូវវត្តដ៏លើសលុប
ដោយការបំពេញនូវបារមីទាំង ១០ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តថាគតាហំ** កាត់បទថា **តថាបិ អហំ** ។ បទថា **អសមសមំ** សេចក្ដីថា អតីតពុទ្ធទាំងឡាយ ឈ្មោះថា មិនមានបុគ្គលស្មើ ព្រះនារទសម្ពុទ្ធ ជាបុគ្គលស្មើ គឺរាស់បានដោយអតីតសម្ពុទ្ធដែលមិនមានបុគ្គលស្មើទាំងនោះ ឈ្មោះថា បុគ្គលស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ។ ន័យម្យ៉ាងទៀត បុគ្គលមិនមានអ្នកស្មើ ប្រាសចាកអ្នកស្មើ ។ សាធុជនអ្នកស្មើ អ្នកប្រាសចាកអ្នកស្មើក៏មិនមែន ។ បណ្ដាអ្នកស្មើ ដោយបុគ្គលអ្នកមិនមានបុគ្គលស្មើទាំងនោះ បុគ្គលស្មើ កាលគួរពោលថា **អសមសមសមោ** ( បុគ្គលស្មើនឹងបុគ្គលដែលមិនមានបុគ្គលស្មើ ) គប្បីជ្រាបថា លោកពោលលុប **សម** សព្ទមួយចេញ ។ សេចក្ដីថា បុគ្គលស្មើដោយបុគ្គលមិនមានបុគ្គលស្មើ គឺប្រាសចាកបុគ្គលស្មើ ។ បទថា **សបរិជ្ជនំ** បានដល់ ទាំងជនដែលជាឧបាសក ។ បាឋៈថា **សោបិ មំ តទា នរមរូនំ មជ្ឈេ ព្យាកាសិ ចក្ខុមា** ដូច្នេះក៏មាន ។ បាឋៈនោះ មានអត្ថន័យយល់ដូចគ្នា ។ បទថា **ភិយ្យោ ហាសេត្វា មានសំ** បានដល់ ញុំាងហទយៈឲ្យត្រេកអរ ឲ្យត្រេកអរជាភិយ្យោភាព ។ បទថា **អធិដ្ឋហឹ វតំ ឧគ្គំ** បានដល់

អធិដ្ឋានវត្តក្រៃលែងឡើង ។ បាឋៈថា **ឧត្តរី វតមធិដ្ឋាសី ធុតគុណេ** ដូច្នេះក៏មាន ។

ព្រះមានព្រះភាគនារទៈអង្គនោះ មាននគរឈ្មោះធញ្ញវតី ព្រះជនកជាក្សត្រព្រះនាមព្រះបាទសុទេវៈ ព្រះជននីព្រះនាមអនោមា គូនៃអគ្គសាវកឈ្មោះភទ្ទសាលៈ ១ ព្រះជិតមិត្តៈ ១ ឧបដ្ឋាកឈ្មោះវាសេដ្ឋៈ គូអគ្គសាវិកាឈ្មោះឧត្តរា ១ ផគ្គុនី ១ ពោធិព្រឹក្សឈ្មោះមហាសោណៈ ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះរស្មីនៃព្រះសរីរៈរបស់ព្រះអង្គ ផ្សាយទៅមួយយោជន៍ជានិច្ច ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ អគ្គមហេសីរបស់ព្រះអង្គ ព្រះនាមវិជិតសេនា ព្រះឱរសព្រះនាមនន្ទុត្តរកុមារ មានប្រាសាទ ៣ ឈ្មោះវិជិតៈ ១ វិជីតាវី ១ និងវិជិតាភិរាម ១[១] ។ ទ្រង់គ្រប់គ្រងឃរាវាសវិស័យអស់ ៩ ពាន់ឆ្នាំ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយព្រះបាទ ដោយហេតុនោះ ទើបត្រាស់ព្រះមានព្រះភាគថា

> ព្រះពុទ្ធព្រះនាមនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះធញ្ញវតី មហាក្សត្រព្រះនាមសុទេវៈជាព្រះបិតា ព្រះមាតាព្រះនាមអនោមា ។ ភិក្ខុឈ្មោះភទ្ទសាលៈ ១ ឈ្មោះជិតមិត្តៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះវាសេដ្ឋៈ ជាឧបដ្ឋាករបស់ព្រះសម្ពុទ្ធនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។
>
> នាងឧត្តរា ១ នាងផគ្គុនី ១ ជាអគ្គសាវិកា ឈើសម្រាប់

---

១- បិដកខ្មែរជា ជិតប្រាសាទ ១ វិជិតប្រាសាទ ១ អភិរាមប្រាសាទ ១ ។

ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា មហា-សោណព្រឹក្ស ។ ព្រះមហាមុនី ទ្រង់មានកម្ពស់ ៨៨ ហត្ថក្រពុំ មានព្រះរូបស្មើដោយគ្រឿងបូជា ជាវិការនៃមាស បានញុំាង លោកធាតុទាំងមួយម៉ឺន ឲ្យភ្លឺរុងរឿង ។ ព្រះកាយរបស់ព្រះ អង្គ មានរស្មីប្រមាណមួយព្យាម តែងផ្សាយទៅកាន់ទិសតូច ទិសធំ តែងផ្សាយទៅកាន់ទីប្រមាណមួយយោជន៍ ទាំងថ្ងៃ ទាំងយប់ ជានិរន្តរ៍ សព្វៗ កាល ។ សម័យនោះ ជនទាំង ឡាយពួកខ្លះ នៅក្នុងទីប្រមាណមួយយោជន៍ដោយជុំវិញ ត្រូវ រស្មីទាំងឡាយនៃព្រះពុទ្ធ គ្របសង្កត់ហើយ មិនចាំបាច់អុជ ភ្លើងគប់ ឬអុជភ្លើងប្រទីបទាំងឡាយឡើយ ។ ព្រះជន្មាយុ កំណត់ប្រាំបួនម៉ឺនឆ្នាំគត់ កាលទ្រង់ព្រះជន្មាយុនៅឋិតថេរនោះ តែងញុំាងប្រជុំជនដ៏ច្រើន ឲ្យឆ្លងចាកសង្សារ ។ អាកាសដ៏ វិចិត្រ រុងរឿងដោយផ្កាយទាំងឡាយ យ៉ាងណា សាសនា របស់ព្រះនារទៈអង្គនោះ ក៏រុងរឿងដោយព្រះអរហន្តទាំងឡាយ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធព្រះនាមនារទៈ ប្រសើរជាងពួក នរៈអង្គនោះ ទ្រង់ធ្វើស្ពាន គឺព្រះធម៌ឲ្យមាំ ដើម្បីចម្លងនូវជន ទាំងឡាយដ៏សេស ដែលកំពុងដើរទៅ ដើម្បីឆ្លងនូវខ្សែទឹក គឺសង្សារ ហើយបរិនិព្វាន ។ ព្រះពុទ្ធ ស្មើដោយព្រះពុទ្ធ ដែលគ្មានបុគ្គលស្មើអង្គនោះក្តី ព្រះខីណាស្រពទាំងឡាយ

មានតេជះប្រឹងពុំបាន ទាំងអម្បាលនោះក្តី ក៏និព្វានបាត់បង់
អស់របស់ទាំងពួង ក៏អន្តរធានអស់ ឧហ្ន៎ ! សង្ខារទាំងពួង
ជារបស់សោះសូន្យពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កញ្ចនគ្ឃិយសង្កាសោ** បានដល់ ដែលមានរូបល្អដូចបដិមាដែលសម្រេចដោយមាស វិចិត្រដោយរតនៈផ្សេងៗ ។ បទថា **ទសសហស្សី វិរោចតិ** សេចក្តីថា លោកធាតុទាំងមួយម៉ឺន រុងរឿងដោយព្រះរស្មីរបស់ព្រះអង្គ ។ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា រស្មីប្រមាណមួយព្យាយាម តែងផ្សាយទៅកាន់ទិសតូចទិសធំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្យាមប្បភា កាយា** បានដល់ ដូចព្រះរស្មីមួយព្យាយាម ហេតុនោះ ទើបឈ្មោះថា **ព្យាមប្បភា** អធិប្បាយថា ដូចព្រះរស្មីមួយព្យាមរបស់ព្រះមានព្រះភាគនៃយើង ។

**ន** អក្ខរៈក្នុងបទថា **ន កេចិ** នេះ ប្រើក្នុងអត្ថបដិសេធ គប្បីឃើញការភ្ជាប់សេចក្តីរបស់ **ន** អក្ខរៈនោះ ជាមួយនឹងសព្ទថា **ឧជ្ជាលេន្តិ** ។ បទថា **ឧក្កា** បានដល់ ប្រទីបមានដង គឺគប់ភ្លើង ។ ជនពួកខ្លះ មិនញ៉ាំងគប់ភ្លើងឬប្រទីបឲ្យឆេះបាន មិនឲ្យឆេះបាន បើនឹងសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយបានថា ព្រោះពន្លឺរបស់រស្មីនៃព្រះពុទ្ធសរីរៈ ។ បទថា **ពុទ្ធរំសីហិ** បានដល់ពុទ្ធរស្មីទាំងឡាយ ប្រើជាបទថា **ពុទ្ធរស្មីហិ** ក៏បាន ។ បទថា **ឱត្ថតា** បានដល់ គ្របសង្កត់ ។

បទថា **ឧទ្ធបហិ** បានដល់ ដោយពួកផ្កាយទាំងឡាយ សេចក្តីថា ផ្ទៃមេឃ វិចិត្រដោយតារាទាំងឡាយ យ៉ាងណា សាសនារបស់ព្រះនារទសម្ពុទ្ធអង្គនោះ ក៏លម្អវិចិត្រដោយព្រះអរហន្តទាំងឡាយ យ៉ាងនោះដូចគ្នា ។ បទថា **សំសារសោតំ តរណាយ** បានដល់ ដើម្បីឆ្លងសាគរ គឺសង្សារវដ្ត ។ បទថា **សេសកេ បដិបន្នកេ** សេចក្តីថា ញុំាងសេក្ខបុគ្គលដ៏សេស និងកល្យាណបុថុជ្ជន វៀរព្រះអរហន្តទាំងឡាយ ។ បទថា **ធម្មសេតុំ** បានដល់ស្ពាន គឺមគ្គ សេចក្តីថា ទ្រង់ធ្វើស្ពាន គឺធម៌ ដើម្បីញុំាងបុគ្គលដ៏សេស ឲ្យឆ្លងចាកវដ្តសង្សារ ទ្រង់ធ្វើនូវកិច្ចសព្វយ៉ាងស្រេចហើយ ក៏បរិនិព្វាន ។ ពាក្យដ៏សេសមានអត្ថងាយយល់ ព្រោះមានន័យដូចបាន ពោលហើយខាងដើមនោះឯង ។ល។

## អដ្ឋកថានារទពុទ្ធវង្សទី ៩ ចប់

# សុត្តន្តបិដក

## បទុមុត្តរពុទ្ធវង្សទី ១០

[ ១១ ] ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មានព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់ឈ្នះមារ ទ្រង់មិនរំភើប ឧបមាដូចសាគរ ។ ព្រះពុទ្ធនេះទ្រង់កើតឡើងក្នុងកប្បណា កប្បនោះឈ្មោះមណ្ឌកប្ប ប្រជុំជនមានកុសលដុះឡើងហើយ តែងកើតក្នុងកប្បនោះ ។ កាលព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់សម្តែងនូវធម៌ជាដំបូង សត្វទាំងឡាយប្រមាណមួយសែនកោដិ ក៏បានត្រាស់ដឹងនូវមគ្គ និងផល ។ លំដាប់តអំពីនោះមក កាលព្រះបរមសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់បង្អុរចុះនូវធម៌ ទ្រង់ញុំាងពួកសត្វ ឲ្យឆ្អែតស្កប់ស្កល់ ពួកសត្វប្រមាណ ៣ ម៉ឺន ៧ ពាន់ បានត្រាស់ដឹងក្នុងលើកទី ២ ។ ក្នុងកាលណា ព្រះមហាវីរបុរស ស្តេចចូលទៅរកព្រះបាទអានន្ទជាព្រះបិតា លុះស្តេចចូលទៅកាន់សម្នាក់ព្រះបិតាហើយ ទ្រង់ទូងស្គរ គឺអមតធម៌ ។ កាលស្គរ គឺអមតធម៌ ដែលព្រះអង្គទ្រង់ទូងហើយ ភ្លៀង គឺធម៌ក៏ធ្លាក់ចុះ ( ក្នុងកាលនោះ ) ពួកសត្វប្រមាណ ៥ លាន បានត្រាស់ដឹងក្នុងលើកទី ៣ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ទូន្មានពន្យល់ ចម្លងនូវសត្វទាំងពួងបានចម្លងហើយ នូវប្រជុំជនជាច្រើន ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១

មានព្រះខីណាស្រព ប្រមាណមួយសែនកោដិ ។ កាលណា ព្រះសម្ពុទ្ធ ស្មើដោយព្រះអតីតពុទ្ធ រកបុគ្គលស្មើគ្មាន ទ្រង់គង់ នៅលើភ្នំវេភារបព៌ត ( ក្នុងកាលនោះ ) ជាសន្និបាតលើកទី ២ មានព្រះខីណាស្រព ប្រមាណ ៩០ ពាន់កោដិ ។ កាលព្រះសម្ពុទ្ធ ចៀសចេញចាកស្រុក ចាកនិគម និងដែន ទៅកាន់ចារិកម្តង ទៀត នេះជាសន្និបាតលើកទី ៣ មានព្រះខីណាស្រព ប្រមាណ ៨០ ពាន់កោដិ ។ សម័យនោះ តថាគតជាជដិល អ្នកនៅក្នុង ដែន តថាគតបានថ្វាយសំពត់ ព្រមទាំងភត្តដល់ព្រះសង្ឃ មាន ព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងកណ្តាលនៃ ភិក្ខុសង្ឃ ហើយទ្រង់ព្យាករតថាគតថា ក្នុងកប្បទីមួយសែន អំពីកប្បនេះ ជដិលនេះ នឹងបានជាព្រះពុទ្ធមួយអង្គ ។ សត្វនេះ នឹងចេញចាក ក្រុងកបិលពស្តុ ជាទីត្រេកអរ តម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះ ជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបច្រាំងស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែង ។ លំដាប់នោះ ព្រះសម្ពុទ្ធទ្រង់មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀប គល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតនៃព្រះសម្ពុទ្ធអង្គនេះ ព្រះ

នាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯព្រះសម្ពុទ្ធអង្គនេះ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ។ ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវក-គហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុរបស់ព្រះគោតម ដ៏មានយស អង្គនោះ កំណត់ ១០០ ឆ្នាំ ។ ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់ព្រះបន្ទូលនេះ នៃព្រះសម្ពុទ្ធ រកបុគ្គលស្មើគ្មាន ទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយក៏ត្រេកអរថា ជដិលនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើច ក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបាន សម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ។ មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងកំពង់ក្នុងទីចំពោះមុខ គង់កាន់យកនូវ

កំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ តថាគតបានឮព្រះបន្ទូល នៃព្រះសម្ពុទ្ធអង្គនោះហើយ បានអធិដ្ឋានវត្តដ៏លើសលុបឡើងទៅ បានធ្វើនូវព្យាយាមដ៏ខ្ពង់ខ្ពស់ មាំមួន ដោយការបំពេញនូវបារមីទាំង ១០ ។ ក្នុងកាលនោះ ត្រិយទាំងពួង អាក់អន់តូចចិត្ត វិនាសខ្ចាត់ខ្ចាយ បរិស័ទពួកខ្លះ នៃត្រិយទាំងនោះ មិនបម្រើត្រិយទាំងនោះ ក៏នាំគ្នាចៀសចេញចាកដែនទៅ ។ ត្រិយទាំងពួង មកប្រជុំគ្នាក្នុងទីនោះហើយ បានចូលទៅក្នុងសម្នាក់នៃព្រះពុទ្ធ ( ហើយពោលថា ) បពិត្រព្រះមហាវីរៈ សូមព្រះអង្គជាទីពឹងពុំនាក់ ( នៃយើងខ្ញុំទាំងឡាយ ) បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គជាទីរឭក ។ ព្រះពុទ្ធទ្រង់អនុគ្រោះ ទ្រង់ប្រកបដោយករុណា ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញ៉ាំងត្រិយទាំងអស់ ដែលមកប្រជុំហើយ ឲ្យស្ថិតនៅក្នុងសីល ៥ ។ សាសនា ( របស់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈនោះ ) មិនរីករវ ជាសាសនាសូន្យចាកពួកត្រិយទាំងនេះ សាសនានោះ វិចិត្រហើយដោយព្រះអរហន្តទាំងឡាយ ជាអ្នកស្ទាត់ជំនាញ ជាតាទិបុគ្គល ។ ព្រះសាស្តាព្រះនាមបទុមុត្តរៈ មានព្រះនគរឈ្មោះហង្សវតី មានមហាក្សត្រព្រះនាមអានន្ទៈ ជា

ព្រះបិតា មានព្រះមាតាព្រះនាមសុជាតា ។ ព្រះអង្គទ្រង់នៅគ្រប់គ្រងផ្ទះអស់ ៩ ពាន់ឆ្នាំ ប្រាសាទទាំងឡាយដ៏ប្រសើរ មាន ៣ ខ្នង គឺនារីប្រាសាទ ១ ពាហនប្រាសាទ ១ យសវតីប្រាសាទ ១ ។ មាននារីបីបួនពាន់ តាក់តែងល្អ ឯនារីដែលជាអគ្គមហេសីឈ្មោះវសុលទត្តា ព្រះរាជបុត្តព្រះនាមឧត្តរៈ ។ ព្រះជិនស្រីប្រសើជាងបុរស ទ្រង់ឃើញនូវនិមិត្តទាំង ៤ យ៉ាងហើយ ស្តេចចេញទៅដោយប្រាសាទ ទ្រង់ប្រព្រឹត្តសេចក្តីព្យាយាម អស់ ៧ ថ្ងៃ ។ ព្រះបទុមុត្តរៈ ជានាយក ជាមហាវីរបុរស ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះមិថិលា ។ ភិក្ខុឈ្មោះទេវិលៈ ១ ឈ្មោះសុជាតៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះសុមនៈជាឧបដ្ឋាក របស់ព្រះសាស្តាព្រះនាមបទុមុត្តរៈ ។ ភិក្ខុនីឈ្មោះអមិតា ១ អសមា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះហៅថា សលឡព្រឹក្ស ( ដើមស្រល់ ) ។ ឧបាសកឈ្មោះអមិតៈ ១ ឈ្មោះតិស្សៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះហត្ថា ១ សុចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះសម្ពុទ្ធមហាមុនី ទ្រង់មានកម្ពស់ ៥៨ ហត្ថក្រពុំ មានព្រះអង្គដ៏ល្អល្អះ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ ទ្វារក្តី គន្លឹះទ្វារក្តី ជញ្ជាំងក្តី ឈើក្តី ភ្នំធំក្តី ជាគ្រឿង

រាំងរានៃព្រះសមុទ្ទនោះ ក្នុងទីប្រមាណ ១២ យោជន៍ដោយជុំវិញ មិនមានឡើយ ។ ព្រះជន្មាយុមានកំណត់មួយសែនឆ្នាំ កាលព្រះសមុទ្ទនោះ ទ្រង់ព្រះជន្មាយុនៅជរាបនោះ ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង ( ចាកសង្សារ ) លុះទ្រង់ចម្លងជនជាច្រើន ហើយកាត់នូវសេចក្តីសង្ស័យទាំងពួង ហើយបរិនិព្វានជាមួយនឹងសាវក ដូចជាគំនរភ្លើង ដែលឆេះរុងរឿង ហើយរលត់ទៅ ដូច្នោះ ។ ព្រះពុទ្ធជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះអង្គមានកម្ពស់ ១២ យោជន៍ ( ដែលគេសាងហើយ ) ក្នុងនន្ទារាមនោះ ។

## បទុមុត្តរពុទ្ធវង្សទី ១០ ចប់

# អដ្ឋកថា

## បទុមុត្តរពុទ្ធវង្សទី ១០

សាសនារបស់ព្រះនារទសម្ពុទ្ធប្រព្រឹត្តទៅបាន ៩ ម៉ឺនឆ្នាំ ក៏អន្តរធានទៅ កប្បក៏វិនាសទៅ ។ បន្ទាប់អំពីនោះ ព្រះពុទ្ធទាំងឡាយ ក៏មិនកើតឡើងក្នុងលោក អស់មួយអសង្ខេយ្យនៃកប្បទាំងឡាយ ។ កប្បទាំងឡាយទទេចាកព្រះពុទ្ធ ប្រាសចាកពន្លឺនៃព្រះពុទ្ធ ។ បន្ទាប់អំពីនោះ កាលកប្ប និងអសង្ខេយ្យទាំងឡាយកន្លងទៅ ក្នុងកប្បមួយ គឺក្នុងកប្បទីមួយសែនរាប់អំពីកប្បនេះ មានព្រះពុទ្ធមួយអង្គ ទ្រង់ឈ្មោះមារ ទ្រង់ជាក់ការៈ មានព្រះមេរុជាសារៈ មិនមានសង្សារវដ្ត មានសត្វជាសារៈ ជាកំពូលនៃលោកទាំងពួង ព្រះនាមបទុមុត្តរៈ កើតឡើងក្នុងលោក ។ ព្រះពុទ្ធអង្គនោះ ទ្រង់បំពេញបារមីទាំងឡាយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីស្ថានតុសិតនោះហើយបដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងសុជាតាទេវី កើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះជាអគ្គមហេសីរបស់ព្រះបាទអានន្ទ ដែលជាអ្នកធ្វើនូវការត្រេកអរដល់ជនទាំងពួង ក្នុងហង្សវតីនគរ ។ ព្រះនាងសុជាតាទេវីនោះ ដែលពួកទេវតារក្សាហើយ គ្រប់កំណត់ទសមាស ក៏ប្រសូតបទុមុត្តរកុមារ ក្នុងព្រះរាជឧទ្យានហង្សវតី ។ ក្នុងសម័យបដិសន្ធិ និងសម័យប្រសូត បាដិហារ្យមានហើយដូចពោលខាងដើម ។

បានឮមកថា ក្នុងសម័យព្រះរាជកុមារអង្គនោះទ្រង់ប្រសូត ភ្លៀងផ្កាឈូកក៏ធ្លាក់ចុះមក ដោយហេតុនោះ ក្នុងថ្ងៃថ្វាយព្រះនាមព្រះរាជកុមារ ពួកញាតិទាំងឡាយក៏ថ្វាយព្រះនាមថា បទុមុត្តរកុមារ ។ ព្រះរាជកុមារអង្គនោះ

ទ្រង់នៅគ្រប់គ្រងផ្ទះអស់មួយម៉ឺនឆ្នាំ ទ្រង់មានប្រាសាទ ៣ សមគួរដល់រដូវទាំង ៣ គឺនរវាហនៈ ១ យសវាហនៈ ១ វសវត្តី ១[១] មានស្រីស្នំ ១ សែន ២ ម៉ឺននាក់ មានព្រះនាងវសុទត្តាទេវី[២] ជាប្រធាន កាលឧត្តរកុមារប្រសើរដោយគុណសព្វយ៉ាង ដែលជាឱរសរបស់ព្រះនាងវសុទត្តាទេវី ប្រសូតហើយ ទ្រង់ឃើញនិមិត្ត ៤ ទ្រង់ត្រិះរិះដើម្បីចេញមហាភិនេស្រ្កមណ៍ លុះទ្រង់ព្រះតម្រិះប៉ុណ្ណោះ ប្រាសាទឈ្មោះវសវត្តី ក៏អណ្តែតទៅតាមអាកាសដូចចក្ររបស់ស្មូនឆ្នាំង ទៅតាមលម្ហ ដូចទេវវិមាន និងដូចព្រះចន្ទ ធ្វើពោធិ-ព្រឹក្សឲ្យនៅត្រង់កណ្តាល ដូចប្រាសាទដែលពោលហើយ ក្នុងវង្សរបស់ព្រះសោភិតៈ ។

បានឮថា ព្រះមហាបុរសយាងចុះអំពីប្រាសាទនោះ ទ្រង់ដណ្តប់សំពត់កាសាវៈ ដែលជាទង់ជ័យនៃព្រះអរហន្ត ដែលទេវតាថ្វាយ ទ្រង់បួសក្នុងប្រាសាទនោះឯង ប្រាសាទក៏ត្រឡប់មកតាំងនៅក្នុងទីដើមរបស់ខ្លួន ។ បរិស័ទទាំងអស់ ដែលទៅជាមួយព្រះមហាសត្វ នាំគ្នាបួស វៀរតែស្ត្រីទាំងឡាយ ។ ព្រះមហាបុរសទ្រង់បំពេញព្យាយាមអស់ ៧ ថ្ងៃ ជាមួយអ្នកបួសទាំងនោះ ក្នុងថ្ងៃ ១៥ កើត ខែវិសាខ ទ្រង់សោយមធុបាយាស ដែលធីតារុបាននូសេដ្ឋីក្នុងឧជ្ជេនីនិគមថ្វាយ ហើយទ្រង់សម្រាកពេលថ្ងៃ ក្នុងសាលវ័ន ក្នុងវេលាល្ងាច ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលសុមិត្តអាជីវកថ្វាយ ទ្រង់ចូលទៅកាន់

---

១- បិដកខ្មែរជា នារីប្រាសាទ ១ ពាហនប្រាសាទ ១ យសវតីប្រាសាទ ១ ។

២- បិដកខ្មែរជា វសុលទត្តា ។

ពោធិព្រឹក្សឈ្មោះដើមសលឡៈ ទ្រង់ធ្វើប្រទក្សិណពោធិព្រឹក្សនោះ ទ្រង់ក្រាលនូវសន្ថតស្មៅ ទំហំប្រមាណ ៣៨ ហត្ថ ទ្រង់គង់ពត់ភ្នែន អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ទ្រង់កម្ចាត់មារ ព្រមទាំងសេនា ក្នុងបឋមយាម ទ្រង់បាននូវបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងយាមទី ២ ទ្រង់ជម្រះទិព្វចក្ខុញ្ញាណឲ្យបរិសុទ្ធក្នុងយាមទី ៣ ទ្រង់ពិចារណាបច្ចយាការ ចេញអំពីចតុត្ថជ្ឈានមានអានាបានស្សតិជាអារម្មណ៍ ហើយឈមចុះក្នុងខន្ធ ៥ ទ្រង់ឃើញលក្ខណៈ ៥០ ដោយអំណាចការកើតឡើង ហើយវិនាសទៅ ទ្រង់ចម្រើនវិបស្សនារហូតដល់គោត្រភូញាណ ទ្រង់ចាក់ធ្លុះនូវពុទ្ធគុណទាំងមូល ដោយអរិយមគ្គទ្រង់បន្លឺព្រះឧទានដែលព្រះពុទ្ធគ្រប់អង្គ ទ្រង់មិនលះបង់ថា

> កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ )
> ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏
> អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយ
> តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ
> ដូច្នេះ ។

បានឮថា កាលនោះ ភ្លៀងផ្កាឈូកធ្លាក់ចុះមក ហាក់បីដូចប្រដាប់ដោយទូទៅក្នុងមួយម៉ឺនចក្កវាឡ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មាន
> ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់

ឈ្មោះមារ ទ្រង់មិនរំភើប ឧបមាដូចសាគរ ។ ព្រះពុទ្ធនេះ ទ្រង់កើតឡើងក្នុងកប្បណា កប្បនោះ ឈ្មោះមណ្ឌកប្ប ប្រជុំជនមានកុសលដុះឡើងហើយ តែងកើតក្នុងកប្បនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាគរូបមោ** បានដល់ មានការៈជ្រាលជ្រៅដូចសាគរ ។ ក្នុងបទថា **មណ្ឌកប្បោ វា សោ អាសិ** នេះ ព្រះសម្មាសម្ពុទ្ធ ២ អង្គកើតឡើងក្នុងកប្បណា កប្បនោះ ឈ្មោះថា មណ្ឌកប្ប ។

ពិតហើយ កប្បមាន ២ គឺសុញ្ញកប្ប ១ អសុញ្ញកប្ប ១ បណ្ដាកប្បទាំង ២ នោះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងស្ដេចចក្កពត្តិ រមែងមិនកើតក្នុងសុញ្ញកប្ប ព្រោះហេតុនោះ កប្បនោះ ទើបហៅថា សុញ្ញកប្ប ព្រោះទទេចាកបុគ្គលដែលមានគុណ ។

អសុញ្ញកប្ប មាន ៥ គឺសារកប្ប ១ មណ្ឌកប្ប ១ វរកប្ប ១ សារមណ្ឌកប្ប ១ ភទ្ទកប្ប ១ ។ ក្នុងអសុញ្ញកប្បនេះ កប្បដែលប្រកបដោយសារៈ គឺគុណ ហៅថា សារកប្ប ព្រោះប្រាកដព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គ ព្រោះទ្រង់ញុំាងនូវគុណសារៈឲ្យកើត ។

ឯក្នុងកប្បណា មានព្រះពុទ្ធ ២ ព្រះអង្គ កប្បនោះ ហៅថា មណ្ឌកប្ប ។ ក្នុងកប្បណា កើតព្រះពុទ្ធ ៣ ព្រះអង្គ បណ្ដាព្រះពុទ្ធ ៣ ព្រះអង្គនោះ អង្គទី ១ ព្យាករអង្គទី ២ អង្គទី ២ ព្យាករអង្គទី ៣ ក្នុងកប្បនោះ មនុស្សទាំងឡាយ មានចិត្តត្រេកអរ រមែងជ្រើសរើសដោយបណិធានដែលខ្លួនប្រាថ្នា ព្រោះហេតុនោះ ទើបកប្បនោះ ហៅថា វរកប្ប ។

ឯក្នុងកប្បណា មានព្រះពុទ្ធ ៤ ព្រះអង្គ កប្បនោះ ហៅថា សារ-មណ្ឌកប្ប ព្រោះប្រសើរជាង មានសារៈជាងកប្បមុនៗ ។

ក្នុងកប្បណា មានព្រះពុទ្ធ ៥ ព្រះអង្គ កប្បនោះ ហៅថា ភទ្ទកប្ប ។ ភទ្ទកប្បនោះ រកបានដោយកម្រក្រៃលែង ។ កប្បនោះ ដោយច្រើន សត្វទាំងឡាយ ច្រើនដោយកល្យាណសុខ ដោយច្រើនតិហេតុកសត្វ រមែងអស់កិលេស ទុហេតុកសត្វរមែងដល់នូវសុគតិ អហេតុកសត្វក៏បាននូវហេតុ ព្រោះហេតុនោះ ទើបកប្បនោះ ហៅថា ភទ្ទកប្ប ដោយហេតុនោះ ទើបខ្ញុំពោលថា អសុញ្ញកប្បមាន ៥ ជាដើម ។ សមដូចបុរាណាចារ្យពោលថា

ក្នុងសារកប្ប មានព្រះពុទ្ធ ១ អង្គ ក្នុងមណ្ឌកប្ប មានព្រះពុទ្ធ ២ អង្គ ក្នុងវរកប្ប មានព្រះពុទ្ធ ៣ អង្គ ក្នុងសារ-មណ្ឌកប្ប មានព្រះពុទ្ធ ៤ អង្គ ក្នុងភទ្ទកប្ប មានព្រះពុទ្ធ ៥ អង្គ ព្រះពុទ្ធច្រើនជាងនោះ មិនមាន ដូច្នេះ ។

ឯក្នុងកប្បណា ដែលព្រះបទុមុត្តរទសពលកើតឡើង កប្បនោះ ជាសារកប្ប លោកហៅថា មណ្ឌកប្ប ព្រោះដូចគ្នានឹងមណ្ឌកប្ប ដោយគុណ-សម្បត្តិ ។ វា សព្ទ គប្បីឃើញថា ចុះក្នុងអត្ថឧបមា ។ បទថា **ឧស្សន្ន-កុសលា** បានដល់ អ្នកសន្សំបុណ្យ ។ បទថា **ជនតា** បានដល់ ប្រជុំជន ។

ព្រះមានព្រះភាគបទុមុត្តរៈ ទ្រង់ជាកំពូលបុរស ទ្រង់សម្ងំនៅត្រង់ពោធិបល្ល័ង ៧ ថ្ងៃ ទ្រង់ឈានព្រះបាទខាងស្តាំ ដោយបំណងថា នឹងជាន់ផែនដី ។ លំដាប់នោះ ផ្កាឈូកទាំងឡាយមានកេសរ និងលម្អងប្រាសចាក

មន្ទិល មានស្លឹកដូចកើតក្នុងទឹក ជាផ្កាមិនសៅហ្មង មិនខ្វះខាត ជាផ្កាបរិបូណ៌ ទម្លុះផែនដីផុសឡើង ឈូកនោះ មានស្លឹកជិតគ្នា ៩០ ហត្ថ កេសរ ៣០ ហត្ថ ដុំកណ្តាល ១២ ហត្ថ លម្អងរបស់ផ្កានីមួយៗ ទំហំប៉ុនក្អមធំ ឯព្រះសាស្តា មានកម្ពស់ ៥៨ ហត្ថ ចន្លោះពាហាទាំងសងខាងរបស់ព្រះអង្គ ១៨ ហត្ថ ព្រះនលាដ ៥ ហត្ថ ព្រះហស្ត និងព្រះបាទ ១១ ហត្ថ ។ លុះទ្រង់ជាន់ដុំកណ្តាលរបស់ផ្កា ដោយព្រះបាទ ១១ ហត្ថ លម្អងប៉ុនក្អម ក៏ផ្សាយឡើងទៅលើ ស្រោចស្រពព្រះសរីរៈ ៥៨ ហត្ថ ហើយធ្លាក់ស្រោចចុះមក ដូចលម្អិតមនោសិលា ។ សំដៅយកសេចក្តីនោះ ទើបអាចារ្យអ្នករចនាគម្ពីរសំយុត្តនិកាយពោលថា ព្រះសាស្តាប្រាកដក្នុងលោកថា ព្រះបទុមុត្តរៈ ដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគបទុមុត្តរៈ ទ្រង់ជាកំពូលនៃលោកទាំងពួង ទ្រង់ទទួលអារាធនារបស់មហាព្រហ្ម ទ្រង់ប្រមើលមើលសត្វទាំងឡាយដែលដូចជាភាជនៈ ទទួលនូវព្រះធម្មទេសនា ទ្រង់ឃើញព្រះរាជឱរស ២ អង្គ គឺទេវលៈ ១ សុជាតៈ ១ ដែលដល់ព្រមដោយឧបនិស្ស័យ ត្រង់នគរមិថិលា រំពេចនោះ ទ្រង់ក៏យាងទៅតាមអាកាស ចុះត្រង់រាជឧទ្យាន ក្រុងមិថិលា ទ្រង់ឲ្យឧទ្យានបាលហៅព្រះរាជកុមារទាំង ២ អង្គមក ស្តេចទាំង ២ អង្គទ្រង់ព្រះត្រិះរិះថា ព្រះបទុមុត្តរកុមារឱរសរបស់ម្ចាស់មាអញ ទ្រង់ព្រះផ្នួស ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ យាងដល់នគររបស់អញ អញនឹងចូលទៅគាល់ទ្រង់ មួយអន្លើដោយបរិវារ ក៏ចូលទៅគាល់ព្រះមានព្រះភាគ

បទុមុត្តរៈ អង្គុយចោមរោម ។ កាលនោះ ព្រះទសពល កាលព្រះរាជកុមារ និងបរិវារទាំងនោះ ចោមរោមហើយ ទ្រង់រុងរឿងដូចព្រះចន្ទ ដែលពួកផ្កាយចោមរោម ទ្រង់ប្រកាសធម្មចក្កក្នុងទីនោះ ។ កាលនោះ ការត្រាស់ដឹងធម៌លើកទី ១ មានដល់សត្វមួយសែនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ទ្រង់សម្ដែងនូវ
> ធម៌ជាដំបូង សត្វទាំងឡាយ ប្រមាណមួយសែនកោដិ ក៏
> បានត្រាស់ដឹងនូវមគ្គ និងផល ដូច្នេះ ។

សម័យតមក ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ឲ្យមហាជន ក្នុងសមាគមរបស់សរទតាបស រឭកដល់កម្ដៅក្នុងនរក ទ្រង់ញ៉ាំងពួកសត្វ ៣ លាន ៧ សែន[១] ឲ្យផឹកនូវអមតធម៌ នោះជាការត្រាស់ដឹងធម៌លើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> លំដាប់តអំពីនោះមក កាលព្រះបរមសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ
> ទ្រង់បង្អុរចុះនូវធម៌ ទ្រង់ញ៉ាំងពួកសត្វ ឲ្យឆ្អែតស្កប់ស្កល់
> ពួកសត្វប្រមាណ ៣ ម៉ឺន ៧ ពាន់ បានត្រាស់ដឹងក្នុងលើកទី
> ២ ដូច្នេះ ។

គ្រានោះ ព្រះបាទអានន្ទមហារាជ ប្រាកដព្រះអង្គក្នុងមិថិលានគរ ក្នុងសម្នាក់របស់ព្រះបទុមុត្តរសម្មាសម្ពុទ្ធ មួយអន្លើដោយបុរស ២ ម៉ឺន និង

---

១- បិដកខ្មែរជា ៣ ម៉ឺន ៧ ពាន់ ។

អមាត្យ ២០ នាក់ ។ ព្រះមានព្រះភាគបទុមុត្តរៈ ទ្រង់ឲ្យជនទាំងនោះបួស ដោយឯហិភិក្ខុ កាលជនទាំងនោះចោមរោមហើយ យាងទៅធ្វើការសង្គ្រោះ ព្រះជនក ប្រថាប់នៅក្នុងក្រុងហង្សវតីរាជធានី ក្នុងទីនោះ ទ្រង់យាងចង្ក្រម ក្នុងរតនចង្ក្រមកណ្តាលអាកាស ត្រាស់ពុទ្ធវង្សដូចព្រះសាស្តានៃយើង ក្នុង ក្រុងកបិលពស្តុ កាលនោះ ការត្រាស់ដឹងធម៌លើកទី ៣ កើតមានដល់សត្វ ៥ លាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងកាលណា ព្រះមហាវីរបុរស ស្តេចចូលទៅរកព្រះបាទ អានន្ទ ជាព្រះបិតា លុះស្តេចចូលទៅកាន់សម្នាក់ព្រះបិតា ហើយ ទ្រង់ទូងស្គរ គឺអមតធម៌ ។ កាលស្គរ គឺអមតធម៌ ដែលព្រះអង្គទ្រង់ទូងហើយ ភ្លៀង គឺធម៌ក៏ធ្លាក់ចុះ ( ក្នុង កាលនោះ ) ពួកសត្វប្រមាណ ៥ លាន បានត្រាស់ដឹងក្នុង លើកទី ៣ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អានន្ទំ ឧបសង្កមិ** ត្រាស់សំដៅដល់ព្រះ បាទអានន្ទ ដែលជាព្រះជនក ។ បទថា **អាហានិ** បានដល់ ទ្រង់ទូង ។ បទ ថា **អាហតេ** គឺ **អាហតាយ** ( លាន់ឮហើយ ) ។ បទថា **អមតភេរិម្ហិ** បានដល់ ស្គរនៃអមតៈ ។ គប្បីឃើញថា ជាលិង្គវិបល្លាស ។ បាឋៈថា **អាសេវិតេ** ដូច្នេះក៏មាន ។ បាឋៈនោះ មានសេចក្តីថាដែលគេសេពហើយ ។ បទថា **វស្សន្តេ ធម្មវុដ្ឋិយា** សេចក្តីថា ទ្រង់បង្អុរនូវភ្លៀង គឺធម៌ ឥឡូវនេះ កាលទ្រង់សម្តែងឧបាយដើម្បីធ្វើនូវការត្រាស់ដឹងធម៌ ទើបត្រាស់ថា

ព្រះពុទ្ធទ្រង់ឈ្មោះសក្នុងទេសនា ទ្រង់ទូន្មានពន្យល់ ចម្លងនូវ
សត្វទាំងពួង បានចម្លងហើយនូវប្រជុំជនជាច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱវាទកោ** មានវិគ្គហៈថា ឈ្មោះថា **ឱវាទក** ព្រោះទូន្មាន ដោយពណ៌នាគុណានិសង្សនៃសរណៈ ការសមាទានសីល និងធុតង្គ ។ បទថា **វិញ្ញាបកោ** មានវិគ្គហៈថា ឈ្មោះថា **វិញ្ញាបក** ព្រោះឲ្យសត្វដឹងសច្ចៈ ៤ គឺឲ្យសត្វត្រាស់ដឹង ។ បទថា **តារកោ** បានដល់ឲ្យឆ្លងឱឃៈ ៤ ។

គ្រានោះ ព្រះសាស្តាទ្រង់មានព្រះភក្ត្រ ដូចព្រះចន្ទពេញវង់ ក្នុងថ្ងៃ ១៥ កើត ខែមាឃ ទ្រង់លើកបាតិមោក្ខឡើងសម្តែងកណ្តាលភិក្ខុមួយសែនកោដិ ក្នុងមិថិលារាជឧទ្យាន ក្រុងមិថិលា នេះជាសន្និបាតលើកទី ១ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តាព្រះនាមបទុមុត្តរៈ មានសាវកសន្និបាត ៣ លើក
គឺសន្និបាតលើកទី ១ មានព្រះខីណាស្រព ប្រមាណមួយ
សែនកោដិ ដូច្នេះ ។

កាលព្រះមានព្រះភាគ ចាំវស្សាត្រង់កំពូលភ្នំវេភារបព៌ត ទ្រង់សម្តែងធម៌ ប្រោសមហាជន ដែលមកមើលបព៌ត ទ្រង់ញុំាងជន ៩ ម៉ឺនកោដិ ឲ្យបួសដោយឯហិភិក្ខុ កាលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់លើកនូវបាតិមោក្ខឡើងសម្តែង នោះជាសន្និបាតលើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលណាព្រះសម្ពុទ្ធ ស្មើដោយព្រះអតីតពុទ្ធ រកបុគ្គលស្មើ
គ្មាន ទ្រង់គង់នៅលើភ្នំវេភារបព៌ត ( ក្នុងកាលនោះ ) ជា
សន្និបាតលើកទី ២ មានព្រះខីណាស្រពប្រមាណ ៩០ ពាន់
កោដិ ដូច្នេះ ។

កាលព្រះមានព្រះភាគ ទ្រង់មានព្រះគុណជាទីពឹងរបស់លោកទាំង ៣ ទ្រង់ធ្វើការដោះមហាជនចាកចំណង ទ្រង់ចារិកទៅតាមជនបទ ភិក្ខុ ៨ ម៉ឺនកោដិប្រជុំគ្នា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលព្រះសម្ពុទ្ធ ចៀសចេញចាកស្រុក ចាកនិគម និងដែន
ទៅកាន់ចារិកម្តងទៀត នេះជាសន្និបាតលើកទី ៣ មានព្រះ
ខីណាស្រពប្រមាណ ៨០ ពាន់កោដិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គាមនិគមរដ្ឋតោ** គឺ **គាមនិគមរដ្ឋេហិ** ។ បាឋៈក៏យ៉ាងនេះដូចគ្នា បាឋៈនោះ មានសេចក្តីថា អ្នកចេញបួសចាកគាម និគម និងរដ្ឋទាំងឡាយ ។

គ្រានោះ ព្រះពោធិសត្វនៃយើង ឈ្មោះជដិល មានទ្រព្យច្រើនកោដិ ជាអ្នកគ្រប់គ្រងរដ្ឋធំ បានថ្វាយទានយ៉ាងល្អ មួយអន្លើដោយចីវរ ដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ចប់អនុមោទនាភត្តទាន ព្រះពុទ្ធអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងអនាគតកាល បុរសនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមថា គោតម ក្នុងទីបំផុតមួយសែនកប្ប ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតជាជដិល អ្នកនៅក្នុងដែន តថាគតបាន ថ្វាយសំពត់ ព្រមទាំងភត្តដល់ព្រះសង្ឃ មានព្រះពុទ្ធជា ប្រធាន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងកណ្តាលនៃភិក្ខុ សង្ឃ ហើយទ្រង់ព្យាករតថាគតថា ក្នុងកប្បទីមួយសែនអំពី កប្បនេះ ជដិលនេះ នឹងបានជាព្រះពុទ្ធមួយអង្គ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីត្រេកអរ តម្កល់នូវព្យាយាម ។បេ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ក្នុងកាល ជាអនាគត គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតម នេះ ក៏យ៉ាងនោះដែរ ។

តថាគតបានឮព្រះបន្ទូល នៃព្រះសម្ពុទ្ធអង្គនោះហើយ បាន អធិដ្ឋានវត្តដ៏លើសលុបឡើងទៀត បានធ្វើនូវព្យាយាមដ៏ខ្ជាប់ខ្ជួន មាំមួន ដោយការបំពេញនូវបារមីទាំង ១០ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សម្ពុទ្ធប្បមុខំ សង្ឃំ** គឺ **ពុទ្ធប្បមុខស្ស សង្ឃស្ស** ដល់សង្ឃ មានព្រះពុទ្ធជាប្រធាន ។ ពាក្យនេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ ។ បទថា **សភត្តំ ទុស្សមទាសហំ** សេចក្តីថា តថាគត បានថ្វាយភត្តាហារ មួយអន្លើដោយចីវរ ។ បទថា **ឧគ្គទឡ្ហំ** បានដល់ មាំទាំ ក្រៃលែង ។ បទថា **ធិតឹ** សេចក្តីថា បានធ្វើសេចក្តីព្យាយាម ។ ក្នុងសម័យ ព្រះមានព្រះភាគបទុមុត្តរៈ មិនមានពួកតិរ្ថិយ ទេវតា និងមនុស្ស ដល់នូវ ព្រះពុទ្ធមួយអង្គជាសរណៈ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងកាលនោះ តិរ្ថិយទាំងពួង អាក់អន់តូចចិត្ត វិនាសខ្ចាត់ខ្ចាយ បរិស័ទពួកខ្លះ នៃតិរ្ថិយទាំងនោះ មិនបម្រើតិរ្ថិយទាំងនោះ ក៏នាំគ្នាចៀសចេញចាកដែនទៅ ។ តិរ្ថិយទាំងពួង មកប្រជុំគ្នាក្នុងទីនោះ ហើយបានចូលទៅក្នុងសម្នាក់នៃព្រះពុទ្ធ ( ហើយពោលថា ) បពិត្រព្រះមហាវីរៈ សូមព្រះអង្គជាទីពឹងពុំនាក់ ( នៃយើងខ្ញុំទាំងឡាយ ) បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គជាទីវព្រក ។ ព្រះពុទ្ធទ្រង់អនុគ្រោះ ទ្រង់ប្រកបដោយករុណា ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញុំាងតិរ្ថិយទាំងអស់ ដែលមកប្រជុំហើយ ឲ្យស្ថិតនៅក្នុងសីល ៥ ។ សាសនា ( របស់ព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈនោះ ) មិនរីកវរ ជាសាសនាសូន្យចាកពួកតិរ្ថិយទាំងនេះ សាសនានោះ វិចិត្រហើយដោយព្រះអរហន្តទាំងឡាយ ជាអ្នកស្ទាត់ជំនាញ ជាតាទិបុគ្គល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្យាហតា** បានដល់ មានការប្រកាន់ខ្លួន និងការរឹងត្អឹងត្រូវកម្ចាត់ហើយ ។ ក្នុងបទថា **តិត្ថិយា** នេះ គប្បីជ្រាបថា **តិត្ថ តិត្ថករ តិត្ថិយ** ។ ក្នុង ៣ បទនោះ មានវិគ្គហៈថា ឈ្មោះថា **តិត្ថ** ព្រោះជាទីឆ្លងទៅដោយអំណាចទិដ្ឋិ មានសស្សតទិដ្ឋិជាដើម បានដល់ លទ្ធិ ។ បុគ្គលធ្វើលទ្ធិនោះឲ្យកើតឡើង ឈ្មោះថា **តិត្ថករ** ( មេលទ្ធិ ) បុគ្គលមានក្នុងលទ្ធិ ឈ្មោះថា **តិត្ថិយ** ( អ្នករាប់អានលទ្ធិ ) ។ គប្បីជ្រាបព្រះតម្រាស់ថា

ពួកតិរ្ថិយត្រូវកម្ចាត់នូវការប្រកាន់ខ្លួន និងការរឹងត្អឹងចេញហើយជាដើម ក៏ដើម្បីសម្ដែងថា បានឮថា ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ មិនមានតិរ្ថិយ ទោះតិរ្ថិយពួកណានៅមាន តិរ្ថិយទាំងនោះក៏ដូច្នេះ ។ បទថា **វិមនា** បានដល់ មានចិត្តខុសប្រក្រតី ។ បទថា **ទុម្មនា** ជាវេវចនៈនៃពាក្យថា **វិមនា** នោះឯង ។ បទថា **ន តេសំ កេចិ បរិចរន្តិ** សេចក្តីថា បុរសពួកខ្លះរបស់តិរ្ថិយទាំងនោះ មិនធ្វើនូវការគក់ប្រឆាំង មិនឲ្យភិក្ខាហារ មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនព្រមក្រោកអំពីទីអង្គុយ មិនធ្វើអញ្ជលីកម្ម ។ បទថា **រដ្ឋតោ** បានដល់ ចាករដ្ឋទាំងមូល ។ បទថា **និច្ឆុភន្តិ** បានដល់ នាំចេញទៅរុករាន អធិប្បាយថា មិនឲ្យលំនៅដល់តិរ្ថិយទាំងនោះ ។ បទថា **តេ** បានដល់ តិរ្ថិយទាំងឡាយ ។

បទថា **ឧបគញ្ឆុំ ពុទ្ធសន្តិកេ** សេចក្តីថា ពួកតិរ្ថិយទាំងអស់ដែលត្រូវពួកមនុស្សអ្នកដែនបៀតបៀនយ៉ាងនេះ មកប្រជុំគ្នាហើយ ក៏ដល់ព្រះបទុមុត្តរទសពលតែមួយព្រះអង្គជាសរណៈ នាំគ្នាពោលដល់សរណៈយ៉ាងនេះថា សូមទ្រង់ជាសាស្តា ជាទីពឹង ជាគតិ ជាទីទៅខាងមុខ ជាសរណៈរបស់ពួកខ្ញុំព្រះអង្គចុះ ។ ឈ្មោះថា **អនុកម្បក** ព្រោះទ្រង់អាណិតអាសូរ ។ ឈ្មោះថា **ការុណិក** ព្រោះទ្រង់ប្រព្រឹត្តដោយសេចក្តីករុណា ។ បទថា **សម្បត្តេ** បានដល់ ពួកតិរ្ថិយដែលមកប្រជុំចូលដល់សរណៈ ។ បទថា **បញ្ចសីលេ បតិដ្ឋហិ** សេចក្តីថា ឲ្យតាំងនៅក្នុងសីល ៥ ។ បទថា **និរាកុលំ** បានដល់ មិនប្របូកប្របល់ អធិប្បាយថា មិនលាយឡំដោយលទ្ធិដទៃ ។ បទថា **សុញ្ញកំ** បាន

ដល់ សូន្យចាកកិរិយាទាំងនោះ ។ បទថា **តំ** គប្បីបន្ថែមចូលទៅក្នុងពាក្យថា សាសនារបស់ព្រះមានព្រះភាគអង្គនោះ ។ បទថា **វិចិត្តំ** បានដល់ ស្អាត វិចិត្រ ។ បទថា **វសីភូតេហិ** បានដល់ ជាអ្នកជំនាញ ។

ព្រះមានព្រះភាគបទុមុត្តរៈអង្គនោះ មាននគរឈ្មោះហង្សវតី ព្រះបិតាព្រះនាមអានន្ទ ព្រះមាតាព្រះនាមសុជាតាទេវី គូនៃអគ្គសាវកឈ្មោះទេវលៈ ១[១] សុជាត ១ ឧបដ្ឋាកឈ្មោះសុមនៈ គូនៃអគ្គសាវិកាឈ្មោះអមិតា ១ អសមា ១ ពោធិព្រឹក្សឈ្មោះដើមសលលៈ ។ ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះរស្មីរបស់ព្រះអង្គផ្សាយទៅអស់ទី ១២ យោជន៍ដោយជុំវិញ ព្រះជន្មាយុ ១ សែនឆ្នាំ អគ្គមហេសីព្រះនាមវសុទត្តា ព្រះឱរសព្រះនាមឧត្តរៈ បានឮថា ព្រះមានព្រះភាគបទុមុត្តរៈរម្លត់ខន្ធបរិនិព្វាន ក្នុងនន្ទារាមមហាវិហារ ដែលគួរជាទីត្រេកអរយ៉ាងក្រៃលែង ។ ឯព្រះបរមសារីរិកធាតុរបស់ព្រះអង្គមិនខ្ចាត់ខ្ចាយទូទៅ ពួកមនុស្សក្នុងជម្ពូទ្វីប នាំគ្នាសាងចេតិយសម្រេចដោយរតនៈ ៧ ប្រការ កម្ពស់ ១២ យោជន៍ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តា ព្រះនាមបទុមុត្តរៈ មានព្រះនគរឈ្មោះហង្សវតី មានមហាក្សត្រ ព្រះនាមអានន្ទៈជាព្រះបិតា មានព្រះមាតាព្រះនាមសុជាតា ។ ភិក្ខុឈ្មោះទេវិលៈ ១ ឈ្មោះសុជាតៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះសុមនៈជាឧបដ្ឋាករបស់ព្រះសាស្តា ព្រះនាមបទុមុត្តរៈ ។ ភិក្ខុនីឈ្មោះអមិតា ១ អសមា ១ ជាអគ្គសាវិកា

---

១- បិដកខ្មែរជា ទេវិលៈ ។

ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា សលឡព្រឹក្ស ( ដើមស្រល់ ) ។ ព្រះសម្ពុទ្ធមហាមុនី ទ្រង់មានកម្ពស់ ៥៨ ហត្ថក្រពុំ មានព្រះអង្គដ៏ល្អល្អះ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ ទ្វារក្តី គន្លឹះទ្វារក្តី ជញ្ជាំងក្តី ឈើក្តី ភ្នំធំក្តី ជាគ្រឿងរាំងរានៃព្រះសម្ពុទ្ធនោះ ក្នុងទីប្រមាណ ១២ យោជន៍ដោយជុំវិញ មិនមានឡើយ ។ ព្រះជន្មាយុមានកំណត់មួយសែនឆ្នាំ កាលព្រះសម្ពុទ្ធនោះ ទ្រង់ព្រះជន្មាយុនៅដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើនឲ្យឆ្លង ( ចាកសង្សារ ) លុះទ្រង់ចម្លងជនជាច្រើន ហើយកាត់នូវសេចក្តីសង្ស័យទាំងពួង ហើយបរិនិព្វានជាមួយនឹងសាវក ដូចជាគំនរភ្លើងដែលឆេះរុងរឿង ហើយរលត់ទៅដូច្នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆគសិលុច្ចយា** បានដល់ គំនរថ្ម ពោលគឺភ្នំ ។ បទថា **អាវរណំ** បានដល់ បិទបាំងធ្វើខាងក្រៅ ។ បទថា **ទ្វាទស-យោជនេ** សេចក្តីថា រស្មីនៃសរីរៈរបស់ព្រះមានព្រះភាគផ្សាយទៅក្នុងទី ១២ យោជន៍ដោយជុំវិញ តាំងនៅទាំងយប់ទាំងថ្ងៃ ។ ក្នុងគាថាដ៏សេស ក្នុងទីគ្រប់កន្លែង ជាក់ច្បាស់ហើយនោះឯង ។

បន្ទាប់អំពីនេះទៅ យើងនឹងសន្ទេបសេចក្តីដែលដដែលៗ មានការបំពេញបារមីជាដើម ពោលតែសេចក្តីដែលប្លែកគ្នាប៉ុណ្ណោះ បើយើងនឹងពោលដដែល កាលណានឹងចប់ពណ៌នានេះ ៕៚

**អដ្ឋកថាបទុមុត្តរពុទ្ធវង្សទី ១០ ចប់**

# សុត្តន្តបិដក

## សុមេធពុទ្ធវង្សទី ១១

[ ១២ ] ក្នុងកាលជាខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ មក មានព្រះពុទ្ធព្រះនាមសុមេធៈ ព្រះអង្គជានាយក គេគ្រប សង្កត់បានដោយក្រ ទ្រង់មានព្រះតេជៈដ៏ខ្ពង់ខ្ពស់ ជាព្រះជិនស្រី ដ៏ប្រសើរ ឧត្តមជាងលោកទាំងមូល ។ ព្រះអង្គមានព្រះនេត្រថ្លា ស្អាត មានព្រះភក្ត្រល្អល្អះ មានព្រះសរីរៈធំ មានព្រះសរីរៈត្រង់ ល្អ មានព្រះតេជៈ ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញ៉ាំងសត្វទាំងឡាយច្រើន ឲ្យរួចចាកចំណង ។ កាលណា ព្រះពុទ្ធទ្រង់បានដល់នូវពោធិញ្ញាណដ៏ឧត្តមសព្វគ្រប់ហើយ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅក្នុងនគរ ឈ្មោះសុទស្សនៈ ។ ក្នុងការសម្ដែងធម៌ទេសនានៃព្រះពុទ្ធ ព្រះនាមសុមេធៈអង្គនោះ មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី ១ មានពួកសត្វមួយសែនកោដិ ។ តមកទៀត ក្នុងការត្រាស់ដឹងទី ២ មានពួកសត្វប្រមាណ ៩០ ពាន់កោដិ ក្នុងគ្រាដែលព្រះជិនស្រី ទ្រង់ទូន្មានយក្ខ ឈ្មោះកុម្ភកណ្ណៈ ។ តមកទៀត ការត្រាស់ដឹងទី ៣ មានពួកសត្វ ៨០ ពាន់កោដិ ក្នុងគ្រាដែលព្រះសម្ពុទ្ធ មានយសរាប់មិនបាន ទ្រង់ប្រកាសនូវសច្ចៈ ៤ ប្រការ ។ ព្រះសុមេធមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង គឺក្នុងកាលដែលព្រះ

ជិនស្រី ស្តេចចូលទៅក្នុងនគរសុទស្សនៈ មានភិក្ខុជាព្រះខីណា-
ស្រព ១០០ កោដិ បានមកប្រជុំ ( នេះសន្និបាតលើកទី ១ ) ។
តមកទៀត សន្និបាតលើកទី ២ មានភិក្ខុប្រមាណ ៩០ កោដិ
( មកប្រជុំ ) ក្នុងពេលក្រាលកឋិនលើភ្នំទេវកូដ ។ តមកទៀត
សន្និបាតលើកទី ៣ មានភិក្ខុប្រមាណ ៨០ កោដិ មកប្រជុំ ក្នុង
កាលព្រះទសពលស្តេចទៅកាន់ចារិក ។ សម័យនោះ តថាគត
កើតជាមាណព ឈ្មោះឧត្តរៈ តថាគតបានសន្សំទ្រព្យទុកក្នុងផ្ទះ
ប្រមាណ ៨០ កោដិ ។ តថាគតថ្វាយទ្រព្យទាំងអស់ ឥតមាន
សេសសល់ ដល់ព្រះលោកនាយក ព្រមទាំងព្រះសង្ឃ ហើយ
បានយកព្រះលោកនាយកនោះ ជាទីពឹង បានពេញចិត្តចំពោះ
បព្វជ្ជា ។ គ្រានោះ ព្រះអង្គទ្រង់ធ្វើនូវអនុមោទនា ហើយព្យាករ
តថាគតថា ក្នុងកប្បទី ៣០ ពាន់ មាណពនេះ នឹងបានជាព្រះពុទ្ធ
( មួយអង្គ ) សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ
ហើយតម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយ
នៅទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយ
ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយ
បាយាស ទៀបច្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់
នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែងហើយ ។ លំដាប់
នោះ ព្រះមានយសធំ នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ

ហើយនឹងត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសម្ពុទ្ធអង្គនេះ នឹងមានព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនោះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គ-សាវិកា ។ ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុព្រះគោតមមានយសនោះ មានកំណត់ ១០០ ឆ្នាំ ។ ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់នូវព្រះបន្ទូលនេះ នៃព្រះមហេសីមិនមានបុគ្គលស្មើ ក៏មានចិត្តត្រេកអរថា មាណពនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស និងទេវតាទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើច ក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ចំពោះ

ព្រះភក្ត្រនៃព្រះគោតមនេះ ។ មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្វាងកំពង់នូវទីចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយ ឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណា ។ ពួកយើងទាំងអស់គ្នា បើ ឃ្វាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត គង់បានសម្រេច ក្នុង ទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ តថាគត បានស្តាប់ព្រះបន្ទូល នៃព្រះសម្ពុទ្ធអង្គនេះហើយ បានញ៉ាំងចិត្តឲ្យ ជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តដ៏លើសលុប ដោយការបំពេញ នូវបារមី ១០ ។ តថាគតបានរៀននូវព្រះសូត្រ ព្រះវិន័យ និង សត្ថុសាសនៈ ដែលមានអង្គ ៩ ទាំងអស់ ហើយញ៉ាំងសាសនា នៃព្រះជិនស្រីឲ្យល្អរុងរឿង ។ តថាគតជាអ្នកមិនប្រមាទ ក្នុង សាសនានោះ កាលតថាគតនៅក្នុងទីអង្គុយ ទីឈរ និងទីដើរ ក៏ បានដល់អភិញ្ញាបារមី ហើយទៅកើតក្នុងព្រហ្មលោក ។ ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ ជាមហេសី មានព្រះនគរឈ្មោះសុទស្សនៈ ព្រះមហាក្សត្រ ព្រះនាមសុទត្តៈជាព្រះបិតា ព្រះមាតាបង្កើត ព្រះនាមសុទត្តា ។ ព្រះសុមេធសម្ពុទ្ធនោះ ទ្រង់នៅគ្រប់គ្រងផ្ទះ អស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើ មាន ៣ ខ្នង គឺសុចន្ទ- ប្រាសាទ ១ កញ្ចនប្រាសាទ ១ សិរិវឌ្ឍប្រាសាទ ១ ។ មាននារី ប្រមាណ ១៦ ពាន់រូប សុទ្ធសឹងតែតាក់តែងល្អហើយ ឯនារី ដែលជាអគ្គមហេសីនោះ ព្រះនាមសុមនា ព្រះរាជបុត្តព្រះនាម

បុនព្វ: ។ ព្រះជិនស្រី ទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាងហើយ ស្តេចចេញទៅដោយហត្ថិយាន ទ្រង់តម្កល់ព្យាយាមអស់ ៨ ខែ គត់ ។ ព្រះលោកនាយក ព្រះនាមសុមេធ: ជាមហាវីរ: ត្រូវព្រហ្មអារាធនាហើយ ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះសុទស្សន: ភិក្ខុឈ្មោះសរណ: ១ ឈ្មោះសព្វកាម: ១ ជាអគ្គសាវករបស់ព្រះសុមេធ: ដែលទ្រង់ស្វែងរកនូវគុណដ៏ធំអង្គនោះ ភិក្ខុជាឧបដ្ឋាកឈ្មោះសាគរ: ។ ភិក្ខុនីឈ្មោះរាមា ១ ឈ្មោះសុរាមា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា និម្ពព្រឹក្ស ( ដើមស្តៅ ) ។ ឧបាសកឈ្មោះឧរុវេល: ១ ឈ្មោះយសវ: ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះយសា ១ សិរិវា ១ ជាអគ្គ-ឧបដ្ឋាយិកា ។ ព្រះមហាមុនីទ្រង់មានកម្ពស់ ៨៨ ហត្ថក្រពុំ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចព្រះចន្ទរុងរឿងកន្ទងពួកផ្កាយ ។ កែវមណីរបស់ស្តេចចក្រពត្តិ ភ្លឺរុងរឿង អស់ទីប្រមាណមួយយោជន៍យ៉ាងណា រតន: គឺពន្លឺនៃព្រះមានព្រះភាគនោះ តែងផ្សាយទៅកាន់ទីប្រមាណមួយយោជន៍ដោយជុំវិញ ក៏យ៉ាងនោះដែរ ។ ព្រះជន្មាយុមានកំណត់ ៩ ម៉ឺនឆ្នាំគត់ ព្រះសុមេធ:អង្គនោះ កាលទ្រង់ព្រះជន្មាយុនៅដរាបនោះ តែងញុំាងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារ ។ ព្រះសាសនានេះ កុះករដោយពួកព្រះអរហន្ត ដែល

មានវិជ្ជា ៣ និងអភិញ្ញា ៦ ដល់នូវកម្លាំង ជាតាទិបុគ្គល ។ ព្រះអរហន្តទាំងពួងនោះ សឹងតែមានយសរាប់មិនបាន សុទ្ធតែរួចផុតហើយ មិនមានឧបធិទាំងអស់ ព្រះអរហន្តទាំងនោះ មានយសធំបានសម្តែងនូវពន្លឺ គឺព្រះញាណ ហើយនិព្វានទៅ ។ ព្រះពុទ្ធព្រះនាមសុមេធៈ ជាព្រះជិនស្រីប្រសើរ ទ្រង់និព្វានក្នុងមេធារាម ព្រះធាតុផ្សាយទៅ ក្នុងប្រទេសទាំងឡាយនោះៗ ។

## សុមេធពុទ្ធវង្សទី ១១ ចប់

# អដ្ឋកថា

## សុមេធពុទ្ធវង្សទី ១១

កាលព្រះបទុមុត្តរសម្មាសម្ពុទ្ធ រលត់ខន្ធបរិនិព្វានហើយ សាសនារបស់ព្រះអង្គក៏អន្តរធានទៅ ព្រះពុទ្ធទាំងឡាយមិនកើតអស់កាល ៧ ម៉ឺនកប្ប ។ ក្នុងកប្បមួយ គឺក្នុងកប្បទី ៣ ម៉ឺន រាប់អំពីកប្បនេះ មានព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គកើតឡើង គឺព្រះសុមេធៈ និងព្រះសុជាតៈ ក្នុង ២ ព្រះអង្គនោះ ព្រះពោធិសត្វព្រះនាមសុមេធៈ សម្រេចសុមេធាបញ្ញាហើយ បំពេញបារមីទាំងឡាយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងផ្ទៃនៃព្រះនាងសុទត្តាទេវី អគ្គមហេសីរបស់ព្រះបាទសុទត្តៈ ក្នុងនគរសុទស្សនៈ គ្រប់កំណត់ទសមាស ក៏ប្រសូតចាកផ្ទៃរបស់ព្រះជននី ក្នុងសុទស្សនរាជឧទ្យាន ហាក់ដូចព្រះទិន្នករដ៏ស្រទន់ រំលៀកខ្លួនចេញអំពីស្រទាប់ពពកដូច្នោះ ។ ទ្រង់នៅជាយរាវាសអស់ ៩ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ឈ្មោះសុចន្ទនៈ ១ កញ្ចនៈ ១ សិរិវឌ្ឍនៈ ១[១] មានពួកនារីប្រាកដ ៤ ម៉ឺន ៨ ពាន់នាក់[២] មានព្រះនាងសុមនាមហាទេវីជាប្រធាន ។

សុមេធកុមារនោះ កាលឱរសរបស់ព្រះនាងសុមនាទេវី ព្រះនាមថាបុនព្វសុមិត្តៈ[៣] ប្រសូត ទ្រង់ឃើញនិមិត្ត ៤ ទ្រង់ចេញមហាភិនេស្រ្កមណ៍ដោយយាន គឺសេះ ហើយទ្រង់បួស ។ មនុស្ស ១០០ កោដិ ក៏បួសតាមកាលមនុស្សទាំងនោះចោមរោមហើយ ទ្រង់ធ្វើសេចក្ដីព្យាយាមអស់ ៨ ខែ

---

១- បិដកខ្មែរជា សុចន្ទៈ ១ កញ្ចនៈ ១ សិរិវឌ្ឍៈ ១ ។ ២- បិដកខ្មែរជា ១៦ ពាន់រូប ។ ៣- បិដកខ្មែរជា បុនព្វៈ ។

ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់សោយមធុបាយាស ដែលធីតានកុលសេដ្ឋី ក្នុងនកុលនិគមថ្វាយហើយ ទ្រង់សម្រាកពេលថ្ងៃក្នុងសាលវ័ន ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលតិរិវច្ឆអាជីវកថ្វាយហើយ ទ្រង់លាតសន្ថតស្មៅទំហំ ២០ ហត្ថ ត្រង់គល់ពោធិព្រឹក្ស ឈ្មោះនីបៈ ( ដើមក្ទម្ព )[១] ទ្រង់កម្ចាត់មារ ព្រមទាំងសេនា ទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏
អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយ
តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ
ដូច្នេះ ។

ទ្រង់សម្ងំនៅក្បែរៗ ពោធិព្រឹក្សអស់ ៧ សប្តាហ៍ ក្នុងសប្តាហ៍ទី ៨ ទ្រង់ទទួលអារាធនាសម្តែងធម៌របស់មហាព្រហ្ម ទ្រង់ប្រមើលមើលភព្វបុគ្គល ទ្រង់ឃើញសរណកុមារ និងសព្វកាមីកុមារ ដែលជាព្រះកនិដ្ឋភាតារបស់ព្រះអង្គ និងភិក្ខុដែលបួសជាមួយនឹងព្រះអង្គ ១០០ កោដិ ដែលជាអ្នកអាចសម្រេចអមតធម៌ គឺសច្ចៈ ៤ ទើបទ្រង់ទៅតាមអាកាស ចុះត្រង់សុទស្សនរាជឧទ្យាន ក្បែរសុទស្សននគរ ទ្រង់ឲ្យឧទ្យានបាលហៅព្រះកនិដ្ឋភាតាមកហើយ ទ្រង់ប្រកាសធម្មចក្រកណ្តាលបរិស័ទទាំងនោះ កាលនោះ ការសម្រេចធម៌កើតមានដល់សត្វ ១ សែនកោដិ នេះជាការត្រាស់ដឹងធម៌លើកទី ១

---

១- បិដកខ្មែរជា និម្ពៈ ( ដើមស្តៅ ) ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងកាលជាខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈមក មានព្រះពុទ្ធព្រះនាមសុមេធៈ ព្រះអង្គជានាយក គេគ្របសង្កត់បានដោយក្រ ទ្រង់មានព្រះតេជៈដ៏ខ្ពង់ខ្ពស់ ជាព្រះជិនស្រីដ៏ប្រសើរ ឧត្តមជាងលោកទាំងមូល ។ ព្រះអង្គមានព្រះនេត្រថ្លាស្អាត មានព្រះភក្ត្រល្អល្អះ មានព្រះសរីរៈធំ មានព្រះសរីរៈត្រង់ល្អ មានព្រះតេជៈ ទ្រង់ស្វែងរកប្រយោជន៍ ដល់សត្វទាំងពួង ទ្រង់ញ៉ាំងសត្វទាំងឡាយច្រើន ឲ្យរួចចាកចំណង ។ កាលណា ព្រះពុទ្ធទ្រង់បានដល់នូវពោធិញ្ញាណដ៏ឧត្តមសព្វគ្រប់ហើយ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅក្នុងនគរ ឈ្មោះសុទស្សនៈ ។ ក្នុងការសម្តែងធម៌ទេសនា នៃព្រះពុទ្ធព្រះនាមសុមេធៈអង្គនោះ មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី ១ មានពួកសត្វមួយសែនកោដិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧគ្គតេជោ** បានដល់ មានព្រះតេជៈខ្ពស់ ។ បទថា **បសន្ននេត្តោ** បានដល់ មានព្រះនេត្រថ្លា មានព្រះនេត្រផូរផង់ដូចកែវមណីដែលជាងខាត់ហើយតម្កល់ទុក ព្រោះហេតុនោះ ទើបជនទាំងឡាយហៅទ្រង់ថា មានព្រះនេត្រថ្លាស្អាត អធិប្បាយថា មានព្រះនេត្រផូរផង់ ប្រកបដោយរោមភ្នែកដ៏ស្រទន់ ខៀវស្រស់ មិនមានមន្ទិល និងល្អិត ទោះពោលថា មានចក្ខុ ៥ ផូរផង់ល្អ ដូច្នេះក៏គួរ ។ បទថា **សុមុខោ** បានដល់ មាន

ព្រះភក្ត្រដូចព្រះចន្ទពេញវង់ក្នុងសរទរដូវ ។ បទថា **ព្រហា** បានដល់ មានព្រះកាយធំ ព្រោះទ្រង់មានព្រះសរីរៈកម្ពស់ ៨៨ ហត្ថ អធិប្បាយថា ទំហំព្រះសរីរៈ មិនទូទៅដល់ជនដទៃ ។ បទថា **ឧជុ** បានដល់ មានព្រះកាយត្រង់ដូចកាយព្រហ្ម គឺមានព្រះសរីរៈត្រង់នោះឯង អធិប្បាយថា មានព្រះវរកាយដូចសសរមាស ដែលគេបញ្ឈរកណ្តាលទេវនគរ ដូច្នោះ ។ បទថា **បតាបវា** បានដល់ មានព្រះសរីរៈរុងរឿង ។ បទថា **ហិតេសី** បានដល់ ស្វែងរកប្រយោជន៍ ។ បទថា **អភិសមយា តីណិ** គឺ **អភិសមយា តយោ** លោកធ្វើឲ្យជាលិង្គវិបល្លាស ។

កាលព្រះមានព្រះភាគ ទ្រង់ចូលមហាករុណាសមាបត្តិក្នុងពេលទៀបភ្លឺ ទ្រង់ចេញអំពីសមាបត្តិហើយ ទ្រង់ប្រមើលមើលសត្វលោក ក៏ឃើញយក្ខស៊ីមនុស្ស ឈ្មោះកុម្ភកណ្ណៈ មានអានុភាពដូចកុម្ភកណ្ណៈ ប្រកដសរីរៈកាចឃោរឃៅ នៅត្រង់មាត់ព្រៃ ឃ្លាំចាំកាត់នូវការសញ្ចរទៅមករបស់អ្នកចូលព្រៃ ។ ព្រះសាស្តាជាបុគ្គលមួយព្រះអង្គឯង មិនមានសម្លាញ់ ចូលទៅកាន់ភពរបស់យក្ខនោះ ចូលដល់ខាងក្នុង ប្រថាប់គង់លើសេយ្យាសនៈដ៏មានសិរីលំដាប់នោះ យក្ខនោះ អត់ធន់នឹងការមើលងាយមិនបាន ក៏ក្រេវក្រោធ ដូចអាសិពិសដែលមានពិសដ៏ពន្លឹក ដែលត្រូវវាយដោយដំបង បំណងនឹងសម្រេងព្រះទសពលឲ្យខ្លាច ទើបធ្វើអត្តភាពរបស់ខ្លួនគួរស្បើម ធ្វើក្បាលដូចភ្នំ និម្មិតភ្នែកទាំង ២ ដូចព្រះអាទិត្យ ធ្វើចង្កូមស្រួចវែងធំ ដូចយាមនង្គ័ល មានពោះធំពណ៌ខៀវ មានដៃដូចដើមត្នោត មានប្រមុះវើចវិកល និងកោង មានមាត់

ធំពណ៌ក្រហម ដូចគ្នានឹងជ្រោះភ្នំភ្លើង មានសរសៃសក់ធំពណ៌លឿង រឹង ក្រញាង មានភ្នែកគួរខ្លាចក្រៃលែង មកឈរចំពោះព្រះភក្ត្ររបស់ព្រះសុមេធ-សម្ពុទ្ធ ផ្ទុំផ្សេង និងបណ្តាលជាភ្លើងឆេះសន្ធោសន្ធៅ ធ្វើនូវភ្លៀង ៩ យ៉ាង គឺភ្លៀងដុំថ្ម ភ្លៀងភ្នំ ភ្លៀងអណ្តាតភ្លើង ភ្លៀងទឹក ភ្លៀងកក់ ភ្លៀងផេះ ភ្លៀងសញ្ញាវុធ ភ្លៀងរងើកភ្លើង ភ្លៀងខ្សាច់ ឲ្យធ្លាក់ចុះមក មិនអាចឲ្យព្រះមានព្រះភាគកម្រើកញាប់ញ័រ សូម្បីប៉ុនចុងរោម គិតថា អញនឹងសួរប្រស្នា រួចសម្លាប់ ហើយសួរបញ្ហាដូចអាឡវកយក្ខ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ធ្វើយក្ខនោះឲ្យចូលកាន់វិន័យ ដោយទ្រង់ព្យាករបញ្ហា ។ បានឮថា ថ្ងៃទី ២ បន្ទាប់ពីថ្ងៃនោះ ពួកមនុស្សដែលនៅក្នុងដែន នាំយកព្រះរាជកុមារ មួយអន្លើដោយកត្តាហារដែលផ្ទុកពេញរទេះមកឲ្យយក្ខនោះ កាលនោះ យក្ខបានថ្វាយព្រះរាជកុមារដល់ព្រះពុទ្ធ ពួកមនុស្សដែលនៅត្រង់មាត់ព្រៃ ក៏ចូលគាល់ព្រះមានព្រះភាគ ។ កាលនោះ ក្នុងសមាគមនោះ ព្រះទសពលកាលទ្រង់សម្តែងធម៌ ដែលសមគួរដល់អធ្យាស្រ័យរបស់យក្ខ ទ្រង់ញុំាងធម្មចក្ខុឲ្យកើតដល់សត្វប្រមាណ ៩ ម៉ឺនកោដិ នេះជាការត្រាស់ដឹងធម៌លើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> តមកទៀត ក្នុងការត្រាស់ដឹងទី ២ មានពួកសត្វប្រមាណ ៩០ 
> ពាន់កោដិ ក្នុងគ្រាដែលព្រះជិនស្រី ទ្រង់ទូន្មានយក្ខ ឈ្មោះ 
> កុម្ភកណ្ណៈ ដូច្នេះ ។

កាលទ្រង់ប្រកាសសច្ចៈ ៤ នៅនាសិរិនន្ទរាជឧទ្យាន ត្រង់ឧបការីនគរ

ការត្រាស់ដឹងធម៌លើកទី ៣ មានដល់សត្វ ៨ ម៉ឺនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

តមកទៀត ការត្រាស់ដឹងទី ៣ មានពួកសត្វ ៨០ ពាន់កោដិ
ក្នុងគ្រាដែលព្រះសម្ពុទ្ធ មានយសរាប់មិនបាន ទ្រង់ប្រកាស
នូវសច្ចៈ ៤ ប្រការ ដូច្នេះ ។

ព្រះមានព្រះភាគសុមេធៈ ទ្រង់មានសន្និបាត ៣ លើក ក្នុងសន្និបាតលើកទី ១ ក្នុងសុទស្សននគរ មានព្រះខីណាស្រព ១០០ កោដិ ក្នុងសន្និបាតលើកទី ២ កាលពួកភិក្ខុក្រាលកឋិនត្រង់ភ្នំទេវកូដ មានព្រះអរហន្ត ៩០ កោដិ ក្នុងសន្និបាតលើកទី ៣ កាលព្រះមានព្រះភាគទ្រង់យាងចារិក មានព្រះអរហន្ត ៨០ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសុមេធមហេសី មានសាវកសន្និបាត ៣ លើក ដែល
សុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់
រម្ងាប់ មានចិត្តនឹងធឹង គឺក្នុងកាលដែលព្រះជិនស្រី ស្តេច
ចូលទៅក្នុងនគរសុទស្សនៈ មានភិក្ខុជាព្រះខីណាស្រព ១០០
កោដិ បានមកប្រជុំ ( នេះសន្និបាតលើកទី ១ ) ។ តមក
ទៀត សន្និបាតលើកទី ២ មានភិក្ខុប្រមាណ ៩០ កោដិ ( មក
ប្រជុំ ) ក្នុងពេលក្រាលកឋិនលើភ្នំទេវកូដ ។ តមកទៀត
សន្និបាតលើកទី ៣ មានភិក្ខុប្រមាណ ៨០ កោដិ មកប្រជុំ
ក្នុងកាលព្រះទសពល ស្តេចទៅកាន់ចារិក ដូច្នេះ ។

កាលនោះ ព្រះពោធិសត្វនៃយើង កើតជាមាណពដែលជាកំពូលនៃមនុស្សទាំងពួង ឈ្មោះ ឧត្តរៈ លះបង់ទ្រព្យ ៨០ កោដិ ដែលកប់ទុក ថ្វាយមហាទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ស្តាប់ធម៌របស់ព្រះទសពលក្នុងកាលនោះ ក៏តាំងនៅក្នុងសរណៈ ហើយចេញបួស ព្រះសាស្តាអង្គនោះកាលទ្រង់ធ្វើអនុមោទនាភោជនទាន ទ្រង់ក៏ព្យាករព្រះពោធិសត្វនោះថា ក្នុងអនាគតកាល នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគត កើតជាមាណព ឈ្មោះឧត្តរៈ តថាគតបានសន្សំទ្រព្យទុកក្នុងផ្ទះ ប្រមាណ ៨០ កោដិ ។ តថាគតថ្វាយទ្រព្យទាំងអស់ ឥតមានសេសសល់ ដល់ព្រះលោកនាយក ព្រមទាំងព្រះសង្ឃ ហើយបានយកព្រះលោកនាយកនោះជាទីពឹង បានពេញចិត្តចំពោះបព្វជ្ជា ។ គ្រានោះ ព្រះអង្គទ្រង់ធ្វើនូវអនុមោទនា ហើយព្យាករតថាគតថា ក្នុងកប្បទី ៣០ ពាន់ មាណពនេះ នឹងបានជាព្រះពុទ្ធ ( មួយអង្គ ) សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាម ។បេ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត គង់បានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្ឌិតគប្បីធ្វើគាថាព្យាករនេះ ឲ្យពិស្តារផងចុះ ។

តថាគត បានស្តាប់ព្រះបន្ទូល នៃព្រះសម្ពុទ្ធអង្គនេះហើយ
បានញ៉ាំងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តដ៏លើសលុប
ដោយការបំពេញនូវបារមី ១០ ។ តថាគត បានរៀននូវ
ព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនៈ ដែលមានអង្គ ៩
ទាំងអស់ ហើយញ៉ាំងសាសនានៃព្រះជិនស្រីឲ្យល្អរុងរឿង ។
តថាគតជាអ្នកមិនប្រមាទ ក្នុងសាសនានោះ កាលតថាគត
នៅក្នុងទីអង្គុយ ទីឈរ និងទីដើរ ក៏បានដល់អភិញ្ញាបារមី
ហើយទៅកើតក្នុងព្រហ្មលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្និចិតំ** បានដល់ សន្សំដោយការគប់ ។ បទថា **កេវលំ** បានដល់ ទាំងអស់ ។ បទថា **សព្វំ** បានដល់ ឲ្យមិនមានសេសសល់ ។ បទថា **សសង្ឃេ** គឺមួយអន្លើដោយសង្ឃ ។ បទថា **តស្សុ-បគញ្ឆឹ** គឺ **តំ ឧបគញ្ឆឹ** ពាក្យនេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ បទថា **អភិរោចយឹ** បានដល់ បួស ។ បទថា **តីសកប្បសហស្សម្ហិ** សេចក្តីថា ក្នុងកាល ៣ ម៉ឺនកប្បកន្លងទៅហើយ ។

ព្រះមានព្រះភាគសុមេធៈ ទ្រង់មាននគរឈ្មោះសុទស្សនៈ ព្រះជនកព្រះនាមព្រះបាទសុទត្តៈ ព្រះមាតាព្រះនាមសុទត្តា គូនៃអគ្គសាវកឈ្មោះសរណៈ ១ សព្វកាមៈ ១ ឧបដ្ឋាកឈ្មោះសាគរៈ គូអគ្គសាវិកាឈ្មោះរាមា ១ សុរាមា ១ ពោធិព្រឹក្សឈ្មោះមហានីបៈ គឺដើមក្តុម្ពធំ ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់នៅជាយរាវាសវិស័យ ៩ ពាន់ឆ្នាំ អគ្គមហេសី

ព្រះនាមសុមនា ព្រះឱរសព្រះនាមបុនព្វសុមិត្តៈ ទ្រង់ចេញអភិនេស្រ្កមណ៍ ដោយយាន គឺដំរី ពាក្យដ៏សេសប្រាកដក្នុងគាថាទាំងឡាយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ ជាមហេសី មានព្រះនគរ ឈ្មោះសុទស្សនៈ ព្រះមហាក្សត្រ ព្រះនាមសុទត្តៈជាព្រះបិតា ព្រះមាតាបង្កើតព្រះនាមសុទត្តា ។ ព្រះលោកនាយក ព្រះ នាមសុមេធៈ ជាមហាវីរៈ ត្រូវព្រហ្មអារាធនាហើយ ទ្រង់ ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះ សុទស្សនៈ ភិក្ខុឈ្មោះសរណៈ ១ ឈ្មោះសព្វកាមៈ ១ ជា អគ្គសាវករបស់ព្រះសុមេធៈ ដែលទ្រង់ស្វែងរកនូវគុណដ៏ធំ អង្គនោះ ភិក្ខុជាឧបដ្ឋាកឈ្មោះសាគរៈ ។ ភិក្ខុនីឈ្មោះរាមា ១ ឈ្មោះសុរាមា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងនៃ ព្រះមានព្រះភាគនោះ ហៅថា និម្ពព្រឹក្ស ( ដើមស្តៅ ) ។ ព្រះមហាមុនីទ្រង់មានកម្ពស់ ៨៨ ហត្ថក្រពុំ ទ្រង់ញ៉ាំងទិស ទាំងពួងឲ្យភ្លឺ ដូចព្រះចន្ទ រុងរឿង កន្លងពួកផ្កាយ ។ កែវ មណីរបស់ស្តេចចក្រពត្តិ ភ្លឺរុងរឿង អស់ទីប្រមាណមួយ យោជន៍ យ៉ាងណា រតនៈ គឺពន្លឺនៃព្រះមានព្រះភាគនោះ តែងផ្សាយទៅកាន់ទីប្រមាណ មួយយោជន៍ដោយជុំវិញ ក៏ យ៉ាងនោះដែរ ។ ព្រះជន្មាយុមានកំណត់ ៩ ម៉ឺនឆ្នាំគត់ ព្រះ

សុមេធៈអង្គនោះ កាលទ្រង់ព្រះជន្មាយុនៅដរាបនោះ តែង ញុំាំងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារ ។ ព្រះសាសនានេះ កុះករដោយពួកព្រះអរហន្ត ដែលមានវិជ្ជា ៣ និងអភិញ្ញា ៦ ដល់នូវកម្លាំង ជាតាទិបុគ្គល ។ ព្រះអរហន្តទាំងពួងនោះ សឹងតែមានយស រាប់មិនបាន សុទ្ធតែរួចផុតហើយ មិនមាន ឧបធិទាំងអស់ ព្រះអរហន្តទាំងនោះ មានយសធំ បាន សម្តែងនូវពន្លឺ គឺព្រះញាណ ហើយនិព្វានទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចន្ទោ តារគណេ យថា** សេចក្តីថា ព្រះចន្ទពេញវង់ក្នុងលម្ហ រមែងត្រចះត្រចង់ក្នុងពួកផ្កាយ យ៉ាងណា ព្រះ សុមេធសម្ពុទ្ធ ទ្រង់ក៏ធ្វើទិសឲ្យភ្លឺស្វាងយ៉ាងនោះដូចគ្នា ។ អាចារ្យពួកខ្លះ ពោលថា **ចន្ទោ បណ្ណរសោ យថា** ដូច្នេះក៏មាន ។ បាឋៈនោះ មាន អត្ថងាយយល់ដូចគ្នា ។

បទថា **ចក្កវត្តិមណី នាម** សេចក្តីថា មណីរ័តន៍របស់ស្តេចចក្រពត្តិ ប្រវែង ៤ ហត្ថ ទំហំប៉ុនដុំរទេះ មានកែវមណី ៨៤០០០ ជាបរិវារ គួរ ពិតពិលរមិលមើល និងគួរជាទីត្រេកអរក្រៃលែង ដូចទាញនូវលម្អដែលកើត អំពីសិរីព្រះចន្ទពេញវង់ ក្នុងសារទរដូវ ដែលពួកផ្កាយចោមរោមហើយ មក អំពីភ្នំវេបុល រស្មីនៃមណីរ័តន៍នោះ ដែលមកយ៉ាងនោះ តែងផ្សាយទៅអស់ ឱកាសប្រមាណមួយយោជន៍ដោយជុំវិញ យ៉ាងណា រតនៈ គឺព្រះរស្មី ក៏ ផ្សាយទៅមួយយោជន៍ដោយជុំវិញ អំពីព្រះសរីរៈរបស់ព្រះមានព្រះភាគ ក៏

*យ៉ាងនោះដូចគ្នា ។*

*បទថា* **តេវិជ្ជឆឡភិញ្ញេហិ** *សេចក្តីថា ដែលមានវិជ្ជា ៣ និងអភិញ្ញា ៦ ។ បទថា* **ពលប្បត្តេហិ** *បានដល់ អ្នកដល់នូវកម្លាំងនៃឫទ្ធិ ។ បទថា* **តាទិហិ** *បានដល់ ដល់នូវភាពជាតាទិបុគ្គល គឺបុគ្គលមិនញាប់ញ័រ ។ បទថា* **សមាកុលំ** *បានដល់ ដេរដាស គឺរុងរឿងដោយសំពត់កាសាវៈដូចគ្នាតែមួយ ។ លោកពោលថា* **ឥធំ** *សំដៅដល់សាសនា ឬផែនដី ។ បទថា* **អមិតយសា** *បានដល់ មានបរិវារប្រមាណមិនបាន ឬមានកិត្តិយសច្រើនមិនបាន ។ បទថា* **និរូបធី** *បានដល់ វៀរចាកឧបធិ ៤ ។ ពាក្យដ៏សេសក្នុងគាថាទាំងឡាយ ក្នុងទីគ្រប់អន្លើ មានអត្ថប្រាកដច្បាស់ហើយ ។*

**អដ្ឋកថាសុមេធពុទ្ធវង្សទី ១១ ចប់**

# សុត្តន្តបិដក

## សុជាតពុទ្ធវង្សទី ១២

[ ១៣ ] ក្នុងមណ្ឌកប្បនោះឯង មានព្រះសម្មាសម្ពុទ្ធ ជានាយក ព្រះនាមសុជាតៈ ទ្រង់មានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍ ទ្រង់មានព្រះស្មារង ដូចជាកនៃគោឧសភៈ ទ្រង់មានព្រះគុណប្រមាណមិនបាន គេគ្របសង្កត់មិនបាន ។ ព្រះសម្ពុទ្ធដ៏បរិសុទ្ធ ប្រាសចាកមន្ទិលដូចជាព្រះចន្ទ មានតេជៈដូចជាព្រះអាទិត្យ ភ្លឺរុងរឿង ដោយព្រះសិរីសព្វៗ កាល យ៉ាងនេះ ។ ព្រះសម្ពុទ្ធ ទ្រង់ដល់នូវពោធិញ្ញាណដ៏ប្រសើរ សព្វគ្រប់ហើយ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅក្នុងព្រះនគរ ឈ្មោះសុមង្គលៈ ។ កាលព្រះលោក-នាយក ព្រះនាមសុជាតៈ ទ្រង់សម្តែងនូវធម៌ដ៏ប្រសើរ សត្វទាំងឡាយ ចំនួន ៨០ កោដិ បានសម្រេចមគ្គផល ក្នុងព្រះធម្ម-ទេសនាជាដំបូង ។ កាលណា ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ទ្រង់មានយសរាប់មិនបាន ស្តេចចូលទៅកាន់ព្រះវស្សាក្នុងទេវលោក កាលនោះ ការត្រាស់ដឹងនូវធម៌លើកទី ២ មានពួកសត្វ ៣៧ សែន ។ កាលណា ព្រះពុទ្ធព្រះនាមសុជាតៈ រកបុគ្គលស្មើគ្មាន ស្តេចចូលទៅកាន់សម្នាក់ព្រះរាជបិតា កាលនោះ ការត្រាស់ដឹងនូវធម៌ទី ៣ មានពួកសត្វ ៦០ សែន ។ ព្រះសុជាតមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ ជាតាទិបុគ្គល ជាអ្នកដល់

នូវអភិញ្ញា និងពល ជាអ្នកមិនដល់ ( នូវការកើត ) ក្នុងភពតូច និងភពធំ គឺព្រះអរហន្តទាំងនោះ ប្រមាណ ៦០ សែន បានមកប្រជុំ ជាសន្និបាតលើកដំបូង ។ តមកទៀត ការប្រជុំក្នុងកាលដែលព្រះជិនស្រី ទ្រង់ចុះចាកទេវលោក នេះជាសន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ៥០ សែន ។ អគ្គសាវកណា របស់ព្រះពុទ្ធព្រះនាមសុជាតៈនោះ បានចូលទៅគាល់ព្រះសម្ពុទ្ធដ៏ប្រសើរជាងនរៈ អគ្គសាវកនោះ បានចូលទៅគាល់ព្រះសម្ពុទ្ធ មួយអន្លើដោយភិក្ខុ ប្រមាណ ៤ សែនរូប ( នេះជាសន្និបាតលើកទី ៣ ) ។ សម័យនោះ តថាគតជាស្តេចចក្រពត្តិ មានកម្លាំងច្រើន ជាធំក្នុងទ្វីបទាំង ៤ អាចហោះទៅក្នុងអាកាសបាន ។ តថាគតបានថ្វាយនូវរាជសម្បត្តិជាច្រើន ក្នុងទ្វីបទាំង ៤ នូវកែវដ៏ឧត្តមទាំង ៧ ប្រការចំពោះព្រះពុទ្ធ ហើយបួសក្នុងសម្នាក់នៃព្រះសម្ពុទ្ធអង្គនោះ ។ អារាមិកជនទាំងឡាយ ក្នុងជនបទ បានប្រមូលមកនូវសួយសារអាករជាបច្ច័យ ទីដេក ទីអង្គុយ ហើយនាំចូលទៅថ្វាយដល់ភិក្ខុសង្ឃ ។ កាលនោះ ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់ព្យាករតថាគតថា ក្នុងទីបំផុតនៃកប្បទី ៣០ ពាន់ ស្តេចចក្រពត្តិអង្គនេះនឹងបានត្រាស់ជាព្រះពុទ្ធ ជាធំក្នុងមួយម៉ឺនលោកធាតុ ។ សត្វនេះនឹងស្តេចចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយនៅទៀបគល់

អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយនូវបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែង ។ លំដាប់នោះ ព្រះមានយសធំធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសម្ពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនេះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ ជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុនៃព្រះគោតម ដ៏ទ្រង់យសអង្គនោះ មានកំណត់ ១០០ ឆ្នាំ ។ មនុស្ស និងទេវតាទាំងឡាយ លុះបានស្តាប់ព្រះបន្ទូលនេះ នៃព្រះពុទ្ធរកបុគ្គលស្មើគ្មាន ទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយត្រេកអរ

ថា ស្តេចចក្រពត្តិអង្គនេះ ជាពូជពន្ធកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើច ក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងឃ្លាង មគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជា អនាគត ពួកយើងទាំងអស់គ្នា គង់បានសម្រេចក្នុងទីចំពោះព្រះ ភក្ត្រ នៃព្រះគោតមនេះពុំខាន ។ ពួកមនុស្ស កាលឆ្លងស្ទឹង បើ ឃ្លាងកំពង់ក្នុងទីចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយ ឆ្លងស្ទឹងធំបានដែរ យ៉ាងណា ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះ ជិនស្រីអង្គនេះ ក្នុងកាលជាអនាគត គង់នឹងបានសម្រេចក្នុងទី ចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ តថាគត បានស្តាប់នូវព្រះបន្ទូល នៃព្រះពុទ្ធនោះហើយ បានញុំាងសេចក្តី រីករាយ ឲ្យកើតដោយក្រៃលែង ហើយបានអធិដ្ឋាននូវវត្តដ៏ លើសលុប ដោយការបំពេញនូវបារមីទាំង ១០ ។ តថាគតបាន រៀននូវព្រះសូត្រផង ព្រះវិន័យផង សត្ថុសាសនាដែលមានអង្គ ៩ ទាំងអស់ផង ហើយបានញុំាងសាសនា នៃព្រះជិនស្រីឲ្យល្អ រុងរឿង ។ កាលតថាគតនៅក្នុងសាសានានោះ ជាអ្នកមិនប្រមាទ បានចម្រើននូវភាវនាដ៏ប្រសើរ ហើយបានដល់នូវបារមី ក្នុងអភិញ្ញា ទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោក ។ ព្រះសម្ពុទ្ធព្រះនាម សុជាតៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះនគរឈ្មោះសុមង្គលៈ

ព្រះមហាក្សត្រ ព្រះនាមឧគ្គតៈជាព្រះបិតា ព្រះមាតាព្រះនាម បភាវតី ។ ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់នៅគ្រប់គ្រងផ្ទះ អស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ ( របស់ព្រះពុទ្ធនោះ ) មាន ៣ ខ្នង គឺសិរិប្រាសាទ ១ ឧបសិរិប្រាសាទ ១ ចន្ទប្រាសាទ ១ ។ មាន នារីប្រមាណ ២ ម៉ឺន ៣ ពាន់នាក់ សុទ្ធសឹងតែតាក់តែងល្អ ហើយ ឯនារីដែលជាអគ្គមហេសី ព្រះនាមសិរិនន្ទា ព្រះរាជបុត្ត ព្រះនាមឧបសេនៈ ។ ព្រះជិនស្រីទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាង ហើយ ស្ដេចចេញទៅដោយយានសេះ តម្កល់នូវព្យាយាមអស់ ៩ ខែគត់ ។ ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ជាលោកនាយក ជា មហាវីរៈ ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្កឲ្យ ប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះសុមង្គលៈ ។ ភិក្ខុឈ្មោះ សុទស្សនៈ ១ ឈ្មោះសុទេវៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះនារទៈ ជាឧបដ្ឋាក នៃព្រះពុទ្ធព្រះនាមសុជាតៈ ទ្រង់ស្វែងរកគុណធំ ។ ភិក្ខុនីឈ្មោះនាគា ១ ឈ្មោះនាគសមានា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា មហា-វេឡុព្រឹក្ស ( ដើមឫស្សីធំ ) ។ ឫស្សីនោះ មានដើមតាន់ មិន មានប្រហោង មានស្លឹកច្រើន ជាឫស្សីមានដើមត្រង់ មានដើមធំ គួររមិលមើល ជាទីរីករាយនៃចិត្ត ។ ជាឫស្សីតែមួយដើម លូត លាស់ឡើងហើយ ឯមែកក៏បែកចេញអំពីដើមនោះជា ៥ មែក

ឫស្សីនោះជាឈើល្អ ដូចជាបាច់នៃកន្ទុយក្ងោក ដែលគេចងល្អហើយ ដូច្នោះ ។ ឫស្សីនោះ ជាឫស្សីឥតបន្លា ឥតប្រហោង មានមែកត្រសុំត្រសាយ ដេរដាសដោយមែក មានម្លប់ត្រឈៃ ជាទីរីករាយនៃចិត្ត ។ ឧបាសកឈ្មោះសុទត្តៈ ១ ឈ្មោះចិត្តៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនាងសុភទ្រា ១ នាងបទុមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះជិនស្រីអង្គនោះ មានកម្ពស់ ៥០ ហត្ថក្រពុំ ទ្រង់ប្រកបដោយអាការប្រសើរគ្រប់យ៉ាង ទ្រង់ប្រកបដោយគុណទាំងពួង ។ រស្មីនៃព្រះសម្ពុទ្ធអង្គនោះ ស្មើដោយរស្មីនៃព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ តែងផ្សាយចេញទៅក្នុងទីជុំវិញ ព្រះសម្ពុទ្ធនោះ មានព្រះគុណប្រមាណមិនបាន មានព្រះគុណថ្លឹងមិនបាន មិនមានឧបមា ដោយសេចក្តីឧបមាទាំងឡាយឡើយ ។ ព្រះជន្មាយុមានកំណត់ ៩០ ពាន់ឆ្នាំគត់ ព្រះពុទ្ធអង្គនោះ កាលគង់ព្រះជន្មាយុនៅដរាបនោះ តែងញុំាងប្រជុំជនជាច្រើន ឲ្យឆ្លង ( ចាកសង្សារ ) ។ ក្នុងកាលនោះ សាសនារបស់ព្រះពុទ្ធនោះ ដ៏វិចិត្រដោយព្រះអរហន្តទាំងឡាយ ដូចជារលកក្នុងសាគរ ឬដូចជាផ្កាយក្នុងអាកាស ។ សាសនានេះ កុះករដោយព្រះអរហន្តទាំងឡាយ ដែលមានវិជ្ជា ៣ និងអភិញ្ញា ៦ លោក

ដល់នូវកម្លាំង ជាតាទិបុគ្គល ។ ព្រះសម្ពុទ្ធនោះ ស្មើដោយព្រះពុទ្ធ រកបុគ្គលស្មើគ្មាន គុណទាំងឡាយនោះ ជាគុណថ្លឹងពុំបាន ធម្មជាតទាំងពួង ក៏អន្តរធានអស់ ឱហ្ន៎! សង្ខារទាំងពួង ជារបស់សោះសូន្យទទេ ។ ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ជាព្រះជិនស្រីប្រសើរ បរិនិព្វានក្នុងសេលារាម ព្រះចេតិយរបស់ព្រះសាស្តាមានកម្ពស់ ៣ គាវុត ( ដែលគេសាង ) ក្នុងសេលារាមនោះ ។

## សុជាតពុទ្ធវង្សទី ១២ ចប់

# អដ្ឋកថា

## សុជាតពុទ្ធវង្សទី ១២

ខាងក្រោយសម័យរបស់សុមេធសម្ពុទ្ធ ក្នុងមណ្ឌកប្បនោះឯង កាលសត្វទាំងឡាយមានអាយុរាប់មិនបានដោយលំដាប់ និងថយចុះមកតាមលំដាប់រហូតមានអាយុ ៩ ម៉ឺនឆ្នាំ ព្រះសាស្តាព្រះនាមសុជាតៈ ទ្រង់មានព្រះរូបកាយកើតល្អ មានព្រះជាតិបរិសុទ្ធ កើតឡើងក្នុងលោក ។ ព្រះពោធិសត្វអង្គនេះទ្រង់ក៏បានបំពេញបារមី ហើយកើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងបភាវតី អគ្គមហេសីក្នុងរាជត្រកូលនៃព្រះបាទឧគ្គតៈ ក្រុងសុមង្គលៈ គ្រប់កំណត់ទសមាស ក៏ប្រសូតចាកព្រះឧទររបស់ព្រះជននី ក្នុងថ្ងៃថ្វាយព្រះនាម ព្រះជនក ព្រះជននី កាលថ្វាយព្រះនាម ក៏ថ្វាយរបស់ព្រះអង្គ ក៏បានថ្វាយព្រះនាមថា សុជាតៈ ព្រោះកើតមកហើយ ញុំាងសុខឲ្យកើតដល់សត្វទាំងឡាយពេញជម្ពូទ្វីប ។ ទ្រង់នៅជាឃរាវាសវិស័យ អស់ ៩ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ឈ្មោះសិរី ១ ឧបសិរី ១ សិរិនន្ទ ១ មាននារី ២ ម៉ឺន ៣ ពាន់ជាស្នំ មានព្រះនាងសិរិនន្ទាទេវីជាប្រធាន ។

កាលព្រះរាជឱរសព្រះនាមឧបសេនៈ របស់ព្រះនាងសិរិនន្ទាទេវីប្រសូតហើយ ទ្រង់ក៏ឃើញនិមិត្ត ៤ ទ្រង់ឡើងផែលសេះឈ្មោះហង្សវហៈ ចេញមហាភិនេស្រ្កមណ៍ ទ្រង់ព្រះផ្នួសជាមួយមនុស្ស ១ កោដិកន្លះ ។ លំដាប់នោះ មហាបុរសនោះ កាលមនុស្សចោមរោមហើយ ទ្រង់បំពេញព្យាយាមអស់ ៩ ខែ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់សោយមធុបាយាស មានរសឆ្ងាញ់

ដែលសេដ្ឋីធីតារបស់សិរិនន្ទនសេដ្ឋី ក្នុងសិរិនន្ទនគរប្រគេន ហើយទ្រង់សម្រាកពេលថ្ងៃ ក្នុងព្រៃសាលវ័ន លុះដល់វេលាល្ងាច ទ្រង់បានទទួលស្មៅ ៨ ក្តាប់ អំពីសុនន្ទអាជីវក ទ្រង់ចូលកាន់មណ្ឌលពោធិព្រឹក្សឈ្មោះវេឡុ គឺដើមឫស្សី ទ្រង់ក្រាលសន្ថ័តស្មៅទំហំ ៣៣ ហត្ថ កាលព្រះអាទិត្យមិនទាន់លិច ទ្រង់កម្ចាត់មារ ព្រមទាំងសេនា ទ្រង់ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ទ្រង់បន្លឺឧទាន ដែលព្រះពុទ្ធគ្រប់អង្គ ទ្រង់ប្រព្រឹត្តមកហើយ ទ្រង់សម្ងំនៅក្បែរពោធិព្រឹក្សនោះឯង អស់ ៧ សប្តាហ៍ កាលមហាព្រហ្មអារាធនាហើយ ទ្រង់ឃើញសុទស្សនកុមារដែលជាព្រះកនិដ្ឋភាតារបស់ព្រះអង្គ និងទេវកុមារបុត្តបុរោហិត ជាអ្នកអាចចាក់ធ្លុះនូវធម៌ គឺសច្ចៈ ៤ ទ្រង់យាងទៅតាមអាកាស ចុះត្រង់សុមង្គលរាជឧទ្យាន ជិតនគរសុមង្គលៈ ទ្រង់ឲ្យឧទ្យាន-បាលហៅសុទស្សនកុមារ ដែលជាប្អូនប្រុស និងទេវកុមារដែលជាបុរោហិត-បុត្តមកហើយ ទ្រង់ប្រថាប់គង់កណ្តាលកុមារទាំង ២ នោះ មួយអន្លើដោយបរិវារ ទ្រង់ប្រកាសធម្មចក្រក្នុងទីនោះ ការត្រាស់ដឹងធម៌ មានដល់សត្វមួយកោដិ(១) នេះជាការសម្រេចធម៌លើកទី ១ ។

កាលព្រះសាស្តាទ្រង់ធ្វើយមកបាដិហារ្យ ត្រង់គល់មហាសាលព្រឹក្ស ក្បែរទ្វារសុទស្សនរាជឧទ្យាន ហើយទ្រង់ចាំវស្សាក្នុងស្ថានតាវត្តិង្សទេវលោក ការសម្រេចធម៌មានដល់សត្វ ៣ លាន ៧ សែន នេះជាការសម្រេចធម៌លើកទី ២ ។ កាលព្រះសុជាតទសពល ចូលគាល់ព្រះជនក ការសម្រេច

១- បិដកខ្មែរជា ៨០ កោដិ ។

ធម៌មានដល់សត្វ ៦ លាន នេះជាការត្រាស់ធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងមណ្ឌកប្បនោះឯង មានព្រះសម្មាសម្ពុទ្ធ ជានាយក ព្រះនាមសុជាតៈ ទ្រង់មានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍ ទ្រង់មានព្រះសូរង ដូចជាកនៃគោឧសភៈ ទ្រង់មានព្រះគុណប្រមាណមិនបាន គេគ្របសង្កត់មិនបាន ។ ព្រះសម្ពុទ្ធដ៏បរិសុទ្ធប្រាសចាកមន្ទិលដូចជាព្រះចន្ទ មានតេជះ ដូចជាព្រះអាទិត្យភ្លឺរុងរឿងដោយព្រះសិរីសព្វៗ កាលយ៉ាងនេះ ។ ព្រះសម្ពុទ្ធទ្រង់ដល់នូវពោធិញ្ញាណ ដ៏ប្រសើរសព្វគ្រប់ហើយ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងព្រះនគរឈ្មោះសុមង្គលៈ ។ កាលព្រះលោកនាយក ព្រះនាមសុជាតៈ ទ្រង់សម្តែងនូវធម៌ដ៏ប្រសើរ សត្វទាំងឡាយ ចំនួន ៨០ កោដិ បានសម្រេចមគ្គផល ក្នុងព្រះធម្មទេសនាជាដំបូង ។ កាលណា ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ទ្រង់មានយសរាប់មិនបាន ស្តេចចូលទៅកាន់ព្រះវស្សា ក្នុងទេវលោក កាលនោះ ការត្រាស់ដឹងនូវធម៌លើកទី ២ មានពួកសត្វ ៣៧ សែន ។ កាលណា ព្រះពុទ្ធព្រះនាមសុជាតៈ រកបុគ្គលស្មើគ្មាន ស្តេចចូលទៅកាន់សម្នាក់ព្រះរាជបិតា កាលនោះ ការត្រាស់ដឹងនូវធម៌ទី ៣ មានដល់ពួកសត្វ ៦០ សែន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តត្ថេវ មណ្ឌកប្បម្ហិ** សេចក្តីថា ក្នុងមណ្ឌកប្បណា ព្រះមានព្រះភាគសុមេធៈទ្រង់កើតហើយ ក្នុងកប្បនោះឯង ព្រះមានព្រះភាគសុជាតៈក៏កើតដែរ ។ បទថា **សីហហនុ** បានដល់ ឈ្មោះថា **សីហហនុ** ព្រោះចង្ការបស់ព្រះអង្គ ដូចចង្កាពជសីហ៍ រាជសីហ៍ចង្កាខាងក្រោមប៉ុណ្ណោះពេញ ចង្កាខាងលើមិនពេញឡើយ ឯព្រះមហាបុរសពេញទាំង ២ ព្រះហនុដូចចង្កាខាងក្រោមរបស់រាជសីហ៍ គឺដូចព្រះចន្ទ ១២ កើត ដោយហេតុនោះ ទើបត្រាស់ថា **សីហហនុ**។ បទថា **ឧសភក្ខន្ធោ** បានដល់ មានព្រះសូរង់ស្មើ ពេញមូល ដូចគោឧសភ អធិប្បាយថា មានព្រះសូរង់ដូចដុំមាស ដែលមានសភាពពេញលេញ ។ បទថា **សតរំសីវ** បានដល់ ដូចព្រះអាទិត្យ ។ បទថា **សិរិយា** បានដល់ ដោយព្រះពុទ្ធសិរី ។ បទថា **ពោធិមុត្តមំ** បានដល់ ព្រះសម្ពោធិញ្ញាណដ៏ឧត្តម ។

ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ប្រោសមនុស្សដែលមកក្នុងសុធម្មរាជឧទ្យាន ក្រុងសុធម្មវតី ទ្រង់ញ៉ាំងជន ៦ លាន ឲ្យបួសដោយឯហិភិក្ខុភាវៈ ទ្រង់លើកបាតិមោក្ខឡើងសម្តែងកណ្តាលភិក្ខុទាំងនោះ នុ៎ះជាសន្និបាតលើកទី ១ បន្ទាប់អំពីនោះ កាលព្រះមានព្រះភាគទ្រង់ចុះអំពីទេវលោក ភិក្ខុ ៥ លានប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ។ ព្រះសុទស្សនត្ថេរនាំបុរស ៤ សែន ដែលបានដំណឹងថា សុទស្សនកុមារទ្រង់បួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ សម្រេចអរហត្ត ទើបមកគាល់ដោយគិតថា ពួកយើងនឹងបួស ទើបមកគាល់ព្រះសុជាតនរាសភ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ប្រោស

បុរសទាំងនោះ ទ្រង់ឲ្យបួសដោយឯហិភិក្ខុ ទ្រង់លើកបាតិមោក្ខឡើង សម្តែងក្នុងសន្និបាតដែលប្រកបដោយអង្គ ៤ នេះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសុជាតមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ ជាតាទិបុគ្គល ជាអ្នកដល់នូវអភិញ្ញា និងពល ជាអ្នកមិនដល់ ( នូវការកើត ) ក្នុងភពតូច និងភពធំ គឺព្រះអរហន្តទាំងនោះ ប្រមាណ ៦០ សែន បានមកប្រជុំ ជាសន្និបាតលើកដំបូង ។ តមកទៀត ការប្រជុំក្នុងកាលដែលព្រះជិនស្រី ទ្រង់ចុះចាកទេវលោក នេះជាសន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ៥០ សែន ។ អគ្គសាវកណារបស់ព្រះពុទ្ធ ព្រះនាមសុជាតៈនោះ បានចូលទៅគាល់ព្រះសម្ពុទ្ធដ៏ប្រសើរជាងនរៈ អគ្គសាវកនោះ បានចូលទៅគាល់ព្រះសម្ពុទ្ធមួយអន្លើដោយភិក្ខុប្រមាណ ៤ សែនរូប ( នេះជាសន្និបាតលើកទី ៣ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អប្បត្តានំ** សេចក្តីថា ដែលមិនដល់ព្រមក្នុងភពតូចភពធំ ។ បាឋៈថា **អប្បវត្តា ភវាភវេ** ដូច្នេះក៏មាន ។ ឯសេចក្តីក៏យ៉ាងនោះដូចគ្នា ។ បទថា **តិទិវោរោហណេ** បានដល់ កាលព្រះជិនសម្ពុទ្ធយាងចុះអំពីទេវលោក ។ គប្បីឃើញថា ចុះក្នុងអត្ថកត្តុការកៈ លោក

ពោលជាការកវិបល្លាស ។ម្យ៉ាងទៀត បទថា **តិទិវាភោហរណោ** បានដល់ក្នុងការយាងចុះអំពីទេវលោក ។ បទថា **ឯវេ** កែជា **ឯវស្ស** គប្បីឃើញជាសត្តមីវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វនៃយើង កើតជាស្ដេចចក្រពត្តិ បានស្ដាប់ដំណឹងថា ព្រះពុទ្ធកើតឡើងក្នុងលោក ក៏ចូលគាល់ព្រះមានព្រះភាគ ស្ដាប់ធម្មកថា ក៏ថ្វាយរាជសម្បត្តិក្នុងទ្វីបទាំង ៤ មួយអន្លើដោយរតនៈ ៧ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់ព្រះផ្នួសក្នុងសម្នាក់របស់ព្រះសាស្ដា ជនដែលរស់នៅក្នុងទ្វីបទាំងមូល ប្រមូលតម្លៃដែលកើតក្នុងរដ្ឋ ធ្វើកិច្ចជាអារាមិកឲ្យសម្រេច ថ្វាយមហាទានជាប្រចាំដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្ដាអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ដឹងជាព្រះពុទ្ធព្រះនាមគោតម ក្នុងអនាគតកាល ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> សម័យនោះ តថាគតជាស្ដេចចក្រពត្តិ មានកម្លាំងច្រើន ជាធំក្នុងទ្វីបទាំង ៤ អាចហោះទៅក្នុងអាកាសបាន ។ តថាគតបានថ្វាយនូវរាជសម្បត្តិជាច្រើន ក្នុងទ្វីបទាំង ៤ នូវកែវដ៏ឧត្ដមទាំង ៧ ប្រការ ចំពោះព្រះពុទ្ធ ហើយបួសក្នុងសម្នាក់នៃព្រះសម្ពុទ្ធអង្គនោះ ។ អារាមិកជនទាំងឡាយ ក្នុងជនបទបានប្រមូលមកនូវសួយសារអាករជាបច្ច័យ ទីដេក ទីអង្គុយ ហើយនាំចូលទៅថ្វាយដល់ភិក្ខុសង្ឃ ។ កាលនោះ ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់ព្យាករតថាគតថា ក្នុងទីបំផុតនៃកប្បទី ៣០

ពាន់ ស្តេចចក្រពត្តិអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ជាធំក្នុងមួយម៉ឺនលោកធាតុ ។ សត្វនេះ នឹងស្តេចចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាម ។បេ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក្នុងកាលជាអនាគត គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់នូវព្រះបន្ទូលនៃព្រះពុទ្ធនោះហើយ បានញ៉ាំងសេចក្តីរីករាយ ឲ្យកើតដោយក្រៃលែង ហើយបានអធិដ្ឋាននូវវត្តដ៏លើសលុបដោយការបំពេញនូវបារមីទាំង ១០ ។ តថាគតបានរៀននូវព្រះសូត្រផង ព្រះវិន័យផង សត្ថុសាសនាដែលមានអង្គ ៩ ទាំងអស់ផង ហើយបានញ៉ាំងសាសនានៃព្រះជិនស្រី ឲ្យល្អរុងរឿង ។ កាលតថាគតនៅក្នុងសាសានានោះ ជាអ្នកមិនប្រមាទ បានចម្រើននូវភាវនាដ៏ប្រសើរ ហើយបានដល់នូវបារមី ក្នុងអភិញ្ញាទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុទីបម្ហិ** សេចក្តីថា នៃមហាទ្វីបទាំង ៤ ដែលមានទ្វីបតូចជាបរិវារ ។ បទថា **អន្តលិក្ខចរោ** សេចក្តីថា ធ្វើចក្ករ័តន៍ខាងមុខ ត្រាច់ទៅក្នុងអាកាស ។ បទថា **រតនេ សត្ត** បានដល់ រតនៈ ៧ មានហត្ថិរ័តន៍ជាដើម ។ បទថា **ឧត្តមេ** កែបទជា **ឧត្តមានិ**។ ន័យម្យ៉ាង

ទៀត គប្បីឃើញថា **ឧត្តមេ ពុទ្ធេ** ក្នុងព្រះពុទ្ធដ៏ឧត្តម ។ បទថា **និយ្យាត-យិត្វាន** បានដល់ ថ្វាយ ។ បទថា **ឧដ្ឋានំ** បានដល់ ផលកម្រៃដែលកើតក្នុងរដ្ឋ អធិប្បាយថា ចំណូល ។ បទថា **បដិបិណ្ឌិយ** បានដល់ ប្រមូលមកគរជាគំនរ ។ បទថា **បច្ចយំ** បានដល់ បច្ច័យផ្សេងៗ មានចីវរជាដើម ។ បទថា **ទសសហស្សម្ហិ ឥស្សរោ** បានដល់ ជាធំក្នុងម៉ឺនលោកធាតុ ពាក្យនេះគប្បីជ្រាបថា ត្រាស់សំដៅដល់ខេត្តនៃជាតិ ព្រះមានព្រះភាគទ្រង់ជាធំនៃលោកធាតុ ដែលមិនមានទីបំផុត ។ បទថា **តឹសកប្បសហស្សម្ហិ** សេចក្ដីថា ក្នុងទីបំផុត ៣ ម៉ឺនកប្ប រាប់អំពីកប្បនេះ ។

ព្រះមានព្រះភាគសុជាតៈ ទ្រង់មានព្រះនគរឈ្មោះសុមង្គលៈ ព្រះជនកព្រះនាមព្រះបាទឧគ្គតៈ ព្រះជននីព្រះនាមព្រះនាងបភាវតី គូនៃអគ្គសាវកឈ្មោះសុទស្សនៈ ១ សុទេវៈ ១ ពុទ្ធុបដ្ឋាកឈ្មោះនារទៈ អគ្គសាវិកាឈ្មោះនាគា ១ នាគសមាលា[1] ពោធិព្រឹក្សឈ្មោះមហាវេឡុ គឺដើមឫស្សីបានឮថា ដើមឫស្សីនោះ មានប្រហោងខាងក្នុងតូច មានដើមធំ មានមែកច្រើន គ្របដណ្ដប់ដោយស្លឹកទាំងឡាយ ដែលប្រាសចាកមន្ទិល មានពណ៌ដូចកែវពិទូរ្យ គួរជាទីត្រេកអរក្រៃលែង ដូចគ្នានឹងរោមកន្ទុយក្ងោក ។ ព្រះមានព្រះភាគអង្គនោះ មានព្រះសរីរៈកម្ពស់ ៥០ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ អគ្គមហេសីព្រះនាមព្រះនាងសិរិនន្ទា ព្រះរាជឱរសព្រះនាមឧបសេនៈ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយយាន គឺសេះ ទ្រង់រម្ងត់ខន្ធបរិនិព្វានក្នុងព្រះ

---

១- បិដកខ្មែរជា នាគសមានា ។

វិហារសិលារាម ក្រុងចន្ទវតី ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ព្រះសម្ពុទ្ធ ព្រះនាមសុជាតៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះនគរឈ្មោះសុមង្គលៈ ព្រះមហាក្សត្រ ព្រះនាមឧគ្គតៈជាព្រះបិតា ព្រះមាតាព្រះនាមបភាវតី ។ ភិក្ខុឈ្មោះសុទស្សនៈ ១ ឈ្មោះសុទេវៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះនារទៈជាឧបដ្ឋាកនៃព្រះពុទ្ធព្រះនាមសុជាតៈ ទ្រង់ស្វែងរកគុណធំ ។ ភិក្ខុនីឈ្មោះនាគា ១ ឈ្មោះនាគសមានា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា មហាវេឡុព្រឹក្ស ( ដើមឫស្សីធំ ) ។ ឫស្សីនោះ មានដើមតាន់ មិនមានប្រហោង មានស្លឹកច្រើន ជាឫស្សីមានដើមត្រង់ មានដើមធំ គួររមិលមើល ជាទីរីករាយនៃចិត្ត ។ ជាឫស្សីតែមួយដើម លូតលាស់ឡើងហើយឯមែកក៏បែកចេញអំពីដើមនោះជា ៥ មែក ឫស្សីនោះជាឈើល្អដូចជាបាច់នៃកន្ទុយក្ងោក ដែលគេចងល្អហើយ ។ ឫស្សីនោះជាឫស្សីឥតបន្លា ឥតប្រហោង មានមែកត្រសុំត្រសាយ ដេរដាសដោយមែក មានម្លប់ត្រឈៃ ជាទីរីករាយនៃចិត្ត ។ ព្រះជិនស្រីអង្គនោះ មានកម្ពស់ ៥០ ហត្ថក្រពុំ ទ្រង់ប្រកបដោយអាការប្រសើរគ្រប់យ៉ាង ទ្រង់ប្រកបដោយគុណទាំងពួង ។ រស្មីនៃព្រះសម្ពុទ្ធអង្គនោះ ស្មើដោយរស្មីនៃព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ តែងផ្សាយចេញទៅក្នុងទីជុំវិញ ព្រះសម្ពុទ្ធនោះ មានព្រះគុណ

ប្រមាណមិនបាន មានព្រះគុណថ្លឹងមិនបាន មិនមានឧបមា ដោយសេចក្ដីឧបមាទាំងឡាយឡើយ ។ ព្រះជន្មាយុមានកំណត់ ៩០ ពាន់ឆ្នាំគត់ ព្រះពុទ្ធអង្គនោះ កាលគង់ព្រះជន្មាយុនៅដរាប នោះ តែងញ៉ាំងប្រជុំជនជាច្រើន ឲ្យឆ្លង ( ចាកសង្សារ ) ។ ក្នុង កាលនោះ សាសនារបស់ព្រះពុទ្ធនោះ ដ៏វិចិត្រដោយព្រះអរហន្ត ទាំងឡាយ ដូចជារលកក្នុងសាគរ ឬដូចជាផ្កាយក្នុងអាកាស ។ ព្រះសម្ពុទ្ធនោះ ស្មើដោយព្រះពុទ្ធ រកបុគ្គលស្មើគ្មាន គុណទាំង ឡាយនោះ ជាគុណថ្លឹងពុំបាន ធម្មជាតទាំងពួង ក៏អន្តរធានអស់ ឱហ្ន៎ ! សង្ខារទាំងពួង ជារបស់សោះសូន្យទទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អច្ចិច្ឆោ** បានដល់ មានប្រហោងតូច គប្បី ឃើញដូចក្នុងប្រយោគជាដើមថា **អច្ឆិនា កញ្ញា** សេចក្ដីថា ស្រីក្រមុំដែល មានពោះតូច អាចារ្យពួកខ្លះពោលថា **ឆិទ្ទំ ហោតិ បរិត្តកំ** ដូច្នេះក៏មាន ។ បទថា **បត្តិកោ** បានដល់ មានស្លឹកក្រាស់ អធិប្បាយថា គ្របដណ្ដប់ដោយ ស្លឹកទាំងឡាយ មានពណ៌ដូចកែវផលិក ។ បទថា **ឧជុ** បានដល់ មិនកោង មិនវៀច ។ បទថា **វំសោ** បានដល់ ឫស្សី ។ បទថា **ព្រហា** បានដល់ ធំដោយជុំវិញ ។ បទថា **ឯកក្ខន្ធោ** សេចក្ដីថា ដុះឡើងមួយដើមគត់ មិន មានសម្ងាញ់ ។ បទថា **បវឌ្ឍិតោ** បានដល់ ធំហើយ ។ បទថា **តតោ សាខា បភិជ្ជតិ** បានដល់ មានមែក ៥ បែកចេញអំពីចុងឫស្សីនោះ ។ បាឋៈថា **តតោ សាខា បភិជ្ជថ** ដូច្នេះក៏មាន ។ បទថា **សុពទ្ធោ** បានដល់

ដែលគេចងដោយអាការចងជា ៥ សរសៃយ៉ាងល្អ សំណុំកន្ទុយក្ងោក ដែលគេចងដើម្បីបាំងកម្ដៅថ្ងៃ ហៅថា **មោរហត្ថ** ។

បទថា **ន តស្ស កណ្ឌកា ហោន្តិ** សេចក្ដីថា ដើមឫស្សីនោះ ជាដើមឈើមិនមានបន្លាតាមធម្មតា ។ បទថា **អវិរឡា** បានដល់ គ្របដណ្ដប់ទៅដោយមែក មិនមានចន្លោះ ។ បទថា **សន្ទច្ឆាយោ** បានដល់ មានម្លប់ត្រជាក់ លោកពោលថា មានម្លប់ក្រាស់ ក៏ព្រោះមិនមានចន្លោះ ។ បទថា **បញ្ញាសរតនោ អាសិ** បានដល់ កម្ពស់ ៥០ ហត្ថ ។ បទថា **សព្វាការ វរូបេតោ** បានដល់ ប្រកបហើយដោយភាពប្រសើរទាំងឡាយ ដោយអាការទាំងពួង ឈ្មោះថា ប្រកបព្រមដោយភាពប្រសើរ ដោយអាការសព្វយ៉ាង ។ បទថា **សព្វគុណាមុបាគតោ** ត្រឹមតែជាវេវចនៈនៃបទខាងដើម ។ បទថា **អប្បមាណោ** បានដល់ វៀរចាកប្រមាណ ឬមិនមានប្រមាណ ព្រោះមិនអាចរាប់បាន ។ បទថា **អតុលិយោ** បានដល់ ថ្លឹងមិនបាន អធិប្បាយថា មិនមានបុគ្គលណាដូច ។ បទថា **ឱបម្មេហិ** បានដល់ ដែលគប្បីប្រៀបធៀប ។ បទថា **អនូបមោ** បានដល់ វៀរចាកការប្រៀប អធិប្បាយថា ឧបមាមិនបាន ព្រោះមិនអាចពោលឧបមាថា ដូចបុគ្គលនេះ បុគ្គលនេះ ។ បទថា **គុណានិ ច តានិ** ក៏គឺ **គុណា ច តេ** សេចក្ដីថា ព្រះគុណទាំងឡាយ មានសព្វញ្ញុតញ្ញាណជាដើម លោកពោលជាលិង្គវិបល្លាស ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។ល។

**អដ្ឋកថាសុជាតពុទ្ធវង្សទី ១២ ចប់**

# សុត្តន្តបិដក

## បិយទស្សិពុទ្ធវង្សទី ១៣

[ ១៤ ] ក្នុងកាលជាខាងក្រោយនៃព្រះសម្ពុទ្ធ ព្រះនាមសុជាតៈមក មានព្រះពុទ្ធទ្រង់ព្រះនាមបិយទស្សី ជាសយម្ភូ ជាលោកនាយក ទ្រង់មានយសច្រើន គេគ្របសង្កត់បានដោយក្រ ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានយសប្រមាណមិនបាន ទ្រង់រុងរឿង ដូចជាព្រះអាទិត្យ ទ្រង់កម្ចាត់បង់នូវងងឹតទាំងពួង ទ្រង់ញុំាងធម្មចក្កទាំងពួង ឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះមានតេជៈប្រឹងមិនបាន មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី ១ មានពួកសត្វមួយសែនកោដិ ។ ទេវរាជព្រះនាមសុទស្សនៈ គាប់ព្រះហឫទ័យនឹងមិច្ឆាទិដ្ឋិ ព្រះសាស្តា កាលទ្រង់បន្ទោបង់នូវទិដ្ឋិ នៃសុទស្សនទេវរាជនោះ ទ្រង់បានសម្ដែងធម៌ ។ ក្នុងកាលនោះ ការប្រជុំជនច្រើនប្រឹងមិនបាន ជាការប្រជុំធំ ឈ្មោះថា ត្រាស់ដឹងទី ២ មានពួកសត្វ ៩ ពាន់កោដិ ។ ក្នុងកាលណា ព្រះពុទ្ធព្រះអង្គជាសារថី ទូន្មាននូវនរៈ ទ្រង់ទូន្មានដំរីឈ្មោះទោណមុខៈ ក្នុងកាលនោះ ឈ្មោះថាត្រាស់ដឹងទី ៣ មានពួកសត្វ ៨០ កោដិ ។ ព្រះបិយទស្សីអង្គនោះ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានពួកព្រះអរហន្ត មួយសែនកោដិ ។ តពីនោះមក ព្រះខីណាស្រពទាំងឡាយ ជាអ្នកប្រាជ្ញ ចំនួន ៩០ កោដិ បានមកប្រជុំ

ព្រមក្នុងទីជាមួយគ្នា នេះជាសន្និបាតលើកទី ២ ក្នុងសន្និបាតលើកទី ៣ មានព្រះខីណាស្រព ៨០ កោដិ ។ សម័យនោះ តថាគតកើតជាមាណព ឈ្មោះកស្សបៈ ជាអ្នកស្វាធ្យាយមន្ត ចងចាំមន្ត ដល់នូវត្រើយនៃត្រៃវេទ ។ តថាគតបានស្តាប់ធម៌ របស់ព្រះពុទ្ធ ព្រះនាមបិយទស្សីនោះ ហើយបានញុំាងសេចក្តីជ្រះថ្លា ឲ្យកើតឡើង តថាគតបានសាងនូវសង្ឃារាម ដោយទ្រព្យប្រមាណមួយសែនកោដិ ។ តថាគតបានថ្វាយអារាម ដល់ព្រះពុទ្ធអង្គនោះ ហើយមានចិត្តរីករាយ មានចិត្តសង្វេគ បានសមាទានសរណគមន៍ និងសីល ៥ ធ្វើឲ្យមាំមួន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ក្នុងកណ្តាលសង្ឃហើយ ទ្រង់ព្យាករតថាគតថា មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងទី ១៨០០ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ទៅតម្កល់ការព្យាយាម ហើយធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់ នៃអជបាលព្រឹក្សទទួលបាយាសក្នុងទីនោះ ហើយទ្រង់ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅទៀបគល់ នៃពោធិព្រឹក្សតាមផ្លូវដ៏ប្រសើរដែលគេតាក់តែងហើយ ។ លំដាប់នោះ ព្រះមានយសធំ នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់ នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើត នៃព្រះពុទ្ធអង្គ

នេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះ ព្រះនាមគោតម ។ ភិក្ខុឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអគ្គសាវក ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រី អង្គនោះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ។ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុនៃព្រះគោតម មានយសអង្គនោះ មានកំណត់ ១០០ ឆ្នាំ ។ ទេវតា និងមនុស្ស ទាំងឡាយ លុះបានស្តាប់នូវព្រះបន្ទូលនេះ នៃព្រះមហេសី រកបុគ្គលស្មើគ្មាន ក៏ត្រេកអរថា មាណពនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើច ក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផលក្នុងសាសនា នៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់បានសម្រេចមគ្គផល ចំពោះព្រះភក្ត្រនៃព្រះគោតមនេះមិនខាន ។ មនុស្សទាំងឡាយ កាលនឹងឆ្លងស្ទឹង បើឃ្លាងនូវកំពង់ក្នុងទីចំពោះមុខហើយ គង់កាន់

យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ លុះតថាគតបានស្តាប់ព្រះបន្ទូលនៃព្រះពុទ្ធអង្គនេះហើយ បានញុំាងចិត្តឲ្យជ្រះថ្លា ដោយក្រៃលែង ហើយអធិដ្ឋានវត្តលើសលុប ដោយការបំពេញនូវបារមីទាំង ១០ ។ ព្រះសាស្តាព្រះនាមបិយទស្សី មានព្រះនគរឈ្មោះសុធញ្ញៈ មានព្រះមហាក្សត្រ ព្រះនាមសុទត្តៈជាព្រះបិតា មានព្រះមាតាព្រះនាមសុចន្ទា ។ ព្រះពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងផ្ទះអស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ មាន ៣ ខ្នង គឺសុនិម្មលប្រាសាទ ១ វិមលប្រាសាទ ១ គិរិគុហាប្រាសាទ ១ ។ មាននារីប្រមាណ ៣៣ ពាន់នាក់ សុទ្ធសឹងតែតាក់តែងល្អ ឯនារីដែលជាអគ្គមហេសីនោះ ព្រះនាមនាងវិមលា ព្រះរាជបុត្តបង្កើតព្រះនាមកញ្ចនាវេឡៈ ។ ព្រះជិនស្រី ជាបុរសប្រសើរ ទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាងហើយ ស្តេចចេញទៅដោយយាន គឺរថ ហើយទ្រង់ប្រព្រឹត្តនូវសេចក្តីព្យាយាម អស់ ៦ ខែគត់ ។ ព្រះមហាមុនី ព្រះនាមបិយទស្សី ជាព្រះមហាវីរបុរស ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងឧសភឧទ្យាន ជាទីរីករាយនៃចិត្ត ។ ភិក្ខុឈ្មោះបាលិតៈ ១ ឈ្មោះសព្វទស្សី ១ ជាអគ្គសាវក ភិក្ខុ

ឈ្មោះសោភិតៈជាឧបដ្ឋាកនៃព្រះសាស្តា ព្រះនាមបិយទស្សី ។ ភិក្ខុនីឈ្មោះសុជាតា ១ ឈ្មោះធម្មទិន្នា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា កកុធព្រឹក្ស ( ដើមថ្ងាន់ ) ។ ឧបាសកឈ្មោះសន្ទកៈ ១ ធម្មិកៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនាងវិសាខា ១ ឈ្មោះនាងធម្មទិន្នា ១ ជាអគ្គឧបដ្ឋាយិកា ព្រះពុទ្ធអង្គនោះ ទ្រង់មានយសរាប់មិនបាន មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានកម្ពស់ ៨០ ហត្ថ ទ្រង់ប្រាកដដូចជាស្តេចនៃឈើ ឈ្មោះសាលព្រឹក្ស ។ រស្មីនៃភ្លើង រស្មីនៃព្រះចន្ទ និងរស្មីនៃព្រះអាទិត្យ ប្រាកដដូចជារស្មីនៃព្រះពុទ្ធមហេសី ដែលរកបុគ្គលស្មើគ្មាននោះ មិនមានឡើយ ។ ព្រះសម្ពុទ្ធជាទេវតាដ៏ប្រសើរអង្គនោះ មានព្រះជន្មាយុនៅជាបនោះ គឺព្រះចក្ខុសម្ពុទ្ធ ទ្រង់ស្ថិតនៅក្នុងលោក អស់ ៩០ ពាន់ឆ្នាំ ។ ព្រះពុទ្ធដែលមិនមានបុគ្គលស្មើអង្គនោះក្តី គូនៃសាវកទាំងអម្បាលនោះក្តី មានគុណប្រឹងពុំបាន របស់ទាំងអស់នេះ អន្តរធានទៅឱហ្ន៎ ! សង្ខារទាំងពួង ជារបស់សោះសូន្យទទេ ។ ព្រះពុទ្ធព្រះនាមបិយទស្សី ជាព្រះមុនីប្រសើរ ទ្រង់បរិនិព្វានក្នុងអស្សត្ថារាម ព្រះស្តូបនៃព្រះជិនស្រីអង្គនោះ មានកម្ពស់ ៣ យោជន៍ ( គេបានសាងហើយ ) ក្នុងអស្សត្ថារាមនោះ ។

បិយទស្សិពុទ្ធវង្សទី ១៣ ចប់

# អដ្ឋកថា

## បិយទស្សិពុទ្ធវង្សទី ១៣

បន្ទាប់អំពីព្រះសុជាតសម្ពុទ្ធ ក្នុងកប្បមួយ ក្នុងទីបំផុតនៃ ១៨០០ កប្ប អំពីកទ្ទកប្បនេះ មានព្រះពុទ្ធ ៣ ព្រះអង្គកើតឡើង គឺព្រះបិយទស្សី ១ ព្រះអត្ថទស្សី ១ ព្រះធម្មទស្សី ១ ។ ក្នុង ៣ ព្រះអង្គនោះ ព្រះមានព្រះភាគបិយទស្សី ទ្រង់បំពេញបារមីហើយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងចន្ទាទេវី ជាស្ត្រីដែលមានកក្រដូចព្រះចន្ទ ជាអគ្គមហេសីរបស់ព្រះបាទសុទត្តៈ ក្នុងសុធញ្ញវតីនគរ គ្រប់កំណត់ទសមាស ក៏ប្រសូតចាកព្រះឧទររបស់ព្រះជននី ក្នុងវរុណរាជឧទ្យាន ក្នុងថ្ងៃថ្វាយព្រះនាម ព្រះជនកព្រះជននីថ្វាយព្រះនាមថា បិយទស្សី ព្រោះឃើញបាដិហារ្យវិសេស ដែលជាទីស្រឡាញ់របស់សត្វលោក ។ ព្រះពោធិសត្វសោយរាជសម្បត្តិអស់ ៩ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ គឺសុនិម្មលៈ ១ វិមលៈ ១ គិរិព្រហា ១[១] ។ មានស្រីស្នំ ៣ ម៉ឺន ៣ ពាន់នាក់ មាននាងវិមលាមហាទេវីជាប្រធាន ។

កាលព្រះរាជឱរសព្រះនាមកញ្ចនវេឡុៈ[២] របស់ព្រះនាងវិមលាទេវីប្រសូតហើយ ព្រះមហាបុរសនោះ ទ្រង់ឃើញនិមិត្ត ៤ ហើយទ្រង់យាងចេញមហាភិនេស្ក្រមណ៍ ដោយរថដែលទឹមដោយសេះ ទ្រង់ព្រះផ្នួសហើយមួយអន្លើនឹងបុរស ១ កោដិ ព្រះមហាបុរសដែលជន ១ កោដិនោះចោមរោម

---

១- បិដកខ្មែរជា គិរិគុហា ។ ២- បិដកខ្មែរជា កញ្ចនាវេឡុៈ ។

ហើយ ទ្រង់បំពេញព្យាយាមអស់ ៦ ខែ ក្នុងថ្ងៃវិសាខបុណ្ណមី សោយមធុ-បាយាសដែលធីតារបស់វសកព្រាហ្មណ៍ ក្នុងស្រុកវរុណព្រាហ្មណ៍ថ្វាយ ហើយទ្រង់សម្រាកពេលថ្ងៃ ក្នុងព្រៃសាលវ័ន ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអាជីវកឈ្មោះសុជាតថ្វាយ ហើយយាងចូលទៅកាន់មណ្ឌលពោធិព្រឹក្ស ឈ្មោះដើមកកុធៈ គឺដើមថ្ងាន់ ទ្រង់លាតសន្ថតស្មៅទំហំ ៥៣ ហត្ថ ប្រថាប់គង់ពត់ភ្នែន ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ទ្រង់បន្លឺឧទានថា **អនេកជាតិ-សំសារំ** ជាដើមហើយ ទ្រង់សម្ងំនៅក្បែរៗ គល់ពោធិព្រឹក្សនោះឯង អស់ ៧ សប្តាហ៍ ទ្រង់ជ្រាបថា កុលបុត្តដែលបួសជាមួយព្រះអង្គ អាចចាក់ធ្លុះនូវអរិយធម៌ ទើបយាងទៅក្នុងទីនោះតាមអាកាស ចុះត្រង់ឧសភវតីរាជឧទ្យានក្បែរក្រុងឧសភវតី ដែលភិក្ខុមួយកោដិចោមរោមហើយ ទ្រង់ប្រកាសព្រះធម្មចក្រ កាលនោះ ការត្រាស់ដឹងធម៌មានដល់សត្វ ១ សែនកោដិ នេះជាការសម្រេចធម៌លើកទី ១ ។

បន្តមកទៀត ស្តេចនៃទេវតា ព្រះនាមសុទស្សនៈ ប្រថាប់នៅត្រង់សុទស្សនបព៌ត មិនឆ្ងាយអំពីក្រុងឧសភវតី ទ្រង់ជាបុគ្គលមិច្ឆាទិដ្ឋិ ពួកមនុស្សពេញជម្ពូទ្វីប នាំគ្រឿងបូជាយញ្ញរាប់សែន មកបួងសួងព្រះរាជា ស្តេចសុទស្សនទេវរាជនោះ គង់ប្រថាប់លើអាសនៈតែមួយ ជាមួយព្រះរាជារបស់មនុស្ស ទ្រង់ទទួលគ្រឿងជង្វាយ កាលនោះ ព្រះមានព្រះភាគបិយទស្សីទ្រង់ព្រះតម្រិះថា តថាគតនឹងបន្ទោបង់មិច្ឆាទិដ្ឋិរបស់ស្តេចសុទស្សនទេវរាជនោះ កាលស្តេចសុទស្សនទេវរាជយាងទៅកាន់សមាគមយក្ខ ទើបយាងទៅកាន់

កពរបស់ទ្រង់ ឡើងកាន់សិរិសេយ្យាសនៈ ប្រថាប់គង់បញ្ចេញព្រះឆព្វណ្ណរង្សី ដូចព្រះអាទិត្យក្នុងសរទរដូវ បញ្ចេញពន្លឺលើកំពូលភ្នំយុគន្ធរបព៌ត ។ ទេវតាដែលជាបរិវាររបស់ទេវរាជ ក៏បូជាព្រះទសពលដោយផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាដើម ឈរចោមរោម ។

ឯសុទស្សនទេវរាជ ត្រឡប់អំពីយក្ខសមាគម ឃើញឆព្វណ្ណរង្សីផ្សាយចេញអំពីកពរបស់ខ្លួន ក៏គិតថា ក្នុងថ្ងៃដទៃៗ មិនធ្លាប់ឃើញកពរបស់អញចម្រើនរុងរឿង ដោយរស្មីច្រើនដល់ម្ល៉េះ អ្នកណាហ្ន៎ ជាទេវតា ឬជាមនុស្សចូលទៅក្នុងទីនេះ ពិនិត្យមើលក៏ឃើញព្រះមានព្រះភាគ គង់ប្រថាប់រុងរឿងដោយពន្លឺព្រះឆព្វណ្ណរង្សី ដូចព្រះអាទិត្យក្នុងសរទរដូវ លើកំពូលភ្នំឧទយ-គិរី គិតថា សមណៈត្រងោលនេះ ដែលជនជាបរិវាររបស់អញចោមរោមហើយ អង្គុយលើទីដេកដ៏ល្អ ត្រូវសេចក្ដីក្រោធគ្របសង្កត់ចិត្ត គិតថា ណ្ហើយចុះ អញនឹងសម្ដែងកម្លាំងរបស់អញដល់សមណៈត្រងោលនោះ រួចក៏ធ្វើភ្នំទាំងមូល ឲ្យឆេះជាអណ្ដាតភ្លើង សម្លឹងមើលថា សមណៈត្រងោលប្រហែលជាក្លាយជាផេះ ព្រោះអណ្ដាតភ្លើងហើយ ឃើញព្រះទសពល មានព្រះវរកាយគ្របដណ្ដប់ទៅដោយព្រះរស្មី មានព្រះភក្ត្រល្អផូរផង់ មានព្រះឆវីស្រស់ថ្លា រុងរឿង គិតថា សមណៈនេះអត់ធន់នឹងភ្លើងបាន ណ្ហើយចុះ អញនឹងបៀតបៀនសមណៈនេះ ដោយក្រសែទឹកជំនន់ ហើយសម្លាប់បង់ ទើបលែងខ្សែទឹកជំនន់ដ៏ធំតម្រង់ទៅកាន់វិមាន ។

បន្ទាប់ពីនោះ ទឹកក៏មិនសើមត្រឹមតែជាយចីវរ ឬត្រឹមតែព្រះលោមា

ក្នុងព្រះសរីរៈរបស់ព្រះមានព្រះភាគអង្គនោះ ដែលគង់នៅក្នុងវិមាននោះ ដែលពេញដោយក្រសែទឹកជំនន់ បន្ទាប់អំពីនោះ ស្តេចសុទស្សនទេវរាជ ដឹងថា ក្រសែទឹកជំនន់នេះ សមណៈនឹងដកដង្ហើមមិនចេញ ក៏នឹងស្លាប់ ទើបសោកមន្ត មើលទៅក្នុងទឹក ឃើញព្រះមានព្រះភាគប្រថាប់គង់ ដែលមានបរិស័ទរបស់ខ្លួនចោមរោម រុងរឿងដោយបណ្តាញនៃព្រះរស្មីច្រើនប្រភេទ ដូចរស្មីរជនីករក្នុងសរទរដូវ បញ្ចេញពន្លឺអំពីស្រទាប់ពពកពណ៌ខៀវចាស់ អត់ធន់មិនបាន គិតថា អញនឹងសម្លាប់សមណៈនោះចោល ហើយក៏បណ្តាលភ្លៀងអាវុធ ៩ ប្រការឲ្យធ្លាក់ចុះ ដោយសេចក្តីក្រោធ លំដាប់នោះ ដោយអានុភាពរបស់ព្រះមានព្រះភាគអង្គនោះ អាវុធគ្រប់យ៉ាង ក៏ក្លាយជាផ្កាក្រអូបច្រើនប្រភេទ ល្អគួរមើលក្រៃលែង ធ្លាក់ចុះទៀបបាទារបស់ព្រះទសពល ។

បន្ទាប់អំពីនោះ សុទស្សនមហារាជឃើញភាពអស្ចារ្យនោះ រឹងរឹតតែមានចិត្តក្រោធ ទើបយកដៃទាំង ២ ចាប់ព្រះបាទារបស់ព្រះមានព្រះភាគអូសចេញទៅអំពីភពរបស់ខ្លួន ហើយបោះរំលងមហាសមុទ្រ ដល់កណ្តាប់ចក្កវាឡ ពិចារណាមើលថា សមណៈរស់ ឬស្លាប់ហើយ ក៏ឃើញព្រះមានព្រះភាគគង់ប្រថាប់នៅលើអាសនៈនោះឯង គិតថា ឱ ! សមណៈនេះមានអានុភាពច្រើន អញមិនអាចចាប់ទាញសមណៈនេះចេញអំពីទីនេះបាន បើមានអ្នកដទៃដឹងរឿងរបស់អញ អញនឹងអាប់យស អញនឹងដោះលែងសមណៈនេះ ដរាបណាអ្នកដទៃ មិនឃើញសមណៈនេះ ។

លំដាប់នោះ ព្រះទសពលទ្រង់ជ្រាបការប្រព្រឹត្តផ្លូវចិត្តរបស់សុទស្សនទេវរាជនោះ ទ្រង់ក៏អធិដ្ឋានឲ្យពួកទេវតា និងមនុស្សទាំងអស់ឃើញទ្រង់ក្នុងថ្ងៃនោះឯង ព្រះរាជា ១០១ អង្គ ក្នុងជម្ពូទ្វីប ក៏នាំគ្នាមកប្រជុំដើម្បីថ្វាយដង្វាយដល់ស្តេចសុទស្សនទេវរាជនោះ ព្រះរាជានៃមនុស្សទាំងឡាយនោះឃើញស្តេចសុទស្សនមហារាជប្រថាប់គង់ ចាប់ព្រះបាទរបស់ព្រះមានព្រះភាគក៏មានចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគថា ទេវរាជរបស់ពួកយើង បម្រើបាទារបស់ព្រះមានព្រះភាគបិយទស្សី ជាកំពូលនៃមុនី ឱ ! ធម្មតាព្រះពុទ្ធទាំងឡាយ គួរអស្ចារ្យហ្ន៎ ឱ ! ធម្មតាព្រះពុទ្ធទាំងឡាយវិសេសពិតៗ ហ្ន៎ នាំគ្នានមស្ការ ឈរផ្គងអញ្ជលីលើសិរសាគ្រប់អង្គ គ្រប់គ្នា ក្នុងសន្និបាតនោះព្រះមានព្រះភាគបិយទស្សី ទ្រង់ធ្វើសុទស្សនទេវរាជនោះឲ្យជាប្រធាន ទ្រង់សម្តែងធម៌ប្រោស កាលនោះ ទេវតា និងមនុស្ស ៩ ម៉ឺនកោដិ សម្រេចអរហត្ត នេះជាការត្រាស់ដឹងធម៌លើកទី ២ ។

កាលសត្រូវរបស់ព្រះសម្ពុទ្ធ ក្នុងកុមុទនគរដែលមានទំហំ ៩ យោជន៍ឈ្មោះព្រះសោណត្ថេរ ប្រឹក្សាជាមួយមហាបទុមរាជកុមារឲ្យផ្តាច់ព្រះជន្មព្រះបិតា របស់ព្រះរាជកុមារនោះ ដូចគ្នានឹងទេវទត្ត សូម្បីព្យាយាមផ្សេងៗ ដើម្បីផ្តាច់ព្រះជន្មរបស់ព្រះវិបស្សីសម្ពុទ្ធ ក៏មិនអាចផ្តាច់បាន ទើបហៅហត្ថាចារ្យឈ្មោះទោណមុខ មកលួងលោមប្រាប់ថា កាលណា សមណៈបិយទស្សីនេះចូលទៅកាន់នគរដើម្បីបិណ្ឌបាត កាលនោះ ចូរអ្នកលែងស្តេចដំរីឈ្មោះទោណមុខ ឲ្យសម្លាប់សមណៈបិយទស្សី ។

កាលនោះ ហត្ថាចារ្យនោះ ជារាជវល្លភៈ មិនពិចារណាដល់វត្ថុជាប្រយោជន៍ និងមិនជាប្រយោជន៍ ដឹងថា សមណៈនេះគប្បីធ្វើអញឲ្យធ្លាក់ចាកតំណែងពិត ទើបទទួលពាក្យ ។ ស្អែកឡើង ក៏កំណត់កាលដែលព្រះទសពលយាងចូលទៅកាន់ព្រះនគរ ចូលទៅរកស្តេចដំរី ឈ្មោះទោណមុខដែលមានថ្វាសដូចផ្ទាំងបាយគ្រង់ពោងដែលកើតល្អហើយ មានប្រមោយវែងដូចថ្នូ មានត្រចៀកធំទន់ ភ្នែកលឿងដូចទឹកឃ្មុំ មានទីអគ្គុយលើដងខ្នងល្អ មានត្រគាកមូលក្រាស់ បិទបាំងនូវគុយ្ហបទេស មានក្លុកល្អ ដូចយាមនង្គ័ល មានកន្ទុយល្អ មានគល់កន្ទុយគួរស្ញើម សម្បូរដោយលក្ខណៈគ្រប់យ៉ាងល្អគួរមើល ដូចមេឃពណ៌ខៀវចាស់ ទៅកាន់ទីដែលរាជសីហ៍សម្តែងឫកដូចដុំពពកដែលរសាត់ មានកម្លាំងស្មើនឹងដំរី ៧ ចុះប្រេង ៧ ដង មានពិសពេញខ្លួន ដូចមច្ចុមារដែលមានសរីរៈធ្វើឲ្យស្រវឹងក្រៃលែង ដែលគេប្រណិ-ប័តន៍ដោយវិធីវិសេស ដូចជាដុំបាយលាយដោយកំញានបន្តក់ភ្នែក បំពក់ផ្សែងលាបស្រឡាបជាដើម ហើយបញ្ជូនទៅដើម្បីផ្តាច់ព្រះជន្មព្រះមុនីដ៏ប្រសើរដែលការពារជនជាសត្រូវបាន ដូចដំរីឯករណ៍ ការពារនូវដំរីដែលជាសត្រូវដូច្នោះ ។ លំដាប់នោះ ស្តេចដំរីឈ្មោះទោណមុខនោះ ជាដំរីដ៏ប្រសើរ គ្រាន់តែលែងទៅប៉ុណ្ណោះ ក៏សម្លាប់ដំរី ក្របី សេះ បុរស ស្ត្រី មានខ្លួន ក្លុក និងប្រមោយប្រឡាក់ដោយឈាមរបស់សត្វដែលត្រូវសម្លាប់ មានភ្នែកគ្របដណ្តប់ដោយសំណាញ់នៃអាឃាត កាច់បំបាក់នូវរទេះ សន្ទះទ្វារ ទ្វារផ្ទះកំពូល សសរខឿនជាដើម ដែលហ្វូងភ្នែក ភ្លៃ និងត្មាតជាដើម ហើរតាម

ទៅចឹកស៊ីអវយវៈរបស់ក្របី មនុស្ស សេះ និងដំរីញីជាដើម ស៊ីដូចយក្ខស៊ីមនុស្ស ឃើញព្រះទសពលដែលពួកសាវកចោមរោម កំពុងយាងមកអំពីចម្ងាយ មានកម្លាំងរហ័ស ដូចគ្រុឌក្នុងអាកាស ឆ្ពោះមុខទៅរកព្រះមានព្រះភាគ ដោយសម្ទុះដ៏រហ័ស ។

កាលនោះ ពួកអ្នកនគរមានចិត្តរួញរាដោយកម្តៅ ព្រោះភ័យ ក៏ចូលទៅកាន់ញោចកំពែងនៃប្រាសាទ ឃើញស្តេចដំរីរត់តម្រង់មករកព្រះតថាគត ក៏ស្រែកឆោឡោ ឯឧបាសកពួកខ្លះនាំគ្នាឃាត់ស្តេចដំរីនោះ ដោយវិធីផ្សេងៗ លំដាប់នោះ ព្រះពុទ្ធនាគអង្គនោះ ទ្រង់សម្លឹងមើលស្តេចដំរីដែលកំពុងមក មានព្រះហឫទ័យត្រជាក់ ដោយសេចក្តីករុណា ទ្រង់ផ្សាយមេត្តាទៅកាន់ស្តេចដំរីនោះ បន្ទាប់អំពីនោះ ស្តេចដំរីនោះ មានសន្តានចិត្តដែលព្រះហឫទ័យមេត្តាផ្សាយទៅ ធ្វើឲ្យទន់ភ្លន់ ក៏ដឹងទោស និងកំហុសរបស់ខ្លួន មិនអាចឈរចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគបាន ដោយការខ្មាស ទើបក្រាបចុះ ទៀបយុគលបាទនៃព្រះមានព្រះភាគ ដូចជ្រែកចូលទៅក្នុងផែនដី ។ ស្តេចដំរីនោះក្រាបចុះយ៉ាងនោះហើយ សរីរៈដូចដុំពពក ក៏រុងរឿងដូចដុំពពកពណ៌ខៀវចាស់ ចូលទៅជិតកំពូលភ្នំមាស ដែលបូកលាបដោយពន្លឺសន្ធ្យា ។

គ្រានោះ ពួកអ្នកនគរឃើញស្តេចដំរីក្រាបទៀបបាទារបស់ព្រះមុនី មានចិត្តជ្រួតជ្រាបដោយបីតិយ៉ាងក្រៃលែង ក៏នាំគ្នាបន្លឺសំឡេងឲ្យសាធុការកងរំពង ដូចសំឡេងរាជសីហ៍ បូជាព្រះសាស្តា ដោយប្រការផ្សេងៗ ដោយផ្កាក្រអូប ផ្កាកម្រង ខ្លឹមចន្ទន៍ លម្អិតក្រអូប និងគ្រឿងប្រដាប់ជាដើម បោះ

សំពត់ទៅដោយជុំវិញ ស្គរទិព្វរបស់ទេវតា ក៏បន្លឺក្នុងនភាកាស ។ គ្រានោះ ព្រះមានព្រះភាគទ្រង់សម្លឹងមើលស្តេចដំរី ដែលឱនក្បាលទៀបបាទា ដូចកំពូលភ្នំដែលលាបដោយពណ៌ខ្មៅ ទ្រង់ក៏ស្ទាបពោងដំរីដោយបាតព្រះហស្ត ដែលប្រដាប់ដោយកង្វេរ ទង់ ស័ង្ខ និងចក្រ ហើយទ្រង់ទូន្មានស្តេចដំរីនោះដោយព្រះធម្មទេសនា ដែលឧបការៈដល់ការប្រព្រឹត្តផ្លូវចិត្តរបស់ស្តេចដំរីនោះថា

ម្នាលស្តេចដំរី អ្នកចូរស្តាប់ពាក្យរបស់តថាគត ដែលប្រៀនប្រដៅ និងចូរបដិបត្តិតាមពាក្យប្រៀបប្រដៅរបស់តថាគត ដែលប្រកបដោយប្រយោជន៍ ចូរកម្ចាត់បង់នូវការត្រេកអរក្នុងបាណាតិបាត និងចិត្តអាក្រក់របស់អ្នកចេញ ចូរអ្នកជាដំរីគួរជាទីស្រឡាញ់ ជាអ្នកស្ងប់ ។

ម្នាលស្តេចដំរី បុគ្គលណាបៀតបៀនសត្វមានជីវិត ដោយលោភៈ និងទោសៈ ឬដោយមោហៈ បុគ្គលនោះ ឈ្មោះថាជាអ្នកសម្លាប់នូវសត្វមានជីវិត រមែងសោយទុក្ខដ៏ពន្លឹក ក្នុងនរកអស់កាលយូរ ។

ម្នាលស្តេចដំរី អ្នកកុំធ្វើកម្មបែបនោះ ដោយសេចក្តីប្រមាទ ដោយសេចក្តីស្រវឹង ព្រោះបុគ្គលធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះ គឺសម្លាប់សត្វ រមែងជួបនូវទុក្ខដ៏ខ្លោចផ្សាក្នុងនរកអស់កប្ប ។ បុគ្គលបៀតបៀនអ្នកដទៃ ការសោយទុក្ខដ៏ខ្លោចផ្សាក្នុងនរក ហើយ លុះមកកាន់មនុស្សលោក ក៏ជាអ្នកមានអាយុខ្លី មាន

រូបរាងអាក្រក់ និងមានចំណែកពិសេសនៃសេចក្តីទុក្ខ ។
ម្នាលកុញ្ជរ អ្នកមានបញ្ញាតិច អ្នកដឹងថា បើជីវិតជាទី
ស្រឡាញ់ យ៉ាងក្រៃលែងរបស់អ្នក យ៉ាងណា ក្នុងមហាជន
មានជីវិត គឺក្នុងអ្នកដទៃ ក៏ជាទីស្រឡាញ់យ៉ាងនោះដែរ
ហើយគប្បីវៀរបាណាតិបាតជាសមុច្ឆេទ ។
បើអ្នកដឹងទោសក្នុងការបៀតបៀន និងគុណដែលវៀរចាក
បាណាតិបាតហើយ ចូរវៀរបង់នូវបាណាតិបាត អ្នកនឹងបាន
សុខក្នុងស្ថានសួគ៌ នាបរលោក ។
បុគ្គលវៀរចាកបាណាតិបាត ទូន្មានខ្លួនហើយ រមែងជាទី
ស្រឡាញ់នៃជនក្នុងលោកនេះ លុះកាយបែកធ្លាយទៅហើយ
ព្រះពុទ្ធទាំងឡាយពោលថា បុគ្គលនោះ នឹងទៅកាន់ស្ថានសួគ៌ ។
បុគ្គលណាមួយ ក្នុងលោកនេះ រមែងមិនប្រាថ្នាឲ្យទុក្ខមកដល់
ដែលកើតមកហើយគ្រប់គ្នា រមែងស្វែងរកសេចក្តីសុខ ម្នាល
ស្តេចដំរីដ៏ប្រសើរ ព្រោះហេតុនោះ ចូរអ្នកវៀរបង់នូវការ
បៀតបៀន ចម្រើនមេត្តា និងករុណា ក្នុងកាលដ៏សមគួរចុះ
ដូច្នេះ ។

លំដាប់នោះ ស្តេចដំរី កាលព្រះទសពលទ្រង់ប្រៀនប្រដៅយ៉ាងនេះហើយ ក៏បានសិក្សា ជាសត្វដែលទ្រង់ទូន្មានល្អហើយ ដល់ព្រមដោយវិន័យ និងចរិយា ដល់នូវភាពជាអន្តេវាសិក ។ កាលព្រះមានព្រះភាគបិយទស្សីអង្គ

នោះ ទ្រង់ទូន្មានស្តេចដំរីឈ្មោះទោណមុខ ដូចព្រះសាស្តានៃយើងទូន្មានដំរីធនបាល ហើយទើបទ្រង់សម្តែងធម៌ប្រោសមហាជនក្នុងសមាគមនោះ ។ កាលនោះ ការត្រាស់ដឹងធម៌មានដល់សត្វ ៨ ម៉ឺនកោដិ[១] ។ នេះជាការសម្រេចធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងកាលជាខាងក្រោយនៃព្រះសម្ពុទ្ធ ព្រះនាមសុជាតៈមក
មានព្រះពុទ្ធទ្រង់ព្រះនាមបិយទស្សី ជាសយម្ភូ ជាលោក-
នាយក ទ្រង់មានយសច្រើន គេគ្របសង្កត់បានដោយក្រ
ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ ។ ព្រះ
សម្ពុទ្ធអង្គនោះ ទ្រង់មានយសប្រមាណមិនបាន ទ្រង់រុងរឿង
ដូចជាព្រះអាទិត្យ ទ្រង់កម្ចាត់បង់នូវងងឹតទាំងពួង ទ្រង់ញុំាង
ធម្មចក្កទាំងពួងឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះ មានតេជៈប្រឹង
មិនបាន មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី ១
មានពួកសត្វមួយសែនកោដិ ។ ទេវរាជ ព្រះនាមសុទស្សនៈ
គាប់ព្រះហឫទ័យនឹងមិច្ឆាទិដ្ឋិ ព្រះសាស្តា កាលទ្រង់បន្ទោបង់
នូវទិដ្ឋិនៃសុទស្សនទេវរាជនោះ ទ្រង់បានសម្តែងធម៌ ។ ក្នុង
កាលនោះ ការប្រជុំជនច្រើនប្រឹងមិនបាន ជាការប្រជុំធំ ឈ្មោះ
ថា ត្រាស់ដឹងទី ២ មានពួកសត្វ ៩ ពាន់កោដិ ក្នុងកាលណា

---

១- បាលីបិដកខ្មែរជា អសីតិកោដិសហស្សានំ គួរតែជា ៨០ ពាន់កោដិ តែលោកប្រែត្រឹមតែ ៨០ កោដិ ។

ព្រះពុទ្ធព្រះអង្គជាសារថី ទូន្មាននូវនរៈ ទ្រង់ទូន្មានដំរី ឈ្មោះ
ទោណមុខៈ ក្នុងកាលនោះ ឈ្មោះថា ត្រាស់ដឹងទី ៣ មាន
ពួកសត្វ ៨០ កោដិ ដូច្នេះ ។

ក្នុងសុមង្គលនគរ មានសម្លាញ់ ២ នាក់ គឺព្រះរាជឱរសព្រះនាមថា បាលិតៈ និងកូនបុរោហិតឈ្មោះថាសព្វទស្សីកុមារ សម្លាញ់ ២ នាក់នោះ កាលព្រះបិយទស្សីសម្មាសម្ពុទ្ធទ្រង់ចារិកមក បានដំណឹងថា ព្រះសាស្ដា យាងដល់នគររបស់ខ្លួន មានបរិវារមួយសែនកោដិ ចេញទៅទទួលស្ដាប់ ធម្មកថារបស់ព្រះអង្គ ហើយថ្វាយមហាទានអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ចប់ ភត្តានុមោទនារបស់ព្រះមានព្រះភាគ មួយអន្លើដោយបរិវារមួយសែនកោដិ បួសហើយ ក៏បានសម្រេចអរហត្ត ព្រះមានព្រះភាគទ្រង់លើកបាតិមោក្ខ សម្ដែងកណ្ដាលភិក្ខុសាវកទាំងនោះ នេះជាសន្និបាតលើកទី ១ ។ សម័យ តមក សត្វ ៩០ កោដិសម្រេចអរហត្ត ក្នុងសមាគមរបស់ស្ដេចសុទស្សនទេវរាជ ព្រះសាស្ដា កាលភិក្ខុសាវកទាំងនោះចោមរោមហើយ ទ្រង់លើក បាតិមោក្ខឡើងសម្ដែង នេះជាសន្និបាតលើកទី ២ ។ បន្ទាប់មកទៀត ក្នុង សម័យទ្រង់ទូន្មានស្ដេចដំរីទោណមុខ សត្វ ៨០ កោដិ បួសហើយ សម្រេច អរហត្ត ។ ព្រះមានព្រះភាគ ទ្រង់លើកបាតិមោក្ខឡើងសម្ដែងកណ្ដាលភិក្ខុសាវកទាំងនោះ នេះជាសាវកសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះ មានព្រះភាគត្រាស់ថា

ព្រះបិយទស្សីអង្គនោះ មានសាវកសន្និបាត ៣ លើក គឺ សន្និបាតលើកទី ១ មានពួកព្រះអរហន្តមួយសែនកោដិ ។ តពីនោះមក ព្រះខីណាស្រពទាំងឡាយ ជាអ្នកប្រាជ្ញ ចំនួន ៩០ កោដិ បានមកប្រជុំព្រមក្នុងទីជាមួយគ្នា នេះជាសន្និបាតលើកទី ២ ក្នុងសន្និបាតលើកទី ៣ មានព្រះខីណាស្រព ៨០ កោដិ ដូច្នេះ ។

កាលនោះ ព្រះពោធិសត្វនៃយើង ជាព្រាហ្មណមាណពឈ្មោះកស្សបៈ រៀនចប់ត្រៃវេទ មានឥតិហាសៈជាគម្រប់ ៥ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ឲ្យគេសាងសង្ឃារាមដែលគួរជាទីត្រេកអរក្រៃលែង ដោយបរិច្ចាគទ្រព្យមួយសែនកោដិ តាំងនៅក្នុងសរណៈ និងសីល ៥ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ព្យាករព្រះពោធិសត្វនោះថា អំណឹះតទៅ ១៨០០ កប្បរាប់អំពីកប្បនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធក្នុងលោក ព្រះនាមថាគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតកើតជាមាណព ឈ្មោះកស្សបៈ ជាអ្នកស្វាធ្យាយមន្ត ចងចាំមន្ត ដល់នូវត្រើយនៃត្រៃវេទ ។ តថាគតបានស្តាប់ធម៌របស់ព្រះពុទ្ធ ព្រះនាមបិយទស្សីនោះហើយ បានញុំាងសេចក្តីជ្រះថ្លាឲ្យកើតឡើង តថាគតបានសាងនូវសង្ឃារាម ដោយទ្រព្យ ប្រមាណមួយសែនកោដិ ។ តថាគតបានថ្វាយអារាមដល់ព្រះពុទ្ធអង្គនោះ ហើយមានចិត្តរីករាយ

មានចិត្តសង្វេគ បានសមាទានសរណគមន៍ និងសីល ៥ ធ្វើឲ្យមាំមួន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ក្នុងកណ្ដាលសង្ឃ ហើយ ទ្រង់ព្យាករតថាគតថា មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងទី ១៨០០ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ទៅតម្កល់ការព្យាយាម ។បេ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ លុះតថាគតបានស្ដាប់ព្រះបន្ទូល នៃព្រះពុទ្ធអង្គនេះហើយ បានញ៉ាំងចិត្តឲ្យជ្រះថ្លាដោយក្រៃលែង ហើយអធិដ្ឋានវត្តលើសលុប ដោយការបំពេញនូវបារមីទាំង ១០ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សរណេ បញ្ចសីលេ ច** សេចក្ដីថា សរណៈ ៣ និងសីល ៥ ។ បទថា **អដ្ឋារសេ កប្បសតេ** សេចក្ដីថា កន្លងទៅ ១៨០០ កប្ប រាប់អំពីភទ្ទកប្បនេះ ។

ព្រះមានព្រះភាគបិយទស្សីអង្គនោះ មាននគរឈ្មោះសុធញ្ញៈ ព្រះបិតាព្រះនាមព្រះបាទសុទត្តៈ ព្រះមាតាព្រះនាមព្រះនាងសុចន្ទាទេវី គូនៃអគ្គសាវកឈ្មោះបាលិតៈ ១ សព្វទស្សី ១ ពុទ្ធុបដ្ឋាកឈ្មោះសោភិតៈ គូនៃអគ្គសាវិកាឈ្មោះសុជាតា ១ ធម្មទិន្នា ១ ពោធិព្រឹក្សឈ្មោះកកុធៈ គឺដើមថ្កាន់ ព្រះសរីរៈកម្ពស់ ៨០ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ អគ្គមហេសី

ព្រះនាមព្រះនាងវិមលា ឱរសព្រះនាមកញ្ចនាវេឡុះ ទ្រង់ចេញអភិនេស្រ្កមណ៍ ដោយរថដែលទឹមដោយសេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តា ព្រះនាមបិយទស្សី មានព្រះនគរឈ្មោះសុធញ្ញៈ មានព្រះមហាក្សត្រ ព្រះនាមសុទត្តៈជាព្រះបិតា មានព្រះមាតា ព្រះនាមសុចន្ទា ។ ភិក្ខុឈ្មោះបាលិតៈ ១ ឈ្មោះសព្វទស្សី ១ ជាអគ្គសាវក ភិក្ខុឈ្មោះសោភិតៈជាឧបដ្ឋាក នៃព្រះសាស្តាព្រះនាមបិយទស្សី ។ ភិក្ខុនីឈ្មោះសុជាតា ១ ឈ្មោះធម្មទិន្នា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា កកុធព្រឹក្ស ( ដើមថ្ងាន់ ) ។ ឧបាសកឈ្មោះសន្ទកៈ ១ ធម្មិកៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនាងវិសាខា ១ ឈ្មោះនាងធម្មទិន្នា ១ ជាអគ្គឧបដ្ឋាយិកា ព្រះពុទ្ធអង្គនោះ ទ្រង់មានយសរាប់មិនបាន មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានកម្ពស់ ៨០ ហត្ថ ទ្រង់ប្រាកដដូចជាស្តេចនៃឈើឈ្មោះសាលព្រឹក្ស ។ រស្មីនៃភ្លើង រស្មីនៃព្រះចន្ទ និងរស្មីនៃព្រះអាទិត្យ ប្រាកដដូចជារស្មីនៃព្រះពុទ្ធមហេសី ដែលរកបុគ្គលស្មើគ្មាននោះ មិនមានឡើយ ។ ព្រះសម្ពុទ្ធជាទេវតាដ៏ប្រសើរអង្គនោះ មានព្រះជន្មាយុនៅដរាបនោះ គឺព្រះចក្ខុសម្ពុទ្ធ ទ្រង់ស្ថិតនៅក្នុងលោក

អស់ ៩០ ពាន់ឆ្នាំ ។ ព្រះពុទ្ធដែលមិនមានបុគ្គលស្មើអង្គនោះក្តី គូនៃសាវកទាំងអម្បាលនោះក្តី មានគុណប្រឹងពុំបាន របស់ទាំងអស់នេះ អន្តរធានទៅ ឱហ្ន៎ ! សង្ខារទាំងពួង ជារបស់សោះសូន្យទទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាលរាជាវ** សេចក្តីថា ប្រាកដដូចស្តេចសាលព្រឹក្ស ដែលមានដើមមូល មានផ្ការីកស្គុះស្គាយ តាំងអំពីគល់ឡើងទៅ គួរជាទីត្រេកអរក្រៃលែង ។ បទថា **យុគានិបិ តានិ** បានដល់ គូទាំងឡាយ មានគូអគ្គសាវកជាដើម ។ គាថាដ៏សេស មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថាបិយទស្សិពុទ្ធវង្សទី ១៣ ចប់**

# សុត្តន្តបិដក

## អត្ថទស្សិពុទ្ធវង្សទី ១៤

[ ១៥ ] ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមអត្ថទស្សី មានយសធំ ទ្រង់កម្ចាត់បង់ងងឹតធំ សម្រេចសម្ពោធិញ្ញាណ ដ៏ឧត្តម ។ ព្រះសម្ពុទ្ធត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្ម-ចក្កឲ្យប្រព្រឹត្តទៅ ហើយញុំាងមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ ឲ្យឆ្អែតដោយទឹកអម្រឹត ។ ព្រះលោកនាទអង្គនោះ ទ្រង់មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងលើកទី ១ មានពួកសត្វចំនួនមួយសែនកោដិ ។ ក្នុងការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធទ្រង់ព្រះនាមអត្ថទស្សី ទ្រង់ត្រាច់ទៅកាន់ទេវចរិក ។ តមក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់សម្តែងព្រះធម៌ក្នុងសម្នាក់ព្រះបិតា ។ ព្រះមហេសីអង្គនោះ មានសាវកសន្និបាត ( ការជួបជុំសាវ័ក ) ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះហឫទ័យស្ងប់ ប្រកបដោយតាទិគុណ គឺសន្និបាតលើកទី ១ មានពួកព្រះខីណាស្រពចំនួន ៩៨ ពាន់អង្គ សន្និបាតលើកទី ២ មានពួកព្រះខីណាស្រពចំនួន ៨៨ ពាន់អង្គ ។ សន្និបាតលើកទី ៣ មានពួកព្រះខីណាស្រពចំនួន ៧៨ ពាន់អង្គ សុទ្ធតែមានព្រះហឫទ័យផុតស្រឡះ ឥតប្រកាន់ ប្រាសចាកមន្ទិល ជាអ្នកស្វែងរកគុណ

ដ៏ធំ ។ ក្នុងសម័យនោះ តថាគតកើតជាជដិល ឈ្មោះសុសិមៈ មានតាបៈដ៏ខ្ពង់ខ្ពស់ ដែលគេសន្មតថា ជាបុគ្គលប្រសើរលើផែនដី ។ តថាគតបាននាំយកផ្កាមន្ទារវបុស្ស ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ អំពីទេវលោក មកបូជាចំពោះព្រះសម្ពុទ្ធ ។ ឯព្រះពុទ្ធជាមហាមុនី ព្រះនាមអត្ថទស្សីអង្គនោះ ទ្រង់បានព្យាករតថាគតថា តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី ១៨០០ ។ សត្វនេះ នឹងចេញអំពីបុរី ជាទីរីករាយ ឈ្មោះកបិលពស្តុ តម្កល់ព្យាយាម ហើយធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលមធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះមានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌៈ ហើយត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពោធិសត្វនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ បុរសនេះ នឹងជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះ

ខេមាថេរី ១ ព្រះឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស គហបតីឈ្មោះចិត្តៈ ១ គហបតី ឈ្មោះហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ទ្រង់ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើហើយ ក៏រីករាយថា បុរសនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់នឹងទៅកាន់កំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ក្នុងកាលជាអនាគត យ៉ាងនោះដែរ ។ លុះតថាគតបានស្តាប់ភាសិត នៃព្រះលោកនាថអង្គនោះ

ហើយ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ទំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមី ១០ ប្រការ ។ ព្រះមហេសី ព្រះនាមអត្ថទស្សី មានទីក្រុងឈ្មោះសោភណៈ មានព្រះមហាក្សត្រព្រះនាមសាគរៈ ( ជាព្រះបិតា ) មានព្រះជននីព្រះនាមសុទស្សនា ។ ព្រះអត្ថទស្សីអង្គនោះ ទ្រង់គ្រងគេហដ្ឋានអស់ ៩០០០ ឆ្នាំ មានប្រាសាទប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះអមរគិ ១ ប្រាសាទឈ្មោះសុរគិ ១ ប្រាសាទឈ្មោះគិរិវាហនៈ ១ ។ នារី ៣៣០០០ រូប សឹងប្រដាប់យ៉ាងសមសួន ព្រះនារី ( ជាអគ្គមហេសី ) នោះព្រះនាមវិសាខា ព្រះរាជបុត្រព្រះនាមសេលៈ ។ ព្រះជិនស្រីទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាងហើយ ទ្រង់ស្តេចចេញទៅដោយយានសេះ តម្កល់ព្យាយាមអស់ ៨ ខែគត់ ។ ព្រះអត្ថទស្សីមានយសធំ មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ថ្លៃថ្លា ។ ព្រះមហេសីព្រះនាមអត្ថទស្សី មានអគ្គសាវកពីរអង្គ គឺព្រះសន្តៈ ១ ព្រះឧបសន្តៈ ១ មានភិក្ខុជាឧបដ្ឋាកឈ្មោះអភយៈ ។ មានព្រះថេរីឈ្មោះធម្មា ១ សុធម្មា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា ចម្បកព្រឹក្ស ។ ឧបាសកឈ្មោះនកុឡៈ ១ ឈ្មោះនិសភៈ ១ ជាអគ្គឧបដ្ឋាក នាងមកិលា ១ នាងសុនន្ទា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះពុទ្ធអង្គ

នោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ មានកម្ពស់ ៨០ហត្ថ ទ្រង់រុងរឿងហាក់ដូចដើមសាលរាជព្រឹក្ស ឬដូចព្រះចន្ទពេញវង់ ។ រស្មីជាប្រក្រតីនៃព្រះពុទ្ធអង្គនោះ ច្រើនរយកោដិ តែងផ្សាយទៅកាន់ទិសទាំង ១០ ទាំងខាងលើ ទាំងខាងក្រោម ចម្ងាយមួយយោជន៍សព្វៗ កាល ។ម្យ៉ាងទៀត ព្រះពុទ្ធអង្គនោះ ប្រសើរជាងជន ខ្ពង់ខ្ពស់ជាងសត្វទាំងពួង ជាអ្នកប្រាជ្ញ មានបញ្ញាចក្ខុ ស្ថិតនៅក្នុងមនុស្សលោកអស់មួយសែនឆ្នាំ ។ ព្រះពុទ្ធនោះ ទ្រង់សម្តែងពន្លឺថ្លឹងពុំបាន ញុំាងមនុស្សលោក ព្រមទាំងទេវលោក ឲ្យរុងរឿង ហើយទ្រង់ដល់នូវអនិច្ចតាធម៌ ដូចជាភ្លើងអស់កំញម ។ ព្រះអត្ថទស្សីជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអនោមារាម មានការសាយភាយទៅនៃព្រះធាតុ ក្នុងប្រទេសទាំងឡាយនោះៗ ។

## អត្ថទស្សិពុទ្ធវង្សទី ១៤ ចប់

# អដ្ឋកថា

## អត្ថទស្សិពុទ្ធវង្សទី ១៨

កាលព្រះបិយទស្សីសម្មាសម្ពុទ្ធ រម្ងត់ខន្ធបរិនិព្វានហើយ សាសនារបស់ព្រះអង្គក៏អន្តរធានទៅ កាលមនុស្សទាំងឡាយមានអាយុវិនាសហើយចម្រើនឡើង រហូតដល់មានអាយុប្រមាណមិនបាន ចម្រើនហើយ ក៏ថយចុះដោយលំដាប់ រហូតមានអាយុមួយសែនឆ្នាំ ។ សម័យនោះ ព្រះអត្ថទស្សីទ្រង់ឃើញនូវប្រយោជន៍ដ៏ក្រៃលែង កើតឡើងក្នុងលោក ។ ទ្រង់បំពេញបារមី កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងសុទស្សនទេវី អគ្គមហេសីក្នុងរាជត្រកូលរបស់ព្រះបាទសាគរៈ ក្នុងនគរសោភណៈ ជានគរស្អាតក្រៃលែង ។ ព្រះពោធិសត្វ នៅក្នុងព្រះឧទរ ១០ ខែ ប្រសូតចាកព្រះឧទរព្រះជននី ត្រង់សុចិន្ទនរាជឧទ្យាន ។ ព្រះមហាបុរសប្រសូតចាកព្រះឧទរព្រះជននី ម្ចាស់ទ្រព្យទាំងឡាយ ក៏នាំគ្នាបាននូវកំណប់ទ្រព្យធំ ដែលកប់ទុកអស់កាលយូរ បន្តត្រកូលគ្នាមក ដោយហេតុនោះ ក្នុងថ្ងៃទទួលព្រះនាមរបស់ព្រះអង្គ ទើបព្រះមាតាបិតាថ្វាយព្រះនាមថា អត្ថទស្សី ទ្រង់គ្រងឃរាវាសវិស័យអស់ ៩ ម៉ឺនឆ្នាំ ទ្រង់មានប្រាសាទ ៣ មានក្លិនក្រអូបក្រៃលែង ឈ្មោះអមរគិរី ១ សុរគិរី ១ និងគិរិវាហនៈ ១[១] មានស្នំ ៣ ម៉ឺន ៣ ពាន់នាក់ មានព្រះនាងវិសាខាទេវីជាប្រធាន ។

កាលព្រះរាជឱរសព្រះនាមថា សេលកុមារ របស់ព្រះនាងវិសាខាទេវីប្រសូត ទ្រង់ឃើញនិមិត្ត ៤ ទ្រង់ឡើងកាន់ដំរីឈ្មោះសុទស្សនៈ យាងចេញ

---

១- បិដកខ្មែរជា អមរគិ ១ សុរគិ ១ ។

មហាភិនេស្រ្កមណ៍ ទ្រង់ព្រះផ្នួស មនុស្ស ៩ កោដិ ក៏បួសតាម ។ ព្រះមហាបុរសដែលបព្វជិតទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាម អស់ ៨ ខែ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់សោយមធុបាយាស ដែលមហាជននាំមកជាពលីដល់នាគីឈ្មោះសុចិន្ទ្រា នាគីមានសរីរៈគ្រប់ចំណែក ដែលមហាជនកំពុងឃើញ បានថ្វាយ មួយអន្លើដោយថាសមាស ទ្រង់ប្រថាប់គង់ក្នុងពេលថ្ងៃ ត្រង់ព្រៃសាលព្រឹក្ស ដែលប្រដាប់ដោយដើមឈើសារ ១០០ ដើម ក្នុងវេលាល្ងាច ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលស្តេចនាគឈ្មោះមហារុចិ ជាអ្នកគាប់ចិត្តក្នុងធម៌ថ្វាយដល់ព្រះអង្គ ហើយទ្រង់ចូលទៅកាន់មណ្ឌលពោធិព្រឹក្សឈ្មោះចម្បកៈ គឺដើមចម្ប៉ា ទ្រង់ក្រាលសន្ថតស្មៅទំហំ ៥៣ ហត្ថ គង់ប្រថាប់ពត់ភ្នែន ទ្រង់សម្រេចសម្ពោធិញ្ញាណ ទ្រង់បន្លឺព្រះឧទានថា

> កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយដូច្នេះ ។

ដែលព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ប្រព្រឹត្តមក ទ្រង់សម្ងំនៅក្បែរពោធិព្រឹក្ស ៧ សប្តាហ៍ ទ្រង់ទទួលអារាធនារបស់មហាព្រហ្ម ទ្រង់ឃើញភិក្ខុ ៩ កោដិ ដែលបួសជាមួយព្រះអង្គ ជាអ្នកអាចចាក់ធ្លុះអរិយធម៌បាន ទ្រង់យាងទៅតាមអាកាស ចុះត្រង់អនោមរាជឧទ្យាន ក្បែរអនោមនគរ កាលភិក្ខុទាំងនោះ

ចោមរោមហើយ ទ្រង់ប្រកាសធម្មចក្រក្នុងទីនោះឯង កាលនោះ ការត្រាស់ដឹងធម៌លើកទី ១ មានដល់សត្វមួយសែនកោដិ ។

តមកទៀត កាលព្រះមានព្រះភាគជាលោកនាយក យាងចារិកទៅក្នុងទេវលោក ទ្រង់សម្តែងធម៌ប្រោសទេវតាក្នុងទីនោះ ការសម្រេចធម៌លើកទី ២ មានដល់សត្វ ១ សែនកោដិ ។ កាលព្រះមានព្រះភាគ អត្ថទស្សីយាងចូលទៅកាន់នគរសោភណៈ ដូចព្រះមានព្រះភាគនៃយើង យាងទៅកាន់នគរកបិលពស្តុ ទ្រង់សម្តែងធម៌ប្រោស ការសម្រេចធម៌លើកទី ៣ មានហើយដល់សត្វ ១ សែនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមអត្ថទស្សី មានយសធំ ទ្រង់កម្ចាត់បង់ងងឹតធំ សម្រេចសម្ពោធិញ្ញាណ ដ៏ឧត្តម ។ ព្រះសម្ពុទ្ធត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ហើយញុំាងមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ ឲ្យឆ្អែតដោយទឹកអម្រឹត ។ ព្រះលោកនាថអង្គនោះ ទ្រង់មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងលើកទី ១ មានពួកសត្វចំនួនមួយសែនកោដិ ។ ក្នុងការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធ ទ្រង់ព្រះនាមអត្ថទស្សី ទ្រង់ត្រាច់ទៅកាន់ទេវចារិក ។ តមក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ

ចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់សម្ដែងព្រះធម៌ ក្នុងសម្នាក់ព្រះបិតា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តត្ថេវ** សេចក្ដីថា ក្នុងកប្បនោះឯង តែក្នុងទីនេះ វរកប្ប លោកបំណងយកថា ជាមណ្ឌកប្ប ។ កន្លងមក ខ្ញុំបានពោលក្នុងអដ្ឋកថា ព្រះបទុមុត្តរពុទ្ធវង្សថា ក្នុងកប្បណា មានព្រះពុទ្ធ ៣ ព្រះអង្គ កប្បនោះ ឈ្មោះថា វរកប្ប ព្រោះហេតុនោះ ទើបក្នុងទីនេះ វរកប្បលោកបំណងយកថា ជាមណ្ឌកប្ប ។ បទថា **និហាតូន** បានដល់ ទ្រង់កម្ចាត់ហើយ បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **សន្តោ** កែជា **សមានោ** ។ បទថា **អមតេន** បានដល់ ដោយផឹកអមតធម៌ គឺការសម្រេចមគ្គផល ។ បទថា **តប្បយិ** បានដល់ ឲ្យឆ្អែតហើយ អធិប្បាយថា ឲ្យឆ្អែតស្កប់ស្កល់ ។ បទថា **ទសសហស្សី** បានដល់ ម៉ឺនលោកធាតុ ។ បទថា **ទេវចារិកំ** សេចក្ដីថា ចារិកទៅក្នុងទេវលោក ដើម្បីទូន្មានទេវតាទាំងឡាយ ។

បានឮថា ក្នុងសុចន្ទកនគរ ព្រះសន្ទរាជឱរស និងឧបសន្តបុត្តបុរោហិតមិនឃើញសារៈក្នុងត្រៃវេទ លះលទ្ធិសម័យសព្វយ៉ាង ទើបដាក់បុគ្គលដែលឈ្លាសវាងវៃ និងក្លាហាន ៤ នាក់ ត្រង់ទ្វារទាំង ៤ របស់ព្រះនគរ ត្រាស់ថា ពួកអ្នកបើឃើញ ឬបានឮសមណៈក្ដី ព្រាហ្មណ៍ក្ដី ដែលជាបណ្ឌិតណាមួយ ចូរពួកអ្នកប្រាប់យើង ។ សម័យនោះ ព្រះលោកនាថអត្ថទស្សី យាងដល់សុចន្ទកនគរ ។ លំដាប់នោះ ពួកបុរសដែលមនុស្សទាំងនោះប្រាប់ហើយក៏នាំគ្នាទៅប្រាប់ការយាងមកក្នុងទីនោះ របស់ព្រះទសពល ដល់កុលបុត្តទាំង

២ នោះ ។ បន្ទាប់អំពីនោះ ព្រះសន្តរាជឱរស និងឧបសន្តបុត្តបុរោហិត ស្តាប់ដំណឹងនៃការមករបស់ព្រះតថាគត មានចិត្តត្រេកអរ មានបរិវារ ១០០០ ទៅទទួលព្រះទសពល ដែលមិនមានបុគ្គលស្មើ ថ្វាយបង្គំហើយ និមន្តថ្វាយមហាទាន ដែលមិនមានបុគ្គលធ្វើដូច ដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងថ្ងៃទី ៧ ស្តាប់ធម្មកថា មួយអន្លើដោយអ្នកនគរទាំងមូល ។ បានឮថា ថ្ងៃនោះ បុរស ៩ ម៉ឺន ៨ ពាន់ បានបួសជាឯហិភិក្ខុ ហើយសម្រេចអរហត្ត ព្រះមានព្រះភាគ ទ្រង់លើកបាតិមោក្ខសម្តែង ត្រង់កណ្តាលបរិស័ទ នេះជាសន្និបាតលើកទី ១ ។

កាលព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់ព្រះសេលត្ថេរឱរសរបស់ព្រះអង្គ ទ្រង់ញ៉ាំងបុរស ៨ ម៉ឺន ៨ ពាន់ឲ្យជ្រះថ្លា ហើយឲ្យបួសជាឯហិភិក្ខុភាវៈ សម្រេចអរហត្តហើយ ទ្រង់លើកបាតិមោក្ខឡើងសម្តែង នេះជាសន្និបាតលើកទី ២ ។ បន្ទាប់មកទៀត កាលទ្រង់សម្តែងធម៌ដល់ទេវតា និងមនុស្ស ក្នុងមាឃបុណ្ណមី ក្នុងមហាមង្គលសមាគម ទ្រង់ញ៉ាំងសត្វ ៧ ម៉ឺន ៨ ពាន់ឲ្យសម្រេចអរហត្ត ទ្រង់លើកបាតិមោក្ខឡើងសម្តែង នេះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហេសីអង្គនោះ មានសាវកសន្និបាត ( ការជួបជុំសាវក )
៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល
មានព្រះហឫទ័យស្ងប់ ប្រកបដោយតាទិគុណ គឺសន្និបាត
លើកទី ១ មានពួកព្រះខីណាស្រព ចំនួន ៩៨ ពាន់អង្គ

សន្និបាតលើកទី ២ មានពួកព្រះខីណាស្រព ចំនួន ៨៨ ពាន់អង្គ ។ សន្និបាតលើកទី ៣ មានពួកព្រះខីណាស្រព ចំនួន ៧៨ ពាន់អង្គ សុទ្ធតែមានព្រះហឫទ័យផុតស្រឡះ ឥតប្រកាន់ ប្រាសចាកមន្ទិល ជាអ្នកស្វែងរកគុណដ៏ធំ ដូច្នេះ ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វនៃយើង កើតជាព្រាហ្មណ-មហាសាល តាមលោកសន្មតថា ឈ្មោះសុសិមៈ ក្នុងនគរចម្បកៈ ព្រះពោធិសត្វនោះឯង លះនូវសម្បត្តិគ្រប់យ៉ាងដល់អ្នកក្រ អ្នកអនាថា អ្នកកំព្រា អ្នកធ្វើដំណើរផ្លូវឆ្ងាយជាដើម នៅក្បែរព្រៃហិមពាន្ត បួសជាតាបស ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយ ជាអ្នកមានឫទ្ធានុភាពច្រើន សម្ដែងនូវការមិនមានទោស និងការមានទោសនៃកុសលធម៌ និងអកុសល-ធម៌ទាំងឡាយ ដល់មហាជន រង់ចាំការកើតឡើងនៃព្រះពុទ្ធ ។

សម័យតមក កាលព្រះអត្ថទស្សីសម្ពុទ្ធ ជាលោកនាយក ទ្រង់កើតឡើងក្នុងលោកហើយ ទ្រង់ញុំាងភ្លៀង គឺអមតធម៌ឲ្យធ្លាក់ក្នុងកណ្ដាលបរិស័ទ ៨ ក្នុងសុទស្សនមហានគរ ព្រះពោធិសត្វស្ដាប់ធម៌របស់ព្រះសាស្ដាហើយ ក៏ទៅកាន់ទេវលោក នាំយកផ្កាទិព្វ មានមណ្ឌារវៈ បទុម បារិច្ឆត្តកៈជាដើម មកអំពីទេវលោក កាលសម្ដែងអានុភាពរបស់ខ្លួន ទើបប្រាកដខ្លួន ញុំាងភ្លៀងផ្កាឲ្យធ្លាក់ក្នុងទិសទាំង ៤ ដូចមហាមេឃធ្លាក់ក្នុងទ្វីប ៤ ហើយសាងវត្ថុដែលសម្រេចដោយផ្កា មានទីបូជា សសរខឿន បណ្ដាញមាស ដែលសម្រេចដោយផ្កាជាដើម ជាមណ្ឌបផ្កាដោយជុំវិញ បូជាព្រះទសពល ដោយ

ធត្រផ្កាមណ្ឌារវៈ ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វថា ក្នុងអនាគតកាល ឥសីនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងសម័យនោះ តថាគតកើតជាជដិល ឈ្មោះសុសិមៈ មានតបៈដ៏ខ្ពង់ខ្ពស់ ដែលគេសន្មតថា ជាបុគ្គលប្រសើរលើផែនដី ។ តថាគតបាននាំយកផ្កាមន្ទារវបុស្ស ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ អំពីទេវលោក មកបូជាចំពោះព្រះសម្ពុទ្ធ ។ ឯព្រះពុទ្ធជាមហាមុនី ព្រះនាមអត្ថទស្សីអង្គនោះ ទ្រង់បានព្យាករតថាគតថា តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី ១៨០០ ។ សត្វនេះ នឹងចេញអំពីបុរី ជាទីរីករាយឈ្មោះកបិលពស្តុ តម្កល់ព្យាយាម ។បេ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក្នុងកាលជាអនាគតយ៉ាងនោះដែរ ។

លុះតថាគតបានស្តាប់ភាសិត នៃព្រះលោកនាថអង្គនោះហើយ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមី ១០ ប្រការ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជដិលោ** បានដល់ ឈ្មោះថា ជដិល ព្រោះមានជដា គឺផ្នួងសក់ ។ បទថា **មហិយា សេដ្ឋសម្មតោ** សេចក្ដីថា ដែលលោកទាំងមូលសន្មតថា ជាបុគ្គលប្រសើរ ឧត្ដមក្រៃលែង ។

ព្រះមានព្រះភាគអត្ថទស្សីអង្គនោះ ទ្រង់មាននទនគរឈ្មោះសោភណៈ ព្រះបិតាព្រះនាម ព្រះបាទសាគរ ព្រះជននីព្រះនាម ព្រះនាងសុទស្សនា គូនៃអគ្គសាវកឈ្មោះសន្ដៈ ១ ឧបសន្ដៈ ១ ពុទ្ធុបដ្ឋាកឈ្មោះអភ័យ គូនៃអគ្គសាវិកាឈ្មោះធម្មា ១ សុធម្មា ១ ពោធិព្រឹក្សឈ្មោះចម្បក ព្រះសរីរៈកម្ពស់ ៨០ ហត្ថ ព្រះរស្មីនៃព្រះសរីរៈផ្សាយទៅដោយជុំវិញ ប្រមាណមួយយោជន៍សព្វកាល ព្រះជន្មាយុមួយសែនឆ្នាំ អគ្គមហេសីព្រះនាមថាវិសាខា ព្រះរាជឱរសព្រះនាមថាសេលៈ ចេញអភិនេស្រ្កមណ៍ដោយយាន គឺដំរី ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហេសី ព្រះនាមអត្ថទស្សី មានទីក្រុងឈ្មោះសោភណៈ មានព្រះមហាក្សត្រ ព្រះនាមសាគរៈ ( ជាព្រះបិតា ) មានព្រះជននីព្រះនាមសុទស្សនា ។ ព្រះមហេសី ព្រះនាមអត្ថទស្សី មានអគ្គសាវកពីរអង្គ គឺព្រះសន្ដៈ ១ ព្រះឧបសន្ដៈ ១ មានភិក្ខុជាឧបដ្ឋាកឈ្មោះអភយៈ ។ មានព្រះថេរីឈ្មោះធម្មា ១ សុធម្មា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា ចម្បកព្រឹក្ស ។ ឯព្រះពុទ្ធអង្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ មានកម្ពស់ ៨០ ហត្ថ ទ្រង់រុងរឿង ហាក់ដូចដើមសាលរាជព្រឹក្ស ឬដូចព្រះចន្ទពេញវង់ ។ រស្មី

ជាប្រក្រតីនៃព្រះពុទ្ធអង្គនោះ ច្រើនរយកោដិ តែងផ្សាយទៅកាន់ទិសទាំង ១០ ទាំងខាងលើ ទាំងខាងក្រោម ចម្ងាយមួយយោជន៍សព្វៗ កាល ។ ម្យ៉ាងទៀត ព្រះពុទ្ធអង្គនោះ ប្រសើរជាងជន ខ្ពង់ខ្ពស់ជាងសត្វទាំងពួង ជាអ្នកប្រាជ្ញ មានបញ្ញាចក្ខុស្ថិតនៅក្នុងមនុស្សលោកអស់មួយសែនឆ្នាំ ។ ព្រះពុទ្ធនោះ ទ្រង់សម្តែងពន្លឺថ្លឹងពុំបាន ញុំាងមនុស្សលោក ព្រមទាំងទេវលោកឲ្យរុងរឿង ហើយទ្រង់ដល់នូវអនិច្ចតាធម៌ ដូចជាភ្លើងអស់កំញមដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧឡុរាជាវ បុណ្ណោ** សេចក្តីថា ដូចព្រះចន្ទដែលជាស្តេចនៃផ្កាយ បរិបូណ៌ប្រាសចាកមន្ទិល ក្នុងសារទរដូវ ។ បទថា **ធាតុកា** សេចក្តីថា កើតឡើងតាមប្រក្រតី មិនមែនតាមអធិដ្ឋាន កាលណាព្រះមានព្រះភាគទ្រង់បំណាង កាលនោះ ទ្រង់ផ្សាយព្រះរស្មីទៅក្នុងចក្កវាឡច្រើនសែនកោដិ ។ បទថា **រំសិ** បានដល់ រស្មីទាំងឡាយ ។ បទថា **ឧបាទានសង្ខយា** បានដល់ ព្រោះអស់ឧបាទាន ។ ព្រះមានព្រះភាគអង្គនោះទ្រង់រម្លត់ខន្ធបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ព្រោះអស់ឧបាទាន ៤ ដូចភ្លើងរលត់ ព្រោះអស់នូវកំញម ព្រះធាតុទាំងឡាយរបស់ព្រះអង្គ ផ្សាយទៅកាន់ទីផ្សេងៗ ព្រោះទ្រង់អធិដ្ឋាន ។ ពាក្យដ៏សេស ក្នុងគាថាទាំងឡាយមានអត្ថងាយហើយ ៕

**អដ្ឋកថាអត្ថទស្សិពុទ្ធវង្សទី ១៤ ចប់**

# សុត្តន្តបិដក

## ធម្មទស្សីពុទ្ធវង្សទី ១៥

[ ១៦ ] ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមធម្មទស្សី មានយសធំ ទ្រង់កម្ចាត់បង់ងងឹតអន្ធការ ហើយញ៉ាំងមនុស្សលោក ព្រមទាំងទេវលោក ឲ្យរុងរឿង ។ ការត្រាស់ដឹងលើកទី ១ មានពួកសត្វមួយសែនកោដិ ក្នុងការញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ នៃព្រះធម្មទស្សីនោះ ទ្រង់មានតេជះប្ញទ្ធិពុំបាន ។ ការត្រាស់ដឹងលើកទី ២ មានសត្វចំនួន ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធព្រះនាមធម្មទស្សី ទ្រង់ទូន្មានឥសីឈ្មោះសញ្ជយៈ ។ ការត្រាស់ដឹងលើកទី ៣ មានសត្វចំនួន ៨០ កោដិ ក្នុងកាលដែលសក្កទេវរាជ ព្រមទាំងបរិស័ទ ចូលទៅគាល់ព្រះធម្មទស្សី ទ្រង់ជានាយក ។ ព្រះធម្មទស្សីនោះ ជាទេវតាក្រៃលែងជាងទេវតា មានសាវកសន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រព មានមន្ទិលទៅប្រាសហើយ មានព្រះហឫទ័យស្ងប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រពមួយពាន់កោដិ ក្នុងវេលាដែលព្រះពុទ្ធព្រះនាមធម្មទស្សី ទ្រង់ចូលកាន់វស្សា ក្នុងអារាមឈ្មោះសរណៈ ។ សន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ១០០ កោដិ ក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ ស្ដេចចុះចាកទេវលោក មកកាន់មនុស្សលោក ។ មួយទៀត សន្និបាតលើកទី ៣ មានព្រះខីណាស្រព ចំនួន ៨០ កោដិ ក្នុងវេលាដែលព្រះពុទ្ធ

ទ្រង់ប្រកាសនូវពុតង្គគុណទាំងឡាយ ។ ក្នុងសម័យនោះ តថាគត កើតជាព្រះឥន្ទ ឈ្មោះបុរិន្ទទ: បានបូជាព្រះពុទ្ធជាម្ចាស់ ដោយគ្រឿងក្រអូប ផ្កាកម្រង និងតូរ្យតន្ត្រីទិព្វ ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ចំកណ្តាលពួកទេវតា ហើយព្យាករតថាគតថា ក្នុងកប្បទី ១៨០០ ទេវរាជនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពីបុរី ជាទីគួរត្រេកអរ ឈ្មោះកបិលពស្តុ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់នៃ អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅឯស្ទឹង នេរញ្ជរា ។ ព្រះពុទ្ធជិនស្រីអង្គនោះ បានឆាន់បាយាសទៀបឆ្នេរ ស្ទឹងនេរញ្ជរា ហើយនឹងត្រឡប់ទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះជិនស្រី មានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះតថាគតនេះ ព្រះ នាមមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ទេវរាជនេះនឹងបាន ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ នឹងជាអគ្គសាវក ជាអ្នកមិនមានអាសវៈ មាន រាគៈអស់ហើយ មានចិត្តស្ងប់ម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជា ឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះខេមា- ថេរី ១ ព្រះឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា ជាអ្នកមិន

មានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា អសុត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ឈ្មោះហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីការនេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើហើយ ក៏រីករាយថា ព្រះឥន្ទនេះ ជាពូជពន្ធកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានយ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតម ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះឯង ។ តថាគត លុះបានស្តាប់ភាសិតនៃព្រះជិនស្រីអង្គនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ។ ព្រះសាស្តា

ព្រះនាមធម្មទស្សី មានទីក្រុងឈ្មោះសរណៈ មានមហាក្សត្រព្រះនាមសរណៈជាព្រះបិតា មានព្រះជននីព្រះនាមសុនន្ទា ។ ព្រះធម្មទស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋាន អស់ ៨ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ខ្នង គឺប្រាសាទឈ្មោះអរជៈ ១ ប្រាសាទឈ្មោះវិរជៈ ១ ប្រាសាទឈ្មោះសុទស្សនៈ ១ ។ ពួកនារីចំនួន ៤០ ពាន់ សឹងប្រដាប់ខ្លួនយ៉ាងសមសួន នារី (ជាអគ្គមហេសី) ឈ្មោះវិចិកោលី ព្រះរាជបុត្រឈ្មោះបុញ្ញវឌ្ឍនៈ ។ ព្រះធម្មទស្សីជាបុរសដ៏ប្រសើរ ទ្រង់ឃើញនូវនិមិត្ត ៤ ហើយ ទ្រង់ចេញទៅទាំងប្រាសាទ ទៅប្រព្រឹត្តព្យាយាមអស់ ៧ ថ្ងៃ ។ ព្រះពុទ្ធព្រះនាមធម្មទស្សី ប្រសើរជាងពួកជន មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន ។ ព្រះសាស្តាព្រះនាមធម្មទស្សី មានព្រះបទុមត្ថេរ ១ ព្រះបុស្សទេវត្ថេរ ១ ជាអគ្គសាវ័ក ព្រះសុទត្តត្ថេរជាឧបដ្ឋាក ។ មានព្រះខេមាថេរី ១ ព្រះសច្ចនាមាថេរីជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា តិម្ពជាលព្រឹក្ស ។ សុភទ្ទគហបតី ១ កដិស្សហគហបតី ១ ជាអគ្គឧបដ្ឋាក នាងសាឡិសា ១ នាងកឡិស្សា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ទ្រង់មានកម្ពស់ ៨០ ហត្ថ ទ្រង់រុងរឿងក្រៃលែងដោយតេជៈ ក្នុងមួយ

ម៉ឺនលោកធាតុ ។ ដើមសាលរាជព្រឹក្ស មានផ្ការីកស្គុះស្គាយល្អ ផ្ទេកបន្ទោរលើអាកាស ព្រះអាទិត្យនាថ្ងៃត្រង់ រុងរឿងល្អ យ៉ាងណាមិញ ព្រះពុទ្ធអង្គនោះ ទ្រង់រុងរឿងល្អយ៉ាងនោះ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានតេជះប្រឹងពុំបាន មានជីវិតដ៏ស្មើល្អ ព្រះពុទ្ធមានបញ្ញាចក្ខុ ទ្រង់ស្ថិតនៅក្នុងលោក អស់មួយសែនឆ្នាំ ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ទ្រង់សម្តែងរស្មី ធ្វើសាសនាមិនឲ្យមានមន្ទិល ដូចព្រះចន្ទកាលរុងរឿងព្ធដ៏អាកាស ហើយបរិនិព្វាន ។ ព្រះធម្មទស្សី ទ្រង់មានព្យាយាមធំ ទ្រង់បរិនិព្វានក្នុងអារាមឈ្មោះកេសៈ ព្រះស្តូបដ៏ប្រសើរនោះ របស់ព្រះពុទ្ធអង្គនោះឯង មានកម្ពស់ ៣ យោជន៍ ។

ធម្មទស្សីពុទ្ធវង្សទី ១៥ ចប់

# អដ្ឋកថា

## ធម្មទស្សីពុទ្ធវង្សទី ១៤

កាលព្រះអត្ថទស្សីសម្មាសម្ពុទ្ធបរិនិព្វានហើយ អន្តរកប្បកន្លងទៅហើយ កាលសត្វទាំងឡាយមានអាយុរាប់មិនបាន ហើយថយចុះមកតាមលំដាប់ រហូតដល់មានអាយុមួយសែនឆ្នាំ ព្រះសាស្តាព្រះនាមធម្មទស្សី ទ្រង់ធ្វើលោកឲ្យភ្លឺ ទ្រង់កម្ចាត់មន្ទិល មានលោកៈជាដើម ជាលោកនាយកឯក ទ្រង់កើតឡើងក្នុងលោក ព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមីទាំងឡាយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងសុនន្ទាទេវី អគ្គមហេសីរបស់ព្រះបាទសរណៈ ជាទីពឹងនៃលោកទាំងពួង ក្នុងសរណនគរ គ្រប់កំណត់ទសមាស ទ្រង់ក៏ប្រសូតចាកព្រះឧទរព្រះជននី ក្នុងសរណរាជឧទ្យាន ដូចព្រះចន្ទពេញវង់គោចរចេញពីស្រទាប់ពពកក្នុងរដូវវស្សា ។ កាលព្រះមហាបុរស ប្រសូតចាកព្រះឧទរព្រះជននីប៉ុណ្ណោះ វោហារដែលមិនប្រពៃតាមធម៌ក្នុងសាស្ត្រ និងគម្ពីរដែលពោលអំពីអធិករណ៍ក៏វិនាសទៅឯង តាំងនៅតែការពោលដែលប្រពៃតាមធម៌ប៉ុណ្ណោះ ដោយហេតុនោះ ក្នុងថ្ងៃថ្វាយព្រះនាមរបស់ព្រះអង្គ ទើបព្រះជនកព្រះជននីថ្វាយព្រះនាមថា ធម្មទស្សី ទ្រង់នៅជាយរាវាសវិស័យ អស់ ៨ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ឈ្មោះអរជៈ ១ វិរជៈ ១ សុទស្សនៈ ១ មាននារី ២ សែន ២ ម៉ឺនជាស្នំ មានព្រះនាងវិចិកោឡិទេវីជាប្រធាន ។

កាលរាជឱរសរបស់ព្រះនាងវិចិកោឡិទេវី ឈ្មោះ បុញ្ញវឌ្ឍនៈប្រសូតព្រះមហាបុរសទ្រង់ឃើញនិមិត្ត ៤ ទ្រង់ជាសុខុមលជាតិក្រៃលែងដូចទេវកុមារ

សោយសម្បត្តិដូចទេវសម្បត្តិ ទ្រង់ក្រោកឡើងក្នុងមជ្ឈិមយាម ប្រថាប់លើសិរីសេយ្យាសនៈ ទ្រង់ឃើញអាការចម្លែករបស់ស្រីស្នំដែលដេកលក់ ទ្រង់កើតសេចក្ដីសង្វេគ កើតចិត្តគិតចេញមហាភិនេស្ក្រមណ៍ ក្នុងលំដាប់ចិត្តុប្បាទនោះឯង សុទស្សនប្រាសាទរបស់ព្រះអង្គ ក៏សណ្ដកហោះឡើងទៅលើអាកាស ដែលមានចតុរង្គសេនាចោមរោមហើយ លយលឿនទៅ ដូចព្រះអាទិត្យដួងទី ២ និងដូចទេវវិមាន ហើយតាំងនៅក្បែរពោធិព្រឹក្ស ឈ្មោះដើមរត្តកុរវកៈ បានឮថា ព្រះមហាបុរសទទួលសំពត់កាសាវៈ ដែលមហាព្រហ្មថ្វាយ ទ្រង់ព្រះផ្នួសហើយ ចុះអំពីប្រាសាទ ប្រថាប់ឈរមិនឆ្ងាយ ។ ប្រាសាទនោះក៏អណ្ដែតទៅតាមអាកាស ធ្វើពោធិព្រឹក្សឲ្យនៅខាងក្នុង ហើយធ្លាក់ចុះលើផែនដី សូម្បីស្រីស្នំ និងបរិវារ ក៏ចុះអំពីប្រាសាទ ដើរទៅកន្លះគាវុត ក៏ឈប់ក្នុងទីនោះ វៀរស្រីស្នំ បរិចារិកា និងស្រីបម្រើរបស់ស្នំទាំងនោះ មនុស្សទាំងអស់ក៏បួសតាមព្រះរាជា ។ ភិក្ខុទាំងឡាយ មានចំនួនដល់ទៅមួយសែនកោដិ ។

លំដាប់នោះ ព្រះធម្មទស្សីពោធិសត្វ បំពេញព្យាយាម ៧ ថ្ងៃ សោយមធុបាយាស ដែលព្រះនាងវិចិកោឡិទេវីថ្វាយ ទ្រង់សម្រាកពេលថ្ងៃ នាព្រៃពុទ្រា វេលាល្ងាច ទ្រង់ទទួលស្មៅ ៨ ក្ដាប់ ដែលអ្នកយាមស្រូវដំណើបឈ្មោះសិរិវឌ្ឍនៈថ្វាយ ហើយយាងទៅកាន់ពោធិព្រឹក្ស ឈ្មោះពិម្ពិជាល ទ្រង់លាតសន្ថតស្មៅទំហំ ៥៣ ហត្ថ ទ្រង់ត្រាស់ដឹងសព្វញ្ញុតញ្ញាណត្រង់ពោធិព្រឹក្សនោះ ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ រវល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏
អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយ
តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ
ដូច្នេះ ។

ហើយទ្រង់សម្ងំនៅក្បែរៗ ពោធិព្រឹក្សអស់ ៧ សប្តាហ៍ ទ្រង់ទទួលអារាធនារបស់មហាព្រហ្ម ទ្រង់ជ្រាបថា ភិក្ខុមួយសែនកោដិ ដែលបួសជាមួយព្រះអង្គ អាចចាក់ធ្លុះព្រះសទ្ធម្មបាន ទ្រង់យាងទៅដោយព្រះបាទ អស់ចម្ងាយផ្លូវ ១៨ យោជន៍ ក្នុងពេលមួយថ្ងៃប៉ុណ្ណោះ ដល់ព្រៃឥសិបតនៈ កាលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់ក៏ប្រកាសធម្មចក្កក្នុងឥសិបតនៈនោះ ការសម្រេចធម៌លើកទី ១ មានដល់ភិក្ខុមួយសែនកោដិ ១ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមធម្មទស្សី មាន
យសធំ ទ្រង់កម្ចាត់បង់ងងឹតអន្ធការ ហើយញុំាងមនុស្សលោក
ព្រមទាំងទេវលោក ឲ្យរុងរឿង ។ ការត្រាស់ដឹងលើកទី ១
មានពួកសត្វមួយសែនកោដិ ក្នុងការញុំាងធម្មចក្ក ឲ្យប្រព្រឹត្ត
ទៅ នៃព្រះធម្មទស្សីនោះ ទ្រង់មានតេជះប្រឹងពុំបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តមន្ធការំ** សេចក្តីថា បានដល់អន្ធការ គឺមោហៈ ដែលរាប់ថា ងងឹត ។

កាលព្រះរាជាព្រះនាមសញ្ជ័យ ក្នុងនគរឈ្មោះតគរៈ ទ្រង់ឃើញទោសក្នុងកាម និងគុណដ៏ក្រៃមក្នុងនេក្ខម្មៈ ទើបទ្រង់ព្រះផ្នួសជាឥសី មនុស្ស ៩០ កោដិបួសតាមព្រះរាជា ជនទាំងនោះបានអភិញ្ញា ៥ និងសមាបត្តិ ៨ ទាំងអស់ កាលនោះ ព្រះធម្មទស្សីសាស្តា ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់ជនទាំងនោះ ទើបយាងទៅតាមអាកាស ដល់អាស្រមបទរបស់សញ្ជយតាបសហើយ ទ្រង់ប្រថាប់ឈរក្នុងអាកាស ទ្រង់សម្តែងធម៌ដ៏សមគួរដល់អធ្យាស្រ័យនៃតាបសទាំងនោះ ទ្រង់ញ៉ាំងធម្មចក្ខុឲ្យកើតឡើង នុ៎ះជាការសម្រេចធម៌លើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ការត្រាស់ដឹងលើកទី ២ មានសត្វចំនួន ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធព្រះនាមធម្មទស្សី ទ្រង់ទូន្មានឥសី ឈ្មោះសញ្ជយៈ ដូច្នេះ ។

កាលសក្កទេវរាជបំណងនឹងស្តាប់ធម៌ព្រះទសពល ទើបយាងចូលទៅគាល់ ការសម្រេចធម៌លើកទី ៣ មានដល់សត្វ ៨០ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ការត្រាស់ដឹងលើកទី ៣ មានសត្វចំនួន ៨០ កោដិ ក្នុងកាលដែលសក្កទេវរាជ ព្រមទាំងបរិស័ទ ចូលទៅគាល់ព្រះធម្មទស្សី ទ្រង់ជានាយក ដូច្នេះ ។

កាលព្រះធម្មទស្សីសម្ពុទ្ធ ទ្រង់បបួលព្រះបទុមកុមារ និងព្រះផុស្សទេវកុមារ ដែលជាព្រះកនិដ្ឋភាតាមាតាដទៃ មួយអន្លើដោយបរិវារ ក្នុង

សរណនគរ ទ្រង់ធ្វើសុទ្ធិបវារណា កណ្តាលភិក្ខុមួយសែនកោដិ[១] ដែលបួសខាងក្នុងវស្សានោះ នេះជាសន្និបាតលើកទី ១ បន្ទាប់មកទៀត កាលព្រះមានព្រះភាគយាងចុះអំពីទេវលោក ភិក្ខុ ១០០ កោដិប្រជុំគ្នា នេះជាសន្និបាតលើកទី ២ កាលព្រះមានព្រះភាគ ទ្រង់ប្រកាសគុណានិសង្សនៃធុតង្គ ១៣ នៅក្នុងសុទស្សនារាម ទ្រង់ស្ថាបនាមហាសាវកឈ្មោះហារិតៈក្នុងតំណែងឯតទគ្គៈ ទ្រង់លើកបាតិមោក្ខសម្តែងកណ្តាលភិក្ខុ ៨០ កោដិនុ៎ះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះធម្មទស្សីនោះ ជាទេវតាក្រៃលែងជាងទេវតា មានសាវកសន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រព មានមន្ទិលទៅប្រាសហើយ មានព្រះហឫទ័យស្ងប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រពមួយពាន់កោដិ ក្នុងវេលាដែលព្រះពុទ្ធព្រះនាមធម្មទស្សី ទ្រង់ចូលកាន់វស្សាក្នុងអារាម ឈ្មោះសរណៈ ។ សន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ១០០ កោដិ ក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ ស្តេចចុះចាកទេវលោក មកកាន់មនុស្សលោក ។ មួយទៀត សន្និបាតលើកទី ៣ មានព្រះខីណាស្រពចំនួន ៨០ កោដិ ក្នុងវេលាដែលព្រះពុទ្ធ ទ្រង់ប្រកាសនូវធុតង្គគុណទាំងឡាយ ដូច្នេះ ។

---

១- បិដកខ្មែរជា ១ ពាន់កោដិ ។

កាលនោះ ព្រះពោធិសត្វនៃយើងជាសក្កទេវរាជ ដែលទេវតាក្នុងទេវលោកទាំង ២ ចោមរោមហើយ យាងមកបូជាព្រះតថាគត ដោយរបស់ទិព្វមានគ្រឿងប្រអប់ និងផ្កាជាដើម និងទិព្វតន្ត្រី ព្រះសាស្តាអង្គនោះទ្រង់ព្យាករព្រះពោធិសត្វថា ក្នុងអនាគតកាល សក្កទេវរាជនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ក្នុងសម័យនោះ តថាគតកើតជាព្រះឥន្ទ ឈ្មោះបុរិន្ទទៈ បានបូជាព្រះពុទ្ធជាម្ចាស់ ដោយគ្រឿងក្រអូប ផ្កាកម្រង និងតូរ្យតន្ត្រីទិព្វ ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ចំកណ្តាលពួកទេវតា ហើយព្យាករតថាគតថា ក្នុងកប្បទី ១៨០០ ទេវរាជនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពីបុរី ជាទីគួរត្រេកអរ ឈ្មោះកបិលពស្តុ ទៅតម្កល់ព្យាយាម ។បេ។ ពួកមនុស្សកាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ។ តថាគតលុះបានស្តាប់ភាសិត នៃព្រះជិនស្រីអង្គនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ដូច្នេះ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់មាននគរឈ្មោះសរណៈ ព្រះបិតាព្រះនាមសរណៈ ព្រះមាតាព្រះនាមសុនន្ទា គូនៃអគ្គសាវកឈ្មោះបទុមៈ ១

ផុស្សទេវៈ ១ ពុទ្ធុបដ្ឋាកឈ្មោះសុនេត្តៈ[១] គូនៃអគ្គសាវិកា ឈ្មោះខេមា ១ សច្ចនាមា ១ ពោធិព្រឹក្សឈ្មោះពិម្ពិជាល ព្រះសរីរៈកម្ពស់ ៨០ ហត្ថ ព្រះជន្មាយុមួយសែនឆ្នាំ អគ្គមហេសីព្រះនាមវិចិកោឡិទេវី ឱរសព្រះនាមបុញ្ញវឌ្ឍនៈ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយប្រាសាទ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសាស្តា ព្រះនាមធម្មទស្សី មានទីក្រុងឈ្មោះសរណៈ មានមហាក្សត្រព្រះនាមសរណៈជាព្រះបិតា មានព្រះជននីព្រះនាមសុនន្ទា ព្រះសាស្តាព្រះនាមធម្មទស្សី មានព្រះបទុមត្ថេរ ១ ព្រះបុស្សទេវត្ថេរ ១ ជាអគ្គសាវ័ក ព្រះសុទត្តត្ថេរជាឧបដ្ឋាក ។ មានព្រះខេមាថេរី ១ ព្រះសច្ចនាមាថេរីជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា តិម្ពជាលព្រឹក្ស ។ ព្រះពុទ្ធនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ទ្រង់មានកម្ពស់ ៨០ ហត្ថ ទ្រង់រុងរឿងក្រៃលែងដោយតេជះ ក្នុងមួយម៉ឺនលោកធាតុ ។ ដើមសាលរាជព្រឹក្ស មានផ្ការីកស្គុះស្គាយល្អ ផ្ទេកបន្ទោរលើអាកាស ព្រះអាទិត្យនាថ្ងៃត្រង់ រុងរឿងល្អ យ៉ាងណាមិញ ព្រះពុទ្ធអង្គនោះ ទ្រង់រុងរឿងល្អយ៉ាងនោះ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានតេជះប្រឹងពុំបាន មានជីវិតដ៏ស្មើល្អ ព្រះពុទ្ធមានបញ្ញាចក្ខុ ទ្រង់ស្ថិតនៅក្នុងលោក

១- បិដកខ្មែរជា សុទត្តត្ថេរ ។

*អស់មួយសែនឆ្នាំ ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ទ្រង់សម្ដែងរស្មី ធ្វើសាសនាមិនឲ្យមានមន្ទិល ដូចព្រះចន្ទ កាលវង់វៀងឮដ៏អាកាស ហើយបរិនិព្វាន ដូច្នេះ ។*

*ដើមពិម្ពិជាលៈ ឈ្មោះថា ដើមរត្តកុរវកៈ ក្នុងគាថានេះ ។ បទថា* **ឧសសហស្សម្ហិ ធាតុយា** *គឺ* **ឧសហស្សិយា លោកធាតុយា** *សេចក្ដីថា ក្នុងម៉ឺនលោកធាតុ ។ បទថា* **វិដ្ឋវ** *គឺ* **វិដ្ឋលតា វិយ** *សេចក្ដីថា ដូចផ្ទេក-បន្ទោរ ។ បទថា* **ឧបសោភថ** *សេចក្ដីថា ព្រះមានព្រះភាគអង្គនោះ ល្អដូចផ្ទេកបន្ទោរ និងដូចព្រះអាទិត្យក្នុងពេលថ្ងៃត្រង់ ដូច្នេះ ។ បទថា* **សមកំ** *សេចក្ដីថា ព្រះជន្មាយុរបស់ព្រះអង្គ ស្មើគ្នានឹងនរសត្វទាំងពួង ។ បទថា* **ចវិ** *បានដល់ ឃ្លាតហើយ ។ បទថា* **ចន្ទោវ** *សេចក្ដីថា ដូចព្រះចន្ទឃ្លាតចាកមេឃ បានឮថា ព្រះមានព្រះភាគធម្មទស្សីទ្រង់បរិនិព្វាន ក្នុងវិហារកេសារាម នគរសោលវតី ។ ពាក្យដ៏សេស ក្នុងគាថាគ្រប់អន្លើ ជាក់ច្បាស់ហើយ ។៕*

**អដ្ឋកថាធម្មទស្សីពុទ្ធវង្សទី ១៥ ចប់**

# សុត្តន្តបិដក

## សិទ្ធត្ថពុទ្ធវង្សទី ១៦

[ ១៧ ] ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ បីដូចព្រះអាទិត្យរះឡើង ។ ព្រះសិទ្ធត្ថៈអង្គនោះ ទ្រង់ដល់នូវសម្ពោធិញ្ញាណហើយ ចម្លងមនុស្ស ព្រមទាំងទេវតា បង្ហុរភ្លៀង គឺធម៌ ហើយញុំាងមនុស្ស ព្រមទាំងទេវតា ឲ្យរលត់ទុក្ខ ។ ព្រះអង្គមានតេជះប្រឹងពុំបាន ទ្រង់មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងលើកទី ១ មានពួកសត្វមួយសែនកោដិ ។ តមក ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ ក្នុងកាលព្រះសម្ពុទ្ធទ្រង់ទូងស្គរ គឺធម៌ ក្នុងដែនឈ្មោះភីមៈ ។ ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធប្រសើរជាងជនអង្គនោះ ទ្រង់សម្តែងធម៌ ទៀបក្នុំឈ្មោះវេភារៈ ។ ព្រះមហេសីព្រះនាមសិទ្ធត្ថៈ មានសន្និបាត ៣ លើក សុទ្ធតែព្រះខីណាស្រព ឥតមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ ឋានៈ គឺសន្និបាតទាំង ៣ ក្នុងសមាគមនៃព្រះខីណាស្រព ដែលមិនមានមន្ទិលទុំ៖ មានចំនួន ១០០ កោដិម្តង ៩០ កោដិម្តង ៨០ កោដិម្តង ។ សម័យនោះ តថាគតជាតាបសឈ្មោះមង្គលៈ មានតេជះខ្ពង់ខ្ពស់ គេគ្របសង្កត់មិនបាន ជាអ្នកប្រកបដោយកម្លាំងនៃអភិញ្ញា ។ តថាគតបាននាំផ្លែព្រីង មកថ្វាយព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ

ព្រះសម្ពុទ្ធទ្រង់ទទួលយកហើយ ទ្រង់បានត្រាស់ព្រះតម្រាស់នេះថា អ្នកទាំងឡាយ ចូរមើលជដិលតាបស ដែលមានតបៈខ្ពង់ខ្ពស់នេះចុះ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី ៩៤ អំពីកប្បនេះទៅ ។ សត្វនេះ នឹងចេញពីបុរី ឈ្មោះកបិលពស្តុ ជាទីរីករាយ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចត្រឡប់ចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះជិនស្រីទ្រង់មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះគោតមនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ខេមាថេរី ១ ព្រះឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះ

មានជោគនោះ ហៅថា អសុរត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថា-ឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់យសអង្គនោះ មានព្រះជន្មាយុមួយរយឆ្នាំ ។ មនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ក៏រីករាយថា តាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃ អបអរ ធ្វើអញ្ជលី នមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់ទៅកាន់កំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណា ។ ពួកយើងទាំងអស់ បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះដែរ ។ តថាគត លុះស្តាប់ភាសិតនៃព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ។ ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានទីក្រុងឈ្មោះវេភារៈ ព្រះមហាក្សត្រ ព្រះនាមឧទេនៈជាព្រះបិតា ព្រះជននីព្រះនាមសុផស្សា ។ ព្រះសិទ្ធត្ថៈនោះ គ្រប់គ្រងគេហដ្ឋាន

អស់មួយម៉ឺនឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺកោកាស-ប្រាសាទ ១ ឧប្បលប្រាសាទ ១ កោកនុទប្រាសាទ ១ ។ នារី ៤៨០០០ រូប សុឹងមានខ្លួនតាក់តែងល្អ នារីជាអគ្គមហេសី ព្រះនាមសុមនា ព្រះរាជបុត្រព្រះនាមអនុបមៈ ។ ព្រះជិនស្រី ទ្រង់ឃើញនិមិត្ត ៤ យ៉ាង ក៏ចេញទៅដោយ-វ តម្កល់ព្យាយាមអស់ ១០ ខែគត់ ។ ព្រះលោកនាយកព្រះនាមសិទ្ធត្ថៈ មានព្យាយាមធំប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានព្រះសម្ពលត្ថេរ ១ ព្រះសុមិត្តត្ថេរ ១ ជាអគ្គសាវក ភិក្ខុឈ្មោះរេវតៈជាឧបដ្ឋាក ។ ព្រះសីវលាថេរី ១ ព្រះសុរាមាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា កណ្ណិការព្រឹក្ស ។ សុប្បិយគហបតី ១ សមុទ្ទ-គហបតី ១ ជាអ្នកបម្រើដ៏ប្រសើរ រម្មាឧបាសិកា ១ សុរម្មា-ឧបាសិកា ១ ជាស្រីបម្រើប្រសើរ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៦០ ហត្ថ ទ្រង់ខ្ពស់ដល់អាកាស ប្រាកដស្មើដោយគ្រឿងបូជាមាស ទ្រង់រុងរឿង អស់មួយម៉ឺនលោកធាតុ ។ ព្រះពុទ្ធអង្គ

នោះ ទ្រង់ស្មើព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ឥតមានបុគ្គលប្ដឹងបាន ឥតមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់មានចក្ខុ ស្ថិតនៅក្នុងលោក អស់មួយសែនឆ្នាំ ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ទ្រង់សម្ដែងពន្លឺភ្លឺត្រចះ ហើយញ៉ាំងសាវ័ក ឲ្យសាយកាយទៅ ទ្រង់ក្រសាលដោយសមាបត្តិដ៏ប្រសើរ ហើយបរិនិព្វាន ។ ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងអនោមារាម ព្រះស្តូបដ៏ប្រសើរនៃព្រះអង្គនោះ មានកម្ពស់ ៤ យោជន៍ ប្រតិស្ឋាននៅក្នុងអនោមារាមនោះឯង ។

## សិទ្ធត្ថពុទ្ធវង្សទី ១៦ ចប់

# អដ្ឋកថា

## សិទ្ធត្ថពុទ្ធវង្សទី ១៦

កាលព្រះមានព្រះភាគធម្មទស្សីបរិនិព្វានហើយ សាសនារបស់ព្រះអង្គក៏អន្តរធានទៅ រាប់អំពីកប្បនោះកន្លងទៅ ១៧០៦ កប្ប ក្នុងកប្បមួយរាប់អំពីកទ្ទកប្បនេះទៅ ៩៤ កប្ប មានព្រះសាស្តាមួយអង្គ ព្រះនាមសិទ្ធត្ថៈ ទ្រង់សម្រេចប្រយោជន៍ដ៏ឧត្តម បំពេញប្រយោជន៍ដល់លោក ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយក ព្រះនាម
សិទ្ធត្ថៈ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ បីដូចព្រះអាទិត្យរះ
ឡើង ដូច្នេះ ។

ព្រះពោធិសត្វអង្គនេះ ទ្រង់ក៏បំពេញបារមីទាំងឡាយ ហើយកើតក្នុងស្ថានតុសិត ចុតិអំពីស្ថានតុសិតហើយ បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងសុផស្សាទេវី អគ្គមហេសីរបស់ព្រះបាទឧទេន ក្រុងវេការៈ គ្រប់កំណត់ទសមាស ក៏ប្រសូតចាកព្រះឧទររបស់ព្រះជននី ត្រង់វិរិយរាជឧទ្យាន កាលមហាបុរសប្រសូតហើយ ការងារដែលមនុស្សទាំងឡាយចាប់ផ្តើម និងប្រយោជន៍ដែលប្រាថ្នាក៏សម្រេច ព្រោះហេតុនោះ ព្រះញាតិទាំងឡាយរបស់ព្រះអង្គ ក៏ថ្វាយព្រះនាមថា សិទ្ធត្ថៈ ។ ទ្រង់នៅជាឃរាវាស អស់មួយម៉ឺនឆ្នាំ ក្នុងប្រាសាទ ៣ គឺកោកាសៈ ១ ឧប្បលៈ ១ បទុមៈ ១[១] មាននារី ៨៤០០០ មានព្រះនាងសោមនស្សាទេវីជាប្រធាន ។

---

១- បិដកខ្មែរជា កោកនុទប្រាសាទ ។

កាលព្រះអនុបមកុមារ ឱរសរបស់ព្រះនាងសោមនស្សាទេវីប្រសូត ហើយ ទ្រង់ឃើញនិមិត្ត ៤ ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ក៏ចេញអភិនេស្រ្កមណ៍ ដោយ-វិមាស ទ្រង់ទៅកាន់វិរិយរាជឧទ្យាន ទ្រង់ព្រះផ្នួស មនុស្សមួយសែនកោដិក៏បួសតាម ៗ បានពួថា មហាបុរសទ្រង់បំពេញព្យាយាម អស់ ១០ ខែ ជាមួយបព្វជិតទាំងនោះ ក្នុងថ្ងៃវិសាខបុណ្ណមី សោយមធុបាយាសដែលធីតាព្រាហ្មណ៍ឈ្មោះសុនេត្តា ក្នុងស្រុកព្រាហ្មណ៍ឈ្មោះអសទិសថ្វាយ ទ្រង់សម្រាកពេលថ្ងៃ ត្រង់ព្រៃពុទ្រា ពេលល្ងាច ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអ្នកយាមស្រែស្រូវជំណើបឈ្មោះវរុណៈថ្វាយ ទ្រង់លាតសន្ថតស្មៅ ៤០ ហត្ថ ប្រថាប់គង់ពត់ភ្នែន សម្រេចសព្វញ្ញុតញ្ញាណហើយ ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វិលវិតែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់ប្រើពេលវេលា ៧ សប្តាហ៍ ទ្រង់ឃើញភិក្ខុមួយសែនកោដិដែលបួសជាមួយព្រះអង្គ ជាអ្នកអាចចាក់ធ្លុះសច្ចៈ ៤ ទើបយាងទៅតាមអាកាស ទ្រង់ចុះត្រង់គយាមិគទាយវ័ន ទ្រង់ប្រកាសធម្មចក្រដល់ភិក្ខុទាំងនោះ កាលនោះ ការសម្រេចធម៌លើកទី ១ មានដល់ភិក្ខុមួយសែនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះសិទ្ធត្ថៈអង្គនោះ ទ្រង់ដល់នូវសម្ពោធិញ្ញាណហើយ ចម្លង
មនុស្ស ព្រមទាំងទេវតា បន្លឺភ្លៀង គឺធម៌ ហើយញ៉ាំងមនុស្ស
ព្រមទាំងទេវតា ឲ្យរលត់ទុក្ខ ។ ព្រះអង្គមានតេជះប្រឹងពុំបាន
ទ្រង់មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងលើកទី ១
មានពួកសត្វមួយសែនកោដិ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សទេវកំ** បានដល់ មនុស្សលោក ព្រមទាំងទេវលោក ។ បទថា **ធម្មមេឃេន** បានដល់ ភ្លៀង គឺធម្មកថា ។ បន្តមកទៀត ព្រះរាជាព្រះនាមភីមរថៈ ក្នុងភីមរថនគរ ទូលនិមន្តព្រះសិទ្ធត្ថសម្ពុទ្ធ ឲ្យប្រថាប់គង់ក្នុងសណ្ឋាគារ ដែលគេសាងកណ្ដាលព្រះនគរ ទ្រង់ធ្វើទិសទាំង ១០ ឲ្យពេញដោយព្រះសូរសៀងដូចសំឡេងព្រហ្ម ពីរោះដូចសំឡេងសត្វករវិកយំ ពីរោះត្រចៀកក្រៃលែង ទាក់ចិត្តបណ្ឌិតជន ដូចអភិសេកដោយទឹកអម្រឹត ទ្រង់ទូងអមតធម្មភេរី ។ កាលនោះ ការសម្រេចធម៌លើកទី ២ មានដល់សត្វ ៩០ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

តមក ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ
ក្នុង កាលព្រះសម្ពុទ្ធទ្រង់ទូងស្គរ គឺធម៌ ក្នុងដែនឈ្មោះភីមៈ
ដូច្នេះ ។

សម័យដែលព្រះសិទ្ធត្ថសម្ពុទ្ធ ទ្រង់សម្ដែងពុទ្ធវង្ស ក្នុងសមាគមព្រះញាតិ ក្រុងវេភារៈ ទ្រង់ញ៉ាំងធម្មចក្កឲ្យកើតដល់សត្វ ៩០ កោដិ នេះជាការសម្រេចធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធប្រសើរជាងជនអង្គនោះ ទ្រង់សម្តែងធម៌ទៀបភ្នំឈ្មោះវេភារៈ ដូច្នេះ ។

ព្រះរាជា ២ អង្គ ជាបងប្អូននឹងគ្នា គឺព្រះបាទសម្ពលៈ ១ សុមិត្តៈ ១ ទ្រង់គ្រងរាជ្យ ក្នុងអមរនគរ ដែលល្អគួរមើលដូចទេវនគរ លំដាប់នោះ ព្រះសិទ្ធត្ថសាស្តាឃើញឧបនិស្ស័យសម្បត្តិរបស់ព្រះរាជាអង្គនោះ ទើបទ្រង់យាងទៅតាមផ្លូវនភាកាស ទ្រង់ចុះត្រង់កណ្តាលអមរនគរ ទ្រង់ប្រតិស្ឋានចេតិយ គឺស្នាមព្រះបាទ ដូចជាន់ផ្ទៃផែនដីដោយព្រះបាទទាំងគូ ដែលមានផ្ទៃព្រះបាទប្រដាប់ដោយចក្រ ហើយយាងទៅកាន់អមររាជឧទ្យាន គង់ប្រថាប់លើផ្ទាំងថ្មទ្រង់មានព្រះហឫទ័យត្រជាក់ដោយករុណារបស់ព្រះអង្គ ដែលគួរត្រេកអរក្រៃលែង បន្ទាប់អំពីនោះ ព្រះរាជា ២ អង្គដែលជាបងប្អូននោះ ឃើញព្រះចេតិយ គឺស្នាមព្រះបាទ ក៏យាងទៅតាមស្នាមព្រះបាទ ចូលគាល់ព្រះសិទ្ធត្ថ-សាស្តា សម្រេចប្រយោជន៍ក្រៃលែង ថ្វាយបង្គំហើយ គង់ប្រថាប់ជុំវិញព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដ៏សមគួរដល់អធ្យាស្រ័យប្រោសព្រះរាជា ២ អង្គ ដែលជាបងប្អូនទាំង ២ ព្រះអង្គនោះ ។ ព្រះរាជាទាំង ២ អង្គនោះ ទ្រង់ស្តាប់ធម្មកថារបស់ព្រះសាស្តាអង្គនោះហើយ បាននូវសទ្ធា ទ្រង់ព្រះផ្នួសហើយ សម្រេចអរហត្តទាំងអស់ ។ ព្រះមានព្រះភាគទ្រង់លើកបាតិមោក្ខឡើងសម្តែង ត្រង់កណ្តាលព្រះខីណាស្រព ១០០ កោដិនោះ នេះជាសន្និបាតលើកទី ១ ។ ទ្រង់លើកបាតិមោក្ខឡើងសម្តែងកណ្តាល

បព្វជិត ៩០ កោដិ ក្នុងសមាគមព្រះញាតិ ក្រុងវេភារៈ នុ៎ះជាសន្និបាតលើកទី ២ ។ ទ្រង់លើកបាតិមោក្ខឡើងសម្តែងកណ្តាលបព្វជិត ៨០ កោដិ ដែលប្រជុំគ្នាត្រង់សុទស្សនវិហារ នុ៎ះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានសន្និបាត ៣ លើក សុទ្ធតែព្រះខីណាស្រព ឥតមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ ឋានៈ គឺសន្និបាតទាំង ៣ ក្នុងសមាគមនៃព្រះខីណាស្រព ដែលមិនមានមន្ទិលនុ៎ះ មានចំនួន ១០០ កោដិម្តង ៩០ កោដិម្តង ៨០ កោដិម្តង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នវុតីនំ អសីតិយាបិ ច កោដិនំ** សេចក្តីថា មានសន្និបាតនៃសាវក ៩០ កោដិ និង ៨០ កោដិ ។ បទថា **ឯតេ អាសុំ តយោ ឋានា** សេចក្តីថា មានហេតុឲ្យប្រជុំគ្នា ៣ ដងនោះ ។ បាឋៈថា **ឋានានេតានិ តីណិ អហេសុំ** ដូច្នេះក៏មាន ។

សម័យនោះ ព្រះពោធិសត្វនៃយើង ជាព្រាហ្មណ៍ឈ្មោះមង្គលៈ ក្នុងសុរសេននគរ ជាអ្នកចប់ត្រៃវេទ និងវេទង្គសាស្ត្រ បរិច្ចាគគំនរទ្រព្យច្រើនកោដិ ជាអ្នកត្រេកអរក្នុងវិវេក បួសជាតាបស ញ៉ាំងឈាន និងអភិញ្ញាឲ្យកើត បានដំណឹងថា ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ កើតឡើងហើយ ក្នុងលោក ទើបចូលទៅគាល់ ថ្វាយបង្គំហើយ ស្តាប់ធម្មកថារបស់ព្រះអង្គ ហើយចូលទៅកាន់ដើមព្រីង ដែលជារបស់អ្នកជម្ពូទ្វីបនេះ ដោយឫទ្ធិ នាំផ្លែព្រីង

មកហើយ ថ្វាយព្រះសិទ្ធត្ថសាស្តា ដែលមានភិក្ខុបរិវារ ៩០ កោដិ ឲ្យប្រថាប់នៅក្នុងសុរសេនវិហារ អង្គាសដោយផ្លែព្រីង ឲ្យទ្រង់ឆ្អែតស្កប់ស្កល់ ។ គ្រានោះ ព្រះសាស្តាសោយផ្លែព្រីងនោះហើយ ទ្រង់ព្យាករថា ក្នុងទីបំផុត ៩៤ កប្ប រាប់អំពីកប្បនេះ អ្នកនឹងបានជាព្រះពុទ្ធព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតជាតាបស ឈ្មោះមង្គលៈ មានតេជះខ្ពង់ខ្ពស់ គេគ្របសង្កត់មិនបាន ជាអ្នកប្រកបដោយកម្លាំងនៃអភិញ្ញា ។ តថាគតបាននាំផ្លែព្រីងមកថ្វាយ ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ព្រះសម្ពុទ្ធទ្រង់ទទួលយកហើយ ទ្រង់បានត្រាស់ព្រះតម្រាស់នេះថា អ្នកទាំងឡាយ ចូរមើលជដិលតាបស ដែលមានតបៈខ្ពង់ខ្ពស់នេះចុះ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បទី ៩៤ អំពីកប្បនេះទៅ ។ សត្វនេះ នឹងចេញពីបុរីឈ្មោះកបិលពស្តុ ជាទីរីករាយ ទៅតម្កល់ព្យាយាម ។បេ។ ពួកយើងទាំងអស់ បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្រ្ត ព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះដែរ ។ តថាគតលុះស្តាប់ភាសិតនៃព្រះពុទ្ធព្រះនាមសិទ្ធត្ថៈនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧប្បសយោ** បានដល់ មិនមានបុគ្គល

ប្រៀប ។ បាឋៈក៏យ៉ាងនោះដូចគ្នា ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់មាននគរឈ្មោះវេភារៈ ព្រះជនកព្រះនាមព្រះបាទឧទេន ព្រះនាមព្រះបាទជ័យសេន ក៏ព្រះនាមរបស់ព្រះឧទេននោះដូចគ្នា ព្រះជននីព្រះនាមព្រះនាងសុផស្សា គូនៃអគ្គសាវកឈ្មោះសម្ពលៈ ១ សុមិត្តៈ ឧបដ្ឋាកឈ្មោះរេវតៈ គូនៃអគ្គសាវិក ឈ្មោះសីវលា ១ សុរាមា ១ ព្រះជន្មាយុ ១ សែន អគ្គមហេសីព្រះនាមព្រះនាងសោមនស្សា ឱរសព្រះនាមអនុបមៈ ចេញអភិនេស្រ្កមណ៍ ដោយវិមាស ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

> ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានទីក្រុងឈ្មោះវេភារៈ ព្រះមហាក្សត្រ ព្រះនាមឧទេនៈជាព្រះបិតា ព្រះជននីព្រះនាមសុផស្សា ។ ព្រះមហេសីព្រះនាមសិទ្ធត្ថៈ មានព្រះសម្ពលត្ថេរ ១ ព្រះសុមិត្តត្ថេរ ១ ជាអគ្គសាវក ភិក្ខុឈ្មោះរេវតៈ ជាឧបដ្ឋាក ។ ព្រះសីវលាថេរី ១ ព្រះសុរាមាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹងនៃព្រះមានព្រះភាគនោះ ហៅថា កណ្ណិការព្រឹក្ស ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៦០ ហត្ថ ទ្រង់ខ្ពស់ដល់អាកាស ប្រាកដស្មើដោយគ្រឿងបូជាមាស ទ្រង់រុងរឿងអស់មួយម៉ឺនលោកធាតុ ។ ព្រះពុទ្ធអង្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ឥតមានបុគ្គលប្ញឹងបាន ឥតមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់មានចក្ខុ

*ស្ថិតនៅក្នុងលោក អស់មួយសែនឆ្នាំ ។ ព្រះពុទ្ធអង្គនោះ*
*ព្រមទាំងសាវក ទ្រង់សម្តែងពន្លឺភ្លឺត្រចះ ហើយញុំាងសាវក*
*ឲ្យស្វាយកាយទៅ ទ្រង់ក្រសាលដោយសមាបត្តិដ៏ប្រសើរ*
*ហើយបរិនិព្វាន ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **សដ្ឋិរតនំ** សេចក្តីថា កម្ពស់ប្រមាណ ៦០ ហត្ថ ។ បទថា **កញ្ចនគ្ឃិយសង្កាសោ** បានដល់ គួរមើល ដូចគ្នានឹងរូបបដិមាដែលសម្រេចដោយមាស វិចិត្រដោយរតនៈផ្សេងៗ ។ បទថា **ទសសហស្សី វិរោចតិ** បានដល់ រុងរឿងក្នុងម៉ឺនលោកធាតុ ។ បទថា **វិបុលំ** បានដល់ ព្រះរស្មីដ៏ឱឡារ ។ បទថា **បុប្ផាបេត្វាន** សេចក្តីថា ធ្វើឲ្យរីកហើយដោយផ្កា គឺឈាន អភិញ្ញា មគ្គ ផល និងសមាបត្តិ គឺដល់នូវភាពល្អក្រៃលែង ។ បទថា **វិលាសេត្វា** បានដល់ លីលាហើយ ។ បទថា **វរសមាបត្តិយា** បានដល់ ដោយសមាបត្តិ និងអភិញ្ញាដែលជាលោកិយ និងលោកុត្តរ ។ បទថា **និព្វុតោ** បានដល់ បរិនិព្វានហើយដោយអនុបាទាបរិនិព្វាន ។

បានឮថា ព្រះសិទ្ធត្ថសាស្តា ទ្រង់រម្លត់ខន្ធបរិនិព្វាន ក្នុងអនោមរាជឧទ្យាន ក្រុងកញ្ចនវេឡុ ក្នុងព្រះរាជឧទ្យាននោះឯង ជនទាំងឡាយនាំគ្នាសាងព្រះចេតិយសម្រេចដោយរតនៈកម្ពស់ ៤ យោជន៍ សម្រាប់ព្រះអង្គ ។ ក្នុងគាថាទាំងឡាយដ៏សេស ជាក់ច្បាស់ហើយនោះឯង ។l

## អដ្ឋកថាសិទ្ធត្ថពុទ្ធវង្សទី ១៦ ចប់

# សុត្តន្តបិដក

## តិស្សពុទ្ធវង្សទី ១៧

[ ១៨ ] ក្រោយពីព្រះពុទ្ធព្រះនាមសិទ្ធត្ថៈមក មានព្រះពុទ្ធព្រះនាមតិស្សៈ ជានាយកដ៏ប្រសើរក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មានយសរាប់ពុំបាន ទ្រង់មានសេចក្ដីអាណិតអាសូរ មានព្យាយាមធំ មានចក្ខុ ទ្រង់កើតឡើងក្នុងលោក កម្ចាត់បង់ងងឹតអន្ធការ ញ៉ាំងលោកនេះ ព្រមទាំងទេវលោកឲ្យភ្លឺស្វាងហើយ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានឫទ្ធិប្រឹងពុំបាន មានសីលសមាធិប្រឹងពុំបាន ព្រះអង្គសម្រេចនូវបារមីក្នុងធម៌ទាំងពួង ហើយទ្រង់ញ៉ាំងចក្រ គឺធម៌ ឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះ ទ្រង់បញ្ចេញព្រះសូរសៀង ដ៏ជ្រះស្អាតល្អក្នុងលោកធាតុមួយម៉ឺន ពួកសត្វទាំងមួយរយកោដិ សឹងបានត្រាស់ដឹង ក្នុងការសម្ដែងធម៌លើកទី ១ ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៦០ កោដិ ពេលនោះ ព្រះសម្ពុទ្ធនោះ ទ្រង់ដោះមនុស្ស និងទេវតាដែលមកដល់ ឲ្យរួចចាកចំណង គឺមារ ។ ព្រះតិស្សមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធសឹងតែជាពួកព្រះខីណាស្រព មិនមានមន្ទិល គឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រពមួយសែនអង្គ សន្និបាតលើកទី ២ មានព្រះខីណា-

ស្រព ៩០ សែនអង្គ ។ សន្និបាតលើកទី ៣ មានព្រះខីណាស្រព ៨០ សែនអង្គ សុទ្ធតែជាអ្នកអស់អាសវៈ ឥតមានមន្ទិល គឺកិលេស រីកហើយដោយវិមុត្តិ ។ គ្រានោះ តថាគតជាក្សត្រនាមសុជាតៈ លះបោលភោគៈដ៏ច្រើន ហើយទៅបួសជាឥសី ។ កាលដែលតថាគតបួសស្រេចហើយ ព្រះលោកនាយក ទ្រង់កើតឡើង តថាគតកើតមានបីតិ ព្រោះបានស្តាប់សំឡេងថាព្រះពុទ្ធ ។ តថាគតបានកាន់យកផ្កាមន្ទារវព្រឹក្ស ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ដោយដៃទាំងពីរ ជជុះរលាស់ ហើយចូលទៅគាល់ ។ តថាគតកាន់ផ្កានោះ បាំងលើព្រះសិរ្ស នៃព្រះជិនស្រីព្រះនាមតិស្សៈ ជាលោកគ្គនាយក ដែលមានបរិស័ទ ៤ ចោមរោម ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់កណ្តាលប្រជុំជន ហើយព្យាករតថាគតកាលនោះថា ក្នុងកប្បទី ៩២ អំពីមណ្ឌកប្បនេះទៅ តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពីបុរី ឈ្មោះកបិលពស្តុ ជាទីត្រេកអរ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគាល់អជបាលព្រឹក្ស ទទួលបាយាសត្រង់ទីនោះហើយ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបច្រាំងស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើប្រទក្សិណ

ពោធិមណ្ឌៈដ៏ប្រសើរហើយ ត្រាស់ដឹងទៀបគល់អសុរត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពុទ្ធនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ នាងខេមា-ថេរី ១ នាងឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា អសុរត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ជាអគ្គឧបដ្ឋាក ។ នន្ទមាតាឧបាសិកា ១ ឧត្តរាឧបាសិកា ១ ជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់នូវព្រះពុទ្ធដីកានេះ នៃព្រះមហេសី ទ្រង់ឥតមានបុគ្គលស្មើហើយ រីករាយថា តាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃ អបអរសាទរ ធ្វើអញ្ជលី នមស្ការថា បើយើងឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថអង្គនេះ គង់យើងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងកាលជាអនាគត

មិនខាន ។ ពួកមនុស្សក្រាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណា ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបាន សម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងអនាគត យ៉ាង នោះដែរ ។ តថាគតលុះបានស្តាប់នូវព្រះពុទ្ធដីកា នៃព្រះជិនស្រី អង្គនោះហើយ ធ្វើចិត្តឲ្យរឹងរឹតតែជ្រះថ្លាថែមទៀត ទំអធិដ្ឋានវត្ត តទៅ ដើម្បីបំពេញបារមីទាំង ១០ ។ ព្រះមហេសីព្រះនាមតិស្សៈ មានទីក្រុងឈ្មោះខេមកៈ មានព្រះមហាក្សត្រ ព្រះនាមជនសន្ធៈ ជាព្រះបិតា មានព្រះជននីព្រះនាមបទុមា ។ ព្រះតិស្សៈនោះ ទ្រង់ គ្រប់គ្រងព្រះរាជគេហដ្ឋាន អស់ ៧ ពាន់ឆ្នាំ មានប្រាសាទដ៏ ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះគុណសេលៈ ១ ប្រាសាទ ឈ្មោះអនាទិយៈ ១ ប្រាសាទឈ្មោះនិសភៈ ១ ។ ពួកនារីចំនួន ៣ ម៉ឺននាក់ សុទ្ធសឹងតែតាក់តែងខ្លួនល្អ ឯនាងនារីជាអគ្គមហេសី នោះ ព្រះនាមសុភទ្រា ព្រះរាជបុត្រព្រះនាមអានន្ទ ។ ព្រះជិនស្រី ទ្រង់ឃើញនិមិត្តទាំង ៤ ក៏យាងចេញទៅដោយយានសេះ ទៅ តម្កល់ព្យាយាម អស់កាលកន្លះខែគត់ ។ ព្រះលោកនាយក ព្រះ នាមតិស្សៈ ប្រសើរក្នុងលោក មានព្យាយាមធំ ត្រូវព្រហ្ម អារាធនាហើយ ទើបទ្រង់ញ៉ាំងចក្រ គឺធម៌ ឲ្យប្រព្រឹត្តទៅក្នុង យសវតីទាយវ័នដ៏ឧត្តម ។ ព្រះព្រហ្មទេវត្ថេរ ១ ព្រះឧទយត្ថេរ ១

ជាអគ្គសាវក ភិក្ខុឈ្មោះសមគៈជាឧបដ្ឋាក នៃព្រះមហេសីព្រះនាមតិស្សៈ ។ នាងផុស្សាថេរី ១ នាងសុទត្តាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានជោគអង្គនោះ ហៅថា អសនព្រឹក្ស ( ដើមធ្នង់ ) ។ សម្ពលគហបតី ១ សិរិគហបតី ១ ជាអគ្គឧបដ្ឋាក កីសាគោតមីឧបាសិកា ១ ឧបសេនាឧបាសិកា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះជិនស្រីសម្ពុទ្ធនោះឯង ទ្រង់មានកម្ពស់ ៦០ ហត្ថ ឥតមានបុគ្គលប្រៀបផ្ទឹមបាន ឥតមានបុគ្គលស្មើបាន ប្រាកដដូចភ្នំហិមពាន្ត ។ ព្រះជិនស្រីអង្គនោះ ទ្រង់មានតេជះប្រឹងពុំបាន ទ្រង់មានព្រះជន្មមួយសែនឆ្នាំ ព្រះអង្គមិនមានបុគ្គលក្រៃលែងជាង ទ្រង់មានចក្ខុ ស្ថិតនៅក្នុងលោក ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវក ទ្រង់សោយនូវយសធំ ដ៏ឧត្តមប្រសើរ រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវក ទ្រង់បរិនិព្វានហើយ ដូចជាភ្លៀង ( ដែលបាត់ទៅ ) ព្រោះខ្យល់ ឬដូចទឹកសន្សើម ( អស់ទៅ ) ព្រោះព្រះអាទិត្យ ឬដូចងងឹត ( បាត់ទៅ ) ព្រោះប្រទីប ។ ព្រះពុទ្ធព្រះនាមតិស្សៈ ជាព្រះជិនស្រីដ៏ប្រសើរ បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបព្រះជិនស្រីអង្គនោះ ពួកមហាជនសាងទុកកម្ពស់ ៣ យោជន៍ ក្នុងនន្ទារាមនោះ ។

**តិស្សពុទ្ធវង្សទី ១៧ ចប់**

# អដ្ឋកថា

## តិស្សពុទ្ធវង្សទី ១៧

ក្រោយអំពីសម័យព្រះមានព្រះភាគសិទ្ធត្ថៈអង្គនោះ មិនមានព្រះសម្ពុទ្ធត្រាស់ដឹងអស់មួយកប្ប ក្នុងកប្បទី ៩២ រាប់អំពីកប្បនេះ មានព្រះពុទ្ធ ២ ព្រះអង្គកើតក្នុងកប្បមួយ គឺព្រះតិស្សៈ និងព្រះផុស្សៈ ។ បណ្ដាព្រះសម្ពុទ្ធ ២ ព្រះអង្គនោះ មហាបុរសព្រះនាមតិស្សៈ ទ្រង់បំពេញបារមីទាំងឡាយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងបទុមាទេវី ព្រះនាងមានព្រះនេត្រល្អដូចត្របកឈូក ជាអគ្គមហេសីរបស់ព្រះបាទជនសន្ធៈ[១] ក្នុងខេមកនគរ គ្រប់កំណត់ទសមាស ក៏ប្រសូតចាកព្រះឧទររបស់ព្រះជននី ក្នុងអនោមរាជឧទ្យាន ។ ទ្រង់គ្រប់គ្រងឃរាវាស-វិស័យអស់ ៧ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ឈ្មោះគុហាសេលៈ ១ នារិសយៈ[២] ១ និងនិសភៈ ១ មាននារី ៣ ម៉ឺន ៣ ពាន់នាក់ មានព្រះនាងសុភទ្ទាទេវីជាប្រធាន កាលអានន្ទកុមារឱរសរបស់ព្រះនាងសុភទ្ទាទេវីប្រសូតហើយ ព្រះមហាបុរសឃើញនិមិត្ត ៤ ទ្រង់ឡើងផែលសេះដ៏ប្រសើរ ឈ្មោះសោនុត្តរៈ ចេញមហាភិនេស្ក្រមណ៍ ទ្រង់ព្រះផ្នួស មនុស្សមួយកោដិក៏បួសតាម កាលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាម ៨ ខែ ក្នុងវិសាខបុណ្ណមី សោយមធុបាយាស ដែលធីតាវីរសេដ្ឋី ក្នុងវីរនិគមថ្វាយហើយ ទ្រង់សម្រាកពេលថ្ងៃ ក្នុងព្រៃសលលវ័ន ( ព្រៃស្រល់ ) លុះវេលាល្ងាច ទ្រង់ទទួលស្មៅ ៨ ក្ដាប់ ដែលមនុស្សចាំស្រែស្រូវជំណើប

---

១- បិដកខ្មែរជា ជនសន្ធៈ ។ ២- បិដកខ្មែរជា អនារិយៈ ។

ឈ្មោះវិជិតសង្គាមកៈថ្វាយហើយ ទ្រង់ចូលទៅកាន់ពោធិព្រឹក្ស ឈ្មោះអសនៈ គឺដើមធ្នង់ ទ្រង់លាតសន្ថតស្មៅទំហំ ៤០ ហត្ថ ប្រថាប់គង់ពត់ភ្នែន លើបល្ល័ង្កស្មៅនោះ ។ ទ្រង់កម្ចាត់កម្លាំងមារ ព្រមទាំងសេនា ត្រាស់ដឹងសព្វញ្ញុតញ្ញាណ ទើបទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វិលវល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគត
បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់ឃើញព្រះរាជឱរស ក្នុងយសវតីនគរ ២ អង្គ ព្រះនាមព្រហ្មទេវៈ ១ ឧទយៈ ១ មួយអន្លើដោយបរិវារ ដល់ព្រមដោយឧបនិស្ស័យសម្បត្តិ ទើបទ្រង់យាងទៅតាមអាកាស ចុះត្រង់យសវតីមិគទាយវ័ន ទ្រង់ឲ្យឧទ្យានបាល យាងព្រះឱរសមកហើយ ទ្រង់ញ៉ាំងលោកធាតុមួយម៉ឺន ឲ្យដឹងដោយព្រះសូរសៀងដូចព្រហ្ម មិនស្អកមិនស្អា ប្រកាសធម្មចក្រដល់ព្រះរាជឱរសទាំង ២ អង្គនោះ មួយអន្លើដោយបរិវារ ។ កាលនោះ ការត្រាស់ធម៌លើកទី ១ មានដល់សត្វ ១០០ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្រោយពីព្រះពុទ្ធព្រះនាមសិទ្ធត្ថៈមក មានព្រះពុទ្ធ ព្រះនាម
តិស្សៈ ជានាយកដ៏ប្រសើរក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ
មិនមានបុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មាន

យសរាប់ពុំបាន ទ្រង់មានសេចក្តីអាណិតអាសូរ មានព្យា-
យាមធំ មានចក្ខុ ទ្រង់កើតឡើងក្នុងលោក កម្ចាត់បង់ងងឹត
អន្ធការ ញុំាងលោកនេះ ព្រមទាំងទេវលោក ឲ្យភ្លឺស្វាង
ហើយ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានឫទ្ធិប្រឹងពុំបាន មានសីល
សមាធិប្រឹងពុំបាន ព្រះអង្គសម្រេចនូវបារមីក្នុងធម៌ទាំងពួង
ហើយទ្រង់ញុំាងចក្រ គឺធម៌ ឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះ
ទ្រង់បញ្ចេញព្រះសូរសៀងដ៏ជ្រះស្អាតល្អ ក្នុងលោកធាតុមួយ
ម៉ឺន ពួកសត្វទាំងមួយរយកោដិ ស៊ីងបានត្រាស់ដឹងក្នុងការ
សម្តែងធម៌លើកទី ១ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វត្ថ** សេចក្តីថា ដល់នូវត្រើយក្នុងធម៌ទាំងពួង ។ បទថា **ឧសសហស្សិម្ហិ** គឺ **ឧសសហស្សិយំ** សេចក្តីថា ក្នុងម៉ឺនលោកធាតុ ។

សម័យក្រោយមក ក្នុងកាលដែលព្រះមហាបុរសទ្រង់លះបង់ការនៅជាពួក ហើយចូលទៅកាន់គល់ពោធិព្រឹក្ស ភិក្ខុបួសជាមួយព្រះតិស្សសាស្តាចំនួនមួយកោដិក៏បែកខ្ញែកទៅកាន់ទីដទៃហើយ កាលភិក្ខុមួយកោដិនោះជ្រាបថា ព្រះតិស្សសម្មាសម្ពុទ្ធ ទ្រង់ប្រកាសធម្មចក្រ ក៏នាំគ្នាមកត្រង់យសវតី-មិគទាយវ័ន ថ្វាយបង្គំព្រះទសពលហើយ អង្គុយចោមរោមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ប្រោសភិក្ខុទាំងនោះ កាលនោះ ការត្រាស់ដឹងធម៌លើកទី ២ មានដល់សត្វ ៩០ កោដិ ក្រោយមកទៀត ក្នុងមហាមង្គលសមាគម ក្នុង

កាលចប់មង្គល ការត្រាស់ដឹងធម៌លើកទី ៣ មានដល់សត្វ ៦០ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៦០ កោដិ ពេលនោះ ព្រះសម្ពុទ្ធនោះ ទ្រង់ដោះមនុស្ស និងទេវតា ដែលមកដល់ឲ្យរួចចាកចំណង គឺមារ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុតិយោ នវុតិកោដីនំ** សេចក្ដីថា ការត្រាស់ដឹងធម៌លើកទី ២ មានដល់សត្វ ៩០ កោដិ ។ បទថា **ពន្ធនាតោ** បានដល់ ចាកចំណង សេចក្ដីថា ទ្រង់ដោះចាកសំយោជនៈ ១០ ។ ឥឡូវនេះ កាលទ្រង់សម្ដែងដល់សត្វដែលទ្រង់ដោះដោយសរុប ទើបត្រាស់ថា **នរមរូ។** បទថា **នរមរូ** គឺ **នរាមរេ** បានដល់ មនុស្ស និងទេវតា ។

បានឮថា ព្រះតិស្សសម្ពុទ្ធដែលព្រះអរហន្ត បួសក្នុងវស្សា ក្នុងយសវតីនគរចោមរោមហើយ ទ្រង់បវារណាចេញវស្សាហើយ នេះជាសន្និបាតលើកទី ១ ។ កាលព្រះលោកនាថយាងដល់នារិវាហននគរ នារិវាហនកុមារបុត្តរបស់ព្រះបាទសុជាតៈ ជាសត្វកើតល្អទាំង ២ ចំណែក មួយអន្ទើដោយបរិវារយានចេញទៅទទួល និមន្តព្រះទសពល មួយអន្ទើដោយភិក្ខុសង្ឃ ថ្វាយអសទិសទាន ៧ ថ្ងៃ ទើបប្រគល់រាជសម្បត្តិរបស់ព្រះអង្គដល់ព្រះឱរស មួយអន្ទើដោយបរិវារ ទ្រង់ព្រះផ្នួសដោយឯហិភិក្ខុ ក្នុងសម្នាក់របស់ព្រះតិស្ស-សម្មាសម្ពុទ្ធ ដែលជាធំនៃលោកទាំងពួង ។ បានឮថា បព្វជ្ជារបស់ព្រះអង្គ

ប្រាកដគ្រប់ទិស ព្រោះហេតុនោះ មហាជនចេញអំពីទិសនោះៗ បួសតាមព្រះបាទនារិវាហនកុមារ ។ កាលនោះ ព្រះតថាគតយាងទៅកណ្ដាលភិក្ខុ ៩ លាន ទ្រង់លើកបាតិមោក្ខឡើង នេះជាសន្និបាតលើកទី ២ បន្ទាប់មកទៀតជន ៨ លានស្ដាប់ធម្មកថាអំពីពុទ្ធវង្ស ក្នុងសមាគមញាតិ ក្រុងខេមវតី ក៏នាំគ្នាបួសក្នុងសម្នាក់របស់ព្រះអង្គ ហើយសម្រេចអរហត្ត ។ ព្រះសុគតដែលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់លើកបាតិមោក្ខឡើងសម្ដែង នេះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះតិស្សមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធសឹងតែជាពួកព្រះខីណាស្រព មិនមានមន្ទិល គឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រពមួយសែនអង្គ សន្និបាតលើកទី ២ មានព្រះខីណាស្រព ៩០ សែនអង្គ ។ សន្និបាតលើកទី ៣ មានព្រះខីណាស្រព ៨០ សែនអង្គ សុទ្ធតែជាអ្នកអស់អាសវៈ ឥតមានមន្ទិល គឺកិលេស រីកហើយដោយវិមុត្តិ ដូច្នេះ ។

សម័យនោះ ព្រះពោធិសត្វនៃយើង ជាព្រះរាជាព្រះនាមសុជាតៈក្រុងយសវតី ទ្រង់លះរាជអាណាចក្រ ដែលស្ដុកស្ដម្ភរុងរឿង និងគំនរទ្រព្យច្រើនកោដិ និងមនុស្សដែលជិតស្និទ្ធ ដែលមានចិត្តកក្តី ដូចលះបាច់ស្មៅសង្វេគក្នុងទុក្ខ មានជាតិទុក្ខជាដើម ទើបចេញបួសជាតាបស មានឫទ្ធានុភាព

ច្រើន បានដំណឹងថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក មានព្រះវរកាយដែលបីតិ ៥ ពាល់ត្រូវហើយ មានការកោតក្រែង ចូលគាល់ព្រះមានព្រះភាគតិស្សៈ ថ្វាយបង្គំហើយ ត្រិះរិះថា អញនឹងបូជាព្រះមានព្រះភាគដោយផ្កាទិព្វ មានផ្កាមន្ទារវៈ ផ្កាបារិច្ឆត្តកៈជាដើម កាលត្រិះរិះយ៉ាងនោះហើយ ក៏ទៅកាន់ទេវលោកដោយឫទ្ធិ ចូលទៅកាន់ចិត្តលតាវ័ន ដាក់ផ្កាទិព្វ មានផ្កាឈូក ផ្កាបារិច្ឆត្តកៈ និងផ្កាមន្ទារវៈជាដើម ពេញប្រអប់ ដែលសម្រេចដោយរតនៈទំហំមួយគាវុត នាំមកតាមអាកាស បូជាព្រះមានព្រះភាគដោយទិព្វបុប្ផាមានក្លិនក្រអូប យកផ្កាឈូកធ្វើជាឆត្រ ដែលមានដើមជាកែវមណី មានកេសរជាមាស មានស្លឹកជាកែវទទឹម ដូចឆត្រដែលសម្រេចកេសរក្រអូប អំពីខាងលើព្រះសិរសារបស់ព្រះមានព្រះភាគ ឈរក្នុងកណ្តាលបរិស័ទ ៤ ។ កាលនោះ ព្រះមានព្រះភាគ ទ្រង់ព្យាករព្រះពោធិសត្វថា ក្នុងកប្បទី ៩២ អំពីកប្បនេះ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

គ្រានោះ តថាគតជាក្សត្រ នាមសុជាតៈ លះបោលភោគៈដ៏ច្រើន ហើយទៅបួសជាឥសី ។ កាលដែលតថាគត បួសស្រេចហើយ ព្រះលោកនាយកទ្រង់កើតឡើង តថាគតកើតមានបីតិ ព្រោះបានស្តាប់សំឡេងថាព្រះពុទ្ធ ។ តថាគតបានកាន់យកផ្កាមន្ទារវព្រឹក្ស ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ដោយដៃទាំងពីរ ជជុះរលាស់ ហើយចូលទៅគាល់ ។

តថាគតកាន់ផ្កានោះ បាំងលើព្រះសិរ្ស នៃព្រះជិនស្រីព្រះនាម
តិស្សៈ ជាលោកគ្គនាយក ដែលមានបរិស័ទ ៤ ចោមរោម ។
ព្រះពុទ្ធអង្គនោះ ទ្រង់គង់កណ្ដាលប្រជុំជន ហើយព្យាករ
តថាគតកាលនោះថា ក្នុងកប្បទី ៩២ អំពីមណ្ឌកប្បនេះទៅ
តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពី
បុរីឈ្មោះកបិលពស្តុ ជាទីត្រេកអរ ទៅតម្កល់ព្យាយាម ។បេ។
បើយ្វាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេច ចំពោះ
ព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងអនាគត យ៉ាងនោះដែរ ។
តថាគតលុះបានស្ដាប់នូវព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះ
ហើយ ធ្វើចិត្តឲ្យរីងរឹតតែ ជ្រះថ្លាថែមទៀត ខំអធិដ្ឋាន
វត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មយិ បព្វជិតេ** បានដល់ កាលតថាគត ចូលដល់នូវភាពជាអ្នកបួស ។ អាចារ្យទាំងឡាយរចនាក្នុងគម្ពីរថា **មម បព្វជិតំ សន្តំ** បាឋៈនោះ គប្បីឃើញថា រចនាក្លាំងក្លាត់ ។

បទថា **ឧបបជ្ជថ** បានដល់ កើតឡើងហើយ ។ បទថា **ឧភោ ហត្ថេហិ** បានដល់ យកដៃទាំងពីរ។ បទថា **បគ្គយ្ហ** បានដល់ កាន់ហើយ។ បទថា **ធុនមានោ** បានដល់ រលាស់សំពត់សម្បកឈើ ។ បទថា **ចាតុវណ្ណបរិវុតំ** បានដល់ ដែលបរិស័ទ ៤ ចោមរោមហើយ អធិប្បាយថា ដែលបរិស័ទ គឺក្សត្រ ព្រាហ្មណ៍ គហបតី និងសមណៈចោមរោមហើយ អាចារ្យពួកខ្លះ

ពោលថា **ចតុវណ្ណាហិ បរិវុតំ** សេចក្ដីថា ដែលវណ្ណៈ ៤ ចោមរោមហើយ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់មានព្រះនគរឈ្មោះខេមៈ ព្រះបិតាព្រះនាមជនសន្ធៈ ព្រះជននីព្រះនាមព្រះនាងបទុមា គូនៃអគ្គសាវកឈ្មោះព្រហ្មទេវៈ ១ ឧទយៈ ១ ពុទ្ធុបដ្ឋាកឈ្មោះសមង្គៈ[១] គូអគ្គសាវិកាឈ្មោះផុស្សា ១ សុទត្តា ១ ពោធិព្រឹក្សឈ្មោះអសនៈ គឺដើមធ្នង់ ព្រះសរីរកម្ពស់ ៦០ ហត្ថ ព្រះជន្មាយុមួយសែនឆ្នាំ អគ្គមហេសីព្រះនាមព្រះនាងសុភទ្ទា ឱរសព្រះនាមអានន្ទ ទ្រង់ចេញអភិនេស្ក្រមណ៍ដោយយាន គឺសេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ព្រះមហេសីព្រះនាមតិស្សៈ មានទីក្រុងឈ្មោះខេមកៈ មានព្រះមហាក្សត្រ ព្រះនាមជនសន្ធៈជាព្រះបិតា មានព្រះជននីព្រះនាមបទុមា ។ ព្រះព្រហ្មទេវត្ថេរ ១ ព្រះឧទយត្ថេរ ១ ជាអគ្គសាវក ភិក្ខុឈ្មោះសមគៈ ជាឧបដ្ឋាកនៃព្រះមហេសី ព្រះនាមតិស្សៈ ។ នាងផុស្សាថេរី ១ នាងសុទត្តាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានជោគអង្គនោះ ហៅថា អសនព្រឹក្ស ( ដើមធ្នង់ ) ។ ព្រះជិនស្រីសម្ពុទ្ធនោះឯង ទ្រង់មានកម្ពស់ ៦០ ហត្ថ ឥតមានបុគ្គលប្រៀបផ្ទឹមបាន ឥតមានបុគ្គលស្មើបាន ប្រាកដដូចភ្នំហិមពាន្ត ។ ព្រះជិនស្រីអង្គនោះ ទ្រង់មានតេជះឬទ្ធិពុំបាន ទ្រង់មានព្រះ

---

១- បិដកខ្មែរជា សមគៈ ។

ជន្មមួយសែនឆ្នាំ ព្រះអង្គមិនមានបុគ្គលក្រៃលែងជាង ទ្រង់មានចក្ខុ ស្ថិតនៅក្នុងលោក ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវ័ក ទ្រង់សោយនូវយសធំ ដ៏ឧត្តមប្រសើរ រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវ័ក ទ្រង់បរិនិព្វានហើយ ដូចជាភ្លៀង ( ដែលបាត់ទៅ ) ព្រោះខ្យល់ ឬដូចទឹកសន្សើម ( អស់ទៅ ) ព្រោះព្រះអាទិត្យ ឬដូចងងឹត ( បាត់ទៅ ) ព្រោះប្រទីប ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧច្ចត្តនេ** បានដល់ ដោយចំណែកកម្ពស់ ។ បទថា **ហិមវា វិយ ទិស្សតិ** បានដល់ ប្រាកដដូចភ្នំហិមពាន្ត បាឋៈក៏យ៉ាងនេះដូចគ្នា មានអធិប្បាយថា ហិមវន្តបញ្ចបព៌ត កម្ពស់ ១០០ យោជន៍ ប្រាកដច្បាស់គួរជាទីត្រេកអរក្រៃលែង ដល់បុគ្គលដែលឈរក្នុងទីឆ្ងាយ ជាភ្នំដែលខ្ពស់ និងស្អាត យ៉ាងណា សូម្បីព្រះមានព្រះភាគ ក៏ប្រាកដច្បាស់យ៉ាងនោះ ។ បទថា **អនុត្តរោ** បានដល់ មិនវែងពេក មិនខ្លីពេក អធិប្បាយថា ព្រះជន្មាយុមួយសែនឆ្នាំ ។ បទថា **ឧត្តមំ បវរំ សេដ្ឋំ** ជាវេវចនៈនៃគ្នានិងគ្នា ។ បទថា **ឧស្សាវោ** បានដល់ តំណក់សន្សើម អធិប្បាយថា ព្រះមានព្រះភាគ មួយអន្លើដោយសាវ័ក ដែលខ្យល់ព្រះអាទិត្យ និងប្រទីប គឺភាព

ជាអនិច្ចតាបៀតបៀនហើយ ក៏បរិនិព្វាន ដូចពពកដែលត្រូវខ្យល់បក់ ទឹកសន្សើមត្រូវពន្លឺព្រះអាទិត្យ និងងងឹតត្រូវពន្លឺ ប្រទីបក៏អស់ទៅ ដូច្នោះ ។

បានឮថា ព្រះមានព្រះភាគព្រះនាមតិស្សៈ រម្ងត់ខន្ធបរិនិព្វាន ក្នុងវិហារនាមសុនន្ទារាម ក្រុងសុនន្ទវតី ។ ពាក្យដ៏សេស ក្នុងគាថាទាំងឡាយ ជាក់ច្បាស់ល្អហើយ ។៚

## អដ្ឋកថាតិស្សពុទ្ធវង្សទី ១៧ ចប់

# សុត្តន្តបិដក

## បុស្សពុទ្ធវង្សទី ១៨

[ ១៩ ] ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្តាព្រះនាមបុស្សៈ ទ្រង់មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ជានាយកប្រសើរក្នុងលោក ។ ព្រះពុទ្ធអង្គនោះ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ ហើយត្រដោះគ្រឿងចាក់ស្រែះធំ ( កិលេស ) ទ្រង់ញុំាងមនុស្ស ព្រមទាំងទេវតា ឲ្យឆ្អែតស្កប់ស្កល់ ទ្រង់បង្អុរភ្លៀងទឹកអម្រឹតចុះមក ។ កាលព្រះពុទ្ធព្រះនាមបុស្សៈ ញុំាងចក្ក គឺធម៌ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វ ៨០ សែន ក្នុងមគ្គលនៃថ្ងៃនក្ខត្តឫក្ស ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ សែន ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ សែន ។ ព្រះមហេសីព្រះនាមបុស្សៈ មានសាវកសន្និបាន ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព ឥតមានមន្ទិល គឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រព ៦០ សែន សន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ៥០ សែន ។ សន្និបាតលើកទី ៣ មានពួកព្រះខីណាស្រព ៤០ សែន លោកផុតស្រឡះហើយ ព្រោះមិនប្រកាន់ មានតំណ គឺជាតិកាត់ផ្តាច់ហើយ ។ សម័យនោះ តថាគតជាក្សត្រ ព្រះនាមវិជិតៈ លះបោលរាជសម្បត្តិដ៏ធំ ទៅបួសក្នុងសម្នាក់ព្រះពុទ្ធនោះ ។ ព្រះពុទ្ធ

ជាម្ចាស់ព្រះនាមបុស្សៈ ជាលោកគ្គនាយកនោះ បានទ្រង់ព្យាករ តថាគតថា ក្នុងកប្បទី ៩២ អំពីកប្បនេះទៅ ភិក្ខុនេះ នឹងបាន ត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទី រីករាយ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយ ទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូល ទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបច្រាំងស្ទឹងនេរញ្ជរា ហើយស្តេចទៅឯគល់នៃពោធិព្រឹក្ស តាម ផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធ មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពុទ្ធអង្គនេះ ព្រះ នាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ភិក្ខុនេះ នឹងបានត្រាស់ ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ខេមាភិក្ខុនី ១ ឧប្បលវណ្ណាភិក្ខុនី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាង

ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះឮព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើហើយ ក៏រីករាយថា ភិក្ខុនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ គង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងកាលអនាគតមិនខាន ។ ចំណែកខាងតថាគតបានស្តាប់ព្រះពុទ្ធដីកា នៃព្រះបុស្សសម្ពុទ្ធនោះហើយ ក៏ញុំាងចិត្តឲ្យរីងរឹតតែជ្រះថ្លា ហើយខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមីទាំង ១០ ប្រការ ។ តថាគតរៀនយកនូវព្រះសូត្រផង ព្រះវិន័យផង ពាក្យប្រៀនប្រដៅ ព្រះសាស្តាប្រកបដោយអង្គ ៩ ទាំងអស់ផង ហើយញុំាងសាសនាព្រះជិនស្រីឲ្យរុងរឿង ។ តថាគតមិនប្រមាទ សម្រេចសម្រាន្តនៅក្នុងសាសនានោះ ខំចម្រើនភាវនា ដែលប្រកបដោយព្រហ្មវិហារ ហើយដល់នូវបារមីក្នុងអភិញ្ញាទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោក ។ ព្រះមហេសីព្រះនាមបុស្សៈ មានទីក្រុងឈ្មោះកាសិកៈ មានមហាក្សត្រ ព្រះនាមជយសេនជាព្រះបិតា មានព្រះជននីព្រះនាមសិរិមា ។ ព្រះបុស្សៈនោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់ ៩ ពាន់ឆ្នាំ មានប្រាសាទ

ដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះគរុឡ្ហៈ ១ ប្រាសាទឈ្មោះហំសៈ ១ ប្រាសាទឈ្មោះសុវណ្ណតារៈ ១ ។ ពួកនារី ២៣ ពាន់ សឹងមានខ្លួនតាក់តែងល្អហើយ ឯនារីជាអគ្គមហេសី ឈ្មោះកីសាគោតមី ព្រះរាជបុត្រឈ្មោះអានន្ទ ។ ព្រះជិនស្រីជាបុរសដ៏ប្រសើរ ទ្រង់ទតឃើញនិមិត្តទាំង ៤ យ៉ាងហើយ ចេញទៅដោយយានដំរី បានប្រព្រឹត្តធ្វើព្យាយាមអស់ ៧ ថ្ងៃ ។ ព្រះលោកគ្គនាយក ព្រះនាមបុស្សៈ មានព្យាយាមធំ ទ្រង់ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងចក្ក គឺធម៌ ឲ្យប្រព្រឹត្តទៅ នាព្រៃមិគទាយវ័ន ។ ព្រះសុរក្ខិតភិក្ខុ ១ ព្រះធម្មសេនភិក្ខុ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសភិយ្យៈ ជាឧបដ្ឋាកនៃព្រះមហេសីព្រះនាមបុស្សៈ ។ នាងចាលាភិក្ខុនី ១ នាងឧបចាលាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា អាមលកព្រឹក្ស ( ដើមកន្ទួតព្រៃ ) ។ អនញ្ញគហបតី ១ វិសាខគហបតី ១ ជាអគ្គឧបដ្ឋាក នាងបទុមា ១ នាងសិរិនាគា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមុនីអង្គនោះ មានកម្ពស់ ៥៨ ហត្ថ ទ្រង់រុងរឿងដូចព្រះអាទិត្យ ឬដូចព្រះចន្ទពេញវង់ ។ ទ្រង់មានព្រះជន្ម ៩០ ពាន់ឆ្នាំ ព្រះអង្គកាលទ្រង់ធរមាន

នៅឡើយ បានចម្លងប្រជុំជនជាច្រើន ។ ព្រះសាស្តាអង្គនោះ ព្រម ទាំងសាវ័ក ទ្រង់មានយសប្រឹងពុំបាន ទ្រង់ទូន្មានពួកសត្វជាច្រើន ហើយចម្លងពួកសត្វជាច្រើន រួចបរិនិព្វាន ។ ព្រះជិនស្រីដ៏ប្រសើរ ព្រះនាមបុស្សៈ ទ្រង់ជាសាស្តា បរិនិព្វានហើយ ក្នុងសេនារាម ការផ្សាយចេញទៅនៃព្រះធាតុ មានក្នុងប្រទេសទាំងឡាយនោះៗ ។

បុស្សពុទ្ធវង្សទី ១៨ ចប់

# អដ្ឋកថា

## ផុស្សពុទ្ធវង្សទី ១៨

ក្រោយអំពីសម័យព្រះមានព្រះភាគតិស្សៈអង្គនោះ កាលមនុស្សទាំងឡាយមានអាយុថយចុះដោយលំដាប់ និងចម្រើនឡើងវិញ រហូតមានអាយុប្រមាណមិនបាន ហើយក៏ថយចុះតាមលំដាប់ រហូតដល់មានអាយុ ៩ ម៉ឺនឆ្នាំ ក្នុងកប្បនោះឯង ព្រះសាស្តាព្រះនាមផុស្សៈ កើតឡើងក្នុងលោក ព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមីទាំងឡាយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ ក៏បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងសិរិមាទេវីអគ្គមហេសីរបស់ព្រះបាទជយសេន នគរកាសី គ្រប់កំណត់ទសមាស ក៏ប្រសូតចាកព្រះឧទរព្រះជននី ក្នុងសិរិមារាជឧទ្យាន ទ្រង់នៅជាឃរាវាស-វិស័យអស់ ៩ ពាន់ឆ្នាំ បានឮថា ទ្រង់មានប្រាសាទ ៣ ឈ្មោះគរុឡបក្ខៈ ១[១] ហង្ស ១ សុវណ្ណការៈ ១[២] មានស្រីស្នំ ៣ ម៉ឺន មានព្រះនាងកីសាគោតមីជាប្រធាន ។

កាលឱរសព្រះនាមអនុបមៈ របស់ព្រះនាងកីសាគោតមីប្រសូត មហាបុរសឃើញនិមិត្ត ៤ ក៏ឡើងកាន់ដំរីព្រះទីនាំងដែលប្រដាប់ហើយ យាងចេញមហាភិនេស្ក្រមណ៍ ទ្រង់ព្រះផ្នួស ជនមួយកោដិបួសតាម កាលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាមអស់ ៦ ខែ បន្ទាប់អំពីនោះ ទ្រង់លះពួកគណៈ ទ្រង់ប្រព្រឹត្តម្នាក់ឯង អស់ ៧ ថ្ងៃ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់សោយមធុបាយាស ដែលនាងសិរិវឌ្ឍា ធីតាសេដ្ឋីម្នាក់ ក្នុងនគរមួយថ្វាយ

---

១- បិដកខ្មែរជា គរុឡៈ ។ ២- បិដកខ្មែរជា សុវណ្ណតារៈ ។

ទ្រង់សម្រាកពេលថ្ងៃ ក្នុងព្រៃសីសបាវ័ន ក្នុងវេលាល្ងាច ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលឧបាសកឈ្មោះសិរិវឌ្ឍថ្វាយ ចូលទៅកាន់ពោធិព្រឹក្ស ឈ្មោះ អាមលកៈ គឺដើមកន្ទួតព្រៃ ទ្រង់កម្ចាត់មារ ព្រមទាំងសេនា សម្រេច សព្វញ្ញុតញ្ញាណ ទើបទ្រង់បន្លឺព្រះឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ )

ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល

ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយ តថាគត

បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់សម្ងំនៅក្បែរពោធិព្រឹក្សអស់ ៧ សប្តាហ៍ ទ្រង់ឃើញភិក្ខុមួយ កោដិដែលបួសជាមួយនឹងព្រះអង្គ ជាអ្នកអាចចាក់ធ្លុះធម៌បាន ទើបយាងទៅ តាមអាកាស ចុះត្រង់ឥសិបតនមិគទាយវ័ន ក្នុងសង្កស្សនគរ ទ្រង់ប្រកាស ធម្មចក្រកណ្តាលភិក្ខុទាំងនោះ ។ គ្រានោះ ការត្រាស់ដឹងធម៌លើកទី ១ មាន ដល់សត្វមួយសែនកោដិ [១] ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្តា ព្រះនាមបុស្សៈ ទ្រង់

មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន

ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ជានាយកប្រសើរ

ក្នុងលោក ។ ព្រះពុទ្ធអង្គនោះ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់

ហើយត្រដោះគ្រឿងចាក់ស្រែះធំ ( កិលេស ) ទ្រង់ញុំាង

---

១- បិដកខ្មែរជា ៨០ សែន ។

មនុស្ស ព្រមទាំងទេវតា ឲ្យឆ្អែតស្កប់ស្កល់ ទ្រង់បង្អុរភ្លៀង
ទឹកអម្រឹតចុះមក ។ កាលព្រះពុទ្ធព្រះនាមបុស្ស ញ៉ាំងចក្ក គឺ
ធម៌ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វ
៨០ សែន ក្នុងមណ្ឌលនៃថ្ងៃនក្ខត្តឫក្ស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តត្ថេវ មណ្ឌកប្បម្ហិ** សេចក្តីថា ក្នុងកប្បណាមានព្រះពុទ្ធកើតឡើង ២ ព្រះអង្គ កប្បនោះ យើងហៅអំពីខាងដើមថា មណ្ឌកប្ប ។ បទថា **វិជដេត្វា** បានដល់ ទ្រង់ដោះស្រាយពាក្យថា ជដ ក្នុងពាក្យថា **មហាជដំ** នេះ ជាឈ្មោះនៃតណ្ហា លោកពោលថា ពិតហើយ តណ្ហានោះ ឈ្មោះថា ជដ ព្រោះដូចគ្នានឹង ជដ ពោល គឺសរីរៈនៃសំណាញ់ ដែលចាក់ដោយអំបោះទាំងឡាយ ព្រោះកើតរឿយៗ ព្រោះក្រង់ដោយអំណាចតណ្ហាខាងក្រោម ខាងលើ ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ។ នូវព្រៃស្តុកដ៏ធំនោះ ។ បទថា **សទេវកំ** បានដល់ លោក ព្រមទាំងទេវលោក ។ បទថា **អភិវស្សិ** បានដល់ ឲ្យធ្លាក់ចុះមក ។ បទថា **អមតម្ពុនា** សេចក្តីថា កាលឲ្យឆ្អែត ទើបបង្អុរនូវទឹក គឺធម្មកថា ពោល គឺអមតធម៌ឲ្យធ្លាក់ចុះមក ។

កាលព្រះបាទសិរិវឌ្ឍ ក្រុងពារាណសី ទ្រង់លះគំនរភោគសម្បត្តិធំ ទ្រង់ព្រះផ្នួសជាតាបស មានតាបសដែលបួសជាមួយព្រះអង្គចំនួន ៩ លាន ព្រះមានព្រះភាគទ្រង់សម្តែងធម៌ប្រោសតាបសទាំងនោះ កាលនោះ ការត្រាស់ដឹងធម៌លើកទី ២ មានដល់សត្វ ៩ លាន ។ កាលទ្រង់សម្តែងធម៌ប្រោស អនុបមកុមារព្រះឱរសរបស់ព្រះអង្គ ការត្រាស់ដឹងធម៌លើកទី ៣ មានដល់

សត្វ ៨ លាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ សែន ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ សែន ដូច្នេះ ។

បន្ទាប់អំពីនោះ ព្រះសុរេវិត្តរាជឱរស និងព្រះធម្មសេនកុមារ បុរោហិតបុត្ត ក្នុងកណ្ណកុជ្ជនគរ កាលព្រះផុស្សសម្មាសម្ពុទ្ធយាងដល់នគររបស់ខ្លួន ក៏ចេញទៅទទួល មួយអន្លើដោយបុរស ៦ លាន ថ្វាយបង្គំហើយ និមន្ត ថ្វាយមហាទាន ៧ ថ្ងៃ ស្តាប់ធម្មកថារបស់ព្រះទសពលហើយ ជ្រះថ្លា មួយអន្លើដោយបរិវារនាំគ្នាបួស ហើយសម្រេចអរហត្ត ។ ព្រះមានព្រះភាគទ្រង់លើកបាតិមោក្ខឡើងសម្តែងកណ្តាលភិក្ខុ ៦ លាននោះ នេះជាសន្និបាតលើកទី ១ ។ ក្រោយមកទៀត ព្រះមានព្រះភាគទ្រង់សម្តែងពុទ្ធវង្សក្នុងសមាគមនៃព្រះញាតិប្រមាណ ៦០[១] របស់ព្រះបាទជ័យសេន ក្រុងកាសី ជន ៥ លាន ស្តាប់ពុទ្ធវង្សនោះ នាំគ្នាបួសដោយឯហិភិក្ខុ ហើយសម្រេចអរហត្ត ព្រះមានព្រះភាគ ទ្រង់នៅក្នុងកណ្តាលភិក្ខុទាំងនោះ ទ្រង់លើកបាតិមោក្ខឡើងសម្តែង នេះជាសន្និបាតលើកទី២ ។ បន្ទមកទៀត បុរស ៤ លាន ស្តាប់មង្គលកថា ក្នុងមហាមង្គលសមាគម នាំគ្នាបួសហើយ សម្រេចអរហត្ត ។ ព្រះសុគត ទ្រង់នៅក្នុងកណ្តាលភិក្ខុទាំងនោះ ទ្រង់លើកបាតិមោក្ខឡើងសម្តែង នេះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហេសី ព្រះនាមបុស្សៈ មានសាវកសន្និបាន ៣ លើក

---

១- ពាក្យថា ប្រមាណ ៦០ ប្រែចេញអំពីបាលីថា សដ្ឋិមត្តានំ ។

ដែលសុទ្ធតែជាពួកព្រះខីណាស្រព ឥតមានមន្ទិល គឺកិលេស
មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើក
ទី ១ មានព្រះខីណាស្រព ៦០ សែន សន្និបាតលើកទី ២
មានព្រះខីណាស្រពចំនួន ៥០ សែន ។ សន្និបាតលើកទី ៣
មានពួកព្រះខីណាស្រព ៤០ សែន លោកផុតស្រឡះហើយ
ព្រោះមិនប្រកាន់ មានតំណា គឺជាតិកាត់ផ្តាច់ហើយ ដូច្នេះ ។

គ្រានោះ ព្រះពោធិសត្វនៃយើង ទ្រង់ជាក្សត្រ ព្រះនាមវិជិតាវី ក្នុងនគរអរិន្ទម: ទ្រង់ស្តាប់ធម៌របស់ព្រះផុស្សសម្ពុទ្ធអង្គនោះ ទ្រង់ជ្រះថ្លាក្នុងព្រះមានព្រះភាគ ទ្រង់ថ្វាយមហាទានដល់ព្រះអង្គ ទ្រង់លះមហារាជសម្បត្តិ ទ្រង់ព្រះផ្នួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ ទ្រង់រៀនព្រះត្រៃបិដក ទ្រទ្រង់ព្រះត្រៃបិដក ត្រាស់ធម្មកថាដល់មហាជន ទ្រង់បំពេញសីលបារមី ព្រះផុស្សសម្ពុទ្ធអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតជាក្សត្រ ព្រះនាមវិជិត: លះបោលរាជ-
សម្បត្តិដ៏ធំ ទៅបួសក្នុងសម្នាក់ព្រះពុទ្ធនោះ ។ ព្រះពុទ្ធជាម្ចាស់
ព្រះនាមបុស្ស: ជាលោកគ្គនាយកនោះ បានទ្រង់ព្យាករតថាគត
ថា ក្នុងកប្បទី ៩២ អំពីកប្បនេះទៅ ភិក្ខុនេះ នឹងបានត្រាស់
ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទី
រីករាយ ទៅតម្កល់ព្យាយាម ។បេ។ ដើម្បីបំពេញបារមីទាំង

១០ ប្រការ ។

តថាគតរៀនយកនូវព្រះសូត្រផង ព្រះវិន័យផង ពាក្យប្រៀនប្រដៅព្រះសាស្ដា ប្រកបដោយអង្គ ៩ ទាំងអស់ផង ហើយញុំាំងសាសនាព្រះជិនស្រីឲ្យរុងរឿង ។

តថាគតមិនប្រមាទ សម្រេចសម្រាន្តនៅក្នុងសាសនានោះ ខំចម្រើនភាវនា ដែលប្រកបដោយព្រហ្មវិហារ ហើយដល់នូវបារមីក្នុងអភិញ្ញាទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោកដូច្នេះ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់មាននគរឈ្មោះកាសិកៈ ព្រះជនកព្រះនាមព្រះបាទជយសេន ព្រះជននីព្រះនាមព្រះនាងសិរិមា គូនៃអគ្គសាវកឈ្មោះសុរក្ខិតៈ ១ ធម្មសេន ១ ពុទ្ធុបដ្ឋាកឈ្មោះសភិយៈ គូនៃអគ្គសាវិកាឈ្មោះចាលា ១ ឧបចាលា ១ ពោធិព្រឹក្សឈ្មោះអាមលកៈ គឺដើមកន្ទួតព្រៃកម្ពស់សរីរៈ ៥៨ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ អគ្គមហេសីព្រះនាមកិសាគោតមី ព្រះរាជឱរសព្រះនាមអនុបមៈ ទ្រង់យាងចេញអភិនេស្ក្រមណ៍ដោយយាន គឺដំរី ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហេសី ព្រះនាមបុស្សៈ មានទីក្រុងឈ្មោះកាសិកៈ មានមហាក្សត្រ ព្រះនាមជយសេនជាព្រះបិតា មានព្រះជននីព្រះនាមសិរិមា ។បេ។ ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា អាមលកព្រឹក្ស ( ដើមកន្ទួតព្រៃ ) ។ ព្រះ

មុនីអង្គនោះ មានកម្ពស់ ៥៨ ហត្ថ ទ្រង់រុងរឿងដូចព្រះអាទិត្យ ឬដូចព្រះចន្ទពេញវង់ ។ ទ្រង់មានព្រះជន្ម ៩០ ពាន់ឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បានចម្លងប្រជុំជនជាច្រើន ។ ព្រះសាស្តាអង្គនោះ ព្រមទាំងសាវ័ក ទ្រង់មានយសប្រឹងពុំបាន ទ្រង់ទូន្មានពួកសត្វជាច្រើន ហើយចម្លងពួកសត្វជាច្រើន រួចបរិនិព្វានដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាមណ្ឌា** បានដល់ ដើមកន្ទួតព្រៃ ។ បទថា **ឱវធិត្វា** បានដល់ ឲ្យឱវាទ អធិប្បាយថា ប្រៀនប្រដៅ ។ បទថា **សោបិ សត្ថា អតុលយសោ** សេចក្តីថា ព្រះសាស្តាមានព្រះយសប្រឹងមិនបានអង្គនោះ ។ បាឋៈថា **សោ ជហិត្វា អមិតយសោ** ដូច្នេះក៏មាន បាឋៈនោះ សេចក្តីថា ទ្រង់ចាំបាច់លះនូវគុណវិសេសដូចពោលហើយសព្វយ៉ាង ។

បានឮថា ព្រះបុស្សសម្ពុទ្ធ រម្ងត់ខន្ធបរិនិព្វាន ក្នុងព្រះវិហារសេនារាម ក្នុងនគរកុសិនារា បានឮថា ព្រះបរមសារីរិកធាតុរបស់ព្រះអង្គផ្សាយទៅ គឺរាយទៅច្រើន ។ ក្នុងគាថាដ៏សេស ជាក់ច្បាស់ហើយនោះឯង ។

**អដ្ឋកថាផុស្សពុទ្ធវង្សទី ១៨ ចប់**

# សុត្តន្តបិដក

## វិបស្សិពុទ្ធវង្សទី ១៩

[ ២០ ] ក្រោយអំពីព្រះពុទ្ធព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធ ព្រះនាមវិបស្សីដ៏ឧត្តមជាងសត្វជើងពីរ ទ្រង់មានចក្ខុកើតឡើងក្នុង លោក ។ ព្រះអង្គទ្រង់រំលាយស៊ុត គឺអវិជ្ជាចេញ ហើយដល់ សម្ពោធិញ្ញាណដ៏ឧត្តម ទ្រង់ចៀសចេញទៅកាន់ពន្ធុមតីបុរី ដើម្បី ញ៉ាំងចក្ក គឺធម៌ឲ្យប្រព្រឹត្តទៅ ។ ព្រះនាយក ទ្រង់ញ៉ាំងចក្ក គឺធម៌ ឲ្យប្រព្រឹត្តទៅ រួចហើយ ញ៉ាំងខណ្ឌរាជកុមារ និងតិស្សកុមារទាំង ពីរ ឲ្យត្រាស់ដឹង ការត្រាស់ដឹងលើកទី ១ មានចំនួនសត្វ គេមិន គប្បីពោលដោយការរាប់ឡើយ ។ តមកទៀត ព្រះពុទ្ធជាម្ចាស់ មានយសរាប់មិនបាន ប្រកាសសច្ចៈទាំង ៤ ក្នុងបុរីនោះ ការ ត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួន ៨ ម៉ឺន ៤ ពាន់ ។ មាន មនុស្ស ៨ ម៉ឺន ៤ ពាន់ បួសតាមព្រះពុទ្ធ ព្រះពុទ្ធមានចក្ខុ ទ្រង់ សម្ដែងធម៌ដល់បព្វជិតទាំងនោះ ដែលមកដល់អារាម ។ ភិក្ខុទាំង នោះ អាស្រ័យព្រះជិនស្រី កាលទ្រង់សម្ដែងដោយអាការទាំងពួង ក៏បានសម្រេចនូវធម៌ដ៏ប្រសើរ នេះជាការត្រាស់ដឹងលើកទី ៣ ។ ព្រះមហេសី ព្រះនាមវិបស្សី មានសាវកសន្និបាត ៣ លើក ដែល សុទ្ធតែពួកព្រះខីណាស្រព ឥតមានមន្ទិល គឺកិលេស មានចិត្ត ស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ គឺសន្និបាតលើកទី ១ មាន ពួកព្រះខីណាស្រពចំនួន ៦៨ សែន សន្និបាតលើកទី ២ មានពួក

ព្រះទីណាស្រេពចំនួនមួយសែន ។ សន្និបាតលើកទី ៣ មានភិក្ខុចំនួន ៨ ម៉ឺន ព្រះសម្ពុទ្ធរុងរឿងក្នុងកណ្តាលពួកភិក្ខុនោះ ។ សម័យនោះ តថាគតកើតជាស្តេចនាគ ឈ្មោះអតុលៈ មានឫទ្ធិច្រើន មានបុណ្យ ទ្រទ្រង់ពន្លឺ ។ ក្នុងកាលនោះ តថាគតមានពួកនាគច្រើនកោដិចោមរោម ប្រគំតូរ្យតន្ត្រីដ៏ជាទិព្វ ហើយចូលទៅជិតព្រះលោកជេដ្ឋៈ ។ លុះចូលទៅដល់ហើយ ក៏និមន្តព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ហើយថ្វាយតាំងមាស ដែលដាំដោយកែវមណី និងកែវមុក្តា ដ៏ស្អិតស្អាងហើយ ដោយអាភរណៈគ្រប់យ៉ាង ដល់ព្រះអង្គជាធម្មរាជ ។ ព្រះពុទ្ធជាម្ចាស់នោះ ទ្រង់គង់នៅក្នុងកណ្តាលសង្ឃ ហើយព្យាករតថាគតថា ក្នុងកប្បទី ៩១ អំពីមណ្ឌកប្បនេះ ស្តេចនាគនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទីត្រេកអរ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងនូវសម្ពោធិញ្ញាណ ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតាព្រះនាម

សុទ្ធោទនៈ នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ នាងខេមាភិក្ខុនី ១ នាងឧប្បលវណ្ណាភិក្ខុនី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានជោគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះមហេសីព្រះនាមគោតមនោះ មានជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសីឥតមានបុគ្គលស្មើហើយ រីករាយថា នាគរាជនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើយើងឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថអង្គនេះ គង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងអនាគតកាលជាមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់បាន

សម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងអនាគតកាល យ៉ាងនោះដែរ ។ តថាគតបានស្ដាប់ព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះហើយ ញ៉ាំងចិត្តឲ្យរីងរឹតតែជ្រះថ្លា បានទាំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ប្រការ ។ ព្រះមហេសីព្រះនាមវិបស្សី មានទីក្រុងឈ្មោះ ពន្ធុមតី មានមហាក្សត្រ ព្រះនាមពន្ធុមៈជាព្រះបិតា មានព្រះមាតាព្រះនាមពន្ធុមតី ។ ព្រះវិបស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋាន អស់ ៨ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះនន្ទៈ ១ ប្រាសាទឈ្មោះសុនន្ទៈ ១ ប្រាសាទឈ្មោះសិរិមៈ ១ ។ ពួកនារីចំនួន ៤ ម៉ឺន ៣ ពាន់ សឹងមានខ្លួនតាក់តែងល្អ ឯនារីជាអគ្គមហេសី ព្រះនាមសុទស្សនា ព្រះរាជបុត្តព្រះនាមសមវត្តក្ខន្ធ ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ ហើយចេញទៅដោយយានរថ តម្កល់ព្យាយាម អស់ ៨ ខែគត់ ។ ព្រះវិបស្សី ជាលោកនាយក ទ្រង់មានព្យាយាមធំ ប្រសើរជាងជនត្រូវព្រហ្មអារាធនាហើយ ទើបញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះរាជកុមារនាម ខន្ធៈ ១ បុត្តនៃបុរោហិតនាមតិស្សៈ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះអសោក ជាឧបដ្ឋាកនៃព្រះមហេសីព្រះនាមវិបស្សី ។ នាងចន្ទាភិក្ខុនី ១ នាងចន្ទមិត្តាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា បាដលិព្រឹក្ស ។ បុនព្វសុមិត្តគហបតី ១ នាគ-

គហបតី ១ ជាអគ្គឧបដ្ឋាក នាងសិរិមា ១ នាងឧត្តរា ១ ជាអគ្គ-ឧបដ្ឋាយិកា ។ ព្រះវិបស្សី លោកនាយក មានកម្ពស់ ៨០ ហត្ថ ពន្លឺព្រះអង្គផ្សាយចេញទៅជុំវិញ ៧ យោជន៍ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានព្រះជន្ម ៨ ម៉ឺនឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បានចម្លងប្រជុំជនច្រើន ចាកសង្សារវដ្ត ។ ព្រះអង្គទ្រង់ដោះស្រាយនូវចំណងនៃទេវតា និងមនុស្សជាច្រើន ទាំងប្រាប់ផ្លូវត្រូវ ផ្លូវខុសចំពោះពួកបុថុជ្ជនដ៏សេសទៀតផង ។ ព្រះអង្គ ព្រមទាំងសាវក ទ្រង់សម្តែងពន្លឺ ហើយបង្ហាញឧបាយជាទីទៅកាន់ព្រះនិព្វាន ឈ្មោះអមតៈ ទ្រង់រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះសរីរៈដែលមានឫទ្ធិដ៏ខ្ពង់ខ្ពស់ មានបុណ្យដ៏ប្រសើរ ប្រដាប់ហើយដោយលក្ខណៈ គឺចក្ក គង់បាត់បង់អស់ទៅបាន ឱហ្ន៎ ! សង្ខារទាំងអស់ សោះសូន្យទទេតើ ! ព្រះវិបស្សីជានរៈដ៏ប្រសើរ ទ្រង់មានព្យាយាម បរិនិព្វានហើយ ក្នុងសុមិត្តារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះអង្គនោះ គេបានសាងទុកកម្ពស់ ៧ យោជន៍ក្នុងអារាមនោះ ។

## វិបស្សិពុទ្ធវង្សទី ១៩ ចប់

# អដ្ឋកថា

## វិបស្សិពុទ្ធវង្សទី ១៩

ក្រោយសម័យរបស់ព្រះផុស្សសម្ពុទ្ធ កប្បនោះ ព្រមទាំងអន្តរកប្ប កន្លងទៅ ក្នុងកប្បទី ៩១ រាប់អំពីភទ្ទកប្បនេះ ព្រះសាស្តាព្រះនាមវិបស្សី ទ្រង់ឃើញច្បាស់ក្នុងធម៌ទាំងពួង ទ្រង់ឈ្នះកប្បទាំងពួង ទ្រង់មានព្រះតម្រិះ ត្រេកអរក្នុងប្រយោជន៍របស់អ្នកដទៃ ទ្រង់កើតឡើងក្នុងលោក ទ្រង់បំពេញ បារមីទាំងឡាយ ហើយកើតក្នុងស្ថានសួគ៌ជាន់តុសិត ដែលរុងរឿងដោយពន្លឺ នៃរតនមុនីដ៏ច្រើន ចុតិអំពីនោះហើយ បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាង ពន្ធុមតី អគ្គមហេសីរបស់ព្រះបាទពន្ធុមៈ ទ្រង់មានញាតិច្រើន ក្នុងនគរ ពន្ធុមតី គ្រប់កំណត់ទសមាស ទ្រង់ក៏ប្រសូតចាកព្រះឧទររបស់ព្រះជននី ក្នុង ខេមមិគទាយវ័ន ដូចព្រះចន្ទពេញវង់ចេញចាកស្រទាប់ពពកពណ៌ខៀវចាស់ ។ ក្នុងថ្ងៃថ្វាយព្រះនាមរបស់ព្រះអង្គ ពួកហោរាទាយលក្ខណៈ និងព្រះញាតិ ទាំងឡាយ បានថ្វាយព្រះនាមថា វិបស្សី ព្រោះហោរាអ្នកទាយលក្ខណៈ និងព្រះញាតិឃើញជាក់ច្បាស់ ព្រោះមិនមានងងឹត ដែលកើតអំពីការប៉ប្រិច ភ្នែកក្នុងចន្លោះៗ ទាំងពេលថ្ងៃ និងពេលយប់ ឬទ្រង់ទតដោយមិនប៉ប្រិច ភ្នែក ។ អាចារ្យពួកខ្លះពោលថា ព្រះនាមថាវិបស្សី ព្រោះគប្បីពិចារណា ទើបឃើញ ។ ទ្រង់នៅជាឃរាវាសវិស័យអស់ ៨ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ឈ្មោះនន្ទៈ ១ សុនន្ទៈ ១ សិរិមា ១ មានស្រីស្នំ ១ សែន ២ ម៉ឺននាក់ ដែលមានព្រះនាងសុទស្សនាទេវីជាប្រធាន ព្រះនាងសុទស្សនា ហៅថា នាង សុតនូក៏មាន ។

កាលកន្លងទៅ ៨០០០ ឆ្នាំ កាលព្រះឱរសរបស់ព្រះនាងសុតនូទេវី ព្រះនាមសមវដ្តក្ខន្ធ ទ្រង់កើតឡើង ព្រះពោធិសត្វឃើញនិមិត្ត ៤ ទើបយាង ចេញមហាភិនេស្រ្កមណ៍ដោយរថដែលទឹមដោយសេះ បុរស ៨៤០០០ នាក់ ចេញបួសតាម ៗ ព្រះមហាបុរស កាលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់ បំពេញព្យាយាមអស់កាល ៨ ខែ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់សោយមធុ-បាយាស ដែលធីតាសុទស្សនសេដ្ឋីថ្វាយ ទ្រង់សម្រាកពេលថ្ងៃ ក្នុងព្រៃ សាលវ័ន ដែលប្រដាប់ដោយផ្កា ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអ្នកយាម ស្រូវជំណើបឈ្មោះសុជាតថ្វាយ ទ្រង់ឃើញពោធិព្រឹក្សឈ្មោះបាដលី គឺដើម ប្រទៀង ដែលកំពុងចេញផ្កា ទើបចូលទៅកាន់ពោធិព្រឹក្សនោះ តាមផ្លូវទិស ទក្សិណ ៗ

ថ្ងៃនោះ ដើមបាដលិព្រឹក្សនោះលូតឡើងលើ ៥០ ហត្ថ មានមែក ៥០ ហត្ថ កម្ពស់ ១០០ ហត្ថ ៗ ថ្ងៃនោះឯង ដើមបាដលីនោះ ចេញផ្កាដេរដាស ពេញដើមទាំងអស់ ចាប់តាំងអំពីគល់ឡើងទៅ ផ្កាទាំងឡាយមានក្លិនក្រអូប ក្រៃលែង ដូចចង់ជាចង្ក្រាម ក្លិនទិព្វផ្សាយទៅ ៗ មិនមែនតែដើមបាដលីនោះ មួយប៉ុណ្ណោះទេ ដែលចេញផ្កាក្នុងវេលានោះ ដើមបាដលីទាំងអស់ក្នុងម៉ឺន ចក្កវាឡ ក៏ចេញផ្ការីកស្គុះស្គាយដូចគ្នា មិនមែនដើមបាដលីតែម្យ៉ាងប៉ុណ្ណោះ ទេ សូម្បីតែដើមឈើ គុម្ពឈើ និងវល្លិទាំងឡាយ ក្នុងម៉ឺនចក្កវាឡក៏ចេញ ផ្ការីក ៗ មហាសមុទ្រ ក៏ដេរដាសទៅដោយឈូកក្រហម ព្រលិត ឧប្បល និងកោមុទដែលមានពណ៌ ៥ មហាសមុទ្រ មានទឹកត្រជាក់ មានរសឆ្ងាញ់

ក្នុងម៉ឺនចក្រវាឡ ដេរដាសដោយទង់ និងមាល័យ ផ្ទៃធរណីតាក់តែងដោយផ្កាមានក្លិនក្រអូបច្រើនប្រភេទ ក៏ដេរដាសដោយកម្រងមាល័យ ចម្រុះទៅដោយលម្អិតក្រអូប និងធូបក្រអូប ទ្រង់ចូលទៅកាន់គល់បាដលីនោះ ទ្រង់លាតសន្ថតស្មៅទំហំ ៥៣ ហត្ថ ទ្រង់អធិដ្ឋានព្យាយាមប្រកបដោយអង្គ ៤ គង់ប្រថាប់ធ្វើប្ដេជ្ញាថា បើអាត្មាអញ មិនបានត្រាស់ជាព្រះពុទ្ធដរាបណា ក៏មិនក្រោកចាកទីនេះដរាបនោះ កាលប្រថាប់គង់យ៉ាងនេះហើយ ទ្រង់កម្ចាត់មារនិងសេនា ទ្រង់ធ្វើមគ្គញ្ញាណ ៤ ដោយលំដាប់មគ្គ ផលញ្ញាណ ៤ ក្នុងលំដាប់បន្ទាប់អំពីមគ្គ បដិសម្ភិទា ៤ ចតុយោនិបរិច្ឆេទកញ្ញាណ គឺញាណដឹងកំណើត ៤ បញ្ចគតិបរិច្ឆេទកញ្ញាណ គឺញាណជាគ្រឿងដឹងគតិ ៥ វេសា-រជ្ជញ្ញាណ ៤ អសាធារណញ្ញាណ ៦ និងពុទ្ធគុណទាំងអស់ក្នុងព្រះហស្តទ្រង់មានព្រះតម្រិះបរិបូណ៌ ប្រថាប់គង់លើពោធិបល្ល័ង្កនោះឯង ទ្រង់បន្លឺឧទានយ៉ាងនេះថា

> កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វៀរតែ )
> ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
> ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគត
> បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។
> បុគ្គលរមែងមិនដឹងគតិ របស់ភ្លើងកំពុងឆេះ និងដុំដែកដែល
> គេដំហើយ ដែលរលត់ទៅដោយលំដាប់ យ៉ាងណាមិញ គតិ
> របស់ពួកលោកអ្នក រួចស្រឡះចាកកិលេសដោយប្រពៃ អ្នក

ធូនចាកចំណង និងឱឃៈ គឺកាម ដល់នូវសេចក្ដីសុខ មិន
ញាប់ញ័រ រមែងមិនអាចដឹងបានក៏យ៉ាងនោះដែរ មិនមានបុគ្គល
ដឹងនូវគតិ គឺការទៅរបស់បុគ្គលដែលរួចផុតដោយប្រពៃ ជា
អ្នកធូននូវចំណងកាម និងឱឃៈ ជាអ្នកដល់នូវសេចក្ដីសុខ
ដែលមិនញាប់ញ័រ ក៏ដូច្នោះ ។

ទ្រង់សម្រាំនៅអស់ ៧ សប្ដាហ៍ ក្បែរពោធិព្រឹក្សនោះឯង ទ្រង់ទទួលអារាធនារបស់មហាព្រហ្ម ទ្រង់ប្រមើលមើលឧបនិស្សយសម្បត្តិរបស់ខណ្ឌ-កុមារ កនិដ្ឋភាតាមាតាដទៃរបស់ព្រះអង្គ និងតិស្សកុមារបុរោហិតបុត្ត យាងទៅតាមអាកាស ចុះត្រង់ខេមមិគទាយវ័ន ទ្រង់ឲ្យឧទ្យានបាលទៅហៅជនទាំង ២ មកហើយ ទ្រង់ប្រកាសធម្មចក្រកណ្ដាលបរិវារទាំងនោះ កាលនោះការសម្រេចធម៌មានដល់ទេវតាទាំងឡាយប្រមាណមិនបាន ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

ក្រោយអំពីព្រះពុទ្ធព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធព្រះនាម
វិបស្សីដ៏ឧត្ដមជាងសត្វជើងពីរ ទ្រង់មានចក្ខុកើតឡើងក្នុង
លោក ។ ព្រះអង្គទ្រង់រំលាយស៊ុត គឺអវិជ្ជាចេញហើយ ដល់
សម្ពោធិញ្ញាណដ៏ឧត្ដម ទ្រង់ចៀសចេញទៅកាន់ពន្ធុមតីបុរី
ដើម្បីញុំាងចក្ក គឺធម៌ឲ្យបប្រព្រឹត្តទៅ ។ ព្រះនាយក ទ្រង់
ញុំាងចក្ក គឺធម៌ឲ្យប្រព្រឹត្តទៅ រួចហើយ ញុំាងខណ្ឌរាជកុមារ
និងតិស្សកុមារទាំងពីរ ឲ្យត្រាស់ដឹង ការត្រាស់ដឹងលើកទី ១

មានចំនួនសត្វ គេមិនគប្បីពោលដោយការរាប់ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បធានេត្វា** បានដល់ ទ្រង់ទម្លាយ អធិប្បាយថា ទម្លាយនូវងងឹត គឺអវិជ្ជា ។ បាឋៈថា **វត្តេត្វា ចក្កមាកាសេ** ដូច្នេះក៏មាន បាឋៈនោះ មានសេចក្តីនោះ បទថា **អាកាសេ** បានដល់ ក្នុងខេមមិគទាយវ័ន ។ បទថា **ឧភោ ពោធេសិ** បានដល់ ទ្រង់ញ៉ាំងកុមារទាំង ២ គឺខណ្ឌរាជឱរស ដែលជាប្អូនប្រុសរបស់ព្រះអង្គ និងតិស្សកុមារបុរោហិតបុត្តឲ្យត្រាស់ដឹង ។ បទថា **គណនាយ ន វត្តព្វោ** សេចក្តីថា មិនមានកំណត់ចំនួនទេវតា និងមនុស្សទាំងឡាយ ដោយការសម្រេចធម៌ឡើយ ។

សម័យក្រោយមក ទ្រង់ញ៉ាំងភិក្ខុ ៨៤០០០ ដែលបួសតាមព្រះខណ្ឌរាជឱរស និងតិស្សកុមារបុរោហិតបុត្ត ឲ្យផឹកនូវអមតធម៌ នេះជាការត្រាស់ដឹងធម៌លើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

តមកទៀត ព្រះពុទ្ធជាម្ចាស់ មានយសរាប់មិនបាន ប្រកាស
សច្ចៈទាំង ៤ ក្នុងបុរីនោះ ការត្រាស់ដឹងលើកទី ២ មាន
ពួកសត្វចំនួន ៨ ម៉ឺន ៤ ពាន់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តត្ថ** បានដល់ ត្រង់ខេមមិគទាយវ័ន ក្នុងពាក្យថា **ចតុរាសីតិសហស្សានិ សម្ពុទ្ធមនុបព្វជុំ** នេះ បុរសដែលមានចំនួន ៨៤០០០ ទាំងនេះ គឺ ពួកបុរសដែលទទួលបម្រើព្រះវិបស្សីកុមារនោះឯង បុរសទាំងនោះ ទៅកាន់ទីបម្រើព្រះវិបស្សីកុមារអំពីព្រលឹម មិនឃើញព្រះរាជកុមារ ក៏ត្រឡប់ទៅដើម្បីបរិភោគអាហារព្រឹក លុះបរិភោគអាហារហើយ

សួរគ្នាថា ព្រះរាជកុមារនៅឯណា បន្ទាប់អំពីនោះ បានស្តាប់ដំណឹងថា ទ្រង់យាងទៅកាន់រាជឧទ្យាន ទើបនាំគ្នាចេញទៅដោយបំណងថា នឹងជួបព្រះអង្គក្នុងរាជឧទ្យាននោះ ឃើញសារថីរបស់ព្រះអង្គត្រឡប់មក បានដំណឹងថា ព្រះរាជកុមារបួសហើយ ក៏ដោះអាភរណៈទាំងអស់ ក្នុងទីដែលបានទទួលដំណឹងនោះឯង ឲ្យនាំសំពត់កាសាវៈមកអំពីផ្សារ កោរសក់ និងពុកមាត់ នាំគ្នាបួស បុរសទាំងនោះ កាលបួសហើយ ក៏នាំគ្នាចោមរោមមហាបុរស ។

បន្ទាប់អំពីនោះ ព្រះវិបស្សីពោធិសត្វ ទ្រង់ព្រះតម្រិះថា អាត្មាអញកាលបំពេញព្យាយាម តែនៅប្រឡូកប្រឡំ សេចក្តីនេះ មិនសមគួរ មនុស្សទាំងនេះ កាលនៅជាគ្រហស្ថ ក៏នាំគ្នាហែហមអញ ប្រយោជន៍អ្វីដោយមនុស្សទាំងនេះ ទ្រង់នឿយណាយដោយការប្រឡូកប្រឡំដោយពួកគណៈ ទ្រង់ព្រះតម្រិះថា នឹងទៅក្នុងថ្ងៃនេះឯង ទ្រង់ព្រះតម្រិះទៀតថា ថ្ងៃនេះ មិនមែនកាលបើអញទៅក្នុងថ្ងៃនេះ អ្នកទាំងនេះនឹងដឹង ស្អែកនេះ សឹមអាត្មាអញទៅ ។ ក្នុងថ្ងៃនោះឯង មនុស្សក្នុងស្រុកមួយ ដូចគ្នានឹងឧរុវេលគាម បាននិមន្តព្រះមហាបុរស និងបរិវារដើម្បីសោយក្នុងថ្ងៃស្អែក ។ បានចាត់ចែងមធុបាយាសប៉ុណ្ណោះ ដើម្បីបព្វជិត ៨៤០០០ អង្គនោះ មួយអន្លើដោយមហាបុរស ។ ស្អែកឡើង ក្នុងថ្ងៃវិសាខបុណ្ណមី ព្រះវិបស្សីមហាបុរសសោយភត្តាហារជាមួយនឹងជនដែលបួសទាំងនោះក្នុងថ្ងៃនោះហើយ ក៏យាងចូលទៅកាន់លំនៅក្នុងទីនោះ បព្វជិតទាំងនោះ សម្តែងវត្តបដិបត្តិ ដល់ព្រះមហាបុរសហើយ ក៏នាំគ្នាទៅកាន់លំនៅសម្រាប់សម្រាកពេលយប់ និងពេលថ្ងៃរៀងៗ ខ្លួន ។

ព្រះពោធិសត្វចូលទៅកាន់បណ្ណសាលា ប្រថាប់គង់ ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ ជាថ្ងៃសមគួរនឹងចេញទៅបាន ទើបទ្រង់យាងចេញអភិនេស្រ្កមណ៍ ទ្រង់បិទទ្វារបណ្ណសាលា បែរព្រះភក្ត្រទៅកាន់ពោធិមណ្ឌលដ្ឋាន បានឮថា បព្វជិតទាំងនោះ ក្នុងពេលល្ងាច ក៏នាំគ្នាទៅកាន់ទីប្រណិប័តន៍ព្រះពោធិសត្វ អង្គុយត្រង់បណ្ណសាលាពោលថា ព្រលប់ហើយ ពួកយើងពិនិត្យមើលចុះ ទើបបើកទ្វារបណ្ណសាលា ក៏មិនឃើញព្រះពោធិសត្វ នាំគ្នាគិតថា មហាបុរស ទៅណាហ្ន៎ មិននាំគ្នាទៅតាមគិតថា មហាបុរសប្រហែលជានឿយណាយ ក្នុងការរស់នៅជាពួកជាគណៈ បំណងនៅឯកអង្គ ពួកយើងនឹងជួបព្រះអង្គ ក្នុងកាលដែលទ្រង់បានត្រាស់ជាព្រះពុទ្ធប៉ុណ្ណោះ ទើបនាំគ្នាចារិក បែរមុខទៅ ក្នុងជម្ពូទ្វីប ។ គ្រានោះ បព្វជិតទាំងនោះបានដំណឹងថា បានឮថា ព្រះវិបស្សី បានត្រាស់ជាព្រះពុទ្ធហើយ ប្រកាសធម្មចក្រ ទើបប្រជុំគ្នាត្រង់ខេមមិគ-ទាយវ័ន ពន្ធុមតីរាជធានីដោយលំដាប់ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់ក៏សម្តែងធម៌ប្រោសបព្វជិតទាំងនោះ ។ កាលនោះ ការត្រាស់ដឹងធម៌ មានដល់ភិក្ខុ ៨៤០០០ នេះជាការត្រាស់ធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> មានមនុស្ស ៨ ម៉ឺន ៤ ពាន់ បួសតាមព្រះពុទ្ធ ព្រះពុទ្ធមាន
> ចក្ខុ ទ្រង់សម្តែងធម៌ដល់បព្វជិតទាំងនោះ ដែលមកដល់
> អារាម ។ ភិក្ខុទាំងនោះ អាស្រ័យព្រះជិនស្រី កាលទ្រង់
> សម្តែងដោយអាការទាំងពួង ក៏បានសម្រេចនូវធម៌ដ៏ប្រសើរ

*នេះជាការត្រាស់ដឹងលើកទី ៣ ដូច្នេះ ។*

*ក្នុងបទថា* **ចតុរាសីតិសហស្សានិ សម្ពុទ្ធំ អនុបព្វជុំ** *នេះ ក្នុងគាថានោះ គប្បីជ្រាបថា លោកធ្វើជាទុតិយាវិភត្តិថា* **សម្ពុទ្ធំ** *ដោយប្រកប* **អនុ** *សព្ទ សេចក្តីថា បួសខាងក្រោយព្រះសម្ពុទ្ធ គប្បីកាន់យកលក្ខណៈតាមសព្ទសាស្ត្រ ( បទថា* **តេសមារាមបត្តានំ)** មានបាឋៈថា **តត្ថ អារាមបត្តានំ** *ដូច្នេះក៏មាន ។ បទថា* **ភាសតោ** *បានដល់ ត្រាស់ដឹង ។ បទថា* **ឧបនិសានិនោ** *សេចក្តីថា យាងទៅប្រទាន ធម៌តាមឧបនិស្ស័យ ។ បទថា* **តេបិ** *បានដល់ បព្វជិតនោះប្រមាណ ៨ ម៉ឺន ៤ ពាន់ ជាអ្នកបម្រើព្រះវិបស្សីសម្ពុទ្ធ ។ បទថា* **គន្ត្វា** *បានដល់ ដឹងធម៌របស់ព្រះអង្គ ។ ការត្រាស់ធម៌លើកទី ៣ មានដល់បព្វជិតទាំងនោះ ដោយប្រការយ៉ាងនេះ ។ ព្រះមានព្រះភាគវិបស្សីប្រថាប់គង់ត្រង់កណ្តាលភិក្ខុ ១ សែន ៦ ម៉ឺន ៨ ពាន់*[១] *ដែលបួសតាមព្រះវិបស្សីសម្ពុទ្ធ និងអគ្គសាវកទាំងពីរ ក្នុងខេមមិគទាយវ័នទ្រង់លើកបាតិមោក្ខឡើងសម្តែងដូច្នេះថា*

**ខន្តី បរមំ តបោ តិតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា**
**ន ហិ បព្វជិតោ បរូបឃាតី ន សមណោ ហោតិ បរំ**
**វិហេឋយន្តោ ។**

*អធិវាសនខន្តី ពោល គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម*
*ព្រះពុទ្ធទាំងឡាយតែងត្រាស់ថា ព្រះនិព្វានជាធម៌ដ៏ឧត្តម*

---

*១- បិដកខ្មែរជា ៦៨ សែន ។*

បព្វជិតអ្នកសម្លាប់សត្វដទៃ បៀតបៀនសត្វដទៃ មិនឈ្មោះ
ថា សមណៈឡើយ ។

**សព្វបាបស្ស អករណំ កុសលស្ស ឧបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ។**

ការមិនធ្វើអំពើបាបទាំងពួង ការបំពេញកុសល ការញុំាង
ចិត្តរបស់ខ្លួនឲ្យផូរផង់ ទាំង ៣ នេះ ជាពាក្យប្រដៅរបស់
ព្រះពុទ្ធទាំងឡាយ ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ**
**មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ**
**អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធានសាសនំ។**

ការមិនពោលតិះដៀល ការមិនបៀតបៀន ការសង្រួម ក្នុង
បាតិមោក្ខ ការៈជាអ្នកដឹងប្រមាណក្នុងភត្ត ទីដេក ទីអង្គុយដ៏
ស្ងាត់ ការបំពេញព្យាយាមក្នុងអធិចិត្ត ទាំង ៦ នេះជាពាក្យ
ប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ដូច្នេះ ។

គប្បីជ្រាបថា នេះជាបាតិមោក្ខទេសគាថា របស់ព្រះពុទ្ធគ្រប់អង្គ នេះជាសន្និបាតលើកទី ១ ។ បន្ទាប់មកទៀត សន្និបាតលើកទី ២ មានដល់ភិក្ខុមួយសែន ដែលឃើញយមកបដិហារ្យហើយបួស ។ កាលព្រះកនិដ្ឋភាតាមាតាដទៃ ៣ អង្គនៃព្រះវិបស្សីសម្ពុទ្ធ ធ្វើបច្ចន្តប្បទេសឲ្យរាបទាបហើយបានទទួលពរ ដោយការទំនុកបម្រុងព្រះមានព្រះភាគ នាំព្រះសាស្ដាមកកាន់

នគររបស់ព្រះអង្គហើយ ទំនុកបម្រុង ទ្រង់ស្តាប់ធម៌របស់ព្រះពុទ្ធអង្គហើយ ទ្រង់ព្រះផ្នួស ។ ព្រះមានព្រះភាគប្រថាប់គង់ក្នុងកណ្តាលភិក្ខុ ៨ លាន[១] នោះ ទ្រង់លើកបាតិមោក្ខឡើងសម្តែង ក្នុងខេមមិគទាយវ័ន នេះជាសន្និបាត លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហេសីព្រះនាមវិបស្សី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែពួកព្រះខីណាស្រព ឥតមានមន្ទិល គឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ គឺសន្និបាតលើក ទី ១ មានពួកព្រះខីណាស្រពចំនួន ៦៨ សែន សន្និបាត លើកទី ២ មានពួកព្រះខីណាស្រពចំនួនមួយសែន ។ សន្និបាត លើកទី ៣ មានភិក្ខុចំនួន ៨ ម៉ឺន ព្រះសម្ពុទ្ធរុងរឿងក្នុង កណ្តាលពួកភិក្ខុនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អដ្ឋសដ្ឋិសតសហស្សានំ** សេចក្តីថា ភិក្ខុទាំងឡាយ ១ សែន ៦ ម៉ឺន ៨ ពាន់រូប[២] ។ បទថា **តត្ថ** បានដល់ ខេមមិគទាយវ័ននោះ ។ បទថា **ភិក្ខុគណមជ្ឈេ** បានដល់ កណ្តាលពួកនៃភិក្ខុ ។ បាឋៈថា **តស្សភិក្ខុគណមជ្ឈេ** ដូច្នេះក៏មាន សេចក្តីថា កណ្តាលពួកភិក្ខុនោះ ។

ព្រះពោធិសត្វនៃយើងជាស្តេចនាគ ឈ្មោះអតុលៈ មានឫទ្ធានុភាពច្រើន

---

១- បិដកខ្មែរជា ៨ ម៉ឺន ។ ២- សង្ខ្យានេះ ប្រែមកពីបាលីថា អដ្ឋសដ្ឋិសហស្សាធិកានំ សតសហស្សភិក្ខូនន្តិ ។

មាននាគមួយសែនកោដិជាបរិវារ សាងមណ្ឌបសម្រេចដោយរតនៈ ៧ ប្រការ មានគ្រោងមណ្ឌប និងចំណែកប្រកបគួរមើល ដូចគ្នានឹងមណ្ឌលព្រះចន្ទ ដើម្បីធ្វើសក្ការៈដល់ព្រះទសពល មានកម្លាំង និងសីល ដែលមិនមានបុគ្គលស្មើ មានព្រះហឫទ័យត្រជាក់ដោយករុណា មួយអន្លើដោយបរិវារ និមន្តឲ្យប្រថាប់គង់នៅក្នុងមណ្ឌបនោះ ថ្វាយមហាទានដ៏សមគួរដល់សម្បត្តិទិព្វ ៧ ថ្ងៃ បានថ្វាយតាំងមាស ដែលរំលិចដោយរតនៈ ៧ ប្រការ ដ៏រុងរឿងដោយពន្លឺនៃកែវមណីផ្សេងៗ សមគួរក្រៃលែងដល់ព្រះមានព្រះភាគ ។ កាលនោះ ព្រះវិបស្សីសម្ពុទ្ធទ្រង់ព្យាករព្រះពោធិសត្វនោះ ក្នុងកាលចប់អនុមោទនាបីបទានថា ក្នុង ៩១ កប្ប អំពីកប្បនេះ ស្តេចនាគនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតកើតជាស្តេចនាគ ឈ្មោះអតុលៈ មានឫទ្ធិច្រើន មានបុណ្យ ទ្រទ្រង់ពន្លឺ ។ ក្នុងកាលនោះ តថាគតមានពួកនាគច្រើនកោដិចោមរោម ប្រគំតូរ្យតន្ត្រីដ៏ជាជាទិព្វ ហើយចូលទៅជិតព្រះលោកជេដ្ឋៈ ។ លុះចូលទៅដល់ហើយ ក៏និមន្តព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ហើយថ្វាយតាំងមាស ដែលដាំដោយកែវមណី និងកែវមុក្តា ដ៏ស្អិតស្អាងហើយ ដោយអាភរណៈគ្រប់យ៉ាង ដល់ព្រះអង្គជាធម្មរាជ ។ ព្រះពុទ្ធជាម្ចាស់នោះ ទ្រង់គង់នៅក្នុងកណ្តាលសង្ឃ ហើយព្យាករតថាគតថា ក្នុងកប្បទី ៩១ អំពីមណ្ឌកប្ប

នេះ ស្តេចនាគនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទីត្រេកអរ ទៅតម្កល់ព្យាយាមធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងនូវសម្ពោធិញ្ញាណ ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះពុទ្ធនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ នាគរាជនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ នាងខេមាភិក្ខុនី ១ នាងឧប្បលវណ្ណាភិក្ខុនី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ។ ដើមឈើជាទីត្រាស់ដឹងនៃព្រះមានជោគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ។បេ។ តថាគតបានស្តាប់ព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះ ហើយញុំាំងចិត្ត

ឲ្យរីងរឹតតែជ្រះថ្លា បានទំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមី ទាំង ១០ ប្រការ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុញ្ញវន្តោ** បានដល់ មានបុណ្យ អធិប្បាយថា ជាអ្នកមានគំនរបុណ្យសន្សំហើយ ។ បទថា **ជុតិន្ធរោ** បានដល់ ប្រកបដោយរស្មី ។ បទថា **នេកានំ នាគកោដីនំ** គឺ **អនេកាហិ នាគកោដីហិ** ពាក្យនេះ គប្បីឃើញថា ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថតតិយាវិភត្តិ ។ បទថា **បរិវារេត្វាន** បានដល់ ចោមរោមព្រះមានព្រះភាគ ។ ទ្រង់សម្ដែងព្រះអង្គដោយពាក្យថា **អហំ**។ បទថា **វជ្ជន្តោ** បានដល់ ប្រគំ ។ បទថា **មណិ-មុត្តារតនខចិតំ** សេចក្ដីថា រំលេចដោយរតនៈច្រើនប្រភេទ មានកែវមណីនិងកែវមុក្ដាជាដើម ។ បទថា **សព្វាភរណវិភូសិតំ** សេចក្ដីថា ប្រដាប់ដោយអាភរណៈសព្វយ៉ាង ដែលសម្រេចដោយរតនៈ ដូចរូបសត្វសាហាវជាដើម ។ បទថា **សុវណ្ណបីឋំ** បានដល់ តាំងដែលសម្រេចដោយមាស ។ បទថា **អធាសហំ** កាត់បទជា **អធាសឹ អហំ**។

ព្រះមានព្រះភាគវិបស្សីអង្គនោះ ទ្រង់មាននគរឈ្មោះពន្ធុមតី ព្រះបិតាព្រះនាមពន្ធុមា ព្រះមាតាព្រះនាមពន្ធុមតី គូនៃអគ្គសាវកឈ្មោះខណ្ឌៈ[១] ១ តិស្សៈ ១ ពុទ្ធុបដ្ឋាកឈ្មោះអសោក គូអគ្គសាវិកា ឈ្មោះចន្ទា ១ ចន្ទមិត្តា ១ មានដើមបាដលីជាពោធិព្រឹក្ស មានព្រះសរីរៈ កម្ពស់ ៨០ ហត្ថ រស្មីនៃសរីរៈផ្សាយទៅ ៧ យោជន៍សព្វកាល ព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ អគ្គមហេសី

---

១- បិដកខ្មែរជាខន្ធៈ ។

របស់ព្រះអង្គព្រះនាមសុតនូ ព្រះរាជឱរសរបស់ព្រះអង្គព្រះនាមសមវត្តក្ខន្ធៈ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយរថទឹមដោយសេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហេសីព្រះនាមវិបស្សី មានទីក្រុងឈ្មោះពន្ធុមតី មានមហាក្សត្រ ព្រះនាមពន្ធុមៈជាព្រះបិតា មានព្រះមាតាព្រះនាមពន្ធុមតី ។ ព្រះរាជកុមារនាមខន្ធៈ ១ បុត្តនៃបុរោហិតនាមតិស្សៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះអសោកជាឧបដ្ឋាកនៃព្រះមហេសីព្រះនាមវិបស្សី ។ នាងចន្ទាភិក្ខុនី ១ នាងចន្ទមិត្តាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថា បាដលិព្រឹក្ស ។ ព្រះវិបស្សីលោកនាយក មានកម្ពស់ ៨០ ហត្ថ ពន្លឺព្រះអង្គផ្សាយចេញទៅជុំវិញ ៧ យោជន៍ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានព្រះជន្ម ៨ ម៉ឺនឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បានចម្លងប្រជុំជនច្រើនចាកសង្សារវដ្ត ។ ព្រះអង្គទ្រង់ដោះស្រាយនូវចំណងនៃទេវតា និងមនុស្សជាច្រើន ទាំងប្រាប់ផ្លូវត្រូវផ្លូវខុសចំពោះពួកបុថុជ្ជនដ៏សេសទៀតផង ។ ព្រះអង្គ ព្រមទាំងសាវក ទ្រង់សម្តែងពន្លឺ ហើយបង្ហាញឧបាយជាទីទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ទ្រង់រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះសរីរៈដែលមានឫទ្ធិដ៏ខ្ពង់ខ្ពស់ មានបុណ្យដ៏ប្រសើរ ប្រដាប់

ហើយដោយលក្ខណៈ គឺចក្ក គង់បាត់បង់អស់ទៅបាន ឱហ្ន៎ !

សង្ខារទាំងអស់ សោះសូន្យទទេតើ ! ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពន្ធនា** សេចក្ដីថា ដោះនូវទេវតា និង មនុស្សអំពីចំណង មានកាមរាគសំយោជនៈជាដើម ។ បទថា **មគ្គាមគ្គញ្ច អាចិក្ខិ** សេចក្ដីថា ទ្រង់ប្រាប់បុថុជ្ជនដ៏សេសថា ផ្លូវ គឺមជ្ឈិមប្បដិបទា វៀរ ចាកឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិនេះ ជាផ្លូវដើម្បីសម្រេចអមតធម៌ ការធ្វើ ខ្លួនឲ្យលំបាកទទេជាដើមនេះ មិនមែនផ្លូវ ។ បទថា **អាលោកំ ទស្សយិត្វាន** បានដល់ ទ្រង់សម្ដែងពន្លឺ គឺមគ្គញាណ និងពន្លឺ គឺវិបស្សនាញាណ ។ បទ ថា **លក្ខណញ្ច កុសុមិតំ** សេចក្ដីថា ព្រះសរីរៈរបស់ព្រះមានព្រះភាគ ល្អពេញហើយ ប្រដាប់ហើយដោយព្រះលក្ខណៈដ៏វិចិត្រជាដើម ។ ពាក្យ ដ៏សេស ក្នុងគាថាទាំងឡាយសព្វអន្លើ មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថា វិបស្សិពុទ្ធវង្សទី ១៩ ចប់**

# សុត្តន្តបិដក

## សិខិពុទ្ធវង្សទី ២០

[ ២១ ] ក្រោយព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាមសិខី ជិនស្រី ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹមបាន ។ ព្រះអង្គកម្ចាត់បង់សេនានៃមារ ហើយដល់សម្ពោធិញ្ញាណដ៏ប្រសើរ ញុំាងចក្ក គឺធម៌ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីអនុគ្រោះដល់ពួកសត្វ ។ កាលព្រះសិខីជិនស្រីដ៏ប្រសើរ ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វចំនួនមួយសែនកោដិ ។ កាលព្រះសិខីប្រសើរជាងគណៈ ឧត្តមជាងជន ទ្រង់សម្តែងធម៌ដទៃទៀត ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួន ៩០ ពាន់កោដិ ។ កាលព្រះសិខី ទ្រង់សម្តែងយមកប្បាដិហារ្យ ក្នុងមនុស្សលោក ព្រមទាំងទេវលោក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ ពាន់កោដិ ។ ព្រះមហេសីព្រះនាមសិខី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព ឥតមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានភិក្ខុចំនួនមួយសែនរូប សន្និបាតលើកទី ២ មានពួកភិក្ខុចំនួន ៨ ម៉ឺនរូប ។ សន្និបាតលើកទី ៣ មានពួកភិក្ខុចំនួន ៧ ម៉ឺនរូប ជាសមាគមមិនប្រឡាក់ ( ដោយពួកបុថុជ្ជន ) ដូចបទុមជាតិ ដែលលូតលាស់នៅក្នុងទឹក ។

សម័យនោះ តថាគតជាក្សត្រនាមអរិន្ទម: បានញ៉ាំងព្រះសង្ឃមានព្រះសម្ពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ តថាគតបានប្រគេនសំពត់ជាច្រើន គឺកោដិនៃសំពត់មិនតិច ហើយថ្វាយយានដំរី ដ៏ប្រដាប់ហើយដល់ព្រះសម្ពុទ្ធ ។ តថាគតសាងយានដំរី ហើយបង្អោនចូលទៅជិត ឲ្យជារបស់គួរបំពេញចិត្តរបស់តថាគត ឲ្យតម្កល់នៅមាំ អស់កាលជានិច្ច ។ ព្រះពុទ្ធព្រះនាមសិខី ជាលោកគ្គនាយកនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បទី ៣១ អំពីមណ្ឌកប្បនេះ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទីរីករាយទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលយកបាយាសនៅទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះពុទ្ធនេះ នឹងមានព្រះជននីព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះរាជាអង្គនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មាន

ចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹង បម្រើព្រះជិនស្រីអង្គនេះ ។ នាងខេមាភិក្ខុនី ១ នាងឧប្បលវណ្ណាភិក្ខុនី ១ ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនេះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសនោះ មានព្រះជន្ម ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតាលុះបានស្តាប់ ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើហើយ រីករាយ ថា ព្រះរាជាអង្គនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោ ក៏ ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលី នមស្ការថា បើពួកយើងនឹងឃ្លាង មគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក្នុងអនាគតកាលមិន ខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ខាងលើ គង់ទៅ កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងបាន យ៉ាងណាមិញ ពួក យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក្នុងអនាគតកាល យ៉ាងនោះដែរ ។ ឯតថាគតលុះបានស្តាប់ព្រះពុទ្ធដីកា នៃព្រះអង្គ

នោះហើយ រីងរឹតតែធ្វើចិត្តឲ្យជ្រះថ្លា ហើយបានទំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ប្រការ ។ ព្រះមហេសីព្រះនាមសិខី មានទីក្រុងឈ្មោះអរុណវតី មានព្រះមហាក្សត្រ ព្រះនាមអរុណៈ ជាព្រះបិតា មានព្រះជននីព្រះនាមបភាវតី ។ ព្រះអង្គទ្រង់គ្រប់គ្រងគេហដ្ឋាន អស់ ៧ ពាន់ឆ្នាំ ទ្រង់មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះសុវឌ្ឍកៈ ១ ប្រាសាទឈ្មោះគិរី ១ ប្រាសាទឈ្មោះនារីវាហនៈ ១ ។ ពួកនារីចំនួន ២ ម៉ឺន ៤ ពាន់ សឹងមានខ្លួនតាក់តែងល្អហើយ ឯនាងនារីជាអគ្គមហេសីនោះ ព្រះនាមសព្វកាមា ព្រះរាជបុត្រព្រះនាមអតុលៈ ។ ( ព្រះតថាគត ) ជាបុរសដ៏ឧត្តម ទ្រង់ឃើញនិមិត្តទាំង ៤ ហើយ ចេញទៅដោយយានដំរី បានប្រព្រឹត្តធ្វើព្យាយាមអស់ ៨ ខែគត់ ។ ព្រះសិខីលោកគ្គនាយក មានព្យាយាមដ៏ធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះមហេសីព្រះនាមសិខី មានអភិភូភិក្ខុ ១ សម្ភវភិក្ខុ ១ ជាអគ្គសាវក ភិក្ខុឈ្មោះខេមង្ករៈជាឧបដ្ឋាក ។ នាងមខិលាភិក្ខុនី ១ នាងបទុមាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ គេហៅថា បុណ្ឌរីកព្រឹក្ស ( ដើមស្វាយ-ស ) សិរិវឌ្ឍគហបតី ១ នន្ទគហបតី ១ ជាអគ្គឧបដ្ឋាក នាងចិត្តា ១ នាងសុចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធអង្គនោះ ទ្រង់មាន

កម្ពស់ ៧០ ហត្ថ ប្រាកដស្មើដោយគ្រឿងមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ ព្រះពុទ្ធជាម្ចាស់អង្គនោះ មានពន្លឺប្រមាណមួយព្យាម ផ្សាយចេញអំពីព្រះកាយជានិច្ច ផ្សាយចេញទៅកាន់ទិសតូច និងទិសធំ ក៏ចេញទៅចម្ងាយ ៣ យោជន៍ ។ ព្រះមហេសីអង្គនោះ មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ព្រះអង្គកាលទ្រង់គង់ធរមាននៅឡើយ បានញុំាងប្រជុំជនជាច្រើនឲ្យឆ្លង ( ត្រើយសង្សារវដ្ត ) ។ ព្រះពុទ្ធនោះ ព្រមទាំងសាវកបន្ទុរក្មៀង គឺធម៌ស្រោចស្រពផ្ញើមពួកមនុស្ស ព្រមទាំងទេវតា ធ្វើឲ្យដល់នូវសេភាពក្សេមក្សាន្ត ហើយបរិនិព្វាន ព្រះសរីរៈបរិបូណ៌ដោយអនុព្យញ្ជនៈមានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ គង់បាត់បង់សូន្យទាំងអស់ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ។ ព្រះសិខីសម្ពុទ្ធ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអស្សារាម ព្រះស្តូបដ៏ប្រសើរនៃព្រះអង្គនោះ គេបានសាងទុកកម្ពស់ ៣ យោជន៍ក្នុងទីនោះឯង ។

## សិរិពុទ្ធវង្សទី ២០ ចប់

# អដ្ឋកថា

## សិខិពុទ្ធវង្សទី ២០

បន្ទាប់អំពីសម័យព្រះវិបស្សីសម្ពុទ្ធ កាលកប្បនោះអន្តរធានទៅហើយ បន្ទាប់អំពីនោះ ព្រះពុទ្ធទាំងឡាយ ក៏មិនកើតឡើងក្នុងលោក ៥៩ កប្ប លោកប្រាសចាកពន្លឺរបស់ព្រះពុទ្ធ ឯករាជរបស់កិលេសមារ និងទេវបុត្តមារ ក៏ប្រាសចាកគ្រឿងរារាំង ។ ក្នុង ៣១ កប្បរាប់អំពីកប្បនេះ ព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គកើតឡើងក្នុងលោក គឺព្រះសិខី និងព្រះវេស្សភូ ទ្រង់ដូចជាភ្លើងឈើខ្ទឹមដែលស្ងួតល្អស្រោចដោយសប្បិដ៏ច្រើន មិនមានផ្សែង ។ បណ្តាព្រះសម្ពុទ្ធ ២ ព្រះអង្គនោះ ព្រះមានព្រះភាគសិខី ទ្រង់បំពេញបារមីទាំងឡាយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះ ទ្រង់បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងបភាវតីទេវី ជាអ្នកមានពន្លឺល្អ ដូចបដិមាមាស ជាអគ្គមហេសីរបស់ព្រះបាទអរុណ ជាក្សត្រមានគុណក្រៃលែង ក្នុងអរុណវតីនគរ ព្រះនាងធ្វើតែកុសល លុះកន្លងទៅ ១០ ខែ ព្រះពោធិសត្វក៏ប្រសូតចាកព្រះឧទររបស់ព្រះជននី ត្រង់និសភរាជឧទ្យាន ។ ឯហោរាអ្នកទាយនិមិត្ត កាលថ្វាយព្រះនាម ក៏ថ្វាយព្រះនាមថា សិខី ព្រោះកំពូលជុំវិញព្រះកត្រ្កផុសឡើងដូចកំពូលព្រះឧណ្ហិស ។ ព្រះពោធិសត្វសោយរាជ្យដោយរាវាសអស់ ៧ ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ ឈ្មោះសុចន្ទកសិរី ១ គិរិយស ១ នារិវសភៈ ១[១] មានស្រីស្នំ ២៤០០០ នាក់ មាននាងសព្វកាមទេវីជាប្រធាន ។

---

១- បិដកខ្មែរជា សុវឌ្ឍនៈ ១ គិរី ១ នារីវាហនៈ ១ ។

កាលព្រះរាជឱរសព្រះនាមអតុលៈ ជាបុគ្គលមិនអាចថ្លឹងបាន មិនមានបុគ្គលប្រៀនបានដោយគុណ របស់ព្រះនាងសព្វកាមាទេវីប្រសូត ព្រះមហាបុរសទ្រង់ឃើញនិមិត្ត ៤ ទ្រង់ឡើង-កដរី ចេញមហាភិនេស្រ្កមណ៍ដោយយាន គឺដរី ទ្រង់ព្រះផ្នួស បុរស ១ សែន ៣ ម៉ឺន ៧ ពាន់នាំគ្នាបួសតាម ។ ព្រះពោធិសត្វដែលបព្វជិតទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាមអស់ ៨ ខែ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់លះការប្រឡូកប្រឡំដោយពួកគណៈ សោយមធុបាយាសដែលធីតារបស់បិយសេដ្ឋី ក្នុងសុទស្សនទិគមថ្វាយ ហើយទ្រង់សម្រាកពេលថ្ងៃ ក្នុងព្រៃគគីរសោវ ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលតាបសឈ្មោះអនោមទស្សីថ្វាយ ហើយទ្រង់ចូលកាន់មណ្ឌលពោធិព្រឹក្ស ឈ្មោះដើមបុណ្ឌរីក គឺដើមស្វាយស ។ បានឮថា បុណ្ឌរីកពោធិព្រឹក្សនោះ មានទំហំប៉ុនដើមប្រទៀង ។ ក្នុងថ្ងៃនោះ ដើមស្វាយសនោះ ក៏លូតដើម ៥០ ហត្ថទៀត មែកនីមួយៗ ប្រវែង ៥០ ហត្ថដូចគ្នា ដេរដាសដោយផ្កាក្រអូប ដូចផ្កាទិព្វ មិនមែនដេរដាសដោយផ្កាតែម្យ៉ាងប៉ុណ្ណោះទេ គង់ដេរដាសដោយផ្លែទាំងឡាយផងដែរ ។ ស្វាយសនោះ មួយមែកមានផ្លែខ្ចី មួយមែកមានផ្លែចាស់ មួយមែកមានផ្លែស្រគាល មួយមែកមានផ្លែមានរសល្អ ដល់ព្រមដោយពណ៌ ក្លិន និងរស ដូចទិព្វឱជា ដែលទេវតាដាក់សំយុងចុះតាមមែកនោះៗ ដើមផ្កា ក៏ប្រដាប់ដោយផ្កា ឈើផ្លែ ក៏ប្រដាប់ដោយផ្លែ ឈើក្នុងម៉ឺនចក្កវាឡ ក៏ដូចគ្នានឹងដើមស្វាយស ។

ព្រះពោធិសត្វទ្រង់ក្រាលសន្ថតស្មៅ ទំហំ ២៤ ហត្ថ ប្រថាប់គង់ពត់

ក្មេន អធិដ្ឋានព្យាយាមប្រកបដោយអង្គ ៤ កាលប្រថាប់គង់យ៉ាងនោះហើយ ទ្រង់កម្ចាត់មារ មួយអន្លើដោយសេនាដែលមានកម្រាស់ ៣៦ យោជន៍ ទ្រង់សម្រេចសម្ពោធិញ្ញាណ ទើបទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វិលវល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយ តថាគត
បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់សម្ងំនៅក្បែរៗ ពោធិព្រឹក្សនោះឯង អស់ ៧ សប្តាហ៍ ទ្រង់ទទួលអារាធនារបស់មហាព្រហ្ម ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់ភិក្ខុ ១ សែន ៧ ម៉ឺន ដែលបួសជាមួយព្រះអង្គ ទើបយាងទៅតាមអាកាស ចុះត្រង់មិគាចិរាជឧទ្យាន ក្បែរក្រុងអរុណាវតីរាជធានី ដែលមានរបងការពារផ្សេងៗ ដែលពួកមុនីទាំងនោះចោមរោមហើយ ទ្រង់ប្រកាសធម្មចក្រកណ្តាលពួកមុនីទាំងនោះ កាលនោះ ការត្រាស់ដឹងធម៌លើកទី ១ មានដល់ពួកសត្វ ១ សែនកោដិ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្រោយព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាមសិខីជិនស្រី
ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គល
ប្រៀបផ្ទឹមបាន ។ ព្រះអង្គកម្ចាត់បង់សេនានៃមារ ហើយដល់
សម្ពោធិញ្ញាណដ៏ប្រសើរ ញ៉ាំងចក្ក គឺធម៌ ឲ្យប្រព្រឹត្តទៅ
ដើម្បីសេចក្តីអនុគ្រោះដល់ពួកសត្វ ។ កាលព្រះសិខីជិនស្រី

ដ៏ប្រសើរ ទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹង
លើកទី ១ មានពួកសត្វចំនួនមួយសែនកោដិ ដូច្នេះ ។

បន្ទាប់មកទៀត ព្រះសិរិសម្ពុទ្ធទ្រង់សម្តែងធម៌ប្រោសព្រះរាជឱរសរបស់ព្រះអង្គ គឺព្រះអភិក្កូរាជឱរស និងព្រះសម្ភវរាជឱរស មួយអន្លើដោយបរិវារ ក្បែរក្រុងអរុណវតីរាជធានី ទ្រង់ញុំាងសត្វ ៩ ម៉ឺនកោដិ ឲ្យផឹកនូវអមតធម៌ នេះជាការត្រាស់ដឹងធម៌លើកទី ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលព្រះសិរិប្រសើរជាងគណៈ ឧត្តមជាងជន ទ្រង់សម្តែង
ធម៌ដទៃទៀត ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួន
៩០ ពាន់កោដិ ដូច្នេះ ។

ក្នុងកាលព្រះមានព្រះភាគទ្រង់ធ្វើយមកបា្បដិហារ្យ ដើម្បីកាច់បំបាក់នូវការស្រវឹង និងមានះរបស់តិរ្ថិយ និងដើម្បីដោះចំណងរបស់ជនទាំងពួង ក្បែរទ្វារសុរិយវតីនគរ ទ្រង់សម្តែងធម៌ប្រោស ការត្រាស់ធម៌លើកទី ៣ ក៏មានដល់ពួកសត្វ ៨ ម៉ឺនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលព្រះសិរិទ្រង់សម្តែងយមកបា្បដិហារ្យ ក្នុងមនុស្សលោក
ព្រមទាំងទេវលោក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ
៨០ ពាន់កោដិ ដូច្នេះ ។

ព្រះមានព្រះភាគប្រថាប់គង់កណ្តាលព្រះអរហន្តមួយសែន ដែលបួសជាមួយព្រះរាជឱរស គឺព្រះអភិក្កូ និងព្រះសម្ភវៈ ទ្រង់លើកបាតិមោក្ខឡើង

សម្តែង នេះជាសន្និបាតលើកទី ១ ទ្រង់ប្រថាប់គង់កណ្តាលភិក្ខុ ៨ ម៉ឺន ដែលបួសក្នុងសមាគមព្រះញាតិ ក្នុងអរុណវតីនគរ ទ្រង់សម្តែងបាតិមោក្ខ នេះជាសន្និបាតលើកទី ២ ។ ព្រះមានព្រះភាគ ទ្រង់លើកបាតិមោក្ខឡើង សម្តែងកណ្តាលភិក្ខុ ៧ ម៉ឺន ដែលបួសក្នុងសម័យទ្រង់ផ្ចាញ់ដំរីធនបាលកៈ ក្នុងធនញ្ជយនគរ នេះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះមហេសីព្រះនាមសិខី មានសាវកសន្និបាត ៣ លើក
ដែលសុទ្ធតែជាពួកព្រះខីណាស្រព ឥតមានមន្ទិល មានចិត្ត
ស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១
មានភិក្ខុចំនួនមួយសែនរូប សន្និបាតលើកទី ២ មានពួកភិក្ខុ
ចំនួន ៨ ម៉ឺនរូប ។ សន្និបាតលើកទី ៣ មានពួកភិក្ខុចំនួន ៧
ម៉ឺនរូប ជាសមាគមមិនប្រឡាក់ ( ដោយពួកបុថុជ្ជន ) ដូច
បទុមជាតិ ដែលលូតលាស់នៅក្នុងទឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុបលិត្តោ បទុមំវ** សេចក្តីថា ភិក្ខុសន្និបាតនោះ កើតក្នុងលោក លោកធម៌ក៏ជ្រួតជ្រាបមិនបាន ដូចផ្កាឈូកកើតក្នុងទឹក ធំចម្រើនក្នុងទឹកនោះឯង ទឹកក៏ជ្រួតជ្រាបមិនបាន ដូច្នោះ ។

បានឮថា កាលនោះ ព្រះពោធិសត្វនៃយើងជាព្រះរាជា ព្រះនាមអរិន្ទមៈ ក្នុងបរិភុត្តនគរ ទ្រង់មិនជាប់ជំពាក់ក្នុងទីណាមួយ កាលព្រះសិខីសាស្តាយាងដល់បរិភុត្តនគរ ព្រះរាជា មួយអន្លើដោយរាជបរិវារ ចេញទៅទទួល មានព្រះ

ហឫទ័យ ព្រះនេត្រ និងព្រះសោតៈ ដែលសេចក្តីជ្រះថ្លាឲ្យចម្រើនហើយ មួយអន្លើដោយរាជបរិវារ ថ្វាយបង្គំដោយព្រះសិរសា ត្រង់ព្រះយុគលបាទ ដែលមិនមានមន្ទិលរបស់ព្រះទសពល និមន្តព្រះទសពល ថ្វាយមហាទាន ដែលសមគួរដល់ព្រះឥស្សរិយត្រកូល សម្បត្តិ និងសទ្ធា ៧ ថ្ងៃ ឲ្យបើកទ្វារឃ្លាំងសំពត់ ថ្វាយសំពត់មានតម្លៃច្រើនដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយដំរីដែលការពារសត្រូវបាន ដូចដំរីឯរាវណ ដែលដល់ព្រមដោយរូបលក្ខណៈ និងសម្ពុះ ប្រដាប់ដោយបណ្តាញមាស និងមាល័យ បក់ដោយផ្កិតដ៏ស្អាត ចងនូវត្រដោកមាស មានមុខ និងត្រចៀកប្រាកដច្បាស់ ដោយរូបព្រះចន្ទ និងថ្វាយកប្បិយភណ្ឌ មានទំហំប៉ុនដំរីនោះឯង ព្រះសាស្តាអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វនោះថា ក្នុង ៣១ កប្បរាប់អំពីកប្បនេះទៅ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> សម័យនោះ តថាគតជាក្សត្រនាមអរិន្ទមៈ បានញ៉ាំងព្រះសង្ឃមានព្រះសម្ពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ។ តថាគតបានប្រគេនសំពត់ជាច្រើន គឺកោដិនៃសំពត់មិនតិច ហើយថ្វាយយានដំរី ដ៏ប្រដាប់ហើយដល់ព្រះសម្ពុទ្ធ ។ តថាគតសាងយានដំរី ហើយបង្អោនចូលទៅជិត ឲ្យជារបស់គួរបំពេញចិត្តរបស់តថាគត ឲ្យតម្កល់នៅមាំ អស់កាលជានិច្ច ។ ព្រះពុទ្ធព្រះនាមសិខី ជាលោកគ្គនាយកនោះ ទ្រង់

ព្យាករតថាគតថា ក្នុងកប្បទី ៣១ អំពីមណ្ឌកប្បនេះ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទីរីករាយ ទៅតម្កល់ព្យាយាម ។បេ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក្នុងអនាគតកាល យ៉ាងនោះដែរ ។ ឯតថាគត លុះបានស្តាប់ព្រះពុទ្ធដីកានៃព្រះអង្គនោះហើយ រឹងរឹតតែធ្វើចិត្តឲ្យជ្រះថ្លា ហើយបានទំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និម្មិនិត្វា** បានដល់ ប្ដឹងដោយជញ្ជីងប៉ុនដំរីនោះ ។ បទថា **កប្បិយំ** បានដល់ កប្បិយភណ្ឌ ។ វត្ថុដែលគួរសម្រាប់ភិក្ខុទាំងឡាយ ឈ្មោះថា កប្បិយភណ្ឌ ។ បទថា **បូរយឹ មានសំ មយ្ហំ** សេចក្តីថា ញ៉ាំងចិត្តរបស់តថាគតឲ្យពេញដោយបីតិក្នុងទាន ធ្វើឲ្យអាច គឺកើតនូវសេចក្តីត្រេកអរដល់តថាគត ។ បទថា **និច្ចំ ទឡ្ហមុបដ្ឋិតំ** សេចក្តីថា ចិត្តដែលតាំងមាំដោយទានចេតនាថា នឹងឲ្យទានជានិច្ច ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់មាននគរឈ្មោះអរុណវតី ព្រះជនកព្រះនាមព្រះបាទអរុណវា[១] ព្រះជននីព្រះនាមព្រះនាងបភាវតី គូនៃអគ្គសាវកឈ្មោះអភិភូ ១ សម្ភវៈ ១ ពុទ្ធុបដ្ឋាកឈ្មោះខេមង្ករៈ គូអគ្គសាវិកាឈ្មោះ

---

១- បិដកខ្មែរជា អរុណៈ ។

សខិលា ១[១] បទុមា ១ ពោធិព្រឹក្សឈ្មោះបុណ្ឌរីក គឺដើមស្វាយ-ស ព្រះសរីរៈកម្ពស់ ៧០ ហត្ថ ព្រះរស្មីនៃព្រះសរីរៈផ្សាយទៅ ៣ យោជន៍ជានិច្ច ព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ អគ្គមហេសីព្រះនាមសព្វកាមា ឱរសព្រះនាមអតុលៈ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយយាន គឺដំរី ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

១- បិដកខ្មែរជា មខិលា ។

ព្រះមហេសីព្រះនាមសិខី មានទីក្រុងឈ្មោះអរុណវតី មានព្រះមហាក្សត្រ ព្រះនាមអរុណៈជាព្រះបិតា មានព្រះជននីព្រះនាមបភាវតី ។ ព្រះមហេសីព្រះនាមសិខី មានអភិភូភិក្ខុ ១ សម្ភវភិក្ខុ ១ ជាអគ្គសាវក ភិក្ខុឈ្មោះខេមង្ករៈ ជាឧបដ្ឋាក ។ នាងមខិលាភិក្ខុនី ១ នាងបទុមាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា បុណ្ឌរីកព្រឹក្ស ( ដើមស្វាយ-ស ) ។ សិរិវឌ្ឍគហបតី ១ នន្ទគហបតី ១ ជាអគ្គឧបដ្ឋាក នាងចិត្តា ១ នាងសុចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានកម្ពស់ ៧០ ហត្ថ ប្រាកដស្មើដោយគ្រឿងមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ ព្រះពុទ្ធជាម្ចាស់អង្គនោះ មានពន្លឺប្រមាណមួយព្យាម ផ្សាយចេញអំពីព្រះកាយជានិច្ច ផ្សាយចេញទៅកាន់ទិសតូច និងទិសធំ ភ្លឺចេញទៅចម្ងាយ ៣

យោជន៍ ។ ព្រះមហេសីអង្គនោះ មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ព្រះអង្គកាលទ្រង់គង់ធរមាននៅឡើយ បានញុំាងប្រជុំជនជាច្រើន ឲ្យឆ្លង ( ត្រើយសង្សារវដ្ត ) ។ ព្រះពុទ្ធនោះ ព្រមទាំងសាវក បង្អុរភ្លៀង គឺធម៌ ស្រោចស្រពផ្សើមពួកមនុស្ស ព្រមទាំងទេវតា ធ្វើឲ្យដល់នូវសភាពក្សេមក្សាន្ត ហើយបរិនិព្វាន ។ ព្រះសរីរៈបរិបូណ៌ដោយអនុព្យញ្ជនៈ មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ គង់បាត់បង់សូន្យទាំងអស់ ឱ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុណ្ឌរីកោ** បានដល់ ដើមស្វាយ ។ បទថា **តីណិ យោជនសោ បភា** សេចក្តីថា ព្រះរស្មីទាំងឡាយផ្សាយទៅ ៣ យោជន៍ ។ បទថា **ធម្មមេឃំ** បានដល់ ភ្លៀង គឺធម៌ ។ មេឃ គឺព្រះពុទ្ធដែលញុំាងភ្លៀង គឺធម៌ឲ្យធ្លាក់ចុះមក ។ បទថា **តេមយិត្វា** បានដល់ ឲ្យសើម អធិប្បាយថា ស្រោចដោយទឹក គឺធម្មកថា ។ បទថា **សទេវកេ** បានដល់ ញុំាងសត្វលោកព្រមទាំងទេវលោក ។ បទថា **ខេមន្តំ** បានដល់ ប្រទេសដ៏ក្សេម គឺព្រះនិព្វាន ។ បទថា **អនុព្យញ្ជនសម្បន្នំ** សេចក្តីថា ព្រះសរីរៈរបស់ព្រះមានព្រះភាគ ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ដល់ព្រមដោយអនុព្យញ្ជនៈ ៨០ មានព្រះនខាក្រហម ព្រះនាសិកកោង និងព្រះអង្គុលីមូលជាដើម ។ បានឮថា ព្រះសិខីសម្មាសម្ពុទ្ធ ទ្រង់រម្ងត់ខន្ធបរិនិព្វាន ក្នុងព្រះវិហារអស្សារាម សីលវតីនគរ ។

ព្រះសិខីសម្ពុទ្ធទ្រង់រុងរឿងដោយតបៈ ក្នុងលោក ដូចគំនរភ្លើង ទ្រង់បន្ទឺក្នុងអាកាស ដូចសត្វក្ងោក ព្រះសិខីសម្ពុទ្ធទ្រង់លះព្រះមហេសី និងទ្រព្យ ទ្រង់ដល់នូវការស្ងប់ យានទៅល្អហើយ ដូចភ្លើង ដូច្នេះ ។

បានឮថា ព្រះមានព្រះភាគសិខី មានព្រះបរមសារីរិកធាតុ តាំងនៅទាំងមូលមិនបែកខ្ចាត់ខ្ចាយ មនុស្សក្នុងជម្ពូទ្វីប នាំគ្នាសាងព្រះស្តូប សម្រេចដោយរតនៈ ៧ ល្អដូចភ្នំហិមពាន្ត កម្ពស់ ៣ យោជន៍ ។ ពាក្យដ៏សេសក្នុងគាថាទាំងឡាយគ្រប់អន្លើ ប្រាកដជាក់ច្បាស់ហើយនោះឯង ។៚

## អដ្ឋកថាសិខិពុទ្ធវង្សទី ២០ ចប់

# សុត្តន្តបិដក

## វេស្សភូពុទ្ធវង្សទី ២១

[ ២២ ] ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រីព្រះនាមវេស្សភូ ព្រះអង្គមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់កើតឡើងក្នុងលោក ។ ព្រះជិនស្រីនោះ កាលជ្រាបច្បាស់នូវលោកទាំង ៣ នេះ ដែលឆេះសព្វដោយភ្លើង គឺរាគៈផង នូវដែននៃតណ្ហាទាំងឡាយផង ទ្រង់កាត់នូវចំណង ដូចដំរីដ៏ប្រសើរ ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះវេស្សភូ ជាលោកនាយក ទ្រង់សម្តែងធម្មចក្ក មានពួកបរិស័ទចំនួន ៨០ ពាន់កោដិ បានត្រាស់ដឹងក្នុងគ្រាជាដំបូង ។ កាលដែលព្រះលោកជេដ្ឋៈប្រសើរជាងពួកនរជន ចៀសចេញទៅកាន់ចារិកក្នុងដែន មានពួកបរិស័ទចំនួន ៧០ ពាន់កោដិ បានត្រាស់ដឹងក្នុងគ្រាទី ២ ។ ព្រះជិនស្រីអង្គនោះ ទ្រង់បន្ទោបង់នូវមហាទិដ្ឋិ ហើយធ្វើនូវបាដិហារ្យ ពួកមនុស្ស និងទេវតា ក្នុងមួយម៉ឺនលោកធាតុ ព្រមទាំងទេវលោក ក៏បានមកប្រជុំគ្នា ។ ពួកទេវតា និងមនុស្សចំនួន ៦០ កោដិ ឃើញហេតុអស្ចារ្យធំចម្លែក ជាទីព្រឺរោមហើយ ក៏បានត្រាស់ដឹង ( ក្នុងគ្រាទី ៣ ) ។ ព្រះពុទ្ធព្រះនាមវេស្សភូ ស្វែងរកគុណដ៏ធំ មានសាវកសន្និបាត ៣ លើក សុទ្ធតែព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ គឺសន្និបាតលើកទី ១ មានភិក្ខុចំនួន ៨០ ពាន់កោដិ សន្និបាតលើកទី ២

មានភិក្ខុចំនួន ៧០ ពាន់កោដិ ។ សន្និបាតលើកទី ៣ មានពួកភិក្ខុចំនួន ៦០ ពាន់កោដិ ដែលភ័យតក់ស្លុតអំពីទុក្ខ មានជរាជាដើម ជាឱរសរបស់ព្រះពុទ្ធ ស្វែងរកនូវគុណដ៏ធំ ។ កាលព្រះសម្ពុទ្ធមិនមានបុគ្គលស្មើអង្គនោះ ទ្រង់សម្ដែងធម្មចក្កដ៏ឧត្តម សម័យនោះ តថាគតជាក្សត្រ ឈ្មោះសុទស្សនៈ បានស្ដាប់នូវធម៌ដ៏ប្រសើរហើយ ក៏ពេញចិត្តនឹងផ្នួសយ៉ាងក្រៃលែង បានបូជានូវព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ដោយបាយទឹក និងសំពត់ ។ តថាគតញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ជាអ្នកមិនខ្ជិលទាំងយប់ទាំងថ្ងៃ ហើយចូលទៅកាន់ផ្នួស ដែលបរិបូណ៌ដោយគុណ ក្នុងសម្នាក់ព្រះជិនស្រី ។ តថាគតបរិបូណ៌ដោយអាចារគុណ មានចិត្តតម្កល់ខ្ជាប់ក្នុងវត្ត និងសីល ស្វែងរកនូវសព្វញ្ញុតញ្ញាណ ត្រេកអរក្នុងសាសនានៃព្រះជិនស្រី ។ តថាគតញ៉ាំងសទ្ធា និងបីតិឲ្យកើតឡើងហើយ ថ្វាយបង្គំព្រះសម្ពុទ្ធជាសាស្ដា បីតិរបស់តថាគត ក៏កើតឡើង ព្រោះហេតុនៃការត្រាស់ដឹង ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបចិត្តមិនវិលត្រឡប់ហើយ ទ្រង់ត្រាស់ថា ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្សត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពីក្រុងកបិលពស្ដុ ជាទីរីករាយ ហើយតាំងសេចក្ដីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រី

អង្គនោះ បានឆាន់បាយាសក្បៀរឆ្នេរស៊ីងនេរញ្ជរាហើយ ចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែង ។ លំដាប់នោះ ព្រះសម្ពុទ្ធមានយសធំ ធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ស្ដេចនេះនឹងបានជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះថេរៈ ២ អង្គ គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទនឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ដើមឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ហត្ថាឡវកគហបតី ១ នឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា១ ឧត្តរា១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះសម្ពុទ្ធព្រះនាមគោតមមានយសអង្គនោះ មានព្រះជន្ម ១០០ ឆ្នាំ ។ ពួកទេវតានិងមនុស្សបានស្ដាប់នូវព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធ ទ្រង់រកបុគ្គលស្មើគ្មាន ស្វែងរកគុណដ៏ធំហើយ ក៏រីករាយថា ក្សត្រនេះជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយ

ម៉ឺនលោកធាតុ មានសំឡេងហៅ ទះដៃ អបអរសាទរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ មនុស្សទាំងឡាយកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ តថាគត បានស្តាប់នូវព្រះពុទ្ធដីកា នៃព្រះសាស្តានោះហើយ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាក្រៃលែង បានខំអធិដ្ឋានវត្តតទៅដោយការបំពេញបារមីទាំង ១០ ។ ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មាននគរឈ្មោះអនោមៈ មានព្រះមហាក្សត្រ ព្រះនាមសុប្បតិតៈជាព្រះបិតា មានព្រះមាតាព្រះនាមយសវតី ព្រះអង្គគង់នៅគ្រប់គ្រងព្រះដំណាក់អស់ ៦ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ គឺរុចិប្រាសាទ ១ សុរតិប្រាសាទ ១ វឌ្ឍកប្រាសាទ ១ ។ ពួកនារីមិនខ្វះពី ៣០ ពាន់នាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសី ព្រះនាមសុចិត្តា ព្រះរាជបុត្រ ព្រះនាមសុប្បពុទ្ធ ។ ព្រះសម្ពុទ្ធជាបុរសដ៏ឧត្តម បានឃើញនូវនិមិត្ត ៤ យ៉ាង ស្តេចចេញទៅទ្រង់ព្រះផ្នួសដោយ-វ បានប្រព្រឹត្តព្យាយាមអស់ ៦ ខែ ។

ព្រះវេស្សភូ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ មានចក្ក គឺធម៌ ប្រព្រឹត្តទៅ មានព្យាយាមធំ ឧត្តមជាងពួកជន ត្រូវព្រហ្មអារាធនាហើយ ក្នុងអរុណារាម ។ ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈឈ្មោះសោណៈ ១ ឧត្តរៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះឧបសន្តៈជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះរាមា ១ សមាលា ១ ជាអគ្គសាវិកា ឯឈើសម្រាប់ត្រាស់ដឹងរបស់ព្រះមានព្រះភាគអង្គនោះ គេតែងហៅថា មហាសាលព្រឹក្ស ។ ឧបាសកឈ្មោះសោត្ថិកៈ ១ រម្មៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះគោតមី ១ សិរិមា ១ ជាអគ្គឧបដ្ឋាយិកា ។ រស្មីមានកម្ពស់ ៦០ ហត្ថ មានឧបមាស្មើដោយប្រាសាទមាស ផ្សាយចេញពីព្រះកាយ ដូចអណ្តាតភ្លើងលើកំពូលភ្នំ ក្នុងវេលាយប់ ។ ព្រះសម្ពុទ្ធទ្រង់ស្វែងរកគុណដ៏ធំអង្គនោះ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ព្រះអង្គស្ថិតនៅអស់កាលត្រឹមនោះ ញ៉ាំងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវកញែកធម៌ធ្វើឲ្យពិស្តារ តម្កល់មហាជនក្នុងសំពៅ គឺធម៌ ហើយ

បរិនិព្វាន ។ ជនទាំងអស់នោះ វិហារ និងឥរិយាបថជារបស់ដែលគេគប្បីរមិលមើល របស់ទាំងអស់នេះ វិនាសសាបសូន្យអស់ទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ។ ព្រះជិនស្រីដ៏ប្រសើរ ព្រះនាមវេស្សភូជាសាស្តា បរិនិព្វានក្នុងខេមារាម ព្រះធាតុផ្សាយទៅក្នុងប្រទេសនោះៗ ។

## វេស្សភូពុទ្ធវង្សទី ២១ ចប់

# អដ្ឋកថា

## វេស្សភូពុទ្ធវង្សទី ២១

បន្ទាប់អំពីសម័យព្រះសិខីសម្មាសម្ពុទ្ធ កាលសាសនារបស់ព្រះអង្គអន្តរធានហើយ មនុស្សដែលមានអាយុ ៧ ម៉ឺនឆ្នាំ ក៏ថយចុះដោយលំដាប់ រហូតមានអាយុ ១០ ឆ្នាំ ហើយចម្រើនឡើង រហូតដល់មានអាយុរាប់មិនបាន រួចក៏ថយចុះដោយលំដាប់ រហូតនៅសល់ ៦ ម៉ឺនឆ្នាំ កាលនោះ ព្រះសាស្តា ព្រះនាមវេស្សភូ ទ្រង់ឈ្នះព្រះហឫទ័យ ទ្រង់គ្របសង្កត់នូវលោកទាំងពួង ជាអ្នកកើតឯង ទ្រង់កើតឡើងក្នុងលោក ទ្រង់បំពេញបារមីទាំងឡាយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងយសវតី ដែលជាអ្នកមានសីល ជាអគ្គមហេសីរបស់ព្រះបាទសុប្បតីតៈ ដែលជាទីកោតក្រែង ( របស់មហាជន ) ក្នុងអនោមនគរ គ្រប់កំណត់ទសមាស ក៏ប្រសូតចាកព្រះឧទររបស់ព្រះជននី ក្នុងអនោម-រាជឧទ្យាន ។ កាលប្រសូត ញុំាងជនឲ្យត្រេកអរ ទ្រង់បន្លឺដូចគោឧសភ ព្រោះហេតុនោះ ក្នុងថ្ងៃថ្វាយព្រះនាម ទើបព្រះញាតិវង្សានុវង្សថ្វាយព្រះនាមថា វេស្សភូ ព្រោះទ្រង់បន្លឺសីហនាទដូចគោឧសភ ។ ទ្រង់គ្រងរាជ្យ ជាឃរាវាសវិស័យអស់ ៦ ពាន់ឆ្នាំ មានប្រាសាទ ៣ ឈ្មោះរុចិ ១ សុរុចិ ១ និងរតិវឌ្ឍនៈ ១[1] មានស្រីស្នំ ៣ ម៉ឺននាក់ មានព្រះនាងសុចិត្តាទេវីជាប្រធាន ។

កាលព្រះសុប្បពុទ្ធកុមារ ឱរសរបស់ព្រះនាងសុចិត្តាទេវីប្រសូត ព្រះ

---

១- បិដកខ្មែរជា រុចិប្រាសាទ ១ សុរតិប្រាសាទ ១ វឌ្ឍកប្រាសាទ ១ ។

ពោធិសត្វឃើញនិមិត្ត ៤ ទ្រង់ប្រពាតព្រះរាជឧទ្យានដោយ-វមាស ទ្រង់ទទួលសំពត់កាសាវៈ ដែលទេវតាថ្វាយ ទ្រង់ព្រះផ្នួស ។ បុរស ៧ ម៉ឺន ក៏បួសតាម ។ លំដាប់នោះ ព្រះពោធិសត្វដែលបព្វជិតទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាមអស់ ៦ ខែ ក្នុងថ្ងៃវិសាខបុណ្ណមី សោយមធុបាយាស ដែលកីលៀងឈ្មោះសិរិវឌ្ឍនា ដែលប្រាកដខ្លួនក្នុងសុចិត្តនិគមថ្វាយ ទ្រង់សម្រាកពេលថ្ងៃ ក្នុងព្រៃសាលវន លុះវេលាល្ងាច ទ្រង់ទទួលស្មៅ ៨ ក្ដាប់ ដែលស្ដេចនាគឈ្មោះនរិន្ទៈថ្វាយ ទ្រង់ចូលទៅកាន់មណ្ឌលពោធិព្រឹក្សឈ្មោះដើមសាលៈអំពីទិសទក្សិណ ដើមសាលៈនោះមានទំហំប៉ុនដើមប្រទៀងនោះឯង ។ ផ្កា ផ្លែ សិរី និងសម្បត្តិ ក៏គប្បីជ្រាបយ៉ាងនោះដូចគ្នា ។ ព្រះពោធិសត្វចូលទៅកាន់គល់សាលព្រឹក្ស ទ្រង់លាតសន្ថតស្មៅទំហំ ៤០ ហត្ថ ប្រថាប់គង់ពត់ភ្នែន ទ្រង់បានអនាវរញ្ញាណដែលប្រាសចាកនីវរណៈ ដែលហាមការស្រវឹងក្នុងកាមគ្រប់យ៉ាង ទើបទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វេលំតែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគត
បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់សម្រុំនៅក្បែរគល់ពោធិព្រឹក្សនោះឯងអស់ ៧ សប្ដាហ៍ ទ្រង់ឃើញឧបនិស្ស័យរបស់សោណកុមារ និងឧត្តរកុមារ ព្រះកនិដ្ឋភាតារបស់ព្រះអង្គ ទើបទ្រង់យាងទៅតាមអាកាស ចុះត្រង់អរុណរាជឧទ្យាន ក្បែរអនោមនគរ

ទ្រង់ឲ្យឧទ្យានបាលទៅហៅព្រះរាជកុមារមកហើយ ទ្រង់ប្រកាសធម្មចក្ក ក្នុងកណ្តាលកុមារទាំង ២ នោះ មួយអន្លើដោយបរិវារ ការត្រាស់ដឹងធម៌លើកទី ១ មានដល់សត្វ ៨ ម៉ឺនកោដិ ។

បន្ទាប់មកទៀត ព្រះមានព្រះភាគ កាលទ្រង់ចារិកទៅក្នុងជនបទ ទ្រង់សម្តែងធម៌ប្រោសក្នុងទីនោះៗ ការត្រាស់ដឹងធម៌មានដល់សត្វ ៧ ម៉ឺនកោដិ នេះជាការត្រាស់ដឹងធម៌លើកទី ២ ។ ព្រះមានព្រះភាគ កាលទ្រង់ទម្លាយសំណាញ់ គឺទិដ្ឋិ រម្ងំនូវទង់ គឺមានះរបស់តិត្ថិយ កម្ចាត់នូវការស្រវឹង ដោយមានះ ទ្រង់លើកទង់ គឺធម៌ ទ្រង់ធ្វើយមកប្បាដិហារ្យក្នុងមនុស្សបរិស័ទដែលមានកម្រាស់ ៩០ យោជន៍ ក្នុងទេវបរិស័ទប្រមាណមិនបាន ក្នុងអនោមនគរនោះឯង ញ៉ាំងទេវតា និងមនុស្សឲ្យជ្រះថ្លាហើយ ទ្រង់ញ៉ាំងសត្វ ៦ ម៉ឺនកោដិ ឲ្យឆ្អែតដោយអមតធម៌ នេះជាការត្រាស់ដឹងធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រីព្រះនាមវេស្សភូ ព្រះអង្គមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់កើតឡើងក្នុងលោក ។ ព្រះជិនស្រីនោះ កាលជ្រាបច្បាស់នូវលោកទាំង ៣ នេះ ដែលឆេះសព្វដោយភ្លើង គឺរាគៈផង នូវដែននៃតណ្ហាទាំងឡាយផង ទ្រង់កាត់នូវចំណង ដូចដំរីដ៏ប្រសើរ ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះវេស្សភូ ជាលោកនាយក ទ្រង់សម្តែងធម្មចក្ក មានពួកបរិស័ទចំនួន ៨០ ពាន់កោដិ

បានត្រាស់ដឹងក្នុងគ្រាជាដំបូង ។ កាលដែលព្រះលោកជេដ្ឋៈ
ប្រសើរជាងពួកនរជន ចៀសចេញទៅកាន់ចារិកក្នុងដែន មាន
ពួកបរិស័ទចំនួន ៧០ ពាន់កោដិ បានត្រាស់ដឹងក្នុងគ្រាទី ២ ។
ព្រះជិនស្រីអង្គនោះ ទ្រង់បន្ទោបង់នូវមហាទិដ្ឋិហើយ ធ្វើនូវ
បាដិហារ្យ ពួកមនុស្ស និងទេវតា ក្នុងមួយម៉ឺនលោកធាតុ
ព្រមទាំងទេវលោក ក៏បានមកប្រជុំគ្នា ។ ពួកទេវតា និង
មនុស្សចំនួន ៦០ កោដិ ឃើញហេតុអស្ចារ្យធំចម្លែក ជាទី
ព្រឺរោមហើយ ក៏បានត្រាស់ដឹង ( ក្នុងគ្រាទី ៣ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាទិត្តំ** សេចក្តីថា លោកបីទាំងមូលនេះ ត្រូវភ្លើងឆេះហើយ ។ បទថា **រាគគ្គិ** បានដល់ រាគៈ ។ បទថា **តណ្ហានំ វិជិតំ** សេចក្តីថា ទ្រង់ជ្រាបថា លោកទាំង ៣ ជាប្រទេស ជាទីដែន ជានគរជ្ជាក់របស់តណ្ហាទាំងឡាយ ។ បទថា **ឆាគោវ ពន្ធនំ ឆេត្វា** សេចក្តីថា ទ្រង់កាត់នូវចំណង ដូចដំរីផ្តាច់នូវវល្លិផោម ទ្រង់ត្រាស់ដឹងនូវសម្ពោធិញ្ញាណ ។ បទថា **ឧសភសាស្មី** គឺ **ឧសភសាស្មិយំ**។ បទថា **សទេវកេ** បានដល់ ក្នុងលោក ព្រមទេវលោក ។ បទថា **ពុជ្ឈរេ** បានដល់ ត្រាស់ដឹងហើយ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគវេស្សភូ ទ្រង់លើកបាតិមោក្ខឡើងសម្តែងក្នុងថ្ងៃមាឃបុណ្ណមី កណ្តាលព្រះអរហន្ត ៨ ម៉ឺន ដែលបួសក្នុងសមាគមរបស់សោណៈ និងឧត្តរៈ ជាគូនៃអគ្គសាវក នេះជាសាវកសន្និបាតលើកទី ១ ។

កាលភិក្ខុចំនួន ៧ ម៉ឺន បួសជាមួយព្រះវេស្សភូ ដែលទ្រង់គ្របសង្កត់នូវលោកទាំងពួង នាំគ្នាចៀសចេញទៅ សម័យដែលព្រះវេស្សភូ ចៀសចេញចាកគណៈទៅ ភិក្ខុទាំងនោះស្តាប់ដំណឹង គឺការប្រកាសធម្មចក្ររបស់ព្រះវេស្សភូសម្មាសម្ពុទ្ធ ក៏នាំគ្នាមកកាន់សោរេយ្យនគរ បានជួបព្រះមានព្រះភាគៗ ទ្រង់សម្តែងធម៌ប្រោសភិក្ខុទាំងនោះ ទ្រង់ឲ្យភិក្ខុទាំងនោះបួសដោយឯហិភិក្ខុទាំងអស់ ហើយទ្រង់លើកបាតិមោក្ខឡើងសម្តែង ក្នុងបរិស័ទដែលប្រកបដោយអង្គ ៤ នេះជាសន្និបាតលើកទី ២ ។

ម្យ៉ាងទៀត កាលព្រះរាជបុត្តព្រះនាមឧបសន្តៈ ឡើងគ្រងរាជ្យក្នុងនគរនារិវាហនៈ ព្រះមានព្រះភាគយាងទៅនគរនោះ ដើម្បីអនុគ្រោះព្រះរាជបុត្តនោះ ។ ព្រះរាជបុត្តនោះ ទ្រង់ជ្រាបដំណឹងនៃការយាងមករបស់ព្រះមានព្រះភាគ មួយអន្លើដោយបរិវារ ទើបទ្រង់ចេញទៅទទួល និមន្តមកថ្វាយមហាទាន ទ្រង់ស្តាប់ធម៌របស់ព្រះអង្គ មានព្រះហឫទ័យជ្រះថ្លា ហើយទ្រង់ព្រះផ្នួស បុរស ៦ ម៉ឺនកោដិក៏បួសតាម ភិក្ខុទាំងនោះសម្រេចអរហត្តមួយអន្លើដោយរាជបុត្តនោះ ព្រះមានព្រះភាគវេស្សភូ កាលភិក្ខុទាំងនោះចោមរោមហើយ លើកបាតិមោក្ខឡើងសម្តែង នេះជាសន្និបាតលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ព្រះពុទ្ធព្រះនាមវេស្សភូ ស្វែងរកគុណដ៏ធំ មានសាវកសន្និ-
> បាត ៣ លើក សុទ្ធតែព្រះខីណាស្រព ប្រាសចាកមន្ទិល
> មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ គឺសន្និបាតលើកទី ១

មានភិក្ខុចំនួន ៨០ ពាន់កោដិ សន្និបាតលើកទី ២ មានភិក្ខុ
ចំនួន ៧០ ពាន់កោដិ ។ សន្និបាតលើកទី ៣ មានពួកភិក្ខុ
ចំនួន ៦០ ពាន់កោដិ ដែលភ័យតក់ស្លុតអំពីទុក្ខ មានជរា
ជាដើម ជាឱរសរបស់ព្រះពុទ្ធ ស្វែងរកនូវគុណដ៏ធំ ដូច្នេះ ។

គ្រានោះ ព្រះពោធិសត្វនៃយើង ជាព្រះរាជាព្រះនាមថា ព្រះបាទសុទស្សនៈ គួរមើល គួរសរសើរក្រៃលែង ក្នុងនគរសរភវតី កាលព្រះវេស្សភូសម្ពុទ្ធ ជាលោកនាយក យាងមកដល់នគរសរភៈ ស្តាប់ធម៌របស់ព្រះសាស្តា មានព្រះហឫទ័យជ្រះថ្លាហើយ ទ្រង់លើកអញ្ជលីដ៏រុងរឿង ដោយទសនខសមោធាន ដូចផ្កាឈូកក្រពុំកើតក្នុងទឹក មិនមានមន្ទិល មិនវិកល មិនខ្វះខាត ដាក់លើសិរសា គឺត្បូង ថ្វាយមហាទាន មួយអន្លើដោយចីវរដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សាងព្រះគន្ធកុដិ ដែលជាទីគង់នៃព្រះមានព្រះភាគ ក្នុងនគរនោះ ទ្រង់សាងវិហារ ១០០០ ជុំវិញព្រះគន្ធកុដិនោះ ទ្រង់បរិច្ចាគសម្បត្តិសព្វយ៉ាង ក្នុងសាសនារបស់ព្រះមានព្រះភាគ ទ្រង់ព្រះផ្នួសក្នុងសម្នាក់របស់ព្រះអង្គហើយ មួយអន្លើដោយអាចារគុណ ទ្រង់ត្រេកអរក្នុងធុតង្គគុណ ១៣ ទ្រង់ត្រេកអរក្នុងការស្វែងរកពោធិសម្ភារ ទ្រង់ត្រេកអរក្នុងពុទ្ធសាសនា ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វថា ក្នុងអនាគតកាល ៣១ កប្បអំពីកប្បនេះទៅ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលព្រះសម្ពុទ្ធមិនមានបុគ្គលស្មើអង្គនោះ ទ្រង់សម្តែងធម្មចក្ក ដ៏ឧត្តម សម័យនោះ តថាគតជាក្សត្រ ឈ្មោះសុទស្សនៈ បានស្តាប់នូវធម៌ដ៏ប្រសើរហើយ ក៏ពេញចិត្តនឹងផ្នួស យ៉ាង ក្រៃលែង បានបូជានូវព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ដោយ បាយទឹក និងសំពត់ ។ តថាគតញុំាងមហាទានឲ្យប្រព្រឹត្តទៅ ជាអ្នកមិនខ្ជិលទាំងយប់ទាំងថ្ងៃ ហើយចូលទៅកាន់ផ្នួស ដែល បរិបូណ៌ដោយគុណ ក្នុងសម្នាក់ព្រះជិនស្រី ។ តថាគតបរិបូណ៌ ដោយអាចារគុណ មានចិត្តតម្កល់ខ្ជាប់ ក្នុងវត្ត និងសីល ស្វែងរកនូវសព្វញ្ញុតញ្ញាណ ត្រេកអរក្នុងសាសនា នៃព្រះ ជិនស្រី ។ តថាគតញុំាងសទ្ធា និងបីតិឲ្យកើតឡើង ហើយ ថ្វាយបង្គំព្រះសម្ពុទ្ធជាសាស្តា បីតិរបស់តថាគត ក៏កើតឡើង ព្រោះហេតុនៃការត្រាស់ដឹង ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបចិត្ត មិន វិលត្រឡប់ហើយ ទ្រង់ត្រាស់ថា ក្នុងកប្បទី ៣១ អំពីកប្ប នេះ ក្សត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹង ចេញពីក្រុងកបិលពស្តុ ជាទីរីករាយ ។បេ។ ចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់នូវព្រះពុទ្ធដីកា នៃព្រះសាស្តានោះហើយ ក៏ ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានទំអធិដ្ឋានវត្តតទៅ ដោយ ការបំពេញបារមីទាំង ១០ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចក្កំ វត្តិតំ** បានដល់ ធម្មចក្រដែលទ្រង់ប្រកាសហើយ ។ បទថា **បណរិតំ ធម្មំ** បានដល់ ធម៌ដ៏ប្រសើរបស់មនុស្ស ។ បទថា **បព្វជ្ជំ គុណសម្បន្នំ** សេចក្ដីថា តថាគតដឹងនូវការបួសថាដល់ព្រមដោយគុណ ទើបបួស ។ បទថា **វត្តសីល សមាហិតោ** បានដល់ តាំងមាំក្នុងវត្ត និងសីល អធិប្បាយថា មាំទាំក្នុងការបំពេញវត្ត និងសីលនោះៗ ។ បទថា **រមាមិ** បានដល់ ត្រេកអរក្រៃលែងហើយ ។ បទថា **សទ្ធាបីតី** បានដល់ ចូលដល់សទ្ធា និងបីតិ ។ បទថា **វន្ទាមិ** បានដល់ថ្វាយបង្គំហើយ ។ គប្បីឃើញថា ពាក្យនេះ ជាបច្ចុប្បន្នកាល ប្រើក្នុងអត្ថអតីតកាល ។ បទថា **សត្ថរំ** គឺ **សត្ថារំ** ។ បទថា **អនិវត្តមានសំ** បានដល់ មានចិត្តមិនត្រឡប់ ។

ព្រះសម្មាសម្ពុទ្ធវេស្សភូអង្គនោះ ទ្រង់មាននគរឈ្មោះអនោមៈ ព្រះបិតាព្រះនាមសុប្បតីតៈ ព្រះមាតាព្រះនាមយសវតី គូអគ្គសាវកឈ្មោះសោណៈ ១ ឧត្តរៈ ១ ពុទ្ធុបដ្ឋាកឈ្មោះឧបសន្តៈ គូនៃអគ្គសាវិកាឈ្មោះរាមា ១ សមាលា ១ ពោធិព្រឹក្សឈ្មោះសាលព្រឹក្ស គឺដើមរាំងភ្នំ ព្រះសរីរៈកម្ពស់ ៦០ ហត្ថ ព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ អគ្គមហេសីព្រះនាមសុចិត្តា ព្រះរាជឱរសព្រះនាមសុប្បពុទ្ធ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយ-វមាស ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មាននគរឈ្មោះ
អនោមៈ មានព្រះមហាក្សត្រព្រះនាមសុប្បតិតៈ ជាព្រះបិតា

មានព្រះមាតា ព្រះនាមយសវតី ។ ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈឈ្មោះសោណៈ ១ ឧត្តរៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះឧបសន្តៈជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះរាមា ១ សមាលា ១ ជាអគ្គសាវិកា ឯឈើសម្រាប់ត្រាស់ដឹងរបស់ព្រះមានព្រះភាគអង្គនោះ គេតែងហៅថា មហាសាលព្រឹក្ស ។ ឧបាសកឈ្មោះសោត្ថិកៈ ១ រម្មៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះគោតមី ១ សិរិមា ១ ជាអគ្គឧបដ្ឋាយិកា ។ រស្មីមានកម្ពស់ ៦០ ហត្ថ មានឧបមាស្មើដោយប្រាសាទមាស ផ្សាយចេញពីព្រះកាយ ដូចអណ្តាតភ្លើងលើកំពូលភ្នំ ក្នុងវេលាយប់ ។ ព្រះសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំអង្គនោះ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ព្រះអង្គស្ថិតនៅអស់កាលត្រឹមនោះ ញុំាងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវកញែកធម៌ធ្វើឲ្យពិស្តារ តម្កល់មហាជនក្នុងសំពៅ គឺធម៌ហើយបរិនិព្វាន ។ ជនទាំងអស់នោះ វិហារ និងឥរិយាបថជារបស់ដែលគេគប្បីរមិលមើល របស់ទាំងអស់នេះ វិនាសសាបសូន្យអស់ទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហេមយូបសមូបមោ** សេចក្តីថា ដូច

សសរមាស ។ បទថា **និច្ឆរតិ** បានដល់ ស្ទុះទៅក្នុងទិសផ្សេងៗ ។ បទថា **រស្មិ** បានដល់ ពន្លឺនៃព្រះរស្មី ។ បទថា **រត្តឹវ បព្វតេ សិខី** សេចក្តីថា រស្មីភ្លឺស្វាងក្នុងព្រះវរកាយរបស់ព្រះអង្គ ដូចអណ្តាតភ្លើងលើកំពូលភ្នំ នារាត្រីកាល ។ បទថា **វិភជិត្វា** សេចក្តីថា ធ្វើនូវការចែកជាឧគ្ឃដិតញ្ញូបុគ្គលជាដើម ឬជាសោតាបន្នជាដើម ។ បទថា **ធម្មនាវំ** សេចក្តីថា ទ្រង់តាំងធម្មនាវា គឺមគ្គមានអង្គ ៨ ដើម្បីជួយឲ្យឆ្លងឱឃៈ ៤ ។ បទថា **ទស្សនេយ្យំ** គឺ **ទស្ស-នីយោ** ប្រែថា គួរមើល ។ បទថា **សព្វជនំ** គឺ **សព្វជនោ** អធិប្បាយថា ព្រះសម្មាសម្ពុទ្ធ មួយអន្លើដោយសង្ឃសាវ័ក ។ បទថា **វិហារំ** គឺ **វិហារោ** គប្បីឃើញថា ជាទុតិយាវិភត្តិ ចុះក្នុងអត្ថបឋមាវិភត្តិសព្វអន្លើ ។

បានឮថា ព្រះមានព្រះភាគវេស្សភូ ទ្រង់រលត់ខន្ធបរិនិព្វានក្នុងខេម-មិគទាយវ័ន ក្រុងឧសភវតី ។ ព្រះបរមសារីរិកធាតុរបស់ព្រះអង្គ ខ្ចាត់ខ្ចាយទៅ សមដូចគាថាលោកពោលថា

បានឮថា ព្រះមានព្រះភាគវេស្សភូជិនស្រីដ៏ប្រសើរ ទ្រង់រម្លត់
ខន្ធបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វាន ក្នុងវិហារ
ក្បែរព្រៃជាទីគួរត្រេកអរ ក្នុងនគរឧសភវតី ដូច្នេះ ។ ពាក្យ
ដ៏សេសក្នុងគាថាទាំងឡាយ ជាក់ច្បាស់ហើយនោះឯង ៕

**អដ្ឋកថាវេស្សភូពុទ្ធវង្សទី ២១ ចប់**

# សុត្តន្តបិដក

## កក្កុសន្ធពុទ្ធវង្សទី ២២

[ ២៣ ] ក្នុងកាលជាក្រោយ នៃព្រះវេស្សភូសម្ពុទ្ធមក មានព្រះសម្ពុទ្ធព្រះនាមកកុសន្ធៈ ទ្រង់ប្រសើរជាងពួកសត្វទ្វេបាទ មានគុណរាប់មិនបាន គេគ្របសង្កត់បានដោយកម្រ ព្រះអង្គរម្ងើងនូវភពទាំងពួង ដល់នូវបារមីដោយចរិយា ហើយសម្រេចនូវពោធិញ្ញាណដ៏ឧត្តម ដូចសីហៈទម្លាយនូវទ្រុង ។ កាលព្រះកកុសន្ធៈ ជាលោកនាយក ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ មានពួកបរិស័ទចំនួន ៤ ម៉ឺនកោដិ បានត្រាស់ដឹងក្នុងគ្រាដំបូង ។ ព្រះកកុសន្ធៈ ទ្រង់ធ្វើនូវវិកុព្វនបាដិហារ្យជាគូៗ ឰដ៏អាកាស ញ៉ាំងទេវតា និងមនុស្ស ៣ ម៉ឺនកោដិឲ្យត្រាស់ដឹង ( នេះជាការត្រាស់ដឹងទី ២ ) ។ ក្នុងការប្រកាសនូវចតុស្សច្ចធម៌ នៃព្រះពុទ្ធនោះ មានមនុស្ស ទេវតា និងយក្ខត្រាស់ដឹងនូវធម៌ គេមិនអាចរាប់បាន ( នេះជាការត្រាស់ដឹងទី ៣ ) ។ ព្រះមានជោគ ព្រះនាមកកុសន្ធៈ មានសាវកសន្និបាតតែមួយដង សុទ្ធតែជាព្រះខីណាស្រព មិនមានមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ សាវកសមាគមក្នុងកាលនោះ មានពួកព្រះខីណាស្រព ៤ ម៉ឺន ដែលដល់នូវទន្តភូមិ ( ភូមិនៃបុគ្គលអ្នកមានខ្លួនទូន្មានហើយ ) ព្រោះអស់ទៅនៃកិលេសមានអាសវៈជាដើម ។ សម័យនោះ តថាគតជាក្សត្រឈ្មោះខេមៈ បានថ្វាយទានដ៏ច្រើន ចំពោះព្រះតថាគត និងព្រះសង្ឃជាជិនបុត្ត ។

តថាគតបានចាត់ចែងថ្វាយបាត្រ ចីវរ ថ្នាំបន្តក់ និងដើមឈើអែម ទាំងអស់នេះ ជារបស់ប្រសើរក្រៃពេក ដែលតថាគតប្រាថ្នាហើយ ។ ព្រះមុនីកកុសន្ធៈ ជានាយកអគ្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងភទ្ទកប្បនេះ ក្សត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់ នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ នឹងសោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចសំដៅទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែង ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតានៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ក្សត្រនេះ ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទជាឧបដ្ឋាក បម្រើព្រះជិនស្រីនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវិកា ។ ឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសក

ឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះ នន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមាន យសអង្គនោះ មានជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធ ទ្រង់មិនមានបុគ្គលស្មើ ស្វែងរកនូវគុណដ៏ធំហើយ ក៏រីករាយថា ក្សត្រអង្គនេះ ជាពូជ ពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺន លោកធាតុ មានសំឡេងហ៊ោ ទះដៃ អបអរ ធ្វើអញ្ជលីនមស្ការ ថា បើយើងនឹងឃ្លាងមគ្គផលក្នុងសាសនា នៃព្រះលោកនាថអង្គ នេះ យើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គ នេះ ក្នុងកាលជាអនាគតមិនខាន ។ មនុស្សទាំងឡាយ កាលឆ្លង ស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់នឹងកាន់យកនូវកំពង់ខាង ក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណាមិញ ។ យើងទាំង អស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ គង់តែនឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតពុំខាន ក៏យ៉ាងនោះដែរ ។ តថាគតស្តាប់ព្រះពុទ្ធដីកា របស់ព្រះពុទ្ធនោះ ហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាដោយក្រៃលែង បានអធិដ្ឋានវត្តតទៅ ដោយការបំពេញបារមីទាំង ១០ ។ កាលនោះ នគរឈ្មោះខេមវតី ឯតថាគតជាបុរសឈ្មោះខេមៈ ស្វែងរកនូវសព្វញ្ញុតញ្ញាណ បាន បួសក្នុងសម្នាក់នៃព្រះពុទ្ធអង្គនោះ ។ ព្រះពុទ្ធព្រះនាមកកុសន្ធៈ

ទ្រង់ស្វែងរកនូវគុណដ៏ធំ មានអគ្គិទត្តព្រាហ្មណ៍ ជាព្រះបិតា ព្រះមាតាព្រះនាមវិសាខា ។ មហាត្រកូលរបស់ព្រះសម្ពុទ្ធ នៅក្នុងខេមបុរីនោះ ជាត្រកូលប្រសើរបំផុត មានជាតិខ្ពង់ខ្ពស់ មានយសធំជាងមនុស្សទាំងឡាយ ។ ព្រះកកុសន្ធៈអង្គនោះ ទ្រង់គង់នៅគ្រប់គ្រងឃរាវាសអស់ ៤ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ គឺ កាមវឌ្ឍប្រាសាទ ១ កាមសុទ្ធិប្រាសាទ ១ រតិវឌ្ឍនប្រាសាទ ១ ។ មាននារី ៣ ម៉ឺននាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាមហេសីនោះ ព្រះនាមរោចិនី ព្រះរាជបុត្តព្រះនាមឧត្តរៈ ។ ព្រះជិនស្រីទ្រង់ឃើញនូវនិមិត្តទាំង ៤ ទ្រង់ចេញទៅដោយរថយាន តម្កល់ទុកនូវព្យាយាម មិនលើសពី ៨ ខែ ។ ព្រះកកុសន្ធៈ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមធំ ទ្រង់ឧត្តមជាងពួកជន ត្រូវព្រហ្មអារាធនាហើយ ទើបញ៉ាំងចក្កឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះកកុសន្ធៈ ស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈឈ្មោះវិធុរៈ ១ សញ្ជីវៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះពុទ្ធិជៈជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះសាមា ១ ឈ្មោះចម្បា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថា សិរិសព្រឹក្ស ( ដើមច្រេស ) ។ ឧបាសកឈ្មោះអច្ចុគ្គតៈ ១ សុមនៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនន្ទា ១ សុនន្ទា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីមានកម្ពស់ ៤០ ហត្ថ ស្មើដូច

ជាមាស ផ្សាយចេញទៅកាន់ទីចម្ងាយ ១០ យោជន៍ដោយជុំវិញ ។ ព្រះមហេសីនោះ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ព្រះអង្គគង់នៅកំណត់ប៉ុណ្ណោះ ទ្រង់ញុំាងប្រជុំជនដ៏ច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះសម្ពុទ្ធនោះ ព្រមទាំងសាវ័ក តាំងពានផ្សារ គឺព្រះសទ្ធម្ម បន្លឺឡើងដូចជាសីហនាទចំពោះនរៈ និងនារីទាំងឡាយ ក្នុងមនុស្ស-លោក ព្រមទាំងទេវលោក ហើយនិព្វាន ។ ព្រះសម្ពុទ្ធ បរិបូណ៌ដោយពាក្យ ប្រកបដោយអង្គ ៨ សីលទាំងឡាយ មិនធ្លុះធ្លាយជាប់មិនដាច់ របស់ទាំងអស់ វិនាសសូន្យទៅ ឱ ! សង្ខារទាំងពួងជារបស់មិនទៀងទេតើ ។ ព្រះកកុសន្ធៈ ជាព្រះជិនស្រីដ៏ប្រសើរនិព្វានក្នុងខេមារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះពុទ្ធនោះ មានកម្ពស់ទៅក្នុងអាកាស មួយគាវុត ក្នុងទីនោះឯង ។

**កកុសន្ធពុទ្ធវង្សទី ២២ ចប់**

# អដ្ឋកថា

## កក្កុសន្ធពុទ្ធវង្សទី ២២

កាលព្រះវេស្សភូសម្ពុទ្ធបរិនិព្វានហើយ កប្បនោះកន្លងទៅ ព្រះទិន្នករ គឺព្រះជិនសម្ពុទ្ធ ក៏មិនកើតឡើងអស់ ២៩ កប្ប ឯក្នុងភទ្ទកប្បនេះ មាន ព្រះពុទ្ធ ៤ ព្រះអង្គកើតឡើងហើយ គឺព្រះកក្កុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ ព្រះសម្ពុទ្ធនៃយើង ១ ។ ឯព្រះមានព្រះភាគមេត្តេយ្យ នឹង កើតឡើងក្នុងអនាគតកាល ដោយប្រការដូចពោលមកនេះ ទើបកប្បនេះ ព្រះមានព្រះភាគទ្រង់សរសើរថា ជាភទ្ទកប្ប ព្រោះប្រដាប់ដោយការកើត នៃព្រះពុទ្ធ ៥ ព្រះអង្គ ។

ក្នុងព្រះពុទ្ធ ៥ ព្រះអង្គនោះ ព្រះមានព្រះភាគព្រះនាមកកុសន្ធៈ ទ្រង់ បំពេញបារមីទាំងឡាយ ហើយកើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីទីនោះ ហើយ បដិសន្ធិក្នុងគភ៌របស់ព្រាហ្មណីឈ្មោះវិសាខា ជាភរិយាឯកនៃបុរោហិត ឈ្មោះអគ្គិទត្តៈ ដែលជាអ្នកថ្វាយអត្ថ និងធម៌របស់ព្រះបាទខេមង្ករៈ ក្នុង ខេមវតីនគរ ។ សម័យណា ក្សត្រទាំងឡាយ ធ្វើសក្ការគោរពកោតក្រែង បូជាព្រាហ្មណ៍ទាំងឡាយ សម័យនោះ ព្រះពោធិសត្វទាំងឡាយ រមែងកើត ក្នុងត្រកូលព្រាហ្មណ៍ សម័យណា កាលព្រាហ្មណ៍ទាំងឡាយធ្វើសក្ការគោរព កោតក្រែងបូជាក្សត្រទាំងឡាយ សម័យនោះ ព្រះពោធិសត្វទាំងឡាយ ក៏ កើតក្នុងត្រកូលក្សត្រ ។ បានឮថា ក្នុងកាលនោះ ព្រាហ្មណ៍ទាំងឡាយ ត្រូវ ក្សត្រទាំងឡាយធ្វើសក្ការៈ និងគោរពកោតក្រែង ព្រោះហេតុនោះ ទើបព្រះ ពោធិសត្វឈ្មោះកក្កុសន្ធៈ ដែលជាអ្នកមាំទាំក្នុងសច្ចៈ កាលញ៉ាំងម៉ឺនលោក-

ធាតុឲ្យកម្រើក ទើបកើតក្នុងត្រកូលព្រាហ្មណ៍ ដែលច្រើនទៅដោយហេតុឲ្យកើតសិរីសម្បត្តិ ដែលរីកវរ ៗ បាដិហារ្យដូចពោលមកហើយ ក៏កើតឡើង ៗ បន្ទាប់អំពីនោះ លុះកំណត់គ្រប់ទសមាស ក៏ប្រសូតចាកផ្ទៃមាតាត្រង់ខេមវតីឧទ្យាន ដូចអណ្តាតភ្លើងលៀនចេញអំពីវល្លិមាស ។ ព្រះពោធិសត្វអង្គនោះ គ្រប់គ្រងឃរាវាសអស់ ៤ ពាន់ឆ្នាំ មានប្រាសាទ ៣ ឈ្មោះកាមប្រាសាទ ១ កាមវណ្ណប្រាសាទ ១ កាមសុទ្ធិប្រាសាទ ១[១] មានស្រីជាបរិចារិកា ៣ ម៉ឺន មាននាងរោចិនីព្រាហ្មណី[២] ជាប្រធាន ។

កាលកុមារឈ្មោះឧត្តរៈ ជាឱរសរបស់នាងរោចិនីព្រាហ្មណីកើតហើយ ព្រះពោធិសត្វឃើញនិមិត្ត ៤ ហើយចេញមហាភិនេស្រ្កមណ៍ដោយរថដែលទឹមដោយសេះ រួចព្រះផ្នួស បុរស ៤ ម៉ឺនបួសតាមព្រះពោធិសត្វនោះ ព្រះពោធិសត្វដែលបព្វជិតទាំងនោះចោមរោមហើយ បំពេញព្យាយាម ៨ ខែ ក្នុងថ្ងៃវិសាខបុណ្ណមី បរិភោគមធុបាយាសដែលធីតាវជិរិន្ទព្រាហ្មណ៍ ក្នុងសុចិរិន្ទនិគមថ្វាយ ព្រះពោធិសត្វសម្រាកពេលថ្ងៃ ត្រង់ព្រៃគគីរ ពេលល្ងាចទទួលស្មៅ ៨ ក្តាប់ ដែលអ្នកយាមស្រែស្រូវជំណើបឈ្មោះសុភទ្ទថ្វាយ ចូលទៅកាន់ពោធិសព្រឹក្សឈ្មោះសិរីសៈ គឺដើមប្រេស ដែលមានទំហំប៉ុនដើមប្រទៀង មានក្លិនក្រអូបឈ្ងុយឈ្ងប់ លាតសន្ថតស្មៅ ៣៤ ហត្ថ គង់ពត់ភ្នែន សម្រេចសម្មាសម្ពោធិញ្ញាណ បន្លឺព្រះឧទានថា

---

១- បិដកខ្មែរជា កាមវឌ្ឍប្រាសាទ ១ កាមសុទ្ធិប្រាសាទ ១ រតិវឌ្ឍនប្រាសាទ ១ ។

២- បិដកខ្មែរជា រោចិនី ។

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វរល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគត
បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់សម្ងំនៅអស់ ៧ សប្តាហ៍ ទ្រង់ឃើញថា ភិក្ខុ ៤ ម៉ឺន ដែលបួសជាមួយព្រះអគ្គអាចចាក់ផ្ទះសច្ចៈ ក្នុងពេលមួយថ្ងៃប៉ុណ្ណោះ ក៏យាងចូលទៅកាន់ឥសិបតនមិគទាយវ័ន ដែលនៅក្បែរមេកិលនគរ ។ ព្រះមានព្រះភាគគង់នៅត្រង់កណ្តាលបព្វជិតទាំងនោះ ទ្រង់ប្រកាសធម្មចក្រ ជាការត្រាស់ដឹងលើកទី ១ មានដល់សត្វ ៤ ម៉ឺនកោដិ ។

សម័យក្រោយមក ទ្រង់ធ្វើយមកប្បាដិហារ្យ ត្រង់គល់មហាសាលព្រឹក្ស ក្បែរទ្វារកណ្ណកុជ្ជនគរ ទ្រង់ញ៉ាំងធម្មចក្រចក្ខុឲ្យកើតដល់សត្វ ៣ ម៉ឺនកោដិ នេះជាការត្រាស់ដឹងធម៌លើកទី ២ ។ កាលយក្ខឈ្មោះនរទេវៈ ដែលគេស្គាល់ថា ជាទេវតានៃនរជន ក្នុងទេវាល័យមួយកន្លែង មិនឆ្ងាយអំពីខេមវតីនគរ ប្រាកដខ្លួនជាមនុស្ស ឈរក្បែរស្រះមួយ ដែលមានទឹកត្រជាក់ប្រដាប់ដោយឈូកក្រហម ឈូក-ស និងឧប្បល មានទឹកត្រជាក់ មានរសឆ្ងាញ់ក្រៃលែង មានក្លិនក្រអូបគួរជាទីត្រេកអរ សម្រាប់ជនទាំងពួង នៅកណ្តាលផ្លូវកន្តារ បញ្ឆោតសត្វទាំងឡាយ ធ្វើជាមនុស្សបេះឈូកក្រហមឈូក-សជាដើម ហើយស៊ីមនុស្ស ។ កាលផ្លូវនោះកាត់ផ្តាច់ មិនមានមនុស្សទៅដល់ យក្ខឈ្មោះនរទេវៈ ក៏ចូលទៅកាន់ព្រៃធំ ស៊ីសត្វដែលប្រជុំ

គ្នាក្នុងទីនោះៗ ទើបផ្លូវនោះ សត្វលោកសន្មតថា ជាផ្លូវមហាកន្តារ បានឮថា ពួកមហាជន ឈរប្រជុំគ្នាត្រង់ផ្លូវចូលផ្លូវកន្តារទាំងសងខាង ដើម្បីជួយគ្នាឆ្លងផ្លូវកន្តារ ។ សម័យថ្ងៃមួយ ក្នុងវេលាទៀបភ្លឺ ព្រះសាស្ដាកកុសន្ធៈ ទ្រង់ប្រាសចាកកិលេសជាគ្រឿងចងក្នុងកព ទ្រង់ចេញអំពីមហាករុណាសមាបត្តិប្រមើលមើលលោក ទ្រង់ឃើញយក្ខមានសក្តិធំនោះ និងជនទាំងនោះចូលក្នុងសំណាញ់ញាណ កាលទ្រង់ជ្រាបហើយ ព្រះមានព្រះភាគក៏យាងទៅតាមអាកាស ក្នុងកាលដែលប្រជុំជនកំពុងឃើញនោះឯង ទ្រង់ក៏សម្ដែងយមកបាដិហារ្យច្រើនយ៉ាង ទ្រង់ចុះត្រង់លំនៅរបស់នរទេវយក្ខនោះ គង់លើបល្ល័ង្កដែលជាមង្គល ។

កាលនោះ យក្ខស៊ីមនុស្សនោះឃើញព្រះទិនករដ៏ជាមុនី ទ្រង់បញ្ចេញឆព្វណ្ណរង្សីដូចព្រះអាទិត្យ ដែលចោមរោមដោយឥន្ទធនូ កំពុងតែយាងមកតាមព្រៃធំ ក៏មានចិត្តជ្រះថ្លាថា ព្រះទសពលយាងមកទីនេះ ដើម្បីអនុគ្រោះអញ ទើបទៅព្រៃហិមពាន្ត មានពួកម្រឹគច្រើន មួយអន្លើដោយបរិវារយក្ខបេះផ្កាដែលកើតក្នុងទឹក និងលើគោក មានពណ៌ និងក្លិនផ្សេងៗ ជ្រើសរើសយកចំពោះតែផ្កាដែលមានក្លិនក្រអូប គួរជាទីត្រេកអរក្រៃលែង មកបូជាព្រះកកុសន្ធៈ ដែលជាលោកនាយក ប្រាសចាកទោស ដែលគង់លើបល្ល័ង្ករបស់ខ្លួន ដោយផ្កាក្រអូប និងគ្រឿងលាបជាដើមហើយ ច្រៀងដោយសំឡេងដ៏ពីរោះ ធ្វើអញ្ជលីដាក់លើសិរសា ឈរនមស្ការ ។ បន្ទាប់អំពីនោះ មនុស្សទាំងឡាយ ឃើញបាដិហារ្យនោះ មានចិត្តជ្រះថ្លា មកប្រជុំគ្នា នាំគ្នាឈរ

ចោមរោមព្រះមានព្រះភាគ ។ កាលនោះ ព្រះមានព្រះភាគកកុសន្ធៈដែលមិនមានបដិសន្ធិ ទ្រង់ញ៉ាំងនរទេវយក្ខ ដែលមនុស្ស និងទេវតាបូជាក្រៃលែងឲ្យអាចហ៊ាន ទ្រង់សម្តែងការទាក់ទងដោយកម្ម និងផលនៃកម្ម ឲ្យយក្ខតក់ស្លុត ដោយនិយកថា ហើយទើបត្រាស់ចតុសច្ចកថា ។ គ្រានោះ ការត្រាស់ដឹងធម៌មានដល់សត្វប្រមាណមិនបាន នេះជាការត្រាស់ដឹងលើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ក្នុងកាលជាក្រោយ នៃព្រះវេស្សភូសម្ពុទ្ធមក មានព្រះសម្ពុទ្ធព្រះនាមកកុសន្ធៈ ទ្រង់ប្រសើរជាងពួកសត្វទ្វេបាទ មានគុណរាប់មិនបាន គេគ្របសង្កត់បានដោយកម្រ ព្រះអង្គរម្លើងនូវភពទាំងពួង ដល់នូវបារមីដោយចរិយា ហើយសម្រេចនូវពោធិញ្ញាណដ៏ឧត្តម ដូចសីហៈទម្លាយនូវទ្រុង ។ កាលព្រះកកុសន្ធៈ ជាលោកនាយក ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ មានពួកបរិស័ទចំនួន ៤ ម៉ឺនកោដិ បានត្រាស់ដឹងក្នុងគ្រាដំបូង ។ ព្រះកកុសន្ធៈ ទ្រង់ធ្វើនូវវិកុព្វនបាដិហារ្យជាគូៗ ក្នុងអាកាស ញ៉ាំងទេវតា និងមនុស្ស ៣ ម៉ឺនកោដិ ឲ្យត្រាស់ដឹង ( នេះជាការត្រាស់ដឹងទី ២ ) ។ ក្នុងការប្រកាសនូវចតុស្សច្ចធម៌ នៃព្រះពុទ្ធនោះ មានមនុស្ស ទេវតា និងយក្ខត្រាស់ដឹងនូវធម៌ គេមិនអាចរាប់បាន ( នេះជាការត្រាស់ដឹងទី ៣ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧគ្គាតេត្វា** បានដល់ ទ្រង់ដកឡើងហើយ ។ បទថា **សព្វភវំ** បានដល់ នូវភពទាំង ៩ អធិប្បាយថា កម្មដែលជានិមិត្តនៃឧប្បត្តិក្នុងភព ។ បទថា **ចរិយាយ ធារមី គតោ** សេចក្តីថា ទ្រង់ដល់នូវត្រើយ ដោយទ្រង់បំពេញបារមីសព្វយ៉ាងបរិបូណ៌ ។ បទថា **សីហោវ បញ្ជរំ ភេត្វា** សេចក្តីថា ព្រះមុនីកុញ្ជរ ទ្រង់ទម្លាយបង្អួច គឺ ភព ដូចរាជសីហ៍ទម្លាយនូវទ្រុង ។

ព្រះកកុសន្ធៈទ្រង់វៀរនូវចំណង គឺភពហើយ ទ្រង់មានសាវកសន្និបាតតែម្តងប៉ុណ្ណោះ ព្រះមានព្រះភាគដែលព្រះអរហន្ត ៤ ម៉ឺន បួសដំណាលព្រះអង្គ ក្នុងឥសិបតនមិគទាយវ័ន ក្រុងកណ្ណកុជ្ជនគរចោមរោមហើយ ទ្រង់លើកបាតិមោក្ខឡើងសម្តែង ក្នុងថ្ងៃពេញបូណ៌មី ខែមាឃ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ព្រះមានជោគព្រះនាមកកុសន្ធៈ មានសាវកសន្និបាតតែមួយដង សុទ្ធតែជាព្រះខីណាស្រព មិនមានមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ សាវកសមាគមក្នុងកាលនោះ មានពួកព្រះខីណាស្រព ៤ ម៉ឺន ដែលដល់នូវទន្តភូមិ ( ភូមិនៃបុគ្គលអ្នកមានខ្លួនទូន្មានហើយ ) ព្រោះអស់ទៅនៃកិលេសមានអាសវៈជាដើម ដូច្នេះ ។

កាលនោះ ព្រះពោធិសត្វនៃយើង ជាព្រះរាជាព្រះនាមថា ខេមៈ ទ្រង់ថ្វាយបាត្រ ចីវរជាមហាទាន និងថ្វាយភេសជ្ជៈសព្វយ៉ាង មានថ្នាំបន្តក់ភ្នែក

ជាដើមដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន និងថ្វាយសមណបរិក្ខារដទៃ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ មានព្រះហឫទ័យជ្រះថ្លា ទ្រង់ព្រះផ្នួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ ព្រះសាស្តាអង្គនោះ ទ្រង់ព្យាករថា ក្នុងអនាគតកាល ក្នុងកប្បនេះឯង សត្វនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> សម័យនោះ តថាគតជាក្សត្រឈ្មោះខេមៈ បានថ្វាយទានដ៏ច្រើន ចំពោះព្រះតថាគត និងព្រះសង្ឃជាជិនបុត្ត ។ តថាគតបានចាត់ចែងថ្វាយបាត្រ ចីវរ ថ្នាំបន្តក់ និងដើមឈើអែម ទាំងអស់នេះ ជារបស់ប្រសើរក្រៃពេក ដែលតថាគតប្រាថ្នាហើយ ។ ព្រះមុនីកកុសន្ធៈ ជានាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងភទ្ទកប្បនេះ ក្សត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្ដុ ជាទីរីករាយ ។បេ។ បើឃ្លាងព្រះជិនស្រីអង្គនេះហើយ គង់តែនឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតពុំខាន ក៏យ៉ាងនោះដែរ ។ កាលនោះ នគរឈ្មោះខេមវតី ឯតថាគតជាបុរសឈ្មោះខេមៈ ស្វែងរកនូវសព្វញ្ញុតញ្ញាណ បានបួសក្នុងសម្នាក់នៃព្រះពុទ្ធអង្គនោះ ដូច្នេះ ។

ក្នុងគាថានោះ បទថា **អញ្ជនំ** ( ថ្នាំបន្តក់ភ្នែក ) មានសេចក្តីជាក់ច្បាស់ហើយ ។ បទថា **មធុលដ្ឋិកំ** បានដល់ ឈើប្រត់ដែលធ្វើអំពីដើម

ស្រគំ ។ បទថា **ឥមេតំ** កាត់បទជា **ឥមំ ឯតំ។** បទថា **បត្ថិតំ** បានដល់ ប្រាថ្នាហើយ ។ បទថា **បដិយាទេមិ** បានដល់ ប្រគេន អធិប្បាយថា បាន ប្រគេនហើយ ។ បទថា **វរំ វរំ** សេចក្តីថា ប្រសើរបំផុត ។ បាឋៈថា **យទេតំ បត្ថិតំ** ដូច្នេះក៏មាន ។ បាឋៈនោះ សេចក្តីថា តថាគតថ្វាយវត្ថុដែល ទ្រង់ប្រាថ្នាសព្វយ៉ាងដល់ព្រះអង្គ ។ សេចក្តីនេះល្អជាង ។

ព្រះមានព្រះភាគកកុសន្ធៈ ទ្រង់មិនមានកិលេសជាហេតុឃឹតយូរអង្គ នោះ មាននគរឈ្មោះខេមៈ បិតាជាព្រាហ្មណ៍ឈ្មោះអគ្គិទត្តៈ មាតាជា ព្រាហ្មណីឈ្មោះវិសាខា គូនៃអគ្គសាវកឈ្មោះវិធុរៈ ១ សញ្ជីវៈ ១ ពុទ្ធុបដ្ឋាក ឈ្មោះពុទ្ធិជៈ គូអគ្គសាវិកាឈ្មោះសាមា ១ ចម្បា ១ ពោធិព្រឹក្សឈ្មោះ សិរីសៈ គឺដើមច្រេស ព្រះសរីរៈកម្ពស់ ៤០ ហត្ថ ព្រះរស្មីនៃព្រះសរីរៈ ផ្សាយទៅជុំវិញ ១០ យោជន៍ ព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ឯករិយាជាព្រាហ្មណី ឈ្មោះរោចិនី ឱរសឈ្មោះឧត្តរៈ ទ្រង់ចេញអភិនេស្រ្កមណ៍ ដោយរថទឹម សេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះពុទ្ធព្រះនាមកកុសន្ធៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាន អគ្គិទត្តព្រាហ្មណ៍ ជាព្រះបិតា ព្រះមាតាព្រះនាមវិសាខា ។ មហាត្រកូលរបស់ព្រះសម្ពុទ្ធ នៅក្នុងខេមបុរីនោះ ជាត្រកូល ប្រសើរបំផុត មានជាតិខ្ពង់ខ្ពស់ មានយសធំជាងមនុស្ស ទាំងឡាយ ។ ព្រះកកុសន្ធៈ ស្វែងរកនូវគុណដ៏ធំ មានព្រះ ថេរៈឈ្មោះវិធុរៈ ១ សញ្ជីវៈ ១ ជាអគ្គសាវក ព្រះថេរៈ

ឈ្មោះពុទ្ធិជៈជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះសាមា ១ ឈ្មោះ
ចម្បា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងរបស់ព្រះ
មានព្រះភាគនោះ ហៅថា សិរិសព្រឹក្ស ( ដើមប្រេស ) ។
ព្រះមហាមុនីមានកម្ពស់ ៨០ ហត្ថ រស្មីដូចជាមាសផ្សាយចេញ
ទៅកាន់ទិចម្ងាយ ១០ យោជន៍ដោយជុំវិញ ។ ព្រះមហេសី
នោះ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ព្រះអង្គគង់នៅកំណត់
ប៉ុណ្ណោះ ទ្រង់ញុំាងប្រជុំជនដ៏ច្រើន ឲ្យឆ្លង ( ចាកសង្សារ ) ។
ព្រះសម្ពុទ្ធនោះ ព្រមទាំងសាវ័ក តាំងពានផ្សារ គឺព្រះសទ្ធម្ម
បន្លឺឡើងដូចជាសីហនាទ ចំពោះនរៈ និងនារីទាំងឡាយ ក្នុង
មនុស្សលោក ព្រមទាំងទេវលោក ហើយនិព្វាន ។ ព្រះសម្ពុទ្ធ
បរិបូណ៌ដោយពាក្យ ប្រកបដោយអង្គ ៨ សីលទាំងឡាយ
មិនធ្លុះធ្លាយ ជាប់មិនដាច់ របស់ទាំងអស់ វិនាសសូន្យទៅ
ឱ ! សង្ខារទាំងពួង ជារបស់មិនទៀងទេតើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វសេតេ តត្ថ ខេមេ បុរេ** នេះ គប្បីជ្រាប
ថា លោកពោលចង្អុលបង្ហាញនគរ ដែលព្រះកកុសន្ធៈទ្រង់ប្រសូត ។ បទថា
**មហាកុលំ** បានដល់ ត្រកូលខាងព្រះជនកនៃព្រះមានព្រះភាគ ជាត្រកូល
រុងរឿង ។ បទថា **នរានំ បវរំ សេដ្ឋំ** សេចក្តីថា ប្រសើរជាងមនុស្ស
ទាំងអស់ដោយជាតិ ។ បទថា **ជាតិមន្តំ** បានដល់ មានជាតិក្រៃលែង មាន
ជាតិខ្ពស់ ។ បទថា **មហាយសំ** បានដល់ មានបរិវារច្រើន ។ ត្រកូលធំ

របស់ព្រះពុទ្ធនោះ ដូចម្ដេច ។ ពាក្យនោះ គប្បីឃើញការភ្ជាប់សេចក្ដីជាមួយបទថា **មហាកុលំ ខេមេ បុរេ វសតេ** សេចក្ដីថា ត្រកូលធំនៅក្នុងក្រុងខេមៈ ។

បទថា **សមន្តា ទសយោជនំ** សេចក្ដីថា រស្មីពណ៌មាសចេញចាកព្រះសរីរៈជានិច្ចផ្សាយទៅ ១០ យោជន៍ដោយជុំវិញ ។ បទថា **ធម្មាបណំ** បានដល់ ផ្សារ ពោល គឺធម៌ ។ បទថា **បសារេត្វា** សេចក្ដីថា ផ្សាយនូវផ្សារ គឺធម៌ ដូចផ្សាយនូវផ្សារដែលស្តុកស្តម្ភដោយទំនិញច្រើនប្រភេទ ដើម្បីលក់ ។ បទថា **នរនារីនំ** បានដល់ ដើម្បីជួបនូវរតនៈវិសេស គឺឈានសមាបត្តិ មគ្គ និងផល សម្រាប់បុរសស្ត្រីទាំងឡាយ ។ បទថា **សីហនាទំ** ។ គឺ **សីហនាទំ វិយ** បានដល់ បន្ទឺសំឡេងដែលមិនមានភ័យ ។ បទថា **អដ្ឋង្គវចនសម្បន្នោ** បានដល់ ព្រះសាស្ដា ទ្រង់មានព្រះសូរសៀងប្រកបដោយអង្គ ៨ ។ បទថា **អច្ឆិទ្ទានិ** បានដល់ សីលដែលវៀរចាកភាវៈមិនដាច់ជាដើម គឺមិនដាច់ មិនពព្រុះ មិនពពាល ម្យ៉ាងទៀត សីលមិនធ្លុះមិនមានប្រហោង គឺគូអគ្គសាវកដែលមិនដាច់ មិនធ្លុះ ។ បទថា **និរន្តរំ** បានដល់ រឿយៗ អស់កាលជានិច្ច ។ បទថា **សតុំ តមន្តរហិតំ** សេចក្ដីថា

ព្រះសាស្ដា និងគូអគ្គសាវកជាដើម ទាំងអស់នោះ ចូលដល់ភាពជាមុនី ហើយក៏ចូលដល់ភាពជាបុគ្គលមើលមិនឃើញ ។

បានឮថា ព្រះកកុសន្ធៈ ទ្រង់ប្រាសចាកចំណង មានបញ្ញា
មិនឃើតឃូរ ប្រាសចាកទោសទាំងពួង ទ្រង់តាំងមាំក្នុង
ត្រៃលោក ទ្រង់មាំទាំក្នុងសច្ចៈ គង់នៅក្នុងខេមវ័ន ។

ពាក្យក្នុងគាថាដ៏សេស ជាក់ច្បាស់ហើយ ។

**អដ្ឋកថាកក្កុសន្ធពុទ្ធវង្សទី ២២ ចប់**

# សុត្តន្តបិដក

## កោនាគមនពុទ្ធវង្សទី ២៣

[ ២៤ ] កាលជាខាងក្រោយអំពីព្រះកកុសន្ធៈមក មានព្រះជិនស្រីសម្ពុទ្ធ ព្រះនាមកោនាគមនៈ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន ។ ព្រះសម្ពុទ្ធអង្គនោះ បានបំពេញបារមីធម៌ទាំង ១០ កន្លងផ្លូវឆ្ងាយ គឺជាតិ លះបង់មន្ទិលទាំងអស់ ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះកោនាគមនសម្ពុទ្ធជានាយក ញុំាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ពួកសត្វចំនួន ៣ ម៉ឺនកោដិ បានត្រាស់ដឹងជំបូង ។ កាលទ្រង់ធ្វើបាដិហារិយ៍ ញុំាំញីពាក្យត្មះតិះដៀលនៃជនដទៃ ពួកសត្វចំនួន ២ ម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី ២ ។ លំដាប់ពីនោះ ព្រះជិនស្រីធ្វើនូវវិកុព្វនបាដិហារិយ៍ ហើយទ្រង់យាងទៅកាន់ទេវបុរី ព្រះសម្ពុទ្ធគង់នៅលើបណ្ឌុកម្ពលសិលា ក្នុងទេវលោកនោះ ។ ព្រះមុនីនោះ កាលសម្តែងសត្តបករណាភិធម្ម គង់ចាំវស្សា ( ក្នុងទេវលោក ) ពួកសត្វចំនួនមួយម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី ៣ ។ ព្រះពុទ្ធជាទេវតាទ្រង់ប្រសើរជាងទេវតាអង្គនោះ ទ្រង់មានសាវកសន្និបាតតែមួយដង ដែលសុទ្ធតែជាពួកព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ សាវកសមាគមក្នុងកាលនោះ មានភិក្ខុ ៣ ម៉ឺន ដែលកន្លងឱឃៈ ផ្តាច់បង់មច្ចុ ។ សម័យនោះ តថាគតជាក្សត្រ ឈ្មោះបព្វតៈ បរិបូណ៌ដោយមិត្ត និងអាមាត្យ

មានពល និងពាហនៈច្រើន ។ តថាគតទៅគាល់ព្រះសម្ពុទ្ធ ស្តាប់ធម៌ដ៏ប្រសើរ ហើយនិមន្តព្រះសង្ឃ ព្រមទាំងព្រះជិនស្រី ថ្វាយទានតាមសេចក្តីប្រាថ្នា ។ តថាគតបានថ្វាយវត្ថុ ៤ មុខ គឺសំពត់ចិនប្រទេស ១ សំពត់សូត្រ ១ សំពត់កម្ពល ១ ស្បែកជើងមាស ១ ចំពោះព្រះសាស្តា ព្រមទាំងសាវ័ក ។ ព្រះមុនីនោះទ្រង់គង់នៅក្នុងកណ្តាលសង្ឃ ទ្រង់ព្យាករតថាគតថា មហាបុរសនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បនេះ ។ សត្វនេះ នឹងចេញពីនគរកបិលពស្តុ ជាទីត្រេកអរ តាំងនូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះហើយ ចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានឆាន់បាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចសម្តៅទៅឯពោធិមណ្ឌៈ តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់នោះ មហាបុរសមានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយបានត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនេះព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ក្សត្រអង្គនេះនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរី

ឈ្មោះខេមា ១ ឧប្បលវណ្ណា ១ សុទ្ធតែមិនមានអាសវៈ ប្រាស ចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថ-ព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធរកបុគ្គលស្មើគ្មាន ស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា មហាបុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោឡើង ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថនេះ គង់នឹងសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលអនាគតមិនខាន ។ មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងអនាគតកាលក៏យ៉ាងនោះដែរ ។ តថាគតស្តាប់ព្រះពុទ្ធដីកានៃព្រះសម្ពុទ្ធនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាដោយក្រៃលែង បានទំអធិដ្ឋានវត្តតទៅ ដោយការបំពេញនូវបារមីទាំង ១០ ។ តថាគត

ប្រសើរជាងជន កាលស្វែងរកសញ្ញាតញ្ញាណ បានឲ្យទាន លះបង់រាជសម្បត្តិដ៏ធំ ហើយបួសក្នុងសម្នាក់ព្រះជិនស្រី ។ មាននគរឈ្មោះសោភវតី ក្សត្រព្រះនាមសោភៈ ត្រកូលធំរបស់ព្រះពុទ្ធនៅក្នុងនគរនោះ ។ ព្រាហ្មណ៍ឈ្មោះយញ្ញទត្ត ( ជាព្រះបិតា ) នាងឧត្តរាជាព្រះមាតារបស់ព្រះសម្ពុទ្ធ ព្រះនាមកោនាគមនៈ ជាសាស្តានោះ ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅគ្រប់គ្រងព្រះដំណាក់ អស់ ៣ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ គឺតុសិត-ប្រាសាទ ១ សន្តុសិតប្រាសាទ ១ សន្តុដ្ឋប្រាសាទ ១ ។ មាននារីមិនខ្វះពីមួយម៉ឺន ៦ ពាន់នាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសី ព្រះនាមរុចិគត្តា ព្រះរាជបុត្តព្រះនាមសត្ថវាហៈ ។ បុរសដ៏ឧត្តមឃើញនូវនិមិត្តទាំង ៤ យ៉ាងហើយ ចេញទៅដោយយានដំរី បានប្រព្រឹត្តព្យាយាមអស់ ៦ ខែ ។ ព្រះកោនាគមនៈជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមធំប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងចក្កឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះពុទ្ធព្រះនាមកោនាគមនៈ ដ៏មានយស មានព្រះថេរៈឈ្មោះភិយ្យោសៈ ១ ឧត្តរៈ ១ ជាអគ្គ-សាវ័ក ព្រះថេរៈឈ្មោះសោត្ថិជៈជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះសមុទ្ទា ១ ឧត្តរា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា ឧទុម្ពរព្រឹក្ស ( ដើមល្វា ) ។ ឧបាសក

ឈ្មោះឧគ្គៈ ១ ឈ្មោះសោមទេវៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកា ឈ្មោះសីវលា ១ ឈ្មោះសាមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធនោះ មានកម្ពស់ ៣០ ហត្ថ ប្រដាប់ដោយរស្មីយ៉ាងនេះ ដូចជាមាសក្នុងមាត់នៃបាវ ។ ព្រះពុទ្ធមានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ជាកំណត់ ព្រះអង្គស្ថិតនៅកំណត់ត្រឹមនោះ ញ៉ាំងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័កលើកឡើងនូវធម្មចេតិយ ស្អិតស្អាងដោយសំពត់ គឺធម៌ ធ្វើនូវកម្រងផ្កា គឺធម៌ ហើយបរិនិព្វាន ។ ជនជាសាវ័ករបស់ព្រះពុទ្ធនោះ សម្ដែងនូវធម៌ដ៏មានសិរី ដល់នូវឫទ្ធិដ៏ធំទូលាយ របស់ទាំងអស់នេះ វិនាសសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ។ ព្រះសម្ពុទ្ធព្រះនាមកោនាគនៈ និព្វានក្នុងបព្វតារាម ព្រះធាតុផ្សាយទៅក្នុងទីនោះៗ តាមចំណែក ។

កោនាគមនពុទ្ធវង្សទី ២៣ ចប់

# អដ្ឋកថា

## កោណាគមនពុទ្ធវង្សទី ២៣

ក្រោយអំពីសម័យព្រះមានព្រះភាគកកុសន្ធៈ កាលសាសនារបស់ព្រះអង្គអន្តរធានហើយ កាលសត្វទាំងឡាយកើតមកមានអាយុ ៣ ម៉ឺនឆ្នាំ ព្រះសាស្ដាព្រះនាមកោនាគមនៈ ដែលមានន័យថា បុគ្គលមានឈើផ្ដាត់ពិណមកជាប្រយោជន៍ដល់អ្នកដទៃ ទ្រង់បានកើតឡើងក្នុងលោក ន័យម្យ៉ាងទៀតព្រះសាស្ដាព្រះនាមកោនាគមនៈ ព្រោះជាទីមកនៃអាករណោមាស កើតឡើងក្នុងលោក ។ គ្រឿងប្រដាប់ មានមាសជាដើមធ្លាក់ចុះមក ក្នុងកាលដែលព្រះមានព្រះភាគអង្គណាកើតឡើង ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថាកោនាគមនៈ ដោយន័យរបស់និរុត្តិសាស្ត្រ ព្រោះអាទេស **ក** ជា **កោ** អាទេស **ន** ជា **ណា** លុប **ក** មួយតួចេញ ក្នុងពាក្យថា **កោណាគមនោ** នោះ ក្នុងសេចក្ដីនេះ អាយុ លោកធ្វើឲ្យវិនាសចុះដោយលំដាប់ តែមិនមែនវិនាសយ៉ាងនេះ គប្បីជ្រាបថា ចម្រើនហើយ វិនាសចុះវិញ ។ សេចក្ដីនេះដូចម្ដេច ក្នុងកប្បនេះប៉ុណ្ណោះ ព្រះមានព្រះភាគកកុសន្ធៈ ទ្រង់កើតឡើងក្នុងកាលដែលមនុស្សមានអាយុ ៤ ម៉ឺនឆ្នាំ តែអាយុនោះកំពុងថយចុះដល់ ១០ ឆ្នាំ ហើយចម្រើនឡើង ដល់អាយុរាប់មិនអស់ បន្ទាប់អំពីនោះ ក៏ថយចុះមកសល់ ៣ ម៉ឺនឆ្នាំ កាលនោះគប្បីជ្រាបថា ព្រះមានព្រះភាគកោនាគមនៈ ទ្រង់កើតឡើងក្នុងលោក ។

ព្រះពោធិសត្វបំពេញបារមីទាំងឡាយ ហើយកើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងផ្ទៃរបស់ព្រាហ្មណី ឈ្មោះឧត្តរា ជា

អ្នកប្រសើរដោយគុណ មានរូបជាដើម ជាភរិយារបស់យញ្ញទត្តព្រាហ្មណ៍ ក្រុងសោភវតី គ្រប់កំណត់ទសមាស ក៏ប្រសូតចាកផ្ទៃរបស់ព្រះជននី ក្នុងសុភវតីឧទ្យាន កាលព្រះពោធិសត្វប្រសូត ភ្លៀងមាសក៏ធ្លាក់ចុះមកពេញជម្ពូទ្វីប ព្រោះហេតុដែលទ្រង់ជាទីមកនៃមាស ទើបព្រះញាតិវង្សព្រានុវង្សថ្វាយព្រះនាមថា កនកាគមនៈ ។ ព្រះនាមរបស់ព្រះពោធិសត្វនោះ ក៏ក្លាយមកដោយលំដាប់ជា កោនាគមនៈ ។ ព្រះពោធិសត្វ នៅជាឃរាវាសវិស័យអស់ ៣ ពាន់ឆ្នាំ មានប្រាសាទ ៣ ឈ្មោះតុសិតៈ ១ សន្តុសិតៈ ១ សន្តុដ្ឋៈ ១ មានស្រីបម្រើ ១ ម៉ឺន ៦ ពាន់នាក់ មាននាងរុចិគត្តាព្រាហ្មណី ជាប្រធាន ។

កាលបុត្តឈ្មោះសត្ថវាហៈ របស់នាងរុចិគត្តាព្រាហ្មណីប្រសូត ព្រះពោធិសត្វឃើញនិមិត្ត ៤ ក៏ឡើងកាន់ករជីរ ចេញអភិនេស្រ្កមណ៍ ទ្រង់បួសមួយអន្លើដោយ... ៣ ម៉ឺននាក់ ។ ព្រះពោធិសត្វដែលបព្វជិតទាំងនោះចោមរោម ក៏បំពេញព្យាយាម ៦ ខែ ក្នុងថ្ងៃវិសាខបុណ្ណមី ក៏សោយមធុបាយាស ដែលអគ្គិសោណព្រាហ្មណកុមារី ជាធីតារបស់អគ្គិសោណព្រាហ្មណ៍ប្រគេន ហើយទ្រង់សម្រាកពេលថ្ងៃក្នុងព្រៃគគីរ លុះដល់វេលាល្ងាច ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអ្នកយាមស្រែស្រូវដំណើបឈ្មោះជដាតិន្ទុកៈប្រគេន ទើបចូលទៅកាន់មណ្ឌលពោធិព្រឹក្ស ឈ្មោះដើមឧទុម្ពរ គឺដើមល្វាមានទំហំដូចពោលហើយ ក្នុងដើមបុណ្ឌរីក ដែលដល់ព្រមដោយសេចក្តីចម្រើននៃផ្លែ អំពីទិសទក្សិណ ទ្រង់លាតសន្ថតស្មៅ ២០ ហត្ថ អង្គុយពត់

ក្អែន កម្ចាត់ពលមារ ទ្រង់បាននូវទសពលញ្ញាណ ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វង្វេងតែ )

ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល

ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគត

បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ព្រះសាស្តាសម្ងំនៅអស់ ៧ សប្តាហ៍ ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់ភិក្ខុ ៣ ម៉ឺន ដែលបួសជាមួយព្រះអង្គ យាងទៅតាមអាកាស ទ្រង់ចុះត្រង់ព្រៃឥសិបតនមិគទាយវ័ន ក្បែរសុទស្សននគរ កណ្តាលភិក្ខុទាំងនោះ ទ្រង់ប្រកាសធម្មចក្រ គ្រានោះ ការត្រាស់ដឹងធម៌លើកទី ១ មានដល់សត្វ ៣ ម៉ឺនកោដិ ។

ក្រោយមក ទ្រង់ធ្វើយមកប្បាដិហារត្រង់មណ្ឌលពោធិព្រឹក្ស ក្បែរទ្វារសុទ្ធនគរ ទ្រង់ញុំាងសត្វ ២ ម៉ឺនកោដិ ឲ្យផឹកនូវអមតធម៌ នេះជាការត្រាស់ដឹងធម៌លើកទី ២ កាលព្រះមានព្រះភាគ ទ្រង់សម្តែងអភិធម្មបិដកប្រោសទេវតាទាំងឡាយ ដែលមកប្រជុំគ្នាក្នុងម៉ឺនចក្កវាឡ មាននាងឧត្តរាមាតារបស់ព្រះអង្គជាប្រធាន ការត្រាស់ដឹងធម៌លើកទី ៣ មានដល់សត្វ ១ ម៉ឺនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលជាខាងក្រោយ អំពីព្រះកកុសន្ធៈមក មានព្រះជិនស្រី-

សម្ពុទ្ធ ព្រះនាមកោនាគមនៈ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ

ជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន ។ ព្រះសម្ពុទ្ធអង្គនោះ

បានបំពេញបារមីធម៌ទាំង ១០ កន្លងផុតឆ្ងាយ គឺជាតិ លះបង់
មន្ទិលទាំងអស់ ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រះកោនា-
គមនសម្ពុទ្ធ ជានាយក ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ពួកសត្វ
ចំនួន ៣ ម៉ឺនកោដិ បានត្រាស់ដឹងជំបូង ។ កាលទ្រង់ធ្វើ
បាដិហារិយ៍ ញាំញីពាក្យត្មះតិះដៀលនៃជនដទៃ ពួកសត្វចំនួន
២ ម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី ២ ។ លំដាប់ពីនោះ
ព្រះជិនស្រីធ្វើនូវវិកុព្វនបាដិហារិយ៍ ហើយទ្រង់យាងទៅកាន់
ទេវបុរី ព្រះសម្ពុទ្ធគង់នៅលើបណ្ឌុកម្ពលសិលា ក្នុងទេវលោក
នោះ ។ ព្រះមុនីនោះ កាលសម្ដែងសត្តបករណាភិធម្ម គង់ចាំ
វស្សា ( ក្នុងទេវលោក ) ពួកសត្វចំនួនមួយម៉ឺនកោដិ បាន
ត្រាស់ដឹងជាលើកទី ៣ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធសធម្មេ បូរយិត្វាន** បានដល់ បំពេញនូវ
បារមីធម៌ ១០ ។ បទថា **កន្តារំ សមតិក្កមិ** បានដល់ ឈានកន្លងនូវជាតិ-
កន្តារ ។ បទថា **បវាហិយ** បានដល់ ទ្រង់បន្សាត់ហើយ ។ បទថា **មលំ
សព្វំ** បានដល់ មន្ទិល ៣ មានរាគៈជាដើម ។ បទថា **ចាដិហីរំ ករោន្តេ ច
បរវាទប្បមទ្ទនេ** សេចក្ដីថា កាលព្រះមានព្រះភាគទ្រង់ធ្វើបាដិហារ្យ ក្នុងការ
ញាំញីវាទៈនៃបរបក្ខ ។ បទថា **វិកុព្វនំ** បានដល់ សម្ដែងឫទ្ធិផ្សេងៗ ។ ព្រះ
មានព្រះភាគ ទ្រង់ធ្វើនូវយមកប្បាដិហារ្យ ក្បែរទ្វារសុន្ទរនគរហើយ យាង
ទៅកាន់ទេវលោក ចាំវស្សាលើបណ្ឌុកម្ពលសិលាអាសនៈ ក្នុងទេវលោកនោះ

សួរថា ទ្រង់ចាំវស្សាដូចម្តេច ឆ្លើយថា ទ្រង់សម្តែងអភិធម្ម ៧ គម្ពីរ អធិប្បាយថា ទ្រង់ចាំវស្សា សម្តែងអភិធម្មបិដក ៧ គម្ពីរ ដល់ទេវតាទាំងឡាយ ក្នុងទេវលោកនោះ កាលព្រះមានព្រះភាគ ទ្រង់សម្តែងអភិធម្ម ក្នុងទីនោះយ៉ាងនេះ ការត្រាស់ដឹងធម៌ មានដល់ទេវតាមួយម៉ឺនកោដិ ។

សូម្បីព្រះកោនាគមនសម្ពុទ្ធ ទ្រង់បំពេញបារមីបរិសុទ្ធ ទ្រង់មានសាវកសន្និបាតម្តងប៉ុណ្ណោះ ។ ព្រះមានព្រះភាគ កាលគង់នៅក្នុងសុរិន្ទវតីឧទ្យាន ក្នុងសុរិន្ទវតីនគរ ទ្រង់សម្តែងធម៌ប្រោសរាជបុត្ត ២ អង្គ គឺភិយ្យោសរាជបុត្ត ១ ឧត្តររាជបុត្ត ១ មួយអន្លើដោយបរិវារ ទ្រង់ញុំាងជនទាំងអស់ ឲ្យបួសដោយឯហិភិក្ខុ ទ្រង់គង់កណ្តាលភិក្ខុទាំងនោះ ទ្រង់លើកបាតិមោក្ខឡើង ក្នុងថ្ងៃមាឃបុណ្ណមី ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ព្រះពុទ្ធជាទេវតា ទ្រង់ប្រសើរជាងទេវតាអង្គនោះ ទ្រង់មាន
> សាវកសន្និបាតតែមួយដង ដែលសុទ្ធតែជាពួកព្រះខីណា-
> ស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។
> សាវកសមាគមក្នុងកាលនោះ មានភិក្ខុ ៣ ម៉ឺន ដែលកន្លង
> ឱឃៈ ផ្តាច់បង់មច្ចុ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱឃានំ** បានដល់ ឱឃៈ មានកាមោឃៈជាដើម ពាក្យនេះ ជាឈ្មោះនៃឱឃៈ ៤ ។ ឱឃៈទាំងនោះរបស់បុគ្គលណាមាន រមែងប្រាទបុគ្គលនោះឲ្យលិចចុះក្នុងវដ្តៈ ព្រោះហេតុនោះ ទើបឈ្មោះថា ឱឃៈ ។ សំដៅដល់ឱឃៈទាំងនោះ គប្បីឃើញថា ជាឆដ្ឋីវិភត្តិ ចុះក្នុង

អត្តុទ្ធតិយាវិកត្តិ សេចក្តីថា ឈានកន្ទង់នូវឱឃៈ ៤ យ៉ាង ។ ក្នុងពាក្យថា **ភិជ្ជិតានំ** នេះ ក៏មានន័យយ៉ាងនេះដូចគ្នា ។ បទថា **មច្ចុយា** គឺ **មច្ចុនោ**។

គ្រានោះ ព្រះពោធិសត្វនៃយើងជាព្រះរាជាព្រះនាមបព្វតៈ ក្នុងមិថិលនគរ ។ គ្រានោះ ព្រះរាជា មួយអន្ទើដោយបរិវារ ទ្រង់ស្តាប់ដំណឹងថា ព្រះកោនាគមនសម្ពុទ្ធ ជាទីមកនៃសព្វសត្វដែលដល់សរណៈ យាងដល់ក្រុងមិថិលនគរហើយ ទ្រង់យាងចេញទៅទទួល ថ្វាយបង្គំនិមន្តព្រះទសពល ថ្វាយមហាទាន ទូលអារាធនាព្រះមានព្រះភាគ ឲ្យចាំវស្សាក្នុងមិថិលនគរនោះ ឧបត្ថម្ភព្រះសាស្តា ព្រមទាំងព្រះសង្ឃសាវ័កអស់ត្រៃមាស ថ្វាយរបស់មានតម្លៃច្រើន ដូចជាសំពត់សូត្រធ្វើក្នុងបត្តុន្ននគរ និងសំពត់ធ្វើក្នុងចីននគរ សំពត់កម្ពល សំពត់ព្រៃ សំពត់សម្បកឈើ សំពត់ដែលត្បាញអំពីកប្បាសជាដើម សំពត់សាច់ម៉ដ្ឋ ទ្រនាប់ព្រះបាទដែលធ្វើអំពីមាស និងបរិក្ខារដទៃៗ ជាច្រើន ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វនោះថា ក្នុងភទ្ទកប្បនេះឯង ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ លំដាប់នោះ មហាបុរសស្តាប់ពាក្យព្យាករណ៍របស់ព្រះមានព្រះភាគអង្គនោះ ទ្រង់បរិច្ចាគរាជសម្បត្តិដ៏ធំក្រៃលែង ទ្រង់ព្រះផ្នួសក្នុងសម្នាក់របស់ព្រះមានព្រះភាគអង្គនោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

សម័យនោះ តថាគតជាក្សត្រ ឈ្មោះបព្វតៈ បរិបូណ៌ដោយ
មិត្ត និងអាមាត្យ មានពល និងពាហនៈច្រើន ។ តថាគតទៅ
គាល់ព្រះសម្ពុទ្ធស្តាប់ធម៌ដ៏ប្រសើរ ហើយនិមន្តព្រះសង្ឃ ព្រម

ទាំងព្រះជិនស្រី ថ្វាយទានតាមសេចក្តីប្រាថ្នា ។ តថាគតបាន ថ្វាយវត្ថុ ៤ មុខ គឺសំពត់ចិនប្រទេស ១ សំពត់សូត្រ ១ សំពត់កម្ពល ១ ស្បែកជើងមាស ១ ចំពោះព្រះសាស្តា ព្រមទាំងសាវ័ក ។ ព្រះមុនីនោះ ទ្រង់គង់នៅក្នុងកណ្តាល សង្ឃ ទ្រង់ព្យាករតថាគតថា មហាបុរសនេះ នឹងបានត្រាស់ ជាព្រះពុទ្ធក្នុងកប្បនេះ ។ សត្វនេះ នឹងចេញពីនគរកបិល-ពស្តុ ជាទីត្រេកអរ តាំងនូវព្យាយាម ។បេ។ បើឃ្លាងព្រះ ជិនស្រីនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តា អង្គនេះ ក្នុងអនាគតកាលក៏យ៉ាងនោះដែរ តថាគតស្តាប់ព្រះ ពុទ្ធដីកា នៃព្រះសម្ពុទ្ធនោះហើយ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាដោយ ក្រៃលែង បានទំអធិដ្ឋានវត្តតទៅ ដោយការបំពេញនូវបារមី ទាំង ១០ ។ តថាគតប្រសើរជាងជន កាលស្វែងរកសព្ញ-តញ្ញាណ បានឲ្យទាន លះបង់រាជសម្បត្តិដ៏ធំ ហើយបួសក្នុង សម្នាក់ព្រះជិនស្រី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនន្តពលវាហនោ** សេចក្តីថា កម្លាំងពល និងវាហនៈ មានដំរី សេះជាដើមរបស់តថាគតមានច្រើន មិនមានបំផុត ។ បទថា **សម្ពុទ្ធទស្សនំ** បានដល់ ដើម្បីគាល់ព្រះសម្ពុទ្ធ ។ បទថា **យថិច្ឆកំ** សេចក្តីថា គ្រប់គ្រាន់ដល់តម្រូវការ គឺទ្រង់អង្គាសព្រះសង្ឃ មានព្រះពុទ្ធ ជាប្រធាន ដោយអាការ ៤ យ៉ាង រហូតដល់ព្រះសាស្តាឃាត់ថា ល្មមហើយ

ល្មមហើយ យកព្រះហស្តបិទបាត្រ ។ បទថា **សត្ថុសាវកេ** បានដល់ ថ្វាយដល់ព្រះសាស្តា និងសាវកទាំងឡាយ ។ បទថា **នរុត្តមេ** គឺ **នរុត្តមស្ស** បានដល់ ឧត្តមបំផុតក្នុងនរជន ។ បទថា **ឱហាយ** បានដល់ លះ ឬលះបង់ ។

ព្រះមានព្រះភាគកោនាគមនៈអង្គនោះ ទ្រង់មាននគរឈ្មោះសោភវតី ព្រះជនកជាព្រាហ្មណ៍ឈ្មោះយញ្ញទត្តៈ ព្រះជននីជាព្រាហ្មណីឈ្មោះឧត្តរា គូអគ្គសាវកឈ្មោះភិយ្យសៈ ១ ឧត្តរៈ ១ ពុទ្ធុបដ្ឋាកឈ្មោះសោត្ថិជៈ គូអគ្គសាវិកាឈ្មោះសមុទ្ទា ១ ឧត្តរា ១ ពោធិព្រឹក្សឈ្មោះឧទុម្ពរព្រឹក្ស ព្រះសរីរៈកម្ពស់ ៣០ ហត្ថ ព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ភរិយាជាព្រាហ្មណីឈ្មោះរុចិគត្តា ឱរសឈ្មោះសត្ថវាហៈ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយយានដំរី ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

មាននគរឈ្មោះសោភវតី ក្សត្រព្រះនាមសោភៈ ត្រកូលធំ
របស់ព្រះពុទ្ធ នៅក្នុងនគរនោះ ។ ព្រាហ្មណ៍ឈ្មោះយញ្ញទត្ត
( ជាព្រះបិតា ) នាងឧត្តរាជាព្រះមាតារបស់ព្រះសម្ពុទ្ធ ព្រះ
នាមកោនាគមនៈជាសាស្តានោះ ។ ព្រះពុទ្ធព្រះនាមកោនាគមនៈ
ដ៏មានយស មានព្រះថេរៈឈ្មោះភិយ្យោសៈ ១ ឧត្តរៈ ១
ជាអគ្គសាវក ព្រះថេរៈឈ្មោះសោត្ថិជៈជាឧបដ្ឋាក ។ ព្រះថេរី
ឈ្មោះសមុទ្ទា ១ ឧត្តរា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់
ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា ឧទុម្ពរព្រឹក្ស
( ដើមល្វា ) ។ ព្រះពុទ្ធនោះ មានកម្ពស់ ៣០ ហត្ថ ប្រដាប់

ដោយរស្មីយ៉ាងនេះ ដូចជាមាសក្នុងមាត់នៃបាវ ។ ព្រះពុទ្ធ មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ជាកំណត់ព្រះអង្គស្ថិតនៅកំណត់ត្រឹមនោះ ញ៉ាំងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័ក លើកឡើងនូវធម្មចេតិយ ស្អិតស្អាងដោយសំពត់ គឺធម៌ ធ្វើនូវកម្រងផ្កា គឺធម៌ ហើយបរិនិព្វាន ។ ជនជាសាវ័ករបស់ព្រះពុទ្ធនោះ សម្តែងនូវធម៌ ដ៏មានសិរី ដល់នូវឫទ្ធិដ៏ធំទូលាយ របស់ទាំងអស់នេះ វិនាសសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧក្កាមុខេ** បានដល់ ចង្ក្រានរបស់ជាងមាស ។ បទថា **យថា កម្ពុ** សេចក្តីថា ដូចដុំមាស ។ បទថា **ឯវំ រំសីហិ មណ្ឌិតោ** បានដល់ ប្រដាប់តាក់តែងដោយរស្មីទាំងឡាយ យ៉ាងនេះ ។ បទថា **ធម្មចេតិយំ សមុស្សេត្វា** បានដល់ ប្រតិស្ឋានចេតិយ សម្រេចដោយពោធិបក្ខិយធម៌ ៣៧ ។ បទថា **ធម្មទុស្សវិភូសិតំ** បានដល់ ប្រដាប់ដោយទង់ធម៌ គឺសច្ចៈ ៤ ។ បទថា **ធម្មបុប្ផគុឡំ កត្វា** បានដល់ ធ្វើឲ្យជាកម្រងមាល័យផ្កា សម្រេចដោយធម៌ អធិប្បាយថា ព្រះសាស្តា មួយអន្លើដោយសង្ឃសាវ័ក ប្រោសឲ្យប្រតិស្ឋានព្រះធម្មចេតិយ ដើម្បីមហាជនដែលនៅត្រង់លានព្រះចេតិយ សម្រាប់បំពេញវិបស្សនា នឹងបានទទមស្ការ ហើយក៏រម្ងត់ខន្ធបរិនិព្វាន ។ បទថា **មហាវិលាសោ** បានដល់ ដល់នូវភាពវិលាសនៃឫទ្ធិដ៏ក្រៃលែង ។ បទថា **តស្ស** បានដល់ របស់ព្រះមានព្រះភាគអង្គនោះ ។

បទថា **ជនោ** បានដល់ ជន គឺសាវ័ក ។ បទថា **សិរិធម្មប្បកាសនោ** សេចក្ដីថា ព្រះមានព្រះភាគអង្គនោះ ប្រកាសលោកុត្តរធម៌ទាំងពួងនោះ ក៏ទ្រង់អន្តរធានទៅ ។ ក្នុងគាថាដ៏សេសសព្វអន្លើ ជាក់ច្បាស់ហើយនោះឯង ។

ព្រះកោនាគមនសម្ពុទ្ធ ទ្រង់មានអាសវៈទៅប្រាសហើយ
ដោយស្រួល ជាទីមកនៃសត្វដែលប្រាសចាកកាម ជាអ្នក
ស្វែងរកគុណធំ ជាទីមកនៃវង្សរបស់បុគ្គលបរិសុទ្ធ ប្រថាប់
នៅក្នុងព្រៃ ដែលមាននាមជាសិរីដ៏ស្វាត់ ៗ៚

## **អដ្ឋកថាកោនាគមនពុទ្ធវង្សទី ២៣ ចប់**

# សុត្តន្តបិដក

## កស្សបពុទ្ធវង្សទី ២៤

[ ២៥ ] កាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមកោនាគមនៈមក មានព្រះសម្ពុទ្ធព្រះនាមកស្សបៈ ដ៏ឧត្តមជាងសត្វទ្វេបាទ ជាធម្មរាជ ទ្រង់ធ្វើពន្លឺ ។ ផុះជាឫសនៃត្រកូលព្រះពុទ្ធ ទ្រង់លះបង់ហើយ ព្រះពុទ្ធនោះទ្រង់ឲ្យទាន គឺបាយ និងទឹកច្រើនដល់យាចកទាំងឡាយ ហើយញ៉ាំងព្រះហឫទ័យឲ្យពេញ ដល់សម្ពោធិញ្ញាណដ៏ឧត្តម ដូចជាគោឧសភទម្លាយនូវក្រោល ។ កាលព្រះកស្សបៈជាលោកនាយក ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ពួកបរិស័ទចំនួន ២ ម៉ឺនកោដិ បានត្រាស់ដឹងជាគ្រាដំបូង ។ កាលព្រះសម្ពុទ្ធយាងទៅកាន់ចារិកក្នុងទេវលោក អស់ ៤ ខែ ពួកបរិស័ទមួយម៉ឺនកោដិ បានត្រាស់ដឹងជាគ្រាទី ២ ។ ព្រះសាស្តាធ្វើយមកប្បាដិហារ្យ និងវិកុព្វនឫទ្ធិ សម្តែងនូវញាណធាតុ ពួកបរិស័ទ ៥ ពាន់កោដិ បានត្រាស់ដឹងជាគ្រាទី ៣ ។ ព្រះជិនស្រីសម្តែងធម៌ ក្នុងសុធម្មទេវបុរី ជាទីរីករាយក្នុងទេវលោកនោះ ញ៉ាំងទេវតា ៣ ពាន់កោដិឲ្យត្រាស់ដឹង ។ ក្នុងការសម្តែងធម៌ដទៃទៀត ដល់ទេវតាមនុស្ស និងយក្ខ ជនទាំងនោះ បានត្រាស់ដឹងរាប់មិនអស់ ។ ព្រះពុទ្ធជាទេវតាដ៏ប្រសើរនោះ មានសាវកសន្និបាតតែមួយដង ដែលសុទ្ធតែជាពួកព្រះខីណាស្រព មិនមានមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ ការប្រជុំក្នុងកាលនោះ មានភិក្ខុ ២ ម៉ឺនរូប ដែល

មានភពកន្លងហើយ មានចិត្តនឹងធឹង ដោយហិរិ និងសីល ។ កាល
នោះ តថាគតជាមាណព ឈ្មោះជោតិបាល ជាអ្នករៀនមន្ត ចេះ
ចាំមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ។ តថាគតដល់នូវបារមីក្នុង
គម្ពីរលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងព្រះសទ្ធម្មផង
ឈ្លាសវៃក្នុងផែនដី និងអាកាស មានវិជ្ជាធ្វើរួចហើយ ជាអ្នក
មិនមានរោគ ។ ឧបាសកឈ្មោះឃដិការ ជាឧបដ្ឋាករបស់ព្រះ
មានព្រះភាគព្រះនាមកស្សបៈ ប្រកបដោយសេចក្ដីគោរព ប្រកប
ដោយសេចក្ដីកោតក្រែង និព្វានក្នុងផលទី ៣ ឃដិការនាំតថាគត
ចូលទៅគាល់ព្រះជិនស្រី ព្រះនាមកស្សបៈ តថាគតស្ដាប់ធម៌
របស់ព្រះពុទ្ធនោះ ក៏បួសក្នុងសម្នាក់នៃព្រះអង្គ ។ តថាគតមាន
ព្យាយាមក្លៀវក្លា ឈ្លាសវៃក្នុងវត្តតូច និងវត្តធំ មិនមានសេចក្ដី
សាបសូន្យក្នុងសីល និងសមាធិណាមួយឡើយ ញ៉ាំងសាសនា
នៃព្រះជិនស្រីឲ្យពេញបរិបូណ៌ ។ សាសនាព្រះសាស្ដា មានអង្គ
៩ ដែលព្រះអង្គសម្ដែងហើយទាំងប៉ុន្មាន តថាគតបានរៀននូវធម៌
ទាំងអស់នោះ ហើយញ៉ាំងសាសនាព្រះជិនស្រីឲ្យរុងរឿង ។ ព្រះ
ពុទ្ធនោះ ឃើញហេតុជាអស្ចារ្យរបស់តថាគត ក៏ទ្រង់ព្យាករថា
ជោតិបាលមាណពនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ក្នុងភទ្ទកប្ប
នេះឯង ។ សត្វនេះ នឹងចេញអំពីនគរកបិលពស្ដុ ជាទីរីកកាយ
តម្កល់សេចក្ដីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយ

នៅទៀបគល់នៃអជបាលព្រឹក្ស ទទួលយកបាយាសក្នុងទីនោះ ហើយចូលទៅឯស្ទឹងនេរញ្ជរា ។ សត្វនេះ សោយបាយាសទៀបច្រាំងស្ទឹងនេរញ្ជរា ហើយចូលសម្តៅទៅរកគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេចាត់ចែងហើយ ។ លំដាប់ពីនោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងបានត្រាស់ដឹងនូវសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ នឹងបានជាអគ្គសាវក ព្រះថេរៈឈ្មោះអានន្ទជាឧបដ្ឋាក នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះនាងខេមា ១ នាងឧប្បលវណ្ណា ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ នឹងបានជាអគ្គសាវិកា ។ ឈើជាទីត្រាស់ដឹង របស់ព្រះមានជោគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធរក

បុគ្គលស្មើគ្មាន ស្វែងរកគុណធំហើយ ក៏រីករាយថា មាណពនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស និងទេវតា ទាំងមួយម៉ឺនលោកធាតុ មានសំឡេងហ៊ោឡើង ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ មនុស្សទាំងឡាយកាលឆ្លងនូវស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ តថាគត បានស្តាប់ព្រះពុទ្ធដីការបស់ព្រះពុទ្ធអង្គនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានទំអធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមីទាំង ១០ ។ តថាគតកាលបំពេញបារមីយ៉ាងនេះ តថាគតតែងអន្ទោលទៅ វៀរនូវមារយាទអាក្រក់ អំពើដែលបុគ្គលធ្វើដោយកម្រ តថាគតបានធ្វើហើយព្រោះហេតុពោធិញ្ញាណ ។ នគរឈ្មោះពារាណសី ក្សត្រព្រះនាមកិកី ត្រកូលធំរបស់ព្រះសម្ពុទ្ធ នៅក្នុងនគរនោះ ព្រះពុទ្ធព្រះនាមកស្សបៈ ទ្រង់ស្វែងរកគុណដ៏ធំ មានព្រហ្មទត្តព្រាហ្មណ៍ ជាព្រះបិតា ព្រះមាតាព្រះនាមធនវតី ។ ព្រះអង្គគង់គ្រប់គ្រងព្រះ

ដំណាក់អស់ ២ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ គឺហំសប្រាសាទ ១ យសប្រាសាទ ១ សិរិចន្ទប្រាសាទ ១ ។ នារី ១៦ ពាន់ ៣ ជន មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសីនោះ ព្រះនាមសុនន្ទា ព្រះរាជបុត្តព្រះនាមវិជិតសេន ។ ព្រះពុទ្ធជាបុរសដ៏ឧត្តម ឃើញនូវនិមិត្តទាំង ៤ ក៏បានចេញទៅដោយប្រាសាទ ទ្រង់ប្រព្រឹត្តសេចក្តីព្យាយាមអស់ ៧ ថ្ងៃ ( បានត្រាស់ជាព្រះពុទ្ធ ) ។ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ទ្រង់ឧត្តមជាងនរជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងចក្កឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះថេរៈឈ្មោះតិស្សៈ ១ ភារទ្វាជៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះសព្វមិត្តជាឧបដ្ឋាក របស់ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ស្វែងរកគុណដ៏ធំ ។ ព្រះថេរីឈ្មោះអនុលា ១ ឧរុវេលា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានជោគនោះ ហៅថា និគ្រោធព្រឹក្ស ( ដើមជ្រៃ ) ។ ឧបាសកឈ្មោះសុមង្គលៈ ១ ឃដិការៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះវិជិតសេនា ១ ភទ្រា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះសម្ពុទ្ធនោះមានកម្ពស់ ២០ ហត្ថ ដូចជាផ្លេកបន្ទោរដ៏អាកាស ឬដូចជាព្រះចន្ទ ដែលផ្កាយចោមរោមហើយ ។ ព្រះមហេសីអង្គនោះ មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ព្រះអង្គស្ថិតនៅត្រឹមនោះ

ទ្រង់ញ៉ាំងប្រជុំជនដ៏ច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះអង្គនិម្មិតស្រះ គឺព្រះសទ្ធម្ម ទ្រង់ប្រទានគ្រឿងលាប គឺសីល ទ្រង់ញ៉ាំងសត្វឲ្យស្លៀកសំពត់ គឺព្រះធម៌ ទ្រង់ចែកកម្រងផ្កា គឺព្រះធម៌ ទ្រង់តម្កល់ទុកកញ្ចក់ មិនមានមន្ទិល គឺព្រះសទ្ធម្ម ចំពោះពួកមហាជនថា ពួកជនណាមួយ កាលប្រាថ្នានិព្វាន ចូរមើលមើលគ្រឿងប្រដាប់របស់តថាគតចុះ ។ ព្រះសម្ពុទ្ធនោះ ឲ្យអាវ គឺសីល ឲ្យស្បែកក្រោះ គឺឈាន ឲ្យដណ្តប់ស្បែក គឺព្រះធម៌ ឲ្យកាំបិតស្នៀតដ៏ឧត្តម គឺព្យាយាម ។ ឲ្យខែល គឺសតិ ឲ្យកាំបិត គឺញាណដ៏មុត ឲ្យព្រះខ័នដ៏ប្រសើរ គឺធម៌ ឲ្យប្រដាប់សម្រាប់ញាំញីសត្រូវ គឺសីល ។ ឲ្យគ្រឿងស្អិតស្អាង គឺវិជ្ជា ៣ ឲ្យគ្រឿងពាក់ត្រចៀក គឺផល ៤ ឲ្យគ្រឿងអាភរណៈ គឺអភិញ្ញា ៦ ឲ្យគ្រឿងប្រដាប់ជាវិការនៃផ្កា គឺព្រះសទ្ធម្ម ។ ព្រះសម្ពុទ្ធអង្គនោះព្រមទាំងសាវ័ក ឲ្យឆត្រស គឺព្រះសទ្ធម្មជាគ្រឿងឃាត់នូវបាបនិម្មិតនូវផ្កាមិនមានភ័យហើយ ទើបបរិនិព្វាន ។ ព្រះសម្មាសម្ពុទ្ធអង្គនុ៎ះ ប្រមាណមិនបាន បុគ្គលគ្របសង្កត់បានដោយកម្រ ព្រះ

ធម្មរតនៈនុ៎ះ ដែលព្រះអង្គសម្តែងហើយ ដោយប្រពៃ ជាធម៌គួរហៅអ្នកផង ឲ្យចូលមកមើលបាន ។ ព្រះសង្ឃរតនៈនុ៎ះ លោកប្រតិបត្តិហើយ ដោយប្រពៃ ជាព្រះសង្ឃដ៏ប្រសើរ របស់ទាំងនេះ វិនាសសោះសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ។ ព្រះជិនស្រីជាសាស្តា ព្រះនាមមហាកស្សបៈ ទ្រង់និព្វានក្នុងសេតព្យារាម ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះ មានកម្ពស់មួយយោជន៍ ក្នុងទីនោះ ។

## កស្សបពុទ្ធវង្សទី ២៤ ចប់

# អដ្ឋកថា

## កស្សបពុទ្ធវង្សទី ២៤

ខាងក្រោយសម័យនៃព្រះមានព្រះភាគកោនាគមនៈ កាលសាសនានៃព្រះអង្គអន្តរធានហើយ សត្វមានអាយុ ៣ ម៉ឺនឆ្នាំ ក៏ថយចុះដោយលំដាប់ រហូតដល់មានអាយុ ១០ ឆ្នាំ ហើយចម្រើនឡើងវិញ រហូតដល់មានអាយុរាប់មិនអស់ ហើយក៏ថយចុះមកវិញដោយលំដាប់ រហូតដល់សត្វមានអាយុ ២ ម៉ឺនឆ្នាំ ។ ព្រះសាស្តាព្រះនាមកស្សបៈ ជាអ្នកគ្រប់គ្រងមនុស្សដ៏ច្រើនកើតឡើងក្នុងលោក ទ្រង់បំពេញបារមីទាំងឡាយហើយ កើតក្នុងស្ថានសួគ៌ជាន់តុសិត ចុតិអំពីនោះហើយ បដិសន្ធិក្នុងផ្ទៃរបស់ព្រាហ្មណីឈ្មោះធនវតី ជាអ្នកមានគុណបរិបូណ៌នៃព្រាហ្មណ៍ឈ្មោះព្រហ្មទត្ត ក្នុងនគរពារាណសី ។ លុះគ្រប់កំណត់ទសមាស ក៏ប្រសូតចាកផ្ទៃព្រះជននី ក្នុងឥសិបតនមិគទាយវ័ន តែញាតិទាំងឡាយថ្វាយព្រះនាមព្រះអង្គដោយគោត្ត កស្សបកុមារ ទ្រង់នៅជាយរាវាស ២ ពាន់ឆ្នាំ មានប្រាសាទ ៣ ឈ្មោះហំសវា ១ យសវា ១ និងសិរិនន្ទៈ ១[១] មានស្រីបម្រើ ៤ ម៉ឺន ៨ ពាន់នាក់ មាននាងសុនន្ទាព្រាហ្មណីជាប្រធាន ។ កាលបុត្តឈ្មោះវិជិតសេនរបស់នាងសុនន្ទាព្រាហ្មណីកើតហើយ ព្រះពោធិសត្វឃើញនិមិត្ត ៤ យ៉ាង កើតសេចក្តីសង្វេគ កាលព្រះអង្គទ្រង់ត្រិះរិះប៉ុណ្ណោះ ប្រាសាទក៏វិលដូចក្អារយន្ត សម្រាប់ធ្វើភាជន៍ដីរបស់ស្មូនឆ្នាំង អណ្តែតទៅកាន់អាកាស កាលមនុស្សចោមរោមហើយ ដូចព្រះទិន្នករក្នុងសារទរដូវ ដែលជាគ្រឿងធ្វើឲ្យល្អក្រៃលែង ដែលពួកផ្កាយ

---

១- បិដកខ្មែរជា ហំសប្រាសាទ ១ យសប្រាសាទ ១ សិរិចន្ទប្រាសាទ ១ ។

ចោមរោមហើយ អណ្តែតទៅហាក់បីដូចប្រដាប់អាកាស ហាក់បីដូចប្រកាសបុញ្ញានុភាព ហាក់បីដូចឆក់ទាញកែវភ្នែក និងដួងចិត្តរបស់ជន ដូចត្រួយឈើទាំងឡាយល្អក្រៃលែង ត្រង់កណ្តាល ហើយចុះលើផែនដី ដោយឲ្យដើមនិគ្រោធ ដែលជាពោធិព្រឹក្សនៅត្រង់កណ្តាល ។ កាលនោះ ព្រះពោធិសត្វដែលមហាសត្វឈរត្រង់ផែនដី កាន់យកទង់ជ័យនៃអរហត្ត ដែលទេវតាប្រគេន ទ្រង់ព្រះផ្នួសហើយ អ្នកបម្រើរបស់ព្រះអង្គក៏ចុះអំពីប្រាសាទ ធ្វើដំណើរទៅកន្ទះគាវុត មួយអន្ទើដោយបរិវារ ទើបនាំគ្នាអង្គុយ ដូចការបោះបន្ទាយនៃកងទ័ព បន្ទាប់អំពីនោះ បុគ្គលដែលមកជាមួយ ក៏នាំគ្នាបួសទាំងអស់ វៀរតែអ្នកបម្រើ ។

បានឮថា ព្រះមហាបុរសដែលជនទាំងនោះចោមរោមហើយ ទ្រង់បំពេញព្យាយាមអស់ ៧ ថ្ងៃ ក្នុងថ្ងៃវិសាខបុណ្ណមី សោយមធុបាយាសដែលនាងសុនន្ទាព្រាហ្មណីថ្វាយហើយ ទ្រង់សម្រាកពេលថ្ងៃ ក្នុងព្រៃគគីរលុះដល់វេលាល្ងាច ទ្រង់ទទួលស្មៅ ៨ ក្តាប់ ដែលអ្នកយាមស្រូវជំណើបឈ្មោះសោមៈថ្វាយ ទើបចូលទៅកាន់ពោធិព្រឹក្ស ឈ្មោះដើមនិគ្រោធ ទ្រង់លាតស្មៅទំហំ ១៥ ហត្ថ គង់លើសន្ថតស្មៅនោះ សម្រេចអភិសម្ពោធិញ្ញាណទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល

ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន ។បេ។ ហើយតថាគត
បានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

ទ្រង់សម្ងំនៅ ៧ សប្តាហ៍ ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់ភិក្ខុមួយកោដិ ដែលបួសតាមព្រះអង្គ ទ្រង់យាងទៅតាមអាកាស ចុះត្រង់ឥសិបតនមិគទាយវ័ន ក្រុងពារាណសី ដែលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់ប្រកាសព្រះធម្មចក្រ ក្នុងឥសិបតនមិគទាយវ័ននោះ ។ កាលនោះ ការត្រាស់ដឹងលើកទី ១ មានដល់សត្វ ២ ម៉ឺនកោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមកោនាគមនៈមក មាន
ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ដ៏ឧត្តមជាងសត្វទ្វេបាទ ជាធម្មរាជ
ទ្រង់ធ្វើពន្លឺ ។ ផុះជាឫសនៃត្រកូលព្រះពុទ្ធ ទ្រង់លះបង់ហើយ
ព្រះពុទ្ធនោះ ទ្រង់ឲ្យទាន គឺបាយ និងទឹកច្រើន ដល់យាចក
ទាំងឡាយ ហើយញ៉ាំងព្រះហឫទ័យឲ្យពេញ ដល់សម្ពោ-
ធិញ្ញាណដ៏ឧត្តម ដូចជាគោឧសភទម្លាយនូវក្រោល ។ កាល
ព្រះកស្សបៈជាលោកនាយក ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ពួក
បរិស័ទចំនួន ២ ម៉ឺនកោដិ បានត្រាស់ដឹងជាគ្រាដំបូង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សញ្ឆឌ្ឌិតំ** បានដល់ ដែលព្រះអង្គលះបង់ហើយ ចោលហើយ បោះបង់ហើយ ។ បទថា **កុលមូលំ** សេចក្តីថា ផុះនៃត្រកូល មានគំនរកោគៈរាប់មិនអស់ មានគំនរទ្រព្យច្រើនពាន់កោដិ មាន

ភោគៈដូចកពសហស្សនេត្រ ដែលលះបង់បានដោយលំបាក ក៏លះបានដូច លះស្មៅ ។ បទថា **យាចកេ** បានដល់ ឲ្យដល់យាចកទាំងឡាយ ។ បទថា **អាឡកំ** បានដល់ ក្រោលគោ អធិប្បាយថា គោឧសភកាច់បំបាក់ក្រោល ហើយ ទៅកាន់ទីដែលខ្លួនប្រាថ្នាតាមសប្បាយ យ៉ាងណា សូម្បីព្រះមហា-បុរស ទម្លាយនូវចំណង គឺផ្ទះ ហើយទ្រង់សម្រេចអភិសម្ពោធិញ្ញាណបាន ក៏យ៉ាងនោះ ។

តមកទៀត កាលព្រះសាស្តាចារិកទៅក្នុងជនបទ ការត្រាស់ដឹងធម៌ លើកទី ២ មានដល់សត្វ ១ ម៉ឺនកោដិ កាលទ្រង់ធ្វើយមកប្បាដិហារ្យត្រង់ គល់ធ្នង់ ក្បែរទ្វារសុន្ទរនគរ ទ្រង់សម្តែងធម៌ ការត្រាស់ដឹងធម៌លើកទី ៣ មានដល់សត្វ ៥ ពាន់កោដិ ។ បន្ទាប់មកទៀត ទ្រង់ធ្វើយមកប្បាដិហារ្យ ហើយគង់ក្នុងទេវសភាឈ្មោះ សុធម្មា ក្នុងស្ថានតាវត្តិង្ស ដែលសត្រូវរបស់ ទេវតាគ្របសង្កត់មិនបាន កាលទ្រង់សម្តែងអភិធម្មបិដក ៧ គម្ពីរ ដើម្បី អនុគ្រោះទេវតាទាំងឡាយក្នុងម៉ឺនលោកធាតុ មានជនវតីជននីរបស់ព្រះអគ្គ ជាប្រធាន ទ្រង់ញ៉ាំងទេវតា ៣ ពាន់កោដិ ឲ្យផឹកនូវអមតធម៌ ដោយ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលព្រះសម្ពុទ្ធយាងទៅកាន់ចារិក ក្នុងទេវលោក អស់ ៤
ខែ ពួកបរិស័ទមួយម៉ឺនកោដិ បានត្រាស់ដឹងជាគ្រាទី ២ ។
ព្រះសាស្តាធ្វើយមកប្បាដិហារ្យ និងវិកុព្វនឫទ្ធិ សម្តែងនូវ
ញាណធាតុ ពួកបរិស័ទ ៥ ពាន់កោដិ បានត្រាស់ដឹងជាគ្រា

ទី ៣ ។ ព្រះជិនស្រីសម្ដែងធម៌ ក្នុងសុធម្មទេវបុរី ជាទីរីករាយ ក្នុងទេវលោកនោះ ញ៉ាំងទេវតា ៣ ពាន់កោដិ ឲ្យត្រាស់ដឹង ។ ក្នុងការសម្ដែងធម៌ដទៃទៀត ដល់ទេវតា មនុស្ស និងយក្ខ ជនទាំងនោះ បានត្រាស់ដឹងរាប់មិនអស់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចតុមាសំ** គឺ **ចតុមាសេ** ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **ចរតិ** គឺ **អចរិ** ។ បទថា **យមកំ វិកុព្វនំ កត្វា** បានដល់ ទ្រង់ធ្វើយមកប្បាដិហារ្យ ។ បទថា **ញាណធាតុំ** បានដល់ សភាវៈនៃព្រះសព្វញ្ញុតញ្ញាណ អាចារ្យពួកខ្លះពោលថា **សព្វញ្ញាណធាតុំ** ដូច្នេះក៏មាន ។ បទថា **បកិត្តយិ** បានដល់ ទ្រង់ប្រកាសដល់មហាជន ។ បទថា **សុធម្មា** សេចក្ដីថា សភា ឈ្មោះថា សុធម្មា មានក្នុងស្ថានតាវត្តិង្ស ទ្រង់គង់នៅក្នុងសភានោះ ។ បទថា **ធម្មំ** បានដល់ ព្រះអភិធម្ម ។

បានឮថា កាលនោះ មានយក្ខឈ្មោះនរទេវៈ មានអានុភាព ជាអ្នកឈ្នះក្នុងសង្គ្រាម មានសក្តិធំ មានឫទ្ធិច្រើន ដូចនរទេវយក្ខដែលពោលមកហើយ អំពីខាងដើម ។ នរទេវយក្ខនោះ កាឡាខ្លួនដូចព្រះរាជាក្នុងនគរមួយក្នុងជម្ពូទ្វីប ទាំងរូបរាង ទ្រង់ទ្រាយ សំឡេង ហើយសម្លាប់ព្រះរាជាពិតប្រាកដចោល បន្លំខ្លួនជាព្រះរាជា គ្រប់គ្រងព្រះរាជដំណាក់ សោយសាច់មិនកំណត់ចំនួន ។ បានឮថា នរទេវយក្ខនោះ ជាអ្នកលេងស្រីផងដែរ តែកាលណាស្ត្រីដែលឈ្លាស ស្គាល់យក្ខនោះថា មិនមែនព្រះរាជា ជាអមនុស្ស គ្រានោះ យក្ខនោះធ្វើជាខ្នាស ស៊ីស្ត្រីទាំងនោះអស់ ហើយក៏ធ្វើដំណើរទៅនគរ

ដទៃ ៗ ដោយប្រការដូច្នេះ នរទេវយក្ខនោះ ស៊ីមនុស្សហើយ បែរមុខទៅកាន់សុទ្ធវនគរ ។ ពួកមនុស្សអ្នកនគរឃើញយក្ខនោះហើយ ត្រូវមរណភ័យគំរាម ក៏តក់ស្លុត នាំគ្នាចេញអំពីនគររបស់ខ្លួន រត់ភៀសខ្លួនទៅ ។

កាលនោះ ព្រះកស្សបទសពលឃើញពួកមនុស្សនាំគ្នាគេចទៅ ក៏ឈរទល់មុខនរទេវយក្ខនោះ ។ នរទេវយក្ខកាលឃើញព្រះទេវទេព គឺព្រះទសពលឈរក្នុងទីចំពោះមុខ ក៏បន្លឺសំឡេងខ្លួនខ្លារ តែមិនអាចឲ្យព្រះមានព្រះភាគតក់ស្លុតបានឡើយ ក៏ដល់នូវព្រះពុទ្ធជាសរណៈ ហើយទូលសួរបញ្ហា កាលព្រះសាស្ដាទ្រង់វិសជ្ជនា សម្ដែងធម៌ទូន្មានយក្ខនោះ ការត្រាស់ដឹងធម៌ មានដល់មនុស្ស និងទេវតាដែលមកប្រជុំគ្នា ហួសនឹងគណនារាប់បាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **នរទេវស្ស យក្ខស្ស** ជាដើម ។ ក្នុងគាថានោះ បទថា **អបរេ ធម្មទេសនេ** បានដល់ ក្នុងការសម្ដែងធម៌គ្រាដំបូង ។ បទថា **ឯតេសានំ** គឺ **ឯតេសំ** ។ បាលីក៏យ៉ាងនោះដូចគ្នា ។

ព្រះមានព្រះភាគកស្សបៈអង្គនោះ មានសាវកសន្និបាតម្ដងប៉ុណ្ណោះ ។ មានបុត្តបុរោហិតក្នុងក្រុងពារាណសីឈ្មោះតិស្សៈបានស្ដាប់បិតា ដែលឃើញលក្ខណសម្បត្តិក្នុងសរីរៈ នៃព្រះកស្សបពោធិសត្វហើយ ពោលឲ្យស្ដាប់ ក៏គិតថា បុរសនេះ នឹងចេញមហាភិនេស្ក្រមណ៍ ត្រាស់ជាព្រះពុទ្ធ ដោយឥតសង្ស័យ អញនឹងបួសក្នុងសម្នាក់របស់ព្រះអង្គ នឹងផុតចាកសង្សារទុក្ខ ទើបទៅកាន់ព្រៃហិមពាន្ត ដែលមានពួកមុនីបរិសុទ្ធ បួសជាតាបស មានតាបស ២ ម៉ឺនជាបរិវារ តមកខាងក្រោយ បានដឹងថា ព្រះកស្សបកុមារចេញអភិនេ-

ស្រ្កមណ៍ សម្រេចអភិសម្ពោធិញ្ញាណ ដល់ព្រមដោយបរិវារ មកបួសដោយឯហិភិក្ខុ ក្នុងសម្នាក់ព្រះមានព្រះភាគកស្សបៈ ហើយសម្រេចអរហត្ត ។ ព្រះមានព្រះភាគកស្សបៈ ទ្រង់លើកបាតិមោក្ខឡើងសម្ដែង ក្នុងថ្ងៃមាឃបុណ្ណមី ក្នុងសមាគមនោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ព្រះពុទ្ធជាទេវតា ដ៏ប្រសើរនោះ មានសាវកសន្និបាតតែមួយ
ជន ដែលសុទ្ធតែជាពួកព្រះខីណាស្រព មិនមានមន្ទិល មាន
ចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ ការប្រជុំក្នុងកាលនោះ មាន
ភិក្ខុ ២ ម៉ឺនរូប ដែលមានភពកន្លងហើយ មានចិត្តនឹងធឹង
ដោយហិរិ និងសីល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អតិក្កន្តភវន្តានំ** បានដល់ បុគ្គលលើសលំដាប់បុថុជ្ជន និងអរិយបុគ្គល មានសោតាបន្នជាដើម គឺជាព្រះខីណាស្រពទាំងអស់ ។ បទថា **ហិរិសីលេន តាទិនំ** បានដល់ បុគ្គលស្មើគ្នា ដោយហិរិ និងសីល ។

គ្រានោះ ព្រះពោធិសត្វនៃយើងជាមាណពឈ្មោះជោតិបាល ចប់ត្រៃវេទ មានឈ្មោះបោះសំឡេងក្នុងការទាយលក្ខណៈ និងមើលដីជយភូមិ និងលក្ខណៈអាកាស ជាសម្លាញ់របស់ឃដិការឧបាសក ដែលជាស្មូនឆ្នាំង ។ ជោតិបាលមាណពនោះ ចូលគាល់ព្រះសាស្ដា មួយអន្លើដោយឃដិការឧបាសកនោះ ស្ដាប់ធម្មកថារបស់ព្រះអង្គហើយ ក៏បួសក្នុងសម្នាក់របស់ព្រះអង្គ ។ ព្រះពោធិសត្វនោះ ប្រារព្ធព្យាយាម រៀនព្រះត្រៃបិដក ញុំាងពុទ្ធសាសនាឲ្យ

ស្អាត ដោយកិច្ចបដិបត្តិមហាវត្ត និងខុទ្ទកវត្ត ព្រះសាស្តាអង្គនោះ ទ្រង់ក៏ព្យាករព្រះពោធិសត្វនោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលនោះ តថាគតជាមាណព ឈ្មោះជោតិបាល ជាអ្នករៀនមន្ត
ចេះចាំមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ។ តថាគតដល់នូវបារមី
ក្នុងគម្ពីរលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងព្រះសទ្ធម្មផង
ឈ្លាសវៃក្នុងផែនដី និងអាកាស មានវិជ្ជាធ្វើរួចហើយ ជាអ្នក
មិនមានរោគ ។ ឧបាសកឈ្មោះឃដិការ ជាឧបដ្ឋាករបស់ព្រះ
មានព្រះភាគព្រះនាមកស្សបៈ ប្រកបដោយសេចក្តីគោរព ប្រកប
ដោយសេចក្តីកោតក្រែង និព្វានក្នុងផលទី ៣ ឃដិការនាំតថាគត
ចូលទៅគាល់ព្រះជិនស្រី ព្រះនាមកស្សបៈ តថាគតស្តាប់ធម៌
របស់ព្រះពុទ្ធនោះ ក៏បួសក្នុងសម្នាក់នៃព្រះអង្គ ។ តថាគតមាន
ព្យាយាមក្លៀវក្លា ឈ្លាសវៃក្នុងវត្តតូច និងវត្តធំ មិនមានសេចក្តី
សាបសូន្យក្នុងសីល និងសមាធិណាមួយឡើយ ញុំាងសាសនា
នៃព្រះជិនស្រី ឲ្យពេញបរិបូណ៌ ។ សាសនាព្រះសាស្តាមានអង្គ
៩ ដែលព្រះអង្គសម្តែងហើយទាំងប៉ុន្មាន តថាគតបានរៀននូវធម៌
ទាំងអស់នោះ ហើយញុំាងសាសនាព្រះជិនស្រីឲ្យរុងរឿង ។ ព្រះ
ពុទ្ធនោះ ឃើញហេតុជាអស្ចារ្យរបស់តថាគត ក៏ទ្រង់ព្យាករថា
ជោតិបាលមាណពនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ក្នុងកប្បកប្ប
នេះឯង ។ សត្វនេះ នឹងចេញអំពីនគរកបិលពស្តុ ជាទីរីករាយ

តម្កល់សេចក្តីព្យាយាម ។បេ។ បើឃ្លាំងព្រះជិនស្រីអង្គនេះហើយ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះពុទ្ធដីការបស់ព្រះពុទ្ធអង្គនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានទំអធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមីទាំង ១០ ។ តថាគតកាលបំពេញបារមីយ៉ាងនេះ តថាគតតែងអន្ទោលទៅ វៀរនូវមារយាទអាក្រក់ អំពើដែលបុគ្គលធ្វើដោយកម្រ តថាគតបានធ្វើហើយ ព្រោះហេតុពោធិញ្ញាណ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភូមន្តលិក្ខកុសលោ** សេចក្តីថា ជាអ្នកឈ្លាសក្នុងវិជ្ជាមើលដី វិជ្ជាមើលលក្ខណៈអាកាស វិជ្ជាតារាសាស្ត្រ និងវិជ្ជាហោរាសាស្ត្រ ។ បទថា **ឧបដ្ឋកោ** បានដល់ អ្នកបម្រើ ។ បទថា **សប្បតិស្សោ** បានដល់ គួរកោតក្រែង ។ បទថា **និព្វុតោ** បានដល់ ដែលបានទទួលការទូន្មានហើយ ឬប្រាកដហើយ ។ បទថា **តតិយេ ផលេ** ជានិមិត្តសត្តមី សេចក្តីថា ជាអ្នកស្ងប់ហើយ ព្រោះហេតុសម្រេចអរិយផលទី ៣ ។ បទថា **អានាយ** បានដល់ នាំយក ។ បទថា **វត្តាវត្តេសុ** បានដល់ ក្នុងវត្តតូច និងវត្តធំ ។ បទថា **កោវិទោ** បានដល់ ឈ្លាស ក្នុងការញុំាងវត្តទាំងនោះឲ្យបរិបូណ៌ ។ ដោយបទថា **ន ក្វចិ បរិហាយាមិ** ទ្រង់សម្តែងថា តថាគតមិនវិនាសក្នុងទីណាមួយឡើយ សូម្បីតែក្នុងសីល ឬសមាធិសមាបត្តិជាដើមណាមួយ ឈ្មោះថា ការវិនាសរបស់តថាគតក្នុងគុណទាំងពួង មិន

មានឡើយ ។ បាឋៈថា **ន កោចិ បរិហាយាមិ** ដូច្នេះក៏មាន ។ សេចក្តីក៏យ៉ាងនោះដូចគ្នា ។

បទថា **យាវតា** នោះ ជាពាក្យសម្តែងកំណត់នូវបរិច្ឆេទ សេចក្តីថា មានប្រមាណត្រឹមណា ។ បទថា **ពុទ្ធភណិតំ** បានដល់ ព្រះពុទ្ធវចនៈ ។ បទថា **សោភយឹ** បានដល់ ឲ្យស្អាតហើយ ឲ្យជាក់ច្បាស់ហើយ ។ បទថា **មម អច្ឆរិយំ** សេចក្តីថា ព្រះមានព្រះភាគកស្សបៈទ្រង់ឃើញសម្មាបដិបត្តិរបស់តថាគតមិនទូទៅដល់អ្នកដទៃ គួរអស្ចារ្យមិនធ្លាប់មាន ។ បទថា **សំសរិត្វា** បានដល់ អន្ទោលទៅក្នុងសង្សារវដ្ត ។ បទថា **អនាចរំ** បានដល់ អនាចារដែលមិនគប្បីធ្វើ មិនគួរធ្វើ ។

ព្រះមានព្រះភាគកស្សបៈអង្គនោះ ទ្រង់មាននគរកំណើតឈ្មោះពារាណសី បិតាជាព្រាហ្មណ៍ឈ្មោះព្រហ្មទត្តៈ មាតាជាព្រាហ្មណីឈ្មោះធនវតី មានគូអគ្គសាវកឈ្មោះតិស្សៈ ១ ភារទ្វាជៈ ១ មានពុទ្ធុបដ្ឋាកឈ្មោះសព្វមិត្ត គូនៃអគ្គសាវិកាឈ្មោះអនុឡា ១ ឧរុវេឡា ១ ពោធិព្រឹក្សឈ្មោះនិគ្រោធ ព្រះសរីរៈកម្ពស់ ២០ ហត្ថ ព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ភរិយាឈ្មោះសុនន្ទា បុត្តឈ្មោះវិជិតសេន ចេញអភិនេស្ក្រមណ៍ដោយយាន គឺប្រាសាទ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

នគរ ឈ្មោះពារាណសី ក្សត្រ ព្រះនាមកិកី ត្រកូលធំរបស់ព្រះ
សមុទ្ទ នៅក្នុងនគរនោះ ព្រះពុទ្ធព្រះនាមកស្សបៈ ទ្រង់ស្វែងរក
គុណដ៏ធំ មានព្រហ្មទត្តព្រាហ្មណ៍ជាព្រះបិតា ព្រះមាតាព្រះនាម

ធនវតី ។ ព្រះថេរៈឈ្មោះតិស្សៈ ១ ភារទ្វាជៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះសព្វមិត្តជាឧបដ្ឋាក របស់ព្រះសម្ពុទ្ធ ព្រះនាម កស្សបៈ ស្វែងរកគុណដ៏ធំ ។ ព្រះថេរីឈ្មោះអនុលា ១ ឧរុវេលា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានជោគ នោះ ហៅថា និគ្រោធព្រឹក្ស ( ដើមជ្រៃ ) ។ ព្រះសម្ពុទ្ធនោះ មានកម្ពស់ ២០ ហត្ថ ដូចជាធ្នូតនៃផ្លេកបន្ទោរព្ធដ៏អាកាស ឬដូច ជាព្រះចន្ទ ដែលផ្កាយចោមរោមហើយ ។ ព្រះមហេសីអង្គនោះ មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ព្រះអង្គស្ថិតនៅត្រឹមនោះ ទ្រង់ញ៉ាំង ប្រជុំជនដ៏ច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ ព្រះអង្គនិម្មិតស្រះ គឺ ព្រះសទ្ធម្ម ទ្រង់ប្រទានគ្រឿងលាប គឺសីល ទ្រង់ញ៉ាំងសត្វឲ្យ ស្លៀកសំពត់ គឺព្រះធម៌ ទ្រង់ចែកកម្រងផ្កា គឺព្រះធម៌ ទ្រង់តម្កល់ ទុកកញ្ចក់ មិនមានមន្ទិល គឺព្រះសទ្ធម្មចំពោះពួកមហាជនថា ពួក ជនណាមួយ កាលប្រាថ្នានិព្វាន ចូរមិលមើលគ្រឿងប្រដាប់ របស់តថាគតចុះ ។ ព្រះសម្ពុទ្ធនោះ ឲ្យអាវ គឺសីល ឲ្យស្បែក ក្រោះ គឺឈាន ឲ្យដណ្តប់ស្បែក គឺព្រះធម៌ ឲ្យកាំបិតស្នៀតដ៏ ឧត្តម គឺព្យាយាម ។ ឲ្យខែល គឺសតិ ឲ្យកាំបិត គឺញាណដ៏មុត ឲ្យព្រះខ័នដ៏ប្រសើរ គឺធម៌ ឲ្យប្រដាប់សម្រាប់ញាំញីសត្រូវ គឺ សីល ។ ឲ្យគ្រឿងស្អិតស្អាង គឺវិជ្ជា ៣ ឲ្យគ្រឿងពាក់ត្រចៀក គឺផល ៤ ឲ្យគ្រឿងអាភរណៈ គឺអភិញ្ញា ៦ ឲ្យគ្រឿងប្រដាប់

ជាវិការនៃផ្កា គឺព្រះសទ្ធម្ម ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ឲ្យធត្រស គឺព្រះសទ្ធម្មជាគ្រឿងឃាត់នូវបាប និម្មិតនូវផ្កា មិនមានភ័យហើយ ទើបបរិនិព្វាន ។ ព្រះសម្មាសម្ពុទ្ធអង្គនុ៎ះ ប្រមាណមិនបាន បុគ្គលគ្របសង្កត់បានដោយកម្រ ព្រះធម្មរតនៈនុ៎ះ ដែលព្រះអង្គសម្តែងហើយដោយប្រពៃ ជាធម៌គួរហៅអ្នកផងឲ្យចូលមកមើលបាន ។ ព្រះសង្ឃរតនៈនុ៎ះ លោកប្រតិបត្តិហើយដោយប្រពៃ ជាព្រះសង្ឃដ៏ប្រសើរ របស់ទាំងនេះ វិនាសសោះសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិជ្ជុលដ្ឋីវ** បានដល់ ដូចផ្លេបន្ទោរដែលតាំងនៅដោយជារបស់ក្រាស់ ។ បទថា **ចន្ទោវ គហាប្ចុរិតោ** បានដល់ ដូចព្រះចន្ទពេញវង់ ដែលបាំងឆត្រហើយ ។ បទថា **ធម្មតឡាកំ មាបយិត្វា** បានដល់ ទ្រង់សាងស្រះ គឺព្រះបរិយត្តិធម៌ ។ បទថា **សីលំ ឧត្វា វិលេបនំ** បានដល់ ប្រទានគ្រឿងលាប ដើម្បីប្រដាប់សន្តិនៃចិត្ត ពោល គឺចតុប្បារិសុទ្ធិសីល ។ បទថា **ធម្មឧស្សំ និវាសេត្វា** បានដល់ ស្លៀកគូសំពត់ពោល គឺធម៌ បានដល់ ហិរិ និងឱត្តប្បៈ ។ បទថា **ធម្មមាលំ វិភជ្ជិយ** បានដល់ ចែក គឺបើកកម្រងមាល័យ គឺពោធិបក្ខិយធម៌ ៣៧ ប្រការ ។

បទថា **ធម្មវិមលមាធាសំ** សេចក្តីថា ដាក់កញ្ចក់ ពោល គឺសោតាបត្តិមគ្គ ដែលឥតមន្ទិល គឺកញ្ចក់ធម៌ ក្បែរមាត់ស្រះធម៌ សម្រាប់មហាជន ដើម្បីកំណត់ធម៌ដែលមានទោស និងធម៌ដែលមិនមានទោស ដែលជាកុសល

និងអកុសល ។ បទថា **មហាជនេ** គឺ **មហាជនស្ស** ( ដល់មហាជន ) ។ បទថា **កេចិ** គឺ **យេកេចិ។** បទថា **និព្វានំ បត្ថេន្តា** សេចក្ដីថា ត្រាច់ប្រាថ្នាព្រះនិព្វាន ដែលធ្វើនូវសេចក្ដីលំបាកដល់មនុស្ស គឺអកុសលទាំងមូល ដែលមិនស្លាប់ បច្ច័យតាក់តែងមិនបាន មិនមានទុក្ខ ស្ងប់ក្រៃលែង មានការមិនចុតិជាកិច្ច ជនទាំងនោះ ចូរមើលគ្រឿងប្រដាប់នេះ មានប្រការដូចពោលហើយ ដែលតថាគតសម្ដែងហើយ ។ បាឋៈថា **និព្វានមភិបត្ថេន្តា បស្សន្តុ មំ អលង្កតំ** ដូច្នេះក៏មាន ។ សេចក្ដីក៏យ៉ាងនោះ ដូចគ្នា ។ បទថា **អលង្កតំ** លោកពោលជាវេស្ស: ។

បទថា **សីលកញ្ចុកំ ឧត្តមំ** បានដល់ ប្រទានអាវដែលសម្រេចដោយសីល ៥ សីល ១០ និងចតុប្បារិសុទ្ធិសីល ។ បទថា **ឈានកវចវម្មិតំ** បានដល់ គ្រឿងចង គឺក្រោះ បានដល់ ចតុក្កជ្ឈាន និងបញ្ចកជ្ឈាន ។ បទថា **ធម្មចម្មំ ធារុបិត្វា** បានដល់ ដណ្ដប់នូវស្បែក គឺធម៌ដែលរាប់ថា ជាសតិសម្បជញ្ញ: ។ បទថា **ឧត្វា សន្នាហមុត្តមំ** សេចក្ដីថា ប្រទានគ្រឿងចង គឺវិរិយ: ដែលប្រកបដោយអង្គ ៤ ដ៏ឧត្តម ។ បទថា **សតិផលកំ ឧត្តមំ** បានដល់ ប្រទានគ្រឿងការពារ គឺខែល បានដល់ សតិប្បដ្ឋាន ៤ ដើម្បីការពារទោសសត្រូវ និងបាប មានរាគ:ជាដើម ។ បទថា **តិខិណំ ញាណកុន្តិមំ** បានដល់ លំពែង គឺវិបស្សនាញាណដ៏មុត គឺលំពែងដ៏មុតយ៉ាងល្អ គឺវិបស្សនាញាណ ដែលអាចចាក់ធ្លុះបាន ឬសេចក្ដីថា ទ្រង់តាំងអ្នកចម្បាំង គឺព្រះយោគាវចរដែលអាចធ្វើការកម្ចាត់កម្លាំងនៃកិលេសបាន ។

បទថា **ធម្មខគ្គវរំ ឧត្វា** បានដល់ ប្រទានព្រះខ័នយ៉ាងល្អ គឺមគ្គប្បញ្ញា ដែលមានមុខសំលៀងដោយត្រូវបកឧប្បល គឺសេចក្តីព្យាយាម ដល់ព្រះយោគាវចរនោះ ។ បទថា **សីលសំសគ្គមទ្ទនំ** សេចក្តីថា លោកុត្តរសីល ដែលជាអរិយៈ ដើម្បីញាំញីការប្រឡូកប្រឡំដោយកិលេស គឺដើម្បីសម្លាប់កិលេស ។

បទថា **តេវិជ្ជាភូសនំ ឧត្វា** បានដល់ ប្រទានគ្រឿងប្រដាប់សម្រេចដោយវិជ្ជា ៣ ។ បទថា **អាវេឡំ ចតុរោ ផលេ** បានដល់ ធ្វើផល ៤ ឲ្យជាកម្រងមាល័យសម្រាប់ពាក់ត្រង់ក ។ បទថា **ឆឡភិញ្ញាភរណំ** បានដល់ ប្រទានអភិញ្ញា ៦ ដើម្បីជាអាភរណៈ និងដើម្បីធ្វើការប្រដាប់ ។ បទថា **ធម្មបុប្ផបិលន្ធនំ** បានដល់ នាំនូវកម្រងផ្កា ពោល គឺលោកុត្តរធម៌ ៩ ។ បទថា **សទ្ធម្មបណ្ឌរច្ឆត្តំ ឧត្វា ទាបនិវារណំ** បានដល់ ប្រទានស្វេតច្ឆត្រ គឺវិមុត្តិដ៏បរិសុទ្ធដោយឥតសេសសល់ ជាគ្រឿងការពារកម្តៅ គឺអកុសលទាំងពួង ។ បទថា **មាបយិត្វាភយំ បុប្ផំ** សេចក្តីថា ធ្វើនូវផ្កា គឺមគ្គមានអង្គ ៨ ដែលឲ្យដល់នូវនគរ ដែលមិនមានភ័យ ។

បានឮថា ព្រះមានព្រះភាគកស្សបៈ រម្ងត់ខន្ធបរិនិព្វាន ក្នុងសេតព្យ-ឧទ្យាន ក្បែរសេតព្យនគរ ដែនកាសី បានឮថា ព្រះបរមសារីរិកធាតុរបស់ព្រះអង្គមិនខ្ចាត់ខ្ចាយទៅឡើយ មនុស្សក្នុងជម្ពូទ្វីប កាលសាងប្រើឥដ្ឋមួយដុំៗ ជាឥដ្ឋមាស មានតម្លៃ ១ កោដិ ប្រដាប់ដោយរតនៈសម្រាប់កខាងក្រៅ ប្រើឥដ្ឋមួយដុំៗ ដែលមានតម្លៃកន្លះកោដិ សម្រាប់កខាងក្នុង ប្រើមនោសិលាជំនួសដី ប្រើប្រេងជំនួសទឹក នាំគ្នាសាងជាព្រះស្តូបកម្ពស់មួយយោជន៍ ។

ព្រះមានព្រះភាគកស្សបៈ ទ្រង់ធ្វើកិច្ចស្រេចហើយ ទ្រង់ធ្វើ
ប្រយោជន៍ដល់សព្វសត្វតែម្យ៉ាង ទ្រង់ធ្វើនូវការត្រេកអរដល់
លោក គង់នៅជាប្រចាំ ក្នុងមិគទាយវ័ន នគរពារាណសី
ដែនកាសីនោះឯង ដូច្នេះ ។

ក្នុងគាថាដ៏សេសគ្រប់អន្ទី មានន័យជាក់ច្បាស់ហើយនោះឯង ។

## អដ្ឋកថាកស្សបពុទ្ធវង្សទី ២៤ ចប់

# សុត្តន្តបិដក

## គោតមពុទ្ធវង្សទី ២៥

[ ២៦ ] ក្នុងកាលឥឡូវនេះ តថាគតជាព្រះសម្ពុទ្ធព្រះនាមគោតម ចម្រើនក្នុងត្រកូលសក្យ តាំងព្យាយាមដល់សម្ពោធិញ្ញាណឧត្តម ។ តថាគតមានចិត្តស្ងប់រម្ងាប់ ត្រូវព្រហ្មអារាធនាហើយ ក៏ញុំាង ធម្មចក្កឲ្យប្រព្រឹត្តទៅ ពួកបរិស័ទ ១៨ កោដិ បានត្រាស់ដឹង គ្រាដំបូង ។ លំដាប់តទៅ កាលតថាគត សម្តែងធម៌ដទៃទៀត ក្នុងការប្រជុំនៃពួកមនុស្ស និងទេវតា ការត្រាស់ដឹងគ្រាទី ២ គេ មិនគប្បីពោលដោយការរាប់បានឡើយ ។ ឥឡូវនេះ តថាគតបាន ទូន្មានកូនរបស់តថាគតក្នុងទីនេះ ការត្រាស់ដឹងគ្រាទី ៣ បុគ្គល មិនគប្បីពោលដោយការរាប់បានឡើយ ។ ការប្រជុំសាវ័ករបស់ តថាគត អ្នកស្វែងរកគុណដ៏ប្រសើរ មានតែមួយដង គឺប្រជុំពួក ភិក្ខុ ១២៥០ របស់តថាគត ។ តថាគតរុងរឿង មិនមានមន្ទិល ទៅក្នុងកណ្តាលនៃសង្ឃ ឲ្យសេចក្តីប្រាថ្នាទាំងពួង គឺបុគ្គលប្រាថ្នា ហើយ ដូចជាកែវមណី ដែលអាចឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់ យ៉ាង ។ តថាគតប្រកាសសច្ចៈទាំង ៤ ដើម្បីអនុគ្រោះដល់ពួក សត្វ ដែលប្រាថ្នានូវផល លះបង់នូវតណ្ហៈក្នុងភព ។ មានពួកសត្វ ២ សែន បានត្រាស់ដឹងធម៌ ការត្រាស់ដឹងរបស់បុគ្គលមួយនាក់ ឬក៏ ២ នាក់ គេមិនអាចរាប់បានឡើយ ។ សម័យនេះ សាសនា នៃតថាគត ជាសក្យមុនី បានផ្សាយទៅ ជាសាសនាដែលទេវតា

និងមនុស្សដ៏ច្រើន ជាសាសនាស្តុកស្តម្ភមាំមួន រីកសាយភាយ តថាគតបានពិសោធហើយ ដោយប្រពៃ ។ ពួកភិក្ខុជាច្រើនរយ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្ត តម្កល់មាំគ្រប់រូប តែងតែចោមរោមតថាគត សព្វៗ កាល ។ ក្នុង កាលឥឡូវនេះឯង ពួកភិក្ខុណា លះបង់ភពជារបស់មនុស្ស តែ ភិក្ខុទាំងនោះ មិនទាន់បានអរហត្តផល នៅជាសេក្ខបុគ្គល ពួកភិក្ខុ ទាំងនោះ ត្រូវអ្នកប្រាជ្ញតិះដៀលបាន ។ នរជនទាំងឡាយ កាល សរសើរផ្លូវដ៏ប្រសើរ ( អដ្ឋង្គិមគ្គ ) ត្រេកអរក្នុងធម៌សព្វកាល មានសេចក្តីរុងរឿង អន្ទោលទៅក្នុងសង្សារ នឹងបានត្រាស់ដឹង ។ នគររបស់តថាគត ឈ្មោះកបិលពស្តុ ស្តេចជាព្រះបិតាព្រះនាម សុទ្ធោទនៈ ព្រះមាតាបង្កើតរបស់តថាគត ព្រះនាមមាយាទេវី ។ តថាគតនៅគ្រប់គ្រងព្រះដំណាក់ អស់ ២៩ ឆ្នាំ មានប្រាសាទ ដ៏ប្រសើរ ៣ គឺសុចន្ទប្រាសាទ ១ កោកនុទប្រាសាទ ១ កោញ្ចប្រាសាទ ១ ។ មាននារី ៤ ម៉ឺននាក់ មានខ្លួនប្រដាប់ សមរម្យ នារីជាអគ្គមហេសី ព្រះនាមយសោធរា ព្រះរាជបុត្ត ព្រះនាមរាហុល ។ តថាគតឃើញនិមិត្ត ៤ យ៉ាងហើយ ក៏ចេញ ទៅដោយយានសេះ ប្រព្រឹត្តព្យាយាម ធ្វើទុក្ករកិរិយា អស់ ៦ វស្សា ។ តថាគតជាព្រះជិនស្រី បានញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងព្រៃឥសិបតនៈ ទៀបក្រុងពារាណសី តថាគតជាគោតម-

សមុទ្ទ ជាទីពឹងនៃសត្វទាំងពួង ។ ភិក្ខុ ២ រូប ឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះអានន្ទជាឧបដ្ឋាក អ្នកបម្រើផ្ទាល់របស់តថាគត ។ ភិក្ខុនីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអគ្គសាវិកា ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា តថាគតបានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ទៀបគល់អស្សត្ថព្រឹក្ស ។ តថាគតមានរស្មីមួយព្យាម សព្វៗ កាល មានកម្ពស់ ១៦ ហត្ថ ក្នុងកាលឥឡូវនេះ តថាគតមានអាយុតិចបានតែ ១០០ ឆ្នាំ ។ តថាគតកាលស្ថិតនៅអស់កាលត្រឹមនោះ បានញុំាងប្រជុំជនដ៏ច្រើន ឲ្យឆ្លងចាកសង្សារ ហើយតម្កល់ទុកគប់ភ្លើង គឺធម៌ ដើម្បីញុំាងជនខាងក្រោយឲ្យបានត្រាស់ដឹងផង ។ មិនយូរប៉ុន្មានទេ តថាគត ព្រមទាំងសង្ឃជាសាវក នឹងនិព្វានក្នុងទីនេះ ដូចជាភ្លើងរលត់ ព្រោះអស់អាហារ គឺឧស ។ អគ្គសាវកទាំងគូនេះឯង មានតេជៈប្រឹងពុំបានផង មានយស និងកម្លាំងឫទ្ធិផង តថាគតមានរាងកាយ ទ្រទ្រង់នូវគុណ វិចិត្រដោយលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ រស្មី ៦ ពណ៌ ភ្លឺទៅក្នុងទិសទាំង ១០ ដូចព្រះអាទិត្យ របស់ទាំងអស់នេះ នឹងវិនាសសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ។

**គោតមពុទ្ធវង្សទី ២៥ ចប់**

# អដ្ឋកថា
# គោតមពុទ្ធវង្សទី ២៥

## ទូរេនិទានកថា

*ព្រោះហេតុដែលលំដាប់ពណ៌នាវង្ស របស់ព្រះសម្ពុទ្ធនៃយើង ហើយ ហេតុនោះ ឥឡូវនេះ នឹងពណ៌នាវង្សព្រះពុទ្ធនៃយើង ដូចតទៅនេះ*

*ក្នុងទូរេនិទាននោះ ព្រះពោធិសត្វនៃយើងធ្វើអភិការក្នុងសម្នាក់របស់ព្រះពុទ្ធ ២៤ អង្គ មានព្រះពុទ្ធទីបង្ករជាដើម អស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប លុះក្រោយសម័យព្រះកស្សបទសពលទៅ មិនមានព្រះពុទ្ធអង្គដទៃ វៀរលែងតែព្រះសម្មាសម្ពុទ្ធនៃយើងនេះ ហេតុនោះ ព្រះពោធិសត្វបានព្យាករក្នុងសម្នាក់របស់ព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះពុទ្ធទីបង្ករជាដើម ព្រះពោធិសត្វនោះ បានសមោធានធម៌ ៨ ប្រការទាំងនេះ*

*អភិនីហារ រមែងសម្រេច ព្រោះសមោធានធម៌ ៨ ប្រការ គឺ* **មនុស្សត្តំ** *ភាពជាមនុស្ស ១* **លិង្គសម្បត្តិ** *ភាពជាបុរស ១* **ហេតុ** *មានឧបនិស្ស័យអាចសម្រេចអរហត្តបាន ១* **សត្ថារទស្សនំ** *បានជួបព្រះសាស្តា ១* **បព្វជ្ជា** *បានបួសជាតាបស ឬភិក្ខុ ១* **គុណសម្បត្តិ** *បាននូវសមាបត្តិ ៨ និង*

អភិញ្ញាប្រាំ ១ **អធិការោ** អាចលះបង់ជីវិតដល់ព្រះពុទ្ធ ១ **ឆន្ទតា** មានឆន្ទៈ ១ ដូច្នេះ ។

ព្រះពោធិសត្វនៃយើង ធ្វើអភិនីហារទៀបបាទាព្រះពុទ្ធទីបង្ករ ហើយធ្វើឧស្សាហៈថា បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយពីខាងនេះពីខាងនោះ ហើយបានឃើញពុទ្ធការកធម៌ មានទានបារមីជាដើមពួកណាថា កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូង ទើបបានបំពេញបារមីទាំងនោះ រហូតមកដល់អត្តភាពជាព្រះវេស្សន្តរ កាលមកដល់ ក៏មកជួបអានិសង្ស ដែលលោកសរសើរសម្រាប់ព្រះពោធិ-សត្វទាំងឡាយ ដែលធ្វើអភិនីហារហើយថា

និយតពោធិសត្វទាំងឡាយ ដល់ព្រមដោយអង្គគ្រប់យ៉ាង ជាអ្នកទៀងចំពោះពោធិញ្ញាណ សូម្បីអន្ទោលទៅ អស់កាលយូរ រាប់រយកោដិកប្ប ក៏មិនកើតក្នុងអវិចី និងក្នុងលោកន្តរិកនរក មិនកើតជានិជ្ឈាមតណ្ហិកប្រេត ខុប្បិបាសិកប្រេត កាលកញ្ជិកាសុរ សូម្បីចូលដល់ទុគ្គតិ ក៏មិនកើតជាសត្វតូចៗ បើកើតក្នុងមនុស្សក៏មិនខ្វាក់អំពីកំណើត ត្រចៀក ក៏មិនថ្លង់ មិនគ មិនជាស្ត្រី មិនជាមនុស្សភេទ ២ មិនជាខ្ទើយ ដូច្នេះ ។ និយតពោធិសត្វ ជាបុគ្គលមិនជាប់ជំពាក់ ដូចពោលហើយ ជាអ្នកផុតចាកអនន្តរិយកម្ម មានគោចរបរិសុទ្ធ ក្នុងភពទាំងពួង មិនសេពមិច្ឆាទិដ្ឋិ មានការយល់ឃើញថា កម្មដែលធ្វើ

មានផល សូម្បីកើតក្នុងស្ថានសួគ៌ទាំងឡាយ ក៏មិនកើតក្នុង
អសញ្ញីភព ទាំងមិនមែនជាហេតុ ដែលទៅកើតក្នុងជាន់
សុទ្ធាវាស ជាអ្នកបង្អោនទៅក្នុងនេក្ខម្មៈ ជាសប្បុរស មិន
ជាប់ជំពាក់ក្នុងភពតូចភពធំ បំពេញតែលោកត្ថចរិយាទាំង
ឡាយ បំពេញបារមីទាំងពួង ដូច្នេះ ។

កាលមកជួបអានិសង្សយ៉ាងនេះ ក៏តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ធ្វើបុណ្យធំក្រៃលែង ធ្វើមហាប្រឹថពីឲ្យញាប់ញ័រ ដូចលោកពោលថា

ប្រឹថពីមិនមានចេតនាទេ មិនដឹងសុខ និងទុក្ខទេ តែមហា-
ប្រឹថពីនោះ បានកម្រើកញាប់ញ័រអស់វារៈ ៧ ដង ព្រោះ
កម្លាំងទានរបស់តថាគត ដូច្នេះ ។

ចុងក្រោយនៃអាយុ ក៏ចុតិចាកអត្តភាពនោះ
កើតក្នុងស្ថានសួគ៌ជាន់តុសិត ។

# អវិទូរេនិទានកថា

កាលព្រះពោធិសត្វកំពុងនៅក្នុងស្ថានតុសិត ឈ្មោះថា ពុទ្ធកោលាហល ក៏កើតឡើង ។ ពិតហើយ កោលាហលក្នុងលោក មាន ៣ យ៉ាង គឺកប្ប-កោលាហល ១ ពុទ្ធកោលាហល ១ ចក្កវត្តិកោលាហល ១ ។ បណ្ដាកោលាហលទាំង ៣ នោះ ពួកទេវតាជាន់កាមាវចរ ឈ្មោះលោកព្យូហៈ បានដឹងថា កន្លងទៅមួយសែនឆ្នាំ កប្បនឹងវិនាស ដូច្នេះ ក៏រំសាយសក់យំ យកដៃជូតទឹកភ្នែក ស្លៀកសំពត់ពណ៌ក្រហម កាន់ឡាខ្លួនប្លែកៗ ក្រៃលែង ត្រាច់ទៅក្នុងទឹកដីមនុស្ស ពោលថា អ្នកនិទ៌ុក្ខទាំងឡាយ អ្នកនិទ៌ុក្ខទាំងឡាយ កន្លងទៅមួយសែនឆ្នាំ រាប់អំពីថ្ងៃនេះទៅ កប្បនឹងតាំងឡើង លោកនេះនឹងវិនាស មហាសមុទ្រក៏រីងស្ងួត មហាប្រឹថពីនេះ និងស្ដេចភ្នំសិនេរុ នឹងឆេះវិនាសទៅ សេចក្ដីវិនាសនឹងមានដល់ព្រហ្មលោក នែអ្នកនិទ៌ុក្ខ ចូរពួកអ្នកចម្រើនមេត្តា ករុណា មុទិតា ឧបេក្ខា ចូរបម្រើមាតាបិតា ចូរកោតក្រែងរៀមច្បងក្នុងត្រកូល ដូច្នេះ នេះ ឈ្មោះថា **កប្បកោលាហល** ។

ឯលោកបាលទេវតាដឹងថា កន្លងទៅ ១០០០ ឆ្នាំ ព្រះសព្វញ្ញុពុទ្ធនឹងកើតឡើងក្នុងលោក ទើបត្រាច់ទៅឃោសនាថា នែលោកនិទ៌ុក្ខ ចាប់ពីនេះទៅ ១០០០ ឆ្នាំ ព្រះពុទ្ធនឹងកើតឡើងក្នុងលោក ដូច្នេះ នេះ ឈ្មោះថា **ពុទ្ធកោលាហល** ។

ពួកទេវតាដឹងថា កន្លងទៅ ១០០ ឆ្នាំ ស្ដេចចក្កពត្តិនឹងកើតឡើង ទើបត្រាច់ទៅប្រកាសថា នែលោកនិទ៌ុក្ខ រាប់ពីនេះកន្លងទៅ ១០០ ឆ្នាំ ស្ដេចចក្កពត្តិនឹងកើតឡើង នេះ ឈ្មោះថា **ចក្កពត្តិកោលាហល** ។

បណ្ដាកោលាហល ៣ នោះ ទេវតាម៉ឺនចក្កវាឡ ស្ដាប់សំឡេង គឺ ដំណឹងពុទ្ធកោលាហល ក៏ប្រជុំគ្នា ដឹងថា សត្វឈ្មោះនោះនឹងបានត្រាស់ ជាព្រះពុទ្ធ ក៏ចូលទៅអារាធនា តែកាលអារាធនា ក៏អារាធនាកាលបុព្វ-និមិត្តរបស់សត្វនោះកើតឡើង ។ ក្នុងកាលនោះ ទេវតាទាំងអស់ក្នុងចក្កវាឡ នីមួយៗ ក៏មកប្រជុំគ្នាក្នុងចក្កវាឡមួយ មួយអន្លើដោយមហារាជទាំង ៤ និងសក្កៈ ស្ដេចសុយាម ស្ដេចសន្តុសិត ស្ដេចសុនិម្មិត ស្ដេចវសវត្តី និង មហាព្រហ្ម នាំគ្នាទៅកាន់សម្នាក់ព្រះពោធិសត្វ ដែលមាននិមិត្តនៃចុតិកើត ហើយ ក្នុងតុសិតភព នាំគ្នាអារាធនាថា បពិត្រលោកនិទ្ទុក្ខ បារមី ១០ លោកបំពេញហើយ កាលបំពេញ លោកមិនមែនបំពេញប្រាថ្នាសម្បត្តិសក្កៈ សម្បត្តិព្រហ្មជាដើម តែលោកបំពេញ ប្រាថ្នាសព្វញ្ញុតញ្ញាណ ដើម្បីស្រោច ស្រង់សត្វ ដើម្បីបានត្រាស់ជាព្រះពុទ្ធ ។

បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ គួរដល់ព្រះអង្គ
ហើយ សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្ស-
លោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន
ឈ្មោះអមតៈ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វកាលទេវតាទូលអារាធនាយ៉ាងនេះ មិនបាន ប្រទានបដិញ្ញាដល់ទេវតាទាំងឡាយ តែទ្រង់ពិចារណាមហាវិលោកនៈ ៥ គឺ កាល ទ្វីប ប្រទេស ត្រកូល ប្រមាណព្រះជន្មាយុរបស់ព្រះជននី ។ បណ្ដា មហាវិលោកនៈ ៥ នោះ ព្រះមហាបុរសទ្រង់ពិចារណាកាល ជាលំដាប់

ដំបូងថា ជាកាលសមគួរឬហ្ន៎ ។ ក្នុងពាក្យថា **កាល** នោះ កាលដែលអាយុមនុស្សចម្រើនឡើងច្រើនជាងមួយសែនឆ្នាំ ជាកាលមិនសមគួរ ព្រោះហេតុអ្វី ព្រោះថា ក្នុងកាលនោះ ជាតិ ជរា មរណៈ មិនប្រាកដដល់សត្វទាំងឡាយ ហើយព្រះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយ មិនផុតចាកត្រៃលក្ខណ៍ កាលព្រះពុទ្ធត្រាស់ថា **អនិច្ចំ ទុក្ខំ អនត្តា** សត្វទាំងឡាយរមែងមិនសម្គាល់ព្រះពុទ្ធតម្រាស់ដែលគួរស្តាប់ ដែលគួរកាន់យកថា ព្រះពុទ្ធទាំងឡាយកំពុងត្រាស់រឿងអ្វីហ្ន៎ ។ បន្ទាប់អំពីនោះ ការត្រាស់ដឹងធម៌ ក៏មិនមាន កាលការត្រាស់ដឹងធម៌មិនមាន ពាក្យប្រៀនប្រដៅ ក៏មិនជានិយ្យានិក ព្រោះហេតុនោះ ទើបមិនជាកាលសមគួរ សូម្បីកាលមនុស្សមានអាយុតិចជាង ១០០ ឆ្នាំ ក៏មិនមែនជាកាលសមគួរ ព្រោះហេតុអ្វី ព្រោះថា ក្នុងកាលនោះ សត្វទាំងឡាយក្រាស់ដោយកិលេស ឱវាទដែលប្រទានដល់សត្វដែលមានកិលេសក្រាស់ មិនតាំងនៅក្នុងឋានៈជាឱវាទ នឹងបាត់បង់ទៅដោយរហ័ស ដូចស្នាមគំនូសដែលគូសក្នុងទឹក ព្រោះហេតុនោះ ទើបមិនមែនជាកាលដែលសមគួរ តែកាលនៃអាយុទាបជាងមួយសែនឆ្នាំ ខ្ពស់ជាង ១០០ ឆ្នាំ ឈ្មោះថា កាលសមគួរ ។ កាលនោះ ជាកាលដែលមនុស្សមនុស្សអាយុ ១០០ ឆ្នាំ ហេតុនោះ ទើបព្រះមហាសត្វឃើញកាលថា ជាកាលដែលគួរកើត ។

បន្ទាប់អំពីនោះ កាលទ្រង់ពិចារណាដល់ទ្វីប ក៏ទ្រង់ពិចារណាដល់មហាទ្វីបទាំង ៤ ព្រមទាំងទ្វីបជាបរិវារ ទ្រង់ឃើញទ្វីបថា ព្រះពុទ្ធទាំងឡាយមិនកើតក្នុងទ្វីបទាំង ៣ កើតតែក្នុងជម្ពូទ្វីបប៉ុណ្ណោះ ។

បន្ទាប់អំពីនោះ ទ្រង់ក៏ប្រមើលមើលប្រទេសថា ធម្មតាជម្ពូទ្វីប ជាទ្វីបធំ ទំហំដល់មួយម៉ឺនយោជន៍ ព្រះពុទ្ធទាំងឡាយទ្រង់កើតក្នុងទីណាហ្ន៎ ទ្រង់ក៏ឃើញមជ្ឈិមប្បទេស ទើបសម្រេចព្រះហឫទ័យថា មាននគរកបិលពស្តុ អាត្មាអញនឹងកើតក្នុងនគរនោះ ។

បន្ទាប់អំពីនោះ ទ្រង់ពិចារណាមើលត្រកូល ទ្រង់ឃើញត្រកូលថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនកើតក្នុងត្រកូលវេស្សៈ ឬត្រកូលសូទ្រៈ តែកើតក្នុងត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ ដែលសត្វលោករាប់អាន ឥឡូវនេះ ត្រកូលក្សត្រ សត្វលោករាប់អាន អញនឹងកើតក្នុងត្រកូលនោះ ព្រះបាទសុទ្ធោទនៈ ទ្រង់ជាព្រះជនករបស់អញ ។

បន្ទាប់អំពីនោះ កាលទ្រង់ពិចារណាមើលមាតា ទ្រង់ឃើញថា ធម្មតាពុទ្ធមាតា មិនមែនជាស្រីឡេះឡោះ ជាស្រីលេងសុរា តែបំពេញបារមីមកអស់ ១ សែនកប្ប មានសីលមិនដាច់មកអំពីកំណើត ព្រះទេវីព្រះនាមមហាមាយាអគ្គនេះ មានសភាពដូច្នេះ ព្រះនាងនឹងជាព្រះជននីរបស់អញ ។ ព្រះជន្មាយុរបស់ព្រះនាងប៉ុនណា ក៏ឃើញថា ១០ ខែ និង ៧ ថ្ងៃ ។

ព្រះមហាសត្វកាលពិចារណាមហាវិលោកនៈ ៥ យ៉ាងនេះដូច្នេះហើយ ទើបទ្រង់ទទួលបដិញ្ញារបស់ទេវតាទាំងឡាយថា លោកនិទុក្ខ ជាកាលសមគួរត្រាស់ដឹងជាព្រះពុទ្ធសម្រាប់ខ្ញុំ ទើបបញ្ជូនទេវតាទាំងនោះទៅដោយពាក្យថា សូមពួកលោកទៅចុះ កាលទេវតាជាន់តុសិតចោមរោមហើយ ក៏យាងចូលទៅកាន់សួននន្ទនវ័ន ក្នុងជាន់តុសិត ព្រោះថា ក្នុងទេវលោកគ្រប់ជាន់ មាន

សួនទន្ទនវ័នទាំងអស់ ។ ក្នុងសួនទន្ទនវ័នជាន់តុសិតនោះ ទេវតាទាំងឡាយធ្វើឲ្យព្រះមហាសត្វនោះរឭកដល់ឱកាស នៃកុសលកម្មដែលធ្វើអំពីកាលមុនថា លោកចុតិអំពីនេះហើយ សូមទៅកាន់សុគតិ ។ ព្រះមហាសត្វនោះ ដែលទេវតាទាំងនោះឲ្យរឭកដល់កុសលហោមរោមហើយ ក៏ត្រាច់ទៅក្នុងនន្ទនវ័ននោះ ចុតិបដិសន្ធិក្នុងព្រះឧទររបស់ព្រះនាងមហាមាយាទេវី ដោយផ្កាយនក្ខត្តខែអាសាឍ ។ ក្នុងខណៈដែលព្រះមហាបុរសបដិសន្ធិក្នុងព្រះឧទររបស់ព្រះជននី លោកធាតុមួយម៉ឺនញាប់ញ័រព្រមគ្នាក្នុងគ្រាតែមួយ បុព្វនិមិត្ត ៣២ ប្រការ ក៏ប្រាកដ ។

ទេវបុត្រ ៤ អង្គកាន់ព្រះខ័ន ធ្វើកិច្ចរក្សា ដើម្បីការពារឧបទ្រវហេតុដល់ព្រះពោធិសត្វដែលបដិសន្ធិ និងព្រះជននីរបស់ព្រះពោធិសត្វ ដោយប្រការដូច្នេះ ។ រាគចិត្តក្នុងបុរសទាំងឡាយ មិនបានកើតដល់ព្រះមាតារបស់ព្រះពោធិសត្វ ព្រះជននីនោះជួបនូវលាភដ៏ក្រៃលែង យសដ៏ក្រៃលែង មានសេចក្តីសុខ ព្រះវរកាយមិនលំបាក ព្រះជននីឃើញព្រះពោធិសត្វដែលនៅក្នុងព្រះឧទររបស់ព្រះនាង ដូចអំបោះសដែលដោតក្នុងកែវមណីថ្លា ដូច្នោះព្រោះហេតុដែលព្រះឧទរដែលព្រះពោធិសត្វនៅ ដូចគ្នានឹងបន្ទប់ចេតិយ សត្វដទៃមិនអាចនៅ ឬប្រើប្រាស់បាន ព្រោះហេតុនោះ ព្រះមាតារបស់ព្រះពោធិសត្វ កាលព្រះពោធិសត្វកើតបាន ៧ ថ្ងៃ ក៏ត្រូវសោយព្រះវិលាល័យហើយកើតក្នុងស្ថានសួគ៌ជាន់តុសិត ឯស្ត្រីដទៃៗ តាំងគភ៌ ១០ ក៏មាន ជាង ១០ ខែក៏មាន អង្គុយប្រសូតខ្លះ ដេកប្រសូតខ្លះ យ៉ាងណា ព្រះមាតារបស់

ព្រះពោធិសត្វ មិនមែនយ៉ាងនោះទេ មាតារបស់ព្រះពោធិសត្វ បរិហារគភ៌អស់ ១០ ខែ ព្រះនាងឈរប្រសូត នេះជាធម្មតារបស់មាតានៃពោធិសត្វ ។

ព្រះនាងមហាមាយាទេវី បរិហារគភ៌ព្រះពោធិសត្វអស់ ១០ ខែ ហើយមានព្រះគភ៌បរិបូណ៌ មានបំណងយាងទៅកាន់ផ្ទះព្រះញាតិ ទើបក្រាបទូលដល់ព្រះបាទសុទ្ធោទនមហារាជថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ប្រាថ្នាទៅកាន់ទេវ-ទហនគរ ព្រះរាជាទ្រង់អនុញ្ញាតហើយ ឲ្យធ្វើផ្លូវតាំងអំពីនគរកបិលភស្តុរហូតដល់ទេវទហនគរឲ្យរាបស្មើ ឲ្យប្រដាប់ដោយដើមចេក ក្អមពេញដោយទឹក ដើមស្លា ទង់ជ្វាលាជាដើម ឲ្យគង់ប្រថាប់ក្នុងវិមាស ទ្រង់បញ្ជូនទៅដោយសិរីដ៏ល្អ និងដោយបរិវារជាច្រើន ។ ក្នុងរវាងនគរទាំង ២ មានមង្គល-សាលវ័ន ឈ្មោះលុម្ពិនីដែលគួរប្រើប្រាស់របស់នគរទាំង ២ ។ មង្គល-សាលវ័ននោះ សម័យនោះ ចេញផ្ការីកស្គុសស្គាយ តាំងពីគល់ដល់ចុងព្រោះព្រះនាងឃើញព្រៃរាំងល្អដូចនន្ទនវ័នឧទ្យាន ដែលជាទីត្រេកអរនៃទេវតាដែលពួកមេឃ្មុំ និងឃ្មុំដទៃៗ កំពុងក្រេប ជាអ្នកត្រេកអរក្នុងរសផ្អែម ដែលធ្វើសេចក្តីត្រេកអរក្រៃលែង ដែលគួរត្រេកអរ ត្រេកអរដោយការស្រវឹងមានសម្បុកសេពហើយ យំរងំតាមចន្លោះមែក និងចន្លោះផ្កាទាំងឡាយ ព្រះទេវីក៏កើតចិត្តគិតនឹងលេងសួនសាលវ័ន សមដូចលោកពោលថា

ឧទ្យានលុម្ពិនី ដែលធម្មជាតិប្រដាប់ហើយ ទាញចិត្តរបស់
ជនដែលនៅក្នុងទ្វីប ពួកភមរជាតិ ដែលមានពណ៌ស្អាត
រមែងត្រេកត្រអាល មានពួកឃ្មុំហាក់បីដូចទាញយកកែវភ្នែក

របស់ជនទាំងឡាយ ហើរក្រឡឹង រមែងស្អាតជានិច្ច ដូច្នេះ ។

ពួកអមាត្យក្រាបទូលព្រះរាជាហើយ នាំព្រះរាជទេវីចូលទៅកាន់លុម្ពិនីវ័ននោះ ព្រះនាងចូលទៅកាន់គល់មង្គលសាលៈ មានបំណងនឹងចាប់មែកណារបស់មង្គលសាលព្រឹក្សនោះ ដែលមានដើមមូលត្រង់ស្មើ ប្រដាប់ដោយផ្កាផ្លែ និងស្លឹកខ្ចី មែកមង្គលសាលព្រឹក្សនោះ ក៏ទោរទន់ ទៅតាមចិត្ត បង្អោនចុះមកឯង ដល់ដៃរបស់ព្រះនាង ។ លំដាប់នោះ ព្រះនាងក៏ចាប់មែកសាលព្រឹក្សនោះ ដោយព្រះហស្តស្តាំ ដែលធ្វើនូវសេចក្តីត្រេកអរក្រៃលែងលម្អដោយកងដៃមាស មានព្រះអង្គុលីមូលដូចត្របកឈូក រុងរឿងដោយព្រះនខាដែលមានសភាពប៉ោងឡើង មានពណ៌ក្រហម ។ ព្រះទេវីប្រថាប់ឈរ ចាប់មែកសាលព្រឹក្សនោះ ព្រះនាងល្អផូរផង់ដូចព្រះចន្ទទើបរះ ត្រង់ស្រទាប់ពពកពណ៌ខៀវចាស់ រុងរឿងដូចពន្លឺអណ្តាតភ្លើង និងដូចទេវី ( ទេពធីតា ) ដែលកើតក្នុងនន្ទនវ័នឧទ្យាន ។ ក្នុងទីនោះឯង ខ្យល់កម្មជវាតរបស់ព្រះនាងក៏កម្រើក ខណៈនោះ មហាជនក៏នាំគ្នាបាំងវាំងនន ហើយចៀសចេញទៅ ។ ព្រះនាង កាលឈរប្រថាប់ចាប់មែកសាលព្រឹក្សនោះឯង ព្រះពោធិសត្វក៏ប្រសូតចាកព្រះឧទររបស់ព្រះនាង ។

ក្នុងវេលានោះឯង មហាព្រហ្មដែលមានចិត្តបរិសុទ្ធ ៤ អង្គ កាន់យកបណ្តាញមាសមកទទួលព្រះពោធិសត្វ ដាក់ព្រះពោធិសត្វខាងមុខព្រះជននីរួចត្រាស់ថា បពិត្រព្រះទេវី សូមព្រះនាងត្រេកអរចុះ ឱរសរបស់ព្រះនាងមានសក្តិធំប្រសូតហើយ ។ សត្វដទៃៗ កាលចេញចាកផ្ទៃមាតា ក៏ប្រឡាក់

ដោយរបស់បដិកូល យ៉ាងណា ព្រះពោធិសត្វមិនយ៉ាងនោះឡើយ តែព្រះពោធិសត្វ លាព្រះហស្តទាំង ២ ព្រះបាទទាំង ២ ឈរ មិនប្រឡាក់ដោយរបស់មិនស្អាតក្នុងព្រះឧទររបស់ព្រះជននី បរិសុទ្ធស្រស់ថ្លា រុងរឿង ដូចមណីរតនៈ ដែលគេដាក់លើសំពត់កាសី ចេញចាកព្រះឧទររបស់ព្រះជននីយ៉ាងបរិសុទ្ធ រុងរឿងដូចមណីរតនៈ ដែលគេដាក់លើសំពត់ដែនកាសី ។ លំដាប់នោះ ដើម្បីធ្វើសក្ការៈដល់ព្រះពោធិសត្វ និងព្រះជននីរបស់ព្រះពោធិសត្វ ធ្នារទឹក ២ ខ្សែ ក៏ធ្លាក់ចុះមកអំពីអាកាស ស្រពស្រង់ព្រះសរីរៈរបស់ព្រះពោធិសត្វ និងព្រះជននីរបស់ព្រះពោធិសត្វ ។

គ្រានោះ មហារាជទាំង ៤ ក៏យកសំពត់រោមសត្វដែលមានសម្ផស្សគួរជាទីសប្បាយ ដែលគេសន្មតថាជាមង្គល ទទួលអំពីព្រះហស្តរបស់មហាព្រហ្ម ដែលឈរទទួលព្រះពោធិសត្វនោះ ដោយបណ្តាញមាស ពួកមនុស្សក៏យកកែបដែលមានសាច់ល្អ ទទួលអំពីព្រះហស្តរបស់មហារាជទាំង ៤ នោះ ព្រះពោធិសត្វផុតចាកដៃរបស់មនុស្ស ក៏ឈរត្រង់ផែនដី សម្លឹងមើលទិសខាងកើត ចក្កវាឡច្រើនពាន់ប្រាកដដូចគ្នាជាលានតែមួយ ។ ទេវតា និងមនុស្សក្នុងទីនោះ កាលបូជាដោយកម្រងផ្កា គ្រឿងក្រអូបជាដើម ក៏នាំគ្នាក្រាបទូលថា បពិត្រមហាបុរស បុគ្គលដែលស្មើជាមួយព្រះអង្គក្នុងទីនេះមិនមាន បុគ្គលដែលក្រៃលែងជាងនឹងមកអំពីណា ។ ព្រះពោធិសត្វ ទ្រង់សម្លឹងមើលទិសទាំង ១០ មិនឃើញបុគ្គលស្មើព្រះអង្គ ទើបបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ទ្រង់យាងទៅ ៧ ជំហាន ។ កាលយាងទៅ ក៏យាងទៅលើ

ផែនដីនោះឯង មិនមែនយាងទៅក្នុងអាកាសឡើយ មិនមានសំពត់បិទបាំងយាងទៅ មិនមែនមានសំពត់យាងទៅ ជាទារកតូចយាងទៅ មិនមែនទារកអាយុ ១៦ ឆ្នាំ យាងទៅ តែប្រាកដដល់មហាជន ដូចយាងទៅក្នុងអាកាស ដូចប្រដាប់តាក់តែងព្រះអង្គ ដូចមានអាយុ ១៦ ឆ្នាំ ។ បន្ទាប់អំពីនោះ ក្នុងជំហានទី ៧ ទ្រង់ក៏ឈប់ ទ្រង់បន្លឺអាសភិវាចាថា **អគ្គោហមស្មិ លោកស្ស** ដូច្នេះជាដើម ។

ព្រះពោធិសត្វគ្រាន់តែប្រសូតចាកផ្ទៃមាតា បន្លឺវាចាបានក្នុង ៣ អត្តភាព គឺអត្តភាពជាមហោសថ ១ អត្តភាពជាព្រះវេស្សន្តរ ១ អត្តភាពចុងក្រោយនេះ ១ ។ បានឮថា ក្នុងអត្តភាពជាមហោសថ គ្រាន់តែប្រសូតចាកផ្ទៃមាតាប៉ុណ្ណោះ សក្កទេវរាជក៏យាងមក ដាក់ខ្លឹមចន្ទន៍ក្នុងព្រះហស្ត ហើយចៀសចេញទៅ ។ មហោសថកុមារនោះក្តាប់ខ្លឹមចន្ទន៍ ហើយក៏ប្រសូតមក ។ គ្រានោះ មាតាសួរមហោសថនោះថា នែកូន កូនកាន់អ្វីមក មហោសថឆ្លើយថា បពិត្រអ្នកម៉ែ ថ្នាំ ដូច្នេះ ព្រោះកាន់ឱសថមកផង ទើបមាតាបិតាដាក់ឈ្មោះថា ឱសថកុមារ ។

ឯក្នុងអត្តភាពជាព្រះវេស្សន្តរ គ្រាន់តែចេញចាកផ្ទៃព្រះមាតា ក៏លាព្រះហស្តស្តាំពោលថា បពិត្រមាតា ក្នុងផ្ទះនេះ មានទ្រព្យដែរឬ កូននឹងឲ្យទាន ។ ខណៈនោះ ព្រះមាតាយកហត្ថាព្រះឱរសដាក់ត្រង់បាតដៃព្រះនាង ហើយដាក់ថង់ទ្រព្យ ១០០០ ក្នុងដៃព្រះពោធិសត្វ ត្រាស់ថា នែបុត្ត បុត្តកើតមកក្នុងត្រកូលមានទ្រព្យហើយ ។

ក្នុងអត្តភាពនេះ ទ្រង់បន្លឺសីហនាទ ហេតុនោះ ព្រះពោធិសត្វគ្រាន់តែប្រសូតចាកផ្ទៃព្រះមាតា ទ្រង់បន្លឺវាចាក្នុង ៣ អត្តភាព ដោយប្រការដូច្នេះ ។ សូម្បីក្នុងគ្រាប្រសូត បុព្វនិមិត្ត ៣២ ប្រការ ក៏ប្រាកដដល់ព្រះអង្គ តែក្នុងសម័យណា ព្រះពោធិសត្វនៃយើងប្រសូតក្នុងលុម្ពិនីវ័ន ក្នុងសម័យនោះដូចគ្នា រាហុលមាតា អានន្ទ ឆន្ន កាឡុទាយិអមាត្យ ស្តេចសេះកណ្ឋកៈ ដើមមហាពោធិព្រឹក្ស និងកំណប់ទ្រព្យទាំង ៤ ក៏កើតជំណាលគ្នា ។ បណ្តាកំណប់ទ្រព្យទាំង ៤ នោះ កំណប់ទ្រព្យទី ១ ទំហំមួយគាវុត កំណប់ទ្រព្យទី ២ ទំហំកន្លះយោជន៍ កំណប់ទ្រព្យទី ៣ ទំហំបីគាវុត កំណប់ទ្រព្យទី ៤ ទំហំមួយយោជន៍ របស់ទាំងនេះ ឈ្មោះថា សហជាតទាំង ៧ ។

អ្នកនគរទាំង ២ នាំព្រះមហាបុរសទៅកាន់នគរកបិលពស្តុ ថ្ងៃនោះឯងពួកទេវតាក្នុងជាន់តាវត្តិង្សត្រេកអរថា ឱរសរបស់ព្រះបាទសុទ្ធោទនមហារាជក្នុងនគរកបិលពស្តុ នឹងគង់ត្រង់មណ្ឌលពោធិព្រឹក្ស បានត្រាស់ជាព្រះពុទ្ធ ទើបនាំគ្នាលើកទង់ជ្វាលាគ្រវី លេងនូវសាធុការ ។ សម័យនោះ តាបសឈ្មោះកាឡទេវលៈ ជាអ្នកបានសមាបត្តិ ៨ ជាកុលុបកៈរបស់ព្រះបាទសុទ្ធោទនៈ ឆាន់អាហារហើយ ក៏ទៅកាន់ស្ថានតាវត្តិង្ស ដើម្បីសម្រាកពេលថ្ងៃ អង្គុយសម្រាកពេលថ្ងៃក្នុងទីនោះហើយ ឃើញទេវតាទាំងនោះ ត្រេកអររីករាយ ទើបសួរថា ហេតុអ្វី ទើបពួកអ្នកត្រេកអររីករាយ លេងសាធុការចូរប្រាប់ហេតុនោះដល់អាត្មាចុះ ។ បន្ទាប់អំពីនោះ ទេវតាទាំងឡាយក៏ប្រាប់ថា លោកនិទ្ទុក្ខ ឱរសរបស់ព្រះបាទសុទ្ធោទនៈកើតហើយ ឱរសអង្គនោះ នឹង

គង់ត្រង់ពោធិមណ្ឌលដ្ឋាន ត្រាស់ជាព្រះពុទ្ធ ប្រកាសធម្មចក្ក ដោយហេតុនេះ ទើបខ្ញុំត្រេកអរចំពោះព្រះអង្គថា ពួកយើងនឹងបានឃើញពុទ្ធលីលា ដែលមិនមានទីបំផុត ។

តាបសបានស្តាប់ពាក្យរបស់ទេវតាទាំងនោះហើយ ក៏ចុះអំពីទេវលោក ដែលភ្លឺដោយរតនៈ គួរមើលក្រៃលែង ចូលទៅកាន់រាជនិវេសន៍របស់ព្រះនរបតី អង្គុយលើអាសនៈដែលគេក្រាល ទូលព្រះរាជាដែលធ្វើបដិសណ្ឋារៈថា បពិត្រមហារាជ បានឮថា ព្រះរាជឱរសរបស់មហាបពិត្រ ប្រសូតហើយ អាត្មាចង់ឃើញព្រះរាជឱរសនោះ ។ ព្រះរាជាឲ្យនាំព្រះពោធិសត្វដែលប្រដាប់តាក់តែងមក ហើយនាំចូលទៅជិត ដើម្បីឲ្យថ្វាយបង្គំតាបស ។ ព្រះបាទនៃមហាបុរសបែរជាទៅប្រតិស្ឋានលើជដារបស់តាបស ដូចផ្លេកបន្ទោរកំពុងនៅលើពពកពណ៌ខៀវចាស់ ។ ពិតហើយ បុគ្គលដទៃឈ្មោះថា ព្រះពោធិសត្វ គប្បីថ្វាយបង្គំដោយអត្តភាពនោះ មិនមាន ហេតុនោះ ទើបតាបសក្រោកចាកអាសនៈ ផ្គងអញ្ជលីចំពោះព្រះពោធិសត្វ ព្រះរាជាទ្រង់ឃើញភាពអស្ចារ្យនោះ ទ្រង់ថ្វាយបង្គំព្រះរាជឱរសរបស់ព្រះអង្គ ។ តាបសឃើញលក្ខណសម្បត្តិរបស់ព្រះពោធិសត្វ រពឹកថា បុគ្គលនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ឬមិនបានត្រាស់ជាព្រះពុទ្ធហ្ន៎ ពិចារណាទៅមុខ ដឹងបានដោយអនាគតំសញ្ញាណថា នឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ ទើបធ្វើការញញឹម ពោលថា បុរសនេះ ជាអច្ឆរិយបុរស ។

បន្ទាប់អំពីនោះ ទើបពិចារណាថា អញបានឃើញបុរសនេះត្រាស់ជា

ព្រះពុទ្ធ ឬមិនបានឃើញហ្ន៎ ដឹងថា មិនបានឃើញ ព្រោះធ្វើកាលកិរិយាក្នុងចន្លោះនេះឯង ទៅកើតក្នុងអរូបភព ដែលព្រះពុទ្ធរាប់រយអង្គ រាប់ពាន់អង្គមិនអាចទៅប្រោសឲ្យត្រាស់ដឹងបាន ហើយក៏ទ្រហោយំ ពោលថា អញមិនបានឃើញអច្ឆរិយបុរសបែបនេះត្រាស់ជាព្រះពុទ្ធ អញវិនាសធំ មនុស្សទាំងឡាយក៏សួរថា លោកម្ចាស់របស់យើងសើចអម្បាញ់មិញនេះឯង ហើយបែរជាយំ អន្តរាយណាមួយ នឹងមានដល់អយ្យបុត្តរបស់យើងឬ ។ តាបសឆ្លើយថា អន្តរាយមិនមានដល់អយ្យបុត្តទេ អយ្យបុត្តនឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ មនុស្សទាំងឡាយក៏សួរថា កាលបើដូច្នេះ ហេតុអ្វីទើបលោកយំ តាបសឆ្លើយថា អាត្មាអាសូរខ្លួនអាត្មាថា មិនបានឃើញអច្ឆរិយ-បុរសបែបនេះត្រាស់ជាព្រះពុទ្ធ អាត្មានឹងវិនាសធំ ដូច្នេះ ទើបយំ ។

បន្ទាប់អំពីនោះ ព្រះញាតិឲ្យស្រពស្រង់ព្រះសិរសារបស់ព្រះពោធិសត្វក្នុងថ្ងៃទី ៥ ប្រឹក្សាគ្នាថា នឹងថ្វាយព្រះនាម ទើបប្រោះព្រំព្រះរាជនិវេសន៍ដោយគន្ធជាតិ ៤ ប្រភេទ រោយនូវលាជជាគម្រប់ ៥ ឲ្យចម្អិនមធុបាយាសមិនផ្សំ អញ្ជើញព្រាហ្មណ៍ ១០៨ ដែលចប់ត្រៃវេទ ឲ្យអង្គុយក្នុងរាជនិវេសន៍ឲ្យបរិភោគមធុបាយាស ធ្វើសក្ការៈហើយ ឲ្យទាយព្រះលក្ខណៈថា តើនឹងបានជាអ្វី? បណ្តាព្រាហ្មណ៍ ១០៨ នោះ ព្រាហ្មណ៍ ៨ នាក់ មានរាម-ព្រាហ្មណ៍ជាដើម ជាអ្នកទាយព្រះលក្ខណៈ បណ្តាព្រាហ្មណបណ្ឌិត ៨ នាក់នោះ ព្រាហ្មណ៍ ៧ នាក់ លើកម្រាមដៃ ២ ព្យាករ ២ ផ្លូវថា បុគ្គលប្រកបដោយលក្ខណៈទាំងនេះ កាលនៅជាយរាវាសវិស័យ នឹងបានជាស្តេច

ចក្រពត្តិ បើបួសនឹងបានត្រាស់ជាព្រះពុទ្ធ បណ្តាបណ្ឌិតព្រាហ្មណ៍ទាំង ៨ នាក់នោះ ព្រាហ្មណ៍ឈ្មោះកោណ្ឌញ្ញគោត្តក្មេងជាងគេ ឃើញព្រះវរលក្ខណ-សម្បត្តិរបស់ព្រះពោធិសត្វ លើកម្រាមដៃមួយប៉ុណ្ណោះ ព្យាករដោយចំណែកមួយថា បុរសនេះ មិនមានហេតុនៅគ្រប់គ្រងឃរាវាសវិស័យឡើយ នឹងបានត្រាស់ជាព្រះពុទ្ធ ជាអ្នកមានទូវដំបូលបើកហើយ ដោយចំណែកមួយ ។ កាលនោះ ព្រះញាតិកាលកាន់យកព្រះនាមព្រះពោធិសត្វនោះ ទើបថ្វាយព្រះនាមថា សិទ្ធត្ថៈ ព្រោះទ្រង់ធ្វើនូវការសម្រេចប្រយោជន៍ដល់សត្វលោកទាំងពួង ។

កាលនោះ ព្រាហ្មណ៍ទាំងនោះត្រឡប់ដល់ផ្ទះរបស់ខ្លួនហើយ ហៅកូនទាំងឡាយមក ពោលយ៉ាងនេះថា ឪពុកចាស់ហើយ មិនដឹងថា បានរស់នៅឃើញព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនៈ សម្រេចសព្វញ្ញុតញ្ញាណដែរឬអត់ តែបើព្រះរាជឱរសអង្គនោះទ្រង់ចេញព្រះផ្នួស សម្រេចសព្វញ្ញុតញ្ញាណហើយ ចូរកូនទាំងឡាយ បួសក្នុងសាសនារបស់ព្រះអង្គចុះ ។ បន្ទាប់អំពីនោះ ព្រាហ្មណបណ្ឌិតទាំង ៧ រស់នៅដរាបដល់អស់ជីវិត ក៏ទៅតាមយថាកម្ម ។ កោណ្ឌញ្ញមាណពមិនមានរោគ ។ ក្នុងកាលនោះ ព្រះរាជាទ្រង់ស្តាប់ពាក្យព្រាហ្មណ៍ពឹទ្ធបណ្ឌិតទាំងនោះហើយ ត្រាស់សួរថា កូនរបស់យើងឃើញអ្វីទើបបួស ព្រាហ្មណ៍ទាំងនោះទូលក្រាបថា បពិត្រព្រះសម្មតិទេព ព្រោះឃើញបុព្វនិមិត្ត ៤ ។ ព្រះរាជាត្រាស់សួរថា និមិត្ត ៤ ដូចម្តេច ក៏ក្រាបទូលថា គឺមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួស ។ ព្រះរាជា

ត្រាស់ថា ចាប់តាំងពីនេះទៅ ពួកអ្នកកុំឲ្យមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួស មកក្បែរកូនរបស់យើង រួចទ្រង់តាំងការរក្សាចម្ងាយមួយគាវុត ក្នុងទិសទាំង ៤ ដើម្បីការពារមនុស្សចាស់ជាដើម កុំឲ្យមកប្រាកដក្នុងគន្លងចក្ខុព្រះរាជកុមារ ។ ថ្ងៃនោះ ព្រះញាតិវង្សានុវង្ស ៨ ម៉ឺនត្រកូលប្រជុំគ្នាក្នុងមង្គលដ្ឋាន ព្រះញាតិមួយអង្គៗ ក៏ទូលប្ដេជ្ញាថ្វាយឱរសមួយអង្គៗថា កុមារនេះ ទោះបីបានត្រាស់ជាព្រះពុទ្ធក្ដី ជាព្រះរាជាក្ដី ពួកយើងនឹងថ្វាយឱរសមួយអង្គៗ បើកុមារបានជាព្រះពុទ្ធសោត ក៏នឹងមានខត្តិយ-សមណៈចោមរោមចារិកទៅ បើជាស្ដេចចក្រពត្តិសោត នឹងមានខត្តិយកុមារតាមហែហមទៅ ។ ព្រះរាជាទ្រង់ព្រះរាជទានកីលៀង ៦៤ នាក់ ដែលប្រាសចាកទោសសព្វយ៉ាង ដល់ព្រមដោយរូបសម្បត្តិក្រៃលែងដល់ព្រះមហាបុរសព្រះពោធិសត្វទ្រង់ចម្រើនវ័យដោយបរិវារមិនមានទីបំផុត ដោយការកើតឡើងនៃសិរីយ៉ាងធំ ។

ថ្ងៃមួយ ជាថ្ងៃព្រះរាជពិធីវប្បមង្គល គឺពិធីច្រត់ព្រះនង្គ័ល ថ្ងៃនោះព្រះរាជា ទ្រង់ចេញអំពីព្រះនគរ ដោយព្រះសិរីធំក្រៃលែង មួយអន្លើដោយមហារាជបរិវារ ទ្រង់នាំព្រះរាជឱរសទៅដែរ ។ ក្នុងទីកសិកម្ម មានដើមព្រីងមួយ មានម្លប់ត្រឈឹងត្រឈៃ គួរជាទីត្រេកអរក្រៃលែង ។ ទ្រង់ឲ្យក្រាលទីបន្ទំសម្រាប់ព្រះរាជកុមារខាងក្រោមដើមព្រីងនោះ ចងពិតានដោយសំពត់ពណ៌ក្រហម ប្រដាប់ដោយផ្កាយមាសអំពីខាងលើ បាំងវាំងននបាំងមនុស្សឲ្យរក្សា ។ ព្រះរាជាទ្រង់ប្រដាប់គ្រឿងអលង្ការសព្វយ៉ាង កាលពួកអមាត្យ

ចោមរោមហើយ យាងទៅដើម្បីច្រត់ព្រះនង្គ័ល ។ ក្នុងទីកសិកម្មនោះ ព្រះរាជាទ្រង់កាន់នង្គ័លមាស ដែលជាមង្គលក្រៃលែង ពួកអមាត្យជាដើមកាន់នង្គ័លប្រាក់ ថ្ងៃនោះ ប្រកបព្រះរាជពិធីច្រត់ព្រះនង្គ័ល ១០០០ ពីលៀងអង្គុយចោមរោមព្រះពោធិសត្វ គិតថា នឹងមើលសម្បត្តិរបស់ព្រះរាជា ហើយនាំគ្នាចេញទៅខាងក្រៅវាំងនន ។

លំដាប់នោះ ព្រះពោធិសត្វទ្រង់ក្រឡេកមើលដោយជុំវិញ មិនឃើញនរណាមួយ ក៏ក្រោកឡើងដោយរហ័ស អង្គុយពត់ភ្នែន កំណត់ខ្យល់ដង្ហើមចេញចូលជាអារម្មណ៍ ញុំាងបឋមជ្ឈានឲ្យកើត ។ ពួកពីលៀងត្រាច់ទៅក្នុងវាងអាហារឃឹតយូរបន្តិច ស្រមោលនៃដើមឈើដទៃៗ ជ្រេទៅ តែស្រមោលដើមព្រីងនោះ នៅជាបរិមណ្ឌលតាំងនៅក្នុងទីនោះឯង ឯពីលៀងរបស់ព្រះពោធិសត្វនោះ គិតថា ព្រះអយ្យបុត្តនៅតែមួយអង្គឯង រូតរះមកបើកវាំងននឃើញព្រះមហាសត្វប្រថាប់គង់ពត់ភ្នែនលើទីបន្ទំដ៏មានសេរី និងឃើញបាដិហារ្យនោះ ក៏ទៅក្រាបទូលរឿងនោះដល់ព្រះរាជា ។ ព្រះរាជាប្រញាប់យាងមកឃើញបាដិហារ្យនោះ ទ្រង់ថ្វាយបង្គំព្រះរាជឱរស ត្រាស់ថា នែបា បិតាថ្វាយបង្គំបុត្ត នេះជាលើកទី ២ ។

កាលនោះ ព្រះមហាបុរសទ្រង់មានព្រះជន្មវស្សា ១៦ តាមលំដាប់ព្រះរាជាឲ្យសាងប្រាសាទ ៣ ឈ្មោះរម្មៈ ១ សុរម្មៈ ១ សុភៈ ១[១] ដល់រដូវទាំង ៣ ប្រាសាទ ៩ ជាន់មួយខ្នង ៧ ជាន់មួយខ្នង ៥ ជាន់មួយខ្នង

---

១- បិដកខ្មែរជា សុចន្ទប្រាសាទ ១ កោកនុទប្រាសាទ ១ កោញ្ចប្រាសាទ ១ ។

ដល់ព្រះពោធិសត្វ ។ ប្រាសាទទាំង ៣ ខ្នង កម្ពស់ស្មើគ្នា ផ្សេងគ្នាតែជាន់ប៉ុណ្ណោះ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា កូនរបស់អញចម្រើនវ័យហើយ អញនឹងឲ្យស្វេតច្ឆត្រដល់កូន នឹងឃើញសិរីរាជសម្បត្តិ ។ ព្រះរាជាទ្រង់បញ្ជូនសាសន៍ដល់ស្តេចសក្យៈទាំងឡាយថា កូនរបស់យើងចម្រើនវ័យហើយ យើងនឹងស្ថាបនាក្នុងសិរីរាជសម្បត្តិ ចូរស្តេចសក្យៈគ្រប់អង្គ បញ្ជូនទារិកាដែលចម្រើនវ័យហើយ ក្នុងផ្ទះរបស់ខ្លួន មកកាន់ព្រះរាជវាំងនេះ ។ ស្តេចសក្យៈទាំងអស់នោះ ស្តាប់ព្រះរាជសាសន៍របស់ព្រះរាជា ក៏នាំគ្នាពោលថា ព្រះរាជកុមារ ល្អរូបតែម្យ៉ាង មិនចេះសិប្បៈអ្វីឡើយ មិនអាចចិញ្ចឹមកិរិយាបាន ពួកយើងមិនឲ្យធីតារបស់យើង ។ ព្រះរាជាទ្រង់ស្តាប់រឿងនោះហើយ ក៏យាងទៅរកព្រះរាជឱរស ទ្រង់ប្រាប់រឿងនោះ ។ ព្រះពោធិសត្វទូលសួរថា គួរសម្តែងសិប្បៈអ្វី ។ ព្រះរាជាត្រាស់ថា នែបា គួរលើកសហស្សថាមធ្នូ ព្រះពោធិសត្វពោលថា បើយ៉ាងនោះ ចូរនាំធ្នូមក ព្រះរាជាឲ្យនាំធ្នូមកថ្វាយ ។ បុរស ១០០០ លើកធ្នូនោះឡើង បុរស ១០០០ ដាក់ចុះ ។ ព្រះមហាបុរសឲ្យនាំអាសនៈធ្នូនោះមកហើយ ប្រថាប់គង់ពត់ភ្នែន ទ្រង់ប្រើមេជើងក្តិះខ្សែធ្នូទាញមក ទ្រង់ប្រើម្រាមដៃនោះឯងលើកធ្នូឡើង ទ្រង់កាន់ដងធ្នូដោយព្រះហស្តឆ្វេង យឺតខ្សែធ្នូដោយព្រះហស្តស្តាំ ។ នគរទាំងមូល ក៏លាន់ឮខ្ទរខ្ទារកាលត្រូវសួរថា នុ៎ះជាសំឡេងអ្វី អ្នកខ្លះ ក៏ឆ្លើយថា ផ្គរលាន់ ដូច្នេះ ។ ជនខ្លះប្រាប់ថា ពួកអ្នកមិនដឹង មិនមែនផ្គរលាន់ទេ នុ៎ះជាសំឡេងខ្សែធ្នូរបស់

អង្គីរសរាជកុមារ ដែលកំពុងលើកសហស្សថាមធ្នូ ទាញខ្សែ ( បាញ់ ) ។ ស្តេចសក្យៈទាំងឡាយ ស្តាប់រឿងនោះហើយ ក៏មានចិត្តត្រេកអរដោយហេតុប៉ុណ្ណោះឯង ។

លំដាប់នោះ ព្រះមហាបុរសត្រាស់ថា គួរធ្វើអ្វីទៀត ព្រះរាជាត្រាស់ថា គួរបាញ់បន្ទះដែកកម្រាស់ ៨ ធ្នាប់ ។ ព្រះពោធិសត្វបាញ់ទម្លុះបន្ទះដែកនោះធ្លុះហើយ ត្រាស់ថា គួរធ្វើអ្វីទៀត ព្រះរាជាត្រាស់ថា គួរបាញ់ទម្លុះបន្ទះក្តារធ្នង់កម្រាស់ ៤ ធ្នាប់ ព្រះពោធិសត្វបាញ់ទម្លុះក្តារធ្នង់នោះហើយ ត្រាស់ថា គួរធ្វើអ្វីទៀត ព្រះរាជាត្រាស់ថា គួរបាញ់ទម្លុះបន្ទះក្តារល្វាកម្រាស់ ១ ចំអាម ។ ព្រះពោធិសត្វបាញ់ទម្លុះបន្ទះក្តារល្វាហើយ ត្រាស់ថា គួរធ្វើអ្វីទៀត ។

ស្តេចសក្យៈទាំងឡាយត្រាស់ថា គួរបាញ់រទេះដែលផ្ទុកខ្សាច់ ព្រះមហាសត្វបាញ់ទម្លុះរទេះផ្ទុកខ្សាច់ផង រទេះផ្ទុកចំបើងផង បាញ់ព្រួញទៅក្នុងទឹកប្រមាណ ១ ឧសភផង បាញ់លើគោកប្រមាណ ៨ ឧសភផង ។

គ្រានោះ ស្តេចសក្យៈទាំងឡាយត្រាស់នឹងព្រះពោធិសត្វថា ចូរបាញ់រោមទ្រាយដែលដាក់លើផ្លែត្រប់ខារ ។ ព្រះពោធិសត្វត្រាស់ថា បើយ៉ាងនោះ ចូរអ្នកទាំងឡាយចងផ្លែត្រប់ខារចម្ងាយប្រមាណ ១ យោជន៍ ហើយដាក់រោមទ្រាយត្រង់ផ្លែត្រប់ខារចម្ងាយប្រមាណ ១ យោជន៍ ទ្រង់បាញ់ទៅក្នុងទិសដែលបិទបាំងដោយពពក គឺបាញ់ក្នុងពេលរាត្រី ព្រួញនោះ ទម្លុះរោមទ្រាយចម្ងាយប្រមាណ ១ យោជន៍ ហើយលិចចុះក្នុងផែនដី ។ មិនមែនត្រឹមតែប៉ុណ្ណោះ ថ្ងៃនោះ ព្រះមហាបុរសទ្រង់សម្តែងសិប្បៈ ដែលសត្វលោក

ចេះគ្រប់យ៉ាង ។

សម័យនោះ ស្តេចសក្យៈទាំងឡាយប្រដាប់ធីតារបស់ខ្លួន បញ្ជូនទៅស្ត្រី ៤ ម៉ឺនបានជាស្នំ ឯរាហុលមាតា បានជាអគ្គមហេសី ។ ព្រះមហាបុរសដែលស្ត្រីកំពុងចម្រើនវ័យនៃមនុស្សចោមរោម ដូចទេវកុមារដែលស្ត្រីចម្រើនវ័យនៃទេវតាចោមរោម ដូច្នោះ មានអ្នកតន្ត្រីដែលមិនមានបុរសបម្រើ សោយមហាសម្បត្តិ ប្រថាប់នៅក្នុងប្រាសាទ ៣ តាមរដូវកាល ។

ថ្ងៃមួយ ព្រះពោធិសត្វមានបំណងនឹងយាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់ហៅសារថីមកហើយ ត្រាស់ថា ចូរទឹមរថ យើងនឹងទៅឧទ្យាន សារថីនោះទទួលព្រះតម្រាស់ហើយ ក៏ប្រដាប់រថដ៏ប្រសើរជាពាហនៈសមគួរក្រៃលែងមានទូក និងខ្សែជ្រាមមាំទាំ មានខ្នង់កង់ និងដុំរីងមាំ មានចន្ទោលប្រដាប់ទៅដោយមាស ប្រាក់ និងកែវមណី ចំហៀងនៃខ្នងកង់ប្រដាប់ដោយផ្កាយមាស និងប្រាក់ មានសិរីល្អដូចកម្រងផ្កា មានក្ងិនក្រអូបប្រភេទផ្សេងៗ ដែលក្រង់រួមគ្នាគួរមើល ដូចសុរិយរថដែលទឹមដោយសេះសិន្ធព ៤ ជាអាជានេយ្យមានសម្ពុះជើងដូចស្តេចគ្រុឌក្នុងអាកាស មានពណ៌ដូចព្រះចន្ទ និងផ្កាកុមុទរួចទូលឲ្យព្រះពោធិសត្វទ្រង់ជ្រាប ។ ព្រះពោធិសត្វ ឡើងរថព្រះទីន័ងនោះដែលដូចគ្នានឹងទេវវិមាន បែរមុខទៅកាន់ព្រះរាជឧទ្យាន ។

លំដាប់នោះ ទេវតាទាំងឡាយត្រិះរិះថា នេះជាពេលជិតត្រាស់ដឹងរបស់សិទ្ធត្ថកុមារហើយ អញនឹងសម្តែងបុព្វនិមិត្តដល់ព្រះអង្គ ទើបសម្តែងជាទេវបុត្តមួយអង្គ មានសរីរៈចាស់ជាំគ្រាំគ្រា មានធ្មេញបាក់ សក់ស្កូវ ខ្នង

កោង មានដើងញ័រទទ្រើក ។ ព្រះពោធិសត្វ និងសារថីក៏ឃើញមនុស្សចាស់នោះ ។ បន្ទាប់អំពីនោះ ព្រះពោធិសត្វក៏ត្រាស់សួរដោយន័យដែលមកក្នុងមហាបទានសូត្រថា ហៃនាយសារថីជាសម្លាញ់ស្មើចិត្តអើយ ចុះបុរសនេះឈ្មោះអ្វី បានជាសក់គាត់មិនដូចជាសក់អ្នកឯទៀត ដូច្នេះជាដើម ។ កាលស្តាប់ពាក្យរបស់សារថីនោះហើយ ទ្រង់ក៏សង្វេគថា ថ្វីយ អើហ្ន៎ សេចក្តីចាស់ តែងមានប្រាកដដល់សត្វលោកដែលកើតហើយ ដូច្នេះ ។ ទ្រង់ត្រឡប់អំពីទីនោះហើយ ក៏ឡើងកាន់ប្រាសាទ ។

ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ទើបកូនយើងត្រឡប់ សារថីទូលថា ព្រោះទ្រង់ឃើញមនុស្សចាស់ ។ បន្ទាប់អំពីនោះ ព្រះរាជាទ្រង់រន្ធត់ព្រះហឫទ័យ ទើបដាក់កម្លាំងរក្សាក្នុងទីកន្លះ ១ យោជន៍ ។ ស្អែកឡើង ព្រះពោធិសត្វយាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់ឃើញមនុស្សឈឺ ដែលទេវតាទាំងនោះនិម្មិត ទ្រង់សួរដោយន័យមុននោះឯង ទ្រង់សង្វេគ ទ្រង់ត្រឡប់ឡើងកាន់ប្រាសាទ ។ ព្រះរាជាត្រាស់សួរហើយ ទ្រង់ចាត់អ្នករបាំទាំងឡាយ ទ្រង់ព្រះតម្រិះថា អញនឹងធ្វើចិត្តកូនអញឲ្យឃ្លាតចាកការបួស ទើបទ្រង់បន្ថែមការរក្សា ទ្រង់តាំងការរក្សាក្នុងទីប្រមាណ ៣ គាវុត ដោយជុំវិញ ។

ថ្ងៃមួយ ព្រះពោធិសត្វយាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់ឃើញមនុស្សស្លាប់ ដែលទេវតានិម្មិតយ៉ាងនោះដូចគ្នា ទ្រង់សួរដោយន័យមុន សង្វេគក្នុងព្រះហឫទ័យហើយ យាងត្រឡប់ឡើងកាន់ប្រាសាទ ។ ព្រះរាជាត្រាស់សួរដល់ហេតុដែលព្រះរាជបុត្តត្រឡប់ ទ្រង់បន្ថែមការរក្សាទៀត ទ្រង់តាំងការ

រក្សាក្នុងទី ១ យោជន៍ ។

ថ្ងៃមួយ ព្រះពោធិសត្វទ្រង់យាងទៅកាន់ឧទ្យាន ទ្រង់ឃើញអ្នកបួសស្លៀកដណ្តប់រៀបរយដែលទេវតានិម្មិតដូចគ្នា ត្រាស់សួរសារថីថា នែសារថីបុគ្គលនោះ ឈ្មោះអ្វី ។ សារថីមិនស្គាល់អ្នកបួស ឬគុណរបស់អ្នកបួស ព្រោះព្រះសម្ពុទ្ធទ្រង់មិនទាន់កើតឡើងក៏ពិត តែសារថីឆ្លើយដោយអានុភាពរបស់ទេវតាថា បុគ្គលនេះ ជាអ្នកបួស ។ ហើយពណ៌នាគុណនៃការបួសដល់ព្រះពោធិសត្វនោះ ។

បន្ទាប់អំពីនោះ ព្រះពោធិសត្វកើតការពេញចិត្តក្នុងការបួស ទើបយាងទៅកាន់ព្រះរាជឧទ្យានក្នុងថ្ងៃនោះ ។ ព្រះពោធិសត្វទាំងឡាយ ដែលមានអាយុវែង យាងទៅទតឧទ្យាន ១០០ ឆ្នាំម្តង ទើបឃើញបុព្វនិមិត្តនីមួយៗ បណ្តាបុព្វនិមិត្ត ៤ មានមនុស្សចាស់ជាដើម ។ ឯព្រះពោធិសត្វនៃយើង ព្រោះកើតក្នុងសម័យដែលមនុស្សមានអាយុតិច ទ្រង់យាងទៅកាន់ព្រះរាជ-ឧទ្យាន ៤ ខែម្តង ទ្រង់ឃើញបុព្វនិមិត្តនីមួយៗ ដោយលំដាប់ ។ តែអាចារ្យអ្នករចនាគម្ពីរទីឃនិកាយពោលថា ទ្រង់ឃើញនិមិត្ត ៤ ក្នុងមួយថ្ងៃប៉ុណ្ណោះ ។ ព្រះពោធិសត្វក្រសាលក្នុងឧទ្យាននោះអស់មួយថ្ងៃ ទ្រង់សរសើរព្រះរាជ-ឧទ្យាន ទ្រង់ស្រង់ទឹកក្នុងស្រះមង្គលបោក្ខរណី កាលព្រះអាទិត្យអស្តង្គត ទ្រង់ប្រថាប់គង់លើផ្ទៃមង្គលសិលា មានបំណងនឹងតែងព្រះកាយ ។

លំដាប់នោះ វិស្សកម្មទេវបុត្តដែលសក្កទេវរាជទ្រង់ជ្រាបព្រះហឫទ័យនៃព្រះពោធិសត្វ ទ្រង់ប្រើហើយក៏មក មានរូបដូចជាងកោរកាត់សម្រាប់ព្រះ

ពោធិសត្វ ។ ព្រះពោធិសត្វប្រដាប់ដោយគ្រឿងអលង្ការដែលជាទិព្វ កាល អ្នកតន្ត្រីសម្តែងបដិភាណរៀងៗ ខ្លួន ដល់ព្រះពោធិសត្វនោះ ដែលប្រដាប់ ដោយអលង្ការសព្វយ៉ាងហើយ កាលព្រាហ្មណ៍ទាំងឡាយសរសើរដោយ ពាក្យជាដើមថា **ជយ នន្ទ** សេចក្តីថា បពិត្រព្រះអង្គ ជាធំជាងនរៈ សូម ទ្រង់មានជ័យជម្នះ កាលបុគ្គលអ្នកកាន់យកសុតមង្គលិកជាដើម សរសើរ ដោយពាក្យជាមង្គល និងសំឡេងសាធុការមានប្រការផ្សេងៗ ព្រះពោធិសត្វ ក៏ឡើងរថដែលប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ។

សម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានដំណឹងថា រាហុល-មាតាប្រសូត ទ្រង់ក៏បញ្ជូនដំណឹងទៅថា ចូរអ្នកប្រាប់ការត្រេកអរដល់កូន របស់យើង ។ ព្រះពោធិសត្វស្តាប់ពាក្យនោះហើយ ត្រាស់ថា **រាហុ ជាតោ ពន្ធនំ ជាតំ** អន្ទាក់កើតហើយ ចំណងកើតហើយ ។ ព្រះរាជាត្រាស់ សួរថា កូនរបស់យើងពោលដូចម្តេច ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា តាំងអំពីនេះជាដើមទៅ ចៅរបស់យើង ចូរមានឈ្មោះថា រាហុលកុមារ ។

ព្រះពោធិសត្វក៏ឡើងកាន់រថ យាងចូលកាន់ព្រះនគរ ដោយរាជបរិវារ ធំ ដោយសិរីគួរជាទីត្រេកអរក្រៃលែង ។ សម័យនោះ ខត្តិយកញ្ញាព្រះនាម កិសាគោតមី ជាស្រីមិនអាក្រក់ដោយរូបសិរី និងគុណសម្បត្តិ នៅលើប្រាសាទ ខាងលើ ឃើញរូបសម្បត្តិរបស់ព្រះពោធិសត្វកំពុងចូលកាន់នគរ ព្រះនាង កើតបីតិសោមនស្សឯង បន្លឺឧទានថា

បុរសបែបនេះ ជាបុត្តរបស់មាតាណា មាតានោះ រម្ងត់ គឺត្រជាក់ចិត្តពិត ជាបុត្តរបស់បិតាណា បិតានោះ រម្ងត់ពិត ជាស្វាមីរបស់នារីណា នារីនោះ រម្ងត់ពិត ដូច្នេះ ។

ព្រះពោធិសត្វស្តាប់ឧទាននោះហើយ ទ្រង់ត្រិះរិះថា ស្ត្រីនេះ ឲ្យអាត្មាអញបានឮពាក្យដែលគួរស្តាប់ ព្រោះថា អញកំពុងស្វែងរកនិព្វាន ថ្ងៃនេះឯង អញគួរលះបង់យកវាសវិស័យ ហើយចេញបួស ស្វែងរកនិព្វាន ទ្រង់ដោះកែវមុក្តាហារចេញអំពីព្រះសូរង ទ្រង់បញ្ជូនកែវមុក្តាហារ ដែលធ្វើនូវការត្រេកអរក្រៃលែង មានតម្លៃមួយសែន ដល់ខត្តិយកញ្ញាកិសាគោតមី ដោយបំណងថា កែវមុក្តាហារនេះ ចូរជាសក្ការៈ គឺជាចំណែកបូជាអាចារ្យសម្រាប់ព្រះនាង ។ ព្រះនាងកិសាគោតមីនោះ កើតសោមនស្សថា សិទ្ធត្ថកុមារមានចិត្តប្រតិព័ទ្ធក្នុងអញ បញ្ជូនបណ្ណាការមក ។

ឯព្រះពោធិសត្វឡើងកាន់ប្រាសាទ ដែលគួរជាទីត្រេកអរក្រៃលែង ដោយហេតុឲ្យកើតសិរីធំក្រៃលែង ទ្រង់ផ្ទំលើព្រះបន្ទំ ។ ក្នុងថ្ងៃនោះឯង ពួកស្ត្រីក្មេងៗ ទាំងឡាយ មានមុខល្អដូចព្រះចន្ទពេញវង់ មានបបូរមាត់ក្រហមដូចផ្លែបាស់ទុំ មានធ្មេញសស្អាត រាបស្មើ មិនមានមន្ទិល មានកែវភ្នែកមានផ្នែងសក់ពណ៌ខៀវចាស់ មានចិញ្ចើមខ្វង់ពណ៌ខៀវដូចផ្កាអញ្ចន់ មានកន្សោមសុដន់ពេញលេញដូចគេតម្រៀប មានត្រគាកខាងមុខ ខាងក្រោយមូលក្លំ ដូចមណីមេខលាប្រដាប់ដោយមាស និងប្រាក់ ធ្វើនូវការត្រេកអរមានភ្លៅទាំងគូ ដូចប្រមោយដំរី ឈ្លាសក្នុងការរាំងច្រៀង និងការប្រគំ មាន

រូបល្អដូចទេពធីតា កាន់តន្ត្រីមានសំឡេងពីរោះ នាំគ្នាមកចោមរោមនូវព្រះមហាបុរស ឲ្យទ្រង់ត្រេកអរ ប្រកបនូវការរាំច្រៀង និងការប្រគំតន្ត្រី ។ ព្រះពោធិសត្វ ទ្រង់មិនត្រេកអរក្នុងការរាំច្រៀងជាដើម ព្រោះទ្រង់មានចិត្តនឿយណាយក្នុងកិលេសទាំងឡាយ ទ្រង់ផ្ទំលក់មួយស្របក់ ។

ស្ត្រីទាំងនោះ ឃើញព្រះពោធិសត្វនោះគិតថា ពួកយើងប្រកបការរាំជាដើម ដើម្បីប្រយោជន៍ដល់បុរសណា បុរសនោះផ្ទំលក់ទៅហើយ ឥឡូវនេះ ពួកយើងលំបាកដើម្បីប្រយោជន៍អ្វី ហើយក៏ដេកលើឧបករណ៍តន្ត្រីលក់ទៅ ប្រទីបប្រេងក្រអូបនៅឆេះនៅឡើយ ព្រះពោធិសត្វទ្រង់តើនឡើង គង់ពត់ភ្នែនលើទីបន្ទំ ទ្រង់ឃើញស្ត្រីទាំងនោះដេកសង្កត់លើគ្រឿងតូរ្យតន្ត្រី មានទឹកមាត់ហូរ មានថ្ពាល់ និងសាច់ខ្លួនស្មោកគ្រោក ស្ត្រីខ្លះដេកសង្កៀតធ្មេញ ស្ត្រីខ្លះដេកស្រមុក ស្ត្រីខ្លះដេកមមើ ស្ត្រីខ្លះដេកហាមាត់ ស្ត្រីខ្លះដេករបូតសំពត់ប្រាកដវត្ថុក្នុងទីបង្កៀតដែលគួរឲ្យខ្ពើម ស្ត្រីពួកខ្លះមានសក់សំពោងសំពាយ ដេកប្រផេងប្រផាងដូចសាកសពក្នុងព្រៃខ្មោច ។ ព្រះមហាសត្វឃើញអាការចម្លែករបស់ស្ត្រីទាំងនោះ ក៏រឹងរឹតតែធ្វើឲ្យទ្រង់មានចិត្តនឿយណាយក្នុងកាមទាំងឡាយពន់ប្រមាណ ។ ផ្ទៃប្រាសាទដែលប្រដាប់តាក់តែងសូម្បីល្អដូចភពសហស្សនេត្រ ប្រាកដដល់ព្រះមហាសត្វនោះ ជារបស់គួរខ្ពើមក្រៃលែង ដូចព្រៃខ្មោចស្រស់ដែលពេញដោយសាកសព របស់មនុស្សស្លាប់ដែលគេចោល ភពទាំង ៣ ប្រាកដដូចភ្លើងឆេះ ទ្រង់រវើរវាយថា វឹកវរហ្ន៎ សាំញ៉ាំហ្ន៎ ព្រះហឫទ័យក៏បង្អោនទៅដើម្បីបព្វជ្ជា យ៉ាងក្រៃលែង ។

ព្រះពោធិសត្វទ្រង់ព្រះត្រិះរិះថា ថ្ងៃនេះឯង អញគួរចេញមហាភិនេ-ស្រ្កមណ៍ ទ្រង់ក្រោកចាកទីបទំ យាងទៅក្បែរទ្វារ ត្រាស់សួរថា អ្នកណានៅក្នុងទីនេះ នាយឆន្នដេកយកក្បាលកើយធរណីទ្វារទូលថា បពិត្រអយ្យ-បុត្ត ទូលបង្គំឈ្មោះឆន្ន ។ លំដាប់នោះ ព្រះមហាបុរសត្រាស់ថា ថ្ងៃនេះយើងបំណងនឹងចេញមហាភិនេស្រ្កមណ៍ អ្នកកុំប្រាប់បុគ្គលណា ចូរត្រៀមសេះសិន្ធព ១ ដែលមានសម្ទុះជើងរហ័ស ឆន្នទទួលព្រះតម្រាស់ថា សាធុកាន់កណ្ឋះសម្រាប់សេះទៅកាន់រោងសេះ កាលប្រទីបប្រេងក្រអូបកំពុងឆេះឃើញសេះមានសម្ទុះជើងល្អឈ្មោះកណ្ឋកៈ ញាំញីសត្រូវបាន ឈរក្នុងភូមិភាគដែលគួរជាទីត្រេកអរក្រៃលែង ខាងក្រោមពិតានផ្កាម្លិះ គិតថា ថ្ងៃនេះអញគួរត្រៀមសេះមង្គលនេះ ដើម្បីអយ្យបុត្តចេញអភិនេស្រ្កមណ៍ ហើយក៏ត្រៀមសេះកណ្ឋកៈ ។ ឯសេះកណ្ឋកៈនោះ កាលរៀបចំខ្លួន ក៏ដឹងថា ការរៀបចំនេះមាំមួនណាស់ មិនដូចកាលទ្រង់យាងទៅកាន់ឧទ្យានក្នុងថ្ងៃដទៃៗ អយ្យបុត្តនឹងចេញមហាភិនេស្រ្កមណ៍ក្នុងថ្ងៃនេះ ដោយឥតសង្ស័យ បន្ទាប់អំពីនោះ សេះកណ្ឋកៈមានចិត្តត្រេកអរ ស្រែកដោយសំឡេងខ្លាំង លាន់ឮពេញនគរកបិលពស្តុ តែទេវតាពាំង មិនឲ្យអ្នកណាឮឡើយ ។

ព្រះពោធិសត្វគិតថា អញនឹងមើលព្រះរាជបុត្តសិន ទើបយាងអំពីទីប្រថាប់ ទៅកាន់លំនៅរបស់រាហុលមាតា ទ្រង់បើកទ្វារបន្ទប់ ខណៈនោះប្រទីបប្រេងក្រអូបក្នុងបន្ទប់នៅឆេះនៅឡើយ ព្រះមាតានៃព្រះរាហុល ផ្ទំដាក់ហត្ថាខាងលើសីសៈព្រះឱរស ដែលដេរដាសដោយផ្កាម្លិះជាដើម ប្រមាណ

មួយអម្ពណៈ ព្រះពោធិសត្វដាក់ព្រះបាទត្រង់ធរណីទ្វារឈើប្រថាប់ ទ្រង់សម្លឹងមើល ត្រិះរិះថា បើអញលើកដៃព្រះទេវីចេញ ហើយស្ទាបអង្អែលបុត្ត ព្រះទេវីនឹងភ្ញាក់ កាលបើដូច្នោះ អភិនេស្រ្កមណ៍របស់អញនឹងអន្តរាយ អញបានត្រាស់ជាព្រះពុទ្ធហើយ សឹមមកមើលកូន ទ្រង់ចេញអំពីប្រាសាទហើយ ក៏ចូលទៅក្បែរសេះ ត្រាស់យ៉ាងនេះថា នែកណ្ឋកៈ ថ្ងៃនេះ អ្នកត្រូវឲ្យយើងឆ្លងក្នុងរាត្រីមួយ យើងអាស្រ័យអ្នកហើយ នឹងបានត្រាស់ជាព្រះពុទ្ធញុំាងលោក និងទេវលោកឲ្យឆ្លងឱឃៈ បន្ទាប់អំពីនោះ ទ្រង់ឡើងផែលលើខ្នងសេះកណ្ឋកៈៗ បណ្តោយរាប់ត្រឹម-ក ១៨ ហត្ថ ប្រកបដោយកម្ពស់សមនឹងបណ្តោយនោះ ដល់ព្រមដោយរូប មានថ្វីជើង និងកម្លាំងដ៏ក្រៃលែង មានពណ៌សសុទ្ធ មានពណ៌សម្បុរគួរមើល ដូចស័ង្ខដែលគេខាត់ហើយ ។ បន្ទាប់អំពីនោះ ព្រះពោធិសត្វប្រថាប់គង់លើខ្នងសេះ ឲ្យឆន្នអមាត្យតោងកន្ទុយសេះ ដល់ទ្វារធំនៃនគរទាំងកណ្តាលរាត្រី ។

ក្នុងកាលមុន ព្រះរាជាត្រៀមបុរស ១០០០ នាក់ ចាំបើកទ្វារទាំងពីរដើម្បីឃាត់ព្រះពោធិសត្វ ទ្រង់ចាត់បុរសជាច្រើន ដើម្បីរក្សាក្នុងទ្វារនោះ ។ បានឮថា ព្រះពោធិសត្វទ្រង់មានកម្លាំងស្មើនឹងបុរសមួយសែនកោដិ ស្មើនឹងដំរីមួយពាន់កោដិ ព្រោះហេតុនោះ ទើបទ្រង់ព្រះតម្រិះថា បើទ្វារមិនបើកទេ ថ្ងៃនេះ អញនឹងអង្គុយលើខ្នងកណ្ឋកៈ ឲ្យនាយឆន្នចាប់កន្ទុយសេះ យកភ្លៅទាំង ២ កៀបកណ្ឋកៈ លោតឆ្លងកំពែងកម្ពស់ ១៨ ហត្ថ ទៅជាមួយឆន្ន ។ នាយឆន្នគិតថា បើទ្វារមិនបើកទេ អញនឹងយកអយ្យបុត្តដាក់លើ-ក កៀប

កណ្ឋកៈដោយដៃស្តាំ ធ្វើកណ្ឋកៈឲ្យនៅក្នុងចន្លោះភ្លៀក លោតឆ្លងកំពែងទៅ ។ សេះកណ្ឋកៈគិតថា បើទ្វារមិនបើកទេ អញនឹងនាំអយ្យបុត្ត ដែលគង់លើខ្នងជាជម្មតានោះឯង មួយអន្ទើដោយឆន្នដែលតោងត្រង់កន្ទុយ លោតឆ្លងកំពែងទៅ ជនទាំង ៣ នាក់ គិតដូចគ្នាយ៉ាងនេះ តែទេវតាដែលអាស្រ័យនៅត្រង់ទ្វារ ក៏នាំគ្នាបើកទ្វារជំឲ្យ ។

ខណៈនោះ មារមានចិត្តបាបគិតថា នឹងឲ្យព្រះមហាសត្វត្រឡប់ទៅ ទើបមកឈរកណ្តាលអាកាសពោលថា

បពិត្រមហាវីរៈ កុំចេញអភិនេស្រ្កមណ៍ឡើយ ចាប់ពីនេះទៅ
៧ ថ្ងៃ ចក្ករត្នទិព្វ នឹងប្រាកដដល់ទ្រង់ពិតប្រាកដ ដូច្នេះ ។

ហើយមារពោលបន្តថា ទ្រង់នឹងគ្រងរាជ្យក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារ ត្រឡប់ទៅចុះលោកនិទ្ទុក្ខ ។ ព្រះមហាបុរសត្រាស់សួរថា អ្នកជាអ្នកណា មារតបថា ខ្ញុំជាស្តេចវសវត្តី មហាបុរសត្រាស់ថា

នែមហារាជ យើងដឹងថា ចក្ករត្ននឹងប្រាកដដល់យើង តែ
យើងមិនត្រូវការចក្កពត្តិរាជ នែមារ ចូរអ្នកទៅចុះ កុំមកក្នុង
ទីនេះឡើយ ។

យើងនឹងបានត្រាស់ជាព្រះពុទ្ធ ជាអ្នកនាំវិសេសក្នុងលោក
នឹងបន្លឺទូទៅ ក្នុងម៉ឺនលោកធាតុ ដូច្នេះ ។

មារនោះ ក៏អន្តរធានទៅក្នុងទីនោះឯង ។

ក្នុងកាលដែលព្រះជន្មាយុ ២៩ វស្សា ព្រះមហាសត្វទ្រង់ចោលចក្ក-

ពត្តិរាជ ដែលធ្លាក់ក្នុងកណ្តាប់ព្រះហស្ត ទ្រង់មិនអាឡោះអាល័យ ដូចដុំទឹកមាត់ ទ្រង់ចេញអំពីព្រះរាជនិវេសន៍ ដែលជាសិរីនិវាសរបស់ចក្កពត្តិ នាកាលផ្កាយនក្ខត្តឫក្សឧត្តរាសាឡ្ហ ពេញបូណ៌មី ខែអាសាឍ ទ្រង់ចេញអំពីនគរ មានបំណងនឹងសម្លឹងមើលនគរ ក្នុងលំដាប់នៃការត្រិះរិះនោះឯង ផែនដីត្រង់នោះ ក៏វិលទៅដូចចក្កយន្តរបស់ស្មូនឆ្នាំង ។ ព្រះមហាសត្វទ្រង់ស្ថិតនៅជាធម្មតានោះ ទតនគរកបិលពស្តុ សម្តែងចេតិយដ្ឋាន ឈ្មោះថា កណ្ឋកនិវត្តនៈ( ទីវិលត្រឡប់នៃសេះកណ្ឋកៈ ) ក្នុងប្រទេសនោះហើយ ទ្រង់ញាក់សេះកណ្ឋកៈឲ្យបែរមុខទៅតាមផ្លូវ ដែលត្រូវទៅ យាងទៅដោយសក្ការៈធំដោយហេតុឲ្យកើតសិរីដ៏ឱឡារ ។

លំដាប់នោះ កាលព្រះមហាសត្វកំពុងយាងទៅ ទេវតាទាំងឡាយកាន់គប់ភ្លើងចំនួន ៦ លាន ខាងមុខព្រះមហាសត្វ ខាងក្រោយក៏ ៦ លានដូចគ្នា ខាងស្តាំ និងឆ្វេងក៏ដូចគ្នា ។ ទេវតាដទៃៗ ក៏ធ្វើសក្ការៈដោយកម្រងផ្កាសុរភីនិងផ្កាកុសុមៈ ដែលមានក្លិនក្រអូប លម្អិតខ្លឹមចន្ទន៍ បក់នូវផ្លិត និងទង់ជ្វាលាបោមរោមព្រះពោធិសត្វទៅ ទិព្វតន្ត្រីជាច្រើនក៏បន្លឺឯង ។

ព្រះពោធិសត្វយាងទៅដោយហេតុឲ្យកើតសិរីយ៉ាងនេះ អស់ចម្ងាយផ្លូវ ៣០ យោជន៍ ធ្លងរាជាណាចក្ក ៣ ដោយ ១ រាត្រីប៉ុណ្ណោះ ដល់ឆ្នេរស្ទឹងអនោមា ។ លំដាប់នោះ ព្រះពោធិសត្វទ្រង់ឈរត្រង់ឆ្នេរស្ទឹង ត្រាស់សួរឆន្នថា ស្ទឹងនេះ ឈ្មោះអ្វី ឆន្នទូលថា ស្ទឹងអនោមា ទ្រង់ព្រះតម្រិះថា ស្ទឹងអនោមា នឹងជាទីសម្រាប់បួសរបស់អញ ទ្រង់យកកែងព្រះបាទ គោះឲ្យ

សញ្ញាដល់សេះ សេះក៏លោតទៅឈរត្រើយម្ខាងនៃស្ទឹង ដែលមានទទឹង ៨ ឧសភ ។ ព្រះពោធិសត្វចុះអំពីខ្នងសេះ ឈរត្រង់ឆ្នេរខ្សាច់ ដូចគ្នានឹងគំនរកែវមុក្តា ហៅឆន្នមកត្រាស់ថា ឆន្នសម្លាញ់ ចូរអ្នកនាំនូវអាភរណៈរបស់ខ្ញុំ និងសេះកណ្ឋកៈត្រឡប់ទៅ ខ្ញុំនឹងបួស ។

ឆន្នទូលថា បពិត្រអយ្យបុត្ត ខ្ញុំក៏នឹងបួស ព្រះពោធិសត្វត្រាស់ថា ឯងបួសមិនបានឡើយ ឯងត្រូវត្រឡប់ទៅ ទ្រង់ឃាត់អស់វារៈ ៣ ដង ហើយទ្រង់ប្រគល់អាភរណៈ និងសេះកណ្ឋកៈ ហើយទ្រង់ព្រះតម្រិះថា សក់របស់អាត្មាអញ មានសភាពយ៉ាងនេះ មិនសមគួរដល់សមណៈ អញនឹងកាត់សក់ទាំងនេះដោយព្រះខ័ន ទ្រង់ចាប់ព្រះខ័នដ៏មុតដោយព្រះហស្តស្តាំ ទ្រង់ប្រមូលព្រះចូឡា មួយអន្ទើដោយព្រះមោលីដោយព្រះហស្តឆ្វេង ហើយកាត់ព្រះកេសា ទុកត្រឹម ២ ធ្នាប់ ព្រះកេសាទាំងនោះ ដុះវិលទៅខាងស្តាំ ជាប់នឹងសាច់ព្រះសីសៈ ព្រះកេសាទាំងនោះ មានប្រមាណប៉ុណ្ណោះ ដរាបដល់ទ្រង់អស់ព្រះជន្ម ឯព្រះមស្សុក៏សមដល់ប្រមាណព្រះកេសានោះ តែព្រះពោធិសត្វមិនមានកិច្ចដែលត្រូវកោរសក់ និងពុកមាត់ទៀតឡើយ ។ ព្រះពោធិសត្វប្រមូលព្រះចូឡា មួយអន្ទើដោយព្រះមោលី អធិដ្ឋានថា បើអញបានត្រាស់ជាព្រះពុទ្ធសោត សក់នេះចូរតាំងនៅក្នុងអាកាស បើមិនបានត្រាស់សោត ក៏ចូរធ្លាក់ចុះលើផែនដី ហើយបោះទៅក្នុងអាកាស សំណុំព្រះចូឡា-មណីនោះ ទៅក្នុងចម្ងាយមួយយោជន៍ហើយ ក៏តាំងនៅក្នុងអាកាស ។ គ្រានោះ សក្កទេវរាជទ្រង់ប្រមើលមើលដោយទិព្វចក្ខុ ទ្រង់យកប្រអប់រតនៈ

ទំហំមួយយោជន៍ ទទួលសំណុំព្រះចូឡាមណីនោះ ហើយទ្រង់ស្ថាបនាជាព្រះចូឡមណីចេតិយ សម្រេចដោយរតនៈ ៧ ប្រការ ទំហំ ៣ យោជន៍ ក្នុងស្ថានតាវត្តិង្ស ដូចលោកពោលថា

ព្រះអគ្គបុគ្គល ទ្រង់កាត់ព្រះមោលីដែលអប់ដោយគ្រឿងក្រអូបយ៉ាងល្អ ទ្រង់បោះទៅកាន់អាកាស ស្ដេចវាសវ-សហស្សនេត្រ ទ្រង់យកប្រអប់មាសយ៉ាងល្អមកទទួល ដាក់លើសិរសា គឺត្បូង ដូច្នេះ ។

ព្រះពោធិសត្វទ្រង់ត្រិះរិះជាបន្តថា សំពត់កាសីទាំងនេះ មានតម្លៃច្រើនមិនសមគួរដល់សមណៈរបស់អាត្មាអញ លំដាប់នោះ ឃដិការមហាព្រហ្មដែលជាបុរាណសម្លាញ់របស់ព្រះពោធិសត្វ ក្នុងសម័យព្រះកស្សបសម្ពុទ្ធ ត្រិះរិះដោយមិត្តភាព ដែលមិនសាបសូន្យអស់មួយពុទ្ធន្តរថា ថ្ងៃនេះ សម្លាញ់របស់អញ ចេញអភិនេស្រ្កមណ៍ អញនឹងកាន់យកសមណបរិក្ខារ ដើម្បីសម្លាញ់នោះ ទើបនាំបរិក្ខារ ៨ មកថ្វាយ

បរិក្ខារ ៨ គឺត្រៃចីវរ បាត្រ កាំបិតកោរ បំពង់ម្ជុល វត្ថពន្ធ-ចង្កេះ ធម្មក្រក ជារបស់ភិក្ខុដែលប្រកបព្យាយាម ដូច្នេះ ។

ព្រះមហាបុរសទ្រង់គ្រងសំពត់ ដែលជាទង់ជ័យរបស់ព្រះអរហន្ត កាន់យកភេទបព្វជ្ជាដ៏ឧត្តម ទ្រង់បោះគូសំពត់ដណ្ដប់ទៅក្នុងអាកាស ។ មហាព្រហ្មទទួលគូសំពត់នោះហើយ សាងចេតិយសម្រេចដោយរតនៈ ទំហំ ១២ យោជន៍ ក្នុងព្រហ្មលោក ដាក់គូសំពត់នោះខាងក្នុង ។ លំដាប់នោះ ព្រះមហាសត្វ

ត្រាស់នឹងឆន្នថា នែ ឆន្ន ចូរអ្នកប្រាប់ដល់ព្រះជនក ព្រះជននីតាមពាក្យរបស់យើងថា យើងសុខជាទេ ហើយទ្រង់បញ្ជូនទៅ ។ លំដាប់នោះ ឆន្ន ក៏ថ្វាយបង្គំព្រះមហាបុរស ធ្វើប្រទក្សិណហើយ ចៀសចេញទៅ ឯសេះកណ្ឋកៈ ឈរស្តាប់ពាក្យរបស់ព្រះពោធិសត្វ ប្រឹក្សានឹងនាយ ឆន្ន ដឹងថា ឥឡូវនេះ អញលែងបានឃើញម្ចាស់របស់អញហើយ គ្រាន់តែផុតកន្ទុយភ្នែករបស់មហាបុរស មិនអាចអត់ធន់ក្នុងវិប្បយោគទុក្ខបាន ក៏បែកដើមទ្រូងស្លាប់ទៅ កើតជាទេវបុត្ត ឈ្មោះ កណ្ឋកៈ ក្នុងស្ថានតាវត្តិង្ស ជាភពដែលទេវតាជាសត្រូវគ្របសង្កត់បានដោយក្រ ការកើតរបស់កណ្ឋកទេវបុត្តនោះ គប្បីកាន់យកតាមអដ្ឋកថាវិមានវត្ថុ ឈ្មោះវិមលត្ថវិលាសនី ( បរមត្ថទីបនី ) ។ សេចក្ដីសោកមានដល់ឆន្នជាលើកទី ១ ( ព្រោះព្រាត់ប្រាសព្រះពោធិសត្វ ) ព្រោះការស្លាប់របស់សេះកណ្ឋកៈ នាយឆន្នត្រូវសេចក្ដីសោកលើកទី ២ បៀតបៀន ក៏ទ្រហោយំ ធ្វើដំណើរទៅដោយសេចក្ដីទុក្ខ ។

ឯព្រះពោធិសត្វបួសហើយ នៅក្នុងប្រទេសនោះឯង មានចម្ការស្វាយឈ្មោះអនុបិយជាលំនៅ ទ្រង់សម្ងំនៅក្នុងអនុបិយម្ពវ័ននោះអស់ ៧ ថ្ងៃ ដោយសេចក្ដីសោកក្នុងបព្វជ្ជា ខាងក្រោយអំពីនោះ ទ្រង់បិទបាំងដោយសំពត់កាសាវៈដ៏ល្អ ដូចព្រះចន្ទពេញវង់ សម្ងំនៅក្នុងស្រទាប់ពពកដែលបិទបាំងដោយពន្លឺសន្ធិយាមួយព្រះអង្គឯង រុងរឿងដូចជនជាច្រើនចោមរោមហើយ ទ្រង់ធ្វើបព្វជ្ជានោះឲ្យដូចទឹកអម្រឹត ទាញយកនូវកែវភ្នែករបស់ពួកម្រឹគ និងបក្សីក្នុងព្រៃ ព្រះនរសីហៈ ទ្រង់ត្រាច់ទៅមួយអង្គឯងដូចរាជសីហ៍ ដូច

ហត្ថាចារ្យដែលស្គាល់លីលារបស់ដំរីចុះប្រេង ញ៉ាំងផែនដីឲ្យស្រោលដោយសម្ទុះជើង ទ្រង់យាងទៅ ៣០ យោជន៍ ក្នុងកាលមួយថ្ងៃប៉ុណ្ណោះ ទ្រង់ឆ្លងស្ទឹងគង្គា ប្រកបដោយឧតុ និងវលក មិនជាប់ជំពាក់ ចូលកាន់នគររាជគ្រឹះ ដែលភ្លឺផ្លេកដោយពន្លឺនៃរតនៈ កាលទ្រង់ចូលទៅហើយ ទ្រង់បិណ្ឌបាតតាមលំដាប់ច្រក ។ ផ្ទៃនគរទាំងមូលក៏រំជើបរំជួល ព្រោះឃើញព្រះរូបរបស់ព្រះពោធិសត្វ ដូចដំរីធនបាលចូលទៅ និងដូចទេវនគររំជើបរំជួល កាលស្តេចអសុរចូលទៅ ។ កាលមហាបុរសស្វែងរកកិច្ចា ពួកមនុស្សអ្នកនគរកើតអស្ចារ្យ មានទូវបីតិសោមនស្ស ព្រោះឃើញរូបរបស់ព្រះមហាសត្វ មានចិត្តទឹកជល់ការឃើញព្រះរូបរបស់ព្រះពោធិសត្វ ។

បណ្តាមនុស្សទាំងនោះ មនុស្សម្នាក់ពោលនឹងមនុស្សម្នាក់យ៉ាងនេះថា ហេតុអ្វីហ្ន៎ ចន្ទពេញបូណ៌មី ប្រកបដោយសំណុំរស្មី ត្រូវភ័យ គឺរាហុចាំងហើយ នៅតែមកកាន់មនុស្សលោកបាន មនុស្សដទៃក្រៅអំពីនោះ ញញឹមពោលយ៉ាងនេះថា នែសម្លាញ់ អ្នកពោលអ្វី អ្នកឃើញព្រះចន្ទមកកាន់មនុស្សលោកកាលណា ន៉ុះជាកាមទេព មានផ្កាជាទង់មិនមែនឬ លោកកាឡូខនហើយ ឃើញសេចក្តីចម្រើនដែលមានលីលាយ៉ាងក្រៃលែង នៃមហារាជរបស់យើង និងអ្នកនគរ ទើបយាងមកលេង ។ អ្នកដទៃក្រៅពីនោះញញឹមពោលយ៉ាងនេះថា នែសម្លាញ់ អ្នកឆ្កួតហើយឬ ន៉ុះជាព្រះឥន្ទ្រ ដែលមានសរីរៈរុងរឿងដោយយញ្ញរបស់ភ្លើង និងយញ្ញដ៏ខ្ពង់ក្លា ជាស្តេចសហស្សនេត្រ ជាស្តេចនៃទេវតាមកក្នុងទីនេះ ដោយសម្គាល់ថា ជាទេវបុរី អ្នកដទៃ

ក្រៅពីនោះ សើចតិចៗ ហើយពោលថា នែសម្លាញ់ អ្នករាល់គ្នាខុសទាំង មុនទាំងក្រោយ បុរសនោះ មានភ្នែកមួយពាន់មកអំពីណា មានវជិរាវុធមក អំពីណា មានដំរីឯរាវ័ណមកអំពីណា ដែលពិត បុរសនោះ ជាព្រហ្ម លោក ដឹងថា ពួកព្រាហ្មណ៍ប្រមាទ ទើបមកប្រកបក្នុងវេទ និងអង្គនៃវេទទេតើ ។ បុរសដទៃដែលជាបណ្ឌិតហាមប្រាមជនទាំងនោះ ពោលយ៉ាងនេះថា បុរស នោះ មិនមែនព្រះចន្ទពេញបូណ៌មី មិនមែនកាមទេព មិនមែនសហស្សនេត្រ មិនមែនព្រហ្ម តែបុរសនោះជាអច្ឆរិយៈ មនុស្សជាសាស្តា ជាលោកនាយក ។

កាលអ្នកនគរចរចាគ្នាយ៉ាងនេះ ពួករាជបុរសក៏ក្រាបទូលរឿងនោះ ដល់ព្រះបាទពិម្ពិសារថា បពិត្រព្រះសម្មតិទេព មិនដឹងជាទេវតា គន្ធព្វ ឬ នាគរាជ យក្ខ ឬអ្នកណាហ្ន៎ ត្រាច់ភិក្ខាក្នុងនគររបស់យើង ។ ព្រះរាជាទ្រង់ ស្តាប់រឿងនោះហើយ ទ្រង់ឈរក្នុងប្រាសាទជាន់លើ ទ្រង់ឃើញព្រះមហាបុរស ក៏កើតអស្ចារ្យក្នុងចិត្តដែលមិនធ្លាប់មាន ទ្រង់បញ្ជារាជបុរសថា ចូរពួកអ្នក ទៅ ចូរសង្កេតមើលបុរសនោះ បើជាអមនុស្សចេញ ពីនគរនឹងអន្តរធានទៅ បើជាទេវតា នឹងទៅកាន់អាកាស បើជានាគរាជ នឹងមុជចុះក្នុងផែនដី បើជា មនុស្សនឹងបរិភោគអាហារដែលបានមក ។

ឯព្រះមហាបុរស មានឥន្ទ្រិយស្ងប់ មានព្រះហឫទ័យស្ងប់ ហាក់ដូច ទាញយកខ្សែភ្នែកមហាជន ព្រោះលម្អនៃព្រះរូប ទ្រង់សម្លឹងមើលមួយ ជួរទឹម ប្រមូលអាហារបញ្ចូលគ្នា ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ទ្រង់ ចេញពីនគរតាមទ្វារដែលទ្រង់ចូលមក បែរមុខទៅទិសខាងកើត ដល់ញក

ក្នុំបណ្ឌវៈ គង់ពិចារណាអាហារ មិនមានអាការខុសប្រក្រតី ហើយក៏សោយ ។ បន្ទាប់អំពីនោះ ពួករាជបុរសក៏ទៅក្រាបទូលរឿងនោះ ដល់ព្រះរាជា ។

លំដាប់នោះ ព្រះបាទមគធៈ ព្រះនាមពិម្ពិសារ ដែលពួកពាលជនបដិបត្តិតាមបានលំបាក ទ្រង់មាំទាំដូចភ្នំមេរុ និងភ្នំមន្ទារ ទ្រង់ជាសារៈនៃពួកសត្វ ទ្រង់មានការភ្ញាក់ផ្អើលព្រោះការឃើញដែលកើតឡើង ព្រោះបានស្តាប់គុណទាំងនោះរបស់ព្រះពោធិសត្វ ទ្រង់ប្រញាប់យាងចេញអំពីព្រះនគរ បែរមុខទៅកាន់ភ្នំបណ្ឌវៈ ទ្រង់យាងទៅហើយ ចុះអំពីព្រះរាជយាន ទៅកាន់សម្នាក់ព្រះពោធិសត្វ កាលព្រះពោធិសត្វទ្រង់អនុញ្ញាតហើយ គង់លើផ្ទាំងថ្មដ៏ត្រជាក់ ដោយសេចក្តីស្រឡាញ់របស់ជនដែលជាញាតិមិត្ត ទ្រង់ជ្រះថ្លាក្នុងឥរិយាបថរបស់ព្រះពោធិសត្វ ទ្រង់បានទទួលបដិសណ្ឋារៈ ហើយទ្រង់សួរដល់នាម និងគោត្ត ទ្រង់ប្រគល់ភាពជាធំសព្វយ៉ាង ដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វត្រាស់ថា បពិត្រមហារាជ អាត្មាមិនបំណងដោយវត្ថុកាម ឬកិលេសកាម អាត្មាប្រាថ្នាតែបរមាភិសម្ពោធិញ្ញាណ ទើបចេញបួស ។ ព្រះរាជាទ្រង់អង្វរច្រើនប្រការ ក៏មិនបានទឹកព្រះហឫទ័យរបស់ព្រះពោធិសត្វ ទើបត្រាស់ថា ទ្រង់នឹងបានត្រាស់ជាព្រះពុទ្ធពិត ទើបទូលថា បើទ្រង់បានជាព្រះពុទ្ធហើយ សូមនិមន្តមកកាន់ដែនរបស់ខ្ញុំមុន ហើយទ្រង់ត្រឡប់ចូលកាន់ព្រះនគរ ។

កាលព្រះនររាជដ៏ប្រសើរ ទ្រង់ចូលកាន់ក្រុងរាជគ្រឹះ ដែល

មានព្រះរាជវាំងដ៏ប្រសើរ ស្តេចគីរីដ៏ប្រសើរ ព្រះរាជមុនីដ៏ប្រសើរ យាងទៅ ដូចស្តេចម្រឹគ យាងទៅហើយ ឈ្មោះថា យាងទៅល្អហើយ ដូច្នេះ ។

គ្រានោះ ព្រះពោធិសត្វទ្រង់ចារិកទៅតាមលំដាប់ ចូលទៅរកអាឡារតាបសកាលាមគោត្ត និងឧទកតាបសរាមបុត្ត ញ៉ាំងសមាបត្តិ ៨ ឲ្យកើតហើយ ទ្រង់ត្រិះរិះថា ផ្លូវនេះ មិនមែនផ្លូវនៃពោធិញ្ញាណឡើយ ទ្រង់មិនដាក់ចិត្តដល់សមាបត្តិភាវនានោះ មានបំណងនឹងតាំងមហាបធាន ទើបយាងទៅកាន់ឧរុវេលា ទ្រង់ត្រិះរិះថា ភូមិភាគនេះ គួរជាទីត្រេកអរហ្ន៎ ទ្រង់ចូលកាន់តំបន់នោះ ទ្រង់តាំងសេចក្តីព្យាយាមធំ ។

ជន ៥ នាក់ គឺបុត្តរបស់ព្រាហ្មណ៍ដែលទាយមហាបុរិសលក្ខណៈ ៤ នាក់ និងព្រាហ្មណ៍ឈ្មោះកោណ្ឌញ្ញៈម្នាក់ នាំគ្នាបួសមុន រង់ចាំព្រះពោធិសត្វត្រាច់ភិក្ខាចារក្នុងគាមនិគម រាជធានីទាំងឡាយ ជួបព្រះពោធិសត្វក្នុងទីនោះៗ លំដាប់នោះ កាលនាំគ្នាបម្រើព្រះពោធិសត្វដែលតាំងសេចក្តីព្យាយាមធំអស់ ៦ ឆ្នាំ ដោយវត្តបដិបត្តិ មានការបោសបរិវេណជាដើម ដោយបំណងថា ព្រះពោធិសត្វទ្រង់នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលឥឡូវនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលឥឡូវនេះ នៅប្រចាំសម្នាក់របស់ព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វ ទ្រង់តម្កល់ព្រះជន្មដោយល្ង និងអង្ករ ១ គ្រាប់ ដោយទ្រង់បំណងនឹងធ្វើទុក្ករកិរិយាឲ្យដល់ទីបំផុត ទ្រង់បានកាត់បង់នូវអាហារ ដោយប្រការទាំងពួង ទេវតាទាំងឡាយក៏នាំទិព្វឱជាមកដាក់តាមរន្ធរោមទាំងឡាយ ។

គ្រានោះ ព្រះវរកាយដែលមានពណ៌ដូចមាសរបស់ព្រះពោធិសត្វដែលមានពន្លឺ ក៏ដល់នូវការស្គមស្គាំងក្រៃលែង ព្រោះមិនមានអាហារ ក៏ទៅជាកាយមានពណ៌ខ្មៅ ។ ព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ត្រូវបិទបាំង ។ គ្រានោះ ព្រះពោធិសត្វទ្រង់ដល់ទីបំផុតនៃទុក្ករកិរិយា ទ្រង់ព្រះតម្រិះថា នេះមិនមែនផ្លូវនៃពោធិញ្ញាណឡើយ មានបំណងនឹងសោយអាហារគ្រោតគ្រាត ទើបចូលទៅបិណ្ឌបាតក្នុងគាមនិគមទាំងឡាយ សោយព្រះក្រយាហារ ។ គ្រានោះ ព្រះមហាបុរិសលក្ខណៈ ៣២ ក៏មានមកវិញជាប្រក្រតី ព្រះវរកាយមានពណ៌ដូចមាស ។ ខណៈនោះ បញ្ចវគ្គិយភិក្ខុឃើញព្រះពោធិសត្វ គិតថា បុរសនេះ ធ្វើទុក្ករកិរិយាអស់ ៦ ឆ្នាំ មិនអាចត្រាស់ដឹងសព្វញ្ញុតញ្ញាណបានឥឡូវនេះ ត្រាច់បិណ្ឌបាតក្នុងគាមនិគម រាជធានីទាំងឡាយ បរិភោគអាហារគ្រោតគ្រាត តើនឹងត្រាស់ដឹងបានដូចម្ដេច បុរសនេះ ប្រាសចាកសេចក្ដីព្យាយាម ប្រយោជន៍អ្វីរបស់អញដោយបុរសនេះ ហើយលះបង់មហាបុរស នាំគ្នាទៅកាន់ព្រៃឥសិបតនៈ ក្រុងពារាណសី ។

សម័យនោះ ជាថ្ងៃវិសាខបុណ្ណមី ព្រះមហាបុរសសោយមធុបាយាសដែលទេវតាដាក់ទិព្វឱជា ដែលកុលធីតាឈ្មោះសុជាតា កើតក្នុងត្រកូលនៃសេនាកុដុម្ពិកៈ ក្នុងតំបន់ឧរុវេលាសេនានិគម កើតនូវសេចក្ដីជ្រះថ្លាថ្វាយហើយ ទ្រង់កាន់ថាសមាសចុះកាន់ស្ទឹងនេរញ្ជរា ដាស់កាឡនាគរាជដែលកំពុងដេកលក់ឲ្យភ្ញាក់ហើយ ។ កាលនោះ ព្រះពោធិសត្វសម្រាកពេលថ្ងៃក្នុងព្រៃសាលវ័ន ដែលប្រដាប់ដោយផ្កាក្រអូប មានពណ៌ខៀវ គួរជាទី

ត្រេកអរ ត្រង់ឆ្នេរស្ទឹងនេរញ្ជរា លុះដល់វេលាល្ងាច ទ្រង់បែរមុខទៅកាន់គល់ពោធិព្រឹក្ស តាមផ្លូវដែលទេវតាទាំងឡាយប្រដាប់ហើយ ។ ទេវតា នាគ យក្ខសិទ្ធៈជាដើម នាំគ្នាបូជាដោយផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប ។ សម័យនោះ អ្នករកស្មៅឈ្មោះសោត្ថិយៈ កាន់ស្មៅដើរប្រាសផ្លូវមក ដឹងអាការរបស់មហាបុរស ទើបថ្វាយស្មៅ ៨ ក្តាប់ ព្រះពោធិសត្វទ្រង់ទទួលស្មៅហើយ យាងចូលទៅកាន់គល់ពោធិព្រឹក្ស ឈ្មោះដើមអស្សត្ថព្រឹក្ស ដែលជាឈើមានជ័យជម្នះរុងរឿងជាងដើមឈើទាំងឡាយ ដូចគ្នានឹងដើមអញ្ជនគិរីពណ៌ខៀវចាស់ ហាក់បីដូចជួយបន្ទោបង់ពន្លឺទិនករ មានម្លប់ត្រជាក់ត្រជាក់ដោយព្រះករុណា ដូចហឫទ័យរបស់ព្រះអគ្គ វៀរចាកការចោមរោមរបស់វិហគៈ គឺបក្សីច្រើនប្រភេទ ប្រដាប់ដោយមែក និងប្រគាប ត្រូវខ្យល់ត្រសៀកៗ បក់មក ហាក់បីដូចរបាំ និងដូចត្រេកអរដោយបីតិ ទ្រង់ធ្វើប្រទក្សិណដើមអស្សត្ថព្រឹក្ស ៣ ជុំ ប្រថាប់ឈរក្នុងទិសឦសាន ទ្រង់ចាប់ចុងស្មៅអង្រួន ។ លំដាប់នោះ ក៏មានបល្ល័ង្កកម្ពស់ ១៤ ហត្ថ ស្មៅទាំងនោះហាក់ដូចវិចិត្រករគូរ ។ ព្រះពោធិសត្វ គង់ពត់ភ្នែនលើសន្ថ័តស្មៅ ១៤ ហត្ថ ទ្រង់អធិដ្ឋានព្យាយាមប្រកបដោយអង្គ ៤ ទ្រង់ធ្វើដើមពោធិព្រឹក្ស ៥០ ហត្ថឲ្យនៅអំពីខាងក្រោយ ដូចដើមឈើប្រាក់ដែលគេដាក់លើតាំងមាស បាំងដោយមែកពោធិព្រឹក្ស ដូចឆត្រកែវមណីអំពីខាងលើប្រថាប់គង់ ។ ត្រួយពោធិព្រឹក្សជ្រុះមកត្រង់ចីវរពណ៌មាសរបស់ព្រះអង្គក៏រុងរឿង ដូចដាក់កែវពពាលលើដំបារមាស ។

កាលព្រះពោធិសត្វគង់ត្រង់ពោធិបល្ល័ង្កនោះ វសវត្តីមារទេវបុត្ត គិតថា សិទ្ធត្ថកុមារកន្លងវិស័យរបស់អញ ឥឡូវនេះ អញនឹងមិនឲ្យសិទ្ធត្ថកុមារនោះកន្លងវិស័យ ទើបប្រាប់សេចក្តីនោះដល់កម្លាំងរបស់មារ ហើយនាំពលមារចេញមក បានឮថា ទ័ពមារនោះខាងមុខកម្រាស់ ១២ យោជន៍ ខាងស្តាំ និងខាងឆ្វេងក៏យ៉ាងនោះ តែខាងក្រោយតាំងនៅរហូតដល់ទីបំផុតចក្កវាឡ ខាងលើកម្ពស់ ៩ យោជន៍ សម្រែកគំរាមសំឡេងដូចផែនដីស្រុត ឮដល់ទៅ ៩ ពាន់យោជន៍ ។

សម័យនោះ សក្កទេវរាជឈរផ្លុំស័ង្ខ ឈ្មោះវិជយុត្តរ បានឮថា ស័ង្ខនោះប្រវែង ២ ពាន់ហត្ថ ។ គន្ធព្វទេវបុត្តឈ្មោះបញ្ចសិខ កាន់ពិណដែលមានពណ៌លឿងដូចផ្លែព្នៅប្រវែង ៣ គាវុត ឈរច្រៀងប្រកបដោយមង្គល ស្តេចសុយាមទេវរាជកាន់ផ្ចិតទិព្វដ៏មានសិរី ដូចព្រះចន្ទក្នុងសរទរដូវប្រវែង ៣ គាវុត បក់ថ្វាយដោយខ្យល់ត្រសៀកៗ ។ ឯសហម្បតីព្រហ្ម ឈរបាំងឆត្រ ដូចព្រះចន្ទពេញវង់ ២ ដួង ប្រវែង ៣ យោជន៍ ខាងលើព្រះមានព្រះភាគ មហាកាឡនាគដែលនាគរបាំ ៨ ម៉ឺនចោមរោម រាយនូវគាថាសាធុការរាប់រយ ឈរនមស្ការព្រះមហាសត្វ ទេវតាក្នុងម៉ឺនចក្កវាឡបូជាដោយផ្កាក្រអូប លម្អិត និងផ្សែងក្រអូបជាដើម នាំគ្នាឈរថ្វាយសាធុការ ។

លំដាប់នោះ ទេវបុត្តមារឡើងជិះដំរីឈ្មោះគិរិមេខលៈ ដែលរាវាំងសត្រូវបាន ជាដំរីដែលប្រដាប់ដោយរតនៈ ល្អគួរមើលក្រៃលែង ដូចកំពូលភ្នំហិមពាន្ត ដែលមានកម្ពស់ ១៥០ យោជន៍ និម្មិតដៃ ១០០០ កាន់អាវុធ

ផ្សេងៗ ដោយការកាន់អាវុធដែលបុគ្គលណាមួយមិនធ្លាប់កាន់ ។ សូម្បីបរិស័ទរបស់មារ មានកម្លាំងកាន់ដាវ ធ្នូ ព្រួញ លំពែង លើកធ្នូ អង្រ្គែ ផាលដែកស្រួច ស្នូ ចម្រូង ដុំថ្ម ដំបង កងដៃ ច្បូក កងចក្រ គ្រឿងពាក់ត្រង់ករបស់មានមុខមុត និម្មិតមុខដូចប្រើស រាជសីហ៍ រមាស សរភៈ ជ្រូក ខ្លាធំស្វា ពស់ ឆ្មា មានមុខដូចមៀម ក្របី ក្ដាន់ សេះ ដំរីញីជាដើម មានកាយផ្សេងៗ គួរខ្លាច គួរស្ញើម គួរខ្ពើម មានកាយដូចមនុស្ស យក្ខ បិសាចហាក់ដូចជន់លិចព្រះមហាសត្វ ដែលគង់ត្រង់គល់ពោធិព្រឹក្ស ឈរចោមរោម រង់ចាំស្ដាប់ពាក្យបញ្ជារបស់មារ ។

បន្ទាប់អំពីនោះ កាលកម្លាំងរបស់មារចូលទៅកាន់ពោធិមណ្ឌលដ្ឋានបណ្ដាទេវតាទាំងនោះ មានសក្កៈជាដើម សូម្បីតែទេវតាមួយអង្គក៏មិនអាចឈរបាន ។ ទេវតាទាំងឡាយ នាំគ្នាគេចទៅតាមផ្លូវដែលមានចំពោះមុខនោះឯង សក្កទេវរាជ ផ្លុំវិជយុត្តរស័ង្ខ ឲ្យនៅអំពីខាងក្រោយ គេចទៅឈរត្រង់ក្ដឹកណ្ដាប់ចក្កវាឡ ។ មហាព្រហ្មដាក់ឆត្រត្រង់ចុងកណ្ដាប់ចក្កវាឡហើយទៅកាន់ព្រហ្មលោក ។ កាឡនាគរាជបោះបង់អ្នករបាំទាំងអស់ ជ្រែកដីទៅកាន់មញ្ជេរិកនាគពិភពដែលមានទំហំ ៥០០ យោជន៍ ដេកយកដៃក្ដោបមុខ មិនមានសូម្បីតែទេវតាមួយអង្គដែលអាចនៅក្នុងទីនោះបាន ។ ឯព្រះមហាបុរសគង់តែមួយអង្គឯង ដូចមហាព្រហ្មក្នុងវិមានទទេ ។ និមិត្តអាក្រក់ ដែលមិនគួរប្រាថ្នាមកប្រាកដមុននោះឯងថា ឥឡូវនេះ មារនឹងមក ដូច្នេះ ។

កាលចម្បាំងរបស់ស្តេចមារ ពួជអ្នកប្រមាទ និងព្រះតិលោក-
ពន្ធុ កំពុងប្រព្រឹត្តទៅ ឧត្បាតដ៏អាក្រក់ ក៏ធ្លាក់ចុះដោយជុំវិញ
ទិសទាំងឡាយ ក៏ងងឹតដោយផ្សេង ៗ

ផែនដីនេះ មិនមានចិត្ត ក៏ដូចមានចិត្ត ដល់នូវវិយោគ ដូច
ស្រ្តីព្រាត់ប្តី ផែនដីដែលទ្រទ្រង់នូវស្រះផ្សេងៗ មួយអន្លើ
ដោយសាគរ ក៏ញាប់ញ័រ ដូចវល្លិត្រូវខ្យល់ខ្លាំងបក់ផាត់ ។

មហាសមុទ្រមានទឹករញ្ជួយ ស្ទឹងទាំងឡាយក៏ហូរជោរជន់
ដើមឈើទាំងឡាយលើភ្នំទាំងឡាយ ក៏ទោរទន់ដួលដល់ដី ។

ខ្យល់ដ៏អាក្រក់បោកបក់ដោយជុំវិញ មានសំឡេងគគ្រឹក
គគ្រេង ភាពងងឹតក៏ផ្សាយទៅ សត្វដែលឥតក្បាលក៏ត្រាច់
ទៅកណ្តាលអាកាស ។

បានឮថា ឧត្បាតដ៏ពន្លឹកដូចពោល មិនគួរត្រេកអរ មិន
គួរប្រាថ្នា ទាំងនៅក្នុងអាកាស និងនៅត្រង់ផែនដីដ៏ច្រើន ក៏
មាននៅជុំវិញក្នុងខណៈដែលមារមក ។

ឯពួកទេវតាទាំងឡាយ ឃើញមារបំណងនឹងប្រហារព្រះ
មហាសត្វ ជាទេវតានៃទេវតា ក៏មានសេចក្តីករុណា មួយ
អន្លើដោយពួកទេវតា នាំគ្នាធ្វើនូវសំឡេងថា ហា ហា ។

ក្រោយមក ក៏ឃើញមារនោះ មួយអន្លើដោយពលដ៏ច្រើន
ដែលហ្វឹកហាត់មកល្អហើយ នាំគ្នារត់ទៅកាន់ទិសតូច និង

ទិសធំ អាវុធក្នុងដៃក៏ធ្លាក់ទៅ ។

ព្រះសាស្តាមានយសធំ ជាបុគ្គលក្លៀវក្លា ប្រាសចាកភ័យ

អង្គុយកណ្តាលពលមារ ដូចស្តេចគ្រុឌនៅកណ្តាលហ្វូងបក្សី

ដូចរាជសីហ៍ដ៏អង់អាច នៅកណ្តាលហ្វូងម្រឹគ ដូច្នោះ ។

គ្រានោះ មារគិតថា នឹងញុំាងព្រះសិទ្ធត្ថឲ្យខ្លាច ហើយរត់ទៅ តែមិនអាចឲ្យព្រះពោធិសត្វ គេចទៅដោយឫទ្ធិរបស់មារទាំង ៩ ប្រការ គឺខ្យល់ព្យុះ ១ ភ្លៀងគ្រឿងប្រហារ ១ ភ្លៀងដុំថ្ម ១ ភ្លៀងរងើកភ្លើង ១ ភ្លៀងផេះ ១ ភ្លៀងខ្សាច់ ១ ភ្លៀងភក់ ១ ភាពងងឹត ១ ភ្លៀងទឹកក្រុដ ១ ទើបមានចិត្តខឹងក្រោធ បញ្ជាពួកមារថា ពួកអ្នកបង្អង់នៅធ្វើអ្វី ចូរធ្វើសិទ្ធត្ថ កុំឲ្យជាសិទ្ធត្ថ ចូរចាប់ ចូរសម្លាប់ ចូរកាត់ ចូរចង ចូរកុំលែង ចូរឲ្យរត់ទៅ ឯខ្លួនឯងអង្គុយលើ-កដំរីឈ្មោះគិរិមេខលៈ ប្រើដៃម្ខាងគ្រវីព្រួញ ចូលទៅរកព្រះពោធិសត្វ ពោលថា នែសិទ្ធត្ថ ចូរក្រោកឡើងចាកបល្ល័ង្ក ទាំងពួកមារ ក៏បានធ្វើការបៀតបៀនដ៏ខ្លាំងក្លាដល់ព្រះមហាសត្វ ។

គ្រានោះ ព្រះមហាបុរសត្រាស់ពាក្យជាដើមថា ម្នាលមារ អ្នកបំពេញបារមីដើម្បីបល្ល័ង្កពីកាលណា ហើយទ្រង់បង្អោនព្រះហស្តស្តាំទៅកាន់ប្រឹថពី ខណៈនោះឯង ខ្យល់ និងទឹកទ្រផែនដី ដែលមានកម្រាស់ ១ លាន ១ ម៉ឺន ៤ ពាន់យោជន៍ក៏ញាប់ញ័រ បន្ទាប់អំពីនោះ មហាប្រឹថពីនេះដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ក៏ញាប់ញ័រអស់ ៦ ដង ។ ផ្គរបន្ទោរក៏វាសផ្ទៀលឆ្វាត់ អសនីបាតរាប់ពាន់ក៏ធ្លាក់ចុះអំពីអាកាស ។ លំដាប់នោះ ដំរីគិរិមេខលៈ

ក៏លុតជង្គង់ ។ មារដែលអង្គុយលើគិរិមេខលៈ ក៏ធ្លាក់ចុះមកលើផែនដី សូម្បីពលមារក៏ខ្ចាត់ខ្ចាយទៅក្នុងទិសតូចធំ ដូចអង្កាមដែលខ្ចាយទៅ ដូច្នោះ ។

លំដាប់នោះ ព្រះមហាបុរសទ្រង់កម្ចាត់កម្លាំងរបស់មារ ព្រមទាំងមារនោះ ដោយអានុភាពបារមីទាំងឡាយរបស់ព្រះអង្គ មានខន្តី មេត្តា វីរិយៈ និងបញ្ញាជាដើម ក្នុងបឋមយាម ទ្រង់រឭកដល់ខន្ធដែលធ្លាប់អាស្រ័យមកពីមុន ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងបច្ចូសសម័យថ្ងៃជិតរះ ទ្រង់ញ៉ាំងញាណឲ្យធ្លាក់ចុះក្នុងបច្ចយាការ ដែលព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់បដិបត្តិមក ទ្រង់ញ៉ាំងចតុត្ថជ្ឈាន មានអានាបានស្សតិជាអារម្មណ៍ឲ្យកើតហើយ ទ្រង់ធ្វើចតុត្ថជ្ឈាននោះឲ្យជាបាទហើយ ទ្រង់ចម្រើនវិបស្សនា ទ្រង់ញ៉ាំងកិលេសទាំងពួង ឲ្យអស់ទៅដោយមគ្គទី ៤ ដែលទ្រង់សម្រេចតាមលំដាប់មគ្គ ទ្រង់ចាក់ធ្លុះនូវគុណទាំងពួង ដែលព្រះពុទ្ធគ្រប់អង្គទ្រង់បដិបត្តិមក ទ្រង់បន្លឺឧទានថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណវល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺ តណ្ហា អ្នកធ្វើផ្ទះ គឺ អត្តភាព ក៏
អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើត
ជាទុក្ខរឿយៗ ។
នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺ អត្តភាព តថាគតឃើញហើយ
អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹង
ជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់

ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ ។

## សត្តកៅតិបាន

ព្រះមានព្រះភាគ កាលគង់ឧទានហើយ ក៏ទ្រង់មានព្រះតម្រិះថា អាត្មាអញអន្ទោលទៅមកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ព្រោះហេតុនៃបល្ល័ង្កនេះៗ ជាវិជយបល្ល័ង្ក មង្គលបល្ល័ង្ករបស់អញ អញអង្គុយលើបល្ល័ង្កនេះ ការត្រិះរិះមិនបរិបូណ៌ដរាបណា អញក៏មិនក្រោកឡើងចាកបល្ល័ង្កនេះដរាបនោះ ទ្រង់ចូលសមាបត្តិច្រើនសែនកោដិ គង់លើបល្ល័ង្កនោះអស់ ៧ ថ្ងៃ ដែលលោកពោល ( ក្នុងវិនយបិដកមហាវគ្គ ) ថា គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់ដោយព្រះភ្នែនតែមួយអស់ ៧ ថ្ងៃ ក្រោមម្លប់ពោធិព្រឹក្សទ្រង់សោយវិមុត្តិសុខ ( គឺសុខក្នុងផលសមាបត្តិ ) ដូច្នេះ ។

គ្រានោះ ទេវតាពួកខ្លះកើតបរិវិតក្កថា ថ្ងៃនេះ ព្រះសិទ្ធត្ថ ក៏នៅមានកិច្ចដែលត្រូវធ្វើពិត ព្រោះទ្រង់មិនទាន់លះអាល័យក្នុងបល្ល័ង្ក ។ លំដាប់នោះព្រះសាស្តាទ្រង់ជ្រាបវិតក្ករបស់ទេវតាទាំងឡាយ ក៏ហោះឡើងទៅកាន់អាកាសទ្រង់សម្តែងយមកប្បាដិហារ្យ ដើម្បីរម្ងាប់សេចក្តីត្រិះរិះរបស់ទេវតាទាំងនោះ

កាលទ្រង់រម្ងាប់សេចក្តីត្រិះរិះរបស់ទេវតាទាំងឡាយ ដោយបាដិហារ្យនេះ យ៉ាងនេះហើយ ទ្រង់ឈរក្នុងចំណែកទិសឧត្តរ ចៀងទិសខាងកើតបន្តិច អំពីបល្ល័ង្ក ទ្រង់ត្រិះរិះថា តថាគតត្រាស់ដឹងសព្វញ្ញុតញ្ញាណក្នុងបល្ល័ង្កនេះហើយហ្ន៎ ទ្រង់ទតបល្ល័ង្ក និងពោធិព្រឹក្សដែលជាទីសម្រេចផលនៃបារមីទាំងឡាយ ដែលទ្រង់បំពេញមកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ដោយព្រះនេត្រមិនប៉ប្រិច ទ្រង់សម្លឹងមើលអស់ ៧ ថ្ងៃ ទីនោះ មានឈ្មោះថា **អនិមិសចេតិយ** ។

លំដាប់នោះ ទ្រង់និម្មិតទីចង្រ្កមចន្លោះបល្ល័ង្ក និងទីទ្រង់ឈរ ទ្រង់យាងចង្រ្កមក្នុងរតនចង្រ្កម ត្រឡប់ទៅត្រឡប់មក ខាងមុខខាងក្រោយ ទ្រង់ប្រើពេលអស់ ៧ ថ្ងៃ ទីនោះ ឈ្មោះថា **រតនចង្កមចេតិយ** ។

តែក្នុងសប្តាហ៍ទី ៤ ទេវតាទាំងឡាយនិម្មិតរតនឃរៈ គឺផ្ទះកែវ ក្នុងទិសពាយព្យអំពីពោធិព្រឹក្ស ទ្រង់គង់ពត់ភ្នែន ក្នុងផ្ទះកែវនោះ ទ្រង់ពិចារណាព្រះអភិធម្មបិដក ទ្រង់ប្រើពេលអស់ ៧ ថ្ងៃ ទីនោះ ឈ្មោះថា **រតនឃរចេតិយ** ។

ព្រះមានព្រះភាគ ទ្រង់សម្ងំនៅអស់ ៤ សប្តាហ៍ក្បែរពោធិព្រឹក្សយ៉ាងនេះហើយ ក្នុងសប្តាហ៍ទី ៥ ទ្រង់ចេញអំពីគល់ពោធិព្រឹក្ស ចូលទៅកាន់ដើមអជបាលនិគ្រោធ ទ្រង់គង់ពិចារណាធម៌ និងសោយវិមុត្តិសុខ ត្រង់ដើមអជបាលនិគ្រោធនោះ ។

ព្រះសាស្តា កាលទ្រង់សម្ងំត្រង់ដើមអជបាលនិគ្រោធនោះអស់ ៧ ថ្ងៃ

ហើយ ក៏យាងទៅកាន់គល់មុច្ចលិន្ទ គឺដើមរាំងអន្ទក់ ក្នុងទីនោះ ស្ដេចនាគឈ្មោះមុច្ចលិន្ទ ធ្វាយវង្វេល ៧ ជាន់ជុំវិញ ដើម្បីការពារវង្វាជាដើម កាលភ្លៀងរលឹម ៧ ថ្ងៃ ព្រះសាស្ដាសោយវិមុត្តិសុខ ដូចទ្រង់គង់នៅក្នុងព្រះគន្ធកុដិ ដែលមិនចង្អៀត ទ្រង់សម្ងំនៅត្រង់គល់មុច្ចលិន្ទនោះ ៧ ថ្ងៃ ទើបចូលទៅកាន់គាល់រាជាយតនៈ គឺដើមកែស ទ្រង់គង់សោយវិមុត្តិសុខក្នុងទីនោះអស់ ៧ ថ្ងៃ ។ ៧ សប្ដាហ៍កន្លងទៅដោយបរិបូណ៌ ដោយប្រការដូច្នេះ ។ ក្នុងចន្លោះនេះ ព្រះមានព្រះភាគ មិនមានការខ្ពុរព្រះឱស្ឋ មិនមានកិច្ចបដិបត្តិសរីរកិច្ច មិនមានការសោយព្រះក្រយាហារ ទ្រង់សម្ងំនៅដោយសុខក្នុងផលតែម្យ៉ាង ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ជម្រះព្រះឱស្ឋ ដោយឈើស្ទន់ឈ្មោះនាគលតា និងដោយទឹកក្នុងអនោតត្តស្រះ ដែលសក្កទេវរាជស្ដេចទេវតា ទ្រង់ថ្វាយក្នុងថ្ងៃទី ៤៩ ដែលជាថ្ងៃចុងក្រោយនៃសប្ដាហ៍ទី ៧ ទ្រង់គង់ត្រង់ដើមរាជាយតនៈនោះឯង ។

សម័យនោះ ពាណិជ្ជបងប្អូនឈ្មោះតបុស្សៈ និងភល្លិកៈ ដែលទេវតាជាញាតិសាលោហិតឲ្យប្រឹងប្រែងក្នុងការថ្វាយទានដល់ព្រះសាស្ដា កាន់យកសដូវជុំ និងសដូវផង់ ចូលទៅគាល់ព្រះសាស្ដា ឈរក្រាបទូលថា សូមព្រះមានព្រះភាគទ្រង់អាស្រ័យសេចក្ដីករុណា មេត្តាទទួលកត្តនេះផងចុះ ។ ព្រោះបាត្រដែលពួកទេវតាថ្វាយ កាលទ្រង់ទទួលមធុបាយាសអន្តរធានទៅ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ព្រះតថាគតទាំងឡាយ មិនទទួលអាហារដោយដៃទេ តថាគតគប្បីទទួលកត្តនេះបានដូចម្ដេចហ្ន៎ ។

កាលនោះ មហារាជ ៤ អង្គ មកអំពីទិសទាំង ៤ ដឹងអធ្យាស្រ័យព្រះមានព្រះភាគ ក៏បង្អោនបាត្រ ៤ ដែលសម្រេចដោយកែវមណី និងកែវមកថ្វាយ ព្រះមានព្រះភាគ ទ្រង់ហាមនូវបាត្រទាំងនោះ ។ ទើបស្តេចចាតុម្មហារាជបង្អោនបាត្រ ៤ សម្រេចដោយថ្ម មានពណ៌ដូចសណ្តែកបាយ ។ ព្រះមានព្រះភាគទ្រង់អាស្រ័យនូវសេចក្តីករុណា ទេវតាទាំង ៤ អង្គនោះ ទើបទ្រង់ទទួល ហើយតម្រួតបាត្រទាំង ៤ ទ្រង់អធិដ្ឋានឲ្យជាបាត្រតែមួយ ទទួលអាហារដាក់ក្នុងបាត្រ ដែលសម្រេចដោយសិលា មានតម្លៃច្រើននោះ សោយហើយទ្រង់ធ្វើអនុមោទនា ។ ពាណិជ្ជទាំង ២ នាក់នោះ ដល់នូវព្រះពុទ្ធ និងព្រះធម៌ជាសរណៈ ជាទ្វេវាចិកឧបាសក ( ឧបាសកដែលដល់នូវព្រះពុទ្ធ និងព្រះធម៌ជាទីពឹងទីរឭក ) ។

លំដាប់នោះ ព្រះសាស្តាយាងទៅកាន់ដើមអជបាលនិគ្រោធម្តងទៀត ទ្រង់គង់ត្រង់ដើមអជបាលនិគ្រោធនោះ ក្នុងទីនោះ ទ្រង់ពិចារណាថា ធម៌ដែលតថាគតត្រាស់ដឹងនោះ ជាធម៌ជ្រាលជ្រៅ ទ្រង់មានបរិវិតក្កដែលព្រះពុទ្ធគ្រប់អង្គទ្រង់បដិបត្តិមក ដល់នូវអាការ គឺមានពុទ្ធបំណងមិនសម្តែងធម៌ប្រោសអ្នកដទៃ ដោយន័យជាដើមថា ធម៌ដែលតថាគតត្រាស់ដឹងហើយនេះដូច្នេះ ។ គ្រានោះ សហម្បតីព្រហ្មត្រិះរិះថា លោកអន្តរធានហើយហ្ន៎ លោកអន្តរធានហើយហ្ន៎ ក៏នាំសក្កទេវរាជស្តេចសុយាមស្តេចសន្តុសិត ស្តេចនិម្មានរតី ស្តេចបរនិម្មិតវសវត្តី និងមហាព្រហ្ម ក្នុងម៉ឺនចក្កវាឡ មកកាន់សម្នាក់ព្រះសាស្តាទូលអារាធនាឲ្យទ្រង់សម្តែងធម៌ ដោយន័យជាដើមថា បពិត្រ

ព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សម្ដែងធម៌ ដូច្នេះ ។

ព្រះសាស្ដាប្រទានបដិញ្ញាដល់សហម្បតីព្រហ្មនោះហើយ ទ្រង់ព្រះតម្រិះថា តថាគតគួរសម្ដែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបស និងឧទកតាបសធ្វើកាលកិរិយាហើយ ទ្រង់ប្រារព្ធបញ្ចវគ្គិយនៅក្នុងហើយ ដាក់ព្រះហឫទ័យថា បញ្ចវគ្គិយភិក្ខុទាំងឡាយ មានឧបការៈច្រើនដល់តថាគត ដូច្នេះ ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងឡាយនៅឯណា ក៏ទ្រង់ជ្រាបថា នៅត្រង់ឥសិបតនមិគទាយវ័ន ក្រុងពារាណសី ទ្រង់ព្រះតម្រិះថា តថាគតនឹងទៅកាន់ទីនោះ សម្ដែងធម្មចក្ក ហើយទ្រង់ត្រាច់បិណ្ឌបាត ទ្រង់គង់នៅជិតពោធិមណ្ឌលដ្ឋាននោះឯងអស់ ២-៣ ថ្ងៃ ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ទ្រង់មានព្រះតម្រិះនឹងយាងទៅកាន់ក្រុងពារាណសី ទ្រង់កាន់បាត្រ និងចីវរ ធ្វើដំណើរអស់ចម្ងាយផ្លូវ ១៨ យោជន៍ ។ ក្នុងរវាងផ្លូវ ទ្រង់ជួបអាជីវកឈ្មោះឧបកៈ ធ្វើដំណើរបញ្ច្រាស់ផ្លូវមក ទ្រង់ប្រាប់អាជីវកនោះថា ព្រះអង្គជាព្រះពុទ្ធ ។ វេលាល្ងាចថ្ងៃនោះឯង ទ្រង់យាងដល់ព្រៃឥសិបតនមិគទាយ-វ័ន ក្រុងពារាណសី ។

ឯបញ្ចវគ្គិយភិក្ខុ ឃើញព្រះតថាគតយាងមកអំពីចម្ងាយ ទើបឲ្យសញ្ញាគ្នាថា អាវុសោ សមណគោតមនេះ វិលមកដើម្បីភាពជាបុគ្គលប្រាថ្នាច្រើន ដោយបច្ច័យ មានកាយបរិបូណ៌ មានឥន្ទ្រិយស្កប់ស្កល់ មានពណ៌សម្បុរដូចមាសយាងមក យើងកុំធ្វើអភិវាទជាដើមដល់លោក គ្រាន់តែក្រាលអាសនៈ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវារៈចិត្តរបស់បញ្ចវគ្គិយភិក្ខុទាំងនោះ

ទ្រង់ផ្សាយមេត្តាចិត្តដែលអាចផ្សាយទៅដោយមិនចំពោះក្នុងសព្វសត្វ មកជាមេត្តាចិត្តដោយចំពោះ ។ បញ្ចវគ្គិយទាំងនោះ កាលមេត្តាចិត្តរបស់ព្រះមានព្រះភាគពាល់ត្រូវហើយ កាលព្រះតថាគតយាងចូលទៅរក ក៏មិនអាចតាំងនៅក្នុងកតិការបស់ខ្លួនបាន នាំគ្នាធ្វើកិច្ចសព្វយ៉ាង មានការថ្វាយបង្គំជាដើម ។ សេចក្ដីពិស្ដារ គប្បីជ្រាបតាមន័យដែលលោកពោលហើយ ក្នុងមហាវគ្គនៃគម្ពីរវិន័យជាដើម ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ញុំាងបញ្ចវគ្គិយភិក្ខុទាំងនោះឲ្យដឹងដល់ភាពជាព្រះពុទ្ធរបស់ព្រះអង្គហើយ ទ្រង់គង់លើពុទ្ធាសនៈយ៉ាងល្អ ដែលគេក្រាលហើយ កាលប្រកបដោយនក្ខត្តឫក្សខែអាសាឍ ដែលព្រហ្ម ១៨ កោដិចោមរោមហើយ ទ្រង់ហៅបញ្ចវគ្គិយត្ថេរមកហើយ សំម្ដែងព្រះធម្មចក្កប្បវត្តនសូត្រ បណ្ដាបញ្ចវគ្គិយភិក្ខុទាំងនោះ អញ្ញាកោណ្ឌញ្ញៈ បញ្ជូនញាណទៅតាមក្រសែទេសនា លុះចប់សូត្រ ក៏តាំងនៅក្នុងសោតាបត្តិផលមួយអន្លើដោយព្រហ្ម ១៨ កោដិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

> ក្នុងកាលឥឡូវនេះ តថាគតជាព្រះសម្ពុទ្ធ ព្រះនាមគោតម
> ចម្រើនក្នុងត្រកូលសក្យៈ តាំងព្យាយាមដល់សម្ពោធិញ្ញាណ
> ឧត្ដម ។ តថាគតមានចិត្តស្ងប់រម្ងាប់ ត្រូវព្រហ្មអារាធនា
> ហើយ ក៏ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ពួកបរិស័ទ ១៨ កោដិ
> បានត្រាស់ដឹងគ្រាដំបូង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អហំ** ទ្រង់សំដែងដល់ព្រះអង្គឯង ។ បទថា **ឯតរហិ** បានដល់ ក្នុងកាលនេះ ។ បទថា **សក្យវឌ្ឍនោ** បានដល់ ដែលចម្រើនក្នុងត្រកូលសក្យៈ ។ បាឋៈថា **សក្យបុង្គវោ** ( ជាធំនៃសក្យៈ ) ដូច្នេះក៏មាន ។ សេចក្ដីព្យាយាម លោកហៅថា **បធាន** ។ បទថា **បធ-ហិត្វាន** បានដល់ ប្រឹងប្រែងព្យាយាម អធិប្បាយថា ធ្វើទុក្ករកិរិយា ។ បទថា **អដ្ឋារសន្នំ កោដីនំ** សេចក្ដីថា ការត្រាស់ដឹងធម៌លើកទី ១ មានដល់ព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញត្ថេរជាប្រធាន ដោយការត្រាស់ធម្មចក្កប្បវត្តនសូត្រ ក្នុងព្រៃឥសិបតនមិគទាយវ័ន ក្រុងពារាណសី ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ការសម្រេចធម៌ ដែលកន្លងមកហើយ កាលនឹងត្រាស់ការសម្រេចធម៌ដែលមិនទាន់មកដល់ ទើបត្រាស់ពាក្យជាដើមថា

> លំដាប់តទៅ កាលតថាគតសំដែងធម៌ដទៃទៀត ក្នុងការប្រជុំ
> នៃពួកមនុស្ស និងទេវតា ការត្រាស់ដឹងគ្រាទី ២ គេមិន
> គប្បីពោលដោយការរាប់បានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នរទេវសមាគមេ** សេចក្ដីថា សម័យដទៃក្រៅអំពីនោះ ក្នុងមហាមង្គលសមាគម កណ្ដាទេវតា និងមនុស្ស ក្នុងម៉ឺនចក្រវាឡ កាលចប់មង្គលសូត្រ ការត្រាស់ដឹងធម៌មានដល់មនុស្ស និងទេវតាហួសនឹងគណនាបាន ។ បទថា **ទុតិយាភិសមយោ អហុ** បានដល់ នឹងមាន ។ គប្បីពោលពាក្យអនាគតកាលថា **ហេស្សតិ** តែក៏ពោលពាក្យ

ជាអតីតកាលថា **អហុ** ព្រោះធ្លាក់ចូលក្រសែហើយ ។ ឬនឹងពោលថា ជាកាលវិបល្លាសក៏បាន ។ ក្នុងពាក្យក្រៅអំពីនេះ និងពាក្យដូច្នេះ ក៏ន័យនេះឯង ។ បន្តមកទៀត ក្នុងការទ្រង់សម្ដែងរាហុលោវាទសូត្រ ទ្រង់ញ៉ាំងសត្វហួសនឹងរាប់ឲ្យផឹកអមតៈ គឺការសម្រេចធម៌ នេះជាការត្រាស់ដឹងធម៌លើកទី ៣ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ឥឡូវនេះ តថាគតបានទូន្មានកូនរបស់តថាគតក្នុងទីនេះ ការត្រាស់ដឹងគ្រាទី ៣ បុគ្គលមិនគប្បីពោលដោយការរាប់បានឡើយ ដូច្នេះ ។

បានឮថា ព្រះមានព្រះភាគទ្រង់មានសាវកសន្និបាត គឺប្រជុំសាវកតែម្ដងប៉ុណ្ណោះ គឺទ្រង់ប្រជុំព្រះអរហន្តសាវក ១២៥០ រូប គឺជដិល ៣ នាក់បងប្អូន មានព្រះឧរុវេលកស្សបៈជាដើម ១០០០ រូប អគ្គសាវកទាំងពីរ ២៥០ រូប ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ការប្រជុំសាវករបស់តថាគត អ្នកស្វែងរកគុណដ៏ប្រសើរ មានតែមួយដង គឺប្រជុំពួកភិក្ខុ ១២៥០ របស់តថាគត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯកោសិ** កាត់បទជា **ឯកោវ អាសិ** គឺមានតែម្ដងប៉ុណ្ណោះ ។ បទថា **អឌ្ឍតេឡសសតានំ** បានដល់ សាវករបស់តថាគត ១២៥០ រូប ។ បទថា **ភិក្ខុនាសិ** កាត់បទជា **ភិក្ខូនំ អាសិ** ។ ព្រះមានព្រះភាគគង់នៅកណ្ដាលភិក្ខុសាវកទាំងនោះ ទ្រង់លើកបាតិមោក្ខឡើងសម្ដែងក្នុងចតុរង្គសន្និបាត ។

គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រវត្តិរបស់ព្រះអង្គ ទើបត្រាស់ពាក្យជាដើមថា

តថាគតរុងរឿង មិនមានមន្ទិល នៅក្នុងកណ្តាលនៃសង្ឃ ឲ្យ
សេចក្តីប្រាថ្នាទាំងពួង គឺបុគ្គលប្រាថ្នាហើយ ដូចជាកែវមណី
ដែលអាចឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិរោចមានោ** បានដល់ រុងរឿងដោយព្រះពុទ្ធសិរីដែលមិនមានទីបំផុត ។ បទថា **វិមលោ** បានដល់ ប្រាសចាកមន្ទិលគឺកិលេស មានរាគៈជាដើម ។ បទថា **មណីវ សព្វកាមទោ** សេចក្តីថា តថាគតឲ្យនូវសុខវិសេស ទាំងជាលោកិយ និងលោកុត្តរសព្វយ៉ាង ដែលសាវកប្រាថ្នា ដូចកែវចិន្តាមណីឲ្យសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ដូច្នេះ ។

ឥឡូវនេះ កាលទ្រង់សម្តែងសេចក្តីប្រាថ្នាដែលសាវកប្រាថ្នា ទើបត្រាស់ពាក្យជាដើមថា

តថាគតប្រកាសសច្ចៈទាំង ៤ ដើម្បីអនុគ្រោះដល់ពួកសត្វ
ដែលប្រាថ្នានូវផល លះបង់នូវឆន្ទៈក្នុងភព ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ផលំ** បានដល់ ។ ផល ៤ មានសោតាបត្តិផលជាដើម ។ បទថា **ភវច្ឆន្ទជហេសិនំ** បានដល់ លះនូវភវតណ្ហាដែលត្រូវការលះភវតណ្ហា ។ បទថា **អនុកម្បាយ** បានដល់ ដោយសេចក្តីអនុគ្រោះ គឺសេចក្តីករុណា ។

ឥឡូវនេះ កាលទ្រង់ធ្វើការប្រកាសសច្ចៈ ៤ កាលទ្រង់សម្តែងការ

ត្រាស់ដឹងធម៌ ទើបត្រាស់ថា **ទសវីសសហស្សានំ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ទសវីសសហស្សានំ** បានដល់ មួយម៉ឺននិងពីរម៉ឺន[១] អធិប្បាយថា ដោយន័យជាដើមថា ១ ម៉ឺន ២ ម៉ឺន ។ ក្នុងគាថាទី ៩ និងទី ១០ មានអត្ថងាយយល់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១១ និងទី ១២ ដូចតទៅនេះ សូម្បីពីរបទថា **ឥធាគតរហិ** សេចក្ដីក៏ដូចគ្នា ។ ទ្រង់ត្រាស់ដូចបុរសបុគ្គលដោយជាវេនេយ្យសត្វ ។ ម្យ៉ាងទៀត **ឥធាតិ** បានដល់ ក្នុងកាលតថាគតកើតឡើងហើយ ។ បទថា **ឯតរហិ** បានដល់ ក្នុងកាលតថាគតសម្ដែងធម៌ ។ បទថា **អបត្តមានសា** បានដល់ ដែលមិនទាន់សម្រេចអរហត្តផល ។ បទថា **អរិយញ្ជសំ** បានដល់ អរិយមគ្គមានអង្គ ៨ ។ បទថា **ថោមយន្តា** បានដល់ កាលសរសើរ ។ បទថា **ពុជ្ឈិស្សន្តិ** សេចក្ដីថា នឹងចាក់ធ្លុះនូវសច្ចធម៌ ៤ ក្នុងអនាគតកាល ។ បទថា **សំសារ សរិតំ** បានដល់ សាគរគឺសង្សារវដ្ដ ។

ឥឡូវនេះ កាលទ្រង់សម្ដែងដល់នគរ ដែលទ្រង់សម្ភពជាដើមរបស់ព្រះអង្គ ទើបត្រាស់ពាក្យជាដើមថា

---

១- បិដកខ្មែរជា ២ សែន តែអដ្ឋកថា លោកពន្យល់ថា ពាក្យថា ទសវីស-សហស្សានំ បានដល់ ទសសហស្សានញ្ច វីសតិសហស្សានញ្ច ( មួយម៉ឺនផង ពីរម៉ឺនផង ) ។

នគររបស់តថាគត ឈ្មោះកបិលពស្តុ ស្តេចជាព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះមាតាបង្កើតរបស់តថាគត ព្រះនាមមាយាទេវី ។ តថាគតនៅគ្រប់គ្រងព្រះដំណាក់ អស់ ២៩ ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺសុចន្ទប្រាសាទ ១ កោកនុទប្រាសាទ ១ កោញ្ចប្រាសាទ ១ ។ មាននារី ៤ ម៉ឺននាក់ មានខ្លួនប្រដាប់សមរម្យ នារីជាអគ្គមហេសី ព្រះនាមយសោធរា ព្រះរាជបុត្តព្រះនាមរាហុល ។ តថាគតឃើញនិមិត្ត ៤ យ៉ាង ហើយ ក៏ចេញទៅដោយយានសេះ ប្រព្រឹត្តព្យាយាម ធ្វើទុក្ករកិរិយាអស់ ៦ វស្សា ។ តថាគតជាព្រះជិនស្រី បានញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងព្រៃឥសិបតនៈ ទៀបក្រុងពារាណសី តថាគតជាគោតមសម្ពុទ្ធ ជាទីពឹងនៃសត្វទាំងពួង ។ ភិក្ខុ ២ រូប ឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះអានន្ទជាឧបដ្ឋាក អ្នកបម្រើផ្ទាល់របស់តថាគត ។ ភិក្ខុនីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអគ្គសាវិកា ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា តថាគតបានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ទៀបគល់អស្សត្ថព្រឹក្ស ។ តថាគតមានរស្មីមួយព្យាម សព្វៗ កាល មានកម្ពស់ ១៦ ហត្ថ ក្នុងកាលឥឡូវនេះ តថាគតមានអាយុតិច បានតែ

១០០ ឆ្នាំ ។ តថាគតកាលឋិតនៅអស់កាលត្រឹមនោះ បាន ញុំាងប្រជុំជនដ៏ច្រើន ឲ្យឆ្លងចាកសង្សារ ហើយតម្កល់ទុកគប់ភ្លើង គឺធម៌ ដើម្បីញុំាងជនខាងក្រោយឲ្យបានត្រាស់ដឹងផង ។ មិនយូរប៉ុន្មានទេ តថាគត ព្រមទាំងសង្ឃជាសាវ័ក នឹងនិព្វានក្នុងទីនេះ ដូចជាភ្លើងរលត់ ព្រោះអស់អាហារ គឺឧស ។ អគ្គសាវ័កទាំងគូនេះឯង មានតេជះ ថ្លឹងពុំបានផង មានយស និងកម្លាំងឫទ្ធិផង តថាគតមានរាងកាយ ទ្រទ្រង់នូវគុណវិចិត្រដោយលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ រស្មី ៦ ពណ៌ភ្លឺទៅក្នុងទិសទាំង ១០ ដូចព្រះអាទិត្យ របស់ទាំងអស់នេះ នឹងវិនាសសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេទទេតើ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ព្យាករគ្រប់យ៉ាងថា តថាគតមានប្រាសាទ ៣ ឈ្មោះរម្មៈ ១ សុរម្មៈ ១ សុកៈ ១[១] មាន ៩ ជាន់ ៧ ជាន់ និង ៥ ជាន់ មានស្រីស្នំ ៤ ម៉ឺននាក់ មានអគ្គមហេសីព្រះនាមយសោធរា តថាគតនោះ ឃើញនិមិត្ត ៤ ហើយ ចេញមហាភិនេស្ក្រមណ៍ដោយយាន គឺសេះ បន្ទាប់អំពីនោះ ក៏តាំងព្យាយាមអស់ ៦ ឆ្នាំ ក្នុងថ្ងៃវិសាខបុណ្ណមី ក៏សោយមធុបាយាស ដែលធីតាឈ្មោះសុជាតារបស់សេនាកុដុម្ពិកៈ ក្នុងឧរុវេលាសេនានិគម ដែលកើតនូវសេចក្ដីជ្រះថ្លា

---

១- បិដកខ្មែរជា សុចន្ទ ១ កោកនុទ ១ កោញ្ចៈ ១ ។

ថ្វាយហើយ ទ្រង់សម្រាកពេលថ្ងៃក្នុងសាលវ័ន វេលាល្ងាចទទួលស្មៅ ៨ ក្តាប់ ដែលអ្នកប្រូតស្មៅឈ្មោះសោត្ថិយៈថ្វាយ ហើយទ្រង់ចូលកាន់គល់ពោធិព្រឹក្ស ឈ្មោះដើមអស្សត្ថព្រឹក្ស កម្ចាត់មារ និងសេនាក្នុងទីនោះ សម្រេចសម្ពោធិញ្ញាណ ។

បណ្តាបទទាំងនោះ បទថា **សទ្ធឹ សាវកសង្ឃតោ** គឺ **សទ្ធឹ សាវកសង្ឃេន** សេចក្តីថា មួយអន្លើដោយសង្ឃសាវក ។ បទថា **បរិនិព្វិស្សំ** គឺ **បរិនិព្វាយិស្សាមិ** បាទដល់ នឹងបរិនិព្វាន ។ បទថា **អគ្គីវាហារ សង្ខយា** បាទដល់ ដូចភ្លើងរលត់ ព្រោះអស់កំញម ដូច្នោះ អធិប្បាយថា តថាគត មិនមានឧបាទាន នឹងបរិនិព្វាន ដូចភ្លើងអស់កំញមរលត់ទៅ ដូច្នោះ ។

បទថា **តានិ ច អតុលតេជានិ** សេចក្តីថា គូនៃអគ្គសាវកជាដើម មានតេជះមិនមានបុគ្គលស្មើទាំងនោះ ។ បទថា **ឥមានិ ច ទសពលានិ** សេចក្តីថា ទសពលមានក្នុងសរីរៈទាំងនេះ ។ បទថា **គុណធារណោ ទេហោ** សេចក្តីថា ព្រះវរកាយដែលទ្រទ្រង់នូវគុណ មានអសាធារណញ្ញាណ ៦ ជាដើមនេះ ។ បទថា **តមន្តរហិស្សន្តិ** សេចក្តីថា គុណលក្ខណៈដូចពោលមកនេះ នឹងអន្តរធានសោះសូន្យទៅ ។ សព្ទថា **ននុ** ក្នុងបទថា **ននុ រិត្តា សព្វសង្ខារា** នេះ ជានិបាត ចុះក្នុងអត្ថថា អនុមតិតាម ។ បទថា **រិត្តា** បាទដល់ ឈ្មោះថា **រិត្តា** ព្រោះវៀរចាកនិច្ចសារៈ ខ្លឹម គឺការទៀង **ធុវសារៈ** ខ្លឹម គឺការស្ថិតស្ថេរ ។ ធម៌ទាំងអស់នោះឯង ដែលបច្ច័យតាក់តែង មានការអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រែប្រួលទៅជា

ធម្មតា រលត់ទៅជាធម្មតា ឈ្មោះថា មិនទៀង ព្រោះមានហើយ ប្រែជាមិនមាន ។ ឈ្មោះថា ជាទុក្ខ ព្រោះការកើតជាដើមបៀតបៀនហើយ ឈ្មោះថា អនត្តា ព្រោះមិននៅក្នុងអំណាច ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរលើកត្រៃលក្ខណ៍ ក្នុងសង្ខារទាំងឡាយ ហើយចម្រើនវិបស្សនា ចូរសម្រេចព្រះនិព្វានដែលជាទីមិនស្លាប់ បច្ច័យតាក់តែងមិនបាន មិនចុតិ នេះជាអនុសាសនីជាពាក្យប្រៀនប្រដៅរបស់តថាគតសម្រាប់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយញុំាងប្រយោជន៍ឲ្យដល់ព្រម ដោយសេចក្តីមិនប្រមាទចុះ ។ បានឮថា ក្នុងកាលចប់ទេសនា ចិត្តរបស់ទេវតាមួយសែនកោដិ ក៏របួតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ឯទេវតាដែលតាំងនៅក្នុងមគ្គផលក្រៅអំពីនេះ ហួសនឹងគណនារាប់បាន ។

ព្រះមានព្រះភាគទ្រង់ចង្រ្កមលើរតនចង្ក្រមក្នុងអាកាស ត្រាស់ពុទ្ធវង្សទាំងអស់ កំណត់ដោយកប្ប នាម និងជាតិជាដើមយ៉ាងនេះហើយ ញុំាងពួកព្រះញាតិ ឲ្យថ្វាយបង្គំ ហើយចុះអំពីអាកាស គង់លើបវរពុទ្ធាសនៈ ដែលគេរៀបចំហើយ កាលព្រះមានព្រះភាគទ្រង់គង់ហើយយ៉ាងនោះ សមាគមព្រះញាតិក៏ដល់នូវភាពឧត្តម ព្រះញាតិគ្រប់អង្គក៏ប្រថាប់គង់ មានចិត្តជាឯកគ្គតា ។ បន្ទាប់អំពីនោះ មហាមេឃក៏ញុំាងភ្លៀងបោក្ខរព័ស្សឲ្យធ្លាក់ចុះមកខណៈនោះឯង ទឹកក៏ស្រក់ចុះមកខាងក្រោម បុគ្គលណាត្រូវការសើមក៏សើម

បុគ្គលណាមិនត្រូវការសើមក៏មិនសើម ។ ព្រះញាតិទាំងអស់ ឃើញភាពអស្ចារ្យនោះ ក៏ចម្លែកក្នុងចិត្ត នាំគ្នាពោលថា ឱ គួរអស្ចារ្យហ្ន៎ ឱ គួរចម្លែកហ្ន៎ ព្រះសាស្ដាស្ដាប់ពាក្យនោះហើយ ត្រាស់ថា ភ្លៀងបោក្ខរព័ស្ស មិនមែនធ្លាក់ចុះមកក្នុងសមាគមញាតិ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាល ក៏ធ្លាក់ចុះមកដូចគ្នា ព្រោះអត្ថុប្បត្តិហេតុនេះ ទើបទ្រង់ត្រាស់វេស្សន្តរជាតក ព្រះធម្មទេសនានោះ មានប្រយោជន៍ហើយ ។ បន្ទាប់អំពីនោះ ព្រះសាស្ដាទ្រង់ក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ ៕៚

## អដ្ឋកថា គោតមពុទ្ធវង្សទី ២៥ ចប់

# សុត្តន្តបិដក

## ពុទ្ធប្បកិណ្ណកកណ្ឌ

[ ២៧ ] ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ មានព្រះពុទ្ធ ជានាយក ៤ ព្រះអង្គ គឺព្រះសម្ពុទ្ធព្រះនាមតណ្ហង្ករៈ ១ មេធង្ករៈ ១ សរណង្ករៈ ១ ទីបង្ករៈ ១ ព្រះជិនស្រីទាំងនោះ ត្រាស់ក្នុងកប្បជាមួយគ្នា ។ ខាងក្រោយអំពីព្រះពុទ្ធទីបង្ករៈមក ព្រះពុទ្ធជានាយកព្រះនាមកោណ្ឌញ្ញៈ បានត្រាស់តែមួយព្រះអង្គ ក្នុងកប្បមួយ ញុំាងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកសង្សារ ) ។ កប្បជាចន្លោះនៃព្រះពុទ្ធ ២ ព្រះអង្គនុ៎ះ គឺព្រះពុទ្ធទីបង្ករៈមានព្រះភាគ និងព្រះសាស្តាព្រះនាមកោណ្ឌញ្ញៈ ជាកប្បគេមិនអាចរាប់បានឡើយ ។ ខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមកោណ្ឌញ្ញៈមក មានព្រះពុទ្ធជានាយក ព្រះនាមមង្គលៈ ( ទ្រង់ត្រាស់ឡើង ) កប្បជាចន្លោះនៃព្រះពុទ្ធទាំង ២ ព្រះអង្គនុ៎ះ បុគ្គលមិនអាចរាប់បានឡើយ ។ ព្រះពុទ្ធព្រះនាមមង្គលៈ ១ ព្រះសុមនៈ ១ ព្រះរេវតៈ ១ និងព្រះមុនីព្រះនាមសោភិតៈ ១ ព្រះសម្ពុទ្ធទាំងនោះ មានចក្ខុធ្វើនូវពន្លឺ ( បានត្រាស់ឡើង ) ក្នុងកប្បជាមួយគ្នា ។ ខាងក្រោយនៃព្រះសម្ពុទ្ធព្រះនាមសោភិតៈមក មានព្រះពុទ្ធព្រះនាមអនោមទស្សីជាមហាមុនីត្រាស់ឡើងក្នុងលោក កប្បជាចន្លោះនៃព្រះពុទ្ធទាំង ២ អង្គនុ៎ះ គេមិនអាចរាប់បានឡើយ ។ ព្រះនាយកព្រះនាមអនោមទស្សី ១ ព្រះនាមបទុមៈ ១ ព្រះនាមនារទៈ ១ ព្រះពុទ្ធជាមហាមុនីទាំងនោះ

ទ្រង់ធ្វើនូវទីបំផុតនៃងងឹត ( ត្រាស់ឡើង ) ក្នុងកប្បជាមួយគ្នា ។ ខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមនារទៈមក មានព្រះនាយកព្រះនាមបទុមុត្តរៈ កើតឡើងក្នុងកប្បមួយ ញុំាំងប្រជុំជនជាច្រើនឲ្យឆ្លងចាកសង្សារ ។ កប្បជាចន្លោះនៃព្រះពុទ្ធទាំងពីរព្រះអង្គនោះ គឺព្រះមានជោគ ព្រះនាមនារទៈ និងព្រះសាស្តាព្រះនាមបទុមុត្តរៈ គេមិនអាចរាប់បានឡើយ ។ ក្នុងកប្បទីមួយសែន មានតែព្រះមហាមុនីមួយព្រះអង្គ ព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា ដែលគេនាំមកបូជា ។ ក្នុងកប្បទី ៣ ម៉ឺន ខាងអាយព្រះពុទ្ធបទុមុត្តរៈមក មានព្រះនាយក ២ អង្គ ព្រះនាមសុមេធៈ ១ សុជាតៈ ១ ត្រាស់ឡើងក្នុងលោក ។ ក្នុងកប្បទី ១ ពាន់ ៨ រយ ខាងអាយព្រះពុទ្ធព្រះនាមសុជាតៈមក មានព្រះនាយក ៣ អង្គ ព្រះនាមបិយទស្សី ១ អត្ថទស្សី ១ ព្រះនាយកធម្មទស្សី ១ ត្រាស់ឡើងក្នុងលោក ។ ព្រះសម្ពុទ្ធទាំងនោះ ឧត្តមជាងសត្វជើងពីរ ជាព្រះសម្ពុទ្ធ រកបុគ្គលប្រៀបផ្ទឹមគ្មានក្នុងលោក បានត្រាស់ដឹងក្នុងកប្បជាមួយគ្នា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ មានព្រះមហាមុនី ព្រះនាមសិទ្ធត្ថៈតែមួយអង្គ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ជាពេទ្យដ៏ប្រសើរ បានត្រាស់ឡើងក្នុងលោក ។ ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះ ព្រះសម្ពុទ្ធជានាយក ២ ព្រះអង្គ ព្រះនាមតិស្សៈ ១ បុស្សៈ ១ រកបុគ្គលស្មើគ្មាន រក

បុគ្គលប្រៀបផ្ទឹមគ្មាន បានត្រាស់ឡើងក្នុងលោក ។ ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ ព្រះសម្ពុទ្ធព្រះនាមវិបស្សី ជាលោកនាយក ព្រះអង្គប្រកបដោយសេចក្តីករុណា ទ្រង់ដោះសត្វទាំងឡាយ ឲ្យរួចចាកចំណង ( បានត្រាស់ឡើងក្នុងលោក ) ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រះនាយក ២ អង្គ ព្រះនាមសិខី ១ វេស្សភូ ១ រកបុគ្គលស្មើគ្មាន រកបុគ្គលប្រៀបផ្ទឹមគ្មាន ( បានត្រាស់ឡើងក្នុងលោក ) ។ ក្នុងភទ្ទកប្បនេះ ព្រះនាយក ៣ ព្រះអង្គ ព្រះនាមកកុសន្ធៈ ១ កោនាគមនៈ ១ និងព្រះនាយកព្រះនាមកស្សបៈ ១ ( បានត្រាស់ឡើងក្នុងលោក ) ។ ក្នុងកាលឥឡូវនេះ មានតថាគតនេះជាព្រះសម្ពុទ្ធ ទៅក្នុងអនាគតកាល នឹងមានព្រះសម្ពុទ្ធព្រះនាមមេត្តេយ្យ ព្រះសម្ពុទ្ធទាំង ៥ អង្គនេះ ជាអ្នកប្រាជ្ញអនុគ្រោះស្រង់សត្វលោក ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវ័ក លុះប្រាប់ផ្លូវរបស់ព្រះពុទ្ធ ជាធម្មរាជទាំងនុ៎ះ ដល់ពួកសត្វដទៃជាច្រើនកោដិហើយ ក៏បរិនិព្វាន ។

ពុទ្ធប្បកិណ្ណកកណ្ឌ ចប់

# ធាតុភាជនីយកថា

[ ២៨ ] ព្រះមហាគោតម ជាព្រះជិនស្រីប្រសើរ ទ្រង់និព្វានក្នុងនគរកុសិនារា ព្រះធាតុផ្សាយទៅក្នុងប្រទេសនោះៗ តាមចំណែក គឺព្រះធាតុមួយចំណែក បានទៅព្រះបាទអជាតសត្តុ មួយចំណែកបានទៅក្រុងវេសាលី មួយចំណែកបានទៅក្រុងកបិលពស្តុ មួយចំណែកបានទៅដែនអល្លកប្បកៈ មួយចំណែកបានទៅក្រុងរាមគ្រាម មួយចំណែកបានទៅក្រុងវេដ្ឋទីបកៈ មួយចំណែកបានទៅក្រុងបាវេយ្យកមល្លៈ ឯព្រះធាតុមួយចំណែកទៀត បានទៅអ្នកក្រុងកុសិនារា ។ ព្រាហ្មណ៍ឈ្មោះទោណៈ បានធ្វើស្តូបបញ្ចុះតុម្ព ( នាឡិ ) ពួកមោរិយជន មានចិត្តជ្រះថ្លា បានធ្វើស្តូបបញ្ចុះព្រះអង្គា ( ធ្យូង ) ។ ព្រះស្តូបបញ្ចុះព្រះសារីរិកធាតុ មាន ៨ បើរាប់តុម្ពចេតិយមួយផង ជា ៩ បើគិតទាំងព្រះស្តូបបញ្ចុះព្រះអង្គាមួយទៀត ត្រូវជា ១០ ដែលមហាជនស្ថាបនាទុកក្នុងកាលនោះ ។ ព្រះចង្កូម ១ តម្កល់ក្នុងស្ថានត្រៃត្រិង្ស ព្រះចង្កូម ១ តម្កល់ក្នុងនាគបុរី ព្រះចង្កូម ១ នៅក្នុងដែនគន្ធារៈ ព្រះចង្កូម ១ នៅក្នុងដែនកាលិង្គរាជ ។ ព្រះទន្តទាំង ៤០ គត់ ព្រះកេសា និងព្រះលោមាទាំងអស់ ពួកទេវតារៀងខ្លួន បាននាំទៅមួយៗ កាន់ចក្រវាលទីទៃៗ ។ បាត្រ ឈើច្រត់ និងចីវររបស់ព្រះមានព្រះភាគ តម្កល់ទុកនៅក្នុងដែនវជិរ ស្បង់ តម្កល់ទុកនៅក្នុងផ្ទះនៃត្រកូល គ្រឿងកម្រាល តម្កល់ទុកនៅក្នុងក្រុងឈ្មោះសិលៈ ។ ធម្មក្រក និងកាយពន្ធ ( វត្ថពន្ធចង្កេះ ) តម្កល់ទុកនៅក្នុងក្រុងបាដលីបុត្រ

ឧទុកសាដក តម្កល់ទុកនៅក្រុងចម្បា ព្រះឧណ្ណាលោម ( រោមចញ្ចើម ) តម្កល់ទុកនៅក្នុងដែនកោសល ។ សំពត់កាសាវៈ តម្កល់ទុកក្នុងព្រហ្មលោក ឆ្នួត តម្កល់ទុកក្នុងស្ថានត្រៃត្រិង្ស ស្នាមព្រះបាទដ៏ប្រសើរ ដែលមិនបាត់ទៅ តម្កល់ទុកលើថ្ម សំពត់និសីទនៈ តម្កល់ទុកក្នុងអវន្តិជនបទ គ្រឿងកម្រាល តម្កល់ទុកក្នុងដែនឈ្មោះទេវៈ ក្នុងកាលនោះ ។ កាលនោះ ដែកភ្លើង តម្កល់ទុកក្នុងក្រុងមិថិលា តម្រងទឹក តម្កល់ទុកក្នុងដែនវិទេហៈ កាំបិតកោរ និងបំពង់ម្ជុល តម្កល់ទុកនៅក្នុងឥន្ទបត្តបុរី ។ កាលនោះ គ្រឿងបរិក្ខារដ៏សេសទាំងឡាយ តម្កល់ទុកក្នុងជនបទជាទីបំផុត ពួកមនុស្សតែងបូជា ចំពោះគ្រឿងបរិក្ខារទាំងឡាយ ដែលព្រះមុនីទ្រង់ប្រើប្រាស់ ។ ការផ្សាយទៅនៃព្រះធាតុរបស់ព្រះមហេសី ព្រះនាមគោតមក្នុងកាលនោះ ជាប្រពៃណីពីបុរាណ ( នៃព្រះពុទ្ធទាំងឡាយ ) សម្រាប់ទុកអនុគ្រោះ ស្រោចស្រង់សត្វទាំងឡាយ ជាខាងក្រោយ ។

ធាតុភាជនីយកថា ចប់

ពុទ្ធវង្ស ចប់

# អដ្ឋកថា

## ពុទ្ធប្បកិណ្ណកកថាជាដើម

ក្នុង ១៨ គាថា មាន **អបរិមេយ្យិតោ កប្បេ ចតុរោ អាសុំ វិនាយកា** ជាដើម គប្បីជ្រាបថា ជានិគមគាថា ដែលព្រះសង្គីតិកាចារ្យទាំងឡាយរចនា ។ ក្នុងគាថាដ៏សេសគ្រប់អន្លើប្រាកដច្បាស់ហើយ ។

## វេមត្តកថា

ព្រះពុទ្ធ ២៥ ព្រះអង្គ ដែលចង្អុលបង្ហាញក្នុងពុទ្ធវង្សនេះ គប្បីជ្រាបថា មានវេមត្តៈ គឺការផ្សេងគ្នា ៨ យ៉ាង គឺអាយុវេមត្តៈ ១ បមាណវេមត្តៈ ១ កុលវេមត្តៈ ១ បធានវេមត្តៈ ១ រស្មិវេមត្តៈ ១ យានវេមត្តៈ ១ ពោធិវេមត្តៈ ១ បល្លង្កវេមត្តៈ ។

បណ្តាវេមត្តៈទាំងនោះ ឈ្មោះថា **អាយុវេមត្ត** គឺការប្លែកគ្នានៃអាយុបានដល់ ព្រះអង្គខ្លះ ព្រះពុទ្ធអង្គខ្លះ មានព្រះជន្មាយុវែង ព្រះពុទ្ធអង្គខ្លះ មានព្រះជន្មាយុខ្លី ។

ពិតហើយ ព្រះពុទ្ធ ៩ អង្គ គឺព្រះពុទ្ធទីបង្ករ ១ ព្រះកោណ្ឌញ្ញៈ ១ ព្រះអនោមទស្សី ១ ព្រះបទុមៈ ១ ព្រះបទុមុត្តរៈ ១ ព្រះអត្ថទស្សី ១ ព្រះធម្មទស្សី ១ ព្រះសិទ្ធត្ថៈ ១ ព្រះតិស្សៈ ១ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

ព្រះពុទ្ធ ៨ ព្រះអង្គ គឺព្រះពុទ្ធមង្គលៈ ១ ព្រះសុមនៈ ១ ព្រះសោភិតៈ ១ ព្រះនារទៈ ១ ព្រះសុមេធៈ ១ ព្រះសុជាតៈ ១ ព្រះបិយទស្សី ១ ព្រះផុស្សៈ ១ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ព្រះពុទ្ធ ២ ព្រះអង្គ គឺព្រះពុទ្ធរេវតៈ ១ ព្រះវេស្សភូ ១ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ។

ព្រះមានព្រះភាគវិបស្សី មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ។

ព្រះពុទ្ធ ៤ ព្រះអង្គ គឺព្រះពុទ្ធសិខី ១ ព្រះកក្កុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ៤ ម៉ឺនឆ្នាំ ៣ ម៉ឺនឆ្នាំ ២ ម៉ឺនឆ្នាំ តាមលំដាប់ ។

ដោយយុគរបស់ព្រះពុទ្ធទាំងឡាយ ដែលបានសន្សំបុញ្ញសម្ភារ ដែលប្រកបដោយកម្ម ដែលធ្វើឲ្យអាយុវែង អាយុមិនមានប្រមាណ អាយុវេមត្តៈរបស់ព្រះពុទ្ធ ២៥ អង្គ ។

ឈ្មោះថា **បមាណវេមត្ត** គឺការប្លែកគ្នានៃប្រមាណ បានដល់ ព្រះពុទ្ធអង្គខ្លះខ្ពស់ អង្គខ្លះទាប ។ ពិតហើយ ព្រះពុទ្ធទីបង្ករ ១ ព្រះរេវតៈ ១ ព្រះបិយទស្សី ១ ព្រះអត្ថទស្សី ១ ព្រះធម្មទស្សី ១ ព្រះវិបស្សី ១ មានសរីរៈកម្ពស់ ៨០ ហត្ថ ។

ព្រះពុទ្ធកោណ្ឌញ្ញៈ ១ ព្រះមង្គលៈ ១ ព្រះនារទៈ ១ ព្រះសុមេធៈ ១ មានសរីរៈកម្ពស់ ៨៨ ហត្ថ ។

ព្រះសុមនសម្ពុទ្ធ មានសរីរៈកម្ពស់ ៩០ ហត្ថ ។

ព្រះសម្ពុទ្ធសោភិតៈ ១ ព្រះអនោមទស្សី ១ ព្រះបទុមៈ ១ ព្រះបទុមុត្តរៈ ១ ព្រះផុស្សៈ ១ មានសរីរៈកម្ពស់ ៥៨ ហត្ថ ។

ព្រះសម្ពុទ្ធសុជាតៈ មានសរីរៈកម្ពស់ ៥០ ហត្ថ ។

ព្រះសម្ពុទ្ធសិទ្ធត្ថៈ ១ ព្រះតិស្សៈ ១ ព្រះវេស្សភូ ១ មានសរីរៈកម្ពស់ ៦០ ហត្ថ ។

មានសិខីសម្ពុទ្ធ មានសរីរៈកម្ពស់ ៧០ ហត្ថ ។

ព្រះកកុសន្ធសម្ពុទ្ធ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ មានសរីរៈកម្ពស់ ៤០ ហត្ថ ៣០ ហត្ថ ២០ ហត្ថ តាមលំដាប់ ។ ឯព្រះមានព្រះភាគនៃយើង មានសរីរៈកម្ពស់ ១៨ ហត្ថ ។ នេះ ឈ្មោះថា បមាណវេមត្តៈរបស់ព្រះពុទ្ធទាំងឡាយ ២៥ ព្រះអង្គ ។

ដែលឈ្មោះថា **កុលវេមត្ត** គឺការប្លែកគ្នានៃត្រកូល បានដល់ ព្រះពុទ្ធអង្គខ្លះ កើតក្នុងត្រកូលក្សត្រ អង្គខ្លះកើតក្នុងត្រកូលព្រាហ្មណ៍ ពិតហើយ ព្រះសម្មាសម្ពុទ្ធកកុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ កើតក្នុងត្រកូលព្រាហ្មណ៍ ។

ព្រះពុទ្ធ ២២ ព្រះអង្គដ៏សេស មានព្រះពុទ្ធទីបង្ករជាដើម មានព្រះពុទ្ធគោតមជាទីបំផុត កើតក្នុងត្រកូលក្សត្រទាំងអស់ ។

នេះ ឈ្មោះថា កុលវេមត្តៈរបស់ព្រះពុទ្ធ ២៥ ព្រះអង្គ ។

ដែលឈ្មោះថា **បធានវេមត្ត** គឺការប្លែកគ្នានៃសេចក្តីព្យាយាម បានដល់ ព្រះពុទ្ធទីបង្ករ ១ ព្រះកោណ្ឌញ្ញៈ ១ ព្រះសុមនៈ ១ ព្រះអនោមទស្សី ១ ព្រះសុជាតៈ ១ ព្រះសិទ្ធត្ថៈ ព្រះកកុសន្ធៈ ១ ទ្រង់បំពេញព្យាយាមអស់ ១០ ខែ ។

ព្រះសម្ពុទ្ធមង្គលៈ ១ ព្រះសុមេធៈ ១ ព្រះតិស្សៈ ១ ព្រះសិខី ១

ទ្រង់បំពេញព្យាយាមអស់ ៨ ខែ ។

ព្រះរេវតសម្ពុទ្ធទ្រង់បំពេញព្យាយាមអស់ ៧ ខែ ព្រះសោភិតៈ ទ្រង់បំពេញព្យាយាមអស់ ៤ ខែ ។

ព្រះបទុមសម្ពុទ្ធ ១ ព្រះអត្ថទស្សី ១ ព្រះវិបស្សី ១ ទ្រង់បំពេញព្យាយាមអស់កន្លះខែ ។

ព្រះសម្ពុទ្ធនារទៈ ១ ព្រះបទុមុត្តរៈ ១ ព្រះធម្មទស្សី ១ ព្រះកស្សបៈ ១ ទ្រង់បំពេញព្យាយាមអស់ ៧ ថ្ងៃ ។

ព្រះសម្ពុទ្ធបិយទស្សី ១ ព្រះផុស្សៈ ១ ព្រះវេស្សភូ ១ ព្រះកោនាគមនៈ ១ ទ្រង់បំពេញព្យាយាមអស់ ៦ ខែ ។

ព្រះសាស្តានៃយើង ទ្រង់បំពេញព្យាយាមអស់ ៦ ឆ្នាំ នេះ ឈ្មោះថា បធានវេមត្តៈ ។

ដែលឈ្មោះថា **រស្មិវេមត្ត** គឺការប្លែកគ្នានៃព្រះរស្មី បានឮថា ព្រះមង្គលសម្ពុទ្ធ មានរស្មីនៃព្រះសរីរៈផ្សាយទៅក្នុងម៉ឺនលោកធាតុ ។

ព្រះបទុមុត្តរៈផ្សាយទៅ ១២ យោជន៍ ព្រះវិបស្សីផ្សាយទៅ ៧ យោជន៍ ព្រះសិខីផ្សាយទៅ ៣ យោជន៍ ព្រះកកុសន្ធៈផ្សាយទៅ ១០ យោជន៍ ព្រះមានព្រះភាគនៃយើង ផ្សាយទៅ ១ ព្យាម ដោយជុំវិញ ។ ព្រះពុទ្ធក្រៅអំពីនេះ មានរស្មីផ្សាយទៅមិនពិតប្រាកដ ។ ឈ្មោះថា ការផ្សេងគ្នានៃព្រះរស្មីនេះ ទាក់ទងដោយព្រះអធ្យាស្រ័យ ព្រះពុទ្ធអង្គណា ទ្រង់មានបំណងក្នុងព្រះរស្មីប្រមាណប៉ុនណា ព្រះរស្មីនៃព្រះសរីរៈ ក៏ផ្សាយទៅ

ប្រមាណប៉ុណ្ណោះ តែការប្លែកគ្នាក្នុងគុណ គឺការត្រាស់ដឹងរបស់ព្រះពុទ្ធអង្គណាមួយរមែងមិនមាន នេះ ឈ្មោះថា រស្មិវេមត្តៈ ។

ដែលឈ្មោះថា **យានវេមត្ត** គឺការប្លែកគ្នានៃយាន បានដល់ ព្រះសម្ពុទ្ធអង្គខ្លះ ចេញអភិនេស្រ្កមណ៍ដោយយាន គឺដំរី អង្គខ្លះដោយយាន គឺសេះ អង្គខ្លះដោយយាន គឺរថ អង្គខ្លះយាងដោយព្រះបាទ អង្គខ្លះយាងទៅទាំងប្រាសាទ អង្គខ្លះយាងដោយ-វជាដើម ។

ពិតហើយ ព្រះពុទ្ធ គឺព្រះទីបង្ករ ១ ព្រះសុមនៈ ១ ព្រះសុមេធៈ ១ ព្រះផុស្សៈ ១ ព្រះសិខី ១ ព្រះកោនាគមនៈ ១ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយយាន គឺដំរី ។

ព្រះពុទ្ធកោណ្ឌញ្ញៈ ១ ព្រះរេវតៈ ១ ព្រះបទុមៈ ១ ព្រះបិយទស្សី ១ ព្រះវិបស្សី ១ ព្រះកកុសន្ធៈ ១ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយយាន គឺរថ ។

ព្រះពុទ្ធមង្គលៈ ១ ព្រះសុជាតៈ ១ ព្រះអត្ថទស្សី ១ ព្រះតិស្សៈ ១ ព្រះគោតម ១ ទ្រង់យាងទៅដោយយាន គឺសេះ ។

ព្រះពុទ្ធអនោមទស្សី ១ ព្រះសិទ្ធត្ថៈ ១ ព្រះវេស្សភូ ១ ទ្រង់យាងទៅដោយយាន គឺ-វ ។

ព្រះសម្ពុទ្ធនារទៈ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយព្រះបាទ ។

ព្រះពុទ្ធសោភិតៈ ១ ព្រះបទុមុត្តរៈ ១ ព្រះធម្មទស្សី ១ ព្រះកស្សបៈ ១ ទ្រង់ចេញអភិនេស្រ្កមណ៍ដោយប្រាសាទ នេះ ឈ្មោះថា យានវេមត្តៈ ។

ដែលឈ្មោះថា **ពោធិវេមត្ត** គឺការប្លែកគ្នានៃពោធិព្រឹក្ស បានដល់ ព្រះ

មានព្រះភាគទីបង្ករ មានពោធិព្រឹក្សឈ្មោះដើមកបិតនៈ គឺដើមខ្វិត ។

ព្រះមានព្រះភាគកោណ្ឌញ្ញៈ មានដើមសាលកល្យាណី គឺដើមក្លៅនាង ជាពោធិព្រឹក្ស ។

ព្រះពុទ្ធមង្គលៈ ១ ព្រះសុមនៈ ១ ព្រះរេវតៈ ១ ព្រះសោភិតៈ ១ មានដើមនាគ គឺដើមខ្លឹងជាពោធិព្រឹក្ស ។

ព្រះអនោមទស្សី មានដើមអជ្ជុន ( ដើមថ្ងាន់ ឬដើមអង្គ្រង ) ជាពោធិព្រឹក្ស ។

ព្រះពុទ្ធបទុមៈ ១ ព្រះនារទៈ ១ មានដើមមហាសោណៈ គឺម្រុម ជាពោធិព្រឹក្ស ។

ព្រះបទុមុត្តរៈ មានដើមសលលៈ គឺដើមស្រល់ ជាពោធិព្រឹក្ស ។

ព្រះសុមេធសម្ពុទ្ធៈ មានដើមនីបៈ គឺដើមក្ទម្ពជាពោធិព្រឹក្ស ។

ព្រះសុជាតសម្ពុទ្ធ មានដើមវេឡុ គឺដើមឫស្សី ជាពោធិព្រឹក្ស ។

ព្រះបិយទស្សីសម្ពុទ្ធ មានដើមកកុធៈ គឺដើមថ្ងាន់ ជាពោធិព្រឹក្ស ។

ព្រះអត្ថទស្សីសម្ពុទ្ធ មានដើមចម្បក គឺដើមចម្បា ជាពោធិព្រឹក្ស ។

ព្រះធម្មទស្សីសម្ពុទ្ធ មានដើមរត្តកុរវកៈ ឬដើមពិម្ពិជាល គឺដើមទន្លាប់ ជាពោធិព្រឹក្ស ។

ព្រះសិទ្ធត្ថសម្ពុទ្ធ មានដើមកណិការ គឺដើមកណិការជាពោធិព្រឹក្ស ។

ព្រះតិស្សសម្ពុទ្ធ មានដើមអសនៈ គឺដើមធ្នង់ ជាពោធិព្រឹក្ស ។

ព្រះផុស្សសម្ពុទ្ធ មានដើមអាលមកៈ គឺដើមកន្ទួតព្រៃ ជាពោធិព្រឹក្ស ។

ព្រះវិបស្សីសម្ពុទ្ធ មានដើមបាដលី គឺដើមប្រទៀង ជាពោធិព្រឹក្ស ។

ព្រះសិខីសម្ពុទ្ធ មានដើមបុណ្ឌរីក គឺដើមស្វាយ-ស ជាពោធិព្រឹក្ស ។

ព្រះវេស្សភូសម្ពុទ្ធ មានដើមសាលៈ គឺដើមរាំងភ្នំ ជាពោធិព្រឹក្ស ។

ព្រះកកុសន្ធសម្ពុទ្ធ មានដើមសិរីសៈ គឺដើមប្រេស ជាពោធិព្រឹក្ស ។

ព្រះកោនាគមនសម្ពុទ្ធ មានដើមឧទុម្ពរ គឺដើមល្វា ជាពោធិព្រឹក្ស ។

ព្រះកស្សបសម្ពុទ្ធ មានដើមនិគ្រោធ គឺដើមជ្រៃ ជាពោធិព្រឹក្ស ។

ព្រះគោតមសម្ពុទ្ធ មានដើមអស្សត្ថៈ ជាពោធិព្រឹក្ស ។

នេះ ឈ្មោះថា ពោធិវេមត្តៈ ។

ដែលឈ្មោះថា **បល្លង្កវេមត្ត** គឺការប្លែកគ្នានៃបល្ល័ង្ក បានដល់ ព្រះពុទ្ធទីបង្ករៈ ១ ព្រះរេវតៈ ១ ព្រះបិយទស្សី ១ ព្រះអត្ថទស្សី ១ ព្រះធម្មទស្សី ១ ព្រះវិបស្សី ១ មានបល្ល័ង្ក ៥៣ ហត្ថ ។

ព្រះកោណ្ឌញ្ញសម្ពុទ្ធ ១ ព្រះមង្គលៈ ១ ព្រះនារទៈ ១ ព្រះសុមេធៈ ១ មានបល្ល័ង្កកម្ពស់ ៥៧ ហត្ថ ។

ព្រះសុមនសម្ពុទ្ធ មានបល្ល័ង្កកម្ពស់ ៦០ ហត្ថ ។

ព្រះសោភិតសម្ពុទ្ធ ១ ព្រះអនោមទស្សី ១ ព្រះបទុមៈ ១ ព្រះបទុមុត្តរៈ ១ ព្រះផុស្សៈ ១ មានបល្ល័ង្កកម្ពស់ ៣៨ ហត្ថ ។

ព្រះសុជាតសម្ពុទ្ធ ១ ព្រះសិខី ១ មានបល្ល័ង្កកម្ពស់ ៣២ ហត្ថ ។

ព្រះសិទ្ធត្ថសម្ពុទ្ធ ១ ព្រះតិស្សៈ ១ ព្រះវេស្សភូ ១ មានបល្ល័ង្កកម្ពស់ ៤០ ហត្ថ ។

ព្រះកកុសន្ធសម្ពុទ្ធ មានបល្ល័ង្កខ្ពស់ ២៦ ហត្ថ ។
ព្រះកោនាគមនសម្ពុទ្ធ មានបល្ល័ង្កខ្ពស់ ២០ ហត្ថ ។
ព្រះកស្សបសម្ពុទ្ធ មានបល្ល័ង្កខ្ពស់ ១៥ ហត្ថ ។
ព្រះគោតមសម្ពុទ្ធ មានបល្ល័ង្កខ្ពស់ ១៤ ហត្ថ ។
នេះ ឈ្មោះថា បល្លង្កវេមត្តៈ ។ ទាំងនេះឈ្មោះថា **វេមត្ត៨។**

## ទីដែលព្រះពុទ្ធមិនលះបង់

ព្រះពុទ្ធគ្រប់អង្គ ទ្រង់មិនលះបង់ទី ៤ កន្លែង ។ ពិតហើយ ពោធិបល្ល័ង្ក ព្រះពុទ្ធគ្រប់អង្គទ្រង់មិនលះបង់ គឺត្រង់ទីតែមួយនោះឯង ។ ទ្រង់មិនលះបង់ការប្រកាសធម្មចក្រ ត្រង់ឥសិបតនមិគទាយវ័ន ទ្រង់មិនលះបង់ទីដែលដាក់ព្រះបាទចុះគ្រាដំបូង ក្បែរសង្កស្សនគរ ក្នុងកាលដែលទ្រង់ចុះអំពីទេវលោក ទ្រង់មិនលះបង់ទីដែលដាក់ជើងគ្រែទាំង ៤ នៃព្រះគន្ធកុដិ ក្នុងវិហារជេតពន តែព្រះវិហារតូចក៏មាន ធំក៏មាន ព្រះវិហារក្តី ព្រះនគរក្តី ទ្រង់ក៏មិនលះបង់ ។

## ការកំណត់សហជាត និងកំណត់នក្ខត្តឫក្ស

ន័យម្យ៉ាងទៀត ព្រះសង្គីតិកាចារ្យទាំងឡាយ សម្តែងកំណត់សហជាត កំណត់នក្ខត្តឫក្សនៃព្រះមានព្រះភាគរបស់យើងប៉ុណ្ណោះ ។ វត្ថុដែលកើតរួមគ្នាជាមួយព្រះសព្វញ្ញូពោធិសត្វនៃយើង មាន ៧ គឺរាហុលមាតា ១ អានន្ទ ១ ឆន្ន ១ ស្តេចសេះកណ្ឋកៈ ១ កំណប់ទ្រព្យ ១ មហាពោធិព្រឹក្ស ១

កាឡុទាយី ១ នេះ ឈ្មោះថា កំណត់សហជាត ។

ដោយនក្ខត្តប្ញក្ស គឺនក្ខត្តប្ញក្សឧត្តរាសាឡ្ហ ព្រះមហាបុរស ចុះកាន់ព្រះឧទរព្រះជននី ទ្រង់ចេញមហាភិនេស្រ្កមណ៍ ទ្រង់ប្រកាសធម្មចក្រ ទ្រង់សម្តែងយមកប្បាដិហារ្យ ។ ដោយនក្ខត្តប្ញក្សក្នុងខែវិសាខ ទ្រង់ប្រសូត ត្រាស់ដឹង និងបរិនិព្វាន ។ ដោយនក្ខត្តប្ញក្សខែមាឃ ទ្រង់ប្រជុំសាវក និងដាក់អាយុសង្ខារ ។ ដោយនក្ខត្តប្ញក្សខែអស្សុជ ទ្រង់ចុះអំពីទេវលោក នេះ ឈ្មោះថា កំណត់នក្ខត្តប្ញក្ស ។

## ធម្មតារបស់ព្រះពុទ្ធ

ឥឡូវនេះ យើងនឹងប្រកាសធម្មតារបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ធម្មតារបស់ព្រះពុទ្ធគ្រប់ព្រះអង្គ មាន ៣០ គឺ

ព្រះពោធិសត្វមានភពចុងក្រោយ មានសម្បជញ្ញៈចុះកាន់ព្រះឧទររបស់ព្រះជននី ១ ព្រះពោធិសត្វទ្រង់គង់ពត់ភ្នែនក្នុងព្រះឧទររបស់ព្រះជននី បែរព្រះភក្ត្រទៅខាងមុខ ១ ព្រះជននីរបស់ព្រះពោធិសត្វឈរប្រសូត ១ ព្រះពោធិសត្វប្រសូតចាកព្រះឧទរតែក្នុងព្រៃប៉ុណ្ណោះ ១ ព្រះពោធិសត្វដាក់ព្រះបាទលើជម្ពូរមាស បែរព្រះភក្ត្រទៅទិសឧត្តរ ឈាន ៧ ជំហាន ទ្រង់ទតទិសទាំង ៤ បន្លឺសីហនាទ ១ ព្រះមហាសត្វកាលព្រះឱរសប្រសូត ទ្រង់ឃើញនិមិត្ត ៤ ហើយចេញមហាភិនេស្រ្កមណ៍ ១ ព្រះមហាសត្វទ្រង់កាន់យកទង់ជ័យព្រះអរហន្ត ទ្រង់ព្រះផ្នួស បំពេញព្យាយាមយ៉ាងតិចបំផុត ៧ ថ្ងៃ ១ ទ្រង់សោយមធុបាយាស ក្នុងថ្ងៃដែលទ្រង់សម្រេចសម្ពោធិញ្ញាណ ១

ទ្រង់ប្រថាប់គង់លើសន្ថ័តស្មៅ សម្រេចសព្វញ្ញុតញ្ញាណ ១ ទ្រង់បរិកម្ម អនាបានស្សតិកម្មដ្ឋាន ១ ទ្រង់កម្ចាត់មារ ព្រមទាំងសេនា ១ ក្នុងពោធិ-បល្ល័ង្កនោះឯង ទ្រង់បាននូវគុណ មានអសាធារណញ្ញាណជាដើម តាំងអំពីវិជ្ជាបី ១ ទ្រង់សម្ងំជិតៗ ពោធិព្រឹក្សអស់ ៧ សប្តាហ៍ ១ មហាព្រហ្មទូលអារាធនាឲ្យទ្រង់សម្តែងធម៌ ១ ទ្រង់ប្រកាសធម្មចក្រក្នុងព្រៃឥសិបតនមិគ-ទាយវ័ន ១ ក្នុងថ្ងៃ ១៥ កើត ខែមាឃ ទ្រង់សម្តែងបាតិមោក្ខក្នុងកណ្តាលសាវ័ក ប្រកបដោយអង្គបួន ១ ទ្រង់ប្រថាប់នៅជាប្រចាំក្នុងវិហារជេតពន ១ ទ្រង់ធ្វើយមកប្បាដិហារ្យ ក្បែរទ្វារនគរសាវត្ថី ១ ទ្រង់សម្តែងព្រះអភិធម្មក្នុងស្ថានតាវត្តិង្ស ១ ទ្រង់ចុះអំពីទេវលោកក្បែរទ្វារនគរសង្កស្ស ១ ទ្រង់ចូលផលសមាបត្តិជាប់តគ្នា ១ ទ្រង់ប្រមើលមើលវេនេយ្យជន ២ វារៈ ១ មានរឿងកើតឡើង ទើបទ្រង់បញ្ញត្តសិក្ខាបទ ១ កាលអត្ថុប្បត្តិហេតុកើតឡើងទើបទ្រង់ត្រាស់ជាតក ១ ទ្រង់ត្រាស់ពុទ្ធវង្សក្នុងសមាគមព្រះញាតិ ១ ទ្រង់ធ្វើបដិសណ្ឋារៈក្នុងអាគន្តុកភិក្ខុ ១ ទ្រង់ទទួលនិមន្តចាំវស្សាហើយ មិនត្រាស់លាមុន មិនយាងទៅ ១ ទ្រង់ធ្វើកិច្ចមុនសោយ ក្រោយសោយ បឋមយាម មជ្ឈិមយាម និងបច្ឆិមយាម រាល់ៗ ថ្ងៃ ១ ទ្រង់សោយសេមំសៈ ក្នុងថ្ងៃបរិនិព្វាន ១ ទ្រង់ចូលសមាបត្តិ ២៤ សែនកោដិហើយ ទើបបរិនិព្វាន ១ ធម្មតាព្រះពុទ្ធគ្រប់ព្រះអង្គមាន ៣០ ដូចពោលមក ដូច្នេះ ។

# អំពីអនន្តរាយិកធម៌

ព្រះពុទ្ធគ្រប់ព្រះអង្គ មានអនន្តរាយិកធម៌ គឺធម៌ដែលមិនធ្វើឲ្យអន្តរាយ ៤ គឺបុគ្គលណាមួយក៏មិនអាចធ្វើអន្តរាយដល់បច្ច័យ ៤ ដែលគេនាំមកចំពោះដល់ព្រះពុទ្ធទាំងឡាយ ១ បុគ្គលណាមួយក៏មិនអាចធ្វើអន្តរាយដល់ព្រះជន្មាយុរបស់ព្រះពុទ្ធទាំងឡាយ ១ សមដូចព្រះតម្រាស់ ( ក្នុងវិនយបិដក ចូឡវគ្គ ) ថា អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស ( គួរធ្វើបានឡើយ ) ដូច្នេះ ។ បុគ្គលណាមួយ មិនអាចធ្វើអន្តរាយដល់មហាបុរិសលក្ខណៈ ៣២ ប្រការ និងដល់អនុព្យញ្ជនៈ ៨០ ប្រការ ១ បុគ្គលណាមួយមិនអាចធ្វើអន្តរាយដល់ព្រះពុទ្ធរង្សីបានឡើយ ១ ។ នេះ ឈ្មោះថាអនន្តរាយិកធម៌ ៤ ។

# និគមនកថា

កិរិយាពណ៌នាពុទ្ធវង្ស ដែលមានលម្អដោយន័យដ៏វិចិត្រ ដែលបុគ្គលដឹងនូវបទពណ៌នាបានងាយ ដល់នូវសេចក្ដីសម្រេចដោយកថា មានប្រមាណប៉ុណ្ណេះ ។

ខ្ញុំនាំយកគន្ថរបស់បុរាណដ្ឋកថា ដែលប្រកាសសេចក្ដីនៃបាលី ជាគោលតែម្យ៉ាង ចងនូវអដ្ឋកថា ពុទ្ធវង្ស ។

ព្រោះវៀរចង់នូវពាក្យដែលសាំញុំ ( ដដែលៗ ) ប្រកាសតែសេចក្ដីដែលពីរោះ សព្វប្រការ ហេតុនោះ ទើបឈ្មោះថា មធុរត្ថវិលាសិនី ។

កាលសាធុជន អ្នកមានវាចាពីរោះ ឈ្មោះកណ្ហទាសៈ សាងវិហារដែលមានកំពែង និងខ្លោងទ្វារដ៏ល្អ ដោយអាការផ្សេងៗ ដល់ព្រមដោយម្លប់ និងទឹក គួរមើល គួរត្រេកអរជាទីចង្អៀតចង្អល់នៃទុរជន ដែលត្រូវកិលេសប្រទូស្ត ជាទីសប្បាយដល់បុគ្គល ដែលមានសេចក្ដីសុខ ដែលកើតអំពីវិវេក គួរជាទីត្រេកអរនៃចិត្ត ត្រង់កំពង់ឈ្មោះកាវីរៈ ដែលជាត្រើយ ពោរពេញដោយផ្លូវទឹកនៃស្ទឹងកាវីរៈ គួរជាទីត្រេកអរ ដេរដាសដោយស្ត្រី និងបុរសផ្សេងៗ ។

ខ្ញុំនៅលើប្រាសាទនៃទិសខាងកើត ក្នុងវិហារនោះ ដែលជាទីត្រជាក់ រចនាអដ្ឋកថា ពណ៌នាពុទ្ធវង្ស ។

អដ្ឋកថាពណ៌នាពុទ្ធវង្សនេះ សម្រេចដោយល្អ មិន

មានអន្តរាយ យ៉ាងណា សូមតម្រិះត្រូវរបស់ជនទាំងឡាយ ដែលប្រពៃដោយធម៌ ចូរដល់នូវសេចក្តីសម្រេច ដោយប្រាសចាកអន្តរាយ យ៉ាងនោះចុះ ។

ខ្ញុំអ្នករចនាអដ្ឋកថាពុទ្ធវង្សនេះ សម្រេចដោយមិនមានអន្តរាយ ស្ងប់គ្រប់កាល ។

សូមរោគទាំងពួង ក្នុងមនុស្សទាំងឡាយ វិនាសទៅ សូមភ្លៀងធ្លាក់ត្រូវតាមរដូវកាល សូមសត្វនរកមានសេចក្តីសុខជានិច្ច ពួកបិសាច គឺប្រេតទាំងឡាយ ចូរ ប្រាសចាកសេចក្តីស្រេកឃ្លាន ។

សូមទេវតាទាំងឡាយ និងពួកទេពអប្សរជាដើម សោយសុខនៅក្នុងទេវលោក អស់កាលយូរ សូមធម៌របស់ព្រះមុនី តាំងនៅក្នុងលោក អស់កាលយូរ សូមព្រះរាជាដែលជាអ្នកគ្រប់គ្រងលោក ចូរគ្រប់គ្រងផែនដីឲ្យជាសុខ ។

ព្រះថេរៈ អ្នករចនាអដ្ឋកថា ឈ្មោះមធុរត្ថវិលាសិនី ប្រាកដដោយឈ្មោះ ដែលគ្រូដាក់ឲ្យថា ពុទ្ធទត្តៈ ។

ព្រះថេរៈ ដែលប្រតិស្ឋានគម្ពីរនេះ ដែលនាំប្រយោជន៍តៗ គ្នាមក ធ្លាក់ហើយកាន់អំណាចនៃមច្ចុរាជ ព្រោះសង្ខារជារបស់មិនទៀង ។

គម្ពីរមធុរត្ថវិលាសិនី ពោលដោយភាណវារ មាន ២៦ ភាណវារ ដោយគន្ថៈ មាន ៦៥០០ គន្ថៈ ដោយមានអក្ខរៈ ២ សែន ៣ ពាន់ អក្ខរៈ ។

មធុរត្ថវិលាសិនី ចូលដល់នូវការសម្រេច ប្រាសចាក
អន្តរាយ យ៉ាងណា សូមតម្រិះត្រូវរបស់សត្វទាំងឡាយ
ដែលអាស្រ័យនូវធម៌ សម្រេចយ៉ាងនោះហោង ។៚

## អដ្ឋកថា ពុទ្ធវង្ស ឈ្មោះ មធុរត្ថវិលាសិនី ចប់ ដោយប្រការដូច្នេះ

# ក្បាលទី ៦២

# សុត្តន្តបិដក ចាលីប្រែ

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| **សុត្តន្តបិដក** | |
| រតនចង្កមនកណ្ឌ ...... ...... ...... ...... ...... | ២ |
| **អដ្ឋកថា** | |
| គន្ថារម្ភកថា ...... ...... ...... ...... ...... | ១៧ |
| និទានកថា ...... ...... ...... ...... ...... | ២៦ |
| **អព្ភន្តរនិទានកថា** | |
| អដ្ឋកថារតនចង្កមនកណ្ឌ ...... ...... ...... ...... ...... | ២៨ |
| អត្ថរបស់ព្រហ្មសព្ទ ...... ...... ...... ...... ...... | ៤១ |
| អត្ថរបស់ឥធសព្ទ ...... ...... ...... ...... ...... | ៤៤ |
| អត្ថរបស់ធម្មសព្ទ ...... ...... ...... ...... ...... | ៤៦ |
| ឫទ្ធិ ១០ យ៉ាង ...... ...... ...... ...... ...... | ៨៩ |
| ទសពលញ្ញាណ ១០ ...... ...... ...... ...... ...... | ៩៣ |
| អត្ថរបស់ឧឡារសព្ទ ...... ...... ..... ...... ......... | ១០០ |
| អត្ថរបស់ចក្ខុសព្ទ ...... ...... ...... ...... ...... | ១២៧ |
| អត្ថរបស់រូបសព្ទ ...... ...... ...... ...... ...... | ១២៩ |
| អត្ថរបស់គុណសព្ទ ...... ...... ...... ...... ...... | ១៣៣ |
| អត្ថរបស់សាធុសព្ទ ...... ...... ...... ...... ...... | ១៤២ |
| អត្ថរបស់កុសលសព្ទ ...... ...... ...... ...... ...... | ១៤៦ |
| អត្ថរបស់អគ្គសព្ទ ...... ...... ...... ...... ...... | ១៤៨ |

អត្ថរបស់ពោធសុត្ត ...... ...... ...... ...... ...... ១៦២

អត្ថរបស់ទុក្ខសុត្ត ...... ...... ...... ...... ...... ១៧៨

ទីបង្ករពុទ្ធវង្សទី ១ ...... ...... ...... ...... ...... ១៨១

អដ្ឋកថា ទីបង្ករពុទ្ធវង្សទី ១ ( សុមេធកថា ) .... .... .... ..... .... ២០៩

អត្ថរបស់កប្បសុត្ត ...... ...... ...... ...... ...... ២១១

អត្ថរបស់វេទសុត្ត ...... ...... ...... ...... ...... ២១៩

អត្ថរបស់មានសសុត្ត ...... ...... ...... ...... ...... ៣៤២

កោណ្ឌញ្ញពុទ្ធវង្សទី ២ ...... ...... ...... ...... ...... ៣៥៣

អដ្ឋកថាកោណ្ឌញ្ញពុទ្ធវង្សទី ២ ...... ...... ...... ...... ...... ៣៥៩

មង្គលពុទ្ធវង្សទី ៣ ...... ...... ...... ...... ...... ៣៧៩

អដ្ឋកថាមង្គលពុទ្ធវង្សទី ៣ ...... ...... ...... ...... ...... ៣៨៥

អត្ថរបស់ឧក្កាសុត្ត ...... ...... ...... ...... ...... ៣៩២

អត្ថរបស់ពោធិសុត្ត ...... ...... ...... ...... ...... ៣៩៥

សុមនពុទ្ធវង្សទី ៤ ...... ...... ...... ...... ...... ៤១៣

អដ្ឋកថាសុមនពុទ្ធវង្សទី ៤ ...... ...... ...... ...... ...... ៤១៩

រេវតពុទ្ធវង្សទី ៥ ...... ...... ...... ...... ...... ៤៣៤

អដ្ឋកថារេវតពុទ្ធវង្សទី ៥ ...... ...... ...... ...... ...... ៤៤០

សោភិតពុទ្ធវង្សទី ៦ ...... ...... ...... ...... ...... ៤៥៤

អដ្ឋកថាសោភិតពុទ្ធវង្សទី ៦ ...... ...... ...... ...... ...... ៤៦០

អនោមទស្សិពុទ្ធវង្សទី ៧ ...... ...... ...... ...... ...... ៤៧២

អដ្ឋកថាអនោមទស្សិពុទ្ធវង្សទី ៧ ...... ...... ...... ...... ...... ៤៧៨

បទុមពុទ្ធវង្សទី ៨ ...... ...... ...... ...... ...... ៤៩១

អដ្ឋកថាបទុមពុទ្ធវង្សទី ៨ ...... ...... ...... ...... ...... ៤៩៧

នារទពុទ្ធវង្សទី ៩ ...... ...... ...... ...... ...... ៥០៨

អដ្ឋកថានារទពុទ្ធវង្សទី ៩ ...... ...... ...... ...... ...... ៥១៤
បទុមុត្តរពុទ្ធវង្សទី ១០ ...... ...... ...... ...... ...... ៥៣១
អដ្ឋកថាបទុមុត្តរពុទ្ធវង្សទី ១០ ...... ...... ...... ...... ...... ៥៣៧
សុមេធពុទ្ធវង្សទី ១១ ...... ...... ...... ...... ...... ៥៥២
អដ្ឋកថាសុមេធពុទ្ធវង្សទី ១១ ...... ...... ...... ...... ...... ៥៥៨
សុជាតពុទ្ធវង្សទី ១២ ...... ...... ...... ...... ...... ៥៦៩
អដ្ឋកថាសុជាតពុទ្ធវង្សទី ១២ ...... ...... ...... ...... ...... ៥៧៦
បិយទស្សិពុទ្ធវង្សទី ១៣ ...... ...... ...... ...... ...... ៥៨៧
អដ្ឋកថាបិយទស្សិពុទ្ធវង្សទី ១៣ ...... ...... ...... ...... ...... ៥៩២
អត្ថទស្សិពុទ្ធវង្សទី ១៤ ...... ...... ...... ...... ...... ៦០៧
អដ្ឋកថាអត្ថទស្សិពុទ្ធវង្សទី ១៤ ..... ...... ...... ....... ...... ៦១២
ធម្មទស្សិពុទ្ធវង្សទី ១៥ ...... ...... ...... ...... ...... ៦២១
អដ្ឋកថាធម្មទស្សិពុទ្ធវង្សទី ១៥ ...... ...... ...... ...... ...... ៦២៦
សិទ្ធត្ថពុទ្ធវង្សទី ១៦ ...... ...... ...... ...... ...... ៦៣៤
អដ្ឋកថាសិទ្ធត្ថពុទ្ធវង្សទី ១៦ ...... ...... ...... ...... ...... ៦៣៩
តិស្សពុទ្ធវង្សទី ១៧ ...... ...... ...... ...... ...... ៦៤៧
អដ្ឋកថាតិស្សពុទ្ធវង្សទី ១៧ ...... ...... ...... ...... ...... ៦៥២
បុស្សពុទ្ធវង្សទី ១៨ ...... ...... ...... ...... ...... ៦៦២
អដ្ឋកថាផុស្សពុទ្ធវង្សទី ១៨ ...... ...... ...... ...... ...... ៦៦៧
វិបស្សិពុទ្ធវង្សទី ១៩ ...... ...... ...... ...... ...... ៦៧៤
អដ្ឋកថាវិបស្សិពុទ្ធវង្សទី ១៩ ...... ...... ...... ...... ...... ៦៧៩
សិខិពុទ្ធវង្សទី ២០ ...... ...... ...... ...... ...... ៦៨៤
អដ្ឋកថាសិខិពុទ្ធវង្សទី ២០ ...... ...... ...... ...... ...... ៦៨៩
វេស្សភូពុទ្ធវង្សទី ២១ ...... ...... ...... ...... ...... ៧០៩

អដ្ឋកថាវេស្សភូពុទ្ធវង្សទី ២១ ...... ...... ...... ...... ...... ៧១៥
កកុសន្ធពុទ្ធវង្សទី ២២ ...... ...... ...... ...... ...... ៧២៥
អដ្ឋកថាកកុសន្ធពុទ្ធវង្សទី ២២ ...... ...... ...... ...... ...... ៧៣០
កោនាគមនពុទ្ធវង្សទី ២៣ ...... ...... ...... ...... ...... ៧៤១
អដ្ឋកថាកោនាគមនពុទ្ធវង្សទី ២៣ ...... ...... ...... ...... ...... ៧៤៦
កស្សបពុទ្ធវង្សទី ២៤ ...... ...... ...... ...... ...... ៧៥៦
អដ្ឋកថាកស្សបពុទ្ធវង្សទី ២៤ ...... ...... ...... ...... ...... ៧៦៣
គោតមពុទ្ធវង្សទី ២៥ ...... ...... ...... ...... ...... ៧៧៨
អដ្ឋកថាគោតមពុទ្ធវង្សទី ២៥ ...... ...... ...... ...... ...... ៧៨១
ទូរេនិទាន ...... ...... ...... ...... ...... ៧៨១
អវិទូរេនិទាន ...... ...... ...... ...... ...... ៧៨៤
សន្តិកេនិទាន ...... ...... ...... ...... ...... ៨២៥
ពុទ្ធប្បកិណ្ណកកណ្ឌ ...... ...... ...... ...... ...... ៨៤០
ធាតុភាជនីយកថា ...... ...... ...... ...... ...... ៨៤៣
អដ្ឋកថាពុទ្ធប្បកិណ្ណកកណ្ឌជាដើម ...... ...... ..... ..... ...... ៨៤៥
វេមត្តកថា ...... ...... ...... ...... ...... ៨៤៥
ទីដែលព្រះពុទ្ធមិនលះបង់ ...... ...... ...... ...... ...... ៨៥២
ការកំណត់សហជាត និងកំណត់នក្ខត្តឫក្ស ...... ...... ...... ...... ...... ៨៥២
ធម្មតារបស់ព្រះពុទ្ធ ...... ...... ...... ...... ...... ៨៥៣
អំពីអនន្តរាយិកធម៌ ...... ...... ...... ...... ...... ៨៥៥
និគមនកថា ...... ...... ...... ...... ...... ៨៥៦